# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
## ព្រះអដ្ឋកថា

## ភាគ៥០

បាលីប្រែ ៦០ - ៦១

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

## និង

# ជាតកដ្ឋកថា

### សេចក្តីប្រែជាភាសាខ្មែរ

## ខុទ្ទកនិកាយ ជាតក

## នវមភាគ-ទសមភាគ

# ៥០

## បាលីប្រែ ៦០-៦១

*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៩០

# ចត្តាលីសនិបាត ជាតក

## តេសកុណ ជាតក

[ ៥៦៧ ] ( ព្រះបាទព្រហ្មទត្តសួរថា ) ម្នាលសត្វស្លាប អញសូមសួរ អ្នកឈ្មោះ វេស្សន្តរៈ សេចក្តីចម្រើនចូរមានដល់អ្នក កិច្ចដូចម្តេចដែលអញ ជាអ្នកប្រាថ្នាដើម្បីសោយរាជ្យ ធ្វើហើយ ប្រសើរ ។

[ ៥៦៨ ] ( មៀមឈ្មោះវេស្សន្តរៈទូលថា ) យូរណាស់ហើយ បិតារបស់ខ្ញុំព្រះអង្គ ព្រះនាមកំសៈ ជាអ្នកសង្គ្រោះក្រុងពារាណសី ទ្រង់ប្រហែសជាបិតាចិញ្ចឹម បានចោទសួរនូវខ្ញុំព្រះអង្គជាកូនមិនប្រហែស ។

[ ៥៦៩ ] ( ខ្ញុំទូលថា ) មុនដំបូង ព្រះរាជាត្រូវហាមឃាត់នូវពាក្យឃៀនឃាត សេចក្តីក្រោធនិងការសើចរឡេះរឡោះ តពីនោះ គប្បីធ្វើនូវកិច្ចទាំងឡាយ បពិត្រក្សត្រ បុរាណកបណ្ឌិតទាំងឡាយ បានពោលនូវពាក្យដែលខ្ញុំព្រះអង្គក្រាបទូលនោះ ថាជាវត្ត ។ បពិត្រព្រះបិតា កម្មចំពោះហេតុដ៏ក្តៅក្រហាយណា ដែលព្រះអង្គធ្វើហើយ ក្នុងកាលមុន ឥតសង្ស័យ ព្រះអង្គត្រេកត្រអាលក្តី ទ្រង់ខ្វល់ក្តី ធ្វើនូវកម្មណា ព្រះអង្គមិនត្រូវធ្វើនូវកម្មនោះតទៅទៀតទេ ។ បពិត្រព្រះអង្គអ្នកញុំាងរាស្ត្រឲ្យចម្រើន កាលបើក្សត្រិយ៍ប្រហែសហើយ ភោគសម្បត្តិទាំងអស់ក្នុងដែនទីងវិនាសទៅ សេចក្តីវិនាសនោះ លោកពោលថា ជាទុក្ខរបស់ព្រះរាជា ។ បពិត្រព្រះបិតា បុគ្គលមានសិរីនិងបុគ្គលមានបុណ្យ ដែលសុចិបរិវារសេដ្ឋីសួរហើយ បានពោលនូវពាក្យនេះថា ខ្ញុំត្រេកអរចំពោះបុរសមានសេចក្តីខ្នីឃ្នាត មានសេចក្តីប្រឹងប្រែង ជាអ្នកមិនច្រណែន ។

បពិត្រមហារាជ បុគ្គលកាឡកិណ្ណី ជាអ្នកកាច់បំបាក់នូវចក្កឹកុសល តែង ត្រេកអរក្នុងបុរសជាអ្នកប្រណែន មានចិត្តអាក្រក់ ជាអ្នកប្រទូស្តចំពោះ កល្យាណកម្ម ។ សូមព្រះអង្គ មានហឫទ័យល្អចំពោះពួកជនទាំងពួង សូម ព្រះអង្គរក្សានូវពួកជនទាំងពួង បពិត្រមហារាជ សូមព្រះអង្គបណ្តេញនូវបុគ្គល ឥតបុណ្យចេញ សូមព្រះអង្គយកបុគ្គលមានបុណ្យមកជាទីពំនាក់វិញ ។ បពិត្រ ព្រះអង្គជាម្ចាស់ដែនកាសី ព្រោះថា បុរសមានបុណ្យ បរិបូណ៌ដោយបញ្ញាតាំង នៅក្នុងអធ្យាស្រ័យដ៏ធំ រមែងកាត់បង់នូវគល់និងចុងនៃសត្រូវទាំងឡាយបាន ។ បពិត្រព្រះអង្គ ជាម្ចាស់នៃមនុស្ស ដូចយ៉ាងព្រះឥន្ទ ក៏មិនប្រហែសក្នុងការ ខ្ចីឃ្នាតដែរ លោកធ្វើនូវការព្យាយាមចំពោះកម្មដ៏ល្អ ទាំងធ្វើព្រះហឫទ័យក្នុង ការខ្ចីឃ្នាត ( ជាដរាប ) ។ ពួកគន្ធព្វ ពួកបិតា ( ព្រហ្ម ) ពួកទេវតាមាន អាជីវៈ អាស្រ័យនឹងព្រះរាជាដែលមានអំណរនឹងបុញ្ញកម្មយ៉ាងនោះ ពួក ទេវតាតែងតាមថែ ( រក្សា ) នូវព្រះរាជា ជាអ្នកខ្ចីឃ្នាតមិនប្រហែស ។ បពិត្រ ព្រះបិតា ព្រះអង្គជាអ្នកមិនប្រហែស មិនក្រោធ សូមធ្វើនូវកិច្ចទាំងឡាយចុះ សូមព្រះអង្គប្រឹងប្រែងក្នុងកិច្ចទាំងឡាយរបស់ព្រះអង្គ បុគ្គលខ្ជិលប្រអូស រមែង មិនបានសេចក្តីសុខទេ ។ នោះជាវត្ថុបទ ក្នុងបញ្ហានោះឯង ទុំះឯងជា អនុសាសនី ( របស់ព្រះអង្គ ) ព្រះរាជា កាលប្រព្រឹត្តយ៉ាងនេះ ទើបអាច ញុំាំងពួកមិត្តឲ្យបានសុខផង អាចញុំាំងពួកសត្រូវឲ្យបានទុក្ខផង ។

[ ៥៧០ ] ( ព្រះរាជា... ) ម្នាលនាងកុណ្ឌលិនី នាងអាច ( ឆ្លើយ ប្រស្នាបាន ) នាងជាពង្សនៃមហាសេនគុត្ត ឈ្មោះខត្តៈដឹង ( នូវអាថ៌ប្រស្នា )

កិច្ចដូចម្តេចដែលយើងប្រាថ្នាដើម្បីសោយរាជ្យ ធ្វើហើយប្រសើរ ។

[ ៥៧១ ] *( សារិកាឈ្មោះកុណ្ឌលិនី... )* បពិត្រព្រះបិតា ប្រយោជន៍និងសេចក្តីសុខទាំងអស់ តាំងនៅក្នុងបទណា បទនោះមានពីរយ៉ាង គឺការបាននូវរបស់ដែលមិនធ្លាប់បាន ១ រក្សានូវរបស់ដែលបានមកហើយ ១ ។ បពិត្រព្រះបិតា សូមព្រះអង្គជ្រាបនូវអាមាត្យទាំងឡាយ ដែលមានប្រាជ្ញាឈ្លាសវៃចំពោះប្រយោជន៍ បពិត្រព្រះបិតា សូមព្រះអង្គជ្រាបនូវអាមាត្យទាំងឡាយ ដែលមិនលេងល្បែងភ្នាល់ មិនបោកប្រាស់ មិនជាអ្នកលេងស៊ីផឹក មិនជាអ្នកបំផ្លាញព្រះរាជទ្រព្យ ។ បពិត្រព្រះបិតា អាមាត្យណាគប្បីរក្សានូវទ្រព្យរបស់ព្រះអង្គដែលមាន ដូចនាយសារថីប្រុងប្រយ័ត្ននូវរថ អាមាត្យនោះ ព្រះអង្គគប្បីឲ្យធ្វើនូវកិច្ចការទាំងឡាយរបស់ព្រះអង្គ ។ សូមព្រះអង្គ ដែលមានជនខាងក្នុងសង្គ្រោះល្អ ត្រួតត្រាមើលនូវព្រះរាជទ្រព្យដោយព្រះអង្គឯង មិនគួរធ្វើនូវកំណប់ទ្រព្យ និងការឲ្យជាបំណុល ដោយជឿអ្នកដទៃទេ ។ ព្រះអង្គគប្បីជ្រាបនូវសេចក្តីចម្រើននិងសេចក្តីវិនាស ដោយព្រះអង្គឯង គប្បីជ្រាបនូវកិច្ចការដែលបានធ្វើ និងមិនបានធ្វើដោយព្រះអង្គឯង គប្បីសង្កត់សង្កិននូវបុគ្គលដែលគួរសង្កត់សង្កិន គប្បីលើកតម្កើងនូវបុគ្គលដែលគួរលើកតម្កើង ។ បពិត្រព្រះអង្គ ជាធំលើរថ សូមព្រះអង្គប្រៀនប្រដៅនូវប្រយោជន៍ ដល់អ្នកជនបទដោយព្រះអង្គឯង ពួករាជបុរសអ្នកប្រកបការមិនត្រឹមត្រូវតាមធម៌ សូមកុំឲ្យញុំាងទ្រព្យនិងដែនរបស់ព្រះអង្គឲ្យវិនាស ។ មួយទៀត សូមព្រះអង្គកុំធ្វើ ឬប្រើគេឲ្យធ្វើនូវរាជកិច្ចទាំងឡាយដោយរួសរាន់ ព្រោះមនុស្សល្ងង់ខ្លៅ

តែងក្តៅក្រហាយរឿយ ៗ ក្នុងកាលខាងក្រោយ ចំពោះការងារដែលខ្លួនធ្វើដោយ រួសរាន់ ។ សូមព្រះអង្គ កុំបញ្ចេញនូវព្រះហឫទ័យក្រោធខ្លាំងពេក ចំពោះអកុសល ( របស់អ្នកដទៃ ) ដែលប្រព្រឹត្តកន្លង ( នូវការកុសល ) ព្រោះថា ត្រកូលទាំងឡាយដែលថ្កុំថ្កើងហើយ ច្រើនដល់នូវភាវៈមិនមែនជាត្រកូលទៅវិញ ព្រោះសេចក្តីក្រោធ ។ បពិត្រព្រះបិតា សូមព្រះអង្គកុំបណ្តោយ ( មហាជន ) ឲ្យធ្លាក់ទៅក្នុងសេចក្តីវិនាស ដោយគិតថា ខ្លួនអញជាឥស្សរៈ ការកើតឡើងនៃទុក្ខលំបាក កុំឲ្យមានដល់ស្ត្រីបុរសទាំងឡាយ ក្នុងដែនរបស់ព្រះអង្គ ។ ភោគសម្បត្តិទាំងអស់របស់ព្រះរាជា ជាអ្នកប្រាសចាកការព្រឺរោម ( ឥតកោតញញើត ) តាមចំណង់នឹងវិនាសទៅ ( ដោយពិត ) ការវិនាសនោះ លោកពោលថា ជាទុក្ខរបស់ព្រះរាជា ។ នោះជាវត្តបទក្នុងបញ្ហានោះឯង ទុំជាអនុសាសនី ឥឡូវនេះ សូមព្រះអង្គសង្វាតធ្វើបុណ្យ កុំជាអ្នកលេង កុំញុំាងប្រយោជន៍ឲ្យវិនាស បពិត្រមហារាជ សូមព្រះអង្គមានសីល ( ព្រោះថា ) បុគ្គលអ្នកទ្រុស្តសីល ឈ្មោះថា ជាអ្នកញុំាងខ្លួនឲ្យធ្លាក់ចុះ ។

[ ៥៧២ ] ( ព្រះរាជា... ) អញបានសួរវេស្សន្តរៈ ជាកោសិយគោត្រ និងនាងកុណ្ឌលិនី ដោយប្រការដូច្នោះហើយ ម្នាលជម្ពុកៈ ឥឡូវនេះ អ្នកចូរពោលនូវកម្លាំងដ៏ឧត្តមជាងកម្លាំងទាំងឡាយ ។

[ ៥៧៣ ] ( សេកជម្ពុកពោធិសត្វ... ) កម្លាំងក្នុងលោកមាន ៥ យ៉ាង រមែងមានក្នុងបុរសដែលមានអធ្យាស្រ័យធំ បណ្តាកម្លាំងទាំងនោះ កម្លាំងដៃ

( កាយ ) បណ្ឌិតពោលថាជាកម្លាំងថោកទាប បពិត្រព្រះអង្គ មានព្រះជន្មវែង កម្លាំងភោគៈ បណ្ឌិតពោលថា ជាកម្លាំងទី ២ ។ បពិត្រព្រះអង្គ មានព្រះជន្មវែង កម្លាំងអាមាត្យ បណ្ឌិតពោលថា ជាកម្លាំងទី ៣ កម្លាំងជាតិខ្ពស់ជាកម្លាំងទី ៤ ឥតសង្ស័យ បុគ្គលជាបណ្ឌិត រមែងគ្របសង្កត់នូវកម្លាំងទាំងអស់នេះ ។ កម្លាំងបញ្ញា នោះជាកម្លាំងប្រសើរ ជាកម្លាំងខ្ពង់ខ្ពស់ជាងកម្លាំងទាំងឡាយ បណ្ឌិតដែលមានកម្លាំងបញ្ញាជ្រោមជ្រែងហើយ រមែងបាននូវសេចក្តីចម្រើន ។ បុគ្គលមានបញ្ញាទន់ ទោះបីបាននូវផែនដី ស្តុកស្តម្ភប្រសើរ កាលបើបុគ្គលមានបញ្ញាទន់នោះមិនមានប្រាថ្នា បុគ្គលដែលមានបញ្ញាដទៃ ធ្វើនូវការកំហែង ហើយគ្រប់គ្រងនូវផែនដីនោះ ។ បពិត្រព្រះអង្គជាម្ចាស់ដែនកាសី បើទុកជាបុគ្គលមានជាតិខ្ពង់ខ្ពស់ ជាក្សត្របាននូវរាជ្យ តែអប្បបញ្ញា ក៏រមែងមិនរស់នៅ ដោយរាជ្យទាំងពួងបាន ។ បញ្ញាជាធម្មជាតិសម្រាប់វិនិច្ឆ័យក្នុងសេចក្តីដែលបានស្តាប់ បញ្ញាជាគ្រឿងញុំាងកេរ្តិ៍ឈ្មោះនិងលាភសក្ការៈឲ្យចម្រើន នរជនប្រកបដោយបញ្ញា ក្នុងលោកនេះ សូម្បីទុក្ខ ( កើតឡើង ) ក៏រមែងបានសុខទាំងឡាយវិញ ។ មួយទៀត បុគ្គលណាមួយមិនស្តាប់ដោយគោរព មិនជឿនូវបុគ្គលជាពហុស្សូត មិនឈ្វេងយល់នូវកិច្ចការ ដែលឋិតនៅក្នុងសភាវៈ រមែងមិនបាននូវបញ្ញា ។ លុះតែបុគ្គលណា ជាអ្នកដឹងនូវចំណែកនៃធម៌ ប្រឹងប្រែងក្នុងកាលគួរ មិនខ្ជិលច្រអូស ប្រឹងប្រែងរឿយ ៗ តាមកាលគួរ ផលកើតអំពីការងាររមែងទើបសម្រេចដល់បុគ្គលនោះ ។ កាលបុគ្គលមិនមានសីលជាទីកើត ( នៃលាភ យស សុខ ) សេពគប់នូវ

បុគ្គលទ្រុស្តសីល មិនជាទីកើត ( នៃលាភ យស សុខ ) ធ្វើការធុញទ្រាន់ ប្រយោជន៍រមែងមិនឲ្យផលដោយប្រពៃទេ ។ លុះតែបុគ្គលប្រកបកិច្ចខាងក្នុងសន្តាន សេពគប់នូវបុគ្គលមានសីល ជាទីកើត ( នៃលាភ យស សុខ ) ដូច្នោះ ធ្វើការងាររមិនធុញទ្រាន់ ប្រយោជន៍រមែងឲ្យផលដោយប្រពៃ ។ បពិត្របិតា សូមព្រះអង្គគប់រកនូវហេតុទាំងឡាយនោះ គឺបញ្ញាជាចំណែកនៃព្យាយាមក្នុងហេតុដែលគួរប្រកប និងការថែទាំទុកនូវទ្រព្យ ដែលព្រះអង្គបានព្រះអង្គកុំ ( ញុំាងទ្រព្យ ) ឲ្យវិនាសដោយការងាររមិនគួរ ព្រោះថា បុគ្គលឥតបញ្ញា រមែងលិចចុះ ( ក្នុងសេចក្តីវិនាស ) ដោយហេតុមិនមែនជាការងារ ដូចផ្ទះដែលគេធ្វើដោយដើមបបុស ។

[ ៥៧៤ ] បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ គឺការបម្រើមាតាបិតាទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ គឺការសង្គ្រោះចំពោះបុត្តភរិយាទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះមិត្តនិងអាមាត្យទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះពាហនៈ និងពលទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះជនអ្នកស្រុក និង

អ្នកនិគមទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះអ្នកដែននិងអ្នកជនបទទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះពួកសមណៈ និងព្រាហ្មណ៍ទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ គឺឲ្យអភ័យចំពោះពួកម្រឹគ និងសត្វបក្សីទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ( ព្រោះថា ) ធម៌ដែលព្រះអង្គប្រព្រឹត្តហើយ រមែងនាំមកនូវសេចក្ដីសុខ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ព្រោះពួកព្រះឥន្ទ ទេវតាព្រមទាំងព្រហ្ម បានដល់នូវទិព្វសម្បត្តិ ដោយធម៌ដែលខ្លួនប្រព្រឹត្តល្អ បពិត្រព្រះរាជា សូមព្រះអង្គកុំប្រហែសចំពោះធម៌ ។ នោះជាវត្តបទ ក្នុងបញ្ហានោះឯង នុ៎ះឯងជាអនុសាសនី សូមព្រះអង្គសេពគប់នូវបុគ្គលមានបញ្ញា សូមមានគុណធម៌ដ៏ល្អ ជ្រាបច្បាស់នូវធម៌នោះ ដ៏បរិបូណ៌ដោយព្រះអង្គឯង ( ប្រតិបត្តិតាមពាក្យប្រៀនប្រដៅចុះ ) ។

ចប់ តេសកុណជាតកទី ១

# ចត្តាលីសនិបាត ជាតក

## អដ្ឋកថា តេសកុណជាតក

[ ៥៦៧-៥៧៤ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ត្រាស់ព្រះធម្មទេសនានេះ ដោយទំនងនៃការថ្វាយឱវាទដល់ព្រះបាទកោសល មានពាក្យផ្តើមថា **វេស្សន្តរំ តំ បុច្ឆាមិ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ព្រះសាស្តាត្រាស់យាងព្រះរាជានោះ ដែលយាងមកដើម្បីស្តាប់ព្រះធម្មទេសនាហើយត្រាស់ថា មហាបពិត្រ ធម្មតាព្រះរាជា គួរគ្រងរាជ្យដោយធម៌ ព្រោះសម័យណា ព្រះរាជាមិនតាំងនៅក្នុងធម៌ សម័យនោះ ខ្ញុំរាជការទាំងឡាយ ក៏ជាអ្នកមិនតាំងនៅក្នុងធម៌ ដូច្នេះហើយ ទ្រង់ទូន្មានដោយន័យនៃព្រះសូត្រ ដែលមកក្នុងចតុក្កនិបាត ហើយត្រាស់ពណ៌នាទោសនិងអានិសង្សក្នុងការលុះអំណាចអគតិ និងមិនលុះអំណាចអគតិ ទ្រង់ញ៉ាំងទោសក្នុងកាមទាំងឡាយឲ្យពិស្តារ ដោយន័យជាដើមថា កាមទាំងឡាយប្រៀបដូចការយល់សប្តិ ហើយត្រាស់ថា

បពិត្រមហារាជ ការដោះដូរជាមួយមច្ចុ រមែងមិនមានដល់សត្វទាំងនោះ ការទទួលសំណូកក៏មិនមាន ការច្បាំងក៏មិនមាន ជ័យជម្នះក៏មិនមាន សត្វទាំងអស់ សុទ្ធតែមានសេចក្តីស្លាប់ជាទីបំផុត ។

កាលសត្វទាំងនោះ ទៅកាន់បរលោក វៀរកល្យាណធម៌ ដែលខ្លួនធ្វើទុកហើយ ឈ្មោះថាទីពឹងដទៃមិនមានឡើយ ចាំបាច់ត្រូវលះវត្ថុដែលប្រាកដតិចតួចយ៉ាងនេះទៅ ពិតប្រាកដ មិនគួរអាស្រ័យយស ធ្វើនូវសេចក្តីប្រមាទជាអ្នកចូលចិត្តបុគ្គលមិនប្រមាទ សោយរាជ្យដោយធម៌តែម្យ៉ាង កាលព្រះពុទ្ធ

មិនទាន់កើតឡើង បុរាណកក្សត្រទាំងឡាយ តាំងនៅក្នុងឱវាទរបស់បណ្ឌិត សោយរាជ្យដោយធម៌ យាងទៅកាន់ទេវនគរ ស្តេចកោសលក្រាបទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកត្រាស់ដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី មិនមានព្រះរាជឱរស ទោះបីទ្រង់ប្រាថ្នា ក៏មិនបានព្រះរាជឱរសឬព្រះរាជធីតា ថ្ងៃមួយ ទ្រង់យាងប្រពាតព្រះឧទ្យានជាមួយរាជបរិវារជាច្រើន ទ្រង់លេងក្នុងព្រះរាជឧទ្យានអស់មួយថ្ងៃ ក្រាលព្រះបន្ទំ ក្រោមដើមឈើមង្គលសាលព្រឹក្ស ផ្ទំលក់បន្តិច តើនហើយ ទ្រង់សម្លឹងមើលដើមសាលព្រឹក្ស ឃើញសម្បុកសត្វនៅលើដើមឈើនោះ លុះទតទៅឃើញប៉ុណ្ណោះ ក៏កើតសេចក្តីស្រឡាញ់ ទើបត្រាស់ហៅមហាតលិកម្នាក់មកត្រាស់ថា អ្នកឡើងដើមឈើនេះសាកមើល ឲ្យដឹងថា ក្នុងសម្បុកនោះមានអ្វី ឬមិនមានអ្វី ។ មហាតលិកឡើងទៅឃើញស៊ុតសត្វក្នុងសម្បុកនោះចំនួន ៣ ទើបក្រាបទូលឲ្យទ្រង់ជ្រាប ព្រះរាជាត្រាស់ថា បើដូច្នោះ អ្នកកុំដកខ្យល់ដង្ហើមលើស៊ុតទាំងនោះ ចូរពាសសំឡីក្នុងស្មុគ ដាក់ស៊ុតនោះសន្សឹម ៗ ចុះមក កាលត្រាស់ឲ្យមហាតលិកចុះមកហើយ ទ្រង់ទទួលស្មុគនោះដោយព្រះហស្ត ត្រាស់សួរពួកអាមាត្យថា នេះជាស៊ុតបក្សីប្រភេទអ្វី អាមាត្យទាំងឡាយនាំគ្នាក្រាបទូលថា ទូលព្រះបង្គំមិនជ្រាប ពួកព្រានព្រៃទើបស្គាល់ ព្រះរាជាក៏ត្រាស់ឲ្យពួកព្រានព្រៃចូលគាល់ ហើយត្រាស់សួរ ពួកព្រានក្រាបទូលថា បពិត្រព្រះអង្គស៊ុតទាំងនេះ ស៊ុតមួយជាពងរបស់មៀម ស៊ុតមួយជាពងរបស់សាលិកា ស៊ុតមួយជាពង

*របស់សត្វសេក ព្រះរាជាត្រាស់សួរថា ស៊ុតទាំងឡាយនៅរួមសម្បុកជាមួយ គ្នាបានឬ ទូលថា បពិត្រព្រះអង្គ បាន បើមិនមានអន្តរាយ ស៊ុតបក្សីដែល មេក្រាបល្អហើយ រមែងមិនវិនាស ព្រះរាជាត្រេកអរ ទ្រង់ព្រះតម្រិះថា សត្វទាំងនេះនឹងជាកូនរបស់អញ ឲ្យអាមាត្យ ៣ នាក់ ទទួលស៊ុតនោះម្នាក់ មួយ ត្រាស់ថា សត្វទាំងនេះ ជាបុត្តរបស់យើង ពួកអ្នកជួយថែទាំឲ្យល្អ ពេលកូនបក្សីចេញមកអំពីស៊ុត ចូរប្រាប់ដល់យើង ។*

*អមាត្យទាំង ៣ រក្សាស៊ុតបក្សីទាំងនោះយ៉ាងល្អ ក្នុងចំនួនស៊ុតទាំងនោះ ស៊ុតមៀមញាស់មុន អមាត្យហៅព្រានព្រៃម្នាក់មក សួរថា ឯងស្គាល់ដែរឬទេ តើជាមេឬឈ្មោល កាលព្រានព្រៃនោះពិចារណាហើយ ប្រាប់ថា ឈ្មោល ទើបចូលទៅគាល់ព្រះរាជា ក្រាបទូលថា បពិត្រព្រះអង្គ ឱរសទ្រង់កើតហើយ ព្រះរាជាទ្រង់ត្រេកអរ ព្រះរាជទានទ្រព្យដល់អមាត្យនោះជាច្រើន ត្រាស់ថា ចូរអ្នកថែរក្សាកូនយើងឲ្យល្អ ចូរដាក់ឈ្មោះថា វេស្សន្តរៈ ។ អមាត្យនោះ បាន ធ្វើតាមព្រះរាជឱង្ការ ។ កន្លងមក ២-៣ ថ្ងៃ ស៊ុតសាលិកាក៏ញាស់ អមាត្យ នោះឲ្យព្រានព្រៃមកពិនិត្យមើល ដឹងថា ជាកូនសាលិកាញី ទើបទៅកាន់រាជ សម្នាក់ក្រាបទូលថា បពិត្រព្រះអង្គ រាជធីតារបស់ទ្រង់ប្រសូតហើយ ព្រះរាជា ទ្រង់ត្រេកអរ ព្រះរាជទានទ្រព្យ ដល់អមាត្យនោះជាច្រើន ហើយត្រាស់ផ្តាំ ថា ចូរផ្គត់ផ្គង់ធីតាយើងឲ្យល្អ ចូរដាក់ឈ្មោះថា កុណ្ឌលិនី អមាត្យនោះក៏ ធ្វើតាមព្រះរាជតម្រាស់ កន្លងមក ២-៣ ថ្ងៃទៀត ស៊ុតសេកក៏ញាស់ អមាត្យ ក៏ឲ្យព្រានព្រៃមកពិនិត្យមើល កាលព្រានព្រៃឆ្លើយថា ជាកូនឈ្មោល ទើប*

ទៅកាន់រាជសម្នាក់ ក្រាបទូលថា បពិត្រព្រះអង្គ ឱរសទ្រង់ប្រសូតហើយ ។ ព្រះរាជាទ្រង់ត្រេកអរ ព្រះរាជទានទ្រព្យដល់អាមាត្យនោះជាច្រើន ហើយត្រាស់ផ្តាំថា ចូរឯង រៀបចំធ្វើមង្គលដល់កូនរបស់យើង ដោយបរិវារច្រើន ហើយដាក់ឈ្មោះថា ជម្ពុក: អមាត្យនោះក៏ធ្វើតាមព្រះរាជតម្រាស់ បក្សីទាំង ៣ ក៏ចម្រើនមកក្នុងផ្ទះរបស់អមាត្យទាំង ៣ ដោយការបរិហារ ដូចព្រះរាជកុមារ ។

ព្រះរាជាត្រាស់ហៅថា បុត្តរបស់យើង ធីតារបស់យើង ដូច្នេះរឿយ ៗ កាលនោះ ពួកអាមាត្យរបស់ព្រះរាជានាំគ្នាសើចចំអកថា អ្នកទាំងឡាយចូរមើលការធ្វើរបស់ព្រះរាជា ដែលត្រាស់ហៅសត្វតិរច្ឆានថា បុត្តរបស់យើង ធីតារបស់យើង ព្រះរាជាទ្រង់ស្តាប់ដូច្នោះ ទើបទ្រង់ព្រះតម្រិះថា អាមាត្យទាំងនេះមិនដឹងបញ្ញាសម្បទានៃកូនទាំង ៣ របស់អញ អញនឹងធ្វើឲ្យបាកដដល់អាមាត្យទាំងនេះ ទើបត្រាស់ហៅអាមាត្យម្នាក់ឲ្យទៅរកព្រះបាទវេស្សន្តរៈ ឲ្យប្រាប់ថា បិតារបស់ទ្រង់ចង់ត្រាស់សួរបញ្ហា តើទ្រង់យាងមកសួរបានក្នុងពេលណា អាមាត្យថ្វាយបង្គំព្រះបាទវេស្សន្តរហើយ ប្រាប់ព្រះបំណាំងឲ្យទ្រង់ជ្រាប ។ ព្រះបាទវេស្សន្តរអញ្ជើញអាមាត្យដែលចិញ្ចឹមខ្លួនមកសួរថា បានឮថា ព្រះរាជបិតារបស់យើង ប្រាថ្នានឹងសួរបញ្ហាជាមួយយើង កាលទ្រង់យាងមកទីនេះ យើងគួរធ្វើសក្ការ: នឹងឲ្យទ្រង់យាងមកក្នុងកាលណា អាមាត្យតបថា ចាប់ពីនេះទៅ ៧ ថ្ងៃ ទើបយាងមក ព្រះបាទវេស្សន្តរស្តាប់ដូច្នោះ ទើបបញ្ជូនដំណឹងក្រាបទូលថា ព្រះរាជបិតារបស់ខ្ញុំ យាងមក

បានក្នុងថ្ងៃទី ៧ រាប់អំពីថ្ងៃនេះ ។ អាមាត្យនោះត្រឡប់ទៅទូលដល់ព្រះរាជា ។ ដល់ថ្ងៃទី ៧ ព្រះរាជាត្រាស់ឲ្យវាយស្គរប្រកាសក្នុងព្រះនគរហើយយាងទៅកាន់លំនៅរបស់បុត្ត ព្រះបាទវេស្សន្តរ ត្រាស់ឲ្យធ្វើមហាសក្ការៈដល់ព្រះរាជា សូម្បីទាសៈនិងកម្មករ ក៏ឲ្យធ្វើសក្ការៈផងដែរ ។ ព្រះរាជាសោយក្នុងផ្ទះរបស់វេស្សន្តរៈ ទ្រង់ទទួលការស្វាគមន៍ ហើយយាងទៅត្រឡប់ទៅកាន់ព្រះរាជនិវេសន៍ ត្រាស់ឲ្យធ្វើមណ្ឌប ត្រង់លានព្រះរាជវាំង ឲ្យវាយស្គរប្រកាសក្នុងព្រះនគរ ប្រថាប់គង់ក្នុងមណ្ឌបដ៏ប្រសើរ ចោមរោមទៅដោយមហាជន ទ្រង់បញ្ជូនព្រះរាជសាសន៍ទៅកាន់សម្នាក់របស់អាមាត្យថា ចូរនាំវេស្សន្តរមកចុះ អាមាត្យឲ្យព្រះបាទវេស្សន្តរទំលើតាំងមាស នាំមកថ្វាយវេស្សន្តរទំលើព្រះឧរុរបស់ព្រះរាជបិតា លេងជាមួយព្រះរាជបិតា រួចហើរទៅទំលើតាំងមាសនោះវិញ ។

លំដាប់នោះ ព្រះរាជាកាលត្រាស់សួររាជធម៌ជាមួយព្រះបាទវេស្សន្តរក្នុងកណ្តាលមហាជន ទើបត្រាស់បឋមគាថាដោយសេចក្តីថា

ម្នាលសត្វស្វាប អញសូមសួរអ្នកឈ្មោះវេស្សន្តរៈ សេចក្តីចម្រើន ចូរមានដល់អ្នក កិច្ចដូចម្តេច ដែលអញជាអ្នកប្រាថ្នាដើម្បីសោយរាជ្យធ្វើហើយប្រសើរ ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថានោះ ដូចតទៅនេះថា ព្រះរាជាទ្រង់រាក់ទាក់ព្រះបាទវេស្សន្តរនោះថា នែបក្សីអើយ ។

បទថា **កឹសុ** សេចក្តីថា ព្រះរាជានោះ ត្រាស់សួរបក្សីវេស្សន្តរនោះ

យ៉ាងនេះថា កិច្ចអ្វីដែលបុគ្គលប្រាថ្នាគ្រងរាជ្យធ្វើហើយ ជារបស់ល្អ គឺឧត្តម នៃបា ចូរបាប្រាប់រាជធម៌នោះដល់ខ្ញុំចុះ ។

បក្សីវេស្សន្តរស្តាប់ព្រះរាជតម្រាស់ហើយ មិនទាន់ទូលឆ្លើយបញ្ហា កាល ទូលដាស់តឿនព្រះរាជា អំពីសេចក្តីប្រមាទជាមុន ទើបពោលគាថាទី ២ ថា

យូរណាស់ហើយ បិតារបស់ខ្ញុំព្រះអង្គ ព្រះនាមកំសៈ ជាអ្នក
សង្គ្រោះក្រុងពារាណសី ទ្រង់ប្រហែស ជាបិតាចិញ្ចឹម បាន
ចោទសួរនូវខ្ញុំព្រះអង្គជាកូនមិនប្រហែស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តាតោ** បានដល់ ព្រះរាជបិតា ។ បទថា **កំសោ** នេះ ជាឈ្មោះរបស់ព្រះរាជាអង្គនោះ ។ បទថា **ពារាណសិគ្គហោ** សេចក្តីថា ទ្រង់ប្រព្រឹត្តសង្គ្រោះអ្នកនគរដោយសង្គហវត្ថុ ៤ ប្រការ ។ បទថា **បមត្តោ** សេចក្តីថា ទ្រង់នៅក្នុងសម្នាក់នៃបណ្ឌិតបែបនេះ ឈ្មោះថាជាអ្នក ប្រមាទហើយ ព្រោះមិនបានត្រាស់សួរបញ្ហា ។ បទថា **អប្បមត្តំ** សេចក្តីថា ចិញ្ចឹមខ្ញុំដែលឈ្មោះថាមិនប្រមាទហើយ ព្រោះប្រកបដោយគុណមានសីល ជាដើម ។ បទថា **បិតា** បានដល់ ព្រះរាជបិតាដែលជាអ្នកចិញ្ចឹម ។ បទថា **អចោទយិ** សេចក្តីថា បក្សីវេស្សន្តរពោលថា ព្រះរាជបិតាត្រូវអាមាត្យសើច ចំអកថា ព្រះរាជាត្រាស់ហៅសត្វតិរច្ឆានថា បុត្ត ទ្រង់ដល់នូវសេចក្តីប្រមាទ ហើយ ទើបតែចោទ គឺត្រាស់សួរបញ្ហាក្នុងថ្ងៃនេះ អស់កាលយូរពន់ពេក ។

ព្រះបាទវេស្សន្តរទូលដោយគាថាយ៉ាងនេះហើយ ទូលទៀតថា បពិត្រ ព្រះអង្គ ជាជនកមហារាជ ឈ្មោះថា ព្រះរាជា គួរតាំងនៅក្នុងធម៌ ៣ ប្រការ

សោយរាជសម្បត្តិដោយធម៌ កាលសម្តែងរាជធម៌ ទើបពោលគាថានេះថា

មុនដំបូង ព្រះរាជាត្រូវហាមឃាត់នូវពាក្យឃៀងឃ្លាត សេចក្តីក្រោធនិងការសើចរឡេះរឡោះ តពីនោះ គប្បីធ្វើនូវកិច្ចទាំងឡាយ បពិត្រក្សត្រ បុរាណកបណ្ឌិតទាំងឡាយបានពោលនូវពាក្យដែលខ្ញុំព្រះអង្គក្រាបទូលនោះថា ជាវត្ត ។ បពិត្រព្រះបិតា កម្មចំពោះហេតុដ៏ក្តៅក្រហាយណា ដែលព្រះអង្គធ្វើហើយ ក្នុងកាលមុន ឥតសង្ស័យ ព្រះអង្គត្រេកត្រអាលក្តី ទ្រង់ខ្វាល់ក្តី ធ្វើនូវកម្មណា ព្រះអង្គមិនត្រូវធ្វើនូវកម្មនោះតទៅទៀតទេ ។ បពិត្រព្រះអង្គ អ្នកញុំាងរាស្ត្រឲ្យចម្រើន កាលបើក្សត្រិយ៍ ប្រហែសហើយ ភោគសម្បត្តិទាំងអស់ក្នុងដែននឹងវិនាសទៅ សេចក្តីវិនាសនោះ លោកពោលថា ជាទុក្ខរបស់ព្រះរាជា ។ បពិត្រព្រះបិតា បុគ្គលមានសិរី និងបុគ្គលមានបុណ្យ ដែលសុចិបរិវាសេដ្ឋីសួរហើយ បានពោលនូវពាក្យនេះថា ខ្ញុំត្រេកអរចំពោះបុរសមានសេចក្តីខ្មីឃ្មាត មានសេចក្តីប្រឹងប្រែង ជាអ្នកមិនច្រណែន ។ បពិត្រមហារាជ បុគ្គលកាឡកិណ្ណី ជាអ្នកកាច់បំបាក់នូវចក្ក គឺកុសល តែងត្រេកអរក្នុងបុរសជាអ្នកច្រណែន មានចិត្តអាក្រក់ ជាអ្នកប្រទូស្តចំពោះកល្យាណកម្ម ។ សូមព្រះអង្គមានហឫទ័យល្អចំពោះពួកជនទាំងពួង សូមព្រះអង្គរក្សានូវពួកជនទាំងពួង បពិត្រមហារាជ សូម

ព្រះអង្គ បណ្ដេញនូវបុគ្គលឥតបុណ្យចេញ សូមព្រះអង្គយក បុគ្គលមានបុណ្យមកជាទីពំនាក់វិញ ។ បពិត្រព្រះអង្គជាម្ចាស់ ដែនកាសី ព្រោះថា បុរសមានបុណ្យ បរិបូណ៌ដោយបញ្ញា តាំង នៅក្នុងអធ្យាស្រ័យដ៏ធំ រមែងកាត់បង់នូវគល់និងចុងនៃសត្រូវ ទាំងឡាយបាន ។ បពិត្រព្រះអង្គជាម្ចាស់នៃមនុស្ស ដូចយ៉ាង ព្រះឥន្ទ ក៏មិនប្រហែសក្នុងការខ្មីឃ្មាតដែរ លោកធ្វើនូវការ ព្យាយាមចំពោះកម្មដ៏ល្អ ទាំងធ្វើព្រះហឫទ័យក្នុងការខ្មីឃ្មាត ( ជាដរាប ) ។ ពួកគន្ធព្វ ពួកបិតា ( ព្រហ្ម ) ពួកទេវតា មានអាជីវៈ អាស្រ័យនឹងព្រះរាជាដែលមានអំណរនឹងបុញ្ញកម្ម យ៉ាងនោះ ពួកទេវតាតែងតាមថែ ( រក្សា ) នូវព្រះរាជា ជាអ្នក ខ្មីឃ្មាតមិនប្រហែស ។ បពិត្រព្រះបិតា ព្រះអង្គជាអ្នកមិន ប្រហែស មិនក្រោធ សូមធ្វើនូវកិច្ចទាំងឡាយចុះ សូមព្រះអង្គ ប្រឹងប្រែងក្នុងកិច្ចទាំងឡាយរបស់ព្រះអង្គ បុគ្គលខ្ជិលច្រអូស រមែងមិនបានសេចក្ដីសុខទេ ។ នោះជាវត្ថុបទ ក្នុងបញ្ហានោះឯង នុ៎ះឯងជាអនុសាសនី ( របស់ព្រះអង្គ ) ព្រះរាជា កាល ប្រព្រឹត្តយ៉ាងនេះ ទើបអាចញ៉ាំងពួកមិត្តឲ្យបានសុខផង អាច ញ៉ាំងពួកសត្រូវឲ្យបានទុក្ខផង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បឋមេនេវ វិតថំ** សេចក្ដីថា បពិត្រ ព្រះបិតា ធម្មតាព្រះរាជា គួរហាមមុសាវាទជាខាងដើម អធិប្បាយថា ដែន

របស់ព្រះរាជាដែលត្រាស់មុសា រមែងមិនចម្រើនដុះដាល ។ វត្ថុត្រឹមតែរតនៈ ៧ ប្រការរមែងចូលទៅខាងក្រោមទីដែលធ្វើសេចក្តីចម្រើន ដុះដាលដល់ផែនដី ។ បន្ទាប់អំពីនោះ ក្នុងអាហារ ក្នុងប្រេង ទឹកឃ្មុំ ទឹកអំពៅជាដើម ឬក្នុងឱសថទាំងឡាយ តែងមិនមានឱជា មហាជនបរិភោគអាហារដែលមិនមានឱជារមែងកើតជំងឺតម្កាត់ច្រើន ។ ចំណួលទាំងផ្លូវគោកផ្លូវទឹករមែងមិនកើតឡើងក្នុងដែន កាលចំណួលមិនកើតព្រះរាជាក៏ចូលដល់សេចក្តីលំបាក ។ ទ្រង់រមែងមិនអាចសង្គ្រោះសេវកាមាត្យបាន ។ កាលមិនបានការទទួលការសង្គ្រោះក៏មិនសម្លឹងមើលព្រះរាជាដោយចិត្តគោរពកោតក្រែង បពិត្រព្រះបិតា ឈ្មោះថាមុសាវាទនេះ កាត់នូវសេចក្តីចម្រើនយ៉ាងនេះ ។ ដូច្នោះទើបមិនគួរពោលមុសាវាទនោះ សូម្បីព្រោះហេតុនៃជីវិត ។ តែគួរកំណត់កាន់យកសុភាសិតថា ពាក្យពិតប្រសើរជាងរសទាំងឡាយ ដូច្នេះ ប៉ុណ្ណោះ ។ ម្យ៉ាងទៀត ឈ្មោះថាមុសាវាទជាគ្រឿងកម្ចាត់នូវគុណ គឺសេចក្តីល្អ មានការវិបត្តិជាទីបំផុត ធ្វើខ្លួនឲ្យទៅកាន់អវីចិក្នុងវារៈចិត្តទី ២ ។ ម្យ៉ាងទៀត ក្នុងសេចក្តីនេះ គួរសម្តែងចេតិយជាតក មានជាដើមថា ធម៌ដែលបុគ្គលសម្លាប់ហើយ រមែងសម្លាប់វិញដោយពិត ដូច្នេះ ។

បទថា **កោធំ** សេចក្តីថា បពិត្រព្រះបិតា ធម្មតាព្រះរាជាគួរហាមសេចក្តីក្រោធ ដែលមានការអាក់អន់ជាលក្ខណៈជាមុនដូចគ្នា ។ បពិត្រព្រះបិតា ព្រោះថា សេចក្តីក្រោធរបស់ជនដទៃ រមែងមិនដល់ទីបំផុត ដោយរហ័សឡើយ តែការក្រោធរបស់ព្រះរាជា រមែងដល់ដោយរហ័ស ធម្មតាព្រះរាជា

ទាំងឡាយ មានវាចាជាអាវុធ ក្រេវក្រោធហើយ រមែងញ៉ាំងអ្នកដទៃឲ្យដល់សេចក្តីវិនាសបាន ដោយអាការត្រឹមតែក្រឡេកមើល ព្រោះដូច្នោះ ព្រះរាជាកុំបីមានការក្រោធជាងអ្នកដទៃឡើយ គួរដល់ព្រមដោយខន្តិគុណ មេត្តាគុណនិងករុណា ថែរក្សាពលនិករ ដូចឱរសជាទីស្រឡាញ់របស់ខ្លួន បពិត្រព្រះបិតា ព្រះរាជាដែលក្រៃលែងដោយសេចក្តីក្រោធ ជាអ្នកគ្រប់គ្រងផ្ទះ រមែងមិនអាចរក្សាព្រះកិត្តិយស ដែលកើតឡើងបានទេ ម្យ៉ាងទៀត ដើម្បីសម្តែងសេចក្តីនេះ គួរសម្តែងខន្តិវាទិជាតក និងចុល្លធម្មបាលជាតក ។ ពិតហើយ ក្នុងចុល្លធម្មបាលជាតក ព្រះបាទមហាបតាបនរាជ ត្រាស់ឲ្យផ្តាច់ព្រះជន្ម ព្រះរាជឱរស កាលព្រះទេវី មានព្រះហឫទ័យបែកធ្លាយ អស់ព្រះជន្មជីព ព្រោះសោយសោកដល់ព្រះរាជឱរសហើយ ខ្លួនឯងក៏សោយសោកដល់ព្រះទេវី មានព្រះហឫទ័យបែកធ្លាយ សោយទិវង្គតទៅដូចគ្នា ។ កាលនោះ អាមាត្យទាំងឡាយថ្វាយព្រះភ្លើង លើជើងថ្ករមាសតែមួយ ទាំង ៣ ព្រះសព ។ ព្រោះហេតុនោះ ព្រះរាជាគួរវៀរមុសាវាទជាលំដាប់ដំបូង លំដាប់ទី ២ គួរវៀរសេចក្តីក្រោធ ។

បទថា **ហាសំ** បានដល់ ការសប្បាយរីករាយ ។ ម្យ៉ាងទៀត បាឋៈក៏យ៉ាងនេះដូចគ្នា អធិប្បាយថា ព្រះរាជាគួរហាមឃាត់នូវភាពជាបុគ្គលលេងសើចក្នុងរាជកិច្ចផ្សេង ៗ ដោយភាពជាអ្នកមានព្រះហឫទ័យត្រេកត្រអាល គឺហាមឃាត់នូវការសប្បាយរីករាយចេញ បពិត្រព្រះរាជបិតា ធម្មតាព្រះរាជាមិនគួរជាបុគ្គលឡេះឡោះ មិនគួរជឿតែអ្នកដទៃ ត្រូវចាត់ចែងរាជកិច្ចគ្រប់

យ៉ាង ដោយប្រចក្សដល់ទ្រង់ឯងប៉ុណ្ណោះ ព្រោះព្រះរាជាមានព្រះហឫទ័យ ឡេះឡោះហើយ កាលទ្រង់ធ្វើរាជកិច្ចមិនពិនិត្យពិចារណា រមែងញុំាង ព្រះឥស្សរិយយស ដែលបានហើយឲ្យវិនាស ។ ម្យ៉ាងទៀត សេចក្ដីក្នុង អធិការនេះ គួរសម្ដែងនូវភាពដែលស្ដេចទណ្ឌកីក្នុងសរភង្គជាតក ទ្រង់ជឿ ពាក្យរបស់បុរោហិត ហើយធ្វើខុសក្នុងកីសវច្ឆតាបស សាបសូន្យចាករដ្ឋ-មណ្ឌល កើតក្នុងកុក្កុលនរក ( នរកផេះក្ដៅ ) គួរសម្ដែងភាពដែលព្រះបាទ មេជ្ឈរាជ ក្នុងមាតង្គជាតក ទ្រង់ជឿពាក្យរបស់ព្រាហ្មណ៍ សម្លាប់មាតង្គ តាបស ហើយសាបសូន្យចាករដ្ឋមណ្ឌល ហើយកើតក្នុងនរក និងគួរសម្ដែង ត្រកូលវាសុទេព ( ត្រកូលស្ដេចដែលមានបងប្អូន ១០ អង្គ ) ជឿនូវ ពាក្យរបស់រាជទារកបងប្អូនទាំង ១០ ដែលប្រកបដោយមោហៈ ហើយធ្វើ ខុសក្នុងកណ្ហទីបាយនតាបស ដល់នូវការវិនាសក្នុងយជបណ្ឌិតជាតក ។

បទថា **តតោ កិច្ចានិ ការេយ្យ** សេចក្ដីថា បពិត្រព្រះរាជបិតា ព្រះរាជាវៀរមុសាវាទជាលំដាប់ដំបូង សេចក្ដីក្រោធជាលំដាប់ទី ២ ការ សប្បាយរីករាយ ដែលមិនប្រកបដោយធម៌ជាលំដាប់ទី ៣ បន្ទាប់អំពីនោះ ទើបគួរត្រាស់ ឲ្យធ្វើនូវរាជកិច្ចដែលគួរធ្វើចំពោះអ្នកដែន ក្នុងកាលជាខាង ក្រោយ ។ បទថា **តំ វតំ អាហុ ខត្តិយ** សេចក្ដីថា បពិត្រខត្តិយមហារាជ ពាក្យណា ដែលខ្ញុំទូលហើយ បុរាណកបណ្ឌិតពោលពាក្យនោះថា ជារាជ បវេណីរបស់ព្រះរាជា ។ បទថា **ឆ តំ កយិរា** សេចក្ដីថា បពិត្រព្រះរាជ បិតា កម្មណា ដែលជាគ្រឿងធ្វើឲ្យក្ដៅក្រហាយចិត្តក្នុងកាលជាខាងក្រោយ

ដោយអំណាចនៃកិលេស មានរាគៈជាដើម ដែលជារបស់ទ្រង់ធ្វើទុកហើយ ទ្រង់មិនគួរធ្វើ គឺកុំធ្វើកម្មបែបនោះទៀត ។ បទថា **វុច្ចតេ** សេចក្តីថា សេចក្តីនោះលោកពោលថា ជាសេចក្តីទុក្ខរបស់ព្រះរាជា បុរាណកបណ្ឌិតទាំងឡាយពោលទុកយ៉ាងនេះ ។

បទថា **សិរី ច** សេចក្តីថា បក្សីវេស្សន្តរធ្វើហេតុការណ៍ដែលប្រព្រឹត្តទៅក្នុងក្រុងពារាណសីក្នុងកាលមុន មកពោលសម្តែងបែបនេះ ។ បណ្តាបទទាំងនោះ បទថា **ពុទ្ធំ** សេចក្តីថា សិរីទេពធីតាត្រូវសុចិបរិវារសេដ្ឋីសួរហើយទើបប្រាប់ ។ បទថា **ឧដ្ឋានេ វីរិយេ** សេចក្តីថា សិរីទេពធីតា ពោលថា បុគ្គលណា តាំងមាំនៅក្នុងការប្រឹងប្រែង និងការព្យាយាម ឃើញនូវសម្បត្តិរបស់អ្នកដទៃមិនច្រណែន ខ្ញុំត្រេកអរក្នុងបុគ្គលនោះ បក្សីវេស្សន្តរពោលដល់សិរីទេពធីតាមុនយ៉ាងនេះ ។ បទថា **ឧស្សុយ្យកេ** សេចក្តីថា បពិត្រព្រះរាជបិតា ចំណែកអលក្ខី ( កាឡកណ្ណីទេពធីតា ) ត្រូវសួរហើយ ពោលថា ខ្ញុំត្រេកអរក្នុងបុរសដែលច្រណែនក្នុងសម្បត្តិរបស់អ្នកដទៃ ។

បទថា **ទុហទយេ** បានដល់ បុគ្គលមានចិត្តថោកទាប ។ បទថា **កម្មទុស្សកេ** បានដល់ បុគ្គលដែលប្រទូស្តកល្យាណកម្ម ។ អលក្ខីទេពធីតា ពោលថា អ្នកណាប្រទូស្ត ជាអ្នកស្អប់ខ្ពើម មិនធ្វើកល្យាណកម្ម ខ្ញុំត្រេកអរក្នុងបុរសនោះ បពិត្រមហារាជ នាងកាឡកណ្ណីទេពធីតា ដែលកាច់បំបាក់នូវកុសលចក្ក មានការនៅក្នុងប្រទេសដែលសមគួរជាដើម រមែងត្រេកអរយ៉ាងនេះ ។ បទថា **សុហទយោ** សេចក្តីថា សូមទ្រង់មានព្រះរាជ

ហឫទ័យស្អាត គឺមានព្រះទ័យអនុគ្រោះ ។ បទថា **ឱរុហ** បានដល់ សូមដក ។ បទថា **និវេសនំ** សេចក្ដីថា តែសូមយកបុញ្ញាធិការជាទីពឹងពំនាក់ចុះ ។

បទថា **សលក្ខិ** **ធិតិសម្បន្នោ** សេចក្ដីថា បពិត្រមហារាជជាធំក្នុងដែនកាសី បុរសដែលសម្បូរដោយបញ្ញានិងសេចក្ដីព្យាយាមនោះ ។ បទថា **មហាគ្គតោ** សេចក្ដីថា បក្សីវេស្សន្តរពោលថា បុរសមានអធ្យាស្រ័យធំកាលចាប់ចោរដែលជាបច្ច័យនៃចោរ ឈ្មោះថា ចាប់ចោរដែលជាឫសគល់នៃអមិត្ត រមែងកាត់នូវកំពូលរបស់អន្ទាក់អមិត្តបាន ។

បទថា **សក្កោ** បានដល់ ព្រះឥន្ទ ។ បក្សីវេស្សន្តរហៅព្រះរាជាថា **ភូតបតិ** ជាធំនៃពលនិករ ។ បទថា **ឧដ្ឋានេ** បានដល់ មានការប្រឹងប្រែងព្យាយាម ។ បទថា **នប្បមជ្ជតិ** សេចក្ដីថា ធ្វើនូវកិច្ចទាំងពួង ។

បទថា **សកល្យាណោ** សេចក្ដីថា សក្កទេវរាជនោះយកព្រះហឫទ័យទុកដាក់ក្នុងការប្រឹងប្រែងនិងសេចក្ដីព្យាយាម មិនធ្វើនូវបាបកម្ម ធ្វើសេចក្ដីព្យាយាមក្នុងកល្យាណកម្ម គឺបុញ្ញកម្មតែម្យ៉ាង មិនប្រមាទ ដាក់ចិត្តក្នុងការព្យាយាម ។ ម្យ៉ាងទៀត ដើម្បីសម្ដែងការៈនៃការធ្វើសេចក្ដីព្យាយាមរបស់សក្កៈនោះ គួរសម្ដែងរឿងជាដើមថា កាពដែលសក្កៈនោះមកកាន់កបិដ្ឋារាមមួយអន្លើដោយទេវតាក្នុងទេវលោកទាំង ២ ហើយសួរបញ្ហា ស្ដាប់ធម៌ក្នុងសរកន្តជាតក និងកាពដែលពាក្យទូន្មានសាបសូន្យ សក្កៈញ៉ាំងមហាជន ឲ្យត្រេកអរ ហើយបណ្ដាលឲ្យប្រព្រឹត្តទៅដោយអានុភាពរបស់ខ្លួន ក្នុងមហាកណ្ហជាតក ។

បទថា **គន្ធព្វា** សេចក្តីថា បានឮថា ទេវតាមានកំណើត ៤ កើតខាងក្រោមចាតុម្មហារាជិកា ឈ្មោះថា គន្ធព្វ ព្រោះទេវតាទាំងនោះ មានកំណើត ៤ ។ បទថា **បិតរោ** បានដល់ មហាព្រហ្ម ។ បទថា **ទេវា** បានដល់ ទេវតាក្នុងជាន់ឆកាមាវចរ ដោយអំណាចនៃឧបបត្តិទេព ។ បទថា **តាទិនោ** សេចក្តីថា លោកទាំងនោះ មានអាជីវៈ មានជីវិតស្មើ ចិញ្ចឹមជីវិតទុក ដើម្បីព្រះរាជាដែលទ្រង់ត្រេកអរក្នុងកុសលយ៉ាងនោះ ព្រោះព្រះរាជាបែបនោះ កាលទ្រង់ធ្វើបុញ្ញទានជាដើម ទ្រង់ឧទ្ទិសចំណែកនៃបុណ្យដល់ទេវតាទាំងឡាយ ទេវតាទាំងនោះទទួលអនុមោទនានូវចំណែកបុណ្យនោះហើយរមែងចម្រើនដោយទិព្វយស ។ បទថា **អនុតិដ្ឋន្តិ** សេចក្តីថា កាលព្រះរាជានោះ ទ្រង់ធ្វើសេចក្តីព្យាយាម ដល់នូវការមិនប្រមាទ ទេវតាទាំងឡាយតែងនាំគ្នាពិភាក្សា រក្សាប្រកបដោយធម៌ ។

បទថា **សោ** បានដល់ ព្រះអង្គនោះ ។ បទថា **វាយមស្សុ** សេចក្តីថា កាលទ្រង់ធ្វើរដ្ឋកិច្ចនោះ សូមធ្វើសេចក្តីព្យាយាមក្នុងរដ្ឋកិច្ចនោះ ៗ ដោយអំណាចការប្រៀបធៀប ការវិភាគ ការធ្វើដ៏ប្រចក្សចុះ ។

បទថា **តត្ថេវ តេ វត្តបទា** សេចក្តីថា បពិត្រព្រះរាជបិតា ទ្រង់ត្រាស់សួរបញ្ហាណានីងទូលព្រះបង្គំថា កិច្ចណាដែលបុគ្គលប្រាថ្នាគ្រប់គ្រងសម្បត្តិធ្វើហើយជាកិច្ចប្រសើរ ក្នុងបញ្ហារបស់ទ្រង់នោះឯង ខ្ញុំបានទូលពាក្យជាដើមថា គួរឃាត់នូវមុសាវាទជាមុន ដូច្នេះហើយ សេចក្តីទាំងនោះ ជាវត្តបទជាវត្តកោដ្ឋាស សូមទ្រង់ប្រព្រឹត្តក្នុងវត្តបទនោះ ដូចខ្ញុំទូលហើយ ។ បទថា

**ឯសោ** សេចក្ដីថា សេចក្ដីដែលខ្ញុំទូលហើយនេះឯង ជាអនុសាសនីសម្រាប់ទ្រង់ ។ បទថា **អលំ** សេចក្ដីថា ព្រោះថា កាលព្រះរាជាប្រព្រឹត្តយ៉ាងនេះ រមែងអង់អាច អាចញ៉ាំងពពួកមិត្តឲ្យមានសេចក្ដីសុខ និងញ៉ាំងទុក្ខដល់អមិត្តបាន ។

កាលបក្សីវេស្សន្តរពោលដល់ការប្រមាទរបស់ព្រះរាជា ដោយបទគាថា ១ ហើយពោលធម៌ដោយគាថា ១១ យ៉ាងនេះ មហាជនអស្ចារ្យក្នុងចិត្តថា បក្សីវេស្សន្តរឆ្លើយបញ្ហា ដោយពុទ្ធលីលា ដូច្នេះហើយ ញ៉ាំងសាធុការរាប់រយរាប់ពាន់ឲ្យប្រព្រឹត្តទៅ ព្រះរាជាទ្រង់សោមនស្ស ត្រាស់ហៅពួកអមាត្យមកត្រាស់ថា នែអាមាត្យដ៏ចម្រើន ព្រោះវេស្សន្តរបុត្ររបស់យើង ឆ្លើយបញ្ហា ធ្វើកិច្ចសម្រេចហើយយ៉ាងនេះ យើងគួរធ្វើដូចម្ដេច ។

ពួកអាមាត្យទូលថា គួរឲ្យតំណែងជាមហាសេនា ទើបត្រាស់ថា បើយ៉ាងនោះ យើងគួរឲ្យតំណែងជាមហាសេនាដល់បាវេស្សន្តរនោះ ហើយទ្រង់បានស្ថាបនាបក្សីវេស្សន្តរទុកក្នុងឋានន្តរសក្តិ តាំងអំពីនោះមក បក្សីវេស្សន្តរនោះក៏តាំងនៅក្នុងតំណែងមហាសេនា ស្នងរាជកិច្ចព្រះបិតា ដោយប្រការដូច្នេះ ។

## វេស្សន្តរបញ្ហា ចប់

កន្លងទៅ ២-៣ ថ្ងៃទៀត ព្រះរាជាទ្រង់បញ្ជូនទូតទៅកាន់សម្នាក់របស់បក្សីកុណ្ឌលិនីដោយទំនងមុននោះឯង ហើយទ្រង់យាងទៅក្នុងទីនោះក្នុងថ្ងៃទី ៧ ទ្រង់យាងត្រឡប់មកគង់ក្នុងកណ្ដាលមណ្ឌបនោះ ត្រាស់ឲ្យនាំបក្សីកុណ្ឌលិនី

មកដើម្បីត្រាស់សួររាជធម៌ បក្សីទាំងពីរនោះ ទើបព្រះរាជាទ្រង់ត្រាស់គាថានេះថា

ម្នាលនាងកុណ្ឌលិនី នាងអាច ( ឆ្លើយប្រស្នាបាន ) នាងជាពង្សនៃមហាសេនគុត្ត ឈ្មោះខត្តៈ ដឹង ( នូវអាថ៌ប្រស្នា ) កិច្ចដូចម្តេចដែលយើងប្រាថ្នាដើម្បីសោយរាជ្យ ធ្វើហើយប្រសើរដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សក្កិ** សេចក្តីថា ព្រះរាជាត្រាស់សួរថា នាងអាចឆ្លើយបញ្ហាដែលបិតាសួរបានឬ ព្រះរាជាទ្រង់រក់ទាក់ដោយឈ្មោះដែលមកដោយភេទរបស់បក្សីនោះថា នៃកុណ្ឌលិនី បានឮថា ត្រង់ទងត្រចៀកនៃបក្សីនោះ មានស្នាម ២ សណ្ឋានស្រដៀងកុណ្ឌល ដោយហេតុនោះ ទើបព្រះរាជាតាំងឈ្មោះថា កុណ្ឌលិនី ។ បទថា **មញ្ញសិ** សេចក្តីថា ព្រះរាជាត្រាស់សួរថា នាងនឹងឆ្លើយបញ្ហាដែលបិតាសួរបានឬ ព្រះរាជាទ្រង់រក់ទាក់បក្សីនោះថា នៃនាងមានផៅពង្សនៃបក្សីមានបណ្តាសក្តិ ដូច្នេះ ព្រោះជាប្អូនស្រីរបស់មហាសេនា ជាអ្នកមានសក្តិធំ ។

ព្រោះហេតុអ្វី ទើបព្រះរាជាមិនត្រាស់សួរបក្សីវេស្សន្តរយ៉ាងនេះ ត្រាស់សួរតែនាងកុណ្ឌលិនីតែមួយ ឆ្លើយថា ព្រោះបក្សីនេះជាឥត្ថីភេទ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា ធម្មតាស្ត្រីមានបញ្ញាតិចតួច បើបក្សីនេះអាចក៏នឹងសួរ បើមិនអាចក៏មិនសួរ ដូច្នេះ ទើបត្រាស់សួរយ៉ាងនេះមុន ដោយសាកល្បងមើលហើយត្រាស់សួរបញ្ហាបែបនេះដូចគ្នា ។

កាលព្រះរាជាត្រាស់សួររាជធម៌យ៉ាងនេះហើយ បក្សីកុណ្ឌលិនីក្រាបទូលថា បពិត្រព្រះបិតា ប្រហែលជាព្រះបិតាសាកល្បងខ្ញុំម្ចាស់ ដោយយល់ថា ស្រីនឹងឆ្លើយបានដូចម្តេច ខ្ញុំនឹងពោលរាជធម៌ទាំងអស់ដល់ទ្រង់ទុកក្នុងបទ ២ នោះឯង ដូច្នេះហើយ ទើបពោលគាថាដោយសេចក្តីថា

បពិត្រព្រះបិតា ប្រយោជន៍និងសេចក្តីសុខទាំងអស់ តាំងនៅក្នុងបទណា បទនោះមានពីរយ៉ាង គឺការបាននូវរបស់ដែលមិនធ្លាប់បាន ១ រក្សានូវរបស់ដែលបានមកហើយ ១ ។ បពិត្រព្រះបិតា សូមព្រះអង្គជ្រាបនូវអាមាត្យទាំងឡាយ ដែលមានប្រាជ្ញាឈ្លាសវៃចំពោះប្រយោជន៍ បពិត្រព្រះបិតា សូមព្រះអង្គជ្រាបនូវអាមាត្យទាំងឡាយ ដែលមិនលេងល្បែងភ្នាល់ មិនបោកប្រាស់ មិនជាអ្នកលេងស៊ីផឹក មិនជាអ្នកបំផ្លាញព្រះរាជទ្រព្យ ។ បពិត្រព្រះបិតា អាមាត្យណា គប្បីរក្សានូវទ្រព្យរបស់ព្រះអង្គដែលមាន ដូចនាយសារថីប្រុងប្រយ័ត្ន នូវ រថ អាមាត្យនោះ ព្រះអង្គគប្បីឲ្យធ្វើនូវកិច្ចការទាំងឡាយរបស់ព្រះអង្គ ។ សូមព្រះអង្គ ដែលមានជនខាងក្នុងសង្គ្រោះល្អ ត្រួតត្រាមើលនូវព្រះរាជទ្រព្យដោយព្រះអង្គឯង មិនគួរធ្វើនូវកំណប់ទ្រព្យ និងការឲ្យជាបំណុល ដោយជឿអ្នកដទៃទេ ។ ព្រះអង្គគប្បីជ្រាបនូវសេចក្តីចម្រើន និងសេចក្តីវិនាស ដោយព្រះអង្គឯង គប្បីជ្រាបនូវកិច្ចការដែលបានធ្វើ និងមិនបានធ្វើ

ដោយព្រះអង្គឯង គប្បីសង្កត់សង្កិននូវបុគ្គលដែលគួរសង្កត់សង្កិន គប្បីលើកតម្កើង នូវបុគ្គលដែលគួរលើកតម្កើង ។ បពិត្រព្រះអង្គ ជាធំលើរថ សូមព្រះអង្គប្រៀនប្រដៅនូវប្រយោជន៍ដល់អ្នកជនបទ ដោយព្រះអង្គឯង ពួករាជបុរសអ្នកប្រកបការមិនត្រឹមត្រូវតាមធម៌ សូមកុំឲ្យញ៉ាំងទ្រព្យ និងដែនរបស់ព្រះអង្គឲ្យវិនាស ។ មួយទៀត សូមព្រះអង្គកុំធ្វើ ឬប្រើគេឲ្យធ្វើនូវរាជកិច្ចទាំងឡាយ ដោយរួសរាន់ ព្រោះមនុស្សល្ងង់ខ្លៅ តែងក្ដៅក្រហាយរឿយ ៗ ក្នុងកាលខាងក្រោយចំពោះការងារ ដែលខ្លួនធ្វើដោយរួសរាន់ ។ សូមព្រះអង្គ កុំបញ្ចេញនូវព្រះហឫទ័យ ក្រោធខ្លាំងពេក ចំពោះអកុសល (របស់អ្នកដទៃ) ដែលប្រព្រឹត្តកន្លង (នូវការកុសល) ព្រោះថាត្រកូលទាំងឡាយ ដែលថ្កុំថ្កើងហើយ ច្រើនដល់នូវភាវៈមិនមែនជាត្រកូលទៅវិញ ព្រោះសេចក្ដីក្រោធ ។ បពិត្រព្រះបិតា សូមព្រះអង្គកុំបណ្ដោយ (មហាជន) ឲ្យធ្លាក់ទៅក្នុងសេចក្ដីវិនាស ដោយគិតថា ខ្លួនអញជាឥស្សរៈ ការកើតឡើងនៃទុក្ខលំបាក កុំឲ្យមានដល់ស្ត្រីបុរសទាំងឡាយ ក្នុងដែនរបស់ព្រះអង្គ ។ ភោគសម្បត្តិទាំងអស់របស់ព្រះរាជា ជាអ្នកប្រាសចាកការព្រឺរោម (ឥតកោតញញើត) តាមចំណង់នឹងវិនាសទៅ (ដោយពិត) ការវិនាសនោះ លោកពោលថាជាទុក្ខ

របស់ព្រះរាជា ។ នោះជាវត្ថុបទ ក្នុងបញ្ហានោះឯង ទុំះជា អនុសាសនី ឥឡូវនេះ សូមព្រះអង្គសង្វាតធ្វើបុណ្យ កុំជា អ្នកលេង កុំញុំាងប្រយោជន៍ឲ្យវិនាស បពិត្រមហារាជ សូម ព្រះអង្គមានសីល ( ព្រោះថា ) បុគ្គលអ្នកទ្រុស្តសីល ឈ្មោះ ថា ជាអ្នកញុំាងខ្លួនឲ្យធ្លាក់ចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បធកាតិ** ជាពាក្យប្រារព្ធហេតុ ។ បទថា **យត្ថ** សេចក្តីថា ហិតសុខ ដែលជាផលកើតហើយទាំងអស់ តាំងមាំនៅក្នុង បទទាំង ២ ណា ។ បទថា **អលទ្ធស្ស** សេចក្តីថា ការបានលាភដែលមិន ទាន់បានហើយអំពីមុន ១ ការតាមរក្សាលាភដែលបានហើយ ១ អធិប្បាយ ថា បពិត្រលោកឪពុក ឈ្មោះថា ការញុំាងលាភដែលមិនទាន់កើតឲ្យកើត ឡើងជាការៈ ឯការតាមរក្សាលាភដែលកើតឡើងហើយ ក៏ជាការៈដូចគ្នា ព្រោះថា បុគ្គលពួកខ្លះ សូម្បីញុំាងយសឲ្យកើតឡើងហើយ ស្រវឹងក្នុង យស កើតនូវសេចក្តីប្រមាទ ធ្វើនូវអំពើអាក្រក់ មានបាណាតិបាតជាដើម ជាមហាចោរ ជាអ្នកប្លន់នូវដែន បើព្រះរាជាត្រាស់ឲ្យចាប់មកបាន ត្រូវដាក់ ព្រះរាជអាជ្ញាឲ្យដល់នូវការវិនាសធំ ។

ម្យ៉ាងទៀត បុគ្គលពួកខ្លះ ស្រវឹងក្នុងកាមគុណ មានរូបដែលកើតហើយ ជាដើម បំផ្លាញទ្រព្យឲ្យអស់ ដោយមិនមែនឧបាយ កាលអស់ទ្រព្យក៏ក្លាយ ជាមនុស្សកំព្រា ស្លៀកសំពត់សម្បកឈើ កាន់អំបែងដើរសុំទាន ឬម្យ៉ាង ទៀត បព្វជិតញុំាងលាភសក្ការៈឲ្យកើតដោយអំណាចគន្ថធុរៈជាដើម ហើយ

ស្រវឹងវិលមកដើម្បីសេចក្តីវិនាស ភិក្ខុរូបខ្លះសូម្បីចម្រើនបឋមជ្ឈានជាដើម ឲ្យកើតហើយ ជាប់នៅក្នុងអារម្មណ៍បែបនោះ ព្រោះជាអ្នកមិនមានស្មារតី រមែងវិនាសចាកឈាន ការរក្សាយស ឬការរក្សាការបានឈានជាដើម ដែលកើតឡើងហើយជារបស់លំបាកក្រៃលែង ម្យ៉ាងទៀត ដើម្បីសម្តែងសេចក្តីនោះ គួរសម្តែងរឿងរបស់ទេវទត្ត និងគួរសម្តែងរឿងមុទុលក្ខណជាតក លោមកស្សបជាតក ហារិតជាតក និងសន្តប្បរាគជាតក ។

ចំណែកបុគ្គលពួកខ្លះ ញុំាងលាភសក្ការៈឲ្យកើតឡើងហើយ តាំងនៅដោយការមិនប្រមាទ ធ្វើនូវសុចរិតកម្ម យសរបស់បុគ្គលនោះរមែងចម្រើនដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើត ដូច្នោះ បពិត្រមហារាជ ព្រោះហេតុនោះ ទ្រង់កុំប្រមាទ តាំងនៅក្នុងបយោគសម្បត្តិ គ្រងរាជសម្បត្តិដោយធម៌ តាមរក្សាកិត្តិយសរបស់ទ្រង់ដែលកើតឡើងហើយចុះ ។

បទថា **ជានាហិ** សេចក្តីថា ដើម្បីធ្វើការងារ មាននាយឃ្លាំងជាដើម សូមទ្រង់ពិចារណា ។ បទថា **អនក្ខាកិតវេ** សេចក្តីថា សូមទ្រង់ពិនិត្យមើល ពួកអាមាត្យដែលមិនមែនជាអ្នកលេងល្បែងឡោះ មិនមែនជាបុគ្គលវៀចវេរ គឺមិនជាអ្នកលេងល្បែងភ្នាល់ និងមិនមែនជាមនុស្សបោកបញ្ឆោត ។ បទថា **អសោណ្ឌេ** សេចក្តីថា ជាបុគ្គលវៀរចាកភាពជាអ្នកលេងស្រា និងអ្នកលេងគ្រឿងក្រអូប និងកម្រងផ្កា ។ បទថា **អវិនាសកេ** សេចក្តីថា មិនមែនបុគ្គលដែលញុំាងធនសារៈ និងធញ្ញាហារជាដើមដែលជារាជទ្រព្យរបស់ព្រះអង្គឲ្យវិនាស ។

បទថា **យោ** បានដល់ អាមាត្យណា ។ បទថា **យពោរ** សេចក្តីថា អាមាត្យគប្បីរក្សារាជទ្រព្យដែលមានក្នុងព្រះរាជវាំងរបស់ទ្រង់បាន ។ បទថា **សូតោវ** សេចក្តីថា ដូចសារថីបររថ អធិប្បាយថា នាយសារថី កាលទាញសេះអំពីផ្លូវដែលមិនរាបស្មើ គប្បីទាញរថទុក យ៉ាងណា អាមាត្យណាដែលមានសភាពយ៉ាងនោះ អាចនឹងរក្សាទ្រង់ មួយអន្លើដោយភោគសម្បត្តិបាន អាមាត្យនោះ ឈ្មោះថាជាអាមាត្យរបស់ទ្រង់ ទ្រង់គួរថែរក្សាអាមាត្យបែបនោះទុក ប្រើឲ្យធ្វើរាជកិច្ច ដូចជានាយឃ្លាំងជាដើម ។

បទថា **សុសង្គហិតន្តជនោ** សេចក្តីថា បពិត្រព្រះបិតា ព្រោះថាអន្តោជន និងបរិជនដែលជាអ្នកបម្រើក្នុងរាជសម្នាក់របស់ទ្រង់ មិនបានទទួលការសង្គ្រោះដោយទានជាដើម ព្រះរាជទ្រព្យ មានប្រាក់មាសជាដើមខាងក្នុងព្រះរាជដ្ឋានរបស់ព្រះរាជានោះ រមែងវិនាសដោយអំណាចនៃមនុស្សដែលមិនបានទទួលការសង្គ្រោះទាំងនោះ ក៏នាំគ្នាទៅខាងក្រៅ ព្រោះហេតុនោះសូមទ្រង់សង្គ្រោះអន្តោជនឲ្យល្អ គួរត្រួតត្រាព្រះរាជទ្រព្យរបស់ទ្រង់ឲ្យដឹងថាទ្រព្យរបស់យើងមានចំនួនប៉ុណ្ណេះ ហើយមិនគួរបោត់ការសូម្បីកិច្ចទាំង ២ យ៉ាងថា អញនឹងកប់កំណប់ក្នុងទីឈ្មោះនោះ អញនឹងបុលបំណុល ដល់បុគ្គលឈ្មោះនោះ ។

បទថា **បរបត្តិយា** សេចក្តីថា បក្សីកុណ្ឌលិនីពោលថា ទ្រង់កុំធ្វើដោយការទុកចិត្តអ្នកដទៃគួរបោត់បែងរាជកិច្ចទាំងអស់ដែលប្រកបក្សដល់ទ្រង់ប៉ុណ្ណោះ ។

បទថា **អាយំ វយំ** សេចក្តីថា ទ្រង់គួរជ្រាបចំណូលដែលកើតអំពីផ្លូវ

នោះ ៗ និងគួរជ្រាបចំណាយដែលគួរព្រះរាជទានដល់មនុស្សផ្សេង ៗ ដោយព្រះអង្គឯង ។ បទថា **កតាកតំ** សេចក្តីថា ក្នុងសង្គ្រាម ក្នុងនវកម្ម ឬក្នុងរាជកិច្ចដទៃ ៗ ទ្រង់គួរជ្រាបរាជការនេះដោយព្រះអង្គឯងថា កិច្ចនេះអញត្រូវធ្វើដោយរាជទ្រព្យចំណែកនេះ កិច្ចនេះមិនត្រូវធ្វើដោយរាជទ្រព្យចំណែកនេះ សូមទ្រង់កុំទុកចិត្តអ្នកដទៃឡើយ ។ បទថា **និគ្គណ្ហេ** សេចក្តីថា បពិត្រព្រះបិតាធម្មតាព្រះរាជា ទ្រង់ត្រូវពិចារណាជម្រះនូវបុគ្គលដែលធ្វើការកាត់ទឹត ជាដើម ដែលជាអ្នកគួរសង្កត់សង្កិន ដែលគេនាំមកបង្ហាញ គួរពិនិត្យមើលច្បាប់ដែលព្រះរាជាអំពីមុនចារឹកទុក ហើយសឹមទ្រង់ដាក់ព្រះរាជអាជ្ញាតាមសមគួរដល់ទោស ។ បទថា **បគ្គណ្ហេ** សេចក្តីថា បុគ្គលណា ជាបុគ្គលគួរលើកតម្កើង ជាបុគ្គលទម្លាយនូវបរបក្ខ ដែលបុគ្គលណាទម្លាយមិនបាន ជាបុគ្គលដែលប្រមូលកម្លាំងចំណែកខ្លួនដែលបែកបាក់ហើយក្តី ឬជាអ្នកនាំរាជសម្បត្តិដែលមិនទាន់បានមកថ្វាយក្តី និងធ្វើរាជសម្បត្តិដែលបានមកហើយឲ្យមាំទាំក្តី ឬបុគ្គលណាជួយជីវិតទ្រង់បាន សូមទ្រង់លើកបុគ្គលបែបនោះជាបុគ្គលគួរសរសើរហើយ គួរត្រាស់ឲ្យធ្វើសក្ការៈនិងការរាប់អានដ៏ធំ កាលបើដូច្នេះ អ្នកដទៃនឹងថ្វាយជីវិត ធ្វើកិច្ចដែលគួរធ្វើក្នុងរាជកិច្ចរបស់ព្រះរាជានោះ ។

បទថា **ជានបទំ** សេចក្តីថា សូមទ្រង់អនុសាសន៍ទូន្មានអត្ថនិងធម៌ដល់អ្នកជនបទដោយព្រះអង្គឯង ដោយចំណុចដែលប្រចក្សដល់ទ្រង់នោះឯង ។ បទថា **អធម្មិកា យុត្តា** សេចក្តីថា ភ្នាក់ងាររាជការដែលមិនតាំងនៅក្នុងធម៌ ទទួលសំណូកក្នុងទីនោះ ៗ ហើយត្រឡប់ពាក្យពិភាក្សា កុំញ៉ាំង

ព្រះរាជទ្រព្យ និងដែនរបស់ទ្រង់ឲ្យវិនាសឡើយ ដោយហេតុនេះ សូមទ្រង់កុំប្រមាទ សូមទ្រង់ប្រៀនប្រដៅដោយព្រះអង្គឯងនោះឯង ។ បទថា **វេគេន** សេចក្ដីថា ទ្រង់មិនទាន់បានត្រិះរិះ មិនទាន់បានពិចារណា កុំធ្វើ ឬបញ្ជាឲ្យធ្វើដោយរួសរាន់ ។ បទថា **វេគសា** សេចក្ដីថា ព្រោះកម្មដែលមិនបានពិចារណា ធ្វើដោយឆាប់រួសរាន់ដោយអំណាចឆន្ទាគតិជាដើម មិនល្អ មិនស្អាតឡើយ ព្រោះហេតុអ្វី ព្រោះហេតុថា បុគ្គលល្ងង់ខ្លៅ ធ្វើនូវកម្មបែបនោះ ខាងក្រោយរមែងក្ដៅក្រហាយក្នុងលោកនេះ ដោយអំណាចវិប្បដិសារៈ កាលនឹងសោយសេចក្ដីទុក្ខក្នុងអបាយរមែងក្ដៅក្រហាយក្នុងលោកខាងមុខ ។ សេចក្ដីនេះ បណ្ឌិតគប្បីសម្ដែងដោយកុរាជជាតក ដែលមានអត្ថជាដើមថា តថាគតបានឮដូច្នេះថា ស្ដេចនៅក្នុងដែនកុរុ បានធ្វើនូវទោសដល់ពួកឥសី... ដូច្នេះ ។

បទថា **មា តេ អធិសរេ មុញ្ច សុពាឡ្ហមធិកោបិតំ** សេចក្ដីថា បពិត្រព្រះបិតា ទ្រង់កុំបណ្ដោយឲ្យព្រះហឫទ័យអាក់អន់ ខឹងក្រោធក្នុងអកុសលកម្មរបស់អ្នកដទៃ ដែលរំលងកុសលប្រព្រឹត្តទៅឡើយ គឺកុំឲ្យតាំងនៅបាន ។ លោកពោលអធិប្បាយទុកថា បពិត្រព្រះបិតា កាលណាពួករាជបុរសក្រាបទូល បង្ហាញចោរចំពោះទ្រង់ ដែលកំពុងស្ថិតនៅក្នុងទីវិនិច្ឆ័យថា បុរសនេះសម្លាប់មនុស្ស ឬថា បុរសនេះកាត់ទីត កាលបើដូច្នោះ សូមទ្រង់កុំបណ្ដោយចិត្តអាន់អន់ក្លាម ដោយពាក្យរបស់អ្នកដទៃ ដោយអំណាចទ្រង់ព្រះពិរោធ ដោយមិនទាន់សាកសួរទ្រង់កុំអាលដាក់អាជ្ញាឡើយ ព្រោះ

ហេតុអ្វី ព្រោះថា គេចាប់បុគ្គលដែលមិនមែនចោរ ចោទថាជាចោរនាំមក ក៏បាន ដូច្នោះ ទ្រង់កុំពិរោធ សូមស្តាប់ពាក្យរបស់បុគ្គលដែលជាដើមចោទ និង ចុងចោទទាំង ២ ចំណែក ទ្រង់ជម្រះដោយល្អ ដឹងថាបុគ្គលនោះជាចោរ ដោយប្រចក្សដោយព្រះអង្គហើយ សឹមធ្វើវត្ថុដែលគួរធ្វើ ដោយអំណាចនៃ រាជអាជ្ញា ដែលកត់ត្រាទុក តាមព្រះរាជបវេណី ទោះបីកើតសេចក្តីក្រោធ ឡើងហើយ ព្រះរាជាមិនបានធ្វើព្រះហឫទ័យឲ្យត្រជាក់ជាមុន មិនគួរធ្វើការ វិនិច្ឆ័យ លុះកាលណាព្រះហឫទ័យត្រជាក់ រំលត់នូវកម្តៅ ទន់ភ្លន់ កាលនោះ ទើបគួរធ្វើនូវការវិនិច្ឆ័យ ព្រោះកាលចិត្តក្រោតក្រោធ ហេតុផលរមែងមិន ប្រាកដ ដូចកាលទឹកកំពុងពុះ ស្រមោលមុខក៏មិនប្រាកដដូច្នោះ ។ បទថា **កោធសា ហិ** សេចក្តីថា បពិត្រព្រះបិតា រាជត្រកូលទាំងឡាយដែលមាំទាំ ស្តុកស្តម្ភ ដល់នូវភាពមិនជាត្រកូល គឺដល់នូវសេចក្តីវិនាសក៏ព្រោះសេចក្តី ក្រោធ ព្រោះហេតុនោះ ដើម្បីសម្តែងសេចក្តីនេះគួរពោលដល់ខន្តិវាទិជាតក រឿងព្រះបាទនាឡិកីរាជនិងរឿងព្រះបាទអជ្ជុនដែលមានដៃ ១០០០ ជាដើម ។

បទថា **បតារយិ** សេចក្តីថា បពិត្របិតា សូមទ្រង់កុំញុាំងមហាជន ឲ្យវិកវរ ឈមចុះកាន់កាយទុច្ចរិតជាដើម ដើម្បីសេចក្តីវិនាស ដោយទ្រង់ គិតថា អញជាធំក្នុងផែនដី បុគ្គលកាន់យកទុច្ចរិតដែលជាសេចក្តីវិនាស ប្រព្រឹត្តយ៉ាងណា ទ្រង់កុំធ្វើយ៉ាងនោះ ។ បទថា **មា តេ អាសិ** សេចក្តីថា បពិត្រព្រះបិតា ក្នុងដែនរបស់ទ្រង់ ការបានទទួលទុក្ខ គឺការដល់នូវសេចក្តី ទុក្ខ កុំមានដល់បុរសស្ត្រីឡើយ ទោះជាមនុស្សឬសត្វតិរច្ឆាន ក៏ដោយ ។

អធិប្បាយថា មហាជនក្នុងដែនរបស់ព្រះរាជាដែលមិនតាំងនៅក្នុងធម៌ នាំគ្នាធ្វើកាយទុច្ចរិតជាដើម រមែងកើតក្នុងនរក យ៉ាងណា សម្រាប់អ្នកដែនរបស់ទ្រង់ កុំយ៉ាងនោះឡើយ គឺសេចក្តីទុក្ខបែបនោះនឹងមិនមានដល់អ្នកដែនរបស់ទ្រង់ដោយវិធីណា សូមទ្រង់ធ្វើដោយវិធីនោះចុះ ។

បទថា **អបេតលោមហំសស្ស** សេចក្តីថា បុគ្គលប្រាសចាកភ័យ មានភ័យអំពីការតិះដៀលជាដើម ។ ដោយបទនេះ បក្សីកុណ្ឌលិនីសម្តែងសេចក្តីថា បពិត្រព្រះបិតា ព្រះរាជាណា ទ្រង់ធ្វើសេចក្តីប្រាថ្នាក្នុងអារម្មណ៍ណាហើយ ទ្រង់រឭកដល់តែសេចក្តីប្រាថ្នារបស់ទ្រង់តែម្យ៉ាង ទ្រង់ប្រាថ្នាវត្ថុណាក៏ធ្វើវត្ថុនោះ ដោយអំណាចឆន្ទៈ គឺការពេញចិត្ត ដូចជាបុគ្គលក្មេងខ្វាក់បោះបង់នូវឈើច្រត់ និងដូចដំរីកាចមិនមានកង្វេរ ភោគសម្បត្តិរបស់ព្រះរាជានោះ ដែលប្រាសចាកភ័យ មានការតិះដៀលជាដើម រមែងវិនាសទៅ ការវិនាសនៃភោគៈនោះ លោកពោលថា ជាទុក្ខរបស់ព្រះរាជាអង្គនោះ ។ បទថា **តត្ថេវ** សេចក្តីថា អត្ថដែលក្រាបទូលមកនោះជាវត្ថុបទ ដូច្នេះ គួរប្រកបដោយន័យមុននោះចុះ ។

បទថា **ឧក្ខស្សុឡានិ** សេចក្តីថា បពិត្រព្រះបិតា ទ្រង់ស្តាប់អនុសាសនីនេះហើយ ឥឡូវនេះ គប្បីជាអ្នកព្យាយាមកុំខ្ជិលច្រអូស ទ្រង់សាងបុណ្យកុសល ព្រោះបំពេញបុណ្យកុសល កុំជាអ្នកលេងសុរា ព្រោះបរិហារដោយសុរាជាដើម កុំញ៉ាំងព្រះកាយឲ្យវិនាស ព្រោះមិនញ៉ាំងប្រយោជន៍បច្ចុប្បន្ននិងប្រយោជន៍បរលោកឲ្យវិនាសឡើយ ។ បទថា **សីលវស្សុ** សេចក្តីថា សូម

ទ្រង់ជាអ្នកទ្រទ្រង់នូវសីល បរិបូណ៌ដោយអាចារមារយាទ តាំងនៅក្នុងទស-ពិធរាជធម៌ សោយរាជសម្បត្តិ ។ បទថា **ឧស្សីលោ វិនិបាតិកោ** សេចក្តីថា បពិត្រមហារាជ ព្រោះបុគ្គលទ្រុស្តសីល កាលញុំាងខ្លួនឲ្យធ្លាក់ទៅក្នុងនរក រមែងជាបុគ្គលឈ្មោះថា ធ្វើខ្លួនឲ្យធ្លាក់ទៅក្នុងទីអាក្រក់ ។

ព្រះនាងកុណ្ឌលិនីសម្តែងធម៌ដោយគាថា ១១ ដោយប្រការយ៉ាងនេះ ព្រះរាជាទ្រង់ត្រេកអរ ត្រាស់ហៅអាមាត្យមកសួរថា នែលោកអាមាត្យដ៏ចម្រើនទាំងឡាយ យើងគួរធ្វើកិច្ចណាដល់កុណ្ឌលិនីបុត្រីរបស់យើង ដែលពោលធម៌យ៉ាងនេះ ពួកអាមាត្យក្រាបទូលថា គួរធ្វើដោយការប្រគល់តំណែងជានាយឃ្លាំងឲ្យ ទើបព្រះរាជាត្រាស់ថា បើដូច្នោះ យើងឲ្យនាទីជានាយឃ្លាំងដល់ធីតារបស់យើង ហើយទ្រង់តែងតាំងព្រះនាងកុណ្ឌលិនី ក្នុងឋានន្តរសក្តិ ។ តាំងពីនោះមក ព្រះនាងកុណ្ឌលិនីតាំងនៅក្នុងតំណែងនាយឃ្លាំង ធ្វើរាជកិច្ចស្នងព្រះរាជបិតា ។

## កុណ្ឌលិនីបញ្ហា ចប់

កន្លងមក ២-៣ ថ្ងៃ ព្រះរាជាទ្រង់បញ្ជូនទូតទៅកាន់សម្នាក់ព្រះបាទជម្ពុកបណ្ឌិតដោយន័យមុននោះឯង ហើយយាងទៅកាន់សម្នាក់របស់ជម្ពុកបណ្ឌិតនោះ ក្នុងថ្ងៃទី ៧ ទ្រង់សោយសម្បត្តិហើយ យាងត្រឡប់មកប្រថាប់ត្រង់កណ្តាលមណ្ឌបនោះឯង ។ ក្នុងកាលនោះ អាមាត្យអញ្ជើញព្រះបាទជម្ពុកបណ្ឌិតទំលើតាំងមាស ហើយយកសីសៈទូលតាំងមាសមកគាល់ព្រះរាជា ជម្ពុកបណ្ឌិតទំលើព្រះឧរុរបស់ព្រះរាជបិតា ប្រលែងហើយ ទំត្រង់តាំងមាស

វិញ ។

លំដាប់នោះ កាលព្រះរាជាត្រាស់សួរបញ្ហាដល់បក្សីជម្ពុកបណ្ឌិត ទើបត្រាស់ព្រះគាថាដោយសេចក្តីថា

អញបានសួរវេស្សន្តរៈ ជាកោសិយគោត្ត និងនាងកុណ្ឌលិនី
ដោយប្រការដូច្នោះហើយ ម្នាលជម្ពុកៈ ឥឡូវនេះ អ្នកចូរ
ពោលនូវកម្លាំងដ៏ឧត្តមជាងកម្លាំងទាំងឡាយ ដូច្នេះ ។

ព្រះគាថានេះ មានអធិប្បាយដូច្នេះថា នែបាជម្ពុកៈ បិតាបានសួររាជធម៌ជាមួយបាវេស្សន្តរ ជាកោសិយគោត្ត បងប្រុសរបស់ឯង និងនាងកុណ្ឌលិនី ដែលជាបងស្រីរបស់ឯង អ្នកទាំង ២ ឆ្លើយតាមកម្លាំងប្រាជ្ញារៀង ៗ ខ្លួនម្យ៉ាងទៀត បិតាសួរបងប្រុសនិងបងស្រីឯងយ៉ាងណា នែជម្ពុកៈ ឥឡូវនេះ បិតានឹងសួរឯងយ៉ាងនោះដូចគ្នា ចូរឯងប្រាប់រាជធម៌នោះ និងកម្លាំងដ៏ឧត្តមជាងកម្លាំងទាំងឡាយផងចុះ ។

ព្រះរាជា កាលត្រាស់សួរបញ្ហានឹងព្រះមហាសត្វយ៉ាងនេះ មិនបានត្រាស់សួរដោយទំនងដែលត្រាស់សួរបក្សីដទៃ ៗ ឡើយ ត្រាស់សួរដោយវិសេសក្រៃលែងឡើង ។ លំដាប់នោះ ជម្ពុកបណ្ឌិតទូលថា បពិត្រមហារាជ បើដូច្នោះ សូមទ្រង់ផ្ទៀងនូវសោតបសាទ ទូលព្រះបង្គំនឹងពោលនូវបញ្ហាទាំងពួង ថ្វាយដល់ទ្រង់ ដូច្នេះហើយ ហាក់ដូចជាប្រាប់នូវថង់ប្រាក់ ១០០០ ជាមួយអ្នកដែលលាដៃទទួលដូច្នោះ ផ្តើមសម្តែងធម៌ជាគាថាដោយសេចក្តីថា

កម្លាំងក្នុងលោកមាន ៥ យ៉ាង រមែងមានក្នុងបុរសដែលមាន

អធ្យាស្រ័យធំ បណ្តាកម្លាំងទាំងនោះ កម្លាំងដៃ ( កាយ ) បណ្ឌិតពោលថា ជាកម្លាំងថោកទាប បពិត្រព្រះអង្គមានព្រះជន្មវែង កម្លាំងភោគៈ បណ្ឌិតពោលថា ជាកម្លាំងទី ២ ។ បពិត្រព្រះអង្គមានព្រះជន្មវែង កម្លាំងអមាត្យ បណ្ឌិតពោលថា ជាកម្លាំងទី ៣ កម្លាំងជាតិខ្ពស់ជាកម្លាំងទី ៤ ឥតសង្ស័យ បុគ្គលជាបណ្ឌិត រមែងគ្របសង្កត់នូវកម្លាំងទាំងអស់នេះ ។ កម្លាំងបញ្ញានោះ ជាកម្លាំងដ៏ប្រសើរ ជាកម្លាំងខ្ពង់ខ្ពស់ជាងកម្លាំងទាំងឡាយ បណ្ឌិតដែលមានកម្លាំងបញ្ញាជ្រាលជ្រៅហើយ រមែងបាននូវសេចក្តីចម្រើន ។ បុគ្គលអប្បឥតបញ្ញា ទោះបីបាននូវផែនដីស្តុកស្តម្ភប្រសើរ កាលបើបុគ្គលមានបញ្ញាទន់នោះមិនមានប្រាថ្នា បុគ្គលដែលមានបញ្ញាដទៃ ធ្វើនូវការកំហែងហើយគ្រប់គ្រងនូវផែនដីនោះ ។ បពិត្រព្រះអង្គជាម្ចាស់ដែនកាសី បើទុកជាបុគ្គលមានជាតិខ្ពង់ខ្ពស់ ជាក្សត្របាននូវរាជ្យ តែអប្បបញ្ញា ក៏រមែងមិនអាចរស់នៅដោយរាជ្យទាំងពួងបាន ។ បញ្ញាជាធម្មជាតិសម្រាប់វិនិច្ឆ័យ ក្នុងសេចក្តីដែលបានស្តាប់ បញ្ញាជាគ្រឿងញ៉ាំងកេរ្តិ៍ឈ្មោះ និងលាភសក្ការៈឲ្យចម្រើន នរជនប្រកបដោយបញ្ញាក្នុងលោកនេះ សូម្បីទុក្ខ ( កើតឡើង ) ក៏រមែងបានសុខទាំងឡាយវិញ ។ មួយទៀត បុគ្គលណាមួយមិនស្តាប់ដោយគោរព មិនជឿនូវបុគ្គលជាពហុស្សូត មិន

ឈ្វេងយល់នូវកិច្ចការ ដែលឋិតនៅក្នុងសការៈ រមែងមិនបាននូវបញ្ញា ។ លុះតែបុគ្គលណា ជាអ្នកដឹងនូវចំណែកនៃធម៌ ប្រឹងប្រែងក្នុងកាលគួរ មិនខ្ជិលច្រអូស ប្រឹងប្រែងរឿយៗតាមកាលគួរ ផលកើតអំពីការងារ ទើបសម្រេចដល់បុគ្គលនោះ ។ កាលបុគ្គលមិនមានសីលជាទីកើត ( នៃលាភ យស សុខ ) សេពគប់នូវបុគ្គលទ្រុស្តសីល មិនជាទីកើត( នៃលាភ យស សុខ ) ធ្វើការធុញទ្រាន់ ប្រយោជន៍រមែងមិនឲ្យផលដោយប្រពៃទេ ។ លុះតែបុគ្គលប្រកបកិច្ចខាងក្នុងសន្តានសេពគប់នូវបុគ្គលមានសីលជាទីកើត ( នៃលាភ យស សុខ ) ដូច្នោះ ធ្វើការងារមិនធុញទ្រាន់ ប្រយោជន៍រមែងឲ្យផលដោយប្រពៃ ។ បពិត្របិតា សូមព្រះអង្គគប់រកនូវហេតុទាំងឡាយនោះ គឺ បញ្ញាជាចំណែកនៃព្យាយាម ក្នុងហេតុដែលគួរប្រកប និងការថែទាំទុកនូវទ្រព្យដែលព្រះអង្គបានព្រះអង្គកុំ ( ញុំាងទ្រព្យ ) ឲ្យវិនាស ដោយការងារមិនគួរព្រោះថា បុគ្គលឥតបញ្ញា រមែងលិចចុះ ( ក្នុងសេចក្ដីវិនាស ) ដោយហេតុមិនមែនជាការងារ ដូចផ្ទះដែលគេធ្វើដោយដើមបបុស ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មហាគ្គតេ** សេចក្ដីថា បពិត្រមហារាជកម្លាំងក្នុងបុរសដែលមានអធ្យាស្រ័យធំក្នុងលោកនេះ មាន ៥ យ៉ាង ។

បទថា **ពាហុពលំ** បានដល់ កម្លាំងកាយ ។ បទថា **ចរិមំ** សេចក្តីថា កម្លាំងកាយនោះ ជាកម្លាំងក្រៃលែង ជាកម្លាំងចុងក្រោយនោះឯង ។ ព្រោះហេតុអ្វី ព្រោះជាកម្លាំងរបស់អន្ធពាល ។ អធិប្បាយថា បើកម្លាំងកាយឈ្មោះថាធំពិត កម្លាំងរបស់សត្វចាបចៀបកប្បាសញី ក៏រមែងអន់ជាងកម្លាំងដំរី តែកម្លាំងរបស់ដំរី ជាបច្ច័យនៃសេចក្តីស្លាប់ ព្រោះជាកម្លាំងអន្ធ-ពាល ចាបចៀបកប្បាសបានញ៉ាំងដំរីឲ្យអស់ជីវិតបាន ព្រោះចាបជាសត្វឈ្លាសក្នុងការដឹង ។ ក្នុងសេចក្តីនេះ គួរនាំព្រះសូត្រ ( លដុកិកជាតក ) មកថា **ន ហេវ សព្វត្ថ ពលេន កិច្ចំ ពលំ ហិ ពាលស្ស វធាយ ហោតិ** ប្រែថា កិច្ចដោយកម្លាំងកាយ មិនមែនប្រើបានគ្រប់កន្លែងទេ ព្រោះកម្លាំងកាយ សម្លាប់បានតែអ្នកល្ងង់ទេ ដូច្នេះជាដើមមកសម្តែង ។

បទថា **ភោគពលំ** សេចក្តីថា កម្លាំងដែលកើតអំពីគ្រឿងឧបភោគ ដូចជាប្រាក់ មាសជាដើម ឈ្មោះថា កម្លាំងគឺភោគសម្បត្តិ កម្លាំងភោគសម្បត្តិនោះ ធំជាងកម្លាំងកាយ ដោយអំណាចជាគ្រឿងឧបការៈ ។ បទថា **អមច្ចពលំ** សេចក្តីថា ការមានជុំនុំអមាត្យដែលជាអ្នកមានមន្តមិនបែកធ្លាយ មានភាពក្លៀវក្លា មានហទយៈល្អ កម្លាំងគឺអាមាត្យនោះ ជាកម្លាំងធំជាងកម្លាំងពីរយ៉ាងខាងដើម ព្រោះអាមាត្យជាអ្នកក្លៀវក្លាក្នុងសង្គ្រាម ។ បទថា **អភិជច្ច-ពលំ** សេចក្តីថា ការដល់ព្រមនៃជាតិដោយអំណាចនៃត្រកូលក្សត្រ ឈានកន្លងនូវត្រកូលទាំង ៣ កម្លាំងគឺភាពជាអ្នកមានជាតិខ្ពស់នោះ ធំជាងកម្លាំងក្រៅអំពីនេះ ព្រោះថា ជនដែលដល់ព្រមដោយជាតិប៉ុណ្ណោះ រមែងបរិសុទ្ធិ

ជនក្រៅអំពីនេះ មិនបរិសុទ្ធិឡើយ ។

បទថា **យានិ ចេតានិ** សេចក្តីថា បណ្ឌិតរមែងកាន់យក គឺរមែងគ្របសង្កត់នូវកម្លាំងទាំង ៤ យ៉ាងនេះបាន ដោយអានុភាពនៃកម្លាំងណា កម្លាំងនោះ បានដល់កម្លាំងប្រាជ្ញា លោកពោលថាជារបស់ប្រសើរក្រៃលែងជាងកម្លាំងទាំងពួង ។ ព្រោះហេតុអ្វី ព្រោះបណ្ឌិតដែលកម្លាំងប្រភេទនោះឧបការៈរមែងបាននូវប្រយោជន៍ គឺរមែងដល់នូវសេចក្តីចម្រើន ដើម្បីញ៉ាំងអត្ថនោះឲ្យជាក់ច្បាស់ គួរសម្តែងបុណ្ណទីជាតកថា **បុណ្ណំ នទឹ យេន ច បេយ្យមាហុ** សេចក្តីថា ជនទាំងឡាយពោលនូវស្ទឹង ដែលល្មមសត្វណាផឹកបាន ដូច្នេះជាដើម និងគប្បីសម្តែងសិរិកាឡកណ្ណិប្បញ្ហា បញ្ចបណ្ឌិតប្បញ្ហា សត្តុកត្តជាតក ( សេនកជាតក ) សម្ពុជាតក និងសរភង្គជាតកជាដើម ។

បទថា **មន្ទោ** បានដល់ បុគ្គលមានបញ្ញាថោកថយ ឬបុគ្គលល្ងង់ខ្លៅ ។ បទថា **ដីតំ** សេចក្តីថា បពិត្របិតា បុគ្គលមានបញ្ញាថោកថយ ទោះបីបាននូវផែនដីដែលសម្បូរដោយរតនៈ ៧ សោត មិនប្រាថ្នាឡើយ បុគ្គលដទៃសម្បូរដោយបញ្ញា ធ្វើនូវការសង្កត់សង្កិន ហើយគ្រប់គ្រងផែនដីនោះបាន ព្រោះថាអ្នកមានបញ្ញាថោកថយ រមែងមិនអាចរក្សាយស ដែលខ្លួនបានហើយ ឬថា មិនអាចបាននូវរាជសម្បត្តិដែលជាមត៌ករបស់ត្រកូល ឬដែលដល់ហើយដោយបវេណី ដែលស្តុកស្តម្ភសម្បូរ ។ ដើម្បីនឹងពង្រីកសេចក្តីនោះឲ្យជាក់ច្បាស់ បណ្ឌិតគួរសម្តែងបាទញ្ជលិជាតកថា ព្រះរាជកុមារ ព្រះនាម

បាទញ្ចលី រុងរឿងកន្លងនូវពួកយើងទាំងអស់គ្នា ដោយប្រាជ្ញា ពិតមែន ដូច្នេះជាដើម ។

បទថា **លទ្ធាន** សេចក្តីថា បុគ្គលអាស្រ័យជាតិសម្បត្តិហើយ សូម្បីបានរាជសម្បត្តិដែលជារបស់ត្រកូល ។ បទថា **សព្ពេឧបិ** សេចក្តីថា បុគ្គលមានបញ្ញាថោកថយ រមែងជាអ្នកនៅដោយរាជសម្បត្តិទាំងមូលមិនបាន គឺរមែងជាអ្នកដល់នូវសេចក្តីលំបាក ។ ព្រោះភាពជាអ្នកមិនឈ្លាសក្នុងឧបាយ ព្រះមហាសត្វ ពោលទោសរបស់ជនដែលមិនមែនបណ្ឌិតដោយឋានៈប៉ុណ្ណេះយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងសរសើរបញ្ញាទើបពោលពាក្យជាដើមថា **បញ្ញា** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុតំ** បានដល់ សុត្តបរិយត្តិ គឺការរៀនសូត្រនិងការស្តាប់ ។ ពិតហើយ បញ្ញានោះឯង រមែងវិនិច្ឆ័យនូវវត្ថុដែលបានឮបានស្តាប់នោះ ។ បទថា **កិត្តិសិលោកវឌ្ឍនី** បានដល់ ជាគ្រឿងចម្រើននៃកេរ្តិ៍ឈ្មោះ និងលាភសក្ការៈ ។ បទថា **ទុក្ខេ សុខានិ វិន្ទតិ** សេចក្តីថា បុគ្គលប្រកបដោយបញ្ញា សូម្បីទុក្ខកើតឡើងរមែងជាអ្នកផុតភ័យបាននូវសេចក្តីសុខ ព្រោះជាអ្នកឈ្លាសក្នុងឧបាយ ។ ដើម្បីនឹងសម្តែងសេចក្តីនោះ គួរសម្តែង ( វានរិន្ទជាតកនិងវានរជាតក ) ដែលជាគាថាមានសេចក្តីថា បពិត្រវានរិន្ទ បុគ្គលណា មានធម៌ ៤ ដូចអ្នក...។ ផ្លែឈើទាំងឡាយណា ដែលយើងគប្បីទៅកាន់ត្រើយនៃសមុទ្ទ ហើយស៊ីផ្លែឈើទាំងឡាយនោះ គឺផ្លែស្វាយ ផ្លែព្រីង ផ្លែខ្នុរ... ដូច្នេះជាដើម ។

បទថា **អសុស្សូសំ** សេចក្ដីថា មិនចូលទៅក្បែរ មិនស្ដាប់បុគ្គលដែល ជាបណ្ឌិត ។ បទថា **ពហុស្សុតំ អនាគម្ម** សេចក្ដីថា មិនជឿពាក្យរបស់ បុគ្គលនោះ ។ បទថា **ធម្មដ្ឋំ** សេចក្ដីថា តាំងនៅក្នុងសភាពហេតុផល ។ បទថា **អវិធិត្តជំ** សេចក្ដីថា បពិត្របិតា អ្នកណាមិនសង្កេតមើល គឺមិន ពិចារណាមើលថា ជាប្រយោជន៍ ឬមិនជាប្រយោជន៍ មានហេតុផល ឬមិន មានហេតុផលរមែងមិនបានទូវបញ្ញា ។

បទថា **ធម្មវិកត្តញ្ញូ** សេចក្ដីថា ជាអ្នកឈ្លាសក្នុងកុសលកម្មបថ ១០ ។ បទថា **កាលុដ្ឋាយី** សេចក្ដីថា ធ្វើនូវសេចក្ដីព្យាយាមក្នុងកាលដែលគួរធ្វើ សេចក្ដីព្យាយាម ។ បទថា **អនុដ្ឋហាតិ** សេចក្ដីថា រមែងធ្វើនូវកិច្ចនោះ ៗ ក្នុងកាលនោះ ៗ ។ បទថា **តស្ស** សេចក្ដីថា ផលនៃកម្មរបស់បុគ្គលនោះ រមែងសម្រេច គឺរមែងឲ្យផល ។

បទថា **អនាយតនសីលស្ស** សេចក្ដីថា កម្ម គឺភាពជាអ្នកទ្រុស្តសីល មិនមែនជាប្រកពកើតនៃលាភ យស និងសេចក្ដីសុខឡើយ លោកហៅថា កម្មមិនមែនជាប្រកពកើត កាលបុគ្គលមានប្រក្រតីយ៉ាងនោះ គឺបុគ្គលដែល ប្រកបដោយកម្ម គឺភាពជាអ្នកទ្រុស្តសីលនោះ គប់រកនូវបុគ្គលទ្រុស្តសីល ដែលមិនមែនជាប្រកពកើតតែម្យ៉ាង ក្នុងកាលដែលធ្វើកុសលកម្ម ។ បទថា **និព្វិន្ទិយការិស្ស** សេចក្ដីថា បុគ្គលនឿយណាយ គឺខ្ជិចអោចិត្តធ្វើការងារ ។ អធិប្បាយថា បពិត្របិតា ប្រយោជន៍នៃការងាររបស់បុគ្គលបែបនេះ រមែង មិនឲ្យផល គឺមិនសម្រេចដោយប្រពៃ បានដល់ មិននាំទៅកាន់កាមាវចរ

សួគ៌ ដែលជាកំពូលនៃត្រកូលទាំង ៣ ។

បទថា **អជ្ឈត្តញ្ច** សេចក្តីថា កាលបុគ្គលប្រកបនូវនិយកជ្ឈត្តធម៌នៃ ខ្លួន ដោយអំណាចនៃភាពជារបស់មិនទៀងជាដើម ។ បទថា **តថាយតន សោធិនោ** សេចក្តីថា គប់រកបុគ្គលដែលមានសីលជាប្រក្រតីដូច្នោះតែម្យ៉ាង ។ បទថា **វិបច្ចតិ** សេចក្តីថា ប្រយោជន៍នៃបុគ្គលនោះ រមែងសម្រេចដោយប្រពៃ គឺរមែងឲ្យនូវយសដ៏ធំក្រៃលែង ។

បទថា **យោគប្បយោគសង្ខាតំ** បានដល់ បញ្ញាដែលជាចំណែកនៃការប្រកបក្នុងហេតុការណ៍ដែលសមគួរប្រកប ព្រោះសេចក្តីព្យាយាម ។ បទថា **សម្ភតស្ស** សេចក្តីថា ចូរសេពនូវការតាមរក្សាទ្រព្យ ដែលធ្វើការរួបរួមទុក ។ បទថា **តានិ តុំ** សេចក្តីថា បពិត្រព្រះបិតា សូមទ្រង់បដិបត្តិតាមរក្សាទ្រព្យ ដែលបានរួបរួមទុក សូមបដិបត្តិតាមពាក្យទូន្មានខាងដើមនេះ និងហេតុផលទាំងអស់ ដូចខ្ញុំបានក្រាបទូលហើយ សូមធ្វើឱវាទដែលក្រាបទូលមកហើយ ទុកក្នុងព្រះហឫទ័យ ហើយទ្រង់រក្សារាជទ្រព្យក្នុងឃ្លាំងរបស់ទ្រង់ចុះ ។ បទថា **មា អកម្មាយ រន្ធយិ** សេចក្តីថា ទ្រង់កុំទម្លាយដោយផ្លូវដែលមិនសមគួរ មិនមានហេតុផល គឺកុំបំផ្លាញព្រះរាជទ្រព្យនោះ បានដល់ ទ្រង់កុំញុំាងរាជទ្រព្យនោះឲ្យវិនាស ។ ព្រោះហេតុអ្វី ព្រោះការធ្វើមិនសមគួរ ។ បទថា **អកម្មុនា** សេចក្តីថា ព្រោះធ្វើនូវកម្មមិនសមគួរ បុគ្គលដែលមានបញ្ញាថោកថយ បំផ្លាញនូវទ្រព្យរបស់ខ្លួនឲ្យវិនាសហើយ ក្រោយមកក៏ធ្លាក់ខ្លួនក្រីក្រលំបាក ។ បទថា **ឧឡ្ហាគារំវ សីទតិ** សេចក្តីថា

ផ្ទះបបុសដែលចាស់គ្រាំគ្រា តាំងនៅមិនបាន រមែងដួលទៅ តាំងអំពីគល់យ៉ាងណា បុគ្គលមានបញ្ញាថោកថយ បំផ្លាញនូវទ្រព្យឲ្យវិនាសដោយមិនមានហេតុផល រមែងកើតក្នុងអបាយ ក៏យ៉ាងនោះ ។

ព្រះពោធិសត្វពណ៌នាកម្លាំង ៥ យ៉ាង ដោយឋានៈ មានប្រមាណប៉ុណ្ណេះ យ៉ាងនេះហើយ លើកកម្លាំងបញ្ញាឡើងពោល ដូចបុគ្គលនាំមណ្ឌលនៃព្រះចន្ទទៅ កាលនឹងថ្វាយឱវាទដល់ព្រះរាជាទើបពោល ១០ គាថាក្នុងកាលឥឡូវនេះដោយសេចក្តីថា

បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ គឺការបម្រើមាតាបិតាទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ គឺការសង្គ្រោះចំពោះបុត្តភរិយាទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះមិត្តនិងអាមាត្យទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះពាហនៈនិងពលទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌

ចំពោះជនអ្នកស្រុក និងអ្នកនិគមទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះអ្នកដែននិងអ្នកជនបទទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយនឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះពួកសមណៈ និងព្រាហ្មណ៍ទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ គឺឲ្យអភ័យចំពោះពួកម្រឹគនិងសត្វបក្សីទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ( ព្រោះថា ) ធម៌ដែលព្រះអង្គប្រព្រឹត្តហើយ រមែងនាំមកនូវសេចក្តីសុខ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ព្រោះពួកព្រះឥន្ទ ទេវតា ព្រមទាំងព្រហ្ម បានដល់នូវទិព្វសម្បត្តិដោយធម៌ដែលខ្លួនប្រព្រឹត្តល្អ បពិត្រព្រះរាជា សូមព្រះអង្គកុំប្រហែសចំពោះធម៌ ដូច្នេះ ។

ក្នុងគាថាទាំងនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទី ១ សិន ។ បទថា **ឝ៨**

**ធម្មំ** សេចក្តីថា សូមទ្រង់ប្រព្រឹត្តមាតាបិតុបដ្ឋានធម៌ ។ ព្រះមហាសត្វពោលថា សូមទ្រង់ក្រោកឡើងអំពីព្រលឹម ហើយចាត់ចែងទឹកខ្ពុរមាត់ និងឈើស្ទន់ជាដើម ធ្វើនូវការបរិហារសិរីកិច្ចគ្រប់យ៉ាងឲ្យពេញបរិបូណ៌ ឈ្មោះថា ប្រព្រឹត្តធម៌ក្នុងមាតាបិតា ។

បទថា **បុត្តទារេសុ** សេចក្តីថា បិតាហាមបុត្តធីតាចាកអំពើអាក្រក់មុនឲ្យតាំងនៅក្នុងសុចរិតកម្ម ឲ្យរៀនសិប្បវិជ្ជាក្នុងកាលចម្រើនវ័យហើយ នឹងធ្វើនូវអាវាហមង្គលនិងវិវាហមង្គល ដោយត្រកូល និងវ័យដែលសមគ្នា ប្រគល់ទ្រព្យឲ្យក្នុងសម័យ ឈ្មោះថា ប្រព្រឹត្តធម៌ក្នុងបុត្តធីតា ។ ស្វាមីរមែងលើកតម្កើងភរិយា មិនប្រព្រឹត្តក្រៅចិត្ត ប្រគល់ភាពជាធំឲ្យ ឲ្យនូវគ្រឿងប្រដាប់ ឈ្មោះថាប្រព្រឹត្តធម៌ក្នុងភរិយា ។

បទថា **មិត្តាមច្ចេសុ** សេចក្តីថា ព្រះរាជាសង្គ្រោះមិត្ត និងអាមាត្យដោយសង្គហវត្ថុ ៤ មិនក្លែងពោលឲ្យឃ្លាតពីពាក្យសច្ចៈ ឈ្មោះថាប្រព្រឹត្តធម៌ក្នុងមិត្តនិងអាមាត្យទាំងនោះ ។

បទថា **វាហនេសុ ពលេសុ ច** សេចក្តីថា ព្រះរាជាព្រះរាជទានវត្ថុដែលគួរព្រះរាជទានដល់ពាហនៈ ដូចជាដំរី សេះជាដើម និងដល់ពលនិកាយ ធ្វើនូវការសរសើរ មិនប្រើដំរីសេះជាដើមក្នុងការងារ ក្នុងពេលដែលសត្វទាំងនោះចាស់ ឈ្មោះថាប្រព្រឹត្តធម៌ក្នុងពាហនៈ និងពលនិកាយទាំងនោះ ។

បទថា **គាមេសុ និគមេសុ ច** សេចក្តីថា ព្រះរាជាកាលមិនបៀតបៀនរឹបជាន់អ្នកស្រុក និងអ្នកនិគមដោយអាជ្ញា និងសួយសារអាករ ឈ្មោះថា

ប្រព្រឹត្តធម៌ក្នុងអ្នកស្រុកនិងអ្នកនិគមទាំងនោះ ។

បទថា **រដ្ឋេសុ ជនបទេសុ ច** សេចក្តីថា ព្រះរាជាបៀតបៀនអ្នកដែននិងអ្នកជនបទឲ្យលំបាក ដោយហេតុ ( ឯណាទីមួយ ) មិនចូលទៅតាំងទុកនូវចិត្តឧបការៈ ឈ្មោះថា មិនប្រព្រឹត្តធម៌ក្នុងអ្នកដែននិងអ្នកជនបទនោះ បើមិនបៀតបៀន ផ្សាយមេត្តាទៅដោយចិត្តអនុគ្រោះ ឈ្មោះថាប្រព្រឹត្តធម៌ក្នុងអ្នកដែននិងអ្នកជនបទនោះ ។ បទថា **សមណេ ព្រាហ្មណេសុ ច** សេចក្តីថា ព្រះរាជាកាលព្រះរាជទានចតុប្បច្ច័យ ដល់សមណព្រាហ្មណ៍ទាំងឡាយ ឈ្មោះថាប្រព្រឹត្តធម៌ក្នុងសមណៈនិងព្រាហ្មណ៍ ។

បទថា **មិគបក្ខីសុ** សេចក្តីថា ព្រះរាជាកាលព្រះរាជទានអភ័យដល់សត្វជើង ៤ និងបក្សីទាំងពួង ឈ្មោះថា ប្រព្រឹត្តធម៌ក្នុងម្រឹគជាតិ និងពួកបក្សីទាំងនោះ ។

បទថា **ធម្មោ ចិណ្ណោ** សេចក្តីថា ធម៌ដែលប្រព្រឹត្តស្មើដែលព្រះរាជាប្រព្រឹត្តហើយ គឺនិសម្មចរិយធម៌ដែលព្រះរាជាទ្រង់ប្រព្រឹត្តហើយ ។ បទថា **សុខាវហោ** សេចក្តីថា រមែងនាំមកនូវសេចក្តីសុខក្នុងកុលសម្បត្តិ ៣ និងឆកាមាវចរសួគ៌ ។ បទថា **សុចិណ្ណេន** សេចក្តីថា ព្រោះកាយសុចរិតជាដើមដែលទ្រង់ប្រព្រឹត្តហើយក្នុងលោកនេះ ដែលព្រះអង្គទ្រង់ប្រព្រឹត្តល្អហើយ ។ បទថា **ទិវំ បត្តា** សេចក្តីថា ព្រះឥន្ទ្រ ទេវតា ព្រមទាំងព្រហ្ម ទៅកាន់ទិព្វស្ថាន ពោលគឺទេវលោក និងព្រហ្មលោក បានដល់ កើតជាបុគ្គលបាននូវទិព្វសម្បត្តិក្នុងទិព្វស្ថាននោះ ។ បទថា **មា ធម្មំ រាជ បាមទោ** សេចក្តីថា

បពិត្រមហារាជ ព្រោះដូច្នោះ ព្រះអង្គទោះបីត្រូវលះបង់ជីវិត ទ្រង់កុំប្រមាទនូវធម៌ ។ ព្រះមហាសត្វពោលគាថា និងសម្តែងធម្មចរិយា ១០ យ៉ាងដូច្នេះហើយ កាលនឹងឲ្យឱវាទក្រៃលែងឡើងទើបពោលគាថាចុងក្រោយថា

នោះជាវត្តបទ ក្នុងបញ្ហានោះឯង ទុះឯងជាអនុសាសនី សូមព្រះអង្គសេពគប់នូវបុគ្គលមានបញ្ញា សូមមានគុណធម៌ដ៏ល្អជ្រាបច្បាស់នូវធម៌នោះ ដ៏បរិបូណ៌ដោយព្រះអង្គឯង ( ប្រតិបត្តិតាមពាក្យប្រៀនប្រដៅចុះ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តត្ថេវ តេ វត្តបទា** នេះ គប្បីប្រកបដោយន័យមុននោះឯង ។ បទថា **សប្បញ្ញសេវិ កល្យាណី សមត្តំ សាម តំ វិទូ** សេចក្តីថា បពិត្រមហារាជ សូមទ្រង់គប់រកបុគ្គលដែលមានបញ្ញាជានិច្ចកាល សូមប្រកបដោយគុណ ទ្រង់ដឹងច្បាស់ឯង ពេញបរិបូណ៌ គឺទ្រង់ជ្រាបច្បាស់ ដោយប្រចក្សដោយព្រះអង្គឯងហើយ សូមបដិបត្តិតាមឱវាទដែលខ្ញុំក្រាបទូលហើយ តាមដែលខ្ញុំទូន្មានហើយ ។

ព្រះមហាសត្វសម្តែងធម៌ដោយពុទ្ធលីលាយ៉ាងនេះ ហាក់បីដូចទេវតាញ៉ាំងអាកាសគង្គាឲ្យធ្លាក់ចុះមក ដូច្នោះ មហាជនបានធ្វើមហាសក្ការៈ ហើយឲ្យសាធុការរាប់ពាន់ ។ ព្រះរាជាទ្រង់ត្រេកអរ ត្រាស់ហៅអាមាត្យមកសួរថា នែអាមាត្យដ៏ចម្រើនទាំងឡាយ ជម្ពុកបណ្ឌិត មានចំពុះស្មើដោយផ្លែព្រីងខ្ចី ដែលជាកូនរបស់យើង ជាអ្នកពោលយ៉ាងនេះ គួរធ្វើនូវការតបស្នងដោយវត្ថុណា អាមាត្យទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន គួរធ្វើការ

តបស្នងដោយតំណែងសេនាបតី ។ ព្រះរាជាត្រាស់ថា បើដូច្នោះ យើង នឹងព្រះរាជទានតំណែងសេនាបតីដល់ជម្ពុកៈនោះ ហើយទ្រង់តែងតាំងជម្ពុកពោធិសត្វទុកក្នុងឋានន្តរសក្តិ តាំងអំពីនោះមក ជម្ពុកពោធិសត្វតាំងនៅក្នុងតំណែងសេនាបតី បានធ្វើនូវការស្នងរាជកិច្ចរបស់បិតា ។ សក្ការៈជាច្រើនមានដល់បក្សីទាំង ៣ សូម្បីបក្សីទាំង ៣ ក៏នាំគ្នាថ្វាយឱវាទអត្ថនិងធម៌ដល់ព្រះរាជា ។ ព្រះរាជា ទ្រង់តាំងនៅក្នុងឱវាទរបស់ព្រះមហាសត្វ ទ្រង់បំពេញបុណ្យកុសល មានទានជាដើម ហើយជាអ្នកមានស្ថានសួគ៌ជាទីទៅ ។ អាមាត្យទាំងឡាយនាំគ្នារៀបចំការថ្វាយព្រះភ្លើង ព្រះបរមសពរបស់ព្រះរាជាហើយប្រាប់ដល់បក្សីទាំង ៣ ថា បពិត្រព្រះបាទជម្ពុកៈ ព្រះរាជាទ្រង់ធ្វើរាជវិនយកម្មឲ្យលើកស្វេតច្ឆត្រដល់ទ្រង់ ។ ព្រះមហាសត្វឆ្លើយថា យើងមិនត្រូវការដោយរាជសម្បត្តិ អ្នកទាំងឡាយចូរកុំប្រមាទគ្រប់គ្រងចុះ ហើយញុំាងមហាជនឲ្យតាំងមាំនៅក្នុងសីល ទូន្មានថា ពួកលោកគប្បីញុំាងការវិនិច្ឆ័យឲ្យប្រព្រឹត្តទៅយ៉ាងនេះហើយ ហើយឲ្យចារឹកគោលការណ៍ ក្នុងការវិនិច្ឆ័យក្នុងក្រាំងមាស ហើយត្រឡប់ទៅកាន់ព្រៃ ។ ឱវាទរបស់ព្រះមហាសត្វនោះ ប្រព្រឹត្តទៅអស់ ៤ ម៉ឺនឆ្នាំ ។

ព្រះបរមសាស្តា ទ្រង់សម្តែងនូវព្រះធម្មទេសនានេះ ដោយទំនងនៃឱវាទដល់ព្រះរាជាហើយ ទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ បក្សីកុណ្ឌលិនីក្នុងកាលនោះ បានមកជាឧប្បលវណ្ណា បក្សីវេស្សន្តរក្នុងកាលនោះ បានមកជាសារីបុត្ត រាជអាមាត្យក្នុងកាល

នោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ចំណែកជម្ពុកៈក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា តេសកុណជាតក ចប់

# សរភង្គជាតក

[ ៥៧៥ ] ( អនុសិស្សតាបសសួរថា ) បពិត្រលោក រថទាំងឡាយប្រសើរ លោកទាំងឡាយមានខ្លួនប្រដាប់ហើយ មានកុណ្ឌល មានសំពត់ស្លៀកល្អ សៀតព្រះខ័នមានដង ប្រដាប់ដោយកែវពៃទូរ្យនិងកែវមុក្តា ឈរនៅ ( លើរថតែមួយ ) លោកទាំងឡាយឈ្មោះអ្វី ពួកជនក្នុងមនុស្សលោកស្គាល់លោកទាំងឡាយដូចម្តេច ។

[ ៥៧៦ ] ( ព្រះរាជាព្រះនាមអដ្ឋកៈត្រាស់ថា ) ខ្ញុំជាព្រះរាជា ឈ្មោះអដ្ឋកៈ នេះជាព្រះរាជាព្រះនាមភីមរថ នេះជាព្រះរាជាព្រះនាមកាលិង្គ ដែលមានតេជានុភាព មានកិត្តិសព្ទល្បីល្បាញ យើងទាំងឡាយមកក្នុងទីនេះ ដើម្បីឃើញនូវឥសីទាំងឡាយដែលសង្រួមល្អហើយ ដើម្បីសួរនូវប្រស្នាទាំងឡាយ ។

[ ៥៧៧ ] ( អនុសិស្សតាបស... ) លោកឋិតនៅឰដ៏អាកាស ជាទីរីករាយនៃសត្វស្ទាប ដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើតដែលឋិតនៅនាគន្លងផ្លូវឆ្ងាយ ( អាកាស ) បពិត្រយក្ស អាត្មាសូមសួរលោក ដែលមានអានុភាពធំ ពួកជនក្នុងមនុស្សលោកនឹងស្គាល់លោកដូចម្តេច ។

[ ៥៧៨ ] ( សក្កទេវរាជ... ) ទេវតាទាំងឡាយ ក្នុងពួកទេវតា បានហៅខ្ញុំណាថា មឃវា ខ្ញុំនោះ ជាទេវរាជមកកាន់ទីនេះ ក្នុងថ្ងៃនេះ ដើម្បីឃើញឥសីទាំងឡាយអ្នកសង្រួមល្អហើយ ។

[ ៥៧៩ ] ឥសីទាំងឡាយរបស់យើងខ្ញុំ ដែលចួបជុំគ្នា មានឫទ្ធិធំប្រកបដោយគុណគឺឫទ្ធិ ល្បីទៅក្នុងទីឆ្ងាយ ខ្ញុំមានចិត្តជ្រះថ្លា សូមថ្វាយបង្គំលោកម្ចាស់ទាំងឡាយ ដែលប្រសើរក្នុងពួកមនុស្សក្នុងជីវលោកនេះ ។

[ ៥៨០ ] ( អនុសិស្សតាបស... ) ក្លិនរបស់ឥសីទាំងឡាយ ដែលបួសយូរ រមែងផ្សាយចេញចាកកាយទៅតាមខ្យល់ បពិត្រសហស្សនេត្ត សូមព្រះអង្គថយចេញចាកទីនេះ បពិត្រទេវរាជ ក្លិនរបស់ឥសីទាំងឡាយមិនស្អាតទេ ។

[ ៥៨១ ] ( សក្កទេវរាជ... ) ក្លិនរបស់ឥសីទាំងឡាយ ដែលបួសយូរ ចូរផ្សាយចេញចាកកាយទៅតាមខ្យល់ចុះ បពិត្រលោកដ៏ចម្រើន យើងខ្ញុំរមែងប្រាថ្នានូវក្លិននុ៎ះ ដូចបុគ្គលប្រាថ្នានូវកម្រងផ្កា មានផ្កាដ៏វិចិត្រ មានក្លិនក្រអូប ព្រោះទេវតាទាំងឡាយ ជាអ្នកមិនមានសេចក្តីសំគាល់ក្នុងក្លិននុ៎ះថា ជាបដិកូលទេ ។

[ ៥៨២ ] ( អនុសិស្សតាបស... ) ទេវរាជនោះឈ្មោះបុរិន្ទទៈ ឈ្មោះភូតបតី ជាអ្នកមានយស ឈ្មោះទេវានមិន្ទៈ ឈ្មោះមឃវា ឈ្មោះសុជម្បតិ ជាអ្នកញាំញី ( នូវពួក ) អសុរ ទ្រង់ប្រាថ្នានូវឱកាស ដើម្បីសួរប្រស្នា ។ ក្នុងទីនេះ បណ្តាឥសីជាបណ្ឌិតទាំងឡាយនេះ បណ្ឌិតណាហ្ន៎ ដែលព្រះរាជាទាំង ៣ ព្រះអង្គ ជាធំជាងមនុស្ស និងព្រះវាសវៈជាធំជាងពួកទេវតាត្រាស់សួរប្រស្នាដ៏ល្អិតហើយនឹងឆ្លើយបាន ។

[ ៥៨៣ ] ( ពួកឥសី... ) ឥសីឈ្មោះសរភង្គៈនេះ មានតបៈ ជាអ្នកវៀរចាកមេថុនធម្ម តាំងអំពីកើតមក ជាបុត្តនៃបុរោហិត ដែលជាអាចារ្យ ( របស់ព្រះរាជាពារាណសី ) មានសភាពរៀបរយល្អហើយ ឥសីឈ្មោះសរភង្គៈនោះ នឹងឆ្លើយនូវប្រស្នាទាំងឡាយរបស់ព្រះរាជាទាំងនោះបាន ។

[ ៥៨៤ ] ( អនុសិស្សតាបស... ) បពិត្រកោណ្ឌញ្ញៈ សូមលោកឆ្លើយនូវប្រស្នាទាំងឡាយ ឥសីទាំងឡាយមានសភាពដ៏ល្អ អាពធនាលោកបពិត្រកោណ្ឌញ្ញៈ ការដោះប្រស្នានុ៎ះ ជាទំនៀមតែងមាន ក្នុងពួកមនុស្សប្រស្នាណាមកកាន់សេចក្តីចម្រើន ប្រស្នានុ៎ះ ជាភារៈរបស់លោក ។

[ ៥៨៥ ] ( សរភង្គតាបស... ) លោកដ៏ចម្រើនទាំងឡាយ ខ្ញុំធ្វើឱកាសឲ្យហើយ ចូរសួរនូវប្រស្នាណានីមួយ ដែលលោកទាំងឡាយប្រាថ្នាហើយដោយចិត្តចុះ ព្រោះថា ខ្ញុំដឹងនូវលោកនេះ និងលោកខាងមុខ ដោយខ្លួនឯង នឹងឆ្លើយនូវប្រស្នានោះៗ ប្រាប់លោកទាំងឡាយបាន ។

[ ៥៨៦ ] ( អភិសម្ពុទ្ធគាថា ) លំដាប់នោះ ទេវរាជបុរិន្ទទៈ មឃវាសក្កៈអ្នកឃើញនូវប្រយោជន៍ បានសួរប្រស្នាជាដំបូងដែលខ្លួនប៉ងទុកហើយថា បុគ្គលសម្លាប់អ្វីមិនក្រៀមក្រំក្នុងកាលណាមួងឡើយ ឥសីទាំងឡាយសរសើរនូវការលះបង់អ្វី បុគ្គលគប្បីអត់ធន់ចំពោះពាក្យអាក្រក់ដែលបុគ្គលណាពោលហើយក្នុងលោកនេះ បពិត្រកោណ្ឌញ្ញៈ សូមលោកប្រាប់សេចក្តីនុ៎ះដល់ខ្ញុំ ។

[ ៥៨៧ ] ( សរភង្គតាបស... ) បុគ្គលសម្លាប់សេចក្តីក្រោធ រមែងមិនក្រៀមក្រំក្នុងកាលណាមួងឡើយ ឥសីទាំងឡាយ រមែងសរសើរនូវការលះបង់នូវសេចក្តីលុបគុណគេ បុគ្គលគប្បីអត់ធន់ចំពោះពាក្យអាក្រក់ដែលបុគ្គលទាំងពួងពោលហើយ ពួកសប្បុរសពោលនូវសេចក្តីអត់ធន់នុ៎ះថា ជាគុណដ៏ឧត្តម ។

[ ៥៨៨ ] ( សក្កទេវរាជ... ) បុគ្គលអាចអត់ធន់នូវពាក្យរបស់ជនទាំងពីរពួកបាន គឺបុគ្គលស្មើគ្នា និងបុគ្គលប្រសើរជាង ចុះបុគ្គលអត់ធន់នូវពាក្យរបស់បុគ្គលថោកទាប តើដូចម្តេច បពិត្រកោណ្ឌញ្ញៈ សូមលោកប្រាប់សេចក្តីនុ៎ះដល់ខ្ញុំ ។

[ ៥៨៩ ] ( សរភង្គតាបស... ) បុគ្គលអត់ធន់នូវពាក្យរបស់បុគ្គលដ៏ប្រសើរ ព្រោះសេចក្តីខ្លាច ឯបុគ្គលអត់ធន់នូវពាក្យរបស់បុគ្គលស្មើៗគ្នា ព្រោះហេតុនៃការប្រណាំងប្រជែង ចំណែកបុគ្គលណា ក្នុងលោកនេះ អត់ធន់នូវពាក្យរបស់បុគ្គលថោកទាបបាន សប្បុរសទាំងឡាយ ពោលនូវសេចក្តីអត់ធន់នុ៎ះ ( របស់បុគ្គលនោះ ) ថាជាគុណជាតិដ៏ខ្ពង់ខ្ពស់ ។

[ ៥៩០ ] ធ្វើដូចម្តេច បុគ្គលគប្បីដឹងច្បាស់នូវបុគ្គលប្រសើរជាង ឬបុគ្គលស្មើ ៗ គ្នា ឬក៏បុគ្គលថោកទាប ដែលមានសភាពបិទបាំងដោយឥរិយាបថ ៤ បាន សប្បុរសទាំងឡាយតែងប្រព្រឹត្តតាមរូបនៃបុគ្គលផ្សេងៗគ្នា ព្រោះហេតុនោះ បុគ្គលគួរអត់ធន់នូវពាក្យរបស់បុគ្គលទាំងពួង ។

[ ៥៩១ ] សប្បុរសអ្នកមានខន្តិ គប្បីបាននូវសេចក្តីចម្រើនណា សេនាធំព្រមដោយព្រះរាជា កាលច្បាំងគ្នា មិនគប្បីបាននូវសេចក្តីចម្រើននុ៎ះទេ ពៀរទាំងឡាយរបស់បុគ្គលអ្នកមានខន្តិជាកម្លាំង រមែងស្ងប់រម្ងាប់បាន ។

[ ៥៩២ ] ( សក្កទេវរាជ... ) ខ្ញុំរីករាយនឹងសុភាសិតរបស់លោកហើយ សូមសួរប្រស្នាដទៃនឹងលោកទៀត សូមលោកពោលប្រស្នានោះ ដូចយ៉ាងព្រះបាទទណ្ឌកី ព្រះបាទនាលិកីរៈ ព្រះបាទអជ្ជុនៈ និងព្រះបាទកលាពុ សូម

លោកប្រាប់នូវគតិរបស់ស្តេចទាំងនោះ ដែលមានបាបកម្មដ៏ធ្ងន់ តើព្រះរាជាទាំងនោះ ជាអ្នកបៀតបៀននូវឥសីទាំងឡាយ ទៅកើតក្នុងទីណា ។

[ ៥៩៣ ] ( សរភង្គតាបស... ) ព្រះបាទទណ្ឌកីព្រមទាំងជន ទាំងអ្នកដែនបានស្មោះដាក់តាបសឈ្មោះកីសវច្ឆៈ ព្រះអង្គមានមូលដាច់ហើយ ឆេះក្នុងនរកឈ្មោះកុក្កុលៈ រងើកភ្លើងទាំងឡាយធ្លាក់មិនដាច់លើកាយនៃព្រះអង្គ ។ ព្រះបាទនាលិកីរៈណា បានបៀតបៀនបព្វជិតទាំងឡាយ ជាអ្នកសង្រួម ជាអ្នករម្ងាប់បាប មិនប្រទូស្តកំពុងសំដែងធម៌ ឆ្កែទាំងឡាយចោមខាំស៊ីនូវព្រះបាទនាលិកីរៈនោះ ឲ្យអន្ទះអន្ទែងក្នុងបរលោក ។ ឯព្រះបាទអជ្ជុនៈ មានព្រះសិរចុះក្រោម មានព្រះបាទឡើងលើ ធ្លាក់ក្នុងនរកឈ្មោះសត្តិសូលៈ ព្រោះតែបៀតបៀននូវឥសីឈ្មោះអង្គីរសៈ ជាគោតមគោត្ត ជាអ្នកអត់ធន់ មានតបៈ ប្រព្រឹត្តធម៌ដ៏ប្រសើរអស់កាលយូរ ។ ព្រះបាទកលាពុណា បានកាត់ឲ្យជាកំណាត់តូចនិងកំណាត់ធំ នូវបព្វជិតដែលពោលនូវខន្តិ ជាអ្នករម្ងាប់បាប ជាអ្នកមិនប្រទូស្ត ព្រះបាទកលាពុ ( នោះ ) ក៏កើតឆេះនៅក្នុងនរកឈ្មោះអវីចិ មានកម្តៅដ៏ខ្លាំង មានវេទនាដ៏ផ្សាក្តៅ ជាទីគួរខ្លាច ។ បណ្ឌិតបានឮនូវនរកទាំងឡាយនេះផង នូវនរកទាំងឡាយដទៃដ៏លាមកលើសជាងនរកនេះផង គួរប្រព្រឹត្តធម៌ក្នុងសមណព្រាហ្មណ៍ទាំងឡាយ លុះធ្វើយ៉ាងនេះហើយ រមែងកើតក្នុងឋានសួគ៌ ។

[ ៥៩៤ ] ( សក្កទេវរាជ... ) ខ្ញុំត្រេកអរនឹងសុភាសិតរបស់លោកម្ចាស់ហើយ សូមសួរនូវប្រស្នាដទៃចំពោះលោកម្ចាស់ទៀត សូមលោកម្ចាស់

ប្រាប់នូវប្រស្នានោះ បណ្ឌិតទាំងឡាយ ពោលនូវបុគ្គលបែបដូចម្ដេចថាជាអ្នកមានសីល ពោលនូវបុគ្គលបែបដូចម្ដេចថាជាអ្នកមានប្រាជ្ញា ពោលនូវបុគ្គលបែបដូចម្ដេច ថាជាសប្បុរស សិរីមិនលះបង់នូវបុគ្គលបែបដូច ម្ដេច ។

[ ៥៩៥ ] ( សរភង្គតាបស... ) បុគ្គលណាក្នុងលោកនេះ ជាអ្នកសង្រួមដោយកាយ ដោយវាចា ទាំងមិនធ្វើនូវបាបតិចតួចដោយចិត្ត មិនពោលពាក្យឡេះឡោះ ព្រោះហេតុនៃខ្លួន បណ្ឌិតទាំងឡាយពោលនូវបុគ្គលបែបនោះ ថាជាអ្នកមានសីល ។ បុគ្គលណា កាលគិតនូវប្រស្នាដ៏ជ្រាលជ្រៅដោយចិត្ត ហើយមិនធ្វើនូវអំពើអាក្រក់ ដែលកន្លងនូវប្រយោជន៍ មិនលះបង់នូវចំណែកនៃប្រយោជន៍ ដែលមកក្នុងកាលគួរ បណ្ឌិតទាំងឡាយពោលនូវបុគ្គលបែបនោះ ថាជាអ្នកមានបញ្ញា ។ បុគ្គលណា ជាកតញ្ញូកតវេទី មានប្រាជ្ញា មានមិត្តល្អ មានការសេពគប់មាំ ធ្វើនូវកិច្ចដោយគោរពចំពោះបុគ្គលអ្នកដល់នូវសេចក្ដីទុក្ខ បណ្ឌិតទាំងឡាយ ពោលនូវបុគ្គលបែបនោះថាជាអ្នកសប្បុរស ។ បុគ្គលណា ជាអ្នកប្រកបដោយគុណទាំងពួងនេះ ជាអ្នកមានសទ្ធា មានចិត្តទន់ ជាអ្នកចែករំលែក ជាអ្នកដឹងនូវពាក្យ ( របស់ស្មូម ) សិរីមិនលះបង់នូវបុគ្គលជាអ្នកសង្គ្រោះ មានវាចាពីរោះ មានវាចាម៉ត់ចត់បែបនោះទេ ។

[ ៥៩៦ ] ( សក្កទេវរាជ... ) ខ្ញុំរីករាយនឹងសុភាសិតរបស់លោកហើយ សូមសួរនូវប្រស្នាដទៃនឹងលោកទៀត សូមលោកម្ចាស់ប្រាប់នូវ

ប្រស្នានោះ បណ្ឌិតទាំងឡាយពោលនូវសីលផង សិរីផង ធម៌របស់សប្បុរស ផង ប្រាជ្ញាផង តើគុណជាតិណាប្រសើរបំផុត ។

[ ៥៩៧ ] ( សរភង្គតាបស... ) អ្នកឈ្លាសវៃទាំងឡាយ ពោលថា ប្រាជ្ញាជាគុណជាតិប្រសើរបំផុត ដូចស្តេចនៃផ្កាយ ( ព្រះចន្ទ្រ ) ដ៏ប្រសើរ ជាងផ្កាយទាំងឡាយ ទុកជាសីលក្តី សិរីក្តី ធម៌របស់សប្បុរសក្តី ក៏ប្រព្រឹត្ត ទៅតាមបុគ្គលអ្នកមានប្រាជ្ញា ។

[ ៥៩៨ ] ( សក្កទេវរាជ... ) ខ្ញុំរីករាយនឹងសុភាសិតរបស់លោក ហើយ សូមសួរប្រស្នាដទៃនឹងលោកទៀត សូមលោកប្រាប់ប្រស្នានោះ បុគ្គល ក្នុងលោកនេះ ធ្វើដូចម្តេច ធ្វើការងារអ្វី ប្រព្រឹត្តដូចម្តេច សេពនូវអ្វី ទើប បាននូវប្រាជ្ញា សូមលោកម្ចាស់ ប្រាប់នូវបដិបទានៃប្រាជ្ញាក្នុងកាលឥឡូវនេះ បុគ្គលធ្វើដូចម្តេចទើបជាអ្នកមានប្រាជ្ញា ។

[ ៥៩៩ ] ( សរភង្គតាបស... ) បុគ្គលគប្បីសេពគប់នូវពួកអ្នក ចម្រើន ( ដោយប្រាជ្ញា ) អាចដឹងនូវហេតុដ៏ល្អិត ជាពហុស្សូត គប្បីជា អ្នករៀនផង ជាអ្នកសាកសួរផង គប្បីស្តាប់នូវសុភាសិតទាំងឡាយដោយ គោរពផង បុគ្គលធ្វើយ៉ាងនេះ ទើបជាអ្នកមានប្រាជ្ញា ។ បុគ្គលជាអ្នកប្រាជ្ញ នោះ ឃើញច្បាស់នូវកាមគុណទាំងឡាយថាមិនទៀង ថាជាទុក្ខ ថាជារោគ បុគ្គលឃើញច្បាស់យ៉ាងនេះ ទើបលះបង់នូវឆន្ទៈក្នុងកាមទាំងឡាយ ដែល ជាទុក្ខ ជាភ័យធំបាន ។ បុគ្គលនោះប្រាសចាករាគៈ កម្ចាត់បង់នូវទោសៈ ហើយ គប្បីចម្រើននូវមេត្តាចិត្តរកប្រមាណមិនបាន ដាក់ចុះនូវអាជ្ញាក្នុងសត្វ

ទាំងពួង ជាបុគ្គល គឺអ្នកណាមួយតិះដៀលមិនបាន រមែងទៅកើតក្នុងឋាន ព្រហ្ម ។

[ ៦០០ ] បពិត្រព្រះបាទអដ្ឋកៈ ការយាងមកនៃព្រះអង្គផង នៃព្រះបាទភីមរថៈផង នៃព្រះបាទកាលិង្គៈដែលមានតេជានុភាពដ៏រុងរឿងផង ជាព្រះរាជដំណើរមានឫទ្ធិដ៏ច្រើន ( ព្រោះ ) កាមរាគនៃព្រះអង្គទាំងអស់ បានលះបង់ហើយ ។

[ ៦០១ ] ( ព្រះរាជាទាំង ៣ ព្រះអង្គទ្រង់សរសើរថា ) លោកម្ចាស់បានដឹងច្បាស់នូវចិត្តរបស់បុគ្គលដទៃនុ៎ះ យ៉ាងនេះឯង ឯកាមរាគយើងខ្ញុំទាំងអស់គ្នាបានលះហើយ សូមលោកម្ចាស់ធ្វើឱកាស ដើម្បីអនុគ្រោះ ( បព្វជ្ជា ) ឲ្យយើងខ្ញុំបានដល់នូវគតិរបស់លោក ។

[ ៦០២ ] ( សរភង្គតាបស... ) អាត្មាភាពធ្វើឱកាស ដើម្បីអនុគ្រោះ ព្រោះថា មហារាជទាំងឡាយបានលះបង់នូវកាមរាគ ដោយប្រការដូច្នោះមែន មហារាជទាំងឡាយ ចូរញ៉ាំងកាយឲ្យជ្រួតជ្រាបដោយបីតិដ៏កើត ( អំពីឈាន ) ដ៏ធំទូលាយ ឲ្យមហារាជទាំងឡាយបានដល់នូវគតិរបស់អាត្មាភាព ។

[ ៦០៣ ] ( ព្រះរាជាទាំង ៣ ព្រះអង្គ... ) បពិត្រលោកអ្នកមានប្រាជ្ញាដូចផែនដី លោកម្ចាស់ពោលពាក្យណា ៗ យើងខ្ញុំនឹងធ្វើតាមពាក្យរបស់លោកទាំងអស់នោះ ៗ យើងខ្ញុំនឹងញ៉ាំងកាយឲ្យជ្រួតជ្រាបដោយបីតិដ៏ធំទូលាយ ឲ្យយើងខ្ញុំបានដល់នូវគតិរបស់លោក ។

[ ៦០៤ ] ( សរភង្គតាបស... ) ការបូជានេះ ពួកឥសីបានធ្វើហើយ ដល់ឥសីឈ្មោះកីសវច្ឆៈ ឥសីទាំងឡាយដ៏ចម្រើន មានសភាពល្អ ចូរទៅចុះ អ្នកទាំងឡាយ ចូរត្រេកអរក្នុងឈាន មានចិត្តតាំងមាំសព្វ ៗ កាលចុះ នេះជាសេចក្តីត្រេកអរដ៏ប្រសើររបស់បព្វជិត ។

[ ៦០៥ ] ( អភិសម្ពុទ្ធគាថា ) ទេវតាទាំងឡាយនោះ មានយសបានស្តាប់នូវគាថាទាំងឡាយដ៏ប្រកបដោយប្រយោជន៍ដ៏ក្រៃលែង ដែលឥសីជាបណ្ឌិតពោលល្អហើយ ជាអ្នកបានចេះដឹងហើយអនុមោទនា ចៀសចេញទៅកាន់ទេវបុរី ។ គាថាទាំងឡាយនេះ មានអត្ថមានព្យញ្ជនៈដ៏បរិសុទ្ធិ ដែលឥសីជាបណ្ឌិតពោលល្អហើយ បុគ្គលឯណានីមួយ ស្តាប់គាថាទាំងឡាយនេះ ធ្វើខ្ជួនឲ្យមានប្រយោជន៍ រមែងបាននូវគុណវិសេសខាងដើម និងខាងចុង លុះបានគុណវិសេសខាងដើមនិងខាងចុងហើយ គប្បីដល់នូវព្រះនិព្វានជាគុណមិនឃើញនូវមច្ចុរាជ ។

[ ៦០៦ ] ( ទ្រង់ប្រជុំជាតកថា ) សាលិស្សរតាបស គឺសារីបុត្ត មេណ្ឌិស្សរតាបស គឺកស្សប បព្វតតាបស គឺអនុរុទ្ធ ទេវិលតាបស គឺកច្ចាយនៈ អនុសិស្សតាបស គឺអានន្ទ កីសវច្ឆតាបសគឺកោលិតៈ នារទតាបសគឺឧទាយិត្ថេរ បរិស័ទ ( របស់ពួកតាបស ) គឺពុទ្ធបរិស័ទ សរភង្គតាបសជាពោធិសត្វ គឺតថាគត អ្នកទាំងឡាយចូរចាំទុកនូវជាតកយ៉ាងនេះចុះ ។

**ចប់ សរភង្គជាតក ទី ២ ។**

# អដ្ឋកថា

# សរភង្គជាតក

[ ៥៧៥-៦០៦ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធបរិនិព្វានរបស់ព្រះមហាមោគ្គល្លាន ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អលង្កតា កុណ្ឌលិនោ សុវត្ថា** ដូច្នេះជាដើម ។

បានឮថា ព្រះសារីបុត្តត្ថេរក្រាបទូលឲ្យព្រះតថាគត ដែលគង់នៅក្នុងវត្តជេតពន ទ្រង់អនុញ្ញាតបរិនិព្វានហើយ ធ្វើដំណើរទៅបរិនិព្វានក្នុងបន្ទប់ដែលលោកប្រសូតនៅឯនាលន្ទគ្រាម ។ ព្រះសាស្តាទ្រង់បានដំណឹងថា ព្រះសារីបុត្តបរិនិព្វានហើយ ទើបយាងទៅកាន់ក្រុងរាជគ្រឹះ គង់នៅក្នុងវេឡុវ័នវិហារ ។

កាលនោះ ព្រះមហាមោគ្គល្លានត្ថេរនៅត្រង់កាឡសិលាបទេស ក្បែរភ្នំឥសិគិលិ ។ ព្រះមហាមោគ្គល្លាននោះ ត្រាច់ទៅកាន់ទេវលោកខ្លះ ឧស្សទនរកខ្លះ ដោយភាពជាអ្នកដល់នូវទីបំផុតដោយកម្លាំងឫទ្ធិ ។ លោកឃើញឥស្សរិយយសធំរបស់ពុទ្ធសាវកក្នុងទេវលោក ឃើញទុក្ខធំរបស់តិរ្ថិយសាវកក្នុងឧស្សទនរក ហើយត្រឡប់មកកាន់មនុស្សលោក ប្រាប់ដល់មនុស្សទាំងឡាយថា ឧបាសកឈ្មោះនោះ ឧបាសិកាឈ្មោះនោះកើតឡើង សោយមហាសម្បត្តិក្នុងទេវលោកឈ្មោះនោះ សាវករបស់តិរ្ថិយនោះ ឈ្មោះនោះនិងឈ្មោះនោះ កើតក្នុងនរកជាដើម ក្នុងអបាយឈ្មោះនោះ ។ មនុស្សទាំងឡាយនាំគ្នាជ្រះថ្លាក្នុងព្រះសាសនា លះនូវពួកតិរ្ថិយចោល លាភសក្ការៈធំមានដល់សាវករបស់ព្រះពុទ្ធ ។ លាភសក្ការៈរបស់ពួកតិរ្ថិយក៏សាបសូន្យ ។ ពួកតិរ្ថិយទាំងនោះក៏នាំគ្នាចងអាឃាតក្នុងព្រះថេរៈថា កាលព្រះថេរៈនៅមានជីវិត

ឧបដ្ឋាករបស់ពួកយើងក៏បែកខ្ញែក លាភសក្ការៈក៏ថយចុះ ពួកយើងនឹងសម្លាប់ព្រះថេរៈ ។ ទើបពួកតិរ្ថិយទាំងឡាយជួលចោរឈ្មោះសមណកុត្តៈ ដោយតម្លៃទ្រព្យ ១០០០ ដើម្បីឲ្យសម្លាប់ព្រះថេរៈ ។ ចោរសមណកុត្តៈគិតថា អញនឹងសម្លាប់ព្រះថេរៈ ទើបទៅកាន់គុហាកាឡសិលាមួយអន្លើដោយបរិវារជាច្រើន ព្រះថេរៈឃើញចោរសមណកុត្តៈកំពុងដើរមក ទើបហោះគេចខ្លួនទៅដោយឫទ្ធិ ថ្ងៃនោះ ចោរឃើញព្រះថេរៈហោះ ទើបត្រឡប់ទៅវិញ បានមកជាប់ៗគ្នា រាល់ៗថ្ងៃអស់ ៦ ថ្ងៃ ឯព្រះថេរៈក៏គេចទៅដោយឫទ្ធិដូចសព្វដង ។ តែក្នុងថ្ងៃទី ៧ អបរាបរវេទនីយកម្ម ដែលព្រះថេរៈធ្វើក្នុងកាលមុន បានឱកាស ។ បានឮថា ក្នុងជាតិមុន ព្រះថេរៈជឿពាក្យរបស់ភរិយា បំណងសម្លាប់មាតាបិតា ទើបនាំទៅកាន់ព្រៃដោយយានតូច ធ្វើអាការដូចចោរ ឲ្យប្រាកដឡើងហើយ វាយមាតាបិតា មាតាបិតាទាំង ២ មើលមិនឃើញព្រោះមានភ្នែកពិការ ចាំបុត្តរបស់ខ្លួនមិនបាន ដោយសម្គាល់ថា នោះជាពួកចោរ ក៏យំរៀបរាប់ ដើម្បីប្រយោជន៍ចំពោះបុត្តតែម្យ៉ាងថា ឱកូនអើយ ឲ្យចោរពួកនោះសម្លាប់ពុកម៉ែចុះ ចូរកូនគេចយកតែរួចខ្លួនចុះ ។ កូននោះគិតថា មាតាបិតារបស់អញទាំង ២ នេះ សូម្បីត្រូវអញវាយ ក៏នៅតែយំរៀបរាប់ដើម្បីប្រយោជន៍ដល់អញតែម្យ៉ាង អញធ្វើកម្មមិនសមគួរឡើយ លំដាប់នោះ ទើបលួងលោមមាតាបិតា សម្តែងអាការដូចចោររត់ទៅ ហើយប្របាច់ដៃជើងរបស់លោកទាំង ២ ពោលថា សូមពុកនិងម៉ែកុំខ្លាចឡើយ ពួកចោរគេចទៅហើយ ហើយនាំត្រឡប់មកផ្ទះរបស់ខ្លួនវិញ ។

កម្មនោះ មិនបានឱកាស អស់កាលមានប្រមាណប៉ុណ្ណោះ តាំងនៅដូច គំនរភ្លើង ដែលផេះកប់ទុក ដូច្នោះ កម្មនោះហាក់ដូចស្ទុះរត់ចូលក្នុងសរីរៈ ដែលមិនមានទីបំផុតនេះ កម្មនេះបានឱកាសក្នុងទីណា រមែងឲ្យផលក្នុងទីនោះ ប្រៀបដូចសុនខដែលព្រានជួបម្រឹគ ហើយលែងឲ្យដេញជាប់តាមម្រឹគ ទាន់ក្នុងទីណា ក៏ខាំក្នុងទីនោះ ដូច្នោះ ទើបឈ្មោះថា បុគ្គលដែលផុតចាកកម្មនោះមិនមានឡើយ ព្រះថេរៈដឹងថា កម្មដែលខ្លួនធ្វើទុកនិងតាមមកទាន់ ទើបមិនបានគេចទៅ ព្រោះផលនៃកម្មនោះ ព្រះថេរៈមិនអាចហោះទៅក្នុងអាកាសបាន ។ ឫទ្ធិរបស់ព្រះថេរៈ សូម្បីអាចទូន្មាននន្ទោបនន្ទនាគរាជ និងអាចញុំាងវេជយន្តបសាទឲ្យញាប់ញ័របាន ក៏ដល់នូវភាពទុព្វល ព្រោះកម្លាំងនៃកម្ម ។ ចោរចាប់ព្រះថេរៈបាន វាយរហូតឆ្អឹងរបស់ព្រះថេរៈមានទំហំប៉ុនៗគ្រាប់អង្ករដែលបាក់ ដូចបុកចំបើងឲ្យទៅជាម្សៅដូច្នោះ ហើយបោះទៅត្រង់គុម្ពឈើមួយកន្លែង ដោយសម្គាល់ថា ព្រះថេរៈស្លាប់ហើយ ចោរនិងបរិវារក៏ចៀសចេញទៅ ។ ឯព្រះថេរៈបាននូវសតិហើយ គិតថា អញនឹងថ្វាយបង្គំលាព្រះសាស្តាសិន សឹមបរិនិព្វាន ដូច្នេះហើយ សមោធានអត្តភាពដោយកម្លាំងឈាន ហើយហោះទៅកាន់សម្នាក់របស់ព្រះសាស្តាតាមអាកាស ថ្វាយបង្គំព្រះសាស្តាហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន អាយុសង្ខាររបស់ខ្ញុំព្រះអង្គអស់ហើយ ខ្ញុំព្រះអង្គនឹងបរិនិព្វាន ។ ព្រះសាស្តាត្រាស់សួរថា ម្នាលមោគ្គល្លាន អ្នកនឹងបរិនិព្វានឬ ក៏ក្រាបទូលថា ករុណាព្រះអង្គ ព្រះសាស្តាត្រាស់សួរថា អ្នកនឹងបរិនិព្វានក្នុងទីណា ក៏ក្រាបទូលថា ត្រង់

ផ្ទាំងថ្ម ក្នុងគុហាកាឡសិលា ។ ព្រះសាស្តាត្រាស់ថា ម្នាលមោគ្គល្លាន បើដូច្នោះ អ្នកចូរពោលធម៌ដល់តថាគតហើយ សឹមទៅ ព្រោះពេលនេះ ការដែលបានឃើញសាវ័កដូចអ្នកមិនមានទៀតឡើយ ។ ព្រះមហាមោគ្គល្លាន ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងធ្វើតាមព្រះពុទ្ធតម្រាស់ ហើយហោះទៅលើអាកាសមួយដូរត្នោត សម្តែងឫទ្ធិមានប្រការផ្សេងៗ ដូចព្រះសារីបុត្តក្នុងថ្ងៃបរិនិព្វាន ពោលធម្មកថា ថ្វាយបង្គំព្រះបរមសាស្តាហើយ បរិនិព្វានក្នុងព្រៃ ត្រង់កាឡសិលាបទេស ។ ក្នុងវេលានោះឯង ទេវលោកទាំង ៦ ជាន់ ក៏កើតកោលាហល មួយរំពេចថា បានឮថា អាចារ្យរបស់ពួកយើងបរិនិព្វានហើយ ក៏នាំគ្នាកាន់គ្រឿងក្រអូប ផ្កាកម្រង ធូមគន្ធៈ គ្រឿងអប់ និងលម្អិតដែលជាទិព្វមួយអន្លើដោយឧសច្រើនប្រភេទមក សាងជើងថ្ករហើយដោយចន្ទន៍ក្រហម កម្ពស់ ៩៩ ហត្ថ ។ ព្រះសាស្តាគង់នៅក្បែរសពព្រះថេរៈ ត្រាស់ឲ្យបូជាសពរបស់ព្រះថេរៈ ។ ជុំវិញឈាបនដ្ឋាន ភ្លៀងផ្កាបានធ្លាក់ចុះមកក្នុងទីប្រមាណមួយយោជន៍ ពួកមនុស្សនៅចន្លោះទេវតា ពួកទេវតានៅចន្លោះពួកមនុស្ស បន្ទាប់អំពីទេវតា ពួកយក្ខទាំងឡាយ ក៏ឈរបន្ទាប់អំពីពួកយក្ខ គឺពួកគន្ធព្វ បន្ទាប់អំពីពួកគន្ធព្វ គឺពួកនាគ បន្ទាប់អំពីពួកនាគ គឺពួកគ្រុឌ បន្ទាប់អំពីពួកគ្រុឌ ជាពួកកិន្នរ បន្ទាប់ពីពួកកិន្នរ ក៏ជាឆត្រ បន្ទាប់អំពីឆត្រ ជាសុវណ្ណចាមរ បន្ទាប់ពីសុវណ្ណចាមរ ជាទង់ជ័យ បន្ទាប់ពីទង់ជ័យ ជាទង់ផ្កាលា បុគ្គលដែលមកប្រជុំទាំងអស់ នាំគ្នាលេងសាធុកីឡាអស់ ៧ ថ្ងៃ ។ ព្រះសាស្តាត្រាស់ឲ្យយកធាតុរបស់ព្រះថេរៈ មក

ធ្វើចេតិយ បញ្ចុះត្រង់ខ្លោងទ្វារវត្តវេឡុវ័ន ។

កាលនោះ ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ព្រះសារីបុត្តត្ថេរមិនបានទទួលនូវការលើកតម្កើងធំ ក្នុងសម្នាក់ព្រះសម្មាសម្ពុទ្ធ ព្រោះមិនបានបរិនិព្វានក្នុងទីជិតព្រះតថាគត ព្រះមហាមោគ្គល្លានត្ថេរ បានទទួលកិត្តិយសធំក្រៃលែង ព្រោះបរិនិព្វានក្នុងទីជិតព្រះសម្ពុទ្ធ ។ ព្រះសាស្ដាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកប្រជុំសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយ ក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានមិនមែនបាននូវការរាប់អាន អំពីសម្នាក់នៃតថាគត តែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ក៏ធ្លាប់បានហើយដូចគ្នា ហើយទ្រង់ក៏នាំអតីតនិទានមកត្រាស់ដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ នៅក្នុងនគរពារាណសី ព្រះពោធិសត្វ បដិសន្ធិក្នុងឧទររបស់ព្រាហ្មណីភរិយារបស់បុរោហិត លុះគ្រប់ ១០ ខែក៏ប្រសូតចាកផ្ទៃមាតាក្នុងវេលាទៀបភ្លឺ ។ ខណៈនោះ អាវុធទាំងពួងក្នុងនគរពារាណសី មានអាណាខេត្ត ១២ យោជន៍ ក៏រុងរឿងឡើង ។ ក្នុងខណៈដែលបុត្តប្រសូត បុរោហិតចេញមកខាងក្រៅ សម្លឹងមើលអាកាស ឃើញនិមិត្តគ្រឿងប្រកបនក្ខត្តឫក្ស ក៏ដឹងថា កុមារនេះ ជាកំពូលជាងអ្នកខ្មាន់ធ្នូទាំងពួង ក្នុងជម្ពូទ្វីប ព្រោះជាអ្នកកើតដោយនក្ខត្តឫក្សនេះ ទើបបិតាទៅកាន់រាជត្រកូលអំពីព្រលឹម ទូលសួរភាពដែលព្រះរាជាផ្ទំ

ជាសុខ ។ កាលព្រះរាជាត្រាស់ថា នែលោកអាចារ្យ ឲ្យយើងមានសេចក្តីសុខអំពីណា យប់មិញ អាវុធក្នុងព្រះរាជវាំង ភ្លឺរន្ទាលប្រាលផ្លៀទាំងអស់ ទើបបុរោហិតក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់កុំភិតភ័យឡើយ មិនមែនអាវុធភ្លឺតែក្នុងព្រះរាជវាំងប៉ុណ្ណោះ អាវុធក្នុងព្រះនគរក្នុងទីគ្រប់កន្លែងក៏ភ្លឺដូចគ្នា ព្រោះថ្ងៃនេះ កុមារកើតក្នុងផ្ទះរបស់ទូលព្រះបង្គំ ។ ព្រះរាជាត្រាស់ថា លោកអាចារ្យ កុមាររបស់លោកកើតហើយយ៉ាងនេះ តើនឹងមានហេតុកេទដូចម្តេច បុរោហិតក្រាបទូលថា បពិត្រព្រះអង្គ មិនមានហេតុកេទអ្វីឡើយ តែកុមារនោះ នឹងបានជាកំពូលនៃអ្នកបាញ់ធ្នូទាំងឡាយក្នុងជម្ពូទ្វីប ។ ព្រះរាជាត្រាស់ថា សាធុ លោកអាចារ្យ បើដូច្នោះ ចូរលោកថែរក្សាក្មេងនោះឲ្យល្អ ហើយលើកឲ្យយើងក្នុងកាលដែលគេចម្រើនវ័យ ដូច្នេះហើយ ត្រាស់ឲ្យប្រទានទ្រព្យ ១០០០ ជាថ្លៃទឹកដោះ ។ បុរោហិតនោះទទួលទ្រព្យហើយទៅផ្ទះរបស់ខ្លួន ប្រគល់ឲ្យព្រាហ្មណី ក្នុងថ្ងៃដាក់ឈ្មោះកូនប្រុសបានដាក់ឈ្មោះថា ជោតិបាល ព្រោះក្នុងខណៈដែលកុមារកើត អាវុធមានពន្លឺ ។ ជោតិបាលកុមារចម្រើនវ័យដោយបរិវារជាច្រើន ក្នុងកាលអាយុបាន ១៦ ឆ្នាំ ជាអ្នកមានរូបឧត្តមសមសក្តិ បិតារបស់ជោតិបាលកុមារ សម្លឹងមើលសរីរសម្បត្តិ ទើបប្រគល់ទ្រព្យ ១០០០ ប្រាប់ថា នែកូន ចូរឯងទៅកាន់នគរតក្កសិលា រៀនសិល្បសាស្ត្រ ក្នុងសម្នាក់អាចារ្យទិសាបាមោក្ខចុះ ។ ជោតិបាលកុមារទទួលពាក្យថា សាធុ ហើយកាន់យកទ្រព្យចំណែករបស់អាចារ្យ ថ្វាយបង្គំមាតាបិតាហើយ ទៅកាន់នគរតក្កសិលានោះ ប្រគល់ទ្រព្យឲ្យអាចារ្យមួយ

ពាន់ហើយ ចាប់ផ្ដើមរៀនសិល្បវិជ្ជា ដល់នូវការសម្រេច ក្នុងមួយសប្ដាហ៍ប៉ុណ្ណោះ គ្រានោះ អាចារ្យក៏ត្រេកអរទើបឲ្យព្រះខ័នរតនៈ ធ្នូស្នែងពពែ បំពង់ព្រួញដែលប្រកបគ្នា ជារបស់ផ្ទាល់ខ្លួន មួយអន្ទើដោយអាវក្រោះនិងក្បាំងមុខរបស់ខ្លួន ហើយប្រគល់មាណពទាំង ៥០០ ដល់ជោតិបាលកុមារនោះថា នែបាជោតិបាល យើងចាស់ហើយ ឥឡូវនេះ ឯងជួយបង្រៀនមាណពទាំងនេះផងចុះ ។ ព្រះពោធិ សត្វទទួលគ្រឿងឧបករណ៍គ្រប់យ៉ាងហើយ ថ្វាយបង្គំលាអាចារ្យ មានមុខមកកាន់នគរពារាណសី សួរសុខទុក្ខមាតាបិតាហើយឈរ ។

លំដាប់នោះ បុរោហិតដែលជាបិតាក៏សួរជោតិបាលកុមារ ដែលថ្វាយបង្គំហើយឈរថា នែកូន ឯងរៀនសិប្បវិជ្ជាចប់ហើយឬ មាណពឆ្លើយថា បាទលោកឪពុក ។ បុរោហិតជាបិតាស្ដាប់ហើយ ទៅកាន់រាជត្រកូលក្រាបទូលថា បពិត្រព្រះអង្គ កូនទូលព្រះបង្គំរៀនសិប្បវិជ្ជាត្រឡប់មកហើយ គេនឹងធ្វើដូចម្ដេច ព្រះរាជាត្រាស់ថា លោកអាចារ្យចូរឲ្យគេបម្រើយើងចុះ ។ បុរោ-ហិតក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់ពិចារណាដល់ប្រាក់បំណាច់របស់កូនទូលព្រះបង្គំ ព្រះរាជាត្រាស់ថា យើងនឹងឲ្យ ១០០០ រាល់ៗថ្ងៃ ។ បុរោហិតទទួលព្រះតម្រាស់ហើយ ទើបទៅផ្ទះ ហៅកុមារមកប្រាប់ថា នែកូនឯងចូរទទួលបម្រើព្រះរាជាចុះ ។ តាំងអំពីនោះមក ជោតិបាលកុមារ ក៏បម្រើព្រះរាជា បានទ្រព្យមួយថ្ងៃ ១០០០ រាល់ថ្ងៃ ពួកខ្ញុំរាជការទាំងឡាយនាំគ្នាពោលទោសថា ពួកយើងមិនឃើញការងារដែលជោតិបាលធ្វើ តែគេទទួល

ប្រាក់ មួយថ្ងៃ ១ ពាន់ៗ ពួកយើងចង់ឃើញសិប្បៈរបស់គេ ។ ព្រះរាជាទ្រង់ស្តាប់ពាក្យរបស់ជននោះ ទើបត្រាស់ប្រាប់បុរោហិត បុរោហិតទូលស្នងព្រះរាជតម្រាស់ថា សាធុ ព្រះអង្គ ហើយប្រាប់ដល់បុត្តរបស់ខ្លួន ។ ជោតិបាលកុមារ ពោលថា សាធុ លោកឪពុក ក្នុងថ្ងៃទី ៧ រាប់អំពីថ្ងៃនេះ ខ្ញុំនឹងសម្តែងសិប្បៈ ម្យ៉ាងទៀត សូមព្រះរាជាត្រាស់ហៅនាយខ្មាន់ធ្នូ ក្នុងដែនរបស់ទ្រង់មកប្រជុំគ្នា ។ បុរោហិតបានស្តាប់ដូច្នោះ ទើបទៅក្រាបទូលសេចក្តីនោះដល់ព្រះរាជា ព្រះរាជាឲ្យវាយស្គរប្រកាសក្នុងព្រះនគរ ហើយមានព្រះរាជឱង្ការឲ្យនាយខ្មាន់ធ្នូមកប្រជុំគ្នា ។ ខ្មាន់ធ្នូចំនួន ៦ ម៉ឺននាក់មកប្រជុំគ្នាហើយ ។ ព្រះរាជាទ្រង់ជ្រាបថា នាយខ្មាន់ធ្នូ ប្រជុំគ្នាហើយ ទើបត្រាស់ឲ្យវាយស្គរប្រកាសថា អ្នកនគរទាំងអស់ ចូរមកមើលសិប្បរបស់ជោតិបាលកុមារហើយ រៀបចំលានព្រះរាជវាំង ចោមរោមទៅដោយមហាជន ប្រថាប់គង់លើបល្ល័ង្កដ៏ប្រសើរ ហើយទ្រង់បញ្ជូនរាជបុរសឲ្យហៅជោតិបាលកុមារមកថា ជោតិ-បាលកុមារចូរមកចុះ ។ ជោតិបាលកុមារ ក៏ស៊កធ្នូ បំពង់ធ្នូ អាវក្រោះ និងក្បាំងមុខដែលអាចារ្យឲ្យក្នុងរវាងសំពត់ស្លៀក ឲ្យមនុស្សកាន់ព្រះខ័នហើយដើរមកកាន់សម្នាក់ព្រះរាជា ដោយអាកប្បកិរិយាប្រក្រតី បានឈរក្នុងទីសមគួរនាចំណែកម្ខាង ពួកនាយខ្មាន់ធ្នូឲ្យសញ្ញាគ្នាថា បានឮថា ជោតិបាលកុមារមកដើម្បីសម្តែងសិប្បៈបាញ់ធ្នូ តែមិនកាន់ធ្នូមក ប្រហែលជាចង់យកធ្នូអំពីដៃរបស់ពួកយើង ពួកយើងកុំឲ្យធ្នូដល់គេឡើយ ។ ព្រះរាជាហៅជោតិបាលកុមារមកត្រាស់ថា ចូរអ្នកសម្តែងសិប្បៈចុះ ។ ជោតិបាលកុមារ ឲ្យ

បាំងវាំងននហើយឈរខាងក្នុងវាំងនន លាសំពត់សាដកចេញ ពាក់ក្រោះ ហើយពាក់ក្បាំងត្រង់ក្បាល លើកខ្សែមានពណ៌ដូចកែវប្រពាលត្រង់ធ្នូស្នែង ពពែឡើងហើយ ស្ពាយបំពង់ព្រួញទុកខាងក្រោយ ព្រះខ័នទុកខាងមុខ យកខ្នងក្របកខែព្រួញ ដែលមានចុងដូចពេជ្រ ហើយបើកវាំងននចេញមក ដូចនាគកុមារដែលប្រដាប់តាក់តែងហើយ ជ្រែកផែនដីចេញមក ដូច្នោះ ។ ដើរទៅសម្តែងសេចក្តីគោរពដល់ព្រះរាជា ហើយឈរ មហាជនឃើញកុមារនោះហើយ នាំគ្នាអបអរទះដៃទ្រហឹងអឺងកង ។ ព្រះរាជាត្រាស់ថា នែជោតិបាលចូរអ្នកសម្តែងសិប្បៈចុះ ជោតិបាលកុមារក្រាបទូលថា បពិត្រព្រះអង្គ បណ្តានាយខ្មាន់ធ្នូរបស់ទ្រង់ សូមទ្រង់ឲ្យខ្មាន់ធ្នូ ៤ នាក់ គឺអ្នកដែលបាញ់ដូចផ្លេកបន្ទោរ ១ អ្នកបាញ់មិនខុសសូម្បីតែរោមទ្រាយក៏បាញ់បាន ១ អ្នកបាញ់តាមសំឡេងដែលបានឮ ១ និងអ្នកបាញ់បំបាក់ព្រួញ ដែលបាញ់មកបាន ១ ។ ព្រះរាជាទ្រង់ឲ្យហៅជនទាំង ៤ នោះមក ។

ព្រះមហាសត្វរៀបចំមណ្ឌបខាងក្នុងទីកំណត់ ៤ ជ្រុង ក្នុងលានព្រះរាជវាំង ឲ្យនាយខ្មាន់ធ្នូទាំង ៤ ឈរក្នុងទិសទាំង ៤ ហើយឲ្យព្រួញម្នាក់ ៣ ម៉ឺនព្រួញ ដល់ខ្មាន់ធ្នូទាំងនោះ ឲ្យអ្នកឈរចាំហុចព្រួញម្នាក់ឈរក្បែរខ្មាន់ធ្នូទាំងនោះ ហើយព្រះពោធិសត្វកាន់ព្រួញដែលមានចុងដូចពេជ្រ ឈរត្រង់កណ្តាលមណ្ឌប ក្រាបទូលព្រះរាជាថា បពិត្រមហារាជ ខ្មាន់ធ្នូទាំង ៤ នេះចូរបាញ់ទូលបង្គំព្រមគ្នាចុះ ទូលបង្គំនឹងឃាត់ព្រួញដែលជនទាំងនេះបាញ់មក ព្រះរាជាត្រាស់ថា ពួកអ្នកចូរធ្វើយ៉ាងនេះ ។ ពួកនាយខ្មាន់ធ្នូក្រាបទូលថា

បពិត្រព្រះអង្គ ទូលព្រះបង្គំជានាយខ្មាន់ធ្នូ បាញ់រហ័សដូចផ្លេកបន្ទោរ បាញ់មិនខុសសូម្បីត្រឹមតែរោមទ្រាយ បាញ់តាមសំឡេងដែលបានឮ បាញ់បំបាក់ព្រួញដែលគេបាញ់មក ជោតិបាលជាកំលោះ ទូលព្រះបង្គំមិនហ៊ានបាញ់ឡើយ ព្រះមហាសត្វពោលថា បើពួកលោកអាច អញ្ជើញបាញ់ខ្ញុំចុះ ។ ខ្មាន់ធ្នូទាំងនោះ ទទួលថា សាធុ ទើបលែងព្រួញទៅព្រមគ្នា ព្រះមហាសត្វយកព្រួញចុងពេជ្រ វាយព្រួញទាំងនោះឲ្យធ្លាក់ចុះក្នុងទិសទាំង ៤ ដូចធ្វើរបងព័ទ្ធគល់ពោធិព្រឹក្ស ឲ្យគល់ព្រួញទៅតាមគល់ព្រួញ ខ្នងព្រួញទៅតាមខ្នងព្រួញ ចុងព្រួញទៅតាមចុងព្រួញ មិនឲ្យបញ្ច្រាសទិសគ្នា បានធ្វើដូចជាបន្ទប់ព្រួញ រហូតព្រួញរបស់នាយខ្មាន់ធ្នូបាញ់មកអស់ ។ ព្រះមហាសត្វដឹងថាព្រួញរបស់ខ្មាន់ធ្នូអស់ហើយ មិនញាំងបន្ទប់ព្រួញឲ្យបែកធ្លាយ លោតឡើងទៅគាល់ក្បែរព្រះរាជា មហាជននាំគ្នាហ៊ោកញ្ជ្រៀវ ទះដៃកងរំពង ផ្ទាត់ម្រាមដៃធ្វើកោលាហលធំ បោះសំពត់និងគ្រឿងអាភរណៈឡើងទៅលើ រហូតមានទ្រព្យ ១៨ កោដិ ជាគំនរយ៉ាងនេះ ។ សម័យនោះ ព្រះរាជាត្រាស់សួរជោតិបាលកុមារថា នែបាជោតិបាល នេះគេហៅសិប្បៈអ្វី ព្រះពោធិសត្វក្រាបទូលថា បពិត្រព្រះអង្គ នេះឈ្មោះថា សរបដិពាហនៈ គឺគ្រឿងឃាត់កូនសរ ព្រះរាជាត្រាស់សួរថា អ្នកដទៃដែលធ្វើបានយ៉ាងនេះមានឬ ព្រះមហាសត្វក្រាបទូលថា បពិត្រព្រះអង្គ បើវៀរទូលព្រះបង្គំចេញហើយ អ្នកដទៃក្នុងជម្ពូទ្វីបទាំងមូលមិនមានទេ ព្រះរាជាត្រាស់សួរថា នែជោតិបាល អ្នកនឹងសម្តែងសិប្បៈអ្វីទៀត ព្រះពោធិសត្វក្រាបទូលថា បពិត្រព្រះអង្គ បើនាយខ្មាន់ធ្នូទាំង

៤ ឈរក្នុងទិសទាំង ៤ មិនអាចបាញ់ទូលបង្គំបានសោត បពិត្រព្រះអង្គ ទូលបង្គំនឹងបាញ់ជនទាំង ៤ ដែលឈរក្នុងទិសទាំង ៤ ដោយព្រួញ ១ ប៉ុណ្ណោះ ។ អ្នកខ្មាន់ធ្នូមិនហ៊ានឈរក្នុងទិសទាំង ៤ ឡើយ ។ ទើបព្រះមហាសត្វ ឲ្យយកដើមចេកដាក់តាមជ្រុងទាំង ៤ ហើយយកអំបោះពណ៌ក្រហម ចងព្រួញ បាញ់ដើមចេកទី ១ ព្រួញធ្លុះហើយត្រូវដើមចេកមួយទៀត ហើយបត់ទៅត្រូវដើមចេកទី ៣ ហើយវិលមកត្រូវដើមចេកទី ៤ ព្រួញក៏ទម្លុះដើមចេកទី ១ វិញ ក៏មកតាំងនៅក្នុងដៃរបស់ព្រះពោធិសត្វវិញ ដើមចេកទាំងឡាយត្រូវអំបោះដោតហើយ តាំងនៅបាន ។ មហាជនបន្លឺសំឡេងកក្រើក រំពើករាប់ពាន់ ។ ព្រះរាជាត្រាស់សួរថា នេះជាសិប្បៈអ្វី ព្រះមហាសត្វឆ្លើយថា បពិត្រព្រះអង្គ នេះឈ្មោះចក្កវិទ្ធសិប្បៈ គឺបាញ់ឲ្យព្រួញរត់ជារង្វង់ដូចចក្ក ។ ព្រះរាជាត្រាស់ថា ចូរអ្នកសម្តែងសិប្បៈដទៃទៀតចុះ ។ ព្រះមហាសត្វក៏សម្តែងសិប្បៈឈ្មោះ សរលដ្ឋិ គឺសិប្បៈឈើច្រត់ សិប្បៈឈ្មោះសរជ្ជុ គឺសិប្បៈជារូបខ្សែ សិប្បៈឈ្មោះសរវេណិ គឺសិប្បៈផ្នួងសក់ សិប្បៈឈ្មោះសរបាសាទៈ គឺសិប្បៈរូបប្រាសាទ សិប្បៈឈ្មោះសរមណ្ឌប គឺសិប្បៈរូបមណ្ឌប សិប្បៈឈ្មោះសរសោបាណ គឺសិប្បៈរូបជណ្តើរ សិប្បៈឈ្មោះសរមណ្ឌល គឺសិប្បៈរូបទីលាន សិប្បៈឈ្មោះសរបាការ គឺសិប្បៈរូបកំពែង សិប្បៈឈ្មោះសរវន គឺសិប្បៈរូបព្រៃ សិប្បៈឈ្មោះសរបោក្ខរណិ គឺសិប្បៈរូបស្រះបោក្ខរណី សិប្បៈឈ្មោះសរបទុម គឺសិប្បៈរូបផ្កាឈូក សិប្បៈឈ្មោះសរបុប្ផ គឺសិប្បៈរូបផ្កាឈើ សិប្បៈឈ្មោះសរវស្ស គឺសិប្បៈភ្លៀង

ព្រួញ ។ កាលព្រះមហាសត្វសម្ដែងសិប្បៈ ១២ យ៉ាង ដែលមិនទូទៅដល់ជនដទៃយ៉ាងនេះហើយ ទម្លាយនូវប្រជុំធំ ៧ ដង ដែលមិនទូទៅដល់ជនដទៃ ។ ព្រះមហាសត្វបាញ់ឈើសង្កែកម្រាស់ ៨ ធ្នាប់ បាញ់ឈើធ្នង់កម្រាស់ ៤ ធ្នាប់ បាញ់ទង់ដែងកម្រាស់ ២ ធ្នាប់ បាញ់បន្ទះដែកកម្រាស់ ១ ធ្នាប់ បាញ់បន្ទះក្ដារ ១០០ បន្ទះ ឲ្យជាប់គ្នាតែមួយ បាញ់ព្រួញទៅខាងមុខរទេះដែលដាក់ស្លឹកឈើ រទេះដែលដាក់ខ្សាច់ និងរទេះដែលដាក់បន្ទះក្ដារឲ្យធ្លុះចេញទៅខាងក្រោយ បាញ់ពីក្រោយឲ្យធ្លុះទៅខាងមុខ បាញ់ទៅក្នុងទឹកចម្ងាយ ៤ ឧសភ បាញ់ទៅលើគោកចម្ងាយ ៨ ឧសភ បាញ់រោមទ្រាយក្នុងចម្ងាយ ១ ឧសភ ដោយដាក់ផ្លែត្រប់ជាសញ្ញា កាលជោតិបាលកុមារសម្ដែងសិប្បៈមានប្រមាណប៉ុណ្ណេះ ព្រះអាទិត្យក៏អស្តង្គតទៅ ។ គ្រានោះ ព្រះរាជាត្រាស់ប្រទានតំណែង ជាសេនាបតីដល់ជោតិបាលថា នែជោតិបាល ថ្ងៃនេះយប់ទៅហើយ ស្អែកនេះ នឹងធ្វើសក្ការៈប្រគល់តំណែងសេនាបតី ចូរអ្នកទៅកាត់សក់ កោរពុកមាត់ ងូតទឹក ហើយមកចុះ ដូច្នេះហើយ បានព្រះរាជទានទ្រព្យមួយសែនដើម្បីជាតម្លៃក្នុងថ្ងៃនោះ ។

ព្រះមហាសត្វគិតថា អញមិនត្រូវការដោយទ្រព្យនេះទេ ទើបឲ្យទ្រព្យ ១៨ កោដិ ដល់ម្ចាស់ទ្រព្យវិញ ហើយទៅងូតទឹកជាមួយបរិវារ ឲ្យជាងកាត់សក់ កោរពុកមាត់ ងូតទឹក ប្រដាប់ដោយសព្វាលង្ការ ហើយទៅកាន់ផ្ទះដោយសិរីដែលមិនមានអ្វីប្រៀប បរិភោគភោជនមានរសប្រសើរផ្សេងៗ ស្រេចបាច់ហើយ ចូលកាន់ដំណេកក្នុងទីដេកដ៏មានសិរី ដេកអស់ ២ យាម ភ្ញាក់

ឡើងក្នុងបច្ឆិមយាម ក្រោកឡើងអង្គុយពត់ភ្នែនលើដំណេក ពិចារណាមើលខាងដើម កណ្ដាល និងខាងចុងនៃសិប្បៈរបស់ខ្លួន ត្រិះរិះថា ការញុំាងអ្នកដទៃឲ្យស្លាប់ រមែងប្រាកដក្នុងខាងដើមនៃសិប្បៈរបស់អញ ការបរិភោគប្រើប្រាស់ដោយអំណាចនៃកិលេស ប្រាកដត្រង់កណ្ដាល ការកើតក្នុងនរកប្រាកដនៅខាងចុង ឯបាណាតិបាត និងការប្រមាទ ព្រោះស្រវឹងក្រៃលែងក្នុងការបរិភោគប្រើប្រាស់ ដោយអំណាចកិលេស រមែងឲ្យបដិសន្ធិក្នុងនរក ព្រះរាជាទ្រង់ព្រះរាជទានតំណែងសេនាបតីធំក្រៃលែងដល់អញ អញនឹងជាអ្នកមានឥស្សរិយយសធំ ភរិយា កូនប្រុសស្រីនឹងមានច្រើន វត្ថុដែលជាទីតាំងនៃកិលេសសម្បូរហើយ ជារបស់លះបានដោយលំបាក អញគួរចេញទៅព្រៃម្នាក់ឯង ហើយបួសជាឥសីក្នុងកាលឥឡូវនេះ ទើបក្រោកឡើងចាកមហាសយនៈ មិនឲ្យអ្នកណាដឹង ចុះអំពីប្រាសាទចេញតាមអគ្គទ្វារ ចូលព្រៃម្នាក់ឯង កាត់តាមព្រៃខិត អស់ចម្ងាយផ្លូវ ៣ យោជន៍ ដល់ឆ្នេរស្ទឹងគោធាវរី ។ សក្កទេវរាជទ្រង់ជ្រាបថា ជោតិបាលកុមារចេញបួសហើយ ទើបហៅវិស្សកម្មទេវបុត្តមកត្រាស់ថា នែបា ជោតិបាលកុមារចេញអភិនេស្ក្រមណ៍ នឹងមានសមាគមធំ ចូរឯងនិម្មិតអាស្រមត្រង់កបិដ្ឋវ័ន ក្បែរឆ្នេរស្ទឹងគោធាវរី និងត្រៀមបរិក្ខាររបស់បព្វជិតទុកឲ្យស្រេច ។ វិស្សកម្មទេវបុត្តនោះ បានធ្វើតាមទេវបញ្ជាគ្រប់ប្រការ ។

ព្រះមហាសត្វដល់ទីនោះហើយ ឃើញផ្លូវមានស្នាមដើរបានតែមនុស្សម្នាក់ គិតថា នឹងមានទីលំនៅរបស់ពួកបព្វជិត ទើបចូលទៅកាន់កបិដ្ឋវ័នតាម

ផ្លូវនោះ ក៏មិនជួបអ្នកណា ទើបចូលទៅកាន់បណ្ណសាលា ឃើញបរិក្ខារ របស់ពួកបព្វជិតគិតថា ប្រហែលជាសក្កទេវរាជទ្រង់ជ្រាបថា អញចេញ អភិនេស្រ្កមណ៍ ទើបដោះសំពត់សាដកចេញ ស្លៀកដណ្តប់សំពត់ក្រងដោយ ស្បូវក្ងាំងពណ៌ក្រហម ធ្វើស្បែកខ្លាធៀងស្មាម្ខាង មូរមណ្ឌលជដា លើក អម្រែកដាក់លើស្មា កាន់ឈើប្រត់មនុស្សចាស់ ចេញអំពីបណ្ណសាលាឡើង កាន់ទីចង្ក្រម ហើយចង្ក្រមទៅមកៗ អស់វារៈបន្តិចបន្តួច ញុំាងព្រៃឲ្យរុង រឿងដោយសិរី គឺបព្វជ្ជា ធ្វើកសិណបរិកម្ម ចាប់តាំងពីបួសហើយ ក្នុងថ្ងៃ ទី ៧ ញុំាងសមាបត្តិ ៨ អភិញ្ញា ៥ ឲ្យកើតឡើង ជាអ្នកមានផ្លៃឈើ ឫស ឈើក្នុងព្រៃជាអាហារ ដោយឧញ្ឆាចរិយវត្ត ( វត្តគឺការត្រាច់សន្សំស្បៀង ចិញ្ចឹមជីវិត ) ម្នាក់ឯងប៉ុណ្ណោះ ។ មាតាបិតា មិត្តសម្លាញ់ជាដើម និងពួក ញាតិរបស់ជោតិបាលនោះ កាលមិនឃើញជោតិបាលកុមារ ក៏កន្ទក់កន្ទេញ បរិទេវនាការត្រាច់ទៅ ។

សម័យនោះ ព្រានព្រៃម្នាក់ចូលទៅឃើញព្រះមហាសត្វ អង្គុយត្រង់ អាស្រមបទ ក្នុងកបិដ្ឋវ័ន ( ព្រៃខ្វិត ) ស្គាល់ព្រះពោធិសត្វ បានធ្វើ បដិសណ្ឋារៈជាមួយព្រះមហាសត្វហើយ ត្រឡប់ទៅកាន់ព្រះនគរ ប្រាប់ម្តាយ ឪពុករបស់លោកឲ្យជ្រាប ។ មាតាបិតារបស់ព្រះមហាសត្វ ក៏ក្រាបទូលឲ្យ ព្រះរាជាទ្រង់ជ្រាប ព្រះរាជាត្រាស់ថា មកយើងនឹងទៅសួរសុខទុក្ខ ជោតិ បាលតាបសនោះ ហើយនាំមាតាបិតារបស់លោក ចោមរោមដោយមហា- ជន ចូលដល់ឆ្នេរស៊ឹងគោធាវរី តាមផ្លូវដែលព្រានព្រៃប្រាប់ ។ ព្រះពោធិ

សត្វមកកាន់ច្នៃស្ទឹង អង្គុយលើអាកាសសម្ដែងធម៌ អញ្ជើញជនទាំងអស់ឲ្យចូលទៅកាន់អាស្រម អង្គុយលើអាកាសនោះឯង ប្រកាសទោសក្នុងកាមទាំងឡាយ ហើយសម្ដែងធម៌ដល់ជនទាំងនោះ ជនទាំងអស់ ចាប់តាំងពីព្រះរាជាទៅ នាំគ្នាបួសហើយ ។ ព្រះពោធិសត្វមានពួកឥសីជាបរិវារនៅក្នុងទីនោះឯង ។ ចំណេរតមក ដំណឹងដែលតាបសស្នាក់នៅក្នុងទីនោះ បានល្បីខ្ចរខ្ចាយទៅពេញជម្ពូទ្វីបទាំងមូល ។ ព្រះរាជាអន្លដទៃៗ មួយអន្ទើដោយអ្នកដែន នាំគ្នាមកបួសក្នុងសម្នាក់របស់ព្រះពោធិសត្វនោះ ក្លាយជាមហាសមាគម មានបរិស័ទដល់មួយសែន ដោយលំដាប់ បុគ្គលណា ត្រិះរិះកាមវិតក្ក ព្យាបាទវិតក្ក ឬវិហិង្សាវិតក្ក ព្រះមហាសត្វក៏ទៅក្នុងទីនោះ អង្គុយលើអាកាសសម្ដែងធម៌ ប្រាប់កសិណបរិកម្មខាងមុខបុគ្គលនោះ ។ បរិស័ទទាំងឡាយ តាំងនៅក្នុងឱវាទរបស់ព្រះមហាសត្វ ហើយញុំាងសមាបត្តិ ៨ ឲ្យកើតឡើង ដល់នូវការសម្រេចក្នុងឈាន ព្រះមហាសត្វ មានអន្តេវាសិកធំ ដែលជាសិស្សច្បង ៧ រូប គឺសាលិស្សរៈ ១ មេណ្ឌិស្សរៈ ១ បព្វតៈ ១ កាឡទេវិលៈ ១ កីសវច្ឆៈ ១ អនុសិស្សៈ ១ នារទៈ ១ ក្នុងកាលតមកអាស្រមក្នុងកបិដ្ឋវ័ន ពេញបរិបូណ៌ ឱកាសដែលជាលំនៅរបស់ពួកឥសីមិនគ្រប់គ្រាន់ ។

លំដាប់នោះ ព្រះមហាសត្វ បានហៅសាលិស្សរៈមកប្រាប់ថា នែសាលិស្សរៈ អាស្រមនេះមិនគ្រប់គ្រាន់ដល់ពួកឥសី ចូរអ្នកនាំពួកឥសីនេះចូលទៅអាស្រ័យកលម្បចុល្លកនិគម ក្នុងដែនរបស់ព្រះបាទមេជ្ឈរាជចុះ ។

សាលិស្សរតាបសទទួលពាក្យរបស់ព្រះមហាសត្វថា សាធុ ហើយនាំគណៈឥសីមួយពាន់ថ្វាយ ទៅកាន់កលម្បចុល្លកនិគមនោះ ។ កាលមនុស្សទាំងឡាយនាំគ្នាមកបួស អាស្រមក៏ពេញទៀតព្រះពោធិសត្វក៏ហៅមេណ្ឌិស្សរៈមកប្រាប់ថា នែមេណ្ឌិស្សរៈ ស្ទឹងឈ្មោះសាតោទិកានទី នៅក្នុងវាងដែនសុរដ្ឋជនបទមាន ចូរអ្នកនាំពួកឥសីទៅកាន់ឆ្នេរស្ទឹងសាតោទិកានទីនោះចុះ ដោយឧបាយនោះឯង ព្រះពោធិសត្វ ហៅបព្វតតាបសមកក្នុងវារៈទី ៣ បញ្ជូនទៅថា នែបព្វតៈ ភ្នំឈ្មោះអញ្ជនបព៌ត មានក្នុងព្រៃធំ ចូរអ្នកទៅអាស្រ័យអញ្ជនបព៌តនោះចុះ ។ វារៈទី ៤ ព្រះពោធិសត្វហៅកាឡទេវិលតាបសមកត្រាស់ថា នែកាឡទេវិលៈ ក្នុងដែនអវន្តី ក្នុងទក្ខិណាជនបទ មានភ្នំឈ្មោះឃនសេលបព្វតៈ ចូរអ្នកទៅអាស្រ័យឃនសេលបព៌ត នោះចុះ អាស្រមក្នុងកបិដ្ឋវ៉នក៏ពេញទៀត ក្នុងទីទាំង ៥ មានពួកឥសីចំនួនមួយសែនជាង ឯកីសវច្ឆតាបស លាព្រះមហាសត្វ ចូលទៅអាស្រ័យសេនាបតី ក្នុងព្រះរាជឧទ្យាន នាកុម្ភវតីនគរ ដែនរបស់ព្រះបាទទណ្ឌកីរាជ ចំណែកនារទតាបស ទៅកាន់ជើងភ្នំ ឈ្មោះអញ្ជនគិរី ក្នុងមជ្ឈិមប្រទេស ចំណែកអនុសិស្សតាបសនៅក្នុងសម្នាក់នៃព្រះមហាសត្វនោះឯង ។

ក្នុងកាលនោះ ព្រះបាទទណ្ឌកីរាជទ្រង់ដកតំណែងស្រីផ្កាមាសម្នាក់ដែលបានសក្ការៈហើយអំពីតំណែង នាងដើរទៅតាមធម្មតារបស់ខ្លួនទៅកាន់ព្រះរាជឧទ្យាន ជួបកីសវច្ឆតាបស គិតថា តាបសនេះគង់ជាកាឡកណ្ណី អញនឹងបន្សាត់កាឡកណ្ណីលើសរីរៈតាបសនេះ ងូតទឹកហើយ សឹមទៅ ដូច្នេះ

ហើយ ទើបទំពាឈើស្ងួន់ ហើយស្តោះទឹកមាត់ជាច្រើនលើសរីរៈ តាបស នោះមុនគេ ហើយទើបស្តោះលើផ្នួងសក់ បោះឈើស្ងួន់លើក្បាល កីសវច្ឆ-តាបសនោះទៀត ហើយងូតទឹកជម្រះកាយចេញទៅ ។ បន្ទាប់មក ព្រះរាជា ទ្រង់នឹកឃើញដល់ស្រីនោះ ហើយហៅមកស្ថាបនាទុកតាមតំណែងដើម នាង ជាមនុស្សវង្វេង បានធ្វើសេចក្តីសម្គាល់ថា ព្រោះអញបានបន្សាត់កាឡកណ្ណី លើសរីរៈរបស់មនុស្សកាឡកណ្ណី ទើបព្រះរាជាស្ថាបនាអញទុកក្នុងតំណែង ដើម អញក៏បាននូវយសទៀត ។ មិនយូរប៉ុន្មាន ព្រះរាជាក៏ដកបុរោហិតពី ឋានន្តរសក្តិ បុរោហិតនោះបានទៅកាន់សម្នាក់របស់ស្រីគណិការនោះ សួរ ថា ព្រោះហេតុអ្វីទើបនាងបានតំណែងវិញ ។ លំដាប់នោះ ស្រីគណិការក៏ ប្រាប់ថា ព្រោះខ្ញុំបន្សាត់ចង្រៃដាក់លើសរីរៈរបស់មនុស្សកាឡកណ្ណីក្នុង ព្រះរាជឧទ្យាន ។ បុរោហិតក៏ទៅបន្សាត់ចង្រៃលើសរីរៈរបស់កីសវច្ឆតាបស យ៉ាងនោះដូចគ្នា ព្រះរាជាក៏ទ្រង់ស្ថាបនាបុរោហិតនោះក្នុងឋានន្តរសក្តិទៀត ក្នុងកាលតមក បច្ចន្តជនបទរាជអាណាខេត្តរបស់ព្រះបាទទណ្ឌកីរាជនោះ កើត ចលាចល ទ្រង់ចោមរោមទៅដោយអង្គសេនា យាងចេញដើម្បីយុទ្ធនាការ លំដាប់នោះ បុរោហិតដែលវង្វេងក្រាបទូលព្រះរាជាថា បពិត្រព្រះអង្គ តើ ទ្រង់ចង់បានជ័យជម្នះ ឬចង់បរាជ័យ កាលព្រះរាជាត្រាស់ថា យើងប្រាថ្នា ជ័យជម្នះ ទើបក្រាបទូលថា បើដូច្នោះ មនុស្សកាឡកណ្ណីនៅក្នុងព្រះរាជ ឧទ្យាន សូមទ្រង់បន្សាត់ឧបទ្រពដាក់សរីរៈ របស់មនុស្សកាឡកណ្ណីនោះ ហើយយាងទៅចុះ ។ ព្រះរាជាជឿពាក្យរបស់បុរោហិត ត្រាស់ថា អ្នកណា

ទៅជាមួយយើង ចូរនាំគ្នាទៅបន្សាត់ឧបទ្រព លើសរីរៈរបស់មនុស្សកាឡ-កណ្ណី ក្នុងព្រះរាជឧទ្យាន ហើយយាងចូលទៅកាន់ព្រះរាជឧទ្យាន ទ្រង់ទំពាឈើស្ទន់ ហើយទ្រង់ស្តោះទឹកមាត់និងបោះឈើស្ទន់លើជដារបស់កិសវច្ឆ-តាបសនោះមុនគេ ហើយទ្រង់ស្រង់ទឹក សូម្បីពលនិកាយរបស់ទ្រង់ក៏ធ្វើយ៉ាងនោះ កាលព្រះរាជាចេញទៅហើយ សេនាបតីមកឃើញតាបស ប្រមូលឈើស្ទន់ជាដើមទៅចោល ផ្ងូតទឹក ជម្រះកាយឲ្យយ៉ាងល្អ ហើយសាកសួរថា បពិត្រលោកម្ចាស់ អ្វីនឹងមានដល់ព្រះរាជា ។ កិសវច្ឆតាបសឆ្លើយថា ចម្រើនពរ ការគិតប្រទូសមិនមានក្នុងចិត្តអាត្មាទេ តែទេវតាថែរក្សាព្រះនគរពិរោធ រាប់ពីនេះទៅ ៧ ថ្ងៃ នឹងធ្វើឲ្យដែនទាំងមូលក្លាយជាផេះផង់ ចូរអ្នកគេចទៅដែនដទៃដោយរហ័សចុះ ។ សេនាបតីតក់ស្លុត ទើបទៅក្រាបទូលព្រះរាជាឲ្យទ្រង់ជ្រាប ព្រះបាទទណ្ឌកីរាជ ទ្រង់ស្តាប់ពាក្យសេនាបតីហើយក៏មិនបានជឿ សេនាបតីក៏ត្រឡប់ទៅកាន់ផ្ទះរបស់ខ្លួន នាំកូនប្រពន្ធគេចទៅកាន់ដែនដទៃ ។ ចំណែកសរភង្គតាបស[១]ដែលជាអាចារ្យឃើញហេតុនោះហើយបញ្ជូនតាបសកំលោះ ២ រូប ឲ្យយកមញ្ចសិវិកា សែងកិសវច្ឆតាបសហោះមកតាមអាកាស ។ ព្រះរាជាទ្រង់ច្បាំង ចាប់ចោរបានហើយ ទ្រង់យាងត្រឡប់ទៅកាន់ព្រះនគរនោះឯង កាលព្រះរាជាយាងមកហើយ ទេវតាទាំងឡាយ ក៏បណ្តាលភ្លៀងឲ្យធ្លាក់ចុះមកមុន កាលសាកសពគ្រប់ប្រភេទត្រូវជំនន់ទឹកបន្សាត់ទៅហើយ ភ្លៀងខ្សាច់ក៏ធ្លាក់ចុះមក ភ្លៀងផ្កាឈើទិព្វធ្លាក់

---

១-សរភង្គតាបសគឺព្រះពោធិសត្វនោះឯង ព្រោះលោកកាច់បំបាក់នូវព្រួញទើបឈ្មោះថាសរភង្គៈ

លើគំនរខ្សាច់ ភ្លៀងមាសកៈធ្លាក់លើគំនរផ្កា ភ្លៀងកហាបណៈធ្លាក់លើគំនរមាសកៈ ភ្លៀងអាភរណៈដែលជាទិព្វ ធ្លាក់លើគំនរមាសកៈ មនុស្សទាំងឡាយដល់នូវសោមនស្ស រើសប្រាក់មាសនិងគ្រឿងអាភរណៈរក្សាទុក ។ លំដាប់នោះ ភ្លៀងអាវុធដ៏ប្រាលផ្លោ មានប្រការផ្សេងៗ ធ្លាក់លើសរីរៈរបស់មនុស្សទាំងនោះ មនុស្សទាំងឡាយដាច់ជាកំណាត់តូចធំ គ្រានោះ រងើកភ្លើង ប្រាសចាកអណ្តាតដុំធំៗ បានធ្លាក់មកលើមនុស្សទាំងនោះ កំពូលភ្នំឆេះដោយភ្លើង ធ្លាក់ចុះលើមនុស្សទាំងនោះ ភ្លៀងខ្សាច់ល្អិតញុំាងទីប្រមាណ ៦០ យោជន៍ឲ្យពេញ ធ្លាក់ចុះតាំងលើមនុស្សទាំងនោះ ទី ៦០ យោជន៍ មិនបានជាវដ្តមណ្ឌល ដោយប្រការដូច្នេះ ។ ភាពដែលដែននោះវិនាសទៅយ៉ាងនេះ បានល្បីខ្ចរខ្ចាយទៅពេញជម្ពូទ្វីប ។

គ្រានោះ ស្តេច ៣ អង្គ គឺព្រះបាទកាលិង្គៈ ១ ព្រះបាទអដ្ឋកៈ ១ ព្រះបាទភីមរថ ១ ដែលជាធំក្នុងដែនជាប់បន្តគ្នាជាមួយដែននោះ បានគិតគ្នាថា បានឮថា ក្នុងកាលមុន ស្តេចកលាពុកាសិករាជ ក្នុងនគរពារាណសីធ្វើខុសក្នុងខន្តិវាទិតាបសត្រូវផែនដីស្រូប ព្រះបាទនាឡិកីរាជឲ្យឆ្កែទំពាស៊ីតាបស និងព្រះបាទអជ្ជុនជាអ្នកទ្រទ្រង់នូវកម្លាំងដៃ ១០០០ ប្រព្រឹត្តខុសក្នុងអង្គីរសតាបសត្រូវផែនដីស្រូបដូចគ្នា បានឮថា ពេលនេះ ទណ្ឌកីរាជខុសក្នុងកីសវច្ឆតាបស ដល់នូវសេចក្តីវិនាសព្រមដោយដែន ពួកយើងមិនដឹងទីកើតរបស់ព្រះរាជាទាំង ៤ នេះ វៀរសរភង្គសាស្តាចេញហើយ អ្នកដទៃឈ្មោះថា អាចដើម្បីប្រាប់រឿងនោះដល់យើងមិនមាន ពួកយើងនឹងចូលទៅសួរ

បញ្ហាទាំងនេះដល់ក្សត្រទាំង ៣ អង្គនោះ មួយអន្ទើដោយរាជបរិវារជាច្រើន នាំគ្នាចេញមកដើម្បីសួរបញ្ហា តែព្រះរាជាទាំង ៣ នោះ ទ្រង់មិនបានជ្រាបថា សូម្បីព្រះរាជាអង្គនោះក៏យាងចេញហើយ ទ្រង់សម្គាល់ថា អញទៅតែម្នាក់ឯងប៉ុណ្ណោះ ។ សមាគមនៃក្សត្រទាំងនោះ មានមិនឆ្ងាយអំពីស្ទឹងគោធាវរី ព្រះរាជាទាំងនោះ ទ្រង់ចុះចាករថមួយអង្គមួយគ្រឿង ហើយយាងឡើងរថតែមួយ ទៅជាមួយគ្នា ស្តេចទាំង ៣ អង្គ ដល់ឆ្នេរស្ទឹងគោធាវរី ខណៈនោះ សក្កទេវរាជប្រថាប់គង់លើព្រះទែនបណ្ឌុកម្ពលសិលាអាសនៈ ទ្រង់គិតប្រស្នា ៧ ប្រការ ហើយទ្រង់ត្រិះរិះថា វៀរសរភង្គតាបសហើយ អ្នកដទៃក្នុងមនុស្សលោក ព្រមទាំងទេវលោក ឈ្មោះថា អាចឆ្លើយ បញ្ហានេះមិនមាន អញនឹងសួរបញ្ហាទាំងនេះនឹងសរភង្គសាស្តានោះ ព្រះរាជាទាំង ៣ នោះ មកដល់ច្រាំងស្ទឹងគោធាវរីដើម្បីសួរបញ្ហាជាមួយសរភង្គសាស្តា អញនឹងជាអ្នកសួរបញ្ហារបស់ព្រះរាជាទាំងនោះ ពួកទេវតាក្នុងទេវលោកទាំង ២ ( តាវត្តិង្ស និងចាតុម្មហារាជិកា ) ចោមរោមហើយ យាងចុះអំពីទេវលោក ។ ក្នុងថ្ងៃនោះឯង កីសវច្ឆតាបសក៏បានធ្វើកាលកិរិយា ឥសីទាំងឡាយច្រើនពាន់ក្នុងទីទាំង ៤ ក៏មកក្នុងទីនោះដូចគ្នា ដើម្បីធ្វើការបូជាសពរបស់កីសវច្ឆតាបសនោះ ហើយឲ្យធ្វើមណ្ឌបទុក ពួកឥសីជាង ១០០០ ក្នុងទីទាំង ៥ នាំគ្នាធ្វើជើងថ្ករដោយខ្លឹមចន្ទន៍ ដើម្បីតម្កល់សរីរៈរបស់កីសវច្ឆតាបស ហើយនាំគ្នាដុត-សរីរសព ភ្លៀងផ្កាកោសុមទិព្វធ្លាក់ចុះ ក្នុងទីប្រមាណកន្លះយោជន៍ ជុំវិញឈាបនដ្ឋាន ។ ព្រះមហាសត្វឲ្យរើសសរីរធាតុរបស់ កីសវច្ឆតាបសហើយ

ចូលទៅកាន់ អាស្រម ចោមរោមដោយពួកឥសីទាំងនោះ ហើយអង្គុយ ។ ក្នុងកាល ព្រះរាជាទាំងនោះមកដល់ប្រាំងនទី សំឡេងនៃកងទ័ព សំឡេងនៃពាហនៈនិងសំឡេងតន្ត្រីបានមានហើយ ។ ព្រះមហាសត្វបានស្តាប់សំឡេងនោះទើប ហៅអនុសិស្សតាបសមកប្រាប់ថា នែបា ចូរអ្នកទៅមើល នុ៎ះជាសំឡេងអ្វី ទើបអនុសិស្សតាបសកាន់យកក្អមទឹកទៅកាន់ទីនោះ ជួបព្រះរាជាទាំង ៣ ទើបពោលគាថាជំបូង ដោយជាពាក្យសួរថា

> បពិត្រលោក រថទាំងឡាយប្រសើរ លោកទាំងឡាយមានខ្នងប្រដាប់ហើយ មានកុណ្ឌល មានសំពត់ស្លៀកល្អ សៀតព្រះខ័នមានដង ប្រដាប់ដោយកែវពៃទូរ្យនិងកែវមុក្តា ឈរនៅ ( លើរថតែមួយ ) លោកទាំងឡាយឈ្មោះអ្វី ពួកជនក្នុងមនុស្សលោក ស្គាល់លោកទាំងឡាយដូចម្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វេឡុរិយមុត្តាថរុខគ្គពន្ធា** សេចក្តីថា ប្រកបទៅដោយព្រះខ័នរតនៈ មានដងប្រដាប់ដោយកែវពៃទូរ្យ និងកម្រងកែវមុក្តា ។ បទថា **តិដ្ឋថ** សេចក្តីថា លោកទាំងឡាយឈរក្នុងរថជាមួយគ្នា ។ បទថា **កេ នុ** សេចក្តីថា ពួកលោក គឺនរណា មនុស្សក្នុងមនុស្សលោកស្គាល់លោកបានដូចម្តេច ។

ស្តេចទាំង ៣ ស្តាប់ពាក្យតាបសហើយ ចុះអំពីរថ នមស្ការហើយប្រថាប់ឈរ ក្នុងក្សត្រទាំង ៣ នោះ ព្រះបាទអដ្ឋករាជ កាលទ្រង់សន្ទនានឹងអនុសិស្សតាបស ទើបត្រាស់គាថាទី ២ ថា

ខ្ញុំជាព្រះរាជា ឈ្មោះអដ្ឋកៈ នេះជាព្រះរាជាព្រះនាមភីមរថ នេះជាព្រះរាជា ព្រះនាមកាលិង្គ ដែលមានតេជានុភាព មានកិត្តិសព្ទល្បីល្បាញ យើងទាំងឡាយមកក្នុងទីនេះ ដើម្បីឃើញនូវឥសីទាំងឡាយដែលសង្រួមល្អហើយ ដើម្បីសួរនូវប្រស្នាទាំងឡាយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧគ្គតោ** សេចក្តីថា ជាអ្នកប្រាកដល្បីល្បាញទៅដូចព្រះចន្ទនិងព្រះអាទិត្យ ។ បទថា **សុសញ្ញតានំ ឥសីនំ** សេចក្តីថា ព្រះបាទអដ្ឋករាជត្រាស់ថា បពិត្រលោកម្ចាស់ ពួកខ្ញុំមកដើម្បីលេងកីឡាក្នុងព្រៃក៏មិនមែន ដោយពិតនោះ ពួកខ្ញុំមកក្នុងទីនេះ ដើម្បីជួបឥសីអ្នកមានសីលសង្រួមល្អហើយ ដោយកាយជាដើម ។ បទថា **បុច្ឆិតាយេម្ហ បញ្ហេ** សេចក្តីថា ជាអ្នកមកហើយ ដើម្បីសាកសួរបញ្ហាជាមួយសរភង្គសាស្តាបណ្ឌិតគួរជ្រាបថា **យ** អក្ខរៈ ធ្វើការភ្ជាប់ជាមួយព្យញ្ជនៈ ។

លំដាប់នោះ តាបសក្រាបទូលព្រះរាជាទាំងនោះថា ថ្វាយព្រះពរមហារាជ ទ្រង់ទាំងឡាយយាងមកក្នុងទីដែលគួរមកដោយពិត បើដូច្នោះ សូមទ្រង់ស្រង់ ហើយយាងទៅកាន់អាស្រម ទ្រង់ថ្វាយបង្គំពួកឥសី ហើយត្រាស់សួរបញ្ហាជាមួយសាស្តាចុះ កាលធ្វើបដិសណ្ឋារៈជាមួយព្រះរាជាទាំងនោះហើយ ទើបលើកក្អមទឹកឡើង ជូតទំណក់ទឹកបណ្តើរ សម្លឹងមើលអាកាសឃើញសក្កទេវរាជ ចោមរោមដោយពួកទេវតា គង់លើកដំរីឯរាវណដ៏ប្រសើរកំពុងយាងមក កាលនឹងសន្ទនាជាមួយសក្កទេវរាជនោះ ទើបពោលគាថាទី

៣ ថា

លោកឋិតនៅឰដ៏អាកាស ជាទីកករាយនៃសត្វស្លាប ដូចព្រះចន្ទ
ក្នុងថ្ងៃ ១៥ កើតដែលឋិតនៅនាគន្លងផ្លូវឆ្ងាយ ( អាកាស )
បពិត្រយក្ស អាត្មាសូមសួរលោក ដែលមានអានុភាពធំ ពួក
ជនក្នុងមនុស្សលោកនឹងស្គាល់លោកដូចម្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វេហាសយំ** សេចក្តីថា លោកហោះឡើង ទៅអណ្តែតនៅក្នុងវេហាស៍ គឺលើអាកាស ។ បទថា **បជ្ជុន្នោ** សេចក្តីថា ដូចព្រះចន្ទដែលទៅកាន់គន្លងឆ្ងាយ គឺតាំងនៅក្នុងកណ្តាលអម្ពរ ដែលជាដែនឆ្ងាយដូច្នោះ ។

សក្កទេវរាជទ្រង់ស្តាប់ដូច្នោះ ទើបត្រាស់គាថាទី ៤ ដោយ
សេចក្តីថា ទេវតាទាំងឡាយក្នុងពួកទេវតា បានហៅខ្ញុំណាថា
មឃវា ខ្ញុំនោះជាទេវរាជមកកាន់ទីនេះ ក្នុងថ្ងៃនេះ ដើម្បីឃើញ
ឥសីទាំងឡាយអ្នកសង្រួមល្អហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ស ទេវរាជា** សេចក្តីថា សក្កទេវរាជត្រាស់ថា ខ្ញុំនោះ គឺសក្កទេវរាជ ។ បទថា **ឥទមជ្ជ បត្តោ** សេចក្តីថា មកកាន់ទីនេះ ក្នុងកាលឥឡូវនេះ ។ បទថា **ទស្សនាយ** សេចក្តីថា សក្កទេវរាជត្រាស់ថា ដើម្បីសួរសុខទុក្ខ នមស្ការ និងដើម្បីសួរបញ្ហាជាមួយនឹងសរភង្គ-សាស្តាផងដែរ ។

លំដាប់នោះ អនុសិស្សតាបសក៏ក្រាបទូលសក្កទេវរាជថា បពិត្រមហា

រាជ សូមទ្រង់យាងមកខាងក្រោយ ដូច្នេះហើយ កាន់យកក្អមទឹកទៅកាន់អាស្រម ទុកក្អមហើយ ជម្រាបភាពដែលព្រះរាជាទាំង ៣ អង្គ និងសក្កទេវរាជ យាងមកដើម្បីសួរបញ្ហាដល់ព្រះមហាសត្វ ព្រះមហាសត្វចោមរោមដោយពួកឥសី អង្គុយក្នុងរោងដែលធំទូលាយ ព្រះរាជាទាំងឡាយ ៣ អង្គ យាងមកថ្វាយបង្គំពួកឥសី ហើយប្រថាប់គង់ក្នុងចំណែកម្ខាង ឯសក្កទេវរាជក៏យាងចុះមក ហើយចូលទៅរកពួកឥសី ប្រថាប់ឈរផ្គងអញ្ជលី ដើម្បីសរសើរពួកឥសី ទើបថ្វាយបង្គំ នមស្ការ ពោលគាថាទី ៥ ដោយសេចក្តីថា

ឥសីទាំងឡាយរបស់យើងខ្ញុំ ដែលចួបជុំគ្នា មានឫទ្ធិធំ ប្រកបដោយគុណគឺឫទ្ធិ ល្បីទៅក្នុងទីឆ្ងាយ ខ្ញុំមានចិត្តជ្រះថ្លា សូមថ្វាយបង្គំលោកម្ចាស់ទាំងឡាយ ដែលប្រសើរក្នុងពួកមនុស្សក្នុងជីវលោកនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទូរេ សុតា នោ** សេចក្តីថា កាលសក្កទេវរាជទ្រង់សម្តែងនូវការរាប់អាន ទើបត្រាស់យ៉ាងនេះថា បពិត្រលោកម្ចាស់ទាំងឡាយ ពួកខ្ញុំស្ថិតនៅក្នុងទេវលោកសែនឆ្ងាយ បានឮ បានស្តាប់ហើយ មានពាក្យអធិប្បាយថា ឥសីទាំងឡាយរបស់ពួកយើងដែលមកប្រជុំគ្នាក្នុងទីនេះទាំងនេះ ពួកខ្ញុំបានឮហើយ ក្នុងទីឆ្ងាយ គឺប្រាកដល្បីទៅដល់ព្រហ្មលោក ។ បទថា **មហិទ្ធិកា** បានដល់ មានអានុភាពច្រើន ។ បទថា **ឥទ្ធិគុណូបបន្នា** សេចក្តីថា ប្រកបទៅដោយឥទ្ធិគុណ ៥ យ៉ាង ។ បទថា **អយិរេ** បានដល់ ក្នុងលោកម្ចាស់ ។ បទថា **យេ** សេចក្តីថា ខ្ញុំសូមថ្វាយបង្គំពួក

លោក ដែលប្រសើរបំផុតក្នុងពួកមនុស្ស ក្នុងជីវលោកនេះ ។

សក្កទេវរាជត្រាស់សរសើរពួកឥសីយ៉ាងនេះហើយ កាលទ្រង់វៀរនូវទោសនៃការអង្គុយ ៦ យ៉ាង ទើបប្រថាប់គង់ក្នុងទីសមគួរនាចំណែកម្ខាង គ្រានោះ អនុសិស្សតាបសឃើញសក្កទេវរាជគង់ប្រថាប់ក្នុងទីក្រោមខ្យល់នៃពួកឥសី ទើបពោលគាថាទី ៦ ថា

ក្លិនរបស់ឥសីទាំងឡាយ ដែលបួសយូរ រមែងផ្សាយចេញ
ចាកកាយទៅតាមខ្យល់ បពិត្រសហស្សនេត្ត សូមព្រះអង្គថយ
ចេញចាកទីនេះ បពិត្រទេវរាជ ក្លិនរបស់ឥសីទាំងឡាយ មិន
ស្អាតទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចិរទក្ខិតានំ** សេចក្តីថា របស់អ្នកបួសអស់កាលយូរ ។ បទថា **បដិក្កម្ម** សេចក្តីថា សូមទ្រង់ចៀសចេញទៅ គឺសូមថយទៅ ។ បទថា **សហស្សនេត្ត** នេះ ជាអាលបនៈ ។ ពិតហើយ សក្កទេវរាជមួយអង្គនោះឯង ទ្រង់ឃើញអត្ថដែលអាមាត្យ ១០០០ គិតហើយ ដូច្នោះ ទើបត្រាស់ថា **សហស្សនេត្ត** ។ ម្យ៉ាងទៀត ឈ្មោះថា **សហស្សនេត្ត** ព្រោះជាអ្នកអាចឈានកន្លងឧបចារៈនៃការឃើញរបស់ទេវតា ដែលមានភ្នែក ១០០០ ។ បទថា **អសុចិ** សេចក្តីថា ឈ្មោះថា មានក្លិនស្អុយ ព្រោះអប់ដោយញើសនិងក្អែល និងមន្ទិលជាដើម ម្យ៉ាងទៀត អ្នកទាំងឡាយ ជាអ្នកប្រាថ្នានូវការស្អាត ដោយហេតុនោះ ក្លិននេះរមែងបៀតបៀនអ្នកទាំងឡាយ ។

សក្កទេវរាជទ្រង់ស្តាប់ដូច្នោះ ទើបត្រាស់គាថាបន្តថា

ក្លិនរបស់ឥសីទាំងឡាយដែលបួសយូរ ចូរផ្សាយចេញចាក
កាយទៅតាមខ្យល់ចុះ បពិត្រលោកដ៏ចម្រើន យើងខ្ញុំរមែង
ប្រាថ្នានូវក្លិននុ៎ះ ដូចបុគ្គល ប្រាថ្នានូវកម្រងផ្កា មានផ្កាដ៏វិចិត្រ
មានក្លិនក្រអូប ព្រោះទេវតាទាំងឡាយ ជាអ្នកមិនមានសេចក្តី
សំគាល់ក្នុងក្លិននុ៎ះ ថាជាបដិកូលទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **គច្ឆតុ** សេចក្តីថា ក្លិនរបស់ឥសីទាំងឡាយ ចូរប្រព្រឹត្តទៅតាមសម្រួលចុះ អធិប្បាយថា ចូរប៉ះខ្ទប់ច្រមុះរបស់ពួកខ្ញុំចុះ ។ បទថា **បដិកង្ខាម** សេចក្តីថា ពួកខ្ញុំត្រូវការ គឺប្រាថ្នា ។

បទថា **ឃត្ត** សេចក្តីថា ទេវតាទាំងឡាយមិនមានការសម្គាល់ក្នុងក្លិននេះ ថា គួរខ្ពើម ព្រោះពួកទេវតាទាំងឡាយនាំគ្នារង្កៀសអ្នកទ្រុស្តសីលតែម្យ៉ាង មិនរង្កៀសអ្នកមានសីលឡើយ ។

កាលសក្កទេវរាជពោលយ៉ាងនេះហើយ ទើបត្រាស់ថា បពិត្រអនុសិស្សតាបសដ៏ចម្រើន ខ្ញុំមកដោយឧស្សាហៈធំ ដើម្បីនឹងសួរបញ្ហា សូមលោកម្ចាស់ធ្វើឱកាសដល់ខ្ញុំផងចុះ ។ អនុសិស្សតាបសបានស្តាប់ព្រះតម្រាស់របស់សក្កទេវរាជហើយ ក្រោកឡើងចាកអាសនៈ ដើម្បីញុំាងពួកឥសីឲ្យធ្វើឱកាស ទើបពោលគាថា ២ ថា

ទេវរាជនោះឈ្មោះបុរិន្ទទៈ ឈ្មោះ ភូតបតី ជាអ្នកមានយស
ឈ្មោះទេវានមិន្ទៈ ឈ្មោះ មឃវា ឈ្មោះសុជម្បតិ ជាអ្នក
ញុំាញី ( នូវពួក ) អសុរ ទ្រង់ប្រាថ្នានូវឱកាសដើម្បីសួរ

ប្រស្នា ។ ក្នុងទីនេះ បណ្ដាឥសី ជាបណ្ឌិតទាំងឡាយនេះ បណ្ឌិតណាហ្ន៎ ដែលព្រះរាជាទាំង ៣ ព្រះអង្គ ជាធំជាងមនុស្ស និងព្រះវាសវៈ ជាធំជាងពួកទេវតា ត្រាស់សួរប្រស្នាដ៏ល្អិត ហើយនឹងឆ្លើយបាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បុរិន្ទទោ** ជាដើម ជាគុណនាមរបស់សក្កទេវរាជនោះឯង ។ ពិតហើយ សក្កទេវរាជនោះ ឲ្យទានមុន ទើបឈ្មោះថា បុរិន្ទទៈ ព្រោះជាធំក្នុងពួកភូតនិកាយ ទើបឈ្មោះថា **ភូតបតិ** ព្រោះដល់ព្រមដោយបរិវារទើបឈ្មោះថា **យសស្សី** ព្រោះជាឥស្សរៈក្រៃលែង ទើបឈ្មោះថា **ទេវានមិន្ទោ** ព្រោះទ្រង់ប្រព្រឹត្តវត្តបទ ៧ ប្រការដោយល្អ ទើបឈ្មោះថា **សក្កោ** និងឈ្មោះថា **មឃវា** ដោយអំណាចនាមក្នុងជាតិមុន ព្រោះជាប្ដីរបស់នាងសុជាតាអសុរកញ្ញា ទើបឈ្មោះថា **សុជម្បតិ** ព្រោះញុំាងចិត្តរបស់ទេវតាឲ្យត្រេកអរ ទើបឈ្មោះថា **ទេវរាជា** ។ បទថា **កោនេវ** កាត់បទចេញជា **កោ នុ ឯវ** ប្រែថា អ្នកណាហ្ន៎ ។ បទថា **និបុណោ** បានដល់ បញ្ហាល្អិតសុខុម ។ បទថា **រញ្ញំ** បានដល់ របស់ព្រះរាជាទាំងឡាយ អធិប្បាយថា អនុសិស្សតាបសពោលថា បណ្ដាឥសីដែលជាបណ្ឌិតទាំងនេះ អ្នកណានឹងទាញយកព្រះហឫទ័យរបស់ព្រះរាជាទាំង ៤ អង្គនេះ ហើយពោលឆ្លើយបញ្ហាល្អិតសុខុមបាន អ្នកទាំងឡាយ ចូរជ្រាបដល់បុគ្គលដែលអាចពោលឆ្លើយបញ្ហារបស់ព្រះរាជាទាំងនោះចុះ ។

ពួកឥសីបានឮដូច្នោះ ទើបពោលថា បពិត្រអនុសិស្សអ្នកនិទ្ទុក្ខ លោក

ឈរពោលលើផែនដី ដូចមិនឃើញផែនដី វៀរសរភង្គសាស្តាហើយ អ្នកណានឹងអាចឆ្លើយបញ្ហារបស់ព្រះរាជាទាំងនោះបាន ដូច្នេះហើយ ទើបពោលគាថានេះថា

ឥសីឈ្មោះសរភង្គៈនេះ មានតបៈ ជាអ្នកវៀរចាកមេថុនធម្ម តាំងអំពីកើតមក ជាបុត្តនៃបុរោហិត ដែលជាអាចារ្យ ( របស់ព្រះរាជាពារាណសី ) មានសភាពរៀបរយល្អហើយ ឥសីឈ្មោះ សរភង្គៈនោះ នឹងឆ្លើយនូវប្រស្នាទាំងឡាយរបស់ព្រះរាជាទាំងនោះបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សរភង្គោ** សេចក្តីថា ឥសីបាញ់ធ្នូហើយសម្តែងសិប្បៈ ដូចជាសរបាសាទសិប្បៈជាដើម ក្នុងអាកាស ហើយធ្វើឲ្យបែកបាក់ទៅ ដូចញាំងព្រួញទាំងនោះឲ្យធ្លាក់ទៅ ដោយព្រួញមួយទៀត ហេតុនោះទើបឈ្មោះថា សរភង្គ ។ បទថា **មេថុនស្មា** សេចក្តីថា វៀរចាកមេថុនធម្ម ។ បានឮថា លោកមិនធ្លាប់សេពមេថុនធម្ម មកបួសហើយ ។ បទថា **អាចេរបុត្តោ** សេចក្តីថា លោកជាបុត្តរបស់បុរោហិត ដែលជាអាចារ្យរបស់ព្រះរាជា ។

កាលពួកឥសីពោលយ៉ាងនេះហើយ ទើបប្រាប់អនុសិស្សតាបសថា បពិត្រលោកនិទុក្ខ លោកនោះឯង ចូរថ្វាយបង្គំសាស្តា សូមឲ្យឱកាសដើម្បីឆ្លើយបញ្ហា ដែលសក្កទេវរាជសួរតាមពាក្យរបស់ពួកឥសី ។ អនុសិស្សតាបសទទួលពាក្យហើយ ថ្វាយបង្គំសាស្តា កាលនឹងសូមឱកាស ទើបពោល

គាថាលំដាប់តទៅថា

បពិត្រកោណ្ឌញ្ញៈ សូមលោកឆ្លើយនូវប្រស្នាទាំងឡាយ ឥសីទាំងឡាយមានសភាពដ៏ល្អ អារាធនាលោក បពិត្រកោណ្ឌញ្ញៈ ការដោះប្រស្នានុ៎ះ ជាទំនៀមតែងមានក្នុងពួកមនុស្ស ប្រស្នាណា មកកាន់សេចក្ដីចម្រើន ប្រស្នានុ៎ះ ជាភារៈរបស់លោកដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថានោះដូចតទៅថា អនុសិស្សតាបសហៅសរភង្គតាបសថា កោណ្ឌញ្ញៈដោយគោត្ត ។ បទថា **ធម្មោ** បានដល់ សភាវធម៌ ។ បទថា **យំ វុឌ្ឍំ** សេចក្ដីថា អនុសិស្សតាបសពោលថា ឈ្មោះថាភារៈ គឺការវិសជ្ជនាបញ្ហានេះ រមែងមកដល់បុរសដែលមានបញ្ញាដ៏ចម្រើននុ៎ះជាសភាវធម៌ក្នុងពួកមនុស្ស ព្រោះហេតុនោះ សូមលោកឆ្លើយបញ្ហារបស់សក្កទេវរាជ ធ្វើឲ្យប្រាកដ ដូចញ៉ាំងព្រះចន្ទនិងព្រះអាទិត្យ ១០០០ ដួងឲ្យតាំងឡើង ដូច្នោះ ។

លំដាប់នោះ មហាបុរសកាលធ្វើនូវឱកាស ទើបពោលគាថាជាលំដាប់បន្តទៅថា

លោកដ៏ចម្រើនទាំងឡាយ ខ្ញុំធ្វើឱកាសឲ្យហើយ ចូរសួរនូវប្រស្នាណានីមួយ ដែលលោកទាំងឡាយប្រាថ្នាហើយដោយចិត្តចុះ ព្រោះថា ខ្ញុំដឹងនូវលោកនេះ និងលោកខាងមុខ ដោយខ្លួនឯង នឹងឆ្លើយនូវប្រស្នានោះៗ ប្រាប់លោកទាំងឡាយបាន

ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យន្តិញ្ចិ** សេចក្ដីថា សរភង្គតាបសបវារណា នូវសព្វញ្ញុបវារណា[១]ថា មហាបពិត្រទាំងឡាយ អញ្ជើញត្រាស់សួរបញ្ហាតាមចិត្តដែលទ្រង់ប្រាថ្នា ឬរបស់មនុស្សលោកព្រមទាំងទេវលោក តាមប្រាថ្នានឹងខ្ញុំចុះ ព្រោះយើងធ្វើឲ្យជាក់ច្បាស់នូវលោកនេះនិងលោកខាងមុខ ដោយបញ្ញាខ្លួនឯងហើយ នឹងឆ្លើយបញ្ហាទាំងអស់នោះ ដែលអាស្រ័យលោកនេះ ឬលោកខាងមុខដល់លោកទាំងឡាយ ដោយឥតសេសសល់ ។

កាលសរភង្គតាបស ធ្វើឱកាសយ៉ាងនេះហើយ សក្កទេវរាជក៏ត្រាស់សួរបញ្ហាដែលទ្រង់ត្រៀមស្រេចមក ។

កាលទ្រង់ប្រកាសសេចក្ដីនោះ ទើបព្រះសាស្ដាត្រាស់គាថាដោយសេចក្ដីថា

លំដាប់នោះ ទេវរាជបុរិន្ទទៈ មឃវា សក្កៈអ្នកឃើញនូវ
ប្រយោជន៍ បានសួរប្រស្នាជាដំបូង ដែលខ្លួនប៉ងទុកហើយថា
បុគ្គលសម្លាប់អ្វី មិនក្រៀមក្រំ ក្នុងកាលណាមួយឡើយ ឥសី
ទាំងឡាយសរសើរនូវការលះបង់អ្វី បុគ្គលគប្បីអត់ធន់ចំពោះពាក្យ
អាក្រក់ ដែលបុគ្គលណាពោលហើយក្នុងលោកនេះ បពិត្រ
កោណ្ឌញ្ញៈ សូមលោកប្រាប់សេចក្ដីនុ៎ះដល់ខ្ញុំ ដូច្នេះ ។

---

១-បុគ្គលដែលមិនមែនជាសព្វញ្ញូកាលបវារណាក្នុងប្រស្នា តែងបវារណាថា ចូរអ្នកសួរមកចុះ បើខ្ញុំដឹងខ្ញុំនឹងឆ្លើយ ឯសព្វញ្ញុបវារណា លោកតែងបវារណាថា សូមសួរមកចុះខ្ញុំនឹងឆ្លើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យញ្ចាសិ** សេចក្ដីថា ក្នុងបញ្ហានោះ ធម៌ណាដែលទ្រង់ប្រាថ្នាដោយចិត្ត សក្កទេវរាជក៏ត្រាស់សួរនូវធម៌នោះ ។ បទថា **ឯតំ** សេចក្ដីថា សក្កទេវរាជត្រាស់ថា សូមលោកប្រាប់សេចក្ដីដែលខ្ញុំសួរហើយដល់ខ្ញុំចុះ ។ សក្កទេវរាជទ្រង់ត្រាស់សួរបញ្ហាទាំង ៣ ដោយគាថា ១ គាថា

ខាងមុខអំពីនោះ កាលព្រះមហាសត្វព្យាករ ទើបពោលគាថានេះថា

បុគ្គលសម្លាប់សេចក្ដីក្រោធ រមែងមិនក្រៀមក្រំក្នុងកាលណាមួយឡើយ ឥសីទាំងឡាយ រមែងសរសើរនូវការលះបង់នូវសេចក្ដីលុបគុណគេ បុគ្គលគប្បីអត់ធន់ចំពោះពាក្យអាក្រក់ដែលបុគ្គលទាំងពួងពោលហើយ ពួកសប្បុរសពោលនូវសេចក្ដីអត់ធន់នុ៎ះថាជាគុណដ៏ឧត្តម ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កោធំ វធិត្វា** សេចក្ដីថា បុគ្គលសម្លាប់សេចក្ដីក្រោធបានហើយ ។ ពិតហើយ កាលមនុស្សយើងសោយសោករមែងសោយសោកព្រោះចិត្តមានបដិឃៈតែម្យ៉ាង ព្រោះមិនមានសេចក្ដីក្រោធ សេចក្ដីសោកនឹងមានមកអំពីណា ដោយហេតុនោះ សរភង្គតាបសក៏ពោលថា រមែងមិនក្រៀមក្រំក្នុងកាលណាមួយឡើយ ។ បទថា **មក្ខប្បហានំ** សេចក្ដីថា ឥសីទាំងឡាយសរសើរការលះបង់នូវការលុបគុណ ដែលមានការលុបគុណដែលអ្នកដទៃធ្វើហើយដល់ខ្លួនជាលក្ខណៈ ពោលគឺ ភាពជាបុគ្គលអកតញ្ញូ ។ បទថា **សព្ពេសំ** សេចក្ដីថា បុគ្គលគួរអត់ធន់នូវពាក្យគ្រោត

គ្រាតរបស់បុគ្គលគ្រប់ប្រភេទ ទាំងបុគ្គលជាន់ទាប កណ្ដាល និង ជាន់ខ្ពស់ ។ បទថា **សន្តោ** សេចក្ដីថា បុរាណកបណ្ឌិតទាំងឡាយពោលទុកយ៉ាងនេះ ។

សក្កទេវរាជ ត្រាស់សួរជាគាថាដោយសេចក្ដីថា

បុគ្គលអាចអត់ធន់នូវពាក្យរបស់ជនទាំងពីរពួកបាន គឺបុគ្គលស្មើគ្នា និងបុគ្គលប្រសើរជាង ចុះបុគ្គលអត់ធន់នូវពាក្យរបស់បុគ្គលថោកទាប តើដូចម្ដេច បពិត្រកោណ្ឌញ្ញៈ សូមលោកប្រាប់សេចក្ដីនុ៎ះដល់ខ្ញុំ ដូច្នេះ ។

សរភង្គតាបសទូលឆ្លើយជាគាថាដោយសេចក្ដីថា

បុគ្គលអត់ធន់នូវពាក្យរបស់បុគ្គលដ៏ប្រសើរ ព្រោះសេចក្ដីខ្លាច ឯបុគ្គលអត់ធន់នូវពាក្យរបស់បុគ្គលស្មើៗគ្នា ព្រោះហេតុនៃការប្រណាំងប្រជែង ចំណែកបុគ្គលណាក្នុងលោកនេះ អត់ធន់នូវពាក្យរបស់បុគ្គលថោកទាបបាន សប្បុរសទាំងឡាយពោលនូវសេចក្ដីអត់ធន់នុ៎ះ ( របស់បុគ្គលនោះ ) ថាជាគុណជាតិដ៏ខ្ពង់ខ្ពស់ ដូច្នេះ ។

គាថា ២ ដូចពោលមកហើយយ៉ាងនេះជាដើម គប្បីជ្រាបថា ទាក់ទងដោយអំណាចនៃការសួរនិងការឆ្លើយ ។

បណ្ដាបទទាំងនោះ បទថា **អក្ខាហិ មេ** សេចក្ដីថា កាលសក្កទេវរាជត្រាស់សួរ ទើបត្រាស់យ៉ាងនេះថា បពិត្រកោណ្ឌញ្ញគោត្ត បញ្ហា ២ លោកឆ្លើយល្អហើយ មិនទាន់ពេញចិត្តខ្ញុំនៅឡើយ គឺយើងអាចអត់ធន់នូវពាក្យ

របស់បុគ្គលដែលថោកទាបជាងខ្លួនបានដូចម្តេច សូមលោកម្ចាស់ប្រាប់សេចក្តីនោះដល់ខ្ញុំ ។ បទថា **ឯតំ ខន្តី** សេចក្តីថា ការអត់ធន់នូវពាក្យរបស់បុគ្គលដែលថោកទាបជាង ដោយជាតិនិងគោត្តជាដើម ឯណា បុរាណកបណ្ឌិតទាំងឡាយ ពោលនូវការអត់ធន់នោះថា ឧត្តម ។ ឯការអត់ធន់នូវពាក្យរបស់បុគ្គលដែលខ្ពស់ជាងដោយជាតិជាដើម ព្រោះខ្លាច ការអត់ធន់ចំពោះពាក្យរបស់បុគ្គលស្មើគ្នា ព្រោះឃើញទោសក្នុងការប្រណាំងប្រជែងដែលមានការធ្វើឲ្យក្រៃលែងជាងជាលក្ខណៈ នេះមិនឈ្មោះថា អធិវាសនខន្តីឡើយ ។

កាលព្រះមហាសត្វពោលយ៉ាងនេះហើយ សក្កទេវរាជត្រាស់នឹងព្រះមហាសត្វថា បពិត្រលោកម្ចាស់ ដំបូងលោកពោលថា មនុស្សយើងគួរអត់ធន់នូវពាក្យគ្រោតគ្រាតរបស់មនុស្សគ្រប់ប្រភេទ បុរាណកបណ្ឌិតពោលនូវការអត់ធន់នោះថា ឧត្តម ក្នុងសេចក្តីនេះ ឥឡូវនេះ បែរជាពោលថា ចំណែកបុគ្គលណាក្នុងលោកនេះ អត់ធន់នូវពាក្យរបស់បុគ្គលថោកទាបបាន សប្បុរសទាំងឡាយពោលនូវសេចក្តីអត់ធន់នុ៎ះ ( របស់បុគ្គលនោះ ) ថាជាគុណជាតិដ៏ខ្ពង់ខ្ពស់ ដូច្នេះ ។ ពាក្យរបស់លោកម្ចាស់ដែលពោលក្នុងកាលក្រោយមិនសមគ្នានិងពាក្យដែលពោលក្នុងកាលមុន ។ គ្រានោះ ព្រះមហាសត្វក៏ពោលនឹងសក្កទេវរាជថា បពិត្រសក្កៈ ពាក្យក្រោយ អាត្មាពោលដោយអំណាចនៃបុគ្គលដែលជាអ្នកចេះដឹងថា បុគ្គលនេះជាអ្នកថោកទាប ហើយអត់សង្កត់នូវពាក្យគ្រោតគ្រាតរបស់បុគ្គលនោះបាន ព្រោះភាពដែលសត្វ

ទាំងឡាយជាបុគ្គលប្រសើរជាដើម បុគ្គលណាមួយមិនអាចដឹងបាន ត្រឹមតែឃើញរូបរាង ដូច្នោះ ទើបពោលពាក្យដំបូង កាលនឹងប្រកាសភាពដែលសត្វទាំងឡាយជាបុគ្គលប្រសើរជាដើម ជាការដឹងបានលំបាកដោយអាការត្រឹមតែឃើញរូបរាង វៀរតែការនៅរួមគ្នានៃសត្វទាំងឡាយ ទើបពោលគាថានេះថា

ធ្វើដូចម្ដេច បុគ្គលគប្បីដឹងច្បាស់នូវបុគ្គលប្រសើរជាង ឬបុគ្គលស្មើៗគ្នា ឬក៏បុគ្គលថោកទាប ដែលមានសភាពបិទបាំងដោយឥរិយាបថ ៤ បាន សប្បុរសទាំងឡាយតែងប្រព្រឹត្តតាមរូបនៃបុគ្គលផ្សេង ៗ គ្នា ព្រោះហេតុនោះ បុគ្គលគួរអត់ធន់នូវពាក្យរបស់បុគ្គលទាំងពួង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ចតុមដ្ឋរូបំ** សេចក្ដីថា មានសភាពបិទបាំងដោយឥរិយាបថ ៤ ។ បទថា **វិរូបរូបេន** សេចក្ដីថា សប្បុរសទាំងឡាយដែលមានគុណដ៏ខ្ពង់ខ្ពស់ រមែងត្រាច់ទៅដោយរូបដែលគួរខ្ពើម គឺអាក្រក់បាន ក្នុងសេចក្ដីនេះ គួរសម្ដែងរឿងរបស់ព្រះមជ្ឈន្តិកត្ថេរ ។

សក្កទេវរាជទ្រង់ស្ដាប់ដូច្នោះហើយ អស់នូវការសន្និះសង្ស័យ អារាធនាថា បពិត្រលោកម្ចាស់ សូមលោកសម្ដែងអានិសង្សនៃការអត់ធន់នេះដល់ខ្ញុំចុះ ។ លំដាប់នោះ ទើបព្រះមហាសត្វពោលគាថាដល់សក្កទេវរាជថា

សប្បុរស អ្នកមានខន្តិ គប្បីបាននូវសេចក្ដីចម្រើនណា សេនាធំព្រមដោយព្រះរាជា កាលច្បាំងគ្នា មិនគប្បីបាននូវសេចក្ដី

ចម្រើនទុំរះទេ ពៀរទាំងឡាយរបស់បុគ្គលអ្នកមានខន្តិជាកម្លាំង រមែងស្ងប់រម្ងាប់បាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឯតមត្ថំ** បានដល់ ផល ពោល គឺការមិនទ្រគោះបោះបោក ព្រោះញ៉ាំងពៀរឲ្យស្ងប់បាន ។ កាលព្រះមហាសត្វពោលគុណនៃខន្តិយ៉ាងនេះហើយ ព្រះរាជាទាំងនោះទ្រង់ព្រះតម្រិះថា សក្កទេវរាជត្រាស់សួរតែបញ្ហារបស់ខ្លួន មិនឲ្យឱកាសដល់ពួកយើង លំដាប់នោះ សក្ក-ទេវរាជទ្រង់ជ្រាបអធ្យាស្រ័យរបស់ព្រះរាជាទាំងនោះ ទើបផ្អាកប្រស្នា ដែលទ្រង់ត្រៀមមក ៤ ប្រការ កាលត្រាស់សួរនូវការសង្ស័យរបស់ព្រះរាជាទាំងនោះ ទើបពោលគាថានេះថា

ខ្ញុំរីករាយនឹងសុភាសិតរបស់លោក ហើយសូមសួរប្រស្នាដទៃនឹងលោកទៀត សូមលោកពោលប្រស្នានោះ ដូចយ៉ាងព្រះបាទទណ្ឌកី ព្រះបាទនាលិកីរៈ ព្រះបាទអជ្ជុនៈ និងព្រះបាទកលាពុ សូមលោកប្រាប់នូវគតិ របស់ស្ដេចទាំងនោះ ដែលមានបាបកម្មដ៏ធ្ងន់ តើព្រះរាជាទាំងនោះ ជាអ្នកបៀតបៀននូវឥសីទាំងឡាយ ទៅកើតក្នុងទីណា ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អនុមោទិយាន** សេចក្ដីថា ខ្ញុំអនុមោទនានូវពាក្យជាសុភាសិតនេះរបស់លោក ពោល គឺការវិសជ្ជនាបញ្ហា ៣ ដែលខ្ញុំសួរហើយ ។ បទថា **យថា អហុ** សេចក្ដីថា ព្រះរាជាទាំង ៤ មានហើយដោយប្រការណា ។ បទថា **កលាពុ ច** បានដល់ ព្រះបាទកលាពុ ១ ។

បទថា **អជជ្ជុនោ** បានដល់ ព្រះបាទអជ្ជុន ១ ។

លំដាប់នោះ ព្រះមហាសត្វ កាលវិសជ្ជនាបញ្ហារបស់សក្កទេវរាជ ទើបពោលគាថា ៥ ថា

ព្រះបាទទណ្ឌកីព្រមទាំងជន ទាំងអ្នកដែនបានស្តោះដាក់តាបសឈ្មោះកីសវច្ឆៈ ព្រះអង្គមានមូលដាច់ហើយឆេះក្នុងនរក ឈ្មោះកុក្កុលៈរងើកភ្លើងទាំងឡាយធ្លាក់មិនដាច់លើកាយនៃព្រះអង្គ ។ ព្រះបាទ នាលិកីរៈ ណា បានបៀតបៀនបព្វជិតទាំងឡាយ ជាអ្នកសង្រួម ជាអ្នករម្ងាប់បាប មិនប្រទូស្តកំពុងសំដែងធម៌ ឆ្កែទាំងឡាយចោមខាំស៊ីនូវព្រះបាទនាលិកីរៈនោះ ឲ្យអន្ទះអន្ទែងក្នុងបរលោក ។ ឯព្រះបាទអជ្ជុនៈ មានព្រះសិរចុះក្រោម មានព្រះបាទឡើងលើ ធ្លាក់ក្នុងនរកឈ្មោះសត្តិសូលៈ ព្រោះតែបៀតបៀននូវឥសីឈ្មោះអង្គីរសៈ ជាគោតមគោត្ត ជាអ្នកអត់ធន់ មានតបៈ ប្រព្រឹត្តធម៌ដ៏ប្រសើរអស់កាលយូរ ។ ព្រះបាទកលាពុណា បានកាត់ឲ្យជាកំណាត់តូចនិងកំណាត់ធំនូវបព្វជិតដែលពោលនូវខន្តិ ជាអ្នករម្ងាប់បាប ជាអ្នកមិនប្រទូស្តព្រះបាទកលាពុ ( នោះ ) ក៏កើតឆេះនៅក្នុងនរក ឈ្មោះអវិចិ មានកម្តៅដ៏ខ្លាំង មានវេទនាដ៏ផ្សាក្តៅ ជាទីគួរខ្លាច ។ បណ្ឌិតបានឮនូវនរកទាំងឡាយនេះផង នូវនរកទាំងឡាយដទៃដ៏លាមកលើសជាងនរកនេះផង គួរប្រព្រឹត្តធម៌ក្នុងសមណព្រាហ្មណ៍

ទាំងឡាយ លុះធ្វើយ៉ាងនេះហើយ រមែងកើតក្នុងឋានសួគ៌ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កីសំ** សេចក្តីថា សរីរៈរបស់តាបស ឈ្មោះថា កីសៈ ព្រោះជាអ្នកមានសាច់និងឈាមតិច គឺស្គម ។ បទថា **អវក្រិយ** សេចក្តីថា ព្រះបាទទណ្ឌកីនេះឃោរឃៅ គឺបន្សាត់ឧបទ្រពដាក់ក្នុងសរីរៈរបស់កីសវច្ឆៈ ដោយការស្តោះទឹកមាត់ និងចោលឈើជម្រះធ្មេញ ឲ្យធ្លាក់ចុះទៅ ។ បទថា **ឧច្ឆិន្នមូលោ** បានដល់ ជាអ្នកដាច់សូន្យចាកមូល គឺឫសគល់ ។ បទថា **សជនោ** បានដល់ មួយអន្លើដោយបរិស័ទ ។ បទថា **កុក្កុលនាមេ និរយម្ហិ** សេចក្តីថា ឆេះក្នុងនរកផេះដែលតាំងនៅក្នុងទីប្រមាណ ៣០០ យោជន៍អស់កប្ប ។

បទថា **ផុលិង្គា** បានដល់ ភ្លើងដែលប្រាសចាកអណ្តាត ។ បានឮថា ព្រះបាទទណ្ឌកីនោះ លិចចុះក្នុងកុក្កុលនរកក្តៅនោះ ផេះរមែងចូលទៅតាមទ្វារទាំង ៩ រងើកភ្លើងធំៗធ្លាក់ចុះលើក្បាល ក្នុងកាលរងើកភ្លើងធ្លាក់ចុះលើក្បាលរបស់ព្រះរាជានោះ សរីរៈទាំងមូល ឆេះទ្រលោម ដូចដើមឈើឆេះដោយភ្លើង ដូច្នោះ ទុក្ខវេទនាដ៏មានកម្លាំង រមែងប្រព្រឹត្តទៅ ព្រះរាជានោះកាលមិនអាចអត់សង្កត់បាន ក៏ស្រែកពេទ៍រត់ទៅ ។ សរភង្គតាបសហែកផែនដី បង្ហាញឲ្យឃើញព្រះរាជាដែលឆេះក្នុងកុក្កុលនរកនោះ មហាជនដល់នូវការតក់ស្លុត ព្រះមហាសត្វដឹងថា មហាជនភ័យខ្លាចក្រៃលែង ទើបឲ្យនរកនោះ អន្តរធានទៅ ។

បទថា **ធម្មំ ភណន្តេ** សេចក្តីថា បុគ្គលពោលធម៌ គឺកុសលកម្មបថ ១០ ។ បទថា **សមណោ** បានដល់ លោកជាអ្នកបន្សាត់បាបហើយ ។ បទថា **អទូសកេ** បានដល់ ជាអ្នកមិនខុស ។ បទថា **ឆាលិកឹរំ** បានដល់ ព្រះរាជាដែលមាននាមយ៉ាងនេះ ។ បទថា **បរត្ថ** សេចក្តីថា បុគ្គលណា កើតហើយក្នុងបរលោក គឺនរក ។ បទថា **សង្គម្ម** សេចក្តីថា ឆ្កែទាំងឡាយ ធំៗ មកអំពីទិសផ្សេងៗ ប្រជុំគ្នាខាំព្រះបាទនាឡិកីរាជនោះ ។

បានឮថា ព្រះរាជានាឡិកីរាជ សោយរាជ្យក្នុងទន្តបុរនគរ ក្នុងកាលិង្គរដ្ឋនោះ មហាតាបសមួយរូប ចោមរោមដោយតាបស ៥០០ មកអំពីហិមពាន្ត ស្នាក់នៅក្នុងព្រះរាជឧទ្យាន សម្តែងធម៌ដល់មហាជន ។ ពួកអាមាត្យក្រាបទូលព្រះរាជាថា តាបសមានធម៌នៅក្នុងព្រះរាជឧទ្យាន ឯព្រះរាជា ជាអ្នកមិនតាំងនៅក្នុងធម៌ គ្រងរាជ្យដោយអធម៌ កាលអាមាត្យទាំងឡាយនាំគ្នាសរសើរតាបស ព្រះរាជាទ្រង់ព្រះតម្រិះថា យើងនឹងស្តាប់ធម៌ ហើយយាងទៅកាន់ព្រះរាជឧទ្យាន ថ្វាយបង្គំតាបសហើយប្រថាប់គង់ ។ តាបសកាលធ្វើបដិសណ្ឋារៈជាមួយព្រះរាជា ទើបក្រាបទូលថា សូមថ្វាយព្រះពរមហាបពិត្រ ទ្រង់គ្រងរាជ្យដោយធម៌ឬ ទ្រង់មិនបៀតបៀនមហាជនទេឬ ព្រះរាជាទ្រង់ព្រះពិរោធនូវពាក្យរបស់តាបស ទ្រង់ព្រះតម្រិះថា អស់កាលមានប្រមាណប៉ុណ្ណេះ ប្រហែលជាជដិលកោងនេះ ពោលតែទោសរបស់អញប៉ុណ្ណេះ ក្នុងសម្នាក់របស់អ្នកនគរ ណ្ហើយចុះ អញនឹងធ្វើឲ្យសក្តិសម ហើយត្រាស់និមន្តថា ស្អែកនេះ សូមលោកម្ចាស់ទាំងឡាយមកកាន់ទ្វាររាជវាំងរបស់ខ្ញុំ ដូច្នេះ ។

ស្អែកឡើង ទើបត្រាស់ឲ្យយកលាមកដាក់ពេញក្រឡ កាលតាបសមកហើយ ត្រាស់ឲ្យជួសលាមក ដាក់ក្នុងកាជនៈកិច្ចការបស់តាបសទាំងនោះរហូតពេញឲ្យបិទទ្វារ ហើយត្រាស់ឲ្យមនុស្សយកអង្រែ និងដំបងដែកវាយក្បាលរបស់ឥសីទាំងឡាយ ឲ្យចាប់ផ្ទួងសក់អូសមកឲ្យឆ្កែស៊ី ខ្លួនឯងក៏ចូលទៅកាន់ផែនដី ដែលប្រេះជា ២ ក្នុងទីនោះ កើតក្នុងសុនខមហានរក ។ ខ្លួនប្រាណរបស់ព្រះរាជាក្នុងនរកនោះ មានទំហំ ៣ គាវុត ។ លំដាប់នោះ ឆ្កែទាំងឡាយមានខ្លួនធំប៉ុនៗដំរីមានពណ៌ ៥ ប្រការ ដេញតាមខាំព្រះរាជានោះ ត្របាក់ឲ្យដួលចុះ ត្រង់ផែនដីដែកដែលឆេះទ្រលោមប្រមាណ ៩ យោជន៍ហើយ ត្របាក់សាច់ពេញៗមាត់ ទំពាស៊ីព្រះរាជាដែលកំពុងបម្រះនទៀល ព្រះមហាសត្វហែកផែនដីជា ២ ចំណែក ហើយបង្ហាញឲ្យឃើញនរកនោះ ដឹងថា មហាជនតក់ស្លុតហើយ ក៏បណ្ដាលឲ្យអន្តរធានទៅ ។

បទថា **អជជ្ជុនោ** បានដល់ ព្រះរាជាព្រះនាមថា សហស្សពាហុ ។ បទថា **អង្គីរសំ** បានដល់ ឥសីដែលមានឈ្មោះយ៉ាងនេះ ព្រោះមានរស្មីចេញអំពីអវយវៈទាំងឡាយ ។ បទថា **ហេឋយិត្វា** សេចក្ដីថា ព្រះរាជាអជ្ជុនបៀតបៀនឥសីឈ្មោះអង្គីរស គឺយកកៅទណ្ឌ ( ធ្នូ ) ដែលលាបដោយថ្នាំពិស បាញ់ឲ្យស្លាប់ បានឮថា ព្រះបាទអជ្ជុននោះ សោយរាជ្យក្នុងកេតករាជធានី មហិសករដ្ឋ ទ្រង់ចេញបរបាញ់សត្វ កាលសម្លាប់ម្រឹគបានហើយ ក៏ពេញចិត្តសោយសាច់ដែលអាំងលើរងើកភ្លើង ។ ថ្ងៃមួយ ទ្រង់ចាំស្កាត់ផ្លូវម្រឹគដែលមក ប្រថាប់ឈរមើលម្រឹគទាំងឡាយ ។ កាលនោះ អង្គី

វសេតាបសឡើងលើដើមតង្កៀបក្ដាមមួយក្បែរនោះ កំពុងបេះផ្លែឈើ លែងមែកឈើដែលបេះផ្លែហើយទៅវិញ ។ ព្រោះសំឡេងមែកឈើដែលលែងទៅ ហ្វូងម្រឹគដែលមកដល់ទីនោះហើយ ក៏រត់ទៅ ។ ព្រះរាជាខឹងក្រោធ យកព្រួញដែលលាបដោយថ្នាំពិសបាញ់តាបស ។ តាបសធ្លាក់ចុះមក ក្បាលទង្គិចនឹងគល់គគីរ ធ្វើកាលកិរិយាត្រង់ចុងឈើស្រួចនោះឯង ។ ខណៈនោះ ព្រះរាជាក៏ចូលទៅកាន់ផែនដីដែលប្រេះជា ២ ភាគ កើតក្នុងសត្តិសូលនរក ។ សរីរៈព្រះរាជាទំហំ ៣ គាវុត និរយបាលក្នុងនរកនោះ វាយដោយអាវុធដែលឆេះច្រាលឆ្អៅ បញ្ចូឲ្យឡើងភ្នំដែកដ៏ក្ដៅ ក្នុងពេលដែលព្រះរាជានោះស្ថិតនៅលើកំពូលភ្នំ ខ្យល់វេមែងប្រហារ ព្រះរាជាក៏រមៀលធ្លាក់មកដោយកម្លាំងខ្យល់ ។ ខណៈនោះ លំពែងដែកដែលឆេះសន្ធោសន្ធៅ ទំហំប៉ុនដើមត្នោត ផុសឡើងអំពីផែនដីដែកដែលមានទំហំ ៩ យោជន៍ ព្រះរាជានោះយកក្បាលបោកនឹងចុងលំពែងនោះ ហើយត្រូវលំពែងដោតក្ដាង ខណៈនោះ ផែនដីក៏ឆេះដោយភ្លើង លំពែងក៏ឆេះដោយភ្លើង សរីរៈរបស់ព្រះរាជាក៏ក្រហមដូចរងើកភ្លើង ព្រះរាជាស្រែករោទ៍ ឆេះក្នុងនរកនោះ ព្រះមហាសត្វញុំាងផែនដីឲ្យបែកជា ២ ហើយបង្ហាញនរកនោះ ដឹងថាមហាជនតក់ស្លុតហើយ ទើបឲ្យអន្តរធានទៅវិញ ។

បទថា **ខណ្ឌសោ** សេចក្ដីថា ព្រះបាទកលាពុបានឲ្យគេកាត់ដៃទាំង ២ ជើងទាំង ២ ត្រចៀកនិងច្រមុះរបស់ខន្តិវាទិតាបស ធ្វើឲ្យជាកំណាត់តូចធំ ។ បទថា **អទូសកំ** បានដល់ ជាអ្នកមិនមានកំហុស ។ ព្រះបាទកលាពុ កាល

ឲ្យកាត់យ៉ាងនេះហើយ ត្រាស់ឲ្យវាយដោយផ្តៅសម្រាប់ប្រហារ ១០០០ រំពាត់ ហើយចាប់ផ្តួងសក់អូសមកឲ្យដេកផ្កាប់មុខ យកកែងជើងប្រហារត្រង់ខ្នង ធ្វើឲ្យដល់នូវទុក្ខវេទនាធំ ។ បទថា **កលាពុរិចី** សេចក្តីថា ព្រះបាទកលាពុនោះចូលដល់អវីចិមហានរក ។ បទថា **កដុកំ** សេចក្តីថា ចូលដល់នរកដែលមានវេទនាខ្លាំងក្លាបែបនេះ ត្រូវឆេះក្នុងចន្លោះអណ្តាតភ្លើងទាំង ៦ ។ ម្យ៉ាងទៀត រឿងរបស់ព្រះបាទកលាពុដោយពិស្តារ ខ្ញុំបានពោលទុកហើយក្នុងខន្តិវាទិជាតកឯណោះ ។

បទថា **អញ្ញានិ ចាបិដ្ឋតរានិ ចេត្ថ** សេចក្តីថា កុលបុត្តជាបណ្ឌិត ស្តាប់នរកនោះ និងនរកដទៃ ដែលគ្រោតគ្រាតជាងនរកនោះ ។ បទថា **ធម្មញ្ចរេ** សេចក្តីថា បពិត្រសក្កទេវរាជ កុលបុត្តដែលជាបណ្ឌិតដឹងថា នរកទាំង ៤ នេះ ព្រះរាជា ៤ អង្គកើតក្នុងនរកតែប៉ុណ្ណោះក៏មិនមែន ដែលពិតនោះ សូម្បីនរកដទៃ និងព្រះរាជាដទៃ ក៏គង់កើតក្នុងនរកដូចគ្នា ដូច្នេះហើយ គប្បីប្រព្រឹត្តធម៌ក្នុងសមណព្រាហ្មណ៍ គឺប្រគេនចតុប្បច្ច័យ ចាត់ការរក្សាការពារដោយប្រពៃតាមធម៌ ។

កាលព្រះមហាសត្វសម្តែងទីកើតរបស់ព្រះរាជាទាំង ៤ យ៉ាងនេះហើយ ព្រះរាជាទាំង ៣ អង្គ ក៏អស់សង្ស័យ ។ បន្ទាប់អំពីនោះ សក្កទេវរាជកាលត្រាស់សួរបញ្ហា ៤ ដែលសល់ ទើបត្រាស់គាថាដោយសេចក្តីថា

ខ្ញុំត្រេកអរនឹងសុភាសិតរបស់លោកម្ចាស់ហើយ សូមសួរនូវ
ប្រស្នាដទៃ ចំពោះលោកម្ចាស់ទៀត សូមលោកម្ចាស់ប្រាប់

នូវប្រស្នានោះ បណ្ឌិតទាំងឡាយពោលនូវបុគ្គលបែបដូចម្ដេច ជាជាអ្នកមានសីល ពោលនូវបុគ្គលបែបដូចម្ដេច ជាជាអ្នកមានប្រាជ្ញា ពោលនូវបុគ្គលបែបដូចម្ដេច ជាជាសប្បុរស សិរីមិនលះបង់នូវបុគ្គលបែបដូចម្ដេច ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កថំសុ សិរិ នោ ជហាតិ** សេចក្ដីថា សិរីដែលបុគ្គលបានហើយ រមែងមិនលះបុរសដូចម្ដេច ។

លំដាប់នោះ ព្រះមហាសត្វ កាលវិសជ្ជនាបញ្ហារបស់សក្កទេវរាជ បានពោលគាថា ៤ ថា

បុគ្គលណាក្នុងលោកនេះ ជាអ្នកសង្រួមដោយកាយ ដោយវាចា ទាំងមិនធ្វើនូវបាបតិចតួចដោយចិត្ត មិនពោលពាក្យឡេះឡោះ ព្រោះហេតុនៃខ្លួន បណ្ឌិតទាំងឡាយពោលនូវបុគ្គលបែបនោះ ជាជាអ្នកមានសីល ។ បុគ្គលណា កាលគិតនូវប្រស្នាដ៏ជ្រាលជ្រៅដោយចិត្ត ហើយមិនធ្វើនូវអំពើអាក្រក់ ដែលកន្លងនូវប្រយោជន៍ មិនលះបង់នូវចំណែកនៃប្រយោជន៍ ដែលមកក្នុងកាលគួរ បណ្ឌិតទាំងឡាយពោលនូវបុគ្គលបែបនោះ ជាជាអ្នកមានបញ្ញា ។ បុគ្គលណា ជាកតញ្ញូកតវេទី មានប្រាជ្ញា មានមិត្តល្អ មានការសេពគប់មាំ ធ្វើនូវកិច្ចដោយគោរពចំពោះបុគ្គលអ្នកដល់នូវសេចក្ដីទុក្ខ បណ្ឌិតទាំងឡាយ ពោលនូវបុគ្គលបែបនោះជាជាអ្នកសប្បុរស ។ បុគ្គលណា ជាអ្នក

ប្រកបដោយគុណទាំងពួងនេះ ជាអ្នកមានសទ្ធា មានចិត្តទន់ ជាអ្នកចែករំលែក ជាអ្នកដឹងនូវពាក្យ ( របស់ស្មូម ) សិរីមិន លះបង់នូវបុគ្គលជាអ្នកសង្គ្រោះ មានវាចាពីរោះ មានវាចាម៉ត់ចត់បែបនោះទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កាយេន** ជាដើម លោកពោលទុកដោយអំណាចនៃសុចរិតដោយទ្វារទាំង ៣ ។ បទថា **ន អត្តហេតុ** នេះ ជាមាតិកានៃទេសនាប៉ុណ្ណោះ អធិប្បាយថា មិនពោលឡេះឡោះ ព្រោះហេតុនៃខ្លួនក្ដី ព្រោះហេតុនៃអ្នកដទៃក្ដី ព្រោះហេតុនៃទ្រព្យក្ដី ព្រោះហេតុនៃយសក្ដី ព្រោះហេតុនៃលាភក្ដី ព្រោះហេតុប្រាថ្នាអាមិសក្ដី សូម្បីអត្ថនេះ នឹងសម្រេចដោយបទនេះថា សង្រួមដោយវាចាដូច្នេះក៏ពិត តែទោះជាយ៉ាងនោះ ដើម្បីសម្ដែងអត្ថនោះឲ្យធ្ងន់ គួរជ្រាបថា លោកពោលយ៉ាងនេះទៀតថា បាបដែលឈ្មោះថា បុគ្គលច្រើនដោយការពោលកុហក មិនធ្វើមិនមាន ។

បទថា **គម្ភីរបញ្ហំ** សេចក្ដីថា បុគ្គលណាគិតបញ្ហាដែលជ្រាលជ្រៅដែលកំបាំងទាំងដោយអត្ថនិងបាលី ដូចគ្នានឹងបញ្ហាដែលមកក្នុងសត្តុភស្តជាតក ( សេនកជាតក ) សម្ភវជាតក និងឧម្មង្គជាតក ។ បទថា **មនសាភិចិន្តយំ** សេចក្ដីថា បុគ្គលណាគិតបានដោយចិត្ត ចាក់ធ្លុះនូវអត្ថ អាចពោលដោះស្រាយ ធ្វើឲ្យប្រាកដ ដូចញាំងព្រះចន្ទនិងព្រះអាទិត្យឲ្យតាំងឡើងរាប់ពាន់ ។ បទថា **នច្ចាហិតំ** សេចក្ដីថា បុគ្គលណាមិនធ្វើកម្ម ដែលមិនជាប្រយោជន៍ក្រៃលែង គឺរំលងប្រយោជន៍ ជាអ្នកគ្រោតគ្រាត ក្ដៅក្រហាយ ទារុណ

ម្យ៉ាងទៀត ដើម្បីញ៉ាំងអត្ថនោះឲ្យជាក់ច្បាស់ គួរពោលកូវិបញ្ហាថា បណ្ឌិតទាំងឡាយ រមែងមិនធ្វើបាបកម្ម ព្រោះហេតុគ្រាន់តែសេចក្ដីសុខរបស់ខ្លួន សប្បុរសទាំងឡាយ ទោះទុក្ខពាល់ត្រូវ រមែងមិនលះបង់ធម៌ ព្រោះការស្រឡាញ់និងការស្អប់ឡើយ ។

បទថា **កាលាគតំ** សេចក្ដីថា បុគ្គលណា កាលញ៉ាំងទានជាដើម ទាំងនេះ ឲ្យដល់ព្រម ដោយគិតថា កាលនេះជាកាលគួរឲ្យទាន ឬជាកាលដែលរក្សាសីល ជាកាលដែលត្រូវរក្សាឧបោសថ ជាកាលតាំងមាំក្នុងសរណៈ ជាកាលធ្វើបព្វជ្ជា ជាកាលបំពេញសមណធម៌ ជាវារៈដែលគួរបំពេញវិបស្សនា ឈ្មោះថា មិនក្ដៅក្រហាយ គឺមិនញ៉ាំងផ្លូវនៃប្រយោជន៍ដែលមកដល់ដោយកាលឲ្យវិនាសទៅ ។ បទថា **តថាវិធំ** សេចក្ដីថា នៃសក្កៈ ព្រះសព្វញ្ញុពុទ្ធក្ដី ព្រះបច្ចេកពុទ្ធក្ដី ព្រះមហាសត្វក្ដី កាលនឹងពោលដល់បុគ្គលមានបញ្ញារមែងពោលដល់បុគ្គលបែបនេះ ។

ក្នុងបទថា **យោ វេ** នោះ មានអធិប្បាយថា បុគ្គលណាស្គាល់នូវគុណដែលអ្នកដទៃធ្វើហើយដល់ខ្លួន ឈ្មោះថា ជាបុគ្គលកតញ្ញូ ម្យ៉ាងទៀត កាលដឹងយ៉ាងនេះហើយ ធ្វើនូវការតបស្នងនូវគុណរបស់បុគ្គលនោះ ដែលបានធ្វើគុណទុកដល់ខ្លួន ឈ្មោះថា ជាកតវេទី ។ បទថា **ទុក្ខិតស្ស** សេចក្ដីថា បុគ្គលណា លើកនូវសេចក្ដីទុក្ខនៃសម្លាញ់របស់ខ្លួនដែលដល់នូវទុក្ខ យកមកទុកក្នុងខ្លួន ជួយធ្វើនូវកិច្ចដែលកើតឡើងដល់សម្លាញ់នោះ ដោយដៃរបស់ខ្លួនដោយគោរព ព្រះពុទ្ធជាដើម រមែងហៅបុគ្គលនោះ ដែលមាន

សភាពបែបនេះថា ជាសប្បុរស ម្យ៉ាងទៀត ធម្មតាសប្បុរសទាំងឡាយ រមែងជាអ្នកមានកតញ្ញូកតវេទី ព្រោះដូច្នោះ គួរពោលដល់ជាតក ដូចជាសតបត្តជាតក ចុល្លហង្សជាតក និងមហាហង្សជាតកជាដើម ។

បទថា **ឋានេហិ សព្វេហិ** សេចក្ដីថា បពិត្រសក្កទេវរាជ បុគ្គលណាចូលដល់ដោយគុណសម្បត្តិ មានសីលជាដើម ដូចពោលហើយខាងដើមទាំងអស់នេះ ។ បទថា **សទ្ធោ** សេចក្ដីថា ប្រកបដោយឱកប្បនសទ្ធា ។ បទថា **មុទុ** បានដល់ ជាអ្នកមានប្រក្រតីចរចាគួរជាទីស្រឡាញ់ ។ បទថា **សំវិភាគី** សេចក្ដីថា ឈ្មោះថា ជាអ្នកចែករំលែកដោយល្អ ព្រោះភាពជាបុគ្គលដែលល្អក្រៃលែង ក្នុងការចែកនូវសីល ចែកនូវទាន ឈ្មោះថា **វទញ្ញូ** ព្រោះអាចដឹងនូវពាក្យរបស់យាចក ហើយទើបឲ្យ ។ បទថា **សង្គាហកំ** សេចក្ដីថា ឈ្មោះថា **សង្គាហកំ** ព្រោះសង្គ្រោះជននោះៗ ដោយសង្គហវត្ថុ ៤ ។ ឈ្មោះថា **សខិលំ** ព្រោះពោលពាក្យផ្អែមល្ហែម ។ ឈ្មោះថា **សណ្ហវាចំ** ព្រោះមានពាក្យរាបស្មើ ។ បទថា **តថាវិធំ ឆោ** សេចក្ដីថា សិរី ពោលគឺយស និងលាភដ៏លើសដែលបានហើយ រមែងមិនលះនូវបុគ្គលបែបនោះ គឺសិរីរបស់បុគ្គលនោះរមែងមិនវិនាសទៅ ។

ព្រះមហាសត្វវិសជ្ជនាបញ្ហា ៤ ដូចញុំាងព្រះចន្ទពេញវង់ ឲ្យតាំងឡើងកណ្ដាលលម្ហដូច្នោះ ដោយប្រការដូច្នេះ បន្ទាប់អំពីនោះ ជាបុច្ឆានិងវិសជ្ជនាបញ្ហាដ៏សេស សក្កទេវរាជត្រាស់គាថានេះថា

ខ្ញុំរីករាយនឹងសុភាសិតរបស់លោកហើយ សូមសួរនូវប្រស្នា

ដទៃទឹងលោកទៀត សូមលោកម្ចាស់ប្រាប់នូវប្រស្នានោះ បណ្ឌិតទាំងឡាយ ពោលនូវសីលផង សិរីផង ធម៌របស់សប្បុរសផង ប្រាជ្ញាផង តើគុណជាតិណាប្រសើរបំផុត ។

សរភង្គតាបសពោលថា

អ្នកឈ្លាសវៃទាំងឡាយពោលថា ប្រាជ្ញាជាគុណជាតិប្រសើរបំផុត ដូចស្តេចនៃផ្កាយ ( ព្រះចន្ទ ) ដ៏ប្រសើរជាងផ្កាយទាំងឡាយ ទុកជាសីលក្តី សិរីក្តី ធម៌របស់សប្បុរសក្តី ក៏ប្រព្រឹត្តទៅតាមបុគ្គលអ្នកមានប្រាជ្ញា ។

សក្កទេវរាជពោលថា

ខ្ញុំរីករាយនឹងសុភាសិតរបស់លោកហើយ សូមសួរប្រស្នាដទៃនឹងលោកទៀត សូមលោកប្រាប់ប្រស្នានោះ បុគ្គលក្នុងលោកនេះ ធ្វើដូចម្តេច ធ្វើការងារអ្វី ប្រព្រឹត្តដូចម្តេច សេពនូវអ្វី ទើបបាននូវប្រាជ្ញា សូមលោកម្ចាស់ ប្រាប់នូវបដិបទានៃប្រាជ្ញា ក្នុងកាលឥឡូវនេះ បុគ្គលធ្វើដូចម្តេច ទើបជាអ្នកមានប្រាជ្ញា ។

សរភង្គតាបសពោលថា

បុគ្គលគប្បីសេពគប់នូវពួកអ្នកចម្រើន ( ដោយប្រាជ្ញា ) អាចដឹងនូវហេតុដ៏ល្អិត ជាពហុស្សូត គប្បីជាអ្នករៀនផង ជាអ្នកសាកសួរផង គប្បីស្តាប់នូវសុភាសិតទាំងឡាយ ដោយគោរពផង បុគ្គលធ្វើយ៉ាងនេះ ទើបជាអ្នកមានប្រាជ្ញា ។ បុគ្គលជា

អ្នកប្រាជ្ញនោះ ឃើញច្បាស់នូវកាមគុណទាំងឡាយ ថាមិនទៀង ថាជាទុក្ខ ថាជារោគ បុគ្គលឃើញច្បាស់យ៉ាងនេះ ទើបលះបង់នូវឆន្ទៈក្នុងកាមទាំងឡាយដែលជាទុក្ខ ជាភ័យធំបាន ។ បុគ្គលនោះប្រាសចាករាគៈ កម្ចាត់បង់នូវទោសៈហើយ គប្បីចម្រើននូវមេត្តាចិត្ត រកប្រមាណមិនបាន ដាក់ចុះនូវអាជ្ញាក្នុងសត្វទាំងពួង ជាអ្នក គឺបុគ្គលណាមួយតិះដៀលមិនបាន រមែងទៅកើតក្នុងឋានព្រហ្ម ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សីលំ** បានដល់ អាចារសីល ។ បទថា **សិរិ** បានដល់ ឥស្សរិយយស ។ បទថា **សតញ្ច ធម្មំ** បានដល់ សប្បុរិសធម៌ ។ បទថា **បញ្ញំ** សេចក្តីថា សក្កៈត្រាស់សួរថា លោកអ្នកឈ្លាសទាំងឡាយ រមែងពោលដល់បណ្តាធម៌ទាំង ៤ ប្រការនេះយ៉ាងនេះថា មួយណាប្រសើរជាងគ្នា ។ បទថា **បញ្ញា ហិ** សេចក្តីថា ព្រះមហាសត្វក្រាបទូលថា បពិត្រសក្កៈ ក្នុងធម៌ ៤ យ៉ាងនេះ ឈ្មោះថា បញ្ញានេះ បុគ្គលអ្នកឈ្លាសទាំងឡាយមានព្រះពុទ្ធជាដើម ពោលថាប្រសើរ ដូចព្រះចន្ទចោមរោមដោយហ្វូងតារា ព្រះចន្ទនោះឯង ប្រសើរជាងតារាទាំងនោះ យ៉ាងណា ធម៌ទាំង ៣ គឺសីល សិរីនិងធម៌របស់សប្បុរសទាំងឡាយក៏យ៉ាងនោះដែរ ។ បទថា **អន្វាយិកា បញ្ញវតោ ភវន្តិ** សេចក្តីថា រមែងប្រព្រឹត្តទៅតាមបុគ្គលដែលមានបញ្ញាទាំងនោះ គឺជាបរិវារជនរបស់បញ្ញានោះឯង ។ បទថា **កថំ ករោ** ជាដើម ជាវេវចនៈនៃគ្នានឹងគ្នាប៉ុណ្ណោះ ។ បទថា **កថំ ករោ** សេចក្តីថា សក្កទេវរាជ

ត្រាស់សួរថា បុគ្គលរមែងធ្វើនូវកម្មណា ប្រព្រឹត្តដូចម្តេច សេពនូវកម្មដូចម្តេច រមែងបាននូវបញ្ញាក្នុងលោកនេះ សូមលោកប្រាប់បដិបទានៃបញ្ញាតែម្យ៉ាង ខ្ញុំប្រាថ្នានឹងដឹងសត្វដែលត្រូវស្លាប់ជាសភាវៈ ធ្វើដូចម្តេច ទើបជាបុគ្គលឈ្មោះថា ជាអ្នកមានបញ្ញា ។

បទថា **ពុទ្ធេ** បានដល់ បណ្ឌិតដែលដល់នូវសេចក្តីចម្រើន គឺការដឹង ។ បទថា **និបុណោ** សេចក្តីថា អាចដឹងហេតុការណ៍ដ៏សុខុម ។ បទថា **ឃរំ ករោ** សេចក្តីថា ចំណែកសរភង្គតាបសឆ្លើយថា បុគ្គលណាសមាគម គប់រក អង្គុយជិតនូវបុគ្គលមានប្រការដូចពោលមកហើយយ៉ាងនេះ រមែងរៀនបាលី សាកសួរនូវអធិប្បាយរឿយៗ ផ្ទៀងនូវសោត ស្តាប់នូវសុភាសិតដោយគោរព ដូចបុគ្គលចារឹកស្នាមលើផ្ទាំងថ្ម ឬដូចយកធើងមាសដាក់ខ្លាញ់រាជសីហ៍ដូច្នោះ បុគ្គលដែលធ្វើយ៉ាងនេះរមែងជាអ្នកមានបញ្ញា ព្រះមហាសត្វពោលបដិបទានៃបញ្ញាយ៉ាងនេះ ដូចគ្នានឹងញុំាងព្រះអាទិត្យឲ្យរះឡើងនាទិសខាងកើតនៃលោកធាតុ កាលនឹងពោលគុណរបស់បញ្ញានោះក្នុងឥឡូវនេះ ទើបពោលពាក្យជាដើមថា បុគ្គលអ្នកមានបញ្ញានោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កាមគុណោ** សេចក្តីថា បុគ្គលដែលមានបញ្ញានោះ រមែងឃើញ គឺពិចារណាចំណែកនៃកាមទាំងឡាយ ដោយជារបស់មិនទៀង ព្រោះអត្ថថា មានហើយប្រែជាមិនមាន ដោយភាពជាទុក្ខ ព្រោះជាទីតាំងនៃទុក្ខ ទាំងក្នុងបច្ចុប្បន្ននិងសម្បរាយភព ដោយភាពជារោគ ព្រោះមានព្រមនៃរោគ គឺទុក្ខ ៩៨ ប្រការ អាស្រ័យកាមកើតឡើង ។ បទថា

**ឯវំ វិបស្សិ** សេចក្តីថា កាលបុគ្គលសម្លឹងឃើញនូវការមិនទៀងជាដើម របស់កាមទាំងឡាយ ដោយហេតុទាំងនេះ ដឹងច្បាស់ថា ទីបំផុតនៃទុក្ខដែលអាស្រ័យកាមកើតឡើងមិនមាន លះនូវកាមតែម្យ៉ាងប៉ុណ្ណោះជាសុខ ហើយតែងលះបាននូវការពេញចិត្តក្នុងកាមដែលជាទុក្ខ ជាភ័យធំ ។

បទថា **ស វីតរាគោ** សេចក្តីថា បពិត្រសក្កៈ បុគ្គលនោះប្រាសចាករាគៈយ៉ាងនេះ កម្ចាត់នូវទោសដែលកើតឡើងដោយអំណាចអាឃាតវត្ថុ ៩ ប្រការជាសភាវៈហើយ គប្បីចម្រើនមេត្តាចិត្ត កាលចម្រើនមេត្តាចិត្ត ឈ្មោះថា មិនមានប្រមាណ ព្រោះមានសត្វប្រមាណមិនបានជាអារម្មណ៍ ហើយជាអ្នកមានឈានមិនសាបសូន្យ ដែលបុគ្គលតិះដៀលមិនបាន រមែងកើតក្នុងព្រហ្មលោក ។

កាលព្រះមហាសត្វពោលទោសនៃកាមទាំងឡាយយ៉ាងនេះ ព្រះរាជាទាំង ៣ អង្គនោះ មួយអន្លើដោយពួកពលនិកាយ លះនូវសេចក្តីត្រេកអរក្នុងបញ្ចកាមគុណបានដោយតទង្គប្បហាន ។ ព្រះមហាសត្វ ដឹងដូច្នោះហើយ ទើបពោលគាថា ដោយអំណាចការត្រេកអរនៃជនទាំងនោះថា

បពិត្រព្រះបាទអដ្ឋកៈ ការយាងមកនៃព្រះអង្គផង នៃព្រះបាទភីមរថៈផង នៃព្រះបាទកាលិង្គៈ ដែលមានតេជានុភាពដ៏រុងរឿងផង ជាព្រះរាជដំណើរមានឫទ្ធិដ៏ច្រើន ( ព្រោះ ) កាមរាគនៃព្រះអង្គទាំងអស់ បានលះបង់ហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មហិទ្ធិយំ** សេចក្តីថា ការមានមហិទ្ធិឫទ្ធិ គឺ

ទូលំទូលាយរុងរឿងធំ ។ បទថា **តវមដ្ឋក** កាត់បទជា **វត អដ្ឋកា** សេចក្តីថា របស់ព្រះអង្គដែលមានព្រះនាមថាអដ្ឋកៈ ។ បទថា **បហីនោ** សេចក្តីថា កាមរាគៈដែលទ្រង់គ្រប់អង្គលះបានហើយដោយតទង្គប្បហាន ។

ព្រះរាជាទាំងឡាយ ទ្រង់ស្តាប់នូវពាក្យនោះហើយ កាលទ្រង់សរសើរព្រះមហាសត្វ ទើបនាំគ្នាត្រាស់គាថាដោយសេចក្តីថា

លោកម្ចាស់បានដឹងច្បាស់នូវចិត្តរបស់បុគ្គលដទៃទុំៈ យ៉ាងនេះ
ឯង ឯកាមរាគ យើងខ្ញុំទាំងអស់គ្នាបានលះហើយ សូមលោក
ម្ចាស់ធ្វើឱកាស ដើម្បីអនុគ្រោះ ( បព្វជ្ជា ) ឲ្យយើងខ្ញុំបាន
ដល់នូវគតិរបស់លោក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនុគ្គហាយ** សេចក្តីថា ព្រះរាជាទាំងឡាយត្រាស់ថា សូមលោកធ្វើឱកាសដើម្បីជាប្រយោជន៍ដល់បព្វជ្ជារបស់ខ្ញុំ តាមដែលពួកខ្ញុំបួសហើយគប្បីត្រាស់ដឹង គឺសម្រេចនូវសេចក្តីសម្រេច តាមគតិរបស់លោក បានដល់ គប្បីចាក់ធ្លុះបាននូវគុណដែលលោកចាក់ធ្លុះហើយ ។

លំដាប់នោះ កាលព្រះមហាសត្វធ្វើឱកាសដល់ព្រះរាជាទាំងនោះ ទើបពោលគាថាបន្តទៀតថា

អាត្មាភាពធ្វើឱកាស ដើម្បីអនុគ្រោះ ព្រោះថា មហារាជ
ទាំងឡាយ បានលះបង់នូវកាមរាគ ដោយប្រការដូច្នោះមែន
មហារាជទាំងឡាយ ចូរញុំាងកាយឲ្យជ្រួតជ្រាបដោយបីតិដ៏កើត
( អំពីឈាន ) ដ៏ធំទូលាយ ឲ្យមហារាជទាំងឡាយ បាន

ដល់នូវគតិរបស់អាត្មាភាព ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ផរាម កាយំ** សេចក្តីថា ញ៉ាំងកាយឲ្យជ្រួតជ្រាបដោយបីតិដែលកើតអំពីឈានដ៏ទូលាយ ។

ព្រះរាជាទាំងនោះទ្រង់ស្តាប់ដូច្នោះ កាលទ្រង់ព្រមទទួល ទើបត្រាស់គាថាដោយសេចក្តីថា

បពិត្រលោកអ្នកមានប្រាជ្ញា ដូចផែនដី លោកម្ចាស់ពោលពាក្យណាៗ យើងខ្ញុំនឹងធ្វើតាមពាក្យរបស់លោកទាំងអស់នោះៗ យើងខ្ញុំនឹងញ៉ាំងកាយឲ្យជ្រួតជ្រាប ដោយបីតិដ៏ធំទូលាយ ឲ្យយើងខ្ញុំបានដល់នូវគតិរបស់លោក ដូច្នេះ ។

លំដាប់នោះ ទើបព្រះមហាសត្វឲ្យនូវបព្វជ្ជាដល់ព្រះរាជាទាំងនោះ មួយអន្លើដោយពលនិកាយ កាលបញ្ជូនពួកឥសីទៅ ទើបពោលគាថានេះថា

ការបូជានេះ ពួកឥសីបានធ្វើហើយដល់ឥសីឈ្មោះ កីសវច្ឆៈ ឥសីទាំងឡាយដ៏ចម្រើន មានសភាពល្អ ចូរទៅចុះ អ្នកទាំងឡាយ ចូរត្រេកអរក្នុងឈាន មានចិត្តតាំងមាំសព្វៗកាលចុះ នេះជាសេចក្តីត្រេកអរដ៏ប្រសើររបស់បព្វជិត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **គច្ឆន្តុ** សេចក្តីថា ព្រះមហាសត្វពោលថា អ្នកទាំងឡាយចូរទៅកាន់លំនៅដើមរៀងៗខ្លួនចុះ ។

ឥសីទាំងឡាយទទួលពាក្យរបស់មហាសត្វហើយ ក៏នមស្ការលា ហោះឡើងទៅកាន់អាកាស ត្រឡប់ទៅកាន់លំនៅរបស់ខ្លួន ។ ឯសក្កទេវរាជទ្រង់

*ក្រោកឡើងអំពីអាសនៈ ទ្រង់សរសើរព្រះមហាសត្វ ផ្គងអញ្ជលី នមស្ការព្រះមហាសត្វ ដូចនមស្ការព្រះអាទិត្យ មួយអន្លើដោយទេវបរិស័ទ ចៀសចេញទៅ ។*

*ព្រះសាស្តាទ្រង់ជ្រាបសេចក្តីនោះ ទើបត្រាស់គាថាទាំងនេះថា*

*ទេវតាទាំងឡាយនោះ មានយស បានស្តាប់នូវគាថាទាំងឡាយដ៏ប្រកបដោយប្រយោជន៍ដ៏ក្រៃលែង ដែលឥសីជាបណ្ឌិតពោលល្អហើយ ជាអ្នកបានចេះដឹងហើយអនុមោទនា ចៀសចេញទៅកាន់ទេវបុរី ។ គាថាទាំងឡាយនេះ មានអត្ថមានព្យញ្ជនៈដ៏បរិសុទ្ធិ ដែលឥសីជាបណ្ឌិតពោលល្អហើយ បុគ្គលឯណានីមួយ ស្តាប់គាថាទាំងឡាយនេះ ធ្វើទុកឲ្យមានប្រយោជន៍ រមែងបាននូវគុណវិសេសខាងដើមនិងខាងចុង លុះបានគុណវិសេសខាងដើមនិងខាងចុងហើយ គប្បីដល់នូវព្រះនិព្វាន ជាគុណមិនឃើញនូវមច្ចុរាជ ដូច្នេះ ។*

*បណ្តាបទទាំងនោះ បទថា* **បរមត្ថសញ្ហិតា** *សេចក្តីថា គាថាទាំងនេះឈ្មោះថា អាស្រ័យនូវព្រះនិព្វាន ព្រោះសម្តែងដល់ការមិនទៀងជាដើម ។ ព្រះបរមសាស្តា កាលទ្រង់សរសើរពាក្យសុភាសិតដែលឲ្យនូវព្រះនិព្វាននៃសរភង្គសាស្តា ទើបត្រាស់ពាក្យជាដើមថា* **ឥមា** *ប្រែថា គាថាទាំងនេះ ដូច្នេះ ។*

*បណ្តាបទទាំងនោះ បទថា* **អត្ថវតី** *សេចក្តីថា គាថាទាំងនេះ ឈ្មោះ*

ថា អាស្រ័យប្រយោជន៍យ៉ាងក្រៃលែង ព្រោះអត្ថថា ឲ្យនូវព្រះនិព្វាន ។ បទថា **សុព្យញ្ជនា** បានដល់ មានព្យញ្ជនៈបរិសុទ្ធ ។ បទថា **សុភាសិតា** សេចក្ដីថា ដែលឥសីជាបណ្ឌិតពោលធ្វើឲ្យគួរស្ដាប់ដោយល្អ គឺពោលទុកល្អហើយ ។ បទថា **អដ្ឋិកត្វា** សេចក្ដីថា បុគ្គលណាដល់នូវសេចក្ដីត្រូវការព្រោះធ្វើភាពជាប្រយោជន៍ដល់ខ្លួន គប្បីស្ដាប់ដោយគោរព ។ បទថា **បុព្វា-បរិយំ** សេចក្ដីថា បឋមជ្ឈានជាគុណវិសេសខាងដើម ទុតិយជ្ឈានជាគុណវិសេសខាងចុង គប្បីបាននូវគុណវិសេសដែលតាំងនៅដោយភាពជាខាងដើម ខាងចុង ដោយអំណាចនៃសមាបត្តិ ៨ ដោយអំណាចនៃមគ្គ ៤ យ៉ាងនេះ ។ បទថា **អធស្សនំ** សេចក្ដីថា គប្បីបានអរហត្តផល ដែលជាគុណវិសេសខាងចុង ហើយសម្រេចព្រះនិព្វានក្នុងទីបំផុត ព្រោះថា បុគ្គលដែលសម្រេចព្រះនិព្វានហើយ រមែងជាបុគ្គលឈ្មោះថា ទៅកាន់ទីដែលមច្ចុរាជមើលមិនឃើញ ។

ព្រះបរមសាស្ដា ទ្រង់កាន់យកកំពូលនៃទេសនាដោយអរហត្តផលយ៉ាងនេះហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ភ្លៀងផ្កាក៏បានធ្លាក់ចុះក្នុងឈាបនដ្ឋានមោគ្គល្លានដូចគ្នា ហើយទ្រង់បានប្រកាសអរិយសច្ច កាលទ្រង់ប្រជុំជាតក ទើបត្រាស់គាថានេះថា

សាលិស្សរតាបស គឺសារីបុត្ត មេណ្ឌិស្សរតាបស គឺកស្សប
បព្វតតាបស គឺអនុរុទ្ធ ទេវិលតាបស គឺកច្ចាយនៈ អនុសិស្ស

តាបស គឺអានន្ទ កិសវច្ឆតាបស គឺកោលិតៈ នារទតាបស គឺឧទាយិត្ថេរ បរិស័ទ ( របស់ពួកតាបស ) គឺពុទ្ធបរិស័ទ សរភង្គតាបសជាពោធិសត្វ គឺតថាគត អ្នកទាំងឡាយ ចូរចាំទុកនូវជាតក យ៉ាងនេះចុះ ដូច្នេះ ។

## អដ្ឋកថា សរភង្គជាតក ចប់

# អលម្ពុសា ជាតក

[ ៦០៧ ] ( អភិសម្ពុទ្ធគាថា ) គ្រានោះព្រះឥន្ទ្រជាធំ គ្របសង្កត់នូវអសុរឈ្មោះវត្រៈ ទ្រង់ជាបិតារបស់ទេវបុត្ត អ្នកឈ្នះ ( សង្គ្រាម ) ទ្រង់ឈ្វេងយល់នូវនាងទេវកញ្ញា ឈ្មោះ អលម្ពុសា ដែលនៅក្នុងរោងឈ្មោះធម្មសភា ហើយបានត្រាស់ថា ។

[ ៦០៨ ] ម្នាលនាង ( អ្នកធ្វើបុរស ) ឲ្យប្រឡូកប្រឡំ ( ដោយកិលេស ) ទេវតាទាំងឡាយក្នុងជាន់តាវត្តិង្ស ព្រមទាំងព្រះឥន្ទ្រ អង្វរនាង ម្នាលនាងអលម្ពុសា ជាស្រ្តីលួងលោមនូវឥសី ចូរនាងទៅរកព្រះឥសិសិង្គៈ ។

[ ៦០៩ ] តាបសនេះ មានវត្ត មានព្រហ្មចរិយធម៌ ត្រេកអរក្រៃលែងក្នុងព្រះនិព្វាន ជាអ្នកចម្រើន ( ដោយគុណ ) កុំឲ្យលោកប្រព្រឹត្តកន្លងនូវយើងទាំងឡាយបានមុន នាងចូរបិទផ្លូវទាំងឡាយរបស់លោក ។

[ ៦១០ ] ( នាងអលម្ពុសា... ) បពិត្រទេវរាជ ហេតុអ្វីព្រះអង្គធ្វើយ៉ាងនេះ ព្រះអង្គឃើញខ្ញុំម្ចាស់ហើយក៏ត្រាស់ថា ម្នាលនាង ជាស្រីលួងលោមឥសី នាងចូរទៅចុះ ដូច្នេះ ដ្បិតស្រីអប្សរទាំងឡាយដទៃប្រហែលនឹងខ្ញុំម្ចាស់ ទាំងប្រសើរជាងខ្ញុំម្ចាស់ ក៏មានក្នុងព្រៃដែលមិនមានសេចក្តីសោក មានតែសេចក្តីរីករាយ សូមផ្ចាស់ឲ្យស្រីទេពអប្សរទាំងឡាយនោះទៅវិញ ស្រីអប្សរជាអ្នកអាចលួងលោមទាំងនោះ ចូរទៅចុះ ។

[ ៦១១ ] ( សក្កទេវរាជ... ) នាងពោលនូវពាក្យពិតមែន ឯស្រីអប្សរទាំងឡាយដទៃប្រហែលដូចនាង ទាំងប្រសើរជាងនាង ក៏មានក្នុងព្រៃមិនមានសេចក្តីសោក មានតែសេចក្តីរីករាយ ។ ម្នាលនារី មានអវយវៈ

ទាំងពួងដ៏ល្អ នាងដឹងនូវការផ្គាប់ ( បុរស ) ប្រាកដយ៉ាងណា នាងទេពអប្សរទាំងឡាយនោះ ទៅដល់បុរសហើយ រមែងមិនដឹងនូវការផ្គាប់ យ៉ាងនោះទេ ។ ម្នាលនាងកល្យាណី នាងឯងចូរទៅចុះ ព្រោះថា នាងជាស្ត្រីប្រសើរជាងស្ត្រីទាំងឡាយ នាងនឹងញ៉ាំង ( តាបស ) ឲ្យលុះអំណាចដោយវណ្ណៈ និងរូបរបស់នាង ។

[ ៦១២ ] ( នាងអលម្ពុសា... ) ខ្ញុំម្ចាស់ដែលព្រះអង្គជាទេវរាជទ្រង់ប្រើហើយ នឹងខានទៅមិនបាន ប៉ុន្តែខ្ញុំម្ចាស់ខ្លាចចំពោះឥសិសិង្គនោះត្រេកអរ ព្រោះថា ឥសិសិង្គនោះ ជាព្រាហ្មណ៍ មានតេជះខ្ពង់ខ្ពស់ ។ ជនទាំងឡាយច្រើននាក់ ញ៉ាំងឥសីឲ្យត្រេកអរ ហើយទៅកាន់នរក បានដល់នូវការអន្ទោលវង្វេងឆ្ងាយ ព្រោះសេចក្ដីវង្វេង ហេតុនោះទើបខ្ញុំម្ចាស់ព្រឺរោម ។

[ ៦១៣ ] ( អភិសម្ពុទ្ធគាថា ) ស្រីអប្សរឈ្មោះអលម្ពុសា មានវណ្ណៈគួរប្រាថ្នា ជាស្រីញ៉ាំងបុរសឲ្យប្រឡូកប្រឡំ ប្រាថ្នាញ៉ាំងឥសិសិង្គៈឲ្យប្រឡូកប្រឡំ ( ដោយកិលេស ) លុះពោលនូវពាក្យនេះហើយ ក៏ចៀសចេញទៅ ។ នាងអលម្ពុសានោះ ចូលទៅកាន់ព្រៃ ដែលឥសិសិង្គៈរក្សាហើយនោះ ជាព្រៃដេរដាសដោយវល្លិបាសក្រហម មានទំហំកន្លះយោជន៍ដោយជុំវិញ ។ នាងចូលទៅរកឥសិសិង្គៈ ដែលកំពុងបោសរោងភ្លើង ជិតសម័យជាទីរះឡើងនៃព្រះអាទិត្យ ក្នុងវេលាមុនបរិភោគអាហារ ក្នុងពេលព្រឹកព្រហាម ។

[ ៦១៤ ] ( ឥសិសិង្គៈ... ) នាងជាអ្វី មានគ្រឿងប្រដាប់ដៃដ៏វិចិត្រ

ពាក់កុណ្ឌលជាវិការៈនៃកែវមណី ក្ដីដូចផ្លេកបន្ទោរ ឬដូចផ្កាយព្រឹក ។ នាងមានសម្បុរប្រហែលពណ៌នៃព្រះអាទិត្យ មានក្លិនក្រអូប ដូចខ្លឹមចន្ទន៍ក្រហម មានភ្នែកមូលល្អ មានមាយាច្រើន ជាកុមារី មានលម្អគួរមើល ។ ជើងទាំងឡាយរបស់នាងមិនខូងកណ្ដាល ជាជើងទន់ល្មើយស្អាត ជាន់ស៊ប់ល្អ ជើងទាំងពីរនោះ កាលដើរទៅ គួរឲ្យប្រាថ្នា ដឹកនាំនូវចិត្តរបស់អាត្មាបាន ។ ភ្លៅទាំងឡាយរបស់នាងរៀវជាលំដាប់ ប្រៀបស្មើដោយប្រមោយដំរី ត្រគាករបស់នាងសាយ ដូចជាផែននៃមាស ។ ផ្ចិតរបស់នាងស្និទ្ធល្អពេញ ដូចបណ្ដូលផ្កាឧប្បល ប្រាកដអំពីចម្ងាយដូចជាផ្កាអញ្ចាន់ដ៏ខៀវ ។ ដោះទាំងពីរកើតព្ធដ៏ទ្រូង ជាដោះមិនមានទងលៀនចេញល្អ ទ្រទ្រង់នូវទឹកដោះមិនធ្លាក់យារ ( ដោះក្បំ ) ប្រាកដស្មើដោយផ្លែឃ្លោកពាក់កណ្ដាល ។ ក ( របស់នាង ) ប្រហែលជំពារមាស វែងដូចកទ្រោយ បបូរមាត់ល្អ ដូចជាចិត្ត ជាគម្រប់ ៤ គឺអណ្ដាត ។ ធ្មេញទាំងឡាយរបស់នាង មិនមានទោសជាធ្មេញដុះស្មើទាំងពីរខាង ទាំងខាងលើ ទាំងខាងក្រោម ដែលជម្រះហើយដោយឈើស្ទន់ ជាធ្មេញគួរមិលមើលក្រៃពេក ។ ភ្នែកទាំងឡាយរបស់នាងដ៏ខ្មៅ មានចុងក្រហម ប្រហែលដោយផ្លែទំពាំងបាយជូរ ដ៏វែងទូលាយជាភ្នែកគួរមិលមើលក្រៃពេក ។ សក់ទាំងឡាយរបស់នាង ដែលដុះលើក្បាលមិនវែងពេក ជាសក់រលើប ដែលសិតដោយក្រាសមាស ក្រអូបសាយដោយក្លិននៃខ្លឹមចន្ទន៍ ។ ការភ្ជួររាស់និងការរក្សាគោ ( នៃជនទាំងឡាយណា ) ក្ដី គតិណានៃពាណិជទាំងឡាយក្ដី សេចក្ដីព្យាយាម ( ណា ) នៃ

ឥសីទាំងឡាយអ្នកសង្រួមអ្នកមានតបៈក្តី កាលប្រព្រឹត្តទៅ អាត្មាមិនឃើញនូវជនទាំងនោះ លើមណ្ឌលនៃផែនដីនេះ ឲ្យសមស្មើ ( នឹងនាង ) អ្នកជាអ្វី ជាកូននៃអ្នកណា យើងនឹងដឹងនូវអ្នកដូចម្តេចបាន ។

[ ៦១៥ ] ( នាងអលម្ពុសា... ) បពិត្រកស្សបដ៏ចម្រើន កាលបើចិត្តរបស់លោកប្រព្រឹត្តទៅហើយយ៉ាងនេះ កាលនេះមិនមែនជាកាលនៃប្រស្នាទេ នៃសម្លាញ់ លោកចូរមក យើងទាំងពីរនាក់នឹងត្រេកត្រអាលក្នុងអាស្រមរបស់យើង លោកចូរមក ខ្ញុំនឹងឱបលោក ចូរលោកជាអ្នកឈ្លាសក្នុងសេចក្តីត្រេកអរ ។

[ ៦១៦ ] ( អភិសម្ពុទ្ធគាថា ) ស្រីអប្សរឈ្មោះអលម្ពុសា មានវណ្ណៈគួរប្រាថ្នា ជាស្រីធ្វើបុរសឲ្យប្រឡូកប្រឡំ កាលប្រាថ្នានឹងញាំងឥសិសិង្គៈ ឲ្យប្រឡូកប្រឡំ ( ដោយកិលេស ) លុះពោលពាក្យនេះហើយ ក៏ចៀសចេញទៅ ។

[ ៦១៧ ] ឯឥសិសិង្គៈនោះក៏ផ្តាច់បង់នូវសេចក្តីខ្ជះខ្ជែងដ៏យឺត ហើយស្ទុះទៅ ដោយប្រញាប់ប្រញាល់ ដល់ហើយក៏ស្ទាបអង្អែលនាងអលម្ពុសានោះ ត្រង់ផ្នួងសក់ដ៏ឧត្តម ។ នាងកល្យាណីមានលម្អដ៏ល្អ ងាកមកឱបរឹតតាបសនោះដែរ តាបសនោះ ឃ្លាតចាកព្រហ្មចារ្យនោះ ព្រោះលោកត្រេកត្រអាលចំពោះនាង ក្នុងកាលនោះ ( ដូចបំណងដែលសក្កទេវរាជប្រាថ្នាហើយនោះ ) ។ នាងក៏នឹកដល់ព្រះឥន្ទ្រ ដែលកំពុងប្រថាប់នៅក្នុងនន្ទនវ័នឯមយវាទេវកុញ្ជរ ក៏ជ្រាបនូវសេចក្តីត្រិះរិះរបស់នាងហើយ ទ្រង់បញ្ជូន

បល្ល័ង្កមាស មានទាំងបរិវារ មានទាំងសំពត់សម្រាប់គ្របបិទទ្រូង ៥០ មានទាំងកម្រាល ១០០ ដ៏ធាប់ នាងល្អ ក៏ផ្តេកនូវតាបសនោះលើទ្រូង លើបល្ល័ង្កទិព្វនោះ ។ នាងអលម្ពុសា ផ្តេកតាបសនោះទុកអស់ ៣ ឆ្នាំហាក់ដូចជាមួយរំពេច ព្រាហ្មណ៍ ( ដេកលើទ្រូងនាងអលម្ពុសា ) អស់ ៣ ឆ្នាំ ក៏បាត់សន្ទប់ក្វារឡើងវិញ ។ បានឃើញពួកឈើមានស្លឹកខៀវ ( ដុះព័ទ្ធ ) រោងភ្លើងជុំវិញ និងព្រៃដ៏ដេរដាសដោយស្លឹកថ្មីៗ មានផ្ការីកដ៏គឹកកងដោយពួកតាវៅ ។ តាបសក្រឡេកមើលឃើញច្បាស់ជុំវិញ ក៏យំសម្រក់ទឹកភ្នែកថា អាត្មាអញមិនបូជាភ្លើង មិនរាយមន្ត ការបូជាភ្លើង ក៏សាបសូន្យអស់ ។ បុគ្គលណាហ្ន៎ លួងលោមចិត្តរបស់អាត្មាអញ ដោយការផ្គាប់ក្នុងកាលមុន កាលអាត្មាអញនៅក្នុងព្រៃ បុគ្គលណា ញ៉ាំងឈានគុណដែលកើតព្រមដោយតេជានុភាពរបស់អាត្មាអញ ឲ្យវិនាស ដូចជាបុគ្គលញ៉ាំងទូកដ៏ពេញដោយកែវផ្សេងៗ ឲ្យវិនាសក្នុងសមុទ្ទ បុគ្គលនោះឈ្មោះអ្វីហ្ន៎ ។

[ ៦១៨ ] ( នាងអលម្ពុសា... ) ខ្ញុំដែលទេវរាជត្រាស់ប្រើមក ដើម្បីផ្គាប់លោក បានសម្ងាប់ចិត្ត ( របស់លោក ) ដោយចិត្ត ( របស់ខ្ញុំ ) លោកមិនជ្រាប ព្រោះតែសេចក្តីធ្វេសប្រហែស ។

[ ៦១៩ ] ( តាបស... ) បានស្តាប់មកថា កស្សបជាបិតា បានប្រៀនប្រដៅនូវពាក្យទាំងនេះ ចំពោះអាត្មាអញថា នែមាណព ស្ត្រីទាំងឡាយប្រាកដស្មើដោយ ផ្កានារីផល អ្នកគប្បីស្គាល់នូវស្ត្រីទាំងឡាយនោះចុះ ។ នែមាណព អ្នកគប្បីស្គាល់នូវស្ត្រីទាំងឡាយ ដែលមានបូសពីរព្វដ៏ទ្រូង អ្នក

គប្បីស្គាល់ថា ស្ត្រីទាំងឡាយនោះ បិតាទំនុកបម្រុងអាត្មាអញយ៉ាងណា ក៏ប្រៀនប្រដៅអាត្មាអញ យ៉ាងនោះ ដោយប្រការដូច្នោះ ។ តែអាត្មាអញមិនបានធ្វើតាមពាក្យប្រដៅ របស់បិតា ជាអ្នកចម្រើនដោយគុណសម្បត្តិនោះឡើយ ថ្ងៃនេះអាត្មាអញតែម្នាក់ឯង សញ្ជប់សញ្ជឹងក្នុងព្រៃ ដែលមិនមានមនុស្ស ។ ថ្វីយ ជីវិតរបស់អញ គួរតិះដៀល អញនឹងធ្វើយ៉ាងនោះវិញ តែបើអញជាបុគ្គលមានឈាន ប្រាកដដូច្នោះទៀត សេចក្តីស្លាប់ នឹងមានដល់អញ ។

[ ៦២០ ] ( អភិសម្ពុទ្ធគាថា ) នាងអលម្ពុសា លុះដឹងនូវតេជះ នូវសេចក្តីព្យាយាម និងប្រាជ្ញាដ៏ខ្ជាប់ខ្ជួន របស់ឥសិសិង្គៈនោះហើយ ក៏ឱនក្បាលទៀបជើងឥសិសិង្គៈពោលថា បពិត្រលោកអ្នកមានព្យាយាមធំ សូមលោកកុំខ្ញាល់នឹងខ្ញុំ បពិត្រមហាឥសី សូមលោកកុំខ្ញាល់នឹងខ្ញុំ ផ្សិតប្រយោជន៍ដ៏ធំខ្ញុំបានប្រព្រឹត្តហើយ ដើម្បីទេវតាទាំងឡាយជាន់តាវត្តិង្ស ជាអ្នកមានយសឯទេវបុរីទាំងមូលលោកបានឲ្យកម្រើកញាប់ញ័រហើយក្នុងកាលនោះ ។

[ ៦២១ ] ( ឥសិសិង្គៈ... ) ម្នាលនាងដ៏ចម្រើន ទេវតាទាំងឡាយក្នុងជាន់តាវត្តិង្សក្តី ព្រះវាសវៈ ( ជាឥស្សរៈ ) របស់ទេវតាទាំងឡាយជាន់តាវត្តិង្សក្តី ខ្លួននាងក្តី ចូរមានសេចក្តីសុខចុះ ម្នាលនាងកញ្ញា នាងចូរទៅតាមសប្បាយចុះ ។

[ ៦២២ ] នាងអលម្ពុសា ឱនក្បាលទៀបជើងនៃតាបស រួចធ្វើប្រទក្សិណតាបសនោះ ប្រណម្យអញ្ជលីហើយចៀសចេញទៅ ចាកទីនោះ ។

បល្ល័ង្កមាសណា ដែលមានទាំងបរិវារ មានទាំងសំពត់ សម្រាប់គ្របបិទ ទ្រូង ៥០ មានទាំងកម្រាល ១.០០០ របស់នាង នាងក៏ឡើងកាន់បល្ល័ង្កមាសនោះ ហើយទៅក្នុងសម្នាក់នៃទេវតាទាំងឡាយ ។ សក្កទេវិន្ទ ទ្រង់មានបីតិសោមនស្សរីករាយព្រះហឫទ័យ ចំពោះនាងអលម្ពុសានោះ ដែលមកដូចកោះ រុងរឿងដូចផ្លេកបន្ទោរ ហើយប្រទានពរ ។

[ ៦២៣ ] ( នាងអលម្ពុសា... ) បពិត្រសក្កទេវរាជ ជាឥស្សរៈជាងភូតទាំងពួង បើព្រះអង្គប្រទានពរដល់ខ្ញុំម្ចាស់ ខ្ញុំម្ចាស់សូមកុំបានទៅប្រលោមលួងលោមឥសីទៀត បពិត្រសក្កទេវរាជ ខ្ញុំម្ចាស់សូមពរនេះ ។

**ចប់ អលម្ពុសាជាតក ទី ៣ ។**

# អដ្ឋកថា

# អលម្ពុសាជាតក

[ ៦០៧-៦២៣ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការលួងលោមរបស់នាងបុរាណទុតិយិកា ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អថាព្រវិ** ដូច្នេះជាដើម ។

រឿងក្នុងបច្ចុប្បន្ន ខ្ញុំពោលទុកយ៉ាងពិស្តារក្នុងឥន្ទ្រិយជាតកហើយ ។

ព្រះសាស្តាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ បានឮថា អ្នកអផ្សុកពិតឬ កាលភិក្ខុនោះក្រាបទូលថា ករុណាព្រះអង្គ ពិតមែន ទើបត្រាស់សួរថា អ្នកណាធ្វើឲ្យអ្នកអផ្សុក កាលភិក្ខុនោះក្រាបទូលថា គឺនាងបុរាណទុតិយិកា ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុ ស្រីនេះ ក្នុងកាលមុន បានធ្វើសេចក្តីវិនាសដល់អ្នក អ្នកបានអាស្រ័យស្រីនេះ ញុំាងឈានឲ្យវិនាស ជាអ្នកវង្វេង ដេកសញ្ជប់សញ្ជឹងអស់ ៣ ឆ្នាំ លុះមានសតិ ទើបបរិទេវនាជំកន្ទង ហើយទ្រង់នាំអតីតនិទាន មកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ នៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ក្នុងកាសិករដ្ឋ ចម្រើនវ័យហើយ ដល់នូវការសម្រេចក្នុងសិល្បសាស្ត្រសព្វយ៉ាង ហើយបួសជាឥសី មានមូលផលាផល ក្នុងព្រៃជាអាហារ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងព្រៃ ដែលសម្បូរដោយសត្វប្រើស ។ កាលនោះ មេម្រឹគមួយស៊ីស្មៅ ដែលលាយដោយទឹកកាម ក្នុងទីបន្ទោបង់បស្សាវៈរបស់តាបសនោះ ហើយផឹកទឹកដោយហេតុត្រឹមប្រមាណប៉ុណ្ណោះឯង មេម្រឹគនោះមានចិត្តប្រតិព័ទ្ធក្នុងតាបស

របួតតាំងគភ៌ តាំងអំពីនោះមកក៏មិនព្រមទៅណា ត្រាច់ក្បែរៗអាស្រមនោះឯង ។ ព្រះមហាសត្វ កំណត់មើល ក៏ដឹងហេតុនោះទាំងអស់ ។ ចំណេរតមក ម្រឹគនោះប្រសូតកូនជាមនុស្ស មហាសត្វ ក៏ចិញ្ចឹមទារកនោះដោយសេចក្ដីស្រឡាញ់ដូចកូន បានដាក់ឈ្មោះថា ឥសិសិង្គកុមារ ក្នុងកាលតមកទើបព្រះមហាសត្វឲ្យឥសិសិង្គកុមារ ដែលដឹងក្ដីហើយបួស ក្នុងកាលដែលខ្លួនជរា បាននាំតាបសកុមារនោះ ទៅកាន់នារីវន ទូន្មានថា នែកូន ឈ្មោះថា ស្រីដូចផ្កាទាំងនេះ មានក្នុងហិមពាន្តនេះ ស្រីទាំងនោះតែងញុំាងជនដែលធ្លាក់នៅក្នុងអំណាចខ្លួន ឲ្យដល់នូវសេចក្ដីវិនាសធំបាន មិនគួរឯងចូលទៅកាន់អំណាចស្រីទាំងនោះដូច្នេះ ។ ក្នុងកាលតមក ធ្វើកាលកិរិយា មានព្រហ្មលោកជាទីទៅខាងមុខ ។ ឥសិសិង្គតាបស បានជាអ្នកលេងឈានក្នុងហិមវន្តប្បទេស ជាអ្នកមានតបៈខ្លាំងក្លា មានឥន្ទ្រិយឈ្នះហើយយ៉ាងក្រៃលែង ។ កាលនោះ ពិភពរបស់សក្កទេវរាជ ក៏រំពើកញាប់ញ័រ ដោយតេជៈនៃសីលរបស់តាបស សក្កទេវរាជពិចារណាមើលក៏ជ្រាបហេតុនោះ ទ្រង់ត្រិះរិះថា តាបសនេះ គប្បីញុំាងអញឲ្យឃ្លាតចាកភាពជាសក្កៈ អញត្រូវបញ្ជូនទេពអប្សរមួយ ឲ្យទៅទម្លាយសីលរបស់ឥសីនេះ ដូច្នេះហើយ ទ្រង់ពិចារណាទេវលោកទាំងមូល ក្នុងចំណោមទេវបរិចារិកាចំនួន ២ កោដិកន្លះ មិនបានឃើញអ្នកណា ដែលអាចទម្លាយសីលរបស់ឥសិសិង្គៈបាន ក្រៅអំពីទេពអប្សរឈ្មោះអលម្ពុសាទើបត្រាស់ឲ្យនាងមកគាល់ ហើយទ្រង់បញ្ជាឲ្យទម្លាយសីលរបស់ឥសិសិង្គតាបសនោះ ។

កាលព្រះបរមសាស្តា ទ្រង់ធ្វើអត្ថនោះឲ្យជាក់ច្បាស់ ទើបត្រាស់គាថាដំបូង ដោយសេចក្តីថា

គ្រានោះព្រះឥន្ទ្រជាធំ គ្របសង្កត់នូវអសុរឈ្មោះវត្រៈ ទ្រង់ជាបិតារបស់ទេវបុត្ត អ្នកឈ្នះ ( សង្គ្រាម ) ទ្រង់ឈ្វេងយល់នូវនាងទេវកញ្ញា ឈ្មោះអលម្ពុសា ដែលនៅក្នុងរោងឈ្មោះធម្មសភា ហើយបានត្រាស់ថា ។

បណ្តាបទទាំងនោះ បទថា **ព្រហា** បានដល់ បុគ្គលជាធំ ។ បទថា **វត្រភូ** សេចក្តីថា បុគ្គលដែលគ្របសង្កត់អសុរ ឈ្មោះវត្រៈ ។ បទថា **ជយតំ បិតា** សេចក្តីថា ជាព្រះបិតានៃទេវបុត្តដ៏សេស ៣៣ អង្គ ជាអ្នកឈ្នះ គឺដល់នូវការឈ្នះដោយញុំាងកិច្ចនៃបិតាឲ្យសម្រេច ។ បទថា **បរាភេត្វា** សេចក្តីថា ត្រួតពិនិត្យសព្វកាយចិត្ត ទើបដឹងថា នាងអលម្ពុសានេះជាកម្លាំងអាចទប់ទល់បាន ។ បទថា **សុធម្មាយំ** សេចក្តីថា ប្រថាប់គង់លើបណ្ឌុកម្ពលសិលាអាសនៈ ក្នុងសុធម្មាទេវសភា ឲ្យហៅនាងអលម្ពុសានោះមកគាល់ ហើយត្រាស់គាថានេះថា

ម្នាលនាង ( អ្នកធ្វើបុរស ) ឲ្យប្រឡូកប្រឡំ ( ដោយកិលេស ) ទេវតាទាំងឡាយក្នុងជាន់តាវត្តិង្ស ព្រមទាំងព្រះឥន្ទ្រ អង្វរនាង ម្នាលនាងអលម្ពុសា ជាស្រ្តីលួងលោមនូវឥសី ចូរនាងទៅរកព្រះឥសិសិង្គៈ ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថានោះ ដូចតទៅនេះថា សក្កទេវរាជត្រាស់នឹង

នាងអលម្ពុសាទេវកញ្ញានោះថា **មិស្សេ** ពាក្យនេះ ជាឈ្មោះរបស់ទេវកញ្ញានោះ ។ ស្រីគ្រប់ពួក លោកហៅថា **មិស្សា** ព្រោះប្រឡូកប្រឡំដោយកិលេសក្នុងបុរស ។ កាលសក្កទេវរាជទ្រង់រាក់ទាក់ដោយគុណនាមជាសាធារណៈនោះ ទើបត្រាស់យ៉ាងនេះ ។ បទថា **ឥសិបលោភិកេ** សេចក្ដីថា នាងអាចលួងលោមឥសី ។ បទថា **ឥសិសិង្គំ** សេចក្ដីថា បានឮថា ពក ២ កើតលើក្បាលរបស់ឥសិសិង្គតាបសនោះ ដោយអាការដូចស្នែងម្រឹគ ព្រោះហេតុនោះ ទើបហៅយ៉ាងនេះ ។

ដោយប្រការដូច្នេះ ទើបសក្កទេវរាជត្រាស់បញ្ជានាងអលម្ពុសាថា ចូរនាងទៅ ចូរទៅរកឥសិសិង្គតាបស នាំមកកាន់អំណាចរបស់ខ្លួន ហើយទម្លាយនូវសីលរបស់លោក ដូច្នេះហើយ ត្រាស់ពាក្យជាគាថានេះថា

> តាបសនេះ មានវត្ត មានព្រហ្មចរិយធម៌ ត្រេកអរក្រៃលែងក្នុង
> ព្រះនិព្វាន ជាអ្នកចម្រើន ( ដោយគុណ ) កុំឲ្យលោកប្រព្រឹត្ត
> កន្លងនូវយើងទាំងឡាយបានមុន នាងចូរបិទផ្លូវទាំងឡាយរបស់
> លោក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បុរាយំ** សេចក្ដីថា តាបសនោះជាអ្នកសម្បូរដោយវត្ត និងប្រព្រឹត្តព្រហ្មចរិយៈ ។ម្យ៉ាងទៀត តាបសនោះត្រេកអរក្រៃ-លែងហើយ ក្នុងមគ្គ គឺព្រះនិព្វាន និងចម្រើនដោយគុណ ព្រោះភាពជាអ្នកមានអាយុវែង តាបសនេះនឹងគ្របសង្កត់ពួកយើងមិនបាន គឺមិនគ្របសង្កត់ធ្វើឲ្យពួកយើងឃ្លាតចាកទីបាន ដរាបណា ចូរនាងទៅរាំងផ្លូវដែលមកកាន់

ទេវលោករបស់តាបសនោះ ដរាបនោះ អធិប្បាយថា ចូរនាងធ្វើដោយប្រការដែលតាបសនោះ មកក្នុងទីនេះមិនបាន ។

នាងអលម្ពុសាទេវកញ្ញាបានស្តាប់ដូច្នោះ ទើបពោលគាថា ២ ថា

បពិត្រទេវរាជ ហេតុអ្វីព្រះអង្គធ្វើយ៉ាងនេះ ព្រះអង្គឃើញខ្ញុំម្ចាស់ហើយក៏ត្រាស់ថា ម្នាលនាង ជាស្រីលួងលោមឥសី នាងចូរទៅចុះ ដូច្នេះ ដ្បិតស្រីអប្សរទាំងឡាយដទៃ ប្រហែលនឹងខ្ញុំម្ចាស់ ទាំងប្រសើរជាងខ្ញុំម្ចាស់ ក៏មានក្នុងព្រៃដែលមិនមានសេចក្តីសោក មានតែសេចក្តីរីករាយ សូមផ្ចាស់ឲ្យស្រីទេពអប្សរទាំងឡាយនោះទៅវិញ ស្រីអប្សរជាអ្នកអាចលួងលោមទាំងនោះ ចូរទៅចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កិមេវ ត្វំ** នេះ នាងអលម្ពុសាទេពអប្សរសម្តែងថា ហេតុអ្វី ទើបទ្រង់ធ្វើវត្ថុឈ្មោះនេះ ។ ដោយបទថា **មមេវ តុវំ សិក្ខសិ** នាងអលម្ពុសាទេពអប្សរពោលដោយបំណងថា ក្នុងទេវលោកទាំងមូល ហេតុអ្វី ទើបទ្រង់ផ្តោតចំពោះខ្ញុំម្ចាស់តែម្នាក់ ទ្រង់មិនមើលអ្នកដទៃខ្លះ ឯ **ស** អក្ខរៈ ក្នុងគាថានេះ ធ្វើនូវការភ្ជាប់ព្យញ្ជនៈប៉ុណ្ណោះ អធិប្បាយថា ព្រោះហេតុអ្វី ទើបត្រាស់យ៉ាងនេះថា នាងអាចលួងលោមឥសីបាន ចូរនាងទៅចុះ ដូច្នេះ ។ បទថា **បវរា ចេវ** សេចក្តីថា ទេពធីតាដែលក្រៃលែងជាងខ្ញុំក៏មាន ។ បទថា **អសោកេ** បានដល់ ជាអ្នកប្រាសចាកសេចក្តីសោក ។ បទថា **ឆន្ទនេ** បានដល់ ក្នុងសួនដែលជាទីកើតសេចក្តីត្រេកអរ ។ បទថា

**បរិយាយោ** បានដល់ វារៈ គឺការទៅ ។

លំដាប់នោះ សក្កទេវរាជបានពោលគាថា ៣ ថា

នាងពោលនូវពាក្យពិតមែន ឯស្រីអប្សរទាំងឡាយដទៃ ប្រហែលដូចនាង ទាំងប្រសើរជាងនាង ក៏មានក្នុងព្រៃ មិនមានសេចក្ដីសោក មានតែសេចក្ដីរីករាយ ។ ម្នាលនារីមានអវយវៈទាំងពួងដ៏ល្អ នាងដឹងនូវការផ្គាប់ ( បុរស ) ប្រាកដយ៉ាងណា នាងទេពអប្សរទាំងឡាយនោះ ទៅដល់បុរសហើយ រមែងមិនដឹងនូវការផ្គាប់យ៉ាងនោះទេ ។ ម្នាលនាងកល្យាណី នាងឯងចូរទៅចុះ ព្រោះថា នាងជាស្ត្រីប្រសើរជាងស្ត្រីទាំង-ឡាយ នាងនឹងញ៉ាំង ( តាបស ) ឲ្យលុះអំណាច ដោយវណ្ណៈនិងរូបរបស់នាង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បុមំ គតា** សេចក្ដីថា ស្រីទាំងនោះ កាលចូលទៅរកបុរស ក៏មិនចេះបម្រើ គឺការលួងលោមបុរស ។ បទថា **វណ្ណ-រូបេន** សេចក្ដីថា ដោយពណ៌នៃសរីរៈ និងដោយរូបសម្បត្តិ ។ បទថា **វសមានាបយិស្សសិ** សេចក្ដីថា នាងនឹងនាំតាបសនោះមកកាន់អំណាចរបស់ខ្លួន ។

នាងអលម្ពុសាទេពកញ្ញា ស្ដាប់ដូច្នោះ បានពោលគាថា ២ ថា

ខ្ញុំម្ចាស់ដែលព្រះអង្គជាទេវរាជទ្រង់ប្រើហើយ នឹងខានទៅមិនបាន ប៉ុន្តែខ្ញុំម្ចាស់ខ្លាចចំពោះឥសិសិង្គនោះក្រៃកអរ ព្រោះថា

ឥសិសិង្គនោះ ជាព្រាហ្មណ៍ មានតេជះខ្ពង់ខ្ពស់ ។ ជនទាំងឡាយច្រើននាក់ ញុំាងឥសីឲ្យត្រេកអរ ហើយទៅកាន់នរក បានដល់នូវការអន្ទោលវែងឆ្ងាយ ព្រោះសេចក្តីវង្វេង ហេតុនោះ ទើបខ្ញុំម្ចាស់ព្រឺរោម ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆវាហំ** កាត់បទជា **ឆវេ អហំ** ។ បទថា **វិភេមិ** សេចក្តីថា ខ្ញុំញាប់ញ័រខ្លាចក្រែង ។ បទថា **អាសាទុំ** បានដល់ ធ្វើឲ្យអាក់អន់ ។ លោកអធិប្បាយសេចក្តីទុកថា បពិត្រទេវៈ ទ្រង់ប្រើខ្ញុំម្ចាស់ហើយ មិនទៅមិនបាន តែខ្ញុំម្ចាស់ខ្លាច ដែលត្រូវធ្វើឲ្យឥសិសិង្គៈបែកធ្លាយនូវសីល ព្រោះលោកជាអ្នកមានសីលខ្ពង់ខ្ពស់ ។ បទថា **អាសាទិយា** សេចក្តីថា លួងលោមឥសី ។ បទថា **មោហសំសារំ** សេចក្តីថា សត្វទាំងឡាយមិនមែនតិច លួងលោមឥសី ដល់នូវសង្សារវដ្ត ព្រោះសេចក្តីវង្វេង លួងលោមឥសីព្រោះសេចក្តីវង្វេងហើយ ដល់នូវសង្សារវដ្ត តាំងនៅក្នុងវដ្តទុក្ខរាប់មិនអស់ ។ បទថា **តស្មា** សេចក្តីថា ដោយហេតុនោះ ខ្ញុំ ( ព្រឺរោម ) ។ បទថា **លោមានិ ហំសយេ** សេចក្តីថា ទើបខ្ញុំព្រឺរោម ព្រឺស្បែក ។ នាងអលម្ពុសាទេវកញ្ញាក្រាបទូលថា កាលខ្ញុំគិតថា ខ្ញុំនឹងទម្លាយសីលរបស់តាបសដូច្នេះ លោមជាតិក៏ព្រឺឡើង ។

ព្រះសាស្តាត្រាស់អភិសម្ពុទ្ធគាថាទាំងនេះថា

ស្រីអប្សរឈ្មោះអលម្ពុសា មានវណ្ណៈគួរប្រាថ្នា ជាស្រីញុំាងបុរសឲ្យប្រឡូកប្រឡំ ប្រាថ្នាញុំាងឥសិសិង្គៈឲ្យប្រឡូកប្រឡំ

( ដោយកិលេស ) លុះពោលនូវពាក្យនេះហើយ ក៏ចៀសចេញទៅ ។ នាងអលម្ពុសានោះ ចូលទៅកាន់ព្រៃ ដែលឥសិសិង្គៈរក្សាហើយ នោះជាព្រៃដេរដាសដោយវល្លិបាសក្រហម មានទំហំកន្ទះយោជន៍ដោយជុំវិញ ។ នាងចូលទៅរកឥសិសិង្គៈដែលកំពុងបោសរោងភ្លើង ជិតសម័យជាទីរះឡើងនៃព្រះអាទិត្យ ក្នុងវេលាមុនបរិភោគអាហារ ក្នុងពេលព្រឹកព្រហាម ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បក្កាមិ** សេចក្ដីថា នាងអលម្ពុសាទេវកញ្ញានោះក្រាបទូលថា បពិត្រទេវរាជ បើដូច្នោះ សូមទ្រង់ពិចារណាដល់ខ្ញុំម្ចាស់ ហើយចូលកាន់បន្ទប់របស់ខ្លួន ប្រដាប់តាក់តែង ប្រាថ្នានឹងញ៉ាំងឥសិសិង្គតាបសឲ្យប្រឡូកប្រឡាំដោយកិលេស ទើបចៀសចេញទៅ ម្នាលភិក្ខុទាំងឡាយ ទេពអប្សរនោះ ទៅកាន់អាស្រមរបស់ឥសិសិង្គតាបសហើយ ។ បទថា **ពិម្ពជាលកសញ្ឆន្នំ** សេចក្ដីថា ដែលដេរដាសទៅដោយព្រៃបាសទុំ ។ បទថា **ចាតោវ ចាតរាសម្ហិ** សេចក្ដីថា ក្នុងពេលព្រឹក គឺក្នុងពេលមុនអាហារព្រឹកនោះឯង ។ មុនពេលត្រឹមណា គឺថ្ងៃរណា ។ បទថា **ឧទយ–សមយំ បតិ** សេចក្ដីថា ក្នុងពេលព្រះអាទិត្យទៀបរះឡើងនោះឯង ។ បទថា **អគ្គិដ្ឋំ** បានដល់ រោងភ្លើង អធិប្បាយថា នាងអលម្ពុសាទេពអប្សរនោះ ចូលទៅរកឥសិសិង្គតាបសនោះ ដែលប្រកបព្យាយាមក្នុងវេលាយប់ហើយ ស្រង់ទឹកអំពីព្រឹកព្រលឹម ធ្វើឧទកកិច្ចស្រេចហើយ សម្ងំដោយឈានសុខក្នុងបណ្ណសាលាបន្តិច ទើបចេញមកបោសរោងភ្លើង នាងឈរសម្ដែង

នូវលម្អរបស់ស្រីខាងមុខឥសិសិង្គតាបសនោះ ។ លំដាប់នោះ តាបសកាល
នឹងសួរ ទើបពោលថា

នាងជាអ្វី មានគ្រឿងប្រដាប់ដៃដ៏វិចិត្រ ពាក់កុណ្ឌលជាវិការៈ
នៃកែវមណី ក៏ដូចផ្លេកបន្ទោរ ឬដូចផ្កាយព្រឹក ។ នាងមាន
សម្បុរប្រហែលពណ៌នៃព្រះអាទិត្យ មានក្លិនក្រអូប ដូចខ្លឹម
ចន្ទន៍ក្រហម មានភ្លៅមូលល្អ មានមាយាច្រើន ជាកុមារីមាន
លម្អគួរមើល ។ ជើងទាំងឡាយរបស់នាង មិនខូងកណ្តាល
ជាជើងទន់ល្មើយ ស្អាត ជាន់សឹបល្អ ជើងទាំងពីរនោះ កាល
ដើរទៅ គួរឲ្យប្រាថ្នា ដឹកនាំនូវចិត្តរបស់អាត្មាបាន ។ ភ្លៅ
ទាំងឡាយរបស់នាងរៀវជាលំដាប់ ប្រៀបស្មើដោយប្រមោយ
ដំរី ត្រគាករបស់នាងសាយ ដូចជាផែននៃមាស ។ ផ្ចិតរបស់
នាងស្និទ្ធល្អ ពេញដូចបណ្តូលផ្កាឧប្បល ប្រាកដអំពីចម្ងាយ
ដូចជាផ្កាអញ្ជ័នដ៏ខៀវ ។ ដោះទាំងពីរកើតឰដ៏ទ្រូង ជាដោះ
មិនមានទង លៀនចេញល្អ ទ្រទ្រង់នូវទឹកដោះ មិនធ្លាក់យារ
( ដោះក្បំ ) ប្រាកដស្មើដោយផ្លែឃ្លោកពាក់កណ្តាល ។ ក
( របស់នាង ) ប្រហែលដំបារមាស វែងដូចកទ្រាយ បបូរ
មាត់ល្អ ដូចជាចិត្តជាគម្រប់ ៤ គឺអណ្តាត ។ ធ្មេញទាំងឡាយ
របស់នាងមិនមានទោស ជាធ្មេញដុះស្មើទាំងពីរខាង ទាំងខាង
លើទាំងខាងក្រោម ដែលជម្រះហើយ ដោយឈើស្ទន់ជា

ធ្មេញគួរមើលមើលក្រៃពេក ។ ភ្នែកទាំងឡាយរបស់នាង ដ៏ខ្មៅ មានចុងក្រហម ប្រហែលដោយផ្លែទំពាំងបាយជូរដ៏វែងទូលាយ ជាភ្នែកគួរមើលមើលក្រៃពេក ។ សក់ទាំងឡាយ របស់នាង ដែលដុះលើក្បាលមិនវែងពេក ជាសក់រលើប ដែលសិតដោយក្រាសមាស ក្រអូបសាយដោយក្លិននៃខ្លឹមចន្ទន៍ ។ ការភ្ជួររាស់និងការរក្សាគោ ( នៃជនទាំងឡាយណា ) ក្តី គតិណានៃពាណិជទាំងឡាយក្តី សេចក្តីព្យាយាម ( ណា ) នៃឥសីទាំងឡាយអ្នកសង្រួមអ្នកមានតបៈក្តី កាលប្រព្រឹត្តទៅ អាត្មាមិនឃើញនូវជនទាំងនោះ លើមណ្ឌលនៃផែនដីនេះ ឲ្យសមស្មើ ( នឹងនាង ) អ្នកជាអ្វី ជាកូននៃអ្នកណា យើងនឹងដឹងនូវអ្នកដូចម្តេចបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិចិត្តហត្ថាភរណា** សេចក្តីថា ដល់ព្រមដោយអាភរណៈដ៏វិចិត្រ ។ បទថា **ហេមចន្ទនគន្ធិនី** សេចក្តីថា លាបដោយក្លិនចន្ទន៍ មានពណ៌ខ្ទិនដូចមាស ។ បទថា **សញ្ញត្ថូរុ** សេចក្តីថា ភ្លៅមូលក្លំល្អ គឺមានលក្ខណៈជាភ្លៅដែលបរិបូរ ។ បទថា **វិលាកា** បានដល់ ជើងមិនផតកណ្តាល ។ បទថា **មុទុកា** សេចក្តីថា ទន់ សុខុមាលជាតិ ។ បទថា **សុទ្ធា** បានដល់ ប្រាសចាកមន្ទិល ។ បទថា **សុប្បតិដ្ឋិតា** សេចក្តីថា កាលជាន់ផែនដីក៏រាបស្មើ ប្រតិស្ឋានដោយល្អ ។

បទថា **គមនា** បានដល់ ដែលឈានដើរទៅ ។ បទថា **កាមនីយា**

សេចក្តីថា កាលឈានដើរ ក៏ល្វតល្វន់គួរឲ្យស្រឡាញ់ ។ បទថា **ហរន្តិ-យេវ មេ មនោ** សេចក្តីថា ជើងទាំង ២ របស់នាងឈានទៅ ដោយលីលាដ៏ស្អាតរបស់ស្រីជាន់ខ្ពស់បែបនេះ រមែងចាប់ចិត្តរបស់យើងនេះឯង ។

បទថា **វិមដ្ឋា** បានដល់ ស្អាត ។ បទថា **សុសណ្ឋានា** បានដល់ មានត្រគាកសាយល្អ ។ បទថា **អក្ខស្ស** សេចក្តីថា ត្រគាករបស់នាងសាយល្អ ដូចគ្នានឹងដំបារមាស ។

បទថា **ឧប្បលស្សេវ កិញ្ជក្ខា** សេចក្តីថា ដូចគ្នានឹងបាច់នៃផ្កាឧប្បលទៀវ ។ បទថា **កញ្ចាញ្ជនស្សេវ** សេចក្តីថា តាបសពោលយ៉ាងនេះ ព្រោះទេពអប្សរនោះ ជាអ្នកមានលោមជាតិខ្មៅល្អិតវិចិត្រ ។ តាបសកាលសរសើរស្តនទាំងគូ ទើបពោលថា **ឧរិជា** ជាដើម ពិតហើយ ដោះដែលកើតត្រង់ទ្រូងទាំងគូនោះ ឈ្មោះថា **អវណ្ដា** ព្រោះមិនមានទង ជារបស់ជាប់ត្រង់ទ្រូងតែម្យ៉ាង ឈ្មោះថា **សាធុបច្ចុទា** ព្រោះផុសចេញមកដោយល្អ ឈ្មោះថា **បយោធរា** ព្រោះទ្រទ្រង់ទុកនូវខ្សីររស ។

បទថា **អប្បតីតា** សេចក្តីថា មិនយុរយារ ឈ្មោះថា **អប្បតីតា** ព្រោះមិនស្វិត ឬព្រោះមិនលិបចូលទៅខាងក្នុង ។ ដោះទាំងគូសម្រេចហើយដោយមាស តាំងនៅលើបន្ទះមាស ឈ្មោះថា **អឡ្ហលាពុសមា** ព្រោះប្រៀបនឹងឃ្លោកមូលដែលគេកាត់ពាក់កណ្តាល ។

បទថា **ឃណេយ្យកា យថា** សេចក្តីថា កនៃម្រឹគទ្រាយវែងផង មូលផង រមែងស្រស់ស្អាត យ៉ាងណា ករបស់នាងវែងល្មមក៏ស្អាតយ៉ាងនោះ ។

បទថា **កម្ពុតលាភាសា** សេចក្តីថា ករបស់នាងរាបស្មើ ដូចសុវណ្ណកេរី ( ស្គរមាស ) ។ បទថា **បណ្ឌាវរណា** បានដល់ មានធ្មេញស្មើល្អ ។ បទថា **ចតុត្ថមនសន្និភា** សេចក្តីថា អណ្តាតដែលជាទីតាំងនៃមនះទី៤[១] លោកហៅថា **ចតុត្ថមន** តាបសពោលថា បបូរមាត់របស់នាង ដូចគ្នានឹងអណ្តាតពណ៌ក្រហម គួរឲ្យស្រឡាញ់ ។

បទថា **ឧទ្ធគ្គា** បានដល់ ធ្មេញលើ ។ បទថា **អធគ្គា** បានដល់ ធ្មេញក្រោម ។ បទថា **ឧមគ្គបរិមជ្ជិតា** សេចក្តីថា ធ្មេញទាំងខាងលើខាងក្រោមជម្រះដោយឈើស្ទន់ ស្អាតបរិសុទ្ធិ ។ បទថា **ទុវិជា** បានដល់ កើត ២ ដង ។ បទថា **ឆេលសម្ភូតា** សេចក្តីថា ធ្មេញកើតឯង ២ ដង ក្នុងទីបំផុតនៃសាច់ចង្កា ដែលមិនមានទោស ។

បទថា **អបណ្ឌរា** ដោយអត្ថថា ខ្មៅ ។ បទថា **លោហិតន្តា** បានដល់ មានត្របកក្រហម ។ បទថា **ជិញ្ជុកផលសន្និភា** សេចក្តីថា ក្នុងទីដែលគួរក្រហមដូចគ្នានឹងផ្លែទំពាំងបាយជូរ ។ បទថា **សុទស្សនា** សេចក្តីថា ប្រកបដោយបសាទទាំង ៥ នាំឲ្យចង់មើល ចង់សរសើរមិនឆ្អែតឆ្អន់ ។

បទថា **នាតិទីឃា** សេចក្តីថា ទំហំល្មមសមល្អ ។ បទថា **សុសមដ្ឋា** សេចក្តីថា រលោងដោយល្អ ។ បទថា **កនកព្យា សមោចិតា** សេចក្តីថា ស្និតមាស លោកហៅថា **កនកព្យា** យកប្រេងក្រអូបលាបស្និតមាសនោះ

---

១-ភ្នែកជាអាយតនៈទី ១ ត្រចៀកជាអាយតនៈទី ២ ច្រមុះជាអាយតនៈទី ៣ អណ្តាតជាអាយតនៈទី ៤ តែក្នុងទីនេះលោកហៅថាមនៈទី ៤ ។

តាក់តែងឲ្យស្អាត ។ តាបសសម្តែងដល់សត្វដែលមានជីវិតរស់នៅបាន ក៏ព្រោះអាស្រ័យកសិកម្មនិងគោរក្ខកម្ម ដោយបទនេះថា **កសិគោរក្ខា** ។

បទថា **យា គតិ** សេចក្តីថា ការសម្រេចមានប្រមាណប៉ុនណា ។ បទថា **បរក្កន្តំ** សេចក្តីថា ការព្យាយាមរបស់ឥសីមានប្រមាណប៉ុនណា អធិប្បាយថា ឥសីទាំងឡាយ រស់នៅក្នុងព្រៃហិមពាន្តនេះ មានប្រមាណប៉ុនណា ។

បទថា **ន តេ សមសមំ** សេចក្តីថា ក្នុងជនទាំងនោះ យើងមិនឃើញមនុស្សស្រួម្បីតែម្នាក់ ដែលផ្ទឹមស្មើនឹងនាងបាន ដោយរូបរាង លម្អ ទ្រង់ទ្រាយនិងលីលាជាដើម កាលតាបសដឹងថា នាងជាស្ត្រី ទើបសួរដោយអំណាចវោហារនៃបុរសថា **កោ វា ត្វំ** ជាដើម ។

កាលតាបសពោលសរសើរខ្លួន តាំងអំពីជើងរហូតដល់សក់យ៉ាងនេះ នាងអលម្ពុសាទេវកញ្ញាក៏នៅស្ងៀម កាលបន្តអនុសន្ធិតាមលំដាប់របស់ពាក្យនោះហើយ នាងអលម្ពុសាទេវកញ្ញា ដឹងថាតាបសនេះជាអ្នកវង្វេង ទើបពោលគាថានេះថា

> បពិត្រកស្សបដ៏ចម្រើន កាលបើចិត្តរបស់លោកប្រព្រឹត្តទៅហើយយ៉ាងនេះ កាលនេះមិនមែនជាកាលនៃប្រស្នាទេ នៃសម្លាញ់ លោកចូរមក យើងទាំងពីរនាក់ នឹងត្រេកត្រអាលក្នុងអាស្រមរបស់យើង លោកចូរមក ខ្ញុំនឹងឱបលោក ចូរលោក ជាអ្នកឈ្លាសក្នុងសេចក្តីត្រេកអរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កស្សបេវំ គតេ សតិ** សេចក្តីថា បពិត្រ

កស្សបគោត្ត កាលចិត្តរបស់លោកប្រព្រឹត្តទៅយ៉ាងនេះហើយ ក៏មិនគួរជាកាលសួរប្រស្នា ។ បទថា **សម្ម** នេះ ជាពាក្យអញ្ជើញដោយពាក្យជាទីស្រឡាញ់ ។ បទថា **រតីនំ** សេចក្តីថា សូមលោកជាអ្នកឈ្លាសតម្រានៃការត្រេកអរក្នុងបញ្ចកាមគុណ ។

អលម្ពុសាទេវកញ្ញាពោលយ៉ាងនេះហើយ គិតថា បើអញឈរស្ងៀមតាបសនេះ ក៏មិនព្រមចូលក្នុងរង្វង់ដៃអញ អញនឹងដើរធ្វើអាកប្បកិរិយាដូចនឹងទៅ ទើបនាងចូលទៅរកតាបស ព្រោះភាពជាអ្នកឈ្លាសក្នុងមាយាស្រី ទើបដើរបែរមុខទៅតាមផ្លូវដែលនាងមកហើយ កាលប្រកាស សេចក្តីនោះ ទើបព្រះបរមសាស្តាត្រាស់ថា

ស្រីអប្សរឈ្មោះអលម្ពុសា មានវណ្ណៈគួរប្រាថ្នា ជាស្រីធ្វើបុរសឲ្យប្រឡូកប្រឡំ កាលប្រាថ្នានឹងញុាំងឥសិសិង្គៈ ឲ្យប្រឡូកប្រឡំ ( ដោយកិលេស ) លុះពោលពាក្យនេះហើយ ក៏ចៀសចេញទៅ ដូច្នេះ ។

លំដាប់នោះ តាបសឃើញនាងកំពុងដើរទៅ ទើបគិតថា នាងនឹងទៅហើយ ទើបលះបង់នូវការឃើតយូររបស់ខ្លួន ហើយរត់ទៅដោយរហ័ស យកដៃស្ទាបត្រង់ផ្នួងសក់ ។

កាលព្រះបរមសាស្តាប្រកាសសេចក្តីនោះ ទើបត្រាស់នូវគាថាទាំងឡាយនេះថា

ឯឥសិសិង្គៈនោះក៏ផ្តាច់បង់នូវសេចក្តីខ្ជះខ្ជែងដ៏យឺត ហើយស្ទុះ

ទៅដោយប្រញាប់ប្រញាល់ ដល់ហើយ ក៏ស្ទាបអង្អែលនាង អលម្ពុសានោះ ពួដ៏ផ្ទង់សក់ដ៏ឧត្តម ។ នាងកល្យាណីមាន លម្អដ៏ល្អ ឆាកមកឱបរឹតតាបសនោះដែរ តាបសនោះ ឃ្លាត ចាកព្រហ្មចារ្យនោះ ព្រោះលោកត្រេកត្រអាលចំពោះនាង ក្នុង កាលនោះ ( ដូចបំណងដែលសក្កទេវរាជប្រាថ្នាហើយនោះ ) ។ នាងក៏នឹកដល់ព្រះឥន្ទ្រ ដែលកំពុងប្រថាប់នៅក្នុងនន្ទនវ័ន ឯ មឃវាទេវកុញ្ជរ ក៏ជ្រាបនូវសេចក្តីត្រិះរិះ របស់នាងហើយ ទ្រង់បញ្ជូនបល្ល័ង្កមាស មានទាំងបរិវារ មានទាំងសំពត់ សម្រាប់គ្របបិទទ្រូង ៥០ មានទាំងកម្រាល ១០០ ដ៏ធាប់ នាងល្អ ក៏ផ្តេកនូវតាបសនោះលើទ្រូង លើបល្ល័ង្កទិព្វនោះ ។ នាងអលម្ពុសា ផ្តេកតាបសនោះទុកអស់ ៣ ឆ្នាំ ហាក់ដូចជា មួយរំពេច ព្រាហ្មណ៍ ( ដេកលើទ្រូងនាងអលម្ពុសា ) អស់ ៣ ឆ្នាំ ក៏បាត់សន្លប់ភ្ញាក់ឡើងវិញ ។ បានឃើញពួកឈើ មាន ស្លឹកខៀវ ( ដុះព័ទ្ធ ) រោងភ្លើងជុំវិញ និងព្រៃដ៏ដេរដាសដោយ ស្លឹកថ្មីៗ មានផ្ការីកដ៏គឹកកងដោយពួកតាវៅ ។ តាបស ក្រឡេកមើលឃើញច្បាស់ជុំវិញ ក៏យំសម្រក់ទឹកភ្នែកថា អាត្មា អញមិនបូជាភ្លើង មិនរាយមន្ត ការបូជាភ្លើងក៏សាបសូន្យអស់ ។ បុគ្គលណាហ្ន៎ លួងលោមចិត្តរបស់អាត្មាអញ ដោយការផ្គាប់ ក្នុងកាលមុន កាលអាត្មាអញនៅក្នុងព្រៃ បុគ្គលណា ញ៉ាំង

ឈានគុណ ដែលកើតព្រមដោយតេជានុភាពរបស់អាត្មាអញ ឲ្យវិនាស ដូចជាបុគ្គលញុំាងទូកដ៏ពេញដោយកែវផ្សេងៗ ឲ្យវិនាសក្នុងសមុទ្ទ បុគ្គលនោះឈ្មោះអ្វីហ្ន៎ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អជ្ឈប្បត្តោ** សេចក្តីថា តាបសនោះមកទាន់ ។ បទថា **តមុនាវត្ត កល្យាណី** សេចក្តីថា នាងអលម្ពុសាទេវកញ្ញាជាស្រីស្អាត រាយមន្តស្នេហ៍ បែរខ្លួនត្រឡប់មកឱបរឹតឥសីនោះ ដែលឈរស្ទាបសក់ ។ បទថា **បលស្សជ្ជិ** បានដល់ ឱបរឹត ។ បទថា **ចវិ តម្ហិ ព្រហ្មរិយា យថា តំ អថ តោសិតា** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ រំពេចនោះឯង ឈានរបស់ឥសីនោះ ក៏អន្តរធានទៅ កាលឃ្លាតចាកឈានព្រហ្មចរិយៈនោះហើយ ជាអ្នកប្រព្រឹត្តទៅ ដូចសក្កទេវរាជទ្រង់ប្រាថ្នានោះឯង ។ លំដាប់នោះ ទេវកញ្ញាដែលសក្កទេវរាជទ្រង់បញ្ជូនមកនោះ ដឹងថាការប្រាថ្នារបស់សក្កទេវរាជសម្រេចហើយ កើតនូវបីតិបាមោជ្ជៈ ដោយការញុំាងព្រហ្មចរិយៈរបស់តាបសនោះឲ្យវិនាស ។

បទថា **មនសា អគមា** សេចក្តីថា នាងឈរឱបតាបសនោះ ចិត្តបាននឹកដល់ព្រះឥន្ទ្រយ៉ាងនេះថា សូមសក្កៈទ្រង់បញ្ជូនបល្ល័ង្កមក ។ បទថា **ឆន្ទនេ** សេចក្តីថា សក្កទេវរាជប្រថាប់នៅក្នុងតាវត្តិង្សពិភព ក្នុងនន្ទនវ័ន ព្រោះអាចឲ្យកើតសេចក្តីត្រេកអរ ។ បទថា **ទេវកុញ្ជរោ** បានដល់ ទេវរាជដ៏ប្រសើរ ។

បទថា **បហិណិ** បានដល់ ទើបបញ្ជូនទៅ ។ បាឋៈថា **ទាហិណិ** ដូច្នេះក៏មាន ។ បទថា **សោបវាហនំ** បានដល់ សុវណ្ណបល្ល័ង្កព្រមទាំងបរិវារ ។

បទថា **សឱរច្ឆទបញ្ញាសំ** បានដល់ គ្រឿងដណ្តប់មួយអន្ទើដោយសំពត់សម្រាប់បិទទ្រូង ៥០ ផ្ទាំង ។ បទថា **សហស្សបដិយត្ថតំ** បានដល់ កម្រាលគឺសំពត់កោជវៈដែលជាទិព្វ ១០០០ ។ បទថា **តមេធំ តត្ថ** សេចក្តីថា នាងអន្តុយលើទិព្វបល្ល័ង្កនោះ ឱបឥសិសិង្គតាបសនោះផ្អឹបទុកត្រង់ដើមទ្រូង ។

បទថា **តីណិ វស្សានិ** សេចក្តីថា នាងឱបឥសិសិង្គតាបសឲ្យដេកលើទ្រូងនិងអន្តុយឱបលើបល្ល័ង្កនោះអស់ ៣ ឆ្នាំ ដោយការរាប់ឆ្នាំមនុស្ស ដូចឱបមួយស្របក់ ។ បទថា **វិមនោ** សេចក្តីថា តាបសនោះស្វាងពីស្រវឹង គឺភាពជាអ្នកប្រាសចាកការសន្ធប់ ព្រោះតាបសដេកសន្ធប់អស់ ៣ ឆ្នាំ ក្រោយមកក៏បានដឹងខ្លួនឡើង ។ កាលតាបសដឹងខ្លួនឡើង នាងអាលម្ពុសាឃើញតាបសកម្រើកដៃជាដើមហើយ ដឹងថា តាបសកំពុងដឹងខ្លួន ទើបបណ្តាលឲ្យបល្ល័ង្កអន្តរធានទៅ ខ្លួនឯងក៏បានអន្តរធានទៅ គឺឈរពួនក្នុងទីដទៃ ។

បទថា **អទ្ទសាសិ** សេចក្តីថា តាបសនោះពិនិត្យមើលអាស្រមហើយគិតថា អ្នកណាហ្ន៎ ធ្វើអញឲ្យដល់សីលវិបត្តិ ហើយបរិទេវនាការ ដោយសំឡេងខ្លាំង សម្លឹងមើលហើយ ។ បទថា **ហរិតរុក្ខេ** សេចក្តីថា បានឃើញដើមឈើមានស្លឹកខៀវស្រស់ ឡើងព័ទ្ធរោងភ្លើង គឺរុំព័ទ្ធដោយជុំវិញ ។ បទថា **នវបត្តវនំ** សេចក្តីថា ពួកឈើដេរដាសទៅដោយស្លឹកខ្ចី ។

បទថា **រុទំ** បានដល់ បរិទេវនាការ ។ គាថាបរិទេវនាការរបស់តាបសនោះយ៉ាងនេះថា អញមិនបានបូជាភ្លើង មិនបានបរិកម្មមន្ត ។ បទថា **បហា**–

**បិតំ** សេចក្តីថា អ្វីបណ្តាលឲ្យការបូជាភ្លើងត្រូវវិនាស ។ **ប** អក្ខរៈ ត្រឹមតែជាឧបសគ្គ ។ បទថា **ចារិចរិយាយ** សេចក្តីថា តាបសបរិទេវនាការថា មុនអំពីនេះ នរណាលួងលោមចិត្តរបស់អញ ដោយការបម្រើដោយកិលេស ។ **ហ** អក្ខរៈ ក្នុងបទថា **យោ មេ តេជាហសម្ភូតំ** នេះ ត្រឹមតែជានិបាត សេចក្តីថា ឥសិសិង្គតាបសបរិទេវនាការថា បុគ្គលណាទាញ គឺញុំាងឈានគុណដែលកើតឯងដោយតេជះនៃសមណៈរបស់អញ ឲ្យវិនាស ដូចញុំាងទូកក្នុងមហាសមុទ្រដែលពេញដោយរតនៈផ្សេងៗ ឲ្យវិនាសទៅ ដូច្នោះ បុគ្គលនោះ គឺនរណាហ្ន៎ អាលម្ពុសា ទេវកញ្ញាបានស្តាប់ដូច្នោះ ក៏គិតថា បើអញមិនប្រាប់ តាបសនេះនឹងដាក់ផ្តាសាអញ ណ្ហើយចុះ អញនឹងប្រាប់ឲ្យលោកជ្រាប ទើបឈរប្រាកដកាយ ពោលគាថានេះថា

ខ្ញុំដែលទេវរាជត្រាស់ប្រើមក ដើម្បីផ្តាប់លោក បានសម្ងាប់ចិត្ត ( របស់លោក ) ដោយចិត្ត ( របស់ខ្ញុំ ) លោកមិនជ្រាប
ព្រោះតែសេចក្តីធ្វេសប្រហែស ដូច្នេះ ។

ឥសិសិង្គតាបសបានស្តាប់ពាក្យរបស់នាងហើយ នឹកឃើញដល់ឱវាទដែលបិតាផ្តាំ ក៏បរិទេវនាការថា ព្រោះអញមិនបានធ្វើតាមពាក្យបិតា ទើបដល់នូវសេចក្តីវិនាសយ៉ាងធំកន្ទង ដូច្នេះហើយ បានពោលគាថា ៤ ថា

បានស្តាប់មកថា កស្សបជាបិតា បានប្រៀនប្រដៅនូវពាក្យ
ទាំងនេះ ចំពោះអាត្មាអញថា នែមាណព ស្ត្រីទាំងឡាយ
ប្រាកដស្មើដោយផ្កានារីផល អ្នកគប្បីស្គាល់នូវស្ត្រីទាំងឡាយ

នោះចុះ ។ នៃមាណព អ្នកគប្បីស្គាល់នូវស្ត្រីទាំងឡាយដែលមានបួសពីរព្វដ៏ទ្រូង អ្នកគប្បីស្គាល់ថា ស្ត្រីទាំងឡាយនោះ បិតាទំនុកបម្រុងអាត្មាអញយ៉ាងណា ក៏ប្រៀនប្រដៅ អាត្មាអញយ៉ាងនោះ ដោយប្រការដូច្នោះ ។ តែអាត្មាអញមិនបានធ្វើតាមពាក្យប្រដៅរបស់បិតា ជាអ្នកចម្រើនដោយគុណសម្បត្តិនោះឡើយ ថ្ងៃនេះអាត្មាអញតែម្នាក់ឯង សញ្ជប់សញ្ជឹងក្នុងព្រៃដែលមិនមានមនុស្ស ។ ថ្វីយ ជីវិតរបស់អញ គួរតិះដៀលអញនឹងធ្វើយ៉ាងនោះវិញ តែបើអញជាបុគ្គលមានឈានប្រាកដដូច្នោះទៀត សេចក្តីស្លាប់ នឹងមានដល់អញ[1]ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥមានិ** បានដល់ ពាក្យទាំងនេះ ។ បទថា **កមលាសរិសិត្ថិយោ** សេចក្តីថា នារីផលទាំងឡាយ លោកហៅថា **កមលា** ស្រីទាំងឡាយ ដូចគ្នានឹងផ្កានៃនារីផលទាំងនោះ ។ បទថា **តាយោ ពុជ្ឈសិ មាណវ** សេចក្តីថា កាលនោះ បិតាទូន្មានប្រៀនប្រដៅបែបនេះ ជាមួយអញថា នៃមាណព អ្នកគួរស្គាល់ស្រីទាំងនោះ កាលដឹងហើយ កុំទៅកាន់ទីមើល គួរគេចទៅ បានឮថា នារីផលទាំងនោះគឺស្រីទាំងនេះ ។

បទថា **ឧរេគណ្ឌាយោ** សេចក្តីថា ឯងចូរស្គាល់នារីផល ដែលប្រកបទៅហើយ ដោយបូសសងខាងត្រង់ទ្រូង ។ បទថា **តាយោ ពុជ្ឈសិ** បានដល់ នៃមាណព ឯងគួរដឹងថា ស្រីទាំងនោះ រមែងញុំាងបុគ្គលដែលធ្លាក់

---

១-អញនឹងធ្វើឈានដែលអញធ្លាប់ធ្វើឲ្យកើតបែបនោះទៀត បើមិនដូច្នោះ អញនឹងស្លាប់បង់ ។

នៅក្នុងអំណាចឲ្យវិនាស ។

បទថា **នាកំ** សេចក្តីថា ខ្ញុំមិនបានធ្វើតាមពាក្យរបស់លោក ។ បទថា **ឈាយាមិ** សេចក្តីថា ទើបខ្ញុំត្រូវសុបសៅ គឺកំពុងបរិទេវនាការ ។

បទថា **ធិរត្ថុ ជីវិតេន មេ** សេចក្តីថា ជីវិតរបស់យើងគួរតិះដៀល គឺគួរនិន្ទា ប្រយោជន៍អ្វីដោយការមានជីវិតរស់នៅ ។ បទថា **បុន វា** សេចក្តីថា អញនឹងជាបុគ្គលដូចដើមវិញ គឺញ៉ាំងឈានដែលវិនាសហើយ ឲ្យកើតឡើង ជាអ្នកប្រាសចាករាគៈ ដោយប្រការណា នឹងធ្វើដោយប្រការនោះ ឬអញនឹងជ្រើសរើសយកការស្លាប់ ។

ឥសិសិង្គតាបសនោះ លះកាមរាគៈហើយ ញ៉ាំងឈានឲ្យកើតម្តងទៀតលំដាប់នោះ អលម្ពុសាទេវកញ្ញាឃើញតេជះ នៃសមណៈរបស់តាបសនោះ និងដឹងថា លោកញ៉ាំងឈានឲ្យកើតឡើងហើយ ក៏តក់ស្លុត ទើបសូមឲ្យតាបសអភ័យទោសដល់ខ្លួន ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ បានត្រាស់គាថា ២ ថា

នាងអលម្ពុសា លុះដឹងនូវតេជះ នូវសេចក្តីព្យាយាមនិងប្រាជ្ញា
ដ៏ខ្ជាប់ខ្ជួនរបស់ឥសិសិង្គៈនោះ ហើយក៏ឱនក្បាលទៀបជើង
ឥសិសិង្គៈពោលថា បពិត្រលោក អ្នកមានព្យាយាមធំ សូម
លោកកុំខ្ញាល់នឹងខ្ញុំ បពិត្រមហាឥសី សូមលោកកុំខ្ញាល់នឹងខ្ញុំ
ដ្បិតប្រយោជន៍ដ៏ធំ ខ្ញុំបានប្រព្រឹត្តហើយ ដើម្បីទេវតាទាំង-
ឡាយជាន់តាវត្តិង្ស ជាអ្នកមានយស ឯទេវបុរីទាំងមូលលោក

បានឲ្យកម្រើកញាប់ញ័រហើយ ក្នុងកាលនោះ ដូច្នេះ ។

លំដាប់នោះ ឥសិសិង្គតាបសឆ្លើយថា នែនាង យើងអត់ទោសឲ្យនាង ចូរនាងទៅតាមសប្បាយចុះ កាលដោះលែងនាងទៅ ទើបពោលថា

ម្នាលនាងដ៏ចម្រើន ទេវតាទាំងឡាយ ក្នុងជាន់តាវត្តិង្សក្តី ព្រះវាសវៈ ( ជាឥស្សរៈ ) របស់ទេវតាទាំងឡាយជាន់តាវត្តិង្សក្តី ខ្លួននាងក្តី ចូរមានសេចក្តីសុខចុះ ម្នាលនាងកញ្ញា នាងចូរទៅតាមសប្បាយចុះ ដូច្នេះ ។

នាងអលម្ពុសាទេវកញ្ញា ថ្វាយបង្គំតាបស ត្រឡប់ទៅកាន់ទេវបុរី មួយអន្លើដោយបល្ល័ង្កមាសនោះឯង ។

ព្រះបរមសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះបានត្រាស់គាថា ៣ ថា

នាងអលម្ពុសា ឱនក្បាលទៀបជើង នៃតាបស រួចធ្វើប្រទក្សិណតាបសនោះ ប្រណម្យអញ្ជលីហើយចៀសចេញទៅ ចាកទីនោះ ។ បល្ល័ង្កមាសណា ដែលមានទាំងបរិវារ មានទាំងសំពត់សម្រាប់គ្របបិទទ្រូង ៥០ មានទាំងកម្រាល ១.០០០ របស់នាង នាងក៏ឡើងកាន់បល្ល័ង្កមាសនោះ ហើយទៅក្នុងសម្នាក់នៃទេវតាទាំងឡាយ ។ សក្កទេវិន្ទ ទ្រង់មានបីតិសោមនស្សរីករាយព្រះទ័យ ចំពោះនាងអលម្ពុសានោះ ដែលមកដូចកោះ រុងរឿងដូចផ្លេកបន្ទោរ ហើយប្រទានពរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឱក្កមិវ** សេចក្តីថា ដូចប្រទីប[១]។ ដោយបទ

---

១-បិដកខ្មែរ លោកប្រែថា ដូចកោះ ។

ជាដើមថា **បតីតោ** ដូច្នេះ លោកសម្តែងដល់អាការដែលសក្កទេវរាជ ទ្រង់ត្រេកអរ ។ បទថា **អនឃា វរំ** សេចក្តីថា សក្កទេវរាជទ្រង់ត្រេកអរ បានប្រទានពរដល់នាងអលម្ពុសាទេពកញ្ញា ដែលមកថ្វាយបង្គំ ហើយឈរ ។

នាងអលម្ពុសាទេពកញ្ញា កាលនឹងទទួលពរក្នុងសម្នាក់របស់សក្កទេវរាជ ទើបពោលអវសានគាថានេះថា

បពិត្រសក្កទេវរាជ ជាឥស្សរៈជាងភូតទាំងពួង បើព្រះអង្គ
ប្រទានពរដល់ខ្ញុំម្ចាស់ ខ្ញុំម្ចាស់សូមកុំបានទៅប្រលោមលួង
លោមឥសីទៀត បពិត្រសក្កទេវរាជ ខ្ញុំម្ចាស់សូមពរនេះ
ដូច្នេះ ។

គាថានោះ មានអធិប្បាយដូច្នេះថា បពិត្រសក្កទេវរាជ បើព្រះអង្គទ្រង់ប្រទានពរដល់ខ្ញុំម្ចាស់ហើយ ខ្ញុំម្ចាស់សូមពរនេះ គឺកុំឲ្យខ្ញុំម្ចាស់ទៅលួងលោមឥសីទៀត គឺទ្រង់កុំប្រើខ្ញុំ ដើម្បីប្រយោជន៍នោះ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងដល់ភិក្ខុនោះហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងទីបំផុតនៃសច្ចកថា ភិក្ខុនោះតាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា នាងអលម្ពុសា ក្នុងកាលនោះ បានមកជានាងបុរាណទុតិយិកា ក្នុងកាលឥឡូវនេះ ឥសិសិង្គតាបស ក្នុងកាលនោះ បានមកជាភិក្ខុអផ្សុក ឯមហាឥសីជាបិតា ក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា អលម្ពុសាជាតក ចប់**

# សង្ខបាលជាតក

[ ៦២៤ ] ( ព្រះបាទពារាណសីត្រាស់សួរថា ) លោកជាអ្នកមានឱកាសនៃសរីរៈដ៏ប្រសើរ មានព្រះនេត្រថ្លា ខ្ញុំសំគាល់ថា លោកដ៏ចម្រើនជាអ្នកចេញចាកត្រកូលហើយបួស ចុះលោកអ្នកមានប្រាជ្ញា លះបង់នូវទ្រព្យនិងភោគៈទាំងឡាយ ចេញចាកផ្ទះហើយបួស តើដោយហេតុដូចម្តេច ។

[ ៦២៥ ] ( អាឡារតាបសថ្វាយព្រះពរថា ) បពិត្រព្រះរាជា ជានរទេពអាត្មាភាពជាអ្នកបួសដោយសទ្ធា ព្រោះបានឃើញវិមានរបស់ពស់ធំ ( នាគ ) ដែលមានអានុភាពច្រើន ដោយខ្លួនឯងផង ព្រោះបានឃើញផលដ៏ធំនៃបុណ្យទាំងឡាយផង ។

[ ៦២៦ ] ( ព្រះរាជា... ) បព្វជិតទាំងឡាយ មិនពោលនូវវាចាកុហកព្រោះប្រាថ្នាកាម ព្រោះខ្លាច ព្រោះទោសៈទេ ខ្ញុំសួរហើយ សូមលោកប្រាប់សេចក្តីនុ៎ះ សេចក្តីជ្រះថ្លានឹងកើតដល់ខ្ញុំ ព្រោះស្តាប់ ។

[ ៦២៧ ] ( អាឡារតាបស... ) បពិត្រព្រះអង្គជាធំក្នុងដែន អាត្មាភាពកាលនៅ ( ជាគ្រហស្ថ ) កំពុងដើរទៅដោយបំណងថា ( អញនឹងធ្វើ ) នូវជំនួញ ក៏បានឃើញនូវពួកភោជបុត្តក្នុងផ្លូវសែងពស់ដ៏ធំ មានកាយធាត់ កំពុងសប្បាយរីករាយដើរ ។ បពិត្រព្រះអង្គជាធំជាងជន លុះអាត្មាភាពនោះ មកជួបនឹងពួកភោជបុត្តទាំងនោះហើយ ក៏ព្រឺរោមខ្លាច ហើយសួរថា ម្នាលពួកភោជបុត្ត នាគនេះ មានកាយគួរខ្លាច តើអ្នកទាំងឡាយនាំទៅក្នុងទីណា អ្នកទាំងឡាយនឹងយកនាគនេះទៅធ្វើអ្វី ។

( ពួកភោជបុត្តប្រាប់ថា ) នាគដ៏ធំ ជាសត្វទៅដោយទ្រូង មានកាយដ៏ធាត់

នេះ យើងយកទៅបរិភោគ ( ព្រោះ ) សាច់វា មានរសឆ្ងាញ់ផង ក្រាស់ផង ទន់ផង នៃកូនអ្នកស្រុកវិទេហៈ អ្នកមិនដឹងនូវរសទេឬ ។ ពួកយើងចេញអំពីទីនេះ ទៅកាន់លំនៅរបស់ខ្លួន ហើយយកកាំបិតចិញ្ច្រាំសាច់ទាំងឡាយ ហើយបរិភោគរីករាយសប្បាយ ព្រោះថា ពួកយើងជាសត្រូវចំពោះនាគទាំងឡាយ ។

( អាឡារភាពពោលថា ) ពស់ដ៏ធំនេះ ជាសត្វទៅដោយទ្រូង មានកាយដ៏ធាត់ ប្រសិនបើអ្នកទាំងឡាយយកនាគនេះទៅបរិភោគ យើងនឹងឲ្យគោឧសភ ១៦ ដល់អ្នកទាំងឡាយជំនួសនាគ អ្នកទាំងឡាយចូរស្រាយនាគនេះអំពីចំណងចុះ ។

( ពួកកោជបុត្តពោលថា... ) ពស់នេះជាអាហារ ជាទីពេញចិត្តរបស់ពួកយើងណាស់ តែពស់ជាច្រើន ពួកយើងធ្លាប់បរិភោគហើយ បពិត្រអាឡារៈ ពួកយើងនឹងធ្វើតាមពាក្យរបស់អ្នកនោះ នៃកូនអ្នកស្រុកវិទេហៈ អ្នកចូរជាមិត្តរបស់យើងទាំងឡាយ ។

ពួកកោជបុត្តទាំងនោះ ក៏ស្រាយនាគរាជនោះអំពីចំណង ( ដែលគេដោតចូល ) ទៅតាមច្រមុះ ហើយបញ្ចូលទៅក្នុងអន្ទាក់ ឯនាគរាជនោះ លុះរួចអំពីចំណងហើយ ក៏មានមុខឆ្ពោះទៅកាន់បាចីនទិស ចៀសចេញទៅមួយរំពេច ។ នាគរាជនោះ មានមុខឆ្ពោះទៅកាន់បាចីនទិស លូនទៅមួយរំពេច មានភ្នែកពេញដោយទឹកភ្នែក ហើយសម្លឹងមើលអាឡារភាព កាលនោះ អាឡារភាពបានដើរទៅតាមក្រោយនៃនាគនោះ ហើយផ្គងម្រាមទាំង ១០ ( ពោលថា )

អ្នកចូរប្រញាប់ទៅចុះ កុំឲ្យពួកសត្រូវចាប់អ្នកទៀត ព្រោះថា ការចួបប្រទះដោយព្រានទាំងឡាយម្តងទៀត រមែងនាំមកនូវសេចក្តីទុក្ខ អ្នកចូរទៅកាន់ទីដែលពួកភោជបុត្តមិនឃើញ ។ នាគរាជនោះ បានទៅកាន់អន្លង់ទឹកដ៏ថ្លាមានពណ៌ខៀវ មានកំពង់ល្អ គួររីករាយ ដ៏ទន់ទោរដោយជម្ពូព្រឹក្ស និងវេទិសាព្រឹក្ស ជាសត្វមិនមានភ័យ មានតែការរីករាយ ក៏ចូលទៅ ( កាន់នាគពិភព ) ។ បពិត្រព្រះជនិន្ទ នាគនោះ លុះចូលទៅកាន់ភពនាគនោះហើយ មិនយូរប៉ុន្មាន ក៏វិលមកប្រាកដ ( ខាងមុខ ) នៃអាឡារកាព ដោយបរិវារជាទិព្វ ហើយបម្រើអាឡារកាព ហាក់ដូចជាកូនបម្រើបិតា បានពោលនូវពាក្យត្រូវចិត្ត ស្រួលត្រចៀកថា បពិត្រអាឡារៈ លោកទុកដូចមាតា និងបិតារបស់ខ្ញុំ លោកប្រាកដស្មើដោយសាច់ខាងក្នុង គឺដួងហឫទ័យ ជាអ្នកឲ្យនូវជីវិត ជាសម្លាញ់ ម្យ៉ាងទៀត ខ្ញុំត្រឡប់បាននូវឫទ្ធិរបស់ខ្លួន បពិត្រអាឡារៈ សូមលោកមើលនិវេសនដ្ឋានរបស់ខ្ញុំ ភពនាគមានចំណីច្រើន មានបាយទឹកដ៏ច្រើន ដូចមសក្កសារ គឺទេពនគររបស់វាសវទេវរាជ ដូច្នោះ ។

[ ៦២៨ ] ភពនាគនោះ ប្រកបដោយភូមិភាគ ជាភូមិមិនមានក្រួសទន់ល្អ មានស្មៅដ៏ទាប មិនមានធូលី ជាទីនាំមកនូវសេចក្តីជ្រះថ្លា ជាទីលះបង់នូវសេចក្តីសោកបាន ។ ( ក្នុងភពនាគនោះ មានស្រះបោក្ខរណី ) មិនក្រហែងក្រហូង មានកែវពៃទូរ្យពណ៌ខៀវ មានសួនស្វាយ គួរជាទីរីករាយដោយប្រពៃ តាំងនៅក្នុងទិសទាំង ៤ ( នៃស្រះបោក្ខរណី ) ដើមស្វាយ ទាំង-ឡាយ ក្នុងអម្ពវ័ននោះ មានផ្លែទុំក៏មាន ផ្លែស្រគាលក៏មាន ផ្លែខ្ចីក៏មាន ក្តីប

ក៏មាន ជាឈើមានផ្លែសព្វៗរដូវ ។

[ ៦២៩ ] បពិត្រព្រះនរទេព លំនៅជាវិការៈនៃមាស មានសន្ទះទ្វារជាវិការៈនៃប្រាក់ មានរស្មីផ្លេកៗ រុងរឿងក្រៃលែង ក្នុងកណ្តាលនៃព្រៃឈើទាំងឡាយនោះ ដូចជាផ្លេកបន្ទោរព្ធដ៏អាកាស ។ បពិត្រព្រះរាជា ( ក្នុងប្រាសាទនោះ មានផ្ទះកំពូលនិងល្វែង ) ជាវិការៈនៃកែវមណី ទាំងជាវិការៈនៃមាសរុងរឿង ដ៏វិចិត្រជាអនេក ដែលនិម្មិតល្អហើយរៀយៗ ពេញដោយពួកនាងកញ្ញា ដ៏ទ្រទ្រង់ដោយគ្រឿងប្រដាប់មាស ។ សន្ធបាលនាគរាជនោះមានសម្បុរមិនថោកទាប ( បានចាប់ដៃអាត្មាភាព ) មានសភាពរួសរាន់ឡើងកាន់ប្រាសាទ ដែលមានសសរមួយពាន់ មានអានុភាពថ្លឹងមិនបាន ដែលជាទីនៅនៃកិរិយាជាមហេសី របស់សន្ធបាលនាគរាជនោះ ។ នាងនារីម្នាក់មានសភាពរួសរាន់ កាន់យកនូវកែវមណីដ៏ស្អាត ប្រកបដោយកែវមណីដទៃមានជាតិសុទ្ធ ជាស្ត្រីដែលនាគរាជនោះមិនបាច់តឿន ក៏ក្រាលនូវអាសនៈជាវិការៈនៃកែវពិទូរ្យមានតម្លៃច្រើន ។ លំដាប់នោះ នាគរាជចាប់ដៃអាត្មាភាពឲ្យអង្គុយលើអាសនៈ ជាប្រមុខ ( ពោលថា ) នេះ អាសនៈ សូមលោកដ៏ចម្រើន អង្គុយលើអាសនៈនេះ ព្រោះថា បណ្តាបុគ្គលដែលគួរគោរពទាំងឡាយ លោកដ៏ចម្រើនទុកជាបុគ្គលគួរគោរពមួយរបស់ខ្ញុំ ។ បពិត្រព្រះជនិន្ទ្រ នាងនារីដទៃមានសភាពរហ័សរហួន នាំទឹកចូលមកលាងជើងអាត្មាភាព ដូចជាប្រពន្ធ លាងជើងកស្តាជាទីស្រឡាញ់ ។ មាននាងនារីម្នាក់ទៀត មានសភាពរួសរាន់ បានលើកនូវបាយ មានសម្លដ៏ច្រើន និង

ម្ហូបក្រៀមផ្សេងៗ ដោយភាជន៍ជាវិការៈនៃមាស ហើយបង្អោនចូលមកជិត ។ បពិត្រព្រះភារតៈ នាងនារីទាំងឡាយ បានដឹងនូវចិត្តនៃព្រះភស្តា ( របស់ខ្លួន ) ហើយបម្រើអាត្មាភាព ដែលជាអ្នកបរិភោគរួចហើយ ដោយតូរ្យតន្ត្រីទាំងឡាយ នាគរាជនោះប្រណិប័តន៍អាត្មាភាព ដោយកាមគុណជាទិព្វដ៏ឧឡារិកមានប្រមាណច្រើន ដ៏ក្រៃលែងជាងតូរតន្ត្រីនោះ ។

[ ៦៣០ ] បពិត្រអាឡារៈ ករិយាទាំងឡាយរបស់ខ្ញុំនុ៎ះ ៣០០ នាក់ ករិយាទាំងអស់ មានពាក់កណ្តាលខ្លួន ( រៀវល្អ ) មានរស្មីដ៏ក្រៃលែង ហាក់ដូចជាពណ៌នៃផ្កាឈូក បពិត្រអាឡារៈ លោកចូរធ្វើសេចក្តីស្រឡាញ់ចំពោះស្ត្រីទាំងនុ៎ះ ខ្ញុំនឹងឲ្យដល់លោកៗចូរឲ្យស្ត្រីទាំងនោះបម្រើចុះ ។

[ ៦៣១ ] អាត្មាភាពបានទទួលដឹងរសនៃកាមគុណជាទិព្វអស់មួយឆ្នាំ កាលនោះ អាត្មាភាពសួរតទៅទៀតថា ព្រះអង្គជានាគ បាននូវសម្បត្តិនេះព្រោះធ្វើនូវកម្មអ្វី ព្រះអង្គបានវិមានដ៏ប្រសើរដោយប្រការដូចម្តេច ។ ព្រះអង្គបានដោយមិនមានហេតុ ឬកើតអំពីបុគ្គលណាមួយបង្អោនមកថ្វាយ ព្រះអង្គព្រះអង្គធ្វើឯង ឬពួកទេវតាថ្វាយ បពិត្រនាគរាជ ខ្ញុំសួរសេចក្តីនេះនឹងព្រះអង្គៗបានវិមានដ៏ប្រសើរដោយប្រការដូចម្តេច ។

[ ៦៣២ ] វិមាននេះ មិនមែនខ្ញុំបានដោយមិនមានហេតុទេ មិនមែនកើតអំពីបុគ្គលណាបង្អោនមកថ្វាយខ្ញុំទេ ខ្ញុំមិនមែនធ្វើដោយខ្លួនឯង ទាំងមិនមែនទេវតាឲ្យខ្ញុំទេ វិមាននេះ ខ្ញុំបានដោយកម្មរបស់ខ្លួន ជាអំពើឥតបាប គឺជាបុណ្យ ។

[ ៦៣៣ ] វត្តរបស់ព្រះអង្គដូចម្តេច ព្រហ្មចារ្យតើដូចម្តេច នេះជាវិបាកនៃកម្ម ដែលប្រព្រឹត្តល្អហើយដូចម្តេច បពិត្រនាគរាជ សូមព្រះអង្គប្រាប់សេចក្តីនុ៎ះដល់ខ្ញុំ វិមាននេះ តើព្រះអង្គបានហើយដោយប្រការដូចម្តេច ។

[ ៦៣៤ ] ខ្ញុំជាស្តេចឈ្មោះទុយ្យោធនៈ ជាធំក្នុងដែនមគធៈ មានអានុភាពធំ ខ្ញុំនោះបានដឹងច្បាស់នូវជីវិតជារបស់ថោកទាប មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ។ ខ្ញុំមានចិត្តជ្រះថ្លា បានឲ្យបាយនិងទឹកជាទានបរិបូណ៌ដោយគោរព ក្នុងកាលនោះ ផ្ទះរបស់ខ្ញុំ ជាទីប្រជុំរបស់សមណៈ ( ព្រាហ្មណ៍ ) ដូចជាអណ្តូង ព្រោះថាសមណព្រាហ្មណ៍ទាំងឡាយ ខ្ញុំបានឲ្យឆ្អែតស្កប់ស្កល់ហើយ ។ ខ្ញុំបានឲ្យផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ប្រទីប យាន លំនៅ សំពត់សម្រាប់ស្លៀកដណ្តប់ ទីដេក និងបាយទឹក ជាទាន ដោយគោរពក្នុងទីនោះ ។ អំពើនោះជាវត្តរបស់ខ្ញុំ អំពើនោះជាព្រហ្មចារ្យរបស់ខ្ញុំ នេះជាវិបាកនៃកម្មដែលប្រព្រឹត្តល្អហើយនោះ ព្រោះហេតុនោះឯង វិមាននេះ ទើបមានចំណីដ៏ច្រើន មានបាយនិងទឹកដ៏ច្រើនដែលខ្ញុំបានហើយ ។

[ ៦៣៥ ] វិមាននេះ សម្បូរដោយការរាំ ទាំងសម្បូរដោយការច្រៀង តាំងនៅអស់កាលយូរ តែមិនទៀងទាត់សោះទេ ពួកអ្នកមានអានុភាពតិច មិនមានតេជះ រមែងបៀតបៀនព្រះអង្គ ដែលមានអានុភាពច្រើន មានតេជះ បពិត្រព្រះអង្គ មានចន្ទមជាអាវុធ ព្រះអង្គមកលុះកណ្តាប់ដៃនៃពួកកោជ-

បុត្ត តើព្រោះអាស្រ័យអ្វី ព្រោះហេតុអ្វី ។ តេជះរបស់ព្រះអង្គទៅតាមភ័យដ៏ធំឬ ឬពិសរបស់ព្រះអង្គទៅតាមគល់ធ្មេញ បពិត្រព្រះអង្គមានចន្ទមជាអាវុធ ព្រះអង្គដល់នូវសេចក្តីលំបាក ( ក្នុងសំណាក់ ) នៃពួកភោជបុត្ត តើព្រោះអាស្រ័យអ្វី ព្រោះហេតុអ្វី ។

[ ៦៣៦ ] តេជះរបស់ខ្ញុំមិនមែនទៅតាមភ័យដ៏ធំទេ តេជះ គឺពិសរបស់ខ្ញុំ ពួកភោជបុត្តទាំងនោះ មិនអាចនឹងបៀតបៀនទេ ធម៌ទាំងឡាយ ពួកសប្បុរសសំដែងល្អហើយ ជាធម៌លះបង់បានដោយក្រ ដូចច្រាំងសមុទ្ទ ។ បពិត្រអាឡារៈ ខ្ញុំរក្សាឧបោសថក្នុងថ្ងៃទី ១៤ និងថ្ងៃទី ១៥ ជានិច្ច គ្រានោះ ពួកភោជបុត្ត ១៦ នាក់ កាន់ខ្សែនិងអន្ទាក់ដ៏មាំដើរមក ។ ព្រានទាំងឡាយទម្លាយ ( សរីរៈ ) យកខ្សែខ្ទះច្រមុះ ហើយសែងនាំយកខ្ញុំទៅ ខ្ញុំញ៉ាំងឧបោសថមិនឲ្យកម្រើក ខំអត់ទ្រាំនូវសេចក្តីទុក្ខទាំងនេះ ។

[ ៦៣៧ ] ( ពួកភោជបុត្តទាំងនោះ ) បានឃើញព្រះអង្គ ជាអ្នកបរិបូណ៌ដោយកម្លាំងនិងសម្បុរ ក្នុងផ្លូវជាទីដើរទៅនៃបុគ្គលតែម្នាក់ ព្រះអង្គជាអ្នកចម្រើនដោយសិរីនិងបញ្ញា បពិត្រនាគរាជ ព្រះអង្គខំប្រឹងធ្វើតបៈ តើដើម្បីអ្វី ។

[ ៦៣៨ ] បពិត្រអាឡារៈ ( ខ្ញុំធ្វើតបៈ ) មិនមែនព្រោះហេតុកូន មិនមែនព្រោះហេតុទ្រព្យ មិនមែនព្រោះហេតុអាយុទេ ខ្ញុំប្រាថ្នាចំពោះកំណើតនៃមនុស្ស ព្រោះហេតុនោះ បានជាខ្ញុំប្រឹងប្រែងធ្វើតបៈ ។

[ ៦៣៩ ] ព្រះអង្គមានចក្ខុក្រហម មានរស្មីព្រោងព្រាត មានខ្លួន

ប្រដាប់ហើយ មានសក់និងពុកមាត់កាត់កោរហើយ លាបហើយដោយខ្លឹមចន្ទន៍ក្រហម ហើយញ៉ាំងទិសទាំងឡាយឲ្យភ្លឺច្បាស់ ដូចស្តេចគន្ធព្វ ។ ព្រះអង្គដល់នូវឫទ្ធិដូចជាឫទ្ធិនៃទេវតា មានអានុភាពធំ ប្រកបដោយកាមទាំងពួង បពិត្រនាគរាជ ខ្ញុំសូមសួរនូវសេចក្តីនុ៎ះចំពោះព្រះអង្គថា មនុស្សលោកប្រសើរជាងភពនាគនេះ តើដោយហេតុអ្វី ។

[ ៦៤០ ] បពិត្រអាឡារៈ សេចក្តីបរិសុទ្ធក្តី ការសង្រួមក្តី វៀរចាកមនុស្សលោកហើយរមែងមិនមានឡើយ ខ្ញុំបើបានកំណើតនៃមនុស្សហើយ នឹងធ្វើនូវទីបំផុតនៃជាតិនិងមរណៈ ។

[ ៦៤១ ] ខ្ញុំនៅក្នុងសំណាក់នៃព្រះអង្គអស់មួយឆ្នាំហើយ ព្រះអង្គក៏បានទំនុកបម្រុងដោយបាយនិងទឹក បពិត្រនាគរាជ ខ្ញុំសូមលាត្រឡប់ទៅវិញ បពិត្រព្រះជនិន្ទ្រ ខ្ញុំឃ្លាត ( ពីមនុស្សលោក ) យូរហើយ ។

[ ៦៤២ ] កូនប្រពន្ធ និងពួកជនជាអ្នករស់នៅដោយសារខ្ញុំៗបានប្រៀនប្រដៅជានិច្ច ឲ្យបម្រើលោក តើអ្នកណាមួយមិនបានថែទាំលោកខ្លះឬទេ បពិត្រអាឡារៈ ព្រោះថា ខ្ញុំមានការស្រឡាញ់ពេញចិត្តចំពោះការចួបប្រទះនូវលោក ។

[ ៦៤៣ ] បពិត្រនាគរាជ ដូចយ៉ាងកូនជាទីស្រឡាញ់របស់មាតានិងបិតា ដែលមាតាបិតាបានថែរក្សាហើយឲ្យនៅក្នុងផ្ទះ ( ការនៅ ) របស់ខ្ញុំក្នុងទីនេះប្រសើរជាងការនៅរបស់កូននោះទៅទៀត ព្រោះថា ចិត្តរបស់អ្នកជ្រះថ្លាចំពោះខ្ញុំ ។

[ ៦៤៤ ] កែវមណីរបស់ខ្ញុំមានពណ៌ក្រហម ជាគ្រឿងនាំមកនូវទ្រព្យ លោកចូរយកកែវមណីដ៏ថ្លៃថ្លា ទៅផ្ទះរបស់ខ្លួនចុះ លុះបានទ្រព្យហើយ ចូរទុកកែវមណីនោះ ( ក្នុងពាងទឹក ) ។

[ ៦៤៥ ] បពិត្រព្រះរាជា កាមគុណទាំងឡាយ សូម្បីជារបស់មនុស្ស អាត្មាភាពបានឃើញហើយថា ជារបស់មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា លុះអាត្មាភាពឃើញទោសក្នុងកាមគុណទាំងឡាយ ទើបបួសដោយសទ្ធា ។ បពិត្រព្រះរាជា មនុស្សទាំងឡាយក្មេងក្តី ចាស់ក្តី កាលមានសរីរៈបែកធ្លាយហើយ រមែងធ្លាក់ចុះ ដូចជាផ្លែឈើទាំងឡាយដូច្នោះដែរ អាត្មាភាពឃើញហេតុនេះហើយ ទើបចេញបួស សាមញ្ញគុណគឺបព្វជ្ជា ជាធម៌ប្រតិបត្តិមិនខុស ជាធម៌ដ៏ប្រសើរ ។

[ ៦៤៦ ] ( ព្រះរាជា... ) ពួកជនណាមានប្រាជ្ញា ជាពហុស្សូត ជាអ្នកគិតនូវហេតុដ៏ច្រើន ពួកជននោះ បុគ្គលគប្បីសេពគប់ បពិត្រអាឡារតាបស ខ្ញុំនឹងធ្វើនូវបុណ្យដ៏ច្រើន ព្រោះបានស្តាប់ ( នូវពាក្យ ) របស់នាគរាជផង របស់លោកផង ។

[ ៦៤៧ ] ( អាឡារតាបស... ) ពួកជនណា មានប្រាជ្ញា ជាពហុស្សូត ជាអ្នកគិតនូវហេតុដ៏ច្រើន ពួកជននោះ បុគ្គលគប្បីសេពគប់ បពិត្រព្រះរាជា ព្រះអង្គទ្រង់ព្រះសណ្តាប់ពាក្យរបស់អាត្មាភាពនិងនាគហើយ សូមព្រះអង្គធ្វើបុណ្យឲ្យច្រើន ។

**ចប់ សង្ខបាលជាតក ទី ៤ ។**

# អដ្ឋកថា

# សង្ខបាលជាតក

[ ៦២៤-៦៤៧ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ ឧបោសថកម្ម ត្រាស់ធម្មទេសនានេះ មានពាក្យផ្ដើមថា **អរិយាវកាសោសិ** ដូច្នេះជាដើម ។

សេចក្ដីពិស្ដារថា កាលនោះ ព្រះបរមសាស្ដាទ្រង់ញ៉ាំងឧបាសកទាំង-ឡាយ ដែលរក្សាឧបោសថឲ្យត្រេកអរដោយព្រះតម្រាស់ថា បុរាណក-បណ្ឌិតទាំងឡាយ លះនាគសម្បត្តិដ៏ធំ ហើយធ្វើឧបោសថដូចគ្នា ឧបាសក ទាំងនោះ ទូលអារាធនាហើយ ទើបទ្រង់នាំអតីតនិទានមកត្រាស់ដូចតទៅ នេះថា

ក្នុងអតីតកាល ព្រះបាទមគធៈសោយរាជសម្បត្តិ នៅក្នុងនគររាជគ្រឹះ ក្នុងកាលនោះ ព្រះពោធិសត្វ យោនយកកំណើតក្នុងព្រះឧទរនៃអគ្គមហេសី របស់ព្រះរាជានោះ ។ ព្រះជនកព្រះជននីថ្វាយព្រះនាមថាទុយ្យោធនកុមារ ។ កុមារចម្រើនវ័យហើយ បានទៅរៀនសិល្បសាស្ត្រគ្រប់យ៉ាង នៅឯនគរ តក្កសិលា ត្រឡប់មកសម្ដែងសិប្បៈថ្វាយព្រះរាជបិតា ក្នុងកាលតមក ទើប ទ្រង់អភិសេកកុមារក្នុងរាជសម្បត្តិ ហើយបួសជាឥសីក្នុងរាជឧទ្យាន។ ព្រះពោធិ សត្វបានយាងទៅកាន់សម្នាក់របស់ព្រះរាជបិតាមួយថ្ងៃ ៣ ដង ។ លាភ សក្ការៈធំកើតឡើងដល់ឥសី ។ ព្រះរាជឥសីមិនអាចធ្វើត្រឹមតែកសិណបរិកម្ម បានឡើយ ព្រោះកង្វល់នោះ ទើបទ្រង់ព្រះតម្រិះថា លាភសក្ការៈរបស់អញ មានច្រើន អញនៅទីនេះមិនអាចកាត់កាពសាំញ៉ាំបាន អញនឹងមិនលា

ព្រះឱរសទៅកាន់ទីដទៃ ។ ព្រះរាជឥសីមិនប្រាប់ឲ្យអ្នកណាដឹង យាងចេញចាកឧទ្យាន ធ្វើដំណើរចូលមគធរដ្ឋ ចូលទៅអាស្រ័យចន្ទកបព៌ត ធ្វើសាលាស្លឹកនៅក្នុងទីនោះ ក្នុងទីដែលល្មមទៅមកបាន មិនឆ្ងាយអំពីស្ទឹងកណ្ណវេណ្ណា ដែលហូរចេញអំពីផ្ទារទឹកឈ្មោះសង្ខបាល នាដែនមហិសករដ្ឋ ធ្វើកសិណបរិកម្ម ញ៉ាំងឈាននិងអភិញ្ញាឲ្យកើតហើយ តាំងជីវិតដោយការសូមចិញ្ចឹមជីវិត ។ នាគរាជឈ្មោះ សង្ខបាល ចេញអំពីកណ្ណវេណ្ណានទីមួយអន្លើដោយបរិវារ ចូលទៅរកឥសីនោះម្តងម្កាល រាជឥសីក៏សម្តែងធម៌ដល់ស្តេចនាគឈ្មោះ សង្ខបាល នោះ ។ ក្នុងកាលតមក ព្រះរាជឱរសរបស់ឥសីនោះចង់ជួបព្រះជនក តែមិនដឹងទីយាងទៅ ទើបចាត់ឲ្យមនុស្សដើររក លុះដឹងថា ព្រះរាជាប្រថាប់នៅក្នុងទីឈ្មោះនោះ ក៏យាងទៅក្នុងទីនោះមួយអន្លើដោយរាជបរិវារជាច្រើន ដើម្បីទ្រង់សួរទុក្ខព្រះរាជឥសី ។ ទ្រង់ត្រាស់ឲ្យបោះព្រះពន្លាទុកក្នុងចំណែកម្ខាងមួយអន្លើដោយអាមាត្យ ២-៣ នាក់ យាងចូលទៅកាន់អាស្រមដ្ឋាន ខណៈនោះ សង្ខបាលនាគរាជកំពុងស្តាប់ធម៌ជាមួយបរិវារជាច្រើន គាប់ជួនឃើញព្រះរាជាយាងមក ក៏ថ្វាយបង្គំឥសីក្រោកឡើងចាកអាសនៈចៀសចេញទៅ ព្រះរាជាថ្វាយបង្គំព្រះបិតា ទ្រង់ធ្វើបដិសណ្ឋារៈ ប្រថាប់គង់ហើយទូលសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន នុ៎ះព្រះរាជាណា យាងមកកាន់សម្នាក់របស់លោក ឥសីក៏តបថា នែកូន នុ៎ះគឺស្តេចសង្ខបាលនាគរាជ ។ រាជឱរសកើតចំណង់ក្នុងនាគពិភព ព្រោះអាស្រ័យសម្បត្តិរបស់នាគនោះ ប្រថាប់នៅ ២-៣ ថ្ងៃ ឲ្យរៀបចំកិច្ចការថ្វាយព្រះរាជ

បិតាជាប្រចាំ ហើយយាងត្រឡប់ទៅកាន់ព្រះនគររបស់ទ្រង់នោះឯង ឲ្យសាងរោងទានក្នុងទិសទាំង ៤ ញ៉ាំងសកលជម្ពូទ្វីបឲ្យកក្រើករំពើក ទ្រង់បរិច្ចាគទាន រក្សាសីល ធ្វើឧបោសថកម្ម ប្រាថ្នានាគពិភព ។ ក្នុងទីបំផុតនៃព្រះជន្មាយុក៏បានទៅកើតជាស្តេចសង្ខបាលនាគរាជ ក្នុងនាគពិភព កាលវេលាកន្លងទៅ ទ្រង់ក្តៅក្រហាយក្នុងសម្បត្តិនោះ តាំងអំពីនោះមក ក៏ប្រាថ្នាកំណើតមនុស្ស រក្សាឧបោសថកម្ម ។ កាលស្តេចនាគសង្ខបាលនៅក្នុងនាគពិភព ការរក្សាឧបោសថមិនសម្រេចផល រមែងដល់នូវការវិនាសសីល ។ តាំងពីនោះមក ទើបចេញអំពីនាគពិភព ទៅពត់រង្វេលជុំវិញជំបូកមួយកន្លែង ក្នុងរវាងផ្លូវធំនិងផ្លូវដើរចំពោះបុគ្គលម្នាក់ៗ មិនឆ្ងាយអំពីស្ទឹងកណ្ណវេណ្ណានទី អធិដ្ឋានឧបោសថ ជាអ្នកមានសីលសមាទានហើយ លះអត្តភាពក្នុងទានមុខថា ជនទាំងឡាយ ដែលមានសេចក្តីត្រូវការដោយស្បែកនិងសាច់ជាដើមរបស់អាត្មាអញ ចូរនាំស្បែកនិងសាច់ជាដើមទៅចុះ ហើយដេកលើកំពូលជំបូក បំពេញសមណធម៌ រក្សាឧបោសថក្នុងថ្ងៃ ១៤-១៥ ហើយទៅកាន់នាគពិភព ក្នុងថ្ងៃបាដិបទ ។

ថ្ងៃមួយ កាលស្តេចនាគ សមាទានសីល ដេកយ៉ាងនេះ មានអ្នកបច្ចន្តគ្រាម ១៦ នាក់ គិតគ្នាថា ពួកយើងនឹងទៅរកសាច់ មានអាវុធគ្រប់ដៃ ត្រាច់ទៅក្នុងព្រៃ កាលមិនបានអ្វី ក៏ត្រឡប់មកវិញ ជួបស្តេចនាគរាជនោះកំពុងដេកលើជំបូក គិតគ្នាថា ថ្ងៃនេះពួកយើងមិនបានសូម្បីត្រឹមតែកូនទន្សង ពួកយើងនឹងសម្លាប់នាគរាជនេះបរិភោគ ហើយគិតគ្នាថា នាគរាជនេះធំ

កាលត្រូវចាប់គង់នឹងគេចទៅ យើងត្រូវយកស្នូចាក់ ទាន់នាគកំពុងដេកឲ្យខ្សោយកម្លាំងហើយ នឹងចាប់យកបាន ហើយកាន់លំពែងជាដើមចូលទៅជិតរាងកាយរបស់ព្រះពោធិសត្វ ដែលមានទំហំប៉ុនទូកកំពោល ដូចគ្នានឹងកម្រងផ្កាម្លិះដែលគេក្រងតម្កល់ទុក នាគរាជនោះ ប្រកបដោយភ្នែកដូចគ្នានឹងផ្លែទំពាំងបាយជូរ ក្បាលពណ៌ដូចផ្កាជយព្រឹក្សនិងផ្កាម្លិះ ល្អពន់ពេកហួសគណនា ។ ដោយស្នូរជើងមនុស្សទាំង ១៦ នាក់ ស្ដេចនាគក៏អើតក្បាលចេញពីរន្ធ្វល បើកភ្នែកពណ៌ក្រហមមើលមនុស្សទាំងនោះ ដែលមានដៃកាន់ស្នូដើរមក ទើបគិតថា ថ្ងៃនេះ មនោរថរបស់អញនឹងដល់ទីបំផុត អញប្រគល់ខ្លួន ឲ្យជាទានមុខ ទើបដេកអធិដ្ឋាន ធ្វើសេចក្ដីព្យាយាមថា អញនឹងមិនបើកភ្នែកមើលមនុស្សទាំងនេះដែលយកស្នូចាក់សរីរៈរបស់អញ ធ្វើឲ្យជាប្រហោងតូច ធំ ដោយអំណាចសេចក្ដីក្រោធ ។ ព្រោះខ្លាចសីលរបស់ខ្លួនត្រូវទម្លាយ ទើបអធិដ្ឋានធ្វើឲ្យមាំទាំ ដាក់ក្បាលចូលទៅក្នុងរន្ធ្វលដេកដូចមុន ។ កាលមនុស្សទាំងនោះចូលមកជិតហើយ ទើបចាប់កន្ទុយស្ដេចនាគអូសឲ្យធ្លាក់ចុះត្រង់ផែនដី យកស្នូដ៏មុតចាក់ក្នុងទី ៨ កន្លែង ស៊កផ្ដៅមានបន្លាចូលទៅតាមប្រហោងដែលចាក់ហើយ ស៊កឈើសម្រាប់សែងដាក់ក្នុងទី ៨ កន្លែង ហើយនាំគ្នាសែងត្រឡប់មករកផ្លូវធំ ព្រះមហាសត្វ តាំងពីចាក់ដោយស្នូ ក៏មិនបានបើកភ្នែកមើលជនទាំងនោះ ដោយអំណាចសេចក្ដីក្រោធសូម្បីក្នុងទីមួយកន្លែង កាលត្រូវយកឈើសម្រាប់សែងទាំង ៨ សែងទៅក្បាលក៏សំយុងចុះប៉ះផែនដី ។ លំដាប់នោះ មនុស្សទាំងនោះនិយាយគ្នាថា

ក្បាលរបស់នាគសំយុងចុះ ទើបដាក់ឲ្យដេកត្រង់ផ្លូវធំ យកស្នចាក់ត្រង់ច្រមុះ ហើយយកខ្សែដោត លើកក្បាលពាក់ត្រង់ឈើស្នែង នាំគ្នាសែងបន្តដំណើរទៅមុខទៀត ។

ខណៈនោះ កុដុម្ពិកៈឈ្មោះអាឡារ អ្នកក្រុងមិថិលា ដែនវិទេហរដ្ឋ អង្គុយលើយានដ៏សប្បាយ នាំរទេះ ៥០០ ធ្វើដំណើរមក ឃើញកូនអ្នកបច្ចន្តគ្រាមកំពុងសែងព្រះពោធិសត្វទៅយ៉ាងនោះទើបឲ្យមាសកមាស ម្នាក់មួយក្តាប់ និងគោ ១៦ ដល់មនុស្សទាំង ១៦ នាក់ សំពត់ស្លៀក សំពត់ដណ្តប់ដល់មនុស្សទាំងនោះ ឲ្យសំពត់និងគ្រឿងប្រដាប់ដល់ភរិយាដល់អ្នកទាំងនោះ សូមឲ្យលែងស្តេចនាគទៅ ។

ស្តេចនាគទៅកាន់នាគពិភព មិនបានរារង់នៅក្នុងនាគពិភពនោះឡើយ ចេញមករកអាឡារកុដុម្ពិកៈ មួយអន្លើដោយបរិវារច្រើន ពោលគុណរបស់នាគពិភពហើយ អញ្ជើញកុដុម្ពិកៈនោះទៅកាន់នាគពិភព ប្រទានយសធំមួយអន្លើដោយនាគកញ្ញា ៣០០ រូបដល់កុដុម្ពិកៈនោះ ឲ្យឆ្អែតស្កប់ស្កល់ដោយកាមគុណដែលជាទិព្វ ។ អាឡារកុដុម្ពិកៈបរិភោគកាមដែលជាទិព្វ ក្នុងនាគពិភពអស់កាលប្រមាណមួយឆ្នាំ ហើយប្រាប់ស្តេចនាគថា នែសម្លាញ់ ខ្ញុំប្រាថ្នានឹងបួស ទទួលយកបព្វជិតបរិក្ខារហើយ ចេញអំពីនាគពិភព បួសក្នុងហិមវន្តប្បទេសអស់កាលយូរ ។ តមក ទើបចារិកទៅរហូតដល់ក្រុងពារាណសី ស្នាក់នៅក្នុងព្រះរាជឧទ្យាន ស្អែកឡើង ទើបចូលទៅកាន់ព្រះនគរដើម្បីភិក្ខាចារ ទៅកាន់ទ្វារព្រះរាជវាំង ។ កាលនោះ ព្រះបាទពារាណសីទតឃើញ

អាឡារតាបសនោះហើយ ទ្រង់ជ្រះថ្លាក្នុងឥរិយាបថ ទើបត្រាស់ឲ្យនិមន្តមក ឲ្យអង្គុយលើអាសនៈ ដែលក្រាលទុក ឲ្យឆាន់ភោជនមានរសដ៏ប្រសើរផ្សេងៗ ហើយប្រថាប់គង់លើអាសនៈទាបមួយកន្លែង ទ្រង់ថ្វាយបង្គំ កាលទ្រង់ប្រាស្រ័យជាមួយតាបសនោះ ទើបត្រាស់គាថាទី ១ ថា

លោកជាអ្នកមានឱកាសនៃសរីរៈដ៏ប្រសើរ មានព្រះនេត្រថ្លា
ខ្ញុំសំគាល់ថា លោកដ៏ចម្រើន ជាអ្នកចេញចាកត្រកូលហើយ
បួស ចុះលោកអ្នកមានប្រាជ្ញា លះបង់នូវទ្រព្យនិងភោគៈ ទាំង-
ឡាយចេញចាកផ្ទះហើយបួស តើដោយហេតុដូចម្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អភិយាវកាសោសិ** សេចក្តីថា ព្រះបាទពារាណសីត្រាស់សួរថា លោកជាអ្នកមានឱកាស គឺសរីរៈស្អាត មិនមានទោស បានដល់ ជាអ្នកមានរូបល្អក្រៃលែង ។ បទថា **បសន្ននេត្តោ** សេចក្តីថា មានព្រះនេត្តប្រកបដោយបសាទទាំង ៥ ។ បទថា **កុលម្ហា** សេចក្តីថា ខ្ញុំសម្គាល់ថា លោកគង់ជាអ្នកបួសអំពីត្រកូលក្សត្រ ត្រកូលព្រាហ្មណ៍ ឬត្រកូលសេដ្ឋី ។ បទថា **កថំ នុ** សេចក្តីថា ព្រោះហេតុអ្វី លោកជាបណ្ឌិតធ្វើអ្វីជាអារម្មណ៍ ទើបលះទ្រព្យនិងភោគសម្បត្តិ ចេញចាកផ្ទះហើយបួស ។ បទថា **សបញ្ញោ** បានដល់ បុរសជាបណ្ឌិត ។

បន្តអំពីនោះទៅ គួរជ្រាបសម្ពន្ធនៃគាថាឆ្លើយឆ្លងរវាងតាបស និងព្រះរាជាដូចតទៅនេះថា

បពិត្រព្រះរាជា ជានរទេព អាត្មាភាពជាអ្នកបួសដោយសទ្ធា

ព្រោះបានឃើញវិមានរបស់ពស់ធំ ( នាគ ) ដែលមាន អានុភាពច្រើន ដោយខ្លួនឯងផង ព្រោះបានឃើញផលដ៏ធំ នៃបុណ្យទាំងឡាយផង ។

ព្រះរាជាត្រាស់ថា

បព្វជិតទាំងឡាយមិនពោលនូវវាចាកុហក ព្រោះប្រាថ្នាកាម ព្រោះខ្លាច ព្រោះទោសៈទេ ខ្ញុំសួរហើយ សូមលោកប្រាប់ សេចក្តីនុ៎ះ សេចក្តីជ្រះថ្លានឹងកើតដល់ខ្ញុំ ព្រោះស្តាប់ ។

អាឡារតាបសតបថា

បពិត្រព្រះអង្គជាធំក្នុងដែន អាត្មាភាពកាលនៅ ( ជាគ្រហស្ថ ) កំពុងដើរទៅដោយបំណងថា ( អញនឹងធ្វើ ) នូវជំនួញ ក៏បាន ឃើញនូវពួកភោជបុត្តក្នុងផ្លូវ សែងពស់ដ៏ធំ មានកាយធាត់ កំពុងសប្បាយរីករាយដើរ ។ បពិត្រព្រះអង្គជាធំជាងជន លុះ អាត្មាភាពនោះ មកជួបនឹងពួកភោជបុត្តទាំងនោះហើយ ក៏ព្រឺ រោមខ្លាច ហើយសួរថា ម្នាលពួកភោជបុត្ត នាគនេះមាន កាយគួរខ្លាច តើអ្នកទាំងឡាយនាំទៅក្នុងទីណា អ្នកទាំងឡាយ នឹងយកនាគនេះទៅធ្វើអ្វី ។

ពួកភោជបុត្តប្រាប់ថា

នាគដ៏ធំ ជាសត្វទៅដោយទ្រូង មានកាយដ៏ធាត់នេះ យើងយក ទៅបរិភោគ ( ព្រោះ ) សាច់វាមានរសឆ្ញាញ់ផង គ្រាស់ផង

ទន់ផង នៃកូនអ្នកស្រុកវិទេហៈ អ្នកមិនដឹងនូវរសទេឬ ។ ពួកយើងចេញអំពីទីនេះ ទៅកាន់លំនៅរបស់ខ្លួន ហើយយកកាំបិតចិញ្ច្រាំសាច់ទាំងឡាយ ហើយបរិភោគរីករាយសប្បាយ ព្រោះថា ពួកយើងជាសត្រូវចំពោះនាគទាំងឡាយ ។

អាត្មាភាពពោលថា

ពស់ដ៏ធំនេះ ជាសត្វទៅដោយទ្រូងមានកាយដ៏ជាត់ ប្រសិនបើអ្នកទាំងឡាយយកនាគនេះទៅបរិភោគ យើងនឹងឲ្យគោបម្រើ ១៦ ដល់អ្នកទាំងឡាយ ជំនួសនាគ អ្នកទាំងឡាយ ចូរស្រាយនាគនេះអំពីចំណងចុះ ។

ពួកភោជបុត្តពោលថា

ពស់នេះជាអាហារ ជាទីពេញចិត្តរបស់ពួកយើងណាស់ តែពស់ជាច្រើន ពួកយើងធ្លាប់បរិភោគហើយ បពិត្រអាឡារៈ ពួកយើងនឹងធ្វើតាមពាក្យរបស់អ្នកនោះ នៃកូនអ្នកស្រុកវិទេហៈ អ្នកចូរជាមិត្តរបស់យើងទាំងឡាយ ។

ពួកភោជបុត្តទាំងនោះ ក៏ស្រាយនាគរាជនោះអំពីចំណង ( ដែលគេដោតចូល ) ទៅតាមច្រមុះ ហើយបញ្ចូលទៅក្នុងអន្ទាក់ ឯនាគរាជនោះ លុះរួចអំពីចំណងហើយ ក៏មានមុខឆ្ពោះទៅកាន់បាចីនទិស ចៀសចេញទៅមួយរំពេច ។ នាគរាជនោះ មានមុខឆ្ពោះទៅកាន់បាចីនទិស លូនទៅមួយរំពេច មានភ្នែកពេញ

ដោយទឹកភ្នែក ហើយសម្លឹងមើលអាត្មាភាព កាលនោះ អាត្មាភាពបាន ដើរទៅតាមក្រោយនៃនាគនោះ ហើយផ្គងម្រាមទាំង ១០ ( ពោលថា ) អ្នកចូរប្រញាប់ទៅចុះ កុំឲ្យពួកសត្រូវចាប់អ្នកទៀត ព្រោះថា ការចួបប្រទះដោយព្រានទាំងឡាយម្តងទៀត រមែងនាំមកនូវសេចក្តីទុក្ខ អ្នកចូរទៅកាន់ទីដែលពួកភោជបុត្ត មិនឃើញ ។ នាគរាជនោះ បានទៅកាន់អន្លង់ទឹកដ៏ថ្លា មានពណ៌ខៀវ មានកំពង់ល្អ គួររីករាយ ដ៏ទន់ទោរដោយជម្ពូព្រឹក្ស និងវេទិសាព្រឹក្ស ( ដើមអសោក ) ជាសត្វមិនមានភ័យ មានតែការរីករាយ ក៏ចូលទៅ ( កាន់នាគពិភព ) ។ បពិត្រព្រះជនិន្ទ នាគនោះ លុះចូលទៅកាន់ភពនាគនោះហើយ មិនយូរប៉ុន្មាន ក៏វិលមកប្រាកដ ( ខាងមុខ ) នៃអាត្មាភាព ដោយបរិវារជាទិព្វ ហើយបម្រើអាត្មាភាព ហាក់ដូចជាកូនបម្រើបិតា បានពោលនូវពាក្យត្រូវចិត្ត ស្រួលត្រចៀកថា បពិត្រអាឡារៈ លោកទុកដូចមាតានិងបិតារបស់ខ្ញុំ លោកប្រាកដស្មើដោយសាច់ខាងក្នុង គឺដួងហឫទ័យ ជាអ្នកឲ្យនូវជីវិត ជាសម្លាញ់ ម្យ៉ាងទៀត ខ្ញុំត្រឡប់បាននូវឫទ្ធិរបស់ខ្លួន បពិត្រអាឡារៈ សូមលោកមើលនិវេសនដ្ឋានរបស់ខ្ញុំ ភពនាគមានចំណីច្រើន មានបាយទឹកដ៏ច្រើន ដូចមសក្កសារ គឺទេពនគររបស់វាសវទេវរាជដូច្នោះ ។

*បណ្តាបទទាំងនោះ បទថា* **វិមានំ** *សេចក្តីថា អាត្មាឃើញវិមានកញ្ចនមណី ដល់ព្រមដោយនាដកិត្តិសម្បត្តិ ( ស្រីអ្នករបាំ ) ១០០ ជាងរបស់ស្តេចសង្ខបាលនាគរាជ ។ បទថា* **បុញ្ញានំ** *សេចក្តីថា កាលឃើញមហាវិបាកនៃបុណ្យ ដែលនាគរាជនោះមក ទើបអាត្មាចេញបួសដោយសទ្ធា ប្រព្រឹត្តទៅ ព្រោះជឿនូវកម្ម ជឿនូវផលនៃកម្ម ជឿនូវបរលោក ។*

*បទថា* **ន កាមកាមា** *សេចក្តីថា ព្រះរាជាត្រាស់ថា បព្វជិតទាំងឡាយរមែងមិនពោលកុហក ព្រោះវត្ថុកាមខ្លះ ព្រោះខ្លាចខ្លះ ព្រោះទោសៈខ្លះ ។ បទថា* **ជាយិហីតិ** *សេចក្តីថា បពិត្រលោកម្ចាស់ ការជ្រះថ្លា សោមនស្សនឹងកើតដល់ខ្ញុំខ្លះ ព្រោះបានស្តាប់ពាក្យរបស់លោក ។*

*បទថា* **វាណិជ្ជ** *សេចក្តីថា តាបសក្រាបទូលថា កាលអាត្មាធ្វើដំណើរទៅដោយគិតថា នឹងធ្វើនូវការជួញដូរ ។ បទថា* **បថេ អទ្ទសាសិម្ហ** *សេចក្តីថា អាត្មាអង្គុយលើយានតូចខាងមុខរទេះ ៥០០ បានឃើញមនុស្សអ្នកជនបទ ត្រង់ផ្លូវធំ ។ បទថា* **បវឌ្ឍកាយំ** *សេចក្តីថា មានរូបកាយធាត់ធំ ។ បទថា* **អានាយ** *សេចក្តីថា សែងទៅដោយស្នែង ( ដងរែក ) ៨ ។*

*បទថា* **អវចម្ហ** *សេចក្តីថា បានពោលហើយ ។ បទថា* **ភីមកាយោ** *បានដល់ មានរាងកាយគួរខ្លាច ។ បទថា* **ភោជបុត្តា** *សេចក្តីថា អាឡារកុដុម្ពិកៈហៅកូននាយព្រានដោយពាក្យជាទីស្រឡាញ់ ។ បទថា* **វិទេហ - បុត្ត** *សេចក្តីថា ពួកកូននាយព្រាននាំគ្នាពោលតបនឹងអាឡារកុដុម្ពិកៈ ព្រោះអាឡារកុដុម្ពិកៈនៅក្នុងវិទេហរដ្ឋ ។*

បទថា **វិកោបយិត្វា** បានដល់ ចិញ្ច្រាំ ឬកាប់ជាកំណាត់ៗ ។ បទថា **មយំ ហិ តេ សត្តវោ** សេចក្ដីថា ពួកយើងជាសត្រូវនៃនាគទាំងឡាយ ។ បទថា **ភោជនត្ថំ** សេចក្ដីថា ដើម្បីនឹងបរិភោគ ។ បទថា **មិត្តញ្ច នោ ហោហិ** សេចក្ដីថា សូមអ្នកជាមិត្តរបស់ពួកយើង ដឹងគុណដែលពួកយើងធ្វើហើយ ។ បទថា **តទស្សុ តេ** សេចក្ដីថា បពិត្រមហារាជ កាលកូននាយព្រានទាំងនោះ ពោលយ៉ាងនេះហើយ អាត្មាបានឲ្យគោមានកម្លាំង ១៦ គ្រឿងស្បៀកដណ្ដប់ និងទ្រព្យម្នាក់មួយរយៗ មាសមួយមាសកដល់កូននាយព្រានទាំងនោះ មួយអន្លើដោយសំពត់និងគ្រឿងប្រដាប់ដល់ភរិយាទាំងឡាយរបស់កូននាយព្រាននោះ ។

លំដាប់នោះ កូនរបស់នាយព្រានទាំងនោះ ឲ្យស្ដេចសង្ខបាលនាគរាជដេកលើផែនដី ព្រោះភាពអាក្រក់របស់ខ្លួន នាំគ្នាយកផ្ដៅដែលមានបន្លាទាញចេញមក អាត្មាឃើញនាគរាជលំបាក កាលមិនឲ្យលំបាក ទើបយកដាវកាត់ផ្ដៅទាំងនោះថ្នមៗ ហូតចេញមិនឲ្យលំបាក ទំនងដូចក្មេងៗ ស្រាយកំណួចអំពីសំពត់ជូតក្បាលដែលទន់ ក្នុងវេលានោះ កូននាយព្រានទាំងនោះ ដោតចំណងត្រង់រន្ធច្រមុះ ធ្វើជារម្ងក ព្រោះដូច្នោះ ទើបនាំគ្នាស្រាយស្ដេចនាគអំពីចំណងនោះ ។ តាបសសម្ដែងថា កូនព្រាននាំខ្សែនោះចេញអំពីច្រមុះរបស់នាគរាជនោះ ព្រមទាំងរម្ងក ។ កូនព្រានទាំងនោះ កាលលែងនាគរាជយ៉ាងនេះហើយ ដើរទៅបន្តិច ក៏នាំគ្នាពួនមើលដោយគិតថា នាគនេះទុព្វលភាព ក្នុងពេលដែលវាស្លាប់ យើងនឹងរែកយកទៅ ។

បទថា **បុណ្ណោហិ** សេចក្តីថា នាគរាជនោះបែរមុខទៅទិសខាងកើត ទៅបានបន្តិច មានភ្នែកពេញដោយទឹកភ្នែក បែរមើលអាត្មាភាព ។ បទថា **តទា-ស្សហំ** កាត់បទជា **តទា អស្ស អហំ** សេចក្តីថា កាលនោះ អាត្មាដើរតាមក្រោយនាគរាជទៅ ។

បទថា **គច្ឆេវ** សេចក្តីថា អាឡារតាបសពោលថា អាត្មាបានពោលយ៉ាងនេះនឹងស្តេចនាគរាជនោះ ។ បទថា **រហាធំ** សេចក្តីថា នាគរាជនោះបានទៅកាន់អន្លង់ទឹកឈ្មោះកណ្ណវេណ្ណានទី ។ បទថា **សមោណតំ** សេចក្តីថា កាលបង្អោនទៅដោយដើមជម្ពូ និងដើមអសោកត្រង់ច្រាំងទាំងសងខាង ។ បទថា **និត្តិណ្ណភយោ បតីតោ** សេចក្តីថា បានឮថា នាគរាជនោះកំពុងមើលអន្លង់ទឹក បានសម្តែងសេចក្តីគោរពដល់អាឡារកុដុម្ពិកៈ ផុសឡើងមកទាំងក្បាលទាំងកន្ទុយ ។ ទីដែលស្តេចនាគនោះមុជទៅហើយ ក្នុងទឹកនោះឯងជាទីផុតភ័យ ព្រោះហេតុនោះ ទើបនាគរាជនោះជាអ្នកប្រាសចាកភ័យ រួចចាកភ័យ ត្រេកអរចូលទៅ ។

បទថា **បវិស្ស** សេចក្តីថា កាលចូលទៅហើយ ។ បទថា **ន ចិរេន មេ** សេចក្តីថា មិនបានដល់នូវសេចក្តីប្រមាទក្នុងនាគពិភព កាលអាត្មាមិនទាន់ហួសច្រាំងកណ្ណវេណ្ណានទីទៅ នាគរាជបានមកប្រាកដខាងមុខអាត្មា មួយអន្លើដោយទិព្វបរិវារ ។ បទថា **ឧបដ្ឋហិ** បានដល់ ចូលមកជិត ។

បទថា **អត្ថាន្តរោ** សេចក្តីថា លោកដូចជាសាច់បេះដូង លោកមានឧបការគុណដល់ខ្ញុំជាច្រើន ខ្ញុំនឹងធ្វើសក្ការៈដល់លោក ។ បទថា **បស្ស មេ**

**និវេសនានិ** សេចក្តីថា អញ្ជើញលោកទៅមើលនាគពិភពរបស់ខ្ញុំ ។ បទថា **មសក្កសារំ វិយ** សេចក្តីថា ភ្នំសិនេរុបព៌តលោកហៅថា មសក្កសារ ព្រោះមានខ្ទឹមក្រាស់ មិនអាចដកបាន ធ្វើឲ្យរង្គើមិនបាន នាគរាជសំដៅយកតាវត្តិង្ស ពិភពដែលខ្លួនសាងទុកក្នុងនាគពិភពនោះឯង ទើបពោលសេចក្តីនេះ ។

បពិត្រមហារាជ នាគរាជនោះ កាលពោលយ៉ាងនេះហើយ កាលនឹងពណ៌នានាគពិភពរបស់ខ្លួនឲ្យក្រៃលែងឡើង ទើបពោលគាថា ២ ថា

> ភពនាគនោះ ប្រកបដោយភូមិភាគ ជាភូមិមិនមានក្រួស ទន់ល្អ មានស្មៅដ៏ទាប មិនមានធូលី ជាទីនាំមកនូវសេចក្តីជ្រះថ្លា ជាទីលះបង់នូវសេចក្តីសោកបាន ។ ( ក្នុងភពនាគនោះមានស្រះបោក្ខរណី ) មិនក្រហេងក្រហូង មានកែវពៃទូរ្យពណ៌ខៀវ មានសួនស្វាយ គួរជាទីរីករាយដោយប្រពៃ តាំងនៅក្នុងទិសទាំង ៤ ( នៃស្រះបោក្ខរណី ) ដើមស្វាយទាំងឡាយក្នុងអម្ពវ័ននោះ មានផ្លែទុំក៏មាន ផ្លែស្រគាលក៏មាន ផ្លែខ្ចីក៏មាន ក្តឹបក៏មាន ជាឈើមានផ្លែសព្វៗរដូវ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អសក្ខរា** សេចក្តីថា ភូមិភាគក្នុងនាគពិភពនោះ ប្រាសចាកថ្មនិងក្រួស ភូមិភាគនោះទន់ស្អាត សម្រេចដោយគំនរមាសប្រាក់និងកែវមណី ដេរដាសដោយខ្សាច់ គឺកែវ ៧ ប្រការ ។ បទថា **នីចត្តិណា** សេចក្តីថា ប្រកបទៅដោយស្មៅទាប ដែលមានពណ៌សដូចស្លាបមេភ្លៀង ។ បទថា **អប្បរជា** សេចក្តីថា ប្រាសចាកលម្អងធូលី ។

បទថា **យត្ថ ជហន្តិ សោកំ** សេចក្ដីថា ជាភូមិភាគដែលចូលទៅហើយ ប្រាសចាកសេចក្ដីសោក ។

បទថា **អនាវកុលា** សេចក្ដីថា មិនក្រហេងក្រហូង គឺមិនមានជង្គត់ ។ ម្យ៉ាងទៀត ដោយសេចក្ដីថា ខាងលើរាបស្មើប្រាសចាកទាបខ្ពស់ ។ បទថា **វេឡុរិយូបនីលា** សេចក្ដីថា ខៀវខ្ចីដោយកែវពៃទូរ្យ អធិប្បាយថា ក្នុងនាគពិភពនោះ មានស្រះបោក្ខរណីសម្រេចដោយកែវពៃទូរ្យ សម្បូរដោយទឹកមានពណ៌ខៀវ ដេរដាសដោយផ្កាឈូក និងផ្កាឧប្បលច្រើនពណ៌ ។ បទថា **ចតុទ្ទិសំ** បានដល់ ក្នុងទិសទាំង ៤ នៃស្រះបោក្ខរណី ។ បទថា **បក្កា ច** សេចក្ដីថា ក្នុងសួនអម្ពនៃនោះ មានដើមស្វាយ ដែលមានផ្លែទុំហើយខ្លះ ស្រគាលខ្លះ ខ្ចីខ្លះ រយោនរយាននោះឯង ។ បទថា **ឆិច្ចោតុកា** សេចក្ដីថា ប្រកបដោយផ្កានិងផ្លែ សមគួរដល់រដូវទាំង ៦ ។

អាឡារតាបសទូលព្រះបាទពារាណសីជាបន្តថា

បពិត្រព្រះនរទេព លំនៅជាវិការៈនៃមាស មានសន្ទះទ្វារជាវិការៈនៃប្រាក់ មានរស្មីផ្លេកៗ រុងរឿងក្រៃលែងក្នុងកណ្ដាលនៃព្រៃឈើទាំងឡាយនោះ ដូចជាផ្លេកបន្ទោរក្នុងអាកាស ។

បពិត្រព្រះរាជា ( ក្នុងប្រាសាទនោះ មានផ្ទះកំពូលនិងល្វែង ) ជាវិការៈនៃកែវមណី ទាំងជាវិការៈនៃមាសរុងរឿង ដ៏វិចិត្រជាអនេក ដែលនិម្មិតល្អហើយរៀបៗ ពេញដោយពួកនាងកញ្ញា ដ៏ទ្រទ្រង់ដោយគ្រឿងប្រដាប់មាស ។ សន្ទុបាលនាគរាជ

នោះ មានសម្បុរមិនថោកទាប ( បានចាប់ដៃអាត្មាភាព ) មានសភាពរួសរាន់ឡើងកាន់ប្រាសាទ ដែលមានសសរមួយពាន់ មានអានុភាពប្រឹងមិនបាន ដែលជាទីនៅនៃកិរិយា ជាមហេសីរបស់សន្ទុបាលនាគរាជនោះ ។ នាងនារីម្នាក់ មានសភាពរួសរាន់កាន់យកនូវកែវមណីដ៏ស្អាត ប្រកបដោយកែវមណីដទៃ មានជាតិសុទ្ធ ជាស្ត្រីដែលនាគរាជនោះ មិនបាច់តឿន ក៏ក្រាលនូវអាសនៈជាវិការៈនៃកែវពិទូរ្យ មានតម្លៃច្រើន ។ លំដាប់នោះ នាគរាជចាប់ដៃអាត្មាភាពឲ្យអង្គុយលើអាសនៈជាប្រមុខ ( ពោលថា ) នេះអាសនៈ សូមលោកដ៏ចម្រើនអង្គុយលើអាសនៈនេះ ព្រោះថា បណ្តាបុគ្គលដែលគួរគោរពទាំងឡាយ លោកដ៏ចម្រើនទុកជាបុគ្គលគួរគោរពមួយរបស់ខ្ញុំ ។ បពិត្រព្រះជនិន្ទ្រ នាងនារីដទៃមានសភាពរហ័សរហួន នាំទឹកចូលមកលាងជើងអាត្មាភាព ដូចជាប្រពន្ធលាងជើងកស្តាជាទីស្រឡាញ់ ។ មាននាងនារីម្នាក់ទៀត មានសភាពរួសរាន់បានលើកនូវបាយ មានសម្លដ៏ច្រើននិងម្ហូបក្រៀមផ្សេងៗដោយភាជន៍ ជាវិការៈនៃមាស ហើយបង្អោនចូលមកជិត ។ បពិត្រព្រះភារតៈនាងនារីទាំងឡាយបានដឹងនូវចិត្តនៃព្រះភស្តា ( របស់ខ្លួន ) ហើយបម្រើអាត្មាភាព ដែលជាអ្នកបរិភោគរួចហើយ ដោយតូរ្យតន្ត្រីទាំងឡាយ នាគរាជនោះប្រណិប័តន៍

អាត្មាភាព ដោយកាមគុណជាទិព្វដ៏ឧឡារិក មានប្រមាណ
ច្រើន ដ៏ក្រៃលែងជាងតួរតន្ត្រីនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **និវេសនំ** បានដល់ ប្រាសាទ ។ បទថា **បភស្សរសន្និកាសំ** បានដល់ មើលទៅក្លីផ្ទេកពណ្ណរាយ ។ បទថា **រជតគ្គឡំ** សេចក្ដីថា មានសន្ទះទ្វារនិងបង្អួចធ្វើដោយប្រាក់ ។

បទថា **មណិមយា** សេចក្ដីថា ផ្ទះកំពូលនិងបន្ទប់ខាងក្នុងមានបែបនេះ ( សម្រេចដោយកែវមណី ) ក្នុងប្រាសាទនោះ ។ បទថា **បរិប្ផា** បានដល់សម្បុរ ។

បទថា **សោ សន្ធុចាលោ** សេចក្ដីថា អាឡារតាបសចង្អុលបង្ហាញថា បពិត្រមហារាជ កាលនាគរាជនោះសរសើរនាគពិភពនោះយ៉ាងនេះ អាត្មាចង់មើលនាគពិភពនោះ គ្រានោះ សង្ខបាលនាគរាជ ក៏នាំអាត្មាទៅក្នុងទីនោះ ចាប់ដៃរួសរាន់ឡើងប្រាសាទដែលមានសសរ ១០០០ សម្រេចហើយដោយកែវពៃទូរ្យ នាំទៅកាន់ទីដែលមហេសីរបស់ស្ដេចនាគនៅ ។

បទថា **ឯកា ច** សេចក្ដីថា កាលអាត្មាឡើងកាន់ប្រាសាទហើយ ស្រីទាំងឡាយនាំអាសនៈកែវពៃទូរ្យដ៏វិចិត្រ ចូលដល់ជាតិកែវមណីដទៃមកក្រាលដោយនាគរាជនោះមិនបានប្រាប់ឡើយ ។ បទថា **អត្ថិហាសិ** សេចក្ដីថា នាំមក អធិប្បាយថា ក្រាលហើយ ។

បទថា **ចាមុខអាសនស្មឹ** បានដល់ លើអាសនៈដែលជាប្រមុខ អធិប្បាយថា អញ្ជើញឲ្យអង្គុយលើអាសនៈដ៏ឧត្ដម ។ បទថា **គរូធំ** សេចក្ដីថា នាគ

រាជនោះពោលអញ្ជើញឲ្យអង្គុយយ៉ាងនេះថា លោកដូចជាម្តាយរបស់យើងម្នាក់ ។

បទថា **វិវិធំ វិយញ្ជនំ** បានដល់ បាយទឹកមានប្រការផ្សេងៗ ។ បទថា **ភត្ត មនុញ្ញរូបំ** បានដល់ ភត្តាហារដែលគួរបរិភោគ ។ អាឡារតាបស ហៅព្រះរាជាថាភារត: ។ បទថា **ភុត្តវន្តំ** បានដល់ បរិភោគស្រេចហើយ ។ បទថា **ឧបដ្ឋហុំ** សេចក្តីថា នារីទាំងឡាយធ្វើនូវការច្រៀងរាំ បម្រើអាត្មាភាពដែលបរិភោគស្រេចហើយ ដោយតន្ត្រីជាង ១០០ ។ បទថា **ភត្តុ មនោវិធិត្វា** សេចក្តីថា នារីទាំងឡាយដឹងចិត្តនៃកស្តាខ្លួន ។ បទថា **តតុត្តរី** សេចក្តីថា ក្រៃលែងជាងការរាំនោះ ។ បទថា **មំ និបតិ** សេចក្តីថា នាគរាជនោះចូលមករកអាត្មា ។ បទថា **មហន្តំ ធិព្វេហិ** សេចក្តីថា ដោយកាមដែលជាទិព្វដ៏មហោឡារ ។ បទថា **កាមេហិ** សេចក្តីថា ដោយកាមដែលជាទិព្វទាំងនោះ មិនមែនតិច គឺមិនមែនតិចតួច ។

កាលនាគរាជនោះ ចូលមករកយ៉ាងនេះ ហើយពោលគាថានេះថា

បពិត្រអាឡារ: ភរិយាទាំងឡាយរបស់ខ្ញុំនុ៎ះ ៣០០ នាក់
ភរិយាទាំងអស់ មានពាក់កណ្តាលខ្លួន ( រៀវល្អ ) មានរស្មី
ដ៏ក្រៃលែង ហាក់ដូចជាពណ៌នៃផ្កាឈូក បពិត្រអាឡារ:
លោកចូរធ្វើសេចក្តីស្រឡាញ់ ចំពោះស្ត្រីទាំងនុ៎ះ ខ្ញុំនឹងឲ្យ
ដល់លោកៗចូរឲ្យស្ត្រីទាំងនោះបម្រើចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សព្វត្តមជ្ឈា** សេចក្តីថា ភរិយារបស់ខ្ញុំ

ទាំងអស់ មានរូបរាងល្អតល្ងន់ អធិប្បាយថា ចង្កេះមូល អាចវាស់ដោយបាតដៃ តែបាលីក្នុងអដ្ឋកថាជា **សុមជ្ឈា** ។ បទថា **បទុមុត្តរាភា** បានដល់មានពណ៌ដូចពណ៌នៃផ្កាឈូក អធិប្បាយថា មានឆវីវណ្ណដូចត្របកឈូក ។ បទថា **បរិចារយស្សុ** សេចក្តីថា នាគរាជនោះពោលថា ចូរលោកធ្វើនាងទាំងនោះឲ្យជាបាទបរិចារិការបស់ខ្លួន ហើយប្រគល់មហាសម្បត្តិ មួយអន្លើដោយស្រី ៣០០ ដល់អាត្មា ។ អាឡារតាបសនោះទូលបន្តថា

អាត្មាភាពបានទទួលដីងរសនៃកាមគុណជាទិព្វ អស់មួយឆ្នាំ កាលនោះ អាត្មាភាពសួរតទៅទៀតថា ព្រះអង្គជានាគ បាននូវសម្បត្តិនេះ ព្រោះធ្វើនូវកម្មអ្វី ព្រះអង្គបានវិមានដ៏ប្រសើរដោយប្រការដូចម្តេច ។ ព្រះអង្គបានដោយមិនមានហេតុ ឬកើតអំពីបុគ្គលណាមួយ បង្អោនមកថ្វាយព្រះអង្គ ព្រះអង្គធ្វើឯង ឬពួកទេវតាថ្វាយ បពិត្រនាគរាជ ខ្ញុំសួរសេចក្តីនេះនឹងព្រះអង្គៗបានវិមានដ៏ប្រសើរដោយប្រការដូចម្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទិព្វរសានុភុត្វា** សេចក្តីថា អាត្មាសោយរសនៃកាមគុណដែលជាទិព្វហើយ ។ បទថា **តតាស្សុហំ** កាត់បទជា **តតោ អស្សុ អហំ** ។ បទថា **នាគស្សិទំ** សេចក្តីថា ខ្ញុំបានសួរនាគរាជនោះដូច្នេះថា សម្បត្តិដែលកើតហើយនេះរបស់សង្ខបាលនាគរាជ ដែលមានមុខដ៏ចម្រើន លោកធ្វើកម្មឈ្មោះអ្វី ទើបបានគ្រប់គ្រងវិមានដ៏ប្រសើរយ៉ាងនេះ ។

បទថា **អធិច្ច លទ្ធំ** សេចក្តីថា លោកមិនមែនបានដោយឥតហេតុទេ ។

បទថា **បរិណាមជន្តេ** សេចក្តីថា ឬឈ្មោះថា កើតហើយដោយការបង្អោន មក ព្រោះជារបស់ដែលបុគ្គលណាមួយ បង្អោនមកដើម្បីជាប្រយោជន៍ដល់ លោក ។ បទថា **សយំ កតំ** សេចក្តីថា ឲ្យហៅជាឯមក ហើយប្រគល់ រតនៈឲ្យធ្វើ ។

លំដាប់តទៅ ជាគាថាពោលឆ្លើយឆ្លងរវាងជនទាំង ២ គប្បីជ្រាបដូច តទៅនេះថា

សន្ធបាលនាគរាជពោលថា

វិមាននេះ មិនមែនខ្ញុំបានដោយមិនមានហេតុទេ មិនមែនកើត
អំពីបុគ្គលណា បង្អោនមកថ្វាយខ្ញុំទេ ខ្ញុំមិនមែនធ្វើដោយខ្លួន
ឯង ទាំងមិនមែនទេវតាឲ្យខ្ញុំទេ វិមាននេះ ខ្ញុំបានដោយកម្ម
របស់ខ្លួន ជាអំពើឥតបាប គឺជាបុណ្យ ។

អាត្មាពោលថា

វត្តរបស់ព្រះអង្គដូចម្តេច ព្រហ្មចារ្យតើដូចម្តេច នេះជាវិបាក
នៃកម្មដែលប្រព្រឹត្តល្អហើយដូចម្តេច បពិត្រនាគរាជ សូម
ព្រះអង្គប្រាប់សេចក្តីនុ៎ះដល់ខ្ញុំ វិមាននេះ តើព្រះអង្គបានហើយ
ដោយប្រការដូចម្តេច ។

សន្ធបាលនាគរាជពោលថា

ខ្ញុំជាស្តេចឈ្មោះទុយ្យោធនៈ ជាធំក្នុងដែនមគធៈ មានអានុភាព
ធំ ខ្ញុំនោះបានដឹងច្បាស់នូវជីវិត ជារបស់ថោកទាប មិនទៀង

មានសេចក្ដីប្រែប្រួលជាធម្មតា ។ ខ្ញុំមានចិត្តជ្រះថ្លា បានឲ្យបាយនិងទឹកជាទានបរិបូណ៌ ដោយគោរព ក្នុងកាលនោះ ផ្ទះរបស់ខ្ញុំ ជាទីប្រជុំរបស់សមណៈ ( ព្រាហ្មណ៍ ) ដូចជាអណ្ដូង ព្រោះថា សមណព្រាហ្មណ៍ទាំងឡាយ ខ្ញុំបានឲ្យឆ្អែតស្កប់ស្កល់ហើយ ។ ខ្ញុំបានឲ្យផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ប្រទីប យាន លំនៅ សំពត់សម្រាប់ស្លៀកដណ្ដប់ ទីដេក និងបាយទឹកជាទាន ដោយគោរពក្នុងទីនោះ ។ អំពើនោះ ជាវត្តរបស់ខ្ញុំ អំពើនោះជាព្រហ្មចារ្យរបស់ខ្ញុំ នេះជាវិបាកនៃកម្មដែលប្រព្រឹត្តល្អហើយនោះ ព្រោះហេតុនោះឯង វិមាននេះទើបមានចំណីដ៏ច្រើន មានបាយនិងទឹកដ៏ច្រើន ដែលខ្ញុំបានហើយ ។

អាត្មាពោលថា

វិមាននេះ សម្បូរដោយការរាំ ទាំងសម្បូរដោយការច្រៀង តាំងនៅអស់កាលយូរ តែមិនទៀងទាត់សោះទេ ពួកអ្នកមានអានុភាពតិច មិនមានតេជះ រមែងបៀតបៀនព្រះអង្គ ដែលមានអានុភាពច្រើន មានតេជះ បពិត្រព្រះអង្គ មានចក្ខុជាអាវុធ ព្រះអង្គមកលុះកណ្ដាប់ដៃ នៃពួកភោជបុត្ត តើព្រោះអាស្រ័យអ្វី ព្រោះហេតុអ្វី ។ តេជះរបស់ព្រះអង្គទៅតាមភ័យដ៏ធំឬ ឬពិសរបស់ព្រះអង្គទៅតាមគល់ធ្មេញ បពិត្រព្រះអង្គមាន

ចន្ទមជាអាវុធ ព្រះអង្គដល់នូវសេចក្ដីលំបាក ( ក្នុងសំណាក់ ) នៃពួកភោជបុត្ត តើព្រោះអាស្រ័យអ្វី ព្រោះហេតុអ្វី ។

សង្ខបាលនាគរាជពោលថា

តេជះរបស់ខ្ញុំមិនមែនទៅតាមភ័យដ៏ធំទេ តេជះ គឺពិសរបស់ខ្ញុំ ពួកភោជបុត្តទាំងនោះ មិនអាចនឹងបៀតបៀនទេ ធម៌ទាំងឡាយ ពួកសប្បុរសសំដែងល្អហើយ ជាធម៌លះបង់បានដោយក្រ ដូចច្រាំងសមុទ្ទ ។ បពិត្រអាឡារៈ ខ្ញុំរក្សាឧបោសថក្នុងថ្ងៃទី ១៤ និងថ្ងៃទី ១៥ ជានិច្ច គ្រានោះ ពួកភោជបុត្ត ១៦ នាក់ កាន់ខ្សែនិងអន្ទាក់ដ៏មាំដើរមក ។ ព្រានទាំងឡាយទម្លាយ ( សរីរៈ ) យកខ្សែខ្ទះច្រមុះ ហើយសែងនាំយកខ្ញុំទៅ ខ្ញុំញ៉ាំង ឧបោសថមិនឲ្យកម្រើក ខំអត់ទ្រាំនូវសេចក្ដីទុក្ខទាំងនេះ ។

អាឡារស្ួរថា

( ពួកភោជបុត្តទាំងនោះ ) បានឃើញព្រះអង្គ ជាអ្នកបរិបូណ៌ ដោយកម្លាំងនិងសម្បុរ ក្នុងផ្លូវជាទីដើរទៅ នៃបុគ្គលតែម្នាក់ ព្រះអង្គជាអ្នកចម្រើនដោយសិរីនិងបញ្ញា បពិត្រនាគរាជ ព្រះអង្គខំប្រឹងធ្វើតបៈ តើដើម្បីអ្វី ។

សង្ខបាលនាគរាជពោលថា

បពិត្រអាឡារៈ ( ខ្ញុំធ្វើតបៈ ) មិនមែនព្រោះហេតុកូន មិនមែនព្រោះហេតុទ្រព្យ មិនមែនព្រោះហេតុអាយុទេ ខ្ញុំប្រាថ្នា

ចំពោះកំណើតនៃមនុស្ស ព្រោះហេតុនោះ បានជាខ្ញុំប្រឹងប្រែង ធ្វើតបៈ ។

អាត្មាសួរថា

ព្រះអង្គមានចក្ខុក្រហម មានរស្មីព្រោងព្រាត មានខ្លួនប្រដាប់ហើយ មានសក់និងពុកមាត់កាត់កោរហើយ លាបហើយដោយខ្លឹមចន្ទន៍ក្រហម ហើយញុំាងទិសទាំងឡាយឲ្យភ្លឺច្បាស់ ដូចស្តេចគន្ធព្វ ។ ព្រះអង្គដល់នូវឫទ្ធិដូចជាឫទ្ធិនៃទេវតា មានអានុភាពធំ ប្រកបដោយកាមទាំងពួង បពិត្រនាគរាជ ខ្ញុំសូមសួរនូវសេចក្តីនុ៎ះ ចំពោះព្រះអង្គថា មនុស្សលោកប្រសើរជាងភពនាគនេះ តើដោយហេតុអ្វី ។

សង្ខបាលនាគរាជពោលថា

បពិត្រអាឡារៈ សេចក្តីបរិសុទ្ធក្តី ការសង្រួមក្តី វៀរចាកមនុស្សលោកហើយរមែងមិនមានឡើយ ខ្ញុំបើបានកំណើតនៃមនុស្សហើយ នឹងធ្វើនូវទីបំផុតនៃជាតិនិងមរណៈ ។

អាត្មាពោលថា

ខ្ញុំនៅក្នុងសំណាក់នៃព្រះអង្គអស់មួយឆ្នាំហើយ ព្រះអង្គក៏បានទំនុកបម្រុងដោយបាយនិងទឹក បពិត្រនាគរាជ ខ្ញុំសូមលាត្រឡប់ទៅវិញ បពិត្រព្រះជនិន្ទ្រ ខ្ញុំឃ្លាត ( ពីមនុស្សលោក ) យូរហើយ ។

សន្ខបាលនាគរាជពោលថា

កូនប្រពន្ធនិងពួកជនជាអ្នករស់នៅ ដោយសារខ្ញុំៗ បានប្រៀនប្រដៅជានិច្ច ឲ្យបម្រើលោក តើអ្នកណាមួយ មិនបានថែទាំលោកខ្វះឬទេ បពិត្រអាឡារៈ ព្រោះថា ខ្ញុំមានការស្រឡាញ់ពេញចិត្ត ចំពោះការចួបប្រទះនូវលោក ។

អាឡារពោលថា

បពិត្រនាគរាជ ដូចយ៉ាងកូនជាទីស្រឡាញ់របស់មាតា និងបិតា ដែលមាតាបិតាបានថែរក្សាហើយ ឲ្យនៅក្នុងផ្ទះ ( ការនៅ ) របស់ខ្ញុំក្នុងទីនេះ ប្រសើរជាងការនៅរបស់កូននោះទៅទៀត ព្រោះថា ចិត្តរបស់អ្នកជ្រះថ្លាចំពោះខ្ញុំ ។

សន្ខបាលនាគរាជពោលថា

កែវមណីរបស់ខ្ញុំមានពណ៌ក្រហម ជាគ្រឿងនាំមកនូវទ្រព្យ លោកចូរយកកែវមណីដ៏ថ្លៃថ្លាទៅផ្ទះរបស់ខ្លួនចុះ លុះបានទ្រព្យហើយ ចូរទុកកែវមណីនោះ ( ក្នុងពាងទឹក ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កិន្នុ វតំ** សេចក្ដីថា អាឡារសួរថា អ្វីជាវត្តសមាទានរបស់លោក ។ បទថា **ព្រហ្មចរិយំ** សេចក្ដីថា អ្វីជាចរិយាដ៏ប្រសើររបស់លោក ។

បទថា **ឱទានភូតំ** សេចក្ដីថា នាគរាជឆ្លើយថា កាលនោះ ផ្ទះរបស់ខ្ញុំដូចស្រះបោក្ខរណីដែលជីកក្នុងផ្លូវធំមានមុំ ៤ មានសម្បត្តិដែលសមណ-

ព្រាហ្មណ៍តាំងនៅក្នុងធម៌គប្បីបរិភោគបានតាមសប្បាយ ។

បទថា **ន ច សស្សតាយំ** សេចក្តីថា នាគរាជនោះពោលនឹងអាត្មាថា សេចក្តីពិតវិមាននេះ ទោះបីជារបស់តាំងនៅបានយូរ ក៏មិនមែនជារបស់ទៀងនៃខ្ញុំ ។ អាឡារតាបសពោលសំដៅដល់កូនព្រានព្រៃថា ជាអ្នកមានអានុភាពតិច ។ បទថា **ហន្តិ** សេចក្តីថា អាត្មាសួរថា ព្រោះហេតុអ្វីទើបកូនព្រានព្រៃយកស្នាចាក់បៀតបៀនបានក្នុងទីទាំង ៨ កន្លែង ។ បទថា **កឹ បដិច្ច** សេចក្តីថា លោកមកកាន់កណ្តាប់ដៃ គឺចូលដល់អំណាចរបស់ពួកស្មូមក្នុងកាលនោះ តើដោយបំណងដូចម្តេច ។ បទថា **វនិព្វកានំ** សេចក្តីថា កូនព្រានព្រៃទាំងឡាយលោកហៅថាស្មូមក្នុងទីនេះ ។

បទថា **តេជោ នុ តេ នាន្វគតំ ទន្តមូលំ** សេចក្តីថា តេជះរបស់លោកដូចម្តេចឬ ព្រោះឃើញពួកកូនព្រានក្នុងកាលនោះ ភ័យធំកើតដល់លោកឬ ឬពិសដែលមានចង្កូមជាមូលមិនទៅតាមលោក ។ បទថា **កិលេសំ** បានដល់ទុក្ខ ។ បទថា **វនិព្វកានំ** សេចក្តីថា ព្រោះអាស្រ័យអ្វី ទើបលោកដល់នូវសេចក្តីទុក្ខ ក្នុងសម្នាក់នៃកូនព្រានទាំងឡាយ គឺព្រោះអាស្រ័យកូនរបស់នាយព្រាន ។

បទថា **តេជោ ន សក្កា មម តេភិ ហន្តុំ** សេចក្តីថា នាគរាជឆ្លើយថា តេជះ គឺពិសរបស់យើង មិនអាចបៀតបៀនដោយតេជះរបស់អ្នកដទៃ គឺជនទាំងនោះ ( មិនអាចបៀតបៀនខ្ញុំដោយតេជះ ) បាន ។ បទថា **សតំ** បានដល់ សប្បុរសទាំងឡាយ មានព្រះពុទ្ធជាដើម ។ បទថា **ធម្មានិ** បាន

ដល់ធម៌ ពោលគឺសីល សមាធិ បញ្ញា ខន្តី ករុណា និងមេត្តាភាវនា ។ បទថា **សុកិត្តិតានិ** សេចក្តីថា លោកពណ៌នាទុកល្អហើយ គឺពោលទុកល្អហើយ ។ បទថា **កឹ** សេចក្តីថា លោកធ្វើដូចម្តេច ។

បទថា **សមុទ្ទវេលាវ ទុរច្ចយានិ** សេចក្តីថា សង្ខបាលនាគរាជពោលថា សប្បុរសទាំងនោះ ពណ៌នាទុកថា បុគ្គលកន្លងបានលំបាកដើម្បីជីវិត ដូចច្រាំងមហាសមុទ្រដែលកន្លងបានដោយក្រ ដូច្នោះ ព្រោះហេតុនោះ ទើបខ្ញុំជាអ្នកប្រកបដោយខន្តីនិងមេត្តា ព្រោះខ្លាចសីលដាច់ បើខ្ញុំអាក់អន់ ក៏មិនបានឲ្យកន្លងល្មើសទីបំផុតរបស់សីល ។ ដោយធម្មទេសនារបស់សង្ខបាលនាគរាជនោះ រមែងបាននូវបារមីគ្រប់ទាំង ១០ គឺភាពដែលមហាសត្វឲ្យសរីរៈក្នុងកាលនោះ ចាត់ជាទានបារមី ១ ភាពដែលសីលមិនបានបែកធ្លាយដោយតេជៈគឺពិសបែបនោះ ចាត់ជាសីលបារមី ១ ការចេញពីពិភពនាគបំពេញសមណធម៌ ចាត់ជានេក្ខម្មបារមី ១ ការចាត់ចែងថាគួរធ្វើវត្ថុនេះ មិនគួរធ្វើវត្ថុនេះ ចាត់ជាបញ្ញាបារមី ១ សេចក្តីព្យាយាមដោយអំណាចនៃការអត់ធន់ ចាត់ជាវីរិយបារមី ១ ការអត់ធន់ដោយអំណាចការអត់សង្កត់ ចាត់ជាខន្តិបារមី ១ ការសមាទានសច្ចៈ ចាត់ជាសច្ចបារមី ១ ការអធិដ្ឋានក្នុងចិត្តថា អញនឹងមិនទម្លាយសីល ចាត់ជាអធិដ្ឋានបារមី ១ ភាពជាអ្នកអាណិតអាសូរ ចាត់ជាមេត្តាបារមី ១ ការដាក់ខ្លួនជាកណ្តាលក្នុងវេទនា ចាត់ជាឧបេក្ខាបារមី ១ ។

បទថា **អជាគមុំ** សេចក្តីថា នៃអាឡារៈ ថ្ងៃមួយ កូនព្រាន ១៦ នាក់ឃើញខ្ញុំដេកលើកំពូលដំបូក នាំគ្នាកាន់ខ្សែរឹង អន្ទាក់ដែលស្វិត និងស្នមក

កាន់សម្នាក់ខ្ញុំ ។

បទថា **ភេត្វាន** សេចក្តីថា ជនទាំងនោះចាក់សរីរៈរបស់ខ្ញុំក្នុងទីទាំង ៨ ហើយស៊កផ្តៅទាំងបន្ទាចូលទៅ ។ បទថា **ឆាសំ អតិកស្ស រជ្ជុំ** សេចក្តីថា ដើរទៅបន្តិច ឃើញក្បាលរបស់ខ្ញុំសំយុង ទើបដាក់ឲ្យដេកត្រង់កណ្តាលផ្លូវធំ ហើយចាក់ច្រមុះរបស់ខ្ញុំទៀត ដោតខ្សែដែលវេញត្រង់ចុងច្រមុះ ចងរុំជុំវិញ នាំខ្ញុំទៅ ។

បទថា **អទ្ទសំសុ** សេចក្តីថា អាត្មាពោលថា នែសម្លាញ់សន្ធបាល កូនរបស់ព្រានទាំងនោះ ឃើញលោកសម្បូរដោយកម្លាំង និងពណ៌សម្បុរ ក្នុងផ្លូវថ្មើរជើង ដែលជាទីទៅមកបានសម្រាប់មនុស្សម្នាក់ តែលោកចម្រើនសិរីគឺឥស្សរិយយស និងការស្អាតក្រៃលែង ចម្រើនដោយបញ្ញា ជាអ្នករុងរឿងបែបនេះ បំពេញតបៈប្រាថ្នាអ្វី ទើបរក្សាឧបោសថ គឺរក្សាសីល ។ បាឋៈថា **អទ្ទសាសឹ** ប្រែថា ខ្ញុំបានឃើញហើយ ដូច្នេះក៏មាន អធិប្បាយថា ខ្ញុំបានឃើញលោកក្នុងផ្លូវធំដែលជាផ្លូវតែមួយ ។

បទថា **អភិបត្ថយានោ** បានដល់ ប្រាថ្នា ។ បទថា **តស្មា** សេចក្តីថា នាគរាជឆ្លើយថា ខ្ញុំប្រាថ្នាកំណើតមនុស្ស ព្រោះដូច្នោះ ទើបព្យាយាមធ្វើតបកម្មដោយសេចក្តីព្យាយាម ។

បទថា **សុភោសិតោ** សេចក្តីថា លោកជាបុគ្គលលាបស្រឡាបហើយដោយល្អ ។ បទថា **ឥតោ** សេចក្តីថា មនុស្សលោក មានអ្វីក្រៃលែងជាងនាគពិភពនេះ ។

បទថា **សុទ្ធី** បានដល់ វិសុទ្ធិ ពោលគឺមគ្គ ផល និងព្រះនិព្វាន ។ បទថា **សំយមោ** បានដល់ សីល ស្តេចនាគនោះសំដៅយកការកើតឡើងនៃព្រះសម្ពុទ្ធ ព្រះបច្ចេកពុទ្ធទាំងឡាយ ក្នុងមនុស្សលោកប៉ុណ្ណោះ ទើបពោលពាក្យនេះ ។

បទថា **កាយាមិ** សេចក្តីថា ស្តេចនាគពោលបន្តថា កាលខ្ញុំធ្វើនូវការមិនមាននៃបដិសន្ធិរបស់ខ្លួននឹងធ្វើទីបំផុតនៃជាតិ ជរា និងមរណៈបាន បពិត្រមហារាជ សង្ឃបាលនាគរាជនោះសរសើរមនុស្សលោកយ៉ាងនេះ ។

បទថា **សំវច្ឆរោ មេ** សេចក្តីថា សូមថ្វាយព្រះពរ កាលនាគរាជនោះសរសើរមនុស្សលោកយ៉ាងនេះ អាត្មាធ្វើនូវការជាប់ជំពាក់ក្នុងបព្វជ្ជា ទើបពោលពាក្យនេះ ។

បណ្តាបទទាំងនោះ បទថា **ឧបដ្ឋិតោស្មិ** សេចក្តីថា ខ្ញុំជាបុគ្គលដែលលោកបម្រើហើយ ដោយបាយទឹក និងកាមគុណដែលជាទិព្វ ។ បទថា **បលេមិ** សេចក្តីថា គង់រឭកដល់ តែត្រូវតែចេញទៅ ។ បទថា **ចិរប្បវុដ្ឋោស្មិ** សេចក្តីថា ខ្ញុំចេញអំពីមនុស្សលោកមកយូរហើយ ។

បទថា **ឆាភិសំសិត្ត** សេចក្តីថា ស្តេចនាគសួរថា ក្នុងបុត្តជាដើមនៃខ្ញុំ បុគ្គលណាមួយមិនបានជេរ មិនបានបរិភាសលោកមិនមែនឬ ។ បាឋៈថា **ឆាភិសជ្ជេថ** ប្រែថា មិនបានផ្តាសាដូច្នេះក៏មាន អធិប្បាយថា មិនបានធ្វើឲ្យអាក់អន់ ។ បទថា **បដិវិហិតោ** បានដល់ បម្រើហើយ ។

បទថា **មណិ មមំ** សេចក្តីថា ស្តេចនាគពោលថា នៃសម្លាញ់អាឡារៈ

បើលោកជម្នះតែខាងទៅ កាលបើដូច្នេះ កែវមណីពណ៌ក្រហម នាំទ្រព្យទាំងពួងមកឲ្យ ឲ្យនូវសម្បត្តិដែលគួរប្រាថ្នាទាំងពួងរបស់ខ្ញុំមាន សូមលោកកាន់យកមណីរតន៍នោះទៅកាន់ផ្ទះរបស់ខ្លួន នឹងបានទ្រព្យតាមប្រាថ្នា ដោយអានុភាពនៃមណីរតន៍នេះហើយ ចូររក្សាមណីរតន៍នេះទុកក្នុងផ្ទះនោះ តែកាលរក្សាកុំទុកក្នុងទីដទៃ គួរទុកក្នុងពាងទឹករបស់ខ្លួន កាលនាគរាជពោលដូច្នេះហើយ ក៏បង្អោនមណីរតន៍មកឲ្យអាត្មា ។

កាលអាឡារតាបសពោលយ៉ាងនេះហើយ ទើបពោលបន្តទៅថា សូមថ្វាយព្រះពរ មហារាជ កាលនោះ អាត្មាបានពោលពាក្យនេះនឹងស្តេចនាគថា នែសម្លាញ់ ខ្ញុំមិនមានសេចក្តីត្រូវការដោយទ្រព្យ តែខ្ញុំប្រាថ្នានឹងបួស ដូច្នេះហើយ ក៏សូមបរិក្ខាររបស់បព្វជិត ចេញអំពីនាគពិភព ព្រមដោយនាគរាជនោះ អញ្ជើញឲ្យស្តេចនាគត្រឡប់ហើយ ទើបទៅកាន់ហិមវន្តប្បទេស បព្វជ្ជា ដូច្នេះហើយ កាលនឹងពោលធម្មកថាថ្វាយព្រះរាជា ទើបពោលគាថា ២ ថា

បពិត្រព្រះរាជា កាមគុណទាំងឡាយ សូម្បីជារបស់មនុស្ស
អាត្មាភាពបានឃើញហើយថាជារបស់មិនទៀង មានសេចក្តី
ប្រែប្រួលជាធម្មតា លុះអាត្មាភាពឃើញទោសក្នុងកាមគុណ
ទាំងឡាយ ទើបបួសដោយសទ្ធា ។ បពិត្រព្រះរាជាមនុស្ស
ទាំងឡាយក្មេងក្តី ចាស់ក្តី កាលមានសរីរៈបែកធ្លាយហើយ
រមែងធ្លាក់ចុះ ដូចជាផ្លែឈើទាំងឡាយដូច្នោះដែរ អាត្មាភាព

ឃើញហេតុនេះហើយ ទើបចេញបួស សាមញ្ញគុណ គឺបព្វជ្ជា

ជាធម៌ប្រតិបត្តិមិនខុស ជាធម៌ដ៏ប្រសើរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សទ្ធាយ** សេចក្ដីថា អាត្មាបួស ព្រោះជឿនូវកម្ម ជឿផលនៃកម្ម និងជឿនូវព្រះនិព្វាន ។ បទថា **ទុមប្ផលានេវ** សេចក្ដីថា ផ្លែឈើទាំងឡាយទុំហើយក្ដី មិនទាន់ទុំក្ដី រមែងជ្រុះយ៉ាងណា មនុស្សទាំងឡាយ ទាំងក្មេង ទាំងចាស់ រមែងជ្រុះទៅក៏យ៉ាងនោះ ។ បទថា **អបណ្ណកំ** បានដល់ សាមញ្ញផលដែលមិនខុស គឺជានេយ្យានិកធម៌ ។ បទថា **សាមញ្ញមេវ សេយ្យោ** សេចក្ដីថា បពិត្រមហារាជ អាត្មាភាពឃើញគុណនៃបព្វជ្ជាថា បព្វជ្ជានោះឯង ជារបស់ប្រសើរ ទើបបួស ដូច្នេះ ។

ព្រះរាជាទ្រង់ស្ដាប់ដូច្នោះ ទើបត្រាស់គាថាជាលំដាប់តទៅថា

ពួកជនណាមានប្រាជ្ញា ជាពហុស្សូត ជាអ្នកគិតនូវហេតុដ៏ច្រើន

ពួកជននោះ បុគ្គលគប្បីសេពគប់ បពិត្រអាឡារតាបស ខ្ញុំ

នឹងធ្វើនូវបុណ្យដ៏ច្រើន ព្រោះបានស្ដាប់ ( នូវពាក្យ ) របស់

នាគរាជផង របស់លោកផង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យេ ពហុឋានចិន្តិនោ** សេចក្ដីថា ជនពួកណា ដឹងហេតុការណ៍បានច្រើន ។ បទថា **នាគញ្ច** សេចក្ដីថា ព្រោះបានស្ដាប់ពាក្យរបស់ស្ដេចនាគរាជ និងរបស់លោក ដែលមានប្រក្រតីនៅដោយការមិនប្រមាទយ៉ាងនេះ ខ្ញុំនឹងសាងកុសលច្រើនប្រការ ។

លំដាប់នោះ កាលតាបសញ៉ាំងឧស្សាហៈឲ្យកើតដល់ព្រះរាជា បាន

ពោលនូវអវសានគាថានេះថា

ពួកជនណា មានប្រាជ្ញា ជាពហុស្សូត ជាអ្នកគិតនូវហេតុដ៏ច្រើន ពួកជននោះ បុគ្គលគប្បីសេពគប់ បពិត្រព្រះរាជា ព្រះអង្គទ្រង់ព្រះសណ្ដាប់ពាក្យរបស់អាត្មាភាពនិងនាគហើយ សូមព្រះអង្គធ្វើបុណ្យឲ្យច្រើន ដូច្នេះ ។

តាបសនោះសម្ដែងធម៌ថ្វាយព្រះរាជាយ៉ាងនេះហើយ នៅក្នុងព្រះរាជឧទ្យាននោះឯង អស់កាល ៤ ខែក្នុងរដូវភ្លៀង ហើយត្រឡប់ទៅកាន់ហិមវន្តប្បទេសវិញ ចម្រើនព្រហ្មវិហារ ៤ ដរាបដល់អស់ជីវិត បានជាអ្នកចូលដល់ព្រហ្មលោកហើយ ។ ឯសង្ខបាលនាគរាជ រក្សាឧបោសថដរាបដល់អស់ជីវិត ឯព្រះបាទពារាណសី ក៏ទ្រង់បំពេញបុណ្យមានទានជាដើម ហើយក៏ទៅតាមយថាកម្មរៀងៗខ្លួន ។

ព្រះសាស្ដា ទ្រង់នាំព្រះធម្មទេសនានេះមកសម្ដែងចប់ហើយ ត្រាស់ថា បុរាណកបណ្ឌិតទាំងឡាយ លះនាគសម្បត្តិ រក្សាឧបោសថកម្មយ៉ាងនេះ ហើយទ្រង់ប្រជុំជាតកថា តាបសដែលជាព្រះរាជបិតាក្នុងកាលនោះ បានមកជាកស្សបៈក្នុងកាលឥឡូវនេះ ព្រះបាទពារាណសីក្នុងកាលនោះ បានមកជាអានន្ទ អាឡារតាបសក្នុងកាលនោះ បានមកជាសារីបុត្ត ឯសង្ខបាលនាគរាជក្នុងកាលនោះ គឺតថាគតជាអរហន្តសម្មាសម្ពុទ្ធនេះឯង ។

**អដ្ឋកថា សង្ខបាលជាតក ចប់**

# ចុល្លសុតសោមជាតក

[ ៦៤៨ ] ( ព្រះបាទសុតសោមត្រាស់ថា ) ខ្ញុំប្រាប់អ្នកនិគម មិត្ត អាមាត្យ និងបរិស័ទឲ្យដឹងថា ស្កូវកើតលើក្បាលហើយ ឥឡូវនេះ ខ្ញុំពេញចិត្តនឹងបព្វជ្ជា ។

[ ៦៤៩ ] ( អាមាត្យម្នាក់ក្រាបទូលថា ) ព្រះអង្គទ្រង់ត្រាស់ព្រះឱង្ការមិនចម្រើនដល់ទូលព្រះបង្គំជាខ្ញុំ បពិត្រព្រះសម្មតិទេព ព្រះអង្គហាក់ដូចជាញ៉ាំងកូនសរ ឲ្យប្រហារត្រង់ដើមទ្រូង របស់ទូលព្រះបង្គំជាខ្ញុំ ចុះស្រីស្នំរបស់ព្រះអង្គចំនួន ៧០០ នាក់ ស្រីស្នំរបស់ព្រះអង្គទាំងនោះ នឹងទៅជាដូចម្តេច ។

[ ៦៥០ ] ( ព្រះរាជា... ) ស្រីស្នំក្មេងៗទាំងនេះ នឹងប្រាកដ ( តាមអំពើរបស់ខ្លួនៗ ) ឬក៏ស្រីស្នំទាំងនោះ នឹងទៅរកស្តេចដទៃ ឯខ្ញុំប្រាថ្នាឋានសួគ៌ ព្រោះហេតុនោះ ខ្ញុំនឹងបួស ។

[ ៦៥១ ] ( ព្រះវររាជមាតា... ) នែសុតសោម ខ្ញុំបានអ្នកដោយកម្រណាស់ នែព្រះសម្មតិទេព ព្រោះខ្ញុំជាមាតារបស់អ្នក កាលខ្ញុំកំពុងយំសោក អ្នកឥតមានសេចក្តីអាឡោះអាល័យ ( ចេញទៅ ) បួស ។ នែសុតសោម ខ្ញុំបានអ្នកដោយកម្រណាស់ នែព្រះសម្មតិទេព ខ្ញុំបានប្រសូតអ្នកមក កាលខ្ញុំកំពុងយំសោក អ្នកឥតមានសេចក្តីអាឡោះអាល័យ ( ចេញទៅ ) បួស ។

[ ៦៥២ ] ( ព្រះវររាជបិតា... ) នែសុតសោម នេះជាទំនៀមឈ្មោះអ្វី បព្វជ្ជាឈ្មោះអ្វី នែព្រះសម្មតិទេព ព្រោះអ្នកជាកូនរបស់យើង លះបង់នូវយើងដែលជាមនុស្សចាស់ជរា ឥតអាឡោះអាល័យសោះ ( ចេញទៅ ) បួស ។

[ ៦៥៣ ] បុត្តនិងធីតា របស់អ្នកមានច្រើន ហើយនៅក្មេងមិនទាន់ដល់នូវវ័យ មានពាក្យពីរោះ យើងយល់ថា បុត្តនិងធីតាទាំងនោះ កាលមិនឃើញអ្នក នឹងដល់នូវសេចក្តីទុក្ខ ។

[ ៦៥៤ ] ( ព្រះរាជា... ) ការតាំងនៅអស់កាលយូរ ហើយព្រាត់ប្រាសចាកបុត្តនិងធីតារបស់ខ្ញុំទាំងនុ៎ះ ដែលនៅក្មេង មិនទាន់ដល់នូវវ័យ មានពាក្យពីរោះផង ចាកសន្ធារទាំងពួងផង ចាកព្រះអង្គផង ( ជាសភាវៈទៀង ) ។

[ ៦៥៥ ] ( ស្រីស្នំទាំង ៧០០ នាក់... ) ព្រះហឫទ័យរបស់ព្រះអង្គកាត់ដាច់ហើយឬ ឬថាមិនមានសេចក្តីករុណាចំពោះពួកយើងទាំងឡាយទេ បពិត្រព្រះសម្មតិទេព ព្រះអង្គ ( លះបង់ ) ពួកយើងដែលកំពុងកន្ទក់កន្ទេញ ព្រះអង្គឥតមានសេចក្តីអាឡោះអាល័យ ( ចេញទៅ ) បួស ។

[ ៦៥៦ ] ( ព្រះរាជា... ) ហឫទ័យរបស់យើងមិនបានកាត់ ទាំងសេចក្តីករុណារបស់យើងក៏នៅមានក្នុងពួកនាង តែយើងប្រាថ្នានូវឋានសួគ៌ ព្រោះហេតុនោះ បានជាយើងនឹងបួស ។

[ ៦៥៧ ] ( អគ្គមហេសី... ) បពិត្រព្រះអង្គ ទ្រង់ព្រះនាមសុតសោម ( ទីអគ្គមហេសី ) ឈ្មោះថា ខ្ញុំម្ចាស់បានដោយកម្រ ខ្ញុំម្ចាស់ជាអគ្គមហេសីរបស់ព្រះអង្គ បពិត្រព្រះសម្មតិទេព កាលខ្ញុំម្ចាស់កំពុងតែយំសោក ព្រះអង្គឥតមានសេចក្តីអាឡោះអាល័យ ( ចេញទៅ ) បួស ។ បពិត្រព្រះអង្គទ្រង់ព្រះនាមសុតសោម ( ទីអគ្គមហេសី ) ឈ្មោះថា ខ្ញុំម្ចាស់បានដោយ

កម្រ ខ្ញុំម្ចាស់ជាអគ្គមហេសីរបស់ព្រះអង្គ បពិត្រព្រះសម្មតិទេព ព្រះអង្គ ( លះបង់ ) នូវបដិសន្ធិក្នុងផ្ទៃរបស់ខ្ញុំម្ចាស់ ឥតមានសេចក្តីអាឡោះអាល័យ ( ចេញទៅ ) បួស ។ គភ៌ដែលតាំងនៅក្នុងផ្ទៃរបស់ខ្ញុំម្ចាស់ចាស់ ហើយ ( សូមព្រះអង្គរង់ចាំ ) ទម្រាំខ្ញុំម្ចាស់ប្រសូតគភ៌នោះសិន កុំឲ្យខ្ញុំម្ចាស់ជាស្ត្រីមេម៉ាយម្នាក់ឯង បានឃើញសេចក្តីទុក្ខក្នុងកាលជាខាងក្រោយឡើយ ។

[ ៦៥៨ ] ( ព្រះរាជា... ) គភ៌ដែលតាំងនៅក្នុងផ្ទៃរបស់នាងចាស់ហើយណ្ហើយ នាងចូរប្រសូតបុត្តដែលមានសម្បុរមិនថោកទាប ( ដោយសួស្តី ) យើងនឹងលះបង់បុត្ត ហើយ ( ចេញទៅ ) បួស ។

[ ៦៥៩ ] ម្នាលនាងចន្ទាទេវី មានព្រះនេត្តស្មើ ដោយផ្កាកណ្ណិការក្នុំ នាងកុំយំ កុំសោកឡើយ ចូរឡើងកាន់ប្រាសាទដ៏ប្រសើរវិញចុះ យើងមិនមានសេចក្តីអាឡោះអាល័យទេ នឹងចេញទៅ ( បួស ) ។

[ ៦៦០ ] ( ព្រះរាជបុត្តច្បង... ) បពិត្រព្រះមាតា បុគ្គលណាធ្វើឲ្យព្រះមាតាទ្រង់ព្រះក្រោធ ព្រះមាតាទ្រង់ព្រះកន្សែងផង ទ្រង់សម្លក់ចំពោះខ្ញុំយ៉ាងខ្លាំងផង តើព្រោះហេតុអ្វី បណ្តាញាតិដែលកំពុងរមិលមើល ខ្ញុំសម្លាប់ញាតិណាដែលជាមនុស្សដែលគេមិនគួរសម្លាប់ ។

[ ៦៦១ ] ( ព្រះរាជមាតា... ) ម្នាលកូន បុគ្គលណាជាអ្នកឈ្នះសង្គ្រាម ញុំាងអញឲ្យក្រោធ បុគ្គលនោះ កូនឯងមិនអាចសម្លាប់បានទេ ម្នាលកូន ព្រះរាជបិតារបស់កូនឯង បានត្រាស់នឹងម្តាយថា យើងមិនមានសេចក្តីអាឡោះអាល័យទេ នឹងទៅ ( បួស ) ។

[ ៦៦២ ] ( ព្រះរាជឱរសច្បង... ) ក្នុងកាលមុន ខ្ញុំទៅកាន់សួនឱទ្យាន ដោយរថ បានច្បាំងនឹងដំរីចុះប្រេងទាំងឡាយ កាលបើព្រះបិតា ទ្រង់ព្រះនាម សុតសោម ទ្រង់ព្រះផ្នួសហើយ ឥឡូវនេះ ខ្ញុំនឹងធ្វើដូចម្តេចហ្ន៎ ។

[ ៦៦៣ ] ( ព្រះរាជឱរសប្អូន... ) កាលព្រះមាតារបស់ទូលព្រះបង្គំជាខ្ញុំ កំពុងទ្រង់ព្រះកន្សែងផង កាលព្រះជេដ្ឋកាតា នៃទូលព្រះបង្គំជាខ្ញុំ មិនប្រាថ្នា ( នឹងឲ្យព្រះអង្គ ទ្រង់ព្រះផ្នួស ) ផង ទូលព្រះបង្គំជាខ្ញុំ នឹងចាប់ព្រះហស្តរបស់ព្រះអង្គទុក កាលបើពួកទូលព្រះបង្គំជាខ្ញុំ មិនចង់ឲ្យព្រះអង្គទ្រង់ផ្នួស ព្រះអង្គនឹងយាងទៅមិនបានទេ ។

[ ៦៦៤ ] ( ព្រះបិតា... ) ម្នាលមេនំ នាងចូរក្រោកឡើង ( ចូរកាន់យកនូវកែវមណីនេះ ) ហើយញ៉ាំងកុមារនេះ ឲ្យត្រេកអរក្នុងទីដទៃចុះ កាលបើអញកំពុងប្រាថ្នាឋានសួគ៌ កុំឲ្យកុមារនេះ ធ្វើនូវសេចក្តីអន្តរាយដល់អញឡើយ ។

[ ៦៦៥ ] ( ស្រីមេនំ... ) ណ្ហើយចុះ អញនឹងថ្វាយនូវកែវមណី មានរស្មីល្អនេះទៅវិញចុះ កែវមណីនេះ មានប្រយោជន៍អ្វីដល់អញ កាលបើព្រះរាជាទ្រង់ព្រះនាមសុតសោម ទ្រង់ព្រះផ្នួសហើយ អញនឹងធ្វើកែវមណីនេះ ដូចម្តេច ។

[ ៦៦៦ ] ( មហាសេនគុត្ត... ) បពិត្រព្រះសម្មតិទេព ឃ្លាំងតូចរបស់ព្រះអង្គពេញ ឃ្លាំងធំរបស់ព្រះអង្គពេញ ទាំងផែនដី ព្រះអង្គក៏ទ្រង់ឈ្នះហើយ សូមព្រះអង្គទ្រង់រីករាយ សូមព្រះអង្គកុំទ្រង់ព្រះផ្នួស ។

[ ៦៦៧ ] ( ព្រះរាជា... ) ឃ្លាំងតូចរបស់ខ្ញុំក៏ពេញឃ្លាំងធំរបស់ខ្ញុំ ក៏ពេញទាំងផែនដី ខ្ញុំក៏បានឈ្នះហើយ ខ្ញុំនឹងលះបង់នូវទ្រព្យទាំងនោះ ហើយទៅបួស ។

[ ៦៦៨ ] ( កុលពន្ធនសេដ្ឋី... ) បពិត្រព្រះសម្មតិទេព ទ្រព្យរបស់ទូលព្រះបង្គំជាខ្ញុំមានច្រើន ទូលព្រះបង្គំជាខ្ញុំមិនអាចនឹងរាប់បាន ទូលព្រះបង្គំជាខ្ញុំនឹងថ្វាយទ្រព្យទាំងនោះ ដល់ព្រះអង្គ សូមព្រះអង្គទ្រង់ត្រេកអរ សូមកុំទ្រង់ព្រះផ្នួស ។

[ ៦៦៩ ] ( ព្រះរាជា... ) ម្នាលកុលពន្ធនវឌ្ឍនៈ ខ្ញុំដឹងថា ទ្រព្យរបស់អ្នកមានច្រើន អ្នកបូជាខ្ញុំហើយ ក៏ប៉ុន្តែខ្ញុំប្រាថ្នាឋានសួគ៌ ហេតុនោះខ្ញុំនឹងបួស ។

[ ៦៧០ ] ម្នាលសោមទត្ត ខ្ញុំជាអ្នកអផ្សុកយ៉ាងខ្លាំង សេចក្ដីមិនត្រេកអរ ( ក្នុងការគ្រប់គ្រងផ្ទះ ) មកគ្របសង្កត់ខ្ញុំហើយ សេចក្ដីអន្តរាយមានច្រើនណាស់ ខ្ញុំនឹងបួសក្នុងថ្ងៃនេះមិនខាន ។

[ ៦៧១ ] ( ព្រះកនិដ្ឋភាតាព្រះនាមសោមទត្ត... ) បពិត្រព្រះរាជា ទ្រង់ព្រះនាមសុតសោម បព្វជ្ជាកម្មនេះ ព្រះអង្គទ្រង់ពេញព្រះទ័យហើយឥឡូវនេះ សូមព្រះអង្គបួសក្នុងថ្ងៃនេះចុះ ទាំងទូលព្រះបង្គំជាខ្ញុំសោតទៀត ក៏នឹងបួសដែរ ( ព្រោះ ) ទូលព្រះបង្គំជាខ្ញុំ បើវៀរចាកព្រះអង្គហើយ នឹងមិនអាចឋិតនៅបានទេ ។

[ ៦៧២ ] ( ព្រះរាជា... ) អ្នកឯងមិនអាចនឹងបួសបានទេ ព្រោះថា

បុគ្គលទីមួយក្នុងនគរ ឬក្នុងជនបទនឹងមិននាំគ្នាចម្អិនអាហារឡើយ ។

[ ៦៧៣ ] ( មហាជន... ) កាលបើព្រះបាទសុតសោមទ្រង់ព្រះផ្នួសហើយ តើឥឡូវនេះ ពួកយើងនឹងធ្វើដូចម្តេចហ្ន៎ ។

[ ៦៧៤ ] ( ព្រះរាជា... ) យើងសំគាល់ថា ជីវិតនេះរមែងរីងស្ងួតទៅ ដូចទឹកដ៏តិច ( ដែលគេដាក់ ) ក្នុងពាងផ្ទះ កាលបើជីវិតតិចយ៉ាងនេះ កាលនេះ មិនមែនជាកាលគួរប្រមាទឡើយ ។ យើងសំគាល់ថា ជីវិតនេះរមែងរីងស្ងួតទៅ ដូចទឹកដ៏តិចក្នុងពាងផ្ទះ កាលជីវិតតិចយ៉ាងនេះ គោតតែជនពាលទាំងឡាយប្រមាទ ។ ជនពាលទាំងនោះ រមែងញ៉ាំងនរក តិរច្ឆានកំណើត និងបេតវិស័យឲ្យចម្រើន ជាអ្នកជាប់ដោយគ្រឿងចងគឺតណ្ហា រមែងញ៉ាំងអសុរកាយឲ្យចម្រើន ។

[ ៦៧៥ ] ( មហាជន... ) គំនរធូលី ហុយឡើងក្នុងទីជិតបុប្ផកប្រាសាទ ពួកយើងសំគាល់គំនរធូលីនោះថា ជាព្រះកេសា ដែលព្រះធម្មរាជ ព្រះអង្គមានយសរបស់យើង ទ្រង់កាត់ហើយ ។

[ ៦៧៦ ] ព្រះរាជាដែលពួកស្រីស្នំហែហមហើយ យាងទៅក្នុងប្រាសាទណា ប្រាសាទនេះ របស់ព្រះរាជានោះ ដ៏ដេរដាសដោយផ្កាមាស និងកម្រងផ្កាផ្សេងៗ ។ ព្រះរាជាដែលពួកព្រះញាតិហែហមហើយ យាងទៅក្នុងប្រាសាទណា ប្រាសាទនេះរបស់ព្រះរាជានោះ ដ៏ដេរដាសដោយផ្កាមាស និងកម្រងផ្កាផ្សេងៗ ។ ព្រះរាជាដែលពួកស្រីស្នំហែហមហើយ ទ្រង់យាងទៅក្នុងបន្ទប់សម្រាប់ផ្ទំណា បន្ទប់សម្រាប់ផ្ទំនេះ របស់ព្រះរាជានោះ ដ៏ដេរ

ជាសជោយផ្កាមាស និងកម្រងផ្កាផ្សេងៗ ។ ព្រះរាជា ដែលពួកញាតិហែហម ហើយ ទ្រង់យានទៅក្នុងបន្ទប់សម្រាប់ផ្ទំណា បន្ទប់សម្រាប់ផ្ទំនេះ របស់ព្រះរាជានោះ ដ៏ជេរជាសជោយផ្កាមាស និងកម្រងផ្កាផ្សេងៗ ។ ព្រះរាជាដែលស្រីស្នំហែហមហើយ ទ្រង់យានទៅក្នុងទីព្រៃឈើអសោកណា ទីព្រៃឈើអសោកនេះ របស់ព្រះរាជានោះ មានផ្ការីកល្អសព្វៗកាល គួរជាទីរីករាយចិត្ត ។ ព្រះរាជាដែលពួកញាតិហែហមហើយ ទ្រង់យានទៅក្នុងទីព្រៃឈើអសោកណា ទីព្រៃឈើអសោកនេះរបស់ព្រះរាជានោះ មានផ្ការីកល្អសព្វៗកាល គួរជាទីរីករាយចិត្ត ។ ព្រះរាជាដែលពួកស្រីស្នំហែហមហើយ ទ្រង់យានទៅក្នុងឱទ្យានណា ឱទ្យាននេះរបស់ព្រះរាជានោះ មានផ្ការីកល្អសព្វៗកាល គួរជាទីរីករាយចិត្ត ។ ព្រះរាជាដែលពួកញាតិហែហមហើយ ទ្រង់យានទៅក្នុងឱទ្យានណា ឱទ្យាននេះរបស់ព្រះរាជានោះ មានផ្ការីកល្អសព្វៗកាល គួរជាទីរីករាយចិត្ត ។ ព្រះរាជា ដែលពួកស្រីស្នំហែហមហើយ ទ្រង់យានទៅក្នុងព្រៃឈើកណិការណា ព្រៃឈើកណិការនេះរបស់ព្រះរាជានោះ មានផ្ការីកល្អសព្វៗកាល គួរជាទីរីករាយចិត្ត ។ ព្រះរាជាដែលពួកញាតិហែហមហើយ ទ្រង់យានទៅក្នុងព្រៃឈើកណិការណា ព្រៃឈើកណិការនេះ របស់ព្រះរាជានោះ មានផ្ការីកល្អសព្វៗកាល គួរជាទីរីករាយចិត្ត ។ ព្រះរាជាដែលពួកស្រីស្នំហែហមហើយ ទ្រង់យានទៅក្នុងព្រៃប្រទៀងណាព្រៃប្រទៀងនេះ របស់ព្រះរាជានោះមានផ្ការីកល្អសព្វ ៗ កាល គួរជាទីរីករាយចិត្ត ។ ព្រះរាជាដែលពួកញាតិហែហមហើយ ទ្រង់

យានទៅក្នុងព្រៃប្រទៀងណា ព្រៃប្រទៀងនេះ របស់ព្រះរាជានោះ មានផ្ការីកល្អសព្វៗកាល គួរជាទីរីករាយចិត្ត ។ ព្រះរាជាដែលពួកស្រីស្នំហែហមហើយ ទ្រង់យានទៅក្នុងព្រៃស្វាយណា ព្រៃស្វាយនេះ របស់ព្រះរាជានោះ មានផ្ការីកល្អសព្វៗកាលគួរជាទីរីករាយចិត្ត ។ ព្រះរាជាដែលពួកញាតិហែហមហើយ ទ្រង់យានទៅក្នុងព្រៃស្វាយណា ព្រៃស្វាយនេះ របស់ព្រះរាជានោះ មានផ្ការីកល្អសព្វៗកាល គួរជាទីរីករាយចិត្ត ។ ព្រះរាជាដែលពួកស្រីស្នំហែហមហើយ ទ្រង់យានទៅក្នុងស្រះបោក្ខរណីណា ស្រះបោក្ខរណីនេះ របស់ព្រះរាជានោះ ដ៏ដេរដាស ( ដោយផ្កាជលជាតនិងផ្កាថលជាត ) ដ៏កុះករដោយពួកអណ្ឌជៈ ( គួរជាទីរីករាយចិត្ត ) ។ ព្រះរាជាដែលពួកញាតិហែហមហើយ ទ្រង់យានទៅក្នុងស្រះបោក្ខរណីណា ស្រះបោក្ខរណីនេះ របស់ព្រះរាជានោះ ដ៏ដេរដាស ( ដោយផ្កាជលជាតនិងថលជាត ) ដ៏កុះករដោយពួកអណ្ឌជៈ គួរជាទីរីករាយចិត្ត ។

[ ៦៧៧ ] ព្រះរាជាទ្រង់ព្រះនាមសុតសោម បានលះបង់រាជសម្បត្តិនេះហើយ ក៏ទ្រង់ព្រះផ្នួស ទ្រង់ព្រះពស្ត្រកាសាយៈ ស្តេចយានទៅតែមួយព្រះអង្គឯង ដូចជាដំរីត្រាច់ទៅតែម្នាក់ឯង ។

[ ៦៧៨ ] ( ព្រះរាជា... ) អ្នកទាំងឡាយកុំរឭកការលេងដោយសេចក្តីត្រេកអរ និងការសើចក្នុងកាលមុនឡើយ កាមទាំងឡាយ កុំបៀតបៀនពួកអ្នកឡើយ នគរឈ្មោះសុទស្សនៈ ជាទីគួររីករាយ ( អ្នកទាំងឡាយកុំរឭកឡើយ ) ។ អ្នកទាំងឡាយ ចូរចម្រើនមេត្តាចិត្ត រកប្រមាណមិនបាន

ទាំងថ្ងៃទាំងយប់ ទើបពួកអ្នកនឹងទៅកាន់ទេពបុរី ដែលជាលំនៅពួកអ្នកមានបុញ្ញកម្ម ។

**ចប់ ចុល្លសុតសោមជាតក ទី ៥ ។**

## ឧទ្ទាននៃចត្តាលីសនិបាតនោះគឺ

និយាយអំពីសេកជាអ្នកប្រាជ្ញឈ្មោះជម្ពុកៈ ១ ពួកព្រះរាជាមានកុណ្ឌល ១ ជាតកនាងអលម្ពុសាជាកញ្ញាដ៏ប្រសើរ ១ នាគរាជមានសិរីឈ្មោះ សង្ខបាល ដ៏ប្រសើរ ១ អរិន្ទមរាជដ៏ប្រសើរព្រះនាមសុតសោម ១ ។

**ចប់ ចត្តាលីសនិបាត ។**

# អដ្ឋកថា

# ចុល្លសុតសោមជាតក

[ ៦៤៨-៦៧៨ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនេក្ខម្មបារមី ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អាមន្តយាមិ និគមំ** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្ន ដូចគ្នានឹងមហានារទកស្សបជាតក ឯរឿងក្នុងអតីតមានដូចតទៅនេះថា

ក្នុងអតីតកាល ក្រុងពារាណសីមានឈ្មោះថា សុទស្សនទនគរ ព្រះរាជាព្រះនាមថា ព្រហ្មទត្ត ប្រថាប់នៅក្នុងនគរនោះ ។ ព្រះពោធិសត្វបដិសន្ធិក្នុងព្រះឧទរនៃអគ្គមហេសីរបស់ព្រះរាជាអង្គនោះ ។ ១០ ខែបានកន្លងផុតទៅ ព្រះពោធិសត្វក៏ប្រសូតចាកព្រះឧទរព្រះមាតា ព្រះភក្ត្ររបស់ព្រះរាជកុមារនោះ មានសិរី ដូចព្រះចន្ទពេញវង់ ដោយហេតុនោះ ទើបព្រះជនកជននីថ្វាយព្រះនាមថា សោមកុមារ ។ ព្រះរាជកុមារនោះ លុះដឹងក្តីហើយ ជាអ្នកដាក់ចិត្តក្នុងសុតៈ មានការស្តាប់ជាប្រក្រតី ដោយហេតុនោះ ទើបអ្នកនគរថ្វាយព្រះនាមថា សុតសោម ។ កាលចម្រើនវ័យហើយ ព្រះរាជកុមារយាងទៅរៀនសិល្បសាស្ត្រក្នុងនគរតក្កសិលា យាងត្រឡប់មក ក៏បានស្វេតច្ឆត្ររបស់ព្រះជនក សោយរាជសម្បត្តិប្រកបដោយធម៌ មានព្រះឥស្សរិយយសធំក្រៃលែង ។ ទ្រង់មានស្រីស្នំ ១ ម៉ឺន ៦ ពាន់នាក់ មានព្រះនាងចន្ទាទេវីជាប្រធាន ។ ក្នុងកាលតមក ព្រះរាជាចម្រើនដោយព្រះរាជឱរសនិងព្រះរាជធីតារហូតដល់ទ្រង់មិនត្រេកអរដោយឃរាវាសវិស័យ មានបំណង

យានទៅកាន់ព្រៃទ្រង់ព្រះផ្នួស ។ ថ្ងៃមួយទើបហៅនាយកូសាមាលាមកត្រាស់ថា នែបា កាលណាបាឃើញសក់ត្រង់ក្បាលរបស់អញស្កូវហើយ ឯងគប្បីប្រាប់ដល់អញក្នុងកាលនោះ ។ កូសាមាលា ក៏ទទួលព្រះរាជតម្រាស់របស់ព្រះរាជា ។ ក្នុងកាលតមក ឃើញសក់ស្កូវ ទើបទូលឲ្យទ្រង់ជ្រាប ព្រះរាជាត្រាស់ថា នែបា បើដូច្នោះ ចូរបាជកនូវសក់ស្កូវនោះមកដាក់ក្នុងដៃយើង ទើបយកចន្ទាសដែកដកព្រះកេសាដាក់ក្នុងព្រះហស្ត ។ មហាសត្វទតព្រះកេសាស្កូវនោះ ក៏សង្វេគថា សរីរៈរបស់អញត្រូវជរាគ្របសង្កត់ហើយ ទើបទ្រង់កាន់យកសរសៃសក់ស្កូវនោះ ចុះអំពីប្រាសាទប្រថាប់គង់លើរាជបល្ល័ង្កដែលរៀបចំទុក ក្នុងទីគាល់របស់មហាជន រួចឲ្យហៅអាមាត្យប្រមាណ ១ ម៉ឺន ៨ ពាន់ មានសេនាបតីជាប្រធាន និងព្រាហ្មណ៍ ៦ ម៉ឺននាក់ មានបុរោហិតជាប្រធាន អ្នកដែននិងអ្នកនិគមដទៃៗ មកគាល់ជាច្រើន ហើយត្រាស់ថា សក់ស្កូវកើតហើយត្រង់ក្បាលរបស់យើង យើងជាមនុស្សចាស់ជរា អ្នកទាំងឡាយចូរដឹងភាពដែលយើងចេញបព្វជ្ជា ដូច្នេះហើយ ទើបត្រាស់គាថាទីមួយថា

ខ្ញុំប្រាប់អ្នកនិគម មិត្ត អាមាត្យ និងបរិស័ទឲ្យដឹងថា ស្កូវកើត
លើក្បាលហើយ ឥឡូវនេះ ខ្ញុំពេញចិត្តនឹងបព្វជ្ជា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាមន្តយាមិ** សេចក្តីថា យើងសូមប្រកាសឲ្យអ្នកទាំងឡាយដឹង ។ បទថា **រោចេហំ** សេចក្តីថា យើងពេញចិត្ត នែអ្នកដ៏ចម្រើនទាំងឡាយ អ្នកទាំងឡាយចូរដឹងថា យើងនឹងបព្វជ្ជា ។

បណ្ដាជនទាំងឡាយ ដែលបានស្ដាប់ព្រះរាជតម្រាស់របស់ព្រះរាជានោះ អាមាត្យម្នាក់ ជាអ្នកអង់អាចក្លៀវក្លា ក្រាបទូលគាថាដោយសេចក្ដីថា

ព្រះអង្គទ្រង់ត្រាស់ ព្រះឱង្ការមិនចម្រើនដល់ទូលព្រះបង្គំជាខ្ញុំ
បពិត្រព្រះសម្មតិទេព ព្រះអង្គហាក់ដូចជាញ៉ាំងកូនសរ ឲ្យ
ប្រហារត្រង់ដើមទ្រូងរបស់ទូលព្រះបង្គំជាខ្ញុំ ចុះស្រីស្នំរបស់
ព្រះអង្គចំនួន ៧០០ នាក់ ស្រីស្នំរបស់ព្រះអង្គទាំងនោះ នឹង
ទៅជាដូចម្ដេច ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អភុំ** សេចក្ដីថា វត្ថុមិនជាសេចក្ដីចម្រើន ។ បទថា **ឧរសិ កប្បេសិ** សេចក្ដីថា ទ្រង់ញ៉ាំងសស្ត្រាដែលលាងហើយដោយល្អ ឲ្យញាប់ញ័រក្បែរទ្រូងនៃទូលបង្គំ ។ បទថា **សត្តសតា** នេះ អាមាត្យនោះ ពោលសំដៅដល់ខត្តិយកញ្ញាដែលមានជាតិស្មើគ្នា ។ បទថា **កថំ នុ តេ តា ភវិស្សន្តិ** សេចក្ដីថា ព្រះរាជជាយារបស់ទ្រង់ទាំងនោះ បើទ្រង់បួសហើយ នឹងទៅជាអនាថា មិនមានទីពឹង នឹងទៅបានដូចម្ដេច ការដែលទ្រង់ធ្វើនាងទាំងនោះឲ្យមិនមានទីពឹង ហើយទ្រង់ព្រះផ្នួសនេះ មិនសមគួរឡើយ ។ គ្រានោះ ព្រះមហាសត្វត្រាស់គាថាទី ៣ ថា

ស្រីស្នំក្មេងៗទាំងនេះ នឹងប្រាកដ ( តាមអំពើរបស់ខ្លួនៗ )
ឬក៏ស្រីស្នំទាំងនោះ នឹងទៅរកស្ដេចដទៃ ឯខ្ញុំប្រាថ្នាឋានសួគ៌
ព្រោះហេតុនោះ ខ្ញុំនឹងបួស ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បញ្ញាយិហិន្តិ** សេចក្ដីថា នារីទាំងនេះ នឹង

ប្រាកដដោយកិច្ចរៀងៗខ្លួន យើងជាអ្វីរបស់ស្រីទាំងនេះ ស្រីទាំងនេះ សុទ្ធតែក្មេង ស្តេចដទៃៗ ក៏គង់មាន នារីទាំងនេះនឹងទៅពឹងព្រះរាជាដទៃៗនោះបាន ។

អាមាត្យជាដើម កាលមិនអាចជំទាស់ព្រះពោធិសត្វបាន ទើបនាំគ្នាទៅកាន់សម្នាក់របស់ព្រះរាជមាតានៃព្រះពោធិសត្វ ទូលសេចក្តីនោះឲ្យទ្រង់ជ្រាប ព្រះរាជជននីប្រញាប់យាងមកដោយរួសរាន់ ត្រាស់ថា នៃកូនសម្លាញ់ បានឮថា បាបំណងនឹងបួសពិតឬ ដូច្នេះហើយ ទើបត្រាស់គាថា ២ ថា

នៃសុតសោម ខ្ញុំបានអ្នកដោយកម្រណាស់ នៃព្រះសម្មតិទេព ព្រោះខ្ញុំជាមាតារបស់អ្នក កាលខ្ញុំកំពុងយំសោក អ្នកឥតមានសេចក្តីអាឡោះអាល័យ ( ចេញទៅ ) បួស ។ នៃសុតសោម ខ្ញុំបានអ្នកដោយកម្រណាស់ នៃព្រះសម្មតិទេព ខ្ញុំបានប្រសូតអ្នកមក កាលខ្ញុំកំពុងយំសោក អ្នកឥតមានសេចក្តីអាឡោះអាល័យ ( ចេញទៅ ) បួស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទុល្លទ្ធំ** សេចក្តីថា អ្នកឈ្មោះថា ជាបុគ្គលបានមកដោយលំបាក ព្រោះកាលមាតាបាន ក៏ត្រូវឆ្លងកាត់សេចក្តីកំបាក ទើបបានអ្នកជាបុត្តមក ។ បទថា **យំ មេ** សេចក្តីថា កាលមាតាយំសោក ដោយប្រការផ្សេងៗ អ្នកនៅតែប្រាថ្នានឹងបួសឲ្យខាងតែបាន ដោយហេតុណា ហេតុនោះ ការបានបុត្តដូចអ្នក ទើបឈ្មោះថា មាតាបានមកដោយលំបាក ។

ព្រះពោធិសត្វមិនបានត្រាស់អ្វីជាមួយព្រះមាតា ដែលទ្រង់បរិទេវនាការ

យ៉ាងនេះ ។ ព្រះរាជជននីទ្រង់ព្រះកន្សែង ប្រថាប់ឈរនាចំណែកម្ខាង យំសោកនោះឯង ។ សម័យនោះ មហាជនក៏នាំគ្នាទៅក្រាបទូលដល់ព្រះរាជបិតារបស់ព្រះពោធិសត្វ ។ ព្រះរាជបិតាយាងមកហើយ ត្រាស់គាថា ដូចគ្នាថា

នែសុតសោម នេះជាទំនៀមឈ្មោះអ្វី បព្វជ្ជាឈ្មោះអ្វី នែព្រះសម្មតិទេព ព្រោះអ្នកជាកូនរបស់យើង លះបង់នូវយើងដែលជាមនុស្សចាស់ជរា ឥតអាឡោះអាល័យសោះ ( ចេញទៅ ) បួស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យំ ឆោ អម្ហេ** សេចក្តីថា ឯងជាកូនរបស់មាតាបិតា ហេតុអ្វី មិនបដិបត្តិមាតាបិតាដែលចាស់ជរា ក្នុងកាលគួរបដិបត្តិបោះបង់មិនបានអាល័យចេញបួស ដូចគ្នានឹងប្រមៀលថ្មទម្លាក់ជ្រោះ ដូច្នោះដោយហេតុនោះ បិតាសួរឯង ធម៌របស់ឯងនេះ ឈ្មោះធម៌អ្វី ។

ព្រះមហាសត្វទ្រង់ស្តាប់ដូច្នោះហើយ ក៏នៅស្ងៀម ។ លំដាប់នោះ ព្រះរាជបិតាត្រាស់និងព្រះមហាសត្វថា នែសុតសោមកូនសំឡាញ់ បើឯង មិនមានសេចក្តីស្នេហាអាឡោះអាល័យក្នុងមាតាបិតាហើយ កូនប្រុស កូនស្រីរបស់ឯង នៅតូចមានច្រើន មិនអាចប្រាត់ប្រាសចាកបាបាន ក្នុងកាលក្មេងទាំងនោះធំហើយ សឹមបាបួសចុះ ហើយបានត្រាស់គាថាទី ៧ ថា

បុត្តនិងធីតារបស់អ្នកមានច្រើន ហើយនៅក្មេងមិនទាន់ដល់នូវវ័យ មានពាក្យពីរោះ យើងយល់ថា បុត្តនិងធីតាទាំងនោះ

កាលមិនឃើញអ្នក នឹងដល់នូវសេចក្តីទុក្ខ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មញ្ញ** សេចក្តីថា ចរចាគួរជាទីស្រឡាញ់ ។ បទថា **និគច្ឆន្តិ** សេចក្តីថា បិតាសម្គាល់ថា កុមារទាំងនោះនឹងនាំគ្នាដល់នូវសេចក្តីលំបាក គឺត្រឡប់បានទុក្ខផ្លូវកាយនិងផ្លូវចិត្ត ។

ព្រះមហាសត្វទ្រង់ស្តាប់ព្រះតម្រាស់នោះហើយ ត្រាស់គាថានេះថា

ការតាំងនៅអស់កាលយូរ ហើយព្រាត់ប្រាសចាកបុត្តនិងធីតា
របស់ខ្ញុំទាំងនុ៎ះ ដែលនៅក្មេងមិនទាន់ដល់នូវវ័យ មានពាក្យ
ពីរោះផង ចាកសង្ខារទាំងពួងផង ចាកព្រះអង្គផង ( ជាសភាវៈ
ទៀង ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សព្វេហិបិ តុម្ហេហិ** សេចក្តីថា បពិត្រព្រះអង្គដ៏ចម្រើន មិនមែនទូលព្រះបង្គំនឹងព្រាត់ប្រាសឱរសនិងធីតាប៉ុណ្ណោះទេ ដោយពិតនោះ យើងទាំង ២ និងសង្ខារដទៃៗ ទោះបីតាំងនៅបានយូរ គឺតាំងនៅអស់កាលយូរ ក៏ត្រូវតែព្រាត់ប្រាសចាកគ្នានឹងគ្នា គឺផ្សេងៗគ្នា ព្រោះក្នុងលោកសន្និវាសទាំងមូល សង្ខារឯណាមួយ ឈ្មោះថាទៀង មិនមាន ។

ព្រះមហាសត្វសម្តែងធម្មកថាដល់ព្រះបិតាយ៉ាងនេះ សម្តេចព្រះរាជបិតាទ្រង់ស្តាប់ធម្មកថារបស់ព្រះពោធិសត្វហើយ ក៏ទ្រង់តុណ្ហីភាព គ្រានោះអាមាត្យទាំងឡាយ ក៏ប្រាប់ដល់ព្រះជាយាជាទីស្រឡាញ់ទាំង ៧០០ របស់ព្រះមហាសត្វ ព្រះរាជជាយាទាំងនោះចុះពីប្រាសាទ ទៅកាន់សម្នាក់របស់ព្រះមហាសត្វ ចាប់ត្រង់កព្រះបាទបរិទេវនាការថា

ព្រះហឫទ័យរបស់ព្រះអង្គកាត់ដាច់ហើយឬ ឬថាមិនមាន
សេចក្តីករុណា ចំពោះពួកយើងទាំងឡាយទេ បពិត្រព្រះសម្មតិ
ទេព ព្រះអង្គ ( លះបង់ ) ពួកយើងដែលកំពុងកន្ទក់កន្ទេញ
ព្រះអង្គ ឥតមានសេចក្តីអាឡោះអាល័យ (ចេញទៅ )
បួស ដូច្នេះ ។

គាថានោះមានអធិប្បាយដូច្នេះថា បពិត្រព្រះសុតសោមដ៏ជាព្រះស្វាមី ព្រះហឫទ័យក្នុងពួកខ្ញុំម្ចាស់របស់ទ្រង់ ដែលធ្វើពួកខ្ញុំម្ចាស់ឲ្យមេម៉ាយ យាងទៅបួស ទ្រង់កាត់ហើយឬហ្ន៎ ព្រោះមិនមានសេចក្តីស្នេហាត្រឹមបន្តិចបន្តួច ឬឈ្មោះថា ភាពករុណារបស់ទ្រង់មិនមានក្នុងពួកខ្ញុំ ព្រោះមិនមានករុណា ទើបទ្រង់លះបង់នូវពួកខ្ញុំដែលកំពុងយំសោកយ៉ាងនេះ ទៅបព្វជ្ជា ។

ព្រះមហាសត្វ ទ្រង់ស្តាប់សំឡេងបរិទេវនាការរបស់ពួកបាទបរិចារិកាទាំងនោះ ដែលយំបម្រះនទៀលទៀបបាទមូល ហើយត្រាស់គាថាជាលំដាប់តទៅថា

ហឫទ័យរបស់យើងមិនបានកាត់ ទាំងសេចក្តីករុណារបស់
យើងក៏នៅមានក្នុងពួកនាង តែយើងប្រាថ្នានូវឋានសួគ៌ ព្រោះ
ហេតុនោះ បានជាយើងនឹងបួស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សគ្គញ្ច** សេចក្តីថា ព្រះមហាសត្វ ទ្រង់លួងលោមព្រះជាយាយ៉ាងនោះថា យើងប្រាថ្នាស្ថានសួគ៌ ម្យ៉ាងទៀត ឈ្មោះថា បព្វជ្ជានេះ ពុទ្ធាទិបណ្ឌិតសរសើរហើយ ព្រោះហេតុនោះ ទើបយើង

បួស នាងទាំងឡាយកុំទោមនស្សឡើយ ។

លំដាប់នោះ អាមាត្យទាំងឡាយ ទើបក្រាបទូលព្រះមហេសីរបស់ព្រះពោធិសត្វឲ្យព្រះនាងជ្រាប ព្រះអគ្គមហេសីនោះ មានភារៈធ្ងន់ ទ្រង់ព្រះឧទរបរិបូណ៌ យាងមកថ្វាយបង្គំព្រះមហាសត្វ ប្រថាប់ឈរក្នុងចំណែកម្ខាង បានត្រាស់ ៣ គាថាដោយសេចក្ដីថា

បពិត្រព្រះអង្គ ទ្រង់ព្រះនាម សុតសោម ( ទីអគ្គមហេសី )
ឈ្មោះថា ខ្ញុំម្ចាស់បានដោយកម្រ ខ្ញុំម្ចាស់ជាអគ្គមហេសីរបស់
ព្រះអង្គ បពិត្រព្រះសម្មតិទេព កាលខ្ញុំម្ចាស់កំពុងតែយំសោក
ព្រះអង្គឥតមានសេចក្ដីអាឡោះអាល័យ ( ចេញទៅ ) បួស ។
បពិត្រព្រះអង្គ ទ្រង់ព្រះនាមសុតសោម ( ទីអគ្គមហេសី )
ឈ្មោះថា ខ្ញុំម្ចាស់បានដោយកម្រ ខ្ញុំម្ចាស់ជាអគ្គមហេសីរបស់
ព្រះអង្គ បពិត្រព្រះសម្មតិទេព ព្រះអង្គ ( លះបង់ ) នូវ
បដិសន្ធិក្នុងផ្ទៃរបស់ខ្ញុំម្ចាស់ ឥតមានសេចក្ដីអាឡោះអាល័យ
( ចេញទៅ ) បួស ។ គភ៌ដែលតាំងនៅក្នុងផ្ទៃរបស់ខ្ញុំម្ចាស់
ចាស់ហើយ ( សូមព្រះអង្គរង់ចាំ ) ទម្រាំខ្ញុំម្ចាស់ប្រសូតគភ៌
នោះសិន កុំឲ្យខ្ញុំម្ចាស់ជាស្ត្រីមេម៉ាយម្នាក់ឯង បានឃើញសេចក្ដី
ទុក្ខ ក្នុងកាលជាខាងក្រោយឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យំ មេ** សេចក្ដីថា ព្រោះហេតុអ្វី កាលខ្ញុំកំពុងយំសោក ទ្រង់មិនអាឡោះអាល័យចេញបួស តំណែងអគ្គមហេសី

ដែលខ្ញុំបានអំពីសម្នាក់ទ្រង់នោះ ខ្ញុំបានមកដោយលំបាក ។ ក្នុងគាថាបន្ទាប់មានអធិប្បាយថា ហេតុអ្វីទ្រង់លះខ្ញុំដែលកំពុងមានផ្ទៃ មិនអាឡោះអាល័យភាពជាអគ្គមហេសីរបស់ទ្រង់ ដែលខ្ញុំបានមកនោះ ខ្ញុំបានមកដោយលំបាក ។ បទថា **យាវ ធំ** សេចក្តីថា សូមទ្រង់បង្អង់សិន ទម្រាំខ្ញុំប្រសូត ។ លំដាប់នោះព្រះមហាសត្វត្រាស់ថា

គភ៌ដែលតាំងនៅក្នុងផ្ទៃរបស់នាងចាស់ហើយ ណ្ហើយ នាងចូរ
ប្រសូតបុត្ត ដែលមានសម្បុរមិនថោកទាប ( ដោយសួស្តី )
យើងនឹងលះបង់បុត្ត ហើយ ( ចេញទៅ ) បួស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បុត្តំ** សេចក្តីថា នៃនាងដ៏ចម្រើន យើងដឹងថា នាងមានគភ៌ចាស់ តែនាងប្រសូតនឹងជាឱរស មិនមែនជាធីតាឡើយ ចូរនាងប្រសូតឱរសដោយសួស្តីចុះ ឯយើងនឹងលះបុត្ត មួយអន្លើដោយនាងហើយបួសនោះឯង ។

ព្រះទេវី ស្តាប់រាជតម្រាស់របស់ព្រះស្វាមីហើយ មិនអាចអត់សង្កត់សេចក្តីសោកបាន ក្រាបទូលថា បពិត្រព្រះអង្គ តាំងអំពីនេះទៅ ឈ្មោះថាសិរីរបស់ខ្ញុំមិនមានឡើយ ហើយយកហត្ថាទាំងទ្វេឱបទ្រូង បង្ហូរទឹកភ្នែកបរិទេវនាការដោយសំឡេងខ្លាំង លំដាប់នោះ កាលព្រះមហាសត្វទ្រង់លួងលោមព្រះនាង ទើបត្រាស់ថា

ម្នាលនាងចន្ទាទេវី មានព្រះនេត្តស្មើដោយផ្កាកណ្ណិការភ្នំ
នាងកុំយំកុំសោកឡើយ ចូរឡើងកាន់ប្រាសាទដ៏ប្រសើរវិញ

ចុះ យើងមិនមានសេចក្ដីអាឡោះអាល័យទេ នឹងចេញទៅ
( បួស ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មា ត្វំ ចន្ទេ រុទិ** សេចក្ដីថា ម្នាលប្អូនស្រីចន្ទាទេវីដ៏ចម្រើន នាងកុំយំសោកប្ដីឡើយ ។ បទថា **វនតិមិរមត្តក្ខិ** បានដល់ មានភ្នែកដូចផ្កាកណ្ណិការភ្នំ តែក្នុងព្រះបាលីលោករចនាទុកថា **កោវិឡារតម្ពក្ខិ** សេចក្ដីថា ព្រះនេត្ររបស់ព្រះនាងចន្ទាទេវីនោះ ក្រហមដូចផ្កាសិរមាន់ ។

ព្រះនាងចន្ទាទេវីស្ដាប់ព្រះរាជតម្រាស់ហើយ មិនអាចតាំងនៅបាន ឡើងកាន់ប្រាសាទប្រថាប់គង់ ទ្រង់ព្រះកន្សែង ។ លំដាប់នោះ ព្រះឱរសច្បងនៃព្រះពោធិសត្វឃើញព្រះមាតាទ្រង់ព្រះកន្សែង ទើបត្រិះរិះថា ហេតុអ្វីហ្ន៎ ទើបព្រះមាតារបស់អញអង្គុយយំ កាលនឹងទូលសួរព្រះរាជមាតា ទើបត្រាស់ថា

បពិត្រព្រះមាតា បុគ្គលណាធ្វើឲ្យព្រះមាតាទ្រង់ព្រះក្រោធ
ព្រះមាតាទ្រង់ព្រះកន្សែងផង ទ្រង់សម្លក់ចំពោះខ្ញុំយ៉ាងខ្លាំងផង
តើព្រោះហេតុអ្វី បណ្ដាញាតិដែលកំពុងរមិលមើល ខ្ញុំសម្លាប់
ញាតិណា ដែលជាមនុស្សដែលគេមិនគួរសម្លាប់ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កោបេសិ** សេចក្ដីថា បពិត្រព្រះមាតា អ្នកណាធ្វើឲ្យព្រះមាតាអាក់អន់ គឺអ្នកណាធ្វើវត្ថុដែលមិនជាទីស្រឡាញ់ដល់មាតា ។ បទថា **អបេក្ខសិ ច** អធិប្បាយថា កាលព្រះមាតាសម្លឹងខ្ញុំ ហេតុអ្វី ទើបព្រះកន្សែង ។ បទថា **កំ អវជ្ឈំ ឃាតេមិ** សេចក្ដីថា ព្រះរាជឱរស

ក្រាបទូលថា ខ្ញុំនឹងសម្លាប់អ្នកណាដែលគួរឲ្យសម្លាប់ សម្រាប់ព្រះញាតិរបស់ព្រះមាតាដែលកំពុងឃើញនោះឯង សូមប្រាប់ដល់ខ្ញុំចុះ លំដាប់នោះព្រះទេវីត្រាស់គាថានេះថា

ម្នាលកូន បុគ្គលណាជាអ្នកឈ្នះសង្គ្រាម ញុំាងអញឲ្យក្រោធ
បុគ្គលនោះ កូនឯងមិនអាចសម្លាប់បានទេ ម្នាលកូន ព្រះរាជ
បិតារបស់កូនឯង បានត្រាស់នឹងម្តាយថា យើងមិនមានសេចក្តី
អាឡោះអាល័យទេ នឹងទៅ ( បួស ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិជិតាវី** សេចក្តីថា នៃកូន អ្នកណាជាអ្នកឈ្នះក្នុងផែនដី ធ្វើឲ្យម៉ែអាក់អន់ គឺញុំាងសេចក្តីក្រោធនិងសេចក្តីសោកឲ្យចូលទៅក្នុងហទយៈរបស់ម៉ែ ដោយការពោលពាក្យមិនជាទីស្រឡាញ់ បុគ្គលនោះ កូនមិនអាចសម្លាប់បានទេ ព្រោះជាបិតារបស់កូនឯង ទ្រង់ត្រាស់នឹងម៉ែថា យើងនឹងលះសិរីរាជសម្បត្តិនិងនាង ចូលកាន់ព្រៃ ហើយបួស នេះគឺហេតុនៃការយំរបស់ម៉ែ ។

ជេដ្ឋរសស្តាប់ព្រះសវនីយ៍របស់ព្រះមាតាហើយ ទូលថា បពិត្រព្រះមាតា ទ្រង់ត្រាស់ពាក្យនេះដូចម្តេច កាលបើដូច្នោះ ពួកយើងធ្លាក់ខ្លួនជាមនុស្សអនាថា មិនមានទីពឹង មិនមែនឬ ដូច្នេះហើយ ក៏បរិទេវនាការត្រាស់គាថានេះថា

ក្នុងកាលមុន ខ្ញុំទៅកាន់សួនឧទ្យាន ដោយរថ បានច្បាំងនឹង
ដំរីចុះប្រេងទាំងឡាយ កាលបើព្រះបិតា ទ្រង់ព្រះនាមសុត

សោម ទ្រង់ព្រះផ្នួសហើយ ឥឡូវនេះ ខ្ញុំនឹងធ្វើដូចម្ដេចហ្ន៎ ដូច្នេះ ។

គាថានោះ មានអធិប្បាយដូច្នេះថា កាលមុនយើងធ្លាប់ឡើងរថដែលប្រដាប់ហើយដោយគ្រឿងអលង្ការទាំងពួង ទឹមដោយអាជានេយ្យ ៤ ទៅ ព្រះរាជឧទ្យាន ច្បាំងនឹងកុញ្ជរជាតិចុះប្រេង លេងកីឡាដទៃៗ ដូចជាអស្សកីឡា ( កីឡាសេះ ) ជាដើម ឥឡូវនេះ កាលព្រះរាជបិតាសុតសោមបួសហើយ យើងនឹងធ្វើដូចម្ដេច ។

លំដាប់នោះ ព្រះឱរសប្អូន មានព្រះជន្មាយុបាន ៧ ឆ្នាំ ឃើញក្សត្រទាំង ២ ទ្រង់ព្រះកន្សែង ទើបចូលទៅគាល់ព្រះមាតា ទូលសួរថា បពិត្រព្រះមាតា ព្រោះហេតុអ្វី ព្រះមាតានិងម្ចាស់បង ទ្រង់ព្រះកន្សែង លុះបានស្ដាប់រឿងនោះហើយ ក៏លួងលោមជនទាំង ២ ថា បើដូច្នោះ សូមព្រះមាតានិងម្ចាស់បង កុំព្រះកន្សែងឡើយ ទូលព្រះបង្គំមិនព្រមឲ្យព្រះបិតាបួសទេ ហើយចុះអំពីប្រាសាទមួយអន្ទើដោយកីលៀង ទៅកាន់សម្នាក់ព្រះរាជបិតា ក្រាបទូលថា បពិត្រព្រះបិតា បានឮថា ព្រះបិតាត្រាស់ថា នឹងលះបង់ខ្ញុំដែលមិនបំណាងឲ្យបួសទៅបួស ខ្ញុំមិនព្រមឲ្យព្រះបិតាបួសឡើយ ហើយឱបព្រះសូរងព្រះបិតាជាប់ត្រាស់គាថានេះថា

កាលព្រះមាតា របស់ទូលព្រះបង្គំជាខ្ញុំ កំពុងទ្រង់ព្រះកន្សែង
ផង កាលព្រះជេដ្ឋភាតានៃទូលព្រះបង្គំជាខ្ញុំមិនប្រាថ្នា ( នឹង
ឲ្យព្រះអង្គទ្រង់ព្រះផ្នួស ) ផង ទូលព្រះបង្គំជាខ្ញុំនឹងចាប់

ព្រះហស្តរបស់ព្រះអង្គទុក កាលបើពួកទូលព្រះបង្គំជាខ្ញុំ មិន
ចង់ឲ្យព្រះអង្គទ្រង់ផ្នួស ព្រះអង្គនឹងយាងទៅមិនបានទេ ដូច្នេះ ។

ព្រះមហាសត្វទ្រង់ព្រះតម្រិះថា ឱរសរបស់អញនេះ នឹងធ្វើអន្តរាយដល់អញ ឧបាយដូចម្តេចហ្ន៎ អញនឹងឲ្យគេចៀសចេញទៅបាន គ្រានោះទើបព្រះមហាសត្វ ទ្រង់សម្លឹងមើលភីលៀងត្រាស់ថា នែនាង នាងទៅចុះ នេះជាគ្រឿងប្រដាប់**ក** គឺកែវមណី ចំណែកនេះសុទ្ធតែជារបស់នាង ឲ្យតែនាងជួយចាប់ព្រះឱរសចេញទៅ កុំឲ្យគេធ្វើអន្តរាយដល់យើងឡើយ កាលទ្រង់មិនអាចបេះព្រះហស្តព្រះឱរសបាន ទើបទ្រង់ឲ្យសំណូកភីលៀង ហើយត្រាស់ថា

ម្នាលមេនំ នាងចូរក្រោកឡើង ( ចូរកាន់យកនូវកែវមណីនេះ )
ហើយញុំាងកុមារនេះឲ្យត្រេកអរក្នុងទីដទៃចុះ កាលបើអញ
កំពុងប្រាថ្នាឋានសួគ៌ កុំឲ្យកុមារនេះ ធ្វើនូវសេចក្តីអន្តរាយ
ដល់អញឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧមំ កុមារំ** សេចក្តីថា នែមេនំ ចូរនាងក្រោកឡើង ជួយនាំកុមារនេះទៅ ហើយទទួលយកកែវមណីនេះ នាំកុមារនេះឲ្យទៅត្រេកអរក្នុងទីដទៃចុះ ។

ភីលៀងនោះបានរង្វាន់ហើយ ទើបជាស់តឿនព្រះរាជកុមារឲ្យដឹងខ្លួនបាននាំទៅកាន់ទីដទៃបណ្តើរ យំរៀបរាប់បណ្តើរថា

ណ្ហើយចុះ អញនឹងថ្វាយនូវកែវមណី មានរស្មីល្អនេះទៅវិញចុះ
កែវមណីនេះ មានប្រយោជន៍អ្វីដល់អញ កាលបើព្រះរាជា

ទ្រង់ព្រះនាមសុតសោម ទ្រង់ព្រះផ្នួសហើយ អញនឹងធ្វើកែវ

មណីនេះដូចម្ដេច ដូច្នេះ ។

គាថានោះ មានអធិប្បាយដូច្នេះថា ភីលៀងយំរៀបរាប់ថា អញទទួលយកកែវមណីនេះជាថ្លៃឈ្នួលនេះធ្វើអ្វីហ្ន៎ អញគប្បីឲ្យកែវមណីនោះ ដែលធ្វើរស្មី គឺបញ្ចេញនូវពន្លឺ កាលព្រះបាទសុតសោមទ្រង់ព្រះផ្នួសហើយ កែវមណីនេះ មានប្រយោជន៍អ្វីដល់អញ ។ បទថា **កឹ នុ មេតំ ករិស្សាមិ** សេចក្ដីថា កាលទ្រង់ព្រះផ្នួសហើយ អញនឹងមិនបានកែវមណីនេះ ទោះបីជាបាន នឹងធ្វើអ្វីដោយកែវមណីនេះ អ្នកទាំងឡាយចូរមើលការធ្វើរបស់ខ្ញុំចុះ ។

លំដាប់នោះ អាមាត្យមហាសេនាគុត្តៈគិតថា ប្រហែលជាព្រះរាជានេះទ្រង់ធ្វើសេចក្ដីសម្គាល់ថា ព្រះរាជទ្រព្យក្នុងឃ្លាំងរបស់យើងមានតិច អញនឹងទូលភាព ដែលព្រះរាជទ្រព្យមានច្រើនដល់ទ្រង់ ហើយក្រោកឡើងថ្វាយបង្គំពោលថា

បពិត្រព្រះសម្មតិទេព ឃ្លាំងតូចរបស់ព្រះអង្គពេញ ឃ្លាំងធំ

របស់ព្រះអង្គពេញ ទាំងផែនដីព្រះអង្គក៏ទ្រង់ឈ្នះហើយ សូម

ព្រះអង្គទ្រង់រីករាយ សូមព្រះអង្គកុំទ្រង់ព្រះផ្នួស ដូច្នេះ ។

ព្រះមហាសត្វស្ដាប់ដូច្នោះ ទើបត្រាស់គាថានេះថា

ឃ្លាំងតូចរបស់ខ្ញុំក៏ពេញ ឃ្លាំងធំរបស់ខ្ញុំក៏ពេញ ទាំងផែនដី

ខ្ញុំក៏បានឈ្នះហើយ ខ្ញុំនឹងលះបង់នូវទ្រព្យទាំងនោះហើយទៅ

បួស ដូច្នេះ ។

កាលមហាសេនគុត្តាមាត្យ បានស្តាប់ព្រះតម្រាស់ដូច្នោះ ទើបថយទៅកុលវឌ្ឍនសេដ្ឋីក្រោកឡើងថ្វាយបង្គំ ពោលថា

បពិត្រព្រះសម្មតិទេព ទ្រព្យរបស់ទូលព្រះបង្គំជាខ្ញុំមានច្រើន
ទូលព្រះបង្គំជាខ្ញុំមិនអាចនឹងរាប់បាន ទូលព្រះបង្គំជាខ្ញុំនឹង
ថ្វាយទ្រព្យទាំងនោះ ដល់ព្រះអង្គ សូមព្រះអង្គទ្រង់ត្រេកអរ
សូមកុំទ្រង់ព្រះផ្នួស ដូច្នេះ ។

កាលព្រះមហាសត្វស្តាប់ដូច្នោះហើយ ទើបត្រាស់គាថានេះថា

ម្នាលកុលពន្ធនវឌ្ឍនៈ ខ្ញុំដឹងថា ទ្រព្យរបស់អ្នកមានច្រើន អ្នក
បូជាខ្ញុំហើយ ក៏ប៉ុន្តែខ្ញុំប្រាថ្នាឋានសួគ៌ ហេតុនោះ ខ្ញុំនឹងបួស
ដូច្នេះ ។

កាលកុលវឌ្ឍនសេដ្ឋីបានស្តាប់រាជតម្រាស់ ក៏ថយចេញទៅ ព្រះមហាសត្វក៏ហៅព្រះអនុជព្រះនាមថាសោមទត្តមក ត្រាស់ថា នែបាសោមទត្ត យើងអផ្សុក ដូចមាន់ព្រៃត្រូវក្រុងក្នុងទ្រុង ការមិនត្រេកអរក្នុងឃរាវាសគ្របសង្កត់យើង យើងនឹងបួសក្នុងថ្ងៃនេះឲ្យបាន ចូរឯងគ្រប់គ្រងរាជសម្បត្តិនេះចុះ កាលទ្រង់ប្រគល់រាជសម្បត្តិឲ្យ ទើបត្រាស់គាថានេះថា

ម្នាលសោមទត្ត ខ្ញុំជាអ្នកអផ្សុកយ៉ាងខ្លាំង សេចក្តីមិនត្រេកអរ
( ក្នុងការគ្រប់គ្រងផ្ទះ ) មកគ្របសង្កត់ខ្ញុំហើយ សេចក្តីអន្តរាយ
មានច្រើនណាស់ ខ្ញុំនឹងបួសក្នុងថ្ងៃនេះមិនខាន ដូច្នេះ ។

សោមទត្ត ស្តាប់រាជតម្រាស់នោះហើយ ក៏មានបំណងបួសដែរ ទើប

សម្តែងបំណងនោះ ត្រាស់ព្រះគាថាបន្តថា

បពិត្រព្រះរាជាទ្រង់ព្រះនាមសុតសោម បព្វជ្ជាកម្មនេះ ព្រះអង្គទ្រង់ពេញព្រះទ័យហើយ ឥឡូវនេះ សូមព្រះអង្គបួសក្នុងថ្ងៃនេះចុះ ទាំងទូលព្រះបង្គំជាខ្ញុំសោតទៀត ក៏នឹងបួសដែរ ( ព្រោះ ) ទូលព្រះបង្គំជាខ្ញុំ បើវៀរចាកព្រះអង្គហើយ នឹងមិនអាចឋិតនៅបានទេ ដូច្នេះ ។

លំដាប់នោះ ព្រះមហាសត្វហាមព្រះអនុជហើយត្រាស់កន្លះគាថាដូច្នេះថា

អ្នកឯងមិនអាចនឹងបួសបានទេ ព្រោះថា បុគ្គលនីមួយក្នុងនគរ ឬក្នុងជនបទនឹងមិននាំគ្នាចម្អិនអាហារឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ន ហិ បច្ចតិ** សេចក្តីថា ព្រោះបានជ្រាបបំណងក្នុងបព្វជ្ជារបស់បងក្នុងកាលឥឡូវនេះ ពីមុននោះ បុគ្គលណាម្នាក់ក្នុងសុទស្សនគរ ដែលមានអាណាខេត្ត ១២ យោជន៍ និងក្នុងជនបទទាំងមូលនេះ នឹងមិននាំគ្នាចម្អិនអាហារ គឺមិននាំគ្នាញ៉ាំងភ្លើងក្នុងជើងក្រានឲ្យឆេះ បើយើងបួសទាំង ២ នាក់ អ្នកដែននឹងឥតទីពឹង ព្រោះហេតុនោះ ឯងបួសមិនបានទេ បងនឹងបួសតែឯកអង្គប៉ុណ្ណោះ ។

មហាជន បានស្តាប់ព្រះរាជតម្រាស់ហើយ នាំគ្នាបម្រះនទៀល ទៀបព្រះយុគលបាទរបស់ព្រះមហាសត្វ បរិទេវនាការថា

កាលបើព្រះបាទសុតសោមទ្រង់ព្រះផ្នួសហើយ តើឥឡូវនេះពួកយើងនឹងធ្វើដូចម្តេចហ្ន៎ ដូច្នេះ ។

លំដាប់នោះ ព្រះមហាសត្វត្រាស់ថា កុំឡើយ អ្នកទាំងឡាយកុំសោកស្តាយថ្វី ទោះបីយើងតាំងនៅបានយូរ ក៏ត្រូវព្រាត់ប្រាសចាកអ្នកទាំងឡាយព្រោះសង្ខារដែលកើតឡើងហើយ ឈ្មោះថា ទៀង មិនមានទេ កាលទ្រង់សម្តែងធម៌ដល់មហាជន ទើបត្រាស់ថា

យើងសំគាល់ថា ជីវិតនេះ រមែងរីងស្ងួតទៅ ដូចទឹកដ៏តិច

( ដែលគេដាក់ ) ក្នុងពាងធ្លុះ កាលបើជីវិតតិចយ៉ាងនេះ

កាលនេះ មិនមែនជាកាលគួរប្រមាទឡើយ ។ យើងសំគាល់

ថា ជីវិតនេះ រមែងរីងស្ងួតទៅ ដូចទឹកដ៏តិចក្នុងពាងធ្លុះ កាល

ជីវិតតិចយ៉ាងនេះ កោតតែជនពាលទាំងឡាយប្រមាទ ។ ជន

ពាលទាំងនោះ រមែងញុំាងនរក តិរច្ឆានកំណើត និងបេត

វិស័យឲ្យចម្រើន ជាអ្នកជាប់ដោយគ្រឿងចង គឺតណ្ហា រមែង

ញុំាងអសុរកាយឲ្យចម្រើន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧបនិយ្យតិទំ មញ្ញេ** សេចក្តីថា នៃអ្នកទាំងឡាយ យើងយល់ថា ជីវិតត្រូវជរានាំចូលទៅក្នុងសត្វទាំងឡាយដទៃៗ ជីវិតនេះមានការត្រូវជរារុករានជាអត្ថ មានការត្រូវជរានាំទៅជាអត្ថ តែក្នុងទីនេះ ត្រូវជរារឹតរុំជាអត្ថ ព្រោះហេតុនោះ ទឹកតិចដែលដាក់ក្នុងថ្នាំង តម្រង់ក្បួនរបស់ជាងជ្រលក់ រមែងរីងស្ងួតឆាប់យ៉ាងណា សូម្បីជីវិតក៏យ៉ាងនោះ កាលជីវិតជារបស់តិចយ៉ាងនេះ ក្នុងកាលដែលប្រមាទក្នុងបុញ្ញកិរិយារបស់សត្វទាំងឡាយ ដែលប្រកាន់អាយុសង្ខារបន្តិចបន្តួចនោះ មិនគួរធ្វើសេចក្តី

ប្រមាទឡើយ ព្រោះហេតុនោះ ក្នុងទីនេះមានអធិប្បាយប៉ុណ្ណេះ ។

បទថា **អជ ពាលា បមជ្ជន្តិ** សេចក្តីថា ជនពាលទាំងឡាយ ហាក់ដូចជាមិនចាស់ មិនស្លាប់ លិចចុះក្នុងភក់ គឺកាមគុណ ជាអ្នកប្រមាទដូចជ្រូកលិចចុះក្នុងភក់ គឺលាមកដូច្នោះ ។ បទថា **អសុរកាយំ** សេចក្តីថា រមែងញ៉ាំងកំណើតកាឡកញ្ជិកាសុរឲ្យចម្រើន ។

ព្រះមហាសត្វ ទ្រង់សម្តែងធម៌ដល់មហាជនយ៉ាងនេះហើយ ទ្រង់ឡើងកាន់បុប្ផកប្រាសាទ ប្រថាប់ឈរលើជាន់ទី ៧ ទ្រង់យកព្រះខ័នកាត់ព្រះមោលីហើយត្រាស់ថា យើងមិនជាអ្វីនឹងអ្នកទាំងឡាយឡើយ អ្នកទាំងឡាយចូររកព្រះរាជារបស់ខ្លួន ហើយបោះព្រះមោលី មួយអន្លើដោយឈ្នួតព្រះសីសៈទៅកណ្តាលមហាជន មហាជនទទួលព្រះមោលី ហើយនាំគ្នាយំបម្រះនទៀលលើផែនដី លម្អងធូលីក៏ហុយឡើងក្នុងទីនោះ មហាជនដែលត្រឡប់មកឈរមើល បានឃើញលម្អងធូលីនោះ នាំគ្នាយំរៀបរាប់ថា ព្រះមោលីនិងឈ្នួតសីសៈព្រះរាជាទ្រង់កាត់បោះមកក្នុងរវាងមហាជន ដូច្នោះ ទើបលម្អងធូលីនេះផ្សាយឡើងក្នុងទីជិតប្រាសាទ ហើយពោលគាថាដូច្នេះថា

គំនរធូលី ហុយឡើងក្នុងទីជិត បុប្ផកប្រាសាទ ពួកយើង
សំគាល់គំនរធូលីនោះថា ជាព្រះកេសា ដែលព្រះធម្មរាជ
ព្រះអង្គ មានយសរបស់យើង ទ្រង់កាត់ហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឩហាញ្ញតេ** បានដល់ ផ្សាយឡើង។ បទថា **រជគ្គំ** បានដល់ គំនរធូលី ។ បទថា **អវិទូរេ** សេចក្តីថា គំនរ ធូលីកើត

ឡើង មិនឆ្ងាយអំពីទីដែលពួកយើងឈរនេះឡើយ ។ បទថា **បុប្ផកម្មិ** សេចក្តីថា ក្បែរៗបុប្ផកប្រាសាទ ។ បទថា **មញ្ញេ ណោ** សេចក្តីថា ពួកយើងយល់ថា ព្រះធម្មរាជារបស់ពួកយើងនឹងកាត់ព្រះកេសាហើយ ចំណែកព្រះមហាសត្វ ទ្រង់ប្រើមហាតលិកឲ្យនាំបរិក្ខារបព្វជិតមក ឲ្យកូសាមាលាដាក់ព្រះកេសានិងព្រះមស្សុ ហើយដោះគ្រឿងរាជអលង្ការ ទុកលើកម្រាលកាត់នូវជាយព្រះភូសា ពណ៌ក្រហម ទ្រទ្រង់នូវកាសាវពស្ត្រ ស្ពាយបាត្រដីត្រង់ចង្កួយស្មាខាងឆ្វេង ចាប់ឈើច្រត់ យាងចង្ក្រមទៅមកក្នុងល្វែងប្រាសាទ ហើយទ្រង់ចុះអំពីប្រាសាទ ទៅកាន់លង្វែកផ្លូវ តែមិនមាននរណាចាំទ្រង់បានឡើយ ។ លំដាប់នោះ ខត្តិយកញ្ញា ៧០០ របស់ព្រះមហាសត្វនោះ នាំគ្នាឡើងទៅកាន់ប្រាសាទ មិនឃើញព្រះមហាសត្វ ឃើញតែគ្រឿងអាភរណៈ ហើយទៅកាន់សម្នាក់របស់ស្រីស្នំទាំង ១៦០០០ ដ៏សេស បានពួថា ព្រះបាទសុតសោម ជាបិយរាជស្វាមីនៃពួកយើងបួសហើយ ក៏នាំគ្នាបរិទេវនាការកងរំពងចេញទៅខាងក្រៅ ។ គ្រានោះ មហាជនបានដឹងថា ព្រះរាជាទ្រង់ព្រះផ្នួសហើយ អ្នកនគរទាំងមូល ក៏ភ្ញាក់ផ្អើលប្រជុំគ្នាត្រង់ទ្វាររាជវាំង ពោលថា បានឮថា ព្រះរាជារបស់ពួកយើងបួសហើយ ។ មហាជននាំគ្នាទៅកាន់ទីដែលធ្លាប់ប្រថាប់ ដូចជាប្រាសាទជាដើម ដោយគិតថា ព្រះរាជានៅក្នុងទីនោះ និងនៅត្រង់នេះ តែមិនបានជួបព្រះរាជា ទើបនាំគ្នាត្រាច់បរិទេវនាការដោយគាថាទាំងនេះថា

ព្រះរាជា ដែលពួកស្រីស្នំហែហមហើយ យាងទៅក្នុងប្រាសាទ

ណា ប្រាសាទនេះ របស់ព្រះរាជានោះ ដ៏ដេរដាសដោយផ្កាមាសនិងកម្រងផ្កាផ្សេងៗ ។ ព្រះរាជាដែលពួកព្រះញាតិហែ-ហមហើយ យាងទៅក្នុងប្រាសាទណា ប្រាសាទនេះ របស់ព្រះរាជានោះ ដ៏ដេរដាសដោយផ្កាមាសនិងកម្រងផ្កាផ្សេង ៗ ។ ព្រះរាជាដែលពួកស្រីស្នំហែហមហើយ ទ្រង់យាងទៅក្នុងបន្ទប់សម្រាប់ផ្ទំណា បន្ទប់សម្រាប់ផ្ទំនេះ របស់ព្រះរាជានោះ ដ៏ដេរដាសដោយផ្កាមាសនិងកម្រងផ្កាផ្សេងៗ ។ ព្រះរាជាដែលពួកញាតិហែហមហើយ ទ្រង់យាងទៅក្នុងបន្ទប់សម្រាប់ផ្ទំណា បន្ទប់សម្រាប់ផ្ទំនេះ របស់ព្រះរាជានោះ ដ៏ដេរដាសដោយផ្កាមាសនិងកម្រងផ្កាផ្សេងៗ ។ ព្រះរាជាដែលស្រីស្នំហែហមហើយទ្រង់យាងទៅ ក្នុងទីព្រៃឈើអសោកណា ទីព្រៃឈើអសោកនេះ របស់ព្រះរាជានោះ មានផ្ការីកល្អសព្វៗកាល គួរជាទីរីករាយចិត្ត ។ ព្រះរាជាដែលពួកញាតិហែហមហើយ ទ្រង់យាងទៅក្នុងទីព្រៃ ឈើអសោកណា ទីព្រៃឈើអសោកនេះ របស់ព្រះរាជានោះ មានផ្ការីកល្អសព្វៗកាល គួរជាទីរីករាយចិត្ត ។ ព្រះរាជាដែលពួកស្រីស្នំហែហមហើយ ទ្រង់យាងទៅក្នុងឱទ្យានណា ឱទ្យាននេះ របស់ព្រះរាជានោះ មានផ្ការីកល្អសព្វៗកាលគួរជាទីរីករាយចិត្ត ។ ព្រះរាជា ដែលពួកញាតិហែហមហើយ ទ្រង់យាងទៅក្នុងឧទ្យានណា ឧទ្យាននេះរបស់

ព្រះរាជានោះ មានផ្ការីកល្អសព្វៗកាល គួរជាទីរីករាយចិត្ត ។ ព្រះរាជា ដែលពួកស្រីស្នំហែហមហើយ ទ្រង់យាងទៅក្នុងព្រៃឈើកណិការណា ព្រៃឈើកណិការនេះ របស់ព្រះរាជានោះ មានផ្ការីកល្អសព្វ ៗ កាល គួរជាទីរីករាយចិត្ត ។ ព្រះរាជា ដែលពួកញាតិហែហមហើយ ទ្រង់យាងទៅក្នុងព្រៃឈើកណិការណា ព្រៃឈើកណិការនេះ របស់ព្រះរាជានោះ មានផ្ការីកល្អ សព្វៗកាល គួរជាទីរីករាយចិត្ត ។ ព្រះរាជា ដែលពួកស្រីស្នំហែហមហើយ ទ្រង់យាងទៅក្នុងព្រៃប្រទៀងណា ព្រៃប្រទៀងនេះ របស់ព្រះរាជានោះមានផ្ការីកល្អសព្វៗកាល គួរជាទីរីករាយចិត្ត ។ ព្រះរាជាដែលពួកញាតិហែហមហើយ ទ្រង់យាងទៅក្នុងព្រៃប្រទៀងណា ព្រៃប្រទៀងនេះ របស់ព្រះរាជានោះ មានផ្ការីកល្អសព្វៗកាល គួរជាទីរីករាយចិត្ត ។ ព្រះរាជា ដែលពួកស្រីស្នំហែហមហើយ ទ្រង់យាងទៅក្នុងព្រៃស្វាយណា ព្រៃស្វាយនេះ របស់ព្រះរាជានោះ មានផ្ការីកល្អសព្វៗកាល គួរជាទីរីករាយចិត្ត ។ ព្រះរាជាដែលពួកញាតិហែហមហើយ ទ្រង់យាងទៅក្នុងព្រៃស្វាយណា ព្រៃស្វាយនេះ របស់ព្រះរាជានោះ មានផ្ការីកល្អសព្វៗកាល គួរជាទីរីករាយចិត្ត ។ ព្រះរាជា ដែលពួកស្រីស្នំហែហមហើយ ទ្រង់យាងទៅក្នុងស្រះបោក្ខរណីណា ស្រះបោក្ខរណីនេះ

របស់ព្រះរាជានោះ ដ៏ដេរដាស ( ដោយផ្កាជលជាតនិងផ្កាថលជាត ) ដ៏កុះករដោយពួកអណ្ឌជៈ ( គួរជាទីរីករាយចិត្ត ) ។ ព្រះរាជាដែលពួកញាតិហែហមហើយ ទ្រង់យាងទៅក្នុងស្រះបោក្ខរណីណា ស្រះបោក្ខរណីនេះរបស់ព្រះរាជានោះដ៏ដេរដាស ( ដោយផ្កាជលជាតនិងថលជាត ) ដ៏កុះករដោយពួកអណ្ឌជៈ គួរជាទីរីករាយចិត្ត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វីតិកិណ្ណោ** សេចក្ដីថា ដេរដាសទៅដោយសុវណ្ណបុប្ផានិងកម្រងមាល័យ ។ បទថា **បរិកិណ្ណោ** បានដល់ ចោមរោមជាបរិមណ្ឌល ។ បទថា **ឥត្ថាគារេហិ** សេចក្ដីថា ស្រីទាំងឡាយ រាប់តាំងពីទាសីទៅ ឈ្មោះថា **ឥត្ថាគារ** គឺស្នំខាងក្នុង ។ សូម្បីអាមាត្យទាំងឡាយក៏ឈ្មោះថា ញាតិទាំងអស់ក្នុងបទថា **ញាតិសង្ឃេន** នេះ ។ បទថា **កូដាគារំ** បានដល់ ទីបន្ទំនិងបន្ទប់កូដាគារ ដែលវិចិត្រទៅដោយរតនៈទាំង ៧ យ៉ាង ។ បទថា **អសោកវនិកា** បានដល់ ក្នុងអសោកវ័ន ។ បទថា **សព្វកាលិកា** សេចក្ដីថា អត់ធន់ចំពោះការប្រើប្រាស់គ្រប់កាល គឺរីកជានិច្ច ។

បទថា **ឧយ្យានំ** បានដល់ ព្រះរាជឧទ្យាន ដូចគ្នានឹងសួនចិត្តលតា ក្នុងនន្ទនវ័ន ។ បទថា **សព្វកាលិកំ** សេចក្ដីថា ដេរដាសទៅដោយផ្កាផ្លែដែលកើតក្នុងរដូវទាំង ៦ ។ បទថា **សព្វកាលិកំ** សេចក្ដីថា ក្នុងកណិការវ័ន ជាដើម ក៏មានផ្ការីកស្គុសស្គាយអស់កាលទាំងពួងដូចគ្នា ។ បទថា **សព្វញ្ញា**

សេចក្ដីថា ដេរដាសដោយល្អ ដោយផ្កាកុសុមៈដែលកើតទាំងក្នុងទឹកនិងលើគោក មានបែបផ្សេងៗ ។ បទថា **អណ្ឌជេហិ វីតិកិណ្ណា** សេចក្ដីថា ដេរដាសទៅដោយពួកបក្សី ។

មហាជនបរិទេវនាការក្នុងទីនោះៗយ៉ាងនេះហើយ ត្រឡប់មកកាន់លានព្រះរាជវាំងវិញ ពោលគាថានេះថា

ព្រះរាជាទ្រង់ព្រះនាមសុតសោម បានលះបង់រាជសម្បត្តិនេះ
ហើយ ក៏ទ្រង់ព្រះផ្នួស ទ្រង់ព្រះពស្ត្រកាសាយៈ ស្ដេចយាង
ទៅតែមួយព្រះអង្គឯង ដូចជាដំរីត្រាច់ទៅតែម្នាក់ឯង ដូច្នេះ ។

ដូច្នេះហើយ នាំគ្នាលះទ្រព្យសម្បត្តិក្នុងផ្ទះរៀងៗខ្លួន ដឹកដៃកូនប្រុសស្រី ចេញទៅកាន់សម្នាក់របស់ព្រះពោធិសត្វនោះឯង ។ ព្រះរាជមាតាបិតា ព្រះជាយា ព្រះរាជឱរស ព្រះរាជធីតា និងស្រីស្នំ ១៦០០០ បដិបត្តិដូច្នោះដូចគ្នា ព្រះនគរទាំងមូលស្ងាត់សូន្យទទេ ឯអ្នកជនបទ នាំគ្នាទៅតាមក្រោយជនទាំងនោះ ព្រះពោធិសត្វទ្រង់នាំបរិស័ទប្រមាណ ១២ យោជន៍ ឆ្ពោះទៅកាន់ព្រៃហិមពាន្ត ។

លំដាប់នោះ សក្កទេវរាជទ្រង់ដឹងថា ព្រះពោធិសត្វចេញអភិនេស្ក្រមណ៍ ទើបហៅវិស្សុកម្មទេវបុត្តមក ត្រាស់ថា នែវិស្សុកម្ម ព្រះបាទសុតសោមមហារាជចេញអភិនេស្ក្រមណ៍ គួរនឹងបានទីប្រថាប់ជាមួយសមាគមដ៏ធំ ចូរអ្នកទៅនិម្មិតអាស្រមបទបណ្ដោយ ៣០ យោជន៍ ទទឹង ១៥ យោជន៍ ត្រង់មាត់ស្ទឹងគង្គា ក្នុងហិមវន្តប្បទេស ។ វិស្សុកម្មទេវបុត្តក៏បណ្ដាល គឺសាង

ឡើងតាមទេវបញ្ជាគ្រប់ប្រការ រៀបចំបព្វជិតបរិក្ខារទុកក្នុងអាស្រមបទនោះ ហើយបណ្ដាលផ្លូវដើរ សម្រាប់មនុស្សម្នាក់ស្រេចហើយ ក៏ត្រឡប់ទៅកាន់ទេវលោកវិញ ។ ព្រះមហាសត្វយាងទៅតាមផ្លូវនោះ ចូលកាន់អាស្រមបទនោះ ទ្រង់បួសឯង ហើយបានឲ្យមហាជនដ៏សេសបួសឯក្រោយ ។ ក្នុងកាលតមក ជនទាំងឡាយបួសច្រើនឡើង ។ ស្ថានទី ៣០ យោជន៍ ក៏ពេញបរិបូណ៌ កំណត់ទីដែលសក្កៈ ទ្រង់ប្រើវិស្សកម្មទេវបុត្ត ឲ្យនិម្មិតអាស្រមបទក្ដី កំណត់ទីដែលមហាជនបួសជាច្រើនក្ដី កំណត់ទីព្រះពោធិសត្វចាត់ចែងអាស្រមបទក្ដី គប្បីជ្រាបដោយន័យដែលពោលមកហើយក្នុងហត្ថិបាល-ជាតកនោះឯង ។ មិច្ឆាវិតក្ក មានកាមវិតក្កជាដើម កើតឡើងដល់បុគ្គលណា ព្រះមហាសត្វក៏យាងចូលទៅរកជនទាំងនោះ ក្នុងទីនោះៗ តាមផ្លូវអាកាស គង់ប្រថាប់ពត់ភ្នែនក្នុងអាកាស កាលទ្រង់ទូន្មានទើបត្រាស់គាថា ២ ថា

> អ្នកទាំងឡាយកុំរឭកការលេង ដោយសេចក្ដីត្រេកអរ និងការ
> សើចក្នុងកាលមុនឡើយ កាមទាំងឡាយ កុំបៀតបៀនពួកអ្នក
> ឡើយ នគរឈ្មោះសុទស្សនៈ ជាទីគួររីករាយ ( អ្នកទាំងឡាយ
> កុំរឭកឡើយ ) ។ អ្នកទាំងឡាយ ចូរចម្រើនមេត្តាចិត្ត រក
> ប្រមាណមិនបាន ទាំងថ្ងៃទាំងយប់ ទើបពួកអ្នកនឹងទៅកាន់
> ទេពបុរី ដែលជាលំនៅពួកអ្នកមានបុញ្ញកម្ម ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **រតិកីឡិតានិ** សេចក្ដីថា អ្នកទាំងឡាយកុំរឭកដល់សេចក្ដីត្រេកអរក្នុងកាម និងការលេងដែលប្រព្រឹត្តទៅដោយ

អំណាចនៃការលេងផ្លូវកាយ វាចា និងចិត្ត ។ បទថា **មា វោ កាមា ហនឹសុ** សេចក្ដីថា វត្ថុកាមនិងកិលេសកាមកុំបៀតបៀនពួកអ្នក ។ បទថា **រម្មញ្ញិ** សេចក្ដីថា សុទស្សនទនគរ គួរជាទីត្រេកអរ អ្នកទាំងឡាយកុំរំពូកដល់ សុទស្សនទនគរនោះ ។ បទថា **មេត្តំ** នេះ ត្រឹមតែជាមាតិកាទេសនាប៉ុណ្ណោះ ព្រះពោធិសត្វត្រាស់ប្រាប់ព្រហ្មវិហារ ៤ ។ បទថា **អប្បមាណំ** បានដល់ មេត្តាព្រហ្មវិហារ មានសត្វប្រមាណមិនបានជាអារម្មណ៍ ។ បទថា **គច្ឆិត្ថ** បានដល់ នឹងបានទៅ ។ បទថា **ឆេវបុរំ** បានដល់ ព្រហ្មលោក ។

ពួកឥសីនោះ តាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វហើយ បានជាអ្នកមានព្រហ្មលោកជាទីទៅខាងមុខ ដោយប្រការដូច្នេះ ។ រឿងទាំងអស់គួរពោលដោយន័យដែលពោលមកហើយ ក្នុងហត្ថិបាលជាតកនោះឯង ព្រះ-សាស្ដា ទ្រង់នាំព្រះធម្មទេសនានេះមកសម្ដែងហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន តថាគតក៏ចេញមហាភិនេស្រ្កមណ៍ដូចគ្នា ហើយទ្រង់ប្រជុំជាតកថា ព្រះមាតាបិតាក្នុងកាលនោះ បានមកជាត្រកូលមហារាជ ក្នុងកាលឥឡូវនេះ ព្រះនាងចន្ទាទេវី ក្នុងកាលនោះ បានមកជារាហុលមាតា ជេដ្ឋារសក្នុងកាល នោះ បានមកជាសារីបុត្ត កនិដ្ឋារស ក្នុងកាលនោះ បានមកជារាហុល ភីលៀង ក្នុងកាលនោះ បានមកជាខុជ្ជុត្តរា កុលវឌ្ឍនសេដ្ឋី ក្នុងកាលនោះ បានមកជាកស្សបៈ មហាសេនាគុត្តៈ ក្នុងកាលនោះ បានមកជាមោគ្គល្លាន សោមទត្តកុមារ ក្នុងកាលនោះ បានមកជាអានន្ទ បរិស័ទដ៏សេសក្នុងកាល

នោះ បានមកជាពុទ្ធបរិស័ទ ក្នុងកាលឥឡូវនេះ ឯព្រះបាទសុតសោម ក្នុងកាលនោះ គឺតថាគត អរហន្តសម្មាសម្ពុទ្ធនេះឯង ។

## អដ្ឋកថា ចុល្លសុតសោមជាតក ចប់

## ចត្តាឡីសនិបាត ចប់

# សុត្តន្តបិដក

# ខុទ្ទកនិកាយ ជាតក

# ទសមភាគ

*សូមថ្វាយនមស្ការព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ*

## បញ្ញាសនិបាត ជាតក

## នឡិនិកា ជាតក

*[ ១ ] ( ព្រះបាទព្រហ្មទត្តត្រាស់ថា ) ម្នាលនាងនឡិនិកា ជនបទក្តៅស្ងួត ទាំងដែនក៏វិនាស ចូរនាងមក ចូរនាងទៅញុំាងព្រាហ្មណ៍ ( អ្នកធ្វើនូវសេចក្តីវិនាស ) ដល់អញនោះ ឲ្យមកលុះអំណាចរបស់ខ្លួន ។*

*[ ២ ] ( នាងនឡិនិកាក្រាបទូលថា ) បពិត្រព្រះរាជា ខ្ញុំម្ចាស់អត់ទ្រាំសេចក្តីលំបាកពុំបាន ខ្ញុំម្ចាស់មិនស្ទាត់ផ្លូវឆ្ងាយ ខ្ញុំម្ចាស់នឹងទៅកាន់ព្រៃដែលមានដំរីនៅអាស្រ័យដូចម្តេចបាន ។*

*[ ៣ ] ( ព្រះរាជា... ) ម្នាលនាងនឡិនិកា នាងចូរទៅកាន់ជនបទដ៏ស្តុកស្តម្ភ ហើយទៅដោយដំរីផង ដោយរថផង ដោយយាន ( ទូក ) ដែលគេគាបដោយឈើផង យ៉ាងនេះចុះ ។ ម្នាលខត្តិយានី ចូរនាងយកដំរី សេះ រថ នឹងពលថ្មើរជើងទៅចុះ ចូរនាងនាំព្រាហ្មណ៍ ឥសិសិង្គៈនោះ មកកាន់អំណាច ( ខ្លួន ) ដោយសម្បុរនឹងរូបឆោមរបស់នាង ។*

*[ ៤ ] ( ពួកព្រានព្រៃបង្ហាញថា ) នុ៎ះ ប្រាកដជាអាស្រមរបស់*

តាបសឈ្មោះឥសិសិង្គៈ ជាទីគួររីករាយ មានដើមចេក ជាទន់ជាគ្រឿងសម្គាល់ មានដើមស្នាច់ដុះព័ទ្ធជុំវិញ ។ ទុំះភ្លើងដែលឥសិសិង្គៈនោះ គាត់តែង ( ដោយឈាន ) ទុំះផ្សែង ដែលឃើញប្រាកដ ខ្ញុំសម្គាល់ថា ឥសិសិង្គៈអ្នកមានឫទ្ធិច្រើន មិនញុំាងភ្លើងឲ្យសាបសូន្យទេ ។

[ ៥ ] ( អភិសម្ពុទ្ធគាថា ) ឥសិសិង្គៈ បានឃើញនាង នឡិនិកានោះពាក់កុណ្ឌលកែវមណី កំពុងដើរមក ក៏ភិតភ័យ ចូលទៅកាន់អាស្រមដែលប្រក់ដោយស្លឹក ។ ឯនាងនឡិនិកានោះ ក៏បង្ហាញនូវអវយវៈទាំងឡាយផងបញ្ចេញនូវគ្រឿងខ្មាសដ៏កំបាំងផង ហើយលេងកូនឃ្លី ក្បែរទ្វារអាស្រមនៃឥសិសិង្គៈនោះ ។

[ ៦ ] អ្នកមានជដា ( ឥសិសិង្គៈ ) នៅក្នុងបណ្ណសាលា ឃើញនាងនឡិនិកានោះកំពុងលេង ចេញអំពីអាស្រមមក និយាយពាក្យនេះថា ម្នាលអ្នកដ៏ចម្រើន ឈើរបស់អ្នកនោះ ឈ្មោះអ្វី ដែលមានផ្លែបែបនេះ សូម្បីអ្នកបោះទៅក្នុងទីឆ្ងាយហើយ ក៏វិលត្រឡប់មកវិញ មិនទៅចោលអ្នក ។

[ ៧ ] ( នាងនឡិនិកា... ) បពិត្រតាបសដ៏ប្រសើរ ផ្លែបែបនេះនៃឈើណា សូម្បីខ្ញុំបោះទៅក្នុងទីឆ្ងាយក៏ត្រឡប់មកវិញ មិនទៅចោលខ្ញុំទេ ឈើបែបនោះមានក្នុងទីជិតអាស្រមនៃខ្ញុំ នាក្នុំគន្ធមាទន៍ ។

[ ៨ ] ( ឥសិសិង្គៈ... ) អ្នកដ៏ចម្រើន ចូរមកកាន់អាស្រមនេះចុះ ចូរបរិភោគអាហារចុះ ចូរទទួលថ្នាំសម្រាប់លាបជើងផង កក្យាហារផង ខ្ញុំជូន ( ដល់អ្នក ) នេះអាសនៈ អ្នកដ៏ចម្រើន ចូរអង្គុយលើអាសនៈនេះ អ្នក

ដ៏ចម្រើន ចូរពិសាមើមឈើនឹងផ្លែឈើក្នុងទីនេះចុះ ។

[ ៩ ] ( ឥសិសិង្គៈសួរថា ) អ្វីនេះកំពុងល្អ ( ដូចមាត់ខ្យងបៀ ) នៅត្រង់ចន្លោះភ្លៅរបស់អ្នក ប្រាកដដូចជាវត្ថុមានពណ៌ខ្មៅៗ ខ្ញុំសួរហើយ អ្នកចូរប្រាប់សេចក្តីនុ៎ះ អវយវៈដ៏ឧត្តម ( លិង្គ ) របស់អ្នក លេចចូលទៅក្នុងស្រោម ( សរីរៈ ) ឬ ។

[ ១០ ] ( នាងនឡិនិកា...) ខ្ញុំត្រាច់ទៅកាន់ទីស្វែងរកមើមឈើ ផ្លែឈើក្នុងព្រៃ បានចោលខ្លាឃ្មុំមានរូបដ៏សម្បើម ខ្លាឃ្មុំនោះស្ទុះមកសង្គ្រុបខ្ញុំដោយរហ័ស ផ្តួលខ្ញុំហើយខាំដកយកអវយវៈដ៏ឧត្តមទៅ ។ ដំបៅនោះឯងឈឺពើតផង រមាស់ផង ខ្ញុំមិនបានសេចក្តីសុខសព្វៗកាលទេ អ្នកដ៏ចម្រើនអាចនាំចេញនូវរោគរមាស់នេះចេញបាន អ្នកដ៏ចម្រើនដែលខ្ញុំអង្វរហើយសូមធ្វើនូវប្រយោជន៍ដល់ព្រាហ្មណ៍ ។

[ ១១ ] ( ឥសិសិង្គៈ... ) ដំបៅរបស់អ្នកមានសភាពដ៏ជ្រៅ មានសម្បុរក្រហម មិនស្អុយទេ គ្រាន់តែមានក្លិនខ្ចោះ ( បន្តិចៗ ) ហើយ ថែមទាំងធំផង ខ្ញុំនឹងប្រកបដោយថ្នាំដុស លាបឲ្យអ្នកបន្តិចមើល ដើម្បីនឹងឲ្យអ្នកដ៏ចម្រើន បានសេចក្តីសុខស្រួល ។

[ ១២ ] ( នាងនឡិនិកា... ) បពិត្រតាបសដ៏ប្រសើរ ការប្រកបដោយមន្តទាំងឡាយក៏មិនត្រូវ ការប្រកបដោយថ្នាំដុសទាំងឡាយក៏មិនត្រូវ ឱសថទាំងឡាយក៏មិនត្រូវ អវយវៈណារបស់លោកដ៏ទន់ៗ ចូរលោកនាំចេញនូវរោគរមាស់ដោយអវយវៈនោះ ទើបខ្ញុំមានសេចក្តីសុខស្រួលតទៅ ។

[ ១៣ ] ( ឥសិសិង្គ:... ) តាបសរបស់អ្នកដ៏ចម្រើននៅខាងណា អំពីទីនេះ ម្នាលអ្នកដ៏ចម្រើន អ្នកអភិរម្យក្នុងព្រៃដែរឬ អ្នកមានមើមឈើ ផ្លៃឈើច្រើនដែរឬ សត្វសាហាវទាំងឡាយមិនបៀតបៀនអ្នកដ៏ចម្រើនទេឬ ។

[ ១៤ ] ( នាងនឡិនិកា... ) អាស្រមរបស់ខ្ញុំជាទីគួរីករាយ ( នៅ ) ក្បែរឆ្នេរនៃស្ទឹងឈ្មោះខេមា ដែលហូរទៅអំពីព្រៃហិមវន្ត នាទិសខាងជើងត្រង់អំពីទីនេះ ធ្វើដូចម្តេចហ្ន៎ អ្នកដ៏ចម្រើន គប្បីឃើញអាស្រមរបស់ខ្ញុំ ។ ( ទៀបអាស្រមរបស់ខ្ញុំ ) មានដើមស្វាយ រាំងភ្នំ ទន្លាប់ ព្រីង រាជព្រឹក្សប្រទៀង មានផ្ការីកស្គុសស្គាយ ធ្វើដូចម្តេចហ្ន៎ អ្នកដ៏ចម្រើនគប្បីឃើញអាស្រមរបស់ខ្ញុំ ដែលមានកិន្នរច្រៀងពីរោះដោយជុំវិញ ។ ក្នុងទីជិតអាស្រមរបស់ខ្ញុំនុ៎ះ មានដើមត្នោតទាំងឡាយផង មើមឈើទាំងឡាយផង ផ្លៃឈើទាំងឡាយផង ធ្វើដូចម្តេចហ្ន៎ ទើបអ្នកដ៏ចម្រើនគប្បីឃើញនូវអាស្រមរបស់ខ្ញុំ ដែលប្រកបដោយពណ៌និងក្លិន ដែលប្រកបដោយភូមិភាគទាំងឡាយ ( ដ៏រាបស្មើ ) នោះ ។ ផ្លៃឈើទាំងឡាយផង មើមឈើទាំងឡាយផង មានគរគោកក្នុងអាស្រមនេះ ប្រកបដោយពណ៌ក្លិននិងរស តែពួកព្រានព្រៃតែងមកកាន់ប្រទេសនោះ កុំឲ្យពួកវាលួចមើមឈើនិងផ្លៃឈើរបស់ខ្ញុំអំពីអាស្រមនោះឡើយ ។

[ ១៥ ] ( ឥសិសិង្គ:... ) បិតារបស់ខ្ញុំ ទៅកាន់ទីស្វែងរកមើមឈើផ្លៃឈើនឹងមកក្នុងកាលល្ងាច ឥឡូវនេះចាំបិតាមកអំពីទីស្វែងរកមើមឈើនឹងផ្លៃឈើសិន សឹមយើងទាំង ២ នាក់ទៅកាន់អាស្រមនោះ ។

[ ១៦ ] ( នាងនឡិនិកា... ) មានពួកព្រាហ្មណ៍ជាឥសី និងពួកព្រះរាជា ជាឥសីដទៃទៀតជាច្រើន ដែលជាមនុស្សត្រឹមត្រូវ នៅក្បែរផ្លូវជាលំដាប់ ចូរអ្នកសួររកអាស្រមខ្ញុំនឹងឥសីទាំងនោះចុះ ឥសីទាំងនោះនឹងនាំអ្នកទៅឯសំណាក់ខ្ញុំ ( មិនខាន ) ។

[ ១៧ ] ( ពោធិសត្វជាបិតាសួរថា ) ឧសក៏អ្នកមិនពុះ ទឹកក៏អ្នកមិនដងទាំងភ្លើងក៏អ្នកមិនបង្កាត់ ហេតុអ្វីបានជាអ្នកជ្រប់ស្រពោន ។ ម្នាលកូនសព្រហ្មចារី ឧសទាំងឡាយអ្នកធ្លាប់តែពុះ ភ្លើងអ្នកធ្លាប់តែបង្កាត់ ទាំងភ្លើងសម្រាប់អាំងក៏អ្នកធ្លាប់ចាត់ចែង តាំងក៏អ្នកធ្លាប់រៀបចំសម្រាប់អញ ទឹកក៏អ្នកធ្លាប់តែតម្កល់ទុកសម្រាប់អញ កាលពីមុនអ្នកជាមនុស្សប្រសើរ តែងរីករាយ ( ក្នុងអាស្រមនេះ ) ។ ( ឥឡូវនេះ ) អ្នកមិនពុះឧស មិនដងទឹក មិនបង្កាត់ភ្លើង មិនស្ងោរវត្ថុសម្រាប់បរិភោគ នៃកូនរបស់អញ ថ្ងៃនេះអ្នកមិនហៅរកអញ អ្នកបាត់របស់អ្វីឬ ឬក៏អ្នកកើតទុក្ខក្នុងចិត្តដូចម្តេច ។

[ ១៨ ] ( ឥសិសិង្គៈ... ) ជដិលជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរមកក្នុងទីនេះ ជាមនុស្សគួរគយគន់ មានដងខ្លួនទ្រទេសទ្រទន់ មិនខ្ពស់ពេក មិនទាបពេក ញុំាងអាស្រមបទឲ្យភ្លឺស្វាយពាសពេញដោយសក់ទាំងឡាយដែលខ្មៅស្រិល ដូចជាពណ៌នៃស្លាបកន្លង់របស់ជដិលដ៏ចម្រើន ( នោះ ) ។ ( ជដិលនោះ ) មិនទាន់ដុះពុកមាត់នៅឡើយទេ ទើបនឹងបួសថ្មីៗ មានទាំងរបស់មានសណ្ឋានដូចជើងបាត្រ ពាក់ត្រង់ករបស់គាត់ មានពកពីរជាគូភ្លឺបំព្រង ដូចជាផ្លែទន្លាប់មាស ដុះក្បៀល្អត្រង់ទ្រូង ។ មុខជដិលនោះ គួរគយ

គន់ក្រៃពេក មានកំពូលនៃគ្រឿងប្រដាប់ត្រចៀកទាំងឡាយសំយុងចុះ ព្ធដ៏ត្រចៀកទាំងឡាយ កាលមាណព ( នោះ ) ត្រាច់ទៅ គ្រឿងប្រដាប់នៃត្រចៀកទាំងនោះ ក៏រុងរឿងផ្លេកៗផង មានទាំងខ្សែស្រយ រុំព័ទ្ធផ្នួងសក់ទាំងឡាយផង ។ មាណពនោះ មានគ្រឿងប្រដាប់ដទៃទៀត មានពន្ធ៌ ៤ ពណ៌ គឺពណ៌ខៀវ លឿង ប្រហម ស កាលបើមាណព ( នោះ ) ដើរទៅ គ្រឿងប្រដាប់ទាំងនោះញ័រ ដូចជាពួកនៃសត្វមេភ្លៀង ក្នុងពេលកំពុងភ្លៀង ។ ( មាណពនោះ ) មិនពាក់សង្វារស្មៅយាប្លង់ទេ មិនប្រើប្រាស់សំពត់សម្បកឈើទេ មិនប្រើប្រាស់សំពត់ ដែលត្បាញដោយស្មៅជំណោកទន្សាយទេ គ្រឿងប្រដាប់ទាំងនោះ ជាប់នៅត្រង់ចន្លោះនៃស្តន ភ្លឺដូចជាផ្លេកបន្ទោរ ដែលចាំងព្ធដ៏អាកាស ។ ( មាណពនោះមានគ្រឿងប្រដាប់ដេរដោយសូត្រ ) មិនមានស្នាមគ្រោតគ្រាតផង មិនមានទង ( អាចម៍ជង្គង់ ) ផង ចងព័ទ្ធត្រង់ចង្កេះពីត្រឹមផ្ចិតចុះទៅខាងក្រោម គ្រឿងប្រដាប់ទាំងនោះ ទុកជាឥតមានអ្វីប៉ះពាល់សោះ ក៏ធ្វើនូវល្បែងជានិច្ច គឺញ័ររវិចជាប្រក្រតី បពិត្របិតាដ៏ចម្រើន គ្រឿងប្រដាប់ទាំងនោះឈ្មោះថា ផ្លែឈើអ្វី ។ ផ្នួងសក់របស់មាណពនោះ ក៏គួរឲ្យចង់មើលក្រៃពេក ( បើមើល ) ជាងមួយរយដង ( ក៏មិនអស់ចិត្ត ) មានចុងងខ្វង់ មានក្លិនក្រអូប ( មាណពនោះ ) មានសក់ក្បាលញែកជាពីរ សិតញែកស្អាតបាត ធ្វើដូចម្តេចហ្ន៎ នឹងបានឲ្យផ្នួងសក់របស់ខ្ញុំល្អដូច្នោះផង ។ មាណពនោះ រំសាយសក់ក្នុងកាលណា ផ្នួងសក់ទាំងឡាយនោះ ក៏ប្រកបដោយពណ៌ ដោយក្លិនក្នុងកាលនោះ អាស្រមនេះក៏ផ្សព្វផ្សាយទៅ ( ដោយ

ក្លិន ) ដូចជាផ្កាឧប្បលខៀវដែលខ្យល់បក់ត្រូវដូច្នោះ ។ សម្បុររបស់មាណព នោះ គួរឲ្យចង់មើលក្រៃពេក កាយរបស់មាណពនោះ មិនដូចជាកាយរបស់ខ្ញុំឡើយ កាយរបស់មាណពនោះ កាលបើត្រូវខ្យល់បក់មក ផ្សព្វ-ផ្សាយក្លិន ដូចជាព្រៃឈើដែលមានផ្ការីកស្គុសស្គាយ ក្នុងខាងចុងនៃគិម្ហរដូវ ។ មាណពនោះ តែងទះនូវផ្លែឈើ មានសភាពដ៏វិចិត្រល្អរុងរឿង គួរឲ្យចង់មើល បោះទៅលើផែនដី ផ្លែឈើនោះរមែងត្រឡប់មករកដៃរបស់មាណពនោះវិញ បពិត្របិតាដ៏ចម្រើន នោះជាផ្លែឈើអ្វី ។ ធ្មេញទាំងឡាយរបស់មាណពនោះ ក៏គួរឲ្យចង់មើលក្រៃពេក ស្អាតស្មើដូចជាស័ង្ខ ដែលគេខាត់យ៉ាងសំខាន់ កាលដែលគាត់ហាមាត់ឡើង តែងញុំាងចិត្តឲ្យជ្រះថ្លា ដ្បិតមាណពនោះ មិនទំពាស៊ីនូវបន្លែដោយធ្មេញទាំងឡាយនោះទេ ។ សំដីរបស់មាណពនោះ និយាយឡើងមិនមានសំដីអាក្រក់ មិនក្លាត់ ពីរោះ ស្រទន់ត្រង់ៗ មិនរាយមាយ មិនព្រកោកកាក ជាសំដីញុំាងចិត្តឲ្យរីករាយ គួរចាប់ចិត្តដូចជាសំឡេងនៃសត្វករវិកយាសយំ ចិត្តរបស់ខ្ញុំត្រេកអរខ្លាំងណាស់ ។ ( មាណពនោះ ) មានសំឡេងមូល មានពាក្យមិនសូវក្បោះក្បាយពេកទេ មិនមែនជាអ្នកខ្វល់ខ្វាយក្នុងការស្វាធ្យាយ ( មន្ត ) ដោយពិត ខ្ញុំចង់ឃើញមាណពនោះម្តងទៀត ដ្បិតមាណព ( នោះ ) ជាមិត្តរបស់ខ្ញុំតាំងពីមុនដំបូងមក ។ ដំបៅ ( ត្រង់ចន្លោះភ្លៅរបស់មាណពនោះ ) ជិតស្និទ្ធល្អរលីងស្អាត សព្វអន្លើ ក្រាស់ ក្បុំល្អដូចជាផ្កាឈូកក្រពុំ មាណព ( នោះ ) គ្របសង្កត់ខ្ញុំ ដោយដំបៅនោះឯង សើយភ្លៅហើយ គាបខ្ញុំដោយស្មង ។ ( រស្មី

ដូចមាសដែលផ្សាយចេញអំពីសរីរកាយនៃមាណពនោះ ) ភ្លឺត្រចះត្រចង់ ភ្លឺស្វាងរុងរឿង ភ្លឺផ្លេកៗ ដូចជាផ្លេកបន្ទោរធ្លៀលធ្លាត់លើអាកាស ដើមដៃទាំង ២ ទន់ភ្លន់ មានរោមប្រហែលកេសរផ្កាអញ្ចាន់ មាណពនោះ មានម្រាមដៃមូលៗ ដ៏វិចិត្រល្អ ។ ម្យ៉ាងទៀត ( មាណពនោះ ) មានអវយវៈតូចធំមិនរជិបរជុប ( ដោយមុននឹងបួសជាដើម ) ទេ មានរោមមិនវែងពេកទេ ឯក្រចករបស់មាណពនោះវែងៗ មានចុងក្រហមៗ ( មាណពនោះ ) មានរូបល្អ ឱបរឹត ( ខ្ញុំ ) ដោយដើមដៃទាំងពីរដ៏ទន់ល្វន់ ( ផ្គាប់ផ្គួន ) ( ខ្ញុំ ) ឲ្យរីករាយ ។ ដៃទាំងពីររបស់មាណពនោះ ដូចជាប៉ុយឈើ មានរស្មីផ្លេកៗ មានបាតដៃមូល និងធវីវណ្ណស្រស់បំព្រង ដូចផ្ទៃកញ្ចក់ជាវិការៈនៃមាស មាណពនោះពាល់ខ្ញុំដោយដៃទាំងពីរនោះហើយ ទៅពីទីនេះទៅ បពិត្របិតា មាណពនោះ ដុតរោលខ្ញុំ ( ឲ្យក្តៅក្រហាយ ) ដោយសម្ផស្សនៃដៃនោះ ។ មាណពនោះប្រហែលជាមិនដែលនាំទៅនូវវត្ថុមានទម្ងន់ មួយខារី ( មួយអម្រែក ) ទេ មាណពនោះ មិនដែលពុះឧសទាំងឡាយខ្លួនឯងទេ មាណពនោះ មិនដែលកាប់ឈើទាំងឡាយដោយកាំបិតទេ បានជាដៃរបស់មាណពនោះ មិនក្រិនសោះ ។ មានខ្លាឃ្មុំមួយធ្វើមាណពនោះឲ្យមានដំបៅ គេបាននិយាយនឹងខ្ញុំថា សូមឲ្យអ្នកធ្វើខ្ញុំឲ្យបានសេចក្តីសុខស្រួល ខ្ញុំក៏បានធ្វើគាត់ឲ្យបានសុខស្រួល ដោយអវយវៈដ៏ឧត្តមនោះរបស់ខ្ញុំ បពិត្របិតាដ៏ប្រសើរ មាណពនោះបាននិយាយប្រាប់ខ្ញុំថា ខ្ញុំបានសេចក្តីសុខស្រួលហើយ ។ នេះកម្រាលនៃស្លឹកឈើទាល មានសភាពរាត់រាយ ដែលខ្ញុំនឹងគេដេក ប្រគៀក

ប្រឱបលើគ្នា យើងទាំងពីរនាក់នោះអស់កម្លាំង ក៏ចុះងូតទឹក ហើយចូលទៅកាន់បណ្ណកុដិរៀងៗ ។ បពិត្របិតា ខ្ញុំមិនបានជួបនឹងព្រហ្មចារីនោះ ដរាបណា មន្តទាំងឡាយមិនជាក់ច្បាស់ដល់ខ្ញុំ ក្នុងថ្ងៃនេះផង ខ្ញុំមិនពេញចិត្តនឹងការបូជាភ្លើងផង មិនពេញចិត្តនឹងការបូជាយញ្ញផង ទាំងមិនបរិភោគមើមឈើនិងផ្លែឈើរបស់លោកផង ដរាបនោះ ។ បពិត្របិតា ចំណែកលោកជ្រាបច្បាស់ប្រាកដ ព្រហ្មចារី ( នោះ ) នៅក្នុងទិសណា បពិត្របិតា សូមលោកជូនខ្ញុំទៅឲ្យដល់ទិសនោះយ៉ាងឆាប់ កុំឲ្យខ្ញុំស្លាប់ក្នុងអាស្រមរបស់លោកឡើយ ដ្បិតខ្ញុំបានឮថា ព្រៃ ( ជាទីនៅនៃព្រហ្មចារីនោះ ) មានផ្ការីកស្គុសស្គាយដ៏វិចិត្រ ហើយជាទីគឹកកងដោយបក្សី ជាទីដែលពួកបក្សីនៅអាស្រ័យ ( ជានិច្ច ) បពិត្របិតា សូមលោកជូនខ្ញុំទៅឲ្យដល់ព្រៃនោះឆាប់ៗ មុនខ្ញុំនឹងលះជីវិតក្នុងអាស្រមរបស់លោក ។

[ ១៩ ] ( ព្រះមហាសត្វ... ) សេចក្តីពិតថា បុគ្គលមិនគួរដល់នូវសេចក្តីអជ្ញុកបែបនេះ ក្នុងព្រៃដែលរុងរឿងដោយពន្លឺ ជាទីគឹកកងដោយពួកគន្ធព្វនិងស្រីទេពអប្សរ ជាទីនៅនៃឥសីទាំងឡាយ ជាព្រៃមានតាំងពីយូរយារណាស់ហើយនេះឡើយ ។ មិត្តទាំងឡាយមានខ្លះ មិនមានខ្លះ ជនទាំងឡាយគួរធ្វើនូវសេចក្តីស្រឡាញ់ចំពោះញាតិនិងមិត្ត មនុស្សណាមិនដឹងថា អាត្មាអញកើតមកពីណា មនុស្សនេះគម្រក់ ត្រូវមាតុគ្រាមបង្វឹកបានទាំងថ្ងៃ ដោយហេតុអ្វី ។ ធម្មតាមិត្តទាំងឡាយ រមែងជាប់តគ្នាដោយការនៅរួមរៀយ ៗ មិត្តនោះឯង រមែងលាកចិត្តដោយការមិនបាននៅរួមគ្នារបស់បុរសដែលមិន

បានទៅមករកគ្នា ។ បើអ្នកឃើញនូវព្រហ្មចារី ( នោះទៀត ) បើអ្នកចរចាជាមួយនឹងព្រហ្មចារី ( នោះទៀត ) អ្នកនឹងបំផ្លាញនូវតបោគុណនេះយ៉ាងឆាប់មិនខាន ដូចជាសន្ទូងដ៏ល្អបរិបូណ៌ ដែលទឹកធំបំផ្លាញដូច្នោះ ។ បើអ្នកនឹងឃើញនូវព្រហ្មចារី ( នោះ ) ទៀត បើអ្នកចរចាជាមួយនឹងព្រហ្មចារី ( នោះ ) ទៀត អ្នកនឹងបំផ្លាញនូវតេជះរបស់សមណៈនេះ យ៉ាងឆាប់មិនខាន ដូចជាសន្ទូងល្អបរិបូណ៌ ដែលទឹកធំបំផ្លាញដូច្នោះ ។ នែកូន ភូតទាំងឡាយនេះតែងត្រាច់ទៅក្នុងមនុស្សលោក ដោយបែបភាពនៃរូបផ្សេងៗ ជនអ្នកមានប្រាជ្ញា មិនត្រូវគប់រកនឹងភូតទាំងឡាយនោះឡើយ បុគ្គលជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ តែងវិនាសទៅ ( ព្រោះដល់ ) នូវការជាប់ជំពាក់ ( នឹងភូតបែបនោះឯង ) ។

**ចប់ នឡិនិកាជាតកទី ១ ។**

# ជាតកដ្ឋកថា

# អដ្ឋកថា ជាតក

# បញ្ញាសនិបាត

## នឡិនិកាជាតក

[ ១-១៩ ] *ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធដល់ការលួងលោមរបស់បុរាណទុតិយិកា ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **ឧទ្ធយ្ហតេ ជនបទោ** *ដូច្នេះជាដើម ។*

*ព្រះសាស្តា កាលត្រាស់សួរភិក្ខុនោះថា អ្នកត្រូវអ្នកណាធ្វើឲ្យអផ្សុក កាលភិក្ខុនោះក្រាបទូលថា ត្រូវកិរិយាចាស់ជាអ្នកធ្វើឲ្យអផ្សុកដូច្នេះ ទើបត្រាស់ថា ម្នាលភិក្ខុ ស្រីនេះឯងជាអ្នកធ្វើសេចក្តីវិនាសដល់អ្នកតែក្នុងកាលឥឡូវនេះក៏មិនមែន សូម្បីក្នុងកាលមុន អ្នកអាស្រ័យស្រីនេះហើយ សាបសូន្យចាកឈាន ដល់នូវសេចក្តីវិនាសយ៉ាងធំ ដូច្នេះ ទើបទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅនេះថា*

*ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ ក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណមហាសាល ឈ្មោះថាឧទិច្ចៈ ។ លុះចម្រើនវ័យហើយ បានសិក្សាសិប្បៈរហូតចប់ បួសជាឥសី ធ្វើឈាននិងអភិញ្ញាឲ្យកើតឡើងហើយ សម្រេចការនៅអាស្រ័យ ក្នុងហិមវន្តប្បទេស ។ ព្រោះអាស្រ័យហេតុនោះដោយន័យដូចពោលមកហើយក្នុងអាលម្ពុសា*

ជាតកនោះឯង ។ ម្រឹគញីមួយក៏ផើមហើយកើតកូន ។ កូនម្រឹគនោះ បាន ឈ្មោះថាឥសិសិង្គៈ ។ អំណឹះតមក បិតាឲ្យចម្រើនវ័យហើយ បួសសិក្សា នូវការបរិកម្មកសិណ មិនយូរប៉ុន្មាន ក៏ធ្វើឈាននិងអភិញ្ញាឲ្យកើតឡើងបាន ទើបនៅដោយសុខដែលកើតអំពីឈាន ជាអ្នកមានតបៈខ្លាំងក្លា មានតបៈដ៏ កំពូល មានឥន្ទ្រិយឈ្នះដ៏ក្រៃលែង ។ ព្រោះតេជះនៃសីលរបស់តាបសនោះ ភពសក្កទេវរាជក៏ញាប់ញ័រ ។ ទ្រង់ពិចារណាមើល ក៏ដឹងដល់ហេតុ គិតថា យើងនឹងប្រើឧបាយទម្លាយសីលរបស់តាបសនេះ ទើបឃាត់ភ្លៀងមិនឲ្យធ្លាក់ ក្នុងកាសិករដ្ឋទាំងមូលអស់ ៣ ឆ្នាំ ក្នុងដែនហាក់បីដូចត្រូវភ្លើងដុតហើយ ។ កាលសន្ទូងមិនសម្បូរ ពួកមនុស្សត្រូវទុព្ភិក្ខភ័យបៀតបៀន ទើបមកប្រជុំគ្នា ត្រង់លានព្រះរាជវាំង ។ សម័យនោះ ព្រះរាជាប្រថាប់ឈរ ត្រង់មាត់បង្អួច ត្រាស់សួរមនុស្សទាំងនោះថា នុ៎ះជាអ្វី ពួកមនុស្សដែលបានទទួលនូវសេច ក្ដីទុក្ខនាំគ្នាក្រាបទូលថា បពិត្រមហារាជ ភ្លៀងមិនធ្លាក់អស់ ៣ ឆ្នាំ ដែនទាំង មូលក៏ក្ដៅ ពួកមនុស្សក៏លំបាក បពិត្រព្រះសម្មតិទេព សូមទ្រង់ឲ្យភ្លៀង ធ្លាក់ចុះ ។ ព្រះរាជាទោះបីសមាទានសីល រក្សាឧបោសថ ក៏ទ្រង់មិនអាច ឲ្យភ្លៀងធ្លាក់មកបាន ក្នុងកាលនោះ សក្កទេវរាជទ្រង់ចូលទៅកាន់បន្ទប់ដែល ប្រកបដោយសិរីរបស់ព្រះរាជាអង្គនោះ ក្នុងពេលកណ្ដាលយប់ ទ្រង់ធ្វើពន្លឺ ហើយ បានប្រថាប់ឈរកណ្ដាលអាកាស ។ ព្រះរាជាទតឃើញពន្លឺនោះ ហើយ ត្រាស់សួរថា អ្នកជានរណា សក្កៈឆ្លើយថា យើងជាសក្កៈ ។ ព្រះ រាជាត្រាស់សួរថា ទ្រង់យាងមកបំណងដូចម្ដេច សក្កទេវរាជត្រាស់ថា បពិត្រ

មហារាជ ភ្លៀងក្នុងដែនរបស់ទ្រង់ធ្លាក់ខ្វះដែរឬទេ ព្រះរាជាត្រាស់ថា មិនធ្លាក់ឡើយ សក្កៈត្រាស់សួរថា ទ្រង់ជ្រាបហេតុដែលភ្លៀងមិនធ្លាក់ដែរឬទេ ព្រះរាជាត្រាស់ថា មិនជ្រាបឡើយ ។ ទើបសក្កទេវរាជត្រាស់ចង្អុលបង្ហាញថា មហារាជ ក្នុងហិមវន្តប្បទេស មានតាបសឈ្មោះថា ឥសិសិង្គៈ នៅអាស្រ័យ តាបសនោះមានតបៈខ្លាំងក្លា មានឥន្ទ្រិយឈ្នះល្អក្រៃលែង កាលភ្លៀងធ្លាក់មកជានិច្ច តាបសក្រោធ ហើយសម្លឹងមើលអាកាស ព្រោះហេតុនោះទើបភ្លៀងមិនធ្លាក់ ព្រះរាជាត្រាស់សួរថា ឥឡូវនេះ ក្នុងរឿងនេះ តើធ្វើដូចម្តេចល្អ សក្កៈក៏ត្រាស់ថា បើទម្លាយតបៈរបស់តាបសនោះបាន ភ្លៀងក៏នឹងធ្លាក់ ។ ព្រះរាជាត្រាស់សួរថា បុគ្គលណាអាចទម្លាយតបៈរបស់តាបសនោះបាន សក្កទេវរាជត្រាស់ថា មហារាជ ព្រះរាជធីតាព្រះនាមថា និឡិនិកា របស់ទ្រង់នេះឯង ជាអ្នកអាច សូមទ្រង់ឲ្យមនុស្សហៅនាងមក ហើយត្រាស់ថា ចូរបុត្រីទៅកាន់ទីឈ្មោះនោះ ហើយទម្លាយតបៈរបស់តាបសឲ្យបាន សក្កទេវរាជទូន្មានព្រះរាជាយ៉ាងនោះហើយ ក៏ទៅកាន់លំនៅរបស់ទ្រង់វិញ ។ ក្នុងថ្ងៃស្អែកឡើង ព្រះរាជាទ្រង់ប្រឹក្សាជាមួយពួកអាមាត្យ ហើយត្រាស់ឲ្យហៅព្រះរាជធីតាមក ហើយត្រាស់ព្រះគាថាដំបូងថា

ម្នាលនាងនិឡិនិកា ជនបទក្តៅស្ងួត ទាំងដែនក៏វិនាស ចូរនាង
មក ចូរនាងទៅញុំាងព្រាហ្មណ៍ ( អ្នកធ្វើនូវសេចក្តីវិនាស )
ដល់អញនោះ ឲ្យមកលុះអំណាចរបស់ខ្លួន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥំ មេ** សេចក្តីថា ចូរនាំព្រាហ្មណ៍ដែលធ្វើ

សេចក្ដីវិនាសឲ្យដល់យើងនោះមកទុកក្នុងអំណាចរបស់ខ្លួន គឺចូរធ្វើសីលរបស់តាបសនោះ ដោយវិធីឲ្យត្រេកអរក្នុងកិលេសចុះ ។ ព្រះរាជធីតាស្ដាប់គាថានោះហើយ បានត្រាស់គាថាទី ២ ថា

បពិត្រព្រះរាជា ខ្ញុំម្ចាស់អត់ទ្រាំ សេចក្ដីលំបាកពុំបាន ខ្ញុំម្ចាស់
មិនស្គាល់ផ្លូវឆ្ងាយ ខ្ញុំម្ចាស់នឹងទៅកាន់ព្រៃ ដែលមានដំរីនៅ
អាស្រ័យ ដូចម្ដេចបាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ទុក្ខក្ខមា** សេចក្ដីថា បពិត្រមហារាជ ខ្ញុំម្ចាស់ជាអ្នកអត់ធន់សេចក្ដីទុក្ខមិនបាន ទាំងខ្ញុំម្ចាស់ក៏មិនស្គាល់ផ្លូវ ខ្ញុំម្ចាស់នោះនឹងទៅបានដូចម្ដេច ។ លំដាប់នោះ ព្រះរាជាបានត្រាស់គាថា ២ ថា

ម្នាលនាងនឡិនិកា នាងចូរទៅកាន់ជនបទដ៏ស្តុកស្តម្ភ ហើយ
ទៅដោយដំរីផង ដោយរថផង ដោយយាន ( ទូក ) ដែល
គេគាបដោយឈើផង យ៉ាងនេះចុះ ។ ម្នាលខត្តិយានី ចូរ
នាងយកដំរី សេះ រថ នឹងពលថ្មើរជើងទៅចុះ ចូរនាងនាំ
ព្រាហ្មណ៍ ឥសិសិង្គៈនោះមកកាន់អំណាច ( ខ្លួន ) ដោយ
សម្បុរនឹងរូបឆោមរបស់នាង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ទារុសង្ឃាដយានេន** សេចក្ដីថា នៃនាងនឡិនិកា នាងមិនចាំបាច់ដើរទៅទេ តែនាងទៅកាន់ជនបទដ៏ចម្រើន មានកិច្ចារកបានងាយ ដែលក្រុមរបស់ខ្លួន ដោយពាហនៈដំរី ដោយអាហនៈរថទាំងឡាយ ហើយបន្ទាប់អំពីនោះ ទៅក្នុងទីស្រទ្បះចូលទៅដោយយាន ដែល

បិទបាំងហើយជាដើម ក្នុងផ្លូវទឹក ចូរទៅដោយទូកនិងក្បូន ដោយយានដែលធ្វើដោយឈើចុះ ។ បទថា **វណ្ណារូបេន** សេចក្តីថា នាងមិនចាំបាច់លំបាកយ៉ាងនោះ លុះទៅហើយ នឹងនាំព្រាហ្មណ៍នោះមកកាន់អំណាចរបស់ខ្លួន បានដោយពណ៌សម្បុរ និងរូបសម្បត្តិរបស់នាង ។ ព្រះរាជាអង្គនោះ ត្រាស់ព្រះតម្រាស់ដែលមិនគួរត្រាស់ ជាមួយព្រះរាជធីតាយ៉ាងនេះ ក៏ព្រោះអាស្រ័យការរក្សាដែន ។ ព្រះរាជធីតានោះ ក៏ទូលស្នងថា សាធុ ។ លំដាប់នោះ ព្រះរាជាទ្រង់បានព្រះរាជទានវត្ថុដែលគួរព្រះរាជទានទាំងអស់ ដល់ព្រះរាជធីតាហើយ ទ្រង់បញ្ជូនព្រះរាជធីតាទៅជាមួយពួកអាមាត្យ ។ អាមាត្យទាំងឡាយ នាំព្រះរាជធីតាទៅដល់បច្ចន្តជនបទ ហើយឲ្យបោះព្រះពន្លា ក្នុងជនបទនោះ ឲ្យលើកព្រះរាជធីតាឡើង ហើយចូលទៅកាន់ហិមវន្តប្បទេស ដោយផ្លូវដែលព្រានចង្អុលប្រាប់ ក្នុងពេលព្រឹក ក៏ដល់ទីជិតអាស្រមបទនៃតាបសនោះ ។

ក្នុងខណៈនោះ ព្រះពោធិសត្វឲ្យបុត្តយាមត្រង់អាស្រមបទ ខ្លួនឯងចូលទៅកាន់ព្រៃ ដើម្បីរកផ្លែឈើតូចធំ ។ ពួកព្រានព្រៃមិនទៅកាន់អាស្រមបទឯង តែឈរក្នុងទីល្មមមើលឃើញអាស្រមបទនោះ កាលនឹងប្រាប់លំនៅដល់នាងនឡិនិកា ទើបពោលគាថា ២ ថា

នុ៎ះ ប្រាកដជាអាស្រមរបស់តាបសឈ្មោះឥសិសិង្គៈ ជាទីគួររីករាយ មានដើមចេកជាទង់ ជាគ្រឿងសម្គាល់ មានដើមស្នាច់ដុះព័ទ្ធជុំវិញ ។ នុ៎ះភ្លើងដែលឥសិសិង្គៈនោះ តាក់តែង

( ដោយឈាន ) នុ៎ះផ្សែងដែលឃើញប្រាកដ ខ្ញុំសម្គាល់ថា ឥសិសិង្គៈ អ្នកមានឫទ្ធិច្រើន មិនញុំាងភ្លើងឲ្យសាបសូន្យទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កណ្ហវត្តនីបញ្ញាណោ** មានវិគ្គហៈថា ឈ្មោះថា **កណ្ហវត្តនីបញ្ញាណោ** ព្រោះអត្ថថា មានទង់គឺដើមចេកប្រាកដ ។ បទថា **អាកុលិបរិវារិតោ** បានដល់ ឡោមព័ទ្ធដោយព្រៃស្មាច់ ។ បទថា **សង្ខាតោ** សេចក្ដីថា នុ៎ះគឺពន្លឺភ្លើងដែលឥសិសិង្គតាបសនោះតាក់តែងដោយឈានទៅឆេះប្រេចក្បេទៅឡើយ ។ បទថា **មញ្ញេ នោ អគ្គិ** សេចក្ដីថា យើងរមែងសម្គាល់ថា ឥសិសិង្គតាបស មិនធ្វើភ្លើងឲ្យវិនាស គឺឲ្យឆេះហើយបម្រើ ។

ឯពួកអាមាត្យ នាំគ្នាចោមរោមអាស្រម ក្នុងពេលដែលព្រះពោធិសត្វចូលទៅកាន់ព្រៃមួយរំពេច នាំគ្នាតាំងកងទ័ពរក្សា ឲ្យព្រះរាជធីតាកាន់យកគេទជាឥសី យកសំពត់សម្បកឈើពណ៌មាសស្តើងធ្វើជាសំពត់ដណ្ដប់ ប្រដាប់ដោយគ្រឿងអលង្ការសព្វយ៉ាង ឲ្យព្រះរាជធីតាកាន់យកវូ ដែលវិចិត្រដោយខ្សែអំបោះចូលទៅកាន់អាស្រមបទ ខ្លួនឯងឈររក្សាខាងក្រៅ ។ ព្រះរាជធីតានោះលេងវូនោះបណ្ដើរ ក៏ហួសដល់ចុងទីចង្ក្រម ។ ក្នុងខណៈនោះ ឥសិសិង្គតាបសកំពុងអង្គុយលើផ្ទាំងថ្ម ជិតទ្វារបណ្ណសាលា ។ តាបសឃើញស្រីនោះកំពុងដើរមក ភិតភ័យ ក្រោកឡើង ហើយចូលទៅកាន់បណ្ណសាលាឈប់ហើយឈរ ។ ព្រះរាជធីតានោះ ចូលទៅកាន់ទ្វារបណ្ណសាលារបស់តាបសនោះហើយ ក៏លេងវូបន្តទៅទៀត ។

ព្រះសាស្តា កាលប្រកាសសេចក្តីនោះឲ្យក្រៃលែងជាងនេះ ទើបត្រាស់គាថា ៣ ថា

ឥសិសិង្គៈ បានឃើញនាងនឡិនិកានោះ ពាក់កុណ្ឌលកែវមណីកំពុងដើរមក ក៏ភិតភ័យ ចូលទៅកាន់អាស្រមដែលប្រក់ដោយស្លឹក ។ ឯនាងនឡិនិកានោះ ក៏បង្ហាញនូវអវយវៈទាំងឡាយផង បញ្ចេញនូវគ្រឿងខ្មាសដ៏កំបាំងផង ហើយលេងកូនឃ្លីក្បែរទ្វារអាស្រមនៃឥសិសិង្គៈនោះ ។

អ្នកមានជដា ( ឥសិសិង្គៈ ) នៅក្នុងបណ្ណសាលា ឃើញនាងនឡិនិកានោះកំពុងលេង ចេញអំពីអាស្រមមក និយាយពាក្យនេះថា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **គេណ្ឌុកេនស្ស** សេចក្តីថា លេងវូត្រង់ទ្វារអាស្រមរបស់ឥសិសិង្គតាបសនោះ ។ បទថា **វិធំសយន្តី** បានដល់ បង្ហាញ ។ បទថា **គុយ្ហំ បកាសិតានិ ច** បានដល់ អវយវៈដែលកំបាំង និងអវយវៈដែលមិនកំបាំង មានមុខ និងដៃជាដើម ។ បទថា **ព្រាវិ** សេចក្តីថា បានឮថាតាបសនោះឈរក្នុងបណ្ណសាលា ហើយគិតថា បើបុរសនេះជាយក្ខសោតគប្បីចូលមកកាន់បណ្ណសាលា រួចហែកសាច់អញស៊ី បុរសនេះប្រហែលជាមិនមែនយក្ខ គង់ជាតាបសពិត ។

ព្រោះហេតុនោះ ឥសិសិង្គតាបសក៏ចេញអំពីអាស្រម ហើយពោលពាក្យនេះថា

ម្នាលអ្នកដ៏ចម្រើន ឈើរបស់អ្នកនោះ ឈ្មោះអ្វី ដែលមាន
ផ្លែបែបនេះ សូម្បីអ្នកបោះទៅក្នុងទីឆ្ងាយ ហើយក៏វិលត្រឡប់
មកវិញ មិនទៅចោលអ្នក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យស្ស តេវំ គតំ** សេចក្ដីថា ដើមឈើប្រភេទណារបស់អ្នក មានផ្លែ គួរចាប់ចិត្ត ប្រព្រឹត្តទៅយ៉ាងនេះ ។ បទថា **កោ ឆាម សោ រុក្ខោ** បានដល់ តាបសសម្គាល់ថា វូនោះជាផ្លែឈើ ព្រោះវូដ៏វិចិត្រ ខ្លួនមិនធ្លាប់ឃើញក្នុងកាលមុន ទើបសួរយ៉ាងនោះ ។

លំដាប់នោះ ព្រះរាជធីតានោះ កាលប្រាប់ ទើបត្រាស់គាថាដល់តាបសនោះថា

បពិត្រតាបសដ៏ប្រសើរ ផ្លែបែបនេះនៃឈើណា សូម្បីខ្ញុំបោះ
ទៅក្នុងទីឆ្ងាយក៏ត្រឡប់មកវិញ មិនទៅចោលខ្ញុំទេ ឈើបែប
នោះ មានក្នុងទីជិតអាស្រមនៃខ្ញុំ នាភ្នំគន្ធមាទន៍ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សមីបេ គន្ធមាទនេ** បានដល់ ក្នុងទីជិតអាស្រមរបស់ខ្ញុំ ត្រង់ភ្នំគន្ធមាទន៍ ។ បទថា **យស្ស តេវំ គតំ** បានដល់ ដើមឈើដែលមានផ្លែយ៉ាងនេះ ។ **ត** អក្ខរៈ គ្រាន់តែធ្វើការភ្ជាប់បទព្យញ្ជនៈនោះ ព្រះរាជធីតានោះ បានពោលមុសាវាទដូច្នេះឯង ។

ឯតាបសជឿហើយ កាលធ្វើនូវការទទួលដោយសម្គាល់ថា បុរសនេះជាតាបស ទើបពោលគាថានេះថា

អ្នកដ៏ចម្រើន ចូរមកកាន់អាស្រមនេះចុះ ចូរបរិភោគអាហារ

ចុះ ចូរទទួលថ្នាំសម្រាប់លាបជើងផង ភក្សាហារផង ខ្ញុំជូន ( ដល់អ្នក ) នេះអាសនៈ អ្នកដ៏ចម្រើន ចូរអង្គុយលើអាសនៈនេះ អ្នកដ៏ចម្រើន ចូរពិសាមើមឈើនឹងផ្លែឈើក្នុងទីនេះចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អស្សមិមំ** សេចក្ដីថា អញ្ជើញអ្នកដ៏ចម្រើនចូលមកកាន់អាស្រមនេះចុះ ។ បទថា **អនេត្រុ** សេចក្ដីថា អញ្ជើញអ្នកបរិ-ភោគអាហារដែលខ្ញុំបានត្រៀមហើយចុះ ។ បទថា **បជ្ជំ** បានដល់ ប្រេងសម្រាប់លាបជើង ។ បទថា **ភក្ខំ** បានដល់ ផ្លែឈើតូចធំ ដែលមានរសឆ្ងាញ់ ។ បទថា **បដិច្ច** បានដល់ ចូរកាន់យក ។ បទថា **ឥធមាសនំ** សេចក្ដីថា តាបសពោលហើយយ៉ាងនោះ ក្នុងកាលដែលព្រះរាជធីតាចូលទៅហើយ ។

បទថា **កិរេដ្ឋ ឥធំ** សេចក្ដីថា កាលព្រះរាជធីតាអង្គនោះ ចូលទៅកាន់បណ្ណសាលា អង្គុយត្រង់ចន្លោះឈើ កាលសំពត់សម្បកឈើស្ដើងពណ៌មាសញែកជា ២ សរីរៈត្រង់ទីកំបាំងក៏ប្រាកដឡើង ។ តាបសឃើញអវយវៈក្នុងទីកំបាំងនៃសរីរៈរបស់មាតុគ្រាម ព្រោះខ្លួនមិនធ្លាប់ឃើញអំពីមុន ទើបសម្គាល់ថា ជាដំបៅ ហើយពោលយ៉ាងនេះថា

អ្វីនេះកំពុងល្អ ( ដូចមាត់ខ្យងបៀ ) នៅត្រង់ចន្លោះភ្លៅរបស់អ្នក ប្រាកដដូចជាវត្ថុមានពណ៌ខ្មៅៗ ខ្ញុំសួរហើយ អ្នកចូរប្រាប់សេចក្ដីនុ៎ះ អវយវៈដ៏ឧត្តម ( លិង្គ ) របស់អ្នក លេចចូល

ទៅក្នុងស្រោម ( សរីរៈ ) ឬ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុបិច្ចិតំ** សេចក្តីថា សណ្ឋានមុខដំបៅដែលមានសិប្បៈ ត្រូវសម្លស្សជោយល្អ ក្នុងពេលដែលភ្លៅទាំង ២ ប៉ះគ្នា ។ ពិតហើយ សរីរៈត្រង់នោះ បានក្លាយដូចជាអណ្តូង ព្រោះមិនប្រកបដោយលក្ខណៈដែលស្អាត និងមានសណ្ឋានមុខដំបៅ ដែលមានសិប្បៈប៉ុងឡើងប្រាកដច្បាស់ ព្រោះប្រកបដោយលក្ខណៈដែលស្អាត ។ បទថា **កណ្ហាវិ-វប្បកាសតិ** សេចក្តីថា ប្រាកដពណ៌ខ្មៅត្រង់សងខាង ។ បទថា **កោសេ ឆុតេ ឧត្តមង្គំ បវិដ្ឋំ** សេចក្តីថា អវយវៈចំណែកវែង គឺសណ្ឋាននៃភេទរបស់អ្នក រមែងមិនប្រាកដ គឺតាបសសួរថា អវយវៈវែងចូលទៅក្នុងស្រោម គឺសរីរៈរបស់អ្នកឬ ។

លំដាប់នោះ ព្រះរាជធីតាកាលបញ្ឆោតតាបសនោះ ទើបបានត្រាស់គាថា ២ ថា

ខ្ញុំត្រាច់ទៅកាន់ទីស្វែងរកមើមឈើ ផ្លែឈើក្នុងព្រៃ បានបោលខ្លាឃ្មុំមានរូបដ៏សម្បើម ខ្លាឃ្មុំនោះស្ទុះមកសង្គ្រុបខ្ញុំដោយរហ័ស ផ្តួលខ្ញុំហើយ ខាំដកយកអវយវៈដ៏ឧត្តមទៅ ។ ដំបៅនោះឯង ឈឺពើតផង រមាស់ផង ខ្ញុំមិនបានសេចក្តីសុខសព្វៗកាលទេ អ្នកដ៏ចម្រើន អាចនាំចេញនូវរោគរមាស់នេះចេញបាន អ្នកដ៏ចម្រើនដែលខ្ញុំអង្វរហើយ សូមធ្វើនូវប្រ-យោជន៍ដល់ព្រាហ្មណ៍ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អសាធយិ** សេចក្ដីថា ជួបខ្លាឃ្មុំកំពុងរត់មក ទើបព្យាយាមយកដុំដីគប់វា ។ បទថា **បតិត្វា** សេចក្ដីថា រត់ដេញមក ។ បទថា **សហាសជ្ឈប្បត្តោ** បានដល់ ដល់ គឺទាន់ខ្ញុំដោយរហ័ស ។ បទថា **បន្នុជ្ជ** បានដល់ ធ្វើឲ្យខ្ញុំដួលចុះហើយ ។ បទថា **អព្ពហិ** សេចក្ដីថា ខ្លាឃ្មុំប្រើមាត់ខាំអវយវៈវែងរបស់ខ្ញុំដកចេញហើយ ក៏ចៀសចេញទៅ ចាប់តាំងពីនោះមក ក្នុងទីត្រង់នេះឯង ទើបក្លាយជាដំបៅ ។ បទថា **ស្វាយំ** សេចក្ដីថា តាំងពីកាលនោះមក ទើបមុខដំបៅរបស់ខ្ញុំនេះមាស់ និងត្រូវអេះជានិច្ច ព្រោះសេចក្ដីនោះជាបច្ច័យ ខ្ញុំក៏មិនបានទទួលសេចក្ដីសុខ ទាំងផ្លូវកាយនិងផ្លូវចិត្តអស់កាលទាំងពួង ។ បទថា **បហោ** បានដល់ ជាអ្នកអាច ។ បទថា **ព្រាហ្មណាត្តំ** សេចក្ដីថា ព្រះរាជធីតាពោលថា បពិត្រលោកម្ចាស់ ខ្ញុំអង្វរហើយ សូមលោកម្ចាស់ ជួយធ្វើប្រយោជន៍នេះដល់ខ្ញុំជាព្រាហ្មណ៍ចុះ គឺសេចក្ដីទុក្ខនេះ កុំបីមានដល់ខ្ញុំ បានដល់ សូមជួយនាំទៅ ។

តាបសនោះ ជឿពាក្យមុសាវាទរបស់ព្រះរាជធីតានោះថា ជាការពិត ទើបគិតថា បើសេចក្ដីសុខយ៉ាងនេះមានដល់គេសោត អញធ្វើឲ្យ ដូច្នេះហើយ ក៏សម្លឹងមើលចំណែកត្រង់នោះ ហើយពោលគាថាបន្ទាប់ថា

ដំបៅរបស់អ្នកមានសភាពដ៏ជ្រៅ មានសម្បុរក្រហមមិនស្អុយទេ គ្រាន់តែមានក្លិនខ្មោះ ( បន្តិចៗ ) ហើយថែមទាំងធំផង ខ្ញុំនឹងប្រកបដោយថ្នាំផ្សេង លាបឲ្យអ្នកបន្តិចមើល ដើម្បីនឹងឲ្យអ្នកដ៏ចម្រើន បានសេចក្ដីសុខស្រួល ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សលោហិតោ** បានដល់ មានសាច់ពណ៌ក្រហម ។ បទថា **អប្ផុតិកោ** បានដល់ វៀរចាកសាច់ដែលស្អុយ ។ បទថា **បក្កគន្ធោ** បានដល់ មានក្លិនខ្ទោះបន្តិចបន្តួច ។ បទថា **កសាយយោគំ** សេចក្តីថា ខ្ញុំនឹងកាន់យកទឹកម្ចត់អំពីដើមឈើប្រភេទខ្លះ ធ្វើទឹកម្ចត់នោះ ប្រកបជាថ្នាំលាបដំបៅដល់អ្នក លំដាប់នោះ ទើបព្រះនាងនឡិនិកាត្រាស់គាថានេះថា

បពិត្រតាបសដ៏ប្រសើរ ការប្រកបដោយមន្តទាំងឡាយ ក៏មិនត្រូវ ការប្រកបដោយថ្នាំជុសទាំងឡាយក៏មិនត្រូវ ឱសថទាំងឡាយ ក៏មិនត្រូវ អវយវៈណារបស់លោកដ៏ទន់ៗ ចូរលោកនាំចេញនូវរោគរមាស់ដោយអវយវៈនោះ ទើបខ្ញុំមានសេចក្តីសុខស្រួល តទៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កមន្តិ** សេចក្តីថា បពិត្រអ្នកប្រព្រឹត្តព្រហ្មចរិយៈដ៏ចម្រើន ការប្រកបមន្តក្តី ការប្រកបថ្នាំក្តី ឱសថមានផ្កានិងផ្លែជាដើមក្តី រមែងព្យាបាលមិនបានឡើយ ការប្រកបមន្តជាដើមនោះ ទោះបីធ្វើច្រើនដង ក៏មិនជាផាសុកដល់ដំបៅនេះឡើយ តែបើលោកយកអង្គជាតដ៏ទន់របស់លោកនោះត្រដុសទៅមកប៉ុណ្ណោះ ការមាស់ក៏មិនប្រាកដ ព្រោះហេតុនោះ សូមលោកជួយយកអង្គជាតនោះ កម្ចាត់ការរមាស់ឲ្យខ្ញុំផងចុះ ។

តាបសនោះកំណត់ថា បុរសនោះនិយាយពិត មិនដឹងថា សីលដាច់ឈានវិនាស ដោយមេថុនសំសគ្គៈ កាលព្រះរាជធីតានោះពោលថា គេសជួ

ដូច្នេះ ព្រោះការមិនស្គាល់មេថុនធម្ម ព្រោះខ្លួនមិនធ្លាប់ឃើញមាតុគ្រាមមក អំពីមុន ទើបសេពមេថុនធម្ម ក្នុងវេលានោះសីលរបស់តាបសនោះក៏ដាច់ ឈានក៏វិនាស ។ តាបសនោះ ធ្វើការរួមសង្វាស ២-៣ ដង ក៏អស់កម្លាំង រួចចុះទៅកាន់ស្រះងូតទឹក រម្ងាប់នូវការក្រវល់ក្រវាយ ត្រឡប់មកអង្គុយត្រង់ បណ្ណសាលា តែទោះជាយ៉ាងនោះ ក៏នៅតែសម្គាល់ខ្លួនថាជាតាបសដដែល កាលសួរដល់ទីលំនៅ ទើបពោលគាថាដូច្នេះថា

តាបសរបស់អ្នកដ៏ចម្រើន នៅខាងណាអំពីទីនេះ ម្នាលអ្នក ដ៏ចម្រើន អ្នកអភិរម្យក្នុងព្រៃដែរឬ អ្នកមានមើមឈើផ្លែឈើ ច្រើនដែរឬ សត្វសាហាវទាំងឡាយមិនបៀតបៀនអ្នកដ៏ចម្រើន ទេឬ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កតមេន** បានដល់ អាស្រមរបស់អ្នក ដ៏ចម្រើននៅក្នុងទិសណាអំពីទីនេះ ។ បទថា **ភវំ** នេះ ជាអាលបនៈ ។

លំដាប់នោះ ព្រះនាងនឡិនិកាបានត្រាស់គាថា ៤ ថា

អាស្រមរបស់ខ្ញុំជាទីគួររីករាយ ( នៅ ) ក្បែរឆ្នេរនៃស្ទឹង ឈ្មោះខេមា ដែលហូរទៅអំពីព្រៃហិមវន្ត នាទិសខាងជើង ត្រង់អំពីទីនេះ ធ្វើដូចម្ដេចហ្ន៎ អ្នកដ៏ចម្រើនគប្បីឃើញអាស្រម របស់ខ្ញុំ ។ ( ទៀបអាស្រមរបស់ខ្ញុំ ) មានដើមស្វាយ រាំង ក្នុំ ទន្ទាប់ ព្រីង រាជព្រឹក្ស ប្រនៀង មានផ្កាវីកស្គុសស្គាយ ធ្វើដូចម្ដេចហ្ន៎ អ្នកដ៏ចម្រើន គប្បីឃើញអាស្រមរបស់ខ្ញុំដែល

មានកិន្នរច្រៀងពីរោះដោយជុំវិញ ។ ក្នុងទីជិតអាស្រមរបស់ខ្ញុំនុ៎ះ មានដើមត្នោតទាំងឡាយផង មើមឈើទាំងឡាយផង ផ្លៃឈើទាំងឡាយផង ធ្វើដូចម្ដេចហ្ន៎ ទើបអ្នកដ៏ចម្រើនគប្បីឃើញនូវអាស្រមរបស់ខ្ញុំ ដែលប្រកបដោយពណ៌និងក្លិន ដែលប្រកបដោយភូមិភាគទាំងឡាយ ( ដ៏រាបស្មើ ) នោះ ។ ផ្លៃឈើទាំងឡាយផង មើមឈើទាំងឡាយផង មានគរគោកក្នុងអាស្រមនេះ ប្រកបដោយពណ៌ក្លិននិងរស តែពួកព្រានព្រៃតែងមកកាន់ប្រទេសនោះ កុំឲ្យពួកវាលួចមើមឈើ និងផ្លៃឈើរបស់ខ្ញុំអំពីអាស្រមនោះឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧត្តរាយំ** បានដល់ ទិសខាងជើង ។ បទថា **ខេមា** បានដល់ ស្ទឹងដែលមានឈ្មោះយ៉ាងនោះ ។ បទថា **ហិមវន្តា បភាតិ** សេចក្ដីថា រមែងហូរមកអំពីព្រៃហិមពាន្ត ។ បទថា **អហោ** ជានិបាត ប្រើក្នុងអត្ថនៃការអង្វរ ។ បទថា **ឧទ្ទាលកា** បានដល់ ដើមឈើដែលការពារខ្យល់ ( ដើមរាជព្រឹក្ស ) ។ បទថា **កិំបុរិសាភិគីតំ** បានដល់ដែលមានពួកកិន្នរនាំគ្នាចោមរោមដោយជុំវិញ ហើយច្រៀងដោយសំឡេងពីរោះល្វេងល្វើយ ។ បទថា **តាលា ច មូលា ច ផលា ច មេត្ថ** សេចក្ដីថាដើមត្នោតដែលគួរជាទីស្រឡាញ់ មើមពោលគឺកំពីង និងផ្លៃដែលសម្បូរដោយពណ៌ និងក្លិនជាដើមរបស់ដើមឈើទាំងនោះ ត្រង់អាស្រមរបស់ខ្ញុំនោះ ។ បទថា **បហូតមេត្ថ** បានដល់ ផ្លៃច្រើនប្រភេទវល្លិនិងមើមរបស់ដើម

ឈើត្រង់អាស្រមរបស់ខ្ញុំនោះមានច្រើន ។ បទថា **មា មេ តតោ** សេចក្តីថា ព្រះរាជធីតាត្រាស់ថា ពួកព្រានជាច្រើន រមែងនាំគ្នាមកកាន់អាស្រមរបស់ខ្ញុំនោះ ឯមូលផលាហារដែលមានរសឆ្ងាញ់ជាច្រើន ដែលខ្ញុំនាំមកទុកក្នុងទីនោះក៏មាន កាលខ្ញុំរវល់តែឃឹតយូរ ពួកព្រានទាំងនោះក៏គប្បីលួចយកមូលផលាហារទៅអស់ សូមពួកព្រានកុំមកលួចមូលផលាហាររបស់ខ្ញុំទៅអំពីទីនោះឡើយ ព្រោះហេតុនោះ បើលោកមានបំណងនឹងទៅជាមួយខ្ញុំក៏សូមអញ្ជើញ បើមិនមានបំណងនឹងទៅសោត ខ្ញុំឯងនឹងទៅ ។

តាបសបានស្តាប់ដូច្នោះហើយ កាលឃាត់ព្រះរាជធីតា ទម្រាំបិតាខ្ញុំមក ទើបពោលគាថានេះថា

> បិតារបស់ខ្ញុំទៅកាន់ទីស្វែងរកមើមឈើ ផ្លែឈើ នឹងមកក្នុងកាលល្ងាច ឥឡូវនេះ ចាំបិតាមកអំពីទីស្វែងរកមើមឈើនិងផ្លែឈើសិន សឹមយើងទាំង ២ នាក់ទៅកាន់អាស្រមនោះដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧភោវ គច្ឆាមសេ** សេចក្តីថា យើងទាំង ២ នាក់ ប្រាប់ឲ្យបិតាខ្ញុំបានជ្រាបហើយ ទើបទៅបាន ។

លំដាប់នោះ ព្រះរាជធីតានោះ គិតហើយថា តាបសនេះមិនស្គាល់អញថាជាស្រី ព្រោះលោកចម្រើនធំធាត់ក្នុងព្រៃប៉ុណ្ណោះ តែបិតារបស់តាបសនេះ លុះឃើញអញក៏ស្គាល់ គង់សួរថា នាងមកធ្វើអ្វីក្នុងទីនេះ ហើយគង់យកដងរែកវាយអញ ក្បាលរបស់អញក៏នឹងបែក អញគួរចេញទៅ ក្នុង

ពេលដែលបិតារបស់តាបសនេះ មិនទាន់មកល្អជាង ឯកិច្ចនៃការមករបស់អញក៏ចប់សព្វគ្រប់ហើយ ។ ព្រះរាជធីតានោះ កាលប្រាប់ឧបាយនៃការធ្វើដំណើរទៅដល់តាបសនោះ ទើបពោលគាថាក្រៅអំពីនេះថា

> មានពួកព្រាហ្មណ៍ជាឥសី និងពួកព្រះរាជា ជាឥសីដទៃទៀតជាច្រើន ដែលជាមនុស្សត្រឹមត្រូវ នៅក្បែរផ្លូវជាលំដាប់ ចូរអ្នកសួររកអាស្រមខ្ញុំនឹងឥសីទាំងនោះចុះ ឥសីទាំងនោះនឹងនាំអ្នកទៅឯសំណាក់ខ្ញុំ ( មិនខាន ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **រាជីសយោ** សេចក្ដីថា នៃសម្លាញ់ ខ្ញុំមិនអាចរារាំងបានទេ ព្រោះពួកព្រាហ្មណឥសីនិងពួករាជឥសីដែលមានរូបស្អាតបាតដទៃ រមែងនៅក្បែរផ្លូវដោយលំដាប់ គឺនៅក្បែរផ្លូវទៅអាស្រមរបស់ខ្ញុំ ខ្ញុំប្រាប់ដល់ជនទាំងនោះហើយនឹងទៅ លោកគប្បីសួរគេទាំងនោះចុះ គេទាំងនោះនឹងនាំលោកទៅកាន់សម្នាក់របស់ខ្ញុំ ។

រាជធីតានោះ ធ្វើឧបាយសម្រាប់ខ្លួនគេចទៅយ៉ាងនោះហើយ ចេញអំពីបណ្ណសាលា ពោលនឹងតាបសដែលកំពុងសម្លឹងមើលនោះឯងថា សូមលោកត្រឡប់ទៅចុះ ហើយបានទៅកាន់សម្នាក់របស់ពួកអាមាត្យ ដោយផ្លូវដែលមកនោះឯង ។ ពួកអាមាត្យទាំងនោះ បាននាំព្រះរាជធីតានោះ ទៅកាន់ព្រះពន្លានោះឯង ហើយក៏យាងទៅដល់ក្រុងពារាណសីដោយលំដាប់ ។ ក្នុងថ្ងៃនោះឯង សក្កទេវរាជក៏ត្រេកអរ ញុំាងភ្លៀងឲ្យធ្លាក់ជោកជាំពេញព្រះនគរ ។ បន្ទាប់អំពីនោះ ជនបទក៏មានអាហារសម្បូរ ។ គ្រាន់តែព្រះរាជធីតានោះ

ត្រឡប់ទៅប៉ុណ្ណោះ ការក្តៅក្រហាយក៏កើតឡើងក្នុងរាងកាយរបស់ឥសិសិង្គតាបស ។ តាបសនោះរន្ធត់ចិត្ត ចូលទៅកាន់បណ្ណសាលាយកសំពត់សម្បកឈើដណ្តប់រាងកាយ ហើយដេកសុបសៅ ។

ក្នុងវេលាល្ងាច ព្រះពោធិសត្វត្រឡប់មកមិនឃើញកូន ទើបគិតថា កូនអញទៅទីណាហ្ន៎ ហើយដាក់អម្រែក ចូលទៅកាន់បណ្ណសាលា សម្លឹងឃើញកំពុងដេក ទើបស្ទាបខ្នងបណ្តើរសួរបណ្តើរថា នែកូន ឯងកើតអ្វី ហើយបានពោលគាថា ៣ ថា

ឧសក៏អ្នកមិនពុះ ទឹកក៏អ្នកមិនដង ទាំងភ្លើងក៏អ្នកមិនបង្កាត់ ហេតុអ្វី បានជាអ្នកជ្រប់ស្រពោន ។ ម្នាលកូនសព្រហ្មចារី ឧសទាំងឡាយអ្នកធ្លាប់តែពុះ ភ្លើងអ្នកធ្លាប់តែបង្កាត់ ទាំងភ្លើងសម្រាប់អាំងក៏អ្នកធ្លាប់ចាត់ចែង តាំងក៏អ្នកធ្លាប់រៀបចំសម្រាប់អញ ទឹកក៏អ្នកធ្លាប់តែតម្កល់ទុកសម្រាប់អញ កាលពីមុនអ្នកជាមនុស្សប្រសើរ តែងរីករាយ ( ក្នុងអាស្រមនេះ ) ។ ( ឥឡូវនេះ ) អ្នកមិនពុះឧស មិនដងទឹក មិនបង្កាត់ភ្លើង មិនស្ងោរវត្ថុសម្រាប់បរិភោគ នែកូនរបស់អញ ថ្ងៃនេះអ្នកមិនហៅរកអញ អ្នកបាត់របស់អ្វីឬ ឬក៏អ្នកកើតទុក្ខក្នុងចិត្ត ដូចម្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភិន្នានិ** បានដល់ ឧសដែលនាំមកអំពីព្រៃ អ្នកក៏មិនកាច់ ។ បទថា **ន ហាសិតោ** បានដល់ ភ្លើងក៏អ្នកមិនបង្កាត់ឲ្យ

ផេះ ។ បទថា **ភិន្នានិ** សេចក្ដីថា កាលមុន ពេលដែលអញមក ឯងក៏បាន កាច់ឧសទុកស្រេចបាច់ហើយ ។ បទថា **ហុតោ ច អគ្គិ** សេចក្ដីថា ភ្លើង សម្រាប់បូជា ឯងក៏បង្កាត់ ។ បទថា **តបនី** សេចក្ដីថា ភ្លើងសម្រាប់អាំង ឯងក៏ត្រៀមរៀបចំទុក ។ បទថា **បីឋំ** សេចក្ដីថា តាំងក្នុងលំនៅរបស់អញ ឯងក៏រៀបចំទុកហើយនោះឯង ។ បទថា **ឧទកញ្ច** សេចក្ដីថា ទឹកសម្រាប់ លាងជើង ឯងក៏តម្កល់ទុកដូចគ្នា ។ បទថា **ព្រហ្មភូតោ** សេចក្ដីថា ក្នុង ថ្ងៃដទៃ បន្ទាប់អំពីថ្ងៃនេះ ឯងជាបុគ្គលប្រសើរ ត្រេកអរក្នុងអាស្រមនេះ ។ បទថា **អភិន្នកដ្ឋោសិ** បានដល់ ថ្ងៃនេះ ឯងមិនកាច់ឧស ។ បទថា **អសិទ្ធភោជនោ** សេចក្ដីថា ត្រាវនិងដំឡូង ឬអន្ទក់ណាមួយ ដែលឯង ស្ងោរសម្រាប់អញមិនមានឡើយ ។ បទថា **មមជ្ជ** សេចក្ដីថា នៃកូន ថ្ងៃ នេះ ឯងមិនរាក់ទាក់នឹងអញឡើយ ។ បទថា **ឆដ្ឋំ នុ កឹ** នេះ ព្រះពោធិ សត្វទូលសួរតាបសថា វត្ថុណាមួយ ឯងបាត់ទៅឬ ឬឯងមានទុក្ខក្នុងចិត្ត ដូចម្ដេច ប្រញាប់ប្រាប់ហេតុនៃការដេកសុបសៅឲ្យអញដឹងខ្លះ ។

តាបសនោះស្ដាប់ពាក្យរបស់បិតាហើយ កាលពោលដល់ហេតុការណ៍ នោះឲ្យជ្រាបទើបពោលថា

> ជដិលជាអ្នកប្រព្រឹត្តធម៌ ដ៏ប្រសើរមកក្នុងទីនេះ ជាមនុស្សគួរ
> គយគន់ មានដងខ្លួនទ្រទេសទ្រទន់ មិនខ្ពស់ពេក មិនទាប
> ពេក ញុំាងអាស្រមបទឲ្យភ្លឺសាយពាសពេញដោយសក់ទាំង
> ឡាយដែលខ្មៅស្រិល ដូចជាពណ៌នៃស្វាបកន្ទង់របស់ជដិល

ដ៏ចម្រើន ( នោះ ) ។ ( ជដិលនោះ ) មិនទាន់ដុះពុក មាត់នៅឡើយទេ ទើបនឹងបួសថ្មីៗមានទាំងរបស់មានសណ្ឋាន ដូចជើងបាត្រ ពាក់ត្រង់ករបស់គាត់ មានពកពីរជាគូក្លីបំព្រង ដូចជាផ្លែទន្លាប់មាស ដុះក្បាល្អត្រង់ទ្រូង ។ មុខជដិលនោះ គួរគេយកគន់ក្រៃពេក មានកំពូលនៃគ្រឿងប្រដាប់ត្រចៀកទាំង ឡាយសំយុងចុះព្ធដ៏ត្រចៀកទាំងឡាយ កាលមាណព ( នោះ ) ត្រាច់ទៅ គ្រឿងប្រដាប់នៃត្រចៀកទាំងនោះ ក៏រុងរឿងផ្លេកៗ ផង មានទាំងខ្សែស្រយរុំព័ទ្ធផ្នួងសក់ទាំងឡាយផង ។ មាណព នោះ មានគ្រឿងប្រដាប់ដទៃទៀត មានពន្លឺ ៤ ពណ៌ គឺ ពណ៌ខៀវ លឿង ប្រហម ស កាលបើមាណព ( នោះ ) ដើរទៅ គ្រឿងប្រដាប់ទាំងនោះ ញ័រដូចជាពួកនៃសត្វមេភ្លៀង ក្នុងពេលកំពុងភ្លៀង ។ ( មាណពនោះ ) មិនពាក់សង្វារ ស្មៅយាប្លងទេ មិនប្រើប្រាស់សំពត់សម្បកឈើទេ មិនប្រើ ប្រាស់សំពត់ដែលត្បាញដោយស្មៅជំណោកទន្សាយទេ គ្រឿង ប្រដាប់ទាំងនោះ ជាប់នៅត្រង់ចន្លោះនៃស្នូង ភ្លឺដូចជាផ្លេក បន្ទោរដែលចាំងព្ធដ៏អាកាស ។ ( មាណពនោះមានគ្រឿង ប្រដាប់ដេរដោយសូត្រ ) មិនមានស្នាមគ្រោតគ្រាតផង មិន មានទង ( អាចម៍ដង្កូវ ) ផង ចងព័ទ្ធត្រង់ចង្កេះពីត្រឹមផ្ចិត ចុះទៅខាងក្រោម គ្រឿងប្រដាប់ទាំងនោះ ទុកជាឥតមានអ្វីប៉ះ

ពាល់សោះ ក៏ធ្វើនូវល្បែងជានិច្ច គឺញ៉ែរវិចជាប្រក្រតី បពិត្រ បិតាដ៏ចម្រើន គ្រឿងប្រដាប់ទាំងនោះ ឈ្មោះថាផ្លែឈើអ្វី ។ ផ្នួងសក់របស់មាណពនោះ ក៏គួរឲ្យចង់មើលក្រៃពេក ( បើមើល ) ជាងមួយរយដង ( ក៏មិនអស់ចិត្ត ) មានចុងងខ្វង់ មានក្លិនក្រអូប ( មាណពនោះ ) មានសក់ក្បាលញែកជាពីរ សិតញែកស្អាតបាត ធ្វើដូចម្ដេចហ្ន៎ នឹងបានឲ្យផ្នួងសក់របស់ខ្ញុំល្អដូច្នោះផង ។ មាណពនោះ រំសាយសក់ក្នុងកាលណា ផ្នួងសក់ទាំងឡាយនោះ ក៏ប្រកបដោយពណ៌ដោយក្លិន ក្នុងកាលនោះ អាស្រមនេះ ក៏ផ្សព្វផ្សាយទៅ ( ដោយក្លិន ) ដូចជាផ្កាឧប្បលខៀវ ដែលខ្យល់បក់ត្រូវដូច្នោះ ។ សម្បុររបស់មាណពនោះ គួរឲ្យចង់មើលក្រៃពេក កាយរបស់មាណពនោះ មិនដូចជាកាយរបស់ខ្ញុំឡើយ កាយរបស់មាណពនោះ កាលបើត្រូវខ្យល់បក់មក ផ្សព្វផ្សាយក្លិន ដូចជាព្រៃឈើ ដែលមានផ្ការីកស្គុសស្គាយ ក្នុងខាងចុងនៃគិម្ហរដូវ ។ មាណពនោះ តែងទះនូវផ្លែឈើ មានសភាពដ៏វិចិត្រ ល្អរងើរឿងគួរឲ្យចង់មើល បោះទៅលើផែនដី ផ្លែឈើនោះ រមែងត្រឡប់មករកដៃ របស់មាណពនោះវិញ បពិត្របិតាដ៏ចម្រើន នោះជាផ្លែឈើអ្វី ។ ធ្មេញទាំងឡាយរបស់មាណពនោះ ក៏គួរឲ្យចង់មើលក្រៃពេក ស្អាតស្មើដូចជាស័ង្ខ ដែលគេខាត់យ៉ាង

សំខាន់ កាលដែលគាត់ហាមាត់ឡើង តែងញ៉ាំងចិត្តឲ្យជ្រះថ្លា ដ្បិតមាណពនោះ មិនទំពាស៊ីនូវបន្លែ ដោយធ្មេញទាំងឡាយនោះទេ ។ សំដីរបស់មាណពនោះ និយាយឡើងមិនមានសំដីអាក្រក់ មិនភ្លាត់ ពីរោះ ស្រទន់ត្រង់ៗ មិនរាយមាយ មិនព្រោកកោកកាក ជាសំដីញ៉ាំងចិត្តឲ្យរីករាយ គួរចាប់ចិត្តដូចជាសំឡេងនៃសត្វករវិកយាសយំ ចិត្តរបស់ខ្ញុំ ត្រេកអរខ្លាំងណាស់ ។ ( មាណពនោះ ) មានសំឡេងមូល មានពាក្យមិនសូវក្បោះក្បាយពេកទេ មិនមែនជាអ្នកខ្វល់ខ្វាយក្នុងការស្វាធ្យាយ ( មន្ត ) ដោយពិត ខ្ញុំចង់ឃើញមាណពនោះម្តងទៀត ដ្បិតមាណព ( នោះ ) ជាមិត្តរបស់ខ្ញុំតាំងពីមុនដំបូងមក ។ ដំបៅ ( ត្រង់ចន្លោះភ្លៅរបស់មាណពនោះ ) ជិតស្និទ្ធល្អរលីងស្អាតសព្វអន្លើ ក្រាស់ ក្បុំល្អដូចជាផ្កាឈូកក្រពុំ មាណព ( នោះ ) គ្របសង្កត់ខ្ញុំ ដោយដំបៅនោះឯងសើយភ្លៅហើយ គាបខ្ញុំដោយស្នូង ។ ( រស្មីដូចមាសដែលផ្សាយចេញអំពីសរីរកាយនៃមាណពនោះ ) ភ្លឺត្រចះត្រចង់ ភ្លឺស្វាងរុងរឿង ភ្លឺផ្លេក ៗ ដូចជាផ្លេកបន្ទោរផ្លៀលធ្លាត់លើអាកាស ដើមដៃទាំង ២ ទន់ភ្លន់ មានរោមប្រហែលកេសរផ្កាអញ្ចន់ មាណពនោះមានម្រាមដៃមូល ៗ ដ៏វិចិត្រល្អ ។ ម្យ៉ាងទៀត ( មាណពនោះ ) មានអវយវៈតូចធំ មិនរដិប

វដុប ( ដោយមុននិងបួសជាដើម ) ទេ មានរោមមិនវែង ពេកទេ ឯក្រចករបស់មាណពនោះវែង ៗ មានចុងក្រហម ៗ ( មាណពនោះ ) មានរូបល្អ ឱបរឹត ( ខ្ញុំ ) ដោយដើម ដៃទាំងពីរដ៏ទន់ល្វន់ ( ផ្គាប់ផ្គុន ) ( ខ្ញុំ ) ឲ្យរីករាយ ។ ដៃទាំងពីររបស់មាណពនោះ ដូចជាប៉ុយឈើ មានស្នើផ្ទេកៗ មានបាតដៃមូល និងឆវីវណ្ណស្រស់បំព្រង ដូចផ្ទៃកញ្ចក់ជា វិការៈនៃមាស មាណពនោះពាល់ខ្ញុំដោយដៃទាំងពីរនោះហើយ ទៅពីទីនេះទៅ បពិត្របិតា មាណពនោះ ដុតរោលខ្ញុំ (ឲ្យក្តៅ ក្រហាយ) ដោយសម្ផស្សនៃដៃនោះ ។ មាណពនោះ ប្រហែល ជាមិនដែលនាំទៅនូវវត្ថុមានទម្ងន់មួយខារី ( មួយអម្រែក ) ទេ មាណពនោះ មិនដែលពុះឧសទាំងឡាយ ខ្លួនឯងទេ មាណពនោះ មិនដែលកាប់ឈើទាំងឡាយ ដោយកាំបិតទេ បានជាដៃរបស់មាណពនោះ មិនក្រិនសោះ ។ មានខ្លាឃ្មុំមួយ ធ្វើមាណពនោះឲ្យមានដំបៅ គេបាននិយាយនឹងខ្ញុំថា សូមឲ្យ អ្នកធ្វើខ្ញុំឲ្យបានសេចក្តីសុខស្រួល ខ្ញុំក៏បានធ្វើគាត់ឲ្យបានសុខ ស្រួលដោយអវយវៈដ៏ឧត្តមនោះរបស់ខ្ញុំ បពិត្របិតាដ៏ប្រសើរ មាណពនោះបាននិយាយប្រាប់ខ្ញុំថា ខ្ញុំបានសេចក្តីសុខស្រួល ហើយ ។ នេះកម្រាលនៃស្លឹកឈើទាល មានសភាពរាត់រាយ ដែលខ្ញុំនឹងគេដេកប្រគៀកប្រឱបលើគ្នា យើងទាំងពីរនាក់នោះ

អស់កម្លាំងក៏ចុះងូតទឹក ហើយចូលទៅកាន់បណ្ណកុដិរៀយៗ ។ បពិត្របិតា ខ្ញុំមិនបានជួបនឹងព្រហ្មចារីនោះ ដរាបណា មន្ត្រទាំងឡាយមិនជាក់ច្បាស់ដល់ខ្ញុំក្នុងថ្ងៃនេះផង ខ្ញុំមិនពេញចិត្តនឹងការបូជាភ្លើងផង មិនពេញចិត្តនឹងការបូជាយញ្ញផង ទាំងមិនបរិភោគមើមឈើនឹងផ្លៃឈើរបស់លោកផង ដរាបនោះ ។ បពិត្របិតា ចំណែកលោក ជ្រាបច្បាស់ប្រាកដ ព្រហ្មចារី ( នោះ ) នៅក្នុងទិសណា បពិត្របិតា សូមលោកជូនខ្ញុំទៅឲ្យដល់ទិសនោះ យ៉ាងឆាប់ កុំឲ្យខ្ញុំស្លាប់ក្នុងអាស្រមរបស់លោកឡើយ ដ្បិតខ្ញុំបានឮថា ព្រៃ ( ជាទីនៅនៃព្រហ្មចារីនោះ ) មានផ្ការីកស្គុសស្គាយ ដ៏វិចិត្រ ហើយជាទីគឹកកងដោយបក្សី ជាទីដែលពួកបក្សីនៅអាស្រ័យ ( ជានិច្ច ) បពិត្របិតា សូមលោកជូនខ្ញុំទៅ ឲ្យដល់ព្រៃនោះឆាប់ៗ មុនខ្ញុំនឹងលះជីវិតក្នុងអាស្រមរបស់លោក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឥធាគមា** បានដល់ បពិត្រលោកឪពុក ជដិលអ្នកប្រព្រឹត្តព្រហ្មចរិយៈមកកាន់អាស្រមនេះ ។ បទថា **សុទស្សនេយ្យោ** បានដល់ មានរូបគួរមើលដោយល្អ ។ បទថា **សុតនូ** បានដល់ មានរាងស្ដើងល្អ មិនស្គមពេក មិនធាត់ពេក ។ បទថា **វិនេតិ** សេចក្ដីថា រមែងញុំាងអាស្រមឲ្យដល់ គឺឲ្យពេញដោយរស្មីកាយរបស់ខ្លួន អាស្រមហាក់បីដូចមានរស្មីតែមួយ ។ បទថា **សុកណ្ហកណ្ហច្ឆទនេហិ គោតោ** សេចក្ដីថា

បពិត្រលោកឪពុក ក្បាលរបស់មាណពនោះ មានពណ៌ខ្មៅស្រិល ដោយសរសៃសក់ ដែលមានពណ៌ដូចស្លាបកំភេម ព្រោះគ្របដណ្តប់ដោយពណ៌ខ្មៅស្អាតប្រាកដ ហាក់ដូចកែវមណីដែលខាត់ល្អហើយ ដូច្នោះ ។ បទថា **អមស្សុជាតោ** បានដល់ ជដិលនោះនៅកំលោះ ទើបពុកមាត់របស់គេមិនប្រាកដ ។ បទថា **អបុរាណវណ្ណី** បានដល់ បួសមិនទាន់បានយូរប៉ុន្មានទេ ។ បទថា **អាធាររូបញ្ច បនស្ស កណ្ឋេ** នេះ តាបសពោលសំដៅដល់កែវមុក្តាហារថា ជដិលនោះ មានគ្រឿងប្រដាប់ដូចគ្នានឹងជើងបាត្រ សម្រាប់ដាក់កិក្ខារបស់ពួកយើងត្រង់ក ។ បទថា **គណ្ឌា** នេះ តាបស ពោលសំដៅដល់ស្តនទាំងគូ ។ បទថា **ឧរេ សុជាតា** បានដល់ កើតល្អ ហើយត្រង់ទ្រូង ។ បាឋៈថា **ឧរតោ** ដូច្នេះក៏មាន ។ បទថា **បភស្សរា** បានដល់ សម្បូរដោយរស្មី ។ បាឋៈថា **បភាសរេ** ដូច្នេះក៏មាន សេចក្តីថា រមែងចាំងចែងនូវពន្លឺ ។ បទថា **កុសធស្សនេយ្យំ** បានដល់ គួរមើលក្រៃពេក ។ បទថា **កុញ្ចិតគ្គា** នេះ លោកពោលសំដៅដល់ក្បាំងត្រចៀក ។ បទថា **សុត្តញ្ច** សេចក្តីថា ខ្សែដែលចងត្រង់ជដារបស់ជដិលនោះ រមែងភ្លឺផ្លេកពណ្ណរាយ ។ ដោយបទថា **សំយមានិ ចតស្សោ** នេះ លោកសម្តែងដល់គ្រឿងប្រដាប់ ៤ យ៉ាង ដែលធ្វើដោយកែវមណី មាស កែវប្រពាលនិងប្រាក់ ។ បទថា **តា សំសរេ** សេចក្តីថា គ្រឿងប្រដាប់ទាំងនោះ បញ្ចេញនូវសំឡេង ដូចបក្សី តិរិដិយកំក្នុងពេលភ្លៀងធ្លាក់ ។ បទថា **មេខលំ** បានដល់ ខ្សែចង្កេះសម្រាប់ស្ត្រី ។ បាឋៈក៏យ៉ាងនេះដូចគ្នា ។ ពាក្យនេះ លោកពោលសំដៅដល់សំពត់សម្បក

ឈើប្រភេទខ្លះសម្រាប់ស្លៀក ។ បទថា **ន សន្ថរេ** បានដល់ មិនមែនសំពត់សម្បកឈើ ។ មានពាក្យដែលលោកអធិប្បាយទុកថា បពិត្រលោកឪពុក ជដិលនោះ មិនបានប្រើសំពត់ ដែលធ្វើដោយស្មៅយាប្លង ឬដែលធ្វើដោយសម្បកឈើ ដូចពួកយើងឡើយ តែជដិលនោះ ប្រើសំពត់អំបោះប្រភេទស្តើងពណ៌មាស ។ បទថា **អចីលកានិ** បានដល់ មិនមានស្នាម មិនមានអាចម៍ជក្កូវ ។ បទថា **កដិសមោហិតានិ** បានដល់ ដែលជាប់ត្រង់ចង្កេះ ។ បទថា **និច្ចកីឡំ ករោន្តិ** សេចក្តីថា ទោះបីមិនប៉ះគ្នា តែក៏កម្រើកជានិច្ច ។ បទថា **ហន្តាត** បានដល់ បពិត្រលោកឪពុក ។ បទថា **កឹ រុក្ខផលានិ តានិ** នេះ លោកពោលសំដៅដល់កែវមណីនិងសំពត់ដែលព័ទ្ធត្រង់ចង្កេះនិងផ្លែឈើទាំងនោះជាផ្លែឈើអ្វី ដែលចងជាកំណួចជាប់ត្រង់ចង្កេះរបស់មាណពនោះ ។ បទថា **ជដា** លោកពោលសំដៅដល់ផ្នួងសក់ដែលចងដោយរតនៈ ជារបៀបអន្ទាក់ជដា ។ បទថា **វេល្លិតគ្គា** បានដល់ មានចុងងឡើង ។ បទថា **ទ្វេធាសិរោ** បានដល់ ក្បាលរបស់ជដិលនោះមានផ្នួងសក់ដែលចង បែងចែកដោយល្អជា ២ ចំណែក ។ បទថា **តថា** សេចក្តីថា តាបសប្រាថ្នាថា ជដារបស់ខ្ញុំ លោកឪពុកមិនបានចងឲ្យដូចជដារបស់មាណពនោះសោះ ឱហ្ន៎ ! សូមឲ្យជដារបស់ខ្ញុំដូច្នោះចុះ ដូច្នេះទើប បានពោលទុកហើយ ។ បទថា **ឧបេតរូបា** បានដល់ ជដាមានសភាវៈដែលប្រកបហើយ ។ បទថា **វាតសមេរិតំវ** សេចក្តីថា ក្លិនក្រអូបរមែងផ្សាយខ្ចរខ្ចាយទៅក្នុងអាស្រមនេះ ដូចផ្កាឧប្បលខៀវដែលត្រូវខ្យល់បក់

ផ្សាយទៅ ដូច្នោះ ។ បទថា **ធេតាធិសោ** សេចក្តីថា បពិត្រលោកឪពុក ពណ៌សម្បុរត្រង់សរីរៈនៃជដិលនោះ គួរពិតពិលរមិលមើលក្រៃណាស់ផង មានក្លិនក្រអូបផង មិនដូចពណ៌សម្បុរត្រង់កាយរបស់ខ្ញុំឡើយ ។ បទថា **អគ្គតិម្ហេ** បានដល់ ក្នុងសម័យដើមរដូវភ្លៀង ។ បទថា **និហន្តិ** បានដល់ រមែងវាយ ។ បទថា **កឹ រុក្ខផលំ នុខោ តំ** បានដល់ ផ្លែឈើនោះជាផ្លែនៃដើមឈើអ្វីហ្ន៎ ។ បទថា **សន្ធិរូបបន្នា** បានដល់ មានចំណែកប្រៀបស្មើដោយសន្ធិ ដែលខាត់ល្អហើយ ។ បទថា **ន ហិ ន្ធន សោ សាកមខាទិ** សេចក្តីថា មាណពនោះមិនបានទំពាបន្លែ ដំឡូង និងផ្លែឈើដោយឆ្អិនទាំងនោះ ដូចពួកយើងដោយពិត តាបសនោះសម្តែងថា ព្រោះពួកយើងនាំគ្នាទំពាវត្ថុទាំងនោះ ទើបឆ្អិនមានពណ៌ដូចកក់ ប្រឡាក់ពាសពេញ ។ បទថា **អកក្កសំ** សេចក្តីថា បពិត្រលោកឪពុក ពាក្យរបស់តាបសនោះ ឈ្មោះថា **អគ្គឡិតំ** ព្រោះមិនគ្រោតគ្រាត ឈ្មោះថា **មុហុំ មុហុំ** ព្រោះនិយាយរឿយៗក៏ពីរោះផ្អែមល្ហែម ឈ្មោះថា **ឧជុំ** ព្រោះមិនវង្វេង ឈ្មោះថា **អនុទ្ធតំ** ព្រោះមិនរាយមាយ ឈ្មោះថា **អចបលំ** ព្រោះជាពាក្យមាំទាំមានគោល ។ បទថា **រុទំ** សេចក្តីថា សូម្បីសំឡេងស្រែក គឺសំឡេងរបស់មាណព កំពុងនិយាយរមែងចាប់ចិត្ត ជាសំឡេងដែលល្អពីរោះស្រទន់ ដូចសំឡេងករវិក ដូច្នោះ ។ បទថា **រញ្ជយតេវ** សេចក្តីថា ចិត្តរបស់ខ្ញុំរមែងត្រេកត្រអាលក្រៃពេក ។ បទថា **ពិន្ទុស្សរោ** បានដល់ សំឡេងរបស់មាណពនោះមូល ។ បទថា **មាណវាហុ** សេចក្តីថា ព្រោះមាណពនោះ បានជាមិត្តរបស់ខ្ញុំដំបូង ។ បទ

ថា **សុសន្ធិ សព្ពត្ត វិមដ្ឋិមំ វណំ** សេចក្ដីថា បពិត្រលោកឪពុក មុខដំបៅមួយ មានក្នុងរវាងភ្លៅរបស់មាណពនោះ មុខដំបៅនោះ មានស្នាមជាប់តគ្នាស្និទ្ធល្អ មានសម្ផស្សល្អ រលោងក្នុងទីទាំងពួង គឺរលោងដោយជុំវិញ ដូចគ្នានឹងមុខដំបៅដែលជាងថ្នៃ ។ បទថា **បុថុ** បានដល់ ធំ ។ បទថា **សុជាតំ** បានដល់ តាំងនៅសមល្អ ។ បទថា **ខរបត្តសន្និភំ** បានដល់ ដូចគ្នានឹងផ្កាឈូកក្រពុំ ។ បទថា **ឧត្តរិយាន** បានដល់ គ្រប់សង្កត់ ។ បទថា **បីឡយិ** បានដល់ កៀប ។ បទថា **តបន្តិ** សេចក្ដីថា រស្មីមានពណ៌ដូចមាស ផ្សាយចេញអំពីសរីរៈនៃមាណពនោះ រមែងចែងចាំងរុងរឿង ។ បទថា **ពាហា** បានដល់ ដើមដៃទាំង ២ របស់ជដិលនោះក៏ទន់ ។ បទថា **អញ្ជនលោមសទិសា** បានដល់ ប្រកបព្រមដោយរោមទាំងឡាយ ដូចគ្នានឹងផ្កាអញ្ជ័ន ។ បទថា **វិចិត្រវដ្ដង្គុលិកស្ស សោភរេ** សេចក្ដីថា ដៃទាំង ២ របស់ជដិលនោះ ក៏ប្រកបដោយម្រាមដៃដែលរៀវស្អាត មានលក្ខណៈដ៏វិចិត្រ ដូចគ្នានឹងផ្កាថ្ម ។ បទថា **អកក្កសង្គោ** បានដល់ មានអវយវៈតូចធំប្រាសចាករោគ មានរោគរមាស់ និងមុនជាដើម ។ បទថា **រមយំ ឧបដ្ឋហិ** សេចក្ដីថា បម្រើ គឺបម្រើឲ្យខ្ញុំត្រេកអរ ។ បទថា **តូលូបនិភា** បានដល់ ជាឧបមាដល់ការទន់ ។ បទថា **សុវណ្ណកម្ពុតលវដ្ដសុច្ឆវី** បានដល់ ផ្ទៃបាតដៃរលោង មានពណ៌ល្អ ដូចគ្នានឹងផ្ទៃកញ្ចក់មាស អធិប្បាយថា មានផ្ទៃបាតដៃរលីង និងមានពណ៌សម្បុរល្អ ។ បទថា **សំផុសិត្វា** បានដល់ ប៉ះពាល់ដោយល្អ គឺប្រើដៃទាំង ២ នៃខ្លួនប៉ះពាល់ ធ្វើឲ្យសរីរៈរបស់

ខ្ញុំជ្រួតជ្រាប ។ បទថា **ឥតោ គតោ** បានដល់ ទាំងដែលខ្ញុំកំពុងមើល នោះឯង បុរសនោះក៏ចេញទៅហើយ ។ បទថា **តេន មំ ឧហន្តិ** សេចក្តីថា ដោយការឱបរឹត សម្ពស្សដោយដៃនោះរបស់មាណព ធ្វើឲ្យខ្ញុំក្តៅក្រហាយ មកទល់ឥឡូវនេះឯង អធិប្បាយថា ចាប់តាំងពីកាលជដិលនោះចេញទៅ ហើយយ៉ាងនោះ ការក្តៅក្រហាយ រមែងកើតឡើងក្នុងសរីរៈរបស់ខ្ញុំ ដោយ ហេតុនោះ ទើបខ្ញុំដល់នូវទោមនស្ស ដេកសញ្ចប់សញ្ចឹង ។ បទថា **ទារិវិជំ** សេចក្តីថា បពិត្រលោកឪពុក មាណពនោះមិនបានរែកត្រាច់ទៅពិត ។ បទ ថា **វិលាធិ** បានដល់ អស់នូវការរឹងត្អឹង ។ ម្យ៉ាងទៀត បាលីថា **វីឈាធិ** ដូច្នេះក៏មាន ឯន័យក៏ដូចគ្នា ។ បទថា **សោខ្យំ** បានដល់ សេចក្តីសុខ ។ បទថា **សន្ថតា** បានដល់ កម្រាល ។ បទថា **វិកិណ្ណរូបាវ** សេចក្តីថា បពិត្រលោកឪពុក ទីដែលក្រាលដោយស្លឹកឈើទាលរបស់លោកនេះ ក្លាយ ជាទីប្រឡាក់ប្រឡូស ដោយអំណាចខ្ញុំ និងជដិលនោះឱបរឹតនូវគ្នានឹងគ្នា ក្នុង ថ្ងៃនេះ ក៏ខ្ចាត់ខ្ចាយរាត់រាយដោយការបម្រះនទៀលទៅមក ដូច្នោះ ។ បទថា **ឫនប្បុនំ បណ្ណកុដី វជាម** សេចក្តីថា ជដិលនោះ ពោលថា បពិត្រលោក ឪពុក ខ្ញុំនិងមាណពនោះត្រដុសមុខជំរៀបគ្នាហើយក៏អស់កម្លាំង ចេញអំពី បណ្ណសាលា នាំគ្នាទៅកាន់ស្ទឹងនូតហើយ លុះប្រាសចាកសេចក្តីក្រវល់ ក្រវាយហើយ ត្រឡប់ចូលទៅកាន់កុដិនោះរឿយៗ ។ បទថា **មន្តា** សេច ក្តីថា ថ្ងៃនេះ គឺតាំងពីកាលជដិលនោះចេញអំពីខ្ញុំទៅហើយ មន្តទាំងឡាយ ក៏មិនជាក់ច្បាស់ គឺមិនប្រាកដ បានដល់ មិនគាប់ចិត្តខ្ញុំឡើយ ។ បទថា **ន**

**អគ្គិហុត្តំ ឆបិ យញ្ញំ តត្រ** សេចក្តីថា សូម្បីកិរិយារបស់យញ្ញ ដែលមានភ្លើងជាជន្លាយជាដើម ដែលគួរធ្វើដើម្បីអង្វរមហាព្រហ្ម រមែងមិនជាក់ច្បាស់ដល់ខ្ញុំ គឺមិនតាំងឡើង ខ្ញុំមិនគាប់ចិត្តឡើយ ។ បទថា **ឆ ចាបិ តេ** សេចក្តីថា ខ្ញុំមិនព្រមបរិភោគ សូម្បីតែមូលផលាហារ ដែលលោកឪពុកនាំមកហើយ ។ បទថា **យស្សំ ទិសំ** បានដល់ ក្នុងទីណា ។ បទថា **វនំ** បានដល់ ព្រៃឈើដែលដុះព័ទ្ធអាស្រមរបស់មាណពនោះ ។

កាលតាបសនោះកំពុងរវើរវាយនោះឯង ព្រះពោធិសត្វបានស្តាប់ពាក្យនោះហើយ ក៏ដឹងថា សីលរបស់តាបសនេះ ប្រហែលជាត្រូវស្រីនោះទម្លាយឲ្យដាច់ហើយដោយពិត ដូច្នេះ កាលនឹងពោលទូន្មានតាបសនោះ ទើបពោលគាថា ៦ ថា

> សេចក្តីពិតថា បុគ្គលមិនគួរដល់នូវសេចក្តីអផ្សុកបែបនេះ ក្នុងព្រៃដែលរុងរឿងដោយពន្លឺ ជាទីគឹកកងដោយពួកគន្ធព្វ និងស្រីទេពអប្សរ ជាទីនៅនៃឥសីទាំងឡាយ ជាព្រៃមានតាំងពីយូរយារណាស់ហើយ នេះឡើយ ។ មិត្តទាំងឡាយ មានខ្លះមិនមានខ្លះ ជនទាំងឡាយ គួរធ្វើនូវសេចក្តីស្រឡាញ់ចំពោះញាតិនិងមិត្ត មនុស្សណាមិនដឹងថា អាត្មាអញកើតមកពីណា មនុស្សនេះគម្រក់ ត្រូវមាតុគ្រាមបង្វឹកបានទាំងថ្ងៃ ដោយហេតុអ្វី ។ ធម្មតាមិត្តទាំងឡាយ រមែងជាប់តគ្នាដោយការនៅរួមរឿយ ៗ មិត្តនោះឯង រមែងលាកចិត្តដោយការមិនបាន

នៅរួមគ្នា របស់បុរសដែលមិនបានទៅមករកគ្នា ។ បើអ្នកឃើញនូវព្រហ្មចារី ( នោះទៀត ) បើអ្នកចរចាជាមួយនឹងព្រហ្មចារី ( នោះទៀត ) អ្នកនឹងបំផ្លាញនូវតបោគុណនេះ យ៉ាងឆាប់មិនខាន ដូចជាសទ្ធូងដ៏ល្អបរិបូណ៌ ដែលទឹកធំបំផ្លាញដូច្នោះ ។ បើអ្នកនឹងឃើញនូវព្រហ្មចារី ( នោះ ) ទៀត បើអ្នកចរចាជាមួយនឹងព្រហ្មចារី ( នោះ ) ទៀត អ្នកនឹងបំផ្លាញនូវតេជះរបស់សមណៈនេះ យ៉ាងឆាប់មិនខាន ដូចជាសទ្ធូងល្អបរិបូណ៌ ដែលទឹកធំបំផ្លាញដូច្នោះ ។ នែកូន ភូតទាំងឡាយនេះ តែងត្រាច់ទៅក្នុងមនុស្សលោក ដោយបែបភាពនៃរូបផ្សេងៗ ជនអ្នកមានប្រាជ្ញា មិនត្រូវគប់រកនឹងភូតទាំងឡាយនោះឡើយ បុគ្គលជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ តែងវិនាសទៅ ( ព្រោះដល់ ) នូវការជាប់ជំពាក់ ( នឹងភូតបែបនោះឯង ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឥមស្មា** បានដល់ **ឥមស្មឹ** ប្រែថា ក្នុងព្រៃដែលរុងរឿងនេះ ។ បទថា **ហិ** ត្រឹមតែជានិបាត ។ បទថា **ជោតិរសេ** បានដល់ ក្នុងព្រៃដែលភ្លឺស្វាងដោយរស្មីនៃភ្លើងដែលបូជា ។ បទថា **សនន្តនម្ហិ** បានដល់ ក្នុងកាលមុន ។ បទថា **ឆាបុណោឌ** បានដល់ គួរឲ្យដល់ ។ មានពាក្យអធិប្បាយដែលលោកពោលទុកថា នែកូន កុលបុត្តដែលជាបណ្ឌិតនៅក្នុងព្រៃបែបនេះ មិនគួរឲ្យអ្នកនៅក្មេងបែបនេះ ដល់នូវការអផ្សុកឡើយ

អធិប្បាយថា មិនគួរឲ្យដល់ ។ បទថា **ភវន្តិ** សេចក្តីថា ព្រះមហាសត្វ ពោលគាថានេះ ចំពោះបុគ្គលដែលនៅខាងក្នុងប៉ុណ្ណោះ ។ សេចក្តីក្នុងគាថានោះ មានអធិប្បាយដូចតទៅនេះថា ធម្មតាពួកមិត្តរបស់សត្វទាំងឡាយក្នុងលោក រមែងមានខ្លះ មិនមានខ្លះ បណ្តាមនុស្សទាំងនោះ ពួកជនដែលជាមិត្ត រមែងធ្វើនូវសេចក្តីស្រឡាញ់ក្នុងពួកញាតិ និងពួកមិត្តរបស់ខ្លួន ។ បទថា **អ-យញ្ច ជម្មោ** បានដល់ កុមារនេះជាមិគសិង្គ ជាបុគ្គលលាមក ។ បទថា **កិស្ស ធិវា និវេដ្ឋោ** សេចក្តីថា ជឿមាំដោយសម្គាល់ថាជាមិត្តក្នុងមាតុគ្រាមនោះ ព្រោះហេតុអ្វី ព្រោះខ្លួនកើតក្នុងផ្ទៃមេម្រឹគ ហើយទើបតែធំក្នុងព្រៃ ទើបកុមារនោះមិនដឹងទីដែលខ្លួនមកហើយថា អញមកអំពីណា នឹងពោលទៅថ្វីដល់ពួកញាតិនិងមិត្ត ។ បទថា **បុនប្បុនំ** សេចក្តីថា នែកូន ធម្មតាពួកមិត្ត រមែងស្និទ្ធស្នាលគ្នា ជាប់តគ្នារឿយៗ ព្រោះការនៅរួមគ្នា គឺគប់រកគ្នា ។ បទថា **ស្វេវ មិត្តោ** សេចក្តីថា មិត្តនោះឯង រមែងសាបសូន្យទៅ គឺរមែងវិនាសទៅ ព្រោះការមិននៅរួម ពោលគឺការមិនសេពគប់នោះនៃបុរសដែលមិនសេពគប់ គឺរបស់បុរសដែលមិនមករួមគ្នា ។ បទថា **សចេ** សេចក្តីថា ព្រោះហេតុនោះ នែកូន បើឯងបានឃើញព្រហ្មចារីនោះម្តងទៀត ឬបានពោលជាមួយព្រហ្មចារីនោះ អ្នកក៏នឹងលះ នឹងធ្វើឲ្យគុណ គឺតបធម៌នៃខ្លួននេះវិនាសទៅដោយរហ័ស ដូចសន្ទូងដែលឲ្យផលសម្បូរល្អហើយ ខូចទៅព្រោះជំនន់ទឹកធំ ដូច្នោះ ។ បទថា **ឧស្មាគតំ** បានដល់ សមណតេជះ ។ បទថា**វិរូបរូបេន** បានដល់ ដោយរូបប្លែកៗ មានពាក្យដែលលោកអធិប្បាយ

ទុកថា ព្រះពោធិសត្វ ពោលទូន្មានហើយនូវបុត្តយ៉ាងនេះថា កូនជាទីស្រឡាញ់ ភូតគឺពួកយក្ខទាំងនេះ រមែងត្រាច់ទៅក្នុងមនុស្សលោក ដោយរូបរបស់ខ្លួន បិទបាំងរូបប្លែកៗទុក ដើម្បីទំពាស៊ីពួកមនុស្ស ដែលធ្លាក់នៅក្នុងអំណាចរបស់ខ្លួន នរជនមានប្រាជ្ញា មិនគប្បីគប់រកពួកភូត គឺយក្ខទាំងនោះ ព្រោះការទាក់ទងជាមួយជននោះ ការប្រព្រឹត្តព្រហ្មចរិយៈ រមែងវិនាសទៅ ឯងត្រូវយក្ខិនីនោះជួបហើយ តែមិនទាន់ទំពាស៊ី ។

តាបសនោះបានស្តាប់ពាក្យរបស់បិតាហើយ កើតនូវការតក់ស្លុតឡើងថា អញទើបតែដឹងថា ស្រីនោះជាយក្ខិនី ទើបប្រែចិត្ត សូមខមាទោសនឹងឪពុកថា បពិត្រលោកឪពុក ខ្ញុំនឹងមិនទៅអំពីទីនេះ សូមលោកឪពុកអត់ទោសឲ្យខ្ញុំចុះ ព្រះពោធិសត្វលួងលោមឲ្យកូនស្បើយចិត្តហើយ ទើបប្រាប់ដល់វិធីចម្រើនព្រហ្មវិហារថា នែមាណពតូច ឯងមកណេះ ចូរឯងចម្រើនមេត្តា ករុណា មុទិតា និងឧបេក្ខាចុះ ។ តាបសនោះបដិបត្តិតាមយ៉ាងនោះហើយ ក៏ធ្វើឈាននិងអភិញ្ញាឲ្យកើតឡើងបានវិញ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុអផ្សុកតាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា ព្រះរាជធីតានឡិនិកាក្នុងកាលនោះ បានមកជាបុរាណទុតិយិកា ក្នុងកាលឥឡូវនេះ ឥសិសិង្គតាបសក្នុងកាលនោះ បានជាភិក្ខុអផ្សុក ឯតាបសដែលជាបិតា ក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា នឡិនិកាជាតក ចប់**

# ឧម្មាទន្តីជាតក

[ ២០ ] ( ព្រះបាទសិវិត្រាស់សួរសារថីថា ) ហៃសុនន្ទៈ នេះជាទីលំនៅរបស់នរណាហ្ន៎ ដែលព័ទ្ធព័ទ្ធដោយកំពែង ធ្វើដោយឥដ្ឋពណ៌ក្រហម ស្ត្រីអ្វីប្រាកដដូចអណ្តាតភ្លើងក្នុងទីឆ្ងាយ ឬដូចជាអណ្តាតភ្លើងពួងដ៏អាកាស លើកំពូលភ្នំ ។ ម្នាលសុនន្ទៈ ស្ត្រីនេះជាធីតារបស់នរណាហ្ន៎ ស្ត្រីនេះជាកូនប្រសារបស់នរណាហ្ន៎ ឬជាភរិយារបស់នរណា ប្រសិនបើ ( ស្ត្រីនេះ ) មិនទាន់មានគេហួងហែងក្តី មានភស្តាក្តី ខ្ញុំសួរហើយ ចូរអ្នកប្រាប់យ៉ាងឆាប់ក្នុងកាលឥឡូវនេះកុំខាន ។

[ ២១ ] ( សារថីក្រាបបង្គំទូលថា ) បពិត្រព្រះជនិន្ទៈ ខ្ញុំព្រះអង្គស្គាល់ស្ត្រីនុ៎ះជាក់លាក់ អំពីចំណែកខាងមាតាផង អំពីចំណែកខាងបិតាផង ទាំងស្វាមីរបស់ស្ត្រីនោះក៏ខ្ញុំព្រះអង្គស្គាល់ បពិត្រភូមិបាល ស្វាមីនោះជាបុរសរបស់ព្រះអង្គហ្នឹងឯង ជាអ្នកមិនប្រហែសធ្វេសក្នុងប្រយោជន៍របស់ព្រះអង្គទាំងយប់ទាំងថ្ងៃ ។ បពិត្រព្រះជនិន្ទៈ ព្រះអង្គមានអាមាត្យម្នាក់ ជាអ្នកស្តុកស្តម្ភ មាំមួន ថ្កុំថ្កើង បពិត្រព្រះរាជា ស្ត្រីនោះឈ្មោះនាង ឧម្មាទន្តី ជាប្រពន្ធរបស់អាមាត្យឈ្មោះអភិបារកៈនោះឯង ។

[ ២២ ] ( ព្រះរាជា... ) វ៉ឺយ វ៉ឺយ ឈ្មោះនេះ ដែលមាតាបិតាបានឲ្យដល់នាងនេះ ត្រូវល្អណាស់ បានជាថាដូច្នោះ ព្រោះនាងឧម្មាទន្តី កាលក្រឡេកមើលអញ ធ្វើអញឲ្យឆ្កួត ។

[ ២៣ ] ស្ត្រីណា មានភ្នែកស្រទន់ដូចភ្នែកម្រឹគ មានសរីរៈសម្បុរដូចផ្កាឈូកក្រហម អន្ទុយអែប ( ក្បែរបង្អួច ) ក្នុងរាត្រី ដែលមានព្រះចន្ទ

ពេញវង់ អញបានឃើញស្រីនោះ ដែលមានសម្លៀកសំពាក់ក្រហម ដូចជាដើងព្រាប ក៏ស្មានថា ជាព្រះចន្ទពេញវង់ពីរ ។ ( នាងឧម្មាទន្តី ) ប្រឡោមអញដោយអាការទ្រទេសទ្រទន់ល្អស្រស់ ជាប្រធាននៃការដ៏វិសេស ម៉ឹកម៉ក់ ក្រឡេកមើលអញ ចិត្តរបស់អញក៏រវើរវាយ ដូចជាក្នុងកាលដែលកិន្នរញីកើតក្នុងព្រៃភ្នំ ( ហិមពាន្តធ្វើកិន្នរឈ្មោលឲ្យមានចិត្តរវើរវាយដូច្នោះ ) ។ ដ្បិតក្នុងកាលនោះ នាងនារីមានសម្បុរលឿង ពាក់កុណ្ឌលកែវមណី មានសម្លៀកបំពាក់តែមួយ ក្រឡេកមើល ( អញ ) ដូចជាមេម្រឹគផ្អើល ។ កាលណាហ្ន៎ នឹងបាននារីមានក្រចកក្រហមទុំ មានរោមល្អ មានដើមដៃទន់ភ្លន់ លាបស្រឡាបដោយខ្លឹមចន្ទន៍ មានម្រាមដៃមូល ប្រសប់ខាងធ្វើម៉ឹកម៉ក់ ល្អផុតចុងសក់ មកឱបអង្អែលអញ ។ កាលណាហ្ន៎ អញនឹងបានធីតារបស់សេដ្ឋីឈ្មោះ តិរិដិ ដែលមានគ្រឿងប្រដាប់ទ្រូងជាវិការៈនៃមាស មានដងខ្លួនរៀវ មកឱបរឹតអញដោយដើមដៃទាំងពីរដ៏ទន់ភ្លន់ ដូចជាពួរជ្រៃដែលរួបរឹត ដើមឈើដុះក្នុងព្រៃធំ ។ កាលណាហ្ន៎ អញនឹងបាន ( នារី ) ដែលមានសម្បុរល្អស្រស់ ដូចជាទឹកល័ក្តក្រហម មានដោះក្បំដូចជាពពុះទឹក មានសរីរៈសម្បុរដូចផ្កាឈូកក្រហម បង្អោនមុខមកប៉ះនឹងមុខ ( អញ ) ដូចជាអ្នកលេង ( ដែលហុច ) កែវសុរាឲ្យដល់អ្នកលេងផងគ្នា ។ អញបានឃើញនារីនោះមានខ្លួនសមរម្យសព្វអន្លើ ជាតម្រេកនៃចិត្ត កំពុងឈរក្នុងកាលណា អញមិនបានជាឥស្សរៈ ( លើចិត្តរបស់ខ្លួន ) មិនស្គាល់នារីនោះ ថាជាអ្វីឡើយ ក្នុងកាលនោះ ។ អញបានឃើញនាងឧម្មាទន្តី ដែល

ពាក់កុណ្ឌលជាវិការៈនៃកែវមណី ក៏ដេកមិនលក់ទាំងថ្ងៃទាំងយប់ ដូចជាគេផ្ចាញ់អស់ ១ ពាន់ដង ។ បើសក្កទេវរាជប្រទានពរដល់អញ សូមឲ្យអញបានពរនោះថា អភិបារកសេនាបតី សូមត្រេកត្រអាលជាមួយនឹងនាងឧម្មាទន្តី តែមួយយប់ពីរយប់ប៉ុណ្ណោះចុះ តពីនោះទៅ សូមព្រះបាទសីវិរាជ ( ត្រេកត្រអាលជាមួយនឹងនាងឧម្មាទន្តីវិញ ) ។

[ ២៤ ] ( អភិបារកជាសេនាបតី... ) បពិត្រព្រះអង្គជាម្ចាស់នៃជនកាលដែលទូលព្រះបង្គំជាខ្ញុំសំពះទេវតាទាំងឡាយ មានទេវតា ( មួយអង្គ ) មកពោលពាក្យដូច្នេះថា ព្រះទ័យរបស់ព្រះរាជាជាប់ជំពាក់នឹងនាងឧម្មាទន្តី ទូលព្រះបង្គំជាខ្ញុំ សូមថ្វាយព្រះអង្គ សូមព្រះអង្គឲ្យនាងឧម្មាទន្តីនោះបម្រើចុះ ។

[ ២៥ ] ( ព្រះរាជា... ) ខ្ញុំគប្បីឃ្លាតចាកបុណ្យផង ខ្ញុំមិនមែនជាមិនស្លាប់ផង អ្នកផងដឹងនូវអំពើអាក្រក់របស់ខ្ញុំនេះផង សេចក្តីចង្អៀតចង្អល់ចិត្តគប្បីមានដល់អ្នកយ៉ាងខ្លាំង ព្រោះអ្នកឲ្យ ( នាងឧម្មាទន្តី ) ជាទីស្រឡាញ់ហើយមិនបានឃើញទៀតផង ។

[ ២៦ ] ( អភិបារក... ) បពិត្រព្រះជនិន្ទៈ លើកលែងតែព្រះអង្គ នឹងទូលព្រះបង្គំជាខ្ញុំចេញ អ្នកទាំងពួងមិនគប្បីដឹងនូវអំពើដែលទូលព្រះអង្គំជាខ្ញុំ ថ្វាយនាងឧម្មាទន្តីដល់ព្រះអង្គទេ បពិត្រព្រះរាជា សូមព្រះអង្គធ្វើនូវព្រៃគឺតណ្ហាឲ្យខ្លាំងក្លាចុះ ( បើ ) ព្រះអង្គ ( លែងសព្វព្រះរាជហឫទ័យហើយ សូមលះបង់ចុះ ) ។

[ ២៧ ] ( ព្រះរាជា... ) មនុស្សណា ធ្វើអំពើអាក្រក់ មនុស្សនោះតែងសម្គាល់ថា ជនទាំងឡាយដទៃ ពុំដឹងនូវអំពើអញនេះឡើយ តែពួកភូតនឹងពួកនរជនដែលប្រកប ( ដោយឫទ្ធិ ) លើផែនដី រមែងឃើញបុគ្គលដែលធ្វើបាបកម្មនុ៎ះ ។ ជនដទៃណាហ្ន៎ លើផែនដីក្នុងលោក គប្បីជឿចិត្តអ្នកថា នាង ( ឧម្មាទន្តី ) មិនជាទីស្រឡាញ់របស់អញ ដូច្នេះ ទាំងសេចក្តីចង្អៀតចង្អល់ចិត្ត គប្បីមានដល់អ្នកយ៉ាងខ្លាំង ព្រោះអ្នកឲ្យនាងឧម្មាទន្តី ជាទីស្រឡាញ់ហើយ មិនបានឃើញទៀត ។

[ ២៨ ] ( អភិបារកៈ... ) បពិត្រព្រះជនិន្ទៈ នាងឧម្មាទន្តីនុ៎ះ ជាទីស្រឡាញ់របស់ទូលព្រះបង្គំជាខ្ញុំដោយពិត បពិត្រព្រះភូមិបាល នាងនោះ មិនមែន មិនជាទីស្រឡាញ់របស់ទូលព្រះបង្គំជាខ្ញុំទេ សូមសេចក្តីចម្រើន ចូលមានដល់ព្រះអង្គ សូមព្រះអង្គយាងទៅកាន់សំណាក់នាងឧម្មាទន្តីកុំខាន ដូចជាសីហៈឈ្មោល ចូលទៅកាន់គុហាកែវមណី ( ជាលំនៅរបស់សីហៈញី ) ដូច្នោះ ។

[ ២៩ ] ( ព្រះរាជា... ) អ្នកប្រាជ្ញទាំងឡាយ ( បើទុកជា ) ត្រូវសេចក្តីទុក្ខក្នុងខ្លួនបៀតបៀនហើយ ក៏មិនលះបង់នូវអំពើ ដែលមានផលជាសុខឡើយ ឬទោះបីវង្វេងជ្រុលជ្រប់ក្តី ស្រវឹងដោយសេចក្តីសុខក្តី ក៏គង់មិនប្រព្រឹត្តធ្វើបាបកម្មទេ ។

[ ៣០ ] ( អភិបារកៈ... ) ព្រះអង្គដូចជាមាតាបិតា ជាអ្នកចិញ្ចឹម ជាម្ចាស់ ជាអ្នកបីបាច់រក្សា ទាំងជាទេវតារបស់ទូលព្រះអង្គជាខ្ញុំ បពិត្រព្រះបាទ

សិវិ ខ្ញុំព្រះអង្គព្រមទាំងកូនប្រពន្ធ ជាទាសៈរបស់ព្រះអង្គ សូមទ្រង់ធ្វើសេចក្តីប្រាថ្នា តាមសប្បាយចុះ ។

[ ៣១ ] ( ព្រះរាជា... ) បុគ្គលណាអាងថា អាត្មាអញជាធំដូច្នេះ ហើយធ្វើនូវអំពើអាក្រក់ បុគ្គលនោះលុះបានធ្វើរួចហើយ ក៏មិនរវែងនឹងពួកជនដទៃ ព្រោះអំពើនោះ បុគ្គលនោះមិនរស់នៅអស់កាលជាអង្វែង ទាំងពួកទេវតាក៏តែងរំពៃមើលបុគ្គលនោះ ដោយអំពើអាក្រក់ ។

[ ៣២ ] ( អភិបារកៈ... ) បុគ្គលទាំងឡាយណា តាំងនៅក្នុងធម៌ ទទួលយកនូវទានដែលគេមិនស្គាល់ ដែលម្ចាស់ទាំងឡាយប្រគល់ឲ្យហើយ បុគ្គលជាអ្នកទទួលទាំងឡាយ ( នោះ ) ផង អ្នកឲ្យទាំងឡាយផង ឈ្មោះថា ធ្វើនូវអំពើមានផលជាសុខក្នុងហេតុនោះ ។

[ ៣៣ ] ( ព្រះរាជា... ) បុគ្គលដទៃណាហ្ន៎ លើផែនដី ក្នុងលោក គប្បីជឿអ្នកថា ( នាងឧម្មាទន្តី ) មិនមែនជាទីស្រឡាញ់របស់អញ ដូច្នេះ ទាំងសេចក្តីចង្អៀតចង្អល់ចិត្ត គប្បីមានដល់អ្នកយ៉ាងខ្លាំង ព្រោះអ្នកឲ្យនាងឧម្មាទន្តីជាទីស្រឡាញ់ ហើយមិនបានឃើញទៀតផង ។

[ ៣៤ ] ( អភិបារកៈ... ) បពិត្រព្រះជនិន្ទៈ នាងឧម្មាទន្តីនុ៎ះ ជាទីស្រឡាញ់របស់ទូលព្រះបង្គំជាខ្ញុំដោយពិត បពិត្រព្រះភូមិបាល នាងនោះមិនមែនមិនជាទីស្រឡាញ់របស់ទូលព្រះអង្គជាខ្ញុំទេ នាងឧម្មាទន្តី ទូលព្រះអង្គជាខ្ញុំបានថ្វាយហើយ ចំពោះព្រះអង្គដោយហេតុណា បពិត្រព្រះរាជា សូមព្រះអង្គធ្វើនូវព្រៃ គឺតណ្ហា ឲ្យខ្លាំងក្លាចុះ ( បើ ) ព្រះអង្គ ( លែងសព្វ

ព្រះរាជហឫទ័យហើយ ) សូមលះបង់ចុះ ។

[ ៣៥ ] ( ព្រះរាជា... ) បុគ្គលណាឲ្យទុក្ខដល់ជនដទៃ ដោយទុក្ខរបស់ខ្លួន ឬជណ្តើមសុខដើម្បីខ្លួនអំពីសុខ ( របស់ជនដទៃ ) ( បុគ្គលនោះ ឈ្មោះថា មិនស្គាល់ធម៌ ) លុះតែបុគ្គលណា ដឹងច្បាស់យ៉ាងនេះថា សុខទុក្ខរបស់អញនេះយ៉ាងណា សុខទុក្ខរបស់ជនដទៃ ក៏យ៉ាងនោះដែរ បុគ្គលនោះ ទើបឈ្មោះថា អ្នកដឹងធម៌ ។

[ ៣៦ ] បុគ្គលដទៃណាហ្ន៎ លើផែនដី ក្នុងលោកគប្បីជឿអ្នកថា ( នាងឧម្មាទន្តី ) មិនមែនជាទីស្រឡាញ់របស់អញដូច្នេះ ទាំងសេចក្តីចង្អៀតចង្អល់ចិត្ត គប្បីមានដល់អ្នកយ៉ាងខ្លាំង ព្រោះអ្នកឲ្យនាងឧម្មាទន្តីជាទីស្រឡាញ់ហើយ មិនបានឃើញទៀតផង ។

[ ៣៧ ] ( អភិបារកៈ... ) បពិត្រព្រះជនិន្ទៈ ព្រះអង្គគង់ជ្រាបថា នាងឧម្មាទន្តីនោះ ជាទីស្រឡាញ់របស់ទូលព្រះបង្គំជាខ្ញុំ បពិត្រព្រះភូមិបាល នាងនោះមិនមែនមិនជាទីស្រឡាញ់ របស់ទូលព្រះបង្គំជាខ្ញុំទេ បពិត្រព្រះជនិន្ទៈ ទូលព្រះបង្គំជាខ្ញុំ សូមថ្វាយនាងឧម្មាទន្តីជាទីស្រឡាញ់ ចំពោះព្រះអង្គដោយចិត្តជាទីស្រឡាញ់ បពិត្រព្រះសម្មតិទេព បុគ្គលអ្នកឲ្យនូវវត្ថុជាទីស្រឡាញ់ទាំងឡាយ រមែងបាននូវវត្ថុជាទីស្រឡាញ់វិញ ។

[ ៣៨ ] ( ព្រះរាជា... ) អញនោះមុខជានឹងសម្លាប់ខ្លួន ព្រោះមានកាមជាហេតុដោយពិត អញមិនអាចដើម្បីសម្លាប់នូវធម៌ដោយអធម៌ឡើយ ។

[ ៣៩ ] ( អភិបារកៈ... ) បពិត្រព្រះជនិន្ទៈ ទ្រង់មានព្យាយាមក្នុង

ពួកជនដ៏ប្រសើរ បើព្រះអង្គ មិនសព្វព្រះរាជហឫទ័យនឹងនាងឧម្មាទន្តីដែល ជារបស់ទូលព្រះបង្គំជាខ្ញុំទេ ទូលព្រះបង្គំជាខ្ញុំនឹងលះបង់នាង នាកណ្តាលជន ទាំងពួង តពីនោះទៅ ព្រះអង្គគប្បីនាំយកនាងឧម្មាទន្តីនោះ ដែលទូលព្រះបង្គំ ជាខ្ញុំលះបង់ហើយ ។

[ ៤០ ] ( ព្រះរាជា... ) នែអភិបារកៈ បើអ្នកលះបង់ ( នាងឧម្មាទន្តី ) ដែលមិនមានទោស នែអ្នកធ្វើ ( ប្រយោជន៍ដល់ខ្ញុំ ) ការលះបង់នោះ គប្បី មិនជាប្រយោជន៍ដល់អ្នកផង ពាក្យតំណោះតំនៀលយ៉ាងច្រើន គប្បីមានដល់ អ្នកផង បក្ខពួករបស់អ្នកក្នុងនគរ មិនគប្បីមានផង ។

[ ៤១ ] ( អភិបារកៈ... ) បពិត្រព្រះភូមិបាល ទូលព្រះបង្គំជាខ្ញុំ នឹង អត់ទ្រាំនូវពាក្យតំណោះតំនៀលនុ៎ះផង នូវនិន្ទាផង នូវសេចក្តីសរសើរផង នឹងការពោលទោសគ្រប់យ៉ាងថា ហេតុទាំងនុ៎ះ ចូរមកដល់ទូលព្រះបង្គំជាខ្ញុំចុះ បពិត្រព្រះបាទសីវិ សូមទ្រង់ធ្វើនូវសេចក្តីប្រាថ្នាតាមសប្បាយចុះ ។ បុគ្គល ណា មិនអើពើនឹងនិន្ទា មិនអើពើនឹងសេចក្តីសរសើរ មិនអើពើនឹងពាក្យ ពោលទោស មិនអើពើនឹងការបូជា សិរីក្តី បញ្ញាក្តី រមែងទៅប្រាសចាកបុគ្គល នោះ ដូចជាទឹក គឺទឹកភ្លៀងយ៉ាងស្រួល ដែលទៅប្រាសចាកទីទួលដូច្នោះ ។ ទូលព្រះបង្គំជាខ្ញុំ នឹងទទួលនូវសេចក្តីទុក្ខផង នូវសេចក្តីសុខផង នូវអំពើ អាក្រក់ហួសផ្លូវធម៌ផង នូវសេចក្តីចង្អៀតចង្អល់ចិត្តគ្រប់យ៉ាង តាមតែយ៉ាង ណាក៏ដោយ អំពីដំណើរនេះ ដោយផ្ទាល់ទ្រូងដូចជាផែនដី ( ដែលទទួល នូវវត្ថុណាមួយ ) របស់ពួកជនអ្នកមាំមួន គឺ ព្រះអរហន្ត នឹងរបស់ពួកជន

អ្នកតក់ស្លុត គឺបុថុជ្ជន ។

[ ៤២ ] ( ព្រះរាជា... ) ខ្ញុំមិនប្រាថ្នាអំពើអាក្រក់ហួសផ្លូវធម៌ផង សេចក្តីទុក្ខជាគ្រឿងចង្អៀតចង្អល់ចិត្តផង ដល់ជនទាំងឡាយដទៃទេ ខ្ញុំតែម្នាក់ឯង ឋិតនៅក្នុងធម៌ មិនញុំាងប្រយោជន៍បន្តិចបន្តួចឲ្យសាបសូន្យទៅទេ ហើយនឹងធ្ងន់នូវការៈ គឺសេចក្តីទុក្ខនេះ ។

[ ៤៣ ] ( អភិបារកៈ... ) បពិត្រព្រះជនិន្ទៈ ព្រះអង្គកុំធ្វើនូវបុញ្ញកម្ម ជាគ្រឿងញុំាងសត្វឲ្យកើតក្នុងឋានសួគ៌ របស់ទូលព្រះបង្គំជាខ្ញុំ ឲ្យអន្តរាយឡើយ ទូលព្រះបង្គំជាខ្ញុំជ្រះថ្លា ថ្វាយនាងឧម្មាទន្តីចំពោះព្រះអង្គ ដូចជាព្រះរាជា ( ដែលទ្រង់ព្រះរាជទាន ) នូវទ្រព្យក្នុងការបូជា ដល់ពួកព្រាហ្មណ៍ ។

[ ៤៤ ] ( ព្រះរាជា... ) ម្នាលអ្នកធ្វើនូវប្រយោជន៍ អ្នកជាបុគ្គលមានប្រយោជន៍ដល់ខ្ញុំដោយពិត នាងឧម្មាទន្តី និងអ្នកជាសម្លាញ់របស់ខ្ញុំ ពួកទេវតានិងទេវតាជាបិតា និងអ្នកទាំងអស់មុខជានិន្ទា ទាំងខ្ញុំក៏មុខជានឹងឃើញនូវបាបក្នុងអភិសម្បរាយកពពុំខាន ។

[ ៤៥ ] ( អភិបារកៈ... ) បពិត្រព្រះបាទសិវិ ពួកអ្នកនិគមនិងពួកអ្នកជនបទទាំងអស់គ្នា មិនគប្បីពោលនូវអំពើដែលទូលព្រះអង្គជាខ្ញុំ បានថ្វាយនាងឧម្មាទន្តីចំពោះព្រះអង្គនុ៎ះថាជាធម៌ទេ បពិត្រព្រះរាជា សូមព្រះអង្គធ្វើនូវព្រៃ ( តណ្ហា ) ឲ្យខ្ទាំងក្លា ( បើ ) ព្រះអង្គ ( លែងសព្វព្រះរាជហឫទ័យហើយ ) សូមលះបង់ចុះ ។

[ ៤៦ ] ( ព្រះរាជា... ) ម្នាលអ្នកធ្វើនូវប្រយោជន៍ អ្នកជាបុគ្គល

មានប្រយោជន៍ដល់ខ្ញុំ ដោយពិត នាងឧម្មាទន្តីនិងអ្នក ជាសម្លាញ់របស់ខ្ញុំ ធម៌ទាំងឡាយ ដែលពួកសប្បុរសបានសម្តែងល្អហើយ ខ្ញុំប្រព្រឹត្តកន្លងបាន ដោយកម្រ ដូចជាសមុទ្ទនិងច្រាំង ។

[ ៤៧ ] ( អភិបារកៈ... ) ព្រះអង្គជាអាហុនេយ្យបុគ្គល ជាអ្នកអនុគ្រោះដោយប្រយោជន៍ ជាអ្នកទ្រទ្រង់ ជាអ្នកចាត់ចែង ( ឥស្សរិយសុខ ) នឹងជាអ្នករក្សានូវសេចក្តីប្រាថ្នារបស់ទូលព្រះបង្គំជាខ្ញុំ បពិត្រព្រះរាជា នាងឧម្មាទន្តីដែលទូលព្រះបង្គំជាខ្ញុំ បានថ្វាយព្រះអង្គនឹងមានផលច្រើន សូមទ្រង់ទទួលយកនាងឧម្មាទន្តី តាមសេចក្តីប្រាថ្នារបស់ទូលព្រះបង្គំជាខ្ញុំ ។

[ ៤៨ ] ( ព្រះរាជា... ) ម្នាលអភិបារកៈ ជាកូនរបស់សេនាបតី ជាអ្នកធ្វើនូវប្រយោជន៍ អ្នកមិនមែនជាបុគ្គលប្រព្រឹត្តនូវធម៌ទាំងអស់ ដល់ខ្ញុំដោយពិត ជនមានជើង ២ ដទៃ តើរូបណាក្នុងជីវលោកនេះ ជាអ្នកធ្វើនូវសួស្តីដល់អ្នក ក្នុងពេលអរុណោរះ ។

[ ៤៩ ] ( អភិបារកៈ... ) ព្រះអង្គជាបុគ្គលប្រសើរផុត ព្រះអង្គជាបុគ្គលខ្ពង់ខ្ពស់ផុត ព្រះអង្គជាអ្នកដល់នូវធម៌ ជ្រាបច្បាស់នូវធម៌ មានព្រះប្រាជ្ញាប្រពៃ ទ្រង់ជាអ្នកគ្រប់គ្រងនូវធម៌ សូមទ្រង់មានព្រះជន្មាយុអស់កាលដ៏អង្វែង បពិត្រព្រះធម្មបាល សូមទ្រង់សម្តែងធម៌ដល់ទូលព្រះបង្គំជាខ្ញុំ ។

[ ៥០ ] ( ព្រះរាជា... ) បើដូច្នោះ ម្នាលអភិបារកៈ អ្នកចូរស្តាប់ពាក្យខ្ញុំ ខ្ញុំនឹងសម្តែងធម៌ដែលពួកសប្បុរសធ្លាប់សេពដល់អ្នក ។ ព្រះរាជាជាអ្នកគាប់ចិត្តដោយធម៌ទើបល្អ ជនមានប្រាជ្ញាទើបល្អ ការមិនប្រទូស្តមិត្តទើបល្អ

កិរិយាមិនធ្វើបាបទើបសុខ ។ មនុស្សទាំងឡាយ គប្បីនៅជាសុខក្នុងផ្ទះរបស់ខ្លួន ក្នុងម្លប់ដ៏ត្រជាក់ ក្នុងដែននៃស្តេចដែលមិនមានក្រោធ មានច្បាប់បិតថេរ ។ ខ្ញុំមិនគាប់ចិត្តនឹងអំពើដែលមិនពិចារណាហើយធ្វើ ដែលធ្វើមិនប្រពៃនោះទេ ម្យ៉ាងទៀត ជនទាំងឡាយណាដឹងថា ( មិនប្រពៃ ) ហើយ មិនធ្វើដោយខ្លួនឯង ( អំពើរបស់ជនទាំងឡាយនោះ ទើបខ្ញុំពេញចិត្ត ) អ្នកស្តាប់ពាក្យប្រៀបធៀបនេះរបស់ខ្ញុំចុះ ។ កាលគោទាំងឡាយកំពុងឆ្លងទៅ បើគោបាទៅវៀចផ្លូវ កាលបើគោអ្នកនាំផ្លូវទៅវៀចហើយ ពួកមេគោទាំងអស់នោះ ក៏ដើរវៀចដែរ ។ បណ្តាមនុស្សទាំងឡាយ ក៏ដូច្នោះ ជនណាដែលអ្នកផងសន្មតិជាប្រសើរផុត បើជននោះ ប្រព្រឹត្តនូវអធម៌ទៅហើយ នឹងចាំបាច់និយាយទៅថ្វីដល់ប្រជាជនក្រៅនេះ បើព្រះរាជាមិនប្រកបដោយធម៌ រាស្ត្រទាំងអស់តែងដេកជាទុក្ខ ។ កាលបើគោទាំងឡាយកំពុងឆ្លងទៅ គោបាទៅត្រង់ កាលបើគោអ្នកនាំផ្លូវទៅត្រង់ហើយ ពួកមេគោទាំងអស់នោះក៏ដើរទៅត្រង់ ។ បណ្តាមនុស្សទាំងឡាយក៏ដូច្នោះ ជនណាដែលអ្នកផងសន្មតិថា ប្រសើរផុត បើជននោះប្រព្រឹត្តធម៌ នឹងចាំបាច់ពោលទៅថ្វីដល់ប្រជាជនក្រៅនេះ បើព្រះរាជាទ្រង់ប្រកបដោយធម៌ រាស្ត្រទាំងអស់រមែងដេកជាសុខ ។ ម្នាលអភិបារកៈ ខ្ញុំមិនប្រាថ្នានូវភាពនៃខ្លួនជាទេវតា ដោយអធម៌ទេ ម្យ៉ាងទៀត ( ខ្ញុំមិនប្រាថ្នា ) ដើម្បីឈ្នះនូវផែនដីទាំងមូលនេះ ( ដោយអធម៌ទេ ) ។ ថ្វីបើក្នុងមនុស្សលោកនេះ មានរតនវត្ថុណាមួយ គឺគោទាំងឡាយ ខ្ញុំ ប្រាក់ សំពត់ និងខ្លឹមចន្ទន៍ក្រហម ដោយពិតដូច្នោះ ។ ព្រះចន្ទនិងព្រះអាទិត្យទាំងឡាយនេះ

រក្សាទុកនូវគេនៈណាមួយ គឺសេះនិងស្ត្រីទាំងឡាយ កែវមណី បុគ្គលមិនគួរប្រព្រឹត្តនូវធម៌មិនប្រសើរ ព្រោះហេតុនៃរតនវត្ថុនោះៗទេ យើងដូចជាគោឧសភៈ កើតក្នុងចំណោមនៃពួកជនអ្នកនៅក្នុងដែនសីវិ ។ ខ្ញុំនោះ ជាអ្នកដឹកនាំ ជាអ្នកស្វែងរកប្រយោជន៍ ល្បីល្បាញរក្សានូវដែន លំអុតលំឱនចំពោះប្រពៃណី ( របស់ស្តេចជាន់មុន ) នៃអ្នកសីវិរាស្រ្តទាំងឡាយ ជាអ្នកត្រិះរិះតែធម៌ ព្រោះហេតុនោះ ខ្ញុំមិនលុះក្នុងអំណាចនៃចិត្តរបស់ខ្លួនទេ ។

[ ៥១ ] ( អភិបារកៈ... ) បពិត្រមហារាជ ព្រះអង្គនឹងសោយរាជសម្បត្តិទៀងទាត់ មិនវិនាស ក្សេមក្សាន្ត បានយូរយារដោយពិត ដ្បិតប្រាជ្ញារបស់ព្រះអង្គប្រាកដដូច្នោះ ។ ព្រះអង្គមិនប្រមាទចំពោះធម៌ណា ទូលព្រះបង្គំជាខ្ញុំ សូមអនុមោទនា ចំពោះធម៌នុ៎ះរបស់ព្រះអង្គ ក្សត្រជាឥស្សរប្រមាទចំពោះធម៌ហើយ រមែងឃ្លាតចាកដែន ។ បពិត្រខត្តិយមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ក្នុងមាតាបិតាទាំងឡាយ បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រខត្តិយមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ក្នុងរាជបុត្តនិងអគ្គមហេសី បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយនឹងទៅកាន់ឋានសួគ៌ ។ បពិត្រខត្តិយមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ក្នុងពួកមិត្តនិងអាមាត្យ បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ក្នុងពួកវាហនៈផង ក្នុងពួកពលផង បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមទ្រង់

ប្រព្រឹត្តធម៌ក្នុងពួកអ្នកស្រុកផង ក្នុងពួកអ្នកនិគមផង បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ ក្នុងពួកអ្នកដែនផង ក្នុងពួកអ្នកជនបទផង បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ក្នុងសមណៈផង ក្នុងពួកព្រាហ្មណ៍ផង បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រខត្តិយមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ក្នុងពួកម្រឹគនិងបក្សី បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ចុះ ( ដ្បិត ) ធម៌ដែលគេសន្សំហើយ តែងនាំមកនូវសេចក្តីសុខ បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ចុះ ( ដ្បិត ) ព្រះឥន្ទ្រទាំងឡាយ ទេវតាទាំងឡាយ ព្រមទាំងព្រហ្ម បានដល់នូវអត្តភាពជាទិព្វ ដោយសារធម៌ ដែលគេបានសន្សំទុកល្អហើយ បពិត្រព្រះរាជា ព្រះអង្គកុំប្រមាទចំពោះធម៌ឡើយ ។

**ចប់ ឧម្មាទន្តីជាតកទី ២ ។**

# អដ្ឋកថា

# ឧម្មាទន្តីជាតក

[ ២០-៥១ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ ឧក្កណ្ឋិតភិក្ខុ ( ភិក្ខុអ្នកអផ្សុក ) ទើបត្រាស់ធម្មទេសនានេះ មានពាក្យ ផ្តើមថា **និវេសនំ កស្ស នុទំ សុនន្ទ** ដូច្នេះជាដើម ។

បានឮថា ថ្ងៃមួយ ភិក្ខុរូបនោះ ត្រាច់ទៅបិណ្ឌបាតក្នុងនគរសាវត្ថី បាន សម្លឹងឃើញស្ត្រីម្នាក់ ដែលប្រដាប់តាក់តែងល្អហើយ មានរូបស្អាតពន់ពេក កើតចិត្តប្រតិព័ទ្ធ មិនអាចឃាត់ចិត្តបាន ក៏មកកាន់វិហារ ។ ចាប់តាំងពីនោះ ក៏ជាបុគ្គលទន់ខ្សោយ ព្រោះរាគៈ ដូចត្រូវព្រួញចាក់ទម្លុះហើយ មានចំណែក ប្រៀបដូចម្រឹគដែលរត់ទៅ ។ ឯរាងកាយ ក៏ស្គាំងស្គម មានខ្ទួនរវាមដោយ សរសៃ ជាអ្នកស្គមលឿង មិនត្រេកអរក្នុងសាសនា កាលមិនបាននូវការ សប្បាយ សូម្បីក្នុងឥរិយាបថមួយ ទើបលះបង់នូវវត្ត មានអាចរិយវត្តនិង ឧបជ្ឈាយវត្តជាដើម ជាអ្នកនៅឆ្ងាយអំពីការប្រកបព្យាយាមក្នុងឧទ្ទេស បរិ បុច្ឆានិងកម្មដ្ឋាន ។ ភិក្ខុនោះត្រូវសព្រហ្មចារីសួរថា អាវុសោ កាលមុន លោក មានឥន្ទ្រិយស្រស់បស់ មានសម្បុរមុខផូរផង់ តែឥឡូវនេះ ពុំដូច្នោះឡើយ ព្រោះហេតុអ្វីហ្ន៎ ទើបឆ្លើយថា អាវុសោ ខ្ញុំមិនត្រេកអរក្រៃលែងក្នុងសាសនា ឡើយ ។ លំដាប់នោះ សព្រហ្មចារីទាំងនោះ ក៏ពោលទូន្មានថា អាវុសោ ចូរលោកត្រេកអរក្នុងសាសនាចុះ ធម្មតាការកើតឡើងនៃព្រះពុទ្ធ ជាសភាវៈ ដែលកើតឡើងដោយក្រ ការបានស្តាប់ព្រះសទ្ធម្ម និងការបានអត្តភាពជា មនុស្ស ក៏ជាវត្ថុដែលបានដោយក្រដូចគ្នា លោកបានអត្តភាពជាមនុស្សហើយ

កាលប្រាថ្នានឹងធ្វើទីបំផុតទុក្ខ ទើបលះមនុស្សដែលជាញាតិ ដែលមានទឹកភ្នែកជោកមុខ ហើយបួសដោយសទ្ធា ព្រោះហេតុអ្វី ទើបធ្លាក់ទៅក្នុងអំណាចនៃកិលេសទៅវិញ ឈ្មោះថាកិលេសទាំងនោះ មានឧបមាដូចផ្លែឈើ ដែលទូទៅដល់បុគ្គលពាលគ្រប់ពួក តាំងអំពីសត្វមានជីវិត មានជន្ទេនជាដើម វត្ថុទាំងនោះ ជាទីតាំងនៃកិលេសទាំងនោះ វត្ថុទាំងនោះជាកាមដែលមានសេចក្តីត្រេកអរតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងនោះ មានប្រមាណក្រៃលែង កាមទាំងឡាយ ប្រៀបដូចរាងឆ្អឹង កាមទាំងឡាយ ប្រៀបដូចដុំសាច់ កាមទាំងឡាយ ប្រៀបដូចគប់ភ្លើង កាមទាំងឡាយ ប្រៀបដូចរណ្តៅរងើកភ្លើង កាមទាំងឡាយ ប្រៀបដូចយល់សប្តិ កាមទាំងឡាយ ប្រៀបដូចរបស់ដែលខ្ចីគេមក កាមទាំងឡាយ ប្រៀបដូចផ្លែនៃដើមឈើពុល កាមទាំងឡាយ ប្រៀបដូចជ្រញ់ចិញ្ច្រាំសាច់ កាមទាំងឡាយ ប្រៀបដូចចម្រូងនិងលំពែង កាមទាំងឡាយ ប្រៀបដូចក្បាលពស់ ធម្មតាអ្នកបួសហើយក្នុងសាសនាបែបនេះ នៅធ្លាក់ទៅក្នុងអំណាចនៃកិលេស ដែលជាហេតុធ្វើនូវសេចក្តីវិនាសយ៉ាងនោះបាន កាលមិនអាចឲ្យភិក្ខុនោះទទួលយកពាក្យរបស់ខ្លួនបាន ទើបនាំគ្នាទៅគាល់ព្រះសាស្តាឯធម្មសភា កាលព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកនាំភិក្ខុដែលមិនមានសេចក្តីប្រាថ្នាមកធ្វើអ្វី ទើបនាំគ្នាទូលថា បពិត្រព្រះអង្គដ៏ចម្រើន បានឮថាភិក្ខុរូបនេះ ជាអ្នកអផ្សុក ។ ព្រះសាស្តាត្រាស់សួរថា ពាក្យគេនិយាយនេះជាពាក្យពិតឬ កាលភិក្ខុនោះក្រាបទូលថា ករុណាព្រះអង្គ ដូច្នេះ ទើបត្រាស់

ថា ម្នាលភិក្ខុ បុរាណកបណ្ឌិតទាំងឡាយ សូម្បីគ្រប់គ្រងរាជសម្បត្តិក៏មិនធ្លាក់ទៅកាន់អំណាចកិលេសដែលកើតឡើង ហាមឃាត់ចិត្តបាន មិនធ្វើវត្ថុដែលមិនសមគួរ ដូច្នេះហើយ ទើបទ្រង់នាំអតីតនិទានមកត្រាស់ថា

ក្នុងអតីតកាល ក្នុងដែនសីវិ ព្រះរាជាព្រះនាមថាសីវិ ទ្រង់គ្រប់គ្រងរាជសម្បត្តិនៅក្នុងអរិដ្ឋបុរីនគរ ព្រះពោធិសត្វកើតក្នុងព្រះឧទរអគ្គមហេសីរបស់ព្រះរាជាអង្គនោះ ព្រះបរមវង្សានុវង្សទាំងឡាយ នាំគ្នាថ្វាយព្រះនាមព្រះរាជឱរសនោះថា សីវិកុមារ សូម្បីកូនរបស់សេនាបតី ក៏ប្រសូតហើយ ពួកញាតិនាំគ្នាដាក់ឈ្មោះកុមារនោះថា អភិបារកៈ ។ កុមារទាំង ២ នោះជាសម្លាញ់នឹងគ្នា លុះចម្រើនវ័យមានអាយុ ១៦ ឆ្នាំ ទៅកាន់នគរតក្កសិលា លុះរៀនសិប្បៈចប់ហើយ ក៏នាំគ្នាត្រឡប់មក ។ ព្រះរាជាទ្រង់ព្រះរាជទានសម្បត្តិឲ្យព្រះរាជឱរសគ្រប់គ្រង ។ ព្រះរាជឱរសនោះ ក៏ទ្រង់តែងតាំងអភិបារកៈក្នុងតំណែងសេនាបតី ហើយទ្រង់គ្រប់គ្រងរាជសម្បត្តិដោយធម៌ ។ ក្នុងព្រះនគរនោះឯង មានកូនក្រមុំរបស់តិរិដិវច្ឆសេដ្ឋី មានទ្រព្យសម្បត្តិប្រមាណ ៨០ កោដិ ។ មានរូបសម្បត្តិស្អាតក្រៃលែង លើសស្រីទាំងពួងដោយសម្រស់ ប្រកបដោយលក្ខណៈដ៏ប្រពៃ ក្នុងថ្ងៃដាក់ឈ្មោះ ពួកញាតិបានដាក់ឈ្មោះថា ឧម្មាទន្តី ។ ក្នុងពេលនាងមានអាយុ ១៦ ឆ្នាំ មានពណ៌សម្បុរល្អលើសពួកមនុស្ស មានសម្រស់គួរមើលគួរសរសើរ ប្រៀបដូចស្រីទេពអប្សរ ។ ពួកបុថុជ្ជន ដែលឃើញនាង គ្រប់ ៗ គ្នា មិនអាចតាំងនៅដោយការៈរបស់ខ្លួន ជាអ្នកស្រវឹងហើយ ដោយការស្រវឹងគឺកិលេស

ដូចស្រវឹងដោយទឹកស្រវឹងដូច្នោះ ឈ្មោះថា អាចតាំងសតិទុកបាន មិនមានឡើយ ។ កាលនោះ តិរីដិវច្ឆៈជាបិតារបស់នាង ចូលទៅគាល់ព្រះរាជា ហើយក្រាបទូលថា បពិត្រព្រះសម្មតិទេព ឥត្ថីរតនៈសមគួរដល់ស្ដេចផែនដី បានកើតឡើងហើយក្នុងផ្ទះរបស់ទូលព្រះបង្គំ សូមទ្រង់បញ្ជូនព្រាហ្មណ៍ជាអ្នកទាយលក្ខណៈទាំងឡាយទៅ ឲ្យពិចារណាឥត្ថីរតនៈនោះហើយ សូមទ្រង់ធ្វើតាមព្រះរាជហឫទ័យ ។ ព្រះរាជាទ្រង់ទទួលពាក្យហើយ បញ្ជូនព្រាហ្មណ៍ទាំងឡាយទៅ ។ ព្រាហ្មណ៍ទាំងនោះទៅកាន់ផ្ទះរបស់សេដ្ឋីហើយ បានទទួលការស្វាគមន៍ដោយសក្ការៈ និងការរាប់អាន នាំគ្នាបរិភោគបាយាសហើយ ។

ក្នុងខណៈនោះ នាងឧម្មាទន្តីដែលប្រដាប់ដោយគ្រឿងអលង្ការសព្វយ៉ាង បានទៅកាន់សម្នាក់របស់ព្រាហ្មណ៍ទាំងនោះហើយ ។ ព្រាហ្មណ៍ទាំងនោះគ្រាន់តែឃើញនាង ក៏មិនអាចតម្កល់សតិបាន ជាអ្នកស្រវឹងដោយការស្រវឹង គឺកិលេស មិនបានដឹងថា ខ្លួនកំពុងបរិភោគ ។ ព្រាហ្មណ៍ខ្លះក៏ចាប់ដុំបាយទៅដាក់លើក្បាល ដោយសម្គាល់ថា អញនឹងបរិភោគ ព្រាហ្មណ៍ខ្លះក៏ញាត់ក្នុងក្លៀក ព្រាហ្មណ៍ខ្លះវាយជញ្ជាំងផ្ទះ ។ ពួកព្រាហ្មណ៍បានក្លាយដូចជាមនុស្សឆ្កួត ទាំងអស់ នាងឃើញព្រាហ្មណ៍ទាំងនោះក៏ពោលថា បានឮថា ព្រាហ្មណ៍ទាំងនេះ នឹងពិនិត្យមើលលក្ខណៈរបស់អញ អ្នកទាំងឡាយចូរអូសករបស់ព្រាហ្មណ៍ទាំងនេះទៅឲ្យអស់ ដូច្នេះហើយ បានឲ្យអ្នកបម្រើនាំព្រាហ្មណ៍ទាំងនោះចេញទៅ ។ ព្រាហ្មណ៍ទាំងនោះបានជាអ្នកខ្មាសអៀន ទៅកាន់ព្រះរាជ-

និវេសន៍ហើយ ទីងទីងនាងឧម្មាទន្តី ក៏ក្រាបទូលកុហកថា បពិត្រព្រះអង្គ ស្រីនោះ ជាស្រីកាឡកណ្ណី មិនសមគួរដល់ទ្រង់ឡើយ ។ ព្រះរាជាទ្រង់ជ្រាបថា ស្រីនោះជាស្រីកាឡកណ្ណី ទើបទ្រង់មិនបានឲ្យនាំស្រីនោះមក ។ នាងឧម្មាទន្តី បានដឹងរឿងនោះហើយ ទើបពោលថា ព្រះរាជាទ្រង់មិនទទួលអញ ដោយសម្គាល់ថា បានឮថា អញជាមនុស្សកាឡកណ្ណី ឈ្មោះថា ស្រីកាឡកណ្ណី មិនមែនមានរូបដូចអញឡើយ ដូច្នេះ ។ ទើបចងអាឃាតក្នុងព្រះរាជានោះថា ណ្ហើយចុះ បើអញបានចួលគាល់ព្រះរាជា ក៏នឹងដឹងគ្នា ។ ក្នុងកាលតមកឪពុករបស់នាងបានប្រគល់នាងឲ្យដល់អភិបារកៈ ។ នាងបានជាទីស្រឡាញ់ ជាទីពេញចិត្តរបស់អភិបារកសេនាបតី ។ សួរថា នាងមានរូបស្អាតយ៉ាងនេះ ព្រោះវិបាកកម្មដូចម្តេច ឆ្លើយថា ដោយវិបាកនៃការប្រគេនសំពត់ក្រហមនោះឯង ។

បានឮថា ក្នុងអតីតកាល នាងបានកើតក្នុងត្រកូលក្រីក្រ នាទគរពារាណសី ក្នុងថ្ងៃមហោស្រព នាងសម្លឹងឃើញស្រីទាំងឡាយ ដែលសម្បូរដោយបុណ្យ ស្លៀកសំពត់ដែលជ្រលក់ហើយដោយផ្កាជកគាំ ប្រដាប់តាក់តែងកំពុងលេង ជាហេតុឲ្យនាងត្រូវការស្លៀកសំពត់បែបនោះលេងនឹងគេដែរ ក៏ប្រាប់ឲ្យមាតាបិតាបានដឹង កាលលោកទាំង ២ នោះពោលថា នែកូន ពួកយើងជាមនុស្សក្រីក្រ ពួកយើងនឹងបានសំពត់យ៉ាងនោះអំពីណា ដូច្នេះ ទើបពោលថា បើដូច្នោះ សូមលោកអនុញ្ញាតឲ្យខ្ញុំធ្វើការបម្រើ ក្នុងត្រកូលស្តុកស្តម្ភណាមួយចុះ ពួកចៅហ្វាយទាំងនោះដឹងគុណរបស់ខ្ញុំហើយ ក៏គង់នឹងឲ្យ

ឯង ដូច្នេះ លុះបានទទួលអនុញ្ញាត អំពីមាតាបិតាហើយ ទើបចូលទៅកាន់ត្រកូលមួយ ពោលថា ខ្ញុំស្ម័គ្រធ្វើការងារស៊ីឈ្នួល ដើម្បីសំពត់ដែលជ្រលក់ដោយផ្កាដកគាំ ។ លំដាប់នោះ ពួកចៅកែពោលនឹងនាងថា បើនាងធ្វើការឲ្យយើង ៣ ឆ្នាំហើយ យើងដឹងគុណរបស់នាង ហើយនឹងឲ្យពិត ។ នាងទទួលពាក្យហើយ ក៏ចាប់ផ្តើមធ្វើការដល់ពួកចៅហ្វាយទាំងនោះ ។ ជនទាំងនោះដឹងគុណរបស់នាងហើយ ក្នុងកាលមិនទាន់គ្រប់ ៣ ឆ្នាំបរិបូណ៌នោះឯង ក៏បានប្រគល់សំពត់ដទៃ និងសំពត់ដែលជ្រលក់ដោយផ្កាដកគាំប្រភេទសាច់ម៉ដ្តឲ្យដល់នាង ហើយប្រាប់ថា ចូរនាងងូតទឹកជាមួយពួកសម្លាញ់របស់នាង ហើយសាកល្បងស្លៀកសំពត់នេះមើល ។ នាងទៅជាមួយពួកស្រីជាសម្លាញ់ ហើយដាក់សំពត់ដែលជ្រលក់ហើយលើច្រាំង ងូតទឹកហើយ ។ ក្នុងខណៈនោះ សាវ័ករបស់ព្រះទសពលព្រះនាមថាកស្សបៈ មួយរូបមានចីវរត្រូវចោរដណ្តើមយកទៅ ស្លៀកស្ទីកឈើដែលកាច់ បានមកកាន់ទីនោះហើយ នាងឃើញលោកហើយគិតថា លោកម្ចាស់រូបនេះ ប្រហែលជាត្រូវចោរដណ្តើមចីវរទៅ សំពត់របស់អញ ជារបស់រកបានលំបាក ព្រោះមិនបានឲ្យទានទុកក្នុងកាលមុន អញនឹងហែកសំពត់នោះជា ២ ចំណែក ហើយប្រគេនមួយចំណែកដល់ព្រះថេរៈ ដូច្នេះ ឡើងអំពីទឹកហើយ ស្លៀកសំពត់ផ្ទាល់ខ្លួន ហើយពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ឈប់សិនថ្វាយបង្គំព្រះថេរៈហើយ ហែកសំពត់នោះជា ២ ប្រគេនមួយចំណែកដល់ព្រះថេរៈនោះ ។ ព្រះថេរៈឈរក្នុងទីកំបាំងនាចំណែកម្ខាង ចោលមែកឈើ

ដែលកាច់បានហើយ ស្លៀកសំពត់នោះដោយជាយម្ខាង ដណ្តប់ដោយជាយម្ខាង ហើយចេញទៅ ។ លំដាប់នោះ ព្រោះរស្មីនៃសំពត់ផ្សាយចេញអំពីសរីរៈ ព្រះថេរៈមានរស្មីតែមួយដូចព្រះអាទិត្យបញ្ចេញនូវរស្មីស្រទន់ ដូច្នោះ នាងមើលព្រះថេរៈ ហើយគិតថា ដំបូងលោកម្ចាស់របស់អញមិនស្អាតឡើយ ឥឡូវនេះ ស្អាតរុងរឿងដូចព្រះអាទិត្យបញ្ចេញរស្មីដ៏ស្រទន់ ដូច្នោះ អញនឹងប្រគេនសំពត់នេះដល់លោកម្ចាស់នោះឯង ហើយប្រគេនសំពត់ចំណែកទី ២ បានតាំងសេចក្តីប្រាថ្នាថា បពិត្រលោកម្ចាស់ បើខ្ញុំអន្ទោលទៅក្នុងភពគប្បីជាអ្នកទ្រទ្រង់ទុកនូវរូបសម្រស់ បុគ្គលណាមួយ ឃើញខ្ញុំហើយ កុំបីអាចតាំងនៅដោយភាវៈរបស់ខ្លួនបានឡើយ ស្រីដទៃ ឈ្មោះថា មានរូបស្អាតជាងខ្ញុំ កុំបីមានឡើយ ព្រះថេរៈធ្វើអនុមោទនាហើយ ក៏ចៀសចេញទៅ ។ នាងអន្ទោលទៅក្នុងទេវលោក វិលវល់មកកើតក្នុងអរិដ្ឋបុរី ក្នុងកាលនោះហើយ មានរូបរាងស្អាតតាមប្រាថ្នាទុកហើយនោះឯង ។

សម័យនោះ ក្នុងព្រះនគរនោះ មហាជនទាំងឡាយបានឃោសនាលេងមហោស្រពប្រចាំខែកត្តិក ។ មហាជនទាំងឡាយ បានត្រៀមរៀបចំព្រះនគរក្នុងថ្ងៃមហោស្រព ក្នុងខែកត្តិកហើយ ។ អភិបារកសេនាបតី កាលទៅកាន់ទីរក្សារបស់ខ្លួន ទើបហៅភរិយាជាទីស្រឡាញ់មកពោលថា ឧម្មាទន្តី ថ្ងៃនេះពេលយប់នៃខែកត្តិក នឹងមានមហោស្រព ព្រះរាជាទ្រង់នឹងធ្វើប្រទក្សិណព្រះនគរ ទ្រង់ចូលកាត់ទ្វារផ្ទះរបស់យើងនេះមុនគេ នាងកុំបង្ហាញខ្លួនឲ្យព្រះរាជាឃើញ ព្រោះបើទ្រង់ឃើញនាងហើយ មិនអាចតម្កល់សតិទុកបានទេ ។

ឧម្មាទន្តីទទួលពាក្យស្វាមីថា សាធុ ខ្ញុំនឹងដឹងកិច្ចនេះ ដូច្នេះ ។ កាលប្តីទៅហើយ ទើបប្រាប់ទាសីថា ក្នុងកាលដែលព្រះរាជាយាងមកកាន់ទ្វារផ្ទះរបស់យើង ចូរនាងប្រាប់យើងឲ្យដឹងផង ។ លំដាប់នោះ កាលព្រះអាទិត្យអស្តង្គតហើយ ព្រះចន្ទក៏អណ្តែតលយលៀនជំនួស ព្រះនគរដែលប្រដាប់តាក់តែងហើយ មើលទៅប្រៀបដូចទេវនគរ ប្រទីបទាំងឡាយក៏ព្រោងព្រាតគ្រប់ទិស ។ ព្រះរាជា ទ្រង់ប្រដាប់តាក់តែងនូវគ្រឿងអលង្ការសព្វយ៉ាង ទ្រង់ប្រថាប់លើរថសេះដ៏ប្រសើរ ចោមរោមដោយពួកអាមាត្យ ទ្រង់ធ្វើប្រទក្សិណព្រះនគរដោយយសធំ ដល់ទ្វារផ្ទះរបស់អភិបារកសេនាបតី ដែលជាផ្ទះទី ១ ។ ផ្ទះមួយខ្នងនោះ ព័ទ្ធដោយកំពែងពណ៌ដូចមនោសិលា មានរោងសម្រាកត្រង់ខ្លោងទ្វារដែលប្រដាប់តាក់តែងដ៏ល្អ គួរមើល គួរសរសើរ ។ ខណៈនោះ ទាសីបានប្រាប់ឲ្យនាងឧម្មាទន្តីដឹងហើយ ។ នាងឧម្មាទន្តី ឲ្យទាសីកាន់ជើងពានដាក់ផ្កាហើយ ឈរផ្អែកសន្ទះបង្អួច ដោយលីលាដ៏ល្អ ដូចកិន្នរីបាចនូវផ្កាថ្វាយព្រះរាជា ព្រះរាជាសម្លឹងមើលនាង ក៏កើតនូវសេចក្តីស្រវឹងដោយកិលេស មិនអាចតម្កល់សតិបាន រហូតមិនអាចចាំបានថា ផ្ទះនេះជាផ្ទះរបស់អភិបារកសេនាបតី ។ សម័យនោះ ព្រះរាជាត្រាស់ហៅ នាយសារថីមកហើយ កាលនឹងត្រាស់សួរ ទើបពោលគាថា ២ ថា

> ហៃសុនន្ទៈ នេះជាទីលំនៅរបស់នរណាហ្ន៎ ដែលព័ទ្ធព័ទ្ធដោយកំពែង ធ្វើដោយឥដ្ឋពណ៌ក្រហម ស្ត្រីអ្វីប្រាកដ ដូចអណ្តាតភ្លើងក្នុងទីឆ្ងាយ ឬដូចជាអណ្តាតភ្លើងព្ធដ៏អាកាស លើ

កំពូលភ្នំ ។ ម្នាលសុនន្ទៈ ស្ត្រីនេះជាធីតារបស់នរណាហ្ន៎ ស្ត្រីនេះជាកូនប្រសាររបស់នរណាហ្ន៎ ឬជាភរិយារបស់នរណា ប្រសិនបើ ( ស្ត្រីនេះ ) មិនទាន់មានគេហួងហែងក្តី មានភស្តាក្តី ខ្ញុំសួរហើយ ចូរអ្នកប្រាប់យ៉ាងឆាប់ក្នុងកាលឥឡូវនេះ កុំខាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កស្ស នុធំ** កាត់បទថា **កស្ស នុ ឥធំ** ប្រែថា នេះជាផ្ទះរបស់អ្នកណាហ្ន៎ ។ បទថា **បណ្ឌុមយេន** បានដល់ សម្រេចដោយកំពែងឥដ្ឋពណ៌ក្រហម ។ បទថា **ធិស្សតិ** សេចក្តីថា ឈរត្រង់សន្ទះបង្អួច ។ បទថា **អច្ចិ** បានដល់ គំនរភ្លើងដែលមានខ្យល់បក់ ឆេះសន្ធោសន្ធៅ ។ បទថា **ធីតា ន្វាយំ** កាត់បទជា **ធីតា នុ អយំ** ប្រែថា ជាកូនស្រីរបស់អ្នកណាហ្ន៎ ។ បទថា **អវាវតា** បានដល់ មិនមានអ្នកការពារ គឺមិនមានអ្នកហួងហែង ។ បទថា **ភត្តា** សេចក្តីថា ប្តីរបស់នាងមានដែរឬទេ ចូរឯងប្រាប់សេចក្តីនេះដល់យើង ។

លំដាប់នោះ នាយសារថី កាលក្រាបទូលសេចក្តីនេះដល់ព្រះរាជា ក៏ក្រាបទូលគាថា ២ ថា

បពិត្រព្រះជនិន្ទៈ ខ្ញុំព្រះអង្គស្គាល់ស្ត្រីនុ៎ះជាក់លាក់ អំពីចំណែកខាងមាតាផង អំពីចំណែកខាងបិតាផង ទាំងស្វាមីរបស់ស្ត្រីនោះ ក៏ខ្ញុំព្រះអង្គស្គាល់ បពិត្រភូមិបាល ស្វាមីនោះជាបុរសរបស់ព្រះអង្គហ្នឹងឯង ជាអ្នកមិនប្រហែសធ្វេសក្នុង

ប្រយោជន៍របស់ព្រះអង្គ ទាំងយប់ទាំងថ្ងៃ ។ បពិត្រ ព្រះជនិន្ទៈ
ព្រះអង្គមាន អាមាត្យម្នាក់ ជាអ្នកស្អុកស្អម មាំមួន ប៉ុំប៉ើន
បពិត្រព្រះរាជា ស្ត្រីនោះឈ្មោះនាងឧម្មាទន្តី ជាប្រពន្ធរបស់
អាមាត្យឈ្មោះ អភិបារកៈនោះឯង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មត្យា ច បេត្យា ច** សេចក្ដីថា ខ្ញុំរមែងស្គាល់ស្រីនោះ ព្រមទាំងមាតានិងបិតា ។ សព្ទថា **អថោបិ អស្សា** នាយសារថីក្រាបទូលថា ប្ដីរបស់នាងទូលព្រះបង្គំក៏ស្គាល់ ។ បទថា **ឥទ្ធោ** បានដល់ ជាអ្នកបានទទួលនូវការសម្រេចហើយ ។ បទថា **ផីតោ** បានដល់ដល់ព្រមដោយសំពត់និងគ្រឿងអលង្ការទាំងឡាយ ។ បទថា **សុវឌ្ឍិតោ** បានដល់ ជាអ្នកស្អុកស្អមបរិបូណ៌ល្អ ។ បទថា **ឆាមធេយ្យេន** បានដល់មានឈ្មោះ ។ ពិតហើយ ស្រីនេះរមែងធ្វើបុរសដែលមើលនាងឲ្យវង្វេងដូចមនុស្សឆ្កួត គឺមិនឲ្យបុរសនោះតម្កល់សតិបាន ព្រោះហេតុនោះ ទើបលោកហៅថា ឧម្មាទន្តី ដូច្នេះ ។

ព្រះរាជាទ្រង់ស្ដាប់ពាក្យនោះហើយ កាលទ្រង់សរសើរឈ្មោះនាង ទើបត្រាស់គាថាបន្តថា

> វ៉ុយ វ៉ុយ ឈ្មោះនេះដែល មាតាបិតាបានឲ្យដល់នាងនេះ ត្រូវ
> ល្អណាស់ បានជាថាដូច្នោះ ព្រោះនាងឧម្មាទន្តី កាលក្រឡេក
> មើលអញ ធ្វើអញឲ្យឆ្កួត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មត្យា ច បេត្យា ច** បានដល់ មាតា និង

បិតា ។ បទថា **មយ្ហំ** ជាសម្បទាន ប្រើក្នុងអត្ថនៃទុតិយាវិភត្តិ ។ បទថា **អវលោកយន្តី** សេចក្តីថា នាងត្រូវយើងសម្លឹងមើលហើយ បែរមើលមកយើងដែរ បានធ្វើយើងឲ្យវង្វេង ដូចគ្នានឹងមនុស្សឆ្កួត ។

នាងឧម្មាទន្តីនោះ បានដឹងថា ព្រះរាជាទ្រង់ញាប់ញ័រក្នុងព្រះហឫទ័យហើយ ទើបបិទបង្អួច បានចូលទៅកាន់បន្ទប់ប្រកបដោយសិរីវិញ ។ តាំងពីកាលដែលព្រះរាជាទតឃើញនាងហើយ ទ្រង់មិនមានព្រះហឫទ័យ ដើម្បីធ្វើប្រទក្សិណព្រះនគរឡើយ ។ ព្រះរាជាត្រាស់ហៅនាយសារថីមកហើយ ត្រាស់ថា សុនន្ទះសម្លាញ់ ចូរឯងត្រឡប់រថចុះ បុណ្យនក្ខត្តឫក្សនេះ មិនសមគួរដល់យើង តែសមគួរដល់អភិបារកសេនាបតី សូម្បីរាជសម្បត្តិ ក៏សមគួរដល់អភិបារកសេនាបតីដូចគ្នា ដូច្នេះ ទើបឲ្យសារថីត្រឡប់រថទៅកាន់ព្រះរាជវាំង ទ្រង់ឡើងលើប្រាសាទហើយ ទ្រង់ផ្ទំរវើរវាយ លើព្រះបន្ទំដ៏មានសិរី ត្រាស់ថា

ស្ត្រីណាមានភ្នែកស្រទន់ដូចភ្នែកម្រឹគ មានសរីរៈសម្បុរដូចផ្កាឈូកក្រហមអង្គុយអែប ( ក្បែរបង្អួច ) ក្នុងរាត្រីដែលមានព្រះចន្ទពេញវង់ អញបានឃើញស្រីនោះ ដែលមានសម្លៀកសំពាក់ក្រហមដូចជាជើងព្រាប ក៏ស្មានថាជាព្រះចន្ទពេញវង់ពីរ ។ ( នាងឧម្មាទន្តី ) ប្រឡោមអញ ដោយអាការទ្រទេសទ្រទន់ ល្អស្រស់ ជាប្រធាននៃការដ៏វិសេស ម៉ឹកម៉ក់ ក្រឡេកមើលអញ ចិត្តរបស់អញក៏រវើរវាយ ដូច

ជាក្នុងកាលដែលកិន្នរញីកើតក្នុងព្រៃភ្នំ ( ហិមពាន្តធ្វើកិន្នរឈ្មោលឲ្យមានចិត្តរវើរវាយដូច្នោះ ) ។ ដ្បិតក្នុងកាលនោះ នាងនារីមានសម្បុរលឿង ពាក់កណ្ដាលកែវមណី មានសម្លៀកបំពាក់តែមួយ ប្រឡេកមើល ( អញ ) ដូចជាមេម្រឹគផ្អើល ។ កាលណាហ្ន៎ នឹងបាននារីមានក្រចកក្រហមទុំ មានរោមល្អ មានដើមដៃទន់ភ្លន់ លាបស្រឡាបដោយខ្លឹមចន្ទន៍ មានម្រាមដៃមូល ប្រសប់ខាងធ្វើម្ហូបម្ហូក់ ល្អផុតចុងសក់ មកឱបអង្អែលអញ ។ កាលណាហ្ន៎ អញនឹងបានធីតារបស់សេដ្ឋីឈ្មោះ តិរិដិ ដែលមានគ្រឿងប្រដាប់ទ្រូងជាវិការៈនៃមាស មានដងខ្លួនរៀវ មកឱបរឹតអញ ដោយដើមដៃទាំងពីរដ៏ទន់ភ្លន់ ដូចជាពួរជ្រៃដែលរួបរឹតដើមឈើដុះក្នុងព្រៃធំ ។ កាលណាហ្ន៎ អញនឹងបាន ( នារី ) ដែលមានសម្បុរល្អស្រស់ ដូចជាទឹកល័ក្តក្រហម មានដោះក្បុំដូចជាពពុះទឹក មានសរីរៈសម្បុរដូចផ្កាឈូកក្រហម បង្អោនមុខមកប៉ះនឹងមុខ ( អញ ) ដូចជាអ្នកលេង ( ដែលហុច ) កែវសុរាឲ្យដល់អ្នកលេងផងគ្នា ។ អញបានឃើញនារីនោះមានខ្លួនសមរម្យសព្វអន្លើ ជាតម្រេកនៃចិត្ត កំពុងឈរក្នុងកាលណា អញមិនបានជាឥស្សរៈ ( លើចិត្តរបស់ខ្លួន ) មិនស្គាល់នារីនោះថាជាអ្វីឡើយ ក្នុងកាលនោះ ។ អញបានឃើញនាងឧម្មាទន្តី ដែលពាក់កុណ្ឌលជា

វិការៈនៃកែវមណី ក៏ដេកមិនលក់ទាំងថ្ងៃទាំងយប់ ដូចជាគេ ផ្ចាញ់អស់ ១ ពាន់ដង ។ បើសក្កទេវរាជប្រទានពរដល់ អញ សូមឲ្យអញបានពរនោះថា អភិបារកសេនាបតី សូម ត្រេកត្រអាលជាមួយនឹងនាងឧម្មាទន្តី តែមួយយប់ពីរយប់ ប៉ុណ្ណោះចុះ តពីនោះទៅ សូមព្រះបាទសិវិរាជ ( ត្រេក ត្រអាលជាមួយនឹងនាងឧម្មាទន្តីវិញ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បុណ្ណមាសេ** បានដល់ ក្នុងរាត្រី ១៥ កើត ។ បទថា **មិគមន្ទលោចនា** សេចក្តីថា ឈ្មោះថា មិគមន្ទលោចនា ព្រោះអត្ថថា មានភ្នែកក្រឡង់ ដូចភ្នែកម្រឹគស្មាន់ដែលកំពុងភ័យខ្លាចនូវព្រួញ រត់ទៅពួន ក្នុងព្រៃ ហើយលួចមើលព្រាន ដូច្នោះ ។ បទថា **ឧបាវិសី** សេចក្តីថា នាង អង្គុយក្បែរបង្អួច យកបាតដៃដ៏ស្អាត ពណ៌ដូចផ្កាឈូក ច្បិចផ្កាបាចហើយ សម្លឹងមើលអញ ។ បទថា **បុណ្ណរីកត្តចង្គី** បានដល់ រាងកាយដែលមាន ពណ៌ដូចផ្កាឈូកក្រហម ។ បទថា **ទ្វេ បុណ្ណមាយោ** សេចក្តីថា ក្នុងថ្ងៃ នោះគឺក្នុងថ្ងៃមហោស្រពនោះ អញបានឃើញនាងស្លៀកដណ្តប់សំពត់ពណ៌ ក្រហម មានពណ៌ដូចដើងព្រាបនោះ ហើយសម្លឹងមើលនូវសម្រស់ផ្ទៃមុខ របស់នាង បានសម្គាល់ថា ព្រះចន្ទរះ ២ ព្រោះព្រះចន្ទពេញវង់រះឡើង ២ គឺ ១ រះឡើងបំភ្លឺលោកធាតុទិសខាងកើត ១ រះក្នុងផ្ទះរបស់អភិបារក សេនាបតី ។ បទថា **អឡារបម្ហេហិ** បានដល់ មានមុខទូលាយ ។ បទថា **សុភេហិ** បានដល់ សស្អាត ។ បទថា **វគ្គុភិ** បានដល់ ដោយកិរិយាទន់

ភ្ញូន់ ។ បទថា **ឧទិក្ខតិ** បានដល់ ក្នុងខណៈដែលនាងសម្លឹងមើលអញ ដោយភ្នែកទាំងគូ បែបនោះ ។ បទថា **បញ្ចេតេ** សេចក្ដីថា ហាក់ដូចជាធក់យកដួងហទយៈរបស់អញទៅ គឺប្ញូន់យកទៅ ដូចកិន្នរីកើតលើកំពូលភ្នំហិមពាន្ត ក្នុងព្រៃដែលមានផ្ការីកស្គុសស្គាយ កាន់ពិណាប្រៀបធៀបសំឡេងរបស់ខ្លួននឹងសំឡេងពិណា រមែងធក់យកចិត្តកិន្នរមកបាន យ៉ាងនោះ ។ បទថា **ព្រហាតី** គឺនាងដ៏ប្រសើរ ។ បទថា **សាមា** គឺជាអ្នកមានខ្លួនពណ៌ដូចមាស ។ បទថា **ឯកច្ចវសនា** បានដល់ នៅដោយសំពត់មួយផ្ទាំង អធិប្បាយថា មានសំពត់ស្លៀកដណ្ដប់មួយផ្ទាំង ។ បទថា **ភគ្គាវុទិក្ខតិ** ព្រះរាជាត្រាស់ថា ស្រីឧត្តមនោះ មានសរសៃសក់ល្អិតឆ្មារ មានថ្ងាសទូលាយ មានចិញ្ចើមវែងវៀវ មានភ្នែកធំស្អាត មានប្រមុះកោង មានបបូរមាត់ក្រហម មានធ្មេញទាំងឡាយស្អាត មានចង្កូមមុត មានកមូលល្អ មានដៃទន់ មានស្តនស្អាតល្អ មានចង្កេះដូចម្រឹគញី មានត្រគាកធំ មានរូបស្មើ ដូចគ្នានឹងដើមចេកមាស ក្នុងខណៈដែលនាងមើលអញបណ្តើរ រត់ចូលទៅក្នុងបណ្តើរដោយការខ្លាច ហើយបែរមកមើលអញ ដូចម្រឹគញីផាកមើលព្រាន ដូច្នោះ ។ បទថា **ពាហា មុទូ** សេចក្ដីថា មានដើមដៃទន់ ។ បទថា **សន្ទតធីរកុត្តិយា** បានដល់ មានអាកប្បកិរិយាឈ្លាសវាងវៃ ។ បទថា **ឧបញ្ញិស្សតិ មំ** សេចក្ដីថា ព្រះរាជាទ្រង់រវើរវាយប្រាថ្នាថា ស្រីស្អាតនោះ មានក្រចកទាំងអស់ពណ៌ក្រហម មានអាកប្បកិរិយាឈ្លាសវាងវៃ ស្អាតតាំងអំពីចុងសក់ចុះទៅ កាលណាហ្ន៎ នឹងបានអញ ។ បទថា **កាញ្ចនជាលុរច្ឆទា** បានដល់ មាន

ទ្រូងប្រដាប់ដោយមាស គាក់តែងហើយ ។ បទថា **វិលាកមជ្ឈា** បានដល់ សរីរៈត្រង់ចង្កេះ ។ បទថា **ព្រហាវនេ** បានដល់ក្នុងព្រៃធំ ។ បទថា **រត្ត-សុច្ឆវី** បានដល់ មានពណ៌សម្បុរដូចកែវប្រពាល ក្រហមដូចទឹកល័ខត្រង់ បាតដៃ បាតជើង ចុងក្រចក និងសាច់បបូរមាត់ ។ បទថា **ពិឡុត្ថនី** បាន ដល់ មានសុដន់ជាបរិមណ្ឌលដូចពពុះទឹក ។ បទថា **តតោ** សេចក្តីថា តាំង ពីកាលដែលអញបានឃើញនាងឈរ ។ បទថា **សកស្ស ចិត្តស្ស** អធិប្បាយ ថា អញមិនមានភាពជាធំកើតអំពីចិត្តរបស់ខ្លួនឡើយ ។ បទថា **កញ្ញិំ** អធិប្បាយថា ព្រះរាជាត្រាស់ថា អញមិនស្គាល់ស្រីនោះថា ស្រីនេះ ឈ្មោះ នោះ អញជាមនុស្សឆ្កួតហើយ ។ បទថា **ទិដ្ឋា** បានដល់ គ្រាន់តែឃើញ នាងហើយ ។ បទថា **ន សុប្បាមិ** សេចក្តីថា យើងរមែងមិនបានទូវការ ដេកលក់ទាំងពេលយប់និងពេលថ្ងៃ ។ បទថា **សោ ច លព្ភេថ** សេចក្តីថា សូមឲ្យពរដែលសក្កៈប្រទានដល់អញ ចូរជារបស់អញចុះ គឺអញគប្បីបាន ពរនេះចុះ ។

ពួករាជបុរស ក៏នាំគ្នាទៅប្រាប់ដល់អភិបារកសេនាបតីថា បពិត្រលោក ម្ចាស់ ស្តេចផែនដីទ្រង់ប្រទក្សិណព្រះនគរ លុះមកដល់ទ្វារផ្ទះរបស់លោក ហើយ ក៏យាងត្រឡប់ទៅកាន់ប្រាសាទវិញ ។ អភិបារកសេនាបតីនោះ ក៏ទៅ កាន់ផ្ទះរបស់ខ្លួនហើយ ហៅនាងឧម្មាទន្តីមកសួរថា នែនាង នាងបង្ហាញខ្លួន ឲ្យប្រាកដដល់ព្រះរាជាឬ នាងឆ្លើយថា បពិត្រអ្នក បុរសម្នាក់ពោះធំ ចង្កូមធំ ឈរលើរាជរថ ខ្ញុំមិនស្គាល់បុរសនោះថាជាព្រះរាជា ឬមិនមែនព្រះរាជា តែ

លុះពួកមនុស្សពោលថា ជាបុរសឯក ដូច្នេះ ខ្ញុំឈរត្រង់មាត់បង្អួច ទើបបាចផ្កាទៅ បុរសនោះឈរមួយស្របក់ ហើយក៏ត្រឡប់ទៅ អភិបារកសេនាបតីស្តាប់ពាក្យនោះហើយ ក៏ពោលថា នាងធ្វើឲ្យអញវិនាសហើយ ដូច្នេះ ។ ស្អែកឡើង ក៏ប្រញាប់ប្រញាល់ទៅកាន់ព្រះរាជនិវេសន៍អំពីព្រលឹម ឈរត្រង់ទ្វារបន្ទប់ដ៏មានសិរី បានឮសំឡេងព្រះរាជាវេរីវាយដល់នាងឧម្មាទន្តី ទើបគិតថា ព្រះរាជាអង្គនេះ ស្រឡាញ់ឧម្មាទន្តី បើមិនបានគង់នឹងសោយទិវង្គតពិត អញគួរជួយដោះទោសដែលមិនមែនជាគុណរបស់ព្រះរាជា ហើយថ្វាយជីវិតដល់ព្រះរាជាអង្គនេះចុះ ទើបត្រឡប់ទៅកាន់ផ្ទះរបស់ខ្លួន ហៅអ្នកបម្រើស្និទ្ធស្នាលម្នាក់មកប្រាប់ថា នែបា ក្នុងទីនោះ មានដើមជ្រៃធំប្រហោងមួយដើម ឯងកុំឲ្យអ្នកណាដឹង កាលព្រះអាទិត្យលិចហើយ ឯងចូរទៅក្នុងទីនោះ ចូលទៅអង្គុយក្នុងដើមឈើ អញនឹងធ្វើពលីកម្មត្រង់ដើមឈើនោះ ។ លុះទៅដល់ដើមឈើនោះ នមស្ការទេវតាហើយនឹងអង្វរថា បពិត្រទេវរាជជាធំកាលមហោស្រពមានក្នុងព្រះនគរ ព្រះរាជារបស់ខ្ញុំ ទ្រង់មិនក្រសាល យាងត្រឡប់ទៅកាន់បន្ទប់ដ៏មានសិរី ទ្រង់ផ្ទុំវេរីវាយ ពួកខ្ញុំមិនដឹងដល់ហេតុនោះឡើយ ព្រះរាជាទ្រង់មានឧបការៈច្រើនដល់ពួកទេវតា ទ្រង់លះទ្រព្យ ១០០០ ធ្វើពលីកម្មរៀងរាល់កន្លះឆ្នាំ សូមពួកលោកប្រាប់ថា ព្រះរាជាទ្រង់វេរីវាយ ព្រោះអាស្រ័យហេតុឈ្មោះនេះ ដូច្នេះ អញនឹងអង្វរថា ចូរឲ្យជីវិតទានដល់ព្រះរាជាពួកខ្ញុំផងចុះ ក្នុងខណៈនោះ ឯងគប្បីធ្វើសំឡេង ហើយពោលថា នែលោកសេនាបតី ឈ្មោះថាជំងឺតម្កាត់ មិនមានដល់ព្រះរាជារបស់ពួកអ្នកឡើយ តែ

ទ្រង់មាន ចិត្តប្រតិព័ទ្ធក្នុងនាងឧម្មាទន្តី ដែលជាភរិយារបស់លោក បើទ្រង់បាននាង ទើបរស់រានមានជីវិត បើមិនបាននឹងសោយទិវង្គតពិត បើលោកប្រាថ្នាឲ្យទ្រង់មានព្រះជន្ម ចូរថ្វាយនាងឧម្មាទន្តីដល់ទ្រង់ចុះ ដូច្នេះ ។ កាលសេនាបតីឲ្យអ្នកបម្រើចាំនូវពាក្យសម្ដីយ៉ាងនេះហើយ ក៏បញ្ជូនទៅ ។ អ្នកបម្រើនោះ ចូលទៅអង្គុយក្នុងព្រង់ឈើនោះ ស្អែកឡើង សេនាបតីទៅកាន់ទីនោះហើយ ទើបពោលពាក្យអង្វរ អ្នកបម្រើធ្វើតាមពាក្យប្រាប់គ្រប់ប្រការ ។ សេនាបតីពោលថា សាធុ ហើយថ្វាយបង្គំទេវតា ប្រាប់ឲ្យពួកអាមាត្យជ្រាបរឿង ហើយចូលទៅកាន់ព្រះនគរ ឡើងទៅកាន់ព្រះរាជនិវេសន៍ ហើយគោះទ្វារបន្ទប់ ដែលប្រកបដោយសិរី លុះស្ដេចផែនដីត្រឡប់បាននូវសតិ បានត្រាស់ថា អ្នកណា សេនាបតីក្រាបទូលថា បពិត្រព្រះអង្គទូលព្រះបង្គំ គឺអភិបារកសេនាបតី ។ លំដាប់នោះ ព្រះរាជាទ្រង់បើកទ្វារឲ្យចូល អភិបារកៈចូលទៅ ថ្វាយបង្គំព្រះរាជាហើយ ពោលគាថាដូច្នេះថា

> បពិត្រព្រះអង្គជាម្ចាស់នៃជន កាលដែលទូលព្រះបង្គំជាខ្ញុំ សំពះ
> ទេវតាទាំងឡាយ មានទេវតា ( មួយអង្គ ) មកពោលពាក្យ
> ដូច្នេះថា ព្រះទ័យរបស់ព្រះរាជាជាប់ជំពាក់នឹងនាងឧម្មាទន្តី ទូល
> ព្រះបង្គំជាខ្ញុំ សូមថ្វាយព្រះអង្គ សូមព្រះអង្គឲ្យនាងឧម្មាទន្តី
> នោះ បម្រើចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឆមស្សតោ** បានដល់ កាលទូលព្រះបង្គំធ្វើពលីកម្មបន់ស្រន់ ដើម្បីដឹងដល់ហេតុនៃការរវើរវាយរបស់ទ្រង់ ។ បទថា **តំ**

សេចក្ដីថា ទូលបង្គំសូមថ្វាយនាងឧម្មាទន្តីនោះឲ្យជាបាទបរិចារិកាសម្រាប់ទ្រង់ ។

លំដាប់នោះ ព្រះរាជាត្រាស់សួរសេនាបតីថា នែអភិបារកៈសម្លាញ់ ពួកទេវតាក៏ដឹងរឿងដែលយើងរវើរវាយ ព្រោះមានចិត្តស្រឡាញ់ក្នុងនាងឧម្មាទន្តីដែរឬ សេនាបតីទូលថា យ៉ាងនោះឯងព្រះអង្គ ។ ព្រះរាជាត្រិះរិះថា អំពើអាក្រក់របស់អញ សត្វលោកទាំងអស់ដឹងហើយ ដូច្នេះ ទើបទ្រង់តាំងនៅក្នុងលជ្ជីធម៌ ហើយត្រាស់គាថាជាបន្ទថា

ខ្ញុំគប្បីឃ្លាតចាកបុណ្យផង ខ្ញុំមិនមែនជាមិនស្លាប់ផង អ្នកផង ដឹងនូវអំពើអាក្រក់របស់ខ្ញុំនេះផង សេចក្ដីបង្អៀតចង្អល់ចិត្ត គប្បីមានដល់អ្នកយ៉ាងខ្លាំង ព្រោះអ្នកឲ្យ ( នាងឧម្មាទន្តី ) ជាទីស្រឡាញ់ ហើយមិនបានឃើញទៀតផង ដូច្នេះ ។

បណ្ដាបទទាំងនោះបទថា **ធំសេ** សេចក្ដីថា នែអភិបារកសេនាបតី សម្លាញ់កាលយើងបម្រើជាមួយនាងដោយអំណាចកិលេស គប្បីសាបសូន្យចាកបុណ្យ នឹងមិនបានជាទេវតា ព្រោះហេតុត្រឹមតែការនៅរួមជាមួយ នាងនោះម្យ៉ាងទៀត មហាជនគប្បីដឹងអំពើលាមកនេះ បន្ទាប់អំពីនោះ ក៏នឹងតិះដៀលថា ព្រះរាជាទ្រង់ធ្វើវត្ថុដែលមិនសមគួរឡើយ ម្យ៉ាងទៀត ឯងឲ្យនាងដែលជាកិរិយាជាទីស្រឡាញ់ដល់យើងហើយ ក្នុងកាលខាងក្រោយ មិនបានឃើញកិរិយា ការបង្អៀតចង្អល់ចិត្តគប្បីមានដល់ឯង ។

គាថាដ៏សេស ជាពាក្យឆ្លើយឆ្លងរវាងជនទាំង ២ មានដូចតទៅនេះ

អភិបារកពោលថា

បពិត្រព្រះជនិន្ទៈ លើកលែងតែព្រះអង្គនឹងទូលព្រះបង្គំជាខ្ញុំចេញ អ្នកទាំងពួងមិនគប្បីដឹងនូវអំពើដែលទូលព្រះបង្គំជាខ្ញុំថ្វាយនាងឧម្មាទន្តីដល់ព្រះអង្គទេ បពិត្រព្រះរាជា សូមព្រះអង្គធ្វើនូវព្រៃគឺតណ្ហាឲ្យខ្ទាំងក្ខាចុះ ( បើ ) ព្រះអង្គ ( លែងសព្វព្រះរាជហឫទ័យហើយសូមលះបង់ចុះ ) ។

ព្រះរាជាត្រាស់ថា

មនុស្សណា ធ្វើអំពើអាក្រក់ មនុស្សនោះតែងសម្គាល់ថា ជនទាំងឡាយដទៃពុំដឹងនូវអំពើអញនេះឡើយ តែពួកភូតនឹងពួកនរជនដែលប្រកប ( ដោយឫទ្ធិ ) លើផែនដី រមែងឃើញបុគ្គលដែលធ្វើបាបកម្មនុ៎ះ ។ ជនដទៃណាម្នាក់ លើផែនដី ក្នុងលោកគប្បីជឿចិត្តអ្នកថា នាង ( ឧម្មាទន្តី ) មិនជាទីស្រឡាញ់របស់អញ ដូច្នេះ ទាំងសេចក្តីបង្អៀតបង្អល់ចិត្ត គប្បីមានដល់អ្នកយ៉ាងខ្លាំង ព្រោះអ្នកឲ្យនាងឧម្មាទន្តី ជាទីស្រឡាញ់ហើយ មិនបានឃើញទៀត ។

អភិបារកពោលថា

បពិត្រព្រះជនិន្ទៈ នាងឧម្មាទន្តីនុ៎ះ ជាទីស្រឡាញ់របស់ទូលព្រះបង្គំជាខ្ញុំដោយពិត បពិត្រព្រះភូមិបាល នាងនោះមិនមែនមិនជាទីស្រឡាញ់របស់ទូលព្រះបង្គំជាខ្ញុំទេ សូមសេចក្តីចម្រើនចូរមានដល់ព្រះអង្គ សូមព្រះអង្គ យាងទៅកាន់សំណាក់នាង

ឧម្មាទន្តីកុំខាន ដូចជាសីហៈឈ្មោល ចូលទៅកាន់គុហាកែវមណី ( ជាលំនៅរបស់សីហៈញី ) ដូច្នោះ ។

ព្រះរាជាត្រាស់ថា

អ្នកប្រាជ្ញទាំងឡាយ ( បើទុកជា ) ត្រូវសេចក្តីទុក្ខក្នុងខ្លួនបៀតបៀនហើយ ក៏មិនលះបង់នូវអំពើដែលមានផលជាសុខឡើយ ឬទោះបីវង្វេងជ្រុលជ្រប់ក្តី ស្រវឹងដោយសេចក្តីសុខក្តី ក៏គង់មិនប្រព្រឹត្តធ្វើបាបកម្មទេ ។

អភិបារកពោលថា

ព្រះអង្គដូចជាមាតាបិតាជាអ្នកចិញ្ចឹម ជាម្ចាស់ ជាអ្នកបីបាច់រក្សា ទាំងជាទេវតារបស់ទូលព្រះបង្គំជាខ្ញុំ បពិត្រព្រះបាទសីវិ ខ្ញុំព្រះអង្គព្រមទាំងកូនប្រពន្ធ ជាទាសៈរបស់ព្រះអង្គ សូមទ្រង់ធ្វើសេចក្តីប្រាថ្នាតាមសប្បាយចុះ ។

ព្រះរាជាត្រាស់ថា

បុគ្គលណាអាងថា អាត្មាអញជាធំដូច្នេះ ហើយធ្វើនូវអំពើអាក្រក់ បុគ្គលនោះលុះបានធ្វើរួចហើយ ក៏មិនរវែងនឹងពួកជនដទៃ ព្រោះអំពើនោះ បុគ្គលនោះមិនរស់នៅអស់កាលជាអង្វែង ទាំងពួកទេវតាក៏តែងរំពៃមើលបុគ្គលនោះ ដោយអំពើអាក្រក់ ។

អភិបារកពោលថា

បុគ្គលទាំងឡាយណា តាំងនៅក្នុងធម៌ ទទួលយកនូវទាន ដែលគេមិនស្គាល់ ដែលម្ចាស់ទាំងឡាយ ប្រគល់ឲ្យហើយ បុគ្គលជាអ្នកទទួលទាំងឡាយ ( នោះ ) ផង អ្នកឲ្យទាំងឡាយផង ឈ្មោះថា ធ្វើនូវអំពើមានផលជាសុខក្នុងហេតុនោះ ។

ព្រះរាជាត្រាស់ថា

បុគ្គលដទៃណាហ្ន៎ លើផែនដី ក្នុងលោកគប្បីជឿអ្នកថា ( នាងឧម្មាទន្តី ) មិនមែនជាទីស្រឡាញ់របស់អញ ដូច្នេះ ទាំងសេចក្តីចង្អៀតចង្អល់ចិត្តគប្បីមានដល់អ្នកយ៉ាងខ្លាំង ព្រោះអ្នកឲ្យនាងឧម្មាទន្តីជាទីស្រឡាញ់ ហើយមិនបានឃើញទៀតផង ។

អភិបារកពោលថា

បពិត្រព្រះជនិន្ទ: នាងឧម្មាទន្តី ទុំជាទីស្រឡាញ់របស់ទូលព្រះបង្គំជាខ្ញុំដោយពិត បពិត្រព្រះភូមិបាល នាងនោះមិនមែនមិនជាទីស្រឡាញ់របស់ទូលព្រះអង្គជាខ្ញុំទេ នាងឧម្មាទន្តី ទូលព្រះបង្គំជាខ្ញុំបានថ្វាយហើយ ចំពោះព្រះអង្គដោយហេតុណា បពិត្រព្រះរាជា សូមព្រះអង្គធ្វើនូវព្រៃ គឺតណ្ហាឲ្យខ្លាំងក្លាចុះ ( បើ ) ព្រះអង្គ ( លែងសព្វព្រះរាជហឫទ័យហើយ ) សូមលះបង់ចុះ ។

ព្រះរាជាត្រាស់ថា

បុគ្គលណាឲ្យទុក្ខដល់ជនដទៃ ដោយទុក្ខរបស់ខ្លួន ឬជណ្តើមសុខដើម្បីខ្លួនអំពីសុខ ( របស់ជនដទៃ ) ( បុគ្គលនោះឈ្មោះថាមិនស្គាល់ធម៌ ) លុះតែបុគ្គលណា ដឹងច្បាស់យ៉ាងនេះថា សុខទុក្ខរបស់អញនេះយ៉ាងណា សុខទុក្ខរបស់ជនដទៃ ក៏យ៉ាងនោះដែរ បុគ្គលនោះ ទើបឈ្មោះថា អ្នកដឹងធម៌ ។

បុគ្គលដទៃណាហ្ន៎ លើផែនដីក្នុងលោក គប្បីជឿអ្នកថា ( នាងឧម្មាទន្តី ) មិនមែនជាទីស្រឡាញ់របស់អញដូច្នេះ ទាំងសេចក្តីចង្អៀតចង្អល់ចិត្ត គប្បីមានដល់អ្នកយ៉ាងខ្លាំង ព្រោះអ្នកឲ្យនាងឧម្មាទន្តីជាទីស្រឡាញ់ហើយ មិនបានឃើញទៀតផង ។

អភិបារកពោលថា

បពិត្រព្រះជនិន្ទ: ព្រះអង្គគង់ជ្រាបថា នាងឧម្មាទន្តីនោះ ជាទីស្រឡាញ់របស់ទូលព្រះអង្គំជាខ្ញុំ បពិត្រព្រះភូមិបាល នាងនោះមិនមែនមិនជាទីស្រឡាញ់របស់ទូលព្រះបង្គំជាខ្ញុំទេ បពិត្រព្រះជនិន្ទ: ទូលព្រះបង្គំជាខ្ញុំ សូមថ្វាយនាងឧម្មាទន្តី ជាទីស្រឡាញ់ចំពោះព្រះអង្គ ដោយចិត្តជាទីស្រឡាញ់ បពិត្រព្រះសម្មតិទេព បុគ្គលអ្នកឲ្យនូវវត្ថុជាទីស្រឡាញ់ទាំងឡាយរមែងបាននូវវត្ថុជាទីស្រឡាញ់វិញ ។

ព្រះរាជាត្រាស់ថា

អញនោះមុខជានឹងសម្លាប់ខ្លួន ព្រោះមានកាមជាហេតុដោយ

ពិត អញមិនអាចដើម្បីសម្លាប់នូវធម៌ដោយអធម៌ឡើយ ។

អភិបារកពោលថា

បពិត្រព្រះជនិន្ទ: ទ្រង់មានព្យាយាមក្នុងពួកជនដ៏ប្រសើរ បើព្រះអង្គមិនសព្វព្រះរាជហឫទ័យ នឹងនាងឧម្មាទន្តីដែលជារបស់ទូលព្រះបង្គំជាខ្ញុំទេ ទូលព្រះបង្គំជាខ្ញុំនឹងលះបង់នាង នាកណ្តាលជនទាំងពួង តពីនោះទៅ ព្រះអង្គគប្បីនាំយកនាងឧម្មាទន្តីនោះ ដែលទូលព្រះអង្គជាខ្ញុំលះបង់ហើយ ។

ព្រះរាជាត្រាស់ថា

នែអភិបារក: បើអ្នកលះបង់ ( នាងឧម្មាទន្តី ) ដែលមិនមានទោស នែអ្នកធ្វើ ( ប្រយោជន៍ដល់ខ្ញុំ ) ការលះបង់នោះគប្បីមិនជាប្រយោជន៍ដល់អ្នកផង ពាក្យតំណេះតំនៀលយ៉ាងច្រើន គប្បីមានដល់អ្នកផង បក្ខពួករបស់អ្នកក្នុងនគរ មិនគប្បីមានផង ។

អភិបារកពោលថា

បពិត្រព្រះភូមិបាល ទូលព្រះបង្គំជាខ្ញុំនឹងអត់ទ្រាំនូវពាក្យតំណេះតំនៀលនុ៎ះផង នូវនិន្ទាផង នូវសេចក្តីសរសើរផង នឹងការពោលទោសគ្រប់យ៉ាងថា ហេតុទាំងនុ៎ះ ចូរមកដល់ទូលព្រះបង្គំជាខ្ញុំចុះ បពិត្រព្រះបាទសីវិ សូមទ្រង់ធ្វើនូវសេចក្តីប្រាថ្នាតាមសប្បាយចុះ ។ បុគ្គលណា មិនអើពើ

នឹងនិន្ទា មិនអើពើនឹងសេចក្ដីសរសើរ មិនអើពើនឹងពាក្យពោលទោស មិនអើពើនឹងការបូជា សិរីក្ដី បញ្ញាក្ដី រមែងទៅប្រាសចាកបុគ្គលនោះ ដូចជាទឹក គឺទឹកភ្លៀងយ៉ាងស្រួលដែលទៅប្រាសចាកទីទួល ដូច្នោះ ។ ទូលព្រះបង្គំជាខ្ញុំ នឹងទទួលនូវសេចក្ដីទុក្ខផង នូវសេចក្ដីសុខផង នូវអំពើអាក្រក់ហួសផ្លូវធម៌ផង នូវសេចក្ដីចង្អៀតចង្អល់ចិត្តគ្រប់យ៉ាង តាមតែយ៉ាងណាក៏ដោយ អំពីដំណើរនេះដោយផ្ទាល់ទ្រូង ដូចជាផែនដី ( ដែលទទួលនូវវត្ថុណាមួយ ) របស់ពួកជនអ្នកមាំមួន គឺ ព្រះអរហន្ត នឹងរបស់ពួកជនអ្នកតក់ស្លុត គឺបុថុជ្ជន ។

ព្រះរាជាត្រាស់ថា

ខ្ញុំមិនប្រាថ្នាអំពើអាក្រក់ហួសផ្លូវធម៌ផង សេចក្ដីទុក្ខជាគ្រឿងចង្អៀតចង្អល់ចិត្តផង ដល់ជនទាំងឡាយដទៃទេ ខ្ញុំតែម្នាក់ឯង ឋិតនៅក្នុងធម៌ មិនញុំាងប្រយោជន៍បន្តិចបន្តួចឲ្យសាបសូន្យទៅទេ ហើយនឹងធ្ងន់នូវភារៈ គឺសេចក្ដីទុក្ខនេះ ។

អភិបារកពោលថា

បពិត្រព្រះជនិន្ទៈ ព្រះអង្គកុំធ្វើនូវបុញ្ញកម្ម ជាគ្រឿងញុំាងសត្វឲ្យកើតក្នុងឋានសួគ៌របស់ទូលព្រះបង្គំជាខ្ញុំ ឲ្យអន្តរាយឡើយ ទូលព្រះបង្គំជាខ្ញុំជ្រះថ្លា ថ្វាយនាងឧម្មាទន្តីចំពោះព្រះអង្គ ដូច

ជាព្រះរាជា ( ដែលទ្រង់ព្រះរាជទាន ) នូវទ្រព្យក្នុងការបូជាដល់ពួកព្រាហ្មណ៍ ។

ព្រះរាជាត្រាស់ថា

ម្នាលអ្នកធ្វើនូវប្រយោជន៍ អ្នកជាបុគ្គលមានប្រយោជន៍ដល់ខ្ញុំ ដោយពិត នាងឧម្មាទន្តី និងអ្នកជាសម្លាញ់របស់ខ្ញុំ ពួកទេវតានឹងទេវតាជាបិតា និងអ្នកទាំងអស់មុខជានិន្ទា ទាំងខ្ញុំក៏មុខជានឹងឃើញនូវបាបក្នុងអភិសម្បរាយកពុំខាន ។

អភិបារកពោលថា

បពិត្រព្រះបាទសីវិ ពួកអ្នកនិគមនិងពួកអ្នកជនបទទាំងអស់គ្នា មិនគប្បីពោលនូវអំពើដែលទូលព្រះបង្គំជាខ្ញុំ បានថ្វាយនាងឧម្មាទន្តីចំពោះព្រះអង្គនុ៎ះ ថាជាធម៌ទេ បពិត្រព្រះរាជាសូមព្រះអង្គធ្វើនូវព្រៃ (តណ្ហា) ឲ្យខ្វាំងក្លា ( បើ ) ព្រះអង្គ ( លែងសព្វព្រះរាជហឫទ័យហើយ ) សូមលះបង់ចុះ ។

ព្រះរាជាត្រាស់ថា

ម្នាលអ្នកធ្វើនូវប្រយោជន៍ អ្នកជាបុគ្គលមានប្រយោជន៍ដល់ខ្ញុំដោយពិត នាងឧម្មាទន្តី និងអ្នកជាសម្លាញ់របស់ខ្ញុំ ធម៌ទាំងឡាយ ដែលពួកសប្បុរសបានសម្តែងល្អហើយ ខ្ញុំប្រព្រឹត្តកន្លងបានដោយកម្រ ដូចជាសមុទ្រនឹងច្រាំង ។

អភិបារកពោលថា

ព្រះអង្គជាអាហុនេយ្យបុគ្គល ជាអ្នកអនុគ្រោះដោយប្រយោជន៍ ជាអ្នកទ្រទ្រង់ជាអ្នកចាត់ចែង ( ឥស្សរិយសុខ ) និងជាអ្នករក្សានូវសេចក្តីប្រាថ្នា របស់ទូលព្រះបង្គំជាខ្ញុំ បពិត្រព្រះរាជា នាងឧម្មាទន្តីដែលទូលព្រះបង្គំជាខ្ញុំបានថ្វាយព្រះអង្គ នឹងមានផលច្រើន សូមទ្រង់ទទួលយកនាងឧម្មាទន្តី តាមសេចក្តីប្រាថ្នារបស់ទូលព្រះបង្គំជាខ្ញុំ ។

ព្រះរាជាត្រាស់ថា

ម្នាលអភិបារកៈ ជាកូនរបស់សេនាបតី ជាអ្នកធ្វើនូវប្រយោជន៍ អ្នកមិនមែនជាបុគ្គលប្រព្រឹត្តនូវធម៌ទាំងអស់ដល់ខ្ញុំ ដោយពិត ជនមានជើង ២ ដទៃ តើរូបណាក្នុងជីវលោកនេះ ជាអ្នកធ្វើនូវសួស្តីដល់អ្នក ក្នុងពេលអរុណរះ ។

អភិបារកពោលថា

ព្រះអង្គ ជាបុគ្គលប្រសើរផុត ព្រះអង្គជាបុគ្គលខ្ពង់ខ្ពស់ផុត ព្រះអង្គជាអ្នកដល់នូវធម៌ ជ្រាបច្បាស់នូវធម៌ មានព្រះប្រាជ្ញាប្រពៃ ទ្រង់ជាអ្នកគ្រប់គ្រងនូវធម៌ សូមទ្រង់មានព្រះជន្មាយុអស់កាលដ៏អង្វែង បពិត្រព្រះធម្មបាល សូមទ្រង់សម្តែងធម៌ដល់ទូលព្រះបង្គំជាខ្ញុំ ។

ព្រះរាជាពោលថា

បើដូច្នោះ ម្នាលអភិបារកៈ អ្នកចូរស្តាប់ពាក្យខ្ញុំ ខ្ញុំនឹងសម្តែង

ធម៌ ដែលពួកសប្បុរសធ្លាប់សេពដល់អ្នក ។ ព្រះរាជាជាអ្នកគាប់ចិត្តដោយធម៌ ទើបល្អ ជនមានប្រាជ្ញា ទើបល្អ ការមិនប្រទូស្តមិត្ត ទើបល្អ កិរិយាមិនធ្វើបាប ទើបសុខ ។ មនុស្សទាំងឡាយ គប្បីនៅជាសុខក្នុងផ្ទះរបស់ខ្លួន ក្នុងម្លប់ដ៏ត្រជាក់ ក្នុងដែននៃស្តេចដែលមិនមានក្រោធ មានច្បាប់បិតថេរ ។ ខ្ញុំមិនគាប់ចិត្តនឹងអំពើដែលមិនពិចារណាហើយធ្វើ ដែលធ្វើមិនប្រពៃនោះទេ ម្យ៉ាងទៀត ជនទាំងឡាយណាដឹងថា ( មិនប្រពៃ ) ហើយ មិនធ្វើដោយខ្លួនឯង ( អំពើរបស់ជនទាំងឡាយនោះទើបខ្ញុំពេញចិត្ត ) អ្នកស្តាប់ពាក្យប្រៀបធៀបនេះរបស់ខ្ញុំចុះ ។ កាលគោទាំងឡាយកំពុងឆ្លងទៅ បើគោបាទៅវៀចផ្លូវ កាលបើគោអ្នកនាំផ្លូវទៅវៀចហើយ ពួកមេគោទាំងអស់នោះ ក៏ដើរវៀចដែរ ។ បណ្តាមនុស្សទាំងឡាយ ក៏ដូច្នោះ ជនណាដែលអ្នកផងសន្មតថាប្រសើរផុត បើជននោះប្រព្រឹត្តនូវអធម៌ទៅហើយ នឹងចាំបាច់និយាយទៅថ្វីដល់ប្រជាជនក្រៅនេះ បើព្រះរាជាមិនប្រកបដោយធម៌ រាស្ត្រទាំងអស់តែងដេកជាទុក្ខ ។ កាលបើគោទាំងឡាយកំពុងឆ្លងទៅ គោបាទៅត្រង់ កាលបើគោអ្នកនាំផ្លូវទៅត្រង់ហើយ ពួកមេគោទាំងអស់នោះក៏ដើរទៅត្រង់ ។ បណ្តាមនុស្សទាំងឡាយ ក៏ដូច្នោះ ជនណាដែលអ្នកផងសន្មតថាប្រសើរផុត

បើជននោះប្រព្រឹត្តធម៌ នឹងចាំបាច់ពោលទៅថ្វី ដល់ប្រជាជនក្រៅនេះ បើព្រះរាជាទ្រង់ប្រកបដោយធម៌ រាស្ត្រទាំងអស់រមែងដេកជាសុខ ។ ម្នាលអភិបារកៈ ខ្ញុំមិនប្រាថ្នានូវភាពនៃខ្លួនជាទេវតាដោយអធម៌ទេ ម្យ៉ាងទៀត ( ខ្ញុំមិនប្រាថ្នា ) ដើម្បីឈ្នះនូវផែនដីទាំងមូលនេះ ( ដោយអធម៌ទេ ) ។ ថ្វីបើក្នុងមនុស្សលោកនេះ មានរតនវត្ថុណាមួយ គឺគោទាំងឡាយ ខ្ញុំ ប្រាក់ សំពត់ និងខ្លឹមចន្ទន៍ក្រហមដោយពិតដូច្នោះ ។ ព្រះចន្ទនិងព្រះអាទិត្យ ទាំងឡាយនេះ រក្សាទុកនូវរតនៈណាមួយ គឺសេះ ស្ត្រីទាំងឡាយ និងកែវមណី បុគ្គលមិនគួរប្រព្រឹត្តនូវធម៌មិនប្រសើរ ព្រោះហេតុនៃរតនវត្ថុនោះៗទេ យើងដូចជាគោឧសភៈ កើតក្នុងចំណោមនៃពួកជន អ្នកនៅក្នុងដែនសីវិ ។ ខ្ញុំនោះជាអ្នកដឹកនាំ ជាអ្នកស្វែងរកប្រយោជន៍ ល្បីល្បាញរក្សានូវដែន លំអុតលំឱនចំពោះប្រពៃណី ( របស់ស្តេចជាន់មុន ) នៃអ្នកសីវិរាស្ត្រទាំងឡាយ ជាអ្នកត្រិះរិះតែធម៌ ព្រោះហេតុនោះ ខ្ញុំមិនលុះក្នុងអំណាចនៃចិត្តរបស់ខ្លួនទេ ។

អភិបារកពោលថា

បពិត្រមហារាជ ព្រះអង្គនឹងសោយរាជសម្បត្តិទៀងទាត់ មិនវិនាស ក្សេមក្សាន្ត បានយូរយារដោយពិត ដ្បិតប្រាជ្ញារបស់

ព្រះអង្គប្រាកដដូច្នោះ ។ ព្រះអង្គមិនប្រមាទចំពោះធម៌ណា ទូលព្រះបង្គំជាខ្ញុំ សូមអនុមោទនាចំពោះធម៌នុ៎ះរបស់ព្រះអង្គ ក្សត្រជាឥស្សរប្រមាទចំពោះធម៌ហើយ រមែងឃ្លាតចាកដែន ។ បពិត្រខត្តិយមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ក្នុងមាតាបិតាទាំងឡាយ បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ ក្នុងលោកនេះ ហើយនឹងទៅកាន់ឋានសួគ៌ ។ បពិត្រខត្តិយមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ ក្នុងរាជបុត្តនិងអគ្គមហេសី បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ ក្នុងលោកនេះហើយនឹងទៅកាន់ឋានសួគ៌ ។ បពិត្រខត្តិយមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ក្នុងពួកមិត្តនឹងអាមាត្យ បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ក្នុងពួកវាហនៈផង ក្នុងពួកពលផង បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយនឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ក្នុងពួកអ្នកស្រុកផង ក្នុងពួកអ្នកនិគមផង បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ក្នុងពួកអ្នកដែនផង ក្នុងពួកអ្នកជនបទផង បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ក្នុងសមណៈ

ផង ក្នុងពួកព្រាហ្មណ៍ផង បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រខត្តិយមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ក្នុងពួកម្រឹគនិងបក្សី បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមទ្រង់ ប្រព្រឹត្តធម៌ចុះ ( ដ្បិត ) ធម៌ដែលគេសន្សំហើយ តែងនាំមកនូវសេចក្តីសុខ បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ចុះ ( ដ្បិត ) ព្រះឥន្ទទាំងឡាយ ទេវតាទាំងឡាយព្រមទាំងព្រហ្ម បានដល់នូវអត្តភាពជាទិព្វ ដោយសារធម៌ ដែលគេបានសន្សំទុកល្អហើយ បពិត្រព្រះរាជា ព្រះអង្គកុំប្រមាទចំពោះធម៌ឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សព្ពាបិ** សេចក្តីថា បពិត្រព្រះអង្គជាធំនៃពួកជន ទូលព្រះបង្គំម្នាក់ប៉ុណ្ណោះនឹងបិទបាំងរឿងនេះ ហើយនាំនាងឧម្មាទន្តីមកថ្វាយ ព្រោះហេតុនោះ វៀរទ្រង់និងខ្ញុំចេញហើយ មហាជនដទៃទាំងអស់មិនគប្បីដឹង គឺនឹងមិនដឹងត្រឹមតែកិរិយាអាការ នៃរឿងដែលធ្វើមកហើយនេះ ។ បទថា **ភុសេហិ** សេចក្តីថា ខ្ញុំនាំនាងឧម្មាទន្តីមកថ្វាយទ្រង់ហើយ សូមទ្រង់រួមអភិរម្យជាមួយនាងចុះ សូមទ្រង់ធ្វើព្រៃ គឺតណ្ហារបស់ខ្លួនឲ្យក្រៃលែង គឺធ្វើឲ្យចម្រើន បានដល់ សូមធ្វើសេចក្តីប្រាថ្នានៃចិត្តឲ្យពេញ

ប្រៀបចុះ ។ បទថា **សជាហិ** សេចក្តីថា កាលទ្រង់ធ្វើសេចក្តីប្រាថ្នានៃចិត្តឲ្យពេញប្រៀបហើយ បើនាងមិនជាទីពេញព្រះហឫទ័យរបស់ទ្រង់សោត ក្រោយមកទ្រង់បោះបង់នាងចោលក៏បាន គឺ ទ្រង់ឲ្យដល់ទូលបង្គំវិញចុះ ។ បទថា **កម្មករំ** សេចក្តីថា នៃអភិបារកសេនាបតីសម្លាញ់ មនុស្សណាធ្វើកម្មដែលជាបាប ក្រោយមក មនុស្សនោះសម្គាល់ គឺគិតថា ជនដទៃក្នុងលោកនេះ កុំសម្គាល់ គឺ កុំស្គាល់កម្មបែបនេះរបស់យើងឡើយ ការគិតរបស់បុគ្គលនោះ ជាការគិតលាមក ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះនរជនទាំងនោះ រមែងឃើញការធ្វើនោះ ។ បទថា **បស្សន្តិ ភូតានិ ករោន្តមេតំ** សេចក្តីថា ព្រះសម្មាសម្ពុទ្ធ ព្រះបច្ចេកពុទ្ធ និងពុទ្ធបុត្តទាំងឡាយ ដែលប្រកបដោយឫទ្ធិទាំងនោះ រមែងឃើញការធ្វើរបស់បុគ្គលនោះឯង ។ បទថា **ន មេ បិយា** សេចក្តីថា នៃអភិបារកសេនាបតីសម្លាញ់ អ្នកដទៃណាក្នុងលោកនេះ គឺក្នុងផែនដីទាំងមូល គប្បីជឿលោកយ៉ាងនេះថា នាងឧម្មាទន្តីមិនជាទីស្រឡាញ់របស់ខ្លួន ។ បទថា **សីហោវ សេលស្ស គុហំ** សេចក្តីថា បពិត្រមហារាជ បើទ្រង់មិនឲ្យនាំនាងមកក្នុងទីនេះសោត សូមទ្រង់យាងទៅកាន់លំនៅ របស់នាងចុះ សូមធ្វើសេចក្តីប្រាថ្នារបស់ទ្រង់ឲ្យសម្រេចបរិបូណ៌ក្នុងទីនោះចុះ ដូចរាជសីហ៍រោលរាលដោយអំណាចនៃកិលេសចូលទៅកាន់គុហាកែវ ដែលជាលំនៅរបស់រាជសីហ៍ញី ដូច្នោះ ។ បទថា **សុខប្បលំ** សេចក្តីថា នៃអភិបារកសេនាបតីសម្លាញ់ ពួកជនជាបណ្ឌិត ត្រូវសេចក្តីទុក្ខបៀតបៀនហើយ រមែងមិនលះកម្មដែលឲ្យផលជាសុខ ឬជាអ្នក

វង្វេងហើយ គឺវង្វេងដោយមោហៈ ស្រវឹងដោយសេចក្ដីសុខ រមែងមិនព្រម ប្រព្រឹត្តកម្មដែលជាបាប ។ បទថា **យថាសុខំ សីវិ ករោហិ កាមំ** សេចក្ដីថា បពិត្រព្រះបាទសីវិរាជជាធំ ឈ្មោះថា ការតិះដៀល តែងមិនមានដល់អ្នកបម្រើដែលឲ្យទាសីរបស់ខ្លួនបម្រើឡើយ សូមទ្រង់បរិភោគកាមតាមសប្បាយ តាមអធ្យាស្រ័យ គឺសូមធ្វើនូវសេចក្ដី ប្រាថ្នារបស់ទ្រង់ ឲ្យបរិបូណ៌ចុះ ។ បទថា **ន តេន សោ ជីវតិ** សេចក្ដីថា ម្នាលអភិបារកសេនាបតីសម្លាញ់ បុគ្គលណាធ្វើបាបដោយសម្គាល់ថា យើងជាអ្នកជាំក្រៃលែង កាលធ្វើហើយ ក៏មិនបានតក់ស្លុត មិនបានខ្លាចថា ទេវតានិងមនុស្សទាំងឡាយនឹងពោលដល់កម្មនោះ ព្រោះកម្មនោះ បុគ្គលនោះរមែងមិនតម្កល់ជីវិតបានអស់កាលយូរ រមែងស្លាប់ដោយឆាប់រហ័ស ម្យ៉ាងទៀតទោះជាទេវតាទាំងឡាយ ក៏រមែងនាំគ្នាសម្លឹងមើលតាមខ្សែភ្នែកដែលរំពៃទុកថា ការគ្រប់គ្រងរាជសម្បត្តិរបស់ព្រះរាជាអាក្រក់នេះ មានប្រយោជន៍អ្វី ការដែលបុគ្គលនោះយកថ្នាំងប្រកខ្សាច់ចងកសម្លាប់ខ្លួនឲ្យស្លាប់គង់ប្រសើរជាង ។ បទថា **អញ្ញាតកំ** សេចក្ដីថា បពិត្រមហារាជ ពួកជនដទៃដែលម្ចាស់ទ្រព្យប្រគល់ឲ្យហើយ ជនពួកណា តាំងនៅក្នុងធម៌របស់ខ្លួនហើយ រមែងទទួលយកនូវទាននោះ ជនទាំងនោះ ឈ្មោះថា ជាអ្នកទទួលផង ជាអ្នកឲ្យក្នុងទាននោះផង រមែងនាំគ្នាធ្វើតែកម្មដែលមានផលជាសុខតែម្យ៉ាង កាលបដិគ្គាហកៈ ទទួលទាន ទាននោះរមែងឲ្យផលច្រើនដល់ទាយក ។ គាថាថា **អញ្ញោ នុ ។បេ។ អត្ថា បិយា ។បេ។ យោ អត្តនុក្កេន** សេចក្ដីថា នៃអភិបារកសេនាបតី

សម្លាញ់ បុគ្គលណា ខ្លួនឯងត្រូវសេចក្តីទុក្ខគ្របសង្កត់ហើយ រមែងដាក់សេចក្តីទុក្ខនោះ ឲ្យដល់អ្នកដទៃ គឺនាំសេចក្តីទុក្ខចេញអំពីសរីរៈរបស់ខ្លួនហើយ ទៅដាក់ក្នុងសរីរៈរបស់អ្នកដទៃ ឬកាន់យកសេចក្តីសុខរបស់ខ្លួន ដោយសេចក្តីសុខរបស់អ្នកដទៃ គឺយកសេចក្តីសុខរបស់អ្នកដទៃនោះ មកដាក់ក្នុងខ្លួន ឈ្មោះថា រមែងធ្វើអ្នកដទៃឲ្យដល់នូវសេចក្តីទុក្ខ ដោយសម្គាល់ថា អញនាំសេចក្តីទុក្ខរបស់ខ្លួនចេញទៅហើយ ដូច្នេះ ឈ្មោះថា រមែងធ្វើអ្នកដទៃឲ្យដល់សេចក្តីទុក្ខ ដោយសម្គាល់ថា អញនឹងធ្វើខ្លួនឯងឲ្យមានសេចក្តីសុខសប្បាយ ដូច្នេះ ឈ្មោះថា រមែងធ្វើសេចក្តីសុខរបស់អ្នកដទៃឲ្យវិនាស ដោយសម្គាល់ថា អញនឹងធ្វើខ្លួនឯងឲ្យមានសេចក្តីសុខ ដូច្នេះ បុគ្គលនោះឈ្មោះថា រមែងមិនដឹងធម៌ ។ ឯបុគ្គលណាដឹងយ៉ាងនេះថា សេចក្តីសុខនិងសេចក្តីទុក្ខរបស់យើងនោះ យ៉ាងណា របស់អ្នកដទៃក៏យ៉ាងនោះដូចគ្នា ដូច្នេះ បុគ្គលនោះឈ្មោះថា ដឹងធម៌ គឺស្គាល់ធម៌ ។ បទថា **បិយេន តេ ទម្មិ** សេចក្តីថា ខ្ញុំព្រះអង្គប្រាថ្នាផល ដែលជាទីស្រឡាញ់ ដោយវត្ថុដែលជាទីស្រឡាញ់ដែលជាហេតុ ទើបថ្វាយដល់ទ្រង់ ។ បទថា **បិយំ លភន្តិ** សេចក្តីថា កាលទៅត្រាច់ទៅក្នុងសង្សារវដ្ត រមែងបានវត្ថុដែលជាទីស្រឡាញ់ដូចគ្នា ។ បទថា **កាមហេតុកំ** សេចក្តីថា នៃអភិបារកសេនាបតីសម្លាញ់ យើងកើតបរិវិតក្កឡើងថា អញនឹងធ្វើវត្ថុដែលមិនសមគួរ មានកាមជាហេតុហើយ នឹងសម្លាប់ខ្លួនចោល ។ បទថា **មយ្ហំ សតី** បានដល់ ដែលជារបស់មានរបស់ទូលបង្គំ ។ បាឋៈថា **មយ្ហ សតិ** ដូច្នេះក៏មាន អធិប្បាយថា ទ្រង់សម្គាល់យ៉ាងនេះថា នាង

ឧម្មាទន្តីនោះជារបស់ទូលបង្គំ ទើបទ្រង់មិនប្រាថ្នានាង ។ បទថា **សព្វជនស្ស** សេចក្ដីថា ទូលបង្គំនឹងឲ្យសេនាទាំងអស់ប្រជុំគ្នា ហើយលះបង់ដល់ជនទាំងអស់នោះថា ស្រីនេះមិនជាប្រយោជន៍ដល់ខ្ញុំឡើយ ដូច្នេះ ។ បទថា **តតោ អង្ហាយេសិ** សេចក្ដីថា ទ្រង់គប្បីនាំនាងមកអំពីទីនោះចុះ ព្រោះមិនមានអ្នកណាហួងហែងឡើយ ។ បទថា **អទូសិយំ** បានដល់ បុគ្គលមិនមានកំហុស ។ ព្រះរាជាត្រាស់ហៅអភិបារកសេនាបតីនោះ ដោយឈ្មោះដទៃទៀតថា **កាត្ត** ( អ្នកធ្វើប្រយោជន៍ ) ដូច្នេះ ដ្បិតថា អភិបារកសេនាបតីនោះ រមែងធ្វើប្រយោជន៍ដល់ព្រះរាជា ព្រោះហេតុនោះទើបហៅថា **កាត្ត** ។ បទថា **ន ចាបិ ត្យស្ស** សេចក្ដីថា ក្នុងព្រះនគរ ក៏មិនមានបុគ្គលណាមួយ ចូលជាចំណែកជាមួយលោក ដោយគិតថា សេនាបតីជាអ្នកធ្វើវត្ថុដែលមិនគួរធ្វើយ៉ាងនេះ ។ បទថា **និន្ទំ** សេចក្ដីថា អភិបារកសេនាបតីក្រាបទូលថា មានពាក្យតំណិះដំណៀលតែម្យ៉ាងក៏មិនមែន បើបុគ្គលណាមួយនិន្ទា ឬសរសើរខ្ញុំចំពោះមុខក្ដី និងលើកឡើងតិះដៀលក្ដី ខ្ញុំនឹងអត់សង្កត់នូវពាក្យនិន្ទា ពាក្យសរសើរ និងពាក្យតិះដៀលទាំងអស់ សូមពាក្យនិន្ទាជាដើមនោះធ្លាក់មកដល់ទូលបង្គំចុះ ។ បទថា **តម្ហា** សេចក្ដីថា បុគ្គលណាមិនកាន់យកពាក្យនិន្ទាជាដើមនោះ សិរីគឺឥស្សរិយយសនិងលក្ខី គឺបញ្ញា រមែងទៅប្រាសចាកបុរសនោះ គឺរមែងតាំងនៅមិនបាន ដូចទឹក គឺទឹកភ្លៀងហូរអំពីទីទួល ដូច្នោះ ។ បទថា **ឃត្តោ** សេចក្ដីថា ចាកហេតុដែលទូលបង្គំបានលះបង់នាងហើយនេះ ។ បទថា **ធម្មា-តិសារញ្ច** សេចក្ដីថា វត្ថុឯណានីមួយដែលជាអកុសលធម៌ដែលប្រព្រឹត្តទៅ

កន្លងផុតធម៌មាន ។ បទថា **បដិច្ឆិស្សាមិ** បានដល់ នឹងទទួលយកចំពោះ ។ បទថា **ជាវកានំ តសានំ** សេចក្តីថា អភិបារកសេនាបតី រមែងសម្តែងថា មហាប្រឹថពីមិនព្រមទទួលវត្ថុណាមួយ របស់ព្រះទីណាស្រពទាំងឡាយ និង របស់បុថុជ្ជនទាំងឡាយមិនមាន គឺរមែងអត់ធន់ក្នុងវត្ថុទាំងអស់បាន យ៉ាងណា ខ្ញុំក៏យ៉ាងនោះ រមែងទទួលអត់ធន់ក្នុងវត្ថុទាំងអស់ឲ្យខាងតែបាន ។ បទថា **ឃកោបិមំ** សេចក្តីថា ខ្ញុំម្នាក់ឯងប៉ុណ្ណោះ នឹងធ្វើឲ្យផុតនឹងឆ្លង គឺនឹងនាំ ទៅនូវការៈ គឺសេចក្តីទុក្ខរបស់ខ្លួននេះចេញ ។ បទថា **ធម្មេ ឋិតោ** សេចក្តី ថា ជាបុគ្គលតាំងនៅក្នុងធម៌ជាគ្រឿងវិនិច្ឆ័យ ក្នុងធម៌ដែលទាក់ទងនឹងបវេណី និងក្នុងធម៌ គឺសុចរិត ៣ ប្រការ ។ បទថា **សគ្គបតំ** សេចក្តីថា បពិត្រ ព្រះសម្មតិទេព ធម្មតាបុញ្ញកម្ម រមែងជាហេតុឲ្យចូលដល់ឋានសួគ៌ ។ បទ ថា **យញ្ញោ ធនំ** បានដល់ ទ្រព្យក្នុងការបូជាយញ្ញ ។ម្យ៉ាងទៀត បាឋៈក៏ យ៉ាងនេះដូចគ្នា ។ បទថា **សខា** បានដល់ សូម្បីនាងឧម្មាទន្តីក៏ជាសម្លាញ់ របស់យើង ខ្លួនអ្នកក៏ជាសម្លាញ់របស់យើង ។ បទថា **បិតរោ** បានដល់ ព្រះព្រហ្ម ។ បទថា **សព្វេ** សេចក្តីថា មិនមែនតែទេវតានិងព្រហ្មប៉ុណ្ណោះទេ សូម្បីមហាជនទាំងអស់ ក៏គប្បីនាំគ្នានិន្ទាយើងបានថា ម្នាលគ្នាយើង មើល ចុះស្រីជាសម្លាញ់ ជាកិរិយារបស់សេនាបតីដែលធ្លាប់ជាសម្លាញ់នឹងគ្នា ព្រះរាជា អង្គនេះ គង់ធ្វើទុកក្នុងផ្ទះបានហ្ន៎ ។ បទថា **ឆហោតំ ធម្មំ** សេចក្តីថា ជនទាំង អស់មិនគប្បីរៀននូវកម្មដែលប្រកបដោយធម៌នេះឡើយ ។ បទថា **យំ តេ មយា** សេចក្តីថា ព្រោះខ្ញុំថ្វាយនាងឧម្មាទន្តីដល់ទ្រង់ ដូច្នោះទើបវត្ថុនេះ មិន

ប្រាកដថា ជាអធម៌ឡើយ ។ បទថា **សតំ** សេចក្តីថា ធម៌ទាំងឡាយណា គឺការអត់ធន់ មេត្តាភាវនា សីលនិងមារយាទរបស់សប្បុរសទាំងឡាយ មានព្រះពុទ្ធជាដើមពណ៌នាទុកល្អហើយ ។ បទថា **សមុទ្ទវេលាវ ធុរច្ចយានិ** អធិប្បាយថា ព្រះរាជាត្រាស់ថា សូម្បីយើងក៏មិនឈានកន្លងព្រំដែននៃសីល ដូចមហាសមុទ្រ មិនរំលងច្រាំងដែលជាព្រំដែនដូច្នោះ ។ បទថា **អាហុនេយ្យោ មេសិ** សេចក្តីថា បពិត្រមហារាជ ទ្រង់ជាបុគ្គលសមគួរដល់របស់ដែលគេបូជានិងទទួលសក្ការៈរបស់ខ្ញុំ ។ បទថា **ធាតា វិធាតា ចសិ កាមបាលោ** សេចក្តីថា បពិត្រព្រះសម្មតិទេព ព្រះអង្គឈ្មោះថា **ធាតា** ព្រោះទ្រទ្រង់ទុកនូវខ្ញុំ ឈ្មោះថា **វិធាតា** ព្រោះធ្វើឲ្យកើតសេចក្តីសុខក្នុងឥស្សរិយយស និងឈ្មោះថា **កាមបាលោ** ព្រោះទ្រង់រក្សានូវសេចក្តីត្រូវការ ដែលខ្ញុំចង់បាននិងប្រាថ្នាហើយ ។ បទថា **តយី ហុតា** បានដល់ នាងដែលខ្ញុំថ្វាយដល់ទ្រង់ ។ បទថា **កាមេន មេ** សេចក្តីថា សូមទ្រង់ទទួលនាងឧម្មាទន្តីតាមសេចក្តីត្រូវការរបស់ខ្ញុំ គឺតាមការប្រាថ្នារបស់ខ្ញុំចុះ ។ អភិបារកសេនាបតីថ្វាយនាងឧម្មាទន្តីដល់ព្រះរាជាដោយពាក្យយ៉ាងនេះ ។ ព្រះរាជាទ្រង់បដិសេធថា យើងមិនត្រូវការនាងឡើយ ។ ព្រះរាជានិងសេនាបតីទាំង ២ នាក់ រមែងលះនាងឧម្មាទន្តី ដូចបុគ្គលយកខ្នងជើងទាត់សម្បុកសត្វ ដែលធ្លាក់លើផែនដី ឲ្យអណ្តែតធ្លាក់ទៅក្នុងព្រៃ ដូច្នោះ ។

ឥឡូវនេះ ព្រះរាជាកាលទ្រង់សម្តែងសេនាបតីនោះ ដើម្បីមិនឲ្យគេពោលតទៅទៀត ទើបត្រាស់ពាក្យជាដើមថា **អទ្ធា ហិ** ដូច្នេះ ។ បណ្តាបទទាំង

នោះ បទថា **កត្តុបុត្ត** សេចក្ដីថា បិតារបស់អភិបារកសេនាបតីនោះ ក៏ជាអ្នកធ្វើប្រយោជន៍នោះឯង ព្រោះហេតុនោះ ទើបព្រះរាជាត្រាស់ហៅសេនាបតីនោះយ៉ាងនេះ មានពាក្យដែលលោកពោលអធិប្បាយទុកថា ព្រះរាជាបានត្រាស់សម្មតអភិបារកសេនាបតីនោះថា ពិតប្រាកដ ក្នុងកាលមុននេះ ឯងបានប្រព្រឹត្តធម៌ទាំងអស់ដល់យើង បានបំពេញប្រយោជន៍ និងសេចក្ដីចម្រើនដល់យើង តែឥឡូវនេះ ឯងបែរជាប្រឆាំងនិយាយពាក្យដ៏ច្រើន ឯងកុំផ្ដេសផ្ដាស យ៉ាងនេះឡើយ អ្នកដទៃដែលមានជើងពីរ អ្នកណាដែលជាអ្នកធ្វើសួស្ដីឲ្យឯង ក្នុងវេលាអរុណរះក្នុងជីវលោកនេះ បុគ្គលបើមានព្រះរាជាអង្គដទៃដែលមានចិត្តប្រតិព័ទ្ធក្នុងកិរិយារបស់ឯង ដូចយើងសោត គប្បីប្រើមនុស្សឲ្យកាត់ក្បាលរបស់ឯងចោលខាងក្នុងអរុណនោះឯង ហើយដណ្ដើមយកនាងមកទុក ក្នុងព្រះរាជវាំងរបស់ព្រះអង្គដោយពិត តែយើងមិនធ្វើយ៉ាងនោះ ព្រោះខ្លាចអកុសលកម្ម ចូរឯងនៅស្ងៀមចុះ យើងមិនត្រូវការនាងឡើយ ។ អភិបារកសេនាបតីលុះបានស្ដាប់ ព្រះតម្រាស់នោះហើយ កាលមិនអាចក្រាបទូលពាក្យណាមួយតទៅទៀតបាន ទើបពោលគាថាជាដើមថា **តុំ ន្នុ** ដូច្នេះ ដោយបំណងពោលសរសើរព្រះរាជា ។ អត្ថនៃបាទគាថានោះថា បពិត្រមហារាជ ទ្រង់ប៉ុណ្ណោះជាព្រះរាជាដ៏ប្រសើរជាងព្រះរាជាដែលជាធំនៃមហាជនទាំងអស់ក្នុងជម្ពូទ្វីបទាំងមូល ទ្រង់ជាព្រះរាជាដែលធម៌គ្រប់គ្រងហើយ ព្រោះទ្រង់រក្សាធម៌ដែលជាគ្រឿងវិនិច្ឆ័យ ធម៌ដែលទាក់ទងដោយបវេណី និងធម៌គឺសុចរិត ទ្រង់ជាព្រះរាជាដែលដឹងច្បាស់នូវធម៌ ព្រោះដឹងច្បាស់ទូទៅដល់ធម៌ទាំងនោះ ទ្រង់ជា

បុគ្គលមានបញ្ញាមុតស្រួច ទ្រង់ជាបុគ្គលដែលធម៌រក្សាគ្រប់គ្រងហើយ សូមទ្រង់តាំងព្រះជន្មាយុយឺនយូរចុះ បពិត្រមហារាជដ៏ប្រសើរ អ្នករក្សាធម៌ អ្នកគ្រប់គ្រងធម៌ សូមទ្រង់សម្ដែងធម៌ដល់ទូលព្រះបង្គំចុះ ។

លំដាប់នោះ ព្រះរាជាកាលទ្រង់សម្ដែងធម៌ ទើបផ្ដើមគាថាថា **តធិង្ឃ** ដូច្នេះជាដើម សព្ទថា **តង្ឃ** ក្នុងគាថានេះ ត្រឹមតែជានិបាត ប្រើក្នុងអត្ថថា ជាស់តៀន អធិប្បាយថា ព្រោះអ្នកជាស់តៀនយើង ដូច្នោះ ចូរអ្នកស្ដាប់ពាក្យរបស់យើង ។ បទថា **សតំ** បានដល់ ធម៌ដែលសប្បុរសទាំងឡាយមានព្រះពុទ្ធជាដើមសេពហើយ ។ បទថា **សាធុ** បានដល់ ល្អប្រពៃ គឺប្រសើរបំផុត ។ ព្រះរាជាទ្រង់ឈ្មោះថា ជាអ្នកពេញចិត្តក្នុងធម៌ ព្រោះអត្ថថា ទ្រង់ពេញព្រះហឫទ័យក្នុងធម្មវិនិច្ឆ័យ ធម្មបវេណី និងសុចរិតធម៌ ។ ពិតហើយព្រះរាជានោះ ទោះបីត្រូវលះនូវព្រះជន្ម ក៏ទ្រង់មិនធ្វើកម្មដែលមិនគួរធ្វើ ព្រោះហេតុនោះ ទើបជាព្រះរាជាដែលមានសេចក្ដីល្អ ។ បទថា **បញ្ញាណវា** គឺដល់ព្រមដោយញាណ ។ បទថា **មិត្តានមទុព្ភោ** គឺភាពជាអ្នកមិនប្រទូស្តចំពោះមិត្ត ។ បទថា **ឋិតធម្មស្ស** គឺមានធម៌ទាំង ៣ យ៉ាង តម្កល់ទុកល្អហើយ ។ បទថា **អាសេថ** គឺគប្បីដេក គប្បីអង្គុយ ពិតហើយពាក្យថា គប្បីដេកនេះ ជាមាតិកានៃទេសនាប៉ុណ្ណោះ ក្នុងសេចក្ដីនេះ មានពាក្យអធិប្បាយថា គប្បីសម្រេចសេចក្ដីសុខក្នុងឥរិយាបថទាំង ៤ ។ បទថា **សីតច្ឆាយាយ** បានដល់ ម្លប់ត្រជាក់រវាងបុត្ត ភរិយា ញាតិនិងមិត្តទាំងឡាយ ។ បទថា **សង្ឃរេ** គឺក្នុងផ្ទះដែលជារបស់ខ្លួនឯង ព្រះរាជាទ្រង់សម្ដែងថា ពួកមនុស្សដែលមិន

ត្រូវបៀតបៀនដោយពលីកម្មនិងអាជ្ញាដែលមិនជាធម៌ជាដើម គប្បីនៅជាសុខ ។ បទថា **ន ចាហមេតំ** សេចក្តីថា នែអភិបារកៈសម្លាញ់ កម្មឯណាដែលមិនបានពិចារណាមុន ហើយធ្វើជាកម្មដែលធ្វើមិនល្អ យើងមិនគាប់ចិត្តក្នុងកម្មនោះទេ ។ បទថា **យេវាបិ ញត្វាន** អធិប្បាយថា ខ្ញុំគាប់ចិត្តកម្មរបស់ព្រះរាជាដែលទ្រង់ដឹងហើយ គឺពិចារណាហើយទ្រង់ធ្វើឯង ។ ក្នុងពាក្យថា**ឧបមា ឥមា** នេះ សេចក្តីថា ចូរអ្នកតាំងចិត្តស្តាប់ឧបមា ២ ប្រការរបស់យើងចុះ ។ បទថា **ជិម្ហំ** បានដល់ វៀច ។ បទថា **នេត្តេ** បានដល់ គោឧសភដ៏ប្រសើរនាំហ្វូងមេគោទៅ ។ បទថា **បគេវ** សេចក្តីថា កាលព្រះរាជាអង្គនោះប្រព្រឹត្តអធម៌ មហាជនក្រៅអំពីនេះ រមែងនាំគ្នាប្រព្រឹត្តអធម៌ដែរ គឺក្រៃលែងប្រព្រឹត្តធ្វើនូវការៈធ្ងន់ឡើង ។ បទថា **ធម្មិកោ** បានដល់ ព្រះរាជាទ្រង់លះនូវការដល់អគតិ ៤ ប្រការ ហើយសោយរាជសម្បត្តិដោយធម៌ ។ បទថា **អមរត្តំ** បានដល់ភាពជាទេវតា ។ បទថា **រតនំ** បានដល់ សវិញ្ញាណករតនៈនិងអវិញ្ញាណករតនៈ ។ បទថា **វត្ថិយំ** គឺកាសិកពស្រ្ត ។ បទថា **អស្សិត្ថិយោ** សំដៅដល់ សេះដែលរត់មានសម្ទុះដូចខ្យល់បក់ និងសំដៅដល់មនុស្សស្រីដែលមានរូបស្អាតក្រៃលែង ។ បទថា **រតនំ មណិកញ្ច** សំដៅដល់ កែវ ៧ ប្រការ និងទ្រព្យដែលមានតម្លៃច្រើន ។ បទថា **អភិចាលយន្តិ** សេចក្តីថា រមែងរក្សាសត្វលោកធ្វើឲ្យរុងរឿង ។ បទថា **ន តស្ស** សេចក្តីថា បុគ្គលមិនគួរប្រព្រឹត្តនូវកំហុស ព្រោះហេតុនៃភាពជាស្តេចចក្រពត្តិនោះឡើយ ។ បទថា **ឧសភោស្មិ** សេចក្តីថា ព្រោះយើងជាព្រះរាជាប្រសើរបំផុត បណ្តាអ្នកដែន

សីវិ ដូច្នោះយើងមិនព្រមប្រព្រឹត្តខុស សូម្បីហេតុឲ្យបានជាស្តេចចក្រពត្តិ ។ បទថា **ណេតា** សេចក្តីថា យើងធ្វើឲ្យមហាជនតាំងនៅក្នុងកុសលកម្ម នាំទៅកាន់ទេវនគរ ជាអ្នកស្វែងរកប្រយោជន៍ចំពោះមហាជននោះ ដោយការធ្វើប្រយោជន៍ ជាបុគ្គលមានឈ្មោះល្បីល្បាញ ព្រោះមានមហាជនស្គាល់ពេញជម្ពូទីប បានឮថា ព្រះបាទសីវិរាជទ្រង់ប្រព្រឹត្តធម៌ ជាអ្នករក្សានូវដែន ព្រោះទ្រង់បានគ្រប់គ្រងដែនដោយធម៌ស្មើ ។ បទថា **អបចាយមានោ** គឺបន្ទោនចំពោះធម៌ដែលទាក់ទងដោយព្រះរាជបវេណីរបស់ព្រះរាជា តាំងអំពីបុរាណ-កាល របស់អ្នកដែនសីវិទាំងឡាយ ។ បទថា **សោ** អធិប្បាយថា ខ្ញុំជាអ្នកជ្រើសរើស នូវធម៌នោះឯង ព្រោះហេតុនោះ ទើបខ្ញុំមិនប្រព្រឹត្តទៅក្នុងអំណាចនៃចិត្តរបស់ខ្លួនឯង ។

អភិបារកសេនាបតី លុះបានស្តាប់ធម្មកថា របស់ព្រះមហាក្សត្រយ៉ាងនេះហើយ កាលធ្វើនូវការសរសើរទើបពោលគាថាមានពាក្យផ្តើមថា **អទ្ធា** ដូច្នេះជាដើម ។ បទថា **ឆប្បមជ្ជសិ** សេចក្តីថា ទ្រង់មិនវង្វេងដោយធម៌ដែលទ្រង់បានត្រាស់ទុកហើយ គឺប្រព្រឹត្តក្នុងធម៌នោះប៉ុណ្ណោះ ។ បទថា **ធម្មំ បមជ្ជ** បានដល់ ទ្រង់ភ្លេចនូវធម៌ ហើយប្រព្រឹត្តទៅដោយអំណាចអគតិ អភិបារកសេនាបតីនោះ កាលធ្វើនូវការសរសើរព្រះមហាក្សត្រយ៉ាងនេះហើយ ទើបពោលគាថាទូន្មាន ១០ គាថា មានពាក្យថា **ធម្មញ្ចរ** ដូច្នេះ ជាដើម ឲ្យក្រៃលែងទៀត អត្ថនៃគាថាទាំងនោះ បានពណ៌នាទុកហើយ ក្នុងតេសកុណជាតកខាងដើមនោះឯង ។

កាលអភិបារកសេនាបតី សម្តែងធម៌ដល់ព្រះរាជាយ៉ាងនេះហើយ ព្រះរាជាទ្រង់ក៏បានបន្ទោបង់នូវសេចក្តីស្រឡាញ់ក្នុងនាងឧម្មាទន្តីបាន ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុរូបនោះ ក៏តាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា សុនន្ទសារថីក្នុងកាលនោះ បានមកជាអានន្ទ ក្នុងកាលឥឡូវនេះ អភិបារកសេនាបតីក្នុងកាលនោះ បានមកជាសារីបុត្ត នាងឧម្មាទន្តីក្នុងកាលនោះ បានមកជាឧប្បលវណ្ណា បរិស័ទដ៏សេសក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ឯស្តេចសីវិរាជក្នុងកាលនោះ គឺតថាគតអរហន្តសម្មាសម្ពុទ្ធនេះឯង ។

## អដ្ឋកថា ឧម្មាទន្តីជាតក ចប់

# មហាពោធិជាតក

[ ៥២ ] ( ព្រះបាទព្រហ្មទត្តត្រាស់សួរថា ) បពិត្រព្រាហ្មណ៍ ហេតុអ្វី ក៏លោកប្រញាប់ប្រញាល់កាន់យកឈើច្រត់ផង ស្បែកខ្លាឃ្មុំផង ឆត្រផង ស្បែកជើងផង តម្កក់ផង បាត្រផង សង្ឃាដិផង លោកប្រាថ្នា ( ដើម្បីទៅ ) កាន់ទិសណាហ្ន៎ ។

[ ៥៣ ] ( ព្រះមហាសត្វឆ្លើយថា ) អាត្មាភាពនៅក្នុងសំណាក់ ព្រះអង្គអស់ ១២ ឆ្នាំនេះហើយ មិនដែលស្គាល់សំឡេងដែលឆ្កែក្រហម ព្រុសម្តងឡើយ ។ ឆ្កែនោះបញ្ចេញចង្កូមសស្ងាច ព្រុសដូចជាសាហាវ ព្រោះឮ ( ព្រះបន្ទូល ) របស់ព្រះអង្គ ព្រមទាំងអគ្គមហេសី ដែលមានជំនឿទៅប្រាសហើយក្នុងរវាងអាត្មាភាព ។

[ ៥៤ ] ( ព្រះរាជា... ) បពិត្រព្រាហ្មណ៍ ទោសនុ៎ះខ្ញុំបានធ្វើហើយ ដូចជាលោកពោល ខ្ញុំនោះជ្រះថ្លាលើសដើម បពិត្រព្រាហ្មណ៍ សូមលោកគង់នៅ ចូរកុំទៅ ។

[ ៥៥ ] ( ព្រះមហាសត្វ... ) កាលពីដើម បាយសសុទ្ធ តពីនោះមកបាយពព្រុះ ឥឡូវនេះ បាយក្រហមសុទ្ធ ( កាលនេះ ) ជាកាលគួរអាត្មាភាពចៀសចេញទៅហើយ ។

ពីដើមអាសនៈរបស់ ( អាត្មាភាព ) នៅខាងក្នុង ( ប្រាសាទ ) តមកនៅកណ្តាល ( ក្បាលជណ្តើរ ) តពីនោះមកទៀត នៅខាងក្រៅ អាត្មាភាពនឹងចេញទៅខ្លួនឯង មុនការបណ្តេញ ។ បុគ្គលមិនត្រូវសេពគប់បុគ្គលប្រាសចាកសទ្ធា ដែលទុកដូចអណ្តូងមិនមានទឹក ប្រសិនបើបុគ្គលកកាយអណ្តូង

នោះ ( ទឹកដែលចេញអំពីអណ្តូងនោះ ) មុខជាប្រកបដោយក្លិនភក់មិនខាន ។ បុគ្គលត្រូវសេពគប់ចំពោះតែជនដែលជ្រះថ្លា ត្រូវវៀរចាកជនដែលមិនជ្រះថ្លា ត្រូវចូលទៅអង្គុយជិតជនដែលជ្រះថ្លា ដូចជាបុគ្គលត្រូវការដោយទឹក ( ចូលទៅរក ) អន្លង់ទឹក ដូច្នោះ ។ បុគ្គលគួរគប់រកបុរសដែលគប់រក ( ខ្លួន ) មិនគួរគប់រកបុរសដែលមិនគប់រក ( ខ្លួន ) ទេ បុគ្គលណា មិនគប់រកបុគ្គលដែលគប់រក ( ខ្លួន ) បុគ្គលនោះ ឈ្មោះថា កាន់ធម៌របស់អសប្បុរស ។ បុគ្គលណាមិនគប់រកបុគ្គលដែលគប់រក ( ខ្លួន ) មិនសេពគប់ចំពោះបុគ្គលដែលសេពគប់ ( នឹងខ្លួន ) បុគ្គលនោះឯង ជាមនុស្សអាក្រក់ផុត ដូចជាម្រឹគដែលអាស្រ័យនៅលើមែកឈើ ( ស្វា ) ។ មិត្តទាំងឡាយលាកចិត្តពីគ្នាដោយហេតុនេះគឺ ដោយនៅប្រឡូកប្រឡំគ្នា ញឹកពេក ១ ដោយការមិនជួបគ្នាសោះ ១ ដោយការសូមក្នុងកាលមិនគួរ ១ ព្រោះហេតុនោះ បុគ្គលមិនត្រូវទៅញឹកៗផង មិនត្រូវទៅ ( ឃ្លាតគ្នា ) យូរពេកផង គប្បីសូមនូវរបស់ដែលគួរសូមតាមកាលផង យ៉ាងនេះ ទើបមិត្តទាំងឡាយមិនលាកចិត្តពីគ្នា ។ បុគ្គលជាប់ទីស្រឡាញ់ ទៅជាមិនជាទីស្រឡាញ់វិញ ព្រោះនៅរួមគ្នាយូរពេក អាត្មាភាពសូមលាព្រះអង្គទៅ មុនយើងទាំងឡាយនោះ មិនជាទីស្រឡាញ់គ្នាទេ ។

[ ៥៦ ] ( ព្រះរាជា... ) បើលោកម្ចាស់មិនទទួលដឹងនូវអញ្ជលីរបស់យើងទាំងឡាយដែលអង្វរយ៉ាងនេះ មិនធ្វើតាមពាក្យយើងដែលជាសត្វបម្រើទេយើងខ្ញុំសូមអង្វរលោកម្ចាស់យ៉ាងនេះ សូមលោកម្ចាស់ធ្វើនូវសេចក្តីប្រាថ្នា

( ដើម្បីមកក្នុងទីនេះ ) ម្ដងៗ ។

[ ៥៧ ] ( ពោធិសត្វ... ) បពិត្រមហារាជ ទ្រង់មានសេចក្ដីចម្រើនក្នុងដែន កាលបើយើងទាំងឡាយនៅ ( ផ្សេងគ្នា ) យ៉ាងនេះ អន្តរាយនឹងមិនមានដល់ព្រះអង្គផង ដល់អាត្មាភាពផង សូមយើងទាំងឡាយជួបគ្នា ក្នុងកាលកន្លងទៅមួយថ្ងៃមួយយប់ ។

[ ៥៨ ] ( ព្រះមហាសត្វទម្លាយនូវវាទៈរបស់អាមាត្យជាអហេតុកវាទីថា ) បើពាក្យ ( របស់អ្នកថា ) សត្វប្រព្រឹត្តទៅតាមសង្គតិ ( នៃអភិជាតិទាំង ៦ ) នឹងសភាវ សត្វធ្វើនូវអំពើដែលមិនគួរធ្វើ ( បាប ) ឬអំពើដែលគួរធ្វើ ( បុណ្យ ) តើនរណា ក្នុងលោកនេះ ប្រឡាក់ដោយបាប ព្រោះអំពើដែលធ្វើដោយការមិនចង់ ។ បើ ( សេចក្ដីនៃភាសិតរបស់អ្នក គឺអហេតុកវាទ ) នោះ ជាអត្ថផង ជាធម៌ផង ល្អមិនអាក្រក់ទេ បើពាក្យរបស់អ្នកដ៏ចម្រើនជាពាក្យពិត ពានរក៏ឈ្មោះថា អាត្មាសម្លាប់ត្រូវហើយ ។ បើអ្នកដឹងនូវកំហុសនៃវាទៈរបស់ខ្លួន អ្នកមិនត្រូវតិះដៀលអាត្មាទេ ដ្បិតវាទរបស់អ្នកដ៏ចម្រើនបែបនោះ ។

[ ៥៩ ] ( ព្រះមហាសត្វ ទម្លាយនូវវាទៈរបស់អាមាត្យជាឥស្សរករណវាទីថា ) ប្រសិនបើព្រះឥសូរចាត់ចែងជីវិតរបស់សត្វលោកទាំងអស់ផង ចាត់ចែងនូវឫទ្ធិ គឺឥស្សរិយយសផង នូវភាពនៃសេចក្ដីវិនាសផង នូវកម្មល្អនិងអាក្រក់ផងមាន បុរស ( ណាមួយ ) ជាអ្នកធ្វើតាមបង្គាប់ ( របស់ព្រះឥសូរនោះ ) ព្រះឥសូរទេតើ តែងប្រឡាក់ជិតជាមដោយអំពើអាក្រក់

នោះ ( ដោយខ្លួនឯង ) ។ បើ ( សេចក្តីនៃកាសិតរបស់អ្នក ) នោះ ជាអត្ថផង ជាធម៌ផង ល្អមិនអាក្រក់ទេ បើពាក្យរបស់អ្នកដ៏ចម្រើន ជាពាក្យពិត ពានរក៏ឈ្មោះថាអាត្មាសម្លាប់ត្រូវហើយ ។ បើអ្នកដឹងច្បាស់នូវកំហុសនៃវាទៈរបស់ខ្លួន អ្នកមិនត្រូវតិះដៀលអាត្មាទេ ដ្បិតវាទៈរបស់អ្នកដ៏ចម្រើនបែបនោះ ។

[ ៦០ ] ( ព្រះមហាសត្វ ទម្លាយនូវវាទនៃអាមាត្យដែលជាបុព្វេកតហេតុវាទីថា ) បើបុគ្គលដល់នូវសុខទុក្ខ ព្រោះហេតុនៃអំពើដែលខ្លួនធ្វើក្នុងកាលមុន បុគ្គលនោះឯង រមែងរួចចាកបំណុលនោះ ដែលជាអំពើអាក្រក់គឺខ្លួនធ្វើពីដើមមក ( កាលបើយ៉ាងនេះ ) អាត្មាក៏ឈ្មោះថា បានរួចចាកបំណុលចាស់ តើនរណា ក្នុងលោកនេះប្រឡាក់ដោយបាប ។ បើ ( សេចក្តីនៃកាសិតរបស់អ្នក ) នោះជាអត្ថផង ជាធម៌ផង ល្អមិនអាក្រក់ទេ បើពាក្យរបស់អ្នកដ៏ចម្រើន ជាពាក្យពិត ពានរក៏ឈ្មោះថា អាត្មាសម្លាប់ត្រូវហើយ ។ បើអ្នកដឹងច្បាស់នូវកំហុសនៃវាទៈរបស់ខ្លួន អ្នកមិនត្រូវតិះដៀលអាត្មាទេដ្បិតវាទៈរបស់អ្នកដ៏ចម្រើនបែបនោះ ។

[ ៦១ ] ( ព្រះមហាសត្វទម្លាយនូវវាទៈរបស់អាមាត្យជាឧច្ឆេទវាទីថា ) រូបក្ខន្ធរបស់សត្វទាំងឡាយ តែងកកើតឡើង ព្រោះអាស្រ័យនូវភូតរូបទាំង ៤ ( មានដីជាដើម ) ឯរូប ( នោះ ) កកើតឡើងអំពីភូតរូបណា ( ដល់ពេលរលត់ ) ក៏ត្រឡប់ទៅក្នុងភូតរូបនោះវិញ ។ ជីវៈរស់នៅក្នុងលោកនេះ លុះវិលាសខ្លួនទៅហើយ នឹងសាបសូន្យក្នុងបរលោក លោកនេះ

ជាច់សូន្យ ជនទាំងឡាយ ទាំងពាលទាំងបណ្ឌិត ( រមែងសូន្យដូចគ្នា ) កាល បើលោកនេះដាច់សូន្យហើយ តើនរណាក្នុងលោកនេះ ប្រឡាក់ដោយបាប ។ បើ ( សេចក្ដីនៃកាសិតរបស់អ្នក ) នោះ ជាអត្ថផង ជាធម៌ផង ល្អមិនអាក្រក់ទេ បើពាក្យរបស់អ្នកដ៏ចម្រើន ជាពាក្យពិត ពានរក៏ឈ្មោះថាអាត្មាសម្លាប់ត្រូវ ហើយ ។ បើអ្នកដឹងច្បាស់នូវកំហុសនៃវាទះរបស់ខ្លួន អ្នកមិនត្រូវតិះដៀល អាត្មាទេ ដ្បិតវាទរបស់អ្នកដ៏ចម្រើនបែបនោះ ។

[ ៦២ ] ( ព្រះមហាសត្វទម្លាយនូវវាទះរបស់អាមាត្យជាខត្តវិជ្ជវាទីថា ) ជនទាំងឡាយអ្នកមានខត្តវិជ្ជា ( វិជ្ជាខាងការគាស់រំលើង ) ក្នុងលោកជាជន ពាលសោះទេ តែមានមានះថា ជាបណ្ឌិត ពោលថាបុគ្គលសម្លាប់មាតា ក៏ បាន បិតាក៏បាន ពុំនោះសោតទេ សម្លាប់បងប្អូន ឬកូនប្រពន្ធក៏បាន ប្រសិន បើមានប្រយោជន៍បែបនោះ ។

[ ៦៣ ] ( មហាសត្វប្រកាសនូវលទ្ធិរបស់ខ្លួនថា ) បុគ្គលអង្គុយក្ដី ដេកក្ដី ក្រោមម្លប់ឈើណា មិនត្រូវកាច់មែកឈើនោះទេ ដ្បិតបុគ្គលប្រទូស្ត មិត្ត ជាមនុស្សអាក្រក់ ។ ( ចំណែកខាងអ្នកពោលថា ) កាលបើប្រយោជន៍ កើតឡើង ( ចំពោះខ្លួន ) ហើយ បុគ្គលគប្បីគាស់រំលើង សូម្បីទាំងឫស ក៏បាន ( ដូច្នេះ ) ពានរក៏ឈ្មោះថា អាត្មាសម្លាប់ត្រូវហើយ ព្រោះអាត្មាត្រូវ ការដោយស្បៀង ។ បើសេចក្ដីនៃកាសិតរបស់អ្នកនោះ ជាអត្ថផង ជាធម៌ ផង ល្អមិនអាក្រក់ទេ បើពាក្យរបស់អ្នកដ៏ចម្រើន ជាពាក្យពិត ពានរក៏ឈ្មោះ ថា អាត្មាសម្លាប់ត្រូវហើយ ។ បើអ្នកដឹងច្បាស់នូវកំហុសនៃវាទះរបស់ខ្លួន

អ្នកមិនត្រូវតិះដៀលអាត្មាទេ ដ្បិតវាទៈរបស់អ្នកដ៏ចម្រើនបែបនោះ ។

[ ៦៤ ] ( ព្រះមហាសត្វសម្តែងធម៌ដល់ព្រះរាជាថា ) ( បុរសអ្នកលុះក្នុងអំណាចនៃទិដ្ឋិ ៥ នាក់គឺ ) បុរសជាអហេតុវាទៈ ១ ជាឥស្សរកតវាទៈ ១ ជាបុព្វេកតវាទៈ ១ ជាឧច្ឆេទវាទៈ ១ ជាខត្តវិជ្ជវាទៈ ១ នេះជាអសប្បុរសក្នុងលោក ជាមនុស្សពាល តែប្រកាន់ខ្លួនថាជាបណ្ឌិត បុរសបែបនោះ ធ្វើបាប ( ខ្លួនឯង ) ថែមទាំងញុំាងអ្នកដទៃឲ្យធ្វើបាបទៀតផង ការនៅប្រឡូកប្រឡំនឹងអសប្បុរស មានទុក្ខជាទីបំផុត មានសេចក្តីក្តៅក្រហាយជាកម្រៃ ។

[ ៦៥ ] កាលពីដើម មានសត្វកុក ១ មានរូបដូចចៀម កាលបើឥតគេសង្ស័យ ក៏ចូលទៅរកហ្វូងពពែ សម្លាប់មេចៀមផង មេពពែផង ពពែឈ្មោលផង លុះសម្លាប់បានហើយ ក៏ហើរទៅតាមបំណងរបស់ខ្លួន ។ សមណព្រាហ្មណ៍ពួកខ្លះ ក៏បែបនោះដែរ ធ្វើនូវគ្រឿងបិទបាំង ហើយបញ្ឆោតមនុស្សទាំងឡាយ ( ពួកខ្លះ ) ជាអ្នកមិនបរិភោគអាហារ ( ពួកខ្លះ ) ជាអ្នកដេកលើផែនដី ( ពួកខ្លះ ) ទុកក្អែល ( ពួកខ្លះ ) ព្យាយាមអង្គុយច្រហោង ( ពួកខ្លះ ) បរិភោគបាយដោយកំណត់ថ្ងៃ ( ពួកខ្លះ ) មិនផឹកទឹក មានមារយាទអាក្រក់ នាំគ្នាពោលថា ខ្លួនជាអរហន្ត ។ ជនទាំងនុ៎ះ ជាអសប្បុរសក្នុងលោក ជាមនុស្សពាល តែប្រកាន់ខ្លួនថាជាបណ្ឌិត បុគ្គលបែបនោះធ្វើបាប ( ខ្លួនឯង ) ផង ថែមទាំងញុំាងអ្នកដទៃឲ្យធ្វើបាបទៀតផង ការនៅប្រឡូកប្រឡំដោយអសប្បុរស មានទុក្ខជាទីបំផុត មានសេចក្តីក្តៅ

ក្រហាយជាកម្រែ ។ ពួកជនណាពោលថា ព្យាយាមឥតអំពើផង មិនពោលអាងហេតុផង ពណ៌នានូវអំពើរបស់បុគ្គលដទៃ និងអំពើរបស់ខ្លួនថា ជាអំពើសូន្យទទេផង ។ ពួកជនទុ៎ះជាអសប្បុរសក្នុងលោក ជាមនុស្សពាលតែប្រកាន់ខ្លួនថាជាបណ្ឌិត បុរសបែបនោះធ្វើបាប ( ខ្លួនឯង ) ផង ថែមទាំងញុំាងអ្នកដទៃឲ្យធ្វើបាបទៀតផង ការនៅប្រឡូកប្រឡំដោយអសប្បុរសមានទុក្ខជាទីបំផុត មានសេចក្តីក្តៅក្រហាយជាកម្រែ ប្រសិនបើការព្យាយាមឥតអំពើ មិនមានអំពើល្អនិងអាក្រក់ទេ ព្រះរាជាមិនគប្បីចិញ្ចឹមនូវជាងឈើទាំងមិនគប្បីឲ្យគេធ្វើនូវយន្តទាំងឡាយឡើយ ។ ព្រោះហេតុតែការព្យាយាមមានផង អំពើល្អនិងអាក្រក់មានផង បានជាព្រះរាជាតែងចាត់ឲ្យធ្វើនូវយន្តទាំងឡាយ តែងចិញ្ចឹមនូវជាងឈើ ។ ប្រសិនបើភ្លៀងខានបង្អុរចុះរហូតមួយរយឆ្នាំ ទាំងទឹកសន្សើមក៏មិនធ្លាក់ចុះសោះ មុខជាលោកនេះ នឹងសូន្យឈឹងពពួកសត្វនេះនឹងវិនាស ។ ព្រោះហេតុតែភ្លៀងបង្អុរចុះផង ទាំងទឹកសន្សើមក៏ផ្សើមរឿយៗផង បានជាសន្ទូងទាំងឡាយលូតលាស់ល្អ ទាំងអ្នកដែនក៏ព្រះរាជាទ្រង់រក្សាអស់កាលជាអង្វែងផង ។ កាលពួកគោកំពុងឆ្លងទៅ ( កាន់ទីណាមួយ ) បើគោបាទៅវៀច កាលបើគោបានាំពួកគោទៅវៀច មេគោទាំងអស់នោះក៏ទៅវៀច ។ បណ្តាពួកមនុស្សក៏ដូច្នោះដែរ បុគ្គលណាដែលអ្នកផងសន្មតថាប្រសើរផុត បើបុគ្គលនោះប្រព្រឹត្តអធម៌ហើយ នឹងចាំបាច់និយាយថ្វីដល់ប្រជាជនក្រៅនេះ បើព្រះរាជាមិនប្រកបដោយធម៌ អ្នកដែនទាំងអស់ក៏ដេកជាទុក្ខ ។ កាលពួកគោកំពុងឆ្លងទៅ បើគោបាទៅត្រង់ កាល

បើគោបាទាំគេទៅត្រង់ មេគោទាំងអស់នោះក៏ទៅត្រង់ ។ ពួកមនុស្សក៏ដូច្នោះដែរ បុគ្គលណាដែលអ្នកផងសន្មតថា ប្រសើរផុត ប្រសិនបើបុគ្គលនោះប្រព្រឹត្តធម៌ នឹងចាំបាច់និយាយថ្វីដល់ប្រជាជនក្រៅនេះ បើព្រះរាជាប្រកបដោយធម៌ អ្នកដែនទាំងអស់ក៏ដេកជាសុខ ។ បុគ្គលណាបេះផ្លែខ្ចី នៃឈើធំដែលមានផ្លែ ( បុគ្គលនោះ ) រមែងមិនដឹងនូវរសនៃផ្លែឈើនោះផង ទាំងពូជនៃផ្លែឈើនោះ ក៏វិនាសទៅផង ។ ព្រះរាជាណា គ្រប់គ្រងដែន ដែលប្រៀបដូចដើមឈើធំដោយអធម៌ ( ព្រះរាជានោះ ) ឈ្មោះថា មិនជ្រាបនូវរសរបស់ដែននោះផង ទាំងដែនរបស់រាជានោះក៏វិនាសផង ។ បុគ្គលណាបេះផ្លែឈើទុំនៃដើមឈើធំដែលមានផ្លែ បុគ្គលនោះ រមែងដឹងនូវរសនៃផ្លែឈើនោះផង ទាំងពូជរបស់ផ្លែឈើនោះ ក៏មិនវិនាសផង ។ ព្រះរាជាណាគ្រប់គ្រងដែនដែលប្រៀបដូចជាដើមឈើធំដោយធម៌ ( ព្រះរាជានោះ ) ឈ្មោះថា បានជ្រាបនូវរសរបស់ដែននោះផង ទាំងដែនរបស់ព្រះរាជានោះក៏មិនវិនាសផង ។ ព្រះរាជាណាមួយ គ្រប់គ្រងជនបទដោយអធម៌ ( លុះអំណាចអគតិ ) ព្រះរាជា ជាខត្តិយៈនោះ ឈ្មោះថា សាបសូន្យចាកដើមឈើដែលត្រូវជាឱសថទាំងអស់ មួយទៀត ( ព្រះរាជាអង្គណា ) បៀតបៀនពួកកុដុម្ពិកៈដែលនៅក្នុងនិគម ( ផង ) បៀតបៀនពួកពាណិជដែលប្រកបក្នុងការលក់ចេញទិញចូល ជាអ្នកធ្វើនូវការថ្វាយពន្ធដារ និងពលិកា ( ផង ) ព្រះរាជានោះ ឈ្មោះថា សាបសូន្យចាកឃ្លាំង ។ ព្រះរាជាណាបៀតបៀននូវខ្មាន់ធ្នូដែលជាអ្នកដឹងនូវកន្លែងយ៉ាងតំណំ ដែលគួរប្រហារ និង

ពួកទាហានធំ ដែលជាអ្នកពិចារណា ធ្វើការនៅក្នុងសង្គ្រាម និងមហាមាត្យដែលមានសក្តិធំៗ ព្រះរាជានោះ ឈ្មោះថា សាបសូន្យចាកពល ។ សត្វណាប្រព្រឹត្តនូវអធម៌ បៀតបៀនពួកឥសីអ្នកសង្រួម ប្រព្រឹត្តធម៌ដ៏ប្រសើរ ដូចជាបៀតបៀននូវពួកអ្នកនិគម ដូច្នោះ ក្សត្រនោះ ឈ្មោះថា សាបសូន្យចាកឋានសួគ៌ ។ម្យ៉ាងទៀត ព្រះរាជាណា មិនឋិតនៅក្នុងធម៌ សម្លាប់អគ្គមហេសីដែលជាអ្នកមិនប្រទូស្ត ព្រះរាជានោះ ឈ្មោះថា បានជួបប្រទះនូវឋានៈដ៏អាក្រក់ផង ឈ្មោះថា សាបសូន្យចាកកូនទាំងឡាយផង ។ ព្រះរាជាត្រូវតែប្រព្រឹត្តធម៌ផង មិនត្រូវបៀតបៀនអ្នកជនបទនឹងអ្នកនិគមផង ពួកពលផង ពួកឥសីផង គប្បីប្រព្រឹត្តស្មោះស្មើចំពោះកូននឹងប្រពន្ធផង ។ ព្រះរាជានោះ ទើបឈ្មោះថា ជាម្ចាស់នៃផែនដី ឈ្មោះថា អ្នកគ្រប់គ្រងនូវដែន ឈ្មោះថា ជាអ្នកមិនក្រោធ រមែងញុំាំងពួកអ្នកដែន ជិតខាងឲ្យរំភើបញាប់ញ័រ ដូចព្រះឥន្ទជាធំជាងអសុរ ។

**ចប់ មហាពោធិជាតកទី ៣ ។**

**ឧទ្ទាននៃបញ្ញាសនិបាតនោះគឺ**

និទ្ទេសទី ១ ប្រកបដោយនាងរាជធីតាព្រះនាមនឡិនិកា ១ និទ្ទេសទី ២ ប្រកបដោយសេដ្ឋីធីតាឈ្មោះឧម្មាទន្តីដ៏ប្រសើរ ១ និទ្ទេសទី ៣ ប្រកបដោយតាបសមានសិរីឈ្មោះពោធិ ១ និទ្ទេសទាំង ៣ ដ៏ល្អ ( នេះ ) ព្រះជិនស្រីទ្រង់សម្តែងទុកមកហើយ ។

**ចប់ បញ្ញាសនិបាត ។**

# អដ្ឋកថា

## មហាពោធិជាតក

[ ៥២-៦៥ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះបញ្ញាបារមី ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កិន្នុ ទណ្ឌំ កិមាជិនំ** ដូច្នេះជាដើម ។ ផ្ទៃរឿងមានច្បាស់ក្នុងមហាឧម្មង្គជាតកខាងមុខ ។

ក្នុងកាលនោះ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន តថាគតក៏ជាអ្នកមានបញ្ញាអាចញាំញីវាទៈរបស់អ្នកដទៃបានដូចគ្នា ដូច្នោះទើបទ្រង់នាំអតីតនិទានមកត្រាស់ ដូច្នេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ នៅក្នុងក្រុងពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលឧទិច្ចព្រាហ្មណមហាសាល មានទ្រព្យសម្បត្តិប្រមាណ ៨០ កោដិ ក្នុងដែនកាសី ។ មាតាបិតា បានដាក់ឈ្មោះព្រះពោធិសត្វថា ពោធិកុមារ ពោធិកុមារនោះចម្រើនវ័យហើយ បានសិក្សាសិល្បសាស្ត្រក្នុងនគរតក្កសិលា លុះចប់ហើយ ក៏ត្រឡប់មកគ្រប់គ្រងផ្ទះ ។ ក្នុងកាលតមក បានលះសេចក្តីសុខដែលកើតអំពីកាម ហើយចូលកាន់ហិមវន្តប្បទេស បួសជាបរិព្វាជក មានមើមឈើនិងផ្លែឈើក្នុងព្រៃនោះឯង ជាអាហារអស់កាលយូរ លុះដល់រដូវភ្លៀង ទើបចេញអំពីហិមពាន្ត ចារិកទៅដល់ក្រុងពារាណសីដោយលំដាប់ ចូលទៅកាន់ព្រះរាជឧទ្យាន ។ ស្អែកឡើងត្រាច់បិណ្ឌបាតក្នុងព្រះនគរ ដោយឥរិយាបថសមរម្យនៃបរិព្វាជក រហូតដល់ទ្វារព្រះរាជនិវេសន៍ ។ ព្រះរាជាប្រថាប់ឈរត្រង់សីហបញ្ជរ ទតឃើញ

ព្រះពោធិសត្វហើយ ទ្រង់ជ្រះថ្លាក្នុងកិរិយាស្ងប់ស្ងាត់របស់លោក ទើបត្រាស់ឲ្យរាជបុរស ទៅនិមន្តចូលមកកាន់ទីប្រថាប់របស់ទ្រង់ ទ្រង់ធ្វើបដិសណ្ឋារៈ ទ្រង់បានស្តាប់ធម្មកថាបន្តិចបន្តួច ហើយថ្វាយភោជនមានរសដ៏ប្រសើរផ្សេងៗ ។ ព្រះមហាសត្វទទួលភត្តាមក ពិចារណាថា ឈ្មោះថា រាជត្រកូលមានទោសច្រើនផង ពួកបច្ចាមិត្តក៏មានច្រើនផង អ្នកណាហ្ន៎ នឹងជួយកម្ចាត់ទុក្ខដែលកើតឡើងដល់ខ្លួនអញបាន ។ ព្រះពោធិសត្វបានសម្លឹងឃើញឆ្កែពណ៌ក្រហមមួយក្បាល ដែលជាទីសព្វព្រះហឫទ័យរបស់ព្រះរាជា នៅក្នុងទីក្បែរៗ ទើបចាប់ដុំបាយមួយដុំធំ សម្តែងអាកប្បកិរិយានឹងឲ្យសុនខនោះ ។ ព្រះរាជាទ្រង់ជ្រាបអាការនោះ ទើបឲ្យមនុស្សនាំយកភាជនៈមកដាក់ភត្ត ហើយឲ្យដល់ឆ្កែនោះ ។ ព្រះមហាសត្វ ក៏ធ្វើភត្តកិច្ចរបស់ព្រះរាជាអង្គនោះ ឲ្យសម្រេចហើយ ។ ព្រះរាជា ទ្រង់ទទួលបដិញ្ញារបស់ព្រះមហាសត្វរៀបរយហើយ ឲ្យជាងធ្វើសាលាស្លឹកទុកក្នុងព្រះរាជឧទ្យានខាងក្នុងព្រះនគរ ហើយទ្រង់ប្រគេនបរិក្ខារសម្រាប់បព្វជិត និមន្តឲ្យព្រះមហាសត្វនៅប្រចាំក្នុងទីនោះ ។ ព្រះរាជាបានយាងទៅកាន់ទីបម្រើរបស់ព្រះមហាសត្វ មួយថ្ងៃ ២-៣ លើក ។ លុះដល់វេលាឆាន់ព្រះមហាសត្វ ឡើងអង្គុយលើរាជបល្ល័ង្កនៃព្រះរាជា ហើយឆាន់ភោជនរបស់ព្រះរាជា ជាប្រចាំនោះឯង ធ្វើយ៉ាងនេះរហូតកន្លងទៅអស់ ១២ ឆ្នាំ ។

ព្រះរាជាអង្គនោះ មានអាមាត្យ ៥ នាក់ ធ្វើការបង្រៀនអត្ថនិងធម៌ ។

បណ្តាអាមាត្យទាំង ៥ នោះ ម្នាក់ជាអហេតុកវាទី ម្នាក់ជាឥស្សរករណវាទី ម្នាក់ជាបុព្វេកតវាទី ម្នាក់ជាឧច្ឆេទវាទី និងម្នាក់ជាខត្តវិជ្ជវាទី ។ ក្នុង

អាមាត្យទាំង ៥ នោះ អាមាត្យដែលជាអហេតុកវាទី ទូន្មានមហាជនថា សត្វទាំងនេះ ជាអ្នកបរិសុទ្ធក្នុងសង្សារ ។ អាមាត្យដែលជាឥស្សរករណវាទី ទូន្មានមហាជនថា លោកនេះ ព្រះម្ចាស់សួគ៌ជាអ្នកសាង ។ អាមាត្យដែលជាបុព្វេកតវាទី ទូន្មានឲ្យមហាជនយល់ថា សេចក្ដីសុខឬសេចក្ដីទុក្ខរបស់សត្វទាំងនេះ កាលនឹងកើតឡើង រមែងកើតដោយហេតុដែលខ្លួនធ្វើទុក ក្នុងកាលមុននោះឯង ។ អាមាត្យដែលជាឧច្ឆេទវាទីទូន្មានឲ្យមហាជនកាន់យកថា ឈ្មោះថា បុគ្គលទៅអំពីលោកនេះ ទៅកាន់លោកខាងមុខរមែងមិនមាន លោកនេះរមែងដាច់សូន្យ ។ អាមាត្យដែលជាខត្តវិជ្ជវាទី ទូន្មានមហាជនឲ្យយល់ថា បុគ្គលគួរសម្លាប់សូម្បីមាតាបិតា ហើយធ្វើប្រយោជន៍របស់ខ្លួនឯងតែម្យ៉ាង អាមាត្យទាំង ៥ នោះ តាំងនៅក្នុងតំណែងអ្នកពិភាក្សាអត្ថក្ដីជំនួសព្រះរាជា តែនាំគ្នាស៊ីសំណូក កាត់ក្ដី ធ្វើបុគ្គលមិនជាម្ចាស់ទ្រព្យ ឲ្យបានជាម្ចាស់ទ្រព្យ ធ្វើបុគ្គលជាម្ចាស់ទ្រព្យ មិនឲ្យជាម្ចាស់ទ្រព្យ ។

ថ្ងៃមួយ បុរសម្នាក់ជាអ្នកចាញ់ក្ដី ព្រោះការកាត់ក្ដីមិនយុត្តិធម៌ ឃើញព្រះមហាសត្វត្រាច់បិណ្ឌបាត ចូលទៅកាន់ព្រះរាជនិវេសន៍ ទើបថ្វាយបង្គំបណ្ដើរ យំរៀបរាប់បណ្ដើរថា បពិត្រលោកម្ចាស់ លោកមកឆាន់ក្នុងព្រះរាជនិវេសន៍ ព្រោះហេតុអ្វី ទើបគ្រាន់តែក្រឡេកមើលអាមាត្យ ដែលវិនិច្ឆ័យក្ដីទទួលសំណូក ធ្វើឲ្យសត្វលោកវិនាសទៅវិញ ឥឡូវនេះ ខ្ញុំជាម្ចាស់ទ្រព្យឲ្យត្រឡាំង តែបែរជាត្រូវពួកអាមាត្យទាំង ៥ ទទួលសំណូកពីដៃកូនក្ដី ធ្វើឲ្យខ្ញុំមិនមែនជាម្ចាស់ទ្រព្យ ។ ដោយការអាណិតក្នុងបុរសនោះ ព្រះមហា

សត្វ ក៏ចូលទៅកាន់រោងវិនិច្ឆ័យ ហើយកាត់ក្ដីដោយយុត្តិធម៌ បានធ្វើម្ចាស់ទ្រព្យឲ្យជាម្ចាស់ទ្រព្យវិញ ។ មហាជនបានឲ្យសាធុការ ដោយសំឡេងខ្លាំងព្រមគ្នានោះឯង ។ ព្រះរាជាទ្រង់បានស្ដាប់សំឡេងនោះហើយ ទើបត្រាស់សួរថា នេះសំឡេងអ្វីហ្ន៎ លុះបានស្ដាប់សំឡេងនោះហើយ ទើបយាងចូលទៅអង្គុយជិតព្រះមហាសត្វ ដែលធ្វើកត្តកិច្ចស្រេចហើយ ត្រាស់សួរថា បពិត្រលោកម្ចាស់ បានឮថា ថ្ងៃនេះ លោកម្ចាស់កាត់ក្ដីឯងឬ មហាសត្វទូលថា សូមថ្វាយព្រះពរ មហាបពិត្រ ។ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ បើលោកម្ចាស់ធ្វើការកាត់ក្ដីជាប្រចាំតទៅ សេចក្ដីចម្រើននឹងមានដល់មហាជន ចាប់តាំងអំពីនេះទៅ សូមលោកម្ចាស់ជួយកាត់ក្ដីផងចុះ ។ ព្រះមហាសត្វក្រាបទូលថា បពិត្រមហារាជ អាត្មាជាបព្វជិត ការវិនិច្ឆ័យក្ដីនេះ មិនមែនកិច្ចរបស់អាត្មាភាពឡើយ ។ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ លោកគួរធ្វើករុណាក្នុងមហាជនចុះ លោកម្ចាស់ មិនចាំបាច់វិនិច្ឆ័យអស់មួយថ្ងៃក៏បាន គឺក្នុងពេលព្រឹក ចេញអំពីឧទ្យានចូលមកក្នុងទីនេះ ចៀសចូលទៅកាន់រោងក្ដី ហើយធ្វើនូវការកាត់ក្ដី ត្រឹមតែ ៤ រឿង លុះឆាន់កត្តាហារស្រេចហើយ ត្រឡប់ទៅកាន់ឧទ្យាន សូមជួយវិនិច្ឆ័យក្ដី ៤ រឿងទៀត បើធ្វើយ៉ាងនេះបាន សេចក្ដីចម្រើននឹងមានដល់មហាជន ។ ព្រះមហាសត្វត្រូវព្រះរាជាអង្វររឿយៗ ទើបព្រមទទួលថា សាធុ ដូច្នេះ ។ តាំងពីថ្ងៃនោះមក ក៏បានធ្វើយ៉ាងនោះ ពួកកូនក្ដីកោងទាំងឡាយ ក៏មិនបានឱកាស ។

ចំណែកពួកអាមាត្យ ៥ នាក់នោះសោត កាលមិនបានសំណូក ក៏ធ្លាក់

ខ្លួនក្រៀមក្រំ នាំគ្នាប្រឹក្សាគ្នាថា តាំងពីពោធិបរិញ្វជកមកកាត់ក្តី ពួកយើងមិនបាន អ្វីសោះ ណ្ហើយចុះ ពួកយើងនឹងចាប់កំហុសបរិញ្វជកនោះ ធ្វើឲ្យបែកអំពីព្រះរាជាថា បរិញ្វជកនេះជារាជសត្រូវ ហើយឲ្យសម្លាប់បរិញ្វជកនេះ ។ ពួកអាមាត្យនោះ នាំគ្នាចូលទៅគាល់ព្រះរាជា ហើយក្រាបទូលថា បពិត្រមហារាជ ឥឡូវនេះ ពោធិបរិញ្វជកប្រាថ្នានឹងធ្វើសេចក្តីវិនាសដល់ទ្រង់ កាលព្រះរាជាទ្រង់មិនជឿត្រាស់ថា ពោធិបរិញ្វជកនោះ ជាអ្នកមានសីល សម្បូរដោយប្រាជ្ញា នឹងមិនធ្វើកម្មបែបនោះឡើយ ក៏នាំគ្នាក្រាបទូលថា បពិត្រមហារាជ ប្រជានុរាស្ត្រក្នុងនគរទាំងអស់ ត្រូវពោធិបរិញ្វជកនោះ ធ្វើឲ្យនៅក្នុងកណ្តាប់ដៃរបស់ខ្លួនហើយ តែមិនអាចធ្វើពួកទូលព្រះបង្គំទាំង ៥ នេះបាននៅឡើយ បើទ្រង់មិនជឿពាក្យរបស់ទូលព្រះបង្គំសោត ក្នុងកាលដែលពោធិបរិញ្វជកនោះមកក្នុងទីនេះ ទ្រង់គប្បីទតមើលបរិស័ទរបស់គេចុះ ព្រះរាជាត្រាស់ថា សាធុ ដូច្នេះហើយ ប្រថាប់ឈរត្រង់សីហបញ្ជរ ទតបរិញ្វជកដែលកំពុងដើរមកនោះ ទ្រង់ឃើញបរិវារ ព្រោះទ្រង់ជ្រាបមិនបាន ទើបទ្រង់យល់ក្នុងពួកមនុស្សដែលមកប្តឹងថា ជាបរិវាររបស់ព្រះមហាសត្វនោះ ទ្រង់ជឿហើយត្រាស់ឲ្យពួកអាមាត្យនោះ ចូលមកគាល់ ហើយត្រាស់សួរថា ពួកអ្នកនឹងធ្វើដូចម្តេច ពួកអាមាត្យទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់បញ្ជាឲ្យចាប់បរិញ្វជកនោះចុះ ។ ព្រះរាជាត្រាស់ថា កាលយើងមិនទាន់ឃើញកំហុសធំ នឹងបញ្ជាឲ្យចាប់គេបានដូចម្តេច ។ ពួកអាមាត្យក្រាបទូលថា បើដូច្នោះ សូមទ្រង់ត្រាស់ឲ្យកាត់បន្ថយនូវការឧបដ្ឋាក ដែលធ្លាប់ធ្វើតាមប្រក្រតីដល់បរិញ្វជក

នោះបណ្តើរៗសិនចុះ បណ្ឌិតបរិព្វាជក ឃើញការកាត់បន្ថយនូវការទំនុកបម្រុង មិនប្រាប់ដល់បុគ្គលណា គន់គេចទៅឯង ។

ព្រះរាជាត្រាស់ថា សាធុ ហើយត្រាស់ឲ្យបន្ថយការទំនុកបម្រុងរបស់ព្រះមហាសត្វនោះបន្តិចម្តងៗ ដោយលំដាប់ ។ មុនដំបូង អ្នករៀបចំឲ្យព្រះមហាសត្វអង្គុយលើបល្ល័ង្កទទេ ។ លុះឃើញបល្ល័ង្កទទេ ក៏ដឹងថា ព្រះរាជាអស់សទ្ធាក្នុងអញហើយ កាលត្រឡប់ទៅកាន់ឧទ្យាន ក៏គិតដើម្បីនឹងចៀសចេញទៅក្នុងថ្ងៃនោះតែម្តង តែមិនចៀសចេញទៅ ដោយគិតថា អញត្រូវដឹងឲ្យច្បាស់ ហើយសឹមចៀសចេញទៅ ។ ស្អែកឡើង កាលព្រះមហាសត្វអង្គុយលើបល្ល័ង្កទទេ ភ្នាក់ងារកាន់យកភត្តាហារធម្មតា និងវត្ថុដទៃមកហើយ បានប្រគេនភត្តាហារដែលលាយចូលគ្នា ។ ក្នុងថ្ងៃទី ៣ ភ្នាក់ងារមិនឲ្យចូលទៅកាន់បន្ទប់ធំ ឲ្យអង្គុយត្រង់ជើងជណ្តើរប៉ុណ្ណោះ ហើយប្រគេនភត្តាដែលលាយគ្នា ។ ព្រះមហាសត្វនោះ កាន់យកភត្តាហារនោះ ទៅកាន់ឧទ្យានហើយបានធ្វើភត្តកិច្ច ។ ក្នុងថ្ងៃទី ៤ ភ្នាក់ងារឈរត្រង់ប្រាសាទជាន់ក្រោមហើយ បានប្រគេនភត្តដែលចម្អិនដោយចុងអង្ករ ។ ព្រះមហាសត្វក៏ទទួលភត្តនោះ ទៅកាន់ឧទ្យាន បានធ្វើភត្តកិច្ចហើយ ។ ព្រះរាជាត្រាស់សួរពួកអាមាត្យថា មហាពោធិបរិព្វាជក ទោះបីសក្ការៈកាត់បន្ថយ ក៏មិនព្រមចៀសចេញទៅ ពួកយើងធ្វើដូចម្តេចល្អ ពួកអាមាត្យក្រាបទូលដោយឧបាយថា បពិត្រព្រះសម្មតិទេព លោកប្រព្រឹត្តដើម្បីភត្តក៏មិនមែន តែលោកប្រព្រឹត្តដើម្បីស្វេតច្ឆត្រ បើលោកប្រព្រឹត្តដើម្បីភត្តពិត លោកគប្បីចៀសចេញទៅតាំងពីថ្ងៃដំបូងម៉្លេះ ។ ព្រះរាជា

ត្រាស់សួរថា ឥឡូវនេះ ពួកយើងធ្វើដូចម្តេចល្អ ពួកអាមាត្យក្រាបទូលថា បពិត្រមហារាជ ស្អែកនេះ សូមទ្រង់បញ្ជាឲ្យសម្លាប់គេចោលចុះ ។ ព្រះរាជាត្រាស់ថា សាធុ ហើយប្រគល់ដាវទុកក្នុងដៃរបស់អាមាត្យទាំង ៥ នោះ ហើយត្រាស់ថា ស្អែកនេះ ពួកលោកចូរមកឈរក្នុងរវាងទ្វារ លុះបរិព្វាជកនោះ ដើរមកចូរកាត់ក្បាល ហើយចិញ្ច្រាំឲ្យជាកំណាត់តូចធំ កុំឲ្យនរណាដឹងរឿងនេះ យកទៅចោលក្នុងរណ្តៅលាមក ផ្ទួតទឹកហើយគប្បីត្រឡប់មកចុះ ។ អាមាត្យទាំងនោះទទួលថា សាធុ ហើយណាត់គ្នាថា ស្អែកនេះ ពួកយើងនឹងធ្វើយ៉ាងនោះ ហើយនាំគ្នាទៅកាន់លំនៅរបស់ខ្លួន ។ វេលាល្ងាច ព្រះរាជាទ្រង់សោយភោជនស្រេចហើយ ទ្រង់ផ្ទំលើទីបន្ទំដែលប្រកបដោយសិរី ទ្រង់រឭកដល់គុណរបស់ព្រះមហាសត្វ ។ ក្នុងខណៈនោះឯង សេចក្តីសោកបានកើតឡើងហើយដល់ទ្រង់ ព្រះសេទោហូរចេញអំពីព្រះសរីរៈ ទ្រង់មិនបានទទួលសេចក្តីត្រេកអរក្នុងព្រះហឫទ័យ ទ្រង់រសាប់រសល់ បម្រះនទៀលទៅមកលើទីបន្ទំ ។ សម័យនោះ អគ្គមហេសីរបស់ព្រះអង្គផ្ទំជិតនោះ ព្រះរាជាក៏មិនព្រមធ្វើត្រឹមតែការចរចាជាមួយព្រះនាងឡើយ ។ លំដាប់នោះ ព្រះនាងទូលសួរព្រះរាជាថា បពិត្រមហារាជ ហេតុអ្វីហ្ន៎ ទើបទ្រង់មិនធ្វើហេតុ សូម្បីត្រឹមតែសន្ទនា ឬខ្ញុំម្ចាស់មានកំហុសអ្វី ព្រះរាជាត្រាស់ថា នែទេវី នាងមិនខុសអ្វីឡើយ តែបានឮថា ពោធិបរិព្វាជក បានក្លាយជាសត្រូវរបស់ពួកយើង ដូច្នោះ ទើបយើងឲ្យអាមាត្យទាំង ៥ រៀបចំសម្លាប់លោកក្នុងថ្ងៃស្អែកនេះ អាមាត្យទាំងនោះនឹងសម្លាប់លោក ចិញ្ច្រាំជាកំណាត់តូចធំ ហើយបោះចោល

ក្នុងគំនរលាមក ឯពោធិបរិញ្ជកនោះ បានសម្តែងធម៌ជាច្រើនដល់ពួកយើង អស់កាល ១២ ឆ្នាំ សូម្បីទោសបន្តិចបន្តួចរបស់លោក យើងមិនធ្លាប់ឃើញសោះ គ្រាន់តែបានឮពាក្យពីអ្នកដទៃ យើងក៏ឲ្យសម្លាប់លោកចោល ព្រោះហេតុនោះ ទើបយើងកើតទុក្ខ ។

គ្រានោះ ព្រះនាងក៏លួងលោមព្រះហឫទ័យព្រះរាជាថា បពិត្រព្រះសម្មតិទេព បើពោធិបរិញ្ជកនោះ ក្លាយជាសត្រូវពិត កាលទ្រង់ត្រាស់ឲ្យសម្លាប់ចោល ហេតុអ្វី ទើបទ្រង់សោក ឈ្មោះថា សត្រូវទោះជាកូន ក៏ត្រូវសម្លាប់ដើម្បីសួស្តីដល់ខ្លួន ទ្រង់កុំសោយសោកថ្វីឡើយ ។ ព្រោះពាក្យរបស់ព្រះនាង ព្រះរាជាក៏ស្រាកស្រាន្តព្រះហឫទ័យធូរលក់ទៅ ។ ក្នុងខណៈនោះ ឆ្កែក្រហមឈ្មោះថា កោលេយ្យកៈបានស្តាប់ពាក្យនោះហើយ គិតថា ស្អែកនេះ អញគួរជួយជីវិតពោធិបរិញ្ជកនោះដោយកម្លាំងរបស់ខ្លួន ដូច្នេះ ព្រឹកឡើងក៏រត់ចុះពីប្រាសាទអំពីព្រលឹម មកកាន់ទ្វារធំ ដេកយកក្បាលដាក់លើធរណីទ្វារ ទន្ទឹងមើលផ្លូវដែលព្រះមហាសត្វដើរមក ។ ឯអាមាត្យទាំងនោះ កាន់ដាវដើរមកឈរពួន ត្រង់ជ្រុងខាងទ្វារអំពីព្រលឹម ។ ព្រះពោធិសត្វប៉ាន់ស្មានកាលវេលាហើយ ក៏ចេញអំពីឧទ្យានមកកាន់ទ្វារព្រះរាជវាំង ។

សម័យនោះ ឆ្កែកោលេយ្យកៈគ្រាន់តែឃើញព្រះពោធិសត្វ ទើបបញ្ចេញចង្កូមទាំង ៤ ស្រែកដោយសំឡេងខ្លាំងថា បពិត្រលោកម្ចាស់ លោកមិនបានភិក្ខាក្នុងទីដទៃ ក្នុងផ្ទៃជម្ពូទ្វីបទេឬ ស្តេចផែនដីរបស់ពួកយើង ឲ្យអាមាត្យ ៥ នាក់ មានដាវនៅក្នុងដៃ ពួនត្រង់ជ្រុងខាងទ្វារដើម្បីសម្លាប់លោក លោកកុំ

មកទទួលការស្ងាប់ទុកត្រង់ថ្ងាសឡើយ សូមត្រឡប់ទៅដោយរហ័សចុះ ។ ព្រះមហាសត្វដឹងសេចក្តីនោះបាន ព្រោះខ្លួនអាចដឹងក្នុងសំឡេងរបស់សត្វគ្រប់ប្រភេទ ទើបត្រឡប់អំពីទីនោះ ទៅកាន់ឧទ្យាន កាន់យកបរិក្ខារត្រៀមខ្លួននឹងចៀសចេញទៅ ។ ឯព្រះរាជាប្រថាប់ឈរត្រង់សីហបញ្ជរទតឃើញព្រះមហាសត្វ ក្នុងកាលដើរមកផង ក្នុងកាលត្រឡប់ទៅផង ទើបទ្រង់ព្រះតម្រិះថា បើពោធិបរិព្វាជកនេះ ជាសត្រូវរបស់អញសោត កាលត្រឡប់ទៅកាន់ឧទ្យាន ក៏នឹងប្រជុំពួកពល ត្រៀមខ្លួនធ្វើកិច្ចការ បើមិនមែនទេ គង់កាន់យកបរិក្ខាររបស់ខ្លួន ហើយត្រៀមចៀសចេញទៅ ដូច្នេះ អញនឹងដឹងកិរិយារបស់ពោធិបរិព្វាជកនោះ ដូច្នេះ ទើបយាងទៅកាន់ឧទ្យាន ទតឃើញព្រះមហាសត្វចេញអំពីបណ្ណសាលា ដល់ខាងចុងទីចង្រ្កម ដោយគិតថា អញនឹងកាន់យកបរិក្ខាររបស់ខ្លួន ហើយនឹងទៅ ទើបនមស្ការ ប្រថាប់ឈរក្នុងទីសមគួរនាចំណែកម្ខាង ត្រាស់គាថា ដូច្នេះថា

បពិត្រព្រាហ្មណ៍ ហេតុអ្វី ក៏លោកប្រញាប់ប្រញាល់កាន់យក
ឈើច្រត់ផង ស្បែកខ្លាឃ្មុំផង ឆត្រផង ស្បែកជើងផង តម្ពក់
ផង បាត្រផង សង្ឃាដិផង លោកប្រាថ្នា ( ដើម្បីទៅ ) កាន់
ទិសណាហ្ន៎ ដូច្នេះ ។

គាថានោះមានសេចក្តីថា ព្រះរាជាត្រាស់សួរថា បពិត្រលោកម្ចាស់ ក្នុងកាលមុន លោកមកកាន់ព្រះរាជនិវេសន៍របស់ខ្ញុំ មិនបានកាន់យកឈើច្រត់ជាដើមមកឡើយ តែក្នុងថ្ងៃនេះ ព្រោះហេតុអ្វី ទើបលោករលះរលាំងកាន់

យកបរិក្ខារទាំងអស់នេះ គឺឈើប្រត់ ស្បែកខ្លា ឆត្រ ស្បែកជើង ថ្នាំងដី ផង់យាម តម្កក់សម្រាប់បេះផ្លែឈើ បាត្រដី និងសំពត់សង្ឃាដិទៅវិញ លោកប្រាថ្នាទៅកាន់ទិសណាហ្ន៎ លោកប្រាថ្នាទៅកាន់ទីណាហ្ន៎ ។

ព្រះមហាសត្វបានស្តាប់ដូច្នោះហើយ គិតថា ព្រះរាជាអង្គនេះយល់ថា ឥសីមិនដឹងដល់កម្មដែលខ្លួនបានធ្វើ អញនឹងឲ្យទ្រង់ដឹង ទើបពោលគាថា ២ ថា

អាត្មាភាព នៅក្នុងសំណាក់ព្រះអង្គអស់ ១២ ឆ្នាំនេះហើយ
មិនដែលស្គាល់សំឡេងដែលខ្ពៃក្រហមព្រុសម្តងឡើយ ។ ខ្ពៃ
នោះ បញ្ចេញចង្កូមសស្វាច ព្រុសដូចជាសាហាវ ព្រោះឮ
( ព្រះបន្ទូល ) របស់ព្រះអង្គព្រមទាំងអគ្គមហេសី ដែល
មានជំនឿទៅប្រាសហើយ ក្នុងរវាងអាត្មាភាព ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អភិក្កូជិតំ** សេចក្តីថា ខ្ញុំមិនធ្លាប់បានឮសំឡេងដែលខ្ពៃរបស់ទ្រង់ ស្រែកដោយសំឡេងខ្លាំងយ៉ាងនេះឡើយ ។ បទថា **ធិត្តោរ** បានដល់ ហាក់ដូចមិនធ្លាប់ស្គាល់គ្នា ។ បទថា **សភរិយស្ស** សេចក្តីថា ព្រោះខ្ពៃបានឮពាក្យរបស់មហាបពិត្រនិងព្រះជាយា ត្រាស់ឲ្យអាមាត្យ ៥ នាក់ ត្រៀមខ្លួនដើម្បីសម្លាប់អាត្មា ទើបបញ្ចេញសំឡេងព្រុសយ៉ាងខ្លាំង ហាក់ដូចមិនស្គាល់គ្នាថា ភិក្ខុក្នុងទីដទៃមិនមានឬ ព្រះរាជាត្រាស់ឲ្យអាមាត្យសម្លាប់លោក លោកកុំមកទីនេះឡើយ ។ បទថា **វីតសទ្ធស្ស មំ បតិ** សេចក្តីថា ខ្ពៃនោះបានស្តាប់ពាក្យរបស់មហាបពិត្រ ដែលអស់សទ្ធាក្នុងអាត្មា ទើបពោលយ៉ាងនោះ ។

គ្រានោះ ព្រះរាជាទ្រង់ព្រមទទួលកំហុស កាលទ្រង់ឲ្យព្រះមហាសត្វអភ័យទោស ទើបពោលគាថាទី ៤ ថា

បពិត្រព្រាហ្មណ៍ ទោសនុ៎ះខ្ញុំបានធ្វើហើយ ដូចជាលោកពោល
ខ្ញុំនោះជ្រះថ្លាលើសដើម បពិត្រព្រាហ្មណ៍ សូមលោកគង់
នៅ ចូរកុំទៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភិយ្យោ** សេចក្តីថា ខ្ញុំបានបញ្ញាយ៉ាងនេះដោយពិត នេះជាកំហុសរបស់ខ្ញុំ ខ្ញុំជ្រះថ្លាយ៉ាងក្រៃលែងក្នុងកាលឥឡូវនេះ សូមលោកនៅទីនេះដូចមុនចុះ កុំទៅទីដទៃឡើយ ។

មហាសត្វបានស្តាប់ពាក្យនោះហើយ ក៏ក្រាបទូលថា សូមថ្វាយព្រះពរ ធម្មតា បណ្ឌិតទាំងឡាយ រមែងមិននៅរួមជាមួយសត្រូវ ដែលធ្វើការងារដោយមិនពិចារណាឲ្យគ្រប់ជ្រុងជ្រោយ ដូចទ្រង់នេះឡើយ កាលប្រកាសអនាចារដល់ព្រះរាជានោះ ទើបពោលជាគាថានេះថា

កាលពីដើម បាយសសុទ្ធ តពីនោះមកបាយពព្រុះ ឥឡូវនេះ
បាយក្រហមសុទ្ធ ( កាលនេះ ) ជាកាលគួរអាត្មាភាពចៀស
ចេញទៅហើយ ។

ពីដើមអាសនៈរបស់ ( អាត្មាភាព ) នៅខាងក្នុង ( ប្រា
សាទ ) តមកនៅកណ្តាល ( ក្បាលជណ្តើរ ) តពីនោះ
មកទៀត នៅខាងក្រៅ អាត្មាភាពនឹងចេញទៅខ្លួនឯង មុន
ការបណ្តេញ ។ បុគ្គលមិនត្រូវសេពគប់បុគ្គលប្រាសចាកសទ្ធា

ដែលទុកដូចអណ្តូងមិនមានទឹក ប្រសិនបើបុគ្គលកកាយអណ្តូងនោះ ( ទឹកដែលចេញអំពីអណ្តូងនោះ ) មុខជាប្រកបដោយក្លិនកក់មិនខាន ។ បុគ្គលត្រូវសេពគប់ចំពោះតែជនដែលជ្រះថ្លា ត្រូវវៀរចាកជនដែលមិនជ្រះថ្លា ត្រូវចូលទៅអង្គុយជិតជនដែលជ្រះថ្លាដូចជាបុគ្គលត្រូវការដោយទឹក ( ចូលទៅរក ) អន្លង់ទឹក ដូច្នោះ ។ បុគ្គលគួរគប់រកបុរស ដែលគប់រក ( ខ្លួន ) មិនគួរគប់រកបុរសដែលមិនគប់រក ( ខ្លួន ) ទេ បុគ្គលណា មិនគប់រកបុគ្គលដែលគប់រក ( ខ្លួន ) បុគ្គលនោះ ឈ្មោះថា កាន់ធម៌របស់អសប្បុរស ។ បុគ្គលណាមិនគប់រកបុគ្គលដែលគប់រក ( ខ្លួន ) មិនសេពគប់ចំពោះបុគ្គល ដែលសេពគប់ ( នឹងខ្លួន ) បុគ្គលនោះឯង ជាមនុស្សអាក្រក់ផុត ដូចជាម្រឹគ ដែលអាស្រ័យនៅលើមែកឈើ ( ស្វា ) ។ មិត្តទាំងឡាយលាកចិត្តពីគ្នា ដោយហេតុនេះ គឺដោយនៅប្រឡូកប្រឡំគ្នាញឹកពេក ១ ដោយការមិនជួបគ្នាសោះ ១ ដោយការសូមក្នុងកាលមិនគួរ ១ ព្រោះហេតុនោះ បុគ្គលមិនត្រូវទៅញឹកៗផង មិនត្រូវទៅ ( ឃ្លាតគ្នា ) យូរពេកផង គប្បីសូមនូវរបស់ដែលគួរសូម តាមកាលផង យ៉ាងនេះទើបមិត្តទាំងឡាយមិនលាកចិត្តពីគ្នា ។ បុគ្គលធ្លាប់ជាទីស្រឡាញ់ ទៅជាមិនជាទីស្រឡាញ់វិញ ព្រោះ

នៅរួមគ្នាយូរពេក អាត្មាភាព សូមលាព្រះអង្គទៅមុនយើង
ទាំងឡាយនោះ មិនជាទីស្រឡាញ់គ្នាទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សព្វសោ** សេចក្ដីថា សូមថ្វាយព្រះពរ ចំពោះក្នុងថ្ងៃមុនៗ បាយរបស់អាត្មាក្នុងនិវេសន៍របស់ទ្រង់ មានពណ៌សសុទ្ធ ទ្រង់សោយបាយយ៉ាងណា ក៏ព្រះរាជទានបាយយ៉ាងនោះដល់អាត្មា ។ បទថា **តតោ** សេចក្ដីថា ខាងក្រោយអំពីនោះ គឺក្នុងកាលដែលទ្រង់លាកចិត្តក្នុងអាត្មា ព្រោះទ្រង់ជឿពាក្យបុរសដែលញុះញង់ បាយក៏មានរបស់ដទៃលាយឡំចូលគ្នា ។ បទថា **ឥទានិ** គឺក្នុងឥឡូវនេះ បាយក៏ក្លាយជាបាយក្រហម ។ បទថា **កាលោ** បានដល់ ពេលនេះជាពេលដែលអាត្មាត្រូវចេញអំពីសម្នាក់របស់ព្រះអង្គ ដែលជាបុគ្គលល្ងង់ខ្លៅ ។ បទថា **អព្ភន្តរំ** សេចក្ដីថា កាលដើមឡើយ អាសនៈរបស់អាត្មាមាននៅខាងក្នុង គឺទ្រង់រៀបចំនិមន្តឲ្យអាត្មាអង្គុយលើរាជបល្ល័ង្ក ដែលមានផ្ទៃធំទូលាយប្រដាប់ហើយ មានស្វេតច្ឆត្រលើកឡើងហើយ ។ បទថា **មជ្ឈេ** គឺត្រង់ក្បាលជណ្ដើរ ។ បទថា **ពុរានិទ្ធមនា ហោតិ** សេចក្ដីថា ចាប់កអូសចេញទៅ ។ បទថា **អនុទកោ** សេចក្ដីថា បើបុរសទៅដល់អូរដែលមិនមានទឹក កាលមិនឃើញទឹក ទើបបាកក់ឡើង ទោះធ្វើយ៉ាងនោះ អូរនោះក៏គង់មានតែក្លិនភក់របស់ទឹក បរិភោគមិនបាន ព្រោះមិនជាទីគាប់ចិត្ត យ៉ាងណា សូម្បីបច្ច័យដែលបុគ្គលចូលទៅរកបុគ្គលដែលប្រាសចាកសទ្ធា ហើយបានមក ទើបជារបស់តិចនិងសៅហ្មង មិនជាទីគាប់ចិត្ត មិនសមគួរនឹងបរិភោគ ។ បទថា **បសន្នំ** គឺមានសទ្ធាតាំង

មាំហើយ ។ បទថា **រហាធំ** គឺអន្លង់ទឹកដែលជ្រៅ ។ បទថា **ភជន្តំ** សេចក្ដីថា បុគ្គលគួរគប់រកបុគ្គលដែលសេពគប់ខ្លួនប៉ុណ្ណោះ ។ បទថា **អភជន្តំ** បានដល់ បុគ្គលដែលជាសត្រូវ ។ បទថា **ន ភជ្ជយេ** បានដល់ មិនគប្បីគប់រក ។ បទថា **ន ភជ្ជតិ** សេចក្ដីថា បុរសណា មិនគប់រកបុគ្គលដែលគប់រកខ្លួន ដែលមានចិត្តគិតនូវប្រយោជន៍ បុរសនោះឈ្មោះថា មានធម៌របស់អសប្បុរស ។ បទថា **មនុស្សធាបិដ្ឋោ** បានដល់ មនុស្សលាមក មនុស្សអាក្រក់ គឺមនុស្សជាន់ទាប ។ បទថា **សាខស្សិតោ** គឺស្វា ។ បទថា **អច្ចាភិក្ខណសំសគ្គា** គឺដោយការប្រឡូកប្រឡំគ្នារឿយៗច្រើនពេក ។ បទថា **អកាលេ** សេចក្ដីថា មិត្តទាំងឡាយ ឈ្មោះថា រមែងនឿយណាយនឹងគ្នា ដោយការសូមរបស់ជាទីស្រឡាញ់ ក្នុងកាលដែលមិនគួរ ព្រោះការនៅរួមគ្នាយូរពេក ទោះបីទ្រង់ក៏គង់អស់មេត្តាក្នុងអាត្មា ។ បទថា **តស្មា** សេចក្ដីថា ព្រោះមិត្តទាំងឡាយរមែងបែកគ្នា ដោយការប្រឡូកប្រឡំគ្នាពេក និងដោយការមិនដែលទៅមករកគ្នាពេក ។ ពាក្យថា **ចិរាចិរំ** សេចក្ដីថា មិនបណ្ដោយឲ្យពេលកន្លងទៅយូរហើយទើបទៅរកគ្នា ។ បទថា **យាចំ** សេចក្ដីថា មិនគួរសូមរបស់ដែលគួរសូម ក្នុងកាលដែលមិនគួរ ។ បទថា **ន ជីររេ** សេចក្ដីថា មិត្តទាំងឡាយរមែងមិនបែកគ្នាដោយអាការយ៉ាងនេះ ។ បទថា **បុរា តេ ហោម** សេចក្ដីថា អាត្មាមិនទាន់មិនជាទីស្រឡាញ់របស់ទ្រង់ដរាបណា អាត្មាពោលហើយនឹងទៅដរាបនោះ ។

ព្រះរាជាត្រាស់ថា

បើលោកម្ចាស់ មិនទទួលដឹងនូវអញ្ជលីរបស់យើងទាំងឡាយ
ដែលអង្វរយ៉ាងនេះ មិនធ្វើតាមពាក្យយើងដែលជាសត្វបម្រើ
ទេ យើងខ្ញុំសូមអង្វរលោកម្ចាស់យ៉ាងនេះ សូមលោកម្ចាស់
ធ្វើនូវសេចក្តីប្រាថ្នា ( ដើម្បីមកក្នុងទីនេះ ) ម្តងៗ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **នាវពុជ្ឈសិ** សេចក្តីថា បពិត្រលោកម្ចាស់ បើលោកម្ចាស់មិនព្រមទទួល គឺមិនទទួលអញ្ជលី ដែលខ្ញុំអង្វរហើយយ៉ាងនេះ ។ បទថា **បរិយាយំ** សេចក្តីថា ព្រះរាជាត្រាស់អង្វរថា សូមលោកម្ចាស់រកឱកាសទំនេរម្តងម្កាលដើម្បីមកក្នុងទីនេះ ។

ព្រះពោធិសត្វទូលថា

បពិត្រមហារាជ ទ្រង់មានសេចក្តីចម្រើនក្នុងដែន កាលបើ
យើងទាំងឡាយនៅ ( ផ្សេងគ្នា ) យ៉ាងនេះ អន្តរាយនឹងមិន
មានដល់ព្រះអង្គផង ដល់អាត្មាភាពផង សូមយើងទាំងឡាយ
ជួបគ្នា ក្នុងកាលកន្លងទៅមួយថ្ងៃមួយយប់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឯវញ្ចេ នោ** សេចក្តីថា ព្រះពោធិសត្វសម្តែង ថា មហាបពិត្រ បើអន្តរាយមិនមានដល់យើងទាំង ២ ដែលបែកគ្នាយ៉ាងនេះ ជីវិតរបស់ទ្រង់ឬរបស់អាត្មានឹងបានយឺនយូរ ។ បទថា **បស្សេម** សេចក្តីថា ពួកយើងគប្បីជួបគ្នាដោយពិត ។

ព្រះមហាសត្វ ពោលយ៉ាងនេះស្រេចហើយ សម្តែងធម៌ដល់ព្រះរាជា ហើយទូលថា បពិត្រមហារាជ សូមទ្រង់កុំប្រមាទឡើយ ដូច្នេះហើយចេញ

អំពីឧទ្យាន ត្រាច់ភិក្ខាចារទៅក្នុងទីដែលមានចំណែកស្មើគ្នាមួយ ចេញអំពីនគរពារាណសីហើយ ដល់ហិមវន្តប្បទេសដោយលំដាប់ ស្នាក់នៅអស់កាលបន្តិចបន្តួច ហើយត្រឡប់មកនៅក្នុងព្រៃ អាស្រ័យស្រុកបច្ចន្តគ្រាមមួយ ។ តាំងអំពីកាលដែលព្រះមហាសត្វទៅហើយ ពួកអាមាត្យទាំងនោះ ក៏នាំគ្នាអង្គុយក្នុងរោងវិនិច្ឆ័យទៀត ធ្វើនូវការបៀតបៀន នាំគ្នាគិតថា បើពោធិបរិព្វាជកត្រឡប់មកទៀត ជីវិតរបស់ពួកយើងគង់មិនមានពិត ពួកយើងធ្វើហេតុដែលមិនឲ្យបរិព្វាជកនោះត្រឡប់មកវិញ ដូចម្ដេចល្អហ្ន៎ ។ លំដាប់នោះ ជនទាំងនោះក៏ប្រឹក្សាគ្នាថា ធម្មតាសត្វទាំងឡាយ រមែងមិនអាចលះទីកន្លែងដែលខ្លួនជាប់ជំពាក់បាន ទីកន្លែងដែលពោធិបរិព្វាជកនោះជាប់ជំពាក់ក្នុងទីនេះ គឺអ្វីហ្ន៎ បន្ទាប់អំពីនោះ ពួកអាមាត្យក៏ដឹងបានថា គង់ជាអគ្គមហេសីរបស់ព្រះរាជាដោយពិត ទើបប្រឹក្សាគ្នាថា កាលដែលពោធិបរិព្វាជកនោះគប្បីមក ព្រោះអាស្រ័យអគ្គមហេសី នេះជាឋានៈដែលនឹងមានបាន ពួកយើងគប្បីប្រញាប់សម្លាប់អគ្គមហេសីឲ្យបានឆាប់ ។ ទើបពួកអាមាត្យទាំងនោះ នាំគ្នាក្រាបទូលសេចក្ដីនេះដល់ព្រះរាជាថា ច្រើនថ្ងៃមកនេះ ពួកទូលបង្គំបានដឹងរឿងមួយ ។ ព្រះរាជាត្រាស់សួរថា តើរឿងអ្វី ពួកអាមាត្យក្រាបទូលថា បានឮថា មហាពោធិបរិព្វាជកនិងព្រះរាជទេវី បញ្ជូនដំណឹងឆ្លើយឆ្លងជានិច្ច ។ ព្រះរាជាត្រាស់សួរថា រាជសាសន៍នោះ ឲ្យធ្វើអ្វី ពួកអាមាត្យក្រាបទូលថា មហាពោធិបរិព្វាជកនោះ បញ្ជូនដំណឹងមកដល់ព្រះរាជទេវីថា ព្រះនាងអាចផ្ដាច់ព្រះជន្មព្រះរាជាដោយកម្លាំងរបស់ខ្លួន ហើយលើកស្វេតច្ឆត្រឲ្យដល់ខ្ញុំបានដែរឬទេ

ចំណែកព្រះទេវីនោះ ក៏បញ្ជូនដំណឹងតបទៅមហាពោធិបរិព្វាជកនោះថា ការផ្តាច់ព្រះជន្មព្រះរាជាជាការៈខ្ញុំ សូមមហាពោធិបរិព្វាជកប្រញាប់មកដោយរហ័សចុះ កាលពួកអាមាត្យទាំងនោះក្រាបទូលរឿយៗ ព្រះរាជាទ្រង់ក៏ជឿ ទើបត្រាស់សួរថា ឥឡូវនេះ យើងគប្បីធ្វើដូចម្តេចល្អ ពួកអាមាត្យក៏ក្រាបទូលថា គួរបញ្ជាឲ្យសម្លាប់ព្រះទេវី ដូច្នេះ ព្រះរាជាមិនទាន់ពិចារណាក៏ត្រាស់ថា បើដូច្នោះ ពួកលោក ចូរសម្លាប់នាងចុះ ហើយចិញ្ច្រាំឲ្យជាកំណាត់តូចធំ យកទៅចោលក្នុងរណ្តៅលាមក ។ ពួកអាមាត្យទាំងនោះធ្វើតាមព្រះរាជបញ្ជាហើយ ។ ភាពដែលព្រះទេវីត្រូវផ្តាច់ព្រះជន្មបានល្បីទៅពេញនគរទាំងមូល ។

កាលនោះ ព្រះរាជឱរស ៤ អង្គរបស់ព្រះរាជទេវីនោះ ដឹងថា ព្រះបិតាមានបញ្ជាឲ្យផ្តាច់ព្រះជន្មព្រះមាតាដែលមិនមានកំហុស ដូច្នេះ ទើបបានជាសត្រូវចំពោះព្រះរាជា ព្រះរាជាជួបនូវភ័យយ៉ាងធំ ។ មហាសត្វបានជ្រាបរឿងនោះ ដោយពួតៗមក ទើបត្រិះរិះថា វៀរអាត្មាអញហើយ អ្នកដទៃឈ្មោះថា អាចឲ្យព្រះរាជកុមារទាំងនេះយល់ព្រមឲ្យព្រះរាជបិតាអត់ទោសឲ្យមិនមានឡើយ អញនឹងជួយជីវិតព្រះរាជានិងដោះព្រះរាជកុមារ ឲ្យផុតបាកបាប ។ ស្អែកឡើង ក៏ចូលទៅកាន់បច្ចន្តគ្រាម ឆាន់សាច់ស្វាដែលពួកមនុស្សនាំមកប្រគេន ហើយសុំស្បែកស្វានោះ នាំយកមកហាលឲ្យស្ងួត ទុកត្រង់អាស្រម ធ្វើឲ្យអស់ក្លិនហើយ ស្លៀកខ្លះ ដណ្តប់ខ្លះ ពាក់ត្រង់ស្មាខ្លះ សួរថា ការដែលព្រះមហាសត្វធ្វើដូច្នោះ ព្រោះហេតុអ្វី ឆ្លើយថា ការដែលធ្វើដូច្នោះព្រោះបំណងនឹង ឆ្លើយជាមួយពួកមនុស្សថា ពានរនេះ មានឧបការៈច្រើន

ដល់ខ្ញុំ ។ ព្រះមហាសត្វកាន់យកស្បែកស្វានោះ ចូលទៅកាន់នគរពារាណសី ដោយលំដាប់ ចូលទៅរកព្រះរាជកុមារទាំងឡាយ ពោលដាស់តឿនថា ឈ្មោះជាកម្ម គឺការសម្លាប់បិតា ជាកម្មមានទោសខ្លាំងក្លា ព្រះរាជបុត្តទាំងឡាយមិនគួរធ្វើកម្មនោះឡើយ ធម្មតាសត្វដែលមិនចាស់ មិនស្លាប់មិនមាន ទូលព្រះបង្គំមកទីនេះដោយបំណងថានឹងធ្វើឲ្យទ្រង់មានសាមគ្គីដល់គ្នានឹងគ្នា កាលទូលព្រះបង្គំបញ្ជូនសាសន៍ទៅសូមទ្រង់ទាំងឡាយនាំគ្នាមក លុះទូន្មានព្រះរាជកុមារស្រេចហើយ ទើបចូលទៅកាន់ព្រះរាជឧទ្យានខាងក្នុងនគរ ក្រាលស្បែកពានរហើយ អង្គុយលើផ្ទាំងថ្ម ។ ក្នុងខណៈនោះ អ្នកយាមឧទ្យានឃើញ ក៏ប្រញាប់ទៅក្រាបទូលដល់ព្រះរាជា ព្រះរាជាទ្រង់ស្ដាប់ដំណឹងនោះហើយ ក៏ទ្រង់កើតសោមនស្ស ទើបនាំអាមាត្យទាំង ៥ ទៅក្នុងទីនោះ ទ្រង់ថ្វាយបង្គំព្រះមហាសត្វ ហើយប្រថាប់គង់ ប្រារព្ធធ្វើបដិសណ្ឋារៈ ។ ឯព្រះមហាសត្វមិនបានរាក់ទាក់ជាមួយព្រះរាជា អង្អែលស្បែកពានរធ្វើព្រងើយ លំដាប់នោះព្រះរាជាក៏ត្រាស់នឹងព្រះពោធិសត្វនោះយ៉ាងនេះថា បពិត្រលោកម្ចាស់ លោកមិនព្រមនិយាយជាមួយខ្ញុំ រវល់តែអង្អែលស្បែកស្វា ស្បែកស្វារបស់លោកមានឧបការៈជាងខ្ញុំឬ ។ ព្រះមហាសត្វក្រាបទូលថា មហាបពិត្រ ដូច្នោះឯងពានរនេះមានឧបការៈច្រើនដល់ទូលព្រះបង្គំ ទូលព្រះបង្គំអង្គុយលើខ្នងរបស់វាត្រាច់ទៅ ពានរនេះនាំក្អមទឹកមកឲ្យទូលព្រះបង្គំ បោសទីលំនៅឲ្យដល់ទូលព្រះបង្គំ បានធ្វើអភិសមាចារិកវត្ត បដិបត្តិដល់ទូលព្រះបង្គំ តែទូលព្រះបង្គំបែរជាស៊ីសាច់របស់វា យកស្បែកហាលឲ្យស្ងួត ធ្វើជាកម្រាលអង្គុយខ្វះ

ក្រោលដេកខ្វះ ព្រោះថាខ្លួនមានចិត្តទុព្វល ពានរនេះ មានឧបការៈច្រើន ដល់ទូលព្រះបង្គំយ៉ាងនេះ ។ ព្រះមហាសត្វលើកស្បែកពានរនិងពានរឡើង ពោលជាវោហារដើម្បីទម្លាយវាទៈរបស់អាមាត្យទាំងនោះ អាស្រ័យបរិយាយ នោះៗ ទើបពោលពាក្យនេះ ដោយប្រការដូច្នេះ ។ ពិតហើយ មហាសត្វនោះ ពោលថា ខ្ញុំអង្គុយលើខ្នងស្វាត្រាច់ទៅ ព្រោះធ្លាប់ស្លៀកដណ្តប់ស្បែករបស់ វា លោកពោលថា ស្វានាំក្អមទឹកមកឲ្យ ព្រោះលោកយកស្បែករបស់ស្វា ពាក់លើស្វា ហើយលីក្អមទឹកមក ។ លោកពោលថា ស្វាបោសទីលំនៅឲ្យ ព្រោះលោកធ្លាប់យកស្បែកនោះ បោសទីកន្លែង ។ លោកពោលថា ស្វា ធ្វើវត្តបដិបត្តិដល់ខ្ញុំ ព្រោះខ្នងពាល់ត្រូវស្បែកនោះក្នុងពេលដេក និងយក ជើងជាន់ក្នុងពេលដើរជាន់ ។ លោកពោលថា តែខ្ញុំបែរជាស៊ីសាច់របស់ស្វា នេះ ព្រោះខ្លួនមានចិត្តទុព្វល ព្រោះលោកបានស៊ីសាច់របស់ស្វាមកហើយ ក្នុងកាលឃ្លាន ។

ពួកអាមាត្យទាំងនោះ បានស្តាប់ពាក្យនោះហើយ សម្គាល់ថា ព្រះពោធិ សត្វធ្វើបាណាតិបាត ទើបនាំគ្នាទះដៃចំអកថា មើលអ្នកដ៏ចម្រើន ពួកលោក ចូរមើលកម្មរបស់បព្វជិតចុះ បានឮហើយមែនទេថា បព្វជិតនេះសម្លាប់ស្វា បរិភោគសាច់ ហើយកាន់យកស្បែកត្រាច់ទៅ ។ ព្រះមហាសត្វឃើញ អាមាត្យទាំងនោះធ្វើដូច្នោះ ក៏គិតថា ពួកអាមាត្យទាំងនេះ មិនដឹងភាពដែល អញយកស្បែកស្វាមក ដើម្បីទម្លាយវាទៈរបស់ខ្លួន អញនឹងឲ្យជនទាំងនេះ ដឹងខ្វះ មុនដំបូងក៏ហៅអាមាត្យដែលជាអហេតុកវាទីមកហើយសួរថា អាវុសោ

អ្នកសើចចំអកខ្ញុំ ព្រោះហេតុអ្វី អាមាត្យនោះឆ្លើយថា ព្រោះលោកធ្វើកម្ម គឺការទ្រុស្តចំពោះមិត្ត ហើយធ្វើបាណាតិបាតទៀតផង ។

លំដាប់នោះ ព្រះមហាសត្វគិតថា បុគ្គលណាជឿអាមាត្យទាំងនោះ ដោយគតិនិងដោយទិដ្ឋិ ហើយធ្វើតាមយ៉ាងនោះនឹងមានអ្វីដែលគប្បីពោល បុគ្គលនោះធ្វើនូវអំពើអាក្រក់ ដូច្នេះ កាលទម្លាយវាទៈរបស់អហេតុកវាទីនៃអាមាត្យនោះ ទើបពោលគាថាទាំងនេះថា

> បើពាក្យ ( របស់អ្នកថា ) សត្វប្រព្រឹត្តទៅតាមសង្គតិ ( នៃអភិជាតិទាំង ៦ ) នឹងសភាវ សត្វធ្វើនូវអំពើដែលមិនគួរធ្វើ ( បាប ) ឬអំពើដែលគួរធ្វើ ( បុណ្យ ) តើនរណាក្នុងលោកនេះប្រឡាក់ដោយបាប ព្រោះអំពើដែលធ្វើដោយការមិនចង់ ។ បើ ( សេចក្តីនៃភាសិតរបស់អ្នក គឺអហេតុកវាទ ) នោះ ជាអត្ថផង ជាធម៌ផង ល្អមិនអាក្រក់ទេ បើពាក្យរបស់អ្នកដ៏ចម្រើនជាពាក្យពិត ពានរក៏ឈ្មោះថា អាត្មាសម្លាប់ត្រូវហើយ ។ បើអ្នកដឹងនូវកំហុសនៃវាទៈរបស់ខ្លួន អ្នកមិនត្រូវតិះដៀលអាត្មាទេ ដ្បិតវាទរបស់អ្នកដ៏ចម្រើនបែបនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧធីរណា** បានដល់ វាទៈ ។ បទថា **សង្គត្យា** បានដល់ ផ្លូវទៅដែលល្អ គឺដោយការចូលដល់អភិជាតិនោះៗ ក្នុងបណ្តាអភិជាតិទាំង ៦ ។ បទថា **ភាវាយមនុវត្តតិ** សេចក្តីថា រមែងប្រព្រឹត្តទៅ

តាមការៈជាសម្បទាន ប្រើក្នុងអត្ថនៃករណៈ ។ បទថា **អកាមា** គឺមិនមាន សេចក្តីប្រាថ្នា មិនមានការចង់បាន ។ បទថា **អករណីយំ វា** បានដល់ បាប ជារបស់មិនគួរធ្វើ ។ បទថា **ករណីយំ វា** បានដល់ កុសលជារបស់ដែល គួរធ្វើ ។ បទថា **កុព្វតិ** បានដល់ រមែងធ្វើ ។ ពាក្យថា **កោ្វធ** កាត់បទជា **កោ ឥធ** ប្រែថា អ្នកណាក្នុងលោកនេះ ។ មានពាក្យលោកពោលអធិប្បាយ ទុកថា លោកជាអហេតុកវាទី ជាអ្នកមានទិដ្ឋិជាដើមថា មិនមានហេតុ មិន មានបច្ច័យដើម្បីការសៅហ្មងនៃសត្វទាំងឡាយ ដូច្នេះ ទើបពោលថា លោក នេះប្រែប្រួលទៅ គឺប្រែប្រួលទៅតាមគតិដែលល្អនិងតាមសភាវៈ សោយ សុខនិងទុក្ខក្នុងទីនោះៗ និងសត្វដែលមិនមានសេចក្តីប្រាថ្នា រមែងធ្វើបាបខ្លះ បុណ្យខ្លះ ដ្បិតថា ពាក្យរបស់អ្នកនេះ បើដូច្នោះ កាលបាបដែលសត្វធ្វើដោយ មិនមានការប្រាថ្នាមាន សត្វណាមួយក្នុងលោកនេះ រមែងប្រឡាក់ដោយបាប ក្នុងបាប ដែលប្រព្រឹត្តទៅតាមធម្មតារបស់ខ្លួន បើសត្វរមែងប្រឡាក់ដោយ បាបដែលខ្លួនមិនបានធ្វើហើយ មិនមានបុគ្គលណាមួយប្រឡាក់ដោយបាប ឡើយ ។ បទថា **សោ ចេ** អធិប្បាយថា អត្ថនៃភាសិតរបស់អ្នក គឺវាទៈ ដែលថា មិនមានហេតុនោះ បើជាអត្ថដែលមានប្រយោជន៍ ចុះបញ្ចាំងដល់ ប្រយោជន៍ ជាធម៌ ជាអត្ថដែលល្អ មិនអាក្រក់ បើពាក្យរបស់លោកដែល ថា សត្វទាំងឡាយមិនមានហេតុ មិនមានបច្ច័យ រមែងសៅហ្មងឯង រមែង សោយសុខ និងទុក្ខឯង នេះជាការពិត ពានរក៏ឈ្មោះថា យើងសម្លាប់ល្អ ហើយ ទោសអ្វីក្នុងសេចក្តីនេះ គប្បីមានដល់យើង ។ បទថា **វិជានិយ**

សេចក្ដីថា នែសម្លាញ់ បើលោកគប្បីដឹងដល់នូវការខុសនៃវាទៈរបស់ខ្លួនសោត អ្នកក៏មិនគប្បីតិះដៀលយើង ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះថា វាទៈរបស់អ្នកបែបនោះ ព្រោះដូច្នោះ អ្នកគប្បីសរសើរយើងថា អ្នកធ្វើតាមវាទៈរបស់អញ តែបើមិនដឹងវាទៈរបស់ខ្លួនទេ ក៏រមែងតិះដៀលខ្ញុំ ។

ព្រះមហាសត្វ សង្កត់សង្កិនអាមាត្យនោះ ឲ្យជាបុគ្គលអស់បដិភាណ ដោយប្រការដូច្នេះ ។ សូម្បីព្រះរាជាអង្គនោះ ក៏ទ្រង់អៀនខ្មាសក្នុងកណ្ដាលបរិស័ទ ប្រថាប់គង់ឈ្ងោកព្រះភក្ត្រ ព្រះមហាសត្វកាលទម្លាយអហេតុកវាទីអាមាត្យនោះហើយ ទើបហៅឥស្សរករណវាទីអាមាត្យមក ហើយសាកសួរថា នែអាវុសោ អ្នកសើចចំអកយើង ព្រោះហេតុអ្វី បើអ្នកមានវាទៈថា វត្ថុទាំងពួងព្រះម្ចាស់សួគ៌ជាអ្នកសាងឲ្យដោយភាពជាសារៈដូច្នេះហើយ ទើបពោលគាថាទាំងនេះថា

ប្រសិនបើព្រះឥសូរ ចាត់ចែងជីវិតរបស់សត្វលោកទាំងអស់ផង ចាត់ចែងនូវឫទ្ធិ គឺឥស្សរិយយសផង នូវភាពនៃសេចក្ដីវិនាសផង នូវកម្មល្អនឹងអាក្រក់ផង មានបុរស ( ណាមួយ ) ជាអ្នកធ្វើតាមបង្គាប់ ( របស់ព្រះឥសូរនោះ ) ព្រះឥសូរទេតើ តែងប្រឡាក់ជិតជាម ដោយអំពើអាក្រក់នោះ ( ដោយខ្លួនឯង ) ។ បើ ( សេចក្ដីនៃភាសិតរបស់អ្នក ) នោះ ជាអត្ថផង ជាធម៌ផង ល្អមិនអាក្រក់ទេ បើពាក្យរបស់អ្នកដ៏ចម្រើន ជាពាក្យពិត ពានរក៏ឈ្មោះថា អាត្មា

សម្លាប់ត្រូវហើយ ។ បើអ្នកដឹងច្បាស់នូវកំហុសនៃវាទៈរបស់ខ្លួន អ្នកមិនត្រូវតិះដៀលអាត្មាទេ ដ្បិតវាទៈរបស់អ្នកដ៏ចម្រើនបែបនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កប្បេតិ ជីវិតំ** សេចក្តីថា បើព្រះព្រហ្ម ឬព្រះជាម្ចាស់អង្គដទៃចាត់ចែង ត្រួតត្រាជីវិតឲ្យដល់សត្វលោកទាំងអស់យ៉ាងនេះថា ចូរអ្នកចិញ្ចឹមជីវិតដោយការភ្ជួរស្រែ ចូរអ្នកចិញ្ចឹមជីវិតដោយការចិញ្ចឹមគោ ដូច្នេះជាដើម ។ បទថា **ឥទ្ធិ ព្យសនភាវញ្ច** អធិប្បាយថា បើព្រះជាម្ចាស់សាង គឺធ្វើឫទ្ធិច្រើនប្រភេទ មានភាពជាធំជាដើម សាងនូវការវិនាស មានសេចក្តីវិនាសនៃពួកញាតិជាដើម និងសាងនូវកម្មល្អកម្មអាក្រក់ដ៏សេសទាំងអស់ ។ បទថា **និទ្ទេសការី** សេចក្តីថា បើបុរសណាម្នាក់ធ្វើតាមពាក្យប្រើ គឺពាក្យបង្គាប់របស់ព្រះជាម្ចាស់នោះ កាលបើដូច្នោះ បុគ្គលណាម្នាក់ក៏រមែងធ្វើបាបបាន ព្រះជាម្ចាស់ប៉ុណ្ណោះ រមែងទទួលបាបនោះខ្លួនឯង ព្រោះព្រះជាម្ចាស់ជាអ្នកប្រើឲ្យធ្វើបាបនោះ ។ ពាក្យដ៏សេសគប្បីជ្រាបដោយន័យមុន ។ ម្យ៉ាងទៀត គប្បីជ្រាបអត្ថក្នុងទីទាំងអស់ដូចក្នុងទីនេះចុះ ។

ព្រះមហាសត្វ កាលទម្លាយឥស្សរករណវាទ បានដោយឥស្សរករណៈនោះឯង ដូចបុគ្គលកាន់យកមែកស្វាយគ្រវែងផ្លែស្វាយឲ្យជ្រុះអំពីដើម ដោយប្រការដូច្នេះហើយ ទើបហៅបុព្វេកតវាទីអាមាត្យចូលមកហើយពោលថា នែអាវុសោ អ្នកសើចចំអកយើងព្រោះហេតុអ្វី បើអ្នកសម្គាល់ថា បុព្វេកតវាទជាការពិត ដូច្នេះហើយ ទើបពោលគាថាទាំងនេះថា

បើបុគ្គលដល់នូវសុខទុក្ខ ព្រោះហេតុនៃអំពើ ដែលខ្លួនធ្វើក្នុងកាលមុន បុគ្គលនោះឯងរមែងរួចចាកបំណុលនោះ ដែលជាអំពើអាក្រក់ គឺខ្លួនធ្វើពីដើមមក ( កាលបើយ៉ាងនេះ ) អាត្មាក៏ឈ្មោះថា បានរួចចាកបំណុលចាស់ តើនរណា ក្នុងលោកនេះប្រឡាក់ដោយបាប ។ បើ ( សេចក្តីនៃភាសិតរបស់អ្នក ) នោះជាអត្ថផង ជាធម៌ផង ល្អ មិនអាក្រក់ទេ បើពាក្យរបស់អ្នកដ៏ចម្រើនជាពាក្យពិត ពានរ ក៏ឈ្មោះថាអាត្មាសម្លាប់ត្រូវហើយ ។ បើអ្នកដឹងច្បាស់នូវកំហុសនៃវាទៈរបស់ខ្លួន អ្នកមិនត្រូវតិះដៀលអាត្មាទេ ដ្បិតវាទៈរបស់អ្នកដ៏ចម្រើនបែបនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បុព្វេកតហេតុ** បានដល់ ព្រោះហេតុដែលបានធ្វើកម្មទុកក្នុងកាលមុន គឺព្រោះការធ្វើនូវកម្មដែលខ្លួនបានធ្វើទុកហើយក្នុងភពមុនពិតប្រាកដ ។ បទថា **តមេសោ មុញ្ចតេ ឥណំ** សេចក្តីថា បុគ្គលណារមែងដល់សេចក្តីទុក្ខដោយការត្រូវសម្លាប់ និងការត្រូវចងជាដើម បើបុគ្គលនោះរមែងដោះបំណុល គឺបាបចាស់ដែលបានធ្វើទុកហើយនោះ ក្នុងឥឡូវនេះ កាលបើដូច្នេះ នេះជាការផុតចាកបំណុលចាស់របស់យើង ដ្បិតថា យើងជាស្វា ត្រូវស្វានេះកើតជាបរិព្វាជកមកសម្លាប់បរិភោគ បរិព្វាជកនោះកើតមកជាស្វាក្នុងអត្តភាពនេះ ខ្ញុំក៏ត្រឡប់មកកើតជាបរិព្វាជក សម្លាប់បរិភោគដូចគ្នា អ្នកណាក្នុងលោកនេះប្រឡាក់ដោយបាប ។

ព្រះមហាសត្វកាលទម្លាយនូវវាទៈរបស់បុរោហិតវាទអាមាត្យ ដូច្នោះហើយ ទើបហៅឧច្ឆេទវាទីអាមាត្យមកចំពោះមុខ ហើយពោលសង្កត់សង្កិនថា នែអាវុសោ អ្នកពោលពាក្យជាដើមថា ទានដែលបុគ្គលឲ្យហើយមិនមានផល ដូច្នេះ និងសម្គាល់ថា សត្វទាំងឡាយរមែងដាច់សូន្យទៅក្នុងលោកនេះប៉ុណ្ណោះ ឈ្មោះថា សត្វទៅកាន់បរលោកមិនមានឡើយ លោកសើចចំអកយើង ព្រោះហេតុអ្វី ដូច្នេះហើយ ទើបពោលជាគាថាទាំងនេះថា

រូបក្ខន្ធរបស់សត្វទាំងឡាយ តែងកកើតឡើង ព្រោះអាស្រ័យនូវភូតរូបទាំង ៤ ( មានដីជាដើម ) ឯរូប ( នោះ ) កកើតឡើងអំពីភូតរូបណា ( ដល់ពេលរលត់ ) ក៏ត្រឡប់ទៅក្នុងភូតរូបនោះវិញ ។ ជីវៈរស់នៅក្នុងលោកនេះ លុះរំលាយខន្ធទៅហើយ នឹងសាបសូន្យក្នុងបរលោក លោកនេះដាច់សូន្យជនទាំងឡាយ ទាំងពាលទាំងបណ្ឌិត ( រមែងសូន្យដូចគ្នា ) កាលបើលោកនេះដាច់សូន្យហើយ តើនរណាក្នុងលោកនេះប្រឡាក់ដោយបាប ។ បើ ( សេចក្តីនៃភាសិតរបស់អ្នក ) នោះជាអត្ថផង ជាធម៌ផង ល្អមិនអាក្រក់ទេ បើពាក្យរបស់អ្នកដ៏ចម្រើនជាពាក្យពិត ពានរក៏ឈ្មោះថា អាត្មាសម្លាប់ត្រូវហើយ ។ បើអ្នកដឹងច្បាស់នូវកំហុសនៃវាទៈរបស់ខ្លួន អ្នកមិនត្រូវតិះដៀលអាត្មាទេ ដ្បិតវាទរបស់អ្នកដ៏ចម្រើន បែបនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចតុទ្ធំ** បានដល់ ភូតរូបទាំង ៤ មានបឋវីធាតុជាដើម ។ បទថា **រូបំ** បានដល់ រូបក្ខន្ធ ។ បទថា **តត្ថេវ** សេចក្តីថា រូបនោះ រមែងកើតឡើងអំពីវត្ថុណា ក្នុងកាលរលត់ ក៏រមែងក្លាយទៅជាវត្ថុនោះដូចដើមនោះឯង ។ ព្រះមហាសត្វធ្វើនូវការឃើញរបស់ឧច្ឆេទវាទីអាមាត្យនោះឲ្យតាំងឡើងយ៉ាងនេះថា បុរសដែលប្រកបដោយមហាភូតរូបទាំង ៤ នោះ ធ្វើនូវកាលកិរិយាក្នុងវេលាណា រាងកាយដែលជាចំណែកដី ក៏ក្លាយទៅជាដីទៅ ចំណែកដែលជាទឹកក៏ក្លាយទៅជាទឹកទៅ ចំណែកដែលជាភ្លើងក៏ក្លាយជាភ្លើងទៅ និងរាងកាយដែលជាចំណែកខ្យល់ក៏ក្លាយទៅជាខ្យល់ទៅ ឥន្ទ្រិយទាំងឡាយក៏ចូលដល់ភាពជាអាកាស បុរសទាំងឡាយដែលមានគៅអីវែង ជាគម្រប់ ៥ រមែងលីសាកសពដែលស្លាប់ទៅ ស្នាមជើងប្រាកដរហូតដល់ឆ្អឹងដែលមានពណ៌ដូចសត្វព្រាប មានគ្រឿងបូជាមានផេះជាទីបំផុត ទានដែលពួកបុគ្គលល្ងង់បញ្ញត្តទុក បុគ្គលពួកណាមួយដែលពោលវាទៈថាមាន ការពោលរបស់បុគ្គលទាំងនោះទទេ ជាពាក្យកុហក ពាលក្តី បណ្ឌិតក្តី កាលកាយបែកធ្លាយទៅ រមែងដាច់សូន្យ គឺវិនាស បានដល់ មិនប្រាកដខាងមុខ អំពីស្លាប់ទៅ ។ បទថា **ឥធេវ** សេចក្តីថា ជីវៈរមែងរស់នៅ ក្នុងលោកនេះប៉ុណ្ណោះ ។ បទថា **បេច្ច បេច្ច វិនស្សតិ** សេចក្តីថា សត្វដែលកើតក្នុងបរលោក ក៏មិនបានត្រឡប់មកក្នុងលោកនេះទៀត ដោយអំណាចនៃគតិ តែងវិនាសដាច់សូន្យទៅក្នុងលោកនោះឯង កាលលោកដាច់សូន្យយ៉ាងនេះ អ្នកណានឹងប្រឡាក់ដោយបាបក្នុងលោកនេះ ។

ព្រះមហាសត្វ កាលទម្លាយវាទៈនៃឧច្ឆេទវាទីរបស់អាមាត្យនោះ ដោយប្រការដូច្នេះហើយ ទើបហៅខត្តវិជ្ជវាទីអាមាត្យចូលមក ហើយពោលថា អាវុសោ លោកប្រកាន់លទ្ធិថា បុគ្គលគួរសម្លាប់មាតាបិតា ហើយធ្វើប្រយោជន៍ដល់ខ្លួន ដូច្នេះ លោកសើចចំអកយើង ព្រោះហេតុអ្វី ដូច្នេះហើយ ពោលគាថានេះថា

ជនទាំងឡាយអ្នកមានខត្តវិជ្ជា ( វិជ្ជាខាងការគាស់រំលើង ) ក្នុងលោក ជាជនពាលសោះទេ តែមានមានះថាជាបណ្ឌិត ពោលថា បុគ្គលសម្លាប់មាតាក៏បាន បិតាក៏បាន ពុំនោះសោតទេ សម្លាប់បងប្អូន ឬកូនប្រពន្ធក៏បាន ប្រសិនបើមានប្រយោជន៍បែបនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ខត្តវិធា** បានដល់ បុគ្គលមានការដឹងថា ការសម្លាប់មាតាបិតា ជារបស់ដែលគួរធ្វើ ។ម្យ៉ាងទៀត បាឋៈក៏យ៉ាងនេះដូចគ្នា ។ ពាក្យថា **ខត្តវិជ្ជា** នេះ ជាឈ្មោះរបស់អាចារ្យដែលមានវិជ្ជាថា ការសម្លាប់មាតាបិតាជារបស់ដែលគួរធ្វើ ។ បទថា **ពាលា បណ្ឌិតមានិនោ** សេចក្តីថា ជនទាំងឡាយដែលជាបុគ្គលពាលសម្គាល់ថា ពួកយើងជាបណ្ឌិត និងប្រកាសថា ខ្លួនជាបណ្ឌិត ជាអ្នកមានការសម្គាល់ខ្លួនថា ជាបណ្ឌិត ទើបពោលយ៉ាងនេះ ។ បទថា **អត្ថោ ចេ** សេចក្តីថា អាចារ្យពោលថា បើប្រយោជន៍តិចតួចមានសភាពបែបនោះ គប្បីមានដល់ខ្លួនសោត បុគ្គលមិនគប្បីវៀររបស់ណាមួយឡើយ គប្បីសម្លាប់ទាំងអស់ ដូច្នេះ សូម្បីអ្នកក៏ជា

បុគ្គលណាម្នាក់ បណ្តាអាចារ្យដែលមានវាទៈបែបនោះ ។

ព្រះមហាសត្វ សម្តែងលទ្ធិរបស់ខត្តវិជ្ជវាទីអាមាត្យនោះយ៉ាងនេះហើយ កាលប្រកាសលទ្ធិរបស់ខ្លួន ទើបពោលគាថានេះថា

បុគ្គលអង្គុយក្តី ដេកក្តី ក្រោមម្លប់ឈើណា មិនត្រូវកាច់មែកឈើនោះទេ ដ្បិតបុគ្គលប្រទូស្តមិត្ត ជាមនុស្សអាក្រក់ ។ ( ចំណែកខាងអ្នកពោលថា) កាលបើប្រយោជន៍កើតឡើង ( ចំពោះខ្លួន ) ហើយ បុគ្គលគប្បីគាស់រំលើង សូម្បីទាំងឫសក៏បាន ( ដូច្នេះ ) ពានរក៏ឈ្មោះថា អាត្មាសម្លាប់ត្រូវហើយ ព្រោះអាត្មាត្រូវការដោយស្បៀង ។ បើសេចក្តីនៃកាសិតរបស់អ្នកនោះ ជាអត្ថផង ជាធម៌ផង ល្អមិនអាក្រក់ទេ បើពាក្យរបស់អ្នកដ៏ចម្រើនជាពាក្យពិត ពានរក៏ឈ្មោះថា អាត្មាសម្លាប់ត្រូវហើយ ។ បើអ្នកដឹងច្បាស់នូវកំហុសនៃវាទៈរបស់ខ្លួន អ្នកមិនត្រូវតិះដៀលអាត្មាទេ ដ្បិតវាទៈរបស់អ្នកដ៏ចម្រើនបែបនោះដូច្នេះ ។

ក្នុងគាថានោះ មានពាក្យអធិប្បាយថា នៃខត្តវិជ្ជវាទីអាមាត្យដ៏ចម្រើន អាចារ្យរបស់ពួកយើង ពណ៌នាទុកយ៉ាងនេះថា បុគ្គលមិនគួរកាច់មែកឈើឬស្លឹករបស់ដើមឈើដែលខ្លួនបានអាស្រ័យម្លប់ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះបុគ្គលប្រទូស្តចំពោះមិត្ត ជាបុគ្គលអាក្រក់ តែលោកពោលយ៉ាងនេះថា បើមានសេចក្តីត្រូវការកើតឡើង ក៏ឲ្យដកសូម្បីទាំងឫសយើងមានសេចក្តីត្រូវ

ការស្បៀង ព្រោះដូច្នោះ ទោះបីយើងសម្លាប់ស្វានេះហើយ ប្រយោជន៍គប្បីមានដល់យើងច្រើនពិតយ៉ាងនោះ ពានរក៏ឈ្មោះថាយើងសម្លាប់ដោយល្អ ។

មហាសត្វ បានទម្លាយនូវវាទៈ របស់ខត្តវិជ្ជវាទីអាមាត្យនោះយ៉ាងនេះហើយ កាលអាមាត្យទាំង ៥ នាក់នោះ អស់បដិភាណអង្គុយស្ងៀម ទើបហៅព្រះរាជាមក ហើយក្រាបទូលឲ្យជ្រាបថា បពិត្រមហារាជ ទ្រង់នាំយកមហាចោរប្លន់ដែនទាំង ៥ នាក់នេះតាមទ្រង់ពិត គួរអាណិតហ្ន៎ ទ្រង់ជាបុគ្គលល្ងង់ខ្លៅ ដ្បិតថា បុរសគប្បីដល់នូវសេក្តីទុក្ខធំ ទាំងក្នុងភពនេះនិងភពខាងមុខ ព្រោះការប្រឡូកប្រឡំជាមួយពួកបុគ្គលពាលបែបនេះ ដូច្នេះហើយ កាលសម្តែងធម៌ដល់ព្រះរាជា ទើបពោលគាថានេះថា

( បុរសអ្នកលុះក្នុងអំណាចនៃទិដ្ឋិ ៥ នាក់គឺ ) បុរសជាអហេតុវាទៈ ១ ជាឥស្សរកតវាទៈ ១ ជាបុព្វេកតវាទៈ ១ ជាឧច្ឆេទវាទៈ ១ ជាខត្តវិជ្ជវាទៈ ១ នេះជាអសប្បុរសក្នុងលោក ជាមនុស្សពាល តែប្រកាន់ខ្លួនថាជាបណ្ឌិត បុរសបែបនោះធ្វើបាប ( ខ្លួនឯង ) ថែមទាំងញុំាងអ្នកដទៃឲ្យធ្វើបាបទៀតផង ការនៅប្រឡូកប្រឡំនឹងអសប្បុរស មានទុក្ខជាទីបំផុត មានសេចក្តីក្តៅក្រហាយជាកម្រៃ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តាទិសោ** សេចក្តីថា បពិត្រមហារាជ បុរសដូចគ្នានឹងបុរសដែលមានទិដ្ឋិនិងគតិទាំង ៥ នាក់នោះ គប្បីធ្វើបាបខ្លួនឯង ក៏បាន គប្បីធ្វើការបបួលអ្នកដទៃ ដែលជឿពាក្យរបស់បុគ្គលនោះ ឲ្យធ្វើបាប

ក៏បាន ។ បទថា **ឧក្កុដ្ឋា** សេចក្តីថា ការប្រឡូកប្រឡំជាមួយអសប្បុរស ទាំងឡាយបែបនេះ រមែងជាការអាក្រក់ និងមានការក្តៅក្រហាយជាផល ទាំងក្នុងលោកនេះ ទាំងក្នុងលោកខាងមុខ ដើម្បីប្រកាសអត្ថនេះឲ្យជាក់ច្បាស់ គួរនាំព្រះសូត្រ ( ក្នុងអង្គុត្តរនិកាយ តិកនិបាត ) ជាដើមថា ម្នាលភិក្ខុទាំងឡាយ ភ័យទាំងឡាយណាមួយកើតឡើង ភ័យទាំងអស់នោះ តែងកើតឡើងអំពីជនពាល... ដូច្នេះមកសម្តែង ឬគប្បីនាំសេចក្តីក្នុងរឿងគោធជាតក សព្ហិវជាតក និងអកិត្តិជាតក ជាដើមមកសម្តែងក៏បាន ។

ឥឡូវនេះ ព្រះមហាសត្វ កាលនឹងធ្វើធម្មទេសនាឲ្យចម្រើន ដោយបំណងនឹងសម្តែងដល់ឧបមា ទើបពោលគាថាដោយសេចក្តីថា

កាលពីដើម មានសត្វកុក ១ មានរូបដូចចៀម កាលបើឥតគេសង្ស័យ ក៏ចូលទៅរកហ្វូងពពែ សម្លាប់មេចៀមផង មេពពែផង ពពែឈ្មោលផង លុះសម្លាប់បានហើយ ក៏ហើរទៅតាមបំណងរបស់ខ្លួន ។ សមណព្រាហ្មណ៍ពួកខ្លះ ក៏បែបនោះដែរ ធ្វើនូវគ្រឿងបិទបាំង ហើយបញ្ឆោតមនុស្សទាំងឡាយ ( ពួកខ្លះ ) ជាអ្នកមិនបរិភោគអាហារ ( ពួកខ្លះ ) ជាអ្នកដេកលើផែនដី ( ពួកខ្លះ ) ទុកភ្លុក ( ពួកខ្លះ ) ព្យាយាមអង្គុយប្រហោង ( ពួកខ្លះ ) បរិភោគបាយដោយកំណត់ថ្ងៃ ( ពួកខ្លះ ) មិនផឹកទឹក មានមារយាទអាក្រក់ នាំគ្នាពោលថា ខ្លួនជាអរហន្ត ។ ជនទាំងនុ៎ះជាអសប្បុរសក្នុងលោកជាមនុស្ស

ពាល តែប្រកាន់ខ្លួនថាជាបណ្ឌិត បុគ្គលបែបនោះធ្វើបាប ( ខ្លួនឯង ) ផង ថែមទាំងញុំាងអ្នកដទៃឲ្យធ្វើបាបទៀតផង ការនៅប្រឡូកប្រឡំដោយអសប្បុរមានទុក្ខជាទីបំផុត មាន សេចក្តីក្តៅក្រហាយជាកម្រៃ ។ ពួកជនណា ពោលថា ព្យាយាម ឥតអំពើផង មិនពោលអាងហេតុផង ពណ៌នានូវអំពើរបស់ បុគ្គលដទៃ នឹងអំពើរបស់ខ្លួនថាជាអំពើសូន្យទទេផង ។ ពួក ជនទុ៎ះ ជាអសប្បុរសក្នុងលោក ជាមនុស្សពាល តែប្រកាន់ ខ្លួនថាជាបណ្ឌិត បុរសបែបនោះធ្វើបាប ( ខ្លួនឯង ) ផង ថែមទាំងញុំាងអ្នកដទៃ ឲ្យធ្វើបាបទៀតផង ការនៅប្រឡូក ប្រឡំដោយអសប្បុរស មានទុក្ខជាទីបំផុត មានសេចក្តីក្តៅ ក្រហាយជាកម្រៃ ប្រសិនបើការព្យាយាមឥតអំពើ មិនមាន អំពើល្អនិងអាក្រក់ទេ ព្រះរាជាមិនគប្បីចិញ្ចឹមនូវជាងឈើ ទាំងមិនគប្បីឲ្យគេធ្វើនូវយន្តទាំងឡាយឡើយ ។ ព្រោះ ហេតុតែការព្យាយាមមានផង អំពើល្អនឹងអាក្រក់មានផង បាន ជាព្រះរាជាតែងចាត់ឲ្យធ្វើនូវយន្តទាំងឡាយ តែងចិញ្ចឹមនូវ ជាងឈើ ។ ប្រសិនបើភ្លៀងខានបង្អុរចុះ រហូតមួយរយឆ្នាំ ទាំងទឹកសន្សើមក៏មិនធ្លាក់ចុះសោះ មុខជាលោកនេះ នឹង សូន្យឈឹង ពពួកសត្វនេះនឹងវិនាស ។ ព្រោះហេតុតែភ្លៀង បង្អុរចុះផង ទាំងទឹកសន្សើមក៏ផ្សើមរៀយៗផង បានជាសន្ទូង

ទាំងឡាយលួតលាស់ល្អ ទាំងអ្នកដែន ក៏ព្រះរាជាទ្រង់រក្សា អស់កាលជាអង្វែងផង ។ កាលពួកគោកំពុងឆ្លងទៅ ( កាន់ទីណាមួយ ) បើគោបាទៅវៀច កាលបើគោបាទាំពួកគោទៅវៀច មេគោទាំងអស់នោះ ក៏ទៅវៀច ។ បណ្តាពួកមនុស្សក៏ដូច្នោះដែរ បុគ្គលណា ដែលអ្នកផងសន្មតថាប្រសើរផុត បើបុគ្គលនោះប្រព្រឹត្តអធម៌ហើយ នឹងចាំបាច់និយាយថ្វីដល់ប្រជាជនក្រៅនេះ បើព្រះរាជាមិនប្រកបដោយធម៌ អ្នកដែនទាំងអស់ ក៏ដេកជាទុក្ខ ។ កាលពួកគោកំពុងឆ្លងទៅ បើគោបាទៅត្រង់ កាលបើគោបាទាំគេទៅត្រង់ មេគោទាំងអស់នោះ ក៏ទៅត្រង់ ។ ពួកមនុស្សក៏ដូច្នោះដែរ បុគ្គលណាដែលអ្នកផងសន្មតថាប្រសើរផុត ប្រសិនបើបុគ្គលនោះប្រព្រឹត្តធម៌ នឹងចាំបាច់និយាយថ្វីដល់ប្រជាជនក្រៅនេះ បើព្រះរាជាប្រកបដោយធម៌ អ្នកដែនទាំងអស់ក៏ដេកជាសុខ ។ បុគ្គលណាបេះផ្លែខ្ចីនៃឈើធំដែលមានផ្លែ ( បុគ្គលនោះ ) រមែងមិនដឹងនូវរសនៃផ្លែឈើនោះផង ទាំងពូជនៃផ្លែឈើនោះ ក៏វិនាសទៅផង ។ ព្រះរាជាណាគ្រប់គ្រងដែន ដែលប្រៀបដូចដើមឈើធំដោយអធម៌ ( ព្រះរាជានោះ ) ឈ្មោះថាមិនជ្រាបនូវរសរបស់ដែននោះផង ទាំងដែនរបស់រាជានោះ ក៏វិនាសផង ។ បុគ្គលណាបេះផ្លែឈើទុំនៃដើមឈើធំ ដែល

មានផ្លែ បុគ្គលនោះ រមែងដឹងនូវរសនៃផ្លែឈើនោះផង ទាំងពូជរបស់ផ្លែឈើនោះក៏មិនវិនាសផង ។ ព្រះរាជាណាគ្រប់គ្រងដែនដែលប្រៀបដូចជាដើមឈើធំដោយធម៌ ( ព្រះរាជានោះ ) ឈ្មោះថា បានជ្រាបនូវរសរបស់ដែននោះផង ទាំងដែនរបស់ព្រះរាជានោះក៏មិនវិនាសផង ។ ព្រះរាជាណាមួយគ្រប់គ្រងជនបទ ដោយអធម៌ ( លុះអំណាចអគតិ ) ព្រះរាជាជាខត្តិយៈនោះ ឈ្មោះថាសាបសូន្យចាកដើមឈើដែលត្រូវជាឱសថទាំងអស់ មួយទៀត ( ព្រះរាជាអង្គណា ) បៀតបៀនពួកកុដុម្ពិកៈដែលនៅក្នុងនិគម ( ផង ) បៀតបៀនពួកពាណិជដែលប្រកបក្នុងការលក់ចេញទិញចូល ជាអ្នកធ្វើនូវការថ្វាយពន្ធដារ និងពលិកា ( ផង ) ព្រះរាជានោះឈ្មោះថា សាបសូន្យចាកឃ្លាំង ។ ព្រះរាជាណាបៀតបៀននូវខ្មាន់ធ្នូដែលជាអ្នកដឹងនូវកន្លែងយ៉ាងតំណំ ដែលគួរប្រហារ និងពួកទាហានធំដែលជាអ្នកពិចារណា ធ្វើការនៅក្នុងសង្គ្រាម និងមហាមាត្យដែលមានសក្តិធំៗ ព្រះរាជានោះ ឈ្មោះថា សាបសូន្យចាកពល ។ សត្វណាប្រព្រឹត្តនូវអធម៌ បៀតបៀនពួកឥសីអ្នកសង្រួម ប្រព្រឹត្តធម៌ដ៏ប្រសើរ ដូចជាបៀតបៀននូវពួកអ្នកនិគមដូច្នោះ ក្សត្រនោះឈ្មោះថា សាបសូន្យចាកឋានសួគ៌ ។ម្យ៉ាងទៀត ព្រះរាជាណា មិនឋិតនៅក្នុងធម៌

សម្លាប់អគ្គមហេសី ដែលជាអ្នកមិនប្រទូស្ត ព្រះរាជានោះ ឈ្មោះថា បានជួបប្រទះនូវឋានៈដ៏អាក្រក់ផង ឈ្មោះថាសាបសូន្យចាកកូនទាំងឡាយផង ។ ព្រះរាជាត្រូវតែប្រព្រឹត្តធម៌ផង មិនត្រូវបៀតបៀនអ្នកជនបទ និងអ្នកនិគមផង ពួកពលផង ពួកឥសីផងគប្បីប្រព្រឹត្តស្មោះស្មើចំពោះកូននិងប្រពន្ធផង ។ ព្រះរាជានោះ ទើបឈ្មោះថាជាម្ចាស់នៃផែនដី ឈ្មោះថាអ្នកគ្រប់គ្រងនូវដែន ឈ្មោះថាជាអ្នកមិនក្រោធ រមែងញុំាងពួកអ្នកដែនជិតខាងឲ្យរំភើបញាប់ញ័រ ដូចព្រះឥន្ទ្រជាធំជាងអសុរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វកស្ស បុព្វេ** បានដល់ ក្នុងកាលមុន សត្វឆ្កែព្រៃ[១]។ បទថា **អសុ** នេះ ត្រឹមតែជានិបាត ។ មហាពោធិបរិព្វាជកពោលអធិប្បាយទុកថា បពិត្រមហារាជ ក្នុងកាលមុន មានឆ្កែព្រៃមួយ មានរូបដូចចៀម កន្ទុយរបស់វាវែង វាយកកន្ទុយនោះលាក់ទុកក្នុងប្រឡោះភ្លៅ ចូលទៅកាន់ហ្វូងចៀម ដេញសម្លាប់ចៀមទាំងឈ្មោលទាំងញី ក្នុងទីនោះ ហើយក៏ចៀសចេញទៅដោយអាការឯណាមួយ ។ បទថា **តថាវិធេកេ** សេចក្ដីថា សមណៈនិងព្រាហ្មណ៍ទាំងឡាយពួកខ្លះ ក៏មានអាការយ៉ាងនោះ ធ្វើនូវការបិទបាំង គឺបិទបាំងខ្លួនឯង ដោយភេទបព្វជិត ធ្វើដូចជាប្រាថ្នានូវប្រយោជន៍ត្រាច់បោកបញ្ឆោតសត្វលោកដោយវាចាទន់ផ្អែមជាដើម ។ បទថា **អឆាសកា**

---

១-បិដកខ្មែរជា កុក ។

ជាដើម លោកពោលទុកដើម្បីសម្តែងកិរិយាអាការបិទបាំងរបស់ពួកសមណព្រាហ្មណ៍ទាំងនោះ ។ ពិតហើយ សមណព្រាហ្មណ៍ពួកខ្លះ នាំគ្នាបោកបញ្ឆោតពួកមនុស្សថា ពួកយើងកាន់យកការមិនបរិភោគអាហារជាវត្ត ទើបមិនចាំបាច់ឲ្យពួកអ្នកនាំអាហារណាមួយមកឡើយ ។ ជនពួកខ្លះ ក៏បញ្ឆោតថា ពួកយើងកាន់យកការដេកលើផែនដីជាវត្ត តែសម្រាប់ជនពួកខ្លះ កាន់យកការជុសខាត់ធូលីជាគ្រឿងបិទបាំង ។ ជនពួកខ្លះ កាន់យកការតាំងនូវសេចក្តីព្យាយាមដោយការដើរចំអើតជាវត្ត អធិប្បាយថា ជនទាំងនោះ កាលដើរទៅក៏លើកខ្លួនឡើងចំអើតជើងដើរទៅ ។ ជនពួកខ្លះ បិទបាំងដោយការវៀរចាកការបរិភោគអាហារដោយបរិយាយ គឺអត់ ៧ ថ្ងៃខ្លះ ១០ ថ្ងៃខ្លះ ទើបបរិភោគម្តង ។ ជនពួកខ្លះ មិនព្រមផឹកទឹក នាំគ្នាពោលថា ពួកយើងមិនផឹកទឹកទេ ។ បទថា **អរហាន្តោ វទានា** សេចក្តីថា បុគ្គលទាំងនោះជាអ្នកមានការប្រព្រឹត្តអាក្រក់ នាំគ្នាត្រាច់ពោលថា ពួកយើងជាព្រះអរហន្ត ។ បទថា **ឯតេ** សេចក្តីថា បពិត្រមហារាជ ជនទាំង ៥ នេះ ឬជនដទៃ ដែលឈ្មោះថាមានទិដ្ឋិនិងគតិយ៉ាងនេះ ជនទាំងអស់នេះ ឈ្មោះថា ជាអសប្បុរស ។ បទថា **យមាហុ** កាត់បទជា **យេ អាហុ** ប្រែថា ពួកជនណាពោល ។ បទថា **សចេ ហិ វិរិយំ នាស្ស** សេចក្តីថា បពិត្រមហារាជ បើសេចក្តីព្យាយាមដែលប្រព្រឹត្តទៅផ្លូវកាយនិងផ្លូវចិត្ត ដែលសម្បយុត្តដោយញាណ មិនគប្បីមានសោត ។ បទថា **កម្មំ** សេចក្តីថា បើកម្មល្អ និងកម្មអាក្រក់មិនមានសោត ។ បទថា **ន ភរេ** សេចក្តីថា កាលបើដូច្នេះ ព្រះរាជាមិនគួរចិញ្ចឹម

ជាងឈើ ឬពួករាជការជទៃឡើយ ។ បទថា **នបិ យន្តានិ** សេចក្តីថា សូម្បីមេជាង ក៏មិនគប្បីធ្វើយន្តទាំងឡាយ មានប្រាសាទ ៧ ជាន់ជាដើម ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះមិនមានសេចក្តីព្យាយាមនិងការងារ ។ បទថា **ឧច្ឆិជ្ជេយ្យ** សេចក្តីថា បពិត្រមហារាជ បើភ្លៀងមិនធ្លាក់ ទឹកសន្សើមមិនធ្លាក់ អស់កាលមានប្រមាណប៉ុណ្ណោះ បន្ទាប់អំពីនោះទៅ លោកនេះគប្បីដាច់សូន្យ ដូចកាលជាទីតាំងឡើងនៃកប្ប តែឈ្មោះថា ការដាច់សូន្យរមែងមិនមានដោយទំនងដែលឧច្ឆេទវាទីអាមាត្យពោលហើយ ។ បទថា **ចាលយតេ** បានដល់ រមែងចិញ្ចឹម ។ ព្រះមហាសត្វពោល ៤ គាថា មានពាក្យផ្តើមថា **គវញ្ចេ តរមានានំ** ដូច្នេះ ក៏ដើម្បីសម្តែងធម៌ដល់ព្រះរាជាប៉ុណ្ណោះ ។ ព្រះមហាសត្វពោលគាថា មានពាក្យផ្តើមថា **មហារុក្ខស្ស** ដូច្នេះជាដើម ក៏ដើម្បីសម្តែងធម៌ដល់ព្រះរាជាដូចគ្នា ។ បណ្តាបទទាំងនោះ បទថា **មហារុក្ខស្ស** បានដល់ ដើមស្វាយដែលមានរសឆ្ងាញ់ ។ បទថា **អជម្មេន** បានដល់ ដោយតាំងនៅក្នុងអគតិ ។ បទថា **រសញ្ចស្ស ន ជានាតិ** សេចក្តីថា ព្រះរាជាមិនតាំងនៅក្នុងធម៌ រមែងមិនស្គាល់រស គឺឱជៈនៃរដ្ឋ បានដល់ រមែងមិនបាននូវការសម្បូរដោយសេចក្តីចម្រើន ។ បទថា **វិនស្សតិ** បានដល់ រមែងដាច់សូន្យទៅ មនុស្សទាំងឡាយ រមែងនាំគ្នាចោលស្រុកនិងនិគម ហើយទៅអាស្រ័យស្ថានទីដែលមិនរាបស្មើ គឺភ្នំដែលតាំងនៅក្នុងទីបំផុតដែន ។ ផ្លូវនៃសេចក្តីចម្រើនទាំងអស់ ក៏រមែងដាច់សូន្យទៅ ។ បទថា **សព្វោសធីភិ** សេចក្តីថា ព្រះរាជាទ្រង់រមែងឃ្លាតចាកព្រះឱសថទាំងអស់ មានឫសឈើ សម្បកឈើ

ស្លឹកឈើ ផ្កានិងផ្លែឈើជាដើម និងព្រះឱសថ មានសប្បិនិងនវនីតជាដើម ព្រះឱសថទាំងនោះ រមែងមិនដល់ព្រម ។ ព្រោះថា ផែនដីរបស់ព្រះរាជា ដែលមិនតាំងនៅក្នុងធម៌ រមែងជាផែនដីដែលប្រាសចាកឱជៈ ព្រោះផែនដីនោះ ប្រាសចាកឱជៈហើយ ទើបឱជៈនៃឱសថទាំងឡាយមិនមាន ឱសថទាំងនោះ មិនអាចរក្សារោគឲ្យស្ងប់រម្ងាប់បាន ។ ព្រះរាជាអង្គនោះ ឈ្មោះថា ជាអ្នក ឃ្លាតចាកឱសថទាំងនោះ ដោយប្រការដូច្នេះ ។ បទថា **នេគមេ** សេចក្តីថា ព្រះរាជាទ្រង់បៀតបៀន គឺទ្រង់គាបសង្កត់ពួកកុដុម្ពិកៈដែលនៅក្នុងនិគម ។ បទថា **យេ យុត្តា** សេចក្តីថាម្យ៉ាងទៀត ទ្រង់បៀតបៀនពួកឈ្មួញផ្លូវគោក និងពួកឈ្មួញផ្លូវទឹក ដែលប្រកបការលក់ដូរ បែរមុខទៅកាន់សេចក្តីចម្រើន លូតលាស់ ។ បទថា **ឱជទានពលីការេ** សេចក្តីថា បុគ្គលដែលធ្វើនូវការ ថ្វាយឱជៈ ដោយអំណាចការនាំកណ្តៈមក និងការថ្វាយសួយអំពីជនបទនោះៗ និងធ្វើពលីកម្ម មានចែកជា ៦ និង ១០ ចំណែកជាដើម ។ បទថា **ស-កោសេន** សេចក្តីថា ព្រះរាជាអង្គនោះ ទ្រង់បៀតបៀនមហាជនទាំងនេះ ទើប ឈ្មោះថា ជាព្រះរាជាដែលមិនតាំងនៅក្នុងធម៌ ឈ្មោះថា រមែងវិនាសចាក ទ្រព្យនិងធញ្ញាហារ ឃ្លាតចាកចំណែកនៃព្រះរាជទ្រព្យ ។ បទថា **បហារវរ-ខេត្តញ្ញូ** សេចក្តីថា នាយខ្មាន់ធ្នូជាអ្នកដឹងខេត្តនៃការប្រហារដោយល្អ យ៉ាង នេះថា គួរបាញ់ទៅក្នុងទីត្រង់នេះ ដូច្នេះ ។ បទថា **សង្គាមេ កតនិស្សមេ** បានដល់ នាយទាហានដែលជាធំទាំងឡាយ ជាអ្នកសម្រេចការច្បាំងក្នុងយុទ្ធ ភូមិ ។ បទថា **ឧស្សិតេ** បានដល់ មហាមាត្យដែលជាអ្នកល្បីល្បាញ គឺមាន

ឈ្មោះបោះសំឡេង ។ បទថា **ហឹសយំ** បានដល់ ទ្រង់បៀតបៀនឯងក្តី ប្រើអ្នកដទៃឲ្យបៀតបៀនក្តី នូវមនុស្សទាំងឡាយបែបនេះ ។ បទថា **ពលេធ** បានដល់ពួកនៃកម្លាំង ។ ពិតហើយ ពួកទាហានដ៏សេស ក៏រមែងលះបង់ព្រះរាជាដែលទ្រង់ប្រព្រឹត្តយ៉ាងនោះ ដោយគិតថា ព្រះរាជាអង្គនេះ ទ្រង់បៀតបៀនទាំងបុគ្គលដែលប្រគល់រាជសម្បត្តិដល់ព្រះអង្គ ដែលជាអ្នកមានឧបការៈច្រើន ទ្រង់មិនបៀតបៀនពួកយើងដូចម្តេចកើត ។ ព្រះរាជាអង្គនោះ ឈ្មោះថា រមែងខុសក្លាំងក្លាត់ចាកពួកពលដោយប្រការដូច្នេះ ។ បទថា **តបេវ ឥសយោ ហឹសំ** សេចក្តីថា ព្រះរាជាទ្រង់មិនប្រព្រឹត្តធម៌ ទ្រង់បៀតបៀនបព្វជិត ដែលស្វែងរកគុណដោយការជេរ និងការប្រហារជាដើម ដូចទ្រង់បៀតបៀនអ្នកស្រុកជាដើម ដូច្នោះ កាលកាយបែកធ្លាយស្លាប់ទៅ រមែងចូលដល់អបាយពិតប្រាកដ គឺមិនអាចកើតក្នុងឋានសួគ៌បានឡើយ ដូច្នោះ ព្រះរាជាអង្គនោះ ឈ្មោះថា រមែងឃ្លាតចាកស្ថានសួគ៌ ដោយប្រការដូច្នេះ ។ បទថា **ភរិយំ ហន្តិ អទូសកំ** សេចក្តីថា ព្រះរាជាទ្រង់ជឿពាក្យរបស់ពួកចោរ ដែលជាមិត្តក្លែងក្លាយ រួចឲ្យសម្លាប់ព្រះជាយាដែលជាអ្នកមានសីលដែលចម្រើនដោយបុត្តនិងធីតា ដែលចម្រើនហើយក្នុងម្លប់របស់ខ្លួន ។ បទថា **លុទ្ទំ បសវតេ ឋានំ** សេចក្តីថា ព្រះរាជាអង្គនោះរមែងជួប គឺសម្រេចផល នូវការចូលដល់នរករបស់ខ្លួនឯង ។ បទថា **បុត្តេហិ ច** សេចក្តីថា ព្រះរាជាអង្គនោះ រមែងខុសក្លាំងក្លាត់ ជាមួយព្រះឱរសទាំងឡាយរបស់ព្រះអង្គក្នុងអត្តភាពនេះឯង ។

ព្រះមហាសត្វនោះ ពោលដល់រឿងដែលព្រះរាជាអន្ធនោះជឿនូវពាក្យរបស់ជនទាំង ៥ ហើយសម្លាប់ព្រះទេវី និងពោលដល់រឿងដែលព្រះរាជាអន្ធនោះ ទ្រង់ខុសក្នុងព្រះឱរសទាំងឡាយ ដូចចាប់ចោរត្រង់ផ្លូវសក់ ក្នុងទីដែលជួបដូច្នោះ ។ ពិតហើយ ព្រះមហាសត្វ បំណងនឹងសង្កត់សង្កិនពួកអាមាត្យទាំងនោះ បំណងនឹងសម្តែងធម៌ និងបំណងបើកនូវរឿងដែលព្រះទេវីត្រូវពួកអាមាត្យទាំងនោះសម្លាប់ទើបនាំយកពាក្យមក ចាប់យកឱកាសពោលជាសេចក្តីនេះទុកដោយលំដាប់ ។ ព្រះរាជាទ្រង់បានស្តាប់ពាក្យរបស់ព្រះមហាសត្វនោះហើយ ក៏ទ្រង់ជ្រាបច្បាស់នូវកំហុសរបស់ទ្រង់ លំដាប់នោះ ទើបព្រះមហាសត្វក្រាបទូលព្រះរាជាឲ្យទ្រង់ជ្រាបថា បពិត្រមហារាជ តាំងអំពីថ្ងៃនេះទៅ សូមទ្រង់កុំជឿពាក្យរបស់ពួកជនទាំងនេះ ហើយធ្វើយ៉ាងនេះទៀតឡើយ ដូច្នេះ ។ កាលទូន្មានព្រះរាជា ទើបពោលគាថាជាដើមថា **ធម្មំ ចរ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធម្មំ ចរ** សេចក្តីថា ធម្មតាព្រះរាជា មិនគួរបៀតបៀនអ្នកជនបទដោយពលីកម្មដែលមិនប្រកបដោយធម៌ តែគួរប្រព្រឹត្តធម៌ក្នុងអ្នកជនបទ មិនគួរធ្វើម្ចាស់ទ្រព្យ ឲ្យក្លាយជាបុគ្គលមិនមែនជាម្ចាស់ទ្រព្យ តែគប្បីប្រព្រឹត្តធម៌ក្នុងអ្នកស្រុកទាំងឡាយ មិនគួរលំបាកក្នុងទីដែលមិនមែនជាឋានៈ តែគប្បីប្រព្រឹត្តធម៌ក្នុងពួកពលទាំងឡាយ គួរចៀសវាងនូវការសម្លាប់ ការចង ការជេរ និងការបៀតបៀន និងឲ្យតែបច្ច័យដល់បព្វជិតទាំងនោះ មិនគួរបៀតបៀនបព្វជិតដែលស្វែងរកគុណធម៌ គួរស្តាបនាព្រះរាជធីតា

ទុកក្នុងតំណែងដែលសមគួរ ប្រាថ្នាឲ្យព្រះឱរសទាំងអស់សិក្សារៀនសូធ្យនូវសិប្បៈសព្វយ៉ាង ទ្រង់ចិញ្ចឹមប្រកបដោយធម៌ ទ្រង់អនុគ្រោះព្រះរាជទេវីដោយទ្រង់ប្រគល់ភាពជាធំឲ្យ រកគ្រឿងប្រដាប់តាក់តែងឲ្យ ទ្រង់សរសើរឲ្យខ្ពង់ខ្ពស់ជាដើម គប្បីប្រព្រឹត្តស្មើក្នុងព្រះឱរសផង ក្នុងព្រះរាជទេវីផង ។ បទថា **ស ឆាតិសោ** សេចក្តីថា ព្រះរាជាបែបនោះ មិនព្រមទម្លាយព្រះរាជបវេណីសោយរាជសម្បត្តិដោយធម៌ រមែងធ្វើមហាជនដែលនៅជិតឲ្យញាប់ញ័រ ឲ្យតក់ស្លុត ដោយព្រះរាជអាជ្ញានិងព្រះតេជានុភាពរបស់ទ្រង់ ។ ពាក្យថា **ឥន្ទោវ** នេះ លោកពោលទុកដើម្បីជាពាក្យឧបមា អធិប្បាយថា ព្រះរាជាអង្គនោះរមែងធ្វើមហាជនដែលនៅជិត ឲ្យញាប់ញ័រ ដូចព្រះឥន្ទដែលដល់នូវការរាប់ថាជាស្តេចនៃអសុរ តាំងអំពីកាលដែលទ្រង់ច្បាំងឈ្នះ ហើយគ្រប់គ្រងពួកអសុរ រមែងធ្វើពួកអសុរដែលជាសត្រូវរបស់ទ្រង់ឲ្យញាប់ញ័រ ដូច្នោះ ។ ព្រះមហាសត្វ កាលទ្រង់សម្តែងធម៌ដល់ព្រះរាជាយ៉ាងនោះហើយ ទើបឲ្យហៅព្រះរាជកុមារទាំង ៤ អង្គមកទូន្មាន ហើយប្រកាសដល់កម្មដែលទ្រង់ហើយដល់ព្រះរាជា ឲ្យព្រះរាជាទ្រង់លើកទោសឲ្យ ហើយថ្វាយឱវាទដល់ជនទាំងអស់ថា មហាបពិត្រ ចាប់តាំងអំពីនេះទៅ ព្រះអង្គមិនទាន់ពិចារណាមុនហើយទ្រង់កុំកាន់យកពាក្យរបស់ពួកជនដែលប្រាថ្នានឹងទម្លាយ ហើយធ្វើកម្មដ៏ខ្លាំងក្លាបែបនេះទៀតឡើយ បពិត្រព្រះរាជកុមារទាំងឡាយ សូមទ្រង់ក៏កុំប្រទូស្តចំពោះព្រះរាជា លំដាប់នោះ ព្រះរាជាក៏ត្រាស់នឹងព្រះមហាសត្វថា បពិត្រលោកម្ចាស់ ខ្ញុំខុសក្នុងពួកព្រះរាជឱរសនិងព្រះទេវី ព្រោះបានអាស្រ័យអាមាត្យ

ទាំងនេះ វៀរលែងតែជឿពាក្យនិងស្ដាប់ពាក្យរបស់ជនទាំងនេះ ទើបធ្វើបាបកម្ម មានប្រមាណប៉ុណ្ណេះ ខ្ញុំនឹងសម្លាប់អាមាត្យទាំង ៥ នេះចោល ។ ព្រះមហាសត្វបង្អុលបង្ហាញថា ទ្រង់កុំធ្វើយ៉ាងនេះឡើយ ។ ព្រះរាជាត្រាស់ថា បើដូច្នោះ ខ្ញុំនឹងឲ្យកាត់ដៃនិងជើងរបស់ពួកគេ ។ ព្រះមហាសត្វក្រាបទូលថា សូម្បីកម្មយ៉ាងនេះក៏មិនគួរធ្វើ ។ ព្រះរាជាទទួលថា សាធុ ដូច្នេះហើយ ទ្រង់បញ្ជាឲ្យរឹបអូសទ្រព្យសម្បត្តិរបស់អាមាត្យនោះទាំងអស់ ហើយទ្រង់កោរសក់ទុកកំប៉ោយ ៥ ចងដោយឃ្នាងនិងលាបដោយគោម័យ ឲ្យបណ្ដេញចេញអំពីដែន ។ ព្រះពោធិសត្វស្នាក់នៅក្នុងទីនោះ ២-៣ ថ្ងៃ ហើយ ថ្វាយឱវាទដល់ព្រះរាជាថា សូមទ្រង់កុំប្រមាទ ដូច្នេះហើយ ក៏ត្រឡប់ទៅកាន់ហិមវន្តប្បទេសដូចមុន ធ្វើឈាននិងអភិញ្ញាឲ្យកើត ហើយចម្រើនព្រហ្មវិហារ ដរាបដល់អស់ជីវិត លុះអស់ជីវិត ក៏បានចូលដល់ព្រហ្មលោក ។

ព្រះសាស្ដា ទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្ដែងហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន តថាគតក៏ជាអ្នកមានបញ្ញា ញាំញីនូវវាទៈរបស់អ្នកដទៃបានដូចគ្នា ដូច្នេះហើយ ទ្រង់ប្រជុំជាតកថា អាមាត្យមេលទ្ធិទាំង ៥ ក្នុងកាលនោះ បានមកជាបូរណកស្សបៈ មក្ខលិគោសាល បកុធកច្ចានៈ អជិតកេសកម្ពល និងនិគណ្ឋនាដបុត្ត ក្នុងកាលឥឡូវនេះ ស្វាក្រហម ក្នុងកាលនោះ បានជាអានន្ទ ឯមហាពោធិបរិព្វាជក ក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា មហាពោធិជាតក ចប់**

**បញ្ញាសនិបាត ចប់**

# សដ្ឋិនិបាត សោណកជាតកទី ១

# សដ្ឋិនិបាតជាតក

## សោណកជាតក

[ ៦៦ ] ( ព្រះរាជាព្រះនាមអរិន្ទមៈ ទ្រង់ត្រាស់ថា ) អ្នកណាបានឮអញនឹងឲ្យទ្រព្យ ១ រយ អ្នកណាបានឃើញ សោណកៈ អញនឹងឲ្យទ្រព្យ ១ ពាន់ អ្នកណានឹងប្រាប់អញនូវសោណកៈជាសម្លាញ់ដែលលេងដីជាមួយគ្នា ។

( អភិសម្ពុទ្ធគាថា ) គ្រានោះ មាណពក្មេងមានជុក ៥ បានក្រាបបង្គំទូលថា ទូលព្រះបង្គំជាខ្ញុំបានឮ សូមព្រះអង្គប្រទានទ្រព្យ ១ រយ ទូលព្រះបង្គំជាខ្ញុំបានឃើញសោណកៈ សូមព្រះអង្គប្រទានទ្រព្យ ១ ពាន់ ទូលព្រះបង្គំជាខ្ញុំនឹងក្រាបទូលដល់ព្រះអង្គនូវសោណកៈជាសម្លាញ់ដែលលេងដីជាមួយគ្នា ។

[ ៦៧ ] ( ព្រះរាជា... ) សោណកៈនោះ នៅក្នុងជនបទណា ក្នុងដែនណា ក្នុងនិគមណា ឯងបានឃើញសោណកៈក្នុងទីណា អញសួរហើយ ឯងចូរប្រាប់ពីសោណកៈនោះ ។

[ ៦៨ ] ( កុមារ... ) បពិត្រព្រះសម្មតិទេព ត្រង់ទីឧទ្យានរបស់ព្រះអង្គក្នុងដែនរបស់ព្រះអង្គហ្នឹងឯង មានពួកឈើធំ មានដើមត្រង់ មានពន្លឺខៀវជាតម្រេកនៃចិត្ត ពួកឈើទាំងនោះ មានពណ៌ដូចផ្ទៃមេឃគួរឲ្យត្រេកអរ ដុះទាក់ទងគ្នាទៅវិញទៅមក កាលពួកសត្វលោកមានគ្រឿងធេះ កំពុងត្រូវភ្លើងធេះ សោណកៈមិនមានគ្រឿងធេះ ជាបុគ្គលរលត់ហើយ កំពុងចម្រើនឈាន

ជិតគល់ឈើទាំងនោះ ។

[ ៦៩ ] ( អភិសម្ពុទ្ធគាថា ) លំដាប់នោះ ព្រះរាជាទ្រង់ប្រើបម្រើឲ្យចាត់ចែងធ្វើផ្លូវរាបស្មើ យាងចេញទៅដោយសេនាមានអង្គ ៤ សំដៅទៅត្រង់កន្លែងដែលព្រះបច្ចេកពុទ្ធព្រះនាម សោណកៈគង់នៅ ។ លុះព្រះរាជាទ្រង់យាងទៅដល់ទីឧទ្យានហើយ ទ្រង់ត្រាច់ទៅក្នុងព្រៃធំ បានទតឃើញព្រះសោណកបច្ចេកពុទ្ធ កាលដែលពួកសត្វលោកកំពុងត្រូវភ្លើងឆេះ លោកជាបុគ្គលរលត់ គង់នៅហើយ ។

[ ៧០ ] ( ព្រះរាជា... ) ភិក្ខុត្រងោលដណ្តប់សង្ឃាដិ មិនមានមាតានេះ កំព្រាណាស់តើ ស្ងួតស្ងប់ជិតគល់ឈើ ។

[ ៧១ ] ( អភិសម្ពុទ្ធគាថា ) ព្រះសោណកៈបច្ចេកពុទ្ធ ស្តាប់ព្រះបន្ទូលនេះហើយ បានថ្វាយព្រះពរយ៉ាងនេះថា បពិត្រព្រះរាជា បុគ្គលដែលពាល់ត្រូវនូវធម៌ដោយកាយ មិនមែនឈ្មោះថាកំព្រាទេ ។ បុគ្គលណាក្នុងលោកនេះ លះធម៌ចោលហើយ ប្រព្រឹត្តតាមអធម៌វិញ បពិត្រព្រះរាជា បុគ្គលនោះ ទើបឈ្មោះថាកំព្រា ជាបុគ្គលអាក្រក់ជាទីសង្ឃឹមរបស់បុគ្គលអាក្រក់ ។

[ ៧២ ] ( ព្រះរាជា... ) ខ្ញុំឈ្មោះអរិន្ទម: អ្នកផងស្គាល់ខ្ញុំថា កាសិរាជ បពិត្រព្រះសោណកៈលោកដ៏ចម្រើនមកដល់ក្នុងទីនេះសិងនៅជាសុខទេឬ ។

[ ៧៣ ] ( ព្រះបច្ចេកពុទ្ធ... ) សេចក្តីចម្រើន ( តែងមាន ) ដល់ភិក្ខុមិនមានទ្រព្យ មិនមានផ្ទះសព្វកាលគឺ ( ទ្រព្យនិងធញ្ញជាតិទាំងឡាយ )

របស់ភិក្ខុទាំងនោះ លែងចូលទៅក្នុងជង្រុក លែងចូលទៅក្នុងថ្នាំង លែងចូលទៅក្នុងក្រឡោបីទៀតហើយ លោកមានវត្តល្អមានការស្វែងរកសម្រេចហើយ រមែងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយបិណ្ឌបាតនោះ ។ សេចក្តីចម្រើនទី ២ ( តែងមាន ) ដល់ភិក្ខុមិនមានទ្រព្យ មិនមានផ្ទះ គឺបរិភោគដុំបាយដែលមិនមានទោស កិលេសណាមួយបៀតបៀនមិនបានទេ ។ សេចក្តីចម្រើនទី ៣ ( តែងមាន ) ដល់ភិក្ខុមិនមានទ្រព្យ មិនមានផ្ទះ គឺឆាន់ដុំបាយដ៏ត្រជាក់ ( មិនជាថេយ្យបរិភោគជាដើម ) កិលេសណាមួយបៀតបៀនមិនបានទេ ។ សេចក្តីចម្រើនទី ៤ ( តែងមាន ) ដល់ភិក្ខុមិនមានទ្រព្យ មិនមានផ្ទះ គឺសេចក្តីជាប់ចំពាក់ មិនមានដល់ភិក្ខុដែលផុតស្រឡះ (ចាកត្រកូល ) ត្រាច់ទៅក្នុងដែន ។ សេចក្តីចម្រើនទី ៥ ( តែងមាន ) ដល់ភិក្ខុមិនមានទ្រព្យ មិនមានផ្ទះ គឺកាលបើនគរកំពុងត្រូវភ្លើងឆេះ វត្ថុបន្តិចបន្តួចរបស់ភិក្ខុនោះ ភ្លើងមិនឆេះទេ ។ សេចក្តីចម្រើនទី ៦ ( តែងមាន ) ដល់ភិក្ខុមិនមានទ្រព្យ មិនមានផ្ទះ កាលបើដែនកំពុងត្រូវចោរប្លន់ វត្ថុបន្តិចបន្តួចរបស់ភិក្ខុនោះ ចោរមិនលួចទេ ។ សេចក្តីចម្រើនទី ៧ ( តែងមាន ) ដល់ភិក្ខុមិនមានទ្រព្យ មិនមានផ្ទះ គឺភិក្ខុមានវត្តល្អ នាំយកបាត្រនិងចីវរដើរទៅកាន់ផ្លូវដែលពួកចោរនិងពួកគយដទៃ រក្សាដោយស្រួល ។ សេចក្តីចម្រើនទី ៨ ( តែងមាន ) ដល់ភិក្ខុមិនមានទ្រព្យ មិនមានផ្ទះ គឺភិក្ខុដើរទៅកាន់ទិសណាៗ ទៅបានដោយមិនបាននឹកនា ។

[ ៧៤ ] ( ព្រះរាជា... ) បពិត្រភិក្ខុ លោកសរសើរនូវសេចក្តីចម្រើន

របស់ភិក្ខុទាំងនោះច្រើនមែន បពិត្រព្រះសោណក: តែខ្ញុំជក់ចិត្តក្នុងកាមទាំងឡាយ តើនឹងធ្វើយ៉ាងណា ។ កាមទាំងឡាយជារបស់មនុស្ស ជាទីស្រឡាញ់របស់ខ្ញុំ មួយទៀត កាមជាទិព្វក៏ជាទីស្រឡាញ់របស់ខ្ញុំ បើដូច្នេះ តើយើងនឹងបាននូវកាមទាំងពីរក្នុងលោកដោយហេតុដូចម្តេច ។

[ ៧៥ ] ( ព្រះបច្ចេកពុទ្ធ... ) ពួកជនអ្នកជក់ចិត្តក្នុងកាម ត្រេកអរក្នុងកាម ងប់ក្នុងកាម រមែងធ្វើបាបទាំងឡាយ ហើយទៅកាន់ទុគ្គតិ ។ ចំណែកពួកជនណាលះបង់កាមហើយចេញទៅ មិនមានភ័យអំពីកិលេសណា បាននូវភាពជាបុគ្គលឯក ពួកជននោះ មិនទៅកាន់ទុគ្គតិ ។ បពិត្រព្រះអរិន្ទម អាត្មាភាពនឹងធ្វើសេចក្តីឧបមាថ្វាយព្រះអង្គ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ សេចក្តីឧបមានោះ ព្រោះពួកបណ្ឌិតខ្លះក្នុងលោកនេះ តែងយល់សេចក្តីដោយសារឧបមា ។ ក្អែកឥតប្រាជ្ញា ឥតសេចក្តីត្រិះរិះ ឃើញសាកសព ( ដំរី ) កំពុងអណ្តែតតាមទន្លេគង្គាទៅក្នុងសមុទ្រហើយគិតថា អែយ៉ា! អញបានយាននេះហើយផង ដំរីនេះនឹងបានជាចំណីអញយ៉ាងច្រើនផង ចិត្តរបស់ក្អែកនោះ ក៏ត្រេកអរក្នុងដំរីនោះទាំងថ្ងៃទាំងយប់ ។ ក្អែកចឹកស៊ីសាច់ដំរី ផឹកទឹកទន្លេគង្គា ឃើញព្រៃដែលគេសន្មតថាចេតិយ ក៏មិនហើរទៅ ។ ទន្លេគង្គាហូរទៅ បាននាំក្អែកនោះដែលប្រហែសធ្វេស ត្រេកអរក្នុងសាកសព ទៅកាន់សមុទ្រដែលមិនមែនជាទីទៅនៃបក្សី ។ សត្វហើរនោះអស់ចំណីរលីងហើយ ក៏ហើរឡើងទៅទិសខាងលិចមិនរួច ទៅទិសខាងកើតមិនរួច ទៅទិសខាងជើងមិនរួច ទៅទិសខាងត្បូងមិនរួច ។ ក្អែកនោះទៅកាន់សមុទ្រ ដែលមិនមែនជាទីទៅនៃ

ពួកបក្សី ក៏មិនបានទូវទីពឹងធ្លាក់ទៅក្នុងសមុទ្រនោះឯង ដូចជាបុគ្គលមានកម្លាំងថយ ។ ពួកត្រី ក្រពើ មករ ធ្លាម ដែលកើតក្នុងសមុទ្រ ក៏ហែងខាំក្អែកនោះ ដែលមានស្លាបរបោចហើយ កំពុងបម្រះ ( យ៉ាងណាមិញ ) ។ បពិត្រព្រះរាជា ព្រះអង្គនឹងពួកជនដទៃអ្នកបរិភោគកាមក៏យ៉ាងនោះដែរ បើពួកជនដែលជក់ចិត្តហើយមិនខ្ជាក់ ( កាម ) ចោលចេញទេ បណ្ឌិតទាំងឡាយ ( ស្គាល់ ) ពួកជននោះ ( ថាមានប្រាជ្ញាស្មើ ) ដោយប្រាជ្ញារបស់ក្អែក ។ បពិត្រព្រះរាជា ឧបមាជាគ្រឿងបំភ្លឺនូវសេចក្ដីនេះ អាត្មាភាពបានធ្វើថ្វាយព្រះអង្គហើយ បើព្រះអង្គធ្វើឬមិនធ្វើ ព្រះអង្គនឹងប្រាកដតាមហេតុនោះ ។

[ ៧៦ ] បុគ្គលអ្នកឈឺឆ្អាល គប្បីនិយាយត្រឹមតែមួយម៉ាត់ឬពីរម៉ាត់ មិនគប្បីនិយាយឲ្យលើសហួសពីនោះទៅ ដូចទាសៈនិយាយក្នុងសំណាក់នៃម្ចាស់ ។

[ ៧៧ ] ( ព្រះអភិសម្ពុទ្ធគាថា ) លុះព្រះសោណកៈបច្ចេកពុទ្ធមានប្រាជ្ញារាប់មិនបាន ពោលពាក្យនេះប្រៀនប្រដៅក្សត្រហើយ ទើបចៀសចេញទៅឰដ៏អាកាសវេហាស៍ ។

[ ៧៨ ] ( ព្រះរាជា... ) ពួកជនអ្នករៀបចំអភិសេក បុគ្គលដែលគួរដល់រាជ្យជាអ្នកបន្តក់ប្រសិទ្ធនេះ ចាំស្មាត់នៅក្នុងទីណា អញនឹងប្រគល់រាជ្យឲ្យ អញមិនត្រូវការដោយរាជ្យទេ ។ អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹងថា សេចក្ដីស្លាប់នឹងមានក្នុងថ្ងៃស្អែក អញលែងលុះក្នុងអំណាចនៃកាមទាំងឡាយ ដូចជាក្អែកធោតហើយ ។

[ ៧៩ ] ( ពួកអាមាត្យ... ) ព្រះរាជបុត្តរបស់ព្រះអង្គ ព្រះនាមទីឃាវុនៅក្មេង ជាអ្នកញ៉ាំងដែនឲ្យចម្រើន សូមព្រះអង្គ អភិសេកព្រះរាជបុត្តនោះក្នុងរាជ្យចុះ ព្រះរាជបុត្តនោះនឹងបានជាព្រះរាជារបស់យើងខ្ញុំ ។

[ ៨០ ] ( ព្រះរាជា... ) អ្នកទាំងឡាយ ចូរនាំយកកុមារ ឈ្មោះទីឃាវុ អ្នកញ៉ាំងដែនឲ្យចម្រើនមកឲ្យឆាប់ អញនឹងអភិសេកកុមារនោះក្នុងរាជ្យ កុមារនោះនឹងជាព្រះរាជារបស់អ្នកទាំងឡាយ ។

[ ៨១ ] ( អភិសម្ពុទ្ធគាថា ) លំដាប់នោះ ពួកអាមាត្យ ក៏បាននាំកុមារឈ្មោះទីឃាវុ អ្នកញ៉ាំងដែនឲ្យចម្រើនមកថ្វាយ ព្រះរាជាទតឃើញទីឃាវុកុមារនោះ ជាបុត្តតែមួយ ជាទីត្រេកអរ ពេញព្រះទ័យហើយ ទ្រង់ត្រាស់ថា នែបុត្ត ស្រុកទាំង ៦០.០០០ បរិបូណ៌ដោយវត្ថុទាំងពួង ចូរបាថែទាំស្រុកទាំងនោះចុះ អញនឹងប្រគល់រាជ្យដល់បា ។ អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញ លុះក្នុងអំណាចនៃកាមទាំងឡាយ ដូចជាក្អែកឆោតឡើយ ។ ដំរី ៦០.០០០ ស្អិតស្អាងដោយគ្រឿងប្រដាប់គ្រប់យ៉ាង មានខ្សែជង្គន់ ធ្វើអំពីមាស បិតបាំងដោយកម្រាលដែលធ្វើអំពីមាស ជាដំរីកើតក្នុងព្រៃមាតង្គៈ ។ ដំរីណាដែលពួកហ្មដំរីមានដៃកាន់អាវុធនិងកង្វេរឡើងជិះ នែបុត្ត អ្នកចូរថែទាំពួកដំរីទាំងនោះចុះ អញប្រគល់រាជ្យដល់អ្នក ។ អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញ លុះក្នុងអំណាចនៃកាមទាំងឡាយដូចជាក្អែកឆោតឡើយ ។ សេះ ៦០.០០០ ស្អិតស្អាងដោយគ្រឿង

ប្រដាប់គ្រប់យ៉ាង ជាសេះអាជានីយជោយកំណើត ជាសេះសិន្ធវៈ ជាពាហនៈ យ៉ាងលឿន ដែលពួកសារថីកាន់សៀនិងធ្នូជិះ នែបុត្ត បាចូរថែទាំសេះទាំងនោះចុះ អញប្រគល់រាជ្យដល់បា ។ អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញ លុះក្នុងអំណាចនៃកាមទាំងឡាយ ដូចជាក្អែកចោតឡើយ ។ រថ ៦០.០០០ ដែលគេទឹមហើយ ជោតទង់ជ័យ ស្រោបជោយស្បែកខ្លាដំបង ស្រោបជោយស្បែកខ្លាធំ ស្អិតស្អាងជោយគ្រឿងប្រដាប់គ្រប់យ៉ាង ។ អ្នកបររថមានដៃកាន់ធ្នូ សៀតខែលហើយឡើងជិះ នែបុត្ត បាចូរថែទាំរថទាំងនោះចុះ អញប្រគល់រាជ្យដល់បា ។ អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញលុះក្នុងអំណាចនៃកាមទាំងឡាយ ដូចជាក្អែកចោតឡើយ ។ មេគោ ៦០.០០០ ជាមេគោក្រហមប្រកបជោយគោឈ្មោល ( គោបា ) នែបុត្ត បាចូរថែទាំមេគោទាំងនោះចុះ អញប្រគល់រាជ្យដល់បា ។ អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹងថាសេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញ លុះក្នុងអំណាចនៃកាមទាំងឡាយ ដូចជាក្អែកចោតឡើយ ។ ស្រ្តី ១៦.០០០ ស្អិតស្អាងជោយគ្រឿងប្រដាប់គ្រប់យ៉ាង មានសំពត់និងអាភរណៈដ៏វិចិត្រ ពាក់កុណ្ឌលកែវមណី នែបុត្ត បាចូរថែទាំស្រ្តីទាំងនោះចុះ អញប្រគល់រាជ្យដល់បា ។ អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញលុះក្នុងអំណាចនៃកាមទាំងឡាយ ដូចជាក្អែកចោតឡើយ ។

[ ៨២ ] ( ព្រះរាជកុមារ... ) បពិត្រព្រះវរបិតា កាលដែលទូល

ព្រះបង្គំជាខ្ញុំ នៅក្មេងនៅឡើយ ទូលព្រះបង្គំជាខ្ញុំបានឮថា ព្រះវរមាតាទ្រង់សោយទិវង្គតទៅហើយ បពិត្រព្រះវរបិតា ទូលព្រះបង្គំជាខ្ញុំ ព្រាត់ប្រាសចាកព្រះអង្គហើយ មិនអាចនឹងរស់នៅបានទេ ។ កូនដំរីរមែងទៅតាមក្រោយដំរីដែលនៅក្នុងព្រៃ ដើរទៅក្នុងជង្ហុកនៃភ្នំទាំងឡាយដែលរាបស្មើនិងមិនរាបស្មើ យ៉ាងណាមិញ ។ ទូលព្រះបង្គំជាខ្ញុំ នាំយកកូនទៅតាមព្រះអង្គ ក៏យ៉ាងនោះដែរ ទូលព្រះបង្គំជាខ្ញុំ ជាបុគ្គលព្រះអង្គចិញ្ចឹមងាយ ពុំមែនព្រះអង្គពិបាកចិញ្ចឹមឡើយ ។

[ ៨៣ ] ( ព្រះរាជា... ) សត្រូវជាអ្នកបំផ្លាញ គប្បីចាប់សំពៅដែលដើរក្នុងសមុទ្ទ របស់ពួកពាណិជ ដែលស្វែងរកទ្រព្យក្នុងសមុទ្ទនោះ ពួកពាណិជត្រូវវិនាស យ៉ាងណាមិញ នែកូនលាមក ឯងនេះធ្វើសេចក្តីអន្តរាយដល់អញ ក៏យ៉ាងនោះដែរ ។

[ ៨៤ ] អ្នកទាំងឡាយ ចូរញុំាងកុមារនេះឲ្យដល់ប្រាសាទ ដែលញុំាងតម្រេកឲ្យចម្រើន ក្នុងប្រាសាទនោះមានពួកស្រ្តីមានដៃស្អិតស្អាងដោយគ្រឿងអាភរណៈធ្វើអំពីមាស ស្រ្តីទាំងនោះនឹងត្រេកអរចំពោះកុមារនោះ ក្នុងប្រាសាទនោះដូចជាពួកស្រីអប្សរត្រេកអរនឹងសក្កទេវរាជ កុមារនុ៎ះនឹងត្រេកអរដោយស្រ្តីទាំងនោះ ។

[ ៨៥ ] ( អភិសម្ពុទ្ធគាថា ) លំដាប់អំពីនោះមក ពួកអាមាត្យបានញុំាងកុមារឲ្យដល់ប្រាសាទដែលញុំាងតម្រេកឲ្យចម្រើន ឯពួកនាងកញ្ញាឃើញទីឃាវុកុមារនោះ ជាអ្នកញុំាងដែនឲ្យចម្រើនហើយ ក៏បានពោលថា

លោកជាទេវតា ឬជាគន្ធព្វ ឬក៏ជាព្រះឥន្ទឈ្មោះបុរិន្ទទៈ លោកជាអ្វី ជាបុត្ត នៃអ្នកណា ធ្វើដូចម្តេច យើងនឹងអាចស្គាល់លោកបាន ។

[ ៨៦ ] ( ព្រះរាជកុមារ... ) យើងមិនមែនជាទេវតា មិនមែនជាគន្ធព្វ ទាំងមិនមែនជាព្រះឥន្ទឈ្មោះបុរិន្ទទទេ យើងជាកូននៃព្រះរាជាក្នុងដែនកាសី ឈ្មោះទីឃាវុ ជាអ្នកញុំាងដែនឲ្យចម្រើន នាងទាំងឡាយ ចូរប្រាប់ថាយើងចុះ សេចក្តីចម្រើននឹងមានដល់ពួកនាងទាំងឡាយ យើងជាកស្តារបស់ពួកនាង ។

[ ៨៧ ]( អភិសម្ពុទ្ធគាថា ) ពួកនាងកញ្ញា បានទូលសួរ ទីឃាវុកុមារ នោះ ដែលញុំាងដែនឲ្យចម្រើនក្នុងប្រាសាទនោះថា ព្រះរាជាស្តេចយាងទៅក្នុង ទីណា ព្រះរាជាស្តេចចេញអំពីទីនេះ ទៅក្នុងទីណា ។

[ ៨៨ ] ( ព្រះរាជកុមារ... ) ព្រះរាជាទ្រង់បានឈានកន្លងភក់ ( រាគាទិក្កិលេស ) ព្រះរាជាទ្រង់បានឋិតនៅស៊ប់លើគោក ( ផ្លូស ) ទ្រង់យាង ទៅកាន់ផ្លូវធំ ( ជាទីទៅកាន់សួគ៌និងព្រះនិព្វាន ) ដែលមិនមានបន្លា មិន មានព្រៃញាតស្បាត ( រាគៈ ) ។ ចំណែកយើង ជាអ្នកដើរទៅកាន់ផ្លូវជា ទីទៅកាន់ទុគ្គតិ ប្រកបដោយបន្លា ប្រកបដោយព្រៃញាតស្បាត សម្រាប់ទៅ កាន់ទុគ្គតិរបស់ពួកសត្វ ។

[ ៨៩ ] ( ពួកនាងកញ្ញា... ) បពិត្រព្រះរាជា ព្រះអង្គនោះយាង មកល្អហើយ ហាក់ដូចជាសីហៈដែលមកកាន់គិរិព្វជៈ ( គុហាមាស ) បពិត្រ មហារាជ សូមព្រះអង្គគ្រប់គ្រងចុះ ព្រះអង្គជាម្ចាស់របស់ពួកខ្ញុំម្ចាស់ទាំងអស់ គ្នា ។

**ចប់ សោណកជាតក ទី ១**

# សដ្ឋិនិបាត

## អដ្ឋកថា សោណកជាតក

[ ៦៦-៨៩ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនេក្ខម្មបារមី ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កស្ស សុត្វា សតំ ទម្មិ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ក្នុងកាលនោះ ព្រះមានព្រះភាគ ទ្រង់គង់កណ្តាលនៃភិក្ខុទាំងឡាយ ដែលកំពុងពណ៌នាដល់នេក្ខម្មបារមី ក្នុងធម្មសភា ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតចេញមហាភិនេស្ក្រមណ៍តែក្នុងកាលឥឡូវនេះក៏មិនមែន សូម្បីក្នុងកាលមុន តថាគតក៏បានចេញមហាភិនេស្ក្រមណ៍ហើយដូចគ្នា ដូច្នេះហើយ ទើបទ្រង់នាំអតីតនិទានមកត្រាស់ថា

ក្នុងអតីតកាលស្តេចផែនដីនៃដែនមគធៈ ទ្រង់សោយរាជសម្បត្តិក្នុងក្រុងរាជគ្រឹះ ព្រះពោធិសត្វកើតក្នុងព្រះឧទររបស់អគ្គមហេសី នៃស្តេចផែនដីអង្គនោះ ។ ក្នុងថ្ងៃថ្វាយព្រះនាមព្រះជនកនិងព្រះជននី បានថ្វាយព្រះនាមព្រះឱរសនោះថា អរិន្ទមកុមារ ។ បុត្ររបស់បុរោហិតក៏បានប្រសូតក្នុងថ្ងៃដែលព្រះរាជកុមារនោះប្រសូតហើយដូចគ្នា ឪពុកម្តាយ បានដាក់ឈ្មោះកូននោះថា សោណកកុមារ ។ ព្រះរាជកុមារនិងកុមារទាំង ២ នោះ ចម្រើនវ័យដូចគ្នា កាលចម្រើនវ័យហើយ ជាអ្នកមានរូបស្អាត ជាអ្នកពិសេសដោយរូប បានទៅកាន់នគរតក្កសិលា រៀនសិល្បសាស្ត្រហូតចប់ ហើយចេញអំពីនគរតក្កសិលានោះ នាំគ្នាគិតថា យើងទាំង ២ នឹងសិក្សាឲ្យចេះដល់សិប្បៈក្នុង

លទ្ធិទាំងអស់ និងប្រទេសជាទីត្រាច់ទៅ ដូច្នេះហើយ ទើបនាំគ្នាចារិកទៅដោយលំដាប់ រហូតដល់ក្រុងពារាណសី ស្នាក់នៅក្នុងព្រះរាជឧទ្យាន លុះថ្ងៃស្អែកឡើង ទើបនាំគ្នាចូលទៅកាន់ព្រះនគរ ។ ក្នុងថ្ងៃនោះ មនុស្សពួកខ្លះនាំគ្នាគិតថា ពួកយើងនឹងធ្វើទីសូចម្រមន្តរបស់ព្រាហ្មណ៍ ទើបរៀបចំបាយាសក្រាលសេនាសនៈ ឃើញកុមារទាំង ២ នោះដើរមក ទើបអញ្ជើញឲ្យចូលទៅក្នុងផ្ទះហើយឲ្យអង្គុយលើអាសនៈដែលខ្ជូនត្រៀមទុក ។ លើអាសនៈទាំង ២ នោះ គេក្រាលសំពត់ដែលនាំមកអំពីដែនកាសី មានពណ៌សស្អាត សម្រាប់ព្រះពោធិសត្វ ។ ក្រាលសំពត់កម្ពលពណ៌ក្រហមសម្រាប់សោណកកុមារ ។ កុមារនោះ សម្លឹងមើលគ្រឿងសម្គាល់ ក៏ដឹងថា ក្នុងថ្ងៃនេះឯង អរិន្ទមកុមារសម្លាញ់ជាទីស្រឡាញ់របស់អញនឹងបានជាព្រះរាជា គ្រប់គ្រងព្រះនគរពារាណសី នឹងព្រះរាជទានតំណែងសេនាបតីដល់អញ ។ កុមារទាំង ២ នោះធ្វើភត្តកិច្ចស្រេចហើយ ក៏បាននាំគ្នាទៅកាន់ឧទ្យាននោះឯង ។ ក្នុងកាលនោះជាថ្ងៃដែលព្រះបាទក្រុងពារាណសីសោយទិវង្គតអស់ ៧ ថ្ងៃមកហើយ រាជត្រកូលមិនមានរាជឱរស មហាជនទាំងឡាយ មានអាមាត្យជាប្រធាន កក់សក់ហើយប្រជុំគ្នា ត្រៀមបុស្សរថផ្សងទៅ ដោយគិតថា បុស្សរថនឹងទៅរកបុគ្គលដែលគួរដល់ព្រះរាជសម្បត្តិ ។ បុស្សរថនោះចេញអំពីព្រះនគរទៅកាន់ឧទ្យានដោយលំដាប់ ត្រង់ទ្វារឧទ្យាន ហើយឈប់រង់ចាំទទួលលោកអ្នកដែលគួរគ្រប់គ្រងរាជសម្បត្តិ ។

ព្រះពោធិសត្វបានផ្ទំទទូរក្បាលលើផ្ទាំងថ្មដែលជាមង្គលហើយសោណក

កុមារអង្គុយនៅក្បែរព្រះពោធិសត្វនោះ ។ សោណកកុមារនោះ បានឮសំឡេងតន្ត្រី ទើបត្រិះរិះថា បុស្សរថមកដើម្បីអភិសេកកុមារ ថ្ងៃនេះ ទ្រង់នឹងបានជាព្រះរាជា នឹងព្រះរាជទានតំណែងសេនាបតីឲ្យដល់អញ តែអញមិនត្រូវការដោយឥស្សរិយយសឡើយ កាលព្រះរាជកុមារនេះយាងទៅហើយ អញនឹងចេញបួស ដូច្នេះ ទើបឈរពួនក្នុងទីមួយកន្លែង ។ បុរោហិតចូលទៅកាន់ឧទ្យាន ឃើញមហាសត្វកំពុងផ្ទំ ទើបឲ្យភ្នាក់ងារប្រគំតន្ត្រីឡើង ។ ព្រះមហាសត្វភ្ញាក់ឡើងប្រែខ្លួន ក៏ផ្ទំបន្តទៅទៀតបន្តិច ទើបក្រោកឡើង អង្គុយពត់ភ្នែនត្រង់ផ្ទាំងថ្ម ។ លំដាប់នោះ បុរោហិតផ្គងអញ្ជលី ក្រាបទូលថា បពិត្រព្រះសម្មតិទេព រាជសម្បត្តិមកដល់ទ្រង់ហើយ ។ ព្រះមហាសត្វសួរថា រាជត្រកូលមិនមានព្រះរាជឱរសឬ បុរោហិតទូលថា ដូច្នោះឯង ព្រះអង្គ ។ ព្រះមហាសត្វទទួលថា បើដូច្នោះ ជាការល្អ ។ លំដាប់នោះ មហាជនទាំងឡាយ ក៏នាំគ្នាអភិសេកព្រះមហាសត្វនោះក្នុងឧទ្យាននោះឯង ហើយយាងឲ្យទ្រង់ឡើងលើរថ ត្រឡប់ចូលកាន់ព្រះនគរដោយបរិវារធំ ។ ព្រះមហាសត្វនោះ ទ្រង់ធ្វើប្រទក្សិណព្រះនគរហើយ ទ្រង់ឡើងកាន់ប្រាសាទ ទ្រង់មិនបានរឭកដល់សោណកកុមារ ព្រោះមានឥស្សរិយយសធំ។ឯសោណកកុមារ នោះកាលព្រះពោធិសត្វចូលកាន់ព្រះនគរហើយ ខ្លួនឯងក៏មកអង្គុយត្រង់ផ្ទាំង ថ្ម ។ គ្រានោះ ស្លឹកឈើពណ៌លឿងរបស់សាលព្រឹក្ស រុះរោយចាកទងធ្លាក់ចុះមកចំពោះមុខរបស់កុមារនោះ ។ លុះសោណកកុមារ បានឃើញស្លឹកឈើទុំនោះហើយ ទើបគិតថា ស្លឹកឈើនោះជ្រុះយ៉ាងណា សូម្បីសរីរៈរបស់អញ

ក៏នឹងដល់នូវការជរាជ្រុះទៅយ៉ាងនោះ ដូច្នេះហើយ ទើបផ្តើមវិបស្សនាដោយសាមញ្ញលក្ខណៈ មានអនិច្ចលក្ខណៈជាដើម សម្រេចបច្ចេកពោធិញ្ញាណហើយ ។ ក្នុងខណៈនោះ យាវាសភេទរបស់កុមារនោះក៏អន្តរធានទៅ ភេទបព្វជិតក៏បានប្រាកដជំនួស ។ ព្រះបច្ចេកពុទ្ធអង្គនោះ កាលបន្លឺឧទាន ក៏បន្លឺឧទានថា ឥឡូវនេះ ភពថ្មីរបស់អញមិនមានឡើយ ដូច្នេះហើយ ទើបបានទៅកាន់ញកភ្នំឈ្មោះ នន្ទមូលកៈ ។

ឯព្រះមហាសត្វ ទ្រង់រឭកដល់ព្រះបច្ចេកពុទ្ធនោះបាន ដោយកន្លងទៅប្រមាណ ៤០ ឆ្នាំ ទ្រង់រឭកដល់សោណកៈរឿយៗថា សោណកសម្លាញ់របស់អញទៅណាហ្ន៎ មិនបានដំណឹងដែលអ្នកណានឹងពោលថា ខ្ញុំបានឮដំណឹង ឬខ្ញុំបានឃើញឡើយ ។ ព្រះរាជាប្រថាប់គង់លើព្រះរាជបល្ល័ង្កដែលមានផ្ទៃធំទូលាយដែលប្រដាប់តាក់តែងហើយ ជាបុគ្គលដែលពួកជនប្រគំរាំច្រៀងចោមរោមហើយ សោយរាជសម្បត្តិ ទ្រង់ព្រះតម្រិះថា បុគ្គលណាបានឮក្នុងសម្នាក់នៃបុគ្គលណាម្នាក់ ហើយប្រាប់ដល់យើងថា សោណកកុមារនៅក្នុងទីឈ្មោះនោះ ដូច្នេះ យើងនឹងឲ្យទ្រព្យ ១០០ ដល់បុគ្គលនោះ បុគ្គលណាឃើញដោយខ្លួនឯងហើយ ប្រាប់ដល់យើង យើងនឹងឲ្យទ្រព្យ ១០០០ ដល់បុគ្គលនោះ ដូច្នេះហើយ ទ្រង់និពន្ធឧទានឡើងមួយបទ កាលនឹងទ្រង់បន្លឺដោយទំនងបទចម្រៀង ទើបត្រាស់គាថាទី ១ ថា

អ្នកណាបានឮ អញនឹងឲ្យទ្រព្យ ១ រយ អ្នកណាបានឃើញ
សោណកៈ អញនឹងឲ្យទ្រព្យ ១ ពាន់ អ្នកណានឹងប្រាប់អញ

នូវសោណកៈជាសម្លាញ់ដែលលេងដីជាមួយគ្នា ដូច្នេះ ។

លំដាប់នោះ ស្រីអ្នកបម្រើម្នាក់ ចាំឧទាននោះបាន ដូចធ្លាក់ចុះអំពីព្រះឱស្ឋរបស់ព្រះរាជានោះ ទើបច្រៀងជាបទចម្រៀង ។ ស្រីដទៃៗ ក៏ច្រៀងចម្រៀងនោះតៗគ្នាមកជាលំដាប់ រហូតដល់ស្រីស្នំទាំងអស់ ក៏បានច្រៀងបទនោះដោយនាំគ្នាគិតថា បទចម្រៀងនេះ ជាបទចម្រៀងដែលព្រះរាជារបស់យើងទ្រង់ប្រោសប្រាណ ដោយប្រការដូច្នេះ ។ សូម្បីអ្នកនគរ និងអ្នកជនបទ ក៏បាននាំគ្នាច្រៀងនូវចម្រៀងនោះដោយលំដាប់ដូចគ្នា ។ សូម្បីព្រះរាជាក៏ទ្រង់ច្រៀងនូវចម្រៀងនោះរឿយៗ ដូចគ្នា លុះកន្លងទៅអស់កាល ៥០ ឆ្នាំ ព្រះរាជាអង្គនោះ ក៏មានព្រះរាជឱរសនិងព្រះរាជធីតាច្រើន ព្រះឱរសច្បង ព្រះនាមថាទីឃាវុកុមារ ។ ក្នុងកាលនោះ ព្រះសោណកបច្ចេកពុទ្ធប្រាថ្នានឹងឃើញព្រះបាទអរិន្ទមរាជ ទើបគិតថា អញនឹងសម្តែងដល់ទោសក្នុងកាម និងអានិសង្សក្នុងការចេញបួស ហើយនឹងចន្លុលបង្ហាញឲ្យព្រះរាជាអង្គនោះទ្រង់ចេញបួស ដូច្នេះ ទើបហោះមកតាមអាកាសដោយឫទ្ធិ ហើយគង់ក្នុងឧទ្យាន ។ ក្នុងកាលនោះ កុមារដែលមានជុក ៥ អាយុ ៧ ឆ្នាំម្នាក់ ត្រូវម្តាយប្រើឲ្យរកឧស ក្នុងព្រៃក្បែរឧទ្យាន ក៏ច្រៀងចម្រៀងនោះរឿយៗយ៉ាងនោះ ។ លំដាប់នោះ ព្រះបច្ចេកពុទ្ធហៅកុមារនោះមកសួរថា នែកុមារ ហេតុអ្វី ទើបអ្នកមិនច្រៀងបទដទៃខ្លះ ច្រៀងតែបទដដែលប៉ុណ្ណោះ អ្នកមិនចេះបទដទៃខ្លះទេឬ ។ កុមារនោះ ឆ្លើយថា បទដទៃក៏ចេះ តែបទនេះជាទីគាប់ព្រះរាជហឫទ័យនៃព្រះរាជាពួកខ្ញុំ ព្រោះដូច្នោះ ទើបខ្ញុំច្រៀងនូវបទចម្រៀងនោះរឿយៗ ។ ព្រះបច្ចេកពុទ្ធសួរថា អ្នក

ធ្លាប់ឃើញបុគ្គលណាម្នាក់ច្រៀងឆ្លើយនឹងបទចម្រៀងនេះខ្លះដែរឬទេ កុមារឆ្លើយថា មិនធ្លាប់ឃើញទេលោកម្ចាស់ ព្រះបច្ចេកពុទ្ធពោលថា យើងនឹងបង្រៀនឲ្យឯងរៀនច្រៀងនូវចម្លើយនោះ ឯងអាចទៅកាន់សម្នាក់របស់ព្រះរាជា ហើយច្រៀងឆ្លើយឆ្លងដែរឬទេ ។ កុមារនោះឆ្លើយថា អាចលោកម្ចាស់ ។ លំដាប់នោះ ព្រះសោណកបច្ចេកពុទ្ធនោះ កាលបង្រៀនចម្រៀងសម្រាប់ឆ្លើយដល់កុមារនោះ ទើបពោលគាថាថា **មយ្ហំ សុត្វា** ដូច្នេះជាដើម ។ កាលឲ្យរៀនហើយ ទើបបញ្ជូនកុមារនោះទៅដោយពាក្យថា នែកុមារ ចូរឯងទៅច្រៀង បទនេះឆ្លើយជាមួយនឹងព្រះរាជា ព្រះរាជានឹងព្រះរាជទានឥស្សរិយយសធំ ដល់ឯង ឯងត្រូវការអ្វីដោយឧស ចូរប្រញាប់ទៅចុះ ។

កុមារនោះទទួលថា សាធុ រៀននូវចម្រៀងសម្រាប់ឆ្លើយហើយ ថ្វាយបង្គំព្រះបច្ចេកពុទ្ធពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់នៅក្នុងទីនេះទម្រាំខ្ញុំនាំព្រះរាជាមក ដូច្នេះហើយ ប្រញាប់ទៅជួបមាតាពោលថា បពិត្រអ្នកម៉ែ សូមម៉ែងូតទឹកឲ្យខ្ញុំ ហើយតែងខ្លួនខ្ញុំឲ្យរហ័ស ថ្ងៃនេះ ខ្ញុំនឹងជួយម៉ែ ឲ្យផុតអំពីភាពក្រីក្រ កាលមាតាងូតទឹក តែងខ្លួនឲ្យហើយ ទើបមកកាន់ទ្វារព្រះរាជវាំង ហើយពោលថា បពិត្រលោកទ្វារបាល សូមលោកទៅក្រាបទូលដល់ព្រះរាជាថា មានក្មេងម្នាក់មកពោលថា ខ្ញុំនឹងច្រៀងតបជាមួយទ្រង់ឈរចាំត្រង់ទ្វារព្រះរាជវាំង ។ នាយទ្វារបាលប្រញាប់ទៅក្រាបទូលដល់ព្រះរាជា ព្រះរាជាក៏ត្រាស់ឲ្យហៅកុមារមកថា ឲ្យគេចូលមកចុះ ហើយត្រាស់ថា នែបាឯងនឹងច្រៀងឆ្លើយឆ្លងជាមួយយើងឬ កុមារក្រាបទូលថា ដូច្នោះឯងព្រះអង្គ ។

ព្រះរាជាត្រាស់ថា បើដូច្នោះ ចូរឯងច្រៀងចុះ កុមារនោះក្រាបទូលថា បពិត្រព្រះអង្គ ទូលព្រះបង្គំច្រៀងក្នុងទីនេះមិនបាន សូមទ្រង់ឲ្យពួករាជបុរសវាយស្គរប្រកាសក្នុងនគរ ហើយឲ្យមហាជនប្រជុំគ្នា ទូលព្រះបង្គំនឹងច្រៀងក្នុងកណ្ដាលមហាជន ។ ព្រះរាជាឲ្យធ្វើតាមដែលកុមារនោះពោល ទ្រង់ប្រថាប់គង់កណ្ដាលរាជបល្ល័ង្ក ក្នុងមណ្ឌបដែលគេតាក់តែងហើយ ឲ្យព្រះរាជទានអាសនៈដែលសមគួរដល់កុមារនោះ ហើយត្រាស់ថា ឥឡូវនេះ ឯងអាចច្រៀងចម្រៀងរបស់ឯងបានហើយ ។ កុមារនោះក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់ច្រៀងមុន ទូលបង្គំនឹងច្រៀងតបក្នុងកាលឯក្រោយ ។ គ្រានោះ ព្រះរាជាកាលទ្រង់ច្រៀងមុន ទើបត្រាស់ថា

អ្នកណាបានឮ អញនឹងឲ្យទ្រព្យ ១ រយ អ្នកណាបានឃើញ
សោណកៈ អញនឹងឲ្យទ្រព្យ ១ ពាន់ អ្នកណានឹងប្រាប់អញ
នូវសោណកៈជាសម្លាញ់ដែលលេងដីជាមួយគ្នា ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សុត្វា** សេចក្ដីថា យើងនឹងឲ្យទ្រព្យមួយរយដល់បុគ្គលណាដែលបានឮទីលំនៅរបស់សោណកៈនោះ ហើយមកប្រាប់ថា សោណកៈសម្លាញ់របស់ទ្រង់នៅក្នុងទីឈ្មោះនោះ ។ បទថា **ទិដ្ឋំ** សេចក្ដីថា យើងនឹងឲ្យទ្រព្យមួយពាន់ដល់អ្នកណាដែលឃើញសោណកៈ ហើយមកប្រាប់ថា ខ្ញុំឃើញសោណកៈក្នុងទីឈ្មោះនោះ ដូច្នេះ ។ កាលព្រះរាជាទ្រង់ច្រៀងឧទានគាថាទី ១ យ៉ាងនេះហើយ ព្រះសាស្ដាកាលទ្រង់ត្រាស់ដឹងឯងដោយចំពោះ ទ្រង់ប្រកាសគាថា ដែលកុមារមានជុក ៥ ច្រៀងតប ទើបត្រាស់

គាថា ២ ថា

គ្រានោះ មាណពក្មេងមានជុក ៥ បានក្រាបបង្គំទូលថា ទូលព្រះបង្គំជាខ្ញុំបានឮ សូមព្រះអង្គប្រទានទ្រព្យ ១ រយ ទូលព្រះបង្គំជាខ្ញុំបានឃើញសោណកៈ សូមព្រះអង្គប្រទានទ្រព្យ ១ ពាន់ ទូលព្រះបង្គំជាខ្ញុំនឹងក្រាបទូលដល់ព្រះអង្គនូវ សោណកៈជាសម្លាញ់ដែលលេងដីជាមួយគ្នា ដូច្នេះ ។

អត្ថនៃគាថាដែលកុមារនោះពោលហើយ មានអធិប្បាយដូចតទៅនេះថា បពិត្រមហារាជ ទ្រង់ត្រាស់ថា យើងនឹងឲ្យទ្រព្យដល់អ្នកដែលបានឮដំណឹងនោះ ហើយមកប្រាប់ដល់យើង ដូច្នេះ សូមទ្រង់ព្រះរាជទានទ្រព្យនោះដល់ទូលព្រះបង្គំ ម្យ៉ាងទៀត ទ្រង់ត្រាស់ថា យើងនឹងឲ្យទ្រព្យមួយពាន់ដល់អ្នកដែលឃើញ ហើយមកប្រាប់ ដូច្នេះ សូមទ្រង់ព្រះរាជទានទ្រព្យនោះដល់ទូលព្រះបង្គំ ព្រោះទូលបង្គំឃើញសម្លាញ់ជាទីស្រឡាញ់របស់ទ្រង់ ទើបបានទូលទ្រង់ថា ឥឡូវនេះ ទូលព្រះបង្គំបានឃើញសោណកៈនោះហើយ ។ អត្ថបន្តអំពីនេះទៅ បណ្ឌិតយល់បានងាយហើយ ។ បណ្ឌិតគប្បីជ្រាបព្រះគាថារបស់ព្រះសម្មាសម្ពុទ្ធ ដោយន័យព្រះបាលីនោះឯង ។ ព្រះរាជាទ្រង់ស្តាប់ពាក្យនោះហើយ ត្រាស់សួរថា

សោណកៈនោះ នៅក្នុងជនបទណា ក្នុងដែនណា ក្នុងនិគមណា ឯងបានឃើញសោណកៈក្នុងទីណា អញសួរហើយ ឯងចូរប្រាប់ពីសោណកៈនោះ ដូច្នេះ ។

កុមារក្រាបទូលថា

បពិត្រព្រះសម្មតិទេព ត្រង់ទីឧទ្យានរបស់ព្រះអង្គ ក្នុងដែនរបស់ព្រះអង្គហ្នឹងឯង មានពួកឈើធំ មានដើមត្រង់ មានពន្លឺខៀវ ជាតម្រេកនៃចិត្ត ពួកឈើទាំងនោះ មានពណ៌ដូចផ្ទៃមេឃគួរឲ្យត្រេកអរ ជុះទាក់ទងគ្នាទៅវិញទៅមក កាលពួកសត្វលោកមានគ្រឿងឆេះ កំពុងត្រូវភ្លើងឆេះ សោណកៈមិនមានគ្រឿងឆេះ ជាបុគ្គលរលត់ហើយ កំពុងចម្រើនឈានជិតគល់ឈើទាំងនោះ ដូច្នេះ ។

ព្រះសាស្តាកាលទ្រង់ត្រាស់ដឹងហើយទើបត្រាស់អភិសម្ពុទ្ធគាថានេះថា

លំដាប់នោះ ព្រះរាជាទ្រង់ប្រើបម្រើឲ្យចាត់ចែងធ្វើផ្លូវរាបស្មើ យាងចេញទៅដោយសេនាមានអង្គ ៤ សំដៅទៅត្រង់កន្លែងដែលព្រះបច្ចេកពុទ្ធព្រះនាមសោណកៈគង់នៅ ។ លុះព្រះរាជាទ្រង់យាងទៅដល់ទីឧទ្យានហើយ ទ្រង់ត្រាច់ទៅក្នុងព្រៃធំ បានទតឃើញព្រះសោណកបច្ចេកពុទ្ធ កាលដែលពួកសត្វលោកកំពុងត្រូវភ្លើងឆេះ លោកជាបុគ្គលរលត់គង់នៅហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧជុវំសា** បានដល់ មានដើមត្រង់ ។ បទថា **មហាសាលា** បានដល់ ដើមឈើធំ ។ បទថា **មេឃសមានា** បានដល់ ដូចគ្នានឹងមេឃពណ៌ខៀវ ។ បទថា **រម្មា** បានដល់ ជាទីគួរត្រេកអរ ។ បទថា **អញ្ញោញ្ញនិស្សិតា** បានដល់ មែកនិងមែកប្រទាក់គ្នា ឫសនិងឫសចាក់ស្រេះ

គ្នា ។ បទថា **តេសំ** បានដល់ ខាងក្រោមដើមរាំងដែលមានសភាពបែបនោះ ក្នុងព្រៃដែលជាឧទ្យានរបស់ព្រះអង្គនោះឯង ។ បទថា **ឈាយតិ** សេចក្តីថា សម្ងំនូវឈានទាំង ២ គឺ លក្ខណូបនិជ្ឈាននិងអារម្មណូបនិជ្ឈាន ។ បទថា **អនុទានតោ** បានដល់ ជាបុគ្គលវៀរចាកការប្រកាន់មាំក្នុងកាម ។ បទថា **ឧយ្ហមានេសុ** បានដល់ កាលសត្វទាំងឡាយត្រូវភ្លើង ១១ កងដុតរោល ។ បទថា **និព្វុតោ** សេចក្តីថា ព្រះសោណកៈជាសម្លាញ់របស់ទ្រង់នេះ ធ្វើភ្លើងគ្រប់កងទាំងនោះឲ្យរលត់ បានហើយសម្ងំដោយហទយៈដ៏ត្រជាក់ អង្គុយលើផ្ទាំងថ្មត្រង់គល់រាំងដែលជាមង្គលនៅក្នុងឧទ្យានរបស់ទ្រង់ លោកល្អដូចបដិមាមាស ដូច្នោះ ។ បទថា **តតោ ច** អធិប្បាយថា ម្នាលភិក្ខុទាំងឡាយ ក្នុងលំដាប់នោះ ព្រះបាទអរិន្ទមៈ គ្រាន់តែបានស្តាប់ពាក្យរបស់កុមារនោះហើយ ទ្រង់ព្រះតម្រិះថា អញនឹងឃើញនូវសោណកបច្ចេកពុទ្ធ ដូច្នេះហើយ ចេញទៅមួយអន្លើដោយចតុរង្គសេនា ។ បទថា **វិចរន្តោ** សេចក្តីថា យាងមកតាមផ្លូវត្រង់នោះឯង ចូលទៅក្នុងព្រៃធំនោះហើយ ទើបយាងទៅកាន់សម្នាក់របស់ព្រះសោណកៈ បានទតឃើញលោកកំពុងគង់ ព្រះរាជាទ្រង់នមស្ការព្រះសោណកៈ ហើយប្រថាប់គង់ក្នុងទីសមគួរ នាចំណែកម្ខាង កាលទ្រង់សម្គាល់នូវព្រះសោណកៈនោះថាជាបុគ្គលកំព្រា ព្រោះទ្រង់ត្រេកអរក្នុងកិលេស ទើបត្រាស់គាថានេះថា

> ភិក្ខុត្រងោលដណ្តប់សង្ឃាដិ មិនមានមាតានេះ កំព្រាណាស់
> តើ ស្ងួតស្ងប់ជិតគល់ឈើ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឈាយតិ** សេចក្តីថា ជាអ្នកមិនមានមាតា មិនមានបិតា គួរដល់សេចក្តីករុណា ទើបអង្គុយចូលឈាន ។

ព្រះសាស្តាកាលទ្រង់ត្រាស់ដឹងហើយ ទើបត្រាស់អភិសម្ពុទ្ធគាថានេះថា

ព្រះសោណកៈបច្ចេកពុទ្ធស្តាប់ព្រះបន្ទូលនេះហើយ បានថ្វាយ
ព្រះពរយ៉ាងនេះថា បពិត្រព្រះរាជា បុគ្គលដែលពាល់ត្រូវនូវ
ធម៌ដោយកាយ មិនមែនឈ្មោះថាកំព្រាទេ ។ បុគ្គលណា
ក្នុងលោកនេះ លះធម៌ចោល ហើយប្រព្រឹត្តតាមអធម៌វិញ
បពិត្រព្រះរាជា បុគ្គលនោះ ទើបឈ្មោះថា កំព្រា ជាបុគ្គល
អាក្រក់ ជាទីសង្ឃឹមរបស់បុគ្គលអាក្រក់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥមំ** សេចក្តីថា ព្រះសោណកៈបានស្តាប់ពាក្យតិះដៀលដល់បព្វជ្ជានេះ របស់ព្រះរាជានោះ ទ្រង់ត្រេកអរក្រៃលែងក្នុងកិលេស ទ្រង់មិនពេញព្រះហឫទ័យក្នុងបព្វជ្ជា ។ បទថា **ឯតទព្រវិ** សេចក្តីថា ព្រះសោណកៈ កាលប្រកាសដល់គុណក្នុងបព្វជ្ជា ទើបពោលពាក្យនេះ ។ បទថា **ផស្សយំ** បានដល់ ពាល់ត្រូវ ។ ព្រះសោណកៈកាលសម្តែងថា បុគ្គលពាល់ត្រូវអរិយមគ្គធម៌នោះដោយកាយ រមែងមិនឈ្មោះថា ជាមនុស្សកំព្រា ដូច្នេះ ទើបពោលយ៉ាងនេះ ។ បទថា **និរង្កត្វា** បានដល់ នាំចេញចាកអត្តភាព ។ បទថា **ចាចោ ចាបបរាយនោ** សេចក្តីថា ឈ្មោះថា **ចាចោ** ព្រោះខ្លួនឯងធ្វើតែអាក្រក់ ឈ្មោះថា **ចាបបរាយនោ** ព្រោះជាទីពឹងដល់ជនដទៃដែលកំពុងធ្វើបាប ។

ព្រះសោណកៈនោះ តិះដៀលព្រះពោធិសត្វ ដោយពាក្យយ៉ាងនេះ ។ ព្រះពោធិសត្វទ្រង់ធ្វើដូចជាមិនជ្រាបថា ព្រះសោណកៈតិះដៀលទ្រង់ ទ្រង់ប្រាប់ឈ្មោះនិងគោត្តរបស់ទ្រង់ កាលនឹងធ្វើបដិសណ្ឋារៈជាមួយនឹងព្រះសោណកៈនោះ ទើបត្រាស់ថា

ខ្ញុំឈ្មោះអរិន្ទមៈ អ្នកផងស្គាល់ខ្ញុំថា កាសិរាជ បពិត្រព្រះសោណកៈ លោកដ៏ចម្រើនមកដល់ក្នុងទីនេះ សឹងនៅជាសុខទេឬ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កច្ចិ** សេចក្ដីថា ព្រះរាជាត្រាស់សួរថា ការមិនសប្បាយតិចតួច រមែងមិនមានដល់ខ្ញុំ តែការនៅជាសុខ រមែងមានដល់លោកម្ចាស់ ដែលមកដល់ហើយក្នុងទីនេះ គឺនៅក្នុងឧទ្យាននេះឬ ។

លំដាប់នោះ ទើបព្រះបច្ចេកពុទ្ធទូលតបជាមួយព្រះរាជាថា សូមថ្វាយព្រះពរ ឈ្មោះថា ការមិនសុខរមែងមិនមានដល់អាត្មាដែលនៅក្នុងឧទ្យាននេះប៉ុណ្ណោះក៏មិនមែន ទោះអាត្មាភាពនៅក្នុងទីដទៃៗ ក៏មិនមានឡើយ ដូច្នេះហើយ ទើបផ្ដើមគាថាសម្ដែងសេចក្ដីចម្រើនរបស់សមណៈដល់ព្រះរាជាអង្គនោះថា

សេចក្ដីចម្រើន ( តែងមាន ) ដល់ភិក្ខុមិនមានទ្រព្យ មិនមានផ្ទះសព្វកាលគឺ ( ទ្រព្យនិងធញ្ញជាតិទាំងឡាយ ) របស់ភិក្ខុទាំងនោះ លែងចូលទៅក្នុងជង្រុក លែងចូលទៅក្នុងថ្នាំងលែងចូលទៅក្នុងក្រឡោប៊ីទៀតហើយ លោកមានវត្តល្អ មានការស្វែងរកសម្រេចហើយ រមែងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ

ដោយបិណ្ឌបាតនោះ ។ សេចក្តីចម្រើនទី ២ ( តែងមាន ) ដល់ភិក្ខុមិនមានទ្រព្យ មិនមានផ្ទះ គឺបរិភោគដុំបាយដែលមិនមានទោស កិលេសណាមួយបៀតបៀនមិនបានទេ ។ សេចក្តីចម្រើនទី ៣ ( តែងមាន ) ដល់ភិក្ខុ មិនមានទ្រព្យ មិនមានផ្ទះ គឺឆាន់ដុំបាយដ៏ត្រជាក់ ( មិនជាវេយ្យបរិភោគជាដើម ) កិលេសណាមួយបៀតបៀនមិនបានទេ ។ សេចក្តីចម្រើនទី ៤ ( តែងមាន ) ដល់ភិក្ខុមិនមានទ្រព្យ មិនមានផ្ទះ គឺសេចក្តីជាប់ចំពាក់ មិនមានដល់ភិក្ខុដែលផុតស្រឡះ ( ចាកត្រកូល ) ត្រាច់ទៅក្នុងដែន ។ សេចក្តីចម្រើនទី ៥ ( តែងមាន ) ដល់ភិក្ខុមិនមានទ្រព្យ មិនមានផ្ទះ គឺកាលបើនគរកំពុងត្រូវភ្លើងឆេះ វត្ថុបត្តិចបន្តួចរបស់ភិក្ខុនោះ ភ្លើងមិនឆេះទេ ។ សេចក្តីចម្រើនទី ៦ ( តែងមាន ) ដល់ភិក្ខុមិនមានទ្រព្យ មិនមានផ្ទះ កាលបើដែនកំពុងត្រូវចោរប្លន់ វត្ថុបន្តិចបន្តួចរបស់ភិក្ខុនោះ ចោរមិនលួចទេ ។ សេចក្តីចម្រើនទី ៧ ( តែងមាន ) ដល់ភិក្ខុមិនមានទ្រព្យ មិនមានផ្ទះ គឺភិក្ខុមានវត្តល្អ នាំយកបាត្រនឹងចីវរដើរទៅកាន់ផ្លូវដែលពួកចោរនឹងពួកគយជនទៃរក្សាដោយស្រួល ។ សេចក្តីចម្រើនទី ៨ ( តែងមាន ) ដល់ភិក្ខុមិនមានទ្រព្យ មិនមានផ្ទះ គឺភិក្ខុដើរទៅកាន់ទិសណាៗ ទៅបានដោយមិនបានទីកនា ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អគារស្ស** សេចក្ដីថា សូមថ្វាយព្រះពរ សេចក្ដីចម្រើនសព្វកាល រមែងមានដល់ភិក្ខុដែលមិនមានកន្លង់ មិនមានទ្រព្យ លះភេទយកវាសចេញហើយ ដល់នូវភាពជាបុគ្គលមិនមានផ្ទះ ។ បទថា **ន តេសំ** សេចក្ដីថា បពិត្រមហារាជ ទ្រព្យនិងស្រូវទាំងឡាយរមែងមិនចូលទៅក្នុងជង្រុកមិនចូលទៅក្នុងឆ្នាំងបាយមិនចូលទៅក្នុងក្រឡោប៊ីរបស់ភិក្ខុទាំងឡាយដែលមិនមានទ្រព្យទាំងនោះ ព្រោះភិក្ខុទាំងនោះជាអ្នកមានវត្តល្អ ។ បទថា **បរិនិដ្ឋិតំ** សេចក្ដីថា ភិក្ខុទាំងនោះ ដណ្ដប់សំពត់សង្ឃាដិ ហើយកាន់បាត្រស្វែងរកអាហារដែលឆ្អិនហើយ ក្នុងផ្ទះរបស់ជនដទៃ តាមលំដាប់ផ្ទះ ពិចារណាអាហារនោះ ដោយអំណាចជារបស់បដិកូល ៩ យ៉ាង ហើយបរិភោគ រមែងញុំាងការរស់នៅនៃជីវិតឲ្យប្រព្រឹត្តទៅ ដោយបិណ្ឌបាតដែលបានហើយ អំពីការស្វែងរកនោះ ។ បទថា **អនវជ្ជបិណ្ឌា ភោត្តារោ** សេចក្ដីថា បច្ច័យ ៤ ដែលកើតឡើង ដោយការស្វែងរកមិនសមគួរ មានវេជ្ជកម្មជាដើម ឬដោយមិច្ឆាជីវៈ មានការកុហកបោកបញ្ឆោត ធ្វើគ្រហ្ម ទទួលបម្រើគ្រហស្ថ យកលាភទាក់លាភ សូម្បីកើតឡើងដោយធម៌ ភិក្ខុមិនពិចារណាជាមុន ហើយបរិភោគឈ្មោះថា បិណ្ឌបាតមានទោស បច្ច័យ ៤ ដែលភិក្ខុលះការស្វែងរកដែលមិនសមគួរវៀរមិច្ឆាជីវៈចេញ ហើយឲ្យបច្ច័យកើតឡើងដោយធម៌ ភិក្ខុពិចារណាដោយន័យដូចពោលហើយថា **បដិសង្ខាយោនិសោ ចីវរំ បដិសេវាមិ...** អាត្មាអញពិចារណាហើយដោយឧបាយ ទើបប្រើប្រាស់ចីវរ ដូច្នេះជាដើម ហើយទើបបរិភោគឈ្មោះថា បិណ្ឌបាតមិនមានទោស ភិក្ខុណាគប្បីបរិភោគបិណ្ឌបាត

ដែលមិនមានទោសដូច្នេះឯង កាលភិក្ខុទាំងឡាយបរិភោគបិណ្ឌបាតដែលមិនមានទោសយ៉ាងនេះ កិលេសមានប្រមាណតិចតួចដែលអាស្រ័យបច្ច័យទាំងឡាយ រមែងមិនបៀតបៀន គឺរមែងមិនគ្របសង្កត់ភិក្ខុណា សេចក្តីចម្រើនទី ២ រមែងមានដល់ភិក្ខុមិនមានទ្រព្យ មិនមានផ្ទះ ដូច្នេះឯង ។

បទថា **និព្វុតោ** សេចក្តីថា បិណ្ឌបាតដែលកើតឡើងប្រកបដោយធម៌របស់ភិក្ខុដែលជាបុថុជ្ជន ភិក្ខុពិចារណាហើយ សឹមបរិភោគ ឈ្មោះថា បិណ្ឌបាតរលត់ ( ត្រជាក់ ) ហើយ ឯបិណ្ឌបាតរបស់ព្រះខីណាស្រព ឈ្មោះថា បិណ្ឌបាតរលត់ហើយ ដោយចំណែកមួយ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះថា បណ្តាការបរិភោគ ៤ យ៉ាង គឺថេយ្យបរិភោគ ១ ឥណបរិភោគ ១ ទាយជ្ជបរិភោគ ១ សាមិបរិភោគ ១ ព្រះខីណាស្រព រមែងបរិភោគបិណ្ឌបាតនោះ ដោយអំណាចនៃសាមិបរិភោគ ។ លោកជាសាមិបរិភោគដោយផុតចាកភាពជាទាសៈនៃតណ្ហា កិលេសសូម្បីមានប្រមាណតិច រមែងមិនបៀតបៀនលោក ព្រោះការបរិភោគនោះជាបច្ច័យ ។ បទថា **មុត្តស្ស រដ្ឋេ ចរតោ** សេចក្តីថា កាលភិក្ខុណាមិនជាប់ជំពាក់ក្នុងត្រកូលឧបដ្ឋាក ជាដើម ហាក់បីដូចផ្ទៃមេឃមិនមានពពក ឬដូចព្រះចន្ទដែលភ្លឺថ្លា ផុតអំពីមាត់រាហូ ដូច្នោះ ត្រាច់ទៅក្នុងស្រុកនិងនិគមជាដើម បណ្តាការជាប់ជំពាក់មានរាគៈ ជាដើម ការជាប់ជំពាក់ណាមួយ រមែងមិនមានពិតហើយ បុគ្គលពួកខ្លះ ប្រឡូកប្រឡំជាមួយត្រកូលទាំងឡាយ រួមសោក រួមត្រេកអរជាមួយបុគ្គលនោះៗ ។ បុគ្គលពួកខ្លះ មានចិត្តមិនជាប់ជំពាក់ក្នុងមាតាបិតាតែម្នាក់ ដូចក្មេងអ្នកស្រុក

កោរុនគរ ដូច្នោះ ។ សូម្បីវត្ថុជាបុប្ផជូនបែបនេះ ក៏រមែងមានសេចក្តីចម្រើន ដូចគ្នា ។ បទថា **ឆាស្ស កិញ្ចិ** សេចក្តីថា ពិតហើយ ភិក្ខុណាមួយ ជាអ្នកមានបរិក្ខារច្រើន ភិក្ខុរូបនោះគិតថា ចោរទាំងឡាយកុំលួចបរិក្ខាររបស់អញឡើយ ដូច្នេះ ទើបរក្សាបរិក្ខារទាំងឡាយ មានសំពត់ចីវរជាដើមដ៏សេស ក្នុងត្រកូលឧបដ្ឋាក ខាងក្នុងស្រុក លុះបានដំណឹងថា ភ្លើងកើតឡើងក្នុងត្រកូលនោះ ក៏សោយសោក ទុក្ខទោមនស្ស ។ ឈ្មោះថា សេចក្តីចម្រើន រមែងមិនមានដល់ភិក្ខុបែបនោះឡើយ បពិត្រមហារាជ ឯភិក្ខុណាបំពេញវត្តរបស់សកុណជាតិ ឲ្យពេញបរិបូណ៌ គឺមានបរិក្ខារដែលជាប់កាយប៉ុណ្ណោះ បរិក្ខារណាមួយរបស់ភិក្ខុនោះ រមែងមិនត្រូវភ្លើងឆេះ សូម្បីសេចក្តីចម្រើនទី ៥ រមែងមានដល់ភិក្ខុនោះ ដោយប្រការដូច្នេះឯង ។

បទថា **វិលុម្បមានម្ហិ** បានដល់ នាំគ្នាប្លន់ ម្យ៉ាងទៀត បាលីថា **វិលុប្ប-មានម្ហិ** ក៏មានន័យដូចគ្នា ។ បទថា **អហីរថ** សេចក្តីថា កាលពួកចោរចេញចាកព្រៃភ្នំជាដើម នាំគ្នាប្លន់ដែន មានចោរម្នាក់ដណ្តើមយកបរិក្ខាររបស់ភិក្ខុដែលមានបរិក្ខារច្រើន ដែលផ្ញើទុកក្នុងស្រុក យ៉ាងណា ចោររមែងលួចយកបរិក្ខារណាមួយ របស់ភិក្ខុដែលមានតែបរិក្ខារជាប់កាយ មិនមានទ្រព្យដូច្នោះមិនបានឡើយ សូម្បីសេចក្តីចម្រើនទី ៦ ក៏រមែងមានដល់ភិក្ខុនោះ ដូចគ្នា ។ បទថា **យេ ចញ្ញេ បរិបន្ថិកា** សេចក្តីថា ទៅកាន់ផ្លូវដែលពួកចោរនិងពួកគយគ្រប់គ្រង ដើម្បីទារកាស៊ីក្នុងទីនោះៗ ។ បទថា **បត្តចីវរំ** សេចក្តីថា ភិក្ខុធ្វើបរិក្ខារ ៨ គឺបាត្រដី បង្សុកូលចីវរដែលដេរ ជ្រលក់រៀបរយហើយ វត្ថុ

ពន្ធចង្កេះ ធម្មក្រក បំពង់ម្ជុល កាំបិតកោរ ស្មោកបាត្រដែលមានតម្លៃតិច មិនមានប្រយោជន៍ដល់ពួកចោរ មិនសមគួរដល់អ្នកដកកាសុី មានតែបរិក្ខារដែលជាប់កាយដើរទៅតាមផ្លូវ បុគ្គលណាម្នាក់ ក៏មិនបៀតបៀន រមែងទៅបានដោយសួស្តី ។ បទថា **សុញ្ញតោ** សេចក្តីថា ពិតហើយ ចោរទាំងឡាយឃើញចីវរជាដើម ដែលធ្វើឲ្យកើតនូវសេចក្តីលោភ រមែងលួចទៅក៏មាន នាយកាសុីគិតថា អ្វីហ្ន៎មានក្នុងដៃភិក្ខុរូបនេះ ហើយទើបធ្វើការត្រួតពិនិត្យស្មោកបាត្រ ជាដើម ឯភិក្ខុដែលមានវត្តល្អ កាលជនទាំងនោះឃើញលោក ដែលមានការប្រព្រឹត្តស្រាល រមែងទៅបានស្រួល សេចក្តីចម្រើនទី ៧ ក៏មានដល់ភិក្ខុនោះ ដោយប្រការដូច្នេះឯង ។ បទថា **អនបេក្ខោវ គច្ឆតិ** សេចក្តីថា ភិក្ខុមកកាន់លំនៅហើយ ក៏មិនចាំបាច់ក្រឡេកមើល ព្រោះមិនមានបរិក្ខារណាមួយដែលលើសបរិក្ខារដែលទាក់ទងក្នុងកាយ ដែលខ្លួនរក្សាទុកក្នុងវិហារ ទោះបីទៅកាន់ទិសណា ក៏ទៅកាន់ទិសនោះបាន ដោយមិនអាឡោះអាល័យ ដូចកុលបុត្តពីរនាក់ បួសហើយក្នុងថូបារាម បព្វជិតដែលចាស់ជាងចេញអំពីអនុរាធបុរី ហើយធ្វើដំណើរចេញទៅ ដូច្នោះ ។

ព្រះសោណកបច្ចេកពុទ្ធ សម្តែងសេចក្តីចម្រើននៃសមណៈ ៨ យ៉ាង ដោយប្រការដូច្នេះ តែសេចក្តីពិត លោកជាអ្នកអាចបង្ហាញសេចក្តីចម្រើននៃសមណៈឲ្យក្រៃលែងជាងនោះបានរាប់រយរាប់ពាន់ រហូតប្រមាណមិនបាន ឯព្រះរាជា ទ្រង់រំលងពាក្យរបស់ព្រះសោណកៈនោះ ព្រោះទ្រង់ត្រេកអរក្រៃលែងក្នុងកាម ទើបត្រាស់ថា ខ្ញុំមិនត្រូវការសេចក្តីចម្រើននៃសមណៈ កាល

ទ្រង់ប្រកាសភាពដែលទ្រង់បង្អោនព្រះហឫទ័យទៅក្នុងកាម ទើបត្រាស់ថា

បពិត្រភិក្ខុ លោកសរសើរនូវសេចក្ដីចម្រើនរបស់ភិក្ខុទាំងនោះ ច្រើនមែន បពិត្រព្រះសោណកៈ តែខ្ញុំជក់ចិត្តក្នុងកាមទាំងឡាយ តើនឹងធ្វើយ៉ាងណា ។ កាមទាំងឡាយជារបស់មនុស្ស ជាទីស្រឡាញ់របស់ខ្ញុំ មួយទៀត កាមជាទិព្វ ក៏ជាទីស្រឡាញ់របស់ខ្ញុំ បើដូច្នេះ តើយើងនឹងបាននូវកាមទាំងពីរក្នុងលោកដោយហេតុដូចម្ដេច ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វណ្ណោឆ** បានដល់ ហេតុ ។

លំដាប់នោះ ព្រះបច្ចេកពុទ្ធក៏ក្រាបទូលព្រះរាជានោះថា

ពួកជនអ្នកជក់ចិត្តក្នុងកាម ត្រេកអរក្នុងកាមជប់ក្នុងកាម រមែងធ្វើបាបទាំងឡាយ ហើយទៅកាន់ទុគ្គតិ ។ ចំណែកពួកជនណាលះបង់កាមហើយចេញទៅ មិនមានភ័យអំពីកិលេសណាបាននូវភាពជាបុគ្គលឯក ពួកជននោះ មិនទៅកាន់ទុគ្គតិ ។ បពិត្រព្រះអរិន្ទម អាត្មាភាព នឹងធ្វើសេចក្ដីឧបមាថ្វាយព្រះអង្គ សូមព្រះអង្គទ្រង់ព្រះសណ្ដាប់សេចក្ដីឧបមានោះ ព្រោះពួកបណ្ឌិតខ្លះក្នុងលោកនេះ តែងយល់សេចក្ដីដោយសារឧបមា ។ ក្អែកឥតប្រាជ្ញា ឥតសេចក្ដីត្រេរត្រានៃ ឃើញសាកសព ( ដំរី ) កំពុងអណ្ដែតតាមទន្លេគង្គា ទៅក្នុងសមុទ្រហើយគិតថា អែយ៉ា! អញបានយាននេះហើយផង ដំរីនេះនឹងបានជាចំណីអញ

យ៉ាងច្រើនផង ចិត្តរបស់ក្អែកនោះ ក៏ត្រេកអរក្នុងដំរីនោះ ទាំងថ្ងៃទាំងយប់ ។ ក្អែកចឹកស៊ីសាច់ដំរី ផឹកទឹកទន្លេគង្គា ឃើញព្រៃដែលគេសន្មតថាចេតិយក៏មិនហើរទៅ ។ ទន្លេគង្គាហូរទៅបាននាំក្អែកនោះ ដែលប្រហែសធ្វេស ត្រេកអរក្នុងសាកសពទៅកាន់សមុទ្ទ ដែលមិនមែនជាទីទៅនៃបក្សី ។ សត្វហើរនោះអស់ចំណីរលីងហើយ ក៏ហើរឡើង ទៅទិសខាងលិចមិនរួច ទៅទិសខាងកើតមិនរួច ទៅទិសខាងជើងមិនរួច ទៅទិសខាងត្បូងមិនរួច ។ ក្អែកនោះទៅកាន់សមុទ្ទ ដែលមិនមែនជាទីទៅនៃពួកបក្សី ក៏មិនបានទូវទីពឹងធ្លាក់ទៅក្នុងសមុទ្ទនោះឯង ដូចជាបុគ្គលមានកម្លាំងថយ ។ ពួកត្រី ក្រពើ មករ ឆ្លាម ដែលកើតក្នុងសមុទ្ទ កំហែងខាំ ក្អែកនោះ ដែលមានស្លាប របោចហើយ កំពុងបម្រះ ( យ៉ាងណាមិញ ) ។ បពិត្រព្រះរាជាព្រះអង្គនិងពួកជនដទៃអ្នកបរិភោគកាម ក៏យ៉ាងនោះដែរ បើពួកជនដែលជក់ចិត្តហើយមិនខ្ជាក់ ( កាម ) បោលចេញទេ បណ្ឌិតទាំងឡាយ ( ស្គាល់ ) ពួកជននោះ ( ថាមានប្រាជ្ញា ស្មើ ) ដោយប្រាជ្ញារបស់ក្អែក ។ បពិត្រព្រះរាជា ឧបមាជាគ្រឿងបំភ្លឺនូវសេចក្តីនេះ អាត្មាភាព បានធ្វើថ្វាយព្រះអង្គហើយ បើព្រះអង្គធ្វើ ឬមិនធ្វើ ព្រះអង្គនឹងប្រាកដតាមហេតុនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធាធាធិ** សេចក្តីថា បពិត្រមហារាជ ទ្រង់និងនរជនទាំងឡាយដែលត្រេកអរ ក្នុងការអាស្រ័យកាមទាំងឡាយ ធ្វើតែបាបកម្ម មានការប្រព្រឹត្តអាក្រក់ដោយកាយជាដើម រមែងចូលដល់ទុគ្គតិ ដែលជាទីមិនបាននូវកាមទាំងឡាយដែលជាទិព្វ និងជារបស់មនុស្ស រមែងមិនបានសូម្បីក្នុងការយល់សប្តិ ។ បទថា **បហាន្ត្វាន** បានដល់ លះកាមបាន ដូចប្រមូលទឹកមាត់ខ្ជាក់ចោលដូច្នោះ ។ បទថា **អកុតោភយា** បានដល់ មិនមានភ័យអំពីទីណាឡើយ បណ្តាកិលេស មានរាគៈជាដើម ។ បទថា **ឯកោ-ទិភាវាធិគតា** បានដល់ ដល់នូវឯកក្កតាចិត្ត គឺភាពជាអ្នកមានធម៌ជាគ្រឿងនៅយ៉ាងឯក ។ បទថា **ន តេ** សេចក្តីថា បុគ្គលទាំងនោះ គឺបព្វជិតទាំងនោះមិនទៅកាន់ទុគ្គតិ ។ បទថា **ឧបមន្តេ** សេចក្តីថា បពិត្រមហារាជ អាត្មានឹងធ្វើការប្រៀបធៀបមួយចំណុចថ្វាយដល់ទ្រង់ ដែលមានសេចក្តីប្រាថ្នាក្នុងកាមដែលជាទិព្វ និងជារបស់មនុស្សដែលមិនផ្សេងអំពីក្អែកដែលមានចិត្តជាប់ជំពាក់ក្នុងសាកសពដំរី ដូច្នោះ សូមទ្រង់ស្តាប់ឧបមានោះចុះ ។ បទថា **កុណបំ** បានដល់ សាកសពដំរី ។ បទថា **មហាណ្ណវេ** បានដល់ ក្នុងទឹកដែលជ្រៅផង ធំទូលាយផង ។ បទថា **កុណបំ** នោះ លោកពោលសំដៅដល់ដំរីធំមួយ ត្រាច់ទៅតាមមាត់ច្រាំង ក្នុងស្ទឹងគង្គា ធ្លាក់ចុះក្នុងស្ទឹងគង្គា មិនអាចឡើងបាន ត្រូវក្រសែទឹកបោកបក់ ស្លាប់ក្នុងស្ទឹងនោះឯង ។

បទថា **វាយសោ** បានដល់ មានក្អែកមួយហើរមកតាមអាកាស ។ បទថា **យានញ្ច វតិទំ** សេចក្តីថា ក្អែកនោះ កាលគិតយ៉ាងនេះហើយ ទើបទំត្រង់

សាកសពដំរីនោះ បានធ្វើការសម្រេចចិត្តថា អញបានយាន គឺដំរីនេះ ហើយ អញនឹងទំលើយាន គឺដំរីនេះ នឹងត្រាច់ទៅយ៉ាងសប្បាយ ម្យ៉ាងទៀត ដំរីនេះ ឯង ក៏ជាអាហារបានយ៉ាងច្រើន ឥឡូវនេះ អញមិនគួរទៅក្នុងទីដទៃ ។ បទថា **តត្ថ រត្តោ** សេចក្ដីថា ក្អែកនោះ មានចិត្តត្រេកអរក្រៃលែងក្នុងសាកសពដំរីនោះឯង អស់យប់និងថ្ងៃ ។ បទថា **ន បលេត្ថ** សេចក្ដីថា ក្អែកនោះ មិនហើរចៀសចេញទៅ ។ បទថា **ឱតរណី** បានដល់ ស្ទឹងគង្គានោះ មានប្រក្រតីហូរទៅកាន់មហាសមុទ្ទ បាលីថា **ឱហារិណី** ដូច្នេះក៏មាន អធិប្បាយថា ស្ទឹងគង្គាមានប្រក្រតីហូរទៅកាន់មហាសមុទ្ទ ។ បទថា **អគតី យត្ថ** នោះ លោកពោលសំដៅដល់កណ្ដាលមហាសមុទ្ទ ។ បទថា **ភក្ខបរិក្ខីណោ** បានដល់ អស់អាហារហើយ ។ បទថា **ឧទបត្វា** សេចក្ដីថា កាលស្បែក និងសាច់របស់ដំរីនោះអស់ទៅហើយ គ្រោងឆ្អឹងក៏ត្រូវកម្លាំងរលកបក់បោករហូតលិចចុះក្នុងទឹក លំដាប់នោះ ក្អែកនោះ កាលមិនអាចនៅក្នុងទឹកបាន ទើបហោះឡើងទៅ កាលហើរទៅយ៉ាងនេះហើយ ។ បទថា **អគតី យត្ថ បក្ខិនំ** សេចក្ដីថា ក្អែកនោះ ហើរទៅកាន់ទិសខាងលិច កាលមិនបានទីសម្រាប់ទំក្នុងទីនោះ ហើរអំពីទិសខាងលិចនោះ មកកាន់ទិសខាងកើត ហើរអំពីទិសខាងកើតមកកាន់ទិសខាងជើង ហើរអំពីទិសខាងជើងទៅកាន់ទិសទក្សិណ ហើរទៅកាន់ទិសទាំង ៤ ដោយអាការយ៉ាងនេះ ក៏មិនដល់ទីសម្រាប់ទំរបស់ខ្លួន កណ្ដាលមហាសមុទ្ទ ដែលជាទីទៅមិនដល់នៃពួកបក្សីទាំងឡាយ ។ បណ្ឌិតគប្បីឃើញអត្ថយ៉ាងនេះថា លំដាប់នោះ ក្អែកទៅយ៉ាងនេះហើយ បានហើរទៅក្នុងទិសនីមួយៗ

បណ្តាទិស មានទិសខាងលិចជាដើម តែហើរទៅមិនដល់កោះ ។ បទថា **ចាបត្ត** បានដល់ ធ្លាក់ទៅហើយ ។ បទថា **យថា ឧត្តុលកោ** បានដល់ លិចចុះដូច មនុស្សដែលអស់កម្លាំងលិចចុះ ដូច្នោះ ។ បទថា **សុសុ** បានដល់ ពួកត្រីកាច មានត្រីឈ្មោះ សុសុជាដើម ។ បទថា **បសយ្ហការា** សេចក្តីថា ត្របាក់ស៊ី ក្អែកនោះដែលមិនប្រាថ្នានោះឯង ដោយកម្លាំង ។ បទថា **វិបក្ខិកំ** បានដល់ ក្អែកដែល មានរោមស្លាបវិនាសប្រើការមិនបាន ។ បទថា **គិទ្ធា ចេ ន វមិស្សន្តិ** សេចក្តីថា បើនៅជាអ្នកត្រេកអរក្នុងកាម មិនព្រមលះបង់កាមចោល ។ បទថា **កាកបញ្ញាយ តេ** សេចក្តីថា អ្នកប្រាជ្ញទាំងឡាយដែលជាបណ្ឌិតមានព្រះពុទ្ធ ជាដើម រមែងដឹងច្បាស់ រមែងដឹងជ្រាបច្បាស់ថា ជនទាំងនោះមានបញ្ញាស្មើ ដោយបញ្ញារបស់ក្អែក ដូច្នោះ ។ បទថា **អត្តសន្ទស្សនី កតា** បានដល់ អាត្មា បានសម្តែងឧបមាប្រកាសអត្ថហើយ ។ បទថា **ត្វញ្ច បញ្ញាយសេ** បាន ដល់ ទ្រង់ដឹងច្បាស់ឯង ។ មានពាក្យដែលលោកអធិប្បាយទុកថា មហា បពិត្រ អាត្មាជាអ្នកប្រាថ្នាប្រយោជន៍ ទើបបានថ្វាយឱវាទដល់ទ្រង់ បើទ្រង់ ធ្វើតាមឱវាទនោះសោត ទ្រង់ក៏នឹងកើតក្នុងទេវលោក បើទ្រង់មិនធ្វើតាមឱវាទ នោះ ទ្រង់នឹងលិចចុះក្នុងភក់ គឺកាម ក្នុងកាលអស់ព្រះជន្មនឹងទៅកើតក្នុង នរក ។ ព្រះអង្គ ទ្រង់នឹងជ្រាបស្ថានសួគ៌ ឬនរកដោយហេតុយ៉ាងនេះ ឯអាត្មារួចផុតហើយចាកកពទាំងពួង មិនត្រូវបដិសន្ធិទៀតឡើយ ព្រះបច្ចេក ពុទ្ធថ្វាយឱវាទនេះដល់ព្រះរាជាអង្គនោះ បានសម្តែងដល់ស៊ីង ហើយសម្តែង ដល់សាកសពដំរី ដែលត្រូវទឹកបក់បន្សាត់ទៅក្នុងស្ទឹងគង្គា សម្តែងដល់ក្អែក

ដែលស៊ីសាកសព សម្ដែងដល់ការដែលចឹកស៊ីសាកសពហើយផឹកទឹករបស់ក្អែកនោះ សម្ដែងដល់ការដែលសម្លឹងមើលដងព្រៃដែលគួរត្រេកអរ សម្ដែងដល់ការចូលទៅកាន់មហាសមុទ្រ របស់សាកសព ដែលអណ្ដែតទៅក្នុងស្ទឹង សម្ដែងដល់ការដែលក្អែកមិនបាន ទីទំអាស្រ័យលើសាកសពដំរី ហើយដល់នូវការវិនាសកណ្ដាលមហាសមុទ្រ ។ បណ្ដាវត្ថុទាំងនោះ បណ្ឌិតគប្បីឃើញថា សង្សារវដ្ដដែលមិនមានខាងដើមនិងខាងចុង ប្រៀបដូចជាស្ទឹង ។ កាមគុណ ៥ ក្នុងសង្សារ ប្រៀបដូចសាកសពដំរីដែលអណ្ដែតក្នុងស្ទឹង ។ បុថុជ្ជនដែលជាបុគ្គលពាល ប្រៀបដូចក្អែក ។ កាលនៃបុថុជ្ជនដែលបរិភោគកាមគុណហើយកើតនូវសោមនស្ស ប្រៀបដូចកាលដែលក្អែកចឹកសាកសពហើយផឹកទឹក ។ ការឃើញអារម្មណ៍ ៣៨ ប្រការដោយអំណាចការស្ដាប់របស់បុថុជ្ជនដែលជាប់ជំពាក់ក្នុងកាមគុណទាំងឡាយ ប្រៀបដូចការឃើញដងព្រៃដែលគួរជាទីត្រេកអររបស់ក្អែកដែលជាប់ជំពាក់ក្នុងសាកសពដំរីនោះ ។ លោកអ្នកដែលជាបណ្ឌិតឃើញការដល់នូវសេចក្ដីវិនាសក្នុងមហានរករបស់បុថុជ្ជនដែលជាបុគ្គលពាល ជាអ្នកត្រេកអរក្នុងកាមគុណ មានអំពើអាក្រក់ជាទីទៅខាងមុខ មិនអាចបានទីអាស្រ័យក្នុងកុសលធម៌ថា ប្រៀបដូចកាលដែលក្អែកមិនអាចរកទីទំអាស្រ័យបាន ក៏ដល់នូវសេចក្ដីវិនាស ក្នុងកាលដែលសាកសពទៅកាន់មហាសមុទ្រ ដូច្នោះ ។

ព្រះបច្ចេកពុទ្ធថ្វាយឱវាទដល់ព្រះរាជាអង្គនោះ ដោយឧបមានេះ យ៉ាងនេះហើយ ឥឡូវនេះ បំណងនឹងធ្វើឱវាទនោះឯង ឲ្យតាំងនៅយ៉ាងមាំទាំ ទើប

ពោលគាថានេះថា

បុគ្គលអ្នកឈឺថ្កាល គប្បីនិយាយត្រឹមតែមួយម៉ាត់ឬពីរម៉ាត់
មិនគប្បីនិយាយឲ្យលើសហួសពីនោះទៅ ដូចទាសៈនិយាយ
ក្នុងសំណាក់នៃម្ចាស់ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧ ភាសេយ្យ** សេចក្ដីថា បុគ្គលដែលពោលឲ្យក្រៃលែងជាងប្រយោជន៍ដល់បុគ្គលដែលមិនជឿពាក្យ ដូចជាទាសៈក្នុងសម្នាក់របស់ចៅហ្វាយ ដូច្នោះ ដ្បិតថា ទាសៈ សូម្បីចៅហ្វាយនាយជឿពាក្យ ឬមិនជឿពាក្យក៏ដោយ ត្រូវពោលយ៉ាងនោះឯង ព្រោះហេតុនោះ ទើបលោកពោលថា **តតុត្តរិ ឧ ភាសេយ្យ** មិនគប្បីពោលឲ្យក្រៃលែងជាងនោះដូច្នេះ ។

ព្រះបច្ចេកពុទ្ធពោលដូច្នេះហើយ ទើបហោះទៅដោយឫទ្ធិ ហើយទូន្មានព្រះរាជាថា បើទ្រង់បួសក្ដី មិនបួសក្ដី អាត្មាក៏បានឲ្យឱវាទដល់ទ្រង់ហើយ មហាបពិត្រ សូមទ្រង់ជាអ្នកមិនប្រមាទចុះ ដូច្នេះហើយ ទើបទៅកាន់ញកភ្នំឈ្មោះនន្ទមូលកៈវិញ ។ ព្រះសាស្ដា កាលទ្រង់ប្រកាសសេចក្ដីនោះ ទើបត្រាស់ថា

លុះព្រះសោណកៈបច្ចេកពុទ្ធ មានប្រាជ្ញារាប់មិនបាន ពោល
ពាក្យនេះប្រៀនប្រដៅក្សត្រហើយ ទើបចៀសចេញទៅឰដ៏
អាកាសវេហាស៍ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឥធំ វត្វាន** អធិប្បាយថា ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកពុទ្ធនោះ ជាអ្នកមានបញ្ញាដែលបុគ្គលរាប់មិនបាន ដោយបញ្ញាជា

គ្រឿងត្រាស់ដឹង ដែលជាលោកុត្តរ ដែលបុគ្គលណាមួយរាប់មិនបាន លុះលោកពោលពាក្យនេះហើយ ក៏ហោះទៅដោយឫទ្ធិ ទូន្មានបរមក្សត្រយ៉ាងនេះថា បើទ្រង់ផ្នួស ក៏ជារឿងរបស់ទ្រង់នោះឯង ឬបើទ្រង់មិនបួស ក៏ជារឿងរបស់ទ្រង់ដូចគ្នា អាត្មាថ្វាយឱវាទដល់ទ្រង់ហើយ សូមទ្រង់កុំប្រមាទ ដូច្នេះហើយ ក៏ចៀសចេញទៅ ។

ចំណែកព្រះពោធិសត្វប្រថាប់ឈរទតមើលព្រះបច្ចេកពុទ្ធ ដែលទៅដោយអាកាស ដែលអាចឃើញបាន កាលផុតកន្ទុយភ្នែកហើយ ក៏បាននូវសេចក្តីសង្វេគ ទ្រង់ព្រះតម្រិះថា ព្រាហ្មណ៍នេះ មានជាតិថោកថយ ហោះទៅក្នុងអាកាសរោយនូវធូលីដែលជាប់នឹងជើង លើក្បាលរបស់អញ ដែលកើតក្នុងត្រកូលស្តេច មិនច្រឡូកច្រឡំដោយវង្សដទៃ ឯអញក៏គួរចេញបួសក្នុងថ្ងៃនេះឯង ។ ព្រះរាជាទ្រង់ប្រាថ្នាប្រគល់រាជសម្បត្តិ ហើយទ្រង់ព្រះផ្នួស ទើបពោលគាថា ២ ថា

ពួកជនអ្នករៀបចំអភិសេក បុគ្គលដែលគួរដល់រាជ្យជាអ្នកបន្តក់ប្រសិទ្ធនេះ ចាំស្មាត់នៅក្នុងទីណា អញនឹងប្រគល់រាជ្យឲ្យ អញមិនត្រូវការដោយរាជ្យទេ ។ អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណា គប្បីដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក អញលែងលុះក្នុងអំណាចនៃកាមទាំងឡាយ ដូចជាក្អែកធោតហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កោ ឆុមេ** បានដល់ អ្នកទាំងនេះនៅឯណា ។

បទថា **រាជកត្តារោ** សេចក្តីថា បុគ្គលពួកណាដែលអភិសេក បុគ្គលដែលសមគួរជាព្រះរាជា ហើយធ្វើឲ្យជាព្រះរាជាយ៉ាងបរិបូណ៌ ។ បទថា **សុត្តា វេយ្យត្តិមាគតា** សេចក្តីថា ពួករាជករិនិងបុគ្គលដែលដល់នូវកាពឈ្លាសវៃ គឺដឹងនូវមង្គលដោយស្ទាត់រត់មាត់ ។ បទថា **រដ្ឋេន មង្គិកោ** បានដល់ បុគ្គលដែលមានសេចក្តីត្រូវការដោយរាជសម្បត្តិ ។ បទថា **កោ ជញ្ញា មរណំ សុវេ** សេចក្តីថា ព្រោះថា បុគ្គលណា ដែលនឹងមានសមត្ថភាពដឹងដល់ហេតុនេះបានថា សេចក្តីស្លាប់នឹងមានមកក្នុងថ្ងៃនេះឬស្អែកនេះ ។

កាលព្រះរាជាទ្រង់ប្រគល់រាជសម្បត្តិយ៉ាងនេះ ពួកអាមាត្យបានស្តាប់ហើយ ទើបក្រាបទូលថា

ព្រះរាជបុត្តរបស់ព្រះអង្គ ព្រះនាមទីឃាវុនៅក្មេង ជាអ្នកញ៉ាំងដែនឲ្យចម្រើន សូមព្រះអង្គអភិសេកព្រះរាជបុត្តនោះក្នុងរាជ្យចុះ ព្រះរាជបុត្តនោះ នឹងបានជាព្រះរាជារបស់យើងខ្ញុំ ដូច្នេះ ។

ខាងមុខអំពីនោះ បណ្ឌិតគប្បីធ្វើនូវគាថាដែលព្រះរាជាត្រាស់ហើយ ឲ្យជាគំរូ គប្បីជ្រាបគាថាសម្ពន្ធដោយឧទាន ដោយន័យព្រះបាលីនោះឯង ។ ព្រះរាជាត្រាស់ថា

អ្នកទាំងឡាយ ចូរនាំយកកុមារឈ្មោះទីឃាវុ អ្នកញ៉ាំងដែនឲ្យចម្រើនមកឲ្យឆាប់ អញនឹងអភិសេកកុមារនោះក្នុងរាជ្យ កុមារនោះ នឹងជាព្រះរាជារបស់អ្នកទាំងឡាយ ដូច្នេះ ។

ពួកអាមាត្យស្ដាប់ព្រះតម្រាស់របស់ព្រះរាជាហើយ ទើបនាំគ្នាទៅយាង ទីឃាវុរាជកុមារមក ព្រះរាជាក៏ទ្រង់ប្រគល់រាជសម្បត្តិ ដល់ព្រះរាជកុមារនោះហើយ ។

ព្រះសាស្ដា កាលទ្រង់ប្រកាសសេចក្ដីនោះ ទើបត្រាស់ថា

លំដាប់នោះ ពួកអាមាត្យក៏បាននាំកុមារ ឈ្មោះទីឃាវុ អ្នកញុំាងដែនឲ្យចម្រើនមកថ្វាយ ព្រះរាជាទតឃើញទីឃាវុកុមារនោះជាបុត្តតែមួយ ជាទីត្រេកអរពេញព្រះទ័យហើយ ទ្រង់ត្រាស់ថា នែបុត្ត ស្រុកទាំង ៦០.០០០ បរិបូណ៌ដោយវត្ថុទាំងពួង ចូរបាថែទាំស្រុកទាំងនោះចុះ អញនឹងប្រគល់រាជ្យដល់បា ។ អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹងថា សេចក្ដីស្លាប់ នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញលុះក្នុងអំណាចនៃកាមទាំងឡាយ ដូចជាក្អែកចោតឡើយ ។ ដំរី ៦០.០០០ ស្អិតស្អាងដោយគ្រឿងប្រដាប់គ្រប់យ៉ាង មានខ្សែដង្គន់ ធ្វើអំពីមាស បិតបាំងដោយកម្រាលដែលធ្វើអំពីមាស ជាដំរីកើតក្នុងព្រៃមាតង្គៈ ។ ដំរីណាដែលពួកហ្មដំរីមានដៃកាន់អាវុធនិងកង្វេរឡើងជិះ នែបុត្ត អ្នកចូរថែទាំពួកដំរីទាំងនោះចុះ អញប្រគល់រាជ្យដល់អ្នក ។ អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹងថា សេចក្ដីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញ លុះក្នុងអំណាចនៃកាមទាំងឡាយដូចជាក្អែកចោតឡើយ ។ សេះ

៦០.០០០ ស្អិតស្អាងដោយគ្រឿងប្រដាប់គ្រប់យ៉ាង ជាសេះអាជានីយដោយកំណើតជាសេះសិន្ធវៈ ជាពាហនៈយ៉ាងលឿនដែលពួកសារថីកាន់សែ៊និងផ្ទជិះ នែបុត្ត បាចូរថែទាំសេះទាំងនោះចុះ អញប្រគល់រាជ្យដល់បា ។ អញនឹងបួសក្នុងថ្ងៃនេះឯងអ្នកណាគប្បីដឹងថាសេចក្តីស្លាប់ នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញ លុះក្នុងអំណាចនៃកាមទាំងឡាយ ដូចជាក្អែកឆោតឡើយ ។ រថ ៦០.០០០ ដែលគេទឹមហើយ ដោតទង់ជ័យស្រោបដោយស្បែកខ្លាដំបង ស្រោបដោយស្បែកខ្លាធំ ស្អិតស្អាងដោយគ្រឿងប្រដាប់គ្រប់យ៉ាង ។ អ្នកបររថមានដៃកាន់ធ្នូ សៀតខែលហើយឡើងជិះ នែបុត្ត បាចូរថែទាំរថទាំងនោះចុះ អញប្រគល់រាជ្យដល់បា ។ អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញលុះក្នុងអំណាចនៃកាមទាំងឡាយ ដូចជាក្អែកឆោតឡើយ ។ មេគោ ៦០.០០០ ជាមេគោក្រហម ប្រកបដោយគោខ្វាង ( គោបា ) នែបុត្ត បាចូរថែទាំមេគោទាំងនោះចុះ អញប្រគល់រាជ្យដល់បា ។ អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹងថាសេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញ លុះក្នុងអំណាចនៃកាមទាំងឡាយ ដូចជាក្អែកឆោតឡើយ ។ ស្ត្រី ១៦.០០០ ស្អិតស្អាងដោយគ្រឿងប្រដាប់គ្រប់យ៉ាង មានសំពត់និងអាក-

វណៈដ៏វិចិត្រ ពាក់កុណ្ឌលកែវមណី នៃបុត្ត បាចូរថែទាំស្ត្រី ទាំងនោះចុះ អញប្រគល់រាជ្យដល់បា ។ អញនឹងបួសក្នុង ថ្ងៃនេះឯង អ្នកណាគប្បីដឹងថា សេចក្ដីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញលុះក្នុងអំណាចនៃកាមទាំងឡាយ ដូចជាក្អែកធោត ឡើយ ដូច្នេះ ។

លំដាប់នោះព្រះរាជកុមារក្រាបទូលថា

បពិត្រព្រះវរបិតា កាលដែលទូលព្រះបង្គំជាខ្ញុំនៅក្មេងនៅឡើយ ទូលព្រះបង្គំជាខ្ញុំបានឮថា ព្រះវរមាតាទ្រង់សោយទិវង្គតលាល័យ ទៅហើយ បពិត្រព្រះវរបិតា ទូលព្រះបង្គំជាខ្ញុំព្រាត់ប្រាសចាក ព្រះអង្គហើយ មិនអាចនឹងរស់នៅបានទេ ។ កូនដំរីរមែងទៅ តាមក្រោយដំរីដែលនៅក្នុងព្រៃ ដើរទៅក្នុងជង្ហុកនៃភ្នំទាំងឡាយ ដែលរាបស្មើនិងមិនរាបស្មើ យ៉ាងណាមិញ ។ ទូលព្រះបង្គំ ជាខ្ញុំ នាំយកកូនទៅតាមព្រះអង្គ ក៏យ៉ាងនោះដែរ ទូលព្រះបង្គំ ជាខ្ញុំ ជាបុគ្គលព្រះអង្គចិញ្ចឹមងាយ ពុំមែនព្រះអង្គពិបាកចិញ្ចឹម ឡើយ ដូច្នេះ ។

ព្រះរាជាត្រាស់តបថា

សត្រូវជាអ្នកបំផ្លាញ គប្បីចាប់សំពៅដែលដើរក្នុងសមុទ្រ របស់ពួកពាណិជ ដែលស្វែងរកទ្រព្យក្នុងសមុទ្រនោះ ពួក ពាណិជត្រូវវិនាស យ៉ាងណាមិញ នៃកូនលាមក ឯងនេះ

ធ្វើសេចក្តីអន្តរាយដល់អញ ក៏យ៉ាងនោះដែរ ដូច្នេះ ។

ព្រះរាជកុមារមិនអាចក្រាបទូលពាក្យណាមួយបាន ។ លំដាប់នោះ ព្រះរាជាកាលទ្រង់បង្គាប់ពួកអាមាត្យ ទើបត្រាស់ថា

អ្នកទាំងឡាយ ចូរញ៉ាំងកុមារនេះឲ្យដល់ប្រាសាទ ដែលញ៉ាំងតម្រេកឲ្យចម្រើន ក្នុងប្រាសាទនោះមានពួកស្ត្រីមានដៃស្អិតស្អាងដោយគ្រឿងអាភរណៈធ្វើអំពីមាស ស្ត្រីទាំងនោះ នឹងត្រេកអរចំពោះកុមារនោះ ក្នុងប្រាសាទនោះ ដូចជាពួកស្រីអប្សរ ត្រេកអរនឹងសក្កទេវរាជ កុមារនុ៎ះនឹងត្រេកអរដោយស្ត្រីទាំងនោះ ដូច្នេះ ។

ព្រះសាស្តា កាលទ្រង់ត្រាស់ដឹងហើយ ទើបទ្រង់ត្រាស់អភិសម្ពុទ្ធគាថានេះថា

លំដាប់អំពីនោះមក ពួកអាមាត្យបានញ៉ាំងកុមារឲ្យដល់ប្រាសាទដែលញ៉ាំងតម្រេកឲ្យចម្រើន ឯពួកនាងកញ្ញា ឃើញទីឃាវុកុមារនោះ ជាអ្នកញ៉ាំងដែនឲ្យចម្រើនហើយ ក៏បានពោលថាលោកជាទេវតាឬជាគន្ធព្វ ឬក៏ជាព្រះឥន្ទឈ្មោះបុរិន្ទទៈ លោកជាអ្វី ជាបុត្តនៃអ្នកណា ធ្វើដូចម្តេច យើងនឹងអាចស្គាល់លោកបាន ដូច្នេះ ។

ព្រះរាជកុមារត្រាស់តបថា

យើងមិនមែនជាទេវតា មិនមែនជាគន្ធព្វ ទាំងមិនមែនជាព្រះឥន្ទ

ឈ្មោះបុរិន្ទទទេ យើងជាកូននៃព្រះរាជាក្នុងដែនកាសី ឈ្មោះ ទីឃាវុ ជាអ្នកញ៉ាំងដែនឲ្យចម្រើន នាងទាំងឡាយ ចូរប្រាប់ថា យើងចុះ សេចក្តីចម្រើននឹងមានដល់ពួកនាងទាំងឡាយ យើងជាភស្តារបស់ពួកនាង ដូច្នេះ ។

ព្រះសាស្តា កាលទ្រង់ត្រាស់ដឹងហើយ ទើបទ្រង់ត្រាស់អភិសម្ពុទ្ធគាថានេះថា

ពួកនាងកញ្ញាបានទូលសួរ ទីឃាវុកុមារ នោះដែលញ៉ាំងដែនឲ្យចម្រើន ក្នុងប្រាសាទនោះថា ព្រះរាជាស្តេចយាងទៅក្នុងទីណា ព្រះរាជាស្តេចចេញអំពីទីនេះ ទៅក្នុងទីណា ដូច្នេះ ។

ទីឃាវុកុមារត្រាស់ថា

ព្រះរាជាទ្រង់បានឈានកន្លងភក់ ( រាគាទិក្កិលេស ) ព្រះរាជាទ្រង់បានបិតនៅស៊ប់លើគោក ( ផ្ទុស ) ទ្រង់យាងទៅកាន់ផ្លូវធំ ( ជាទីទៅកាន់សួគ៌និងព្រះនិព្វាន ) ដែលមិនមានបន្លា មិនមានព្រៃញាតស្បាត ( រាគៈ ) ។ ចំណែកយើងជាអ្នកដើរ ទៅកាន់ផ្លូវជាទីទៅកាន់ទុគ្គតិ ប្រកបដោយបន្លា ប្រកបដោយព្រៃញាតស្បាត សម្រាប់ទៅកាន់ទុគ្គតិរបស់ពួកសត្វ ដូច្នេះ ។

ពួកនាងកញ្ញាទូលថា

បពិត្រព្រះរាជា ព្រះអង្គនោះយាងមកល្អហើយ ហាក់ដូចជា

សីហៈដែលមកកាន់គិរិព្វជៈ ( គុហាមាស ) បពិត្រមហារាជ
សូមព្រះអង្គគ្រប់គ្រងចុះ ព្រះអង្គជាម្ចាស់របស់ពួកខ្ញុំម្ចាស់
ទាំងអស់គ្នា ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧិប្បំ** សេចក្ដីថា បើដូច្នោះ ពួកអ្នកចូរប្រញាប់នាំមកចុះ ។ បទថា **អាលបិ** សេចក្ដីថា ព្រះរាជាត្រាស់ព្រះតម្រាស់ជាដើមថា ស្រុកទាំង ៦ ម៉ឺន ដូច្នេះ ទើបទ្រង់រាក់ទាក់ហើយ ។ បទថា **សព្វាលង្ការភូសិតា** អធិប្បាយថាដំរីទាំងនោះតាក់តែងហើយដោយគ្រឿងអលង្ការមានគ្រឿងប្រដាប់សម្រាប់ពាក់ក្បាលជាដើម ។ បទថា **ហេមកប្បនវាសសា** សេចក្ដីថា មានសរីរៈដែលបិទបាំងដោយគ្រឿងស្រោបដែលរំលេចដោយមាស ។ បទថា **គាមណីយេភិ** គឺពួកនាយហត្ថាចារ្យ ។ បទថា **អាជានីយា ច** បានដល់ ជាសេះដែលស្គាល់ហេតុនិងមិនមែនហេតុ តាំងអំពីកើតនោះ ឯង ។ បទថា **សិន្ធវា** បានដល់ សេះដែលកើតត្រង់ឆ្នេរស្ទឹងសិន្ធពក្នុងដែន សិន្ធព ។ បទថា **គាមណីយេភិ** បានដល់ អាចារ្យបង្ហាត់សេះ ។ បទថា **ឥន្ទិយាចាបធារិភិ** សេចក្ដីថា ទ្រទ្រង់ទុកនូវអាវុធ គឺស៊ើនិងធ្នូ ។ បទថា **ឦធា អថោបិ វេយ្យគ្ឃា** បានដល់ មានស្បែកខ្លាដំបងនិងស្បែកខ្លាធំជាគ្រឿងបិទបាំង ។ បទថា **គាមណីយេភិ** បានដល់ អ្នកបររថ ។ បទថា **ចម្មភិ** បានដល់ មានក្រោះដែលពាក់ហើយ ។ បទថា **រោហញ្ញា** បានដល់ មានខ្ទនក្រហម ។ បទថា **បុង្គវូសភា** បានដល់ ប្រកបដោយគោដ៏ប្រសើរ គឺគោឧសភ ។ បទថា **ឧបាវស្សេ មេ** អធិប្បាយថា លំដាប់នោះ ព្រះរាជកុមារ

ក្រាបទូលព្រះបិតាថា បពិត្រព្រះបិតា កាលខ្ញុំនៅកុមារនោះឯង ខ្ញុំបានឮថា ព្រះជននីអស់ព្រះជន្មហើយ ខ្ញុំមិនអាចនឹងមានជីវិតដោយប្រាសចាកទ្រង់បានទេ ។ បទថា **ចោរោ** បានដល់ កូនដ៏វែជំទង់ ។ បទថា **ជេស្សន្តំ** បានដល់ សញ្ចរទៅ ។ បទថា **សាមុទ្ទិកំ** បានដល់ សំពៅដែលសុះទៅក្នុងសមុទ្ទ ។ បទថា **ធនេសិនំ** បានដល់ អ្នកស្វែងរកទ្រព្យ ។ បទថា **វោហារោ** សេចក្តីថា ត្រីកាចក្តី អារក្ខទឹកក្តី ទឹកវល់ក្តី ដែលលេបត្របាក់ខាងក្រោម ឈ្មោះថា ជាអន្តរាយ ជាគ្រឿងនាំចុះដ៏វិចិត្រ ។ បទថា **តត្ថ** បានដល់ ក្នុងសមុទ្ទនោះ ។ បទថា **ពាណិជា ព្យសនី សិយា** សេចក្តីថា លំដាប់នោះ ឈ្មួញទាំងនោះ ក៏នឹងវិនាស គឺគប្បីដល់នូវសេចក្តីវិនាស ។ មួយ៉ាងទៀត បាលីថា **សិយុំ** ក៏មាន ។ បទថា **បុត្តកលិ** បានដល់ កូនអាក្រក់ គឺកូនកាឡកណ្ណី ។ កុមារមិនអាចក្រាបទូលអ្វីបន្តទៅទៀតបាន ។ លំដាប់នោះ ព្រះរាជាកាលទ្រង់បង្គាប់ពួកអាមាត្យ ទើបត្រាស់ព្រះតម្រាស់ថា ចូរញ៉ាំងកុមារនេះ ដូច្នេះជាដើម ។ បទថា **តត្ថ កម្ពុសហត្ថាយោ** សេចក្តីថា មាស ហៅថា **កម្ពុ** អធិប្បាយថា មានដៃតាក់តែងដោយអាភរណៈធ្វើអំពីមាស ។ បទថា **យថា** សេចក្តីថា នារីទាំងនោះ រមែងធ្វើតាមប្រាថ្នា ។

ព្រះមហាសត្វកាលត្រាស់យ៉ាងនេះហើយ ទើបត្រាស់ឲ្យអភិសេកទីឃាវុកុមារនោះក្នុងទីនោះឯង ហើយឲ្យត្រឡប់ចូលកាន់ព្រះនគរ ។ ឯទ្រង់មួយអង្គឯងប៉ុណ្ណោះ ចេញពីព្រះរាជឧទ្យាន ចូលទៅកាន់ព្រៃហិមពាន្ត សាងបណ្ណសាលាត្រង់ភូមិភាគដែលគួរត្រេកអរ ហើយទ្រង់បួសជាឥសី មានឫសឈើនិងផ្លែ

ឈើក្នុងព្រៃជាអាហារ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ។ ឯមហាជនក៏យាង ព្រះរាជកុមារទៅកាន់នគរពារាណសី ។ ព្រះរាជកុមារនោះ ទ្រង់ធ្វើប្រទក្សិណព្រះនគរ ហើយឡើងកាន់ប្រាសាទ ។ បទថា **តំ ទិស្វា អវចុំ កញ្ញា** សេចក្តីថា ពួកអ្នករបាំទាំងនេះ ឃើញព្រះរាជកុមារនោះយាងមកហើយដោយសិរីដ៏ប្រសើរ មានបរិវារច្រើន មិនទាន់ដឹងថា ព្រះរាជកុមារនេះ មានឈ្មោះអ្វី ទើបនាំគ្នាក្រាបទូលសួរ ។ បទថា **មមំ ភរថ** សេចក្តីថា ស្រីទាំងឡាយ ចូរប្រាប្តាចំពោះយើង ។ បទថា **បង្កំ** បានដល់ ភក់គឺកិលេស មានរាគៈជាដើម ។ បទថា **ជលេ** បានដល់ ក្នុងបព្វជ្ជា ។ បទថា **អកាណ្ឌកំ** បានដល់ ប្រាសចាកបន្ទា គឺរាគៈជាដើម ឈ្មោះថា **អគហាណំ** ព្រោះជាព្រៃស្គុក គឺកិលេសទាំងនោះឯង ។ បទថា **មហាបថំ** បានដល់ ទៅកាន់ផ្លូវធំដែលចូលដល់ស្ថានសួគ៌និងព្រះនិព្វាន ។ បទថា **យេន** បានដល់ ព្រះរាជកុមារត្រាស់ថា ជនទាំងឡាយ រមែងដើរទៅកាន់ទុគ្គតិដោយផ្លូវដែលខុសណា អាត្មាអញ ដើរទៅកាន់ផ្លូវខុសនោះ ។ សម័យនោះ ពួកអ្នករបាំទាំងនោះនាំគ្នាគិតថា ព្រះរាជាទ្រង់លះបង់ពួកយើង ចេញបព្វជ្ជាហើយ សូម្បីព្រះរាជកុមារនេះសោត ក៏មានព្រះហឫទ័យត្រេកអរ ក្នុងកាមទាំងឡាយ បើពួកយើងមិនព្រមអភិរម្យជាមួយទ្រង់ ទ្រង់នឹងចេញបព្វជ្ជាទៀត ពួកយើងនឹងធ្វើអាការ គឺការត្រេកអរដល់ទ្រង់ ។ គ្រានោះ ពួកអ្នករបាំ កាលនឹងឲ្យព្រះរាជកុមារត្រេកអរ ទើបក្រាបទូលគាថាចុងក្រោយហើយ ។ បណ្តាបទទាំងនោះ បទថា **គិរិព្វជំ** សេចក្តីថា ការយាងមករបស់ទ្រង់នេះ រាប់ថាជាការយាងមកល្អហើយ ដូច

ស្តេចកេសរសីហរាជ មកកាន់គុហាមាស ដែលជាលំនៅរបស់រាជសីហ៍តូច ដូច្នោះ ។ បទថា **ត្វំ នោ** សេចក្តីថា សូមទ្រង់ជាប្តីជាធំរបស់ពួកខ្ញុំម្ចាស់ចុះ ។

ពួកនារីទាំងនោះ កាលក្រាបទូលយ៉ាងនេះហើយ ក៏ប្រគំតូរ្យតន្ត្រីទាំងពួងឡើង ធ្វើនូវការច្រៀងរាំ មានប្រការផ្សេងៗ ឲ្យប្រព្រឹត្តទៅហើយ កិត្តិយសក៏ក្រៃលែងឡើង ។ ទីឃាវុរាជកុមារនោះ ជាអ្នកដល់ព្រមហើយដោយកិត្តិយស ក៏ទ្រង់មិនបានរឭកដល់ព្រះបិតាឡើយ បានសោយរាជសម្បត្តិដោយធម៌ ប្រព្រឹត្តទៅតាមយថាកម្មហើយ ។ ព្រះពោធិសត្វ បានធ្វើឈាន និងអភិញ្ញាឲ្យកើតឡើងហើយ ក្នុងទីបំផុតនៃព្រះជន្ម ក៏បានកើតក្នុងព្រហ្មលោក ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតចេញមហាភិនេស្រ្កមណ៍តែក្នុងកាលឥឡូវនេះក៏មិនមែន សូម្បីក្នុងកាលមុន ក៏ធ្លាប់ចេញមហាភិនេស្រ្កមណ៍ហើយដូចគ្នា ដូច្នេះហើយ ទើបទ្រង់ប្រជុំជាតកថា ព្រះបច្ចេកពុទ្ធក្នុងកាលនោះ បានបរិនិព្វានហើយ ទីឃាវុកុមារ ក្នុងកាលនោះ បានមកជារាហុល បរិស័ទក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ព្រះបាទអរិន្ទមៈ ក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា សោណកជាតក ចប់

# សង្កិច្ចជាតក

[ ៩០ ] ( អភិសម្ពុទ្ធគាថា ) ( ឧយ្យានបាលនោះ ) ឃើញព្រះរាជាទ្រង់ព្រះនាមព្រហ្មទត្តប្រសើរក្នុងរថហើយ ក្រាបទូលព្រះរាជានោះ ក្នុងគ្រានោះថា ព្រះអង្គជាបុគ្គលឈ្លីធ្លាលដល់ឥសីណា ។ ឥសីឈ្មោះសង្កិច្ចនេះ ដែលគេសន្មតថាជាសប្បុរសរបស់ពួកឥសី មកដល់ហើយ សូមព្រះអង្គប្រញាប់ប្រញាល់ យាងចេញទៅជួបនឹងមហាឥសីឲ្យឆាប់ ។ លំដាប់នោះព្រះរាជាប្រសើរក្នុងរថ មានមិត្តនិងអាមាត្យហែហម ទ្រង់ប្រញាប់ឡើងកាន់រថដែលគេទឹមហើយ ទ្រង់យាងទៅ ។ ព្រះរាជាញ៉ាំងដែននៃពួកកាសីឲ្យចម្រើនទ្រង់ដាក់គ្រឿងកកុធៈ ៥ យ៉ាងគឺ ផ្ចិតរោមសត្វ ១ មកុដ ១ ព្រះខាន់ ១ ឆត្រ ១ សុពណ៌បាទុកា ១ ។ លុះព្រះរាជាទ្រង់យាងចុះអំពីយាន ផ្ទុកគ្រឿងកកុធៈហើយ ទើបយាងចូលទៅរកសង្កិច្ចឥសីដែលអង្គុយក្នុងឧទ្យាន ឈ្មោះទាយបស្សៈ ។ ព្រះរាជានោះចូលទៅសំណេះសំណាលជាមួយនឹងឥសី លុះបញ្ចប់ពាក្យនោះហើយ ក៏គង់ក្នុងទីដ៏សមគួរ ។ ព្រះរាជាគង់ស្ងប់ក្នុងទីសមគួរហើយ ទើបទ្រង់ជ្រាបនូវកាលគួរប្រតិបត្តិ ដើម្បីសួរនូវបាបកម្មទាំងឡាយក្នុងពេលនោះ ។ យើងសូមសួរសង្កិច្ចឥសី ដែលគេសន្មតថាជាសប្បុរសរបស់ពួកឥសី ដែលពួកឥសីចោមរោមហើយ គង់ក្នុងទាយបស្សឧទ្យាន ។ ពួកជនអ្នកប្រព្រឹត្តរំលងធម៌ លុះស្លាប់ទៅវិញទៅកាន់គតិណា ធម៌គឺបិតុឃាតកម្ម ខ្ញុំបានប្រព្រឹត្តកន្លងហើយ ខ្ញុំសួរហើយ សូមលោកប្រាប់សេចក្តីនោះដល់ខ្ញុំ ។

[ ៩១ ] សង្កិច្ចឥសីបានពោលនឹងព្រះរាជាអ្នកញ៉ាំងដែនកាសីឲ្យចម្រើន

គន់ក្នុងទាយបស្សឧទ្យានថា បពិត្រមហារាជ សូមព្រះអង្គទ្រង់ព្រះសណ្ដាប់ពាក្យរបស់អាត្មាភាព ។ អ្នកណាប្រាប់ផ្លូវដល់បុគ្គលអ្នកដើរផ្លូវខុស បើបុគ្គលនោះធ្វើតាមពាក្យរបស់អ្នកប្រាប់នោះ បន្ទា ( ចោរ ) មិនគប្បីចួបនឹងបុគ្គលអ្នកធ្វើតាមនោះទេ ។ អ្នកណាប្រៀនប្រដៅធម៌ដល់បុគ្គលប្រតិបត្តិអធម៌ បើបុគ្គលនោះធ្វើតាមពាក្យរបស់អ្នកប្រដៅនោះ បុគ្គលនោះមិនគប្បីទៅកាន់ទុគ្គតិទេ ។

[ ៩២ ] បពិត្រមហារាជ ធម៌ជាផ្លូវត្រូវ ឯអធម៌ជាផ្លូវខុស អធម៌នាំសត្វទៅកាន់នរក ធម៌ញុំាងសត្វឲ្យដល់សុគតិ ។ បពិត្រព្រះរាជា ពួកជនអ្នកមិនប្រព្រឹត្តធម៌ ចិញ្ចឹមជីវិតខុសគន្លងធម៌ លុះស្លាប់ទៅវិញហើយ រមែងទៅកាន់គតិ ( នរក ) ណា សូមព្រះអង្គព្រះសណ្ដាប់ពាក្យអាត្មាភាព ( ដែលសម្ដែងអំពីនរក ) ទាំងនោះ ។ សញ្ជីវនរក ១ កាឡសុត្ត ១ សង្ឃាដ ១ រោរុវ ២ នរកដទៃទៀតគឺ មហាអវិចិ ១ តាបន ១ បតាបន ១ ។ នរកទាំង ៨ នុ៎ះ ដែលអ្នកប្រាជ្ញទាំងឡាយបានសម្ដែងហើយដោយប្រការដូច្នេះ កម្រមានបុគ្គលណាកន្លងរំលងបាន តាន់តាប់ដោយពួកសត្វ ដែលមានកម្មអាក្រក់ចំពោះមហានរកមួយៗ មានឧស្សទនរក ១៦ ។ ( នរកទាំងនោះ ) ជាទីកំដៅអ្នកកំណាញ់ស្វិតស្វាញ ជានរកដ៏ពន្លឹក មានអណ្ដាតភ្លើង មានភ័យធំ មានសភាពជាទីព្រឺរោម គួរឲ្យស្ញើម បណ្ដាលឲ្យខ្ញបខ្ញួច ជាទុក្ខ ។ ( នរកទាំងនោះ ) មានមុំ ៤ មានទ្វារ ៤ ដែលបាបកម្មចែកវាស់ដោយចំណែក មានកំពែងដែកព័ទ្ធជុំវិញ ប្រក់ដោយក្បឿងដែក ។ ភូមិរបស់នរក

ទាំងនោះ ជាវិការៈនៃដែកឆេះឡើង ប្រកបដោយកំដៅ ( នរកទាំងអស់នោះ ) ផ្សាយទៅអស់ទី ១០០ យោជន៍ជុំវិញ ឋិតនៅសព្វៗកាល ។ ពួកជនអ្នកតិះដៀល ពួកឥសីជាអ្នកសង្រួមមានតបៈនុ៎ះ រមែងធ្លាក់ទៅក្នុងនរកមានជើងឡើងលើមានក្បាលចុះក្រោម ។ ពួកជនអ្នកធ្វើអំពើអាក្រក់ ជាអ្នកបំផ្លិចបំផ្លាញ សេចក្តីចម្រើននោះ ត្រូវពួកនិរយបាលផុត ដូចជាពួកត្រីដែលគេធ្វើឲ្យជាចំណែក ( ដោតអាំង ) អស់ឆ្នាំរាប់មិនអស់ ។ ពួកសត្វនរកមានខ្លួនត្រូវភ្លើងឆេះហើយ ទាំងខាងក្នុងខាងក្រៅជានិច្ច ស្វែងរកនូវទីចេញអំពីនរកតែមិនបាននូវទ្វារ ។ ពួកសត្វនរកនោះ ស្ទុះទៅទិសខាងកើត ស្ទុះអំពីទិសខាងកើតនោះ ទៅទិសខាងលិច ស្ទុះទៅទិសខាងជើង ស្ទុះអំពីទិសខាងជើងទៅទិសខាងត្បូង សត្វនរកទាំងនោះ ទៅដល់ទ្វារណាៗ ទ្វារនោះៗឯងក៏បិទជិត ។ ពួកជនដែលទៅកាន់នរក រងទុក្ខច្រើន ផ្គងដើមដៃកន្ទក់កន្ទេញ អស់សែននៃឆ្នាំជាច្រើន ។ បុគ្គលមិនគប្បីចូលទៅបៀតបៀននូវពួកឥសីដែលមានសភាពជាសប្បុរស ដូចជាបុគ្គលមិនគួរចូលទៅជិតអាសិរពិសដែលខឹងមានតេជះ គេកន្លងរំលងបានដោយក្រ ( ជនទាំងនោះ រមែងធ្លាក់ទៅក្នុងនរក ព្រោះតែបៀតបៀន ) នូវពួកឥសីអ្នកសង្រួម មានតបៈ ។ ព្រះរាជាព្រះនាមអជ្ជុនៈមានខ្នាន់ធ្នូដ៏ប្រសើរ មានពួកពលដ៏ច្រើន ជាអធិបតីក្នុងដែនឈ្មោះកេតកៈ អាចលើកធ្នូដែលពួកខ្នាន់ធ្នូ ៥០០ លើកឡើងបានដោយដើមដៃ ១០០០ បៀតបៀនឥសីឈ្មោះគោតម ហើយវិនាស ។ ព្រះរាជា ទណ្ឌកីបានបាចរោយធូលី ( ស្មោះ ) លើតាបស ឈ្មោះកីសវច្ឆៈមិនមានធូលី

( កិលេស ) ព្រះរាជានោះ ក៏ដល់នូវសេចក្តីវិនាសដូចជាដើមត្នោតដែលគេកាត់ត្រង់គល់ ។ ព្រះរាជាព្រះនាមមេជ្ឈៈ ព្រមទាំងបរិស័ទ ញ៉ាំងចិត្តឲ្យប្រទូស្ត ក្នុងតាបសឈ្មោះ មាតង្គបណ្ឌិត មានយស ហើយក៏ដល់នូវសេចក្តីវិនាស ក្នុងកាលនោះ ដែនឈ្មោះមេជ្ឈៈក៏ទៅជាព្រៃ ។ ពួកព្រះរាជាជាផៅពង្សអន្ធកវេន្ទុ បៀតបៀននូវឥសីឈ្មោះកណ្ហទីបាយនៈ កាន់យកអង្រែសម្លាប់គ្នានឹងគ្នា ហើយក៏ធ្លាក់ទៅក្នុងនរក ។ ព្រះរាជាព្រះនាមចេតិយៈនេះ កាលពីដើមហោះលើអាកាសបាន ដល់មកខាងក្រោយត្រូវកបិលឥសី ផ្តាសាហើយ មានអត្តភាពសាបសូន្យ ចូលទៅកាន់ផែនដី ដល់នូវសេចក្តីស្លាប់ ព្រោះហេតុនោះ បានជាពួកបណ្ឌិតមិនសរសើរអគតិ ៤ មានឆន្ទាគតិជាដើមឡើយ បុគ្គលមានចិត្តមិនប្រទូស្ត គប្បីពោលពាក្យប្រកបដោយសច្ចៈ បើនរណាមានចិត្តប្រទូស្តហើយ សំឡក់ទៅរកអ្នកប្រាជ្ញដែលបរិបូណ៌ដោយវិជ្ជានិងចរណៈ នរៈនោះនឹងធ្លាក់ទៅក្នុងនរកខាងក្រោម ។ ពួកជនណាមានសេចក្តីព្យាយាមអាក្រក់ ជេរប្រទេចពួកចាស់ព្រឹទ្ធាចារ្យ ពួកជននោះ ( លុះទៅកើតក្នុងភពខាងមុខ ) រកកូនគ្មាន រកញាតិគ្មាន ដូចត្នោតកំបុតគល់ ។ ជនណាសម្លាប់បព្វជិតដែលមានកិច្ចធ្វើហើយ អ្នកស្វែងរកនូវគុណដ៏ធំ ជននោះរមែងឆេះ នៅក្នុងកាឡសុត្តនរក អស់កាលជាយូរអង្វែង ។ ព្រះរាជាណា មិនតាំងនៅក្នុងធម៌ កំចាត់កម្ចាយអ្នកដែន ផុតកំដៅអ្នកជនបទ ព្រះរាជានោះ លុះទ្រង់ទិវង្គតទៅ រមែងឆេះនៅក្នុងតាបននរក ។ ព្រះរាជានោះក៏ឆេះអស់សែនឆ្នាំទិព្វ ព្រះរាជានោះ ត្រូវគំនរអណ្តាតភ្លើងហ៊ុំជុំវិញ

ហើយ ក៏រងទុក្ខវេទនាខ្លាំង ។ អណ្តាតភ្លើងទាំងឡាយ ដ៏រន្ធាលប្រាលផ្សៅ ផ្សាយចេញអំពីកាយរបស់សត្វនរកនោះ ខ្លួនរបស់សត្វនរក ដែលមានភ្លើង ជាអាហារ ( មានអណ្តាតភ្លើងតែមួយជាមួយគ្នា ) នឹងចុងរោមទាំងឡាយ ផង នឹងក្រចកទាំងឡាយផង ។ សត្វនរកមានខ្លួនត្រូវភ្លើងឆេះហើយ ទាំង ខាងក្នុងទាំងខាងក្រៅជានិច្ច ត្រូវសេចក្តីទុក្ខចាក់ដោតហើយ ក៏រេទ៍ដូចជា ដំរី ដែលគេចាក់ដោយផ្លៀងកង្វេរ ។ បុរសលាមកណា សម្លាប់បិតាព្រោះ តែលោភៈ ឬព្រោះទោសៈ បុរសលាមកនោះ រមែងឆេះនៅក្នុងកាឡសុត្ត នរក អស់កាលជាយូរអង្វែង ។ បុរសបែបនោះ រមែងឆេះនៅក្នុងលោហ កុម្ភីនរក ពួកនិរយបាល ( នាំចេញ ) នូវសាច់ដ៏ធ្អិន ធ្វើមិនឲ្យមានស្បែក ហើយ ចាក់ដោយលំពែងទាំងឡាយ ធ្វើឲ្យខ្ទាក់ ឲ្យស៊ីនូវមូត្រនិងលាមក ហើយជ្រមុជជនបែបនោះ ទៅក្នុងទឹកខារ ( ទឹកទន់ដែង ) ។ ពួកនិរយ បាល ( ញុំាងសត្វនរកឲ្យស៊ីនូវលាមក ) កំពុងពុះ និងដុំដែកដ៏ក្តៅហើយ យកបណ្តាញដ៏វែងដែលកម្តៅអស់កាលយូរ មកបើកមាត់ ( ហើយបោះ សន្ទូចដែក ) ដែលចងដោយខ្សែ ( ទាញអណ្តាតចេញហើយបោះដុំដែក ) ទៅក្នុងមាត់ដែលប្រហនោះ ។ ពួកឆ្កែក្រហម ឆ្កែពពាល ពួកត្មាត ពួក ក្អែកនិងពួកសត្វស្លាប ( ឯទៀតច្រើនពួក ) មានចំពុះដែកនាំគ្នាមកបោម រោមចឹកជញ្ជែងស៊ីនូវអណ្តាត ( នៃពួកសត្វនរក ) ដែលញាប់ញ័រ ( ដូច ជាស៊ី ) នូវរំពាព្រមទាំងឈាមមានឈាមកំពុងហូរចេញ ។ ពួកនិរយបាល វាយសំពងសត្វនរកនោះ ដែលភ្លើងកំពុងឆេះ មានខ្លួនរយះរយាយដោយ

តម្រេក របស់ពួកនិរយបាលនោះ ចំណែកខាងសត្វនរកទាំងឡាយក្រៅនេះ ក៏ដល់នូវសេចក្តីទុក្ខវេទនា ពួកជនណាទីមួយក្នុងលោកនេះ ជាអ្នកសម្លាប់បិតា ពួកជននោះ តែងទៅនៅក្នុងនរកបែបនុ៎ះ ។ កូនសម្លាប់មាតា លុះទៅអំពីលោកនេះ ទៅកាន់លំនៅរបស់យមរាជ កាន់យកនូវផលនៃកម្មរបស់ខ្លួន ក៏ដល់នូវសេចក្តីទុក្ខយ៉ាងខ្លាំង ។ ពួកអមនុស្ស ( និរយបាល ) ព្រហើនក្រៃលែង យកសរសៃដែក ( មករុំ ) នូវបុគ្គលអ្នកសម្លាប់មាតា ហើយគាប ( ដោយឃ្នាបដែក ) រឿយៗ ។ ពួកនិរយបាល ញុំាងបុគ្គលអ្នកសម្លាប់មាតានោះ ឲ្យផឹកនូវឈាមដ៏ក្តៅ ដែលហូរចេញអំពីកាយរបស់ខ្លួន ដូចជាទឹកទន់ដែងរលាយ ។ បុគ្គលអ្នកសម្លាប់មាតានោះ ចុះទៅ ឋិតនៅក្នុងរណ្តៅគូរទ្ធើម ដូចជាអសុភមានក្លិនស្អុយ មានលាមកជាភក់ មានក្លិនអាក្រក់ ប្រហែលគ្នាដោយខ្ទុះនិងឈាម ។ ក្នុងនរកនោះ មានពួកដង្កូវ មានខ្លួនធំ មានមាត់ដូចម្ជុលដែក រុកត្បុលចូលទៅក្នុងសាច់ និងឈាម ទម្លាយស្បែកសម្បុរថ្ងៃ ហើយស៊ីសត្វនរកនោះ ( ទាំងខួរក្នុងឆ្អឹង ) ។ បុគ្គលអ្នកសម្លាប់មាតានោះ ធ្លាក់ទៅក្នុងនរកនោះ ជ្រមុជ ( ក្បាល ) ចុះទៅ ចំនួន ១០០ ជួរបុរស សាកសពដ៏ស្អុយ ក៏ផ្សាយទៅកាន់ទីចម្ងាយមួយរយយោជន៍ជុំវិញ ។ ព្រោះថា សូម្បីជនមានចក្ខុចុញទ្រាន់ដោយក្លិននោះ ព្រោះអាស្រ័យចក្ខុ បពិត្រព្រះបាទព្រហ្មទត្ត បុគ្គលអ្នកសម្លាប់មាតា តែងបានសេចក្តីទុក្ខបែបនេះ ។ ពួកស្ត្រីរំលូតគភ៌ កន្លងនូវខុរធារានរកដ៏មុត ដែលគេគ្របសង្កត់បានដោយក្រ ធ្លាក់ទៅក្នុងស្ទឹងឈ្មោះ វេត្តរណី ដែលមិនរាបស្មើ ។ ដើម

រកាទាំងឡាយ ជាវិការៈនៃដែក មានបន្ទាប្រវែង ១៦ ធ្នាប់ សំយុងចុះមក ត្រង់ត្រើយទាំងពីរខាងនៃស្ទឹងឈ្មោះវេត្តរណី ដែលមិនរាបស្មើ ។ ដើមរកាទាំងនោះ ត្រូវភ្លើងឆេះមានអណ្តាតខ្ពស់ទៅលើ ១ យោជន៍ដូចជាគំនរភ្លើងអំពីចម្ងាយ ។ ពួកស្រីប្រព្រឹត្តក្បត់ចិត្តប្តី និងពួកប្រុសដែលគប់រកប្រពន្ធគេជនទាំងនុ៎ះ រមែងធ្លាក់ទៅក្នុងសិម្ពលីនរក ដែលក្តៅមានបន្ទាស្រួច ។ ពួកសត្វនរកទាំងនោះ មានក្បាលចុះក្រោម ត្រូវពួកនិរយបាលចាក់ ( ដោយអាវុធ ) ច្រើនដង ក៏វិលធ្លាក់មកវិញ មានខ្លួនធ្លុះធ្លាយ រមែងដេក រមែងភ្ញាក់ អស់កាលជាយូរអង្វែងសព្វៗកាល ។ ( ពួកសត្វនរកត្រូវពួកនិរយបាលចាប់បោះទៅ ) ក្នុងនរកឈ្មោះ លោហកុម្ភី មានឧបមាដោយភ្នំដ៏ធំ មានទឹកស្មើនឹងភ្លើងដ៏ក្តៅ រមែងឆេះអស់កាលកន្លងទៅនៃរាត្រីជាយូរអង្វែង ។ ពួកមនុស្សទ្រុស្តសីល ( គប់រកប្រពន្ធគេ ) ដែលមោហៈគ្របសង្កត់ហើយ រមែងរងកម្មរបស់ខ្លួន ដែលខ្លួនធ្វើអាក្រក់ក្នុងកាលមុន ទាំងថ្ងៃទាំងយប់ យ៉ាងនេះ ។ ប្រពន្ធណាដែលគេទិញមកដោយទ្រព្យ មើលងាយប្តី ម្តាយក្មេក ឪពុកក្មេក បងថ្លៃប្រុស បងថ្លៃស្រី ពួកនិរយបាល តែងទាញដកអណ្តាតព្រមទាំងគល់របស់នាងនោះ ព្រមទាំងចំណងដោយសន្ទូច ។ សត្វនរកនោះ ឃើញអណ្តាតរបស់ខ្លួនប្រមាណមួយព្យាម ពេញដោយដង្កូវ មិនអាចអង្វរ ( ពួកនិរយបាល ) បាន លុះស្លាប់ទៅរមែងឆេះនៅក្នុងតាបននរកទៀត ។ ពួកអ្នកសម្លាប់ចៀម សម្លាប់ជ្រូក សម្លាប់ត្រី ទាក់ម្រឹគ ពួកចោរ ពួកអ្នកសម្លាប់គោ ពួកព្រាន ពួកអ្នកធ្វើគុណក្នុងទោស ( អ្នកញុះញង់ ) ។ ពួក

សត្វនរកនោះ ត្រូវពួកនិរយបាលបៀតបៀនដោយលំពែង ដោយញញួរលោហៈ ដោយសំសែ ដោយព្រួញទាំងឡាយ មានក្បាលសំយុងចុះ ធ្លាក់ទៅក្នុងស្ទឹងខារ ។ អ្នកធ្វើអំពើវៀច ត្រូវពួកនិរយបាលជំដោយញញួរដែកទាំងឡាយ ទាំងល្ងាចទាំងព្រឹកហើយ ស៊ីនូវកំអួតរបស់ពួកសត្វនរកដទៃដែលមានអត្តភាពអាក្រក់នោះសព្វៗកាល ។ ពួកក្អែក ចចក ត្មាត ក្អែកព្រៃមានចំពុះដែក នាំគ្នាចឹកប្រជែងនូវជនអ្នកធ្វើអំពើអាក្រក់កំពុងញាប់ញ័រ ។ ពួកជនណាសម្លាប់ម្រឹគដោយម្រឹគ[១] សម្លាប់បក្សីដោយបក្សី[២] ពួកជននោះជាអសប្បុរសបិទបាំងដោយធូលីគឺរាគាទិក្កិលេស រមែងទៅកាន់ឧស្សទនរក ។

[ ៩៣ ] ពួកសប្បុរសក្នុងលោកនេះ មានកម្មសន្សំល្អហើយ តែងទៅកាន់លោកខាងលើ សូមព្រះអង្គ ទតមើលផលនៃអំពើដែលគេបានសន្សំល្អដូចពួកទេវតា ព្រមទាំងព្រះឥន្ទ្រ ព្រមទាំងព្រះព្រហ្ម បពិត្រមហារាជ អាត្មាភាព ពោលហេតុនោះនឹងព្រះអង្គ បពិត្រព្រះអង្គជាម្ចាស់នៃដែន សូមព្រះអង្គប្រព្រឹត្តធម៌ បពិត្រព្រះរាជា អំពើដែលព្រះអង្គប្រព្រឹត្តល្អនោះ មិនគប្បីដុតកម្តៅរឿយៗក្នុងកាលជាខាងក្រោយយ៉ាងណាៗ សូមព្រះអង្គ ប្រព្រឹត្តធម៌យ៉ាងនោះៗចុះ ។

**ចប់ សង្កិច្ចជាតកទី ២ ។**

---

១-២-យកម្រឹគឬបក្សីផងគ្នាធ្វើជាធ្នាក់ ។

## ឧទ្ទាននៃសង្គិនិបាត

អ្នកទាំងឡាយ ចូរស្ដាប់ភាសិតរបស់ខ្ញុំក្នុងសង្គិនិបាតបន្ទាប់អំពី បញ្ញាសនិបាតនោះគឺ និយាយអំពីឈ្មោះជាតកដ៏ប្រសើរ ដែលហៅថា សោណកតាបស និងព្រះរាជាទ្រង់ព្រះនាមអរិន្ទមៈ ១ ព្រះរាជាដ៏ប្រសើរក្នុងរថដែលយើងពោលហើយដូច្នេះ និងសង្កិច្ចឥសី ១ ។

## ចប់ សង្គិនិបាត ។

## អដ្ឋកថា

## សង្កិច្ចជាតក

[ ៩០-៩៣ ] ព្រះសាស្ដា កាលគង់នៅក្នុងជីវកម្ពវនារាម ទ្រង់ប្រារព្ធបិតុឃាតកម្ម របស់ព្រះបាទអជាតសត្តុ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ទិស្វា និសិន្នំ រាជានំ** ដូច្នេះជាដើម ។

សេចក្ដីពិស្ដារថា ព្រះបាទអជាតសត្តុនោះ អាស្រ័យទេវទត្តភិក្ខុ បានឲ្យផ្ដាច់ព្រះជន្មព្រះបិតា តាមពាក្យរបស់ទេវទត្ត ហើយទ្រង់បានដំណឹងថា ទេវទត្តមានបរិស័ទបែកគ្នា ក្នុងកាលទីបំផុតនៃការបំបែកសង្ឃ កាលមានរោគកើតឡើង ទើបគិតថា អញនឹងញ៉ាំងព្រះតថាគតឲ្យអត់ទោសដល់អញដូច្នេះហើយ ទើបទៅកាន់ក្រុងសាវត្ថីដោយគ្រែស្នែង ត្រូវផែនដីស្រូបក្បែរទ្វារវត្តជេតពន ទើបទ្រង់ត្រិះរិះថា ទេវទត្តជាបដិបក្ខចំពោះព្រះសម្មាសម្ពុទ្ធ

ចូលទៅកាន់ផែនដី មានអវិចិមហានរកដែលប្រព្រឹត្តទៅខាងមុខ សូម្បីខ្ញុំនអញ ក៏បានផ្តាច់ព្រះជន្មព្រះបិតា ដែលជាធម្មរាជាតាំងនៅក្នុងធម៌ ក៏ព្រោះអាស្រ័យទេវទត្តនោះ ខ្ញុំនអញត្រូវផែនដីស្រូបដែរឬហ្ន៎ ដូច្នេះហើយ ទើបភ័យខ្លាច មិនមានការត្រេកអរក្នុងចិត្ត សូម្បីក្នុងរាជសម្បត្តិ ទ្រង់គិតថា អញនឹងដេកឲ្យលក់បន្តិច គ្រាន់តែទៀបលក់ប៉ុណ្ណោះ ក៏ប្រាកដដូចនិរយបាលមកប្រានឲ្យធ្លាក់ទៅក្នុងផែនដីដែកកម្រាស់ ៩ យោជន៍ ហើយចាក់ដោយលំពែងដែក ឬមានអាការដូចត្រូវឆ្កែទាំងឡាយខាំសាច់ស៊ី ទើបទ្រង់បន្លឺព្រះសូរសៀងដោយសំឡេងដែលគួរខ្លាច ហើយក្រោកឡើង ។

ក្នុងកាលតមក ក្នុងថ្ងៃពេញបូណ៌មី នៃខែទី ៤ ដែលជារដូវផ្កាកុមុទរីក ( ខែកត្តិក ) ព្រះបាទអជាតសត្តុ មានពួកអាមាត្យចោមរោម ហើយទតឃើញឥស្សរិយយសរបស់ទ្រង់ ទើបត្រិះរិះថា ឥស្សរិយយសនៃព្រះបិតារបស់អញក្រៃលែងជាងនេះ អញត្រាស់ឲ្យផ្តាច់ព្រះជន្មរបស់ទ្រង់ ដែលជាធម្មរាជាបែបនោះ ព្រោះអាស្រ័យទេវទត្ត ។ កាលទ្រង់ព្រះតម្រិះយ៉ាងនេះឯង ការក្តៅក្រហាយកើតឡើងក្នុងព្រះវរកាយ ព្រះសរីរៈគ្រប់ចំណែកក៏ជោកជាំដោយញើស ។ ក្នុងលំដាប់នោះ ទើបទ្រង់ព្រះតម្រិះថា នរណាហ្ន៎ អាចបន្ទោបង់ភ័យនេះរបស់អញបាន ដូច្នេះហើយ ទ្រង់ជ្រាបថា បុគ្គលដទៃ វៀរព្រះទសពលហើយ រមែងមិនមាន ទើបទ្រង់ព្រះតម្រិះថា អាត្មាអញដល់នូវការខុសធំក្រៃលែងចំពោះព្រះតថាគត នរណាហ្ន៎ នឹងនាំអញទៅគាល់ទ្រង់បានទ្រង់កំណត់ថា អ្នកដទៃក្រៅអំពីពេទ្យជីវក មិនមានពិត ទ្រង់កាន់យក

ការសម្រេចព្រះហឫទ័យនោះ ទ្រង់ធ្វើឧបាយដែលនឹងយាងទៅ បន្លឺឧទានថា អ្នកដ៏ចម្រើន រាត្រីនេះ មានព្រះចន្ទភ្លឺច្បាស់ គួរត្រេកអរពិតៗ ហ្ន៎ ហើយត្រាស់ថា ថ្ងៃនេះ យើងគួរទៅរកសមណៈ ឬព្រាហ្មណ៍ទីណាល្អហ្ន៎ កាលសេវកាមាត្យជាសាវ័ករបស់បូរណកស្សបៈជាដើម ពោលពណ៌នាគុណរបស់គ្រូទាំង ៦ មានបូរណកស្សបៈជាដើម ឲ្យស្ដាប់ ទ្រង់ក៏មិនជឿពាក្យរបស់អ្នកទាំងនោះ បែរជាត្រាស់សួរដល់ពេទ្យជីវក សូម្បីពេទ្យជីវកនោះក៏ពោលសរសើរគុណរបស់ព្រះតថាគតជាមុន ហើយក្រាបទូលថា បពិត្រព្រះអង្គសូមទ្រង់យាងទៅគាល់ព្រះសាស្ដាអង្គនោះចុះ ដូច្នេះ ទើបទ្រង់ត្រាស់ឲ្យត្រៀមយានពាហនៈគឺដំរី ហើយយាងទៅកាន់ជីវកម្ពវ័ន ចូលទៅគាល់ព្រះតថាគតអង្គនោះ ថ្វាយបង្គំហើយ ទ្រង់បានទទួលបដិសណ្ឋារៈអំពីព្រះតថាគត ទើបទូលសួរដល់សាមញ្ញផលដែលគប្បីឃើញដោយខ្លួនឯង ទ្រង់បានស្ដាប់ព្រះធម្មទេសនា ពោលដោយសាមញ្ញផលដ៏ពីរោះ របស់ព្រះតថាគតហើយ ក្នុងកាលចប់ការសម្ដែងសាមញ្ញផលសូត្រ ទ្រង់បានប្រកាសខ្លួនជាឧបាសក ឲ្យព្រះតថាគតទ្រង់អត់ទោសហើយ ទើបទ្រង់យាងត្រឡប់ ។ ចាប់តាំងពីកាលនោះមក ព្រះរាជាក៏ទ្រង់ថ្វាយទាន រក្សាសីល ទ្រង់សេពគប់ជាមួយព្រះតថាគត ទ្រង់ស្ដាប់ធម្មកថាដ៏ពីរោះ ព្រោះបានគប់រកកល្យាណមិត្ត ទើបទ្រង់លះបង់នូវការតក់ស្លុតបាន លោមជាតិដែលព្រឺព្រួចក៏បាត់ទៅបាននូវការសប្បាយព្រះហឫទ័យ សម្រេចឥរិយាបថ ៤ ដោយសេចក្ដីក្សេម ។

ថ្ងៃមួយ ភិក្ខុទាំងឡាយនាំគ្នាសន្ទនា ក្នុងធម្មសភាថា នែអាវុសោទាំង

ឡាយ ព្រះបាទអជាតសត្តុធ្វើបិតុឃាតកម្មហើយ ទ្រង់តក់ស្លុត មិនបានទូវសេចក្តីក្សេមក្នុងព្រះរាជហឫទ័យ ព្រោះអាស្រ័យសិរីរាជសម្បត្តិ ទ្រង់សោយតែសេចក្តីទុក្ខគ្រប់ឥរិយាបថ ឥឡូវនេះ ទ្រង់អាស្រ័យព្រះតថាគតក៏អស់នូវសេចក្តីតក់ស្លុត ព្រោះការសេពគប់ជាមួយកល្យាណមិត្ត ទើបបានសោយនូវសេចក្តីសុខក្នុងឥស្សរិយសម្បត្តិ ។ ព្រះសាស្តា យាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះបាទអជាតសត្តុ ធ្វើបិតុឃាតកម្មហើយ នៅជាសុខ ព្រោះអាស្រ័យតថាគតក្នុងកាលឥឡូវនេះ ក៏មិនមែន សូម្បីក្នុងកាលមុន ធ្វើបិតុឃាតកម្មហើយ ក៏នៅជាសុខ ព្រោះអាស្រ័យតថាគតដូចគ្នាដូច្នេះហើយ ទ្រង់នាំអតីតនិទានមកត្រាស់ថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ នៅក្នុងនគរពារាណសី ទ្រង់មានព្រះរាជឱរសព្រះនាមថា ព្រហ្មទត្តកុមារ ក្នុងកាលនោះព្រះពោធិសត្វ បដិសន្ធិក្នុងផ្ទះរបស់បុរោហិត កាលព្រះពោធិសត្វនោះកើតហើយ មាតាបិតា បានដាក់ឈ្មោះថា សំកិច្ចកុមារ ។ ព្រហ្មទត្តកុមារ និងសំកិច្ចកុមារទាំង ២ នោះ ចម្រើនវ័យជាមួយគ្នាក្នុងរាជនិវេសន៍ ។ ជនទាំង ២ ជាសម្លាញ់នឹងគ្នា កាលចម្រើនវ័យហើយ ទើបនាំគ្នាទៅរៀននូវសិប្បៈក្នុងនគរតក្កសិលា រៀននូវសិប្បៈទាំងអស់ចប់ហើយ ទើបត្រឡប់មក ។ ព្រះរាជាទ្រង់ព្រះរាជទានឋានន្តរសក្តិជាឧបរាជដល់ព្រះរាជឱរស ។ ព្រះពោធិ-

សត្វក៏បានទៅក្នុងសម្នាក់ឧបរាជដូចគ្នា ។ ក្នុងកាលជាខាងក្រោយមក ឧបរាជបានឃើញឥស្សរិយយសក្រៃលែងរបស់ព្រះបិតា ដែលទ្រង់ប្រពាតព្រះឧទ្យានក៏កើតសេចក្តីលោភក្នុងរាជសម្បត្តិ ទើបទ្រង់ព្រះតម្រិះថា ព្រះបិតាអញក៏ដូចព្រះភាតារបស់អញ បើអញរង់ចាំទម្រាំព្រះបិតានេះសោយទិវង្គត អញក៏នឹងបានរាជសម្បត្តិក្នុងកាលឯចាស់ រាជសម្បត្តិដែលអញបានក្នុងកាលដែលអញចាស់នោះ នឹងមានប្រយោជន៍អ្វី អញនឹងផ្តាច់ព្រះជន្មព្រះបិតាចោលជណ្តើមយករាជសម្បត្តិ ដូច្នេះហើយ ប្រាប់សេចក្តីនោះឲ្យព្រះពោធិសត្វដឹង ។ ព្រះពោធិសត្វក៏ក្រាបទូលឃាត់ថា នែសម្លាញ់ ធម្មតាបិតុឃាត ជាកម្មធ្ងន់ ជាផ្លូវនៃនរក បុគ្គលមិនអាចធ្វើកម្មនេះបានទេ សូមទ្រង់កុំធ្វើឡើយ ។ ឧបរាជនោះត្រាស់ឧបាយនោះរឿយៗ ត្រូវព្រះពោធិសត្វជំទាស់អស់វារៈ ៣ ដង ទើបប្តូរទៅប្រឹក្សាជាមួយអ្នកបម្រើជិតស្និទ្ធ ។ ជនទាំងនោះទទួលធានាហើយក៏រកឧបាយដើម្បីផ្តាច់ព្រះជន្មព្រះរាជា ព្រះពោធិសត្វដឹងដល់ព្រឹត្តិការណ៍នោះ គិតថា អញមិនទៅរួមជាមួយបុគ្គលពាលនេះបានទេ ដូច្នេះហើយ ទើបមិនបានលាមាតាបិតា ចេញទៅតាមទ្វារធំ ហើយចូលកាន់ព្រៃហិមពាន្ត បួសជាឥសី បំពេញឈាន និងអភិញ្ញាឲ្យកើតឡើងហើយ មានឫសឈើនិងផ្លែឈើក្នុងព្រៃជាអាហារ ជាអ្នកនៅដោយផាសុក ។ ក្នុងសម័យនោះ ព្រះរាជកុមារ ក៏ប្រើឲ្យមនុស្សសម្លាប់ព្រះបិតា ហើយសោយឥស្សរិយយសធំក្រៃលែង ។ ពួកកុលបុត្តទាំងឡាយជាច្រើន គ្រាន់តែដឹងថា សំកិច្ចកុមារបួសជាឥសីហើយ ទើបនាំគ្នាចេញបួស ក្នុងសម្នាក់នៃសំកិច្ចតាបសនោះ ។

សំកិច្ចឥសីនោះ មានពួកឥសីជាច្រើនចោមរោមហើយ នៅក្នុងហិមវន្តប្បទេស នោះ ។ សូម្បីតាបសទាំងអស់ ក៏បាននូវសមាបត្តិដូចគ្នា ។ ឯព្រះរាជា កាលឲ្យ មនុស្សសម្លាប់បិតាហើយ ក៏សោយសេចក្តីសុខក្នុងរាជសម្បត្តិ អស់កាល មានប្រមាណបន្តិចបន្តួចប៉ុណ្ណោះ បន្ទាប់អំពីនោះ ក៏តក់ស្លុតភ័យខ្លាច មិនបាន នូវការត្រេកអរ ហាក់ដូចត្រូវទណ្ឌកម្មក្នុងនរក ។ ព្រះរាជា ទ្រង់រឭកដល់ព្រះ ពោធិសត្វហើយ ទ្រង់ត្រិះរិះថា សម្លាញ់របស់អញ បានហាមប្រាមហើយ ថា បិតុឃាតកម្មជាកម្មធ្ងន់ កាលគេមិនអាចឲ្យអញកាន់យកពាក្យរបស់ខ្លួន បាន ទើបសម្តែងខ្លួនឲ្យអត់ទោស ហើយគេចចេញទៅ បើគេនៅក្នុងទីនេះ សោត គង់មិនព្រមឲ្យអញធ្វើបិតុឃាតកកម្មដោយពិត គប្បីនាំភ័យនេះរបស់ អញទៅ ឥឡូវនេះ គេនៅទីណាហ្ន៎ បើអញដឹងលំនៅរបស់គេ នឹងឲ្យ មនុស្សទៅហៅមក អ្នកណាហ្ន៎ គប្បីប្រាប់លំនៅរបស់គេ ដល់អញបាន ។ តាំងអំពីកាលនោះមក ព្រះរាជាត្រាស់សរសើរគុណរបស់ព្រះពោធិសត្វតែ ម្យ៉ាង ទាំងខាងក្នុងព្រះរាជវាំងនិងខាងក្នុងរាជសភា ។ ពេលវេលាកន្លងទៅ យូរ យ៉ាងនោះ ព្រះពោធិសត្វ នៅក្នុងព្រៃហិមពាន្តបាន ៥០ ឆ្នាំ ក៏គិតថា ព្រះរាជាទ្រង់រឭកដល់អញ អញគួរទៅក្នុងរាជសម្នាក់នោះ ហើយសម្តែង ធម៌ដល់ទ្រង់ ធ្វើទ្រង់ឲ្យអស់ការតក់ស្លុត ដូច្នេះហើយ មានតាបស ៥០០ ជាបរិវារ នាំគ្នាមកតាមអាកាស ចុះក្នុងឧទ្យានឈ្មោះទាយបស្សៈ មានពួក ឥសីជាបរិវារ អង្គុយត្រង់ផ្ទាំងថ្ម ។ អ្នកយាមឧទ្យានឃើញពួកឥសីនោះ ទើប សួរថា បពិត្រលោកម្ចាស់ សាស្តានៃគណៈមានឈ្មោះដូចម្តេច លុះបានស្តាប់

ថា ឈ្មោះសំកិច្ចបណ្ឌិត ដូច្នេះ សូម្បីខ្លួនឯងក៏ចាំបាន ប្រាប់ឲ្យជ្រាបថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់បង្អង់នៅក្នុងទីនេះ ទម្រាំខ្ញុំយាងព្រះរាជាមក ព្រះរាជារបស់ពួកខ្ញុំ ទ្រង់មានបំណងជួបលោកម្ចាស់ដូច្នេះ ថ្វាយបង្គំហើយ ទើបប្រញាប់ទៅកាន់ព្រះរាជវាំង ក្រាបទូលដល់ព្រះរាជាថា សំកិច្ចនោះមកហើយ ។ ព្រះរាជា យាងទៅកាន់សម្នាក់របស់ព្រះពោធិសត្វនោះ ទ្រង់ធ្វើសក្ការបូជាដ៏សមគួរដែលទ្រង់គប្បីធ្វើ ប្រគេនហើយទើបត្រាស់សួរបញ្ហា ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

( ឧយ្យានបាលនោះ ) ឃើញព្រះរាជា ទ្រង់ព្រះនាមព្រហ្មទត្ត ប្រសើរក្នុងរថហើយ ក្រាបទូលព្រះរាជានោះ ក្នុងគ្រានោះថា ព្រះអង្គជាបុគ្គលឈ្មោលដល់ឥសីណា ។ ឥសីឈ្មោះសត្តិច្ចនេះ ដែលគេសន្មតថា ជាសប្បុរសរបស់ពួកឥសីមកដល់ហើយ សូមព្រះអង្គប្រញាប់ប្រញាល់ យាងចេញទៅជួបនឹងមហាឥសីឲ្យឆាប់ ។ លំដាប់នោះ ព្រះរាជាប្រសើរក្នុងរថ មានមិត្តនឹងអាមាត្យហែហម ទ្រង់ប្រញាប់ឡើងកាន់រថ ដែលគេទឹមហើយ ទ្រង់យាងទៅ ។ ព្រះរាជាញុំាងដែនពួកកាសីឲ្យចម្រើន ទ្រង់ដាក់គ្រឿងកកុធៈ ៥ យ៉ាង គឺ ផ្ចិតរោមសត្វ ១ មកុដ ១ ព្រះខាន់ ១ ឆត្រ ១ សុពណ៌បាទុកា ១ ។ លុះព្រះរាជាទ្រង់យាងចុះអំពីយាន ផុកគ្រឿងកកុធៈហើយ ទើបយាងចូលទៅរកសត្តិច្ចឥសី ដែល

អង្គុយក្នុងឧទ្យាន ឈ្មោះទាយបស្សៈ ។ ព្រះរាជានោះចូល ទៅសំណេះសំណាលជាមួយនឹងឥសី លុះបញ្ចប់ពាក្យនោះ ហើយ ក៏គង់ក្នុងទីដ៏សមគួរ ។ ព្រះរាជាគង់ស៊ប់ក្នុងទីសម គួរហើយ ទើបទ្រង់ជ្រាបនូវកាលគួរប្រតិបត្តិ ដើម្បីសួរនូវ បាបកម្មទាំងឡាយក្នុងពេលនោះ ។ យើងសូមសួរសង្កិច្ច- ឥសី ដែលគេសន្មតថា ជាសប្បុរសរបស់ពួកឥសី ដែល ពួកឥសីចោមរោមហើយ គង់ក្នុងទាយបស្សឧទ្យាន ។ ពួក ជនអ្នកប្រព្រឹត្តរំលងធម៌ លុះស្លាប់ទៅវិញ ទៅកាន់គតិណា ធម៌ គឺបិតុឃាតកម្ម ខ្ញុំបានប្រព្រឹត្តកន្លងហើយ ខ្ញុំសួរហើយ សូមលោកប្រាប់សេចក្ដីនោះដល់ខ្ញុំ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឱស្វា** សេចក្ដីថា ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកយាមឧទ្យាននោះឃើញព្រះរាជាប្រថាប់គង់ក្នុងរាជ- សភា ទើបក្រាបទូលឲ្យទ្រង់ជ្រាបហើយ ។ កាលក្រាបទូលឲ្យទ្រង់ជ្រាប ទើបក្រាបទូលដោយពាក្យថា **យស្សាសិ** ដូច្នេះ ។ បទថា **យស្សាសិ** សេចក្ដីថា បពិត្រមហារាជ ទ្រង់ករុណា មានព្រះហឫទ័យទន់ភ្លន់ដល់បុគ្គលណា អធិប្បាយថា ទ្រង់រឭកដល់គុណរបស់បុគ្គលណារឿយៗ បុគ្គលនោះ គឺ សំកិច្ចឥសី ដែលគេតែងសរសើរថា ជាអ្នកបានល្អហើយក្នុងពួកឥសីទាំង ឡាយ មកដល់ហើយដោយលំដាប់ មានពួកឥសីចោមរោម អង្គុយលើផ្ទាំង ថ្ម ក្នុងព្រះរាជឧទ្យានរបស់ទ្រង់ ល្អប្រៀបដូចបដិមាមាស ដូច្នោះ ។ បទថា

**តរមានរូបោ** សេចក្តីថា បពិត្រមហារាជ ធម្មតាបព្វជិតទាំងឡាយ ជាអ្នកមិនប្រឡូកប្រឡំក្នុងត្រកូល ឬក្នុងពួកគណៈ កាលទ្រង់ចូលទៅ មិនទាន់ដល់ ខ្លាចក្រែងឥសីគេចទៅមុន ព្រោះដូច្នោះ សូមទ្រង់ប្រញាប់ចេញទៅជួបលោកអ្នកស្វែងរកគុណធំ ព្រោះលោកស្វែងរកគុណ មានសីលជាដើមដែលធំក្រៃលែង ។ បទថា **តតោ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ព្រះរាជាអង្គនោះ លុះទ្រង់ស្តាប់ពាក្យរបស់អ្នកយាមឧទ្យាននោះហើយ ទ្រង់ប្រញាប់ចូលទៅ ក្នុងលំដាប់នៃពាក្យក្រាបទូលរបស់ឧទ្យានបាលមួយរំពេច ។ បទថា **និក្ខិប្ប** សេចក្តីថា បានឮថា ព្រះរាជាអង្គនោះ លុះទ្រង់ដល់ទ្វារព្រះរាជឧទ្យាន ក៏ទ្រង់នឹកក្នុកឡើងថា ធម្មតាបព្វជិតទាំងឡាយ ជាអ្នកតាំងនៅក្នុងឋានៈដែលគួរគោរព អញមិនគួរទៅកាន់សម្នាក់របស់សំកិច្ចតាបស ដោយភេទខ្ពង់ខ្ពស់ ទើបដោះគ្រឿងរាជកកុធភណ្ឌ ៥ យ៉ាង គឺផ្ចិតវាលវីជនីមានដងជាមាស ប្រដាប់ដោយកែវមណី ១ មកុដធ្វើដោយមាស ១ ព្រះខ័នមង្គលដែលខ្ចប់ទុកល្អហើយ ១ ស្វេតច្ឆត្រ ១ សុវណ្ណបាទុកា ១ ព្រោះហេតុនោះទើបពោលថា ទ្រង់ដាក់... ដូច្នេះ ។ បទថា **បដិច្ចទំ** សេចក្តីថា ទ្រង់ទុកគ្រឿងរាជកកុធភណ្ឌនោះឯង គឺទ្រង់ទុកក្នុងដៃអ្នករក្សាឃ្លាំង ។ បទថា **ទាយបស្សន្នំ** បានដល់ ក្នុងឧទ្យានដែលមានឈ្មោះ យ៉ាងនោះ ។ បទថា **អថ កាលំ អមញ្ញថ** សេចក្តីថា លំដាប់នោះ ព្រះរាជាទ្រង់ជ្រាបថា ពេលនេះជាពេលដែលសួរបញ្ហាបាន តែក្នុងបាលីថា **យថា កាលំ** ដូច្នេះ អធិប្បាយថា ទ្រង់សម្គាល់ការសួរបញ្ហាដោយសមគួរដល់កាល ដែលទ្រង់

យានមកហើយ ។ បទថា **បដិបន្នំ** បានដល់ ប្រព្រឹត្តទៅហើយ ។ បទថា **បេច្ច** សេចក្តីថា លះទៅហើយ ម្យ៉ាងទៀត ពាក្យថា លះទៅហើយនោះ ជាឈ្មោះនៃបរលោក ព្រោះហេតុនោះទើបសំដៅដល់បរលោក ។ បទថា **មយា** សេចក្តីថា ព្រះរាជាត្រាស់សួរថា បពិត្រលោកម្ចាស់ ខ្ញុំបានប្រព្រឹត្តកន្លងសុចរិតធម៌ហើយ គឺបានធ្វើបិតុឃាតកម្មហើយ សូមលោកម្ចាស់ ប្រាប់សេចក្តីនោះដល់ខ្ញុំចុះថា អ្នកសម្លាប់បិតាទៅកាន់គតិណាគឺនេះក្នុងនរកណា ។

ព្រះពោធិសត្វបានស្តាប់ពាក្យនោះហើយ ទើបក្រាបទូលថា សូមថ្វាយព្រះពរ បើដូច្នោះ សូមទ្រង់តាំងព្រះហឫទ័យស្តាប់ចុះ ហើយទើបថ្វាយឱវាទជាលំដាប់ដំបូង ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

សង្កិច្ចឥសីបានពោលនឹងព្រះរាជា អ្នកញ៉ាំងដែនកាសីឲ្យចម្រើន គង់ក្នុងទាយបស្សឧទ្យានថា បពិត្រមហារាជ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ ពាក្យរបស់អាត្មាភាព ។ អ្នកណា ប្រាប់ផ្លូវដល់បុគ្គលអ្នកដើរផ្លូវខុស បើបុគ្គលនោះ ធ្វើតាមពាក្យរបស់អ្នកប្រាប់នោះ បន្ទា ( ចោរ ) មិនគប្បីចួបនឹងបុគ្គលអ្នកធ្វើតាមនោះទេ ។ អ្នកណា ប្រៀនប្រដៅធម៌ដល់បុគ្គលប្រតិបត្តិអធម៌ បើបុគ្គលនោះ ធ្វើតាមពាក្យរបស់អ្នកប្រដៅនោះ បុគ្គលនោះ មិនគប្បីទៅកាន់ទុគ្គតិទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧប្បថេន** បានដល់ ផ្លូវដែលពួកចោរពួន

ស្កាត់ ។ បទថា **មគ្គមនុសាសតិ** សេចក្តីថា ប្រាប់ផ្លូវដ៏ក្សេមឲ្យ ។ បទថា **ឆាស្ស មគ្គេយ្យ កណ្ដកោ** សេចក្តីថា បន្ទា គឺពួកចោរមិនគប្បីឃើញមុខរបស់បុរសដែលធ្វើតាមឱវាទនោះ ដែលដើរតាមផ្លូវនោះឡើយ ។ បទថា **យោ ធម្មំ** បានដល់ ដែលប្រាប់សុចរិតធម៌ ។ បទថា **ឆ សោ** សេចក្តីថា បុរសនោះ មិនគប្បីដល់ទុគ្គតិផ្សេងៗ មាននរកជាដើម បពិត្រមហារាជ អធម៌ដូចគ្នានឹងផ្លូវខុស សុចរិតធម៌ដូចគ្នានឹងផ្លូវក្សេម កាលមុនទ្រង់បានប្រាប់ដល់អាត្មាថា យើងនឹងផ្តាច់ព្រះជន្មព្រះបិតា ហើយនឹងធ្វើជាព្រះរាជាឯងសូម្បីត្រូវអាត្មាឃាត់ហើយ ក៏មិនស្តាប់ពាក្យរបស់អាត្មាឡើយ សម្លាប់ព្រះបិតាហើយ ទ្រង់សោយសោក ឥឡូវនេះ ធម្មតាបុគ្គលដែលមិនធ្វើតាមឱវាទរបស់បណ្ឌិតទាំងឡាយ ក៏ដូចគ្នានឹងបុគ្គលដែលដើរទៅតាមផ្លូវ មានចោរ រមែងដល់នូវសេចក្តីវិនាសធំ ដូច្នេះ ។

ព្រះពោធិសត្វ កាលបានថ្វាយឱវាទដល់ព្រះរាជាអង្គនោះ យ៉ាងនេះហើយ កាលនឹងសម្តែងធម៌ឲ្យក្រៃលែងឡើង ទើបទូលថា

> បពិត្រមហារាជ ធម៌ជាផ្លូវត្រូវ ឯអធម៌ជាផ្លូវខុស អធម៌នាំសត្វទៅកាន់នរក ធម៌ញ៉ាំងសត្វឲ្យដល់សុគតិ ។ បពិត្រព្រះរាជា ពួកជនអ្នកមិនប្រព្រឹត្តធម៌ ចិញ្ចឹមជីវិតខុសគន្លងធម៌ លុះស្លាប់ទៅវិញហើយ រមែងទៅកាន់គតិ ( នរក ) ណា សូមព្រះអង្គព្រះសណ្តាប់ពាក្យអាត្មាភាព ( ដែលសម្តែងអំពីនរក ) ទាំងនោះ ។ សញ្ជីវនរក ១ កាឡសុត្ត

១ សង្ឃាដ ១ រោរុវ ២ នរកដទៃទៀតគឺ មហាអវីចិ ១ តាបន ១ បតាបន ១ ។ នរកទាំង ៨ នុ៎ះ ដែលអ្នកប្រាជ្ញទាំងឡាយបានសម្តែងហើយ ដោយប្រការដូច្នេះ កម្រមានបុគ្គលណា កន្លងរំលងបាន តាន់តាប់ដោយពួកសត្វដែលមានកម្មអាក្រក់ ចំពោះមហានរកមួយៗ មានឧស្សទនរក ១៦ ។ ( នរកទាំងនោះ ) ជាទីកំដៅអ្នកកំណាញ់ ស្វិតស្វាញ ជានរកដ៏ពន្លឹក មានអណ្តាតភ្លើង មានភ័យធំ មានសភាពជាទីព្រឺរោម គួរឲ្យស្ញើមបណ្តាលឲ្យខ្ញបខ្ញច ជាទុក្ខ ។ ( នរកទាំងនោះ ) មានមុំ ៤ មានទ្វារ ៤ ដែលបាបកម្ម ចែកវាស់ដោយចំណែក មានកំពែងដែកព័ទ្ធជុំវិញ ប្រក់ដោយគ្រឿងដែក ។ ភូមិរបស់នរកទាំងនោះ ជាវិការៈនៃដែកឆេះឡើង ប្រកបដោយកំដៅ ( នរកទាំងអស់នោះ ) ផ្សាយទៅអស់ទី ១០០ យោជន៍ជុំវិញ ឋិតនៅសព្វៗកាល ។ ពួកជន អ្នកតិះដៀល ពួកឥសីជាអ្នកសង្រួមមានតបៈនុ៎ះ រមែងធ្លាក់ទៅក្នុងនរក មានជើងឡើងលើ មានក្បាលចុះក្រោម ។ ពួកជនអ្នកធ្វើអំពើអាក្រក់ ជាអ្នកបំផ្លិចបំផ្លាញសេចក្តីចម្រើននោះ ត្រូវពួកនិរយបាលដុត ដូចជាពួកត្រីដែលគេធ្វើឲ្យជាចំណែក ( ដោតអាំង ) អស់ឆ្នាំរាប់មិនអស់ ។ ពួកសត្វនរក មានខ្លួនត្រូវភ្លើងឆេះហើយទាំងខាង

ក្នុងខាងក្រៅជានិច្ច ស្វែងរកនូវទីចេញអំពីនរក តែមិនបាន នូវទ្វារ ។ ពួកសត្វនរកនោះស្ទុះទៅទិសខាងកើត ស្ទុះអំពី ទិសខាងកើតនោះ ទៅទិសខាងលិច ស្ទុះទៅទិសខាងជើង ស្ទុះអំពីទិសខាងជើង ទៅទិសខាងត្បូង សត្វនរកទាំងនោះ ទៅដល់ទ្វារណាៗ ទ្វារនោះៗឯងក៏បិទជិត ។ ពួកជនដែល ទៅកាន់នរក រងទុក្ខច្រើន ផ្គងដើមដៃកន្ទក់កន្ទេញអស់សែន នៃឆ្នាំជាច្រើន ។ បុគ្គលមិនគប្បីចូលទៅបៀតបៀន នូវពួក ឥសីដែលមានសភាពជាសប្បុរស ដូចជាបុគ្គលមិនគួរចូល ទៅជិតអាសិរពិស ដែលខឹង មានតេជះ គេកន្ទង់រំលងបាន ដោយក្រ ( ជនទាំងនោះ រមែងធ្លាក់ទៅក្នុងនរក ព្រោះតែ បៀតបៀន ) នូវពួកឥសីអ្នកសង្រួម មានតបៈ ។ ព្រះរាជា ព្រះនាមអជ្ជុនៈមានខ្នាន់ធ្នូដ៏ប្រសើរ មានពួកពលដ៏ច្រើន ជា អធិបតីក្នុងដែនឈ្មោះ កេតកៈ អាចលើកធ្នូដែលពួកខ្នាន់ធ្នូ ៥០០ លើកឡើងបានដោយដើមដៃ ១០០០ បៀតបៀនឥសី ឈ្មោះ គោតម ហើយវិនាស ។ ព្រះរាជាទណ្ឌកីបានបាច រោយធូលី ( ស្មោះ ) លើតាបសឈ្មោះកីសវច្ឆៈ មិនមាន ធូលី ( កិលេស ) ព្រះរាជានោះ ក៏ដល់នូវសេចក្តីវិនាស ដូចជាដើមត្នោតដែលគេកាត់ត្រង់គល់ ។ ព្រះរាជាព្រះនាម មេជ្ឈៈព្រមទាំងបរិស័ទ ញុំាងចិត្តឲ្យប្រទូស្តក្នុងតាបសឈ្មោះ

មាតង្គបណ្ឌិត មានយស ហើយក៏ដល់នូវសេចក្តីវិនាស ក្នុងកាលនោះដែនឈ្មោះមេជ្ឈៈ ក៏ទៅជាព្រៃ ។ ពួកព្រះរាជាជាផៅពង្សអន្ធកវេណ្ឌុ បៀតបៀនទូវឥសីឈ្មោះ កណ្ហទីបាយនៈ កាន់យកអង្រែសម្លាប់គ្នានឹងគ្នា ហើយក៏ធ្លាក់ទៅក្នុងនរក ។ ព្រះរាជាព្រះនាម ចេតិយៈ នេះ កាលពីដើមហោះលើអាកាសបាន ដល់មកខាងក្រោយ ត្រូវកបិលឥសីផ្តាសាហើយ មានអត្តភាពសាបសូន្យ ចូលទៅកាន់ផែនដី ដល់នូវសេចក្តីស្លាប់ ព្រោះហេតុនោះ បានជាពួកបណ្ឌិត មិនសរសើរអគតិ ៤ មានឆន្ទាគតិជាដើមឡើយ បុគ្គលមានចិត្តមិនប្រទូស្ត គប្បីពោលពាក្យប្រកបដោយសច្ចៈ បើនរណាមានចិត្តប្រទូស្តហើយ សម្លក់ទៅរកអ្នកប្រាជ្ញដែលបរិបូណ៌ដោយវិជ្ជា និងចរណៈ នរៈនោះនឹងធ្លាក់ទៅក្នុងនរកខាងក្រោម ។ ពួកជនណាមានសេចក្តីព្យាយាមអាក្រក់ ជេរប្រទេចពួកចាស់ព្រឹទ្ធាចារ្យ ពួកជននោះ ( លុះទៅកើតក្នុងភពខាងមុខ ) រកកូនគ្មាន រកញាតិគ្មាន ដូចត្នោតកំបុតគល់ ។ ជនណាសម្លាប់បព្វជិតដែលមានកិច្ចធ្វើហើយ អ្នកស្វែងរកនូវគុណដ៏ធំ ជននោះរមែងឆេះនៅក្នុងកាឡសុត្តនរកអស់កាលជាយូរអង្វែង ។ ព្រះរាជាណា មិនតាំងនៅក្នុងធម៌ កំចាត់កំចាយអ្នកដែន ដុតកំដៅអ្នកជនបទ ព្រះរាជានោះ លុះទ្រង់ទិវង្គតទៅ រមែង

ឆេះនៅក្នុងតាបននរក ។ ព្រះរាជានោះ ក៏ឆេះអស់សែនឆ្នាំទិព្វ ព្រះរាជានោះ ត្រូវគំនរអណ្តាតភ្លើងហ៊ុមជុំវិញហើយ ក៏រងទុក្ខវេទនាខ្លាំង ។ អណ្តាតភ្លើងទាំងឡាយដ៏ខ្ទោលប្រាលផ្កា ផ្សាយចេញអំពីកាយរបស់សត្វនរកនោះ ខ្លួនរបស់សត្វនរកដែលមានភ្លើងជាអាហារ ( មានអណ្តាតភ្លើងតែមួយជាមួយគ្នា ) នឹងចុងរោមទាំងឡាយផង និងក្រចកទាំងឡាយផង ។ សត្វនរកមានខ្លួនត្រូវភ្លើងឆេះហើយ ទាំងខាងក្នុងទាំងខាងក្រៅជានិច្ច ត្រូវសេចក្តីទុក្ខចាក់ដោតហើយ ក៏រេទ៍ដូចជាដីដែលគេ ចាក់ដោយឆៀនកន្ធេរ ។ បុរសលាមកណា សម្លាប់បិតា ព្រោះតែលោភៈ ឬព្រោះទោសៈ បុរសលាមកនោះ រមែងឆេះនៅក្នុងកាឡសុត្តនរក អស់កាលជាយូរអង្វែង ។ បុរសបែបនោះ រមែងឆេះនៅក្នុងលោហកុម្ភីនរក ពួកនិរយបាល ( នាំចេញ ) នូវសាច់ដ៏ឆ្អិន ធ្វើមិនឲ្យមានស្បែក ហើយចាក់ដោយលំពែងទាំងឡាយ ធ្វើឲ្យខ្វាក់ឲ្យស៊ីនូវមូត្រ និងលាមក ហើយជ្រមុជជនបែបនោះទៅក្នុងទឹកខារ ( ទឹកទន់ដែង ) ។ ពួកនិរយបាល ( ញុំាងសត្វនរកឲ្យស៊ីនូវលាមក ) កំពុងពុះ និងដុំដែកដ៏ក្តៅ ហើយយកបណ្តាញដ៏វែង ដែលកំដៅអស់កាលយូរ មកបើកមាត់ ( ហើយបោះសន្ទូចដែក ) ដែលចងដោយខ្សែ ( ទាញ

អណ្តាតចេញហើយបោះដុំដែក ) ទៅក្នុងមាត់ ដែលប្រេហ នោះ ។ ពួកឆ្កែក្រហម ឆ្កែពពាល ពួកត្មាត ពួកក្អែក និង ពួកសត្វស្លាប ( ឯទៀតច្រើនពួក ) មានចំពុះដែក នាំគ្នា មកចោមរោមចឹកជញ្ជែងស៊ីនូវអណ្តាត ( នៃពួកសត្វនរក ) ដែលញាប់ញ័រ ( ដូចជាស៊ី ) នូវរំពាព្រមទាំងឈាមមាន ឈាមកំពុងហូរចេញ ។ ពួកនិរយបាលវាយសំពងសត្វនរក នោះ ដែលភ្លើងកំពុងឆេះ មានខ្លួនរយះរយាយ ដោយតម្រេក របស់ពួកនិរយបាលនោះ ចំណែកខាងសត្វនរកទាំងឡាយក្រៅ នេះ ក៏ដល់នូវសេចក្តីទុក្ខវេទនា ពួកជនណានីមួយក្នុងលោក នេះ ជាអ្នកសម្លាប់បិតា ពួកជននោះ តែងទៅនៅក្នុងនរក បែបនុ៎ះ ។ កូនសម្លាប់មាតា លុះទៅអំពីលោកនេះ ទៅកាន់ លំនៅរបស់យមរាជ កាន់យកនូវផលនៃកម្មរបស់ខ្លួន ក៏ដល់ នូវសេចក្តីទុក្ខយ៉ាងខ្លាំង ។ ពួកអមនុស្ស ( និរយបាល ) ព្រហើនក្រៃលែង យកសរសៃដែក ( មករុំ ) នូវបុគ្គល អ្នកសម្លាប់មាតា ហើយគាប ( ដោយឃ្នាបដែក ) រឿយៗ ។ ពួកនិរយបាល ញុាំងបុគ្គលអ្នកសម្លាប់មាតានោះ ឲ្យផឹកនូវ ឈាមដ៏ក្តៅ ដែលហូរចេញអំពីកាយរបស់ខ្លួន ដូចជាទឹក ទន់ដែងរលាយ ។ បុគ្គលអ្នកសម្លាប់មាតានោះ ចុះទៅឋិត នៅក្នុងរណ្តៅគួរខ្ពើមដូចជាអសុក មានក្លិនស្អុយ មានលាមក

ជាភក់ មានក្លិនអាក្រក់ ប្រហែលគ្នាដោយខ្ទុះនិងឈាម ។ ក្នុងនរកនោះ មានពួកដង្កូវមានខ្លួនធំ មានមាត់ដូចម្ជុលដែក វុកត្បុលចូលទៅក្នុងសាច់និងឈាម ទម្លាយស្បែកសម្បុរថ្ងៃ ហើយស៊ីសត្វនរកនោះ ( ទាំងខួរក្នុងឆ្អឹង ) ។ បុគ្គលអ្នកសម្លាប់មាតានោះ ធ្លាក់ទៅក្នុងនរកនោះ ជ្រមុជ ( ក្បាល ) ចុះទៅចំនួន ១០០ ជួរបុរស សាកសពដ៏ស្អុយ ក៏ផ្សាយទៅកាន់ទីចម្ងាយមួយរយយោជន៍ជុំវិញ ។ ព្រោះថា សូម្បីជនមានចក្ខុចុញទ្រាន់ដោយក្លិននោះ ព្រោះអាស្រ័យចក្ខុ បពិត្រព្រះបាទព្រហ្មទត្ត បុគ្គលអ្នកសម្លាប់មាតា តែងបានសេចក្តីទុក្ខបែបនេះ ។ ពួកស្ត្រីរំលូតគភ៌ កន្លងនូវខុរធារនរកដ៏មុតដែលគេគ្របសង្កត់បានដោយក្រ ធ្លាក់ទៅក្នុងស្ទឹងឈ្មោះវេត្តរណី ដែលមិនរាបស្មើ ។ ដើមរកាទាំងឡាយ ជាវិការៈនៃដែក មានបន្ទាប្រវែង ១៦ ធ្នាប់ សំយុងចុះមកត្រង់ត្រើយទាំងពីរខាងនៃស្ទឹងឈ្មោះវេត្តរណី ដែលមិនរាបស្មើ ។ ដើមរកាទាំងនោះ ត្រូវភ្លើងឆេះមានអណ្តាតខ្ពស់ទៅលើ ១ យោជន៍ដូចជាគំនរភ្លើងអំពីចម្ងាយ ។ ពួកស្រីប្រព្រឹត្តក្បត់ចិត្តប្តី និងពួកប្រុស ដែលគប់រកប្រពន្ធគេ ជនទាំងនុ៎ះ រមែងធ្លាក់ទៅក្នុងសិម្ពលីនរក ដែលក្តៅមានបន្លាស្រួច ។ ពួកសត្វនរកទាំងនោះ មានក្បាលចុះក្រោម ត្រូវពួកនិរយបាល

ចាក់ ( ដោយអាវុធ ) ច្រើនជង់ ក៏វិលធ្លាក់មកវិញ មានខ្លួនធុះធ្លាយ រមែងដេក រមែងភ្ញាក់ អស់កាលជាយូរអង្វែងសព្វៗកាល ។ ( ពួកសត្វនរកត្រូវពួកនិរយបាលចាប់បោះទៅ ) ក្នុងនរកឈ្មោះ លោហកុម្ភី មានឧបមាដោយក្អមដ៏ធំមានទឹកស្មើនឹងភ្លើងដ៏ក្តៅ រមែងឆេះ អស់កាលកន្លងទៅនៃរាត្រីជាយូរអង្វែង ។ ពួកមនុស្សទ្រុស្តសីល ( គប់រកប្រពន្ធគេ ) ដែលមោហៈគ្របសង្កត់ហើយ រមែងរងកម្មរបស់ខ្លួនដែលខ្លួនធ្វើអាក្រក់ក្នុងកាលមុន ទាំងថ្ងៃទាំងយប់យ៉ាងនេះ ។ ប្រពន្ធណា ដែលគេទិញមកដោយទ្រព្យ មើលងាយប្តី ម្តាយក្មេក ឪពុកក្មេក បងថ្លៃប្រុស បងថ្លៃស្រី ពួកនិរយបាលតែងទាញជកអណ្តាត ព្រមទាំងគល់របស់នាងនោះ ព្រមទាំងចំណងដោយសន្ទូច ។ សត្វនរកនោះ ឃើញអណ្តាតរបស់ខ្លួនប្រមាណមួយព្យាម ពេញដោយដង្កូវមិនអាចអង្វរ ( ពួកនិរយបាល ) បាន លុះស្លាប់ទៅ រមែងឆេះនៅក្នុងតាបននរកទៀត ។ ពួកអ្នកសម្លាប់ចៀម សម្លាប់ជ្រូក សម្លាប់ត្រី ទាក់ម្រឹគ ពួកចោរ ពួកអ្នកសម្លាប់គោ ពួកព្រាន ពួកអ្នកធ្វើគុណក្នុងទោស ( អ្នកញុះញង់ ) ។ ពួកសត្វនរកនោះ ត្រូវពួកនិរយបាល បៀតបៀនដោយលំពែង ដោយញញួរ លោហៈ ដោយសំសែ ដោយព្រួញទាំងឡាយ មាន

ក្បាលសំយុងចុះ ធ្លាក់ទៅក្នុងស្ទឹងខារ ។ អ្នកធ្វើអំពើវៀច ត្រូវពួកនិរយបាល ដំដោយញញួរដែកទាំងឡាយ ទាំងល្ងាច ទាំងព្រឹក ហើយស៊ីនូវកំអួតរបស់ពួកសត្វនរកដទៃ ដែល មានអត្តភាពអាក្រក់នោះ សព្វៗកាល ។ ពួកក្អែក ចចក ត្មាត ក្អែកព្រៃ មានចំពុះដែក នាំគ្នាចឹកប្រជែងនូវជនអ្នក ធ្វើអំពើអាក្រក់កំពុងញាប់ញ័រ ។ ពួកជនណា សម្លាប់ម្រឹគ ដោយម្រឹគ សម្លាប់បក្សីដោយបក្សី ពួកជននោះជាអសប្បុរស បិទបាំងដោយធូលី គឺរាគាទិក្កិលេស រមែងទៅកាន់ឧស្សទ នរក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធម្មោ បថោ** សេចក្តីថា ធម៌ គឺកុសល កម្មបថ ១០ ប្រការ ជាផ្លូវក្សេម មិនមានភ័យចំពោះមុខ ជាផ្លូវដែលទៅ កាន់សុគតិ ។ បទថា **វិសមជីវិនោ** បានដល់ សម្រេចការចិញ្ចឹមជីវិតដោយ អធម៌ ។ បទថា **និរយេ** សេចក្តីថា អាត្មានឹងពោលនរកដែលកើតដល់សត្វ ទាំងនេះ ដល់ទ្រង់ ។ បទថា **សុណោហិ មេ** សេចក្តីថា មហាសត្វត្រូវ ព្រះរាជាត្រាស់សួរដល់នរក ដែលពួកជនអ្នកសម្លាប់បិតាទៅកើត ក៏មិនបាន សម្តែងនរកនោះភ្លាម ទើបពោលយ៉ាងនេះ ដើម្បីសម្តែងមហានរក ៨ និង ឧស្សទនរក ១៦ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះបើមហាសត្វសម្តែង នរក ដែលត្រាស់សួរនោះភ្លាម ព្រះរាជាគប្បីបែកព្រះហឫទ័យ សោយ ទិវង្គតក្នុងទីនោះដោយពិត ។ កាលព្រះរាជាទតឃើញសត្វទាំងឡាយ ដែល

ឆេះក្នុងនរកទាំងនេះ រមែងកាន់យកជាគំរូ ទ្រង់មានឧបការៈ ដែលកើតព្រម ហើយ ដោយទ្រង់យល់ថា សត្វដទៃ ក៏មានកម្មអាក្រក់ ច្រើនដូចអញដែរ អញនឹងឆេះក្នុងនរកទាំងនេះ ដូច្នេះហើយ ក៏ជាអ្នកមិនមានរោគ គឺសេចក្តីខ្លាច កាលមហាសត្វសម្តែងនរកទាំងនោះ ក៏ធ្វើផែនដីឲ្យបែកជា ២ ចំណែក ដោយកម្លាំងឫទ្ធិជាមុនហើយ ទើបសម្តែងជាក្រោយ អត្ថនៃពាក្យទាំងនោះ មានដូចតទៅនេះថា សត្វនរកទាំងឡាយ ដែលនាយនិរយបាលកាន់អាវុធផ្សេងៗ ដែលឆេះទ្រលោមហើយ កាត់ឲ្យជាកំណាត់ តូច ធំ រមែងមានជីវិតរឿយៗក្នុងនរកនេះ ហេតុនោះ ទើបនរកនោះឈ្មោះថា សញ្ជីវៈ ( នរកដែលរស់ឡើងឯង ) ។ នាយនិរយបាលទាំងឡាយ នាំគ្នាស្រែកហ៊ោជាប់គ្នាមិនដាច់ កាន់អាវុធ មានប្រការផ្សេងៗ ដែលឆេះដោយភ្លើង ដេញតាមសម្លាប់សត្វនរកទាំងឡាយ ដែលកំពុងរត់គេចទៅលើផែនដីដែក ដែលឆេះដោយភ្លើង កាលសត្វដួលចុះលើផែនដី ដែលឆេះដោយភ្លើងហើយ ទើបសន្ទឹងខ្សែបន្ទាត់ដែក ដែលឆេះដោយភ្លើង ហើយកាន់ពូថៅដែលឆេះដោយភ្លើងនាំគ្នាស្រែក ធ្វើសត្វនរក ដែលកំពុងយំសោកដោយសំឡេងដ៏ខ្លាចផ្សាធ្វើសត្វនរកឲ្យដាច់ជា ៨ ចំណែកខ្លះ ១៦ ចំណែកខ្លះក្នុងនរកនេះ ហេតុនោះ ទើបនរកនោះ ឈ្មោះថា កាឡសុត្តៈ ( នរកអំបោះខ្មៅ ) ។ ភ្នំដែកធំៗដែលឆេះដោយភ្លើងជាច្រើន កិនសត្វនរកក្នុងនរកនេះ ហេតុនោះ ទើបនរកនោះ ឈ្មោះថា សង្ឃាដៈ ( នរកភ្នំទង្គិច ) បានឮថា និរយបាលទាំងឡាយ ឲ្យសត្វនរកចូលទៅក្នុងផែនដីដែក ដែលឆេះដោយភ្លើងកម្រាស់

៩ យោជន៍ ត្រឹមចង្កេះហើយ មិនឲ្យកម្រើកខ្លួនបានក្នុងនរកនោះ លំដាប់នោះ ភ្នំដែកធំៗ ដែលឆេះដោយភ្លើង នៅត្រង់ទិសខាងកើត កក្រើកលាន់សំឡេងដូចអសនីបាត រមៀលមកកិនសត្វនរកទាំងនោះ ដូចគេបុកល្ង ធ្វើឲ្យល្អិតផង់ ហើយទៅដល់ទិសខាងលិច ភ្នំដែកដែលកើតឡើងក្នុងទិសខាងលិច ក៏រមៀលមកយ៉ាងនោះឯង រហូតដល់ទិសខាងកើត ម្យ៉ាងទៀត ភ្នំទាំង ២ បានរមៀលមកជួបគ្នា ហើយកិនសត្វនរក ដូចគេកៀបអំពៅក្នុងគ្រឿងយន្តសម្រាប់គាបដូច្នោះ សត្វនរកទាំងឡាយ រមែងសោយទុក្ខក្នុងសង្ឃាដនរកនោះអស់ច្រើនសែនឆ្នាំ ដោយប្រការដូច្នេះ ។

បទថា **ទ្វេ ច រោរុវា** សេចក្តីថា រោរុវនរកមាន ២ គឺជាលរោរុវៈ ១ ធូមរោរុវៈ ១ ។ បណ្តារោរុវៈទាំង ២ នោះ ជាលរោរុវៈ ពេញទៅដោយអណ្តាតភ្លើង ដែលក្រហមដូចឈាម តាំងនៅអស់កប្ប ។ ធូមរោរុវៈ ពេញទៅដោយផ្សែងខារ ។ ក្នុងរោរុវៈទាំង ២ នោះ អណ្តាតភ្លើងនឹងចូលទៅតាមទ្វារទាំង ៩ របស់សត្វនរក ដែលឆេះក្នុងជាលរោរុវៈហើយ ទើបដុត គឺឆេះសរីរៈ ។ ផ្សែងខារចូលទៅតាមទ្វារទាំង ៩ របស់សត្វនរកដែលឆេះក្នុងធូមរោរុវៈហើយ ទើបធ្វើសរីរៈឲ្យស្រុសជាផេះផង់ ដូចគ្នានឹងម្សៅដូច្នោះ ។ សត្វនរកឆេះក្នុងនរកទាំង ២ នោះ រមែងស្រែកខ្លាំង ទើបលោកហៅនរកទាំង ២ នោះថា រោរុវៈ ( នរកដែលមានសម្រែកពោទ៍ខ្លាំង ) ។ ភាពទទេ គឺចន្លោះផ្សែងនិងអណ្តាតភ្លើង និងសេចក្តីទុក្ខរបស់សត្វដែលឆេះក្នុងនរកនោះ មិនមានក្នុងនរកនេះ ហេតុនោះទើបនរកនោះ ឈ្មោះថា អវីចិ

( នរកមិនមានចន្លោះ ) ។ អវីចិនរក ជាកន្លែងធំ ទើបឈ្មោះថា មហាអវីចិ ។ ពិតហើយ ក្នុងមហាអវីចិនោះ អណ្តាតភ្លើងទាំងឡាយ តាំងឡើងអំពីជញ្ជាំងទិសខាងកើត ជាដើម ហើយបាញ់រហូតមកដល់ជញ្ជាំងទិសខាងលិច ទម្លុះជញ្ជាំងទៅបានមួយរយយោជន៍ អណ្តាតភ្លើងដែលតាំងពីខាងក្រោម បាញ់ដល់ខាងលើ អណ្តាតភ្លើងដែលតាំងឡើងខាងលើ បាញ់មកដល់ខាងក្រោម អណ្តាតភ្លើងទាំងឡាយ ក្នុងអវីចិមហានរកនេះ រមែងមិនមានចន្លោះ យ៉ាងនេះ ឯទីប្រមាណ ១០០ យោជន៍ ខាងក្នុងមហានរកនោះ ពេញទៅដោយសត្វទាំងឡាយ មិនមានចន្លោះឡើយ ដូចនាឡិពេញទៅដោយម្សៅនិងទឹកដោះ ដូច្នោះ ប្រមាណនៃសត្វដែលឆេះ រមែងមិនមានដោយឥរិយាបថទាំង ៤ សត្វទាំងនោះ រមែងមិនបៀតបៀននូវគ្នានឹងគ្នា រមែងឆេះក្នុងទីរៀងៗខ្លួនប៉ុណ្ណោះ ។ ឈ្មោះថារវាងចន្លោះនៃសត្វទាំងឡាយក្នុងមហានរកនេះ រមែងមិនមាន ដោយប្រការដូច្នេះ ។ ឧបេក្ខាដែលជាអកុសលវិបាក ៦ ដ៏សេសរមែងជាអព្វោហារិក ព្រោះសេចក្តីទុក្ខក្នុងមហានរកនោះ មានកម្លាំងដុតរឿយៗ ប្រៀបដូចតំណក់នៃទឹកឃ្មុំ ៦ តំណក់ត្រង់ចុងអណ្តាត រមែងជាអព្វោហារិក ព្រោះតំណក់របស់ទង់ដែង ដែលជាចំណែកទី ៧ ជារបស់មានកម្លាំង ដុតរឿយៗ ដូច្នោះ ។ ទុក្ខប៉ុណ្ណោះ រមែងប្រាកដ គឺរមែងប្រាកដមិនមានចន្លោះ ឈ្មោះថាចន្លោះនៃសេចក្តីទុក្ខក្នុងមហានរកនេះ រមែងមិនមាន ដោយប្រការដូច្នេះ ។ អវីចិមហានរកនេះ រួមទាំងជញ្ជាំងទាំងឡាយ វាស់ដោយពុះពាក់កណ្តាល បាន ៣១៨ យោជន៍ វាស់ដោយជុំវិញ ៩៥៤ យោជន៍ រួមទាំង

ឧស្សទនរកផង ជាមួយម៉ឺនយោជន៍ បណ្ឌិតគប្បីជ្រាបភាពដែលអវីចិមហានរកនោះ មានទីកន្លែងធំ មានប្រមាណប៉ុណ្ណេះ ។ នរកណាដុតសត្វទាំងឡាយមិនឲ្យកម្រើកបាន ព្រោះហេតុនោះ ទើបនរកនោះ ឈ្មោះថា តាបនៈ ( នរកដុតរោល ) ។ នរកណា ញុំាងសត្វទាំងឡាយឲ្យក្តៅពន់ពេក ព្រោះហេតុនោះទើបនរកនោះ ឈ្មោះថា បតាបនៈ ( នរកដុតរោលខ្លាំង ) ។ នាយនិរយបាលទាំងឡាយ រមែងឲ្យសត្វអង្គុយលើលំពែងដែក ដែលឆេះសន្ធោសន្ធៅ មានប្រមាណប៉ុនដើមត្នោត ក្នុងតាបនៈនរកនោះ ផែនដីខាងក្រោមអំពីទីនោះ រមែងឆេះសន្ធោសន្ធៅ ចំណែកលំពែងមិនឆេះដោយភ្លើង សត្វទាំងឡាយ រមែងឆេះជាអណ្តាតភ្លើង នរកនោះ រមែងដុតសត្វមិនឲ្យកម្រើកបាន ដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត នាយនិរយបាល រមែងប្រហារសត្វដែលកើតក្នុងនរកក្រៅអំពីនេះ ដោយអាវុធទាំងឡាយ ដែលភ្លើងកំពុងឆេះហើយ ឲ្យឡើងកាន់ភ្នំដែកមានភ្លើងឆេះ ក្នុងកាលដែលសត្វទាំងនោះឈរលើកំពូលភ្នំ ខ្យល់មានកម្មជាបច្ច័យ រមែងបក់បោកសត្វទាំងនោះ សត្វទាំងនោះ មិនអាចទ្រទ្រង់ខ្លួនបាន មានជើងឡើងលើ មានក្បាលចុះក្រោម ធ្លាក់មក ។ លំដាប់នោះ លំពែងដែកដែលឆេះសន្ធោសន្ធៅ រមែងផុសឡើងអំពីផែនដីដែកខាងក្រោម សត្វនរកទាំងនោះ ជល់ក្បាលនឹងលំពែងដែកនោះឯង មានរាងកាយធ្លុះចូលក្នុងលំពែងដែលកំពុងឆេះ ។ នរកនោះ រមែងដុតសត្វឲ្យក្តៅពន់ពេក ដោយប្រការដូច្នេះ ។

ព្រះពោធិសត្វ កាលសម្តែងនរកទាំងនោះឲ្យប្រាកដ ទើបសម្តែង

សញ្ជីវនរកជាមុន ព្រោះបានឃើញនរកទាំងឡាយ ដែលឆេះក្នុងសញ្ជីវនរក នោះ មហាជនក៏កើតការតក់ស្លុតពន់ពេក ទើបឲ្យសញ្ជីវនរកនោះអន្តរធាន ទៅ ធ្វើផែនដីឲ្យបែកជា ២ ម្តងទៀត ទើបបង្ហាញកាឡសុត្តនរក លុះការ តក់ស្លុតក្រៃលែងកើតឡើងដល់មហាជន ព្រោះបានឃើញសត្វទាំងឡាយ ឆេះក្នុងកាឡសុត្តនរកបែបនោះ ទើបបណ្តាលឲ្យកាឡសុត្តនរកនោះអន្តរធាន ទៅ ។ ព្រះពោធិសត្វសម្តែងនរក ដោយលំដាប់យ៉ាងនេះ ដោយប្រការ ដូច្នេះ ។ លំដាប់នោះ ទើបព្រះពោធិសត្វយាងព្រះរាជាមក ហើយក្រាប ទូលថា បពិត្រមហារាជ ទ្រង់គួរទតសត្វទាំងឡាយដែលឆេះក្នុងមហានរក ទាំង ៨ រណ្តៅនេះខ្លះ ដើម្បីទ្រង់បំពេញអប្បមាទធម៌ ដូច្នេះហើយ បំណាង នឹងពោលដល់កិច្ចនៃមហានរកទាំងនោះ ដដែលម្តងទៀត ទើបពោលពាក្យ ជាដើមថា នរកទាំង ៨ នុ៎ះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អក្ខាតា** សេចក្តីថា នរកទាំង ៨ រណ្តៅ ដែលអាត្មាទូលហើយដល់ព្រះអង្គនេះ បណ្ឌិតទាំងឡាយក្នុងកាលមុន ក៏ធ្លាប់ ពោលទុកហើយដូចគ្នា ។ បទថា **អាកិណ្ណា** បានដល់ បរិបូណ៌ ។ បទថា **បច្ចេកា សោឡសុស្សទា** សេចក្តីថា មហានរកទាំង ៨ រណ្តៅនេះ រណ្តៅ នីមួយៗ មានទ្វារ ៤ ត្រង់ទិសនៃទ្វារនីមួយៗ មានឧស្សទនរក ៤ ដូច្នេះ ទើបមហានរកនីមួយៗ មានឧស្សទនរក ១៦ រួមឧស្សទនរកទាំងអស់ ជា ១២៨ រណ្តៅ យកមហានរក ៨ មកបញ្ចូលជានរក ១៣៦ រណ្តៅ ដោយ ប្រការដូច្នេះ ។ បទថា **កទរិយតាបនា** សេចក្តីថា នរកទាំងអស់នេះ ជា

ទីធ្វើបុគ្គលដែលរីងត្អឹងឲ្យក្តៅ ឈ្មោះថា **ឃោរា** ព្រោះមានទុក្ខខ្លាំងក្លា ឈ្មោះថា **ឥច្ចិមន្តោ** ព្រោះមានអណ្តាតភ្លើងកើតឡើងហើយតាំងនៅអស់កប្ប ឈ្មោះថា **មហព្ភយា** ព្រោះគួរខ្លាចដ៏ខ្លាំងក្លា ឈ្មោះថា **លោមហំសនរូបា ច** ព្រោះត្រឹមតែបុគ្គលឃើញ ក៏ព្រឺរោមព្រឺស្បែក ឈ្មោះថា **ភេស្មា** ព្រោះគួរខ្លាចគួរក្រែង ឈ្មោះថា **បដិភយា** ព្រោះជាទីកើតនៃភ័យ ឈ្មោះថា **ទុក្ខា** ព្រោះមិនមានសេចក្តីសុខ ។ បទថា **ចតុក្កណ្ណា** បានដល់ នរកទាំងអស់ ដូចគ្នានឹងហឹប ៤ ជ្រុង ។ បទថា **វិភត្តា** បានដល់ ចែកជាទ្វារ ៤ ទិស ។ បទថា **ភាគសោ មិតា** បានដល់ តាំងទុកជាចំណែកៗ ដោយអំណាចទ្វារនិងផ្លូវទាំងឡាយ ។ បទថា **អយសា បដិកុជ្ជិតា** សេចក្តីថា នរកទាំងអស់ត្រូវបិទហើយ ដោយដំបូលដែក ប្រមាណ ៩ យោជន៍ ។ បទថា **ផុដា តិដ្ឋន្តិ** សេចក្តីថា នរកទាំងអស់ ផ្សាយទៅតាំងនៅអស់ផ្ទៃប្រមាណប៉ុណ្ណេះ ។ បទថា **ឧទ្ធំថានា អវំសិរា** អធិប្បាយថា ព្រះពោធិសត្វពោលយ៉ាងនេះ សំដៅដល់ សត្វដែលរអិលធ្លាក់ទៅក្នុងនរកនោះរឿយៗ ។ បទថា **អតិវត្តារោ** សេចក្តីថា សត្វដែលប្រព្រឹត្តកន្លងដោយវាចាគ្រោតគ្រាតទាំងឡាយ ។ បានពួមកថា សត្វទាំងឡាយធ្វើនូវកំហុសក្នុងសមណព្រាហ្មណ៍ដែលតាំងនៅក្នុងធម៌ តែងឆេះក្នុងមហានរកដោយច្រើន ព្រោះហេតុនោះទើបលោកពោលយ៉ាងនេះ ។ បទថា **តេ ភូណហុនោ** អធិប្បាយថា សត្វដែលកន្លងល្មើសក្នុងឥសីទាំងនោះ ជាសត្វដែលមានសេចក្តីចម្រើនត្រូវកម្ចាត់ហើយ ព្រោះកម្ចាត់សេចក្តីចម្រើននៃខ្លួនឯង រមែងឆេះដូចគ្នានឹងត្រីដែលគេ

ធ្វើឲ្យជាចម្រៀកៗ ។ បទថា **អសយ្ហំយ្យេ** សេចក្តីថា បុគ្គលណាម្នាក់ មិនអាចនឹងរាប់បាន ។ បទថា **កិព្វិសការិនោ** បានដល់ ជាអ្នកមានប្រក្រតីធ្វើកម្មដ៏ឃោរឃៅ ។ បទថា **និក្ខមនេសិនោ** សេចក្តីថា សត្វទាំងនោះសូម្បីស្វែងរកផ្លូវចេញអំពីនរក ក៏មិនបានដល់ទ្វារចេញឡើយ ។ បទថា **បុរត្ថិមេន** សេចក្តីថា ក្នុងកាលដែលទ្វារមិនទាន់បិទសត្វទាំងនោះ ក៏នាំគ្នាបែរមុខរត់ទៅកាន់ទ្វារនោះ ។ អវយវៈមានពណ៌សម្បុរជាដើមរបស់សត្វទាំងនោះ ក៏ត្រូវភ្លើងឆេះក្នុងទីនោះឯង ។ កាលសត្វទាំងនោះរត់ទៅជិតដល់ទ្វារ ទ្វារក៏បិទ ទ្វារខាងក្រោយក៏ប្រាកដ ហាក់ដូចជាត្រូវបើកហើយ ។ ក្នុងទ្វារដទៃៗ ក៏ន័យនេះដូចគ្នា ។ បទថា **ន សាធុរូបេ** សេចក្តីថា បុគ្គលមិនគប្បីចូលទៅបៀតបៀនឥសីដែលជាសប្បុរស ដោយទីអន្ទិយ ដោយពាក្យគ្រោតគ្រាត ឬដោយកាយកម្ម ដូចមិនគប្បីបៀតបៀនពស់ មានប្រការដូចពោលហើយ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះត្រូវសោយទុក្ខជំកន្លងក្នុងមហានរកទាំង ៨ រណ្តៅ ព្រោះបៀតបៀនបុគ្គលដែលសន្រ្ទមហើយ និងមានតបធម៌ ។

ឥឡូវនេះ ព្រះពោធិសត្វបំណងនឹងសម្តែងដល់ព្រះរាជាដែលទ្រង់បៀតបៀនឥសីបែបនោះហើយ ជួបនូវសេចក្តីទុក្ខយ៉ាងនោះ ទើបពោលពាក្យជាដើមថា **អតិកាយោ** ដូច្នេះ ។ បណ្តាបទទាំងនោះបទថា **អតិកាយោ** បានដល់មានព្រះវរកាយធំ សម្បូរដោយកម្លាំង ។ បទថា **មហិស្សាសោ** បានដល់ជាអ្នកកាន់ធ្នូ ។ បទថា **កេកកាធិបោ** បានដល់ ជាអ្នកជំក្នុងកេកករដ្ឋ ។

បទថា **សហស្សពាហុ** សេចក្តីថា មានដើមដៃ ១០០០ ព្រោះអាចលើកធ្នូដែលបុរស ៥០០ លើកឡើងបានដោយដៃ ១០០០ ។ បទថា **វិភវន្តគោ** បានដល់ ដល់នូវសេចក្តីវិនាស ។ រឿងទាំងឡាយមានពិស្តារហើយ ក្នុងសរភង្គជាតក ។ បទថា **ឧបហច្ច មនំ** បានដល់ ធ្វើចិត្តរបស់ខ្លួនឲ្យប្រទូស្ត ។ បទថា **មាតង្គស្មឹ** បានដល់ ក្នុងមាតង្គបណ្ឌិត ។ រឿងបានពោលទុកហើយក្នុងមាតង្គជាតក ។ បទថា **កណ្ហាទីបាយនាសជ្ជ** បានដល់ ប្រទូស្តនឹងតាបសឈ្មោះកណ្ហទីបាយនៈ ។ បទថា **យមសាធនំ** បានដល់ នរក ។ រឿងមានពិស្តារក្នុងយតបណ្ឌិតជាតក ។ បទថា **ឥសិនា** បានដល់ តាបសឈ្មោះកបិល ។ បទថា **ចាវេក្ខិ** បានដល់ ចូលទៅហើយ ។ បទថា **ចេច្ចោ** បានដល់ ព្រះបាទចេតិយរាជ ។ បទថា **ហីនត្តោ** បានដល់ មានអត្តភាពវិនាសទៅជុំវិញហើយ គឺអស់ឫទ្ធិ ។ បទថា **កាលបរិយាយំ** បានដល់ ដល់នូវពេលស្លាប់ដោយបរិយាយ ។ រឿងពោលទុកហើយក្នុងចេតិយរាជជាតក ។ បទថា **តស្មា** សេចក្តីថា ព្រោះហេតុដែលបុគ្គលប្រព្រឹត្តទៅក្នុងអំណាចនៃចិត្ត ខុសក្នុងឥសីទាំងឡាយហើយរមែងចេះក្នុងមហានរកទាំង ៨ ។ បទថា **តស្មា ហិ ឆន្ទាគមនំ** សេចក្តីថា បណ្ឌិតរមែងមិនសរសើរដល់ការលុះអគតិទាំង ៤ យ៉ាង មានឆន្ទាគតិជាដើម ។ បទថា **បទុដ្ឋេន** បានដល់ ក្រោធហើយ ។ បទថា **គន្តា សោ និរយំ អធោ** សេចក្តីថា បុគ្គលនោះ រមែងទៅកាន់នរកខាងក្រោមនោះឯង ដោយផលកម្មដែលខ្លួនគួរទៅខាងក្រោមនោះ តែក្នុងព្រះបាលី លោករចនាទុកជា **និរយុស្សទំ** ដូច្នេះ ។

*សេចក្តីនោះ មានន័យថា រមែងទៅកាន់ឧស្សទនរក ។ បទថា* **វុឡ្ហា** *បាន ដល់ លោកចម្រើនដោយវ័យនិងចម្រើនដោយគុណ ។ បទថា* **អនបច្ចា** *សេចក្តីថា ជនទាំងនោះ រមែងមិនបានផៅពង្ស ឬទាយាទក្នុងអន្តរកប្ប ។ បទថា* **តាលវត្ថុ** *សេចក្តីថា ជនទាំងនោះ រមែងដល់នូវសេចក្តីវិនាសយ៉ាង ធំ ក្នុងទិដ្ឋធម៌ ដូចគ្នានឹងដើមត្នោត ដែលមានឫសដាច់ហើយដូច្នោះ ហើយ កើតក្នុងនរកទាំងឡាយ ។ បទថា* **ហន្តិ** *បានដល់ ធ្វើឲ្យស្លាប់ ។ បទថា* **ចិរំ រត្តាយ** *បានដល់ អស់កាលយូរ ។*

*ព្រះមហាសត្វ កាលសម្តែងនរកដែលពួកអ្នកបៀតបៀនឥសីទាំងឡាយ ចេះយ៉ាងនេះហើយ កាលសម្តែងនរក ដែលព្រះរាជាមិនតាំងនៅក្នុងធម៌ចេះ ជាបន្ត ទើបពោលពាក្យជាដើមថា* **យោ ច** *ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា* **រដ្ឋាវិធំសនោ** *បានដល់ ជាអ្នកដល់នូវអគតិ ដោយអំណាចឆន្ទាគតិ ជាដើមហើយ កម្ចាត់អ្នកដែនចោល ។ បទថា* **អច្ចិសង្ឃបរេតោ សោ** *បាន ដល់ ព្រះរាជាអង្គនោះ ដែលគំនរនៃអណ្តាតភ្លើងចោមរោមហើយ ។ បទថា* **តេជោភក្ខស្ស** *បានដល់ ទំពាស៊ីភ្លើងនោះឯង ។ បទថា* **គត្តានិ** *បានដល់ អង្គអវយវៈតូចធំទាំងអស់ក្នុងសរីរៈ ក្នុងទីប្រមាណ ៣ គាវុត គឺអណ្តាត ភ្លើងជាគំនរតែមួយ ដូចគ្នាទាំងអស់ មានព្រមដោយអវយវៈទាំងនេះ គឺ ចុងរោមនិងចុងក្រចក ។ បទថា* **តុណ្ហគ្គិតោ** *សេចក្តីថា សត្វនរកនោះរមែង កន្ទក់កន្ទេញ ដូចដីដែលហត្ថាចារ្យកាប់ដោយកង្វេរ ធ្វើមិនឲ្យមានអាការ ញាប់ញ័រ ។*

ព្រះមហាសត្វ កាលសម្ដែងនរក ដែលពួកព្រះរាជាមិនតាំងនៅក្នុងធម៌ ធេះយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងសម្ដែងដល់នរកដែលពួកបុគ្គលអ្នកសម្លាប់បិតាជាដើមឆេះ ទើបពោលពាក្យជាដើមថា **យោ លោភា** ដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា **លោភា** បានដល់ ព្រោះសេចក្ដីលោភក្នុងយស និងក្នុងទ្រព្យ ។ បទថា **ទោសា** បានដល់ ព្រោះខ្លួនមានចិត្តត្រូវទោសៈប្រទូស្ដហើយ ។ បទថា **និទ្ធំ** សេចក្ដីថា នាយនិរយបាលធ្វើបុគ្គលដែលសម្លាប់បិតានោះ ដែលឆេះក្នុងលោហកុម្ភីនរកអស់ច្រើនពាន់ឆ្នាំមកហើយ ធ្វើសរីរៈកម្ពស់ ៣ គាវុតរបស់សត្វនោះ មិនឲ្យមានស្បែក ហើយប្រានឲ្យដួលចុះលើផែនដីដែកដែលឆេះសន្ធោសន្ធៅ ចាក់ដោយលំពែងដែកដ៏មុតរហូតដល់ល្អិតខ្ទេចខ្ទី ។ បទថា **អន្ធំ ករិត្វា** សេចក្ដីថា ព្រះពោធិសត្វក្រាបទូលថា បពិត្រមហារាជ និរយបាលទាំងឡាយទូន្មានអ្នកសម្លាប់បិតានោះឲ្យដួលចុះ ហើយឲ្យដេកផ្ងារលើផែនដីដែកដែលភ្លើងកំពុងឆេះ ហើយយកលំពែងដែកដែលភ្លើងកំពុងឆេះ ចាក់ភ្នែកទាំង ២ ឲ្យខ្វាក់ ហើយយកមូត្រនិងករីសដ៏ក្ដៅដាក់ចូលទៅក្នុងមាត់ ហើយបង្វិលសត្វនោះទៅដូចគ្នានឹងតាំងដែលធ្វើដោយចំបើង ហើយជ្រមុជឲ្យលិចចុះទៅក្នុងទឹកទន់ដែង ដែលតាំងនៅអស់កប្ប ។ បទថា **តត្តំ បក្កុដ្ឋិតមយោគុឡញ្ច** សេចក្ដីថា នាយនិរយបាលទាំងឡាយ ឲ្យសត្វនរកនោះទំពាស៊ីកក់ គឺលាមកដែលក្ដៅគគុកនិងដុំដែកដែលឆេះសន្ធោសន្ធៅទៀត សត្វនរកនោះ លុះឃើញលាមកនិងដុំដែក ដែលនាយនិរយបាលនាំមកនោះហើយ ក៏បិទមាត់ លំដាប់នោះ នាយ

និរយបាលក៏យកផាលដែលមានមុខវែង មានចុងក្តៅក្រៃលែង ឆេះដោយភ្លើងខ្លាស់មាត់របស់សត្វនរកនោះឲ្យហា ហើយដាក់ផ្លែសន្ទូចដែក ដែលចងដោយខ្សែចូលទៅ ថ្កក់យកអណ្តាតចេញមក ហើយញាត់ដុំដែកនោះចូលទៅក្នុងមាត់ដែលកំពុងហា ។ បទថា **អារក្ខសា** បានដល់ នាយនិរយបាល ។ បទថា **សាមា ៤** សេចក្តីថា ព្រះពោធិសត្វ ក្រាបទូលថា បពិត្រមហារាជ ហ្វូងឆ្កែក្រហម ឆ្កែពពាល ហ្វូងត្មាតដែលមានមាត់ជាលោហៈ ហ្វូងក្អែកព្រៃនិងហ្វូងបក្សីច្រើនប្រភេទ ក៏នាំគ្នាមកចោមរោម ខាំអូសទាញអណ្តាតរបស់បុគ្គលដែលសម្លាប់បិតានោះចេញមក ហើយចឹកអណ្តាត នាំចេញទៅទុកលើផែនដី ដូចគ្នានឹងយកអាវុធ មកកាត់ធ្វើឲ្យជាចំណែកៗ ដោយអាការដូចជើងក្អែក ។ បទថា **វិប្ផន្ទមានំ** សេចក្តីថា ហ្វូងសត្វទាំងនោះ រមែងនាំគ្នាទំពាស៊ីសត្វនរកទាំងឡាយ ដូចទំពាស៊ីរបស់ដែលជារំពា ដែលឈាមកំពុងហូរចេញ ដូច្នោះ ។ បទថា **តំ ទឌ្ឍតាលំ** សេចក្តីថា នាយនិរយបាលវាយសំពងសត្វនរកដែលសម្លាប់បិតានោះ ដែលមានសរីរៈត្រូវភ្លើងឆេះសន្ធោសន្ធៅ ដូចផ្លែក្របៅដែលភ្លើងឆេះ ដូច្នោះ ។ បទថា **បរិភិន្នគត្តំ** បានដល់ មានខ្លួនបែកហើយក្នុងទីនោះៗ ។ បទថា **ឆិប្បោឋយន្តា** បានដល់ យកញញួរដែក ដែលភ្លើងឆេះវាយ ។ បទថា **រតី ហិ តេសំ** សេចក្តីថា សេចក្តីត្រេកអរនោះ រមែងជាសេចក្តីសុខរបស់ពួកនិរយបាលទាំងនោះ ។ បទថា **ទុខិនោ បណីតរេ** សេចក្តីថា ចំណែកសត្វនរកក្រៅអំពីនេះ រមែងជាអ្នកបានទទួលសេចក្តីទុក្ខ ។ បទថា **បេត្តិឃាតិនោ** បានដល់ អ្នកសម្លាប់បិតា ។

ព្រះរាជា កាលទតឃើញនរក ដែលជាបុគ្គលអ្នកសម្លាប់បិតាទាំងឡាយនេះ នេះ បានជាអ្នកតក់ស្លុតហើយដោយប្រការដូច្នេះ ។

សម័យនោះ ព្រះមហាសត្វ កាលបានលួងលោមព្រះរាជាអង្គនោះហើយ ទើបសម្តែងនរកដែលបុគ្គលសម្លាប់មាតាទាំងឡាយនេះ ។ បទថា **យមក្ខយំ** គឺលំនៅរបស់ស្តេចយម បានដល់ នរក ។ បទថា **អត្តកម្មផលូបគោ** បានដល់ ចូលដល់ហើយដោយផលនៃកម្មរបស់ខ្លួន ។ បទថា **អមនុស្សា** បានដល់ ពួកនិរយបាល ។ បទថា **ហន្តារំ ជនយន្តិយា** បានដល់ អ្នកសម្លាប់ម្តាយ ។ បទថា **វាលេហិ** សេចក្តីថា នាយនិរយបាលរុំដោយខ្សែដែក និងគាបដោយយន្តដែក ។ បទថា **តំ** បានដល់ បុគ្គលសម្លាប់មាតានោះ ។ បទថា **ធាយេន្តិ** សេចក្តីថា កាលសត្វនរកនោះត្រូវបៀតបៀន ឈាមរមែងហូរចេញពេញអំបែងដែក លំដាប់នោះ ពួកនាយនិរយបាល រមែងនាំសត្វនរកនោះចេញអំពីគ្រឿងយន្ត សរីរៈរបស់សត្វនរកនោះ ក៏ដូចប្រក្រតីដើម ក្នុងខណៈនោះ ពួកនិរយបាល ក៏ឲ្យសត្វនរកនោះដេកផ្ងារលើផែនដី ហើយឲ្យផឹកឈាមដែលកំពុងក្តៅ ដូចទង់ដែងដែលកំពុងរលាយ ដូច្នោះ ។ បទថា **ឱគ្គយ្ហ តិដ្ឋិត** សេចក្តីថា និរយបាលទាំងឡាយគាបសត្វនរកនោះដោយយន្តដែក ហើយបោះទៅក្នុងអណ្តូងភក់ គឺលាមកដែលគួរខ្ពើមនិងបដិកូលដោយក្លិនស្អុយ ដែលផ្សាយចេញទៅច្រើនពាន់ឆ្នាំ ។ សត្វនរកនោះធ្លាក់ចូលក្នុងអន្លង់ទឹកនោះ ។ បទថា **អតិកាយា** បានដល់ មានសរីរៈប្រមាណប៉ុនទូកកំរោល ។ បទថា **អយោមុខា** បានដល់ មានមាត់ជាដែកស្រួច ។ បទថា

**ជរី ភេត្វាន** សេចក្ដីថា ទម្លាយស្បែកខែចូលទៅរហូតដល់ឆ្អឹង ជួនកាលក៏ស៊ីរហូតដល់ខួរក្នុងឆ្អឹង ។ បទថា **បតិដ្ឋា** បានដល់ ចោះចូលទៅ ។ ពួកដង្កូវទាំងនោះ ខាំស៊ីតែម្យ៉ាងប៉ុណ្ណោះ ក៏មិនមែន ថែមទាំងចូលទៅតាមទ្វារខាងក្រោម ចេញទៅតាមមាត់ខាងលើជាដើម ចូលអំពីខាងឆ្វេង ចេញទៅខាងស្ដាំ រមែងធ្វើសរីរៈគ្រប់ចំណែកឲ្យជាប្រហោងតូចធំ សត្វនរកទាំងនោះបានទទួលសេចក្ដីលំបាកក្រៃលែង ស្រែកទ្រហោយំ ឆេះក្នុងនរកនោះ ។ បទថា **សោ ច** សេចក្ដីថា បុគ្គលអ្នកសម្លាប់មាតានោះ ធ្លាក់នរកមានជម្រៅប្រមាណមួយរយជួរបុរសនោះហើយ រមែងលិចទាំងក្បាលចូលទៅ ឯសាកសពនោះ រមែងស្អុយរលួយ ជះនូវក្លិនស្អុយអស់ទីមួយរយយោជន៍ ដោយជុំវិញ ។ បទថា **មាតុឃោ** បានដល់ អ្នកសម្លាប់មាតា ។

ព្រះមហាសត្វ កាលបានសម្ដែងនរក ដែលបុគ្គលអ្នកសម្លាប់មាតាឆេះយ៉ាងនេះហើយ កាលសម្ដែងដល់នរកដែលពួកស្រីអ្នកទម្លាយគភ៌ ធ្វើឲ្យគភ៌ធ្លាក់ ទើបពោលគាថាបន្តទៅទៀត ។ បទថា **ខុរធារមនុក្កម្ម** បានដល់ ឈានកន្លងនូវនរក ដែលមានមុខមុតដូចកាំបិតកោរ បានឮថា នាយនិរយបាលទាំងឡាយក្នុងនរកនោះ រមែងដាក់កាំបិតកោរដែលមានមុខធំៗ ឲ្យផ្ងារឡើងលើ បន្ទាប់អំពីនោះ ស្រីពួកណាបរិភោគថ្នាំក្ដៅ ធ្វើឲ្យគភ៌ធ្លាក់ទៅ នាយនិរយបាល ក៏ដេញតាមវាយសំពងស្រី ដែលធ្វើគភ៌ឲ្យធ្លាក់ទាំងនោះ ដោយអាវុធទាំងឡាយ ដែលមានភ្លើងឆេះសន្ធោសន្ធៅ ស្រីទាំងនោះ ក៏ដាច់ជាកំណាត់តូចធំ ដោយមុខកាំបិតដ៏មុត ក្រោកឡើងរឿយៗ ឈានកន្លងនូវ

នរក ដែលមានកាំបិតមុតដូចកាំបិតកោរ បានដោយលំបាកក្រៃលែង កាលកន្ទងផុតហើយ ក៏ត្រូវនាយនិរយបាលដេញតាម ធ្លាក់ចុះកាន់ស្ទឹងវេត្តរណី ដែលមិនរាបស្មើ ធ្ងន់ទៅបានដោយលំបាក ហេតុនៃកម្មក្នុងនរកនោះៗ នឹងមានច្បាស់ក្នុងនេមិរាជជាតក ។

ព្រះមហាសត្វ កាលបានសម្តែងនរកនៃពួកស្រីដែលធ្វើគភ៌ឲ្យធ្លាក់យ៉ាងនេះហើយ កាលនឹងសម្តែងដល់នរកដើមរកាមានបន្លាស្រួច ដែលពួកបុរសអ្នកខុសក្នុងកិរិយារបស់អ្នកដទៃ និងពួកស្រីដែលប្រព្រឹត្តក្រៅចិត្តប្តីធេះនោះ ទើបពោលពាក្យជាដើមថា **អយោមយា** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **ឧភតោ អភិលម្ពន្តិ** សេចក្តីថា មែករបស់ដើមរកានោះសំយុងចុះមកត្រង់មាត់ច្រាំងនៃស្ទឹងវេត្តរណីទាំង ២ ខាង ។ បទថា **តេ អច្ចិមន្តោ** សេចក្តីថា សត្វទាំងឡាយដែលមានសរីរៈត្រូវភ្លើងឆេះទាំងនោះ ជាអ្នកមានអណ្តាតភ្លើងតាំងនៅ ។ បទថា **យោជនំ** សេចក្តីថា សត្វទាំងនោះមានសរីរៈកម្ពស់ ៣ គាវុត តែរួមជាមួយអណ្តាតភ្លើងតាំងឡើងអំពីសរីរៈ ទើបជាមួយរយោជន៍ ។ បទថា **ឯតេ បជ្ជន្តិ** សេចក្តីថា សត្វទាំងឡាយដែលខុសក្នុងកិរិយារបស់អ្នកដទៃនោះ ត្រូវនាយនិរយបាលចាក់ដោយអាវុធច្រើនប្រភេទ ត្រូវឡើងក្នុងនរកដើមរកាទាំងនេះ ។ បទថា **តេ បតន្តិ** សេចក្តីថា សត្វនរកទាំងនោះជាប់ត្រង់ប្រគាបដើមរកា ឆេះច្រើនពាន់ឆ្នាំ ត្រូវនាយនិរយបាលយកអាវុធចាក់ ក៏ធ្លាក់ចុះមក មានក្បាលចុះក្រោម ។ បទថា **បុថុ** គឺច្រើន ។ បទថា **វិវិវត្តង្គា** សេចក្តីថា ក្នុងកាលដែលសត្វនរកទាំងនោះ

*ធ្លាក់ចុះអំពីដើមរកានោះ លំពែងទាំងឡាយផុសឡើងអំពីផែនដីដែកខាងក្រោម ចាំទទួលក្បាលរបស់សត្វនរកនោះមួយរំពេច លំពែងទាំងនោះ រមែងទម្លុះចេញតាមទ្វារខាងក្រោមរបស់សត្វទាំងនោះ សត្វនរកទាំងនោះត្រូវលំពែង ដែលជាអាវុធដោតហើយ យ៉ាងនេះ រមែងដេកអស់កាលយូរ ។ បទថា* **ឌីឃំ** *សេចក្តីថា កាលមិនបានទូវការដេកលក់ ទើបភ្ញាក់អស់កាលយូរ ។ បទថា* **តតោ រត្យា វិវសនេ** *សេចក្តីថា ដោយកន្លងទៅអស់កាលយូរនៃរាត្រីទាំងឡាយ ។ បទថា* **បវជ្ជន្តិ** *សេចក្តីថា សត្វនរកទាំងនោះត្រូវនិរយបាលចាប់បោះទៅកាន់លោហកុម្ភីដែលភ្លើងកំពុងឆេះ ដែលមានជម្រៅ ៦០ យោជន៍ គឺលោហកុម្ភីដែលពេញដោយទឹកលោហៈដែលរលាយក្តៅគគុកតាំងនៅអស់កប្ប ហើយឆេះនៅក្នុងលោហកុម្ភីនោះ ។ បទថា* **ទុស្សីលា** *បានដល់ប្រព្រឹត្តខុសក្នុងកិរិយាអ្នកដទៃ ។*

*ព្រះមហាសត្វ កាលសម្តែងនរកដើមរកា ដែលពួកបុរសប្រាថ្នាខុសក្នុងកិរិយារបស់អ្នកដទៃ និងពួកស្រីដែលប្រព្រឹត្តក្រៅចិត្តប្តី ឆេះយ៉ាងនេះហើយ បន្ទាប់មក កាលនឹងប្រកាសទីរបស់ពួកស្រីដែលមិនបំពេញវត្តក្នុងស្វាមីនិងវត្តក្នុងឪពុកក្មេកជាដើមនាំគ្នាឆេះ ទើបពោលពាក្យជាដើមថា* **យា ច** *ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា* **អតិមញ្ញតិ** *សេចក្តីថា ស្រីដែលធ្វើនូវសាមិកវត្ត ដូចពោលទុកហើយ ក្នុងកឹសជាតក កន្លងល្មើស មើលងាយប្តី ។ បទថា* **ជេដ្ឋំ វា** *បានដល់ បងប្រុសរបស់ប្តី ។ បទថា* **ននន្ទរំ** *បានដល់ ប្អូនស្រីរបស់ប្តី ។ ពិតហើយ កិរិយាមិនបំពេញវត្តផ្សេងៗ មានគក់ប្រាប់ដៃ*

ជើង គក់ខ្នង ឲ្យផ្ទួតទឹក ឲ្យបរិភោគអាហារដល់ជនទាំងនេះ សូម្បីតែម្នាក់ឲ្យបរិបូណ៌ មិនតាំងហិរិនិងឱត្តប្បៈក្នុងជនទាំងនោះ ឈ្មោះថា មើលងាយជនទាំងនោះ សូម្បីស្រីនោះ ក៏កើតក្នុងនរក ។ បទថា **វង្គេន** សេចក្តីថា កាលស្រីនោះ មិនបំពេញសាមិកវត្តជាដើមឲ្យបរិបូណ៌ ជេរបរិភាសប្តីជាដើម កើតក្នុងនរក នាយនិរយបាលទាំងឡាយចាប់ស្រីនោះ ឲ្យដេកលើផែនដីដែក ហើយយកតម្លក់ដែកខ្វាស់មាត់ឲ្យហា ហើយយកសន្ទូចថ្កក់អណ្តាតទាញចេញមកព្រមទាំងខ្សែដែលចង ។ បទថា **កិមិនំ** បានដល់ ពេញទៅដោយដង្កូវ លោកពោលពាក្យអធិប្បាយទុកថា បពិត្រមហារាជ សត្វនរកនោះត្រូវអូសមកហើយ យ៉ាងនេះ រមែងមើលឃើញចុងអណ្តាតដែលវែង ប្រមាណមួយព្យាម ដោយព្យាមរបស់ខ្លួន ពេញទៅដោយដង្កូវទាំងឡាយ ដែលមានខ្លួនប៉ុនៗទូកកំរោល កើតឡើងក្នុងទីដែលត្រូវវាយដោយអាវុធ ។ បទថា **វិញ្ញាបេតុំ ន សក្កោតិ** សេចក្តីថា ត្រូវអង្វរនាយនិរយបាល ក៏មិនអាចពោលពាក្យណាមួយបាន ។ បទថា **តាបនេ** សេចក្តីថា ស្រីនោះ ឆេះក្នុងនរកនោះរាប់ពាន់ឆ្នាំយ៉ាងនេះហើយ នៅឆេះក្នុងមហានរក ឈ្មោះ តាបនៈទៀត ។

ព្រះមហាសត្វ កាលសម្តែងដល់នរកដែលពួកស្រី អ្នកមិនបំពេញវត្តក្នុងស្វាមី និងវត្តក្នុងម្តាយក្មេក ឪពុកក្មេកយ៉ាងនេះហើយ កាលនឹងសម្តែងដល់នរក ដែលពួកជនអ្នកសម្លាប់ជ្រូកជាដើមឆេះ ក្នុងកាលឥឡូវនេះ ទើបពោលពាក្យជាដើមថា **ឱរព្ភិកា** ដូច្នេះ ។ បណ្តាបទទាំងនោះបទថា **អវណ្ណោ**

**វណ្ណាការកា** បានដល់ ដែលធ្វើការញុះញង់ ។ បទថា **ខារចតំ** សេចក្តីថា បុគ្គលដែលសម្លាប់ចៀមជាដើមនេះ ត្រូវបៀតបៀនដោយអាវុធទាំងឡាយ មានលំពែងជាដើម រមែងធ្លាក់ទៅកាន់ស្ទឹងវេត្តរណី ទីដែលពួកអ្នកសម្លាប់ចៀមជាដើមនេះដ៏សេស មានច្បាស់ក្នុងនេមិរាជជាតក ។ បទថា **កូដការី** លោកពោលសំដៅដល់បុគ្គលដែលកាត់ក្តីកោង និងកោងដោយជញ្ជីងជាដើម ។ ក្នុងសេចក្តីនោះ នរកដែលពួកអ្នកកាត់ក្តីកោង ពិចារណាក្តីកោងនិងកោងដោយតម្លៃហើយនេះ នឹងមានច្បាស់ក្នុងនេមិរាជជាតក ។ បទថា **វន្តំ** បានដល់ វត្ថុដែលខ្ជាក់ចេញមក ។ បទថា **ទុរត្តានំ** បានដល់ មានអត្តភាពប្រព្រឹត្តទៅបានដោយលំបាក ។ សេចក្តីនេះ មានពាក្យអធិប្បាយទុកថា បពិត្រមហារាជ សត្វមានអត្តភាពដល់នូវសេចក្តីលំបាកទាំងនោះ កាលក្បាលត្រូវវាយដោយញញួរដែក ក៏ក្អួតចេញមក បន្ទាប់អំពីនោះ រមែងដាក់កម្អួតដែលចេញមកនោះ ចូលទៅក្នុងមាត់របស់សត្វពួកខ្លះ ក្នុងបណ្តាសត្វទាំងនោះ ដោយអំបែងដែកដែលឆេះសន្ធោសន្ធៅ ។ សត្វទាំងនោះ ឈ្មោះថា រមែងបរិភោគវត្ថុដែលសត្វដទៃក្អួតចេញមក ដោយប្រការដូច្នេះ ។ បទថា **ភេរណ្ឌកា** បានដល់ ឆ្កែចចក ។ បទថា **វិប្ផន្ទមានំ** សេចក្តីថា ត្រូវចាប់ឲ្យដេកផ្កាប់មុខ រួចទាញអណ្តាតចេញមក បម្រះនទៀលទៅកាន់ទីផ្សេងៗ ។ បទថា **មិគេឆ** បានដល់ ម្រឹគដែលត្រាច់ទៅក្នុងស្រុក ។ បទថា **បក្ខិណោ** បានដល់ បក្សីប្រភេទនោះឯង ។ បទថា **គន្ត្វា តេ** បានដល់ មនុស្សទាំងនោះទៅហើយ ។ បទថា **និរយុស្សទំ** បានដល់ ឧស្សទនរក តែក្នុងបាលី លោករចនាទុកថា

នរកខាងក្រោម ដូច្នេះ នរកនោះ នឹងមានច្បាស់ក្នុងនេមិរាជជាតក ។

ព្រះមហាសត្វ កាលសម្ដែងដល់នរកមានប្រមាណប៉ុណ្ណេះ ដោយប្រការដូច្នេះហើយ ឥឡូវនេះ កាលនឹងធ្វើការបើកទេវលោកដល់ព្រះរាជា ហើយសម្ដែងទេវលោកដល់ព្រះរាជា ទើបក្រាបទូលថា

ពួកសប្បុរសក្នុងលោកនេះ មានកម្មសន្សំល្អហើយ តែងទៅកាន់លោកខាងលើ សូមព្រះអង្គទតមើលផលនៃអំពើដែលគេបានសន្សំល្អ ដូចពួកទេវតាព្រមទាំងព្រះឥន្ទ ព្រមទាំងព្រះព្រហ្ម បពិត្រមហារាជ អាត្មាភាពពោលហេតុនោះនឹងព្រះអង្គ បពិត្រព្រះអង្គជាម្ចាស់នៃដែន សូមព្រះអង្គប្រព្រឹត្តធម៌ បពិត្រព្រះរាជា អំពើដែលព្រះអង្គប្រព្រឹត្តល្អនោះ មិនគប្បីដុតកម្ដៅរឿយៗ ក្នុងកាលជាខាងក្រោយយ៉ាងណា ៗ សូមព្រះអង្គប្រព្រឹត្តធម៌ យ៉ាងនោះ ៗ ចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សន្តោ** បានដល់ អ្នកចូលទៅស្ងប់រម្ងាប់ក្នុងទ្វារ ៣ មានកាយទ្វារជាដើម ។ បទថា **ឧទ្ធំ** បានដល់ ទេវលោក ។ បទថា **សឥន្ទា** បានដល់ មួយអន្លើដោយព្រះឥន្ទទាំងឡាយក្នុងទេវលោកនោះៗ ។ ពិតហើយ ព្រះមហាសត្វកាលសម្ដែងដល់ពួកទេវតាទាំងឡាយ ដែលប្រកបដោយទេវតាជាន់ចាតុម្មហារាជ ដល់ព្រះរាជាអង្គនោះ ទើបក្រាបទូលថា បពិត្រមហារាជ សូមទ្រង់ទតទេវតាជាន់ចាតុម្មហារាជទាំងឡាយ សូមទ្រង់ទតទេវមហារាជទាំង ៤ សូមទតទេវតាជាន់តាវត្តិង្ស សូមទតសក្កទេវរាជ

*ចុះ ដូច្នេះ កាលសម្តែងទេវតាទាំងឡាយ មួយអន្លើដោយព្រះឥន្ទ និងព្រះព្រហ្មទាំងអស់នោះយ៉ាងនេះ ទើបសម្តែងបន្តថា នេះជាផលដែលប្រព្រឹត្តល្អហើយ នេះក៏ជាផលនៃកម្មដែលប្រព្រឹត្តល្អហើយដូចគ្នា ។ បទថា* **តស្មា ព្រូមិ** *សេចក្តីថា ព្រោះហេតុនោះ អាត្មានឹងសូមទូលទ្រង់ ។ បទថា* **ធម្មំ** *សេចក្តីថា តាំងអំពីថ្ងៃនេះទៅ សូមទ្រង់វៀរនូវបញ្ចវេរ មានបាណាតិបាតជាដើម ហើយសូមបំពេញបុណ្យទាំងឡាយ មានទានជាដើមចុះ ។ បទថា* **យថា តំ សុចិណ្ណំ ឆានុតប្បេយ្យ** *សេចក្តីថា សូមទ្រង់ប្រព្រឹត្តធម៌នោះឲ្យសុចរិតហើយ គឺសូមធ្វើបុណ្យឲ្យច្រើន ដោយប្រការដែលបុញ្ញកម្ម មានទានជាដើមនោះដែលបុគ្គលប្រព្រឹត្តល្អហើយ កម្មដែលបុគ្គលប្រព្រឹត្តល្អហើយនោះ រមែងមិនតាមក្តៅក្រហាយក្នុងកាលជាខាងក្រោយ ព្រោះមិនអាចបិទបាំងបាននូវការក្តៅក្រហាយ មានបិតុឃាតកម្មជាបច្ច័យបាន ។*

*ព្រះរាជាអង្គនោះ កាលបានស្តាប់ធម្មកថា របស់ព្រះមហាសត្វហើយ តាំងអំពីនោះមក ទ្រង់ក៏ស្រឡះព្រះហឫទ័យ ឯព្រះមហាសត្វអាស្រ័យក្នុងព្រះរាជឧទ្យាននោះ អស់កាលបន្តិចបន្តួចហើយ ក៏ត្រឡប់ទៅកាន់លំនៅរបស់ខ្លួនវិញ ។*

*ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេសូម្បីក្នុងកាលមុន ព្រះបាទអជាតសត្តុអង្គនេះ តថាគតបានធ្វើឲ្យល្ហែល្ហើយព្រះហឫទ័យហើយដូចគ្នា ដូច្នេះហើយ ទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាល*

នោះ បានមកជាព្រះបាទអជាតសត្តុក្នុងកាលឥឡូវនេះ ឥសីបរិស័ទក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ឯសំកិច្ចបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា សង្កិច្ចជាតក ចប់**

**សង្គិនិបាត ចប់**

# សត្តតិនិបាត ជាតក

## កុសជាតក

[ ៩៤ ] ( ព្រះបាទកុសរាជពោធិសត្វត្រាស់ថា ) បពិត្រព្រះមាតា ដែនរបស់ព្រះមាតានេះ ប្រកបដោយទ្រព្យ ប្រកបដោយយាន ប្រកបដោយគ្រឿងសម្រាប់រាជ្យ បរិបូណ៌ដោយកាមគ្រប់យ៉ាង សូមព្រះមាតាត្រួតត្រាដែនរបស់ព្រះមាតានេះចុះ ខ្ញុំនឹងទៅកាន់នគរ ជាទីនៅរបស់នាងបភាវតី ជាទីស្រឡាញ់ ។

[ ៩៥ ] ( នាងបភាវតីពោលថា ) ព្រះអង្គមានព្រះទ័យ មិនត្រង់ នាំយកអម្រែកធំ ( រេងទុក្ខ ) ទាំងថ្ងៃទាំងយប់ ទាំងពេលអធ្រាត្រ សូមព្រះអង្គត្រឡប់ទៅក្រុងកុសាវតីវិញឲ្យឆាប់ ខ្ញុំម្ចាស់មិនចង់បានព្រះអង្គ ដែលមានរាងរៅអាក្រក់មកនៅ ( ក្នុងទីនេះ ) ទេ ។

[ ៩៦ ] ( ព្រះពោធិសត្វ... ) ហៃនាងបភាវតី អញនឹងមិនទៅអំពីទីនេះ កាន់ក្រុងកុសាវតីទេ ព្រោះអញជាប់ចិត្តនឹងវណ្ណរបស់នាង ទើបត្រេកអរក្នុងដំណាក់ជាទីត្រេកអររបស់ព្រះបាទមទ្ទៈ ស៊ូលះបង់ដែន មកត្រេកអរក្នុងការឃើញនាង ។ ហៃនាងបភាវតី អញជាប់ចិត្តនឹងវណ្ណៈរបស់នាង មានសភាពវង្វេង ត្រាច់រង្គាត់ទៅកាន់ផែនដី មិនស្គាល់ទិសថា អញមកអំពីទីណា ហៃនាងមានភ្នែកថ្លាដូចភ្នែកម្រឹគ អញជាមនុស្សវក់ចិត្តក្នុងនាង ហៃនាងមានគ្រឿងសម្លៀកបំពាក់រំលេចដោយមាសមានខ្សែក្រវាត់ល្អ ជាវិការៈនៃមាស មានចង្កេះល្អ អញមិនត្រូវការដោយរាជសម្បត្តិ ព្រោះតែសេចក្តីប្រាថ្នាចំពោះនូវនាង ។

[ ៩៧ ] ( នាងបការតី... ) បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីមិនចម្រើន តែងមានដល់បុគ្គលដែលប្រាថ្នា បុគ្គលកាលមិនប្រាថ្នា ( ខ្ញុំ ) បពិត្រព្រះរាជា ព្រះអង្គមិនជាទីស្រឡាញ់ ចង់បានស្ត្រីជាទីស្រឡាញ់ ដែលមិនមានសេចក្តីប្រាថ្នាដោយកាមទាំងឡាយ ។

[ ៩៨ ] ( ព្រះពោធិសត្វ... ) ជនណាបាននាងជាទីស្រឡាញ់ ទោះមិនមានសេចក្តីប្រាថ្នាក្តី មានសេចក្តីប្រាថ្នាក្តី យើងសរសើរនូវការបានរបស់ជននុ៎ះ បណ្តាការបានទឹងមិនបាននោះ ឯការមិនបាន ចាត់ថាជារបស់លាមក ។

[ ៩៩ ] ( នាងបការតី... ) ព្រះអង្គចង់បានស្ត្រី ដែលគេមិនចង់បានព្រះអង្គ ដូចជាគេជីកខ្ទឹមថ្មដោយដើមកណិកា ឬដូចជាគេទាក់ខ្យល់ដោយសំណាញ់ ។

[ ១០០ ] ( ព្រះពោធិសត្វ... ) ហៃនាងមានលក្ខណៈទន់ភ្លន់ អញមកអំពីជនបទខាងក្រៅ មិនបានសេចក្តីស្រួល ( ក្នុងសំណាក់ ) របស់នាងឈ្មោះថាយកថ្មសង្កត់លើហឫទ័យ ( នៃអញ ) ដោយពិត ។ ព្រះរាជបុត្រីធ្វើមុខក្រញូវ ហើយសំឡឹងមើលមកអញ ក្នុងវេលាណា អញក៏នៅជានាយពិសេសក្នុងរាំង របស់ព្រះបាទមទ្ទុះក្នុងវេលានោះ ។ ព្រះរាជបុត្រីញញឹមញញែម ក្រឡេកមើលអញក្នុងវេលាណា អញមិននៅជានាយពិសេសក្នុងវេលានោះទេ អញនឹងជាព្រះបាទកុសៈ ក្នុងវេលានោះវិញ ។

[ ១០១ ] ( នាងបការតី... ) ប្រសិនបើពាក្យរបស់ហោរពិតមែន ព្រះអង្គមិនត្រូវបានជាកស្តារបស់ខ្ញុំម្ចាស់ទេ ស៊ូឲ្យគេកាត់ ( ខ្ញុំម្ចាស់ ) ជា

ប្រាំពីរកំណាត់ចុះ ។

[ ១០២ ] ( ព្រះពោធិសត្វ... ) ប្រសិនបើពាក្យរបស់ហោរដទៃ ឬរបស់អញពិតមែន កស្ដាររបស់នាងក្រៅអំពីព្រះបាទកុសៈ ដែលមានព្រះសូរស័ព្ទស្មើនឹងសំឡេងសីហៈ ក៏មិនមានទេ ។

[ ១០៣ ] នែនាងគម បើនាងបភាវតីមានភ្លៅដូចជាប្រមោយដំរី គប្បីក្រឡេកមើលអញ លុះអញទៅដល់ក្រុងកុសាវតី នឹងឲ្យគេធ្វើគ្រឿងប្រដាប់សម្រាប់ពាក់ក ជាវិការៈនៃមាសឆ្អាវដល់នាង ។ នែនាងគម បើនាងបភាវតីមានភ្លៅដូចជាប្រមោយដំរី គប្បីហៅរកអញ លុះអញទៅដល់ក្រុងកុសាវតី នឹងឲ្យគេធ្វើគ្រឿងប្រដាប់សម្រាប់ពាក់ក ជាវិការៈនៃមាសឆ្អាវដល់នាង ។ នែនាងគម បើនាងបភាវតីមានភ្លៅដូចជាប្រមោយដំរី គប្បីញញឹមញញែមរកអញ លុះអញទៅដល់ក្រុងកុសាវតី នឹងឲ្យគេធ្វើគ្រឿងប្រដាប់សម្រាប់ពាក់ក ជាវិការៈនៃមាសឆ្អាវដល់នាង ។ នែនាងគម បើនាងបភាវតីមានភ្លៅដូចជាប្រមោយដំរី គប្បីសើចក្អាកក្អាយរកអញ លុះអញទៅដល់ក្រុងកុសាវតី នឹងឲ្យគេធ្វើគ្រឿងប្រដាប់សម្រាប់ពាក់កជាវិការៈនៃមាសឆ្អាវដល់នាង ។ នែនាងគម បើនាងបភាវតីមានភ្លៅដូចជាប្រមោយដំរី គប្បីមកប៉ះពាល់អញដោយដៃទាំងឡាយ លុះអញទៅដល់ក្រុងកុសាវតី នឹងឲ្យគេធ្វើគ្រឿងប្រដាប់សម្រាប់ពាក់ក ជាវិការៈនៃមាសឆ្អាវដល់នាង ។

[ ១០៤ ] ( ស្ត្រីគម... ) ព្រះរាជបុត្រីនេះ មិនបានទូវសេចក្ដីស្រួលចិត្តទៅរកព្រះបាទកុសៈ ជាបុរសនាយពិសេសអ្នកស៊ីឈ្នួល មិនត្រូវការ

ដោយថ្លៃឈ្នួលទេ ។

[ ១០៥ ] ( នាងបភាវតី... ) ស្ត្រីគមនេះ មិនហ៊ានកាត់អណ្តាត ដោយកាំបិតដ៏មុតដោយពិត តែហ៊ាននិយាយពាក្យជាទុព្ភាសិតយ៉ាងនេះ ។

[ ១០៦ ] ( ស្ត្រីគម... ) បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ ( នឹងទំហំរបស់ខ្លួននាង ) ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រែ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ ) មានយសធំហើយធ្វើនូវសេចក្តីស្រឡាញ់ ( ចំពោះព្រះបាទកុសៈនោះ ) ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រែ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ ) មានទ្រព្យច្រើន ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រែ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ ) មានកម្លាំងច្រើន ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រែ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ ) មានដែនធំ ហើយធ្វើនូវសេចក្តី

ស្រឡាញ់ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រៃ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ ) ជាព្រះរាជាធំ ហើយធ្វើនូវសេចក្ដីស្រឡាញ់ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រៃ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ ) មានសំឡេងស្មើនឹងសំឡេងនៃសីហៈ ហើយធ្វើនូវសេចក្ដីស្រឡាញ់ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹម នូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រៃ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ ) មានសំឡេងដ៏ពីរោះ ហើយធ្វើនូវសេចក្ដីស្រឡាញ់ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹម នូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រៃ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ ) មានសំឡេងមូល ហើយធ្វើនូវសេចក្ដីស្រឡាញ់ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹម នូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រៃ ព្រះនាងសូម

ធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ ) មានសំឡេងល្អ ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹម នូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រៃ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ ) មានសំឡេងដ៏ផ្អែមល្ហែម ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹម នូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រៃ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ ) មានសិល្បៈច្រើន ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹម នូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រៃ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ ) ជាក្សត្រិយ៍ ( សុទ្ធ ) ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹម នូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រៃ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ ) ជាព្រះរាជាមាននាមស្មើនឹងស្បូវក្លាំង ( ដែលព្រះឥន្ទប្រទាន ) ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ ។

[ ១០៧ ] ( អាមាត្យទាំងឡាយ... ) ព្រះរាជាដ៏ប្រសើរ ទាំងអស់ទ្ទុំះ

ជាព្រះរាជាគឃើនមកហើយ ប្រដាប់ដោយគ្រឿងក្រោះ ( សូមព្រះអង្គផ្ញើព្រះរាជសារទៅថា ) អ្នកទាំងឡាយ ចូរនាំព្រះនាងបភាវតីនុះមក ( បញ្ជូនទៅថ្វាយព្រះរាជាទាំងនោះ ) កុំឲ្យទម្លាយកំពែងមុនទាន់ ។

[ ១០៨ ] ( ព្រះរាជា... ) អញនឹងធ្វើនាងបភាវតីនុះឲ្យជា ៧ កំណាត់ ហើយឲ្យដល់ពួកក្សត្រដែលមកក្នុងទីនេះ ដើម្បីសម្លាប់អញ ។

[ ១០៩ ] ( អភិសម្ពុទ្ធគាថា ) ព្រះរាជបុត្រីមានសម្បុរលឿង ទ្រង់ព្រះពស្ត្រជាវិការៈនៃសូត្រ ( រំលេចដោយមាស ) ដែលពួកទាសីហែហម មាននេត្រាដ៏ពេញដោយព្រះអស្សុជល បានក្រោក (ចាកអាសនៈ ) ។

[ ១១០ ] ( នាងបភាវតី ... ) បពិត្រព្រះមាតា មុខ ( របស់ខ្ញុំ ) នោះធ្លាប់លាបស្រឡាបគ្រឿងលម្អិត ឆ្លុះកញ្ចក់មានក្របជាវិការៈនៃភ្លុកជាមុខល្អ មានភ្នែកល្អ រលីងរាបធេង ត្រូវពួកក្សត្រលះបោលហើយ នឹងតាំងនៅក្នុងព្រៃ ។ ពួកត្មាត នឹងលើកជើងទាំងឡាយកកាយនូវសក់ទាំងនោះរបស់ខ្ញុំ ជាសក់ ខ្មៅមានចុងងទន់ លាបដោយខ្លឹមចន្ទន៍ ឲ្យប្រឫកប្របល់ ក្នុងកណ្តាលព្រៃស្មសាន ភ្លុកចឹកដៃរបស់ខ្ញុំនោះ ដែលមានក្រចកក្រហម មានរោមល្អទន់ លាបដោយខ្លឹមចន្ទន៍ ដាច់ខ្ទាត់ខ្ទាយ ដែលពួកក្សត្រចោលក្នុងព្រៃហើយ ហើរទៅតាមប្រាថ្នា ។ ចចក ( ឃើញស្តនរបស់ខ្ញុំ ) នោះ ប្រដៀងគ្នានឹងផ្លែត្នោត មិនយា លាបដោយខ្លឹមចន្ទន៍ដ៏ល្អិត ហើយបៀមនូវស្តនរបស់ខ្ញុំនោះ ដូចជាកូនខ្ចីបង្កើតដែលបៀមនូវស្តនរបស់មាតា ហ្វូងចចកជញ្ជែង ត្រគាក ( របស់ខ្ញុំ ) នោះ ជាអវយវៈទូលាយ ដែលគេជំល្អហើយ ពាក់ដោយ

ខ្សែក្រវាត់មាសទាំងឡាយ ដាច់ខ្ចាត់ខ្ចាយ ដែលពួកក្សត្រចោលក្នុងព្រៃ ។ ពួកក្អែ ក្អែក ចចក និងសត្វឯទៀតដែលមានចង្កូម ស៊ីនាងបភាវតី មុខជានឹងមិនចាស់គ្រាំគ្រាដោយពិត ។ ប្រសិនបើពួកក្សត្រដែលទៅឆ្ងាយនាំយកសាច់ទាំងឡាយ ( របស់ខ្ញុំ ) ទៅ បពិត្រព្រះមាតា ចូរព្រះអង្គសូមយកឆ្អឹងទាំងឡាយ ហើយដុតឆ្អឹងនោះក្នុងទីបន្ទាប់ផ្លូវ ( ក្នុងចន្លោះនៃផ្លូវដើរនិងផ្លូវធំ ) ។ បពិត្រព្រះមាតា សូមព្រះមាតា ប្រើគេធ្វើសួនច្បារ ហើយដាំដើមកណិការក្នុងសួនច្បារនុ៎ះ ក្នុងវេលាណាដែលដើមកណិការទាំងនោះមានផ្កា ក្នុងអំណើះទៅនៃកាលជាទីធ្លាក់នៃទឹកសន្សើមក្នុងហេមន្តរដូវ បពិត្រព្រះមាតា សូមព្រះមាតារឭកខ្ញុំថា នាងបភាវតីមានវណ្ណៈយ៉ាងនេះ ។

[ ១១១ ] ( អភិសម្ពុទ្ធគាថា ) ក្សត្រមានវណ្ណៈដូចវណ្ណៈទេវតា ជាមាតារបស់នាងបភាវតីនោះ ក្រោកចាកអាសនៈ ទៅកាន់សំណាក់ព្រះរាជា ហើយបានឃើញដាវនិងជ្រញ់ ក្នុងព្រះរាជវាំងព្រះបាទមទ្ទៈ ។

[ ១១២ ] ( ព្រះមាតា... ) បពិត្រព្រះបាទមទ្ទៈ ព្រះអង្គនឹងសម្លាប់ធីតាដែលគេចំណាំបានដោយងាយ មានកន្ត្រៃរៀវ ដោយប៉ូវថៅនេះ ហើយប្រទានដល់ពួកក្សត្រដោយពិត ។

[ ១១៣ ] ហៃបុត្រី នាងមិនបានធ្វើតាមពាក្យរបស់អញ ដែលប្រាថ្នាប្រយោជន៍ នាងមុខជានឹងពេញពាសដោយឈាម ហើយទៅកាន់កពរបស់មច្ចុរាជ ក្នុងថ្ងៃនេះ ។ បើសត្វដែលមិនធ្វើតាមពាក្យរបស់ពួកជន ដែលបង្ហាញសេចក្តីចម្រើន បង្ហាញប្រយោជន៍ហើយ តែងប៉ះទង្គិចយ៉ាងនេះផង

តែងជួបប្រទះនូវសេចក្តីអាក្រក់ជាង ( នេះ ) ផង ។ បើក្នុងថ្ងៃនេះ នាងនឹងបានទទួលកុមារស្រស់ប៉ប្រែ ជាក្សត្រដែលកើតព្រោះព្រះបាទកុសៈ មានខ្សែក្រវាត់ជាវិការៈនៃមាស និងកែវមណីដែលពួកញាតិបូជាហើយ នាងនឹងមិនទៅកាន់លំនៅយមរាជទេ នែនាងដ៏ចម្រើន ស្គរលាន់ឮក្តី ដំរីស្រែកក្តី ក្នុងខត្តិយៈត្រកូលណា ( នាងឃើញ ) អ្វីដែលជាសុខក្រៃលែងជាងខត្តិយៈត្រកូលនោះ ( បានជានាងមកក្នុងទីនេះ ) ។ សេះក្វាប្រជីប្រចទ្វារ កុមារអ្នករបាំប្រគំ ក្នុងខត្តិយៈត្រកូលណា នែនាងដ៏ចម្រើន ( នាងឃើញ ) អ្វី ដែលជាសុខក្រៃលែងជាងខត្តិយៈត្រកូលនោះ ។ កាលបើក្ងោកនិងក្រៀលយំ និងតាវ៉ៅយំ ឮទ្រហឹងអឺងកងក្នុងខត្តិយៈត្រកូលណា នែនាងដ៏ចម្រើន ( នាងឃើញ ) អ្វី ដែលជាសុខក្រៃលែងជាងខត្តិយៈត្រកូលនោះ ។

[ ១១៤ ] ព្រះបាទកុសៈជាអ្នកញាំញីខ្មាំងសត្រូវ ញាំញីដែនរបស់ព្រះរាជាដទៃ មានប្រាជ្ញាធេីត គប្បីដោះយើងឲ្យរួចចាកទុក្ខបាន តើនៅក្នុងទីណា ។

[ ១១៥ ] ( នាងបភាវតី ... ) ព្រះបាទកុសៈជាអ្នកញាំញីខ្មាំងសត្រូវ ញាំញីដែនរបស់ព្រះរាជាដទៃ មានប្រាជ្ញាធេីត សម្លាប់ក្សត្រទាំងអស់នោះ នៅក្នុងទីនេះឯង ។

[ ១១៦ ] ( ព្រះមាតា... ) នាងជាស្រីឆ្កួត ជាស្រីអន្ធពាល ចេះតែនិយាយ ( ឲ្យរួចតែពីមាត់ ) បើព្រះបាទកុសៈគប្បីមក ពួកយើងធ្វើដូចម្តេចនឹងស្គាល់ព្រះបាទកុសៈនោះបាន ។

[ ១១៧ ] ( នាងបភាវតី... ) ( ព្រះបាទកុសៈ ) គឺបុរសនាយពិសេសទន់ៈ ចងក្បិនយ៉ាងមាំខ្ជិនលាងផ្នាំង ( សូមព្រះមាតាទត ) ត្រង់ចន្លោះដំណាក់កុមារី ។

[ ១១៨ ] ( ព្រះមាតា ... ) នាងជាស្រីនៃត្រកូលជាន់ចាំង ជាស្រីចណ្ឌាល ឬជាស្រីទ្រុស្តត្រកូលទេឬ នាងកើតក្នុងត្រកូលព្រះបាទមទ្ទៈ គួរធ្វើស្វាមី ( របស់ខ្លួន ) ឲ្យជាទាសៈ ដូចម្តេចកើត ។

[ ១១៩ ] ( នាងបភាវតី... ) ខ្ញុំមិនមែនជាស្រីត្រកូលជាន់ចាំង មិនជាស្រីចណ្ឌាល មិនមែនជាស្រីទ្រុស្តត្រកូលទេ បពិត្រព្រះមាតា ( ព្រះបាទកុសៈនោះ ) ជាបុត្តរបស់ព្រះបាទឱក្កាកៈ ( ចំណែកខាង ) ព្រះមាតាទេតើ សម្គាល់ថាជាទាសៈទៅវិញ ។

[ ១២០ ] ព្រះបាទកុសៈណា ញុំាំងពួកព្រាហ្មណ៍ទាំង ២០ ពាន់ ឲ្យបរិភោគសព្វកាល បពិត្រព្រះមាតា ព្រះបាទកុសៈនោះ ជាបុត្តរបស់ព្រះបាទឱក្កាកៈ ( ចំណែកខាង ) ព្រះមាតាទេតើ សម្គាល់ថាជាទាសៈទៅវិញ ។ ពួកជន តែងទឹមដំរីទាំង ២០ ពាន់ របស់ព្រះបាទកុសៈណា សព្វកាល បពិត្រ ព្រះមាតា ព្រះបាទកុសៈនោះ ជាបុត្តរបស់ព្រះបាទឱក្កាកៈ ( ចំណែកខាង ) ព្រះមាតាទេតើ សម្គាល់ថាជាទាសៈទៅវិញ ។ ពួកជនតែងទឹមសេះទាំង ២០ ពាន់ របស់ព្រះបាទកុសៈណាសព្វកាល បពិត្រព្រះមាតា ព្រះបាទកុសៈនោះ ជាបុត្តរបស់ព្រះបាទឱក្កាកៈ ( ចំណែកខាង ) ព្រះមាតាទេតើ សម្គាល់ថាជាទាសៈទៅវិញ ។ ពួកជនតែងទឹមរថទាំង ២០ ពាន់

របស់ព្រះបាទកុសៈណាសព្វកាល បពិត្រព្រះមាតា ព្រះបាទកុសៈនោះ ជាបុត្តរបស់ព្រះបាទឱក្កាកៈ ( ចំណែកខាង ) ព្រះមាតាទេតើ សម្គាល់ថាជាទាសៈទៅវិញ ។ ពួកជនតែងរីតទឹកដោះមេគោទាំង ២០ ពាន់ របស់ព្រះបាទកុសៈណាសព្វកាល បពិត្រព្រះមាតា ព្រះបាទកុសៈនោះ ជាបុត្តរបស់ព្រះបាទឱក្កាកៈ ( ចំណែកខាង ) ព្រះមាតាទេតើ សម្គាល់ថាជាទាសៈទៅវិញ ។

[ ១២១ ] ( ព្រះរាជា.. ) ម្នាលស្រីពាល ហាងឯងធ្វើខ្ជីខ្ជាដល់ក្សត្រដែលមានកម្លាំងច្រើនដូចជាដីរដោយភេទនៃកង្កែប នាងមិនបានប្រាប់ក្សត្រនោះ ដែលយាងមកហើយ ។

[ ១២២ ] បពិត្រមហារាជ ជាបុគ្គលប្រសើរលើរថ សូមព្រះអង្គទ្រង់អត់កំហុសដល់យើង ព្រោះយើងមិនបានដឹងថា ទ្រង់យាងមកក្នុងទីនេះដោយក្លែងភេទសោះ ។

[ ១២៣ ] ( ព្រះមហាសត្ត ... ) បពិត្រសម្មតិទេព ដំណើរដែលទូលព្រះបង្គំជាខ្ញុំធ្វើជានាយពិសេសនោះ មិនកំបាំងដល់ជនដូចទូលព្រះបង្គំជាខ្ញុំទេ សូមព្រះអង្គជ្រះថ្លានឹងទូលបង្គំជាខ្ញុំចុះ អំពើខ្ជីខ្ជារបស់ព្រះអង្គ មិនមានទេ ។

[ ១២៤ ] ( ព្រះរាជា... ) ម្នាលស្រីពាល នាងឯង ចូរទៅសូមខមាទោសនឹងព្រះបាទកុសៈ ដែលមានកម្លាំងច្រើន ព្រះបាទកុសៈនោះ កាលបើនាងសូមខមាទោសហើយ នឹងប្រទានជីវិតដល់នាង ។

[ ១២៥ ] ( អភិសម្ពុទ្ធគាថា ) នាងបភាវតី មានវណ្ណៈដូចជាវណ្ណៈនៃទេវតា ឮព្រះឱង្ការរបស់ព្រះបិតា ( ក៏ក្រាប ) ដោយសិរសៈ អាចចាប់ព្រះបាទកុសៈ ដ៏មានកម្លាំងច្រើនត្រង់ព្រះបាទាបាន ។

[ ១២៦ ] ( នាងបភាវតី... ) បពិត្រព្រះសម្មតិទេព រាត្រីទាំងនោះ វៀរចាកព្រះអង្គកន្លងទៅ បពិត្រព្រះអង្គជាបុគ្គលប្រសើរលើរថ ខ្ញុំម្ចាស់សូម ( ក្រាប ) ដោយក្បាល ថ្វាយបង្គំព្រះបាទទាំងគូរបស់ព្រះអង្គ សូមព្រះអង្គកុំខ្ញាល់នឹងខ្ញុំម្ចាស់ ។ បពិត្រមហារាជ ខ្ញុំម្ចាស់សូមប្ដេជ្ញាពាក្យពិតចំពោះព្រះអង្គ សូមព្រះអង្គទ្រង់ព្រះសណ្ដាប់ពាក្យរបស់ខ្ញុំម្ចាស់ ៗ លែងធ្វើនូវការមិនស្រឡាញ់ព្រះអង្គទៀតហើយ ។ កាលបើខ្ញុំម្ចាស់អង្វរករយ៉ាងនេះហើយ បើព្រះអង្គនឹងមិនធ្វើតាមពាក្យខ្ញុំម្ចាស់ទេ ព្រះរាជបិតា មុខជានឹងសម្លាប់ខ្ញុំម្ចាស់ ឥឡូវនេះ ហើយប្រទានដល់ពួកក្សត្រមិនខាន ។

[ ១២៧ ] ( ព្រះមហាសត្វ... ) កាលបើនាងអង្វរករយ៉ាងនេះហើយ យើងនឹងមិនធ្វើតាមពាក្យរបស់នាងឯណាបាន នែនាងបភាវតីស្រីកល្យាណី បងលែងខឹងនឹងនាងហើយ នាងកុំភ័យឡើយ ។ នែរាជបុត្រី យើងសូមប្ដេជ្ញាពាក្យពិតចំពោះនាង ៗ ចូរស្ដាប់ពាក្យរបស់យើង ៗ លែងធ្វើនូវសេចក្ដីមិនជាទីស្រឡាញ់នាងទៀត ។ នែនាងបភាវតី ជាស្រីមានចង្កេះរៀវ យើងអត់ទ្រាំសេចក្ដីទុក្ខច្រើនជង ព្រោះតែចង់បាននាង យើងហ៊ានសម្លាប់ត្រកូលរបស់ព្រះបាទមទ្ទៈជាច្រើន ហើយនាំយកនាងទៅបាន ។

[ ១២៨ ] ពួកជនទាំងឡាយ ចូរទឹមសេះដ៏រំលេចដោយគ្រឿងប្រដាប់

ផ្សេងៗ ជាសត្វរាបរយក្នុងរថ កាលបើទឹមហើយ អ្នកទាំងឡាយមុខជានឹងឃើញកម្លាំងរបស់ខ្ញុំ ដែលកម្ចាត់ពួកខ្មាំងបាន ។ ( អភិសម្ពុទ្ធគាថា ) ពួកស្រីក្នុងព្រះរាជវាំងរបស់ព្រះបាទមទ្ទៈ ( នាំគ្នាបើកបង្អួច ) អើតមើលព្រះបាទកុសៈនោះ ដែលកំពុងមឹតពត់ កំពុងទង្គិចដើមដៃទាំងពីរខាង ដូចជាសីហៈក្នុងទីនោះ ។

[ ១២៩ ] ព្រះបាទកុសៈ លើកព្រះនាងបភាវតីឡើងកាន់កដំរី លុកលុយចូលទៅក្នុងសង្គ្រាម ហើយក៏បន្លឺនូវសីហនាទ ។ ពួកក្សត្រិយ៍ ឮព្រះបាទកុសៈនោះ បន្លឺសីហនាទនោះ ត្រូវភ័យអំពីសំឡេងគម្រាមនៃព្រះបាទកុសៈបៀតបៀនហើយ ក៏នាំគ្នារត់បែកខ្ញែកដូចជាពួកម្រឹគដទៃ ( ដែលភ័យនឹងសម្រែក ) នៃសីហៈ ។ ពួកទាហានដំរី ទាហានសេះ ទាហានរថ ទាហានថ្មើរជើង ត្រូវភ័យអំពីសំឡេងនៃព្រះបាទកុសៈបៀតបៀនហើយ ក៏រត់ជាន់គ្នាទៅវិញទៅមក ។ ទេវរាជជាធំជាងទេវតា បានឃើញហើយ ក៏មានព្រះទ័យរីករាយ បានប្រទានកែវមណីឈ្មោះវេរោចនៈ ដល់ព្រះបាទកុសៈក្នុងប្រធាននៃសង្គ្រាមនោះ ។ ព្រះរាជានោះ លុះឈ្នះសង្គ្រាមនោះ បានកែវមណីឈ្មោះ វេរោចនៈហើយ គង់លើកដំរី ក៏យាងចូលទៅកាន់បុរី ។ ព្រះបាទកុសៈបានចាប់យកក្សត្រទាំង ៧ អង្គទាំងរស់ ចងនាំមកថ្វាយដល់ព្រះបិតាក្មេកថា បពិត្រព្រះសម្មតិទេព ក្សត្រទាំង ៧ នេះហើយ ជាសត្រូវរបស់ព្រះអង្គ ។ ពួកក្សត្រជាសត្រូវទាំងអស់ ជាអ្នកបៀតបៀនព្រះអង្គ លុះក្នុងអំណាចរបស់ព្រះអង្គហើយ សូមព្រះអង្គធ្វើតាមបំណងរបស់ព្រះអង្គចុះ ទោះ

ព្រះអង្គលែងក្សត្រទាំងនោះ ឬសម្លាប់នូវក្សត្រទាំងនោះចុះ ។

[ ១៣០ ] ( ព្រះរាជា... ) បពិត្រមហារាជ ព្រះរាជាទាំងនុ៎ះ ជាសត្រូវរបស់ព្រះអង្គ ព្រះរាជាទាំងនោះ មិនមែនជាសត្រូវរបស់ខ្ញុំទេ ព្រះអង្គ ( ជាឥស្សរៈ ) របស់ពួកយើងស្រាប់ហើយ ទោះលែងក្សត្រទាំងនោះ ឬសម្លាប់នូវក្សត្រទាំងនោះចុះ ។

[ ១៣១ ] ( ព្រះមហាសត្ត... ) ធីតាទាំងឡាយរបស់ព្រះអង្គទាំង ៧ នេះ ល្អមានឧបមាដោយទេវកញ្ញា សូមព្រះអង្គប្រទានធីតាមួយអង្គៗ ដល់ព្រះរាជាទាំងនោះៗចូរជាកូនប្រសាររបស់ព្រះអង្គចុះ ។

[ ១៣២ ] ( ព្រះបាទមទ្ទ:... ) បពិត្រមហារាជ ព្រះអង្គជាឥស្សរៈរបស់ពួកយើងទាំងអស់គ្នា គឺ ( ព្រះរាជាទាំង ៧ នេះផង ) ខ្ញុំផង ធីតាទាំងនោះផង ព្រះអង្គប្រាថ្នានឹង ( ប្រទាន ) ធីតាណា ( ដល់ព្រះរាជាណា ) សូមប្រទាន ( ធីតានោះ ) ដល់ព្រះរាជានោះចុះ ។

[ ១៣៣ ] ( អភិសម្ពុទ្ធគាថា ) ព្រះបាទកុសៈមានព្រះវាចាសព្ទស្មើនឹងសំឡេងសីហៈ បានប្រទានពួកធីតារបស់ព្រះបាទមទ្ទៈមួយអង្គៗ ដល់ក្សត្រទាំងនោះមួយអង្គៗ ។ ពួកក្សត្រទាំង ៧ អង្គ មានព្រះហឫទ័យស្កប់ស្កល់ដោយលាភនោះហើយ ក៏ត្រេកអរចំពោះព្រះបាទកុសៈ ដែលមានព្រះសូរវាចាស្មើនឹងសំឡេងសីហៈ បានទៅកាន់ដែនទាំងឡាយរៀងខ្លួន ក្នុងលំដាប់នោះឯង ។ ចំណែកឯព្រះបាទកុសៈមានកម្លាំងច្រើន បាននាំយកនាងបភាវតី និងកែវមណីឈ្មោះវេរោចនៈដ៏ល្អ ហើយទ្រង់ស្ដេចវិលត្រឡប់ទៅ

កាន់ក្រុងកុសាវតីវិញ ។ ក្សត្រទាំងនោះ គង់លើរថជាមួយគ្នា បរសំដៅចូលទៅកាន់ក្រុងកុសាវតី ស្មើគ្នាដោយវណ្ណៈនិងរូប មិនរុងរឿងជាងគ្នាប៉ុន្មានទេ ។ ព្រះមាតាបានជួបជុំដោយបុត្ត ចំណែកអគ្គមហេសីនិងព្រះរាជស្វាមីទាំង ២ ព្រះអង្គនោះ បានព្រមព្រៀងគ្នា នៅគ្រប់គ្រងរាជធរណីដ៏សម្បូណ៌សប្បាយក្នុងកាលនោះ ។

**ចប់ កុសជាតកទី ១ ។**

# សត្តតិនិបាត

## អដ្ឋកថា កុសជាតក

[ ៩៤-១៣៣ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអផ្សុកមួយរូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឥទន្តេ រដ្ឋំ** ដូច្នេះជាដើម ។

បានឮថា កុលបុត្តអ្នកក្រុងសាវត្ថីម្នាក់ បានថ្វាយជីវិតក្នុងសាសនាបព្វជ្ជាហើយ ថ្ងៃមួយ លោកត្រាច់ទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ឃើញស្ត្រីម្នាក់ ប្រដាប់តាក់តែងកាយយ៉ាងស្អាត សម្លឹងមើលដោយអំណាចសុភនិមិត្ត ត្រូវកិលេសគ្របសង្កត់ អស់នូវសេចក្តីត្រេកអរហើយ ។ លោកមានសក់និងក្រចកដុះវែង មានចីវរសៅហ្មង មានខ្លួនស្គមលឿង មានកាយរវាមទៅ

ដោយសរសៃ ។ មានឧបមាដូចបុព្វនិមិត្ត ៥ ប្រការដែលប្រាកដដល់ទេវបុត្តទាំងឡាយ ដែលនឹងត្រូវចុតិជាធម្មតាក្នុងទេវលោក គឺកម្រងផ្កាស្វិតស្រពោន ១ សំពត់ស្លៀកដណ្តប់សៅហ្មង ១ មានពណ៌សម្បុរកាយសៅហ្មងឈានចុះក្នុងសរីរៈ ១ ញើសហូរចេញអំពីក្លៀកទាំងសងខាង ១ មិនត្រេកអរក្នុងទិព្វាសនៈ ១ យ៉ាងណា បុព្វនិមិត្ត ៥ ក៏រមែងប្រាកដដល់ភិក្ខុមិនត្រេកអរក្នុងធម្មវិន័យដែលមានចិត្តចង់សឹក ដែលត្រូវឃ្លាតចាកសាសនាជាធម្មតា បានដល់ផ្កា គឺសទ្ធារមែងស្វិតស្រពោនទៅ ១ សំពត់ គឺសីលរមែងសៅហ្មង ១ ពណ៌សម្បុរសៅហ្មងឈានចុះក្នុងសរីរៈ ដោយភាពជាបុគ្គលខ្មាសអៀននិងដោយអំណាចនៃការមិនមានយស ១ ញើសគឺកិលេសរមែងហូរចេញ ១ ភិក្ខុនោះមិនត្រេកអរក្នុងព្រៃ ត្រង់គល់ឈើ ផ្ទះស្ងាត់ដូច្នោះដូចគ្នា ១ និមិត្តទាំងឡាយ ប្រាកដហើយដល់ភិក្ខុនោះ ។ លំដាប់នោះ ភិក្ខុទាំងឡាយ ក៏បាននាំលោកទៅកាន់សម្នាក់ព្រះសាស្ដា ហើយបង្ហាញឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ភិក្ខុរូបនេះអផ្សុក ។ ព្រះសាស្ដាត្រាស់សួរថា ម្នាលភិក្ខុ បានឮថាអ្នកអផ្សុកពិតឬ កាលភិក្ខុរូបនោះក្រាបទូលថា ពិតហើយព្រះអង្គ ទើបត្រាស់ថា ម្នាលភិក្ខុ អ្នកកុំធ្លាក់ក្នុងអំណាចកិលេសឡើយ ធម្មតាមាតុគ្រាមនេះជាសត្រូវចំពោះព្រហ្មចរិយៈ ចូរអ្នកហាមចិត្ត ដែលជាប់ចំពាក់ក្នុងមាតុគ្រាមនេះចេញ ចូរត្រេកអរក្នុងសាសនាចុះ ពិតហើយ បុរាណកបណ្ឌិតទាំងឡាយ ជាអ្នកមានតេជះ រមែងវិនាសទៅបាន ព្រោះជាអ្នកមានចិត្តជាប់ចំពាក់ក្នុងមាតុគ្រាម និងជាអ្នកអស់តេជះ ដល់នូវសេចក្ដីលំបាកព្រោះមាតុ

គ្រាម ដូច្នេះហើយ ទ្រង់បាននៅស្ងៀម បានទទួលការអារាធនាអំពីភិក្ខុទាំងនោះ ទើបទ្រង់នាំអតីតនិទានមកថា

ក្នុងអតីតកាល ព្រះរាជាមួយអង្គ ព្រះនាមថា ព្រះបាទឱក្កាករាជ ទ្រង់គ្រងរាជសម្បត្តិដោយធម៌ ក្នុងរាជធានីឈ្មោះកុសាវតី ដែនមល្លៈ ។ ព្រះរាជាមានអគ្គមហេសីព្រះនាមថា សីលវតី ដែលជាធំជាងស្នំ ១៦០០០ ព្រះនាងសីលវតីនោះ មិនមានព្រះរាជឱរសនិងព្រះរាជធីតាឡើយ ។ លំដាប់នោះ ទើបអ្នកនគរ និងអ្នកដែនទាំងឡាយ នាំគ្នាមកប្រជុំត្រង់ទ្វារព្រះរាជនិវេសន៍ ហើយទូលស្នើព្រះរាជាអង្គនោះថា ស្រុកទេសនឹងវិនាស ស្រុកទេសនឹងវិនាស ព្រះរាជាទ្រង់បើកសីហបញ្ជរ ហើយត្រាស់សួរថា កាលយើងគ្រប់គ្រងរដ្ឋ ឈ្មោះថា ការធ្វើវត្ថុដែលមិនប្រកបដោយធម៌រមែងមិនមាន ពួកអ្នកមកស្រែកធ្វើអ្វី ។ ពួកមហាជនក្រាបទូលថា បពិត្រព្រះអង្គ ឈ្មោះថា ការធ្វើវត្ថុមិនប្រកបដោយធម៌ មិនមានឡើយ តែព្រះរាជឱរសបន្តវង្សរបស់ទ្រង់មិនទាន់មាន ជនដទៃនឹងដណ្តើមយករាជសម្បត្តិ ហើយធ្វើនគរឲ្យវិនាសព្រោះ ហេតុនោះ សូមទ្រង់ប្រាថ្នាព្រះរាជឱរសដែលអាចគ្រប់គ្រងរាជសម្បត្តិដោយធម៌ចុះ ។ ព្រះរាជាត្រាស់ថា យើងប្រាថ្នាព្រះរាជឱរស តើធ្វើដូចម្តេចល្អ ។ ពួកមហាជនក្រាបទូលពិធីការថា បពិត្រព្រះអង្គ ជាបឋម សូមទ្រង់ដោះលែង ស្រីរបាំវ័យក្មេងម្នាក់ ធ្វើឲ្យជាអ្នករបាំដោយធម៌ទៅ ៧ ថ្ងៃ បើនាងបានកូនក៏ជាការល្អ បើមិនបាន បន្ទាប់អំពីនោះ ក៏ចូរដោះលែងអ្នករបាំវ័យកណ្តាល បន្ទាប់អំពីនោះ ដោះលែងអ្នករបាំជាន់ខ្ពស់ បណ្តាស្នំមានប្រមាណ

ប៉ុណ្ណោះ ស្ត្រីអ្នកមានបុណ្យម្នាក់ នឹងមានព្រះរាជឱរសដោយពិត ។ ព្រះរាជាធ្វើតាមពាក្យរបស់អ្នកនគរទាំងនោះគ្រប់យ៉ាង ទ្រង់អភិរម្យតាមសេចក្ដីសុខសប្បាយអស់ ៧ ថ្ងៃ ទើបត្រាស់សួរស្រីស្នំ ដែលនាំគ្នាត្រឡប់មកហើយថា ពួកនាងមានកូនហើយឬ ស្រីស្នំទាំងអស់ក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់ធ្វើឲ្យមានបុត្តមិនបានឡើយ ព្រះរាជាទ្រង់ទោមនស្សថា ឱរសមិនកើតដល់អញ ដោយពិត អ្នកនគរទាំងឡាយក៏នាំគ្នាស្រែកយ៉ាងនោះទៀត ព្រះរាជា ត្រាស់ថា ពួកអ្នកទាំងឡាយ នាំគ្នាមកស្រែកដោយហេតុអ្វី អញបានដោះលែងស្រីស្នំទៅតាមពាក្យរបស់ពួកអ្នកហើយ សូម្បីតែស្រីស្នំម្នាក់ ក៏មិនមានកូន ឥឡូវនេះ ឲ្យអញធ្វើដូចម្ដេច ។ ពួកអ្នកនគរក្រាបទូលថា បពិត្រព្រះអង្គ ស្រីទាំងនោះ ជាស្រីទ្រុស្តសីល មិនមានបុណ្យ ស្រីទាំងនោះមិនមានបុណ្យសម្រាប់បានបុត្ត បើស្រីទាំងនេះមិនបានបុត្ត សូមទ្រង់កុំជាក់នូវព្រះឧស្សាហៈចោលឡើយ ព្រះនាងសីលវតីអគ្គមហេសីរបស់ទ្រង់ ដល់ព្រមដោយសីល សូមទ្រង់ដោះលែងព្រះនាងទៅចុះ ព្រះនាងនឹងបានឱរសដោយពិត ព្រះរាជាទ្រង់ទទួលថា សាធុ ដូច្នេះហើយ ទើបត្រាស់ឲ្យវាយស្គរប្រកាសថា បានឮថា ក្នុងថ្ងៃទី ៧ បន្ទាប់អំពីថ្ងៃនេះទៅ ព្រះរាជាទ្រង់ធ្វើព្រះនាងសីលវតីឲ្យជាអ្នករបាំដោយធម៌ ហើយលែងទៅ បណ្ដាបុរសទាំងឡាយចូរមកប្រជុំគ្នា លុះដល់គម្រប់ ៧ ថ្ងៃ ទើបឲ្យប្រដាប់តាក់តែងព្រះនាង ហើយឲ្យចុះអំពីព្រះរាជនិវេសន៍លែងទៅ ។ ដោយតេជះនៃសីលរបស់នាង សក្កទេវរាជ ក៏សម្ដែងអាការក្ដៅ ។ ទើបសក្កៈពិចារណាថា អ្វីកើតឡើងហ្ន៎

ក៏ទ្រង់ជ្រាបថា ព្រះនាងប្រាថ្នាបុត្ត ទើបទ្រង់ព្រះតម្រិះថា អញគួរឲ្យបុត្តដល់ព្រះនាង បានពិចារណាបន្តថា ព្រះឱរសដែលសមគួរដល់ព្រះនាងក្នុងទេវលោកមានឬទេហ្ន៎ ក៏បានឃើញព្រះពោធិសត្វ ។

បានឮថា ក្នុងកាលនោះ ព្រះពោធិសត្វនោះ អស់អាយុក្នុងតាវត្តិង្សភព ជាអ្នកប្រាថ្នាទៅកើតក្នុងទេវលោកខាងលើជាបន្ត សក្កទេវរាជយាងទៅកាន់ទ្វារវិមានរបស់ព្រះពោធិសត្វនោះ ត្រាស់ថា ម្នាលអ្នកនិទ៌ុក្ខ អ្នកគួរទៅកាន់មនុស្សលោក ហើយបដិសន្ធិក្នុងព្រះឧទរអគ្គមហេសីរបស់ព្រះបាទឱក្កាករាជ ឲ្យព្រះពោធិសត្វទទួលហើយទើបត្រាស់នឹងទេវបុត្តមួយអង្គទៀតថា សូម្បីអ្នកក៏ត្រូវជាឱរសរបស់ព្រះនាង ហើយបានទៅកាន់និវេសន៍របស់ព្រះរាជា ដោយភេទនៃព្រាហ្មណ៍ចាស់ ដោយទ្រង់ព្រះតម្រិះថា បុគ្គលណាម្នាក់ កុំបីទម្លាយសីលរបស់ព្រះនាងឡើយ សូម្បីមហាជនថ្លូតទឹក តាក់តែងកាយហើយ ក៏ទៅប្រជុំត្រង់ទ្វារព្រះរាជនិវេសន៍ ដោយគិតថា អញនឹងទទួលយកព្រះទេវី កាលឃើញសក្កទេវរាជ ក៏ធ្វើការចំអកថា តាកញ្ចាស់នេះមកធ្វើអ្វី ។ សក្កទេវរាជត្រាស់ថា អ្នកទាំងឡាយតិះដៀលខ្ញុំធ្វើអ្វី ទោះជារាងកាយខ្ញុំចាស់ជរាមែន តែរាគៈមិនចាស់ទេ ខ្ញុំមកដោយគិតថា បើខ្ញុំបានព្រះនាងសីលវតីក៏នឹងនាំនាងទៅ ដូច្នេះហើយ ទើបទៅឈរខាងមុខគេបង្អស់ដោយអានុភាពរបស់ខ្លួន អ្នកដទៃមិនអាចឈរពាំងមុខបានឡើយ ព្រោះតេជៈនៃសក្កៈនោះ ។ លុះព្រះនាងប្រដាប់ដោយគ្រឿងអលង្ការទាំងពួងយាងចេញអំពីព្រះរាជនិវេសន៍ សក្កៈចាប់ត្រង់ព្រះហស្ត ហើយក៏នាំចៀសចេញ

ទៅ ។ លំដាប់នោះ មហាជនទាំងឡាយ ដែលនៅក្នុងទីនោះ នាំគ្នាតិះដៀលព្រះនាងថា មើលចុះលោកដ៏ចម្រើន ព្រាហ្មណ៍ ចាស់នាំព្រះទេវីដែលមានរូបល្អឯកដល់ម៉្លេះទៅ តាកញ្ចាស់ប្រហែលជាមិនដឹងវត្ថុដែលសមគួរដល់ខ្លួនទេ សូម្បីព្រះទេវីក៏មិនមានខ្មាសថា ព្រាហ្មណ៍ចាស់នាំអញទៅ ។ សូម្បីព្រះរាជាប្រថាប់ឈរក្បែរបង្អួច ក៏រង់ចាំមើលថា នរណានាំព្រះទេវីទៅ កាលបានឃើញព្រាហ្មណ៍ចាស់ ទ្រង់ក៏ទោមនស្ស ។

សក្កទេវរាជនាំព្រះនាងចេញអំពីទ្វារនគរ ទ្រង់និម្មិតផ្ទះមួយខ្នង ក្បែរទ្វារនគរ ធ្វើការបើកសន្ទះទ្វារទុក និងចាត់ចែងកម្រាល ដែលធ្វើដោយឈើទុកហើយ ។ លំដាប់នោះ ព្រះនាងត្រាស់សួរសក្កៈថា នេះផ្ទះរបស់អ្នកឬ សក្កទេវរាជត្រាស់ថា ពិតហើយនាង កាលមុនខ្ញុំនៅតែឯង ឥឡូវនេះ ខ្ញុំនិងនាងនៅជាមួយគ្នា ២ នាក់ ខ្ញុំត្រូវត្រាច់ទៅរកអង្ករជាដើមមកទុក សូមនាងសម្រាកលើកម្រាលឈើនេះសិនចុះ ហើយទ្រង់យកព្រះហស្តដ៏ទន់ស្ទាបអង្អែលព្រះនាង ទិព្វសម្ផស្សក៏ផ្សាយទៅពេញព្រះកាយ ព្រះនាងក៏ផ្ទំលក់ក្នុងទីនោះ ។ ដោយការផ្សាយនៃទិព្វសម្ផស្ស ព្រះនាងក៏អស់នូវសញ្ញា គឺផ្ទំលក់ទៅ ។ លំដាប់នោះ សក្កទេវរាជទ្រង់ក៏ត្រកងព្រះនាងទៅកាន់តាវត្តិង្សពិភពដោយអានុភាពរបស់ខ្លួន ឲ្យព្រះនាងផ្ទំលើទិព្វសយនៈក្នុងវិមានដែលប្រដាប់តាក់តែងហើយ ។ ក្នុងថ្ងៃទី ៧ ព្រះនាងក៏តើនអំពីផ្ទំ ទតឃើញសម្បត្តិនោះជ្រាបបានថា ព្រាហ្មណ៍នេះមិនមែនជាមនុស្សសាមញ្ញ ជាសក្កទេវរាជពិត ។

ក្នុងសម័យនោះ សក្កទេវរាជទ្រង់មានអ្នករបាំចោមរោម ប្រថាប់គង់

ត្រង់គល់បារិច្ឆត្តកៈ ។ ព្រះនាងឃើញសក្កៈនោះហើយ ទើបក្រោកចាកទីបន្ទំ ចូលទៅរកទ្រង់ ថ្វាយបង្គំហើយ ប្រថាប់ឈរក្នុងចំណែកម្ខាង ។ លំដាប់នោះ សក្កទេវរាជត្រាស់នឹងព្រះនាងថា បពិត្រព្រះទេវី យើងនឹងឲ្យពរមួយ សូមព្រះនាងទទួលយកចុះ ។ ព្រះនាងក្រាបទូលថា បើដូច្នោះ សូមទ្រង់ប្រទានបុត្តដល់ខ្ញុំម្ចាស់មួយអង្គចុះ ។ សក្កទេវរាជត្រាស់ថា មិនត្រឹមតែឱរសមួយអង្គឡើយ យើងនឹងឲ្យឱរស ២ អង្គដល់នាង តែក្នុងឱរសទាំង ២ អង្គនោះ ១ អង្គមានបញ្ញា តែរូបសម្បត្តិមិនស្អាត មួយអង្គរូបស្អាត តែមិនសម្បូរបញ្ញាទេ ក្នុងឱរសទាំង ២ អង្គនោះ ព្រះនាងចង់បានមួយណាមុន ។ ព្រះនាងក្រាបទូលថា ខ្ញុំម្ចាស់ចង់បានព្រះឱរសដែលមានបញ្ញាមុន សក្កទេវរាជត្រាស់ថា សាធុ ដូច្នេះហើយ ទ្រង់ប្រទានរបស់ ៥ ដល់ព្រះនាង គឺស្បូវ ១ សំពត់ទិព្វ ១ លម្អិតចន្ទន៍ទិព្វ ១ ផ្កាបារិច្ឆត្តកទិព្វ ១ ពិណឈ្មោះកោកនទៈ ១ ដល់ព្រះនាង ហើយទ្រង់នាំព្រះនាងហោះទៅកាន់ទីបន្ទំរបស់ព្រះរាជា ឲ្យព្រះនាងផ្ទំលើព្រះភូសា លើព្រះទែនជាមួយព្រះរាជា ទ្រង់ស្ទាបផ្ចិតព្រះនាងដោយព្រះអង្គុដ្ឋ គឺមេដៃ ក្នុងខណៈនោះព្រះពោធិសត្វបដិសន្ធិក្នុងព្រះឧទររបស់ព្រះនាង សូម្បីសក្កទេវរាជ ទ្រង់ក៏ទៅកាន់លំនៅរបស់ទ្រង់វិញ ព្រះទេវីជ្រាបថា ព្រះនាងមានព្រះគភ៌ ព្រោះព្រះនាងជាបណ្ឌិត ។ លំដាប់នោះ ព្រះរាជាតើនចាកព្រះបន្ទំ ទតឃើញព្រះនាង ទើបសួរថា នែព្រះទេវី អ្នកណានាំនាងមក ព្រះទេវីក្រាបទូលថា បពិត្រព្រះអង្គ គឺសក្កទេវរាជ ។ ព្រះរាជាត្រាស់ថា យើងបានឃើញនាងនឹងភ្នែកថា ព្រាហ្មណ៍ចាស់ម្នាក់បាននាំនាងទៅ ហេតុអ្វី

ទើបនាងបោកបញ្ឆោតយើង ។ ព្រះទេវីក្រាបទូលថា សូមទ្រង់ជឿចុះ សក្កទេវរាជនាំខ្ញុំម្ចាស់ទៅ បាននាំទៅដល់ទេវលោក ។ ព្រះរាជាត្រាស់ថា យើងមិនជឿនាងឡើយ ។ លំដាប់នោះ ទើបព្រះនាងបង្ហាញស្បូវដែលសក្កៈប្រទានដល់ព្រះរាជា ក្រាបទូលថា សូមទ្រង់ជឿខ្ញុំម្ចាស់ចុះ ។ ព្រះរាជាត្រាស់ថា គ្រាន់តែស្បូវក្នុងទីណា អ្នកណាក៏យកមកបាន ទើបទ្រង់មិនជឿ ។ លំដាប់នោះ ព្រះនាងក៏នាំយករបស់ ៤ មុខ មានសំពត់ទិព្វជាដើមបង្ហាញដល់ព្រះរាជា ព្រះរាជាលុះបានទតឃើញវត្ថុទាំងនោះហើយ ទើបទ្រង់ជឿ ហើយត្រាស់សួរថា នែនាងដ៏ចម្រើន រឿងសក្កៈនាំនាងទៅ ស្ងេះទុកសិនចុះ តើនាងបានបុត្តហើយឬនៅ ព្រះទេវីក្រាបទូលថា បពិត្រមហារាជ ខ្ញុំម្ចាស់បានបុត្តហើយ ឥឡូវនេះខ្ញុំម្ចាស់កំពុងមានគភ៌ ។ ព្រះរាជាបានស្តាប់ពាក្យនោះហើយក៏ទ្រង់ត្រេកអរ ទើបព្រះរាជទានគ្រឿងបរិហារគភ៌ ដល់ព្រះនាង លុះគ្រប់កំណត់ទសមាស ព្រះនាងក៏ប្រសូតបុត្ត ព្រះជនកនិងព្រះជននី មិនបានថ្វាយព្រះនាមដទៃដល់ព្រះរាជឱរសនោះឡើយ ទ្រង់ថ្វាយព្រះនាមថា កុសតិណរាជកុមារ ។ ក្នុងកាលដែលកុសតិណរាជកុមារចេះដើរទៅមកបាន ទេវបុត្តមួយអង្គទៀត ក៏បដិសន្ធិក្នុងព្រះឧទររបស់ព្រះនាង ។ លុះគ្រប់ទសមាសព្រះនាង ក៏ប្រសូតព្រះរាជឱរសមួយអង្គទៀត ព្រះជនកព្រះជននីបានថ្វាយព្រះនាមព្រះរាជកុមារដែលប្រសូតនោះថា ជយម្បតីរាជកុមារ ។ ព្រះរាជកុមារទាំង ២ អង្គនោះទ្រង់ចម្រើនព្រះជន្មវស្សាដោយព្រះឥស្សរិយយសដ៏ធំ ។ ព្រះពោធិសត្វទ្រង់មានបញ្ញា ទ្រង់មិនចាំបាច់សិក្សារៀនសូត្រនូវសិល្បសាស្ត្រ

ណា ក្នុងសម្នាក់របស់អាចារ្យ ក៏ទ្រង់ដល់នូវការសម្រេចក្នុងសិល្បសាស្រ្ត ទាំងអស់បាន ដោយបញ្ញារបស់ទ្រង់ឯង ។

សម័យនោះ ក្នុងកាលដែលព្រះពោធិសត្វ ទ្រង់ចម្រើនព្រះជន្មាយុបាន ១៦ វស្សា ព្រះរាជាទ្រង់ប្រាថ្នាប្រគល់រាជសម្បត្តិឲ្យ ទើបត្រាស់ឲ្យព្រះទេវី មក ហើយត្រាស់ថា នែទេវី យើងនឹងប្រគល់រាជសម្បត្តិឲ្យដល់ឱរសច្បង របស់នាង និងឲ្យស្រីរបាំទាំងឡាយបម្រើ ទាន់យើងទាំងពីរនៅមានជីវិត យើងនឹងបានឃើញកូនគ្រងរាជសម្បត្តិ ឯកូនរបស់យើងពេញចិត្តក្នុងព្រះរាជធីតារបស់ស្តេចអង្គណា ក្នុងជម្ពូទ្វីបទាំងមូល យើងនឹងនាំព្រះរាជធីតានោះ មកស្ថាបនា ឲ្យជាអគ្គមហេសីដល់កូន ចូរនាងដឹងចិត្តរបស់កូនថា គេពេញ ចិត្តនឹងព្រះរាជធីតាអង្គណា ។ ព្រះនាងទទួលថា សាធុ ហើយបញ្ជូនបរិចារិកា ម្នាក់ទៅដោយព្រះតម្រាស់ថា ចូរនាងទៅប្រាប់រឿងនេះដល់កុមារ ហើយចូរ ដឹងចិត្ត ។ បរិចារិកានោះទៅទូលរឿងនោះដល់ព្រះរាជកុមារនោះ ហើយ ព្រះមហាសត្វបានស្តាប់ពាក្យនោះហើយ គិតថា អញមានរូបមិនស្អាត ព្រះ រាជធីតាដែលសម្បូរដោយរូប ទោះបីនាំមក គ្រាន់តែឃើញអញ ក៏នឹងគេច ទៅ ដោយគិតថា ប្រយោជន៍អ្វី ដោយកុមារដែលមានគួរខ្ពើម ការខ្មាស គប្បីមានដល់អញដោយប្រការដូច្នេះ ប្រយោជន៍អ្វីដោយឃរាវាស អញថែ ទាំមាតាបិតា កាលទ្រង់អស់ព្រះជន្មទាំង ២ ហើយ ក៏នឹងចេញបួស ទើប ព្រះរាជកុមារត្រាស់ថា យើងមិនត្រូវការដោយរាជសម្បត្តិ មិនត្រូវការដោយ អ្នករបាំ លុះព្រះជនកនិងព្រះជននីសោយទិវង្គតទៅហើយ យើងនឹងបួស ។

បរិចារិកានោះ ស្តាប់ព្រះតម្រាស់ហើយ ក៏ត្រឡប់មកក្រាបទូលព្រះតម្រាស់របស់ព្រះរាជកុមារនោះ ដល់ព្រះទេវី ។ សូម្បីព្រះទេវី ក៏ក្រាបទូលដល់ព្រះរាជាហើយ ព្រះរាជាទ្រង់ស្តាប់ពាក្យនោះហើយ ទ្រង់ក៏ទោមនស្ស លុះកន្លងទៅ ២-៣ ថ្ងៃ ក៏ទ្រង់បញ្ជូនដំណឹងទៅទៀត ឯកុមារនោះក៏នៅតែជំទាស់ដូចមុន ។ ព្រះរាជកុមារ ទ្រង់ជំទាស់យ៉ាងនេះអស់វារៈ ៣ ដង ក្នុងវារៈទី ៤ ទើបព្រះតម្រិះថា ធម្មតាកូនដែលរឹងទទឹងនឹងព្រះមាតាបិតារហូត មិនសមគួរឡើយ អញនឹងធ្វើឧបាយណាមួយ ។ ព្រះរាជកុមារនោះ ក៏ហៅមេជាងមាសម្នាក់មកហើយ ព្រះរាជទានមាសជាច្រើន ត្រាស់ថា ចូរអ្នកធ្វើរូបស្រីម្នាក់ចុះ ហើយបញ្ជូនជាងមាសនោះទៅ កាលជាងមាសនោះទៅហើយ ទើបទ្រង់នាំយកមាសដទៃមក ធ្វើជារូបស្រីដោយអង្គឯង ធម្មតាបំណងព្រះពោធិសត្វទាំងឡាយ រមែងសម្រេចរហូតទៅ ។ រូបមាសដែលព្រះពោធិសត្វធ្វើនោះ ល្អពន់ពេក រហូតមិនមានពាក្យពណ៌នា ដោយអណ្តាតបាន ។ គ្រានោះព្រះមហាសត្វ ទ្រង់តាក់តែងរូបស្រីនោះ ឲ្យស្លៀកខោមពស្ត្រហើយទ្រង់តម្កល់ទុកក្នុងបន្ទប់ដ៏មានសិរី ។ ព្រះមហាសត្វនោះ ឃើញរូបស្រីដែលជាងមាសនាំមក ទ្រង់តិះដៀលរូបនោះ ហើយត្រាស់ថា ចូរអ្នកទៅនាំយករូបស្រី ដែលតម្កល់ក្នុងបន្ទប់ដ៏មានសិរីរបស់យើង មកប្រៀបធៀបគ្នាមើលចុះ ជាងមាសនោះចូលទៅកាន់បន្ទប់ដ៏មានសិរី ឃើញរូបស្រីនោះហើយ ស្មានថាទេពអប្សរម្នាក់ មករួមអភិរម្យជាមួយព្រះរាជកុមារ ទើបមិនអាចលាដៃទៅចាប់ ត្រឡប់មកក្រាបទូលថា ទេពអប្សរមួយអង្គប្រថាប់នៅក្នុងបន្ទប់ដ៏មាន

សិរី ទូលព្រះបង្គំមិនអាចចូលទៅបាន ។

ព្រះរាជកុមារត្រាស់ថា នែបា អ្នកចូរទៅនាំយកមកចុះ រូបមាសនោះយើងធ្វើឯង ហើយទ្រង់បញ្ជូនទៅម្ដងទៀត ។ ជាងមាសនោះត្រឡប់ចូលទៅលើកចេញមក ព្រះរាជកុមារឲ្យទុករូបមាសដែលនាំមកនោះក្នុងបន្ទប់ សម្រាប់ដាក់មាស ហើយឲ្យមនុស្សតាក់តែងរូបដែលទ្រង់ធ្វើ ហើយលើកឡើងដាក់លើរថ បញ្ជូនទៅកាន់សម្នាក់របស់ព្រះមាតា ដោយព្រះតម្រាស់ថា បើរកបានស្រីស្អាតដូចរូបនេះ ខ្ញុំនឹងគ្រប់គ្រងផ្ទះ ។

ព្រះទេវីនោះឲ្យហៅពួកអាមាត្យមកហើយ ត្រាស់ថា អ្នកទាំងឡាយព្រះរាជឱរសរបស់យើងមានបុណ្យច្រើន ជាឱរសដែលព្រះឥន្ទ្រប្រទាន ចង់បានកុមារិកាដែលមានរូបបែបនេះ ពួកលោកបានស្រីបែបនេះ ចូរនាំមក ចូរតាំងរូបនេះទុកលើយានដែលបិទបាំងហើយ ត្រាច់ទៅក្នុងជម្ពូទ្វីបទាំងមូល បើបានជួបព្រះធីតានៃព្រះរាជាអង្គណា ដែលមានរូបស្អាតបែបនេះសោត ក៏ចូរថ្វាយរូបមាសនេះដល់ព្រះរាជាអង្គនោះឯង ហើយក្រាបទូលថា ព្រះបាទឱក្កាករាជនឹងធ្វើអាវាហវិវាហមង្គលជាមួយព្រះនាង ទូលកំណត់ថ្ងៃហើយ ចូរប្រញាប់ត្រឡប់មក ។ អាមាត្យទាំងនោះ ទទួលព្រះរាជសវនីយ៍ហើយ នាំរូបនោះចេញអំពីនគរ មួយអន្លើដោយបរិវារច្រើន ត្រាច់ស្វែងរកដល់រាជធានីណា ក៏តាក់តែងរូបស្រីនោះ ដោយគ្រឿងអលង្ការដែលប្រកបដោយសំពត់ និងផ្កា លើកឡើងដាក់វមាស តម្កល់ទុកត្រង់មាត់ផ្លូវ ដែលទៅកាន់កំពង់ទឹក ក្នុងទីដែលមហាជនមកប្រជុំគ្នា ក្នុងពេលល្ងាច ក្នុងរាជធានីនោះ

ចំណែកពួកខ្ញុំ នាំគ្នាគេចទៅឈរក្នុងចំណែកម្ខាង ដើម្បីចាំស្តាប់ពាក្យរបស់មហាជន ដែលមកហើយនឹងមកហើយ ។ ចំណែកមហាជន កាលសម្លឹងមើលរូបស្រីនោះ មិនស្គាល់ថាជារូបមាស ទើបនាំគ្នាសរសើរថា ស្រីនេះសូម្បីជាមនុស្សក៏ស្អាតដល់ម៉្លេះ ប្រៀបដូចស្រីទេពអប្សរ ហេតុអ្វី ទើបមកឈរក្នុងទីនេះ ស្រីនេះមកអំពីណា ស្អាតយ៉ាងនេះ ក្នុងនគររបស់ពួកយើងមិនធ្លាប់មានឡើយ ដូច្នេះហើយ ក៏នាំគ្នាចៀសចេញទៅ ។ ពួកអាមាត្យបានស្តាប់ពាក្យនោះហើយ បានប្រឹក្សាគ្នាថា បើកុមារិកាស្អាតបែបនេះ មានក្នុងនគរនេះសោត ជនទាំងឡាយគប្បីពោលថា ស្រីនេះដូចព្រះរាជធីតាអង្គនោះស្រីនេះ ដូចធីតារបស់អាមាត្យឈ្មោះនោះ ក្នុងនគរនេះ គង់មិនមានស្រីស្អាតដូចរូបនេះពិត ទើបកាន់យករូបស្រីនោះ ទៅកាន់នគរដទៃៗជាបន្តទៀត ។ ពួកអាមាត្យត្រាច់ទៅយ៉ាងនេះ រហូតដល់សាគលនគរ ក្នុងដែនមទ្ទៈ ដោយលំដាប់ ។ ព្រះបាទមទ្ទរាជក្នុងសាគលនគរនោះ មានបុត្រី ៨ អង្គ មានរូបល្អឯក ប្រៀបដូចទេពអប្សរ ព្រះរាជធីតាច្បងព្រះនាមថា បភាវតី ព្រោះមានរស្មីផ្សាយចេញអំពីរាងកាយរបស់ព្រះនាង ដូចគ្នានឹងពន្លឺព្រះអាទិត្យដែលទៀបរះ ។ ក្នុងវេលាយប់ បន្ទប់ដែលមានផ្ទៃប្រមាណ ៤ ហត្ថ មិនចាំបាច់អុជប្រទីបឬគោមឡើយ ។ បរិមាណបន្ទប់ទាំងមូលមានពន្លឺតែមួយដូចគ្នា ។ ព្រះនាងបភាវតីនោះ មានភីលៀងម្នាក់ជាស្រីគម ភីលៀងនោះ លុះឲ្យព្រះនាងបភាវតីសោយស្រេចហើយ ក៏ឲ្យនាងវណ្ណទាសី ៨ នាក់ កាន់ក្អមទឹក ៨ ទៅកាន់កំពង់ទឹកក្នុងពេលល្ងាច ដើម្បីដងទឹក មកស្រពស្រង់ឲ្យព្រះនាង ស្រី

ទាំងនោះ កាលឃើញរូបមាស ដែលតម្កល់ទុកក្បែរផ្លូវដើរទៅកាន់កំពង់ទឹក ក៏យល់ថា ជាព្រះនាងបភាវតី នាំគ្នាក្រាបថា ព្រះនាងនេះ ប្រដៅក្រមែន ព្រះនាងត្រាស់ថា អញនឹងស្រង់ទឹក បញ្ជូនពួកយើងមកដងទឹក បែរជាមកឈរត្រង់ផ្លូវមកកាន់កំពង់ទឹក មុនយើងទៅទៀត ហើយទើបនាំគ្នាពោលថា បពិត្រព្រះនាង នាងធ្វើត្រកូលឲ្យទទួលនូវការខ្មាសមិនសមគួរយ៉ាងក្រៃលែង ដែលព្រះនាងមកឈរក្នុងទីនេះមុនពួកខ្ញុំម្ចាស់ បើស្តេចផែនដីទ្រង់ជ្រាប គង់ធ្វើពួកខ្ញុំឲ្យវិនាសពិត ដូច្នេះហើយ យកដៃទះថ្ពាល់រូបមាសនោះ បាតដៃក៏ហាក់ដូចជាបែក ។ លំដាប់នោះ ទើបដឹងថាជារូបមាស ហើយសើច ទើបចូលទៅរកពួកនាងវណ្ណទាសី ហើយពោលថា ពួកនាងចូរមើលការធ្វើរបស់ខ្ញុំ ខ្ញុំបានវាយដោយស្មានថារូបនេះ ជាព្រះនាងរបស់យើង រូបនេះ មានតម្លៃអ្វីក្នុងសម្នាក់នៃព្រះរាជធីតារបស់យើង បានត្រឹមតែឲ្យដៃរបស់យើង ទទួលនូវការឈឺចាប់តែម្យ៉ាងប៉ុណ្ណោះ ។

សម័យនោះ ពួករាជទូតនាំគ្នាកាន់យករូបមាសនោះ ហើយសួរកីលៀងនោះថា នាងពោលថា ព្រះរាជធីតារបស់យើង ស្អាតជាងរូបនេះ នាងសំដៅដល់នរណា ពួកកីលៀងឆ្លើយថា បុត្រីរបស់ព្រះបាទមទ្ទរាជ ព្រះនាមថា បភាវតី រូបនេះ មិនដល់ចំណែកទី ១៦ របស់ព្រះនាងឡើយ ។ ពួកអាមាត្យទាំងនោះ នាំគ្នាត្រេកអរទៅកាន់ទ្វារព្រះរាជវាំង ឲ្យក្រាបទូលថា ពួករាជទូតរបស់ស្តេចឱក្កាករាជមកគាល់ត្រង់ទ្វារ ។ ព្រះរាជាក្រោកចាកអាសនៈ ប្រថាប់ឈរ ហើយត្រាស់ថា ពួកលោកចូរហៅពួកគេមកចុះ ។ ពួករាជទូតទាំង

នោះចូលទៅហើយថ្វាយបង្គំព្រះរាជា ក្រាបទូលថា បពិត្រមហារាជ ព្រះរាជារបស់ទូលព្រះបង្គំត្រាស់សួរថា ទ្រង់មានសេចក្ដីសុខសប្បាយជាទេឬ ព្រះរាជាទ្រង់ធ្វើសក្ការៈទទួលហើយ ត្រាស់សួរពួកអាមាត្យថា ពួកលោកមកទីនេះដើម្បីអ្វី ។ ពួកអាមាត្យក៏ក្រាបទូលថា ព្រះរាជារបស់ទូលព្រះបង្គំ មានព្រះរាជបុត្ត ព្រះនាមថា កុសកុមារ មានព្រះសូរសៀងដូចរាជសីហ៍ ព្រះរាជាទ្រង់មានបំណងប្រគល់រាជសម្បត្តិឲ្យដល់ព្រះឱរសនោះ ទើបបញ្ជូនពួកទូលបង្គំមកគាល់ទ្រង់ សូមទ្រង់ព្រះរាជទានព្រះនាងបភាវតី បុត្រីរបស់ទ្រង់ដល់ព្រះរាជបុត្តនោះចុះ សូមទ្រង់ទទួលបណ្ណាការដោយរូបមាសនេះចុះ លុះក្រាបទូលស្រេចហើយ ទើបប្រគល់បដិមាមាសនោះដល់ព្រះរាជាអង្គនោះ ។ ព្រះបាទមទ្ទរាជទ្រង់សោមនស្ស ទ្រង់ព្រមទទួលដោយទ្រង់ព្រះតម្រិះថា នឹងមានវិវាហមង្គលជាមួយព្រះរាជាដែលជាធំបែបនេះ ។ លំដាប់នោះ ពួកទូតក៏ក្រាបទូលព្រះរាជាថា បពិត្រព្រះអង្គ ទូលព្រះបង្គំមិនអាចបណ្ដោះបណ្ដោយបានទេ ព្រោះត្រូវប្រញាប់ទៅក្រាបទូលការបានជួបព្រះរាជធីតា ដល់ព្រះរាជាឲ្យទ្រង់ជ្រាប ដើម្បីទ្រង់យាងមកទទួលព្រះនាងទៅ ។ ព្រះបាទមទ្ទរាជអង្គនោះទទួលថា សាធុ ហើយចាត់ចែងសក្ការៈដល់ពួកទូតទាំងនោះ ។ ពួកទូតទាំងនោះ ត្រឡប់ទៅកាន់ក្រុងកុសាវតី ហើយក្រាបទូល រឿងនោះ ដល់ព្រះរាជា និងព្រះទេវីឲ្យទ្រង់ជ្រាប ។ ព្រះរាជាយាងចេញអំពីកុសាវតីនគរមួយអន្លើដោយបរិវារច្រើន ដល់សាគលនគរដោយលំដាប់ ។ ឯព្រះបាទមទ្ទរាជក៏ទ្រង់ធ្វើការទទួលយាងព្រះរាជាចូលទៅកាន់ព្រះនគរ ហើយទ្រង់បាន

ធ្វើមហាសក្ការៈដ៏ធំក្រៃលែង លុះកន្លងទៅ ១ ថ្ងៃ ២ ថ្ងៃ ៣ ថ្ងៃ ព្រះនាងសីលវតីព្រះតម្រិះថា អ្នកណានឹងដឹងថា ព្រះរាជធីតានោះ នឹងទៅជាយ៉ាងណា ព្រោះព្រះនាងជាបណ្ឌិត ទើបក្រាបទូលព្រះបាទមទ្ទរាជថា ខ្ញុំម្ចាស់ប្រាថ្នាចង់ឃើញព្រះសុណិសា ។ ព្រះរាជាត្រាស់ថា សាធុ ហើយត្រាស់ហៅព្រះរាជធីតា បភាវតី មកគាល់ ព្រះរាជធីតា តាក់តែងព្រះកាយ ដោយគ្រឿងអលង្ការសព្វយ៉ាង ចោមរោមដោយកីលៀងនិងស្រីស្នំ យាងចេញមកថ្វាយបង្គំព្រះមាតាក្មេក ។ ព្រះនាងសីលវតីបានទតឃើញព្រះនាងបភាវតី ទើបព្រះតម្រិះថា រាជធីតាអង្គនេះ ជាស្រីមានរូបឆោមលោមពណ៌ល្អពេកណាស់ ឯកូនប្រុសរបស់អញ មានរូបមិនស្អាត បើព្រះរាជធីតាអង្គនេះបានឃើញឱរសរបស់អញ សូម្បីត្រឹមតែមួយថ្ងៃ គង់មិននៅរួមជាដាច់ខាត គង់គេចទៅពិតដូច្នេះ អញត្រូវធ្វើកលឧបាយ ។ ព្រះនាងសីលវតីឲ្យយាងព្រះបាទមទ្ទរាជមកហើយ ក្រាបទូលថា បពិត្រមហារាជ ព្រះសុណិសាសមគួរដល់ឱរសរបស់ខ្ញុំម្ចាស់ តែទំនៀមបន្ទបវេណីនៃវង្សរបស់ខ្ញុំម្ចាស់មាន បើព្រះរាជធីតាអង្គនេះ ប្រព្រឹត្តធ្វើតាមបវេណីនេះបាន ខ្ញុំម្ចាស់នឹងទទួលព្រះរាជធីតាអង្គនេះទុក ។ ព្រះរាជាត្រាស់ថា បវេណីរបស់ព្រះនាងដូចម្តេច ព្រះនាងសីលវតីតបថា បវេណីក្នុងរាជវង្សរបស់ខ្ញុំម្ចាស់មានថា ព្រះជាយានឹងជួបមុខព្រះរាជស្វាមីក្នុងពេលថ្ងៃមិនបាន ទាល់តែតាំងព្រះគភ៌ជាមុនសិន ទើបជួបមុខគ្នាបាន ។ បើព្រះរាជធីតាបភាវតីអង្គនេះ ធ្វើតាមបវេណីនេះបាន ទើបខ្ញុំម្ចាស់ទទួលនាងទុក ព្រះរាជាត្រាស់សួរព្រះរាជធីតាថា នែបុត្រី នាងប្រព្រឹត្តវត្ត

ដូចពោលមកនេះបានដែរឬទេ ព្រះរាជធីតាបភាវតីក្រាបទូលថា បាន ។

លំដាប់នោះ ព្រះបាទឱក្កាករាជ បានថ្វាយព្រះរាជទ្រព្យជាច្រើនដល់ព្រះបាទមទ្ទរាជ ហើយទ្រង់ទទួលព្រះនាងបភាវតីនោះ យាងត្រឡប់ទៅ ។ សូម្បីព្រះបាទមទ្ទរាជ ក៏ទ្រង់បញ្ជូនព្រះរាជធីតាទៅដោយបរិវារធំ ។ ព្រះបាទឱក្កាករាជ ត្រឡប់មកនគរកុសាវតីហើយ មានព្រះរាជឱង្ការឲ្យតាក់តែងព្រះនគរ ដោះលែងអ្នកទោសទាំងអស់ ទ្រង់កំណត់ការអភិសេកព្រះរាជឱរស ទ្រង់ស្ថាបនាព្រះនាងបភាវតីឲ្យជាអគ្គមហេសី ហើយទ្រង់ឲ្យរាជបុរសវាយស្គរប្រកាសថា ឥឡូវនេះ រាជអាណាចក្កជារបស់ព្រះបាទកុសរាជហើយ ។ ព្រះរាជាទាំងឡាយក្នុងជម្ពូទ្វីប ព្រះរាជាអង្គណាមានបុត្រី សូមព្រះរាជាអង្គនោះ បញ្ជូនបុត្រីមកថ្វាយដល់ព្រះបាទកុសរាជ ព្រះរាជាទាំងនោះ ដែលមានព្រះរាជបុត្ត ទ្រង់បំណងភាពជាមិត្តជាមួយព្រះបាទកុសរាជនោះ ទ្រង់បញ្ជូនរាជឱរសរបស់ទ្រង់ទៅជាព្រះរាជឧបដ្ឋាក ។ ព្រះពោធិសត្វទ្រង់មានស្រីស្នំជាបរិវារជាច្រើន ទ្រង់គ្រប់គ្រងរាជសម្បត្តិ ដោយព្រះឥស្សរិយយសធំ ។ ឯព្រះនាងបភាវតី មិនបានឃើញព្រះពោធិសត្វក្នុងពេលថ្ងៃឡើយ សូម្បីព្រះពោធិសត្វ ក៏មិនបានឃើញព្រះនាងក្នុងពេលថ្ងៃដូចគ្នា ។ ព្រះរាជានិងព្រះរាជិនីទាំង ២ អង្គ ឃើញគ្នាតែក្នុងពេលយប់ប៉ុណ្ណោះ សូម្បីរស្មីដែលផ្សាយអំពីព្រះសរីរៈ របស់ព្រះនាងបភាវតីក្នុងពេលយប់នោះ ក៏មិនអាចឲ្យឃើញព្រះភក្ត្រច្បាស់លាស់បាន ព្រះពោធិសត្វទ្រង់ចេញអំពីបន្ទប់ក្នុងពេលរាត្រីប៉ុណ្ណោះ ។ លុះ ២-៣ ថ្ងៃ កន្លងផុតទៅ ព្រះពោធិសត្វអង្គនោះ ក៏ទ្រង់

ប្រាថ្នានឹងឃើញព្រះភក្រ្តរបស់ព្រះនាងបភាវតីក្នុងពេលថ្ងៃ ទើបក្រាបទូលព្រះមាតាឲ្យទ្រង់ជ្រាប ព្រះមាតាក៏ទ្រង់ឃាត់ថា កុំគាប់ចិត្តជួបក្នុងពេលថ្ងៃឡើយ សូមបុត្ររង់ចាំបានព្រះឱរសមួយសិនចុះ ព្រះពោធិសត្វក៏ទ្រង់អង្វររឿយៗ ។ សម័យនោះ ព្រះទេវីមានព្រះតម្រាស់នឹងព្រះពោធិសត្វថា បើយ៉ាងនោះ ចូរបាទៅកាន់រោងដំរីហើយឈរ ដោយភេទនៃអ្នកចិញ្ចឹមដំរី មាតានឹងនាំនាងបភាវតីទៅក្នុងទីនោះ សូមបាមើលនាងឲ្យឆ្អែតឆ្អក កុំឲ្យនាងស្គាល់បាជាដាច់ខាត ព្រះពោធិសត្វទទួលថា សាធុ ហើយបានយាងទៅកាន់រោងដំរី ។ លំដាប់នោះព្រះមាតារបស់មហាសត្វ មានព្រះតម្រាស់ឲ្យតាក់តែងរោងដំរីហើយបបួលនាងបភាវតីថា មកបុត្រី យើងទាំង ២ ទៅមើលដំរីរបស់ព្រះភស្តានាងជាមួយគ្នាចុះ ហើយយាងទៅកាន់រោងដំរីនោះ ។ ព្រះនាងបង្ហាញព្រះនាងបភាវតីថាដំរីនេះមានឈ្មោះយ៉ាងនេះដំរីនេះមានឈ្មោះយ៉ាងនេះដូច្នេះ ។ ព្រះរាជាទតឃើញនាងយាងមកជាមួយព្រះមាតា ទើបចាប់អាចម៍ដំរីមួយដុំគប់ត្រង់ខ្នងព្រះនាង ដោយការបន្លំខ្លួនជាហ្មដំរី ។ ព្រះនាងបភាវតី ពិរោធយ៉ាងខ្លាំង ទើបត្រាស់ថា យើងនឹងឲ្យព្រះរាជាកាត់ដៃរបស់ឯង ហើយទូលព្រះទេវីឲ្យដាក់ទោស ។ ឯព្រះមាតា ទ្រង់លួងលោមយកចិត្តយកថ្លើមថា កុំក្រោធឡើយបុត្រី ហើយព្រះនាងអង្អែលខ្នងឲ្យ ។ ក្រោយមក ព្រះរាជាត្រូវការឃើញព្រះនាងម្តងទៀត ទើបយាងទៅទតព្រះនាងត្រង់រោងសេះដោយការបន្លំខ្លួនជាអ្នកឃ្វាលសេះ ហើយទ្រង់យកអាចម៍សេះគប់ដូចមុនទៀត ក្នុងកាលនោះ ព្រះនាងក៏ក្រោធជាខ្លាំង តែព្រះនាងសីលវតី ក៏លួងលោមដូច

មុនទៀត ។

ក្នុងថ្ងៃមួយ ព្រះនាងបភាវតី ប្រាថ្នាចង់ឃើញព្រះមហាសត្វ ទើបក្រាបទូលដល់មាតាក្មេក តែត្រូវព្រះនាងឃាត់ថា នាងកុំចង់ឃើញឡើយ ដូច្នេះក៏ទូលអង្វររឿយៗ ។ លំដាប់នោះ ព្រះទេវីក៏ត្រាស់នឹងព្រះនាងថា បើដូច្នោះ ស្អែកនេះ កូនប្រុសរបស់យើង នឹងធ្វើប្រទក្សិណព្រះនគរ ចូរនាងបើកសីហបញ្ជរចាំមើលចុះ ។ កាលត្រាស់យ៉ាងនេះហើយ ក្នុងថ្ងៃស្អែកឡើង ទើបមានព្រះតម្រាស់ឲ្យតាក់តែងព្រះនគរ ហើយឲ្យជយម្បតិរាជកុមារទ្រង់គ្រឿងដូចជាក្សត្រ ឲ្យប្រថាប់គង់លើខ្នងដំរី ហើយឲ្យព្រះពោធិសត្វប្រថាប់គង់លើអាសនៈខាងក្រោយ ឲ្យធ្វើប្រទក្សិណព្រះនគរ ហើយនាំព្រះនាងបភាវតី ទៅឈរត្រង់សីហបញ្ជរត្រាស់ថា ចូរនាងមើលសម្រស់ ដ៏លើសនៃសិរីរបស់ស្វាមីនាងចុះ ។ ព្រះនាងបភាវតីសម្គាល់ថា អញបានព្រះស្វាមីមានសភាពសមគ្នាហើយ ដូច្នេះហើយ ក៏មានព្រះហឫទ័យរីករាយក្រៃលែង ។ ក្នុងថ្ងៃនោះ ព្រះមហាសត្វបន្ទំខ្លួនជាហ្មដំរី ប្រថាប់គង់លើអាសនៈខាងក្រោយរបស់ព្រះជយម្បតិរាជកុមារ ក៏បានទតមើលព្រះនាងបភាវតី ពេញតាមបំណងបានសម្តែងអាការក្រមិចក្រមើមតាមពេញព្រះហឫទ័យ ដោយអំណាចការគ្រវីដៃប្លែកៗជាដើម កាលដំរីព្រះទីន័ងទៅផុតហើយ ព្រះរាជមាតាក៏ត្រាស់សួរព្រះនាងបភាវតីថា នាងឃើញកស្តានាងហើយឬ ព្រះនាងទូលថា ឃើញហើយ តែហ្មដំរីអង្គុយលើអាសនៈខាងក្រោយព្រះកស្តានោះ ប្រហែលជាមនុស្សវិន្ទរូស ទូន្មានលំបាកពន់ពេក សម្តែងហត្ថវិការៈប្លែកៗដល់ខ្ញុំម្ចាស់

ព្រោះហេតុអ្វី ទើបឲ្យមនុស្សមិនមានសិរីបែបនោះ ឡើងទៅអង្គុយលើអាសនៈខាងក្រោយស្តេចផែនដីបាន ព្រះទេវីត្រាស់ថា នែកូន ធម្មតាការប្រយ័ត្នប្រយែងនូវភ័យលើអាសនៈខាងក្រោយរបស់ព្រះរាជា បុគ្គលគប្បីប្រាថ្នា ។ ព្រះនាងបភាវតី ក៏ព្រះតម្រិះថា ហ្នដឹរនេះ ប្រហែលជាបាននូវអភ័យពិសេសពន់ពេក មិនធ្លាប់សម្គាល់ព្រះរាជាថាជាព្រះរាជា តិចហោហ្នដឹរនេះ ជាស្តេចកុសរាជទេដឹង ឯព្រះបាទកុសរាជនេះ គង់មានរូប គួរខ្ពើមពន់ពេកដោយពិត ព្រោះហេតុនោះ ទើបមិនបង្ហាញខ្លួនព្រះបាទកុសរាជនោះដល់អញ ។ ព្រះនាងបភាវតី ក៏ខ្សឹបនាងគមថា នែនាង ចូរនាងទៅ ឲ្យដឹងថាព្រះបាទកុសរាជ ប្រថាប់លើអាសនៈខាងមុខ ឬប្រថាប់លើអាសនៈ ខាងក្រោយ ។ ស្រីគមទូលសួរថា ខ្ញុំម្ចាស់នឹងដឹងបានដូចម្តេច ព្រះនាងត្រាស់ថា បើហ្នដឹរនោះជាព្រះរាជាសោត ក៏នឹងចុះអំពីខ្នងដំរីមុន នាងចូរដឹងដោយសញ្ញាយ៉ាងនេះ ។ ស្រីគមបានមកឈរមើល ក្នុងចំណែកម្ខាងហើយ សម្លឹងឃើញព្រះមហាសត្វចុះមកមុន ឃើញជយម្បតិរាជកុមារចុះមកឯក្រោយ ។ ព្រះមហាសត្វក៏ទ្រង់ក្រឡេកមើលឆ្វេងស្តាំ បានឃើញស្រីគម ក៏ជ្រាបថាស្រីគមនេះមកព្រោះហេតុឈ្មោះនេះ ទើបឲ្យហៅនាងមកត្រាស់ផ្តាំផ្តាច់ថា នាងកុំប្រាប់រឿងនេះ ដល់ព្រះនាងបភាវតីឡើយ ក៏បញ្ជូនខ្លួនទៅ ។ ស្រីគមត្រឡប់ទៅ ក៏ក្រាបទូលព្រះនាងបភាវតីថា ព្រះបាទកុសរាជដែលប្រថាប់លើអាសនៈខាងមុខទ្រង់ចុះមុន ។ ព្រះនាងបភាវតីជឿពាក្យរបស់ស្រីគមនោះ ។ ក្នុងថ្ងៃក្រោយមក ព្រះរាជាមានបំណងនឹងទតព្រះនាងបភាវតីទៀត ទើបទូល

អង្វរព្រះរាជមាតាហើយ ។ ព្រះរាជមាតាមិនអាចឃាត់បាន ទើបត្រាស់ថា បើដូច្នោះ ចូរបាំក្លែងខ្លួនកុំឲ្យអ្នកណាស្គាល់ ហើយទៅកាន់ឧទ្យានចុះ ។ ព្រះរាជាយាងទៅកាន់ឧទ្យាន ហើយទ្រង់ឈរត្រាំទឹកក្នុងស្រះបោក្ខរណីប្រមាណត្រឹមព្រះសុរង ទ្រង់យកស្លឹកឈូកបិទបាំងព្រះសិរសា ទ្រង់ឈរយកផ្កាឈូកដែលរីកបាំងព្រះភក្ត្រ ។ ព្រះរាជមាតារបស់ព្រះពោធិសត្វ ក៏នាំព្រះនាងបភាវតីទៅកាន់ព្រះរាជឧទ្យាន ទ្រង់បបួលឲ្យមើលថា ចូរនាងមើលព្រឹក្សាទាំងនេះ ចូរមើលពួកសកុណា ចូរមើលពួកម្រឹគជាដើម ក៏មកដល់មាត់ច្រាំងស្រះបោក្ខរណី ក្នុងវេលាល្ងាច ។

ព្រះនាងបភាវតីនោះ ទតឃើញព្រះបោក្ខរណី ដែលដេរដាសទៅដោយផ្កា ៥ ពណ៌ ព្រះនាងប្រាថ្នានឹងស្រង់ ទើបយាងចុះកាន់ស្រះបោក្ខរណីមួយអន្លើដោយបរិចារិកាទាំងឡាយ ព្រះនាងកាលកំពុងលេង លុះទតឃើញផ្កាឈូក ដែលព្រះពោធិសត្វកំពុងពួននោះ ព្រះនាងចង់បេះ ក៏លាព្រះហស្តចេញទៅ ។ លំដាប់នោះ ព្រះរាជាក៏បើកស្លឹកឈូកចេញ ហើយស្រវាចាប់ព្រះនាងដោយព្រះហស្តបណ្តើរ ប្រាប់បណ្តើរថា យើងគឺកុសរាជ ព្រះនាងគ្រាន់តែទតឃើញព្រះភក្ត្ររបស់ព្រះពោធិសត្វ ក៏ស្រែកឡើងថា យក្ខចាប់ខ្ញុំហើយ ព្រះនាងក៏ដល់នូវវិសញ្ញីភាព គឺសន្លប់ក្នុងទីនោះឯង ។ លំដាប់នោះ ព្រះរាជា ក៏ទ្រង់លែងព្រះហស្តអំពីព្រះនាង ។ លុះព្រះនាងដឹងខ្លួនហើយទើបព្រះនាងត្រិះរិះថា បានឮថា ស្តេចកុសរាជចាប់ដៃយើង ឯយើង ក៏ត្រូវព្រះបាទកុសរាជនេះគប់ដោយអាចម៍ដំរីត្រង់រោងដំរី គប់ដោយអាចម៍សេះ ត្រង់

រោងសេះ ព្រះបាទកុសរាជនេះឯង ប្រថាប់គង់ពីក្រោយ លើខ្នងដំរី បក់ដៃ អញ អញមិនត្រូវការព្រះកស្ដា ដែលមានមុខគួរស្អប់ដល់ម៉្លេះឡើយ អញនឹងលែងព្រះកស្ដានេះ បើអញនៅមានជីវិត ក៏នឹងបានប្ដីដទៃ ដូច្នេះហើយ ទើបហៅពួកអាមាត្យដែលតាមព្រះនាងមក ហើយត្រាស់ថា ពួកលោកចូរត្រៀមយានពាហនៈឲ្យយើង យើងនឹងទៅក្នុងថ្ងៃនេះឯង ។ ពួកអាមាត្យទាំងនោះ ក៏ក្រាបទូលដល់ព្រះរាជាឲ្យទ្រង់ជ្រាប ព្រះរាជាទ្រង់ ព្រះតម្រិះថា បើនាងមិនបានយាងត្រឡប់ បេះដូងរបស់នាងនឹងបែកសញ្ជែកពិត ឲ្យនាងត្រឡប់ទៅសិនចុះ អញនឹងនាំព្រះនាងត្រឡប់មក ដោយកម្លាំងរបស់ខ្លួន លុះទ្រង់ព្រះតម្រិះហើយ បន្ទាប់អំពីនោះ ទើបទ្រង់អនុញ្ញាតឲ្យព្រះនាងបភាវតីនោះ យាងត្រឡប់ទៅ ។ ព្រះនាងក៏យាងដល់នគររបស់ព្រះបិតានាងវិញ ។ ព្រះមហាសត្វក៏ចេញអំពីព្រះរាជឧទ្យាន ទៅកាន់ព្រះនគរ ឡើងកាន់ប្រាសាទដែលប្រដាប់តាក់តែងហើយ ។ ពិតហើយ ព្រះនាងមិនមានសេចក្ដីត្រេកអរជាមួយព្រះពោធិសត្វ ដោយអំណាចព្រះនាងតាំងសេចក្ដីប្រាថ្នាទុកក្នុងកាលមុន ។ ព្រះពោធិសត្វនោះ មានរូបមិនស្អាត ក៏ដោយអំណាចបុព្វកម្មរបស់ទ្រង់ឯង ។

បានឮថា ក្នុងអតីតកាល មានត្រកូលពីរ គឺត្រកូលដែលអាស្រ័យនៅត្រង់វិថីខាងមុខ ១ អាស្រ័យនៅត្រង់វិថីខាងក្រោយ ១ ក្នុងស្រុកដែលតាំងនៅក្បែរទ្វារនគរពារាណសី ។ ត្រកូលមួយមានកូនប្រុស ២ នាក់ ត្រកូលមួយមានកូនស្រីម្នាក់ បណ្ដាកូនប្រុសទាំង ២ នាក់នោះ ព្រះពោធិសត្វជា

ប្អូនប្រុស ។ មាតាបិតាបានសូមកុមារិកានោះ មកឲ្យដល់បងប្រុស ។ ព្រះពោធិសត្វជាប្អូនប្រុស មិនទាន់មានភរិយា ទើបអាស្រ័យនៅក្នុងផ្ទះរបស់បងប្រុស ។ ថ្ងៃមួយ បងថ្លៃស្រីបានចៀននំដែលមានរសជាតិឆ្ងាញ់ក្រៃលែងក្នុងផ្ទះនោះ ។ តែព្រះពោធិសត្វ បានចេញទៅព្រៃ បងថ្លៃស្រី ក៏បានទុកនំមួយចំណែកឲ្យព្រះពោធិសត្វ ចំណែកដ៏សេស ក៏ចែកគ្នាបរិភោគអស់ ។ ក្នុងខណៈនោះ ព្រះបច្ចេកពុទ្ធបានមកដល់ទ្វារផ្ទះដើម្បីភិក្ខា បងថ្លៃរបស់ព្រះពោធិសត្វគិតថា អញនឹងធ្វើនំឲ្យប្អូនថ្លៃជាថ្មី ដូច្នេះហើយ ទើបកាន់យកនំដែលរក្សាទុកឲ្យព្រះពោធិសត្វនោះ ទៅថ្វាយដល់ព្រះបច្ចេកពុទ្ធ ។ ព្រះមហាសត្វនោះក៏ត្រឡប់មកអំពីព្រៃក្នុងខណៈនោះល្មម ។ ពេលនោះ នាងក៏និយាយនឹងព្រះពោធិសត្វថា នែប្អូនប្រុស ចូរប្អូនធ្វើចិត្តឲ្យជ្រះថ្លាចុះ នំដែលជាចំណែករបស់ឯង បងបានប្រគេនដល់ព្រះបច្ចេកពុទ្ធទៅហើយ ។ ព្រះពោធិសត្វនោះក៏ខឹងក្រោធ ពោលថា នាងស៊ីនំដែលជាចំណែករបស់នាងអស់ហើយ មកយកនំដែលជាចំណែករបស់អញទៅប្រគេនភិក្ខុ តើអញនឹងស៊ីអ្វី ទើបរូតរះតាមព្រះបច្ចេកពុទ្ធ យកនំអំពីបាត្រមកវិញ ។ បងថ្លៃស្រីនោះ ក៏ប្រញាប់ទៅផ្ទះរបស់មាតា ហើយនាំយកសប្បិថ្មីៗ និងថ្លាស្អាត មានពណ៌ដូចផ្កាចម្បាមក ហើយដាក់បាត្ររហូតពេញ ថ្វាយព្រះបច្ចេកពុទ្ធជំនួស ។ សប្បិនោះបានផ្សាយរស្មីចេញទៅហើយ ។ នាងបានឃើញរស្មីនោះ ទើបតាំងសេចក្តីប្រាថ្នាថា បពិត្រលោកម្ចាស់ ក្នុងទីដែលខ្ញុំកើតហើយខាងមុខ សូមឲ្យរាងកាយរបស់ខ្ញុំ មានរស្មីចិញ្ចាចចិញ្ចែង មានរូបស្រស់ស្អាតក្រៃលែងចុះ ម្យ៉ាង

ទៀត សូមកុំឲ្យខ្ញុំបាននៅរួមក្នុងទីជាមួយបុគ្គល ដែលជាអសប្បុរសដូចប្អូនថ្លៃប្រុសរបស់ខ្ញុំនេះឡើយ ។ ព្រះនាងបភាវតី មិនបានត្រេកអរពេញចិត្តក្នុងព្រះពោធិសត្វនោះ ក៏ដោយអំណាចសេចក្តីប្រាថ្នា ដែលព្រះនាងតាំងទុកហើយក្នុងកាលមុន ដោយប្រការដូច្នេះ ។ សូម្បីព្រះពោធិសត្វ ក៏ដាក់នំនោះក្នុងបាត្រដែលពេញដោយសប្បិ ហើយតាំងសេចក្តីប្រាថ្នាថា បពិត្រលោកម្ចាស់ បងថ្លៃស្រីខ្ញុំនេះ សូម្បីនៅក្នុងទីឆ្ងាយរាប់រយយោជន៍ក្តី សូមឲ្យខ្ញុំអាចទៅនាំមកធ្វើជាកិរិយារបស់ខ្ញុំបាន ។ ដោយអំណាចនៃបុព្វកម្ម ដែលព្រះពោ-ធិសត្វនោះក្រោធយកនំមកវិញ ព្រះពោធិសត្វ ក៏មានរូបមិនស្អាត គួរស្អប់នោះឯង ។ ឯនាងបភាវតីនោះ ក៏មិនប្រាថ្នាព្រះពោធិសត្វនោះឡើយ ព្រះពោធិសត្វនោះ កាលព្រះនាងបភាវតីយាងទៅហើយ ក៏សោយសោក ។ សូម្បីពួកនាងបរិចារិកាទាំងឡាយ នាំគ្នាបម្រើដោយប្រការផ្សេង ៗ ក៏មិនអាចឲ្យព្រះពោធិសត្វនោះក្រឡេកមើលខ្លួនបាន ។ កាលព្រះរាជាអគ្គនោះ ទ្រង់ព្រាត់អំពីព្រះនាងបភាវតីហើយ ព្រះរាជនិវេសន៍ទាំងអស់របស់ព្រះពោធិសត្វ ក៏ហាក់ដូចជាទទេ ។ ព្រះរាជាទ្រង់កន្ទក់កន្ទេញថា ឥឡូវនេះ នាងគង់ទៅដល់សាគលនគរហើយ លុះស្អែកឡើង ក៏យាងទៅគាល់ព្រះមាតាក្រាបទូលថា បពិត្រព្រះមាតា ខ្ញុំនឹងទៅតាមព្រះនាងបភាវតីមកវិញ សូមព្រះមាតាគ្រប់គ្រងរាជសម្បត្តិផងចុះ ដូច្នេះហើយ ក៏ត្រាស់គាថាទីមួយថា

បពិត្រព្រះមាតា ដែនរបស់ព្រះមាតានេះ ប្រកបដោយទ្រព្យ
ប្រកបដោយយាន ប្រកបដោយគ្រឿងសម្រាប់រាជ្យបរិបូណ៌

ដោយកាមគ្រប់យ៉ាង សូមព្រះមាតា ត្រួតត្រាដែនរបស់
ព្រះមាតានេះចុះ ខ្ញុំនឹងទៅកាន់នគរជាទីនៅរបស់នាងបការតី
ជាទីស្រឡាញ់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សយោគ្គំ** បានដល់ ដល់ព្រមទៅដោយគ្រឿងប្រកបសម្រាប់ដំរីជាដើម ។ បទថា **សកាយុរំ** បានដល់ មានគ្រឿងរាជកកុធភណ្ឌ ៥ យ៉ាងបរិបូណ៌ ។ បទថា **អនុសាស អម្ម** សេចក្តីថា បានឮថា ព្រះរាជាអគ្គនោះ ទ្រង់ព្រះតម្រិះថា ឈ្មោះថា ការប្រគល់រាជសម្បត្តិឲ្យដល់បុរសគ្រប់គ្រងជំនួសខ្លួន ជាការមិនសមគួរ ទើបមិនប្រគល់រាជសម្បត្តិឲ្យដល់ព្រះបិតា ឬព្រះអនុជ កាលទ្រង់ប្រគល់ឲ្យព្រះមាតា ទើបត្រាស់យ៉ាងនេះ ។

ព្រះរាជមាតានោះ ទ្រង់បានស្តាប់រាជតម្រាស់នោះហើយ ទើបត្រាស់ថា នែកូន បើដូច្នោះ ចូរកូនកុំប្រមាទ ព្រោះឈ្មោះថា មាតុគ្រាមមានចិត្តមិនបរិសុទ្ធ ដូច្នេះហើយ ទ្រង់យកភោជនមានរសប្រសើរផ្សេងៗ ដាក់ក្នុងភាជនៈមាសរហូតពេញ ហើយត្រាស់ថា កូនគប្បីបរិភោគភោជននេះក្នុងរវាងផ្លូវ ហើយព្រះនាងបញ្ជូនទៅ ។ ព្រះរាជាអគ្គនោះ ទ្រង់ទទួលភាជនៈនោះហើយ ថ្វាយបង្គំព្រះមាតា ទ្រង់ធ្វើប្រទក្សិណ ៣ ជុំ ហើយក្រាបទូលថា បើទូលបង្គំនៅមានជីវិត គង់បានត្រឡប់មកឃើញព្រះមាតាវិញ ដូច្នេះហើយ ទើបទៅកាន់បន្ទប់ដ៏មានសិរី ទ្រង់សៀតអាវុធ ៥ យ៉ាង កាន់យកកហាបណៈ ១០០០ ដាក់ក្នុងបង្វេច មួយអន្ទើដោយភាជនៈព្រះក្រយាហារ កាន់ពិណ

កោកនទ: ចេញអំពីព្រះនគរ យាងទៅដោយមាគ៌ា ។ ព្រះរាជាទ្រង់មានកម្លាំង ច្រើន មានសម្ទុះរហ័ស រឹងមាំ ទ្រង់យាងទៅបាន ៥០ យោជន៍ ថ្ងៃក៏ត្រង់ សោយព្រះក្រយាហារហើយ ទ្រង់យាងទៅបាន ៥០ យោជន៍ទៀត តែមួយ ថ្ងៃប៉ុណ្ណោះ ទ្រង់យាងបានចម្ងាយ ១០០ យោជន៍ លុះដល់ពេលល្ងាច ទ្រង់ ស្រង់ទឹកហើយ ចូលដល់នគរសាគល ។ កាលទ្រង់ចូលដល់ព្រះនគរប៉ុណ្ណោះ ដោយតេជះនៃព្រះពោធិសត្វ ព្រះនាងបភាវតីផ្ទំលើព្រះសេយ្យាសនៈ មិន បាន ក៏ចុះមកផ្ទំខាងក្រោម ។ ព្រះពោធិសត្វមានព្រះឥន្ទ្រិយហត់នឿយ ទ្រង់ យាងមកតាមផ្លូវ ស្រីម្នាក់ឃើញទ្រង់ ទើបហៅមក ហើយអញ្ជើញឲ្យអង្គុយ យកទឹកលាងជើង រៀបចំទីដេកឲ្យ ។ ព្រះពោធិសត្វនោះ មានព្រះកាយហត់ នឿយ គ្រាន់តែប្រាសខ្នងក៏លក់ទៅ ។ លំដាប់នោះ ស្រីនោះ កាលព្រះពោធិ សត្វផ្ទំលក់ហើយ ក៏រៀបចំភោជនមានរសដ៏ប្រសើរផ្សេងៗ ស្រេចហើយទើប ដាស់ព្រះពោធិសត្វ អញ្ជើញឲ្យបរិភោគអាហារ ព្រះពោធិសត្វទ្រង់ពេញព្រះ ហឫទ័យបានព្រះរាជទានកហាបណៈ ១០០០ និងភាជនៈមាស ដែលដាក់ អាហារដល់ស្រីនោះ ។ ព្រះរាជាទ្រង់ទុកបញ្ចាវុធ ក្នុងផ្ទះរបស់ស្រីនោះឯង ហើយប្រាប់ថា ខ្ញុំមានកន្លែងដែលគួរទៅទៀត ដូច្នេះហើយ ទ្រង់កាន់យក ពិណាទៅកាន់រោងដំរីត្រាស់ថា ចូរអ្នកឲ្យខ្ញុំស្នាក់នៅក្នុងទីនេះមួយថ្ងៃចុះ ខ្ញុំនឹង ច្រៀងឲ្យពួកអ្នកស្តាប់ ដូច្នេះ កាលបានទទួលអនុញ្ញាតពីអ្នកឃ្វាលដំរីហើយ ទើបផ្ទំលក់ក្នុងទីមួយ បានមួយសន្ទុះ រម្ងាប់នូវការហត់នឿយនិងការក្រវល់ ក្រវាយហើយ ក៏ទ្រង់ក្រោកឡើង ស្រាយបង្វេចពិណា ទ្រង់ដេញពិណាច្រៀង

ដោយសំឡេង ( ដ៏ពីរោះ ) ដោយព្រះតម្រិះថា អ្នកសាគលនគរទាំងអស់ចូរស្តាប់សំឡេងពិណនេះ ។

ព្រះនាងបភាវតីផ្ទុំខាងក្រោម លុះបានស្តាប់សំឡេងនោះ ព្រះនាងក៏ដឹងបានថា សំឡេងពិណនេះ មិនមែនសំឡេងពិណរបស់អ្នកដទៃឡើយ ព្រះបាទកុសរាជយាងមកដើម្បីយកអញត្រឡប់ទៅ ដោយឥតសង្ស័យ ។ ព្រះបាទមទ្ទរាជទ្រង់ស្តាប់សំឡេងនោះហើយ ទ្រង់ព្រះតម្រិះថា អ្នកណាដេញពិណពីរោះម៉្លេះ ស្អែកនេះ អញនឹងឲ្យមនុស្សហៅបុគ្គលនោះ មកតាំងទុកឲ្យជាអ្នកតន្ត្រីរបស់យើង ។ ព្រះពោធិសត្វទ្រង់ព្រះតម្រិះថា អញនៅក្នុងទីនេះ មិនអាចឃើញព្រះនាងបភាវតី ទីនេះមិនសមគួរដល់អញឡើយ ទើបយាងចេញទៅអំពីព្រលឹម សោយព្រះក្រយាហារព្រឹកក្នុងផ្ទះរបស់ស្រី ដែលទ្រង់បានសោយហើយ ក្នុងពេលល្ងាចដំបូងនោះឯង ទ្រង់ទុកពិណក្នុងទីនោះហើយទៅកាន់សម្នាក់នាយស្មូនឆ្នាំង របស់ព្រះរាជា ហើយធ្វើខ្លួនជាសិស្សរបស់ស្មូនឆ្នាំងនោះ ត្រឹមតែមួយថ្ងៃប៉ុណ្ណោះ ទ្រង់ក៏ជញ្ជូនដីមករហូតពេញផ្ទះ ហើយប្រាប់ថា លោកអាចារ្យ ខ្ញុំនឹងធ្វើភាជនៈឲ្យ កាលនាយស្មូនឆ្នាំងពោលថា សាធុ ចូរធ្វើចុះ ទើបទ្រង់ដាក់ដុំដីមួយដុំលើក្តារយន្ត ហើយទ្រង់បង្វិលក្តារយន្ត ។ ព្រះពោធិសត្វធ្វើតែម្តងប៉ុណ្ណោះ ក្តារយន្តក៏វិលតាំងអំ-ពីព្រឹកដល់ថ្ងៃត្រង់ ព្រះពោធិសត្វសូនភាជនៈតូចធំបានច្រើនប្រភេទ ច្រើនទំហំ កាលទ្រង់សូនភាជនៈសម្រាប់ព្រះនាងបភាវតី ទ្រង់ធ្វើឲ្យមានក្បាច់ក្បូរជារូបភាពផ្សេងៗ ។ ពិតហើយ ឈ្មោះថា បំណងរបស់ព្រះពោធិសត្វទាំង

ឡាយរមែងសម្រេចបាន ។ ព្រះពោធិសត្វអធិដ្ឋានថា សូមឲ្យព្រះនាងបភាវតី ឃើញរូបទាំងនេះត្រឹមតែមួយអន្លើឯងចុះ ។ ទ្រង់ហាលភាជនៈទាំងអស់ឲ្យស្ងួតហើយ ទ្រង់ដុតស្រេចហើយ តម្រៀបទុករហូតពេញផ្ទះ ។ ស្ទូនធ្នាំងនាំភាជនៈទាំងនោះទៅកាន់រាជត្រកូល ។ ព្រះបាទមទ្ទរាជទតឃើញភាជនៈទាំងនោះហើយ ត្រាស់សួរថា ភាជនៈទាំងនេះ អ្នកណាធ្វើ ស្ទូនធ្នាំងក្រាបទូលថា ទូលបង្គំធ្វើឯង ។ ព្រះរាជាត្រាស់ថា ភាជនៈដែលអ្នកបានធ្វើមកហើយ យើងចាំបានយ៉ាងល្អ អ្នកចូរប្រាប់មកថា ភាជនៈទាំងនេះអ្នកណាធ្វើ ។ ស្ទូនធ្នាំងក្រាបទូលថា កូនសិស្សរបស់ទូលព្រះបង្គំជាអ្នកធ្វើ ។ ព្រះរាជាត្រាស់ថា បុរសនោះ មិនសមគួរជាសិស្សរបស់អ្នក បុរសនោះ ជាអាចារ្យរបស់អ្នក អ្នកចូរសិក្សាសិប្បៈក្នុងសម្នាក់របស់បុរសនោះចុះ ចាប់ពីថ្ងៃនេះទៅ ចូរឲ្យគេធ្វើភាជនៈទាំងឡាយសម្រាប់កូនស្រីរបស់យើងគ្រប់អន្លើ ចូរអ្នកឲ្យទ្រព្យ ១០០០ នេះ ដល់បុរសនោះផង ដូច្នេះហើយ ព្រះរាជទានទ្រព្យ ១០០០ ត្រាស់ថា ចូរនាំភាជនៈតូចៗទាំងនេះ ទៅឲ្យបុត្រីទាំងឡាយរបស់យើង ។

ស្ទូនធ្នាំងនោះ នាំយកភាជនៈទាំងនោះ ទៅកាន់ដំណាក់របស់ព្រះរាជធីតាទាំងនោះហើយ ក្រាបទូលថា ភាជនៈតូចៗនេះទូលព្រះបង្គំសូមថ្វាយសម្រាប់ព្រះនាងលេង ។ ព្រះរាជធីតាទាំងនោះយាងមកហើយ ស្ទូនធ្នាំងក៏បានថ្វាយភាជនៈដែលព្រះមហាសត្វធ្វើ ដើម្បីជាប្រយោជន៍ដល់នាងបភាវតីចំពោះព្រះនាងនោះឯង ។ ព្រះនាងទទួលភាជនៈនោះមកហើយ ទតឃើញរូបរបស់

ព្រះនាង និងរូបរបស់ព្រះមហាសត្វ រូបរបស់ស្រីគមក្នុងភាជនៈនោះ ព្រះនាងក៏ជ្រាបថា ភាជនៈនេះ មិនមែនអ្នកដទៃធ្វើ ព្រះបាទកុសរាជនោះឯង ទ្រង់ជាអ្នកធ្វើ ព្រះនាងតានតឹងក្នុងព្រះហឫទ័យ បោករបស់ទាំងនោះលើផែនដី ហើយត្រាស់ថា យើងមិនត្រូវការដោយរបស់នេះទេ នរណាចង់បានក៏យកទៅចុះ ។ គ្រានោះ ព្រះរាជធីតាដែលជាប្អូនទាំងឡាយរបស់ព្រះនាងជ្រាបថា ព្រះនាងពិរោធក៏នាំគ្នាញញឹមពោលថា ម្ចាស់បងយល់ថា ភាជនៈតូចៗនេះ ព្រះបាទកុសរាជ ជាអ្នកធ្វើទេដឹង ភាជនៈនេះមិនមែនព្រះបាទកុសរាជនោះធ្វើទេ ស្ទូនផ្ទាំងធ្វើទេតើ សូមម្ចាស់បងទទួលយកចុះ ព្រះនាងក៏មិនបានត្រាស់ប្រាប់ដល់រឿងដែលព្រះបាទកុសរាជនោះ ទ្រង់ធ្វើភាជនៈនិងរឿងដែលព្រះបាទកុសរាជនោះយាងមក ដល់ប្អូនស្រីទាំងនោះឡើយ ។ ស្ទូនផ្ទាំងបានឲ្យកហាបណៈ ១០០០ ដល់ព្រះពោធិសត្វ ហើយពោលថា នែបា ព្រះរាជាទ្រង់ពេញចិត្តបានឮថា ចាប់ពីពេលនេះទៅ អ្នកគប្បីធ្វើភាជនៈសម្រាប់ព្រះរាជធីតាគ្រប់ៗអង្គ ខ្ញុំនឹងនាំទៅថ្វាយដល់ព្រះរាជធីតាទាំងនោះឯង ព្រះពោធិសត្វក៏ត្រាស់ថា បពិត្រលោកឪពុក ខ្ញុំមិនធ្វើដើម្បីព្រះរាជធីតាទាំងនោះទេ ។ ព្រះពោធិសត្វទ្រង់ព្រះតម្រិះថា បើអញនៅក្នុងទីនេះ ប្រហែលជាមិនបានឃើញព្រះនាងបភាវតីទេ ទើបឲ្យទ្រព្យ ១០០០ នោះដល់ស្ទូនផ្ទាំងនោះឯង ហើយយាងទៅកាន់សម្នាក់របស់ជាងផែង ដែលជាឧបដ្ឋាករបស់ព្រះរាជា សូមធ្វើជាកូនសិស្សរបស់ជាងផែងនោះ ហើយទ្រង់ធ្វើស្លឹកត្នោតដើម្បីប្រយោជន៍ដល់នាងបភាវតី ហើយរចនារូបផ្សេងៗ គឺរូបស្វេតច្ឆត្រ ទីសម្រាប់ផឹកនិងរូបព្រះនាង

បភាវតីឈរចាប់សំពត់ជាដើម ក្នុងស្ទីកត្នោតនោះ ជាងផែងបានកាន់យកស្ទីកត្នោតនិងរបស់ដទៃទៀត ដែលព្រះពោធិសត្វនោះធ្វើ ហើយនាំទៅកាន់រាជត្រកូល ព្រះរាជាទតឃើញត្រាស់សួរថា របស់ទាំងនេះ អ្នកណាធ្វើ ជាងផែងក្រាបទូលថា បពិត្រព្រះអង្គ ទូលបង្គំធ្វើឯង ព្រះរាជាត្រាស់ថា យើងចាំរបស់ដែលឯងធ្វើបាន ចូរប្រាប់មកចុះថា របស់ទាំងនេះអ្នកណាធ្វើ ជាងផែងក្រាបទូលថា បពិត្រព្រះអង្គ សិស្សរបស់ទូលបង្គំធ្វើ ព្រះរាជាត្រាស់ថា បុរសនោះ មិនមែនជាសិស្ស គេជាអាចារ្យរបស់អ្នក ចូរអ្នកសិក្សាសិប្បៈក្នុងសម្នាក់របស់បុរសនោះ តាំងអំពីថ្ងៃនេះទៅ ចូរឲ្យគេធ្វើរបស់យ៉ាងនេះដល់ធីតារបស់យើង ហើយអ្នកចូរឲ្យទ្រព្យ ១០០០ នេះ ដល់បុរសនោះផងដូច្នេះហើយ ទ្រង់ព្រះរាជទានទ្រព្យ ១០០០ ហើយត្រាស់ថា ចូរអ្នកនាំយកគ្រឿងប្រដាប់ទាំងនេះ ទៅឲ្យដល់ពួកធីតារបស់យើងចុះ ។

សូម្បីជាងផែងនោះ ក៏បានថ្វាយស្ទីកត្នោតដែលព្រះពោធិសត្វធ្វើ ដើម្បីជាប្រយោជន៍ដល់ព្រះនាងបភាវតី ចំពោះតែព្រះនាងប៉ុណ្ណោះ ជនដទៃរមែងមិនឃើញរូបទាំងឡាយក្នុងស្ទីកត្នោតនោះ ឯព្រះនាងបភាវតី លុះបានទតឃើញក៏ជ្រាបថា ព្រះបាទកុសរាជជាអ្នកធ្វើ ព្រះនាងព្រះពិរោធ បោលវត្ថុនោះលើផែនដី ហើយត្រាស់ថា អ្នកណាចង់បានក៏យកទៅចុះ ។ លំដាប់នោះ ព្រះភគិនីទាំងឡាយក៏សើចព្រះនាង ។ ជាងផែងកាន់យកទ្រព្យ ១០០០ ទៅឲ្យព្រះពោធិសត្វ ហើយប្រាប់រឿងនោះឲ្យជ្រាប ព្រះពោធិសត្វនោះព្រះតម្រិះថា ក្នុងទីនេះ មិនមែនជាទីដែលអញគួរនៅឡើយ ទើបប្រគល់

ទ្រព្យ ១០០០ ដល់ជាងផែងនោះ ហើយចូលទៅកាន់សម្នាក់របស់មាលាការ របស់ព្រះរាជា ប្រាប់នូវបំណាង សូមធ្វើជាសិស្ស ទ្រង់ក្រងកម្រងផ្កាប្លែកៗ ច្រើនបែប ច្រើនប្រភេទ ធ្វើជាមកុដផ្កាមួយ ដែលវិចិត្រដោយរូបផ្សេងៗ ដើម្បីជាប្រយោជន៍ដល់ព្រះនាងបភាវតី នាយមាលាការកាន់យកកម្រងផ្កាទាំងអស់នោះ ទៅកាន់រាជត្រកូល ព្រះរាជាទតឃើញ ទើបត្រាស់សួរថា ផ្កាទាំងនេះ អ្នកណាជាអ្នកក្រង នាយមាលាការក្រាបទូលថា ទូលព្រះបង្គំឯងជាអ្នកក្រង ព្រះរាជាត្រាស់ថា ផ្កាដែលអ្នកធ្លាប់ក្រងហើយ យើងចាំបានល្អ ចូរអ្នកប្រាប់មកចុះថា ផ្កាទាំងនេះអ្នកណាក្រង នាយមាលាការក្រាបទូលថា សិស្សរបស់ទូលព្រះបង្គំជាអ្នកក្រង ព្រះរាជាត្រាស់ថា បុរសនោះ មិនគួរជាសិស្សរបស់អ្នកទេ គេគួរជាអាចារ្យរបស់អ្នក ចូរអ្នករៀនសិប្បៈក្នុងសម្នាក់របស់បុរសនោះចុះ ហើយចាប់អំពីថ្ងៃនេះទៅ ចូរឲ្យគេក្រងផ្កាឲ្យធីតារបស់យើងចុះ ចូរអ្នកឲ្យទ្រព្យ ១០០០ នេះដល់បុរសនោះ ដូច្នេះហើយ ទើបព្រះរាជទានទ្រព្យ ១០០០ ត្រាស់ថា ចូរអ្នកនាំផ្កាទាំងនេះ ទៅឲ្យពួកធីតារបស់យើង ។

មាលាការនោះ ក៏បានថ្វាយមកុដផ្កា ដែលព្រះមហាសត្វធ្វើ ដើម្បីជាប្រយោជន៍ដល់ព្រះនាងបភាវតី ចំពោះព្រះហស្តរបស់ព្រះនាងនោះឯង ព្រះនាងគ្រាន់តែឃើញរូបផ្សេងៗ របស់ព្រះនាងនិងរបស់ព្រះរាជា ព្រមទាំងរូបដទៃៗជាច្រើនទៀត ក្នុងមកុដនោះ ក៏ដឹងថា ព្រះបាទកុសរាជជាអ្នកធ្វើ ទើបព្រះពិរោធ ហើយបោកចោលលើផែនដី ពួកកតិនីទាំងឡាយនាំគ្នាសើចចំអកព្រះនាងយ៉ាងនោះឯង ។ នាយមាលាការ ក៏បាននាំទ្រព្យមកឲ្យព្រះពោធិសត្វ ប្រាប់

រឿងនោះឲ្យជ្រាបហើយ ព្រះពោធិសត្វនោះក៏ព្រះតម្រិះថា ទីនេះ ក៏មិនមែនជាទីដែលអញនៅបាន ទើបឲ្យទ្រព្យ ១០០០ ដល់មាលាការនោះ ហើយយាងទៅកាន់សម្នាក់របស់ចុងភៅរបស់ព្រះរាជា សូមផ្ញើខ្លួនជាសិស្ស ។ ក្រោយមក ចុងភៅចម្អិនអាហារដល់ព្រះរាជា បានឲ្យដុំសាច់ជាប់ឆ្អឹងមួយដុំដល់ព្រះពោធិសត្វ ដើម្បីអាំងជាប្រយោជន៍ផ្ទាល់ខ្លួន ព្រះពោធិសត្វ ទ្រង់អាំងសាច់នោះ ឲ្យមានក្លិនក្រអូបឈ្ងុយឈ្ងប់ ផ្សាយទៅពេញព្រះនគរទាំងអស់ ព្រះរាជាទ្រង់ស្រូបស្រង់ក្លិនសាច់នោះ ទើបត្រាស់សួរថា អ្នកអាំងសាច់ចំណែកដទៃរបស់អ្នកទុកក្នុងបន្ទប់ផ្សំគ្រឿងឬ ចុងភៅក្រាបទូលថា មិនមានឡើយ តែទូលព្រះបង្គំ បានឲ្យសាច់ជាប់ឆ្អឹងដល់កូនសិស្សរបស់ទូលព្រះបង្គំដើម្បីអាំងបរិភោគ ក្លិននោះប្រហែលជាក្លិនសាច់នោះឯង ព្រះរាជាទ្រង់ត្រាស់ឲ្យនាំសាច់នោះមក ហើយទ្រង់ដាក់សាច់នោះបន្តិច ត្រង់ចុងព្រះជិវ្ហា ក្នុងខណៈនោះឯង រសនៃដុំសាច់នោះ ក៏ជ្រួតជ្រាបទៅពេញបសាទសម្រាប់ទទួលរសទាំង ៧០០០ ។ ព្រះរាជាទ្រង់ជាប់ចិត្តក្នុងរសតណ្ហា ទើបទ្រង់ព្រះរាជទានទ្រព្យ ១០០០ ដល់ចុងភៅនោះ ហើយត្រាស់ថា ចាប់តាំងអំពីនេះទៅ ចូរអ្នកឲ្យកូនសិស្សរបស់អ្នកចម្អិនព្រះក្រយាហារ ឲ្យដល់ពួកធីតាទាំងឡាយរបស់យើង និងដល់យើងផង ហើយឯងចូរនាំមកឲ្យយើង ចំណែកកូនសិស្សរបស់ឯងនោះ ចូរនាំទៅឲ្យធីតាទាំងឡាយរបស់យើង ។

ចុងភៅទៅប្រាប់ដល់ព្រះពោធិសត្វនោះ ឲ្យជ្រាបហើយ ទើបព្រះពោធិសត្វនោះទ្រង់ព្រះតម្រិះថា ឥឡូវនេះ មនោរថរបស់អញដល់ទីបំផុតហើយ

អញនឹងបានឃើញព្រះនាងបភាវតីក្នុងកាលឥឡូវនេះពិត ទើបទ្រង់សប្បាយព្រះហឫទ័យ ឲ្យទ្រព្យ ១០០០ ដល់ចុងភៅនោះ ។ ស្អែកឡើង ទ្រង់ចាត់ចែងគ្រឿងសោយស្រេចហើយ បញ្ជូនគ្រឿងសោយរបស់ព្រះរាជាទៅ ហើយចំណែកទ្រង់ឯងរែកល្អីដែលជាគ្រឿងសោយរបស់ព្រះរាជធីតា ឡើងទៅកាន់ប្រាសាទដែលជាទីប្រថាប់របស់ព្រះនាងបភាវតី ព្រះនាងបានទតឃើញព្រះពោធិសត្វនោះ ទ្រង់រែកល្អីព្រះក្រយាស្ងោយ យាងឡើងកាន់ប្រាសាទទើបព្រះនាងព្រះតម្រិះថា ព្រះបាទកុសរាជនេះ មកធ្វើការងារដែលពួកទាសៈនិងកម្មករគប្បីធ្វើ ប្រហែលជាមិនសមគួរដល់ទ្រង់ឡើយ បើអញព្រងើយកន្តើយ ២-៣ ថ្ងៃ ព្រះរាជា ក៏មានសេចក្តីសម្គាល់ថា ឥឡូវនេះ ព្រះនាងបភាវតីប្រាថ្នាអញ ក៏នឹងមិនទៅណា សម្លឹងមើលតែអញអញនឹងនៅក្នុងទីនេះឯង ឥឡូវនេះអញនឹងជេរទ្រង់ កុំឲ្យទ្រង់នៅក្នុងទីនេះត្រឹមតែមួយរំពេចឡើយ នឹងឲ្យទ្រង់គេចទៅ ព្រះនាងបើកទ្វារ ទុកពាក់កណ្តាល យកព្រះហស្តម្ខាងកាន់សន្ទះទ្វារ ម្ខាងទៀតដាក់គន្លឹះ ហើយត្រាស់គាថាទី ២ ថា

ព្រះអង្គមានព្រះទ័យមិនត្រង់ នាំយកអម្រែកធំ ( រងទុក្ខ )
ទាំងថ្ងៃទាំងយប់ ទាំងពេលអធ្រាត្រ សូមព្រះអង្គត្រឡប់ទៅ
ក្រុងកុសាវតីវិញឲ្យឆាប់ ខ្ញុំម្ចាស់មិនចង់បានព្រះអង្គដែល
មានរាងរៅអាក្រក់ មកនៅ ( ក្នុងទីនេះ ) ទេ ដូច្នេះ ។

អត្ថនៃគាថានោះ មានអធិប្បាយដូចតទៅនេះ បពិត្រមហារាជ ព្រះអង្គជាអ្នកចម្អិនកត្តាហារ ទ្រង់មិនបានធ្វើការងារនេះ ដោយចិត្តដែលស្មោះត្រង់

ដល់បុគ្គលដែលវាយសីសៈរបស់ទ្រង់ឲ្យបែកបាន តែទ្រង់ រែកនូវអម្រែកធំ មកដើម្បីប្រយោជន៍ដល់ខ្ញុំ ដោយចិត្តមិនស្មោះត្រង់និងសោយទុក្ខធំ ទាំងក្នុងពេលថ្ងៃនិងពេលយប់ ក្នុងកាលដែលជាចំណែកនៃរាត្រី នឹងមានប្រយោជន៍អ្វី ដោយសេចក្តីលំបាក ដែលទ្រង់បានទទួលនោះ សូមទ្រង់ត្រឡប់ទៅកុសាវតី ដែលជានគររបស់ទ្រង់ចុះ សូមទ្រង់ស្តាបនាយក្ខនី ដែលមានមុខមាត់និងទ្រង់ទ្រាយដូចនំអំបែង ដូចគ្នានឹងទ្រង់ ហើយសោយរាជសម្បត្តិចុះ ។ បទថា **ឆិប្ចាមិ ទុព្វណ្ណមហំ វសន្តំ** សេចក្តីថា ចំណែកខ្លួនខ្ញុំ មិនប្រាថ្នាឲ្យទ្រង់ ដែលមានពណ៌សម្បុរអាក្រក់ មានទ្រង់ទ្រាយមិនស្អាតនៅក្នុងទីនេះឡើយ ។

ព្រះពោធិសត្វទ្រង់ត្រេកអរថា អញបានទទួលវាចាអំពីសម្នាក់ព្រះនាងបភាវតីហើយ ក៏ត្រាស់គាថា ៣ ថា

ហៃនាងបភាវតី អញនឹងមិនទៅអំពីទីនេះ កាន់ក្រុងកុសាវតីទេ ព្រោះអញជាប់ចិត្តនឹងវណ្ណរបស់នាង ទើបត្រេកអរក្នុងដំណាក់ជាទីត្រេកអររបស់ព្រះបាទមទ្ទៈ ស៊ូលះបង់ដែន មកត្រេកអរក្នុងការឃើញនាង ។ ហៃនាងបភាវតី អញជាប់ចិត្តនឹងវណ្ណៈរបស់នាង មានសភាពវង្វេង ត្រាច់រង្គាត់ទៅកាន់ផែនដី មិនស្គាល់ទិសថា អញមកអំពីទីណា ហៃនាងមានភ្នែកថ្លាដូចភ្នែកម្រឹគ អញជាមនុស្សវក់ចិត្តក្នុងនាង ហៃនាងមានគ្រឿងសម្មៀករំលេចដោយមាស មានខ្សែក្រវាត់ល្អ ជាវិការៈនៃមាស មានចង្កេះល្អ អញមិនត្រូវការដោយរាជ

សម្បត្តិ ព្រោះតែសេចក្ដីប្រាថ្នាចំពោះនូវនាង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **រមាមិ** បានដល់ ត្រេកអរក្រៃលែង គឺមិនអផ្សុក ។ បទថា **សម្មត្តរូបោ** បានដល់ ជាអ្នកវង្វេងដោយអំណាចកិលេស ។ បទថា **តយិទ្ធិ មត្តោ** សេចក្ដីថា អញជាអ្នកស្រវឹងក្នុងរូបរបស់នាង គឺជាអ្នកស្រវឹងក្នុងសរីរៈសព្វអន្ទើរបស់នាង ។ បទថា **សោវណ្ណចីរវសនេ** បានដល់ ជាអ្នកស្លៀកសំពត់រំលេចដោយមាស ។ បទថា **ឆាហំ រជ្ជេន មត្ថិកោ** សេចក្ដីថា នឹងមានសេចក្ដីត្រូវការដោយរាជសម្បត្តិក៏មិនមែន ។

កាលព្រះពោធិសត្វត្រាស់យ៉ាងនេះហើយ ព្រះនាងព្រះតម្រិះថា អញជេរស្ដីស្ដេចកុសរាជដោយបំណងថា ឲ្យទ្រង់ឈឺចាប់ តែស្ដេចកុសរាជអង្គនេះបែរជាពោលទាក់ទងក្នុងអញទៀត បើទ្រង់ពោលឡើងថា យើងជាស្ដេចកុសរាជ ហើយចូលមកចាប់ដៃអញ អ្នកណានឹងឃាត់ទ្រង់បាន អ្នកណាអាចបានឮពាក្យរបស់អញទាំង ២ នេះបាន ព្រះនាងក៏បិទទ្វារដាក់គន្លឹះ ហើយចូលទៅខាងក្នុង ។ ឯព្រះពោធិសត្វទ្រង់ក៏រែកល្អីព្រះស្ងោយទៅទៀត ចែកកត្ដាហារឲ្យព្រះរាជធីតាទាំងឡាយបានសោយហើយ ព្រះនាងបភាវតី បញ្ជូនស្រីគមទៅដោយព្រះតម្រាស់ថា ចូរនាងទៅនាំយកកត្ត ដែលព្រះបាទកុសរាជចម្អិនហើយមក ។ ស្រីគមនោះ នាំមកហើយ ក្រាបទូលថា សូមព្រះនាងសោយចុះ ព្រះនាងត្រាស់ថា ខ្ញុំមិនបរិភោគកត្តដែលស្ដេចកុសរាជចម្អិនឡើយ ចូរនាងបរិភោគឯងចុះ ចូរនាំយកបន្ទែដែលនាងបានមកហើយ ចាត់ចែងដាំស្ងោនាំមកឲ្យយើងជំនួស ឯរឿងដែលស្ដេចកុសរាជតាមមក នាងកុំប្រាប់ដល់

អ្នកណាឡើយ ។

ចាប់តាំងពីនោះមក ស្រីគមក៏នាំយកព្រះស្ងោយដែលជាចំណែករបស់ព្រះនាងមកបរិភោគឯង នាំយកអាហារដែលជាចំណែកខ្លួនទៅថ្វាយដល់ព្រះនាងជំនួស ។ ចាប់តាំងពីនោះមក ព្រះបាទកុសរាជក៏លែងបានទតឃើញព្រះនាងទៀតហើយ ទើបទ្រង់ព្រះរាជតម្រិះថា ព្រះនាងបភាវតីនៅមានសេចក្ដីស្នេហាក្នុងខ្លួនអញ ឬមិនមានហ្ន៎ អញនឹងពិសោធនាងមើល ។ ព្រះពោធិសត្វ កាលទ្រង់ឲ្យព្រះរាជធីតាគ្រប់អង្គសោយស្រេចហើយ ទើបវែកល្អីព្រះក្រយាចេញមក លុះមកដល់ទ្វារដំណាក់របស់ព្រះនាង ក៏ទ្រង់ធ្វើជាចំពប់ផ្ទៃប្រាសាទដោយព្រះបាទ ទន្ទិចទូវកាជនៈទាំងឡាយ ទ្រង់ថ្ងូរដោយសំឡេងខ្លាំង ធ្វើហាក់ដូចជាសន្ធប់បម្រះនទៀលទៅមក ។ ដោយសំឡេងដែលព្រះពោធិសត្វថ្ងូរនោះ ព្រះនាងក៏បើកទ្វារចេញមក ទតឃើញព្រះពោធិសត្វ ត្រូវជងវែកដែលវែកក្រយាស្ងោយសន្កត់ ព្រះនាងក៏ត្រិះរិះថា ស្ដេចកុសរាជនេះ ជាស្ដេចធំក្នុងជម្ពូទ្វីបទាំងមូល ទ្រង់មកលំបាកទាំងយប់ទាំងថ្ងៃ ព្រោះអាស្រ័យអញ និងព្រោះទ្រង់ជាសុខុមាលជាតិ ទើបត្រូវជងវែកព្រះស្ងោយសន្កត់ហើយដួលចុះ ទ្រង់នៅមានព្រះជន្ម ឬអស់ព្រះជន្មហ្ន៎ ព្រះនាងក៏ចេញអំពីដំណាក់ ឱនមើលព្រះភក្ត្រ ដើម្បីពិនិត្យមើលដង្ហើមត្រង់ព្រះនាសិករបស់ព្រះបាទកុសរាជនោះ ។ ព្រះបាទកុសរាជទ្រង់ប្រមូលព្រះខេឡៈពេញព្រះឱស្ឋហើយព្រួសលើសិរ៍ៈរបស់ព្រះនាង ។ ព្រះនាងទ្រង់ព្រះពិរោធចំពោះព្រះបាទកុសរាជនោះជាខ្លាំង ព្រះនាងជេរ ហើយត្រឡប់ទៅកាន់ព្រះរាជដំ-

ណាក់ ។ បើកទ្វារពាក់កណ្តាលហើយ ប្រថាប់ឈរត្រាស់គាថា ដូច្នេះថា

បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីមិនចម្រើន តែងមានដល់
បុគ្គលដែលប្រាថ្នា បុគ្គលកាលមិនប្រាថ្នា ( ខ្ញុំ ) បពិត្រ
ព្រះរាជាព្រះអង្គមិនជាទីស្រឡាញ់ ចង់បានស្រ្តីជាទីស្រឡាញ់
ដែលមិនមានសេចក្តីប្រាថ្នាដោយកាមទាំងឡាយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អភូតិ** សំដៅដល់ ការមិនចម្រើន ។ ឯព្រះបាទកុសរាជនោះ សូម្បីត្រូវព្រះនាងជេរ ក៏ទ្រង់មិនធ្វើនូវការក្តៅក្រហាយចិត្តឲ្យកើតឡើងឡើយ ព្រោះមានព្រះហឫទ័យប្រតិព័ទ្ធក្នុងព្រះនាង ទើបត្រាស់ព្រះគាថាជាលំដាប់ថា

ជនណា បាននាងជាទីស្រឡាញ់ ទោះមិនមានសេចក្តីប្រាថ្នា
ក្តី មានសេចក្តីប្រាថ្នាក្តី យើងសរសើរនូវការបានរបស់ជន
នុ៎ះ បណ្តាការបាននឹងមិនបាននោះ ឯការមិនបានចាត់ថាជា
របស់លាមក ដូច្នេះ ។

កាលព្រះបាទកុសរាជត្រាស់យ៉ាងនេះក៏ដោយ ព្រះនាងមិនបានកាត់បន្ថយពាក្យសម្តី បែរជាត្រាស់វាចាគ្រោតគ្រាតក្រៃលែងឡើង ព្រោះប្រាថ្នាឲ្យព្រះបាទកុសរាជនោះគេចទៅឲ្យផុត ទើបត្រាស់ព្រះគាថាជាលំដាប់តទៅថា

ព្រះអង្គចង់បានស្រ្តី ដែលគេមិនចង់បានព្រះអង្គ ដូចជាគេ
ជីកខ្ទឹមថ្មដោយដើមកណិកា ឬដូចជាគេទាក់ខ្យល់ដោយ
សំណាញ់ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កណិការស្ស ទារុនា** បានដល់ ឈើកណិការស្ងួត ។ បទថា **ពាឡេសិ** បានដល់ បង់ គឺបង់ខ្យល់ ។

ព្រះរាជា បានស្ដាប់ព្រះតម្រាស់នោះហើយ បានត្រាស់គាថា ៣ ថា

ហៃនាងមានលក្ខណៈទន់ភ្លន់ អញមកអំពីជនបទខាងក្រៅ មិនបានសេចក្ដីស្រួល ( ក្នុងសំណាក់ ) របស់នាង ឈ្មោះថា យកថ្មសង្កត់លើហឫទ័យ ( នៃអញ ) ដោយពិត ។ ព្រះរាជបុត្រី ធ្វើមុខក្រញូវ ហើយសំឡឹងមើលមកអញ ក្នុងវេលាណា អញក៏នៅជានាយពិសេសក្នុងវាំងរបស់ព្រះបាទមទ្ទៈក្នុងវេលានោះ ។ ព្រះរាជបុត្រីញញឹមញញែម ក្រឡេកមើលអញក្នុងវេលាណា អញមិននៅជានាយពិសេសក្នុងវេលានោះទេ អញនឹងជាព្រះបាទកុសៈក្នុងវេលានោះវិញដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មុទុលក្ខណេ** បានដល់ ប្រកបដោយលក្ខណៈទន់ភ្លន់របស់ស្ត្រី ។ បទថា **យោ** គឺ **យោ អហំ** ។ បទថា **តិរោជនបទាគតោ** សេចក្ដីថា តាំងអំពីយើងមកអំពីដែនខាងក្រៅ មកនៅក្នុងវាំងរបស់នាង មិនបានការសរសើរ សូម្បីត្រឹមតែការទទួលឡើយ ទើបយើងយល់យ៉ាងនេះថា នាងប្រហែលជាយកថ្មទៅដាក់ក្នុងហទយៈរបស់នាងដោយពិត ដើម្បីហាមការកើតឡើងនៃសេចក្ដីស្រឡាញ់ក្នុងខ្លួនយើង ។ បទថា **ភ្នកុដីកត្វា** បានដល់ ធ្វើថ្ងាសឲ្យជ្រួញដូចវល្លិដោយសេចក្ដីក្រោធ ។ បទថា

**អានន្ទារិកោ** សេចក្តីថា ព្រះបាទកុសរាជត្រាស់ថា ក្នុងខណៈនោះ យើងក៏នៅតែធ្វើជាអ្នកពិសេស ដូចគ្មានទីងទាសៈ ចម្អិនកត្ត ក្នុងបុរីរបស់ព្រះបាទមទ្ទៈនោះ ។ បទថា **ឧម្មួយមានា** បានដល់ សម្តែងអាការត្រេកអរ គឺញញឹមញញែម ។ បទថា **រាជា ហោមិ** សេចក្តីថា ក្នុងខណៈនោះ ខ្ញុំហាក់ដូចជាព្រះរាជាដែលសោយរាជសម្បត្តិក្នុងនគរកុសាវតី ព្រោះហេតុអ្វី ទើបនាងគ្រោតគ្រាតយ៉ាងនេះ នែនាង តាំងអំពីនេះទៅ ចូរនាងកុំធ្វើបែបនេះទៀតឡើយ ។

ព្រះនាងបានស្តាប់ព្រះតម្រាស់របស់ព្រះបាទកុសរាជនោះហើយ ក៏ព្រះតម្រិះថា ស្តេចកុសរាជនេះ កាន់តែនិយាយធ្ងន់ក្រៃលែងឡើង អញនឹងពោលមុសាវាទ ឲ្យទ្រង់គេចទៅអំពីទីនេះដោយឧបាយ ទើបត្រាស់គាថានេះថា

ប្រសិនបើពាក្យរបស់ហោរពិតមែន ព្រះអង្គមិនត្រូវបានជា
កស្តារបស់ខ្ញុំម្ចាស់ទេ ស៊ូឲ្យគេកាត់ ( ខ្ញុំម្ចាស់ ) ជាប្រាំពីរ
កំណាត់ចុះ ដូច្នេះ ។

អត្ថនៃគាថានោះ មានអធិប្បាយថា បពិត្រមហារាជ ពួកហោរាជាច្រើនកាលត្រូវសួរថា ព្រះបាទកុសរាជ ជាស្វាមីរបស់ខ្ញុំឬ ដូច្នេះ ពួកហោរាទាំងនោះ ក៏ទាយថា បានឮថា អ្នកទាំងឡាយ ចូរកាប់យើងជា ៧ កំណាត់ចុះ ទ្រង់មិនមែនជាស្វាមីរបស់ខ្ញុំដោយពិត ។ ព្រះរាជាបានស្តាប់ពាក្យនោះហើយ កាលទ្រង់ជំទាស់ព្រះនាង ទើបត្រាស់ថា នែព្រះនាង បើខ្ញុំសួរហោរាក្នុងនគររបស់ខ្ញុំ ពួកហោរាទាំងនោះក៏ត្រូវទាយថា ស្វាមីរបស់នាងក្រៅអំពី

កុសរាជ ដែលមានសំឡេងដូចរាជសីហ៍មិនមានឡើយ ខ្ញុំនេះឯងក៏ត្រូវពោល នឹងពួកញាតិមិត្តរបស់ខ្ញុំយ៉ាងនេះដូចគ្នា ដូច្នេះហើយ ទើបត្រាស់បន្តថា

ប្រសិនបើពាក្យរបស់ហោរដទៃ ឬរបស់អញពិតមែន កស្តា
របស់នាងក្រៅអំពីព្រះបាទកុសៈ ដែលមានព្រះសូរស័ព្ទស្មើ
នឹងសំឡេងសីហៈ ក៏មិនមានទេ ដូច្នេះ ។

អត្ថនៃគាថានោះ មានអធិប្បាយថា បើពាក្យរបស់គ្រូទាយដទៃជាការពិត ឈ្មោះថា ស្វាមីរបស់នាងជាមនុស្សដទៃមិនមានឡើយ ព្រះនាងស្តាប់ពាក្យរបស់ព្រះបាទកុសរាជនោះហើយ ព្រះនាងត្រិះរិះថា អញមិនអាចឲ្យស្តេចកុសរាជនេះខ្មាស ឬគេចទៅបានឡើយ ស្តេចកុសរាជនេះ មានប្រយោជន៍អ្វីដល់អញ ទើបព្រះនាងបិទទ្វារ មិនបង្ហាញខ្លួន ។ ព្រះបាទកុសរាជនោះទ្រង់ក៏វែកល្អីព្រះក្រយាចុះមកហើយ តាំងអំពីកាលនោះ ទ្រង់ក៏មិនបានឃើញព្រះនាងទៀត ។ ព្រះរាជាធ្វើនាទីជាអ្នករៀបចំកត្ត លំបាកក្រៃលែង សោយភត្តាហារព្រឹកហើយ ត្រូវពុះឧស លាងភាជនៈជំតូចស្រេចហើយ ទ្រង់ទៅវែកទឹក កាលផ្ទំ ក៏ផ្ទំត្រង់ខាងក្រោយស្នូកទឹក ភ្ញាក់ពីបន្ទំ ក៏ភ្ញាក់អំពីព្រលឹម ទ្រង់ចម្អិនបបរជាដើម វែកទៅថ្វាយព្រះធីតាទាំងឡាយសោយ ទ្រង់សោយសេចក្តីទុក្ខដ៏ខ្លាំងក្លាបែបនេះ ក៏ព្រោះអាស្រ័យតម្រេក ដោយអំណាចការត្រេកអរជាប់ជំពាក់ក្នុងកាមារម្មណ៍ ។ ថ្ងៃមួយ ទ្រង់ទតឃើញស្រីគមដើរមកក្បែររោងចុងភៅ ទើបត្រាស់ហៅមក តែស្រីគមនោះ ក៏មិនអាចមកគាល់ទ្រង់បាន ព្រោះខ្លាចព្រះនាងបភាវតី ទើបប្រញាប់គេចទៅ ។ ព្រះរាជាក៏

ប្រញាប់រត់តាមទៅ ហើយត្រាស់នឹងស្រីគមនោះថា នែនាង ស្រីគមនោះ បែរមកឈរ ហើយសួរថា អ្នកណា ហើយក្រាបទូលថា ខ្ញុំម្ចាស់មិនបានឮសំឡេងរបស់ទ្រង់ ។ លំដាប់នោះ ព្រះបាទកុសរាជ ក៏ត្រាស់នឹងស្រីគមនោះថា នែនាង ម្ចាស់ស្រីរបស់នាង មានចិត្តរឹងត្អឹងពន់ពេក យើងមកក្នុងព្រះរាជវាំងរបស់ពួកនាងអស់កាលមានប្រមាណប៉ុណ្ណេះ មិនបានត្រឹមតែការសាកសួរជំណឺង ដល់ការមិនមានរោគជាដើម រឿងអ្វីនឹងឲ្យទេយ្យធម៌ តែសេចក្ដីនោះ ចូរស្ងេះទុកចុះ តែនាងគួរធ្វើព្រះនាងបភាវតីរបស់យើងឲ្យចិត្តទន់ ហើយឲ្យបានជួបនឹងយើងខ្លះចុះ ។ ស្រីគមទទួលព្រះរាជតម្រាស់ហើយ លំដាប់នោះ ព្រះបាទកុសរាជ ក៏ត្រាស់លួងលោមស្រីគមថា បើនាងអាចឲ្យយើងបានជួបព្រះនាងបភាវតីនោះបាន យើងនឹងធ្វើខ្នងរបស់នាងឲ្យត្រង់ ហើយនឹងឲ្យខ្សែកតម្លៃមួយសែន ដូច្នេះហើយ ទើបត្រាស់គាថា ៥ ថា

នែនាងគម បើនាងបភាវតីមានភ្នែកដូចជាប្រមោយដំរី គប្បីក្រឡេកមើលអញ លុះអញទៅដល់ក្រុងកុសាវតី នឹងឲ្យគេធ្វើគ្រឿងប្រដាប់សម្រាប់ពាក់ក ជាវិការៈនៃមាសត្ថោរដល់នាង ។ នែនាងគម បើនាងបភាវតីមានភ្នែកដូចជាប្រមោយដំរី គប្បីហៅរកអញ លុះអញទៅដល់ក្រុងកុសាវតី នឹងឲ្យគេធ្វើគ្រឿងប្រដាប់សម្រាប់ពាក់ក ជាវិការៈនៃមាសត្ថោរដល់នាង ។ នែនាងគម បើនាងបភាវតី មានភ្នែកដូចជាប្រមោយដំរី គប្បីញញឹមញញែមរកអញ លុះអញទៅដល់

ក្រុងកុសាវតី នឹងឲ្យគេធ្វើគ្រឿងប្រដាប់សម្រាប់ពាក់ក ជាវិការៈនៃមាសឆ្អោរដល់នាង ។ នែនាងគម បើនាងបភាវតី មានភ្នែកដូចជាប្រមោយដំរី គប្បីសើចក្អាកក្អាយរកអញ លុះអញទៅដល់ក្រុងកុសាវតី នឹងឲ្យគេធ្វើគ្រឿងប្រដាប់ សម្រាប់ពាក់កជាវិការៈនៃមាសឆ្អោរដល់នាង ។ នែនាងគម បើនាងបភាវតីមានភ្នែកដូចជាប្រមោយដំរី គប្បីមកប៉ះពាល់អញដោយដៃទាំងឡាយ លុះអញទៅដល់ក្រុងកុសាវតី នឹងឲ្យគេធ្វើគ្រឿងប្រដាប់សម្រាប់ពាក់ក ជាវិការៈនៃមាសឆ្អោរដល់នាង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **នេក្ខំ គីវំ តេ** សេចក្តីថា អញនឹងឲ្យជាងធ្វើករបស់នាងឲ្យពេញដោយមាសទាំងអស់នោះឯង ។ បាលីថា **នេក្ខំ គីវំ តេ ការិស្សាមិ** ដូច្នេះក៏មាន ។ អធិប្បាយថា អញនឹងប្រដាប់គ្រឿងអលង្ការសម្រេចដោយមាសត្រង់ករបស់នាង ។ បទថា **ឱលោកេយ្យ** សេចក្តីថា បើព្រះនាងបភាវតី គប្បីក្រឡេកមើលអញតាមពាក្យរបស់នាង គឺបើអាចឲ្យព្រះនាងសម្លឹងមើលអញបាន ។ ក្នុងបទជាដើមថា គប្បីហៅរកអញ ក៏មានន័យដូចគ្នា ។ ឯក្នុងបទថា **ឧម្ហាយេយ្យ** សេចក្តីថា គប្បីសើចដោយការសើចតិចៗ ។ បទថា **បម្ហាយេយ្យ** សេចក្តីថា គប្បីសើច ដោយសំណើចខ្លាំង ។

ស្រីគមនោះ បានស្តាប់ពាក្យរបស់ព្រះពោធិសត្វនោះហើយ ក៏ក្រាប

ទូលថា បពិត្រព្រះអង្គ សូមទ្រង់យាងត្រឡប់ចុះ ២-៣ ថ្ងៃទៀត ខ្ញុំម្ចាស់នឹងធ្វើព្រះនាងឲ្យនៅក្នុងអំណាចរបស់ព្រះអង្គ សូមទ្រង់ចាំទតតាមសេចក្តីព្យាយាមនៃខ្ញុំម្ចាស់ចុះ ដូច្នេះហើយ ទើបត្រួតត្រាមើលតួនាទីរបស់ខ្លួនស្រេចហើយ ក៏ទៅកាន់ដំណាក់របស់ព្រះនាងបភាវតី ធ្វើជាបោសសម្អាតបន្ទប់ប្រថាប់របស់ព្រះនាង ទុកទីល្មមគ្រវែងបាន មិនឲ្យសេសសល់វត្ថុសូម្បីជុំជីដោយហោចសូម្បីតែស្បែកជើង បោសបន្ទប់ទាំងអស់ ហើយរៀបចំតាំងខ្ពស់ត្រង់ធរណីទ្វារ តម្កល់តាំងទាបមួយដើម្បីនាងបភាវតី ហើយក្រាបទូលថា បពិត្រព្រះនាង សូមព្រះនាងយាងមកចុះ ខ្ញុំម្ចាស់នឹងរកចៃលើសីសៈរបស់ព្រះនាង ហើយយាងឲ្យព្រះនាងប្រថាប់គង់លើតាំងទាបនោះ ដាក់សីសៈរបស់ព្រះនាងទុកក្នុងរវាងភ្លៅរបស់ខ្លួន ចាប់បានពងចៃមួយក៏ទូលថា លើសីសៈរបស់ព្រះនាងមានចៃច្រើនណាស់ ហើយចាប់យកចៃលើក្បាលរបស់ខ្លួន មកដាក់លើព្រះហស្តរបស់ព្រះនាង ហើយទូលដោយពាក្យដែលគួរជាទីស្រឡាញ់ថា សូមព្រះនាងទតចៃលើសីសៈរបស់ព្រះនាងចុះ តើមានប្រមាណប៉ុនណា កាលនឹងពោលគុណរបស់ព្រះមហាសត្វ ក៏ក្រាបទូលថា

ព្រះរាជបុត្រីនេះ មិនបាននូវសេចក្តីស្រួលចិត្តទៅរកព្រះបាទ
កុសៈ ជាបុរសនាយពិសេសអ្នកស៊ីឈ្នួល មិនត្រូវការដោយ
ថ្លៃឈ្នួលទេ ដូច្នេះ ។

អត្ថនៃគាថានោះ មានអធិប្បាយថា ព្រះរាជបុត្រីអង្គនេះ រមែងមិនបាននូវសេចក្តីសុខ សូម្បីមានប្រមាណតិចតួច ដោយកម្រងផ្កា គ្រឿងក្រអូប

គ្រឿងលាប សំពត់និងគ្រឿងប្រដាប់ក្នុងព្រះរាជវាំង របស់ព្រះបាទកុសរាជ ដែលជាកំពូលនៃមហាជន ក្នុងនគរកុសាវតី ក្នុងកាលមុន សូម្បីត្រឹមតែមួយឡើយ សូម្បីវត្ថុត្រឹមតែស្លាម្លូដែលព្រះបាទកុសរាជ ព្រះរាជទានដល់ព្រះនាងក៏គង់មិនធ្លាប់មានឡើយ ។ ព្រោះហេតុអ្វី ព្រោះធម្មតាស្រីទាំងឡាយ តែងមិនអាចទម្លាយហទយៈក្នុងប្តី ដែលដេកសង្កត់អវយវៈក្នុងថ្ងៃមួយបាន ឯព្រះរាជបុត្រីនេះ រមែងមិនធ្វើសូម្បីត្រឹមតែបដិសណ្ឋារៈ ក្នុងបុរសដែលជាភ្នាក់ងារដាំស្ល អ្នកស៊ីឈ្នួល គឺក្នុងបុរសម្នាក់ ដែលជាអ្នកដាំស្ល សេចក្តីថា ជាអ្នកស៊ីឈ្នួលដោយមិនត្រូវការតម្លៃ លះរាជសម្បត្តិមក រមែងសោយទុក្ខយ៉ាងនេះ ព្រោះអាស្រ័យព្រះនាងមួយអង្គប៉ុណ្ណោះ បពិត្រព្រះនាង សូម្បីព្រះនាង មិនស្រឡាញ់ក្នុងស្តេចកុសរាជនោះ ព្រះរាជាដ៏ប្រសើរក្នុងជម្ពូទ្វីបទាំងមូល ទ្រង់ក៏លំបាក ព្រោះអាស្រ័យព្រះនាង ព្រោះដូច្នោះ សូមព្រះនាងព្រះរាជទាន អ្វីតិចតួចដល់ព្រះបាទកុសរាជនោះខ្លះចុះ ។

ព្រះនាងបភាវតី បានស្តាប់ពាក្យនោះហើយ ព្រះនាងពិរោធចំពោះនាងគម ។ លំដាប់នោះ នាងគមក៏ចាប់ព្រះនាងត្រង់កបោះទៅខាងក្នុងបន្ទប់ ឯខ្លួនឈរខាងក្រៅ បិទទ្វារហើយ ទាញខ្សែសម្រាប់ខ្ទាស់ទ្វារមករក្សាទុក ព្រះនាងបភាវតីមិនអាចចាប់ខ្សែនោះបាន ប្រថាប់ឈរក្បែរទ្វារ កាលមិនអាចបើកទ្វារបាន ទើបត្រាស់ព្រះគាថាក្រៅអំពីនេះថា

ស្ត្រីគមនេះ មិនហ៊ានកាត់អណ្តាតដោយកាំបិតដ៏មុត ដោយ
ពិត តែហ៊ាននិយាយពាក្យជាទុក្ខាសិតយ៉ាងនេះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សុធិសិតេន** បានដល់ ដោយកាំបិតដ៏មុត ដែលសំលៀងទុកហើយយ៉ាងល្អ ។ បទថា **ឃរំ ទុព្ភាសិតំ** សេចក្ដីថា នាង ខុជ្ជានេះមកពោលនូវពាក្យដែលជាទុព្ភាសិតមិនសមគួរ ដែលបុគ្គលណាមួយ គប្បីស្ដាប់ បានយ៉ាងនេះ ។

លំដាប់នោះ ស្រីគមនៅតែកាន់ខ្សែស្រម្រាប់ទាក់គន្ទឹះនោះឯង ទូលថា បពិត្រព្រះនាងខ្វះបុណ្យ ជាអ្នកប្រដៅក្រ រូបរបស់នាងនឹងធ្វើអ្វីបាន យើង ទាំងឡាយ នឹងបរិភោគរូបរបស់នាងចិញ្ចឹមជីវិតបានឬ កាលប្រកាសគុណ របស់ព្រះពោធិសត្វ ទើបពោលគាថា ១៣ ដែលមានឈ្មោះថា ខុជ្ជាគជ្ជិត ( ការគ្រហឹមរបស់ស្រីគម ) ថា

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈ
នោះ ដោយរូប ដោយកំពស់ ( នឹងទំហំរបស់ខ្លួននាង )
ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រៃ ព្រះនាងសូមធ្វើទុក
( ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ ) មានយសធំហើយ
ធ្វើនូវសេចក្ដីស្រឡាញ់ ( ចំពោះព្រះបាទកុសៈនោះ ) ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹម នូវព្រះបាទ
កុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាង
ស្រស់ប៉ប្រៃ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទ
កុសៈនោះ ) មានទ្រព្យច្រើន ហើយធ្វើនូវសេចក្ដីស្រឡាញ់
ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹម នូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រែ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ ) មានកម្លាំងច្រើន ហើយធ្វើនូវសេចក្ដីស្រឡាញ់ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹម នូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រែ ព្រះនាងសូមធ្វើទុក ( ក្នុងឫហទ័យថា ព្រះបាទកុសៈនោះ ) មានដែនធំ ហើយធ្វើនូវសេចក្ដីស្រឡាញ់ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹម នូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រែ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ ) ជាព្រះរាជាធំ ហើយធ្វើនូវសេចក្ដីស្រឡាញ់ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹម នូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រែ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ ) មានសំឡេងស្មើនឹងសំឡេងនៃសីហៈ ហើយធ្វើនូវសេចក្ដីស្រឡាញ់ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹម នូវព្រះបាទ

កុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាង ស្រស់ប៉ប្រៃ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ ) មានសំឡេងដ៏ពីរោះ ហើយធ្វើនូវសេចក្ដីស្រឡាញ់ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹម នូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាង ស្រស់ប៉ប្រៃ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ ) មានសំឡេងមូល ហើយធ្វើនូវសេចក្ដីស្រឡាញ់ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹម នូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាង ស្រស់ប៉ប្រៃ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ ) មានសំឡេងល្អ ហើយធ្វើនូវសេចក្ដីស្រឡាញ់ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹម នូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាង ស្រស់ប៉ប្រៃ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ ) មានសំឡេងដ៏ផ្អែមល្ហែម ហើយធ្វើនូវសេចក្ដីស្រឡាញ់ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹម នូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រែ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ ) មានសិល្បៈច្រើន ហើយធ្វើនូវសេចក្ដីស្រឡាញ់ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹម នូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រែ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ ) ជាក្សត្រិយ៍ ( សុទ្ធ ) ហើយធ្វើនូវសេចក្ដីស្រឡាញ់ចុះ ។

បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹម នូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រែ ព្រះនាងសូមធ្វើទុក ( ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ ) ជាព្រះរាជា មាននាមស្មើនឹងស្បូវក្លាំង ( ដែលព្រះឥន្ទប្រទាន ) ហើយធ្វើនូវសេចក្ដីស្រឡាញ់ចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មា នំ រូបេន ចាមេសិ អាកោហេន បភាវតី** សេចក្ដីថា នែព្រះនាងបភាវតី នាងកុំប្រៀបធៀបស្ដេចកុសរាជ ដែលជាធំនៃជនដោយរូបសម្រស់របស់ខ្លួនយ៉ាងនេះ គឺសូមកាន់យកប្រមាណយ៉ាងនេះ ។ បទថា **មហាយសោ** សេចក្ដីថា សូមធ្វើទុកក្នុងព្រះហឫទ័យយ៉ាងនេះថា

ព្រះបាទកុសរាជអង្គនោះ ទ្រង់មានអានុភាពច្រើន ។ បទថា **រុចិរេ** បានដល់ ក្នុងការឃើញវត្ថុដែលជាទីស្រឡាញ់ ។ បទថា **ករស្សុ** សេចក្តីថា នាងគម ពោលថា សូមព្រះនាងធ្វើខ្លួនឲ្យជាទីស្រឡាញ់ ដល់ព្រះបាទកុសរាជនោះ ។ ក្នុងសេចក្តីទាំងអស់ ក៏មានន័យដូចគ្នានោះឯង ។ ម្យ៉ាងទៀត បទថា **មហា-យសោ** បានដល់ មានបរិវារច្រើន ។ បទថា **មហទ្ធនោ** បានដល់ មាន ភោគៈច្រើន ។ បទថា **មហព្វលោ** បានដល់ មានកម្លាំងច្រើន ។ បទថា **មហារដ្ឋោ** បានដល់ មានដែនដ៏ធំទូលាយ ។ បទថា **មហារាជា** បានដល់ ជាព្រះរាជាធំក្នុងជម្ពូទ្វីបទាំងមូល ។ បទថា **សីហស្សរោ** បានដល់ មានសំឡេង ដូចរាជសីហ៍ ។ បទថា **វគ្គុស្សរោ** បានដល់ មានសំឡេងប្រកបដោយ លីលា ។ បទថា **ពិន្ទុស្សរោ** បានដល់ មានសំឡេងមូល មិនបែក ។ បទ ថា **មញ្ជុស្សរោ** បានដល់ មានសំឡេងល្អ ។ បទថា **មធុរស្សរោ** បានដល់ មានសំឡេងប្រកបដោយភាពផ្អែម ។ បទថា **សតសិប្បោ** បានដល់ ទ្រង់ មានសិប្បៈរាប់រយយ៉ាង ដែលមិនបាច់សិក្សាក្នុងសម្នាក់ជនដទៃ សម្រេច ឡើងឯង ដោយកម្លាំងសមត្ថភាពរបស់ទ្រង់ឯង ។ បទថា **ខត្តិយោ** បានដល់ ជាក្សត្របរិសុទ្ធ មិនលាយឡំ កើតហើយក្នុងវង្សនៃព្រះបាទឱក្កាករាជ ។ បទថា **កុសរាជា** បានដល់ ទ្រង់ជាស្តេច មានឈ្មោះស្មើដោយស្បូវក្លាំង ដែលសក្កទេវរាជប្រទាន ។ ពិតហើយ ស្រីគមពោល ពណ៌នាគុណរបស់ព្រះ បាទកុសរាជនោះដោយគាថាទាំងឡាយមានប្រមាណប៉ុណ្ណេះថា សូមព្រះនាង ដឹងចុះថា ព្រះរាជាអង្គដទៃ ដែលមានសភាពបែបនេះ មិនមានទេ ដូច្នេះ

ហើយ សូមធ្វើសេចក្ដីស្រឡាញ់ដល់ព្រះបាទកុសរាជនេះ ។

ព្រះនាងបភាវតីបានស្ដាប់ពាក្យរបស់ស្រីគមនោះហើយ ទើបសម្ដុតស្រីគមថា នែមេគម ហាងសម្ដុតអញពេកហើយ អញចាប់នាងបាន នឹងឲ្យដឹងភាពដែលនាងមានម្ចាស់ ។ ស្រីគមនោះសម្ដុតព្រះនាងហើយ ដោយសំឡេងខ្លាំងថា ខ្ញុំម្ចាស់រក្សាព្រះនាង មិនបានក្រាបទូលថា ព្រះបាទកុសរាជយាងមក ដល់ព្រះរាជបិតារបស់ព្រះនាង ណ្ហើយចុះ បើដូច្នោះ ក្នុងថ្ងៃនេះ ខ្ញុំម្ចាស់នឹងក្រាបទូលឲ្យព្រះរាជាទ្រង់ជ្រាប ។ ព្រះនាងព្រះតម្រិះថា អ្នកដទៃកុំបីដឹងរឿងនេះឡើយ ទើបចុះចាញ់ស្រីគម ។

លំដាប់នោះ ព្រះពោធិសត្វ កាលមិនបានឃើញព្រះនាង ទ្រង់លំបាកដោយព្រះក្រយាហារដែលមិនល្អ ដោយការផ្ទុំដ៏លំបាកអស់ ៧ ខែ ទើបត្រិះរិះថា ស្រីគមនឹងមានប្រយោជន៍អ្វីដល់អញ អញនៅទីនេះអស់ ៧ ខែហើយ មិនបានឃើញព្រះនាងឡើយ ស្រីគមនេះប្រហែលជាអាក្រក់ពន់ពេក អញនឹងទៅសួរសុខទុក្ខព្រះរាជមាតាបិតាចុះ ។ ក្នុងខណៈនោះ សក្កទេវរាជទ្រង់ពិចារណា ក៏ទ្រង់ជ្រាបថា ព្រះពោធិសត្វនឿយណាយក្នុងព្រះហឫទ័យ ទើបទ្រង់ព្រះតម្រិះថា ព្រះរាជាមិនបានឃើញព្រះនាងបភាវតីអស់ ៧ ខែ អញនឹងធ្វើឲ្យព្រះរាជាសមតាមព្រះបំណង ទើបទ្រង់និម្មិតបុរសទាំងឡាយឲ្យធ្វើជាទូតរបស់ព្រះបាទមទ្ទរាជ បញ្ជូនទៅកាន់ព្រះរាជា ៧ នគរ ទ្រង់បញ្ជូនព្រះរាជសាសន៍ដល់ព្រះរាជាមួយអង្គៗថា ព្រះនាងបភាវតី លះបង់ព្រះបាទកុសរាជត្រឡប់មកហើយ បើទ្រង់មានព្រះបំណង ក៏ចូរយាងមក

ទទួលយកព្រះនាងបភាវតីទៅចុះ ។ ព្រះរាជាទាំង ៧ នគរនោះ ក៏នាំគ្នាមក មួយអន្ទើដោយបរិវារធំ ដល់សាគលនគរ មិនបានដឹងដល់ហេតុដែលមករបស់គ្នានឹងគ្នា ព្រះរាជាទាំងនោះក៏ត្រាស់សួរគ្នាថា ទ្រង់យាងមកធ្វើអ្វីកាលទ្រង់ដឹងរឿងនោះ ក៏ទ្រង់ព្រះពិរោធនឹងស្ដេចមទ្ទរាជអង្គនោះ ក៏ត្រាស់ទាំងអស់អង្គថា បានឮថា ព្រះបាទមទ្ទរាជលើកកូនស្រីតែមួយឲ្យដល់ព្រះរាជា ៧ នគរ អ្នកទាំងឡាយ ចូរមើលការប្រព្រឹត្តមិនសមគួររបស់ព្រះរាជានេះទ្រង់មកលលេងជាមួយពួកយើង យើងនឹងនាំគ្នាចាប់ព្រះរាជាឲ្យបាន ដូច្នេះហើយ ស្ដេចគ្រប់អង្គ ក៏បញ្ជូនរាជសាសន៍ទៅថា ព្រះបាទមទ្ទរាជចូរឲ្យព្រះនាងបភាវតីដល់ពួកយើង ឬច្បាំង ហើយលើកពលព័ទ្ធព្រះនគរ ។ ព្រះបាទមទ្ទរាជទ្រង់ស្ដាប់ព្រះរាជសាសន៍ ក៏ភិតភ័យ មានកាយញាប់ញ័រ ទើបហៅអាមាត្យទាំងឡាយមកត្រាស់សួរថា យើងធ្វើនឹងដូចម្ដេចល្អហ្ន៎ ។ លំដាប់នោះ អាមាត្យទាំងឡាយក៏ក្រាបទូលថា បពិត្រព្រះអង្គ ព្រះរាជាទាំង ៧ អង្គយាងមក ព្រោះអាស្រ័យព្រះនាងបភាវតី ស្ដេចទាំងអស់ត្រាស់ថា បើស្ដេចមទ្ទរាជមិនឲ្យព្រះនាង ពួកយើងនឹងទម្លាយកំពែងនគរចូលមកកាន់ព្រះនគរ នឹងញ៉ាំងព្រះបាទមទ្ទរាជនោះ ឲ្យដល់នូវការអស់ជីវិត ហើយនឹងនាំយកព្រះនាងបភាវតីនោះទៅ ដូច្នោះ កាលកំពែងមិនទាន់បាក់នោះឯង ពួកយើងគួរប្រញាប់បញ្ជូនព្រះនាងបភាវតីទៅឲ្យក្សត្រទាំងនោះជាមុន ដូច្នេះហើយ ទើបក្រាបទូលគាថានេះថា

ព្រះរាជាដ៏ប្រសើរទាំងអស់នុ៎ះ ជាព្រះរាជាគឃ្លើន មកហើយ

ប្រដាប់ដោយគ្រឿងក្រោះ ( សូមព្រះអង្គផ្ញើព្រះរាជសារទៅ ថា ) អ្នកទាំងឡាយ ចូរនាំព្រះនាងបភាវតីនុ៎ះមក ( បញ្ជូន ទៅថ្វាយព្រះរាជាទាំងនោះ ) កុំឲ្យទម្លាយកំពែងមុនទាន់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧបន្តទ្ធា** បានដល់ ជាសត្វរឹងត្អឹងក្រៃលែង[១] ។ បទថា **អានេន្តតំ បភាវតិ** សេចក្តីថា បពិត្រមហារាជ សូមទ្រង់បញ្ជូន ព្រះរាជសាសន៍ទៅថា សូមទ្រង់ទទួលព្រះនាងបភាវតីនេះទៅចុះ ព្រោះដូច្នោះ សូមទ្រង់ប្រញាប់បញ្ជូនព្រះនាងបភាវតីទៅថ្វាយព្រះរាជាទាំងនោះជាមុន ទាន់ ដំរីទាំងនោះ មិនទាន់ទម្លាយនគរចូលមក ។

ព្រះរាជាទ្រង់ស្តាប់ពាក្យនោះហើយ ទើបត្រាស់ថា បើយើងបញ្ជូន បភាវតីទៅឲ្យដល់ស្តេចមួយអង្គ ស្តេចដ៏សេសនឹងធ្វើសង្គ្រាម យើងមិនអាច ឲ្យដល់ស្តេចតែមួយអង្គបាន ឯនាងបភាវតីនេះ បោះបង់ព្រះរាជាដ៏ប្រសើរក្នុង ជម្ពូទ្វីបមកហើយដោយរង្កៀសថា ជាស្តេចមានរូបអាក្រក់ គួរខ្ពើម ឥឡូវនេះ ចូរទទួលផលនៃការត្រឡប់មកនោះចុះ អញនឹងសម្លាប់នាង ហើយកាត់ជា ៧ កំណាត់ បញ្ជូនទៅឲ្យព្រះរាជា ៧ អង្គ ដូច្នេះហើយ ទើបត្រាស់ព្រះគាថា ជាលំដាប់ថា

អញនឹងធ្វើនាងបភាវតីនុ៎ះឲ្យជា ៧ កំណាត់ ហើយឲ្យដល់

---

១-បាលីថា នាគា បិដកខ្មែរប្រែថា ព្រះរាជាដ៏ប្រសើរ តែក្នុងអដ្ឋកថា បទថា នាគា នេះ លោកប្រែថា ដំរី ទើបបទថា ឧបត្ថទ្ធា នេះ លោកពន្យល់ថា ជាសត្វរឹងត្អឹងក្រៃលែង ។

ពួកក្សត្រដែលមកក្នុងទីនេះ ដើម្បីសម្លាប់អញ ដូច្នេះ ។

ពាក្យរបស់ព្រះបាទមទ្ទរាជនោះ បានប្រាកដពេញព្រះរាជនិវេសន៍ទាំងមូល នាងបរិចារិកាទាំងឡាយ ក៏ចូលទៅទូលដល់ព្រះនាងបភាវតីថា បានឮថា ព្រះរាជាទ្រង់នឹងកាត់ព្រះនាងជា ៧ កំណាត់ ហើយបញ្ជូនទៅឲ្យព្រះរាជា ៧ នគរ ព្រះនាងស្តាប់ពាក្យនោះហើយ ខ្លាចចំពោះមរណភ័យ ក្រោកចាកទីប្រថាប់ មានព្រះភគិនីទាំងឡាយចោមរោមហើយ យាងទៅកាន់ ដំណាក់របស់ព្រះមាតា ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

ព្រះរាជបុត្រីមានសម្បុរលឿង ទ្រង់ព្រះពស្ត្រជាវិការៈនៃ
សូត្រ ( រំលេចដោយមាស ) ដែលពួកទាសីហែហម មាន
នេត្រាដ៏ពេញដោយព្រះអស្សុជល បានក្រោក ( ចាកអាសនៈ )
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សាមា** បានដល់ មានពណ៌សម្បុរដូចមាស ។ បទថា **កោសេយ្យវាសិនី** បានដល់ ស្លៀកសំពត់សូត្រដែលរំលេចដោយមាស ។ ព្រះនាងយាងទៅគាល់ព្រះមាតា ហើយថ្វាយបង្គំព្រះមាតា ព្រះនាងទ្រង់ព្រះកន្សែងក្រាបទូលថា

បពិត្រព្រះមាតា មុខ ( របស់ខ្ញុំ ) នោះ ធ្លាប់លាបស្រឡាប
គ្រឿងលម្អិត ឆ្នុះកញ្ចក់មានក្របជាវិការៈនៃភ្លុក ជាមុខល្អ
មានភ្នែកល្អ រលើងរាបធេង ត្រូវពួកក្សត្រលះចោលហើយ

នឹងតាំងនៅក្នុងព្រៃ ។ ពួកត្មាត នឹងលើកជើងទាំងឡាយ កកាយនូវសក់ទាំងនោះរបស់ខ្ញុំ ជាសក់ខ្មៅ មានចុងងទន់ លាបដោយខ្លឹមចន្ទន៍ ឲ្យប្រឡូកប្រឡល់ ក្នុងកណ្តាលព្រៃស្មសាន ក្អែកចឹកដៃរបស់ខ្ញុំនោះ ដែលមានក្រចកក្រហម មានរោមល្អទន់ លាបដោយខ្លឹមចន្ទន៍ ដាច់ខ្ចាត់ខ្ចាយ ដែលពួកក្សត្រចោលក្នុងព្រៃ ហើយហើរទៅតាមប្រាថ្នា ។ ចចក ( ឃើញស្តនរបស់ខ្ញុំ ) នោះ ប្រដៀងគ្នានឹងផ្លែត្នោត មិនយារ លាបដោយខ្លឹមចន្ទន៍ដ៏ល្អិត ហើយបៀមនូវស្តនរបស់ខ្ញុំនោះ ដូចជាកូនខ្ចីបង្កើតដែលបៀមនូវស្តនរបស់មាតា ហ្វូងចចកជញ្ជែងត្រគាក ( របស់ខ្ញុំ ) នោះ ជាអវយវៈទូលាយ ដែលគេជំល្អហើយ ពាក់ដោយខ្សែក្រវាត់មាសទាំងឡាយ ដាច់ខ្ចាត់ខ្ចាយ ដែលពួកក្សត្រចោលក្នុងព្រៃ ។ ពួកឆ្កែ ក្អែក ចចកនឹងសត្វឯទៀតដែលមានចង្កូម ស៊ីនាងបភាវតី មុខជានឹងមិនចាស់ គ្រាំគ្រាដោយពិត ។ ប្រសិនបើពួកក្សត្រដែលទៅឆ្ងាយ នាំយកសាច់ទាំងឡាយ ( របស់ខ្ញុំ ) ទៅ បពិត្រព្រះមាតា ចូរព្រះអង្គ សូមយកឆ្អឹងទាំងឡាយ ហើយដុតឆ្អឹងនោះក្នុងទីបន្ទាប់ផ្លូវ ( ក្នុងចន្លោះនៃផ្លូវដើរនឹងផ្លូវធំ ) ។ បពិត្រព្រះមាតា សូមព្រះមាតា ប្រើគេធ្វើសួនច្បារ ហើយដាំដើមកណិការ ក្នុងសួនច្បារនុ៎ះ ក្នុងវេលាណាដែលដើម

កណិការទាំងនោះមានផ្កា ក្នុងអំណឹះទៅនៃកាលជាទីជ្រាក់នៃ
ទឹកសន្សើមក្នុងហេមន្តរដូវ បពិត្រព្រះមាតា សូមព្រះមាតា
ត្រាកខ្ញុំថា នាងបការតីមានវណ្ណៈយ៉ាងនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កក្កូបនិសេវិតំ** សេចក្តីថា លាបហើយដោយម្សៅសម្រាប់លាបមុខ ៥ យ៉ាង គឺសាសបកក្កៈ ម្សៅដែលធ្វើដោយគ្រាប់ស្ពៃ ១ លោណកក្កៈ ម្សៅដែលធ្វើដោយអំបិល ១ មត្តិកកក្កៈ ម្សៅដែលធ្វើដោយដី ១ តិលកក្កៈ ម្សៅដែលធ្វើគ្រាប់ល្ង ១ ហលិទ្ទកក្កៈ ម្សៅដែលធ្វើដោយរមៀត ១ ។ បទថា **អាធាសទន្តាថរុបច្ចវេក្ខិតំ** បានដល់ ឆ្លុះហើយដោយកញ្ចក់ មានដងធ្វើដោយភ្លុក គឺសម្លឹងមើលកញ្ចក់នោះហើយតែងខ្លួន ។ បទថា **សុភំ** បានដល់ មានផ្ទៃមុខស្អាត ។ បទថា **វិរជំ** បានដល់ ប្រាសចាកលម្អងធូលី គឺអស់មន្ទិលជាគ្រឿងសៅហ្មង ។ បទថា **អង្គណាំ** បានដល់ វៀរចាកទោស មានបូសនិងមុនជាដើម ។ បទថា **ឆុឌ្ឌំ** សេចក្តីថា បពិត្រព្រះមាតា ផ្ទៃមុខរបស់ខ្ញុំស្អាតយ៉ាងនេះ នឹងត្រូវពួកស្តេចទាំងឡាយ បោះបោលក្នុងកាលឥឡូវនេះពិត ។ បទថា **វនេ** បានដល់ ក្នុងដងព្រៃ ។ ព្រះនាងកន្ទក់កន្ទេញថា មុខរបស់ខ្ញុំ នឹងត្រូវគេបោះបោលក្នុងព្រៃ ។ បទថា **អសិតេ** បានដល់ ខ្មៅរលោង ។ បទថា **វេល្លិតគ្គេ** បានដល់ មានចុងងំឡើងខាងលើ ។ បទថា **សីវថិកាយ** បានដល់ ក្នុងព្រៃស្មសាន ។ បទថា **បរិកឌ្ឍយន្តិ** សេចក្តីថា ពួកត្មាតទាំងឡាយ ដែលចូលចិត្តទំពាស៊ីសាច់មនុស្ស ក៏នឹងយកជើងទាំង ២ កកាយសក់របស់ខ្ញុំ ដែល

*ស្អាតយ៉ាងនេះ ។ បទថា* **គយ្ហ ធង្កោ គច្ឆតិ យេន កាមំ** *សេចក្ដីថា បពិត្រព្រះមាតា បក្សីឈ្មោះថា ធង្កៈ ( ក្អែក ) នឹងឆាបយកដើមដៃរបស់ខ្ញុំដែលល្អយ៉ាងនេះ ទៅចឹកស៊ី ហើយនឹងហើរទៅតាមប្រាថ្នា ។ បទថា* **តាល្វ-បតិភេ** *បានដល់ ដូចគ្នានឹងផ្លែត្នោតដែលមានពណ៌លឿងដូចមាស ។ បទថា* **កាសិកចន្ទនេន** *បានដល់ លាបហើយដោយលម្អិតខ្លឹមចន្ទន៍ដែលមានសាច់ល្អិត ។ បទថា* **ថនេសុ មេ** *សេចក្ដីថា បពិត្រព្រះមាតា កាលខ្ញុំម្ចាស់ត្រូវបោលក្នុងព្រៃស្មសាន ក្អែចចកមកឃើញស្តនទាំងទ្វេរបស់ខ្ញុំ ដែលស្អាតយ៉ាងនេះ ក៏នឹងយកមាត់ខាំត្រង់ស្តនទាំង ២ របស់ខ្ញុំពិត ដូចកូនខ្ទិរបស់មាតាដែលកើតអំពីខ្លួន ដូច្នោះ ។ បទថា* **សោណី** *គឺចង្កេះ ។ បទថា* **សុកោដ្ដិតំ** *បានដល់ ដែលបុគ្គលយកឈើពាងដូចចង្កាគោវាយ តាក់តែងរហូតល្អ ។ បទថា* **អវត្ថំ** *គឺបោលហើយ ។ បទថា* **ភក្ខយិត្វា** *សេចក្ដីថា បពិត្រព្រះមាតា សត្វទាំងឡាយមានចំនួនប៉ុណ្ណោះ ទំពាស៊ីសាច់របស់ខ្ញុំហើយ នឹងមិនចាស់ពិត ។ បទថា* **សចេ មំសានិ ហរឹសុំ** *សេចក្ដីថា បពិត្រព្រះមាតា បើពួកក្សត្រទាំងនោះ នៅមានចិត្តប្រតិព័ទ្ធក្នុងកូន គប្បីពន្ទះសាច់របស់កូនចេញនាំទៅ កាលបើដូច្នោះ សូមព្រះមាតាយកឆ្អឹងមក ។ បទថា* **អនុបន្ថេ ឧបាជ ឆំ** *សេចក្ដីថា ព្រះនាងបភាវតីក្រាបទូលថា សូមព្រះមាតាដុតឆ្អឹងកូនក្នុងផ្លូវតូចធំ ។ បទថា* **ខេត្តានិ** *សេចក្ដីថា បពិត្រព្រះមាតា សូមព្រះមាតាដាំសួនច្បារឡើង ក្នុងបរិវេណដែលដុតសពរបស់ខ្ញុំ ។ បទថា* **ឯត្ថ** *សេចក្ដីថា គប្បីដាំដើមកណិការទាំងឡាយក្នុងបរិវេណទាំងនោះផង ។ បទថា* **ហិមច្ចយេ**

បានដល់ ក្នុងខែផល្គុនដែលផុតអំពីសន្សើមធ្លាក់ហើយ ។ បទថា **សរេយ្យាជ** សេចក្តីថា ព្រះមាតាគប្បីយកផ្កាទាំងនោះ ដាក់ពេញប្រអប់ទុកត្រង់ភ្លៅ រួចគប្បីរំពឹងថា បកាវតីកូនស្រីរបស់អញ មានពណ៌សម្បុរដូចផ្កាកណិការយ៉ាងនេះ ។

ព្រះនាងបកាវតីនោះ ត្រូវមរណភ័យគំរាមហើយ ទើបព្រះនាងរវើរវាយលើព្រះរាជដំណាក់របស់ព្រះមាតា ដោយប្រការដូច្នេះ ។ ឯព្រះបាទមទ្ទរាជក៏ត្រាស់ប្រើអាមាត្យ ឲ្យយកពូថៅនិងជ្រញ់ ហើយទ្រង់ត្រាស់ថា នាយពេជ្ឈឃាតអ្នកសម្លាប់ចោរ ចូរមកក្នុងទីនេះ ការដែលពេជ្ឈឃាតនោះមកហើយ ក៏ប្រាកដទូទៅពេញលានព្រះរាជវាំង ។ លំដាប់នោះ ព្រះមាតារបស់ព្រះនាងបកាវតីឮថា នាយពេជ្ឈឃាតនោះមកហើយ ក៏យាងចុះអំពីអាសនៈដល់ព្រមដោយសេចក្តីសោក បានយាងទៅកាន់ព្រះដំណាក់របស់ព្រះរាជា ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

> ក្សត្រមានវណ្ណៈដូចវណ្ណៈទេវតា ជាមាតារបស់នាងបកាវតី
> នោះ ក្រោកចាកអាសនៈ ទៅកាន់សំណាក់ព្រះរាជា ហើយ
> បានឃើញដាវនិងជ្រញ់ ក្នុងព្រះរាជវាំងព្រះបាទមទ្ទៈ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧទដ្ឋាសិ** សេចក្តីថា ព្រះទេវីក្រោកឡើងចាកអាសនៈ យាងទៅកាន់ដំណាក់របស់ព្រះរាជា ហើយប្រថាប់ឈរ ។ បទថា **ធិស្វា អសិញ្ច សូនញ្ច** សេចក្តីថា ព្រះទេវីទតឃើញពូថៅនិងជ្រញ់ ដែលគេទុកលើផែនដី ក្នុងទីចំពោះព្រះភក្ត្រព្រះរាជា ដែលប្រដាប់គាក់តែងហើយ

ខាងក្នុងបុរី ទើបព្រះនាងយំរៀបរាប់ដោយព្រះគាថាថា

បពិត្រព្រះបាទមទ្ទៈ ព្រះអង្គនឹងសម្លាប់ធីតា ដែលគេចំណាំ
បានដោយងាយ មានកន្ទេះវៀវ ដោយប៉ូវថៅនេះ ហើយប្រទាន
ដល់ពួកក្សត្រដោយពិត ដូច្នេះ ។

ពាក្យថា **អសិតា** ក្នុងគាថានោះ ព្រះនាងត្រាស់បំណាងដល់ពូថៅ ពិត ហើយពូថៅនោះ ឈ្មោះថា **អសិតា** ក្នុងទីនេះ ។ បទថា **សុសញ្ញំ តនុមជ្ឈិមំ** បានដល់ កាប់ឲ្យជាកំណាត់ត្រង់កណ្តាលខ្លួន ។

លំដាប់នោះ ព្រះរាជាកាលទ្រង់ឲ្យព្រះទេវីនោះសិក្សា ទើបត្រាស់ថា នែទេវី នាងនិយាយអ្វី កូនស្រីរបស់នាង បោះបង់ព្រះរាជាដែលជាធំក្នុងជម្ពូទ្វីបទាំងមូល ដោយរង្កៀសថា ជាអ្នកមានរូបអាក្រក់ កាលផ្លូវដែលមកមិនទាន់វិនាស ក៏នាំយកការស្លាប់មកដោយថ្វាស ឥឡូវនេះ ចូរទទួលផលនៃភាពជាធំ ព្រោះអាស្រ័យរូបរបស់ខ្លួនចុះ ។ ព្រះទេវី បានស្តាប់ព្រះតម្រាស់របស់ព្រះរាជាហើយ ទើបយាងទៅកាន់ដំណាក់របស់ព្រះរាជធីតា យំរៀបរាប់ថា

ហៃបុត្រី នាងមិនបានធ្វើតាមពាក្យរបស់អញ ដែលប្រាថ្នា
ប្រយោជន៍ នាងមុខជានឹងពេញពាសដោយឈាម ហើយ
ទៅកាន់ភពរបស់មច្ចុរាជ ក្នុងថ្ងៃនេះ ។ បើសត្វដែលមិនធ្វើ
តាមពាក្យរបស់ពួកជន ដែលបង្ហាញសេចក្តីចម្រើន បង្ហាញ
ប្រយោជន៍ហើយ តែងប៉ះទង្គិចយ៉ាងនេះផង តែងជួបប្រទះ
នូវសេចក្តីអាក្រក់ជាង ( នេះ ) ផង ។ បើក្នុងថ្ងៃនេះ នាង

នឹងបានទ្រទ្រង់កុមារស្រស់ប៉ប្រៃ ជាក្សត្រដែលកើតព្រោះព្រះបាទកុសៈ មានខ្សែក្រវាត់ជាវិការៈនៃមាស នឹងកែវមណីដែលពួកញាតិបូជាហើយ នាងនឹងមិនទៅកាន់លំនៅយមរាជទេ នៃនាងដ៏ចម្រើន ស្គរលាន់ឮក្តី ដីរស្រែកក្តី ក្នុងខត្តិយៈត្រកូលណា ( នាងឃើញ ) អ្វីដែលជាសុខក្រៃលែងជាងខត្តិយៈត្រកូលនោះ ( បានជានាងមកក្នុងទីនេះ ) ។ សេះក្លាប្រជីប្រប់ទ្វារ កុមារអ្នករបាំប្រគំ ក្នុងខត្តិយៈត្រកូលណា នៃនាងដ៏ចម្រើន ( នាងឃើញ ) អ្វីដែលជាសុខក្រៃលែងជាងខត្តិយៈត្រកូលនោះ ។ កាលបើក្ងោកនិងក្រៀលយំ និងតាវ៉ៅយំឮទ្រហឹងអឹងកង ក្នុងខត្តិយៈត្រកូលណា នៃនាងដ៏ចម្រើន ( នាងឃើញ ) អ្វី ដែលជាសុខក្រៃលែងជាងខត្តិយៈត្រកូលនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឞុត្តិកេ** នេះ ព្រះទេវីត្រាស់ហៅព្រះនាងបភាវតីនោះ ។ ពាក្យនោះ មានអធិប្បាយដូច្នេះថា ក្នុងថ្ងៃនេះ នាងនឹងធ្វើអ្វីក្នុងទីនេះ នាងទៅក្នុងវាំងនៃស្វាមី ស្រវឹងដោយការស្រវឹងក្នុងរូប ព្រោះដូច្នោះ ព្រះរាជបិតា ក៏មិនព្រមធ្វើតាមពាក្យរបស់មាតាឡើយ ទោះបីមាតាអង្វរយ៉ាងនេះ ក្នុងថ្ងៃនេះ នាងនឹងត្រូវប្រឡាក់ដោយឈាម ទៅកាន់សម្នាក់ស្តេចយម គឺទៅកាន់សម្នាក់នៃស្តេចមច្ចុ ។ បទថា **ធាបិយញ្ច** បានដល់រមែងចូលដល់ទោស ដែលអាក្រក់ជាងទោសដែលបានទទួលនេះទៅទៀត ។

បទថា **សចេ អជ្ជ ធារេសិ** សេចក្តីថា នែកូន បើនាងមិនធ្លាក់ក្នុងអំណាចនៃចិត្ត ក៏នឹងបានព្រះរាជឱរស ដែលមានរូបស្អាតដូចមាស ដូចគ្នានឹងរូបរបស់នាង ដែលបានហើយ ព្រោះអាស្រ័យព្រះបាទកុសរាជ ដែលជាកំពូលនៃនរៈ ។ បទថា **យមក្ខយំ** សេចក្តីថា កាលបើដូច្នោះ នាងមិនចាំបាច់ទៅកាន់និវេសន៍នៃស្តេចយម ។ បទថា **តតោ** សេចក្តីថា ក្នុងត្រកូលនៃក្សត្រណា មានសេចក្តីសុខសាន្ត គួរជាទីត្រេកអរដល់ម្ល៉េះ នាងឃើញអ្វី ដែលមានសេចក្តីសុខក្រៃលែងជាងទីបែបនេះ គឺអំពីរាជត្រកូលកុសាវតី ដែលអឺងកងដោយសំឡេងស្គរជ័យ សំឡេងច្រៀង សំឡេងដំរី សំឡេងក្រៀល ទើបមកក្នុងទីនេះ ។ បទថា **ហសិសតិ** បានដល់ ស្រែកខ្ទាំងរំពង ។ បទថា **កុមារោ** បានដល់ គន្ធព្វកុមារ ដែលជាអ្នកតន្ត្រី ដែលសិក្សាជំនាញល្អហើយ ។ បទថា **ឧបរោធតិ** បានដល់ កាន់យកតន្ត្រីប្រភេទផ្សេងៗ ហើយធ្វើនូវការប្រគំ ។ បទថា **កោកិលាភិនិក្ខជិតេ** សេចក្តីថា ក្នុងត្រកូលនៃព្រះបាទកុសរាជ មានពួកតាវ៉ៅទាំងឡាយយំល្វេងល្វើយ ដូចផ្សាយទៅដោយការបម្រើដោយការរាំច្រៀង ប្រគំដែលប្រព្រឹត្តទៅរាល់ពេលល្ងាចនិងពេលព្រឹក ។

ព្រះទេវីនោះ ទ្រង់ចរចាជាមួយព្រះនាងបភាវតីដោយគាថាមានប្រមាណប៉ុណ្ណេះ ដោយប្រការដូច្នេះហើយ ទើបព្រះនាងត្រិះរិះថា បើក្នុងថ្ងៃនេះ ព្រះបាទកុសរាជជាកំពូលនៃជន គប្បីប្រថាប់នៅក្នុងទីនេះសោត ទ្រង់នឹងយាងចេញច្បាំង ព្រះរាជាទាំង ៧ នគរនេះឲ្យខ្ចាត់ខ្ចាយទៅ គប្បីដោះនូវត្រកូលរបស់យើង ឲ្យផុតចាកសេចក្តីទុក្ខ ហើយគប្បីនាំកូនរបស់យើងត្រឡប់ទៅ ទើប

ត្រាស់គាថានេះថា

ព្រះបាទកុសៈ ជាអ្នកញាំញីខ្មាំងសត្រូវ ញាំញីដែនរបស់
ព្រះរាជដទៃ មានប្រាជ្ញាធ្មេីត គប្បីដោះយេីងឲ្យរួចចាកទុក្ខ
បាន តេីនៅក្នុងទីណា ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សោឡារបញ្ញាណោ** បានដល់ ដែលមាន
បញ្ញាក្រៃលែង ។

ក្នុងលំដាប់នោះ ព្រះនាងបភាវតីព្រះតម្រិះថា កាលព្រះមាតារបស់អញ
ពណ៌នាគុណរបស់ព្រះបាទកុសរាជ មាត់ក៏មិនគ្រប់គ្រាន់ អញនឹងប្រាប់ថា
ស្ដេចកុសរាជនោះ ធ្វេីការងារជាអ្នកពិសេស ប្រថាប់នៅក្នុងទីនេះឯងដល់
ព្រះមាតា ទេីបទូលគាថានេះថា

ព្រះបាទកុសៈ ជាអ្នកញាំញីខ្មាំងសត្រូវ ញាំញីដែនរបស់
ព្រះរាជដទៃ មានប្រាជ្ញាធ្មេីត សម្លាប់ក្សត្រទាំងអស់នោះ នៅ
ក្នុងទីនេះឯង ដូច្នេះ ។

លំដាប់នោះ ព្រះមាតារបស់ព្រះនាងបភាវតីនោះ ព្រះតម្រិះថា កូនអញ
នេះ ប្រហែលជាខ្លាចចំពោះមរណភ័យ ទេីបរវេីរវាយ ដូច្នេះហេីយ ក៏ត្រាស់
គាថានេះថា

នាងជាស្រីឆ្កួត ជាស្រីអន្ធពាល ចេះតែនិយាយ ( ឲ្យរួចតែ
ពីមាត់ ) បេីព្រះបាទកុសៈ គប្បីមក ពួកយេីងធ្វេីដូចម្ដេច
នឹងស្គាល់ព្រះបាទកុសៈនោះបាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អន្ធពាលា** បានដល់ ជាអ្នកល្ងង់ខ្លៅ មិនមានវិជ្ជា ។ បទថា **កឹ ឆ ជានេមុ** សេចក្ដីថា ព្រោះហេតុអ្វី ទើបមាតាមិនស្គាល់ទ្រង់ ដ្បិតថា ព្រះបាទកុសរាជអង្គនោះ ទើបតែយាងមកដល់កណ្ដាលផ្លូវប៉ុណ្ណោះ ក៏ត្រូវបញ្ជូនព្រះរាជសាសន៍មកដល់ពួកយើង សេនាប្រកបដោយអង្គ ៤ មានទទង់លើកឡើង ក៏ត្រូវប្រាកដ កូនពោលដល់ស្ដេចកុសរាជអង្គនោះ ព្រោះខ្លាចស្លាប់ទេដឹង ។

កាលព្រះមាតាត្រាស់យ៉ាងនេះ ព្រះនាងបភាវតីក៏ត្រិះរិះថា ព្រះមាតារបស់អញ មិនព្រមជឿ និងមិនដឹងថា ព្រះបាទកុសរាជអង្គនោះ យាងមកប្រថាប់ក្នុងទីនេះអស់ ៧ ខែហើយ អញនឹងបង្ហាញព្រះបាទកុសរាជនោះ ដល់ព្រះមាតា ទើបចាប់ព្រះហស្តព្រះមាតា ហើយបើកបង្អួច លាព្រះហស្តចេញទៅ ហើយឲ្យទត ព្រមទាំងក្រាបទូលជាគាថានេះថា

( ព្រះបាទកុសៈ ) គឺបុរសនាយពិសេសនុ៎ះ ចង់ក្បិនយ៉ាងមាំខ្ជិនលាងឆ្នាំង ( សូមព្រះមាតាទត ) ត្រង់ចន្លោះដំណាក់កុមារី ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កុមារីបុរមន្តរេ** សេចក្ដីថា សូមព្រះមាតាប្រថាប់ឈរត្រង់បង្អួច ទតទៅក្នុងចន្លោះព្រះដំណាក់របស់ពួកកុមារី ដែលជាព្រះរាជធីតារបស់ព្រះមាតាចុះ ។ បទថា **សំវេល្លំ** សេចក្ដីថា កំពុងស្លៀកចង់ក្បិនលាងឆ្នាំង ។

បានឮថា ក្នុងកាលនោះ ព្រះពោធិសត្វទ្រង់ព្រះតម្រិះថា ថ្ងៃនេះ សេចក្ដី

ប្រាថ្នារបស់អញគង់ដល់ទីបំផុត ព្រះនាងបភាវតីខ្លាចនូវសេចក្ដីស្លាប់ គង់ទូល ព្រះមាតានិងព្រះបិតាឲ្យទ្រង់ជ្រាបថា អញនៅក្នុងទីនេះពិត អញនឹងចាត់ចែងលាងកែវ ចាន ហើយនឹងរក្សាទុក ដូច្នេះហើយ ទើបយាងទៅដងទឹកមក ហើយចាប់ផ្ដើមលាងកែវ ចានទាំងឡាយ ។ លំដាប់នោះ ព្រះទេវីក៏បរិភាសព្រះនាងបភាវតីជាគាថានេះថា

នាងជាស្រីនៃត្រកូលជាងចាំង ជាស្រីចណ្ឌាល ឬជាស្រី
ទ្រុស្តត្រកូលទេឬ នាងកើតក្នុងត្រកូលព្រះបាទមទ្ទៈ គួរធ្វើ
ស្វាមី ( របស់ខ្លួន ) ឲ្យជាទាសៈ ដូចម្ដេចកើត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វេណី** បានដល់ ជាងចាំង ។ បទថា **អាទូសិកុលគន្ធិនី** បានដល់ ឬថា នាងជាស្រីទ្រុស្តត្រកូល ។ បទថា **កាមុកំ** សេចក្ដីថា នាងកើតក្នុងត្រកូលបែបនេះ ហេតុអ្វី ទើបធ្វើប្ដីរបស់ខ្លួនឲ្យជាទាសៈ ។

ក្នុងលំដាប់នោះ ព្រះនាងបភាវតីព្រះតម្រិះថា ព្រះមាតារបស់អញប្រហែលជាមិនជ្រាបទេថា ព្រះបាទកុសរាជនេះ យាងមកប្រថាប់យ៉ាងនេះព្រោះអាស្រ័យអញ ទើបទូលគាថាក្រៅអំពីនេះថា

ខ្ញុំមិនមែនជាស្រីត្រកូលជាងចាំង មិនជាស្រីចណ្ឌាល មិន
មែនជាស្រីទ្រុស្តត្រកូលទេ បពិត្រព្រះមាតា ( ព្រះបាទកុសៈ
នោះ ) ជាបុត្តរបស់ព្រះបាទឱក្កាកៈ ( ចំណែកខាង )
ព្រះមាតាទេតើ សម្គាល់ថា ជាទាសៈទៅវិញ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឱក្កាកបុត្តោ** សេចក្ដីថា បពិត្រព្រះមាតា ទ្រង់ គឺព្រះរាជឱរសនៃព្រះបាទឱក្កាករាជ តែព្រះមាតាយល់ថា ជាទាសៈ ខ្ញុំម្ចាស់នឹងហៅព្រះបាទកុសរាជនោះថា ជាទាសៈ ព្រោះហេតុអ្វី ។ ឥឡូវនេះ ព្រះនាងបភាវតី កាលពណ៌នាដល់កិត្តិយសរបស់ព្រះបាទកុសរាជនោះ ក៏ទូលថា

ព្រះបាទកុសៈណា ញុំាំងពួកព្រាហ្មណ៍ទាំង ២០ ពាន់ ឲ្យបរិភោគសព្វកាល បពិត្រព្រះមាតា ព្រះបាទកុសៈនោះ ជាបុត្តរបស់ព្រះបាទឱក្កាកៈ ( ចំណែកខាង ) ព្រះមាតាទេតើសម្គាល់ថាជាទាសៈទៅវិញ ។ ពួកជនតែងទឹមដំរីទាំង ២០ ពាន់ របស់ព្រះបាទកុសៈណាសព្វកាល បពិត្រព្រះមាតា ព្រះបាទកុសៈនោះ ជាបុត្តរបស់ព្រះបាទឱក្កាកៈ ( ចំណែកខាង ) ព្រះមាតាទេតើ សម្គាល់ថាជាទាសៈទៅវិញ ។ ពួកជនតែងទឹមសេះទាំង ២០ ពាន់ របស់ព្រះបាទកុសៈណាសព្វកាល បពិត្រព្រះមាតា ព្រះបាទកុសៈនោះ ជាបុត្តរបស់ព្រះបាទឱក្កាកៈ ( ចំណែកខាង ) ព្រះមាតាទេតើ សម្គាល់ថាជាទាសៈទៅវិញ ។ ពួកជនតែងទឹមរថទាំង ២០ ពាន់ របស់ព្រះបាទកុសៈណា សព្វកាល បពិត្រព្រះមាតា ព្រះបាទកុសៈនោះ ជាបុត្តរបស់ព្រះបាទឱក្កាកៈ ( ចំណែកខាង ) ព្រះមាតាទេតើ សម្គាល់ថាជាទាសៈទៅវិញ ។ ពួកជនតែងរឹតទឹក

ដោះមេគោទាំង ២០ ពាន់ របស់ព្រះបាទកុសៈណា សព្វកាល បពិត្រព្រះមាតា ព្រះបាទកុសៈនោះ ជាបុត្តរបស់ព្រះបាទឱក្កាកៈ ( ចំណែកខាង ) ព្រះមាតាទេតើ សម្គាល់ថា ជាទាសៈទៅវិញ ដូច្នេះ ។

កាលព្រះនាងបភាវតីពណ៌នា ដល់ព្រះឥស្សរិយយស របស់ព្រះមហាសត្វ ៥ គាថាយ៉ាងនេះហើយ លំដាប់នោះ ព្រះមាតារបស់ព្រះនាងក៏ជឿ ដោយទ្រង់ព្រះតម្រិះថា កូនស្រីរបស់យើងនេះ ពោលពាក្យម៉ាំទាំ ពាក្យនេះ គង់ជាយ៉ាងនេះពិត ទើបប្រញាប់ទៅកាន់ដំណាក់ព្រះរាជា ក្រាបទូលសេចក្តីនោះឲ្យទ្រង់ជ្រាប ។ ព្រះរាជាយាងទៅកាន់ព្រះដំណាក់របស់ព្រះនាងបភាវតី ដោយរួសរាន់ ត្រាស់សួរថា ជាការពិតឬបុត្រី បានឮថា ព្រះបាទកុសរាជ យាងមកក្នុងទីនេះ ព្រះនាងបភាវតីក្រាបទូលថា ពិតយ៉ាងនោះឯង បពិត្រព្រះបិតា ព្រះបាទកុសរាជអង្គនោះ ទ្រង់ធ្វើកិច្ចជាអ្នកពិសេសដល់ធីតាទាំងឡាយរបស់ទ្រង់ រាប់ពីថ្ងៃនេះទៅរាប់បាន ៧ ខែហើយ ព្រះរាជាមិនទាន់ជឿព្រះនាង ទើបត្រាស់សួរស្រីគម នាងក៏ក្រាបទូលសេចក្តីពិតគ្រប់ប្រការ ព្រះរាជា កាលស្តាប់ពាក្យនោះហើយ កាលនឹងតិះដៀលព្រះធីតា ទើបត្រាស់គាថានេះថា

ម្នាលស្រីពាល ហាងឯងធ្វើវិរុទ្ធដល់ក្សត្រ ដែលមានកម្លាំងច្រើន ដូចជាដំរី ដោយភេទនៃកង្កែប នាងមិនបានប្រាប់ក្សត្រនោះ ដែលយាងមកហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តគ្ឃ** បានដល់ ដោយចំណែកមួយប៉ុណ្ណោះ ។

ព្រះរាជាអង្គនោះ កាលតិះដៀលព្រះរាជធីតាហើយ ក៏រូតរះទៅកាន់សម្នាក់ព្រះពោធិសត្វ ទ្រង់មានបដិសណ្ឋារៈដែលព្រះពោធិសត្វធ្វើហើយ ទើបទ្រង់ផ្គងអញ្ជលី ដើម្បីទ្រង់សម្ដែងទោសរបស់ព្រះអង្គ ទើបត្រាស់ព្រះគាថានេះថា

បពិត្រមហារាជ ជាបុគ្គលប្រសើរលើរថ សូមព្រះអង្គទ្រង់
អត់កំហុសដល់យើង ព្រោះយើងមិនបានដឹងថា ទ្រង់យាង
មកក្នុងទីនេះ ដោយក្លែងភេទសោះ ដូច្នេះ ។

ព្រះមហាសត្វទ្រង់ស្ដាប់ពាក្យនោះហើយ ទើបព្រះតម្រិះថា បើអញពោលពាក្យកាត់ ឬស្ដីបន្ទោសឡើង បេះដូងរបស់ព្រះរាជានឹងបែកក្នុងទីនេះពិត អញគួរលួងលោមព្រះរាជា ប្រថាប់ឈរក្នុងរវាងកាជនៈនោះឯង ត្រាស់ព្រះគាថានេះថា

បពិត្រសម្មតិទេព ដំណើរដែលទូលព្រះអង្គជាខ្ញុំធ្វើជានាយ
ពិសេសនោះ មិនកំបាំងដល់ជនដូចទូលព្រះបង្គំជាខ្ញុំទេ សូម
ព្រះអង្គជ្រះថ្លានឹងទូលបង្គំជាខ្ញុំចុះ អំពើវិឃ្នរបស់ព្រះអង្គ
មិនមានទេ ដូច្នេះ ។

ព្រះរាជាទ្រង់បានទទួលបដិសណ្ឋារៈ អំពីសម្នាក់របស់ព្រះពោធិសត្វនោះហើយ ទើបឡើងកាន់ប្រាសាទ ត្រាស់ហៅព្រះនាងបភាវតីមកគាល់ ទ្រង់បញ្ជូនទៅ ដើម្បីឲ្យមហាសត្វអត់ទោស ទើបត្រាស់គាថានេះថា

ម្នាលស្រីពាល នាងឯង ចូរទៅសូមខមាទោសនឹងព្រះបាទ
កុសៈ ដែលមានកម្លាំងច្រើន ព្រះបាទកុសៈនោះ កាលបើ
នាង សូមខមាទោសហើយ នឹងប្រទានជីវិតដល់នាង ដូច្នេះ ។

ព្រះនាងបភាវតីនោះ បានស្តាប់ព្រះតម្រាស់របស់ព្រះបិតាហើយ ដល់ព្រមដោយព្រះភគិនីទាំងឡាយ និងពួកបរិចារិកាជាច្រើន យាងទៅកាន់សម្នាក់របស់ព្រះពោធិសត្វនោះ ។ ឯព្រះពោធិសត្វ ប្រថាប់ឈរដោយភេទនៃអ្នកលាងថ្នាំងនោះឯង ទ្រង់ដឹងថា ព្រះនាងបភាវតីនោះ យាងមកកាន់សម្នាក់របស់ទ្រង់ ទើបទ្រង់ព្រះតម្រិះថា ថ្ងៃនេះអញនឹងទម្លាយមានះរបស់ព្រះនាងបភាវតីឲ្យនាងក្រាបក្នុងភក់ ទៀបជើងរបស់អញឲ្យបាន ទើបទ្រង់ជះទឹកដែលជងមកទាំងអស់ ទ្រង់ជាន់ឲ្យបែកក្នុងទីប្រមាណប៉ុនមណ្ឌលនៃលានស្រូវ ធ្វើឲ្យទៅជាភក់ទាំងអស់ ព្រះនាងបភាវតីនោះ យាងទៅកាន់សម្នាក់របស់ព្រះបាទកុសរាជពោធិសត្វ ក្រាបចុះទៀបបាទា ប្រថាប់អង្គុយលើភក់ ហើយសូមខមាទោសជាមួយព្រះពោធិសត្វនោះ ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

នាងបភាវតី មានវណ្ណៈដូចជាវណ្ណៈនៃទេវតា ឮព្រះឱង្ការ
របស់ព្រះបិតា ( ក៏ក្រាប ) ដោយសីសៈអាចចាប់ព្រះបាទ
កុសៈដ៏មានកម្លាំងច្រើន ត្រង់ព្រះបាទាបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សិរសា** សេចក្តីថា ព្រះនាងបភាវតីបង្អោនសិរសាចុះ ហើយចាប់ព្រះបាទារបស់ព្រះបាទកុសរាជ កាលព្រះនាងចាប់

ហើយ ដើម្បីញ៉ាំងព្រះពោធិសត្វឲ្យអត់ទោស ទើបពោលគាថា ៣ ថា

បពិត្រព្រះសម្មតិទេព រាត្រីទាំងនោះវៀរចាកព្រះអង្គកន្លងទៅ បពិត្រព្រះអង្គជាបុគ្គលប្រសើរលើរថ ខ្ញុំម្ចាស់សូម ( ក្រាប ) ដោយក្បាល ថ្វាយបង្គំព្រះបាទទាំងគូ របស់ព្រះអង្គ សូមព្រះអង្គ កុំខ្វាល់នឹងខ្ញុំម្ចាស់ ។ បពិត្រមហារាជ ខ្ញុំម្ចាស់សូមប្ដេជ្ញាពាក្យពិតចំពោះព្រះអង្គ សូមព្រះអង្គទ្រង់ព្រះសណ្ដាប់ពាក្យរបស់ខ្ញុំម្ចាស់ ៗ លែងធ្វើនូវការមិនស្រឡាញ់ ព្រះអង្គទៀតហើយ ។ កាលបើខ្ញុំម្ចាស់អង្វរករយ៉ាងនេះហើយ បើព្រះអង្គនឹងមិនធ្វើតាមពាក្យខ្ញុំម្ចាស់ទេ ព្រះរាជបិតា មុខជានឹងសម្លាប់ខ្ញុំម្ចាស់ឥឡូវនេះ ហើយប្រទានដល់ពួកក្សត្រមិនខាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **រត្យោ** បានដល់ វេលាយប់ ។ បទថា **តាមា** បានដល់ រាត្រីទាំងអស់នេះកន្លងទៅហើយ វៀរចាកព្រះអង្គ ។ បទថា **សច្ចន្តេ បដិជានាមិ** សេចក្ដីថា បពិត្រមហារាជ ខ្ញុំម្ចាស់ធ្វើការស្អប់ខ្ពើមទ្រង់អស់កាលមានប្រមាណប៉ុណ្ណេះ ឥឡូវនេះ ខ្ញុំម្ចាស់សូមប្ដេជ្ញានូវពាក្យសច្ចៈនេះដល់ព្រះអង្គ សូមទ្រង់ស្ដាប់ពាក្យដទៃទៀត ចាប់ពីពេលនេះទៅ ខ្ញុំម្ចាស់នឹងមិនធ្វើការស្អប់ខ្ពើមទ្រង់ទៀតឡើយ ។ បទថា **ឯវញ្ចេ** សេចក្ដីថា បើទ្រង់មិនធ្វើតាមពាក្យរបស់ខ្ញុំម្ចាស់ដែលជាអ្នកអង្វរយ៉ាងនេះ ។

ព្រះរាជាបានស្ដាប់ពាក្យនោះ ទើបទ្រង់ព្រះតម្រិះថា បើអញនិយាយថា

នាងម្នាក់ប៉ុណ្ណោះ នឹងជីងរឿងនេះ ដូច្នេះ ហទយៈរបស់នាងក៏នឹងបែក អញនឹងលួងលោមនាង ហើយទើបត្រាស់ថា

*កាលបើនាងអង្វរករ យ៉ាងនេះហើយ យើងនឹងមិនធ្វើតាមពាក្យរបស់នាងឯណាបាន នែនាងបភាវតីស្រីកល្យាណី បងលែងខឹងនឹងនាងហើយ នាងកុំភ័យឡើយ ។ នែរាជបុត្រី យើងសូមប្ដេជ្ញាពាក្យពិតចំពោះនាង ៗ ចូរស្ដាប់ពាក្យរបស់យើង ៗ លែងធ្វើនូវសេចក្ដីមិនជាទីស្រឡាញ់នាងទៀត ។ នែនាងបភាវតី ជាស្រីមានកង្កែះរៀវ យើងអត់ទ្រាំសេចក្ដីទុក្ខ ច្រើនជង ព្រោះតែចង់បាននាង យើងហ៊ានសម្លាប់ត្រកូលរបស់ប្រាទមទ្ទៈជាច្រើន ហើយនាំយកនាងទៅបានដូច្នេះ ។*

បណ្ដាបទទាំងនោះ បទថា **កឹ ន ករោមិ** សេចក្ដីថា ព្រោះហេតុអ្វីទើបយើងមិនធ្វើតាមពាក្យរបស់នាងនោះ ។ បទថា **វិកុទ្ធោ ត្យស្មិ** សេចក្ដីថា យើងមិនមានសេចក្ដីក្រោធ មិនមានការចង្អៀតចង្អល់ចំពោះនាងទេ ។ បទថា **សច្ចន្តេ** សេចក្ដីថា យើងសូមឲ្យប្ដេជ្ញានូវពាក្យសច្ចៈនេះដល់នាង ២ ចំណុច គឺមិនក្រោធខឹង ១ មិនស្អប់ខ្ពើម ១ ។ បទថា **តវ កាមា** សេចក្ដីថា ព្រោះស្រឡាញ់ គឺប្រាថ្នានូវនាង ។ បទថា **តិតិក្ខិស្សំ** បានដល់ អត់ធន់ ។ បទថា **ពហុមទ្ទកុលំ ហន្ត្វា** សេចក្ដីថា យើងអាចសម្លាប់ត្រកូល ព្រះបាទមទ្ទរាជ ហើយនាំយកនាងទៅដោយកម្លាំងក៏បាន ។

លំដាប់នោះ ព្រះពោធិសត្វនោះ ទតឃើញព្រះនាងបភាវតីអគ្គមហេសីរបស់ទ្រង់ហាក់បីដូចជាទេវកញ្ញា ដែលជាបរិចារិការបស់សក្កទេវរាជ ក៏ទ្រង់ញុំាងខត្តិយមានះឲ្យកើតឡើង ទ្រង់ព្រះតម្រិះថា បានឮថា កាលអញនៅមានជីវិត មនុស្សក្តី ស្តេចទាំងឡាយដទៃក្តី នឹងមកដណ្តើមយកអគ្គមហេសីរបស់យើងទៅឬ ទើបទ្រង់សម្តែងខត្តិយលីលា យាងទៅកាន់លានព្រះរាជវាំងដូចរាជសីហ៍ ទ្រង់បន្លឺសំឡេងទះព្រះហស្តប្រកាសថា អ្នកនគរទាំងមូល ចូរដឹងចុះថា យើងកុសរាជមកហើយ ត្រាស់បញ្ជាថា ឥឡូវនេះ យើងនឹងចាប់ស្តេច ៧ នគរនោះ ឲ្យបានទាំងអស់ អ្នកទាំងឡាយចូរទឹមរថជាដើមមកឲ្យយើង ហើយត្រាស់គាថាជាបន្ទាថា

ពួកជនទាំងឡាយ ចូរទឹមសេះដ៏វិលេចដោយគ្រឿងប្រដាប់ផ្សេងៗ ជាសត្វរាបរយក្នុងរថ កាលបើទឹមហើយ អ្នកទាំងឡាយ មុខជានឹងឃើញកម្លាំងរបស់ខ្ញុំ ដែលកម្ចាត់ពួកខ្មាំងបានដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **នានាចិត្តេ** បានដល់ វិចិត្រដោយគ្រឿងអលង្ការផ្សេងៗ ។ បទថា **សមាហិតេ** នេះ លោកសំដៅដល់សេះទាំងឡាយ អធិប្បាយថា សេះដែលហ្វឹកហាត់ល្អហើយ មិនមានព្យសន៍ ។ បទថា **អថ ទក្ខថ មេ វេគំ** សេចក្តីថា អ្នកទាំងឡាយ នឹងបានឃើញភាពក្លៀវក្លាក្នុងសង្គ្រាមរបស់យើងក្នុងកាលឥឡូវនេះ ។

ព្រះពោធិសត្វបញ្ជូនព្រះបាទមទ្ទរាជទៅ ដោយព្រះតម្រាស់ថា ឈ្មោះថា

ការចាប់ព្រះរាជា ៧ នគរ ជានាទីរបស់ខ្ញុំឯង សូមទ្រង់ទៅស្រេពស្រង់ តាក់តែងរាងកាយ ហើយឡើងកាន់ប្រាសាទចុះ ។ ឯស្តេចមទ្ទរាជ ក៏ទ្រង់បញ្ជូនអាមាត្យទៅ ដើម្បីធ្វើការបម្រើព្រះពោធិសត្វនោះ ។ ពួកអាមាត្យទាំងនោះនាំគ្នាចាត់ចែងបាំងវាំងននជុំវិញទ្វារបន្ទប់ចុងភៅនោះឯង ឲ្យពួកជាងកោរកាត់ចូលទៅកាត់ព្រះកេសា កោរព្រះមស្សុ ព្រះពោធិសត្វនោះ ។ ទ្រង់ឲ្យជាងធ្វើកិច្ចស្រេចហើយ ស្រេពស្រង់ជម្រះព្រះសីសៈ ប្រដាប់នូវគ្រឿងអលង្ការសព្វយ៉ាង មានអាមាត្យចោមរោមជាបរិវារ ឡើងកាន់ប្រាសាទ ទតមើលដោយជុំវិញគ្រប់ទិស ហើយទ្រង់ទះព្រះហស្ត ។ ទីដែលទ្រង់សម្លឹងមើលក៏ញាប់ញ័រ មហាសត្វក៏ត្រាស់ថា អ្នកទាំងឡាយ ចូរមើលនូវការក្បៀវក្លា តតាំងនឹងសត្រូវរបស់យើង ក្នុងកាលឥឡូវនេះ ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

ពួកស្រីក្នុងព្រះរាជវាំង របស់ព្រះបាទមទ្ទៈ ( នាំគ្នាបើកបង្អួច )
អើតមើលព្រះបាទកុសៈនោះ ដែលកំពុងមឹតពត់ កំពុងទង្គិច
ដើមដៃទាំងពីរខាង ដូចជាសីហៈក្នុងទីនោះ ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអធិប្បាយថា ពួកស្រីនាំគ្នាបើកបង្អួចខាងក្នុងបុរីនៃព្រះរាជា ហើយសម្លឹងមើលព្រះពោធិសត្វ ដែលទ្រង់មឹតពត់និងទះព្រះហស្តក្នុងទីនោះ ។

លំដាប់នោះ ព្រះបាទមទ្ទរាជទ្រង់បញ្ជូនដំរីដ៏ប្រសើរដែលប្រដាប់ហើយជាដំរីដែលទូន្មានមិនឲ្យញាប់ញ័រថ្វាយដល់ព្រះពោធិសត្វ ។ ព្រះមហាសត្វ

ឡើងប្រថាប់លើកដីរដែលមានស្វេតច្ឆត្រលើកឡើង ហើយត្រាស់ថា ពួកអ្នកទាំងឡាយ ចូរនាំនាងបភាវតីមកចុះ រួចឲ្យព្រះនាងប្រថាប់គង់លើដីរ ខាងក្រោយខ្នងព្រះអង្គ ដែលចតុរង្គិនីសេនាចោមរោមជាក្បួនទ័ព ទ្រង់ចេញតាមទ្វារទិសខាងកើត ទតឃើញកងទ័ពរបស់សត្រូវ ក៏បន្លឺសីហនាទ ៣ ដងថា យើងកុសរាជ អ្នកណាស្រឡាញ់ជីវិត ចូរដេកផ្កាប់មុខចុះ រួចទ្រង់បានធ្វើការបង្ក្រាបស្តេចទាំង ៧ នគរ ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

ព្រះបាទកុសៈ លើកព្រះនាងបភាវតីឡើងកាន់កដីរ លុកលុយចូលទៅក្នុងសង្គ្រាម ហើយក៏បន្លឺនូវសីហនាទ ។ ពួកក្សត្រិយ៍ឮព្រះបាទកុសៈនោះ បន្លឺសីហនាទនោះ ត្រូវភ័យអំពីសំឡេងគម្រាមនៃព្រះបាទកុសៈបៀតបៀនហើយ ក៏នាំគ្នារត់បែកខ្ញែកដូចជាពួកម្រឹគដទៃ ( ដែលភ័យនឹងសម្រែក ) នៃសីហៈ ។ ពួកទាហានដីរ ទាហានសេះ ទាហានរថ ទាហានថ្មើរជើង ត្រូវភ័យអំពីសំឡេងនៃព្រះបាទកុសៈបៀតបៀនហើយក៏រត់ជាន់គ្នាទៅវិញទៅមក ។ ទេវរាជជាធំជាងទេវតា បានឃើញហើយ ក៏មានព្រះទ័យរីករាយ បានប្រទានកែវមណីឈ្មោះវេរោចនៈ ដល់ព្រះបាទកុសក្នុងប្រធាននៃសង្គ្រាមនោះ ។ ព្រះរាជានោះ លុះឈ្នះសង្គ្រាមនោះ បានកែវមណីឈ្មោះវេរោចនៈ ហើយគង់លើកដីរ ក៏យាងចូលទៅកាន់បុរី ។

ព្រះបាទកុសៈបាន ចាប់យកក្សត្រទាំង ៧ អង្គ ទាំងរស់ចង នាំមកថ្វាយដល់ព្រះបិតាក្មេកថា បពិត្រព្រះសម្មតិទេព ក្សត្រទាំង ៧ នេះហើយ ជាសត្រូវរបស់ព្រះអង្គ ។ ពួកក្សត្រជាសត្រូវទាំងអស់ ជាអ្នកបៀតបៀនព្រះអង្គ លុះក្នុងអំណាចរបស់ព្រះអង្គហើយ សូមព្រះអង្គធ្វើតាមបំណងរបស់ព្រះអង្គចុះ ទោះព្រះអង្គលែងក្សត្រទាំងនោះ ឬសម្លាប់នូវក្សត្រទាំងនោះចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិបលាយឹសុ** សេចក្តីថា ស្តេចទាំងនោះមិនអាចតម្កល់ស្មារតីបាន មានចិត្តវិបល្លាស រត់ខ្វាត់ខ្វាយទៅ ។ បទថា **កុសសទ្ទភយដ្ដិតា** សេចក្តីថា ជាអ្នកត្រូវភ័យកើតឡើង ព្រោះអាស្រ័យសំឡេងនៃព្រះបាទកុសរាជប៉ះសោតប្បសាទហើយ ទើបជាអ្នកមានចិត្តវង្វេង ។ បទថា **អញ្ញមញ្ញស្ស ឆិន្ទន្តិ** សេចក្តីថា សម្លាប់គឺជាន់គ្នាឯង ។ បាលីថា **ភិន្ទឹសុ** ( បែកបាក់ទៅ ) ដូច្នេះក៏មាន ។ បទថា **តស្មឹ** សេចក្តីថា សក្កទេវរាជទតឃើញការច្បាំងនឹងសត្រូវ មានជ័យជម្នះរបស់មហាសត្វនោះក្នុងសង្គ្រាមបែកខ្វាត់ខ្វាយទៅ ដោយអំណាចនៃសំឡេងរបស់ព្រះពោធិសត្វ យ៉ាងនេះក៏មានព្រះហឫទ័យត្រេកអរ ទើបប្រទានកែវមណីមួយឈ្មោះវេរោចនៈ ដល់ព្រះមហាសត្វនោះ ។ បទថា **ឆគាំ បុរំ** បានដល់ បុរី គឺព្រះនគរ ។ បទថា **ពន្ធិត្វា** បានដល់ ប្រើសំពត់សាដករបស់ពួកក្សត្រទាំងនោះឯង ចងក្សត្រទាំងនោះ យកដើមដៃទៅក្រោយ ។ បទថា **កាមំ ករោហិ តេ តយា**

សេចក្តីថា ព្រះមហាសត្វក្រាបទូលថា សូមទ្រង់ធ្វើតាមសេចក្តីត្រូវការសេចក្តីប្រាថ្នា សេចក្តីគាប់ចិត្តរបស់ទ្រង់ចុះ ដ្បិតថា ក្សត្រទាំងនេះ ព្រះអង្គធ្វើឲ្យជាទាសៈហើយ ។

បពិត្រមហារាជ ព្រះរាជាទាំងនុ៎ះ ជាសត្រូវរបស់ព្រះអង្គ
ព្រះរាជាទាំងនោះ មិនមែនជាសត្រូវរបស់ខ្ញុំទេ ព្រះអង្គ ( ជា
ឥស្សរៈ ) របស់ពួកយើងស្រាប់ហើយ ទោះលែងក្សត្រទាំង
នោះ ឬសម្លាប់នូវក្សត្រទាំងនោះចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ត្វញ្ញេវ នោ** សេចក្តីថា បពិត្រមហារាជទ្រង់ប៉ុណ្ណោះ ជាធំជាងពួកខ្ញុំ ។ កាលព្រះបាទមទូរាជ ត្រាស់យ៉ាងនេះហើយ ព្រះមហាសត្វក៏ទ្រង់ព្រះតម្រិះថា ប្រយោជន៍អ្វីដោយការសម្លាប់ស្តេចទាំងនេះ ការមករបស់ស្តេចទាំង ៧ នគរ កុំទទេចាកប្រយោជន៍ឡើយ ព្រះធីតារបស់ព្រះបាទមទូរាជ ដែលជាព្រះកនិដ្ឋភគិនីរបស់ព្រះនាងបភាវតីក៏មាន ៧ អង្គ អញនឹងលើកនាងឲ្យទៅស្តេចទាំង ៧ នគរនោះ ទើបត្រាស់គាថានេះថា

ធីតាទាំងឡាយរបស់ព្រះអង្គទាំង ៧ នេះ ល្អមានឧបមា
ដោយទេវកញ្ញា សូមព្រះអង្គ ប្រទានធីតាមួយអង្គៗ ដល់
ព្រះរាជាទាំងនោះៗ ចូរជាកូនប្រសាររបស់ព្រះអង្គចុះ ដូច្នេះ ។

ព្រះបាទមទូរាជ ទ្រង់ស្តាប់ដូច្នោះហើយ ក៏ពេញព្រះហឫទ័យ ( ក្នុងការ ) ព្រះរាជទានធីតាទាំងឡាយរបស់ទ្រង់ ទើបត្រាស់គាថានេះថា

បពិត្រមហារាជ ព្រះអង្គជាឥស្សរៈរបស់ពួកយើងទាំងអស់

គ្នា គឺ ( ព្រះរាជាទាំង ៧ នេះផង ) ខ្ញុំផង ធីតាទាំងនោះ
ផង ព្រះអង្គប្រាថ្នានឹង ( ប្រទាន ) ធីតាណា ( ដល់ព្រះរាជា
ណា ) សូមប្រទាន ( ធីតានោះ ) ដល់ព្រះរាជានោះចុះ
ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តុំ នោ សព្វេសំ** សេចក្ដីថា បពិត្រមហារាជជាកំពូលនៃអ្នកដែនកុសៈ ទ្រង់ពោលពាក្យណា ទ្រង់មួយអង្គប៉ុណ្ណោះជាធំជាងពួកខ្ញុំ គឺព្រះរាជាទាំង ៧ នគរនេះផង ខ្ញុំផង និងកូនស្រីទាំងឡាយរបស់ខ្ញុំផង ។ បទថា **យទិច្ឆសិ** សេចក្ដីថា ទ្រង់បំណាងព្រះរាជធីតាអង្គណាដើម្បីក្សត្រអង្គណា សូមទ្រង់ប្រទានធីតាអង្គនោះ ដល់ក្សត្រអង្គនោះចុះ ។

ទើបព្រះមហាសត្វ ត្រាស់ឲ្យពួកក្នាក់ងារតាក់តែងព្រះរាជធីតា របស់ស្ដេចមទ្ទរាជទាំង ៧ អង្គនោះ ហើយព្រះរាជទានដល់ព្រះរាជាទាំង ៧ អង្គនោះ ម្នាក់មួយអង្គ ។

ព្រះសាស្ដា កាលទ្រង់ប្រកាសសេចក្ដីនោះ ទើបបានភាសិតគាថា ៥ ថា

ព្រះបាទកុសៈ មានព្រះវាចាសព្ទស្មើនឹងសំឡេងសីហៈ បាន
ប្រទានពួកធីតារបស់ព្រះបាទមទ្ទៈមួយអង្គៗ ដល់ក្សត្រទាំង
នោះ មួយអង្គ ៗ ។ ពួកក្សត្រទាំង ៧ អង្គ មានព្រះហឫទ័យ
ស្កប់ស្កល់ ដោយលាភនោះហើយ ក៏ត្រេកអរចំពោះព្រះបាទ
កុសៈ ដែលមានព្រះសូរវាចាស្មើនឹងសំឡេងសីហៈ បាន
ទៅកាន់ដែនទាំងឡាយរៀងខ្លួន ក្នុងលំដាប់នោះឯង ។

ចំណែកឯព្រះបាទកុសៈមានកម្លាំងច្រើន បាននាំយកនាងបភាវតី និងកែវមណី ឈ្មោះវេរោចនៈដ៏ល្អ ហើយទ្រង់ស្តេចវិលត្រឡប់ទៅកាន់ក្រុងកុសាវតីវិញ ។ ក្សត្រទាំងនោះគង់លើរថជាមួយគ្នា បរសំដៅចូលទៅកាន់ក្រុងកុសាវតី ស្មើគ្នាដោយវណ្ណៈនិងរូប មិនរុងរឿងជាងគ្នាប៉ុន្មានទេ ។ ព្រះមាតាបានជួបជុំដោយបុត្ត ចំណែកអគ្គមហេសី និងព្រះរាជស្វាមីទាំង ២ ព្រះអង្គនោះ បានព្រមព្រៀងគ្នា នៅគ្រប់គ្រងរាជធរណីដ៏សម្បូណ៌សប្បាយក្នុងកាលនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បីណិតា** បានដល់ ទ្រង់ស្កប់ស្កល់ ។ បទថា **ធាយឹសុ** សេចក្តីថា ក្សត្រទាំងនោះ កាលព្រះពោធិសត្វជាធំជាងជនអ្នកកុសៈ ប្រទានឱវាទថា ឥឡូវនេះ អ្នកទាំងឡាយ ចូរកុំប្រមាទចុះ ដូច្នេះហើយ ក៏នាំគ្នាត្រឡប់ទៅ ។ បទថា **អគមាសិ** សេចក្តីថា ចំណែកព្រះបាទកុសរាជ ទ្រង់ស្នាក់នៅ ២-៣ ថ្ងៃ ក៏លាព្រះសស្សុរៈ គឺឪពុកក្មេកថា ទូលព្រះបង្គំនឹងត្រឡប់ទៅកាន់នគររបស់ទូលព្រះបង្គំ ហើយក៏យាងត្រឡប់ ។ បទថា **ឯការថេ យន្តា** បានដល់ ព្រះបាទកុសរាជនិងព្រះនាងបភាវតីទាំង ២ អង្គ យាងឡើងកាន់រាជរថជាមួយគ្នាទៅ ។ បទថា **សមានា វណ្ណរូបេន** សេចក្តីថា ស្មើគ្នាដោយពណ៌សម្បុរនិងព្រះរូបឆោម ។ បទថា **នាញ្ញមញ្ញា - តិរោចិសុំ** សេចក្តីថា មួយអង្គស្អាតជាងមួយអង្គក៏មិនមែន ។ បានឮថា ព្រះមហាសត្វ មានព្រះរូបឆោមស្អាត មានពណ៌សម្បុរដូចមាស គឺដល់នូវភាព

*ជាបុគ្គលប្រសើរដោយលម្អ ព្រោះអានុភាពរបស់កែវមណី ។ បទថា* ***សំគច្ឆិ*** *សេចក្តីថា លំដាប់នោះ ព្រះមាតារបស់មហាសត្វ ទ្រង់ស្តាប់ថា ព្រះមហាសត្វយាងមក ទើបឲ្យពួករាជបុរសវាយស្គរប្រកាសពេញនគរ ហើយកាន់គ្រឿងបណ្ណាការជាច្រើន យាងចេញទៅទទួល ហើយយាងត្រឡប់មកជាមួយគ្នា ។ ព្រះបាទកុសរាជអង្គនោះ ទ្រង់ធ្វើប្រទក្សិណព្រះនគរ មួយអន្ទើ ដោយព្រះជននី ទ្រង់ក្រសាលមហោស្រព ៧ ថ្ងៃ ហើយទ្រង់ឡើងកាន់ប្រាសាទ ដែលប្រដាប់តាក់តែងហើយ ។ ព្រះកស្តានិងព្រះជាយាទាំង ២ អង្គនោះ ក៏មានការសាមគ្គីគ្នាតាំងអំពីនោះមក ព្រះបាទកុសរាជនិងព្រះនាងបភាវតី ក៏ទ្រង់ស្ម័គ្រស្មោះ សាមគ្គីគ្នា ទ្រង់ត្រេកអរ ទ្រង់គ្រប់គ្រងផែនដីឲ្យរុងរឿងដរាបដល់អស់ព្រះជន្មទាំង ២ អង្គ ដោយប្រការដូច្នេះ ។*

*ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុអផ្សុក រូបនោះ ក៏សម្រេចសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា ព្រះជននីនិងព្រះជនករបស់ព្រះបាទកុសរាជក្នុងកាលនោះ បានមកជាត្រកូលមហារាជ ក្នុងកាលឥឡូវនេះ ជយម្បតីដែលជាអនុជរបស់ព្រះបាទកុសរាជក្នុងកាលនោះ បានមកជាអានន្ទ ស្រីគមក្នុងកាលនោះ បានមកជាខុជ្ជុត្តរាឧបាសិកា ព្រះនាងបភាវតីក្នុងកាលនោះ បានមកជា រាហុលមាតា បរិស័ទដ៏សេស ក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ឯព្រះបាទកុសរាជ ក្នុងកាលនោះ គឺតថាគតអរហន្តសម្មាសម្ពុទ្ធនេះឯង ។*

**អដ្ឋកថា កុសជាតក ចប់**

# សោណនន្ទជាតក

[ ១៣៤ ] ( ព្រះរាជាព្រះនាមមនោជៈត្រាស់សួរថា ) លោកជាទេវតា ឬជាគន្ធព្វ ជាសក្កបុរិន្ទទៈឬជាមនុស្សមានឫទ្ធិ ធ្វើដូចម្តេច យើងនឹងស្គាល់លោកបាន ។

[ ១៣៥ ] ( តាបសឈ្មោះនន្ទបណ្ឌិតពោលថា ) អាត្មាភាព មិនមែនជាទេវតា មិនមែនជាគន្ធព្វ មិនមែនជាសក្កបុរិន្ទទៈទេ អាត្មាភាពជាមនុស្សមានឫទ្ធិ បពិត្រព្រះរាជា ទ្រទ្រង់នូវការៈ ( ដែន ) សូមព្រះអង្គជ្រាបយ៉ាងនេះចុះ ។

[ ១៣៦ ] ( ព្រះបាទមនោជៈ... ) ការខ្វល់ខ្វាយ បម្រើមានសភាពដែលលោកដ៏ចម្រើនធ្វើហើយ នេះជាការមិនមែនតិច កាលដែលភ្លៀងកំពុងធ្លាក់ចុះ លោកដ៏ចម្រើនអាចធ្វើមិនឲ្យមានភ្លៀងបាន ។ តពីនោះមក លោកដ៏ចម្រើនអាចធ្វើឲ្យម្លប់ដ៏ត្រជាក់បាន ក្នុងទីមានខ្យល់និងកម្តៅថ្ងៃដ៏ខ្លាំង តពីនោះមក លោកដ៏ចម្រើន អាចធ្វើគ្រឿងការពារព្រួញ ក្នុងកណ្តាលនៃសត្រូវទាំងឡាយបាន ។ តពីនោះមក លោកដ៏ចម្រើនអាចធ្វើដែនទាំងឡាយដ៏សម្បូណ៌ ( និង ) អ្នកដែនទាំងនោះ ឲ្យលុះក្នុងអំណាច ( របស់យើងខ្ញុំ ) តពីនោះមក លោកដ៏ចម្រើនអាចធ្វើក្សត្រ ១០១ ឲ្យជាចំណុះ ( នៃយើងខ្ញុំបាន ) ។ យើងខ្ញុំត្រេកអរនឹងលោកដ៏ចម្រើន លោកចង់បានរតនៈ ( ណា ) ចូរទទួលយករតនៈនោះចុះ យើងខ្ញុំប្រគេនយានដំរី រថសេះ ពួកនាងនារីដែលប្រដាប់ស្រេច ទាំងលំនៅគួរឲ្យត្រេកអរទាំងឡាយ ដល់លោកដ៏ចម្រើន ។ មួយទៀត យើងខ្ញុំប្រគេនដែនអង្គៈឬមគធៈដល់លោកដ៏ចម្រើន មួយទៀត

យើងខ្ញុំ សប្បាយចិត្តប្រគេនដែនអស្សកៈ ឬដែនអវន្តិដល់លោក ។ យើងខ្ញុំ ប្រគេនរាជ្យពាក់កណ្ដាល ដល់លោកដ៏ចម្រើន បើលោកត្រូវការដោយរាជ្យ លោកចង់បានរបស់ណា សូមត្រេកត្រារបស់នោះចុះ ។

[ ១៣៧ ] ( នន្ទបណ្ឌិតតាបស... ) អាត្មាភាព មិនត្រូវការដោយរាជ្យ ដោយនគរ ឬដោយទ្រព្យ ទាំងមិនត្រូវការដោយជនបទទេ ។

[ ១៣៨ ] ក្នុងព្រៃ ក្នុងដែនជាអាណាខេត្តរបស់ព្រះអង្គដ៏ចម្រើន មានអាស្រម ១ បិតាមាតារបស់អាត្មាភាពទាំង ២ នាក់ នៅក្នុងអាស្រមនោះ ។ អាត្មាភាពមិនបានធ្វើបុណ្យចំពោះបុព្វាចារ្យទាំងនោះ យើងធ្វើព្រះអង្គដ៏ចម្រើន ឲ្យប្រសើរលើសលុប ឲ្យសូមនូវការរួបរួមជាមួយនឹងសោណបណ្ឌិតតាបស ។

[ ១៣៩ ] ( ព្រះរាជា... ) បពិត្រព្រាហ្មណ៍ ខ្ញុំធ្វើតាមពាក្យរបស់លោក ដែលលោកពោលនឹងខ្ញុំ សូមលោកប្រាប់ហេតុនោះ ដល់យើងខ្ញុំ តើឲ្យពួកជនប៉ុន្មាននាក់ ជាអ្នកជួយអង្វរករ ។

[ ១៤០ ] ( នន្ទបណ្ឌិតតាបស... ) ពួកគហបតីមហាសាលជាង ១០០ ពួកព្រាហ្មណ៍មហាសាលជាង ១០០ នឹងពួកក្សត្រទាំងអស់ ដែលមានជាតិដ៏ខ្ពស់ មានយសនេះ ទាំងព្រះបាទមនោជៈដ៏ចម្រើន ទើបល្មមជាអ្នកជួយអង្វរករ ។

[ ១៤១ ] ( ព្រះរាជា... ) ពួកអ្នករក្សាដំរី ពួកអ្នករក្សាសេះ ចូរនាំគ្នាចាត់ចែងនូវពួកដំរី ពួកសេះ ម្នាលសារថី អ្នកចូរជ្រាមរថ អ្នកទាំងឡាយចូរយកគ្រឿងប្រដាប់សម្រាប់ចង ( ឯដំរីសេះរថ ) ជនទាំងឡាយ ចូរលើក

ទន់ជ័យត្រង់ជើង ទន់ជ័យដែលតម្កល់លើរថ អញនឹងទៅកាន់អាស្រមជាទីនៅនៃកោសិយគោត្ត ។

[ ១៤២ ] ( អភិសម្ពុទ្ធគាថា ) លំដាប់ពីនោះមក ព្រះរាជាបានយាងទៅដោយសេនាប្រកបដោយអង្គ ៤ ទ្រង់ស្តេចទៅកាន់អាស្រមជាទីរីករាយជាទីនៅនៃកោសិយគោត្ត ។

[ ១៤៣ ] ( ព្រះបាទមនោជៈ... ) ដងរែក ជាវិការៈនៃឈើក្តម្ពរបស់អ្នកណា ដែលទៅដងទឹកហើយមិនប៉ះពាល់ស្មាទៅលើអាកាសចំនួន ៤ ធ្នាប់ ។

[ ១៤៤ ] ( ព្រះមហាសត្ត... ) បពិត្រមហារាជ អាត្មាភាពជាតាបសឈ្មោះសោណៈ ប្រកបដោយវត្ត មិនខ្ជិលច្រអូស ចិញ្ចឹមមាតាបិតា ទាំងយប់ទាំងថ្ងៃ បពិត្រព្រះអង្គ ជាម្ចាស់នៃទិស អាត្មាភាពរឭកឃើញឧបការៈដែលមាតាបិតាធ្វើក្នុងកាលមុន ហើយក៏យកផ្លែឈើនិងមើមឈើក្នុងព្រៃ មកចិញ្ចឹមមាតាបិតា ។

[ ១៤៥ ] ( ព្រះរាជា... ) យើងខ្ញុំចង់ទៅកាន់អាស្រម ជាទីនៅរបស់កោសិយគោត្ត បពិត្រព្រះសោណៈ សូមលោកម្ចាស់ប្រាប់ផ្លូវដល់យើង យើងនឹងទៅកាន់អាស្រម ។

[ ១៤៦ ] ( ព្រះមហាសត្ត... ) បពិត្រព្រះរាជា ផ្លូវដើរចុះតែជើង ១ នេះ មានព្រៃមានពណ៌ដូចជាផ្ទៃមេឃ ដ៏ដេរដាសដោយដើមរលួសផ្អុន ទុំៈ ជាទីនៅរបស់កោសិយគោត្ត ។

[ ១៤៧ ] ( អភិសម្ពុទ្ធគាថា ) លុះមហាឥសីពោលពាក្យនេះទូល

ប្រាប់ពួកក្សត្រហើយ ប្រញាប់ប្រញាល់ចៀសចេញទៅ ( កាន់ស្រះអនោ-តត្ត ) តាមអាកាសវេហាស៍ មហាឥសី ក៏បោសសម្អាតអាស្រម រៀបចំអាសនៈ ចូលទៅកាន់បណ្ណសាលាហើយ ជម្រាបបិតាឲ្យជ្រាបថា បពិត្រមហាឥសី ព្រះរាជាទាំងនេះ មានជាតិខ្ពស់ មានយស យាងមកសូមព្រះបិតាចេញអំពីអាស្រមមកគង់ចាំទទួល ។ មហាឥសីឮពាក្យនោះ របស់កូននោះហើយ ក៏ប្រញាប់ប្រញាល់ចេញអំពីអាស្រមមកអង្គុយជិតទ្វារ ។

[ ១៤៨ ] កោសិយគោត្តតាបស បានឃើញស្តេចនោះ ដូចជារុងរឿងដោយតេជៈ មានពួកក្សត្រហែហម កំពុងយាងមក ហើយបានពោលពាក្យនេះថា ស្គរសម្ភោរ ស័ង្ខ ស្គរតូច និងមហោរធឹករបស់អ្នកណា ញុំាងស្តេចជាបុគ្គលប្រសើរលើរថ ឲ្យរីករាយទៅខាងមុខ ។ ( ទីបំផុតថ្ងាស ) នៃអ្នកណា ( បិទបាំង ) ដោយជំបារមាសដ៏ធំ មានពណ៌ដូចជាផ្លេកបន្ទោរបុរសកម្លោះណា សៀតបំពង់ព្រួញ រុងរឿងដោយសិរីហើយដើរមក ។ អ្នកណាមានមុខរុងរឿងភ្លឺចាំងដូចជាមាសភ្លឺចិញ្ចាច ត្រង់មាត់បាវ ស្រដៀងនឹងរងើកភ្លើងនៃឧសគគីរ រុងរឿងដោយសិរី ហើយដើរមក ។ អ្នកណា បាំងឆត្រព្រមទាំងធ្អឹងជាទីរីករាយនៃចិត្ត ការពាររស្មីព្រះអាទិត្យ អ្នកណា រុងរឿងដោយសិរី ហើយដើរមក ។ ពួកជនបិទបាំងជុំវិញខ្នងនៃអ្នកណាដែលមានបុណ្យដ៏ប្រសើរ កំពុងជិះលើកនៃដំរី ដោយផ្លិតរោមសត្វដ៏ឧត្តម ហើយដើរទៅ ។ ពួកឆត្រសនិងពួកអាជានេយ្យប្រដាប់ដោយក្រោះខ្នាន់ខ្នាប់ជុំវិញនៃអ្នកណា អ្នកណារុងរឿងដោយសិរី ហើយដើរមក ។ ពួកក្សត្រមួយរយ

មួយ សុទ្ធតែមានយស ជាស្តេចចំណុះ ដើរហែហមជុំវិញនៃអ្នកណា អ្នកណារុងរឿងដោយសិរីដើរមក ។ ពួកសេនាប្រកបដោយអង្គ ៤ គឺដំរី ១ សេះ ១ រថ ១ ពលថ្មើរជើង ១ ដើរហែហមជុំវិញ ( នៃអ្នកណា ) អ្នកណារុងរឿងដោយសិរីដើរមក ។ សេនាដ៏ធំនេះ មិនមានអ្នកណាមួយឲ្យរំកើបបាន មិនមានទីបំផុតដូចជារលកនៃសាគរ ប្រព្រឹត្តទៅតាមខាងក្រោយនៃអ្នកណា ។

[ ១៤៩ ] ( ព្រះមហាសត្ត... ) ព្រះបាទមនោជៈ ជាព្រះរាជាប្រសើរជាងពួកព្រះរាជា ដូចជាព្រះឥន្ទ ជាធំជាងពួកទេវតា ក្នុងឋានត្រៃត្រិង្ស ដែលមានជ័យជម្នះ បានដល់នូវភាពជាបរិស័ទនៃនទូតាបស មកកាន់អាស្រមនៃពួកព្រហ្មចារីបុគ្គល ( ដើម្បីខមាទោសនឹងយើង ) ។ សេនាដ៏ធំនេះ មិនមានអ្នកណាមួយឲ្យរំកើបបាន មិនមានទីបំផុតដូចជារលកនៃសាគរ ប្រព្រឹត្តទៅតាមខាងក្រោយនៃព្រះបាទមនោជៈនោះ ។

[ ១៥០ ] ( អភិសម្ពុទ្ធគាថា ) ពួកព្រះរាជាទាំងអស់ លាបស្រឡាបដោយខ្លឹមចន្ទន៍ទ្រង់កាសិកពស្ត្រដ៏ឧត្តមបានផ្គងអញ្ជលីចូលទៅរកពួកឥសី ។

[ ១៥១ ] ( ព្រះបាទមនោជៈ... ) លោកដ៏ចម្រើន មានសេចក្តីសុខស្រួលទេឬ លោកដ៏ចម្រើនមានអនាម័យទេឬ លោកទាំងឡាយចិញ្ចឹមជីវិតដោយការស្វែងរកឬ មើមឈើនិងផ្លែឈើមានច្រើនដែរឬ ។ ពួករបោម មូស ពស់ មានតិចតួចដែរឬ ក្នុងព្រៃដ៏ដេរដាសដោយម្រឹគសាហាវ មិនបៀតបៀនទេឬ ។

[ ១៥២ ] ( កោសិយគោត្ត... ) បពិត្រព្រះរាជា អាត្មាភាពមាន

សេចក្ដីស្រួលទេ បពិត្រព្រះរាជា មួយទៀត អាត្មាភាពមិនមានសេចក្ដីឈឺចាប់ទេ អាត្មាភាព ចិញ្ចឹមជីវិតដោយការស្វែងរក ( ផលាផល ) ស្រួលទេ ទាំងមើមឈើនិងផ្លែឈើ ក៏មានច្រើន ។ មួយទៀត ពួករបោម មូស ពស់ ក៏មានតិចតួចទេ ក្នុងព្រៃដ៏ដេរដាសដោយម្រឹគសាហាវ ក៏មិនបៀតបៀនអាត្មាភាពទេ ។ អាត្មាភាព មកនៅក្នុងអាស្រមនេះ អស់ប្រជុំនៃឆ្នាំជាច្រើន មិនដែលស្គាល់អាពាធ មិនជាទីត្រេកអរនៃចិត្តកើតឡើងទេ ។ បពិត្រមហារាជ ព្រះអង្គយាងមកល្អហើយ មួយទៀត ព្រះអង្គមិនមែនយាងមក អាក្រក់ទេ ព្រះអង្គជាឥស្សរៈ យាងមកដល់ហើយ វត្ថុណាមានក្នុងទីនេះ សូមព្រះអង្គមានព្រះបន្ទូល ។ បពិត្រព្រះរាជា សូមព្រះអង្គសោយផ្លែទន្លាប់ ផ្លែទ្រយឹង ផ្លែស្រគំ ផ្លែមាក់ដោក មានរសឆ្ងាញ់ពិសា ដូចជាទឹកឃ្មុំ ។ ទឹកត្រជាក់នេះ អាត្មាភាព បានដងមកអំពីជ្រោះភ្នំ បពិត្រមហារាជ សូមព្រះអង្គសោយទឹកនោះចុះ ប្រសិនបើទ្រង់ត្រូវការ ។

[ ១៥៣ ] ( ព្រះរាជា... ) របស់ណាដែលលោកឲ្យហើយ ( របស់នោះ ) ឈ្មោះថា យើងខ្ញុំទទួលហើយ ទាំងបានធ្វើឲ្យជាជំនូនដល់ជនទាំងពួង លោកទាំងឡាយចូរស្ដាប់ពាក្យនទ្ទបណ្ឌិតតាបស លោកនឹងនិយាយឥឡូវនេះ ពួកយើងជាបរិស័ទនៃនទ្ទបណ្ឌិតតាបស បានមកកាន់សំណាក់នៃលោកដ៏ចម្រើន សោណបណ្ឌិតដ៏ចម្រើន ចូរស្ដាប់ពាក្យនៃខ្ញុំផង នៃបរិស័ទរបស់នទ្ទបណ្ឌិតតាបសផង ។

[ ១៥៤ ] ( នទ្ទបណ្ឌិតតាបស... ) ពួកគហបតិមហាសាលជាងមួយរយ

ពួកព្រាហ្មណមហាសាលជាងមួយរយ និងពួកក្សត្រទាំងអស់ ដែលមានជាតិខ្ពស់ មានយសនេះ ទាំងព្រះបាទមនោជៈដ៏ចម្រើន សូមជ្រាបតាមសំដីរបស់អាត្មាភាពចុះ ។ ពួកជនដែលមកជួបជុំគ្នា ពួកយក្ស ពួកភូតនិងទេវតា ក្មេងមានក្នុងអាស្រមក្នុងព្រៃនេះ ចូរស្តាប់នូវពាក្យរបស់អាត្មា ។ អាត្មាធ្វើនមស្ការដល់ពួកភូតហើយ នឹងនិយាយចំពោះឥសី ( ឈ្មោះសោណបណ្ឌិត ) ដែលមានវត្តល្អថា ខ្ញុំនោះហើយដែលកោសិយគោត្តសន្មតថា ជាដើមដៃស្តាំរបស់លោក ។ បពិត្រអ្នកមានព្យាយាម ការទំនុកបម្រុងមាតាបិតានេះ ជាបុណ្យរបស់ខ្ញុំ ដែលជាអ្នកប្រាថ្នាចិញ្ចឹមបិតានិងមាតារបស់ខ្ញុំ បពិត្រព្រះកោសិយៈ សូមលោកកុំឃាត់ខ្ញុំឡើយ ។ ការទំនុកបម្រុងមាតាបិតានុ៎ះ ពួកសប្បុរសបានដឹងហើយ សូមលោកលះនូវការទំនុកបម្រុងមាតាបិតានេះឲ្យដល់ខ្ញុំ លោកបានធ្វើ ( កុសល ) ដោយការខ្នះខ្នែងនិងការបម្រើយូរយារណាស់មកហើយ ( ឥឡូវនេះខ្ញុំចង់ធ្វើ ) បុណ្យទាំងឡាយដល់មាតានិងបិតា សូមលោកប្រគល់សួគ៌ទេវលោកដល់ខ្ញុំ ។ បពិត្រឥសី លោកដឹងផ្លូវទៅកាន់សួគ៌ទេវលោកយ៉ាងណា ពួកមនុស្សក៏ដឹងចំណែកធម៌ក្នុងធម៌ក៏យ៉ាងនោះដែរ ។ កិរិយានាំមកនូវសេចក្តីសុខដល់មាតាបិតា ដោយការខ្នះខ្នែងនិងការបម្រើឥឡូវនេះ ជន ( សោណបណ្ឌិត ) ហាមឃាត់ខ្ញុំនោះចាកបុណ្យ ឈ្មោះថាជាអ្នករាំងផ្លូវដ៏ប្រសើរ ( ឋានសួគ៌ ) ។

[ ១៥៥ ] ( ព្រះមហាសត្ត ... ) លោកដ៏ចម្រើនទាំងឡាយ ដែលជាបរិស័ទនៃប្អូនរបស់ខ្ញុំ សូមស្តាប់ពាក្យរបស់ខ្ញុំ បពិត្រមហារាជ អ្នកណា

មិនប្រព្រឹត្តធម៌ ចំពោះបុគ្គលជាច្បងទាំងឡាយ ញុំាងប្រវេណីពីបុរាណឲ្យសាបសូន្យ អ្នកនោះរមែងទៅកើតក្នុងនរក ។ បពិត្រព្រះអង្គជាម្ចាស់នៃទិសពួកជនណាឈ្លាសវៃក្នុងធម៌ ( ជេដ្ឋាបចាយនធម៌ ) ជាប្រវេណីអំពីបុរាណ ព្រមទាំងបរិបូណ៌ដោយសណ្ដាប់ធ្នាប់ ពួកជននោះ រមែងមិនទៅកាន់ទុគ្គតិទេ ។ បពិត្រព្រះអង្គជាអ្នកទ្រទ្រង់នូវបន្ទុក ( ដែន ) សូមព្រះអង្គជ្រាបយ៉ាងនេះថា មាតាបិតា បងប្អូនប្រុសស្រី ញាតិនិងផៅពង្សទាំងអស់នោះ ជាភារៈរបស់កូនច្បង ។ បពិត្រព្រះអង្គជាបុគ្គលប្រសើរលើរថ អាត្មាភាពដូចជានាយសំពៅ អាចនាំយកនូវភារៈដ៏ធ្ងន់ អាត្មាភាព ពុំប្រមាទនូវជេដ្ឋាបចាយនធម៌ទេ ព្រោះអាត្មាភាពជាច្បង ។

[ ១៥៦ ] ( ព្រះរាជាទាំងឡាយ... ) ពួកយើងបានញាណ ដូចបុគ្គលបានអណ្ដាតភ្លើងអំពីភ្លើងក្នុងទីងងឹត កោសិយតាបសដ៏ចម្រើន បានចុះបញ្ចាំងធម៌ដល់ពួកយើង យ៉ាងនេះឯង ។ ព្រះអាទិត្យដែលបំភ្លឺនូវទ្រព្យ ធ្វើពន្លឺកាលរះឡើង តែងចុះបញ្ចាំងនូវរូបល្អអាក្រក់ ដល់សត្វទាំងឡាយយ៉ាងណា កោសិយៈដ៏ចម្រើន បានចុះបញ្ចាំងនូវធម៌ដល់ពួកយើង ក៏យ៉ាងនោះដែរ ។

[ ១៥៧ ] ( នន្ទបណ្ឌិតតាបស... ) កាលបើខ្ញុំអង្វរយ៉ាងនេះហើយ លោកនៅតែមិនទទួលអញ្ជលី ខ្ញុំនឹងជាអ្នកប្រព្រឹត្តតាមពាក្យ ជាអ្នកប្រឹងបម្រើលោក ។

[ ១៥៨ ] ( ព្រះមហាសត្វ... ) ម្នាលនន្ទ អ្នកស្គាល់ច្បាស់នូវព្រះសទ្ធម្មដែលពួកសប្បុរសសម្ដែងហើយមែន អ្នកជាមនុស្សល្អ មានឫកពា

ល្អ ត្រូវចិត្តយើងហើយ ។ ខ្ញុំសូមនិយាយនឹងបិតាដ៏ចម្រើន និងមាតាដ៏ចម្រើន សូមលោកទាំងឡាយស្តាប់ពាក្យរបស់ខ្ញុំ ភារៈនេះមិនមែនគ្រាន់តែជាភារៈរបស់ខ្ញុំក្នុងកាលម្តងៗទេ ។ នន្ទៈធ្វើនូវខ្ញុំ ដែលជាអ្នកបម្រើ នាំមកនូវសេចក្តីសុខដល់មាតានិងបិតានោះ ឲ្យជាធំហើយ សូមដើម្បីការបម្រើដែរ ។ បណ្តា ( មាតានិងបិតា ) ជាព្រហ្មចារី បើលោកណាម្នាក់ចង់បាន សូមលោកទទួលយកនន្ទៈ តាមប្រាថ្នាចុះ តើឲ្យនន្ទបម្រើលោកណា ។

[ ១៥៩ ] ( មាតា... ) នែសោណៈកូន យើងអាស្រ័យនឹងអ្នក អ្នកអនុញ្ញាតហើយ គួរបានដើម្បីចូលទៅថើបក្បាលនន្ទៈ ជាព្រហ្មចារី ។

[ ១៦០ ] ដួងហឫទ័យរបស់ម្តាយរំជួល ព្រោះខានឃើញនន្ទៈអស់កាលយូរហើយ ដូចជាស្លឹកខ្ចីរបស់អស្សត្ថព្រឹក្ស ដែលត្រូវខ្យល់បក់ ។ វេលាណា ម្តាយដេកលក់ យល់សប្តិឃើញនន្ទៈមក ក៏មានចិត្តត្រេកអរ មានចិត្តរីករាយ ( ដោយគិតថា ) នន្ទៈរបស់យើងនេះមកហើយ វេលាណា ម្តាយភ្ញាក់ឡើង មិនឃើញនន្ទៈមកទេ សេចក្តីសោកនិងទោមនស្សជាច្រើនរឹងរឹតតែបណ្តាលឡើង ។ យូរណាស់ហើយ ស្រាប់តែក្នុងថ្ងៃនេះ ម្តាយនោះឃើញនន្ទៈមកដល់ នន្ទជាទីស្រឡាញ់នៃស្វាមីរបស់ម្តាយផង នៃម្តាយផង បានចូលមកកាន់ផ្ទះរបស់ពួកយើង ។ នន្ទៈជាទីស្រឡាញ់ក្រៃលែងរបស់បិតា កុំឲ្យនន្ទៈទៅប្រាសចេញអំពីផ្ទះ នែកូន ឯនន្ទៈ ( ចង់បានអ្នកណា ) ចូរបានអ្នកនោះចុះ នន្ទៈចូរបម្រើនូវអញចុះ ។

[១៦១] ( ព្រះមហាសត្ត... ) ម្នាលឥសី មាតាជាអ្នកឈឺឆ្អាល ជា

ទីពឹង ជាអ្នកឲ្យរស ( ទឹកក្សីរៈ ) ដល់ពួកយើងជាមុន ជាផ្លូវនៃសួគ៌ទេវលោកចង់បានអ្នក ។ មាតាជាអ្នកឲ្យរសជាមុន ជាអ្នកគ្រប់គ្រងដែលយើងចូលទៅអាស្រ័យបុណ្យ ជាផ្លូវនៃសួគ៌ទេវលោក ម្នាលឥសី មាតាចង់បានអ្នក ។

[ ១៦២ ] មាតាកាលប្រាថ្នាចង់បានផ្លែពីកូន រមែងនមស្ការទេវតា សួរនក្ខត្តឫក្សទាំងឡាយផង សួររដូវនិងឆ្នាំទាំងឡាយផង ។ កាលមាតានោះ មានរដូវលាងស្អាតហើយ សត្វក៏ចុះមកកាន់គភ៌ស៊ប់ មាតាជាស្ត្រីមានសេចក្តីចាញ់ផ្ទៃដោយហេតុនេះ ព្រោះហេតុនោះ បានជាបណ្ឌិតហៅថា សុហទា ( មានដួងហឫទ័យល្អ ) ។ មាតារក្សា ( ផ្ទៃ ) អស់ ១ ឆ្នាំ ឬថយពី ១ ឆ្នាំ ហើយប្រសូតបុត្តមក ព្រោះហេតុនោះ បានជាបណ្ឌិត ហៅមាតានោះថា ជនយន្តីផង ជនេត្តីផង ( អ្នកបង្កើតកូន ) មាតាញុំាងកូនដែលកំពុងយំ ឲ្យត្រេកអរ ដោយទឹកក្សីរៈផង ដោយការបំពេផង ដោយការឱបក្រសោបផង ព្រោះហេតុនោះ បានជាបណ្ឌិតហៅថា តោសេន្តី ( អ្នកញុំាងកូនឲ្យត្រេកអរ ) ។ តពីនោះមក មាតាធ្វើនូវសេចក្តីស្រឡាញ់រាប់អាន ហើយក្រឡេកមើលទារកដែលនៅពុំទាន់ដឹងក្តី ក្នុងទីមានខ្យល់និងកម្តៅថ្ងៃដ៏ពន្លឹក ព្រោះហេតុនោះបានជាបណ្ឌិតហៅថា បោសេន្តី ( អ្នកចិញ្ចឹមកូន ) ។ ទ្រព្យណាខាងមាតាផង ទ្រព្យណាខាងបិតាផង មាតាក៏គ្រប់គ្រងទ្រព្យទាំង ២ ចំណែក ដើម្បីកូននោះ ( ដោយបំណងថា ទ្រព្យនេះ ) ត្រូវមានដល់កូនរបស់យើង ។ មាតារមែងលំបាក ដោយការបង្ហាត់បង្រៀនកូនដូច្នេះថា ម្នាលកូន ( ឯង

ចូរកុំប្រមាទក្នុងរាជត្រកូលជាដើម ) យ៉ាងនេះ ម្នាលកូន ( ឯងចូរធ្វើការ ) ឯណោះ ។ កាលបើកូនមានវ័យចម្រើនឡើងហើយ មាតា ( បានដឹង ) កូននោះប្រមាទ ក្នុងប្រពន្ធរបស់អ្នកដទៃ ក្នុងពេលអធ្រាត្រ ហើយមិនមក ក្នុងវេលាល្ងាច ក៏រមែងលំបាកចិត្តដូច្នេះ ។ សត្វដែលមាតាចិញ្ចឹម ដោយត្រដាបត្រដួសយ៉ាងនេះ ហើយមិនបម្រើមាតា ប្រព្រឹត្តខុសក្នុងមាតានោះ តែងទៅកើតក្នុងនរក ។ សត្វដែលបិតាចិញ្ចឹមដោយត្រដាបត្រដួសយ៉ាងនេះ ហើយមិនបម្រើបិតា ប្រព្រឹត្តខុសក្នុងបិតានោះ តែងទៅកើតក្នុងនរក ។ យើងបានឮមកថា សូម្បីតែទ្រព្យរបស់កូនអ្នកចង់បានទ្រព្យ តែងវិនាសទៅវិញ ឬកូននោះរមែងក្រីក្រលំបាកព្រោះមិនបម្រើមាតា ។ យើងបានឮមកថា សូម្បីតែទ្រព្យរបស់កូនអ្នកចង់បានទ្រព្យ តែងវិនាសទៅវិញ ឬកូននោះរមែងក្រីក្រលំបាក ព្រោះមិនបម្រើបិតា ។ បណ្ឌិតបម្រើមាតា គប្បីបាននូវសុខនុ៎ះ គឺសេចក្តីត្រេកអរក្នុងរាយ ការសើចលេងសព្វៗកាល ។ បណ្ឌិតបម្រើបិតា គប្បីបាននូវសុខនុ៎ះ គឺសេចក្តីត្រេកអរក្នុងរាយ ការសើចលេងសព្វៗកាល ។ ទាន ១ វាចាជាទីស្រឡាញ់ ១ ការប្រព្រឹត្តជាប្រយោជន៍ក្នុងលោកនេះ ១ ភាពនៃបុគ្គលមានខ្លួនប្រព្រឹត្តស្មើក្នុងជេដ្ឋាបចាយនធម៌នោះ ៗ តាមសមគួរ ១ ។ សង្គហធម៌ទាំង ៤ នុ៎ះឯង រមែងប្រព្រឹត្តទៅក្នុងលោក ដូចជាផ្ចិតនៃកង់រថ ដែលវិលទៅ បើសង្គហធម៌ទាំងនុ៎ះមិនមានទេ មាតាមិនត្រូវបាននូវសេចក្តីរាប់អាននិងការបូជា ព្រោះហេតុនៃកូនទាំងបិតាក៏មិនត្រូវបាននូវសេចក្តីរាប់អាននិងការបូជា ព្រោះហេតុនៃកូន ពួកបណ្ឌិតរមែងឃើញដោយ

ល្អនូវសគ្គហធម៌ទាំងនុ៎ះ ព្រោះហេតុនោះ បណ្ឌិតទាំងនោះ រមែងដល់នូវភាពជាធំ ទាំងជាអ្នកគួរសរសើរ ។ មាតាបិតាជាអ្នកអនុគ្រោះដល់ពួកសត្វ គឺបុត្ត បណ្ឌិតហៅថា ព្រហ្មផង បុព្វាចារ្យផង អាហុនេយ្យៈផង របស់កូនទាំងឡាយ ។ ព្រោះហេតុនោះ បណ្ឌិតគប្បីនមស្ការ ធ្វើសក្ការៈចំពោះមាតាបិតានោះ ដោយបាយ ទឹក សំពត់ ទីដេក គ្រឿងអប់ ដោយការផ្ងូតនិងការលាងជើង ។ បណ្ឌិតទាំងឡាយ រមែងសរសើរនូវបុគ្គលនោះ ព្រោះតែការបម្រើចំពោះមាតាបិតានោះ លុះបុគ្គលនោះ លះលោកនេះទៅ រមែងរីករាយក្នុងឋានសួគ៌ ។

**ចប់ សោណនន្ទជាតកទី ២ ។**

**ឧទ្ទាននៃសត្តតិនិបាតនោះគឺ**

រឿងព្រះរាជាប្រសើរ ក្នុងក្រុងកុសាវតី ក្នុងនិបាតដ៏ប្រសើរ គម្រប់ចិតសិប និងរឿងសោណតាបស និងនន្ទតាបសដ៏ប្រសើរក្នុងសូត្រគម្រប់ចិតសិប ។

**ចប់ សត្តតិនិបាត ។**

# អដ្ឋកថា

## សោណនន្ទជាតក

[ ១៣៤-១៦២ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុចិញ្ចឹមមាតាមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ទេវតា នុសិ** ដូច្នេះជាដើម ។

ផ្ទៃរឿងនៃជាតកនេះ ដូចគ្នានឹងរឿងសុវណ្ណសាមជាតកនោះឯង ។

ក្នុងកាលនោះ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកកុំតិះដៀលភិក្ខុរូបនេះឡើយ បណ្ឌិតក្នុងកាលមុន សូម្បីបានរាជសម្បត្តិក្នុងជម្ពូទ្វីបទាំងមូល ក៏មិនព្រមទទួលយករាជសម្បត្តិនោះ សុខចិត្តចិញ្ចឹមមាតាបិតាតែម្យ៉ាង ហើយទ្រង់នាំអតីតនិទានមកត្រាស់ថា

ក្នុងអតីតកាល នគរពារាណសី មានឈ្មោះថា ព្រហ្មវឌ្ឍនៈ ព្រះរាជាមាននាមថា មនោជៈ សោយរាជសម្បត្តិក្នុងនគរនោះ ។ មានព្រាហ្មណមហាសាលម្នាក់ មានទ្រព្យសម្បត្តិ ៨០ កោដិ តែជាអ្នកមិនមានកូន នៅអាស្រ័យក្នុងនគរនោះ ។ នាងព្រាហ្មណីជាភរិយារបស់ព្រាហ្មណ៍នោះ កាលព្រាហ្មណ៍ជាស្វាមីនោះពោលថា នែនាង ចូរនាងប្រាថ្នាកូនចុះ ដូច្នេះ ក៏បានប្រាថ្នាហើយ កាលនោះ ព្រះពោធិសត្វចុតិអំពីព្រហ្មលោក បដិសន្ធិក្នុងផ្ទៃរបស់ព្រាហ្មណីនោះ កាលកុមារនោះកើតហើយ មាតាបិតាក៏តាំងឈ្មោះថា សោណកុមារ ។ ក្នុងកាលសោណកុមារនោះចេះដើរ សត្វដទៃ ក៏ចុតិអំពីព្រហ្មលោក បដិសន្ធិក្នុងផ្ទៃរបស់ព្រាហ្មណីនោះទៀត មាតាបិតាដាក់ឈ្មោះកុមារនោះថា នន្ទកុមារ កាលកុមារទាំង ២ នោះរៀនទូវវេទ រហូតដល់ចប់

ការសិក្សាសិល្បសាស្ត្រទាំងអស់ហើយ ព្រាហ្មណ៍ជាបិតា ឃើញរូបសម្បត្តិដែលចម្រើនវ័យ ទើបហៅព្រាហ្មណីមកពោលថា នែនាង អញនឹងចងសោណកុមារកូនប្រុសរបស់យើងទុកដោយចំណង គឺផ្ទះ នាងទទួលថា សាធុ ហើយប្រាប់សេចក្តីនោះឲ្យបុត្តជ្រាប ។ សោណកុមារនោះ ក៏ពោលថា កុំឡើយ ការនៅគ្រប់គ្រងផ្ទះសម្រាប់ខ្ញុំ មិនមានឡើយ ខ្ញុំនឹងបជិបត្តិលោកពុកអ្នកម្តាយ ដរាបដល់អស់ជីវិត កាលលោកឪពុកអ្នកម្តាយអនិច្ចកម្មទៅ នឹងចូលព្រៃហិមពាន្តបួស ។ ព្រាហ្មណី ក៏ប្រាប់សេចក្តីនោះ ដល់ព្រាហ្មណ៍ឲ្យជ្រាប ។ សូម្បីជនទាំង ២ នោះពោលរឿយៗ ក៏មិនបានទូវការយល់ព្រមអំពីសោណកុមារនោះ ទើបហៅនន្ទកុមារមកពោលថា នែកូន បើដូច្នោះ ចូរកូនគ្រប់គ្រងទ្រព្យសម្បត្តិចុះ កាលនន្ទកុមារពោលថា ខ្ញុំមិនឱនក្បាលទទួលទឹកមាត់ដែលបងប្រុសខ្ជាក់ចោលឡើយ ខ្ញុំកាលលោកឪពុកនិងអ្នកម្តាយស្លាប់ហើយ ក៏ចេញបួសជាមួយបងប្រុសដូចគ្នា ស្តាប់ពាក្យរបស់កូនប្រុសទាំង ២ នោះ ហើយ ទើបទាំំគ្នាគិតថា កូនប្រុសទាំង ២ នេះ កំពុងនៅកំលោះយ៉ាងនេះ ក៏លះកាមារម្មណ៍ទាំងឡាយចេញបាន នឹងពោលថ្វី ដល់ពួកយើង ពួកយើងនាំគ្នាបួសឲ្យអស់ចុះ ទើបនិយាយនឹងកូនទាំង ២ ថា នែកូន កាលម៉ែនិងពុកមិនមានជីវិតហើយ ការបួសរបស់ឯងទាំង ២ នឹងមានប្រយោជន៍អ្វី យើងទាំងអស់គ្នា នឹងចេញបួសព្រមគ្នា ក្នុងកាលឥឡូវនេះចុះ ហើយក្រាបទូលដល់ព្រះរាជា លះទ្រព្យទាំងអស់ទៅជាទាន ធ្វើជនជាទាសៈ ឲ្យបានជាអ្នកជា បញ្ជូនរបស់ដែលគួរឲ្យដល់ញាតិ ជនទាំង ៤

នាក់ចេញអំពីនគរ ព្រហ្មវឌ្ឍនៈ សាងអាស្រមក្នុងព្រៃដែលគួរត្រេកអរ អាស្រ័យស្រះ ដែលដេរដាសដោយផ្កាឈូក ៥ ពណ៌ ក្នុងហិមវន្តប្បទេស ហើយបព្វជ្ជា អាស្រ័យនៅក្នុងអាស្រមនោះ ។ ព្រះសោណៈនិងព្រះនន្ទៈ ទាំង ២ នោះ នាំគ្នាបដិបត្តិមាតាបិតា ក្រោកអំពីព្រឹក រៀបចំឈើស្ទន់ និងទឹកលុបមុខ ឲ្យដល់ជនទាំង ២ ហើយ ទៅបោសបណ្ណសាលានិងបរិវេណអាស្រម តម្កល់ទឹកឆាន់ទុកស្រេចហើយ នាំគ្នាទៅបេះផ្លែឈើតូចធំ ដែលមានរសឆ្ងាញ់មកអំពីព្រៃ នាំមកឲ្យមាតាបិតាបរិភោគ លុះដល់ថ្ងៃក្តៅ ក៏ដងទឹកត្រជាក់មកងូតឲ្យជម្រះផ្ទួងសក់ឲ្យស្អាត ធ្វើនូវការគក់ប្របាច់ជាដើមដល់មាតាបិតាទាំង ២ នោះ ។

ដោយការបដិបត្តិយ៉ាងនេះ ក្នុងកាលកន្លងទៅយូរ គ្រាមួយ នន្ទបណ្ឌិតត្រិះរិះថា យើងនឹងឲ្យមាតាបិតាបានបរិភោគផ្លែឈើតូចធំ ដែលអញរកបានមកមុន ។ ទើបប្រញាប់ទៅមុនបងប្រុសអំពីព្រលឹម បេះផ្លែឈើតូចធំតាមដែលរកបានមក អំពីទីដែលខ្លួនធ្លាប់បេះ កាលពីម្សិលមិញខ្លះ ម្សិលម៉្ងៃខ្លះ ហើយប្រញាប់នាំមកឲ្យមាតាបិតាបរិភោគមុន ។ មាតាបិតាបរិភោគផ្លែឈើ ហើយខ្ពុរមាត់រក្សាឧបោសថ ។ ឯសោណបណ្ឌិតទៅកាន់ទីឆ្ងាយ បេះផ្លែឈើតូចធំ មានរសឆ្ងាញ់ ទុំល្អ ហើយនាំមកឲ្យ ។ លំដាប់នោះ មាតាបិតា ក៏ពោលនឹងសោណបណ្ឌិតនោះថា នែកូន អញបានបរិភោគផ្លែឈើដែលប្អូនប្រុសរបស់ឯង រកមកឲ្យ ស្រេចបាច់អំពីព្រលឹម សមាទានឧបោសថហើយ ឥឡូវនេះ យើងមិនត្រូវការ ។ ផ្លែឈើល្អៗរបស់សោណតាបសនោះ មិន

មានអ្នកណាបរិភោគឡើយ ចេះតែស្អុយរលួយទៅ ដោយប្រការដូច្នេះ ។ សូម្បីក្នុងថ្ងៃបន្ទាប់មក ក៏យ៉ាងនោះដូចគ្នា សោណតាបសនោះ អាចទៅកាន់ទីឆ្ងាយៗ ហើយនាំផ្លែឈើមកបាន ដោយប្រការដូច្នេះ ព្រោះលោកបានអភិញ្ញា ៥ ប្រការ តែមាតាបិតាក៏មិនបានបរិភោគ ។ លំដាប់នោះ ព្រះមហាសត្វក៏គិតថា មាតាបិតារបស់អញជាសុខុមាលជាតិ នន្ទះទៅរកផ្លែឈើតូចខ្លះ ធំខ្លះ ខ្ចីខ្លះ ទុំខ្លះ មកឲ្យលោកបរិភោគ កាលបើដូច្នេះ អ្នកទាំង ២ នេះ ក៏មិនរស់នៅបែបនេះ បានយូរឡើយ អញត្រូវឃាត់នន្ទះ ។ សម័យនោះ សោណបណ្ឌិត ក៏ហៅប្អូនប្រុសនោះមក ហើយប្រាប់ថា នែនន្ទះ ចាប់ពីពេលនេះទៅ បើឯងរកផ្លែឈើមកបានហើយ ចូរបង្អង់ឲ្យអញត្រឡប់មកសិន យើងទាំង ២ នឹងឲ្យមាតាបិតាបរិភោគជាមួយគ្នា ។ កាលព្រះមហាសត្វពោលយ៉ាងនេះហើយ នន្ទះតាបសក៏គិតតែអំពីបុណ្យរបស់ខ្លួនតែម្យ៉ាង មិនបានធ្វើតាមពាក្យបងប្រុសឡើយ ។ គ្រានោះ ព្រះមហាសត្វគិតថា នន្ទះមិនធ្វើតាមពាក្យរបស់អញ ធ្វើកិច្ចដែលមិនសមគួរ ត្រូវបណ្ដេញចេញ អញម្នាក់ឯងប៉ុណ្ណោះនឹងបដិបត្តិមាតាបិតា ទើបផ្ទាត់ម្រាមដៃ សម្គុតនន្ទតាបសដោយពាក្យថា នែនន្ទះ ឯងជាបុគ្គលមិននៅក្នុងឱវាទ មិនធ្វើតាមពាក្យរបស់បណ្ឌិតទាំងឡាយ អញជាបងប្រុសរបស់ឯង មាតាបិតាជាកិច្ចទទួលខុសត្រូវរបស់អញតែម្នាក់ អញប៉ុណ្ណោះនឹងបដិបត្តិមាតាបិតា ឯងកុំនៅក្នុងទីនេះ ចូរទៅក្នុងទីដទៃចុះ ។ នន្ទតាបសត្រូវសោណតាបសបងប្រុសបណ្ដេញ មិនអាចនៅក្នុងសម្នាក់បងប្រុសបាន ទើបថ្វាយបង្គំបងប្រុស ចូលទៅរកមាតា

បិតា រៀបរាប់សេចក្តីនោះឲ្យស្តាប់ ថ្វាយបង្គំមាតាបិតា ហើយចូលទៅកាន់បណ្ណសាលារបស់ខ្លួន សម្រឹងកសិណជាអារម្មណ៍ ក្នុងថ្ងៃនោះឯង ក៏ធ្វើអភិញ្ញា ៥ សមាបត្តិ ៨ ឲ្យកើតឡើងបាន ហើយគិតថា អញនឹងនាំខ្សាច់រតនៈ អំពីជើងភ្នំសិនេរុ រោយក្នុងបរិវេណបណ្ណសាលា នៃបងប្រុសរបស់អញ ក៏ជាការគ្រប់គ្រាន់ ដើម្បីឲ្យបងប្រុសអភ័យទោសដល់អញបាន សូម្បីការធ្វើយ៉ាងនេះក៏មិនល្អ អញនឹងទៅនាំទឹកមកអំពីអនោតត្តស្រះ ស្រោចក្នុងបរិវេណបណ្ណសាលា នៃបងប្រុសរបស់អញ ក៏ល្មមឲ្យបងប្រុសអភ័យទោសបាន តែបើធ្វើយ៉ាងនេះ មិនទាន់ល្អ អញនឹងធ្វើបងប្រុសរបស់អញឲ្យអភ័យទោស ដោយអំណាចទេវតាទាំងឡាយ អញនឹងនាំមហារាជទាំង ៤ និងសក្កៈមក ក៏ល្មមឲ្យបងប្រុសអត់ទោសបាន បើដូច្នេះ នៅតែមិនល្អ អញនឹងនាំព្រះរាជាទាំងឡាយ មានព្រះបាទមនោជៈ ដែលជាព្រះរាជាដ៏ធំក្នុងជម្ពូទ្វីបទាំងមូលនេះ មកជាប្រធានក៏ល្មមឲ្យបងប្រុសអភ័យទោស ដល់អញបាន កាលបើដូច្នេះ គុណរបស់បងប្រុសអញក៏នឹងផ្សាយទៅពេញ ជម្ពូទ្វីបទាំងមូល នឹងប្រាកដដូចព្រះចន្ទនិងព្រះអាទិត្យដូច្នោះ ។

ខណៈនោះ នន្ទតាបសក៏ហោះទៅដោយឫទ្ធិ ចុះត្រង់ទ្វារព្រះរាជនិវេសន៍នៃព្រះរាជានោះ ក្នុងព្រហ្មវឌ្ឍនគរ ត្រាស់ឲ្យរាជបុរសក្រាបទូលដល់ព្រះរាជាថា បានឮថា តាបសមួយអង្គ ត្រូវការចូលគាល់ព្រះអង្គ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា ប្រយោជន៍អ្វីដោយការឃើញបព្វជិតនោះ បព្វជិតរូបនោះប្រហែលជាមកដើម្បីត្រូវការអាហារពិត ទើបបញ្ជូនកត្តាហារទៅប្រគេន ។

តាបសមិនប្រាថ្នាភត្ត ព្រះរាជាក៏បញ្ជូនអង្ករទៅប្រគេន តាបសនោះក៏មិនត្រូវការអង្ករ ទើបបញ្ជូនសំពត់ទៅប្រគេន តាបសមិនទទួលសំពត់ ទើបទ្រង់បញ្ជូនស្វាម្ពូទៅប្រគេន តាបសនោះក៏មិនទទួលស្វាម្ពូ ។ លំដាប់នោះ ព្រះរាជាបញ្ជូនទូតទៅកាន់សម្នាក់របស់តាបសនោះ ឲ្យសួរថា លោកម្ចាស់មកបំណងដូចម្តេច តាបសកាលត្រូវសួរ ទើបប្រាប់ថា អាត្មាមកដើម្បីបម្រើព្រះរាជា ។ ព្រះរាជា ទ្រង់ស្តាប់ពាក្យនោះមកហើយ ទើបបញ្ជូនមនុស្សម្នាក់ទៅប្រាប់ថា ពួកឧបដ្ឋាករបស់ខ្ញុំមានច្រើនហើយ សូមតាបសបំពេញកិច្ចរបស់ខ្លួនចុះ ។ តាបសស្តាប់ពាក្យនោះហើយក៏ពោលថា អាត្មានឹងយករាជសម្បត្តិក្នុងជម្ពូទ្វីបទាំងមូល ដោយកម្លាំងរបស់ខ្លួនហើយថ្វាយដល់ព្រះរាជារបស់អ្នកទាំងឡាយ ។ ព្រះរាជាស្តាប់ដូច្នោះហើយ ទ្រង់ព្រះតម្រិះថា ធម្មតាបព្វជិតទាំងឡាយជាបណ្ឌិត គង់ជ្រាបឧបាយណាមួយទេដឹង ទើបត្រាស់ឲ្យនិមន្តតាបសចូលមកឲ្យអង្គុយលើអាសនៈ ទ្រង់ថ្វាយបង្គំហើយ ត្រាស់សួរថា បពិត្រលោកម្ចាស់បានឮថា លោកម្ចាស់ កាន់យករាជសម្បត្តិក្នុងជម្ពូទ្វីបទាំងមូល ហើយលើកឲ្យដល់ខ្ញុំឬ ។ តាបសក្រាបទូលថា យ៉ាងនោះឯង មហាបពិត្រ ។ ព្រះរាជាត្រាស់សួរថា លោកម្ចាស់កាន់យកបានដូចម្តេច តាបសក្រាបទូលថា បពិត្រមហារាជ អាត្មាមិនចាំបាច់ឲ្យឈាមស្រក់ត្រឹមមួយចម្អែតរុយ ដោយកំណត់យ៉ាងទាប ឲ្យកើតឡើងដល់អ្នកណាមួយឡើយ ទាំងមិនធ្វើនូវការអស់ព្រះរាជទ្រព្យរបស់ទ្រង់ឡើយ នឹងកាន់យកដោយឫទ្ធិរបស់អាត្មា ហើយថ្វាយដល់ទ្រង់ តែមិនគួរធ្វើនូវការយឺតយូរ តែម្យ៉ាង ប្រញាប់យាងចេញក្នុងថ្ងៃនេះឯង ។

ព្រះរាជា ទ្រង់ជឿពាក្យនន្ទតាបសនោះ ហោមរោមទៅដោយពួកសេនានិករ ចេញអំពីព្រះនគរ ។ បើកម្តៅកើតឡើងដល់ពួកសេនា នន្ទបណ្ឌិតក៏និម្មិតឲ្យមានម្លប់ ធ្វើឲ្យត្រជាក់ដោយឫទ្ធិរបស់ខ្លួន កាលភ្លៀងធ្លាក់ ក៏មិនធ្លាក់ខាងលើពួកសេនា ឃាត់នូវការក្តៅនិងការរងាបាន បណ្តាលឲ្យអន្តរាយទាំងអស់មានបន្លា និងជង្គត់ក្នុងរវាងផ្លូវជាដើម ឲ្យអន្តរធានអស់ទៅ ធ្វើនូវផ្លូវឲ្យរាបស្មើ ដូចមណ្ឌលនៃកសិណ សូម្បីខ្លួនឯង ក៏ក្រាលបន្ទះស្បែក អង្គុយលើបល្ល័ង្ក មានពួកសេនាចោមរោម ហើយហោះទៅក្នុងអាកាស ។

នន្ទបណ្ឌិតនាំពួកសេនាទៅដោយអាការយ៉ាងនេះ ដល់ដែនកោលសមុទ្រ ទើបឲ្យបញ្ឈប់កងទ័ព បោះជំរំខាងក្រៅនគរ ហើយបញ្ជូនទូតទៅទូលព្រះបាទកោសលរាជថា តើច្បាំងជាមួយពួកយើង ឬឲ្យស្វេតច្ឆត្រ ។ ព្រះបាទកោសលរាជទ្រង់បានស្តាប់ពាក្យរបស់ទូតនោះ ក៏ទ្រង់ពិរោធត្រាស់ថា យើងមិនមែនជាស្តេចទេឬ យើងនឹងច្បាំង ។ ទ្រង់ធ្វើសេនាឲ្យនៅខាងមុខលើកពលចេញទៅ ។ សេនាទាំង ២ ចំណែកផ្តើមច្បាំងគ្នា ។ លំដាប់នោះ នន្ទបណ្ឌិត ក៏និម្មិតស្បែកខ្លាជំបង ដែលជាអាសនៈអង្គុយរបស់ខ្លួនឲ្យធំយ៉ាងក្នុងរវាងកងទ័ពទាំង ២ ដើម្បីទទួលព្រួញសេនាទាំង ២ ចំណែក ដែលបាញ់គ្នាទៅមក ដោយបន្ទះស្បែកនោះឯង ។ សេនាទាំង ២ ខាង បុគ្គលណាម្នាក់ដែលត្រូវព្រួញមុតមិនមានឡើយ កងទ័ពទាំង ២ ចំណែកក៏អស់នូវឧស្សាហៈឈរធ្វើព្រងើយព្រោះព្រួញដែលនៅក្នុងដៃអស់ទាំង ២ ចំណែក ។ នន្ទបណ្ឌិត ក៏ទៅកាន់សម្នាក់របស់ព្រះបាទមនោជរាជ ទូលលួងលោមថា

សូមទ្រង់កុំវិតក្កឡើយ ហើយទៅកាន់សម្នាក់របស់ព្រះបាទកោសលទូលថា សូមទ្រង់កុំវិតក្កឡើយ អន្តរាយមិនមានដល់ទ្រង់ឡើយ រាជសម្បត្តិនៅតែជារបស់ទ្រង់នោះឯង តែសូមទ្រង់ឱនលំទោនព្រះបាទមនោជរាជតែម្យ៉ាងប៉ុណ្ណោះ ។ ព្រះបាទកោសលទ្រង់ជឿនទូបណ្ឌិតនោះ ក៏ទ្រង់ទទួលថា សាធុ ដូច្នេះ ។

គ្រានោះ នទូបណ្ឌិត ក៏នាំព្រះរាជាទៅកាន់សម្នាក់របស់ព្រះបាទមនោជៈ ហើយទូលថា បពិត្រមហារាជ ព្រះបាទកោសលទ្រង់ថ្វាយបង្គំព្រះអង្គ តែសូមឲ្យរាជសម្បត្តិរបស់ព្រះបាទកោសលរាជនេះ នៅជារបស់ទ្រង់ ដូចដើមនោះឯង ។ ព្រះបាទមនោជរាជត្រាស់ថា សាធុ ទ្រង់ធ្វើព្រះបាទកោសលរាជអង្គនោះ ឲ្យនៅក្នុងអំណាចរបស់ទ្រង់ហើយ លើកពលសេនាទាំង ២ នគរទៅកាន់ដែនអង្គៈ បានទូវដែនអង្គៈហើយ បន្ទាប់អំពីនោះ ក៏ទៅកាន់ដែនមគធៈ បានដែនមគធៈដោយឧបាយយ៉ាងនេះ ទ្រង់ធ្វើព្រះរាជាទាំងឡាយក្នុងជម្ពូទ្វីបទាំងមូល ឲ្យធ្លាក់នៅក្នុងអំណាចរបស់ទ្រង់ទាំងអស់ បន្ទាប់អំពីនោះ ជាព្រះរាជាដែលមានស្តេចទាំងនោះ ជាបរិវារ ចេញទៅកាន់ព្រហ្មទត្តនគរនោះឯង ។ ព្រះបាទមនោជរាជនេះ ទ្រង់ដណ្តើមយករាជសម្បត្តិដល់ទៅ ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ ទើបស្រេចរៀបរយ ។ ព្រះបាទមនោជរាជនោះ ត្រាស់ឲ្យព្រះរាជាទាំងនោះ នាំរបស់ទំពាំនិងរបស់បរិភោគ មានប្រការផ្សេងៗ មកអំពីរាជធានីរបស់ខ្លួនគ្រប់ៗនគរ ទ្រង់នាំព្រះរាជាទាំង ១០១ អង្គនោះ ផឹកនូវគ្រឿងផឹកដ៏ធំ ជាមួយព្រះរាជាទាំងនោះអស់ ៧ ថ្ងៃ ។

នទូបណ្ឌិតតាបសគិតថា ព្រះរាជាសោយសុខ ដែលកើតអំពីភាពជាធំ

អស់ ៧ ថ្ងៃ ដរាបណា អញនឹងបង្ហាញខ្លួនដល់ព្រះរាជាដរាបនោះ ទើបត្រាច់ទៅបិណ្ឌបាតក្នុងឧត្តរកុរុទ្វីប ហើយទៅកាន់មាត់ទ្វារគុហាមាសក្នុងហិមវន្តប្បទេសអស់ ៧ ថ្ងៃ ។ សូម្បីព្រះបាទមនោជរាជ ក្នុងថ្ងៃទី ៧ ទ្រង់មើលសិរីរាជសម្បត្តិដ៏ធំក្រៃលែងរបស់ព្រះអង្គ ទ្រង់រឭកដល់នន្ទបណ្ឌិតតាបសថា ឥស្សរិយយសទាំងអស់នេះ មាតាបិតារបស់យើងមិនបានឲ្យជនដទៃមិនបានឲ្យដល់អញ កើតឡើងព្រោះអាស្រ័យនន្ទបណ្ឌិតតាបស អញមិនបានឃើញលោកអស់ ៧ ថ្ងៃ ថ្ងៃនេះហើយ ឥឡូវនេះ លោកឲ្យឥស្សរិយយសដល់អញ តើលោកនៅឯណាហ្ន៎ ។ នន្ទបណ្ឌិតនោះ បានជ្រាបថា ព្រះរាជារឭកដល់ខ្លួន ទើបហោះមកឈរក្នុងអាកាស ចំពោះព្រះភក្ត្រព្រះរាជា ព្រះរាជាទតឃើញនន្ទតាបសឈរ ក៏ទ្រង់ព្រះតម្រិះយ៉ាងនេះថា យើងមិនជ្រាបថា តាបសនេះជាទេវតា ឬមនុស្ស បើជាមនុស្សអញនឹងលើករាជសម្បត្តិក្នុងជម្ពូទ្វីបឲ្យដល់លោកនោះឯង បើជាទេវតា អញនឹងធ្វើគ្រឿងសក្ការៈសម្រាប់ទេវតាដល់លោក ។ ព្រះរាជាអង្គនោះ កាលទ្រង់សាក សួរនន្ទបណ្ឌិតនោះឲ្យជ្រាបច្បាស់ ទើបត្រាស់គាថាជាបឋមថា

លោកជាទេវតា ឬជាគន្ធព្វ ជាសក្កបុរិន្ទទៈ ឬជាមនុស្សមាន
ឫទ្ធិ ធ្វើដូចម្តេច យើងនឹងស្គាល់លោកបាន ដូច្នេះ ។

នន្ទតាបសស្តាប់ពាក្យនោះហើយ កាលនឹងទូលតាមសេចក្តីពិត ទើបពោលគាថាទី ២ ថា

អាត្មាភាពមិនមែនជាទេវតា មិនមែនជាគន្ធព្វ មិនមែនជាសក្ក

*បុរិន្ទទៈទេ អាត្មាភាពជាមនុស្សមានឫទ្ធិ បពិត្រព្រះរាជា ទ្រទ្រង់នូវភារៈ ( ដែន ) សូមព្រះអង្គ ជ្រាបយ៉ាងនេះចុះ ដូច្នេះ ។*

ននួបណ្ឌិតហៅព្រះរាជានោះថា **ភារវ** ដូច្នេះ ក្នុងគាថានោះ ព្រោះទ្រង់ជាអ្នកទ្រទ្រង់ទុកនូវភារៈនៃរដ្ឋ ។

ព្រះរាជាទ្រង់ស្តាប់ពាក្យនោះហើយ ទើបព្រះតម្រិះថា បានឮថា តាបសនេះជាមនុស្ស លោកមានឧបការៈច្រើន យ៉ាងនេះដល់អញ អញនឹងឲ្យលោកឆ្អែតស្កប់ស្កល់ ដោយឥស្សរិយយស ទើបត្រាស់ថា

*ការខ្វល់ខ្វាយបម្រើមានសភាពដែលលោកដ៏ចម្រើនធ្វើហើយនេះ ជាការមិនមែនតិច កាលដែលភ្លៀងកំពុងធ្លាក់ចុះ លោកដ៏ចម្រើនអាចធ្វើមិនឲ្យមានភ្លៀងបាន ។ តពីនោះមក លោកដ៏ចម្រើនអាចធ្វើឲ្យម្លប់ដ៏ត្រជាក់បាន ក្នុងទីមានខ្យល់និងកម្តៅថ្ងៃដ៏ខ្លាំង តពីនោះមក លោកដ៏ចម្រើន អាចធ្វើគ្រឿងការពារព្រួញ ក្នុងកណ្តាលនៃសត្រូវទាំងឡាយបាន ។ តពីនោះមក លោកដ៏ចម្រើន អាចធ្វើដែនទាំងឡាយដ៏សម្បូណ៌ ( និង ) អ្នកដែនទាំងនោះឲ្យលុះក្នុងអំណាច ( របស់យើងខ្ញុំ ) តពីនោះមក លោកដ៏ចម្រើនអាចធ្វើក្សត្រ ១០១ ឲ្យជាចំណុះ ( នៃយើងខ្ញុំបាន ) ។ យើងខ្ញុំត្រេកអរនឹងលោកដ៏ចម្រើន លោកចង់បានរតនៈ ( ណា ) ចូរទទួលយករតនៈនោះចុះ យើង*

ខ្ញុំប្រគេនយានដំរី រថសេះ ពួកនាងនារី ដែលប្រដាប់ស្រេច
ទាំងលំនៅគួរឲ្យត្រេកអរទាំងឡាយ ដល់លោកដ៏ចម្រើន ។
មួយទៀតយើងខ្ញុំប្រគេនដែនអង្គៈឬមគធៈ ដល់លោកដ៏ចម្រើន
មួយទៀត យើងខ្ញុំសប្បាយចិត្ត ប្រគេនដែនអស្សកៈ ឬដែន
អវន្តិដល់លោក ។ យើងខ្ញុំ ប្រគេនរាជ្យពាក់កណ្តាល ដល់
លោកដ៏ចម្រើន បើលោកត្រូវការដោយរាជ្យ លោកចង់បាន
របស់ណា សូមត្រួតត្រារបស់នោះចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កតរូបមិទំ** បានដល់ មានសភាពដែលលោកម្ចាស់ធ្វើហើយ ។ បទថា **វេយ្យាវច្ចំ** បានដល់ ការងារដែលជួយខ្វាយខ្វល់ផ្លូវកាយ ។ បទថា **អនោវស្សំ** បានដល់ មិនឲ្យភ្លៀងធ្លាក់ ។ អធិប្បាយថា លោកម្ចាស់បានធ្វើដោយប្រការដែលភ្លៀងមិនធ្លាក់ចុះមក ។ បទថា **សីតច្ឆាយំ** បានដល់ មានម្លប់ត្រជាក់ ។ បទថា **វសិនោ តេ** បានដល់ លោកម្ចាស់បានធ្វើមហាជនអ្នកដែននោះៗ ឲ្យលុះក្នុងអំណាចរបស់ខ្ញុំ ។ បទថា **ខត្យេ** បានដល់ ក្សត្រទាំងឡាយ ។ ក្នុងអដ្ឋកថាលោកពោលទុកយ៉ាងនេះដូចគ្នា ។ បទថា **បតីតាស្សុ មយំ** បានដល់ ខ្ញុំត្រេកអរក្រៃលែង ។ បទថា **វរ តំ ភុញ្ជមិច្ឆសិ** សេចក្តីថា ពាក្យថា **ភុញ្ជ** នេះ ជាឈ្មោះនៃរតនៈ អធិប្បាយថា ខ្ញុំនឹងឲ្យពរដល់លោកម្ចាស់ លោកម្ចាស់ប្រាថ្នារតនៈឯណា សូមលោកទទួលយករតនៈនោះចុះ ។ ព្រះរាជាទ្រង់សម្តែងរតនៈនោះ ដោយសរុបដោយពាក្យថា **ហត្ថិយានំ** ដូច្នេះជាដើម ។ បទថា **អស្សកាវន្តី** បានដល់ ដែន

អស្សកៈឬដែនអវន្តី ដោយបទថា **រដ្ឋេន** នេះ ព្រះរាជាទ្រង់សម្តែងថា ទោះ បីលោកម្ចាស់មានសេចក្តីប្រាថ្នារាជសម្បត្តិ ក្នុងជម្ពូទ្វីបទាំងមូល ខ្ញុំនឹងឲ្យរាជ សម្បត្តិនោះដល់លោកម្ចាស់ ហើយនឹងមានដៃកាន់ខែលនិងអាវុធ រត់ទៅខាង មុខរថលោកម្ចាស់ ដូច្នេះ ។ បទថា **យទិច្ឆសិ** សេចក្តីថា លោកម្ចាស់ប្រាថ្នា វត្ថុណា ក្នុងបណ្តាវត្ថុគ្រប់យ៉ាង ដែលខ្ញុំពោលមកហើយនេះ ក៏ចូរប្រាប់វត្ថុ នោះ ដល់ខ្ញុំចុះ ។

នន្ទបណ្ឌិតតាបសបានស្តាប់ព្រះតម្រាស់នោះហើយ កាលចង់សម្តែង នូវបំណងរបស់ខ្លួនឲ្យជាក់ច្បាស់ក៏ក្រាបទូលថា

អាត្មាភាព មិនត្រូវការដោយរាជ្យ ដោយនគរ ឬដោយទ្រព្យ
ទាំងមិនត្រូវការដោយជនបទទេ ដូច្នេះ ។

នន្ទបណ្ឌិតទូលបន្តថា បពិត្រមហារាជ បើទ្រង់ស្រឡាញ់ក្នុងអាត្មា សូម ធ្វើតាមពាក្យរបស់អាត្មាត្រឹមតែមួយ៉ាង ហើយទូលជាគាថានេះថា

ក្នុងព្រៃ ក្នុងដែនជាអាណាខេត្តរបស់ព្រះអង្គដ៏ចម្រើន មាន
អាស្រម ១ បិតាមាតារបស់អាត្មាភាពទាំង ២ នាក់ នៅក្នុង
អាស្រមនោះ ។ អាត្មាភាពមិនបានធ្វើបុណ្យចំពោះបុព្វាចារ្យ
ទាំងនោះ យើងធ្វើព្រះអង្គដ៏ចម្រើនឲ្យប្រសើរលើសលុប ឲ្យ
សូមនូវការរួបរួមជាមួយនឹងសោណបណ្ឌិតតាបស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **រដ្ឋេ** បានដល់ ក្នុងរាជសម្បត្តិ ។ បទថា **វិជិតេ** បានដល់ ទីដែលទ្រង់ផ្សាយរាជអាជ្ញាទៅ ។ បទថា **អស្សមោ** បាន

ដល់ ក្នុងហិមវន្តប្បទេសនោះ មានអាស្រមមួយកន្លែង ។ បទថា **សម្មន្តិ** បានដល់ នៅក្នុងអាស្រមនោះ ។ បទថា **តេសាហំ** កាត់បទជា **តេសុ អហំ** ប្រែថា អាត្មាមិនបានធ្វើបុណ្យក្នុងបុព្វចារ្យទាំង ២ នោះ ។ បទថា **កាតវេ** សេចក្តីថា អាត្មាមិនបានធ្វើបុណ្យ ពោល គឺវត្តបដិបត្តិនិងការនាំផ្លែឈើតូចធំមក ព្រោះថា បងប្រុសរបស់អាត្មាឈ្មោះ សោណបណ្ឌិត បានបណ្តេញអាត្មាកាព ព្រោះមានកំហុសមួយ ដោយពាក្យថា ឯងកុំនៅក្នុងទីនេះឡើយ ។ បទថា **អញ្ញាវរំ** សេចក្តីថា អាត្មាសូមយាងទ្រង់ដ៏ប្រសើរ មួយអន្លើដោយបរិវារយាងទៅសូមខមាទោស សោណបណ្ឌិត គឺអាត្មាកាពនឹងសន្រ្ទមតទៅ បាលីថា **យាចេមិ មំ វរំ** ប្រែថា អាត្មាសូមនូវពរនេះ ដូច្នេះក៏មានអធិប្បាយថា អាត្មានឹងទៅអង្វរ សោណតាបស ឲ្យអត់ទោសជាមួយទ្រង់ គឺអាត្មានឹងទទួលពរនេះអំពីសម្នាក់របស់ទ្រង់ ។

លំដាប់នោះ ព្រះរាជាត្រាស់នឹងនន្ទតាបសនោះថា

> បពិត្រព្រាហ្មណ៍ ខ្ញុំធ្វើតាមពាក្យរបស់លោក ដែលលោក
> ពោលនឹងខ្ញុំ សូមលោកប្រាប់ហេតុនោះ ដល់យើងខ្ញុំ តើឲ្យ
> ពួកជនប៉ុន្មាននាក់ ជាអ្នកជួយអង្វរគេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ករោមិ** សេចក្តីថា ព្រះរាជាត្រាស់ថា ខ្ញុំនឹងឲ្យរាជសម្បត្តិក្នុងជម្ពូទ្វីបទាំងមូល នឹងមិនបានធ្វើកម្មណាមួយ មានប្រមាណប៉ុណ្ណោះដូចម្តេចបាន គឺខ្ញុំនឹងធ្វើ ។ បទថា **កីវន្តោ** បានដល់ មានប្រមាណប៉ុនណា ។

នន្ទបណ្ឌិតតាបសទូលថា

ពួកគហបតីមហាសាលជាងមួយរយ ពួកព្រាហ្មណ៍មហាសាល ជាងមួយរយនិងពួកក្សត្រទាំងអស់ដែលមានជាតិដ៏ខ្ពស់ មានយសនេះ ទាំងព្រះបាទមនោជៈដ៏ចម្រើន ទើបល្មមជាអ្នកជួយអង្វរករ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ជានបទា** បានដល់ គហបតីមហាសាល ។ បទថា **ព្រាហ្មណា** បានដល់ ព្រាហ្មណ៍ដែលស្តុកស្តម ប្រមាណជាង ១០០ ប៉ុណ្ណោះ ។ បទថា **អលំ ហោស្សន្តិ** សេចក្តីថា ក៏ជាការគ្រប់គ្រាន់ហើយ ។ បទថា **យាចកា** បានដល់ បុគ្គលដែលនឹងទៅសូមឲ្យសោណបណ្ឌិត អត់ទោស ដើម្បីប្រយោជន៍ដល់អាត្មា ។ លំដាប់នោះ ព្រះរាជាត្រាស់នឹងនន្ទបណ្ឌិតនោះថា

ពួកអ្នករក្សាដំរី ពួកអ្នករក្សាសេះ ចូរនាំគ្នាចាត់ចែងនូវពួកដំរី ពួកសេះ ម្នាលសារថី អ្នកចូរជ្រាមរថ អ្នកទាំងឡាយចូរយកគ្រឿងប្រដាប់សម្រាប់ចង ( ឯដំរីសេះរថ ) ជនទាំងឡាយ ចូរលើកទង់ជ័យ ត្រង់ជើងទង់ជ័យដែលតម្កល់លើរថ អញនឹងទៅកាន់អាស្រម ជាទីនៅនៃកោសិយគោត្ត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យោជេន្តុ** សេចក្តីថា ហ្មដំរីទាំងឡាយ ចូរត្រៀមដំរី និងអស្សាចារ្យទាំងឡាយ ចូរត្រៀមសេះ ។ បទថា **រថំ សន្នយ្ហ**

**សារថិ** សេចក្ដីថា នែសារថីសម្លាញ់ សូម្បីខ្លួនអ្នកក៏ចូរបង់រថនោះ ។ បទថា **អាតបត្តានិ** សេចក្ដីថា អ្នកទាំងឡាយ ចូរកាន់យកគ្រឿងសម្រាប់ចងទូទៅក្នុងដីរ៍ សេះ និងរថទាំងឡាយ ។ បទថា **ចាបាសុស្សារយន្តុដេ** សេចក្ដីថា ចូរលើក គឺលើកទង់ត្រង់ជងទង់ដែលតាំងនៅលើរថ ។ បទថា **កោសិយោ** សេចក្ដីថា ព្រះរាជាត្រាស់ថា តាបសកោសិយគោត្ត នៅក្នុងអាស្រមណា ដូច្នេះ ។

ព្រះសាស្ដា កាលទ្រង់ប្រកាសសេចក្ដីនោះ ទើបត្រាស់ថា

លំដាប់ពីនោះមក ព្រះរាជាបានយាងទៅដោយសេនា ប្រកប
ដោយអង្គ ៤ ទ្រង់ស្ដេចទៅកាន់អាស្រមជាទីរីករាយ ជាទី
នៅនៃកោសិយគោត្ត ដូច្នេះ ។

នេះជាគាថាដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់បន្ថែម បណ្ដាបទទាំងនោះ បទថា **តតោ ច** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ ព្រះរាជាអង្គនោះ កាលត្រាស់យ៉ាងនេះហើយ ក្នុងលំដាប់នោះ ទើបទ្រង់នាំក្សត្រ ១០១ អង្គ ចោមរោមដោយសេនាធំ ឲ្យតាបសនន្ទបណ្ឌិតនាំផ្លូវ យាងចេញអំពីព្រះនគរ ។ បទថា **ចតុរង្គិនី** សេចក្ដីថា ទ្រង់យាងទៅកាន់អាស្រម មួយអន្លើដោយចតុរង្គសេនា ។ សូម្បីកំពុងយាងនៅក្នុងរវាងផ្លូវ លោកក៏ពោលទុកយ៉ាងនេះ ព្រោះត្រូវយាងទៅយ៉ាងពិតប្រាកដ នន្ទបណ្ឌិតតាបស ធ្វើដំណើរទៅ មួយអន្លើដោយពួកពលសេនាប្រមាណ ២៤ អក្ខោភិនី និម្មិតផ្លូវទទឹង ៨ ឧសភឲ្យរាបស្មើ ដោយអានុភាពនៃឫទ្ធិ ហើយក្រាលកម្រាលស្បែកនៅក្នុងអាកាស

អន្ទុយពត់ភ្នែនលើកំណាត់ស្បែកនោះ មានសេនាចោមរោមហើយ ពោលពាក្យប្រកបដោយធម៌ ជាមួយព្រះរាជា ដែលប្រថាប់គន់លើកដីរ ដែលប្រថាប់ហើយ យាន់ទៅជាមួយគ្នា ហើយហាមទូវអន្តរាយ មានត្រជាក់និងក្តៅជាដើម បានទៅហើយ ។

ក្នុងថ្ងៃដែលនន្ទតាបសនោះមកដល់អាស្រម សោណបណ្ឌិតតាបស ពិ-ចារណាថា ប្អូនប្រុសរបស់យើងចេញទៅអស់ ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃហើយ ទើបសម្លឹងមើលដោយទិព្វចក្ខុថា ឥឡូវនេះ គេនៅឯណាហ្ន៎ ក៏ឃើញថា កំពុងនាំព្រះរាជា ១០១ អង្គ មួយអន្លើដោយបរិវារប្រមាណ ២៤ អក្ខោភិនីមក ដើម្បីឲ្យអញអត់ទោសដោយពិត ទើបត្រិះរិះបន្តថា ក្សត្រទាំងនោះមួយអន្លើដោយបរិស័ទ បានឃើញបាដិហារ្យរបស់ប្អូនប្រុសអញជាច្រើន តែមិនបានជ្រាបអានុភាពរបស់អញ ក៏នឹងនាំគ្នាចរចា សម្មតមើលងាយអញថា បុរសនេះជាជដិលកោង មិនស្គាល់ប្រមាណខ្លួនឯង នឹងមកច្បាំងជាមួយលោកម្ចាស់របស់យើងទាំងឡាយ ដូច្នេះ ។ ជនទាំងអស់ គប្បីមានអវិចិជាទីទៅខាងមុខ អញនឹងសម្តែងឥទ្ធិប្បាដិហារ្យដល់ពួកក្សត្រ និងពួកបរិស័ទទាំងនោះ

សោណបណ្ឌិតតាបសនោះ ក៏ទុកដងរែកសម្រាប់រែកទឹកក្នុងអាកាស ដោយមិនឲ្យពាល់ដល់ស្មាប្រមាណ ៤ ធ្នាប់ ហើយហោះទៅតាមអាកាស ក្នុងទីមិនឆ្ងាយអំពីព្រះរាជា ដើម្បីនាំយកទឹកមកអំពីអនោតត្តស្រះ នន្ទបណ្ឌិតតាបសគ្រាន់តែឃើញបងប្រុសហោះមក មិនអាចបង្ហាញខ្លួនបាន ទើបអន្តរធានក្នុងទីអង្គុយនោះឯង គេចទៅកាន់ព្រៃហិមពាន្ត ព្រះបាទមនោជរាជទតឃើញ

នូវសោណបណ្ឌិតនោះហោះមកដោយភេទឥសី ដែលគួរជ្រះថ្លា ទើបត្រាស់គាថានេះថា

ដងវែក ជាវិការៈនៃឈើក្តម្ពរបស់អ្នកណា ដែលទៅដងទឹក
ហើយមិនប៉ះពាល់ស្មា ទៅលើអាកាសចំនួន ៤ ធ្នាប់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កាឧម្ពរោយា** បានដល់ ធ្វើដោយដើមក្តម្ព ។ បទថា **អំសំ អសំផុសំ ឯតិ** សេចក្តីថា ដងវែកនេះ មិនបានពាល់ត្រូវស្មាអណ្តែតមក ។ បទថា **ឧទហារស្ស** សេចក្តីថា ដងវែករបស់អ្នកណា ដែលទៅដើម្បីនាំទឹកមក គឺលោកឈ្មោះអ្វី ឬលោកមកអំពីណា ។ ព្រះរាជាកាលត្រាស់យ៉ាងនេះហើយ ទើបព្រះមហាសត្វពោលគាថា ២ ថា

បពិត្រមហារាជ អាត្មាភាពជាតាបស ឈ្មោះសោណៈ ប្រកប
ដោយវត្ត មិនខ្ជិលច្រអូស ចិញ្ចឹមមាតាបិតា ទាំងយប់ទាំង
ថ្ងៃ បពិត្រព្រះអង្គជាម្ចាស់នៃទិស អាត្មាភាពរឭកឃើញឧប-
ការៈ ដែលមាតាបិតាធ្វើក្នុងកាលមុន ហើយក៏យកផ្លែឈើ
និងមើមឈើក្នុងព្រៃមកចិញ្ចឹមមាតាបិតា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សហិតព្វតោ** សេចក្តីថា សោណបណ្ឌិតតាបសនោះពោលថា អាត្មាជាតាបសមួយរូប ជាអ្នកមានវត្តដែលសមាទានហើយ គឺដែលសម្បូរដោយសីលនិងមារយាទ ។ បទថា **ភរាមិ** បានដល់ ចិញ្ចឹមជាប្រចាំ ។ បទថា **អតន្ទិតោ** បានដល់ ជាអ្នកមិនខ្ជិលច្រអូស ។ បទថា **បុព្វេកតមនុស្សរំ** សេចក្តីថា អាត្មារឭកដល់គុណដែលមាតានិងបិតាទាំង ២

នោះបានធ្វើទុកហើយដល់អាត្មាក្នុងកាលមុន ។

ព្រះរាជាទ្រង់បានស្តាប់ពាក្យនោះហើយ មានព្រះបំណងនឹងទតអាស្រម មួយអន្លើដោយព្រះពោធិសត្វនោះ ទើបត្រាស់គាថាជាលំដាប់តទៅថា

យើងខ្ញុំចង់ទៅកាន់អាស្រម ជាទីនៅរបស់កោសិយគោត្ត
បពិត្រព្រះសោណៈ សូមលោកម្ចាស់ប្រាប់ផ្លូវដល់យើង
យើងនឹងទៅកាន់អាស្រម ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អស្សមំ** សេចក្តីថា យើងទាំងឡាយប្រាថ្នា នឹងទៅកាន់អាស្រមរបស់លោកទាំងឡាយ ។

លំដាប់នោះ ទើបព្រះមហាសត្វនិម្មិតផ្លូវសម្រាប់ទៅកាន់អាស្រមបទ ដោយអានុភាពរបស់ខ្លួន ហើយក្រាបទូលព្រះបាទមនោជៈនោះថា

បពិត្រព្រះរាជា ផ្លូវដើរចុះតែជើង ១ នេះ មានព្រៃ មាន
ពណ៌ដូចជាផ្ទៃមេឃ ដ៏ដេរដាសដោយដើមរលួសផ្អុង នុ៎ះជា
ទីនៅរបស់កោសិយគោត្ត ដូច្នេះ ។

អត្ថនៃពាក្យដែលជាគាថានោះ មានដូចតទៅនេះថា មហាបពិត្រ ផ្លូវនេះ ជាផ្លូវថ្មើរជើង ដើរបានតែម្នាក់ សូមទ្រង់យាងទៅដោយទិសាភាគ ដែល ឈើទាំងឡាយ ដេរដាសទៅដោយដើមរលួសផ្អុង មានផ្ការីកស្គុសស្គាយ ល្អហើយ មានពណ៌ដូចមេឃប្រាកដនេះ ។ បិតារបស់អាត្មាកោសិយគោត្ត នៅក្នុងអាស្រមនេះ នុ៎ះគឺអាស្រមនៃបិតារបស់អាត្មា ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

លុះមហាឥសីពោលពាក្យនេះ ទូលប្រាប់ពួកក្សត្រហើយ ប្រញាប់ប្រញាល់ចៀសចេញទៅ ( កាន់ស្រះអនោតត្ត ) តាមអាកាសវេហាស៍ មហាឥសី ក៏បោសសម្អាតអាស្រម រៀបចំអាសនៈ ចូលទៅកាន់បណ្ណសាលា ហើយជម្រាប បិតាឲ្យជ្រាបថា បពិត្រមហាឥសី ព្រះរាជាទាំងនេះ មាន ជាតិខ្ពស់ មានយស យាងមក សូមព្រះបិតាចេញអំពី អាស្រមមកគង់ចាំទទួល ។ មហាឥសីឮពាក្យនោះរបស់ កូននោះហើយ ក៏ប្រញាប់ប្រញាល់ចេញអំពីអាស្រមមក អង្គុយជិតទ្វារ ដូច្នេះ ។

នេះជាគាថាដែលព្រះសម្មាសម្ពុទ្ធត្រាស់បន្ថែម ។

បណ្តាបទទាំងនោះ បទថា **បក្កាមិ** បានដល់ ទៅកាន់អនោតត្តស្រះ ។ បទថា **អស្សមំ បរិមជ្ជិត្វា** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ឥសីនោះប្រញាប់ ទៅកាន់អនោតត្តស្រះដោយរហ័ស ហើយដងទឹកមក កាលព្រះរាជាទាំងនោះ មិនទាន់ដល់អាស្រមនោះឯង ក៏ត្រឡប់មកមុន រៀបចំតម្កល់ក្អមទឹកផឹកទុក ក្នុងរោងទឹក ហើយអប់ទឹកដោយផ្កាក្នុងព្រៃទាំងឡាយ ដោយគិតថា មហា ជននឹងបានផឹកទឹក ហើយកាន់យកអំបោសមកបោសអាស្រម រៀបចំចាត់ចែង អាសនៈរបស់បិតា ទុកត្រង់ទ្វារបណ្ណសាលា ហើយចូលទៅប្រាប់ឲ្យបិតាបាន ជ្រាប ។ បទថា **ឧចាវិសិ** បានដល់ អង្គុយលើអាសនៈខ្ពស់ ។

ឯមាតារបស់ព្រះពោធិសត្វ អង្គុយលើអាសនៈទាបជាង ដែលតាំងនៅ

ខាងក្រោយ ។ ព្រះពោធិសត្វកាន់យកអាសនៈទាបក្នុងចំណែកម្ខាង ។

ឯនទ្ទបណ្ឌិតតាបស ក្នុងកាលដែលព្រះពោធិសត្វទៅដងទឹកមកអំពីអនោតត្តស្រះ ត្រឡប់មកកាន់អាស្រមហើយ ទើបចូលទៅកាន់សម្នាក់របស់ព្រះរាជា ឲ្យបញ្ឈប់កងទ័ពក្នុងទីជិតអាស្រម ។ លំដាប់នោះ ព្រះបាទមនោជៈ ទ្រង់ស្រពស្រង់ ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង មានក្សត្រ ១០១ អង្គ ចោមរោមជាបរិវារ នាំនទ្ទបណ្ឌិតចូលទៅកាន់អាស្រម ដោយភាពដ៏ប្រសើរ ដោយលម្អនៃសិរីដ៏ធំ ដើម្បីសូមឲ្យព្រះពោធិសត្វអត់ទោស ។ សម័យនោះ បិតាព្រះពោធិសត្វ ឃើញព្រះរាជាយាងមកដូច្នោះ ទើបសួរព្រះពោធិសត្វ ។ ព្រះពោធិសត្វ ក៏បានពោលដល់ការប្រព្រឹត្តទៅទាំងអស់ឲ្យបិតាបានជ្រាប ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

កោសិយគោត្តតាបស បានឃើញស្តេចនោះ ដូចជារុងរឿង
ដោយតេជៈ មានពួកក្សត្រហែហម កំពុងយាងមក ហើយ
បានពោលពាក្យនេះថា ស្គរ សម្ភោរ ស័ង្ខ ស្គរតូច និង
មហោរធឹក របស់អ្នកណា ញុំាងស្តេចជាបុគ្គលប្រសើរលើរថ
ឲ្យរីករាយទៅខាងមុខ ។ ( ទីបំផុតថ្ងាស ) នៃអ្នកណា
( បិទបាំង ) ដោយដំបារមាសដ៏ធំមានពណ៌ដូចជាផ្លេកបន្ទោរ
បុរសកម្លោះណា សៀតបំពង់ព្រួញ រុងរឿងដោយសិរី ហើយ
ដើរមក ។ អ្នកណាមានមុខរុងរឿងភ្លឺចាំង ដូចជាមាសភ្លឺ
ចិញ្ចាច ត្រង់មាត់បាវ ស្រដៀងនឹងរងើកភ្លើងនៃឧសគគីរ

រុងរឿងដោយសិរី ហើយដើរមក ។ អ្នកណាបាំងឆត្រ ព្រម ទាំងធ្នឹងជាទីរីករាយនៃចិត្ត ការពាររស្មីព្រះអាទិត្យ អ្នកណា រុងរឿងដោយសិរី ហើយដើរមក ។ ពួកជនបិទបាំងជុំវិញ ខ្លួន នៃអ្នកណា ដែលមានបុណ្យដ៏ប្រសើរ កំពុងជិះលើក នៃដំរី ដោយផ្ចិតរោមសត្វដ៏ឧត្តម ហើយដើរទៅ ។ ពួក ឆត្រសនិងពួកអាជានេយ្យប្រដាប់ ដោយគ្រោះខ្នាន់ខ្នាប់ ជុំ វិញនៃអ្នកណា អ្នកណារុងរឿងដោយសិរី ហើយដើរមក ។ ពួកក្សត្រមួយរយមួយ សុទ្ធតែមានយស ជាស្តេចចំណុះ ដើរ ហែហមជុំវិញនៃអ្នកណា អ្នកណារុងរឿងដោយសិរីដើរមក ។ ពួកសេនាប្រកបដោយអង្គ ៤ គឺដំរី ១ សេះ ១ រថ ១ ពល ថ្មើរជើង ១ ដើរហែហមជុំវិញ ( នៃអ្នកណា ) អ្នកណា រុងរឿងដោយសិរីដើរមក ។ សេនាដ៏ធំនេះ មិនមានអ្នក ណាមួយ ឲ្យរំកើបបាន មិនមានទីបំផុតដូចជារលកនៃសា- គរ ប្រព្រឹត្តទៅតាមខាងក្រោយនៃអ្នកណា ដូច្នេះ ។

ព្រះមហាសត្វ កាលនឹងប្រាប់ឈ្មោះរបស់ព្រះបាទមនោជៈនោះ ទើប ពោល ២ គាថានេះថា

ព្រះបាទមនោជៈ ជាព្រះរាជាប្រសើរជាងពួកព្រះរាជា ដូច ជាព្រះឥន្ទ ជាធំជាងពួកទេវតា ក្នុងឋានត្រៃត្រិង្សដែលមាន ជ័យជម្នះ បានដល់នូវភាពជាបរិស័ទនៃនន្ទតាបស មកកាន់

អាស្រមនៃពួកព្រហ្មចារីបុគ្គល ( ដើម្បីខមាទោសនឹងយើង )ៗ
សេនាដ៏ធំនេះ មិនមានអ្នកណាមួយឲ្យរំកើបបាន មិនមាន
ទីបំផុតដូចជារលកនៃសាគរ ប្រព្រឹត្តទៅតាមខាងក្រោយនៃ
ព្រះបាទមនោជៈនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ជលន្តិវ** បានដល់ រុងរឿង ។ បទថា **បដិ-បន្នានិ** សេចក្ដីថា គ្រឿងតន្ត្រីទាំងនេះ មកខាងមុខរបស់អ្នកណា ។ បទថា **ហាសយន្តា** បានដល់ ឲ្យត្រេកអរ ។ បទថា **កញ្ចនបដ្ដេន** សេចក្ដីថា តាបសជាបិតាសួរថា នៃកូន ទីបំផុតនៃថ្ងាសរបស់អ្នកណា ពាក់ហើយដោយបន្ទះមាស គឺឧណ្ហីសដែលធ្វើដោយមាស មានពណ៌ដូចផ្លេកបន្ទោរ ។ បទថា **យុវា** បានដល់ កំពុងពេញកំលោះ ។ បទថា **កលាបសន្នទ្ធោ** បានដល់ មានបំពង់ព្រួញដែលចងស្រេចហើយ ។ បទថា **ឧក្កាមុខបហដ្ឋំវ** បានដល់ ដូចមាសដែលកំពុងដាក់ក្នុងជើងក្រាននៃជាងមាស ។ បទថា **ខទិរង្គារសន្និភំ** បានដល់ មានពណ៌ដូចរងើកភ្លើងនៃឧសគគីរ ដែលគេកាប់ទុកល្អហើយ ។ បទថា **អាទិច្ចរំសាវរណំ** បានដល់ សម្រាប់ការពារនូវរស្មីទាំងឡាយនៃព្រះអាទិត្យ ។ បទថា **អន្តំ បរិគ្គយ្ហ** សេចក្ដីថា ដើរជុំវិញ គឺដើរហោមរោមអន្ត ។ បទថា **វាលវីជនិមិត្តមំ** បានដល់ បក់ដោយផ្លិតវាលវីជនីមួយប្រភេទដ៏ឧត្តម ។ បទថា **ចរន្តិ** បានដល់ ដើរទៅព្រមគ្នា ។ បទថា **ឆត្តានិ** បានដល់ ឆត្រដែលពួកទាហានពាក់ក្រោះ អង្គុយកាន់លើខ្នងសេះ ។ បទថា **បរិកិរន្តិ** សេចក្ដីថា ឈរជង្រែគ្នា ក្នុងចំណែកនៃទិសទាំងអស់ដោយជុំវិញ

របស់បុគ្គលណា ។ បទថា **ចតុរង្គិនី** សេចក្តីថា សេនាដែលប្រកបដោយអង្គ ៤ មានដំរីជាដើម ។ បទថា **អក្ខោភិនី** បានដល់ មិនអាចឲ្យញាប់ញ័របាន ។ បទថា **សាគរស្សេវ** បានដល់ រកទីបំផុតមិនបាន ដូចរលកក្នុងមហាសមុទ្ទ ដូច្នោះ ។ បទថា **រាជាភិរាជា** សេចក្តីថា ឈ្មោះថា ជារាជាធិរាជ ព្រោះជាបុគ្គលដែលស្តេចទាំង ១០១ បូជាហើយ ឬជាព្រះរាជាដែលក្រៃលែងជាងព្រះរាជាទាំងនោះ ។ បទថា **ជយតំ បតិ** សេចក្តីថា ជាអ្នកចម្រើនជាងទេវតាជាន់តាវត្តិង្សដល់នូវជ័យជម្នះហើយ ។ បទថា **អជ្ឈាវរំ** សេចក្តីថា ព្រះរាជាអង្គនោះចូលដល់ភាពជាបរិស័ទរបស់នទ្ទតាបស មកដើម្បីឲ្យកូនអត់ទោស ព្រះសាស្តាកាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

ពួកព្រះរាជាទាំងអស់ លាបស្រឡាបដោយខ្លឹមចន្ទន៍ ទ្រង់
កាសិកពស្ត្រដ៏ឧត្តម បានផ្គងអញ្ជលីចូលទៅរកពួកឥសី
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អជ្ឈុបាគមុំ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ព្រះរាជាទាំងអស់នោះ លាបដោយលម្អិតខ្លឹមចន្ទន៍ក្រអូប ទ្រទ្រង់នូវសំពត់មកអំពីដែនកាសីដ៏ប្រសើរ ទ្រង់លើកអញ្ជលីឡើង ដាក់លើសិរសា ចូលទៅកាន់សម្នាក់របស់ឥសីទាំងឡាយ ។

លំដាប់នោះ ព្រះបាទមនោជៈ ទ្រង់នមស្ការបិតារបស់ព្រះពោធិសត្វនោះហើយ ប្រថាប់គង់ក្នុងចំណែកម្ខាង កាលទ្រង់ធ្វើបដិសណ្ឋារៈ ទើបត្រាស់គាថា ២ ថា

លោកដ៏ចម្រើន មានសេចក្តីសុខស្រួលទេឬ លោកដ៏ចម្រើន មានអនាម័យទេឬ លោកទាំងឡាយចិញ្ចឹមជីវិត ដោយការស្វែងរកឬ មើមឈើនិងផ្លៃឈើមានច្រើនដែរឬ ។ ពួករបោម មូស ពស់ មានតិចតួចដែរឬ ក្នុងព្រៃដ៏ដេរដាសដោយម្រឹគសាហាវ មិនបៀតបៀនទេឬ ដូច្នេះ ។

តទៅនេះជាគាថា ដែលតាបសបិតារបស់ព្រះពោធិសត្វ និងព្រះបាទមនោជៈ សាសង្គាទៅវិញទៅមក ដូច្នេះថា

បពិត្រព្រះរាជា អាត្មាភាពមានសេចក្តីស្រួលទេ បពិត្រព្រះរាជា មួយទៀត អាត្មាភាពមិនមានសេចក្តីឈឺចាប់ទេ អាត្មាភាព ចិញ្ចឹមជីវិតដោយការស្វែងរក ( ផលាផល ) ស្រួលទេ ទាំងមើមឈើនិងផ្លែ ឈើក៏មានច្រើន ។ មួយទៀត ពួករបោម មូស ពស់ ក៏មានតិចតួចទេ ក្នុងព្រៃដ៏ដេរដាសដោយម្រឹគសាហាវ ក៏មិនបៀតបៀនអាត្មាភាពទេ ។ អាត្មាភាព មកនៅក្នុងអាស្រមនេះ អស់ប្រជុំនៃឆ្នាំជាច្រើន មិនដែលស្គាល់អាពាធ មិនជាទីត្រេកអរនៃចិត្ត កើតឡើងទេ ។ បពិត្រមហារាជ ព្រះអង្គយាងមកល្អហើយ មួយទៀត ព្រះអង្គមិនមែនយាងមកអាក្រក់ទេ ព្រះអង្គជាឥស្សរៈ យាងមកដល់ហើយ វត្ថុណាមានក្នុងទីនេះ សូមព្រះអង្គមានព្រះបន្ទូល ។ បពិត្រព្រះរាជា សូមព្រះអង្គសោយផ្លែទន្លាប់ ផ្លែទ្រយឹង ផ្លែ

ស្រគំ ផ្លែមាក់ដោក មានរសឆ្ងាញ់ពិសា ដូចជាទឹកឃ្មុំ ។ ទឹកត្រជាក់នេះ អាត្មាភាពបានដងមកអំពីជ្រោះភ្នំ បពិត្រមហារាជ សូមព្រះអង្គសោយទឹកនោះចុះ ប្រសិនបើទ្រង់ត្រូវការ ។

ព្រះរាជាត្រាស់ថា

របស់ណាដែលលោកឲ្យហើយ ( របស់នោះ ) ឈ្មោះថាយើងខ្ញុំទទួលហើយ ទាំងបានធ្វើឲ្យជាជំនូនដល់ជនទាំងពួងលោកទាំងឡាយ ចូរស្តាប់ពាក្យនន្ទបណ្ឌិតតាបស លោកនឹងនិយាយឥឡូវនេះ ពួកយើងជាបរិស័ទនៃនន្ទបណ្ឌិតតាបស បានមកកាន់សំណាក់នៃលោកដ៏ចម្រើន សោណបណ្ឌិតដ៏ចម្រើន ចូរស្តាប់ពាក្យនៃខ្ញុំផង នៃបរិស័ទរបស់នន្ទបណ្ឌិតតាបសផង ដូច្នេះ ។

គាថាទាំងនេះ មានការទាក់ទងគ្នាជាក់ច្បាស់ហើយ ដោយចំណែកច្រើននោះឯង ។ ឯក្នុងទីនេះ ខ្ញុំនឹងពោលចំពោះពាក្យ ដែលមិនទាន់ជាក់ច្បាស់ប៉ុណ្ណោះ ។ បទថា **បវេទយ** សេចក្តីថា តាបសក្រាបទូលថា សូមទ្រង់ត្រាស់ប្រាប់វត្ថុនោះ ដែលមាននៅក្នុងទីនេះ ដែលជាទីគាប់ព្រះទ័យរបស់ទ្រង់ដល់អាត្មាចុះ ។ បទថា **ខុទ្ទកប្បានិ** សេចក្តីថា ផ្លែឈើផ្សេងៗទាំងនោះ មានរសផ្អែម មានចំណែកប្រៀបដោយរសផ្អែមបន្តិចបន្តួច ។ បទថា **វរំ វរំ** សេចក្តីថា សូមទ្រង់ជ្រើសរើសរកផ្លែដែលល្អៗអំពីផ្លែឈើទាំងនេះ ហើយសោយចុះ ។ បទថា **គិរិគព្ភរា** បានដល់ អំពីអនោតត្តស្រះ ។ បទថា

**សព្វស្ស អគ្ឃិយំ** សេចក្តីថា លោកម្ចាស់អើពើ សួរយើងខ្ញុំទាំងឡាយដោយវត្ថុណា វត្ថុនោះ ឈ្មោះថា យើងខ្ញុំទាំងឡាយទទួលហើយ ម្យ៉ាងទៀត ឈ្មោះថា វត្ថុនោះ ជារបស់ដែលលោកម្ចាស់ឲ្យហើយនោះឯង អធិប្បាយថា លោកម្ចាស់ធ្វើឲ្យជារបស់ដល់ជនទាំងអស់នេះ ដោយពាក្យមានប្រមាណប៉ុណ្ណេះ គឺធ្វើវត្ថុទាំងអស់ដល់យើងខ្ញុំទាំងឡាយមុន ។ បទថា **ឆន្ទស្សាបិ** សេចក្តីថា លោកម្ចាស់ធ្វើវត្ថុទាំងអស់ដល់យើងខ្ញុំទាំងឡាយមុនហើយ ឥឡូវនេះ នន្ទបណ្ឌិត ប្រាថ្នានឹងពោលពាក្យបន្តិចបន្តួច សូមលោកម្ចាស់ស្តាប់នូវពាក្យរបស់លោកសិន ។ បទថា **អជ្ឈាវរម្ហា** សេចក្តីថា ព្រះរាជាត្រាស់ថា យើងខ្ញុំទាំងឡាយមកហើយ ដោយហេតុដទៃក៏មិនមែន តែយើងខ្ញុំទាំងឡាយ ជាបរិស័ទរបស់នន្ទបណ្ឌិតមកហើយ ដើម្បីញ៉ាំងលោកទាំងឡាយឲ្យអត់ទោស ។ បទថា **ភវំ** សេចក្តីថា លោកម្ចាស់ជាបុគ្គលឈ្មោះថា សោណបណ្ឌិត ចូរស្តាប់ចុះ ។

កាលព្រះបាទមនោជៈត្រាស់យ៉ាងនេះហើយ នន្ទបណ្ឌិតក៏ក្រោកចាកអាសនៈ ថ្វាយបង្គំមាតាបិតានិងបងប្រុស កាលចរចាជាមួយបរិស័ទ ទើបពោលថា

ពួកគហបតិមហាសាលជាង ១០០ ពួកព្រាហ្មណមហាសាល
ជាង ១០០ និងពួកក្សត្រទាំងអស់ ដែលមានជាតិខ្ពស់ មាន
យសនេះ ទាំងព្រះបាទមនោជៈដ៏ចម្រើន សូមជ្រាបតាមសំដី
របស់អាត្មាភាពចុះ ។ ពួកជនដែលមកជួបជុំគ្នា ពួកយក្ស

ពួកកូតនិងទេវតាក្មេងមានក្នុងអាស្រមក្នុងព្រៃនេះ ចូរស្តាប់នូវពាក្យរបស់អាត្មា ។ អាត្មាធ្វើនមស្ការដល់ពួកកូតហើយ នឹងនិយាយចំពោះឥសី ( ឈ្មោះសោណបណ្ឌិត ) ដែលមានវត្តល្អថា ខ្ញុំនោះហើយ ដែលកោសិយគោត្ត សន្មតថាជាដើមដៃស្តាំរបស់លោក ។ បពិត្រអ្នកមានព្យាយាម ការទំនុកបម្រុងមាតាបិតានេះ ជាបុណ្យរបស់ខ្ញុំ ដែលជាអ្នកប្រាថ្នាចិញ្ចឹមបិតា និងមាតារបស់ខ្ញុំ បពិត្រព្រះកោសិយៈ សូមលោកកុំឃាត់ខ្ញុំឡើយ ។ ការទំនុកបម្រុងមាតាបិតានុ៎ះពួកសប្បុរសបានដឹងហើយ សូមលោកលះនូវការទំនុកបម្រុងមាតាបិតានេះឲ្យដល់ខ្ញុំ លោកបានធ្វើ ( កុសល ) ដោយការខ្នះខ្នែងនិងការបម្រើ យូរយារណាស់មកហើយ ( ឥឡូវនេះខ្ញុំចង់ធ្វើ ) បុណ្យទាំងឡាយដល់មាតានិងបិតា សូមលោកប្រគល់សួគ៌ទេវលោកដល់ខ្ញុំ ។ បពិត្រឥសី លោកដឹងផ្លូវទៅកាន់សួគ៌ទេវលោក យ៉ាងណា ពួកមនុស្សក៏ដឹងចំណែកធម៌ ក្នុងធម៌ក៏យ៉ាងនោះដែរ ។ កិរិយានាំមកនូវសេចក្តីសុខដល់មាតាបិតា ដោយការខ្នះខ្នែងនិងការបម្រើ ឥឡូវនេះ ជន ( សោណបណ្ឌិត ) ហាមឃាត់ខ្ញុំនោះចាកបុណ្យ ឈ្មោះថាជាអ្នករាំងផ្លូវដ៏ប្រសើរ ( ឋានសួគ៌ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនុមញ្ញន្តុ** សេចក្តីថា ចូរដឹង គឺចូរធ្វើឲ្យ

ល្អ ឲ្យប្រចក្ស ។ បទថា **សមិតាគោ** បានដល់ មកប្រជុំព្រមហើយ ។ បទថា **អរញ្ញេ ភូតភព្យានិ** សេចក្តីថា ភូតទាំងឡាយដល់ហើយនូវដែននៃសេចក្តីចម្រើនផង ទេវតាកំលោះទាំងឡាយដែលកើតហើយផង ក្នុងហិមវន្តប្បទេសនេះ ទេវតាទាំងអស់នោះ ចូរស្តាប់ពាក្យរបស់ខ្ញុំ ។ បទថា **ឆមោកត្វាន** សេចក្តីថា ននូបណ្ឌិតតាបសនោះ កាលឲ្យសញ្ញានេះដល់បរិស័ទហើយ ធ្វើនមស្ការដល់ទេវតាទាំងឡាយដែលកើតហើយក្នុងព្រៃនោះឯង ក៏បានពោលហើយ ។ អត្ថនៃពាក្យនោះ មានអធិប្បាយថា ក្នុងថ្ងៃនេះឯង ទេវតាដែលនៅក្នុងហិមវន្តប្បទេសទាំងឡាយដ៏ច្រើន គប្បីមកប្រជុំគ្នាដើម្បីស្តាប់ធម្មកថារបស់បងប្រុសយើង ឯការថ្វាយបង្គំនេះ ជាការថ្វាយបង្គំដល់លោកទាំងឡាយ សូមលោកទាំងឡាយជាសម្លាញ់របស់ខ្ញុំ ។ ននូបណ្ឌិតនោះផ្គងអញ្ជលីដល់ទេវតាទាំងឡាយ ញុំាងបរិស័ទឲ្យជ្រាបហើយ ទើបពោលពាក្យជាដើមថា ខ្ញុំនឹងពោលជាមួយឥសី ដូច្នេះ ។ បទថា **ឥសឹ** ក្នុងគាថានោះ លោកពោលសំដៅដល់សោណបណ្ឌិត ។ បទថា **សម្មតោ** សេចក្តីថា ធម្មតាបងប្រុសទាំងឡាយ រមែងជាបុគ្គលស្មើដោយរាងកាយ ព្រោះដូច្នោះ ទើបននូបណ្ឌិតនោះសន្មតថា ខ្ញុំស្មើនឹងដៃស្តាំរបស់លោក ដូច្នេះហើយ ទើបសម្តែងថា លោកគួរអត់ទោសឲ្យដល់ខ្ញុំដោយហេតុនោះ ។ បទថា **វីរ** បានដល់ បពិត្របងជាអ្នកមានសេចក្តីព្យាយាម ជាអ្នកមានសេចក្តីប្រឹងប្រែងច្រើន ។ បទថា **បុញ្ញមិទំ ឋានំ** សេចក្តីថា ននូបណ្ឌិតពោលថា ឈ្មោះថា ការបម្រើមាតាបិតានេះជាបុណ្យ គឺជាហេតុដែលញុំាងពួកសត្វឲ្យប្រព្រឹត្តទៅព្រម

ដើម្បីកើតក្នុងស្ថានសួគ៌ ព្រោះដូច្នោះ លោកកុំឃាត់ខ្ញុំដែលធ្វើបុណ្យនោះឡើយ ។ បទថា **សត្តិហោតំ** សេចក្តីថា ពិតហើយ ធម្មតាការទំនុកបម្រុងមាតាបិតានេះ បណ្ឌិតទាំងឡាយសរសើរហើយ គឺចូលទៅដឹងហើយនិងលើកតម្កើងហើយ ។ បទថា **មមេតំ ឧប្បធិស្សជ** សេចក្តីថា សូមលោកអនុញ្ញាត គឺលះបង់ សូមឲ្យនូវការបម្រើនូវមាតាបិតានេះដល់ខ្ញុំចុះ ។ បទថា **ឧដ្ឋាន-ចារិចរិយាយ** បានដល់ ដោយសេចក្តីព្យាយាមជាហេតុឲ្យក្រោកឡើង និងដោយការបម្រើបាតជើង ។ បទថា **កតំ** បានដល់ លោកធ្វើកុសលទុកហើយអស់កាលយូរ ។ បទថា **បុញ្ញានិ** សេចក្តីថា ឥឡូវនេះ ខ្ញុំប្រាថ្នានឹងធ្វើបុណ្យក្នុងមាតាបិតាទាំង ២ ។ បទថា **មម លោកទនោ** សេចក្តីថា ននូបណ្ឌិតពោលថា សូមលោកឲ្យនូវស្ថានសួគ៌ដល់ខ្ញុំ ព្រោះថា ខ្ញុំធ្វើវត្ត គឺការបម្រើមាតាបិតាទាំង ២ នោះ នឹងបានឥស្សរិយយស ប្រមាណមិនបានក្នុងទេវលោក សូមលោកជាទាយករបស់ខ្ញុំចុះ ។ បទថា **តថេវ** សេចក្តីថា លោករមែងដឹងដោយប្រការណា សូម្បីជនដទៃដែលមាននៅក្នុងបរិស័ទនេះ ជនទាំងនោះ រមែងពោលនូវធម៌ទាំងឡាយ មានប្រការផ្សេងៗ គឺចែកនូវធម៌ពោល គឺជាអ្នកប្រព្រឹត្តឱនលំទោនចំពោះបុគ្គលដែលចម្រើនបំផុត យ៉ាងនោះដូចគ្នា ។ សួរថា ជនទាំងនោះពោលដូចម្តេច ឆ្លើយថា ជនទាំងនោះពោលថា ធម៌ គឺការបម្រើមាតាបិតានេះ ជាផ្លូវនៃស្ថានសួគ៌ ។ បទថា **សុខាវហំ** សេចក្តីថា នាំនូវសេចក្តីសុខមកឲ្យដល់មាតាបិតា ដោយឧបដ្ឋាកនិងដោយការបម្រើ ។ បទថា **តំ មំ** សេចក្តីថា សោណបណ្ឌិត ដែលជាបងប្រុស

រមែងហាម គឺរារាំងនូវខ្ញុំដែលជាអ្នកបដិបត្តិប្រពៃយ៉ាងនេះ ឲ្យឃ្លាតចាកបុណ្យនោះ ។ បទថា **អរិយមគ្គាវរោ** សេចក្តីថា រមែងហាមនូវផ្លូវដ៏ប្រសើរ នរៈនោះហាមនូវបុណ្យយ៉ាងនេះ គឺនរៈនេះ ឈ្មោះថា ជាអ្នកហាមនូវផ្លូវនៃទេវលោកពោល គឺភាពប្រសើរព្រោះឃើញវត្ថុដែលគួរស្រឡាញ់របស់ខ្ញុំ ។

កាលនន្ទបណ្ឌិតពោលយ៉ាងនេះហើយ ព្រះមហាសត្វក៏ប្រកាសថា អ្នកទាំងឡាយ បានស្តាប់ពាក្យរបស់នន្ទបណ្ឌិតនេះហើយ ឥឡូវនេះ សូមស្តាប់ពាក្យខ្ញុំម្តង ដូច្នេះហើយ ទើបពោលថា

លោកដ៏ចម្រើនទាំងឡាយ ដែលជាបរិស័ទនៃប្អូនរបស់ខ្ញុំ សូមស្តាប់ពាក្យរបស់ខ្ញុំ បពិត្រមហារាជ អ្នកណា មិនប្រព្រឹត្តធម៌ចំពោះបុគ្គលជាច្បងទាំងឡាយ ញុំាងប្រវេណីពីបុរាណឲ្យសាបសូន្យ អ្នកនោះរមែងទៅកើតក្នុងនរក ។ បពិត្រព្រះអង្គជាម្ចាស់នៃទិស ពួកជនណាឈ្លាសវៃក្នុងធម៌ (ជេដ្ឋាបចាយនធម៌) ជាប្រវេណីអំពីបុរាណ ព្រមទាំងបរិបូណ៌ដោយសណ្តាប់ធ្នាប់ ពួកជននោះ រមែងមិនទៅកាន់ទុគ្គតិទេ ។ បពិត្រព្រះអង្គជាអ្នកទ្រទ្រង់នូវបន្ទុក ( ផែន ) សូមព្រះអង្គជ្រាបយ៉ាងនេះថា មាតាបិតា បងប្អូនប្រុសស្រី ញាតិនិងផៅពង្សទាំងអស់នោះជាភារៈរបស់កូនច្បង ។ បពិត្រព្រះអង្គជាបុគ្គលប្រសើរលើរថ អាត្មាភាពដូចជានាយសំពៅ អាចនាំយកនូវភារៈដ៏ធ្ងន់ អាត្មាភាពពុំប្រមាទនូវជេដ្ឋាបចាយនធម៌ទេ ព្រោះ

អាត្មាភាពជាច្បង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភាតុរជ្ជាវរា មម** សេចក្តីថា លោកដ៏ចម្រើនទាំងឡាយ គឺព្រះរាជាទាំងអស់ ឈ្មោះថា ជាបរិស័ទប្អូនប្រុសរបស់ខ្ញុំ នាំគ្នាមកហើយ ចូរស្តាប់ពាក្យរបស់ខ្ញុំខ្លះ ។ បទថា **បរិហាបយំ** បានដល់ឲ្យសាបសូន្យដោយជុំវិញ ។ បទថា **ធម្មស្ស** បានដល់ ជេដ្ឋាបចាយនធម៌ គឺការប្រព្រឹត្តឱនលំទោនចំពោះបុគ្គលជាច្បង គឺជាធម្មប្បវេណី ។ បទថា **កុសលា** បានដល់ ឈ្លាសវៃ ។ បទថា **ចារិត្តេន ច** បានដល់ ជាអ្នកសម្បូរដោយមារយាទនិងសីល ។ បទថា **ភារា** សេចក្តីថា ជនទាំងអស់នោះដែលជារៀមច្បង គប្បីនាំទៅ គឺគប្បីបដិបត្តិ ព្រោះដូច្នោះ ជនទាំងនោះឈ្មោះថា ជាភារៈរបស់រៀមច្បងនោះ ។ បទថា **នាវិកោ វិយ** សេចក្តីថា ដូចនាយសំពៅទទួលភារៈធ្ងន់ ក្នុងសំពៅហើយ ក៏ត្រូវឧស្សាហ៍ព្យាយាមនាំសំពៅទៅកណ្តាលសមុទ្រ ដោយសួស្តី ទំនិញនិងមហាជន មួយអន្លើដោយសំពៅជាភារៈរបស់នាយសំពៅនោះតែម្នាក់ យ៉ាងណា ញាតិទាំងអស់រមែងជាភារៈរបស់ខ្ញុំនោះឯង ខ្ញុំក៏ឧស្សាហ៍ អាចបដិបត្តិមើលថែជនទាំងនោះបានដូច្នោះដូចគ្នា ទើបខ្ញុំមិនលះបង់ជេដ្ឋាបចាយនធម៌នោះ មយ៉ាងទៀត ខ្ញុំជារៀមច្បងរបស់ជនមានប្រមាណប៉ុណ្ណោះ ក៏មិនមែនខ្ញុំជារៀមច្បងរបស់សត្វលោកទាំងអស់ទៀតផង ព្រោះដូច្នោះ ទើបខ្ញុំសមគួរបដិបត្តិមាតាបិតា ព្រមទាំងនន្ទៈជាប្អូនផង ។

ព្រះរាជាទាំងអស់នោះ បានស្តាប់ពាក្យនោះហើយ ក៏នាំគ្នាត្រេកអរ

ត្រាស់ថា យើងទាំងអស់គ្នាដឹងហើយ ក្នុងថ្ងៃនេះឯងថា បានឮថា កិច្ច គឺនាទី ការបដិបត្តិមាតាបិតាទាំងឡាយ រមែងជាភារៈនៃរៀមច្បង ទើបនាំគ្នាលះបង់ នន្ទបណ្ឌិត ចូលទៅអាស្រ័យព្រះមហាសត្វ កាលទ្រង់សរសើរព្រះមហាសត្វ នោះ ទើបត្រាស់គាថា ២ ថា

ពួកយើង បានញាណដូចបុគ្គល បានអណ្តាតភ្លើងអំពីភ្លើង
ក្នុងទីងងឹត កោសិយតាបសដ៏ចម្រើន បានចុះបញ្ចាំងធម៌
ដល់ពួកយើង យ៉ាងនេះឯង ។ ព្រះអាទិត្យដែលបំភ្លឺនូវ
ទ្រព្យ ធ្វើពន្លឺ កាលរះឡើង តែងចុះបញ្ចាំងនូវរូបល្អអាក្រក់
ដល់សត្វទាំងឡាយយ៉ាងណា កោសិយៈដ៏ចម្រើន បានចុះ
បញ្ចាំងនូវធម៌ដល់ ពួកយើង ក៏យ៉ាងនោះដែរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អជ្ឈគមា្ហ** សេចក្តីថា ក្នុងកាលមុនអំពី នេះ យើងទាំងឡាយ ធ្លាក់នៅក្នុងងងឹត ដែលបិទបាំងនូវជេដ្ឋាបចាយនធម៌ ទើបមិនដឹងធម៌នោះ យើងខ្ញុំទាំងឡាយ បានកើតការដឹងឡើងក្នុងថ្ងៃនេះឯង ដូច ពន្លឺដែលរុងរឿងអំពីភ្លើង ដូច្នោះ ។ បទថា **ឯវមេវ នោ** សេចក្តីថា ភ្លើង ដែលឆេះលើកំពូលភ្នំដែលងងឹត ចែងចាំងពន្លឺដោយជុំវិញ រមែងសម្តែង រូបទាំងឡាយឲ្យប្រាកដបាន យ៉ាងណា ឥសីកោសិយគោត្ត ក៏សម្តែងធម៌ ដល់យើង យ៉ាងនោះដូចគ្នា ។ បទថា **ភាសុទោយោ** សេចក្តីថា ទេវតាដែល ជាម្ចាស់នៃពន្លឺ ជាអ្នកធ្វើនូវពន្លឺ និងជាអ្នកប្រកាសធម៌ ។

ព្រះមហាសត្វ ទម្លាយសេចក្តីជ្រះថ្លាក្នុងនន្ទបណ្ឌិតនោះហើយ ញុំាង

ព្រះរាជាទាំងនោះ ដែលមានព្រះហឫទ័យជ្រះថ្លាក្នុងនទ្ទបណ្ឌិតនោះ ព្រោះបានឃើញ បាដិហារ្យទាំងឡាយរបស់នទ្ទបណ្ឌិត អស់កាលមានប្រមាណប៉ុណ្ណេះ ឲ្យត្រឡប់មកកាន់យកនូវពាក្យរបស់ខ្លួន ដោយកម្លាំងញាណរបស់ខ្លួន បានធ្វើឲ្យព្រះរាជាទាំងអស់នោះ ជឿក្នុងខ្លួនដោយប្រការដូច្នេះ ។

លំដាប់នោះ នទ្ទបណ្ឌិតគិតថា បងប្រុសរបស់អញជាបណ្ឌិត ជាធម្ម-កថិកដ៏កំពូល បានបំបែកព្រះរាជារបស់អញទាំងអស់ ធ្វើឲ្យជាបក្ខពួករបស់ខ្លួនបាន វៀរបងប្រុសរបស់អញនេះចេញហើយ អ្នកដទៃជាទីពឹងរបស់អញមិនមានឡើយ អញនឹងអង្វរបងប្រុសរបស់អញនេះ ទើបពោលគាថានេះថា

កាលបើខ្ញុំអង្វរ យ៉ាងនេះហើយ លោកនូវតែមិនទទួល
អញ្ជលី ខ្ញុំនឹងជាអ្នកប្រព្រឹត្តតាមពាក្យ ជាអ្នកប្រើងបម្រើ
លោក ដូច្នេះ ។

អត្ថដែលជាពាក្យនៃគាថានោះ មានដូចតទៅនេះថា បើបងមិនព្រមទទួល គឺមិនទទួលអញ្ជលីរបស់ខ្ញុំ ដែលជាអ្នកអង្វរយ៉ាងនេះ ដែលខ្ញុំផ្គងដើម្បីឲ្យបងអត់ទោស សូមបងចិញ្ចឹមមាតាបិតាចុះ ឯខ្ញុំក៏នឹងប្រព្រឹត្តតាមពាក្យរបស់បង គឺនឹងជាអ្នកធ្វើតាមឱវាទ ហើយតាំងចិត្តបម្រើ ដោយការមិនខ្ជិលប្រអូស រាល់យប់ថ្ងៃ គឺខ្ញុំនឹងបដិបត្តិបង ។

តាមប្រក្រតីព្រះមហាសត្វ មិនបានប្រកាន់ទោស ឬចងពៀរក្នុងនទ្ទ-បណ្ឌិតក៏ដោយ តែកាលនទ្ទបណ្ឌិតនោះ ពោលពាក្យរឹងត្អឹងក្រៃលែង ទើបបាន ធ្វើដូច្នោះ ដើម្បីសង្កត់សង្កិនឲ្យលោកលះបង់នូវមានះ កាលមកឥឡូវ

នេះ បានស្តាប់ពាក្យរបស់លោក ទើបមានចិត្តត្រេកអរ ជ្រះថ្លាក្នុងលោក ពោលថា នែននូ៖ ឥឡូវនេះ អញលើកទោសឲ្យដល់ឯងហើយ ឯងនឹងបាន បដិបត្តិមាតាបិតា កាលនឹងប្រកាសគុណរបស់នន្ទបណ្ឌិតនោះ ទើបពោលថា

ម្នាលនន្ទ អ្នកស្គាល់ច្បាស់នូវព្រះសទ្ធម្មដែលពួកសប្បុរស សម្តែងហើយមែន អ្នកជាមនុស្សល្អ មានឫកពាល្អ ត្រូវចិត្ត យើងហើយ ។ ខ្ញុំសូមនិយាយនឹងបិតាដ៏ចម្រើន និងមាតា ដ៏ចម្រើន សូមលោកទាំងឡាយស្តាប់ពាក្យរបស់ខ្ញុំ ភារៈនេះ មិនមែនគ្រាន់តែជាភារៈរបស់ខ្ញុំក្នុងកាលម្តង ៗ ទេ ។ នន្ទ៖ ធ្វើនូវខ្ញុំដែលជាអ្នកបម្រើ នាំមកនូវសេចក្តីសុខដល់មាតា និងបិតានោះ ឲ្យជាធំហើយសូមដើម្បីការបម្រើដែរ ។ បណ្តា ( មាតានិងបិតា ) ជាព្រហ្មចារី បើលោកណាម្នាក់ ចង់បាន សូមលោកទទួលយកនន្ទ៖តាមប្រាថ្នាចុះ តើឲ្យនន្ទបម្រើលោក ណា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អរិយោ** បានដល់ ជាមនុស្សល្អ ។ បទថា **អរិយសមាចារោ** បានដល់ លោកមានការប្រព្រឹត្តរាបស្មើ ។ បទថា **ពាឡ្ហំ** សេចក្តីថា ឥឡូវនេះ លោករមែងជាទីគាប់ចិត្តដល់ខ្ញុំក្រៃលែង ។ បទថា **សុណាថ** សេចក្តីថា បពិត្រមាតានិងបិតា សូមលោកស្តាប់ពាក្យរបស់ខ្ញុំ ។ បទថា **ឆាយំ ភារោ** សេចក្តីថា ភារៈ គឺការបដិបត្តិមាតាបិតានេះ មិនមែន ត្រឹមតែជាភារៈរបស់ខ្ញុំម្តងម្កាលនោះឡើយ ។ បទថា **តំ មំ** សេចក្តីថា លោក

ទាំងឡាយ បានសម្គាល់នូវការបម្រើមាតាបិតានោះជាភារៈ ទើបចិញ្ចឹមលោកទាំងឡាយបាន ។ បទថា **ឧបដ្ឋានាយ យាចតិ** សេចក្តីថា នន្ទៈបានមកអង្វរខ្ញុំដើម្បីសូមបម្រើលោកទាំង ២ ខ្ញុំះ ។ បទថា **យោ ចេ ឥច្ឆតិ** សេចក្តីថា ដ្បិតថា ខ្ញុំមិនសមគួរនឹងពោលថា ចូរអ្នកបម្រើមាតា ឬបិតារបស់បង តែបណ្តាលោកទាំង ២ ដែលជាអ្នកស្ងប់រម្ងាប់ហើយ ដែលប្រព្រឹត្តព្រហ្មចរិយៈ បើលោកណាប្រាថ្នា ខ្ញុំនឹងប្រាប់ដល់លោកនោះ បណ្តាលោកទាំង ២ សូមលោកជ្រើសរើសយកនន្ទៈតាមសេចក្តីប្រាថ្នាចុះ លោកទាំងឡាយរមែងពេញចិត្តនន្ទៈប្អូនប្រុសរបស់ខ្ញុំនោះ ក្នុងបណ្តាលោកទាំង ២ នន្ទៈនេះ សមគួរបម្រើលោកណា ព្រោះថា យើងទាំង ២ នាក់ ក៏ជាបុត្តរបស់លោកទាំងអស់គ្នានោះឯង ។

លំដាប់នោះ ទើបមាតាក្រោកឡើងអំពីអាសនៈពោលថា នែបាសោណបណ្ឌិត ប្អូនប្រុសរបស់បា ទៅអស់កាលយូរហើយ គេមកហើយអំពីទីឆ្ងាយយ៉ាងនេះ ម្តាយក៏មិនអាចអង្វរបាន ព្រោះថា យើងទាំង ២ នាក់ បានអាស្រ័យបាហើយ តែឥឡូវនេះ បាបានអនុញ្ញាតហើយ ម៉ែក៏នឹងបានឱបកូននន្ទៈ ដែលប្រព្រឹត្តព្រហ្មចរិយៈនេះ ដោយដើមដៃទាំង ២ ហើយគប្បីបាននូវការថើបសីសៈ ដើម្បីប្រកាសសេចក្តីនេះ ទើបពោលគាថានេះថា

នែសោណៈកូន យើងអាស្រ័យនឹងអ្នក អ្នកអនុញ្ញាតហើយ
គួរបានដើម្បីចូលទៅថើបក្បាលនន្ទៈ ជាព្រហ្មចារី ដូច្នេះ ។

លំដាប់នោះ ព្រះមហាសត្វពោលថា បពិត្រអ្នកម៉ែ បើដូច្នោះ កូនរមែង

អនុញ្ញាត សូមម៉ែឱបនន្ទុះ កូនប្រុសរបស់ម៉ែ ហើយថើបក្បាលនន្ទុះ សូមធ្វើសេចក្តីសោកខាងក្នុងចិត្តរបស់ម៉ែឲ្យរលត់ទៅចុះ ។ មាតាព្រះពោធិសត្វក៏ទៅរកនន្ទុះនោះ ហើយឱបនន្ទបណ្ឌិតក្នុងកណ្តាលបរិស័ទនោះឯង ហើយថើបនន្ទុះនោះត្រង់ក្បាល រំលត់សេចក្តីសោកក្នុងដួងហទយៈហើយ កាលនឹងចរចាជាមួយមហាសត្វ ទើបពោលថា

ដួងហឫទ័យរបស់ម្តាយរំជួល ព្រោះខានឃើញនន្ទុះអស់កាលយូរហើយ ដូចជាស្លឹកខ្ចីរបស់អស្សត្ថព្រឹក្ស ដែលត្រូវខ្យល់បក់ ។ វេលាណា ម្តាយដេកលក់យល់សប្តិឃើញនន្ទុះមក ក៏មានចិត្តត្រេកអរ មានចិត្តរីករាយ ( ដោយគិតថា ) នន្ទុះរបស់យើងនេះមកហើយ វេលាណា ម្តាយភ្ញាក់ឡើងមិនឃើញនន្ទុះមកទេ សេចក្តីសោកនឹងទោមនស្សជាច្រើនរឹងរឹតតែបណ្តាលឡើង ។ យូរណាស់ហើយ ស្រាប់តែក្នុងថ្ងៃនេះ ម្តាយនោះឃើញនន្ទុះមកដល់ នន្ទជាទីស្រឡាញ់នៃស្វាមីរបស់ម្តាយផង នៃម្តាយផង បានចូលមកកាន់ផ្ទុះ របស់ពួកយើង ។ នន្ទុះជាទីស្រឡាញ់ក្រៃលែងរបស់បិតា កុំឲ្យនន្ទុះទៅប្រាសចេញអំពីផ្ទុះ នៃកូន ឯនន្ទុះ ( ចង់បានអ្នកណា ) ចូរបានអ្នកនោះចុះ នន្ទុះចូរបម្រើនូវអញចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មាលុតេរិតំ** សេចក្តីថា មាតារបស់មហាសត្វពោលថា ស្លឹករបស់អស្សត្ថព្រឹក្សត្រូវខ្យល់បក់ហើយ រមែងរលាស់ទៅ

មក យ៉ាងណា ថ្ងៃនេះ ហទយៈរបស់មាតាក៏ញាប់ញ័រ ព្រោះបានឃើញនន្ទៈ ដែលចេញទៅយូរដូច្នោះដូចគ្នា ។ បទថា **សុត្តា** សេចក្តីថា នែបាសោណៈ កាលណាម្តាយដេកលក់ យល់សប្តិឃើញនន្ទៈមក ក្នុងកាលនោះ ម៉ែត្រេកអរពន់ពេក ។ បទថា **ភត្តុ ច** បានដល់ រមែងជាទីស្រឡាញ់របស់ពុកនិងម៉ែ ។ បទថា **ឆន្នោ នោ ចារិសី ឃរំ** សេចក្តីថា នែបាសោណៈ នន្ទៈកូនប្រុសរបស់ម៉ែ សូមចូលទៅកាន់បណ្ណសាលា ។ បទថា **ឃរំ** សេចក្តីថា ព្រោះហេតុនន្ទៈនោះ រមែងជាទីស្រឡាញ់ក្រៃលែងរបស់បិតា ព្រោះហេតុនោះ ទើបនន្ទៈនោះមិនត្រូវចេញអំពីផ្ទះនេះទៀត ។ បទថា **ឆន្នោ តំ** សេចក្តីថា នែបាសោណៈ នន្ទៈប្រាថ្នារបស់ណា ចូរបានរបស់នោះចុះ ។ បទថា **មំ ឆន្នោ** សេចក្តីថា នែបា សោណៈ ចូរបាបម្រើបិតារបស់អ្នកចុះ ចំណែកនន្ទៈ ចូរបម្រើម៉ែ ។

លំដាប់នោះ ព្រះមហាសត្វទទួលពាក្យរបស់មាតាថា សូមប្រព្រឹត្តទៅតាមពាក្យរបស់មាតាយ៉ាងនេះចុះ ដូច្នេះហើយ ទើបពោលទូន្មានប្អូនប្រុសថា នែប្អូននន្ទៈ ឯងបានចំណែកបែងចែករបស់បងហើយ ធម្មតាមាតាជាបុព្វការីយ៉ាងក្រៃលែង ប្អូនកុំប្រមាទ គប្បីតាំងចិត្តបដិបត្តិលោកចុះ កាលប្រកាសគុណរបស់មាតា ទើបពោលគាថា ២ ថា

ម្នាលឥសី មាតាជាអ្នកឈឺឆ្អាល ជាទីពឹង ជាអ្នកឲ្យរស
( ទឹកក្សីរៈ ) ដល់ពួកយើងជាមុន ជាផ្លូវនៃសួគ៌ទេវលោក
ចង់បានអ្នក ។ មាតាជាអ្នកឲ្យរសជាមុន ជាអ្នកគ្រប់គ្រងដែល

យើងចូលទៅអាស្រ័យបុណ្យ ជាផ្លូវនៃសួគ៌ទេវលោក ម្នាល
ឥសី មាតាចង់បានអ្នក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អនុកម្បកា** បានដល់ ជាអ្នកមានចិត្តទន់ភ្លន់ ។ បទថា **បុព្វេ រសទទី** បានដល់ ជាអ្នកឲ្យនូវរស គឺទឹកដោះរបស់ខ្លួនជាលើកដំបូងនោះឯង ។ បទថា **មាតា តំ** សេចក្ដីថា មាតារបស់យើងមិនប្រាថ្នាយើង ជ្រើសរើសយកអ្នក គឺប្រាថ្នាអ្នក ។ បទថា **គោត្តី** បានដល់ ជាអ្នកផ្ដុំផ្ដើម ។ បទថា **បុញ្ញូបសញ្ហិតា** បានដល់ ជាទីនៅអាស្រ័យនៃបុណ្យ ជាអ្នកឲ្យនូវបុណ្យ ។

ព្រះមហាសត្វ កាលពណ៌នាគុណរបស់មាតា ដោយគាថា ២ យ៉ាងនេះហើយ លុះមាតាត្រឡប់មកអង្គុយក្នុងអាសនៈវិញ ទើបពោលទូន្មានប្អូនទៀតថា នែនន្ទ: ឯងបានមាតាដែលធ្វើកិច្ចដែលគេធ្វើបានដោយក្រទុកហើយ សូម្បីយើងទាំង ២ នាក់ មាតាលោកក៏បានបម្រើមកដោយលំបាក ឥឡូវនេះ ឯងកុំប្រមាទ ចូរព្យាយាមបដិបត្តិមាតាចុះ ឯងកុំឲ្យលោកបរិភោគផ្លែឈើតូចធំទាំងឡាយដែលមិនឆ្ងាញ់ទៀត កាលប្រកាសថា មាតាបានជាអ្នកធ្វើកិច្ចដ៏លំបាក ដែលអ្នកដទៃនឹងធ្វើបានក្នុងកណ្ដាលបរិស័ទនោះឯង ទើបពោលថា

មាតាកាលប្រាថ្នាចង់បានផ្លែពីកូន រមែងនមស្ការទេវតា សួរ
នក្ខត្តឫក្សទាំងឡាយផង សួររដូវ និងឆ្នាំទាំងឡាយផង ។
កាលមាតានោះ មានរដូវលាងស្អាតហើយ សត្វក៏ចុះមកកាន់
គភ៌សិប់ មាតាជាស្រ្តី មានសេចក្ដីចាញ់ផ្ទៃដោយហេតុនេះ

ព្រោះហេតុនោះ បានជាបណ្ឌិតហៅថា សុហទា ( មានដួងហឫទ័យល្អ ) ។ មាតារក្សា ( ផ្ទៃ ) អស់ ១ ឆ្នាំ ឬថយពី ១ ឆ្នាំ ហើយប្រសូតបុត្តមក ព្រោះហេតុនោះ បានជាបណ្ឌិត ហៅមាតានោះថា ជនយន្តីផង ជនេត្តីផង ( អ្នកបង្កើតកូន ) មាតាញុំាងកូនដែលកំពុងយំឲ្យត្រេកអរដោយទឹកក្សីរៈផង ដោយការបំពេផង ដោយការឱបក្រសោបផង ព្រោះហេតុនោះ បានជាបណ្ឌិតហៅថា តោសេន្តី ( អ្នកញុំាងកូនឲ្យត្រេកអរ ) ។ តពីនោះមក មាតាធ្វើនូវសេចក្តីស្រឡាញ់រាប់អាន ហើយក្រឡេកមើលទារកដែលនៅពុំទាន់ដឹងក្តី ក្នុងទីមានខ្យល់និងកម្តៅថ្ងៃដ៏ពន្លឹក ព្រោះហេតុនោះ បានជាបណ្ឌិតហៅថាបោសេន្តី ( អ្នកចិញ្ចឹមកូន ) ។ ទ្រព្យណាខាងមាតាផង ទ្រព្យណាខាងបិតាផង មាតាក៏គ្រប់គ្រងទ្រព្យទាំង ២ ចំណែកដើម្បីកូននោះ ( ដោយបំណងថាទ្រព្យនេះ ) ត្រូវមានដល់កូនរបស់យើង ។ មាតារមែងលំបាកដោយការបង្ហាត់បង្រៀនកូនដូច្នេះថា ម្នាលកូន ( ឯងចូរកុំប្រមាទក្នុងរាជត្រកូលជាដើម ) យ៉ាងនេះ ម្នាលកូន ( ឯងចូរធ្វើការ ) ឯណោះ ។ កាលបើកូនមានវ័យចម្រើនឡើងហើយមាតា ( បានដឹង ) កូននោះប្រមាទក្នុងប្រពន្ធរបស់អ្នកដទៃ ក្នុងពេលអធ្រាត្រ ហើយមិនមកក្នុងវេលាល្ងាច ក៏

រមែងលំបាកចិត្តដូច្នេះ ។ សត្វដែលមាតាចិញ្ចឹមដោយត្រដាបត្រដួសយ៉ាងនេះ ហើយមិនបម្រើមាតា ប្រព្រឹត្តខុសក្នុងមាតានោះ តែងទៅកើតក្នុងនរក ។ សត្វដែលបិតាចិញ្ចឹមដោយត្រដាបត្រដួសយ៉ាងនេះ ហើយមិនបម្រើបិតា ប្រព្រឹត្តខុសក្នុងបិតានោះ តែងទៅកើតក្នុងនរក ។ យើងបានឮមកថា សូម្បីតែទ្រព្យរបស់កូនអ្នកចង់បានទ្រព្យ តែងវិនាសទៅវិញ ឬកូននោះរមែងក្រីក្រលំបាក ព្រោះមិនបម្រើមាតា ។ យើងបានឮមកថា សូម្បីតែទ្រព្យរបស់កូនអ្នកចង់បានទ្រព្យ តែងវិនាសទៅវិញ ឬកូននោះ រមែងក្រីក្រលំបាក ព្រោះមិនបម្រើបិតា ។ បណ្ឌិតបម្រើមាតា គប្បីបាននូវសុខនុ៎ះ គឺសេចក្តីត្រេកអររីករាយ ការសើចលេងសព្វៗកាល ។ បណ្ឌិតបម្រើបិតា គប្បីបាននូវសុខនុ៎ះ គឺសេចក្តីត្រេកអររីករាយ ការសើចលេងសព្វៗកាល ។ ទាន ១ វាចាជាទីស្រឡាញ់ ១ ការប្រព្រឹត្តជាប្រយោជន៍ក្នុងលោកនេះ ១ ភាពនៃបុគ្គលមានខ្លួនប្រព្រឹត្តស្មើក្នុងជេដ្ឋាបចាយនធម៌នោះ ៗ តាមសមគួរ ១ ។ សង្គហធម៌ទាំង ៤ នុ៎ះឯង រមែងប្រព្រឹត្តទៅក្នុងលោក ដូចជាផ្ចិតនៃកង់រថ ដែលវិលទៅ បើសង្គហធម៌ទាំងនុ៎ះ មិនមានទេ មាតាមិនត្រូវបាននូវសេចក្តីរាប់អាននិងការបូជា ព្រោះហេតុនៃកូន ទាំងបិតា ក៏មិនត្រូវបាននូវសេចក្តីរាប់អាននឹង

ការបូជា ព្រោះហេតុនៃកូន ពួកបណ្ឌិត រមែងឃើញដោយល្អនូវសង្គហធម៌ទាំងនុ៎ះ ព្រោះហេតុនោះ បណ្ឌិតទាំងនោះ រមែងដល់នូវភាពជាធំ ទាំងជាអ្នកគួរសរសើរ ។ មាតាបិតាជាអ្នកអនុគ្រោះដល់ពួកសត្វ គឺបុត្ត បណ្ឌិតហៅថា ព្រហ្មផង បុព្វាចារ្យផង អាហុនេយ្យៈផង របស់កូនទាំងឡាយ ។ ព្រោះហេតុនោះ បណ្ឌិតគប្បីនមស្ការ ធ្វើសក្ការៈចំពោះមាតាបិតានោះ ដោយបាយ ទឹក សំពត់ ទីដេក គ្រឿងអប់ដោយការផ្ងូតនិងការលាងជើង ។ បណ្ឌិតទាំងឡាយ រមែងសរសើរនូវបុគ្គលនោះ ព្រោះតែការបម្រើចំពោះមាតាបិតានោះ លុះបុគ្គលនោះ លះលោកនេះទៅ រមែងរីករាយ ក្នុងឋានសួគ៌ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បុត្តផលំ** បានដល់ ផ្លែ គឺបុត្ត ។ បទថា **ទេវតាយ នមស្សតិ** សេចក្ដីថា រមែងធ្វើនមស្ការ បួងសួងទេវតាថា សូមឲ្យបុត្តកើតមានដល់ខ្ញុំចុះ ។ បទថា **នក្ខត្តានិ ច បុច្ឆតិ** សេចក្ដីថា និងតែងសួរដល់នក្ខត្តឫក្សទាំងឡាយយ៉ាងនេះថា កូនកើតហើយ ដោយឫក្សណាយាមណា ទើបមានអាយុយឺនយូរ កើតឫក្សណា យាមណា មានអាយុខ្លី ។ បទថា **ឧតុសំវច្ឆរានិ ច** សេចក្ដីថា ម្យ៉ាងទៀត មាតារមែងសួរដល់រដូវនិងឆ្នាំទាំងឡាយយ៉ាងនេះថា ក្នុងបណ្ដារដូវទាំង ៦[១] កូនដែលកើតក្នុងរដូវណា

---

១-ហេមន្តរដូវ រដូវសន្សើមធ្លាក់ ១ សិសិររដូវ រដូវរងា ១ វសន្តរដូវ រដូវស្លឹកឈើលាស់ ១ គិម្ហរដូវ រដូវក្ដៅ ១ វស្សានរដូវ រដូវភ្លៀង ១ សរទរដូវ រដូវរំហើយ ១ ។

ទើបមានអាយុវែង កើតក្នុងវេលាណា ទើបមានអាយុខ្លី ឬមាតាមានអាយុប៉ុន្មាន ទើបកូនកើតមកមានអាយុវែង មាតាមានអាយុប៉ុនណា ទើបកូនកើតមកមានអាយុខ្លី ។ បទថា **ឧតុសិ ន្ហាតាយ** បានដល់ កាលរដូវកើតឡើងហើយ ឈ្មោះថា មានរដូវលាងស្អាតហើយ គឺឈ្មោះថា មាតាមានរដូវ ។ បទថា **អវក្កន្តោ** សេចក្ដីថា ការតាំងគភ៌ រមែងមាន ព្រោះការប្រជុំព្រមនៃហេតុ ៣ ប្រការ ទើបគភ៌តាំងឡើងក្នុងផ្ទៃ[១] ។ បទថា **តេន** សេចក្ដីថា មាតានោះ រមែងចាញ់ផ្ទៃ ព្រោះគភ៌នោះ ។ បទថា **តេន** សេចក្ដីថា ក្នុងកាលនោះ ទើបមាតាកើតការស្រឡាញ់ក្នុងកូនប្រុសស្រី ដែលជាសត្វកើតក្នុងផ្ទៃរបស់ខ្លួន ព្រោះហេតុនោះ ទើបលោកហៅថា **សុហទា** គឺស្រីដែលមានចិត្តល្អ ។ បទថា **តេន** សេចក្ដីថា ព្រោះហេតុនោះ ទើបលោកហៅថា **ជនយន្តី** ខ្លះ **ជនេត្តី** ខ្លះ ប្រែថា អ្នកញ៉ាំងកូនឲ្យកើត ។ បទថា **អង្គុតា-វុរណេន ច** សេចក្ដីថា ដោយការឲ្យកូនដេកក្នុងរវាងដោះទាំង ២ ញ៉ាំងសម្ផស្សនៃសរីរៈឲ្យផ្សាយទូទៅហើយ ទើបឲ្យកម្ដៅដោយគ្រឿងដណ្ដប់ គឺអវយវៈនោះឯង ។ បទថា **តោសេន្តី** បានដល់ ឲ្យចំណាំ គឺឲ្យត្រេកអរ ។ បទថា **មន្តំ កត្វា ឧទិក្ខតិ** សេចក្ដីថា មាតាធ្វើនូវការព្រួយបារម្ភយ៉ាងនេះថា ឧហ្ន៎ ខ្យល់បក់ កម្ដៅថ្ងៃខ្លាំងមកលើកូនរបស់អញ រមែងសម្លឹងមើលដោយទឹកចិត្តស្រឡាញ់ ។ បទថា **ឧភយមេ្បតស្ស** សេចក្ដីថា មាតារមែងមិនត្រូវ

---

២-ហេតុ ៣ ប្រការគឺ មាតាបិតរោ ច សន្និបតិតា ហោន្តិ មាតាបិតានៅរួមគ្នា ១ មាតា ច ឧតុនី ហោតិ មាតាមានរដូវ ១ គព្ភោ ច បច្ចុបដ្ឋិតោ ហោតិ សត្វដែលនឹងកើតក្នុងផ្ទៃមាតានោះ មាន ១ ។

ការឲ្យនូវទ្រព្យទាំង ២ ចំណែកនេះដល់ជនដទៃ នឹងរក្សាទុកក្នុងឃ្លាំងដែលមាំទាំជាដើម ដើម្បីជាប្រយោជន៍កូននេះ ។ បទថា **ឯវំ បុត្ត អធុំ បុត្ត** សេចក្តីថា មាតាឲ្យកូនសិក្សាថា នែកូន ឯងកុំប្រមាទក្នុងរាជត្រកូលជាដើម យ៉ាងនេះ ម្យ៉ាងទៀត ចូរឯងធ្វើកម្មយ៉ាងនោះ ។ បទថា **ឥតិ មាតា វិហញ្ញតិ** បានដល់ រមែងហត់នឿយ ។ បទថា **បត្តយោព្វនេ** សេចក្តីថា កាលបុត្តដល់នូវកាលជាកំលោះ ឬជាក្រមុំ មាតាដឹងថា កូននោះស្រវឹង ក្នុងភរិយាអ្នកដទៃ រហូតងប់ងល់ មិនទាន់ត្រឡប់មក ទើបសម្លឹងមើលកូន ដោយភ្នែកដែលជោកដោយទឹកភ្នែក ។ បទថា **វិហញ្ញតិ** បានដល់ ហត់នឿយ ។ បទថា **កិច្ឆាភតោ** បានដល់ កូនដែលមាតាចិញ្ចឹម គឺទំនុកបម្រុងមកដោយសេចក្តីលំបាក ។ បទថា **មិច្ឆាចរិត្វាន** បានដល់ មិនបដិបត្តិមាតា ។ បទថា **ធនាបិ** បានដល់ ទ្រព្យសម្បត្តិទាំងអស់ ម្យ៉ាងទៀត បាលីក៏យ៉ាងនោះ ដូចគ្នា ។ មានពាក្យដែលលោកអធិប្បាយទុកថា ខ្ញុំបានស្តាប់មកថា ទ្រព្យដែលកើតឡើងដល់កូនដែលចង់បានទ្រព្យ តែមិនបដិបត្តិមាតា រមែងវិនាសអន្តរធានទៅ ។ បទថា **កិច្ឆំ វា សោ** សេចក្តីថា ទ្រព្យរបស់បុគ្គលនោះ រមែងវិនាសទៅខ្លះ រមែងដល់នូវសេចក្តីលំបាកឯងខ្លះ ដោយប្រការ ដូច្នេះ ។ បទថា **លព្ភមេតំ** សេចក្តីថា សេចក្តីសុខ មានការត្រេកអរជាដើម ក្នុងលោកនេះនិងលោកខាងមុខ បណ្ឌិតដឹងច្បាស់ គប្បីបានទំនុកបម្រុងមាតា អធិប្បាយថា បណ្ឌិតបែបនោះ អាចបាន ។ បទថា **ធានញ្ច** សេចក្តីថា កូនគប្បីឲ្យទេយ្យធម៌ដល់មាតាបិតាទាំង ២ គប្បីចរចានូវពាក្យដែលជាទីស្រឡាញ់ គប្បី

ប្រព្រឹត្តប្រយោជន៍ ដោយអំណាចការធ្វើកិច្ច ដែលកើតឡើងហើយឲ្យសម្រេច
ទៅ ។ បទថា **ធម្មេសុ** សេចក្តីថា បុគ្គលគប្បីធ្វើនូវភាពជាបុគ្គលមានខ្លួនស្មើ
ក្នុងធម៌ គឺភាពជាបុគ្គលប្រព្រឹត្តឱនលំទោន ដល់បុគ្គលដែលចម្រើន ក្នុងទី
នោះៗ គឺក្នុងកណ្តាលបរិស័ទ ឬក្នុងទីកំបាំង ដោយអំណាចការក្រាបថ្វាយ
បង្គំជាដើម កូនធ្វើអភិវាទជាដើមក្នុងទីកំបាំង ហើយមិនព្រមធ្វើចំពោះមុខ
មនុស្សទូទៅ មិនសមគួរឡើយ គប្បីជាអ្នកប្រព្រឹត្តស្មើក្នុងទីទាំងអស់នោះ
ឯង ។ បទថា **ឃតេ ច សង្គហា ឆាស្សុ** សេចក្តីថា បើសង្គហវត្ថុទាំង ៤
ប្រការនោះ មិនគប្បីមានសោត ។ បទថា **សមបេក្ខន្តិ** សេចក្តីថា បណ្ឌិត
ទាំងឡាយរមែងឃើញទោសដោយន័យ ដោយហេតុ ដោយប្រពៃ ។ បទថា
**មហត្តំ** បានដល់ ភាពជាបុគ្គលប្រសើរ ។ បទថា **ព្រហ្មា** បានដល់ មាតា
បិតាទាំងឡាយជាបុគ្គលដ៏ឧត្តម ជាបុគ្គលប្រសើរបំផុត ស្មើដោយព្រហ្ម
របស់កូនទាំងឡាយ ។ បទថា **បុព្វាចរិយា** បានដល់ ជាអាចារ្យដំបូង ។
បទថា **អាហុនេយ្យា** បានដល់ ជាបុគ្គលគួរទទួលនូវរបស់ដែលគេផ្ចិតផ្ចង់
គឺជាបុគ្គលសមគួរដល់សក្ការៈគ្រប់យ៉ាង ។ បទថា **អន្នេន អថោ** បានដល់
ទាំងបាយ ទាំងទឹក ។ បទថា **បេច្ច** សេចក្តីថា ក្នុងទីបំផុតនៃការធ្វើកាល
កិរិយា កូននោះទៅអំពីលោកនេះហើយ រមែងត្រេកអរក្នុងស្ថានសួគ៌ ។

ព្រះមហាសត្វ បានសម្តែងធម្មទេសនាចប់ ដូចលើកភ្នំសិនេរុឡើង
ដោយប្រការដូច្នេះ ។ ព្រះរាជាទាំងនោះ និងពួកពលនិកាយទាំងអស់ បាន
ស្តាប់ព្រះធម្មទេសនានេះហើយ នាំគ្នាជ្រះថ្លាហើយ ។ លំដាប់នោះ ទើបព្រះ

មហាសត្វទូន្មានព្រះរាជាទាំងនោះ ឲ្យតាំងនៅក្នុងសីល ៥ ហើយទូន្មានថា សូមមហាបពិត្រទាំងឡាយ ជាអ្នកមិនប្រមាទក្នុងកុសល មានទានជាដើមចុះ ហើយបញ្ជូនព្រះរាជាទាំងនោះត្រឡប់ទៅ ។ ព្រះរាជាទាំងឡាយ ទ្រង់គ្រប់គ្រងរាជសម្បត្តិដោយធម៌ ក្នុងកាលអស់ព្រះជន្មាយុ ក៏ធ្វើទេវនគរឲ្យពេញ ។ សោណបណ្ឌិត និងនន្ទបណ្ឌិត ២ នាក់បងប្អូន បានបដិបត្តិមាតាបិតា ដរាបដល់អស់អាយុ ក៏បានទៅកើតក្នុងព្រហ្មលោក ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយ ទើបទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុចិញ្ចឹមមាតាបិតា បានតាំងនៅក្នុងសោតាបត្តិផលហើយ ទើបទ្រង់ប្រជុំជាតកថា មាតាបិតាក្នុងកាលនោះ បានមកជាត្រកូលមហារាជក្នុងកាលឥឡូវនេះ ព្រះបាទមនោជៈក្នុងកាលនោះ បានមកជាសារីបុត្ត ព្រះរាជា ១០១ អង្គ ក្នុងកាលនោះ បានមកជាអសីតិមហាថេរៈនិងមហាថេរៈដទៃៗ ពួកពលនិកាយ ២៤ អក្ខោភិនី ក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ក្នុងកាលឥឡូវនេះ នន្ទបណ្ឌិតក្នុងកាលនោះ បានមកជាអានន្ទ ឯសោណបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា សោណនន្ទជាតក ចប់**

**សត្តតិនិបាត ចប់**

# អសីតិនិបាត ជាតក

##ចុល្លហំសជាតក

[ ១៦៣ ] ( រាជហង្សឈ្មោះធតរដ្ឋៈពោលថា ) ម្នាលហង្សឈ្មោះសុមុខៈ ពួកបក្សីកាលមិនគយគន់មើល ហើរចេញទៅ អ្នកចូរទៅចុះ កុំប្រាថ្នា ( នៅក្នុងទីនេះឡើយព្រោះថា ) ភាពនៃអ្នកជាសម្លាញ់នឹងយើងដែលជាប់ចំណងមិនមានទេ ។

[ ១៦៤ ] ( ហង្សសេនាបតីឈ្មោះសុមុខៈក្រាបបង្គំទូលថា ) ទូលព្រះបង្គំជាខ្ញុំ ទៅក្តី មិនទៅក្តី ទូលព្រះបង្គំជាខ្ញុំ មិនមែនមិនស្លាប់ ដោយការទៅឬការមិនទៅទេ ទូលព្រះបង្គំជាខ្ញុំ ចូលទៅរកព្រះអង្គដែលដល់នូវសេចក្តីសុខហើយ នឹងលះព្រះអង្គដែលដល់នូវសេចក្តីទុក្ខដូចម្តេចកើត ។ សេចក្តីស្លាប់ជាមួយនឹងព្រះអង្គក្តី ការរស់នៅវៀរចាកព្រះអង្គក្តី សេចក្តីស្លាប់នោះប្រសើរជាង ទូលព្រះបង្គំជាខ្ញុំតែវៀរចាកព្រះអង្គហើយ រស់នៅមិនប្រសើរសោះឡើយ ។ បពិត្រមហារាជ ទូលព្រះបង្គំជាខ្ញុំ លះចោលព្រះអង្គ ដែលដល់ ( នូវសេចក្តីទុក្ខ ) យ៉ាងនេះ ដោយសភាវៈណា សភាវៈនោះ មិនមែនជាធម៌ទេ បពិត្រព្រះអង្គជាធំលើបក្សី ដំណើរណារបស់ព្រះអង្គ ដំណើរនោះ ទូលព្រះបង្គំជាខ្ញុំ ក៏គាប់ចិត្តដែរ ។

[ ១៦៥ ] ( រាជហង្ស... ) ដំណើរដូចម្តេចរបស់ខ្ញុំ ដែលជាប់អន្ទាក់ហើយ ដទៃអំពីរោងគ្រួ ដំណើរនោះ ទៅជាពេញចិត្តដល់អ្នកដែលមានប្រាជ្ញាជាអ្នកផុតអំពីអន្ទាក់ដូចម្តេច ។ ម្នាលអ្នកជាបក្សី កាលបើយើងទាំង ២ នាក់អស់ជីវិតហើយ អ្នកឃើញនូវប្រយោជន៍ដូចម្តេច របស់ខ្ញុំផង របស់

អ្នកផង របស់ពួកញាតិដ៏សេសផង ។ ម្នាលអ្នកមានស្លាបទាំងពីរ ដូចជាមាស ការលះបង់នូវជីវិតរបស់អ្នកណា ការលះបង់នូវជីវិត របស់អ្នកនោះហាក់ដូចជាធ្វើក្នុងទីងងឹត ដោយសេចក្ដីល្ងិតល្ងង់ អ្នកកាលលះបង់នូវជីវិតព្រោះគុណដែលមិនជាក់ច្បាស់ដូច្នោះ តើព្រោះចុះឃើញនូវប្រយោជន៍អ្វី ។

[ ១៦៦ ] ( ហង្សសេនាបតី ... ) បពិត្រព្រះអង្គដ៏ប្រសើរផុត ព្រះអង្គមិនជ្រាបនូវប្រយោជន៍ដែលធ្លាក់ចុះ ក្នុងធម៌ដូចម្ដេច ដ្បិតធម៌ ដែលពួកសត្វគោរពហើយ រមែងបង្ហាញនូវសេចក្ដីចម្រើនដល់សត្វទាំងឡាយ ។ ទូលព្រះបង្គំជាខ្ញុំនោះ កាលឃើញនូវធម៌ផង នូវប្រយោជន៍ដែលកើតអំពីធម៌ផងពិចារណាឃើញនូវសេចក្ដីស្រឡាញ់ចំពោះព្រះអង្គផង បានជាមិនប្រាថ្នាជីវិតទេ ។ មិត្តណា កាលរឭកឃើញនូវធម៌ហើយ មិនលះបង់មិត្តក្នុងកាលដែលមានសេចក្ដីអន្តរាយ ព្រោះហេតុនៃជីវិត ធម៌របស់មិត្តនោះ ឈ្មោះថាជាធម៌របស់សប្បុរសទាំងឡាយដោយពិត ។

[ ១៦៧ ] ( រាជហង្ស... ) ធម៌នោះអ្នកបានសន្សំហើយ ទាំងសេចក្ដីស្រឡាញ់ចំពោះយើងៗ ក៏បានដឹងច្បាស់ហើយ អ្នកចូរធ្វើតាមសេចក្ដីប្រាថ្នារបស់យើងនុ៎ះ អ្នក គឺយើងបានអនុញ្ញាតហើយ ចូរទៅចុះ ។ ម្នាលអ្នកបរិបូណ៌ដោយប្រាជ្ញា មួយទៀត ការបែកបាក់នៃពួកញាតិណា ដែលយើងបានបិទបាំងហើយ ក្នុងកាលដែលប្រព្រឹត្តទៅយ៉ាងនេះ ការបែកបាក់នៃពួកញាតិនោះ អ្នកគួរបិទបាំងទុកឲ្យល្អចុះ ។

[ ១៦៨ ] ( អភិសម្ពុទ្ធគាថា ) កាលដែលអរិយហង្សទាំងឡាយ ជា

សត្វមានការប្រព្រឹត្តដ៏ប្រសើរ កំពុងតែប្រឹក្សាគ្នាយ៉ាងនេះ ស្រាប់តែនាយនេសាទមកប្រាកដដូចជាសេចក្ដីស្លាប់ ដែលប្រាកដដល់បុគ្គលឈឺ ។ ហង្សទាំង ២ នោះមានប្រយោជន៍ ( ដល់គ្នានឹងគ្នា ) យូរអង្វែងហើយ បានឃើញច្បាស់នូវសត្រូវ ក៏ទំនៅស្ងៀមទាំង ២ នាក់ មិនក្រើកចាកទ្រនំឡើយ ។ ព្រានព្រៃជាសត្រូវនៃសត្វស្លាប បានឃើញហង្សឈ្មោះសុមុខៈ នូវរាជហង្សឈ្មោះ ធតរដ្ឋៈ ជាស្ដេចនៃបក្សី កាលខិតចូលមករកគ្នាអំពីទីនោះៗ ក៏ស្ទុះទៅដោយប្រញាប់ ។ លុះនាយនេសាទនោះ ស្ទុះដោយប្រញាប់ទៅជិតពួកបក្សីប្រសើរហើយ ក៏គិតថា សត្វហង្សទាំង ២ នេះ ជាប់ហើយញាប់ញ័រ ។ ក៏នាយនេសាទបានឃើញសត្វហង្ស ១ ជាប់អន្ទាក់ហើយទំនៅ និងសត្វហង្ស ១ ទៀត ដែលមិនជាប់អន្ទាក់ចូលមករកសត្វហង្សដែលជាប់អន្ទាក់ហើយទំនៅ សម្លឹងមើលនូវហង្សដែលមានទោស ។ លំដាប់អំពីនោះទៅ នាយនេសាទនោះមានសេចក្ដីសង្ស័យ ក៏បានសួរនូវសត្វហង្សមានពណ៌សមានកាយដ៏ធំ ជាអធិបតីលើហ្វូងនៃបក្សីថា សត្វហង្សដែលជាប់អន្ទាក់ដ៏ធំដល់ម្ល៉ោះ មិនធ្វើនូវទិស ( ដើម្បីហើរទៅ ) ដោយហេតុណា ( ហេតុនោះគួរហើយ ) ម្នាលសត្វស្លាប ចុះអ្នកមិនជាប់អន្ទាក់ទេ ជាសត្វមានកម្លាំង ហេតុអ្វីក៏មិនហើរទៅ ។ សត្វបក្សីនេះត្រូវជាអ្វីនឹងអ្នក អ្នករួច ( អំពីអន្ទាក់ហើយ ) ចូលមករកបក្សីដែលជាប់អន្ទាក់វិញ បក្សីទាំងឡាយនាំគ្នាហើរចោលទៅអស់ហើយ ប៉ុន្តែអ្នកក្រាញនៅតែម្នាក់ឯង ។

[ ១៦៩ ] ( ហង្សសេនាបតី... ) បពិត្រនាយនេសាទ ជាសត្រូវនៃ

សត្វបក្សី ឯហង្សនោះជាព្រះរាជានៃខ្ញុំផង ជាសម្លាញ់ស្មើដោយជីវិតនៃខ្ញុំផង ខ្ញុំនឹងមិនលះបង់នូវហង្សនោះដរាបដល់សេចក្តីស្លាប់មកដល់ ។

[ ១៧០ ] ( នាយនេសាទ... ) ចុះហេតុអ្វីហង្សនោះ ក៏មិនឃើញនូវអន្ទាក់ដែលគេដាក់ហើយ ដំណើរនេះហើយ ដែលជាដំណើរសម្រាប់ពួកសត្វធំៗ ពួកសត្វធំៗគួរដឹងនូវសេចក្តីអន្តរាយ ។

[ ១៧១ ] ( ហង្សសេនាបតី ... ) កាលណា ដែលសត្វជាអ្នកមានសេចក្តីវិនាស ក្នុងកាលជាទីអស់ទៅនៃជីវិត កាលនោះ សត្វនោះ សូម្បីចូលមកជិតដល់សំណាញ់និងអន្ទាក់ក៏នៅតែមិនដឹងឡើយ ។

[ ១៧២ ] ( នាយនេសាទ... ) ម្នាលសត្វមានប្រាជ្ញាច្រើន មែនហើយ អន្ទាក់ទាំងឡាយយើងបានដាក់ហើយជាច្រើន កាលបើសត្វមានជីវិតអស់ទៅយ៉ាងនេះ សត្វស្លាបទាំងឡាយ តែងចូលមកជាប់នឹងអន្ទាក់ដ៏កំបាំង ។

[ ១៧៣ ] ( ហង្សសេនាបតី... ) សូមឲ្យការនៅរួមជាមួយនឹងអ្នកនេះ មានសុខជាកំរៃ សូមអ្នកអនុញ្ញាតយើងខ្ញុំ សូមអ្នកឲ្យជីវិតដល់យើងខ្ញុំ ។

[ ១៧៤ ] ( នាយនេសាទ... ) ឯងមិនជាប់ ( អន្ទាក់ ) អញទេ ទាំងអញទៀតសោត ក៏មិនប្រាថ្នាសម្លាប់ឯងដែរ ចូរឯងទៅអំពីទីនេះតាមប្រាថ្នា យ៉ាងឆាប់ ហើយរស់នៅមិនមានទុក្ខ អស់កាលជាអង្វែងចុះ ។

[ ១៧៥ ] ( ហង្សសេនាបតី... ) ខ្ញុំប្រាសចាកជីវិតនៃបក្សីនោះហើយ មិនប្រាថ្នាជីវិតទេ ។ បើអ្នកត្រេកអរដោយហង្ស ១ ចូរអ្នកលែងនូវហង្សនេះទៅ ចូរបរិភោគនូវខ្ញុំវិញចុះ ។ យើងទាំង ២ នាក់នោះ មានកម្ពស់

ទំហំនិងវ័យស្មើៗគ្នា អ្នកមិនមែនសាបសូន្យចាកលាភទេ សូមអ្នកប្តូរយកខ្ញុំដោយហង្សនេះ ។ ចូរអ្នកសង្កេតមើលដំណើរនេះចុះ សេចក្តីជាប់ចិត្តរបស់អ្នកចំពោះយើងទាំងឡាយ សូមលើកទុកសិន ចូរអ្នកយកអន្ទាក់ចងខ្ញុំមុនសិនចុះ រួចសឹមលែងស្តេចបក្សីជាខាងក្រោយ ។ លាភរបស់អ្នកក៏នៅដដែលផង សេចក្តីអង្វរនេះ ក៏ឈ្មោះថា អ្នកបានធ្វើតាមផង សេចក្តីរាប់អានដោយរាជហង្សឈ្មោះ ធតរដ្ឋ: គប្បីមានដល់អ្នកដរាបដល់អស់ជីវិតផង ។

[ ១៧៦ ] ( នាយនេសាទ... ) ពួកសត្វបក្សីជាច្រើន ដែលជាមិត្តអាមាត្យក្តី មាតាបិតាក្តី កូនប្រពន្ធក្តី ជាផៅពង្សក្តី ចូរច្រួបទូវរាជហង្សនេះដែលរួចហើយ ព្រោះអ្នកហើរទៅអំពីទីនេះ ។ ពួកមិត្តរបស់ពួកសត្វដទៃ ជាច្រើន ដែលប្រហែលគ្នានឹងមិត្តរបស់អ្នក ដូចអ្នកជា សម្លាញ់ស្មើជីវិតនឹងរាជហង្សឈ្មោះ ធតរដ្ឋ:នេះ មិនមានក្នុងទីនេះទេ ។ ខ្ញុំនោះ បានលែងនូវរាជហង្សជាសម្លាញ់របស់អ្នក ព្រះរាជារបស់អ្នក ចូរទៅតាមអ្នកចុះ អ្នកទាំងឡាយ ចូរហើរទៅអំពីទីនេះតាមប្រាថ្នាជាធាប់ ហើយរុងរឿងក្នុងកណ្តាលពួកញាតិចុះ ។

[ ១៧៧ ] ( អភិសម្ពុទ្ធគាថា ) ហង្សឈ្មោះសុមុខ:នោះ មានចិត្តត្រេកអរ ព្រោះម្ចាស់ផុតចាកចំណង ជាសត្វគោរពម្ចាស់ កាលពោលនូវវាចាដ៏ស្រួលដល់ត្រចៀក ទើបពោលថា បពិត្រនាយនេសាទ យើងត្រេកអរព្រោះបានឃើញនូវស្តេចបក្សី ដែលរួចចាកអន្ទាក់ក្នុងថ្ងៃនេះ យ៉ាងណាលោកចូរត្រេកអរជាមួយនឹងពួកញាតិទាំងអស់ យ៉ាងនោះចុះ ។

[ ១៧៨ ] លោកចូរមកនេះ ខ្ញុំប្រៀនប្រដៅលោកឲ្យបានលាភ រាជហង្សឈ្មោះធតរដ្ឋនេះ ឥតឃើញសេចក្តីអាក្រក់ របស់លោកតិចតួចទេ ។ លោកចូរ ( នាំយើងខ្ញុំ ) ទៅក្នុងរាជបុរីជាឆាប់ ហើយបង្ហាញចំពោះព្រះរាជានូវយើងខ្ញុំទាំង ២ នាក់ ដែលមិនជាប់ចំណង មានសភាពជាប្រក្រតីឋិតនៅលើអម្រែកទាំង ២ ខាង ។ ( លោកក្រាបទូលថា ) បពិត្រមហារាជហង្សទាំង ២ នេះ កើតក្នុងត្រកូលធតរដ្ឋៈ ជាអធិបតីលើពួកហង្ស ឯហង្សនេះជាព្រះរាជារបស់ហង្សទាំងឡាយ ហង្សមួយទៀតនេះជាសេនាបតី ។ ព្រះរាជាជាអធិបតីលើពួកជន ទ្រង់បានទតឃើញរាជហង្សនេះហើយ មុខជាទ្រង់មានព្រះរាជហឫទ័យត្រេកអររីករាយ នឹងប្រទាននូវទ្រព្យជាច្រើនដល់អ្នក ឥតសង្ស័យ ។

[ ១៧៩ ] នាយនេសាទ លុះបានស្តាប់ពាក្យហង្សឈ្មោះ សុមុខៈ នោះហើយ ក៏បង្ហើយកិច្ចការ រួច ( នាំហង្សទាំង ២ ) ទៅខាងក្នុងបុរីយ៉ាងឆាប់ ហើយបង្ហាញចំពោះព្រះរាជានូវហង្សទាំង ២ ដែលមិនជាប់អន្ទាក់ មានសភាពតាមប្រក្រតីឋិតនៅលើអម្រែកទាំង ២ ខាងថា បពិត្រមហារាជ ហង្សទាំង ២ នេះ កើតក្នុងត្រកូលធតរដ្ឋៈជាអធិបតីលើពួកហង្ស ឯហង្សនេះជាព្រះរាជារបស់ហង្សទាំងឡាយ ហង្សមួយទៀតនេះជាសេនាបតី ។

[ ១៨០ ] ( ព្រះរាជា... ) ហង្សទាំងនេះ មកឋិតនៅក្នុងកណ្តាប់ដៃរបស់អ្នក តើដោយហេតុដូចម្តេច អ្នកជានាយព្រាន បានដល់នូវភាពជាធំជាងសត្វហង្សដ៏ធំៗទាំងឡាយក្នុងទីនេះ ដោយហេតុដូចម្តេច ។

[ ១៨១ ] ( ព្រានព្រៃ... ) បពិត្រព្រះអង្គជាធំជាងជន ទូលព្រះបង្គំជាខ្ញុំ ស្គាល់នូវកន្លែង ជាទីប្រជុំនៃពួកសត្វស្លាបណាៗ ជាទីធ្វើឲ្យអស់ទៅនៃជីវិត នៃពួកសត្វស្លាប ទូលព្រះបង្គំជាខ្ញុំបានដាក់អន្ទាក់ទាំងនេះលើកក់ទាំងឡាយ ( ក្នុងកន្លែងនោះៗ ) ។ រាជហង្សបានមកជាប់អន្ទាក់ប្រាកដដូច្នោះ ចំណែកហង្សជាសេនាបតីនេះ មិនជាប់អន្ទាក់ទេ តែចូលទៅទំជិតនឹងរាជហង្សនោះ ហើយបាននិយាយនឹងទូលព្រះបង្គំជាខ្ញុំ ។ ហង្សជាសេនាបតីនេះ ( បានធ្វើ ) នូវអំពើដែលពួកជនមិនមែនជាអរិយៈ ធ្វើបានដោយក្រ ជាសត្វប្រកបដោយធម៌ សង្វាតក្នុងប្រយោជន៍របស់ម្ចាស់ បានប្រកាសនូវភាពនៃខ្លួនជាសត្វដ៏ឧត្តម ។ ហង្សជាសេនាបតីនេះ ជាសត្វគួរនឹងរស់នៅ តែស៊ូលះបង់នូវជីវិតនៃខ្លួន កាលសរសើរ ( នូវគុណនៃម្ចាស់ ) ហើយទំនៅបានសុំនូវជីវិតម្ចាស់ ។ ទូលព្រះបង្គំជាខ្ញុំ បានស្តាប់ពាក្យនោះ របស់ហង្សសេនាបតីនោះហើយ ទើបដល់នូវសេចក្តីជ្រះថ្លា លំដាប់នោះ ទូលព្រះបង្គំបានដោះរាជហង្សនោះចាកអន្ទាក់ ទាំងបានអនុញ្ញាតឲ្យទៅដោយស្រួល ។ ហង្សជាសេនាតីនោះ ក៏មានចិត្តរីករាយ ព្រោះម្ចាស់បានរួចហើយ ជាសត្វគោរពម្ចាស់ កាលនឹងពោលវាចាដ៏ស្រួលដល់ត្រចៀក បានពោលយ៉ាងនេះថា បពិត្រព្រានព្រៃ ថ្ងៃនេះ ខ្ញុំរីករាយ ព្រោះបានឃើញស្តេចបក្សីដែលរួចហើយ យ៉ាងណា សូមឲ្យលោករីករាយ ជាមួយនឹងពួកញាតិទាំងអស់ យ៉ាងនោះ ។ លោកចូរមកនេះ ខ្ញុំនឹងប្រៀនប្រដៅឲ្យបាននូវលាភ រាជហង្សឈ្មោះធតរដ្ឋៈនេះ ឥតឃើញសេចក្តីអាក្រក់តិចតួចរបស់លោកទេ ។ លោកចូរនាំ

យើងទៅក្នុងបុរីជាធាប់ ហើយបង្ហាញព្រះរាជានូវយើងខ្ញុំទាំង ២ នាក់ ដែលមិនជាប់ចំណង មានសភាពជាប្រក្រតី ឋិតនៅលើអម្រែកទាំង ២ ខាង ។ ( លោកក្រាបទូលថា ) បពិត្រមហារាជ ហង្សទាំងនេះ កើតនៅក្នុងត្រកូលធតរដ្ឋៈជាអធិបតីលើពួកហង្ស ឯហង្សនេះជាព្រះរាជារបស់ហង្សទាំងឡាយ ហង្សមួយទៀតនេះជាសេនាបតី ។ ព្រះរាជាជាធំលើពួកជនបានទតឃើញរាជហង្សនេះហើយ មុខជានឹងមានព្រះទ័យត្រេកអរសោមនស្សរីករាយ នឹងព្រះរាជទាននូវទ្រព្យដ៏ច្រើន ដល់លោកដោយពិត ។ ទូលព្រះបង្គំជាខ្ញុំ បាននាំហង្សទាំង ២ នេះ មកតាមពាក្យហង្សជាសេនាបតីនេះ យ៉ាងនេះ ព្រោះថាទូលព្រះបង្គំជាខ្ញុំ បានបើកលែងហង្សទាំង ២ នេះ ក្នុងទីនោះរួចទៅហើយ ។ សត្វបក្សីនោះជាទ្វិជាតិ មានដំណើរយ៉ាងនេះ ប្រកបដោយធម៌ដ៏ក្រៃលែង ព្រោះថា សត្វបក្សីនោះ បានញុំាងចិត្តដ៏ទន់ឲ្យកើតដល់ព្រានព្រៃ ប្រាកដដូចជាទូលព្រះបង្គំជាខ្ញុំ ។ បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំជាខ្ញុំ មិនឃើញដង្វាយដទៃ ក្នុងស្រុកនៃព្រានបក្សីដ៏សមគួរដល់ព្រះអង្គឡើយ បពិត្រព្រះអង្គជាធំជាងពួកមនុស្ស សូមព្រះអង្គទតមើលនូវដង្វាយនោះ ។

[ ១៨២ ] រាជហង្សបានឃើញព្រះរាជា ទ្រង់គង់នៅលើតាំងជាវិការៈនៃមាសដ៏ស្អាត កាលនឹងពោលនូវវាចាឲ្យស្រួលដល់ត្រចៀក បានពោលថា ព្រះអង្គបានសេចក្ដីសុខស្រួលទេឬ ព្រះអង្គមិនមានជំងឺអ្វីទេឬ មួយទៀតព្រះអង្គគ្រប់គ្រងដែនដ៏ធំទូលាយនេះ តាមធម៌ដែរឬ ។

[ ១៨៣ ] ( ព្រះរាជា... ) ម្នាលហង្ស យើងមានសេចក្ដីសុខស្រួលទេ

ម្នាលហង្សយើងមិនមានជំងឺអ្វីទេ ម្យ៉ាងទៀត យើងគ្រប់គ្រងដែនដ៏ធំទូលាយនេះ តាមធម៌ហើយ ។

[ ១៨៤ ] ( រាជហង្ស... ) កំហុសបន្តិចបន្តួចរបស់ព្រះអង្គមិនមានក្នុងពួកអាមាត្យទេឬ ពួកអាមាត្យទាំងនោះ មិនអាល័យជីវិត ព្រោះប្រយោជន៍ទាំងឡាយរបស់ព្រះអង្គទេឬ ។

[ ១៨៥ ] ( ព្រះរាជា... ) កំហុសបន្តិចបន្តួចរបស់យើង មិនមានក្នុងពួកអាមាត្យទេ អាមាត្យទាំងនោះមិនអាល័យជីវិត ព្រោះប្រយោជន៍ទាំងឡាយរបស់យើងទេ ។

[ ១៨៦ ] ( រាជហង្ស... ) អគ្គមហេសីរបស់ព្រះអង្គ ដែលមានជាតិស្មើគ្នា ជាស្រីស្តាប់បង្គាប់ ពោលពាក្យជាទីស្រឡាញ់ ប្រកបដោយបុត្ត រូបនិងយស លុះអំណាចសេចក្តីប្រាថ្នារបស់ព្រះអង្គដែរឬ ។

[ ១៨៧ ] ( ព្រះរាជា... ) អគ្គមហេសីរបស់យើង ដែលមានជាតិស្មើគ្នា ជាស្រីស្តាប់បង្គាប់ ពោលនូវពាក្យជាទីស្រឡាញ់ ប្រកបដោយបុត្ត រូបនិងយស លុះអំណាចសេចក្តីប្រាថ្នារបស់យើង ។

[ ១៨៨ ] អ្នកដ៏ចម្រើន លុះក្នុងកណ្តាប់ដៃសត្រូវដ៏ធំ ដល់នូវសេចក្តីទុក្ខដ៏ធំ ក្នុងអន្តរាយទី ១ នោះដែរឬ ។ ព្រានព្រៃ បានស្ទុះចូលទៅសំពងអ្នកដោយដំបងដែរឬ ដ្បិតអំពើយ៉ាងនេះ តែងមានជាធម្មតា ដល់ពួកអ្នកធ្វើអំពើអាក្រក់ក្នុងខណៈនោះ ។

[ ១៨៩ ] ( រាជហង្ស... ) បពិត្រមហារាជ ទូលព្រះបង្គំជាខ្ញុំ បាន

សេចក្តីក្សេមក្សាន្តទេ កាលបើមានហេតុយ៉ាងនេះ ព្រានព្រៃនេះ មិនដល់ ( នូវភាពនៃខ្លួន ) ដូចជាសត្រូវចំពោះទូលព្រះបង្គំជាខ្ញុំ តិចតួចឡើយ ។ ព្រានព្រៃនេះ ថយបន្តិចៗ ក៏បានសាកសួរទូលព្រះបង្គំជាមុន គ្រានោះ ហង្ស ឈ្មោះសុមុខៈជាបណ្ឌិតបាននិយាយតបវិញ ។ ព្រានព្រៃបានស្តាប់ពាក្យហង្ស ឈ្មោះ សុមុខៈនោះហើយ ក៏បានដល់នូវសេចក្តីជ្រះថ្លា លំដាប់នោះ ព្រាន ព្រៃ បានដោះទូលព្រះបង្គំជាខ្ញុំអំពីអន្ទាក់ ទាំងបានអនុញ្ញាតឲ្យទៅដោយ ស្រួលផង ។ ដំណើរមកក្នុងសំណាក់នៃព្រះអង្គនេះ គឺហង្សឈ្មោះ សុមុខៈ ចង់បានទ្រព្យដល់ព្រានព្រៃនុ៎ះ បានគិតហើយដើម្បីប្រយោជន៍ដល់ព្រានព្រៃ នុ៎ះ ។

[ ១៩០ ] ( ព្រះរាជា... ) ដំណើរមករបស់អ្នកដ៏ចម្រើនទាំងឡាយជា ការស្រួលណាស់ហើយ យើងមានចិត្តត្រេកអរ ព្រោះការបានឃើញអ្នក ឯ ព្រានព្រៃនេះ ចូរបានទ្រព្យជាច្រើនដរាបទាល់អស់ចំណង់ចុះ ។

[ ១៩១ ] ( អភិសម្ពុទ្ធគាថា ) ព្រះរាជាជាធំជាងមនុស្ស បានញុំាង នាយនេសាទឲ្យឆ្អែតស្កប់ស្កល់ដោយភោគៈ តាមដំណើរដែលសត្វបក្សីហង្ស និយាយនូវពាក្យដ៏សុខស្រួលដល់ត្រចៀកបានពោលហើយ ។

[ ១៩២ ] ( ព្រះរាជា... ) អំណាច ( របស់យើង ) ប្រព្រឹត្តទៅអស់ ទីជាទីទ្រង់ទុកនូវធម៌ ( ច្បាប់ ) ណា អ្នកដ៏ចម្រើន ចូរជាធំក្នុងទីទាំងអស់ នោះ សូម្បីតិចតួច ចូរគ្រប់គ្រងនូវទីជាទីប្រាថ្នាចុះ ។ ម្យ៉ាងទៀត ទ្រព្យ ណាដទៃអាចសម្រេច ដើម្បីនឹងឲ្យទាន ឬជាគ្រឿងប្រើប្រាស់ យើងឲ្យនូវ

ទ្រព្យនោះដល់អ្នក យើងនឹងលះនូវភារៈជាធំដល់អ្នក ។

[ ១៩៣ ] ប្រសិនបើហង្សឈ្មោះសុមុខៈ ជាបណ្ឌិត បរិបូណ៌ដោយប្រាជ្ញានេះ ពោលនូវពាក្យដល់យើងតាមសេចក្ដីប្រាថ្នា ពាក្យនោះជាទីស្រឡាញ់របស់យើងក្រៃពេក ។

[ ១៩៤ ] ( ហង្សសេនាបតី... ) បពិត្រព្រះមហារាជ ទូលព្រះបង្គំជាខ្ញុំ ដូចជានាគរាជ ( ចូលទៅ ) កាន់ចន្លោះ ( នៃភ្នំ ) មិនអាចនឹងក្រាបទូលតបបានទេ ដ្បិតការក្រាបទូលតបនេះ មិនមែនជាច្បាប់សម្រាប់ទូលព្រះបង្គំជាខ្ញុំឡើយ ។ រាជហង្សប្រសើរបំផុត ជាងពួកទូលព្រះបង្គំជាខ្ញុំនោះផង ព្រះអង្គជាសត្វដ៏ឧត្ដម រក្សាផែនដីជាធំជាងមនុស្សផង គួរទូលព្រះបង្គំជាខ្ញុំ បូជាដោយហេតុដ៏ចម្រើន ។ បពិត្រព្រះអង្គជាធំ ជាងមនុស្ស កាលដែលការវិនិច្ឆ័យកំពុងប្រព្រឹត្តទៅ អាមាត្យជាអ្នកបម្រើ មិនគប្បីក្រាបទូលក្នុងចន្លោះនៃព្រះអង្គទាំង ២ កំពុងមានព្រះបន្ទូលនោះឡើយ ។

[ ១៩៥ ] ( ព្រះរាជា... ) បានឮថា នាយព្រាន បានសរសើរអ្នកដោយធម៌ថា អ្នកជាបក្សីបណ្ឌិត ប្រាជ្ញាបែបនេះ មិនគប្បីមានដល់សត្វដែលមានអត្តភាពមិនទាន់សម្រេច ។ អ្នកមានប្រក្រតីដ៏ប្រសើរយ៉ាងនេះ ជាសត្វខ្ពង់ខ្ពស់យ៉ាងនេះ សត្វទាំងឡាយទាំងប៉ុន្មាន ដែលយើងបានឃើញហើយ យើងមិនដែលឃើញនូវសត្វដទៃបែបនេះ ។ យើងត្រេកអរដោយបានឃើញអ្នកទាំង ២ ជាដំបូងផង ដោយពាក្យដ៏ពីរោះផង នោះជាសេចក្ដីពេញចិត្តរបស់យើង យើងគប្បីជួបនូវអ្នកទាំង ២ អស់កាលជាអង្វែង ។

[ ១៩៦ ] ( រាជហង្ស... ) អំពើណា ដែលត្រូវធ្វើចំពោះមិត្តដ៏ប្រសើរ អំពើនោះព្រះអង្គបានធ្វើហើយ ចំពោះទូលព្រះបង្គំទាំង ២ សេចក្តីរាប់អានណា របស់ព្រះអង្គ ចំពោះទូលព្រះបង្គំទាំង ២ ទូលព្រះបង្គំទាំង ២ ឃ្លាតហើយចាកព្រះអង្គដោយឥតសង្ស័យ ។ សេចក្តីទុក្ខឯណោះ បានកើតឡើងហើយ ក្នុងបក្សីជាច្រើន ព្រោះមិនឃើញនូវទូលព្រះបង្គំជាខ្ញុំទាំង ២ ក្នុងចន្លោះនៃពួកញាតិជាច្រើនដោយពិត ។ យើងទាំង ២ ដែលព្រះអង្គអនុញ្ញាតហើយ ដើម្បីកម្ចាត់បង់នូវសេចក្តីសោករបស់បក្សីទាំងនោះ បពិត្រព្រះអង្គជាអ្នកទូន្មាននូវសត្រូវ ទូលព្រះបង្គំជាខ្ញុំទាំង ២ សូមធ្វើប្រទក្សិណព្រះអង្គហើយទៅជួបនឹងពួកញាតិ ។ ទូលព្រះបង្គំជាខ្ញុំ បានសេចក្តីត្រេកអរដ៏ធំទូលាយ ព្រោះបានជួបព្រះអង្គដោយពិត ម្យ៉ាងទៀត ប្រយោជន៍ធំនេះ កើតមានព្រោះតែសេចក្តីស្និទ្ធស្នាលចំពោះញាតិ ។

[ ១៩៧ ] ( អភិសម្ពុទ្ធគាថា ) លុះរាជហង្សឈ្មោះ ធតរដ្ឋៈ ( និងហង្សឈ្មោះសុមុខៈ ) បានពោលពាក្យនេះ ចំពោះព្រះរាជាជាធំលើជន រួចហើយក៏ហើរសំដៅទៅរកពួកញាតិ អាស្រ័យនូវសទ្ទុះដ៏ឧត្តម ។ សត្វហង្សទាំងឡាយ បានឃើញនូវហង្សដ៏ឧត្តមទាំង ២ នោះមិនមានរោគមកដល់ហើយ ក៏បានធ្វើនូវសំឡេងថា កេកា ៗ សូរសំឡេងយ៉ាងខ្លាំងក៏កើតមានឡើង ។ បក្សីទាំងនោះ មានសេចក្តីត្រេកអរ ព្រោះម្ចាស់រួចហើយ ជាសត្វគោរពចំពោះម្ចាស់ ជាសត្វបាននូវទីពឹង ហើយហើរក្រឡឹងជុំវិញ ។

[ ១៩៨ ] ប្រយោជន៍ទាំងអស់របស់ពួកជនអ្នកមានមិត្ត រមែងសម្រេច

សេចក្តីសុខយ៉ាងនេះ ដូចជាហង្សឈ្មោះធតរដ្ឋៈ និងហង្សឈ្មោះសុមុខៈ បាន ហើរចូលទៅរកពួកញាតិដូច្នោះ ។

## ចប់ ចុល្លហង្សជាតកទី ១ ។

# អសីតិនិបាត ជាតក

## អដ្ឋកថា ចុល្លហំសជាតក

[ ១៦៣-១៩៨ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធការលះបង់ជីវិតរបស់ព្រះអានន្ទត្ថេរ ទើបត្រាស់ព្រះធម្មទេសនានេះមានពាក្យផ្តើមថា **សុមុខ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា បណ្តាពួកនាយខ្មាន់ធ្នូដែលពួកទេវទត្ត ប្រើឲ្យទៅផ្តាច់ព្រះជន្មព្រះតថាគត ខ្មាន់ធ្នូដែលទៅមុនគេត្រឡប់មករាយការណ៍ថា បពិត្រលោកម្ចាស់ ខ្ញុំមិនអាចផ្តាច់ព្រះជន្មព្រះមានព្រះភាគអង្គនោះបានឡើយ ព្រោះព្រះមានព្រះភាគអង្គនោះ ទ្រង់មានឫទ្ធានុភាពក្រៃលែង ទេវទត្តនោះក៏ពោលថា ណ្ហើយចុះ ឯងមិនបាច់ផ្តាច់ព្រះជន្មព្រះសមណគោតមទេ អញនឹងផ្តាច់ព្រះជន្មព្រះសមណគោតមឯង ។ កាលព្រះតថាគតយាងចង្រ្កម ក្នុងម្លប់ខាងក្រោយនៃភ្នំគិជ្ឈកូដ ក៏ឡើងទៅលើភ្នំគិជ្ឈកូដឯង ហើយប្រមៀលថ្មធំ ដោយកម្លាំងនៃគ្រឿងយន្ត ដោយគិតថា អញនឹងផ្តាច់ព្រះជន្មព្រះសមណគោតមដោយដុំថ្មនេះ ។ ក្នុងកាលនោះ កំពូលភ្នំ ២ ក៏ទទួលថ្មដែលរមៀលទៅនោះបាន តែបំណែកថ្មដែលទង្គិចនឹងថ្មនោះ ក៏ហោះទៅប៉ះព្រះបាទរបស់ព្រះមានព្រះភាគ ធ្វើលោហិតឲ្យពុះពងឡើងហើយ វេទនាមានកម្លាំងប្រព្រឹត្តទៅហើយ ។ ពេទ្យជីវកធ្វើនូវការវះព្រះបាទរបស់ព្រះតថាគតដោយសស្រ្តា យកឈាមអាក្រក់ចេញ យកសាច់អាក្រក់ចេញរហូតអស់ លាងមុខដំបៅស្អាតហើយដាក់ថ្នាំ ធ្វើឲ្យទ្រង់ជាសះស្បើយរោគ ។ ព្រះសាស្តាទ្រង់ជាប្រក្រតីហើយ មានមហាភិក្ខុសង្ឃចោមរោមជាបរិវារ យាងទៅកាន់ព្រះនគរដោយ

ពុទ្ធលីលាធំនោះឯង ។

លំដាប់នោះ ទេវទត្តឃើញដូច្នោះ គិតថា បុគ្គលណាឃើញ ព្រះសរីរៈដែលដល់នូវលម្អដ៏ប្រសើរ ដោយព្រះរូបឆោមរបស់ព្រះគោតម បើជាមនុស្ស ក៏មិនអាចចូលទៅប្រទូស្តបាន ឯដំរីរបស់ព្រះរាជា ឈ្មោះនាឡាគិរីមាន ដំរីនោះជាដំរីកាច សម្លាប់មនុស្សបាន កាលមិនដឹងគុណព្រះពុទ្ធ ព្រះធម៌និងព្រះសង្ឃ នឹងញុំាងព្រះគោតមនោះ ឲ្យដល់នូវការអស់ជីវិតបាន ទើបលោកទៅទូលសេចក្តីនោះ ដល់ព្រះបាទអជាតសត្តុ ព្រះរាជាទ្រង់ទទួលថា សាធុ ដូច្នេះហើយ ត្រាស់ឲ្យហៅនាយហត្ថាចារ្យមកហើយ ទ្រង់បញ្ជាថា នែអ្នក ស្អែកនេះ ចូរឯងឲ្យដំរីនាឡាគិរីស្រវឹង ហើយលែងទៅកាន់វិថី ដែលព្រះសមណគោតមយាងមកអំពីព្រលឹម ទេវទត្តក៏សួរនាយហត្ថាចារ្យនោះថា ក្នុងថ្ងៃដទៃៗ ដំរីនាឡាគិរីផឹកស្រាប៉ុន្មានក្អម កាលបុរសនោះប្រាប់ថា ៨ ក្អម ទើបបញ្ជាថា ស្អែកនេះ ចូរឲ្យដំរីនោះផឹក ១៦ ក្អម ហើយគប្បីធ្វើឲ្យមានមុខទៅកាន់ផ្លូវដែលព្រះគោតមយាងមក ។ នាយហត្ថាចារ្យនោះ ក៏ទទួលថា សាធុ ។ ព្រះរាជាឲ្យរាជបុរសវាយស្គរប្រកាសពេញព្រះនគរថា ស្អែកនេះ នាយហត្ថាចារ្យ នឹងបង្អកដំរីនាឡាគិរីឲ្យស្រវឹង ហើយលែងក្នុងនគរ អ្នកនគរទាំងឡាយគប្បីប្រញាប់ធ្វើកិច្ចដែលត្រូវធ្វើឲ្យស្រេចអំពីព្រលឹម ហើយកុំដើរក្នុងចន្លោះផ្លូវ ឯទេវទត្តចុះអំពីព្រះរាជនិវេសន៍ ហើយទៅកាន់រោងដំរី ហៅអ្នកចិញ្ចឹមដំរីមក ប្រាប់ថា នែអ្នកទាំងឡាយ យើងអាចបន្ទយតំណែងពីខ្ពស់មកទាប និងតម្លើងតំណែងពីទាបទៅខ្ពស់ បើពួកអ្នកត្រូវការយស ស្អែកនេះ

ចូរនាំគ្នាយកស្រាខ្លាំងបញ្ចុកដំរីនាឡាគិរីឲ្យបាន ១៦ ក្អម ដល់ពេលព្រះ-សមណគោតមយាងមក ចូរនាំគ្នាចាក់ដោយចុងលំពែង ពន្យុះដំរីឲ្យទម្លាយរោងដំរី នាំគ្នាបញ្ឆោតឲ្យមានមុខត្រង់ទៅកាន់វិថី ដែលព្រះសមណគោតមយាងមក ហើយឲ្យព្រះសមណគោតមដល់នូវការអស់ជីវិត ។ ពួកអ្នកចិញ្ចឹមដំរីទាំងនោះ នាំគ្នាទទួលថា សាធុ ។ ព្រឹត្តិការណ៍នោះ បានផ្សាយទៅពេញព្រះនគរ ពួកឧបាសកអ្នករាប់អានព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ បានជ្រាបដំណឹងនោះ ក៏នាំគ្នាទៅគាល់ព្រះសាស្ដាក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទេវទត្តផ្សំគំនិត ជាមួយព្រះបាទអជាតសត្តុ បានលែងដំរីនាឡាគិរីក្នុងផ្លូវដែលទ្រង់យាងទៅ ក្នុងថ្ងៃស្អែកនេះ ព្រោះហេតុនោះ ក្នុងថ្ងៃស្អែកនេះ សូមទ្រង់កុំយាងទៅបិណ្ឌបាតឡើយ សូមគង់នៅក្នុងទីនេះចុះ ពួកខ្ញុំព្រះអង្គនឹងថ្វាយភិក្ខាហារដល់ភិក្ខុសង្ឃ មានព្រះពុទ្ធអង្គជាប្រធានក្នុងវិហារនេះឯង ។ ព្រះសាស្ដាមិនបានត្រាស់ទទួលពាក្យថា ស្អែកនេះ តថាគតនឹងមិនចូលទៅបិណ្ឌបាត ទ្រង់ត្រិះរិះថា ស្អែកនេះ តថាគតនឹងទូន្មានដំរីនាឡាគិរី ធ្វើនូវបាដិហារ្យទូន្មានពួកតិរ្ថិយនិងត្រាច់ទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ មានភិក្ខុចោមរោមជាបរិវារ ចេញអំពីនគរទៅកាន់វេឡុវនមហាវិហារនោះឯង ។ ពួកជនអ្នកក្រុងរាជគ្រឹះ នឹងកាន់យកភាជនៈភត្តជាច្រើនមកកាន់វិហារវេឡុវនដូចគ្នា ស្អែកនេះ រោងភត្តនឹងមានក្នុងវិហារនេះឯង ហើយទ្រង់ទទួលអារាធនាដល់ពួកឧបាសកទាំងនោះ ដោយហេតុនេះ ។ ពួកឧបាសកទាំងនោះ ជ្រាបសេចក្ដីថា ព្រះតថាគតទ្រង់ទទួលអារាធនាហើយ ទើបនាំគ្នាពោលថា ពួកយើងនឹងនាំភា-

ជនៈភត្តាហារមកថ្វាយក្នុងវិហារនោះឯង ហើយចៀសចេញទៅ ។

ព្រះសាស្តាទ្រង់សម្តែងធម៌ក្នុងបឋមយាម ទ្រង់ឆ្លើយបញ្ហារបស់ទេវតាក្នុងមជ្ឈិមយាម ទ្រង់សម្រេចសីហសេយ្យាសនៈក្នុងចំណែកដំបូងនៃបច្ឆិមយាម ទ្រង់ចូលផលសមាបត្តិក្នុងចំណែកទី ២ នៃបច្ឆិមយាម ក្នុងចំណែកទី ៣ នៃបច្ឆិមយាម ទ្រង់ចូលករុណាសមាបត្តិ ទ្រង់សម្ទឹងមើលពួកវេនេយ្យសត្វដែលមានឧបនិស្ស័យ ដែលនឹងបានត្រាស់ដឹងធម្មវិសេស ទតឃើញការត្រាស់ដឹងធម៌របស់សត្វ ៨៤០០០ ក្នុងកាលដែលទ្រង់ទូន្មានដំរីនាឡាគិរី ។ កាលរាត្រីអស់ហើយ ទ្រង់ក៏ជម្រះព្រះសរីរៈ ត្រាស់ហៅព្រះអានន្ទមកហើយក៏ត្រាស់ថា ម្នាលអានន្ទ ចូរអ្នកប្រាប់ដល់ភិក្ខុទាំងអស់ក្នុងវិហារ ១៨ កន្លែងដែលនៅក្នុងនគររាជគ្រឹះ ដើម្បីឲ្យចូលទៅក្នុងនគររាជគ្រឹះជាមួយតថាគត ។ ព្រះថេរៈបានធ្វើតាមព្រះពុទ្ធដីកាហើយ ។ ពួកភិក្ខុទាំងអស់ មកប្រជុំគ្នាក្នុងវត្តវេឡុវ័ន ។ ព្រះសាស្តាមានមហាភិក្ខុសង្ឃចោមរោមជាបរិវារ យាងចូលទៅបិណ្ឌបាតក្នុងនគររាជគ្រឹះ ។ លំដាប់នោះ ពួកអ្នកចិញ្ចឹមដំរី ក៏បដិបត្តិតាមភិក្ខុទេវទត្តបញ្ជូ ។ សមាគមធំមានហើយ ពួកមនុស្សដែលដល់ព្រមដោយសទ្ធា ពោលថា បានឮថា ក្នុងថ្ងៃនេះ ព្រះពុទ្ធដែលជាមហានាគនិងដំរីនាឡាគិរី ដែលជាសត្វតិរច្ឆាន ធ្វើសង្គ្រាមគ្នា ពួកយើងនឹងបានឃើញការទូន្មានដំរីនាឡាគិរី ដោយពុទ្ធលីលាដែលគ្មានអ្វីប្រៀប ទើបនាំគ្នាឡើងកាន់ប្រាសាទ អឌ្ឍយោគនិងដំបូលផ្ទះ ហើយឈរមើល ឯពួកជនមិច្ឆាទិដ្ឋិ ដែលមិនមានសទ្ធា មិនបាននាំគ្នាពោលថា ដំរីនាឡាគិរីនេះកាច សម្លាប់មនុស្ស

បាន មិនស្គាល់គុណព្រះពុទ្ធដូចគ្នា ថ្ងៃនេះ ដំរីនោះនឹងញុំាញីសរីរៈដែលមានពណ៌ដូចមាសរបស់ព្រះគោតម ឲ្យដល់នូវការអស់ជីវិត ពួកយើងនឹងបានឃើញ ខ្នងបច្ចាមិត្តក្នុងថ្ងៃនេះឯង ហើយបាននាំគ្នាឡើងទៅឈរមើលលើដើមឈើ និងប្រាសាទដូចគ្នា ។ ដំរីនាឡាគិរីគ្រាន់តែឃើញព្រះមានព្រះភាគយាងមក ទើបញុំាងនូវមនុស្សទាំងឡាយឲ្យភ័យខ្លាច ទម្លាយផ្ទះជាច្រើន រត់ទន្ទិចរទេះបែកខ្ចាត់ខ្ចាយអស់ជាច្រើន បួងប្រមោយឡើង បើកត្រចៀក មានកន្ទុយត្រង់ទៅក្រោយ រត់តម្រង់ទៅរកព្រះមានព្រះភាគ ហាក់បីដូចភ្នំបាក់សង្កត់ព្រះសម្ពុទ្ធដូច្នោះ ។ ភិក្ខុទាំងឡាយឃើញដូច្នោះ ទើបក្រាបទូលសេចក្តីនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ដំរីនាឡាគិរីនេះកាចសម្លាប់មនុស្សបាន បោលតម្រង់មក ដំរីនេះមិនស្គាល់គុណព្រះពុទ្ធជាដើមឡើយ សូមទ្រង់យាងត្រឡប់ចុះ សូមព្រះសុគតទ្រង់យាងត្រឡប់ចុះ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកកុំខ្លាចឡើយ តថាគតមានកម្លាំង អាចទូន្មានដំរីនាឡាគិរីនេះបាន ។

លំដាប់នោះ ព្រះសារីបុត្តក្រាបទូលសូមឱកាសព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ធម្មតាកិច្ចដែលកើតឡើងដល់បិតា រមែងជាភារៈរបស់កូនច្បង ខ្ញុំព្រះអង្គនឹងសូមទូន្មានដំរីនេះ ។ គ្រានោះ ព្រះសាស្តាឃាត់ព្រះសារីបុត្តថា ម្នាលសារីបុត្ត ឈ្មោះថា កម្លាំងនៃព្រះពុទ្ធមួយបែប កម្លាំងពួកសាវកមួយបែប ចូរអ្នកបង្អង់នៅចុះ ។ ព្រះមហាសាវក ៨០ ក៏នាំគ្នាទូលសូមឱកាស យ៉ាងនេះដូចគ្នា ។ ព្រះសាស្តាត្រាស់ឃាត់ព្រះមហាថេរៈទាំងនោះ ។

ខណៈនោះ ព្រះអានន្ទមិនអាចអត់ធន់បាន ដោយការស្រឡាញ់មានកម្លាំង ក្នុងព្រះសាស្ដា ទើបគិតថា ដំរីនេះ ចូរសម្លាប់អញជាមុនចុះ ដូច្នេះហើយ សុខចិត្ត លះបង់ជីវិត ដើម្បីជាប្រយោជន៍ដល់ព្រះតថាគត បានចេញទៅ ឈរខាងមុខនៃព្រះសាស្ដា លំដាប់នោះ ព្រះសាស្ដាក៏ត្រាស់ថា ម្នាលអានន្ទ អ្នកចូរចៀសចេញទៅ ម្នាលអានន្ទ អ្នកចូរចៀសចេញទៅ អ្នកកុំមកឈរ រាំងមុខតថាគតឡើយ ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ដំរីនេះ កាច សម្លាប់មនុស្សបាន ដូចគ្នានឹងភ្លើងប្រល័យកប្ប ចូរសម្លាប់ខ្ញុំព្រះអង្គ មុន សឹមមកកាន់សម្នាក់របស់ព្រះអង្គក្នុងកាលជាក្រោយ ។ ព្រះអានន្ទត្រូវ សូម្បីត្រូវព្រះសាស្ដាត្រាស់ហាមអស់ ៣ ដង ក៏នៅតែឈរយ៉ាងនោះ មិន បានត្រឡប់មកឡើយ ។ គ្រានោះ ព្រះសាស្ដា ក៏ឲ្យព្រះអានន្ទត្រឡប់មក ឈរក្នុងរវាងភិក្ខុទាំងឡាយដោយកម្លាំងនៃឫទ្ធិ ។ ក្នុងខណៈនោះ ស្រីម្នាក់ ឃើញដំរីនាឡាគិរីមានសេចក្ដីតក់ស្លុតចំពោះមរណភ័យ ទើបគេចទៅចោល ទារក ដែលខ្លួនពនឹងចង្កេះ ក្នុងរវាងដំរីនិងព្រះតថាគត ហើយរត់គេចទៅ ។ ដំរីរត់ដេញតាមស្រីនោះ ហើយត្រឡប់មករកទារក ទារកក៏ស្រែកដោយ សំឡេងខ្លាំង ព្រះសាស្ដាទ្រង់ផ្សាយមេត្តាទៅកាន់ដំរីនាឡាគិរី ទ្រង់បន្លឺព្រះសូរ សៀងដ៏ពីរោះក្រៃលែង ដូចសំឡេងព្រហ្ម ត្រាស់ហៅថា នៃនាឡាគិរី គេឲ្យ អ្នកផឹកស្រាអស់ ១៦ ក្អម បង្អករហូតស្រវឹង គេធ្វើដោយបំណងថា នឹង ឲ្យសម្លាប់អ្នកដទៃក៏មិនមែន តែគេធ្វើដោយបំណងឲ្យសម្លាប់តថាគត អ្នកកុំ រត់ផ្ដេសផ្ដាសឲ្យចុករួយជើងដោយឥតហេតុឡើយ ចូរមកទីនេះចុះ ។ ដំរី

នាឡាគិរីនោះ លុះបានឮព្រះតម្រាស់របស់ព្រះសាស្តា ទើបបើកភ្នែកមើលព្រះរូបដ៏មានសិរីរបស់ព្រះមុនី បាននូវសេចក្តីសង្វេគ ស្វាងស្រាដោយតេជះនៃព្រះពុទ្ធ ទើបទម្លាក់ប្រមោយ ក្តាបត្រចៀកទាំង ២ ចូលទៅក្រាបទៀបព្រះបាទាទាំងទ្វេរបស់ព្រះតថាគត ។

លំដាប់នោះ ព្រះសាស្តាក៏ត្រាស់នឹងដំរីនាឡាគិរីនោះថា ម្នាលនាឡាគិរី អ្នកជាសត្វតិរច្ឆានទាគ តថាគតជាព្រះពុទ្ធនាគដ៏ប្រសើរ ចាប់អំពីនេះទៅ អ្នកកុំឃោរឃៅ កុំគ្រោតគ្រាត កុំសម្លាប់មនុស្ស ចូរបាននូវមេត្តាចិត្ត ទ្រង់លាព្រះហស្តស្ទាបចេញទៅ ស្ទាបពោងហើយ ទើបត្រាស់គាថានេះ ( ក្នុងវិនយបិដកចុល្លវគ្គ ) ថា

ម្នាលកុញ្ជរ អ្នកកុំចូលមកប៉ុនប៉ងសម្លាប់ព្រះពុទ្ធនាគឡើយ
ម្នាលកុញ្ជរ ព្រោះថា ការចូលមកប៉ុនប៉ងសម្លាប់ព្រះពុទ្ធ
នាគជាហេតុឲ្យកើតទុក្ខ ។ ម្នាលកុញ្ជរ កាលបើអ្នកសម្លាប់
ព្រះពុទ្ធនាគហើយ ទៅអំពីជាតិនេះ ទៅកាន់លោកខាងមុខ
( អ្នក ) មិនបានទៅកើតក្នុងសុគតិទេ ។ ចូរអ្នកលែងស្រវឹង
លែងប្រមាទទៅ ព្រោះថា សត្វទាំងឡាយ ដែលប្រមាទ
ហើយ តែងមិនបានទៅកាន់សុគតិភូមិឡើយ ។ អ្នកនឹងទៅ
កាន់សុគតិ ដោយប្រការ ដែលអ្នកធ្វើខ្លួនឯង ដូច្នេះ ។

ព្រះសាស្តាទ្រង់សម្តែងធម៌ ដោយប្រការដូច្នេះ សរីរៈទាំងមូលរបស់ដំរីនោះ ជាសរីរៈដែលមានបីតិពាល់ត្រូវហើយ មិនមានចន្លោះ ។ បើមិនជា

សត្តតិរច្ឆាន ក៏នឹងបានសម្រេចសោតាបត្តិផល ។ មនុស្សទាំងឡាយឃើញបាដិហារ្យនោះ នាំគ្នាបន្លឺសំឡេងទះដៃទ្រហឹងអឹងអាប់ កើតនូវសោមនស្ស ក៏បោះគ្រឿងអាករណៈផ្សេងៗ គ្រឿងអាករណៈទាំងនោះ ក៏ទៅគរលើសរីរៈរបស់ដំរី ។ តាំងពីថ្ងៃនោះមក ដំរីនាឡាគិរីក៏ប្រាកដឈ្មោះថា ដំរីធនបាលកៈ ក្នុងខណៈនោះ សត្វ ៨៤០០០ ក្នុងសមាគមនៃដំរីធនបាលកៈ ក៏បានផឹកនូវអមតៈ ។ ព្រះសាស្តាទ្រង់ឲ្យដំរីធនបាលកៈតាំងនៅក្នុងសីល ៥ ដំរីនោះ ក៏យកប្រមោយស្រូបលម្អងធូលីព្រះបាទ របស់ព្រះមានព្រះភាគ ហើយយករោយលើក្បាលរបស់ខ្លួន បង្អោនខ្លួនដើរថយក្រោយ មកឈរត្រង់ទីឧបចារៈល្មមសម្លឹងឃើញ ថ្វាយបង្គំព្រះទសពល ហើយត្រឡប់ចូលទៅកាន់រោងដំរី តាំងអំពីនោះមក ដំរីនាឡាគិរីនោះ ក៏ក្លាយជាដំរី ដែលបានទទួលការទូន្មាន បណ្តាដំរីដែលបានទទួលការទូន្មានហើយទាំងឡាយយ៉ាងនេះ មិនជាប់បៀតបៀនបុគ្គលណា ឲ្យក្តៅក្រហាយទៀតឡើយ ។ ព្រះសាស្តា ទ្រង់មានមនោរថសម្រេចហើយ ទ្រង់អធិដ្ឋានថា ទ្រព្យរបស់អ្នកណា ដែលគេបោះហើយក្នុងទីនេះ ទ្រព្យនោះ ជារបស់បុគ្គលនោះវិញចុះ ហើយទ្រង់ព្រះតម្រិះថា ថ្ងៃនេះ តថាគតបានធ្វើមហាបាដិហារ្យហើយ ការត្រាច់ចារិកទៅដើម្បីបិណ្ឌបាតក្នុងនគរនោះ មិនសមគួរ ទ្រង់ទូន្មានពួកតិត្ថិយហើយ មានភិក្ខុចោមរោមជាបរិវារ ទ្រង់ចេញអំពីព្រះនគរ ទ្រង់យាងទៅកាន់វេឡុវនវិហារ ដូចស្តេចដែលមានជ័យជម្នះហើយ ។ សូម្បីពួកអ្នកនគរ ក៏នាំគ្នាកាន់យកបាយទឹក និងរបស់ទំពាជាច្រើនទៅកាន់វិហារ ញុំាងមហាទានឲ្យប្រព្រឹត្តទៅហើយ

ក្នុងវេលាល្ងាចថ្ងៃនោះ ភិក្ខុទាំងឡាយអង្គុយពេញធម្មសភា សន្ទនាគ្នាថា នែអាវុសោទាំងឡាយ ព្រះអានន្ទដ៏មានអាយុ សុខចិត្តលះបង់ជីវិតរបស់លោក ដើម្បីជាប្រយោជន៍ដល់ព្រះតថាគត ឈ្មោះថា ធ្វើនូវកម្មដែលធ្វើបានដោយក្រ លោកឃើញដំរីនាឡាគិរីហើយ ត្រូវព្រះសាស្តាឃាត់អស់វារៈ ៣ ដង ក៏មិនព្រមថយចេញទៅ នែអាវុសោទាំងឡាយ គួរសរសើរព្រះអានន្ទដ៏មានអាយុ ធ្វើនូវវត្ថុដែលគេធ្វើបានដោយក្រ ។ លំដាប់នោះ ព្រះសាស្តាទ្រង់ស្តាប់ពាក្យសរសើរកិត្តិគុណរបស់ព្រះអានន្ទនោះ ដោយទិព្វសោតធាតុ ទើបទ្រង់ព្រះតម្រិះថា ពាក្យសរសើរកិត្តិគុណរបស់អានន្ទកំពុងប្រព្រឹត្តទៅ តថាគតគួរទៅក្នុងទីនោះ ទើបយាងចេញអំពីព្រះគន្ធកុដិ ទៅកាន់ធម្មសភា ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ថ្ងៃនេះ ពួកអ្នកកំពុងសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបថា ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន កាលអានន្ទកើតក្នុងកំណើតតិរច្ឆាន ក៏ធ្លាប់លះបង់ជីវិតដើម្បីប្រយោជន៍ដល់តថាគតហើយដូចគ្នា ដូច្នេះហើយ ទ្រង់ក៏គង់ស្ងៀម កាលភិក្ខុទាំងឡាយទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកសម្តែងដូចតទៅនេះថា

ម្នាលភិក្ខុទាំងឡាយ ក្នុងអតីតកាល ព្រះរាជាព្រះនាមថា សាគលសោយរាជសម្បត្តិដោយធម៌ ក្នុងសាគលនគរ ក្នុងដែនមហិសកៈ ។ ក្នុងកាលនោះ ក្នុងស្រុកនាយព្រានមួយ មិនឆ្ងាយអំពីនគរ មានព្រានព្រៃម្នាក់យកអន្ទាក់ដាក់បក្សី បានសាច់មកហើយ លក់ដូរចិញ្ចឹមជីវិត ។ ក្នុងទីមិន

ឆ្ងាយអំពីព្រះនគរ មានស្រះឈូកក្រហមមួយ ឈ្មោះមានុសិយៈ វាស់ដោយជុំវិញបាន ១២ យោជន៍ ស្រះនោះដេរដាសដោយឈូក ៥ ប្រភេទ មានបក្សីច្រើនប្រភេទ ច្រើនពណ៌មកចុះក្នុងស្រះនោះ ព្រាននោះដាក់អន្ទាក់ ត្រង់ស្រះនោះដោយមិនរើសថា បក្សីប្រភេទណា ។ ក្នុងកាលនោះ ស្ដេចហង្សធតរដ្ឋៈ មានហង្ស ៩៦០០០ ជាបរិវារ អាស្រ័យនៅក្នុងគុហាមាសត្រង់ភ្នំចិត្តកូដ ។ មានហង្សមួយឈ្មោះថា សុមុខៈ ជាសេនាបតីរបស់ស្ដេចហង្សនោះ កាលនោះ ហង្សមាស ២-៣ ក្នុងហ្វូងហង្សនោះ បានហើរទៅកាន់ស្រះឈ្មោះមានុសិយៈ ត្រាច់ទៅក្នុងស្រះនោះ ដែលមានទីរកស៊ី គ្រប់គ្រាន់តាមសប្បាយ ហើយត្រឡប់មកកាន់ភ្នំចិត្តកូដ ប្រាប់ស្ដេចហង្សធតរដ្ឋៈថា បពិត្រមហារាជ មានស្រះឈូកមួយ ឈ្មោះមានុសិយៈ នៅក្នុងដែនដីរបស់មនុស្ស មានទីរកស៊ីយ៉ាងសម្បូរ ពួកខ្ញុំទៅរកអាហារក្នុងស្រះនោះ ស្ដេចហង្សនោះក៏ឃាត់ថា ឈ្មោះថាដែនដីរបស់មនុស្ស ជាទីគួររង្កៀសច្រើនដោយភ័យចំពោះមុខ កុំគាប់ចិត្តដល់ពួកឯងឡើយ ត្រូវហង្សទាំងនោះរំអុករឿយៗ ទើបពោលថា បើស្រះនោះ រមែងជាទីគាប់ចិត្តរបស់ពួកអ្នក យើងក៏នឹងទៅទីនោះដូចគ្នា មួយអន្លើដោយបរិវារ បានទៅកាន់ស្រះនោះ ស្ដេចហង្សធតរដ្ឋៈនោះបន្ទាបខ្លួនចុះអំពីអាកាស ដាក់ជើងទៅ ក៏ជាប់អន្ទាក់នោះឯង ។ លំដាប់នោះ អន្ទាក់របស់នាយព្រាន ក៏រឹតជើងយ៉ាងណែន ដូចរឹតដោយចម្រៀកដែក ដូច្នោះ ។ សម័យនោះ ទើបស្ដេចហង្សអូសអន្ទាក់មកដោយគិតថា អញនឹងធ្វើអន្ទាក់ឲ្យដាច់ លើកទី ១ ស្បែក ក៏ដាច់ទាំងអស់ លើកទី ២

អន្ទាក់ក៏មុតដល់សាច់ លើកទី ៣ អន្ទាក់ក៏កាត់ផ្តាច់នូវសរសៃ លើកទី ៤ អន្ទាក់ក៏រឹតដល់ឆ្អឹង ឈាមហូរមិនដាច់ វេទនាដ៏មានកម្លាំងប្រព្រឹត្តទៅហើយ ។ ទើបស្តេចហង្សនោះគិតថា បើអញស្រែកថា ជាប់អន្ទាក់ ពួកញាតិរបស់អញ ក៏នឹងនាំគ្នារន្ធត់ចិត្ត មិនទាន់បានបរិភោគអាហារ ត្រូវសេចក្តីឃ្លានដុតរោល នឹងគេចទៅធ្លាក់ចុះក្នុងមហាសមុទ្ទ ព្រោះអស់កម្លាំង ។ ស្តេចហង្សនោះព្យាយាមអត់ធន់ចំពោះទុក្ខវេទនា រហូតដល់ពួកហង្ស ដែលជាញាតិទាំងឡាយបរិភោគអាហារឆ្អែតហើយ កំពុងត្រេកអរ ទើបស្រែកដោយសំឡេងខ្លាំងថា ខ្ញុំជាប់អន្ទាក់ហើយ ។ ហង្សទាំងឡាយបានឮសំឡេងខ្លាំងនោះ មានការខ្លាចចំពោះមរណភ័យជាកម្លាំង ក៏ផ្ទុំគ្នាជាពួកៗ មានមុខទៅកាន់ភ្នំចិត្តកូដដោយរហ័ស កាលហង្សទាំងនោះ នាំគ្នាត្រឡប់ទៅអស់ហើយ សុមុខហង្សដែលជាសេនាបតីគិតថា ភ័យនេះកើតឡើងដល់ព្រះរាជារបស់អញ ឬមិនមែនហ្ន៎ អញនឹងដឹងដល់រឿងនោះ ទើបហើរទៅដោយរហ័ស មិនឃើញមហាសត្វក្នុងរវាងពួកហង្សដែលទៅខាងមុខ ទើបមករកមើលត្រង់កណ្តាល ក៏មិនបានឃើញមហាសត្វ ក្នុងទីនោះ ទើបមករកមើលក្នុងហ្វូងចុងក្រោយ ក៏មិនបានឃើញមហាសត្វ ក្នុងទីនោះទៀត ក៏សម្រេចចិត្តថា ភ័យនេះកើតឡើងដល់ស្តេចហង្សនោះដោយឥតសង្ស័យ ទើបប្រញាប់ត្រឡប់មកកន្លែងដើម ឃើញមហាសត្វជាប់អន្ទាក់ ឈរលើកក់មានឈាមហូរ រងទុក្ខវេទនាដ៏ក្តៅក្រហាយ ទើបប្រាប់ថា បពិត្រមហារាជ សូមទ្រង់កុំភ័យឡើយ ក៏ពោលថា ខ្ញុំនឹងលះបង់ជីវិត នឹងញុំាងទ្រង់ឲ្យផុតអំពីអន្ទាក់ ទើបបន្ទាបខ្លួនចុះ មកលួងលោមមហា

សត្វ ទំលើកក់ ។ គ្រានោះ ព្រះមហាសត្វ កាលពិសោធចិត្តសុមុខហង្សនោះ ទើបពោលបឋមគាថានេះថា

ម្នាលហង្សឈ្មោះ សុមុខៈ ពួកបក្សីកាលមិនគយគន់មើល
ហើរចេញទៅ អ្នកចូរទៅចុះ កុំប្រាថ្នា ( នៅក្នុងទីនេះឡើយ
ព្រោះថា ) ភាពនៃអ្នកជាសម្លាញ់នឹងយើង ដែលជាប់ចំណង
មិនមានទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនុបចិនន្តា** បានដល់ មិនជាប់ជំពាក់ដោយសេចក្តីស្រឡាញ់ គឺដោយសេចក្តីអាល័យ ។ បទថា **បក្កមន្តិ** សេចក្តីថា ស្តេចហង្សនោះពោលថា ហ្វូងហង្សទាំងឡាយសុទ្ធតែជាញាតិរបស់យើង ជាហង្សមានចំនួនប្រមាណ ៩៦០០០ មិនបានសម្លឹងមើលយើងដោយអំណាចសេចក្តីស្រឡាញ់ បោះបង់យើង ហើយហើរគេចទៅអស់ សូម្បីខ្លួនអ្នកក៏ចូរប្រញាប់ទៅចុះ កុំប្រាថ្នានៅក្នុងទីនេះឡើយ ព្រោះថា ភាពជាសម្លាញ់ក្នុងយើងដែលជាប់អន្ទាក់យ៉ាងនេះ មិនមាន ព្រោះថា ឥឡូវនេះ ខ្ញុំមិនអាចធ្វើកិច្ចដោយភាពជាសម្លាញ់តិចតួចដល់អ្នកបានឡើយ នឹងមានប្រយោជន៍អ្វីដល់អ្នក ដោយខ្ញុំដែលមិនមានឧបការៈ អ្នកកុំយឺតយូរឡើយ ចូរប្រញាប់ទៅចុះ ខាងមុខអំពីនោះ សុមុខហង្សពោលថា

ទូលព្រះបង្គំជាខ្ញុំទៅក្តី មិនទៅក្តី ទូលព្រះបង្គំជាខ្ញុំ មិនមែន
មិនស្លាប់ ដោយការទៅ ឬការមិនទៅទេ ទូលព្រះបង្គំជាខ្ញុំ
ចូលទៅរកព្រះអង្គ ដែលដល់នូវសេចក្តីសុខហើយ នឹងលះ

ព្រះអង្គដែលដល់នូវសេចក្តីទុក្ខដូចម្តេចកើត ។ សេចក្តីស្លាប់ជាមួយនឹងព្រះអង្គក្តី ការរស់នៅវៀរចាកព្រះអង្គក្តី សេចក្តីស្លាប់នោះប្រសើរជាង ទូលព្រះបង្គំជាខ្ញុំ តែវៀរចាកព្រះអង្គហើយ រស់នៅមិនប្រសើរសោះឡើយ ។ បពិត្រមហារាជ ទូលព្រះបង្គំជាខ្ញុំលះចោលព្រះអង្គ ដែលដល់ ( នូវសេចក្តីទុក្ខ ) យ៉ាងនេះ ដោយសភាវៈណា សភាវៈនោះ មិនមែនជាធម៌ទេ បពិត្រព្រះអង្គជាធំលើបក្សី ដំណើរណារបស់ព្រះអង្គ ដំណើរនោះទូលព្រះបង្គំជាខ្ញុំ ក៏គាប់ចិត្តដែរ ដូច្នេះ ។ ក្នុងលំដាប់នោះ ព្រះមហាសត្វក៏ពោលថា

ដំណើរដូចម្តេចរបស់ខ្ញុំ ដែលជាប់អន្ទាក់ហើយ ដទៃអំពីរោងគ្រួ ដំណើរនោះ ទៅជាពេញចិត្តដល់អ្នកដែលមានប្រាជ្ញា ជាអ្នកផុតអំពីអន្ទាក់ដូចម្តេច ។ ម្នាលអ្នកជាបក្សី កាលបើយើងទាំង ២ នាក់ អស់ជីវិតហើយ អ្នកឃើញនូវប្រយោជន៍ដូចម្តេច របស់ខ្ញុំផង របស់អ្នកផង របស់ពួកញាតិដ៏សេសផង ។ ម្នាលអ្នកមានស្លាបទាំងពីរដូចជាមាស ការលះបង់នូវជីវិតរបស់អ្នកណា ការលះបង់នូវជីវិតរបស់អ្នកនោះហាក់ដូចជាធ្មើក្នុងទីងងឹត ដោយសេចក្តីល្ងិតល្ងន់ អ្នកកាលលះបង់នូវជីវិត ព្រោះគុណដែលមិនជាក់ច្បាស់ដូច្នោះ តើព្រោះធ្វុះឃើញនូវប្រយោជន៍អ្វី ដូច្នេះ ។

សុមុខៈហង្សតបថា

បពិត្រព្រះអង្គដ៏ប្រសើរផុត ព្រះអង្គមិនជ្រាបនូវប្រយោជន៍ដែលធ្លាក់ចុះក្នុងធម៌ ដូចម្ដេច ដ្បិតធម៌ដែលពួកសត្វគោរពហើយ រមែងបង្ហាញនូវសេចក្ដីចម្រើន ដល់សត្វទាំងឡាយ ។ ទូលព្រះបង្គំជាខ្ញុំនោះ កាលឃើញនូវធម៌ផង នូវប្រយោជន៍ដែលកើតអំពីធម៌ផង ពិចារណាឃើញនូវសេចក្ដីស្រឡាញ់ចំពោះព្រះអង្គផង បានជាមិនប្រាថ្នាជីវិតទេ ។ មិត្តណា កាលវៀកឃើញនូវធម៌ហើយ មិនលះបង់មិត្ត ក្នុងកាលដែលមានសេចក្ដីអន្តរាយ ព្រោះហេតុនៃជីវិត ធម៌របស់មិត្តនោះឈ្មោះថា ជាធម៌របស់សប្បុរសទាំងឡាយដោយពិត ដូច្នេះ ។

លំដាប់នោះ ព្រះមហាសត្វពោលថា

ធម៌នោះអ្នកបានសន្សំហើយ ទាំងសេចក្ដីស្រឡាញ់ចំពោះយើងៗ ក៏បានដឹងច្បាស់ហើយ អ្នកចូរធ្វើតាមសេចក្ដីប្រាថ្នារបស់យើងនុ៎ះ អ្នកគឺយើងបានអនុញ្ញាតហើយ ចូរទៅចុះ ។ ម្នាលអ្នកបរិបូណ៌ដោយប្រាជ្ញា មួយទៀត ការបែកបាក់នៃពួកញាតិណា ដែលយើងបានបិទបាំងហើយ ក្នុងកាលដែលប្រព្រឹត្តទៅយ៉ាងនេះ ការបែកបាក់នៃពួកញាតិនោះ អ្នកគួរបិទបាំងទុកឲ្យល្អចុះ ដូច្នេះ ។

ព្រះសាស្ដា កាលទ្រង់ត្រាស់ដឹងហើយ ទើបត្រាស់អភិសម្ពុទ្ធគាថា

*នេះថា*

*កាលដែលអរិយហង្សទាំងឡាយ ជាសត្វមានការប្រព្រឹត្ត ដ៏ប្រសើរ កំពុងតែប្រឹក្សាគ្នាយ៉ាងនេះ ស្រាប់តែនាយនេសាទ មកប្រាកដដូចជាសេចក្តីស្លាប់ដែលប្រាកដដល់បុគ្គលឈឺ ។ ហង្សទាំង ២ នោះមានប្រយោជន៍ ( ដល់គ្នានឹងគ្នា ) យូរអង្វែងហើយ បានឃើញច្បាស់នូវសត្រូវ ក៏ទំនៅស្ងៀមទាំង ២ នាក់ មិនកក្រើកចាកទ្រនំឡើយ ។ ព្រានព្រៃជាសត្រូវនៃសត្វស្លាប បានឃើញហង្សឈ្មោះ សុមុខៈ នូវរាជហង្សឈ្មោះធតរដ្ឋៈ ជាស្តេចនៃបក្សី កាលខិតចូលមករកគ្នាអំពីទីនោះៗ ក៏ស្ទុះទៅដោយប្រញាប់ ។ លុះនាយនេសាទនោះ*

*ស្ទុះដោយប្រញាប់ទៅជិតពួកបក្សីប្រសើរហើយក៏គិតថាសត្វហង្សទាំង ២ នេះ ជាប់ហើយ ញាប់ញ័រ ។ ក៏នាយនេសាទបានឃើញសត្វហង្ស ១ ជាប់អន្ទាក់ហើយ ទំនៅ និងសត្វហង្ស ១ ទៀត ដែលមិនជាប់អន្ទាក់ ចូលមករកសត្វហង្សដែលជាប់អន្ទាក់ហើយទំនៅ សម្លឹងមើលនូវហង្ស ដែលមានទុក្ខ ។ លំដាប់អំពីនោះទៅ នាយនេសាទនោះ មានសេចក្តីសង្ស័យ ក៏បានសួរនូវសត្វហង្សមានពណ៌ស មានកាយដ៏ធំ ជាអធិបតីលើហ្វូងនៃបក្សីថា សត្វហង្សដែលជាប់អន្ទាក់*

ដ៏ធំដល់ម្ល៉ោះ មិនធ្វើនូវទិស ( ដើម្បីហើរទៅ ) ដោយហេតុណា ( ហេតុនោះគួរហើយ ) ម្នាលសត្វស្វាប ចុះអ្នកមិនជាប់អន្ទាក់ទេ ជាសត្វមានកម្លាំង ហេតុអ្វី ក៏មិនហើរទៅ ។ សត្វបក្សីនេះត្រូវជាអ្វីនឹងអ្នក អ្នករួច ( អំពីអន្ទាក់ហើយ ) ចូលមករកបក្សីដែលជាប់អន្ទាក់វិញ បក្សីទាំងឡាយនាំគ្នាហើរចោលទៅអស់ហើយ ប៉ុន្តែអ្នកក្រាញនៅតែម្នាក់ឯងដូច្នេះ ។

សុមុខៈហង្សពោលតបថា

បពិត្រនាយនេសាទ ជាសត្រូវនៃសត្វបក្សី ឯហង្សនោះជាព្រះរាជានៃខ្ញុំផង ជាសម្លាញ់ស្មើដោយជីវិតនៃខ្ញុំផង ខ្ញុំនឹងមិនលះបង់នូវហង្សនោះ ដរាបដល់សេចក្តីស្លាប់មកដល់ដូច្នេះ ។

នាយព្រានក៏ពោលថា

ចុះហេតុអ្វី ហង្សនោះ ក៏មិនឃើញនូវអន្ទាក់ដែលគេដាក់ហើយ ដំណើរនេះហើយ ដែលជាដំណើរសម្រាប់ពួកសត្វធំៗ ពួកសត្វធំៗ គួរដឹងនូវសេចក្តីអន្តរាយ ដូច្នេះ ។

សុមុខៈហង្សពោលថា

កាលណា ដែលសត្វជាអ្នកមានសេចក្តីវិនាស ក្នុងកាលជាទីអស់ទៅនៃជីវិត កាលនោះ សត្វនោះ សូម្បីចូលមកជិតដល់សំណាញ់និងអន្ទាក់ ក៏នៅតែមិនដឹងឡើយ ដូច្នេះ ។

នាយព្រានពោលថា

ម្នាលសត្វមានប្រាជ្ញាច្រើន មែនហើយ អន្ទាក់ទាំងឡាយ

យើងបានដាក់ហើយជាច្រើន កាលបើសត្វមានជីវិតអស់ទៅ

យ៉ាងនេះ សត្វស្លាបទាំងឡាយ តែងចូលមកជាប់នឹងអន្ទាក់

ដ៏កំបាំង ដូច្នេះ ។

អត្ថនៃគាថាទាំងនេះ បណ្ឌិតគប្បីជ្រាបដោយន័យដែលមកហើយ ក្នុងបាលីនោះឯង ។

បណ្ដាបទទាំងនោះ បទថា **គច្ឆេ វា** សេចក្ដីថា សុមុខហង្សនោះពោលថា បពិត្រមហារាជ ខ្ញុំគប្បីទៅអំពីទីនេះក្ដី មិនទៅក្ដី តែទីដែលខ្ញុំមិនស្លាប់ ព្រោះការទៅ ឬការមិនទៅនោះ មិនមានឡើយ ព្រោះថា ខ្ញុំទោះទៅអំពីទីនេះ ឬមិនទៅក្ដី គង់មិនផុតចាកសេចក្ដីស្លាប់ដោយពិត ក្នុងកាលមុននេះ ព្រះអង្គមានសេចក្ដីសុខ ខ្ញុំក៏បាននៅជិត ឥឡូវនេះ ព្រះអង្គកំពុងទទួលទុក្ខ ខ្ញុំនឹងបោះបង់បានដូចម្ដេច ។ បទថា **មរណំ វា** សេចក្ដីថា កាលខ្ញុំមិនទៅគប្បីស្លាប់ជាមួយទ្រង់តែម្យ៉ាង ឬបើខ្ញុំទៅ តែមានជីវិតវៀរចាកព្រះអង្គក្នុង ២ យ៉ាងនេះ ការស្លាប់ជាមួយព្រះអង្គនោះឯង ជារបស់ប្រសើរពន់ពេកនៃខ្ញុំ ឯការដែលខ្ញុំគប្បីមានជីវិត វៀរចាកព្រះអង្គនោះ មិនជារបស់ប្រសើរសម្រាប់ខ្ញុំឡើយ ។ បទថា **រុច្ចតេ** សេចក្ដីថា ការសម្រេចនោះឯង រមែងជាទីគាប់ចិត្តរបស់ខ្ញុំ ។ បទថា **សា កថំ** សេចក្ដីថា នៃសុមុខហង្សសម្លាញ់ កាលយើងជាប់អន្ទាក់ ដែលធ្វើដោយស្បែកសត្វសាហាវយ៉ាងមាំទាំ ហើយទៅ

ក្នុងដៃរបស់បុគ្គលដទៃ គតិនោះ ទើបជាទីគាប់ចិត្តមុន តែបើអ្នកមានការគិតមានបញ្ញាផុតចាកអន្ទាក់ហើយ នៅជាទីគាប់ចិត្តបានដូចម្តេច ។ បទថា **បក្ខិម** បានដល់ សម្បុរដោយរោមស្លាប ។ បទថា **ឧភិន្នំ** សេចក្តីថា កាលយើងទាំង ២ អស់ជីវិតទៅហើយ អ្នកនឹងឃើញប្រយោជន៍អ្វីរបស់យើង របស់អ្នកឬរបស់ពួកញាតិដ៏សេស ។ **ឆ** អក្ខរៈ ក្នុងពាក្យថា **យន្ន** នេះ ប្រើក្នុងសេចក្តីឧបមា ។ បទថា **កញ្ចនធេបិច្ច** បានដល់ មានរោមស្លាបទាំង ២ ដូចពណ៌មាស ម្យ៉ាងទៀត បាលីក៏យ៉ាងនេះដូចគ្នា សេចក្តីថា មានស្លាបទាំង ២ ដូចមាស ។ បទថា **តមសា** បានដល់ ក្នុងភាពងងឹត ម្យ៉ាងទៀត បាលីក៏យ៉ាងនេះដូចគ្នា ។ **ឆ** អក្ខរៈខាងដើម ភ្ជាប់សេចក្តីជាមួយបទនេះ ។ បទថា **កតំ** សេចក្តីថា ហាក់ដូចជាធ្វើហើយ មានពាក្យអធិប្បាយថា កាលអ្នកលះបង់ជីវិតក្តី មិនលះបង់ជីវិតក្តី ជីវិតរបស់យើងក៏មិនរួចពិត ការលះបង់ជីវិតរបស់អ្នកនោះ ឈ្មោះថា មិនប្រចក្សនូវគុណ ព្រោះមិនបានទទួលប្រយោជន៍តិចតួចឡើយ ប្រៀបដូចការលះបង់ជីវិតដែលមនុស្សក្អែកខ្វាក់ ធ្វើក្នុងទីងងឹត អ្នកលះបង់ជីវិតក្នុងការលះ ដែលមិនប្រចក្សនូវគុណបែបនេះ គប្បីញ៉ាំងប្រយោជន៍អ្វីឲ្យរុងរឿងបាន ។ បទថា **ធម្មោ អបចិតោ សន្តោ** សេចក្តីថា ធម៌ដែលបុគ្គលបូជាហើយ រាប់អានហើយ គោរពហើយ ។ បទថា **អត្ថំ ធស្សេតិ** បានដល់ សម្តែងដល់សេចក្តីចម្រើន ។ បទថា **អបេក្ខានោ** បានដល់ ពិចារណា ។ បទថា **ធម្មា ចត្ថំ** សេចក្តីថា ម្យ៉ាងទៀត ខ្ញុំឃើញនូវប្រយោជន៍ដែលតាំងឡើងហើយអំពីធម៌ ។ បទថា **ភត្តិ** បានដល់ ការស្រឡាញ់

*ជាប់ជំពាក់ ។ បទថា* **សតំ ធម្មោ** *បានដល់ ជាសភាវៈនៃបណ្ឌិតទាំងឡាយ ។ បទថា* **យោ មិត្តោ** *សេចក្តីថា មិត្តណា មិនគប្បីបោះបង់មិត្ត ក្នុងពេលបានទទួលអន្តរាយ ធម៌នេះឯងឈ្មោះថា ជាសភាពរបស់មិត្តដែលមិនបោះបង់មិត្តនោះ ធម៌របស់សប្បុរសទាំងឡាយជាក់ច្បាស់ហើយ គឺប្រាកដហើយដោយពិត ។ បទថា* **ការមំ ករស្សុ** *សេចក្តីថា ចូរធ្វើតាមសេចក្តីប្រាថ្នារបស់យើង គឺតាមពាក្យរបស់យើង ដែលយើងប្រាថ្នាទុកនេះ ។ បទថា* **អបិត្ទោ គតោ កាលោ** *សេចក្តីថា ពេលវេលាកន្លងទៅហើយយ៉ាងនេះ គឺពេលយើងកំពុងជាប់អន្ទាក់នៅក្នុងទីនេះ ។ បទថា* **បរមសំវុតំ** *បានដល់ គប្បីរវាំងប្រយ័ត្នយ៉ាងខ្លាំងក្លា ។*

*បទថា* **ឥច្ចេវំ មន្តយន្តានំ** *បានដល់ កំពុងពោលសំណូមពរគ្នាយ៉ាងនេះថា ចូរអ្នកទៅ ខ្ញុំមិនទៅ ដូច្នេះ ។ បទថា* **អរិយានំ** *បានដល់ ជាបុគ្គលប្រសើរ ដោយការប្រព្រឹត្ត ។ បទថា* **បច្ចទិស្សថ** *សេចក្តីថា នាយព្រានស្លៀកសំពត់ជ្រលក់ដោយទឹកម្ចត់ ប្រដាប់នូវកម្រងផ្កាពណ៌ក្រហម កាន់ដំបងកំពុងដើរមកនោះឯង ប្រាកដដល់ហង្សទាំង ២ ។ បទថា* **អាតុរានំ** *បានដល់ ដូចស្តេចមច្ចុរាជ ប្រាកដដល់អ្នកជំងឺទាំងឡាយ ដូច្នោះ ។ បទថា* **អភិសញ្ចិក្ខុ** *សេចក្តីថា ម្នាលភិក្ខុទាំងឡាយ សុវណ្ណហង្សទាំង ២ នោះឃើញសត្រូវដើរមក ។ បទថា* **ហិតា** *បានដល់ ជាអ្នកឧបការៈ ដល់គ្នានឹងគ្នាមានចិត្តស្រឡាញ់គ្នាទៅវិញទៅមកអស់កាលយូរ ។ បទថា* **ឆ សញ្ញលេសុមាសជា** *បានដល់ មិនបានកម្រើកចាកទីទំក្នុងកន្លែងដែលនោះឯង ព្រោះថា*

សុមុខហង្សគិតថា នាយព្រាននេះមកហើយ បើត្រូវការប្រហារក៏ចូរប្រហារ អញមុន ទើបឈរខាងមុខព្រះមហាសត្វ ទុកព្រះមហាសត្វអំពីខាងក្រោយ ។ បទថា **ធតរដ្ឋេ** សំដៅយកពួកហង្សធតរដ្ឋៈទាំងពីរ ។ បទថា **សមុឌ្ឌេន្តេ** សេចក្ដីថា ព្រានឃើញហង្សកំពុងដើរ ត្រឡប់ទៅត្រឡប់មក ព្រោះខ្លាចសេចក្ដីស្លាប់ ។ បទថា **អាសជ្ជ** បានដល់ គាត់ចូលទៅជិតហង្សទាំង ២ នេះ ។ បទថា **បច្ចកម្បិត្ថ** បានដល់ នាយព្រាន គិតពិចារណាថា ហង្សនោះជាប់អន្ទាក់ ឬមិនជាប់អន្ទាក់ ទើបដើរសន្សឹមៗ គឺបន្ថយល្បឿន ហើយដើរទៅសន្សឹមៗ ។ បទថា **អាសជ្ជ ពន្ធមាសីនំ** សេចក្ដីថា នាយព្រានឃើញសុមុខហង្សទំរក្សព្រះមហាសត្វដែលជាប់អន្ទាក់ ។ បទថា **អាធីនវ៉** បានដល់ នាយព្រានឃើញព្រះមហាសត្វ ដែលមានទោសនោះឯង សម្លឹងមើល ។ បទថា **វិមតោ** សេចក្ដីថា ព្រាននោះកើតសេចក្ដីសង្ស័យថា ហេតុអ្វីហ្ន៎ សត្វដែលមិនជាប់អន្ទាក់ មកទំរក្សសត្វដែលជាប់អន្ទាក់ អញនឹងសួរឲ្យដឹងហេតុ ។ បទថា **បណ្ឌរេ** បានដល់ ហង្សទាំងពីរ ម្យ៉ាងទៀត អធិប្បាយថា ជាសត្វបរិសុទ្ធប្រាសចាកគ្រឿងសៅហ្មង គឺមានពណ៌ដូចមាស ដែលគេរំលាយល្អហើយ ។ បទថា **បវឌ្ឍកាយេ** បានដល់ មានរាងកាយធំហើយ គឺមានរាងកាយធំ ។ បទថា **យន្ទុ** សំដៅយកហង្ស ដែលជាប់អន្ទាក់ធំនេះ ។ បទថា **ន កុរុតេ ទិសំ** សេចក្ដីថា មិនជ្រើសរើសត្រឹមតែទិសមួយ ដើម្បីគេចទៅ អធិប្បាយថា ការធ្វើដូច្នោះជាការសមគួរហើយ ។ បទថា **ពលី** បានដល់ ជាសត្វដែលសម្បូរដោយកម្លាំង ។ នាយព្រានរមែងហៅហង្សនោះថា បក្សី ។

បទថា **ឱហាយ** បានដល់ បោះបង់ចោលហើយ ។ បទថា **យន្តិ** សេចក្តីថា ហ្វូងហង្សដ៏សេសនាំគ្នាហើរទៅអស់ ។ បទថា **អវហីយសិ** បានដល់ ឋិតនៅ ។ បទថា **ឱជាមិត្ត** បានដល់ មិនជាមិត្តដល់ពួកបក្សីទាំងឡាយ ។ បទថា **យាវ កាលស្ស បរិយាយំ** បានដល់ រហូតដល់វារៈចុងក្រោយនៃសេចក្តីស្លាប់មកដល់ ។ បទថា **កថំ បជាយំ** សេចក្តីថា អ្នកពោលថា ស្តេចហង្សនោះជាព្រះរាជារបស់អ្នក ធម្មតាព្រះរាជាទាំងឡាយ រមែងជាបណ្ឌិត ព្រះរាជារបស់អ្នកជាបណ្ឌិត ដោយប្រការដូច្នេះ ព្រោះហេតុអ្វី ទើបមិនឃើញអន្ទាក់ដែលដាក់ ។ បទថា **បទំ មហតំ** សេចក្តីថា ឈ្មោះថា ការដឹងក្នុងអន្តរាយរបស់ខ្លួន រមែងជាបទ គឺជាហេតុនៃបុគ្គលទាំងឡាយ ដែលដល់នូវភាពជាបុគ្គលធំដោយយស ឬភាពជាបុគ្គលធំដោយវិជ្ជា ព្រោះដូច្នោះ ទើបបណ្ឌិតទាំងនោះ គួរដឹងដល់អន្តរាយ ។ បទថា **បរាភវោ** បានដល់ សេចក្តីមិនចម្រើន ។ បទថា **អាសជ្ជាបិ** បានដល់ ទោះបីចូលទៅដល់អន្ទាក់ក៏មិនដឹងខ្លួន ។ បទថា **តតា** បានដល់ បញ្ឆោត ឬលាក់ ។ បទថា **គុយ្ហមាសជ្ជ** សេចក្តីថា បណ្តាអន្ទាក់ទាំងនោះ អន្ទាក់ណាដែលមិនច្បាស់ គឺដាក់បញ្ឆោត សត្វទាំងឡាយចូលក្បែរអន្ទាក់នោះ រមែងត្រូវជាប់ ។ បទថា **អថេវំ** សេចក្តីថា កាលដល់នូវការអស់ជីវិតយ៉ាងនេះ សត្វទាំងឡាយរមែងត្រូវតែរួតជាប់ពិតនោះឯង ។

សុមុខហង្សនោះ ធ្វើព្រានឲ្យមានចិត្តទន់ ដោយការចរចាប្រាស្រ័យដោយប្រការដូច្នេះហើយ កាលនឹងសូមជីវិតរបស់ព្រះមហាសត្វ ទើបពោលគាថានេះថា

សូមឲ្យការនៅរួមជាមួយនឹងអ្នកនេះ មានសុខជាកម្រៃ សូមអ្នកអនុញ្ញាតយើងខ្ញុំ សូមអ្នកឲ្យជីវិតដល់យើងខ្ញុំ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អបិ ឆាយំ** កាត់បទជា **អបិ នុ អយំ** ។ បទថា **សុខុទ្រយោ** បានដល់ មានផលជាសុខ ។ បទថា **អបិ នោ អនុមញ្ញាសិ** សេចក្ដីថា សូមលោកអនុញ្ញាត ឲ្យយើងទាំង ២ ត្រឡប់ទៅកាន់ក្ដិចិត្តកូដដើម្បីជួបជុំញាតិទាំងឡាយចុះ ។ បទថា **អបិ នោ ជីវិតំ ទទេ** សេចក្ដីថា ម្យ៉ាងទៀត លោកមានការស្និទ្ធស្នាលកើតឡើងហើយ ដោយពាក្យសម្ដីនេះ កុំសម្លាប់ខ្ញុំទាំង ២ ឡើយ ។

នាយព្រានត្រូវជាប់ដោយពាក្យសម្ដីដ៏ពីរោះរបស់សុមុខហង្សនោះ ទើបពោលគាថានេះថា

ឯងមិនជាប់ ( អន្ទាក់ ) អញទេ ទាំងអញទៀតសោត ក៏មិន
ប្រាថ្នាសម្លាប់ឯងដែរ ចូរឯង ទៅអំពីទីនេះតាមប្រាថ្នាយ៉ាង
ឆាប់ ហើយរស់នៅមិនមានទុក្ខ អស់កាលជាអង្វែងចុះ ដូច្នេះ ។

លំដាប់នោះ សុមុខហង្សក៏ពោលគាថា ៤ ថា

ខ្ញុំប្រាសចាកជីវិតនៃបក្សីនោះហើយ មិនប្រាថ្នាជីវិតទេ ។ បើ
អ្នកត្រេកអរដោយហង្ស ១ ចូរអ្នកលែងនូវហង្សនេះទៅ ចូរ
បរិភោគនូវខ្ញុំវិញចុះ ។ យើងទាំង ២ នាក់នោះ មានកម្ពស់
ទំហំនិងវ័យស្មើ ៗ គ្នា អ្នកមិនមែនសាបសូន្យចាកលាភទេ
សូមអ្នកប្ដូរយកខ្ញុំដោយហង្សនេះ ។ ចូរអ្នកសង្កេតមើល

ដំណើរនេះចុះ សេចក្តីជាប់ចិត្តរបស់អ្នកចំពោះយើងទាំង
ឡាយ សូមលើកទុកសិន ចូរអ្នកយកអន្ទាក់ចងខ្ញុំមុនសិន
ចុះ រួចសឹមលែងស្តេចបក្សីជាខាងក្រោយ ។ លាភរបស់
អ្នក ក៏នៅដដែលផង សេចក្តីអង្វរនេះ ក៏ឈ្មោះថា អ្នកបាន
ធ្វើតាមផង សេចក្តីរាប់អានដោយរាជហង្សឈ្មោះ ធតរដ្ឋៈ
គប្បីមានដល់អ្នក ដរាបដល់អស់ជីវិតផង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឯតំ** សេចក្តីថា ខ្ញុំមិនប្រាថ្នាការរស់នៅដោយប្រាសចាកជីវិតរបស់ស្តេចហង្សនេះឡើយ ។ បទថា **តុល្យស្មា** បានដល់ យើងទាំង ២ រមែងជាអ្នកស្មើគ្នា ។ បទថា **និមិនា តុវំ** បានដល់ ចូរអ្នកដោះដូរនូវគ្នានឹងគ្នាចុះ ។ បទថា **តវស្មសុ** សេចក្តីថា សុមុខហង្សនោះ ពោលថា លោកមានសេចក្តីប្រាថ្នាក្នុងខ្ញុំទាំង ២ លោកមានប្រយោជន៍អ្វី ដោយស្តេចហង្សនេះ ចូរញុំាំងសេចក្តីលោភឲ្យកើតឡើងក្នុងខ្ញុំ ។ បទថា **តាវទេវ** បានដល់ ត្រឹមប៉ុណ្ណោះឯង ។ បទថា **យាចណាយ ច** បានដល់ ពាក្យសូមរបស់ខ្ញុំឯណា សូមលោកធ្វើតាមពាក្យសូមនោះចុះ ។

ព្រានមានចិត្តទោរទន់បន្តិចទៀត ព្រោះការសម្តែងធម៌នោះ ដូចប៉ុយដែលគេដាក់ក្នុងប្រេង ដូច្នោះ កាលលើកព្រះមហាសត្វឲ្យជារង្វាន់ដល់សុមុខហង្សនោះ ទើបពោលគាថានេះថា

ពួកសត្វបក្សីជាច្រើន ដែលជាមិត្តអាមាត្យក្តី មាតាបិតាក្តី
កូនប្រពន្ធក្តី ជាផៅពង្សក្តី ចូរចួបនូវរាជហង្សនេះ ដែលរួច

ហើយព្រោះអ្នក ហើរទៅអំពីទីនេះ ។ ពួកមិត្តរបស់ពួកសត្វ ដទៃជាច្រើន ដែលប្រហែលគ្នានឹងមិត្តរបស់អ្នក ដូចអ្នកជាសម្លាញ់ស្មើជីវិតនឹងរាជហង្សឈ្មោះ ធតរដ្ឋៈនេះ មិនមានក្នុងទីនេះទេ ។ ខ្ញុំនោះ បានលែងនូវរាជហង្ស ជាសម្លាញ់របស់អ្នក ព្រះរាជារបស់អ្នក ចូរទៅតាមអ្នកចុះ អ្នកទាំងឡាយចូរហើរទៅអំពីទីនេះ តាមប្រាថ្នាជាចាប់ ហើយរុងរឿងក្នុងកណ្តាលពួកញាតិចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆោ** ត្រឹមតែជានិបាត ។ បទថា **តយា មុត្តំ** សេចក្តីថា ពិតហើយ អ្នកម្នាក់ ឈ្មោះថា រមែងលែងនូវស្តេចហង្សនេះ ព្រោះដូច្នោះ ពួកញាតិដ៏ធំទាំងឡាយ និងមិត្តជាដើមនោះ ចូរមើលស្តេចហង្សនេះដែលលោកលែងហើយ បានទៅកាន់ក្តីចិត្តកូដអំពីទីនេះ ។ បទថា **ពន្ធវា** ក្នុងគាថានេះ សំដៅយកបុគ្គលដែលទាក់ទងគ្នា ដោយខ្សែលោហិតជាមួយគ្នា ។ បទថា **វិជ្ជរេ** បានដល់ មាន ។ បទថា **ចាណសាធារណោ** បានដល់ មានជីវិតរួមគ្នា មានជីវិតបែកគ្នាមិនបាន អធិប្បាយថា អ្នកជាសម្លាញ់របស់ស្តេចហង្សនេះ ដោយប្រការណា សូម្បីជនដទៃជាច្រើន ជនដែលឈ្មោះថា ជាមិត្តដូចអ្នកនេះ រមែងមិនមានដោយប្រការនោះ ។ បទថា **តវានុគោ** សេចក្តីថា អ្នកចូរហើរទៅខាងមុខស្តេចហង្សដែលកំពុងបាន ទទួលសេចក្តីលំបាកនេះ ស្តេចហង្សនេះ ចូរហើរតាមអ្នកទៅអំពីខាងក្រោយចុះ ។

នាយព្រានកាលពោលយ៉ាងនេះហើយ ដើរចូលទៅជិតមហាសត្វដោយ

ចិត្តប្រកបដោយមេត្តា កាត់អន្ទាក់ចេញហើយ បីត្រកងចេញអំពីស្រះ ឲ្យទំលើស្បូវភ្លាំងខ្ចីក្បែរមាត់ស្រះ ស្រាយអន្ទាក់ដែលរឹតជើងចេញសន្សឹមៗ ដោយចិត្តទន់ភ្លន់ គ្រវែងចោលក្នុងទីឆ្ងាយ កើតសេចក្តីស្រឡាញ់ក្នុងព្រះមហាសត្វដ៏មានកម្លាំង ទើបទៅដងទឹកមកលាងឈាមឲ្យ ហើយអង្អែលរឿយៗ ដោយមេត្តាចិត្ត ដោយអានុភាពនៃមេត្តាចិត្តរបស់ព្រាននោះ សរសៃជាប់គ្នានឹងសរសៃ សាច់ជាប់គ្នានឹងសាច់ ស្បែកជាប់គ្នានឹងស្បែក ជើងរបស់ព្រះពោធិសត្វ ជាដូចប្រក្រតីក្នុងខណៈនោះឯង កជើងរបស់ព្រះមហាសត្វ ក៏ដុះឡើងពេញបរិបូណ៌ មានស្បែកដូរផង់ មានរោមស្អាតកើតឡើងដូចមុន ដូចគ្នានឹងជើងមិនធ្លាប់ត្រូវអន្ទាក់ជាប់មកអំពីមុននោះឯង ។ ព្រះពោធិសត្វ បានទទួលសេចក្តីសុខ អន្តុយដោយភាពជាប្រក្រតីហើយ ។ លំដាប់នោះ សុមុខហង្សបានដឹងថា ព្រះមហាសត្វ មានសេចក្តីសុខព្រោះអាស្រ័យខ្លួន ក៏កើតសោមនស្សធ្វើនូវការសរសើរនាយព្រានហើយ ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

> ហង្សឈ្មោះសុមុខៈនោះ មានចិត្តត្រេកអរ ព្រោះម្ចាស់ផុតចាកចំណង ជាសត្វគោរពម្ចាស់ កាលពោលនូវវាចាដ៏ស្រួលដល់ត្រចៀក ទើបពោលថា បពិត្រនាយនេសាទ យើងត្រេកអរ ព្រោះបានឃើញនូវស្តេចបក្សី ដែលរួចចាកអន្ទាក់ក្នុងថ្ងៃនេះ យ៉ាងណា លោកចូរត្រេកអរជាមួយនឹងពួកញាតិទាំងអស់ យ៉ាងនោះចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វឌ្ឍេន្តោ** បានដល់ ឱនកគោរព ។

សុមុខហង្សធ្វើនូវការសរសើរដោយពាក្យថា **លុទ្ទក** យ៉ាងនេះហើយ បានពោលនឹងព្រះពោធិសត្វថា បពិត្រមហារាជ ព្រានទេះធ្វើឧបការៈយ៉ាងធំដល់យើងទាំង ២ ដ្បិតថា ព្រាននេះ មិនធ្វើតាមពាក្យរបស់ខ្ញុំហើយ នឹងធ្វើយើងទាំង ២ ទុកក្នុងហង្សក្រីឡា ហើយឲ្យដល់ឥស្សរជនទាំងឡាយនឹងបានទ្រព្យច្រើន ឬសម្លាប់យើងទាំង ២ ហើយយកសាច់លក់ ក៏បានទ្រព្យច្រើនដូចគ្នា តែគេបានឲ្យជីវិត ទើបធ្វើតាមពាក្យរបស់ខ្ញុំ យើងទាំង ២ គួរនាំព្រាននេះ ទៅកាន់សម្នាក់របស់ព្រះរាជា ហើយធ្វើជីវិតរបស់គេឲ្យជាសុខ ។ មហាសត្វក៏យើញយ៉ាងនោះដែរ សុមុខហង្សពោលនឹងមហាសត្វ ដោយភាសារបស់ខ្លួនហើយ ទើបហៅនាយព្រានមកសួរដោយភាសារបស់មនុស្សទៀតថា នែសម្លាញ់ អ្នកដាក់អន្ទាក់ដើម្បីអ្វី កាលបានទទួលចម្លើយថា ដើម្បីទ្រព្យ ក៏ពោលថា កាលបើដូច្នោះ សូមលោកនាំពួកយើងទាំង ២ ចូលកាន់ព្រះនគរ ហើយបង្ហាញដល់ព្រះរាជា ខ្ញុំទាំង ២ នឹងធ្វើព្រះរាជាឲ្យព្រះរាជទានទ្រព្យជាច្រើនដល់លោក ហើយពោលគាថានេះថា

> លោកចូរមកនេះ ខ្ញុំប្រៀនប្រដៅលោកឲ្យបានលាភ រាជហង្ស
> ឈ្មោះធតរដ្ឋនេះ ឥតឃើញសេចក្ដីអាក្រក់ របស់លោក
> តិចតួចទេ ។ លោកចូរ ( នាំយើងខ្ញុំ ) ទៅក្នុងរាជបុរីជាធាប់ ហើយបង្ហាញចំពោះព្រះរាជានូវយើងខ្ញុំទាំង ២ នាក់
> ដែលមិនជាប់ចំណង មានសភាពជាប្រក្រតី ឋិតនៅលើ

អម្រែកទាំង ២ ខាង ។ ( លោកក្រាបទូលថា ) បពិត្រ មហារាជ ហង្សទាំង ២ នេះ កើតក្នុងត្រកូលធតរដ្ឋៈ ជាអធិបតីលើពួកហង្ស ឯហង្សនេះ ជាព្រះរាជារបស់ហង្សទាំងឡាយ ហង្សមួយទៀតនេះជាសេនាបតី ។ ព្រះរាជាជាអធិបតីលើពួកជន ទ្រង់បានទតឃើញរាជហង្សនេះហើយ មុខជាទ្រង់មានព្រះរាជហឫទ័យត្រេកអររីករាយ នឹងប្រទានទ្រព្យជាច្រើនដល់អ្នកឥតសង្ស័យ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អនុសិក្ខាមិ** បានដល់ ទូន្មាន ។ បទថា **ចាបំ** បានដល់ លាមក ។ បទថា **រញ្ញោ ឧស្សេហិ នោ ឧភោ** សេចក្ដីថា សូមលោកបង្ហាញយើងទាំង ២ ដល់ព្រះរាជា សុមុខហង្សពោលយ៉ាងនេះ ដោយហេតុ ៤ ប្រការ គឺសម្ដែងអានុភាពនៃបញ្ញាព្រះពោធិសត្វ ១ ញុំាងមិត្តធម៌របស់ខ្លួនឲ្យប្រាកដជាក់ច្បាស់ ១ ដើម្បីឲ្យព្រានបានទ្រព្យ ១ ដើម្បីញុំាងព្រះរាជាឲ្យតាំងនៅក្នុងសីល ១ ។ បទថា **ធតរដ្ឋា** សេចក្ដីថា កាលលោកនាំខ្ញុំទាំង ២ ទៅហើយ សូមក្រាបទូលដល់ព្រះរាជាយ៉ាងនេះថា បពិត្រមហារាជ ហង្សជាអធិបតីរបស់ហង្សទាំងឡាយនេះ កើតក្នុងត្រកូលធតរដ្ឋៈ បណ្ដាហង្សទាំង ២ នេះ ហង្សនេះជាព្រះរាជា ហង្សនេះជាសេនាបតី ចូរញុំាងព្រះរាជានោះឲ្យសិក្សា ដោយប្រការដូច្នោះ ។ ពាក្យទាំង ៣ មានពាក្យថា **បតីតោ** ដូច្នេះជាដើម ជាពាក្យដែលសម្ដែងអាការត្រេកអរ ។

កាលសុមុខហង្សពោលយ៉ាងនេះហើយ ទើបនាយព្រានពោលថា នែ

អ្នកទាំង ២ អ្នកកុំគាប់ចិត្តចូលគាល់ព្រះរាជាឡើយ ធម្មតាព្រះរាជាទាំងឡាយ មានព្រះហឫទ័យមិនទៀងទាត់ គប្បីធ្វើអ្នកឲ្យជាហង្សក្រីឡា ឬបើមិនដូច្នោះ សម្លាប់អ្នកទាំង ២ ចោល ។ កាលសុមុខហង្សពោលថា នែសម្លាញ់ អ្នកកុំខ្លាចឡើយ បុគ្គលដែលមានចិត្តឃោរឃៅប្រហែលនឹងព្រាន មានបាតដៃប្រឡាក់ដោយឈាមអម្បាលលោក គង់ខ្ញុំធ្វើឲ្យទន់ចិត្ត ហើយក្រាបចុះទៀបជើងទាំង ២ របស់ខ្ញុំបាន ដោយធម្មកថា ធម្មតាព្រះរាជាទាំងឡាយ ជាអ្នកមានបញ្ញា មានបុណ្យ ទ្រង់រមែងដឹងនូវពាក្យដែលជាសុភាសិត ទុព្ភាសិត សូមលោកប្រញាប់នាំខ្ញុំទាំង ២ ទៅគាល់ព្រះរាជាចុះ ទើបពោលថា បើដូច្នោះ អ្នកទាំង ២ កុំខឹងនឹងខ្ញុំឡើយ យើងនឹងនាំទៅតាមបំណងរបស់អ្នកទាំង ២ ប៉ុណ្ណោះ ហើយទើបត្រកងសុវណ្ណហង្សទាំង ២ ដាក់ក្នុងកញ្ជ្រែបីនាំទៅកាន់រាជត្រកូល បង្ហាញដល់ព្រះរាជា កាលព្រះរាជាត្រាស់សួរ ក៏ក្រាបទូលរឿងតាមសេចក្ដីពិតឲ្យទ្រង់ជ្រាបគ្រប់ប្រការ ។

ព្រះសាស្ដា កាលប្រកាសសេចក្ដីនោះ ទើបត្រាស់ថា

នាយនេសាទ លុះបានស្ដាប់ពាក្យហង្ស ឈ្មោះសុមុខៈនោះ ហើយ ក៏បង្ហើយកិច្ចការ រួច ( នាំហង្សទាំង ២ ) ទៅខាងក្នុងបុរីយ៉ាងឆាប់ ហើយបង្ហាញចំពោះព្រះរាជានូវហង្សទាំង ២ ដែលមិនជាប់អន្ទាក់ មានសភាពតាមប្រក្រតី ឋិតនៅលើអម្រែកទាំង ២ ខាងថា បពិត្រមហារាជ ហង្សទាំង ២ នេះ កើតក្នុងត្រកូលធតរដ្ឋៈជាអធិបតីលើពួកហង្ស ឯហង្ស

នេះ ជាព្រះរាជារបស់ហង្សទាំងឡាយ ហង្សមួយទៀតនេះ ជាសេនាបតី ដូច្នេះ ។

ព្រះរាជាទ្រង់ស្តាប់ពាក្យនោះ ទើបត្រាស់សួរថា

ហង្សទាំងនេះ មកឋិតនៅក្នុងកណ្តាប់ដៃរបស់អ្នក តើដោយហេតុដូចម្តេច អ្នកជានាយព្រាន បានដល់នូវភាពជាធំជាងសត្វហង្សដ៏ធំ ៗ ទាំងឡាយក្នុងទីនេះ ដោយហេតុដូចម្តេច ដូច្នេះ ។

ព្រានព្រៃក៏ក្រាបទូលថា

បពិត្រព្រះអង្គជាធំជាងជន ទូលព្រះបង្គំជាខ្ញុំ ស្គាល់នូវកន្លែងជាទីប្រជុំនៃពួកសត្វស្លាបណា ៗ ជាទីធ្វើឲ្យអស់ទៅនៃជីវិតនៃពួកសត្វស្លាប ទូលព្រះបង្គំជាខ្ញុំ បានដាក់អន្ទាក់ទាំងនេះលើភក់ទាំងឡាយ ( ក្នុងកន្លែងនោះៗ ) ។ រាជហង្សបានមកជាប់អន្ទាក់ប្រាកដដូច្នោះ ចំណែកហង្សជាសេនាបតីនេះ មិនជាប់អន្ទាក់ទេ តែចូលទៅទំជិតនឹងរាជហង្សនោះ ហើយបាននិយាយនឹងទូលព្រះបង្គំជាខ្ញុំ ។ ហង្សជាសេនាបតីនេះ ( បានធ្វើ ) នូវអំពើដែលពួកជនមិនមែនជាអរិយៈ ធ្វើបានដោយក្រ ជាសត្វប្រកបដោយធម៌ សង្វាតក្នុងប្រយោជន៍របស់ម្ចាស់ បានប្រកាសនូវភាពនៃខ្លួនជាសត្វដ៏ឧត្តម ។ ហង្សជាសេនាបតីនេះ ជាសត្វគួរនឹងរស់នៅ តែស៊ូលះបង់នូវ

ជីវិតនៃខ្លួន កាលសរសើរ ( នូវគុណនៃម្ចាស់ ) ហើយ ទំនៅ បានសុំនូវជីវិតម្ចាស់ ។ ទូលព្រះបង្គំជាខ្ញុំ បានស្តាប់ពាក្យនោះ របស់ហង្សសេនាបតីនោះហើយ ទើបដល់នូវសេចក្តីជ្រះថ្លា លំដាប់នោះ ទូលព្រះបង្គំបានដោះរាជហង្សនោះ ចាកអន្ទាក់ ទាំងបានអនុញ្ញាតឲ្យទៅដោយស្រួល ។ ហង្សជាសេនាតីនោះ ក៏មានចិត្តរីករាយ ព្រោះម្ចាស់បានរួចហើយ ជាសត្វគោរពម្ចាស់ កាលនឹងពោលវាចាដ៏ស្រួលដល់ត្រចៀក បានពោលយ៉ាងនេះថា បពិត្រព្រានព្រៃ ថ្ងៃនេះខ្ញុំរីករាយ ព្រោះបានឃើញស្តេចបក្សី ដែលរួចហើយយ៉ាងណា សូមឲ្យលោករីករាយ ជាមួយនឹងពួកញាតិទាំងអស់យ៉ាងនោះ ។ លោកចូរមកនេះ ខ្ញុំនឹងប្រៀនប្រដៅឲ្យបាននូវលាភ រាជហង្សឈ្មោះធតរដ្ឋៈនេះ ឥតឃើញសេចក្តីអាក្រក់តិចតួចរបស់លោកទេ ។ លោកចូរនាំយើងទៅក្នុងបុរីជាធាប់ ហើយបង្ហាញព្រះរាជានូវយើងខ្ញុំទាំង ២ នាក់ ដែលមិនជាប់ចំណង មានសភាពជាប្រក្រតី ឋិតនៅលើអម្រែកទាំង ២ ខាង ។ ( លោកក្រាបទូលថា ) បពិត្រមហារាជ ហង្សទាំងនេះ កើតនៅក្នុងត្រកូលធតរដ្ឋៈ ជាអធិបតីលើពួកហង្ស ៦ ហង្សនេះជាព្រះរាជារបស់ហង្សទាំងឡាយ ហង្សមួយទៀតនេះជាសេនាបតី ។ ព្រះរាជាជាធំលើពួកជនបានទតឃើញ

រាជហង្សនេះហើយ មុខជានឹងមានព្រះទ័យត្រេកអរ សោម-នស្សរីករាយ នឹងព្រះរាជទាននូវទ្រព្យដ៏ច្រើន ដល់លោកដោយពិត ។ ទូលព្រះបង្គំជាខ្ញុំ បាននាំហង្សទាំង ២ នេះ មកតាមពាក្យហង្សជាសេនាបតីនេះយ៉ាងនេះ ព្រោះថា ទូលព្រះបង្គំជាខ្ញុំ បានបើកលែងហង្សទាំង ២ នេះ ក្នុងទីនោះរួចទៅហើយ ។ សត្វបក្សីនោះជាទ្វិជាតិ មានដំណើរយ៉ាងនេះ ប្រកបដោយធម៌ដ៏ក្រៃលែង ព្រោះថា សត្វបក្សីនោះ បានញុំាងចិត្តដ៏ទន់ឲ្យកើតដល់ព្រានព្រៃ ប្រាកដដូចជាទូលព្រះបង្គំជាខ្ញុំ ។ បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំជាខ្ញុំ មិនឃើញជង្វាយដទៃ ក្នុងស្រុកនៃព្រានបក្សីដ៏សមគួរដល់ព្រះអង្គឡើយ បពិត្រព្រះអង្គជាធំជាងពួកមនុស្ស សូមព្រះអង្គទតមើលនូវជង្វាយនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កម្មុនា ឧបបាទយិ** សេចក្តីថា សុមុខ-ហង្ស នោះបានពោលពាក្យណា នាយព្រានក៏ធ្វើតាមពាក្យនោះ ឲ្យសម្រេចដោយកាយកម្ម ។ បទថា **គន្ត្វា** អធិប្បាយថា នាយព្រានចាត់ចែងធ្វើកន្ទ្រាប៊ី សម្រាប់ស្តេចហង្សទំឲ្យខ្ពស់ ធ្វើកន្ទ្រាប៊ីសម្រាប់សេនាបតីហង្សទំឲ្យទាបបន្តិច ត្រកងយកហង្សទាំង ២ ដាក់ក្នុងកន្ទ្រាប៊ី ធ្វើមហាជនឲ្យក្រាក់ផ្អើលមកមើលដោយពាក្យថា ស្តេចហង្សនិងហង្សដែលជាសេនាបតី នឹងទៅគាល់ព្រះរាជា អ្នកទាំងឡាយចូរមកមើលចុះ កាលមនុស្សទាំងឡាយនាំគ្នាត្រេកអរ

*ថា ស្តេចហង្សដែលមានពណ៌ដូចមាស ដល់នូវភាពដ៏ប្រសើរដោយលម្អ បែបនេះ ពួកយើងមិនធ្លាប់ឃើញឡើយ ដូច្នេះ ក៏ប្រញាប់ចូលទៅខាងក្នុងនគរ ។ បទថា* **អនុស្សយិ** *សេចក្តីថា នាយព្រានឲ្យរាជបុរសចូលទៅក្រាបទូលដល់ព្រះរាជាថា ស្តេចហង្សមកគាល់ទ្រង់ កាលព្រះរាជាមានព្រះហឫទ័យត្រេកអរ ទើបត្រាស់ឲ្យហៅមកថា សូមចូលមកចុះ ទើបប្រញាប់នាំចូលទៅបន្ទាញ ។ បទថា* **ហត្ថត្តំ** *លោកអធិប្បាយទុកថា មកហើយ គឺបានដាក់ហើយក្នុងដៃ ។ បទថា* **មហាគ្គានំ** *សេចក្តីថា ព្រះរាជាត្រាស់សួរថា ខ្លួនអ្នកជានាយព្រាន ដល់នូវភាពជាធំនៃពួកហង្សធតរដ្ឋៈ មានពណ៌សម្បុរដូចមាស ដល់ហើយនូវភាពជាធំដោយយសបានដូចម្តេច ។ បាលីថា អ្នកដល់នូវភាពជាធំក្នុងទីនេះដូច្នេះក៏មាន អធិប្បាយថា អ្នកដល់នូវភាពជាធំដល់ហង្សទាំង ២ នេះបានដូចម្តេច ។ បទថា* **វិហិតា** *បានដល់ ប្រកបទុកហើយ ។ បទថា* **យំ យទាយតនំ មញ្ញេ** *សេចក្តីថា បពិត្រមហារាជ ខ្ញុំព្រះអង្គរមែងសម្គាល់ទីដែលជាទីប្រជុំណាមួយ ដែលជាទីបំបាត់ជីវិត នៃបក្សីទាំងឡាយ គឺជាទីធ្វើនូវការអស់ទៅនៃជីវិត ទូលព្រះបង្គំក៏ដាក់អន្ទាក់ទាំងឡាយទុកក្នុងភក់ទាំងឡាយក្នុងទីនោះៗ ។ បទថា* **តាទិសំ** *បានដល់ ស្តេចហង្សជាប់នូវអន្ទាក់ យ៉ាងនោះ ដែលខ្ញុំដាក់ក្នុងស្រះឈ្មោះមានុសិយៈ ។ បទថា* **ចាសំ** *បានដល់ អន្ទាក់ដែលចងទុកក្នុងស្រះនោះ ។ បទថា* **ឧចាសីនោ** *បានដល់ មិនបានគិតដល់ជីវិតរបស់ខ្លួន ចូលទៅឈរក្បែរៗ ។ បទថា* **មមាយំ** *សេចក្តីថា ហង្សដែលជាសេនាបតីនេះបានប្រាស្រ័យនឹងទូលព្រះបង្គំ គឺបានពោល*

ជាមួយខ្ញុំ ។ បទថា **សុទុក្ករំ** សេចក្តីថា ហង្សនេះ បានធ្វើកម្មដែលបុគ្គលមិនមែនអរិយៈ ដូចពួកយើងធ្វើបានដោយលំបាកក្នុងខណៈនោះ ។ បទថា **ឧបាគេ ភាវមុត្តមំ** សេចក្តីថា ហង្សនេះ រមែងប្រកាស គឺបើកនូវអធ្យាស្រ័យដ៏ខ្ពង់ខ្ពស់របស់ខ្លួន ។ បទថា **អត្តនោយំ** កាត់បទជា **អត្តនោ អយំ** ។ បទថា **អនុត្ថុនន្តោ** សេចក្តីថា ពណ៌នាដល់គុណរបស់ម្ចាស់ ហើយពោលអង្វរទូលព្រះបង្គំថា សូមលោកឲ្យជីវិតដល់ស្តេចហង្សនេះចុះ ។ បទថា **តស្ស** សេចក្តីថា កាលហង្សនោះ ពោលអង្វរយ៉ាងនេះ ទូលព្រះបង្គំក៏បានអនុញ្ញាតថា ចូរអ្នកត្រឡប់ទៅកាន់ភ្នំចិត្តកូដតាមសប្បាយ ចូរឃើញពួកញាតិចុះ ។ បទថា **ឯវេតេ ហិ** សេចក្តីថា ហង្សទាំង ២ នេះ ទូលបង្គំបានអនុញ្ញាតឲ្យត្រឡប់ទៅកាន់ភ្នំចិត្តកូដ ក្បែរមានុសិយស្រះនោះឯង ។ បទថា **ឯវំ គតោ** បានដល់ ធ្លាក់នៅក្នុងកណ្តាប់ដៃរបស់សត្រូវយ៉ាងនេះ ។ បទថា **ជនយេយ្យាថ មទ្ទវំ** សេចក្តីថា ធ្វើឲ្យកើតមេត្តាចិត្តក្នុងខ្លួន ។ បទថា **ឧបាយនំ** បានដល់ គ្រឿងបណ្ណាការ ។ បទថា **សព្វសាកុណិកគាមេ** សេចក្តីថា ទូលព្រះបង្គំមិនឃើញបណ្ណាការបែបនេះដទៃ ក្នុងស្រុកព្រានបក្សីទាំងអស់ ដែលនាយព្រានបក្សីណាមួយពាំនាំមកថ្វាយទ្រង់ ។ បទថា **តំ បស្ស** សេចក្តីថា បពិត្រព្រះអង្គជាកំពូលនៃមនុស្ស សូមទ្រង់ទតបណ្ណាការ ដែលទូលព្រះបង្គំនាំមកថ្វាយនោះចុះ ។

នាយព្រានឈរក្រាបទូលសរសើរគុណរបស់សុមុខហង្ស ដោយប្រការដូច្នេះ លំដាប់នោះ ព្រះរាជាក៏ត្រាស់ឲ្យរៀបចំអាសនៈ ដែលមានតម្លៃច្រើន

ប្រទានដល់ស្តេចហង្ស និងឲ្យរៀបចំតាំងដ៏ប្រសើរដែលធ្វើដោយមាស ប្រទានដល់សុមុខហង្ស កាលហង្សទាំង ២ ទំនៅក្នុងទីនោះ ទើបត្រាស់ឲ្យនាំយកភាជនៈមាសមកដាក់លាជលាយដោយទឹកឃ្មុំ ទឹកអំពៅប្រទានឲ្យសត្វទាំង ២ កាលចប់កិច្ចនៃការបរិភោគហើយ ទ្រង់ផ្គងអញ្ជលី អារាធនាឲ្យព្រះមហាសត្វសម្តែងធម្មកថា ហើយប្រថាប់គង់លើតាំងមាស ។ ព្រះមហាសត្វកាលព្រះរាជាត្រាស់អារាធនា ទើបបានធ្វើបដិសណ្ឋារៈហើយ ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

> រាជហង្ស បានឃើញព្រះរាជា ទ្រង់គង់នៅលើតាំងជាវិការៈនៃមាសដ៏ស្អាត កាលនឹងពោលនូវវាចាឲ្យស្រួលដល់ត្រចៀក បានពោលថា ព្រះអង្គបានសេចក្តីសុខស្រួលទេឬ ព្រះអង្គមិនមានជំងឺអ្វីទេឬ មួយទៀត ព្រះអង្គគ្រប់គ្រងដែនដ៏ធំទូលាយនេះ តាមធម៌ដែរឬ ដូច្នេះ ។

ព្រះរាជាត្រាស់តបថា

> ម្នាលហង្ស យើងមានសេចក្តីសុខស្រួលទេ ម្នាលហង្ស យើងមិនមានជំងឺអ្វីទេ ម្យ៉ាងទៀត យើងគ្រប់គ្រងដែនដ៏ធំទូលាយនេះតាមធម៌ហើយ ដូច្នេះ ។

រាជហង្សទូលសួរថា

> កំហុសបន្តិចបន្តួចរបស់ព្រះអង្គ មិនមានក្នុងពួកអាមាត្យទេឬ ពួកអាមាត្យទាំងនោះ មិនអាល័យជីវិត ព្រោះប្រយោជន៍

ទាំងឡាយរបស់ព្រះអង្គទេឬ ដូច្នេះ ។

ព្រះរាជាត្រាស់ឆ្លើយថា

កំហុសបន្តិចបន្តួចរបស់យើង មិនមានក្នុងពួកអាមាត្យទេ អាមាត្យទាំងនោះ មិនអាល័យជីវិត ព្រោះប្រយោជន៍ទាំងឡាយរបស់យើងទេ ដូច្នេះ ។

ព្រះមហាសត្វទូលសួរថា

អគ្គមហេសីរបស់ព្រះអង្គ ដែលមានជាតិស្មើគ្នា ជាស្រីស្តាប់បង្គាប់ ពោលពាក្យជាទីស្រឡាញ់ ប្រកបដោយបុត្ត រូបនឹងយស លុះអំណាចសេចក្តីប្រាថ្នារបស់ព្រះអង្គដែរឬ ដូច្នេះ ។

ព្រះរាជាត្រាស់តបថា

អគ្គមហេសីរបស់យើង ដែលមានជាតិស្មើគ្នា ជាស្រីស្តាប់បង្គាប់ ពោលនូវពាក្យជាទីស្រឡាញ់ ប្រកបដោយបុត្ត រូបនិងយស លុះអំណាចសេចក្តីប្រាថ្នារបស់យើង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **រាជាធំ** បានដល់ ព្រះបាទសាគលរាជ ។ បទថា **វដ្ឋផ្កោ** បានដល់ ស្តេចហង្សធតរដ្ឋ: ។ បទថា **ធម្មេន មនុសាសសិ** សេចក្តីថា ទ្រង់គ្រប់គ្រងទូន្មានដោយធម៌ ។ បទថា **ទោសោ** បានដល់ កំហុស ។ បទថា **តវត្ថេសុ** បានដល់ ក្នុងប្រយោជន៍ទាំងឡាយ មានការច្បាំងជាដើមរបស់ព្រះអង្គ ដែលកើតឡើងហើយ ។ បទថា **នាវកង្ខន្តិ** សេចក្តីថា អាមាត្យទាំងនោះឲ្យនូវជីវិត រមែងមិនប្រាថ្នាជីវិតរបស់ខ្លួនតិចតួច គឺលះបង់

ជីវិត ដើម្បីប្រយោជន៍ទ្រង់នោះឯង ។ បទថា **សាធិសី** បានដល់ ជាអ្នកមានជាតិស្មើគ្នា ។ បទថា **អស្សវា** បានដល់ ជាអ្នកទទួលយកនូវពាក្យ ។ បទថា **បុត្តរូបយសូបេតា** បានដល់ ជាអ្នកចូលដល់ហើយ ដោយព្រះរាជឱរសទាំងឡាយ ដោយព្រះរូបឆោមទាំងឡាយ និងដោយយសទាំងឡាយ ។ បទថា **តវ ឆន្ទវសានុគា** សេចក្តីថា ស្តេចហង្សក្រាបទូលថា ព្រះទេវីប្រព្រឹត្តទៅតាមព្រះរាជអធ្យាស្រ័យនៃទ្រង់ គឺនៅក្នុងអំណាចរបស់ទ្រង់ឬ អធិប្បាយថា រមែងប្រព្រឹត្តទៅដោយអំណាចនៃចិត្តរបស់ខ្លួនឬ ។

កាលព្រះពោធិសត្វធ្វើបដិសណ្ឋារៈ ដោយប្រការដូច្នេះហើយ ព្រះរាជាកាលនឹងត្រាស់នូវពាក្យជាមួយស្តេចហង្សនោះទៀត ទើបត្រាស់ថា

អ្នកដ៏ចម្រើន លុះក្នុងកណ្តាប់ដៃសត្រូវដ៏ធំ ដល់នូវសេចក្តីទុក្ខដ៏ធំ ក្នុងអន្តរាយទី ១ នោះដែរឬ ។ ព្រានព្រៃ បានស្ទុះចូលទៅសំពង អ្នកដោយដំបងដែរឬ ដ្បិតអំពើយ៉ាងនេះតែងមានជាធម្មតា ដល់ពួកអ្នកធ្វើអំពើអាក្រក់ ក្នុងខណៈនោះដូច្នេះ ។

រាជហង្សទូលតបថា

បពិត្រមហារាជ ទូលព្រះបង្គំជាខ្ញុំ បានសេចក្តីក្សេមក្សាន្តទេ កាលបើមានហេតុយ៉ាងនេះ ព្រានព្រៃនេះ មិនដល់ ( នូវភាពនៃខ្លួន ) ដូចជាសត្រូវចំពោះទូលព្រះបង្គំជាខ្ញុំតិចតួចឡើយ ។ ព្រានព្រៃនេះ ថយបន្តិចៗ ក៏បានសាកសួរ

ទូលព្រះបង្គំជាមុន គ្រានោះ ហង្សឈ្មោះសុមុខ ជាបណ្ឌិត បាននិយាយតបវិញ ។ ព្រានព្រៃបានស្តាប់ពាក្យហង្សឈ្មោះ សុមុខៈនោះហើយ ក៏បានដល់នូវសេចក្តីជ្រះថ្លា លំដាប់នោះ ព្រានព្រៃ បានដោះទូលព្រះបង្គំជាខ្ញុំអំពីអន្ទាក់ ទាំងបាន អនុញ្ញាតឲ្យទៅដោយស្រួលផង ។ ដំណើរមកក្នុងសំណាក់ នៃព្រះអង្គនេះ គឺហង្សឈ្មោះសុមុខៈ ចង់បានទ្រព្យដល់ព្រាន ព្រៃនុ៎ះ បានគិតហើយដើម្បីប្រយោជន៍ ដល់ព្រានព្រៃនុ៎ះ ដូច្នេះ ។

ព្រះរាជាត្រាស់ថា

ដំណើរមករបស់អ្នកដ៏ចម្រើនទាំងឡាយ ជាការស្រួលណាស់ ហើយ យើងមានចិត្តត្រេកអរ ព្រោះការបានឃើញអ្នក ឯ ព្រានព្រៃនេះ ចូរបានទ្រព្យជាច្រើនដរាបទល់អស់ចំណង់ ចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មហាសត្តុហត្ថត្តំ គតោ** បានដល់ ទៅ ហើយក្នុងកណ្តាប់ដៃរបស់សត្រូវដែលជាធំ ។ បទថា **អាបតិត្វាន** បានដល់ ប្រញាប់រត់តម្រង់ចូលទៅ ។ បទថា **ធាតិកំ** បានដល់ តាមធម្មតា ។ម្យ៉ាង ទៀត បាលីក៏យ៉ាងនេះដូចគ្នា ។ មានពាក្យអធិប្បាយថា បុគ្គលគ្រោតគ្រាត ទាំងនេះ រមែងមានប្រក្រតីយ៉ាងនេះដូចគ្នាទាំងអស់ គេវាយបក្សីទាំងឡាយ ដោយដំបង ធ្វើឲ្យស្លាប់ហើយ ក៏បាននូវតម្លៃ ។ បទថា **កិញ្ចិរស្មាសុ** បាន

ដល់ មិនបានកន្ទេលល្មើសអ្វីមួយក្នុងទូលព្រះបង្គំទាំង ២ឡើយ ។ បទថា **សត្តុវ** បានដល់ ដូចគ្មានីងសត្រូវ ។ បទថា **បច្ចុកម្បិត្ត** សេចក្តីថា បពិត្រមហារាជ ព្រាននេះ ឃើញទូលព្រះបង្គំហើយ រមែងចូលទៅបន្ទិច ដោយសម្គាល់ថាជាប់អន្ទាក់ ។ បទថា **បុព្វេវ** បានដល់ នាយព្រាននេះឯង បានប្រាស្រ័យ ជាមួយទូលព្រះបង្គំមុន ។ បទថា **តទា** បានដល់ ក្នុងកាលនោះ ។ បទថា **ឯតទត្ថាយ** បានដល់ គិតគ្នាហើយ ដើម្បីប្រយោជន៍ដល់នេសាទបុត្តនេះ ។ បទថា **ធនមិច្ឆតា** សេចក្តីថា សុមុខហង្សនោះ ប្រាថ្នានូវទ្រព្យដើម្បីព្រាននេះ ទើបគិតបបួលគ្នា មកកាន់សម្នាក់របស់ទ្រង់ ។ បទថា **ស្វាគតញ្ចេវិទំ** សេចក្តីថា អ្នកដ៏ចម្រើនទាំង ២ កុំគិតថ្វីឡើយ ការមកក្នុងទីនេះរបស់អ្នកដ៏ចម្រើនទាំង ២ នេះ ជាការមកល្អហើយ ។ បទថា **លភតំ** បានដល់ ចូរបាន ។

ព្រះរាជាកាលត្រាស់យ៉ាងនេះហើយ ក៏ទ្រង់សម្លឹងមើលអាមាត្យណាមួយ លុះអាមាត្យនោះទូលថា ទ្រង់មានព្រះបំណងដូចម្តេច ទើបត្រាស់ថា ចូរអ្នកនាំព្រាននេះទៅឲ្យជាងកាត់សក់ កោរពុកមាត់ ឲ្យងូតទឹក លាបដោយគ្រឿងក្រអូប ហើយប្រដាប់ដោយគ្រឿងអលង្ការទាំងពួងហើយនាំមក កាលអាមាត្យធ្វើតាមព្រះតម្រាស់នាំព្រានមកគាល់ហើយ ទើបទ្រង់លើកស្រុកសួយ ដែលមានតម្លៃមួយសែនកហាបណៈក្នុងមួយឆ្នាំ ប្រទានដល់បុរសនោះ ហើយបានប្រទានស្រី ២ នាក់ និងផ្ទះធំមួយខ្នង រថដ៏ប្រសើរ ប្រាក់និងមាសដទៃជាច្រើនទៀត ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

ព្រះរាជាជាធំជាងមនុស្ស បានញុំាងនាយនេសាទឲ្យផ្អែតស្កប់ស្កល់ដោយភោគៈ តាមដំណើរដែលសត្វបក្សីហង្សនិយាយនូវពាក្យដ៏សុខស្រួលដល់ត្រចៀកបានពោលហើយ ដូច្នេះ ។

លំដាប់នោះ ព្រះមហាសត្វក៏សម្តែងធម៌ដល់ព្រះរាជា ព្រះរាជាទ្រង់ស្តាប់ធម្មកថា របស់ព្រះមហាសត្វនោះហើយ ក៏ទ្រង់ត្រេកអរក្នុងព្រះហឫទ័យទ្រង់ព្រះតម្រិះថា យើងនឹងធ្វើសក្ការៈដល់ស្តេចហង្សដែលសម្តែងធម៌ ទើបទ្រង់ប្រទានស្វេតច្ឆត្រ ដល់ស្តេចហង្សនោះ កាលឲ្យស្តេចហង្សទទួលរាជសម្បត្តិ ទើបត្រាស់ថា

អំណាច ( របស់យើង ) ប្រព្រឹត្តទៅអស់ទីជាទីទ្រង់ទុកនូវធម៌ ( ច្បាប់ ) ណា អ្នកដ៏ចម្រើន ចូរជាធំក្នុងទីទាំងអស់នោះ សូម្បីតិចតួច ចូរគ្រប់គ្រងនូវទីជាទីប្រាថ្នាចុះ ។ ម្យ៉ាងទៀត ទ្រព្យណាដទៃអាចសម្រេចដើម្បីនឹងឲ្យទានឬជាគ្រឿងប្រើប្រាស់ យើងឲ្យនូវទ្រព្យនោះដល់អ្នក យើងនឹងលះនូវភារៈជាធំដល់អ្នក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វសោ វត្តតិ** សេចក្តីថា អំណាចរបស់យើងប្រព្រឹត្តទៅក្នុងទីត្រឹមណា ។ បទថា **កិញ្ចិ ធំ** បានដល់ ទីនោះមានប្រមាណតិចតួចពេក ។ បទថា **សព្វត្ថិស្សរិយំ** សេចក្តីថា សម្បត្តិទាំងអស់និងភាពជាធំនោះឯង ចូរមានដល់អ្នកចុះ ។ បទថា **យញ្ចញ្ញំ ឧបកប្បតិ** សេចក្តី

ថា ទ្រព្យជាគ្រឿងបំពេញទាន ព្រោះភាពជាអ្នកប្រាថ្នាក្នុងបុណ្យក្តី ការលើកនូវស្វេតច្ឆត្រឡើងសោយរាជសម្បត្តិក្តី ឬទ្រព្យដទៃណា រមែងជាទីគាប់ចិត្តដល់អ្នក ចូរអ្នកធ្វើនូវវត្ថុនោះចុះ ។ បទថា **ឯតំ ទទាមិ វោ វិត្តំ** សេចក្តីថា យើងលះនូវភាពជាធំដែលជារបស់យើងមួយអន្លើដោយស្វេតច្ឆត្រដល់អ្នក ។

លំដាប់នោះ ព្រះមហាសត្វ បានប្រគល់ស្វេតច្ឆត្រដែលព្រះរាជាប្រគល់ឲ្យដល់ខ្លួន ថ្វាយត្រឡប់ដល់ព្រះរាជាវិញ ព្រះរាជាទ្រង់ព្រះតម្រិះថា អញបានស្តាប់ធម្មកថា របស់ស្តេចហង្សមុនហើយ តែបុត្តរបស់នាយនេសាទសរសើរសុមុខហង្សនេះជាច្រើនថា មានពាក្យពីរោះក្រៃលែង អញនឹងស្តាប់ធម្មកថារបស់សុមុខហង្សនេះខ្លះ ព្រះរាជា កាលទ្រង់សន្ទនាជាមួយសុមុខហង្សនោះ ទើបត្រាស់គាថាដែលជាលំដាប់ថា

ប្រសិនបើហង្សឈ្មោះសុមុខៈ ជាបណ្ឌិតបរិបូណ៌ដោយប្រាជ្ញា
នេះ ពោលនូវពាក្យដល់យើងតាមសេចក្តីប្រាថ្នា ពាក្យនោះ
ជាទីស្រឡាញ់របស់យើងក្រៃពេក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យថា** បានដល់ បើ ។ មានពាក្យដែលលោកអធិប្បាយទុកថា បើសុមុខហង្សនោះជាបណ្ឌិត ដល់ព្រមហើយដោយវិជ្ជា គប្បីចរចាដល់យើងតាមប្រាថ្នា គឺតាមគាប់ចិត្តរបស់ខ្លួន សេចក្តីនោះគប្បីជាទីស្រឡាញ់ក្រៃលែងរបស់យើង ។ លំដាប់នោះ សុមុខហង្សក៏ក្រាបទូលថា

បពិត្រព្រះមហារាជ ទូលព្រះបង្គំជាខ្ញុំ ដូចជានាគរាជ ( ចូល

ទៅ ) កាន់ចន្លោះ ( នៃភ្នំ ) មិនអាចនឹងក្រាបទូលតបបានទេ ដ្បិតការក្រាបទូលតបនេះ មិនមែនជាច្បាប់សម្រាប់ទូលព្រះបង្គំជាខ្ញុំឡើយ ។ រាជហង្សប្រសើរបំផុត ជាងពួកទូលព្រះបង្គំជាខ្ញុំនោះផង ព្រះអង្គជាសត្វដ៏ឧត្តម រក្សាផែនដីជាធំជាងមនុស្សផង គួរទូលព្រះបង្គំជាខ្ញុំបូជាដោយហេតុដ៏ចម្រើន ។ បពិត្រព្រះអង្គជាធំជាងមនុស្ស កាលដែលការវិនិច្ឆ័យកំពុងប្រព្រឹត្តទៅ អាមាត្យជាអ្នកបម្រើ មិនគប្បីក្រាប ទូលក្នុងចន្លោះនៃព្រះអង្គទាំង ២ កំពុងមានព្រះបន្ទូល នោះឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **នាគរាជាវិវន្តរំ** បានដល់ ដូចស្តេចនាគដែលលូនចូលទៅក្នុងរវាងថ្ម ដូច្នោះ ។ បទថា **បដិវត្តុំ** សេចក្តីថា ទូលព្រះបង្គំ មិនអាចនិយាយឡើងក្នុងចន្លោះទ្រង់ទាំង ២ បានទេ ។ បទថា **ន មេ សោ** សេចក្តីថា បើខ្ញុំគប្បីពោលជ្រៀតឡើងសោត ការធ្វើដូច្នោះ មិនមែនជាវិន័យរបស់ទូលព្រះបង្គំឡើយ ។ បទថា **អម្ហាកញ្ចេវ** បានដល់ ស្តេចហង្សប្រសើរជាងទូលបង្គំនិងហង្ស ៩៦០០០ ទៀត ។ បទថា **ឧត្តមសត្តវោ** បានដល់ ជាសត្វដ៏ឧត្តម ។ បទថា **បូជា** សេចក្តីថា ទ្រង់ទាំង ២ គួរដល់ការបូជា និងគួរដល់ការសរសើរដោយហេតុជាច្រើនដល់ទូលបង្គំ ។ បទថា **បេស្សេន** បានដល់ ជាសេវកៈដែលធ្វើនូវការខ្វល់ខ្វាយ ។

ព្រះរាជាទ្រង់ស្តាប់ពាក្យសុមុខហង្សនោះ ទ្រង់ត្រេកអរ ហើយត្រាស់ថា

*ព្រានព្រៃពោលសរសើរអ្នកថា បុគ្គលដទៃដែលសម្ដែងធម៌ពីរោះដូចអ្នកមិនមាន ហើយបានត្រាស់បន្ដថា*

*បានឮថា នាយព្រាន បានសរសើរអ្នកដោយធម៌ថា អ្នកជាបក្សីបណ្ឌិត ប្រាជ្ញាបែបនេះ មិនគប្បីមានដល់សត្វដែលមានអត្តភាពមិនទាន់សម្រេច ។ អ្នកមានប្រក្រតីដ៏ប្រសើរយ៉ាងនេះ ជាសត្វខ្ពង់ខ្ពស់យ៉ាងនេះ សត្វទាំងឡាយទាំងប៉ុន្មានដែលយើងបានឃើញហើយ យើងមិនដែលឃើញនូវសត្វដទៃបែបនេះ ។ យើងត្រេកអរដោយបានឃើញអ្នកទាំង ២ ជាដំបូងផង ដោយពាក្យដ៏ពីរោះផង នោះជាសេចក្ដីពេញចិត្តរបស់យើង យើងគប្បីជួបនូវអ្នកទាំង ២ អស់កាលជាអង្វែង ដូច្នេះ ។*

*បណ្ដាបទទាំងនោះ បទថា* **ធម្មេន** *បានដល់ ដោយសភាវៈ ដោយហេតុការណ៍ ។ បទថា* **អកតត្តស្ស** *បានដល់ ដល់បុគ្គលដែលមានអត្តភាពមិនទាន់អប់រំ គឺនៅទ្រុស្តមិត្ត ។ បទថា* **ឯយោ** *សំដៅយកបញ្ញា ។ បទថា* **អគ្គបកតិមា** *បានដល់ មានសភាពដ៏លើស ។ បទថា* **ឧត្តមសត្តវោ** *បានដល់ សត្វដែលឧត្ដម ។ បទថា* **យាវតត្ថិ មយា** *បានដល់ ឈ្មោះថាដែលយើងឃើញហើយ មានប្រមាណត្រឹមណា ។ បទថា* **ឯាញ្ញំ** *សេចក្ដីថា យើងរមែងមិនឃើញអ្នកដទៃបែបនេះ ក្នុងទីដែលយើងឃើញហើយនោះ ។ បទថា* **តុដ្ឋាស្មិ វោ បកតិយា** *សេចក្ដីថា ម្នាលស្ដេចហង្សជាសម្លាញ់ខ្ញុំ*

ត្រេកអរព្រោះបានឃើញអ្នកទាំង ២ តាមប្រក្រតីនោះឯង ។ បទថា **វាកេ្យន** សេចក្ដីថា តែឥឡូវនេះ យើងត្រេកអរព្រោះពាក្យដ៏ពីរោះរបស់អ្នកទាំង ២ ។ បទថា **ចិរំ បស្សេយ្យំ វោ** សេចក្ដីថា ព្រះរាជាត្រាស់ថា ខ្ញុំឲ្យអ្នកនៅក្នុងទីនេះឯង មិនចង់ឲ្យអ្នកចេញទៅ សូម្បីត្រឹមមួយស្របក់ នឹងបានឃើញអ្នកយូរៗម្ដង ការឃើញនេះ ជាការពេញចិត្តរបស់យើង ដោយប្រការដូច្នេះ ។ លំដាប់នោះ ព្រះមហាសត្វ កាលសរសើរព្រះរាជា ទើបទូលថា

អំពើណាដែលត្រូវធ្វើចំពោះមិត្តដ៏ប្រសើរ អំពើនោះព្រះអង្គបានធ្វើហើយចំពោះទូលព្រះបង្គំទាំង ២ សេចក្ដីរាប់អានណារបស់ព្រះអង្គ ចំពោះទូលព្រះបង្គំទាំង ២ ទូលព្រះបង្គំទាំង ២ ឃ្លាត ហើយចាកព្រះអង្គ ដោយឥតសង្ស័យ ។ សេចក្ដីទុក្ខ ឯណោះ បានកើតឡើងហើយ ក្នុងបក្សីជាច្រើន ព្រោះមិនឃើញនូវទូលព្រះបង្គំជាខ្ញុំទាំង ២ ក្នុងចន្លោះ នៃពួកញាតិជាច្រើនដោយពិត ។ យើងទាំង ២ ដែលព្រះអង្គអនុញ្ញាតហើយ ដើម្បីកម្ចាត់បង់នូវសេចក្ដីសោករបស់បក្សីទាំងនោះ បពិត្រព្រះអង្គ ជាអ្នកទូន្មាននូវសត្រូវទូលព្រះបង្គំជាខ្ញុំទាំង ២ សូមធ្វើប្រទក្សិណព្រះអង្គ ហើយទៅជួបនឹងពួកញាតិ ។ ទូលព្រះបង្គំជាខ្ញុំ បានសេចក្ដីត្រេកអរដ៏ធំទូលាយ ព្រោះបានជួបព្រះអង្គដោយពិត ម្យ៉ាងទៀត ប្រយោជន៍ធំនេះ កើតមានព្រោះតែសេចក្ដីស្និទ្ធស្នាលចំពោះញាតិ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កតមស្មាសុ** បានដល់ ទ្រង់បានធ្វើកិច្ចគ្រប់យ៉ាងក្នុងទូលព្រះបង្គំ ។ បទថា **ចត្តា និស្សំសយំ ត្យម្ហា** បានដល់ ទូលព្រះបង្គំទាំង ២ ឈ្មោះថា ទ្រង់ដោះលែងហើយនោះឯង ដោយឥតសង្ស័យ ។ បទថា **ភត្តិរស្មាសុ យា តវ** សេចក្ដីថា ព្រះមហាសត្វសម្ដែងថា ការភក្ដីក្នុងទូលព្រះបង្គំទាំង ២ របស់ទ្រង់ឯណា ទូលព្រះបង្គំឈ្មោះថា ទ្រង់ដោះលែង ហើយដោយ ឥតសង្ស័យព្រោះភក្ដីនោះ ម្យ៉ាងទៀត ទូលព្រះបង្គំទាំង ២ មិនជាអ្នកព្រាត់ប្រាសចាកគ្នា ទូលព្រះបង្គំសូម្បីបែកគ្នា ក៏ឈ្មោះថា នៅរួមគ្នា ។ បទថា **អស្មាកំ** សេចក្ដីថា សេចក្ដីទុក្ខដែលកើតឡើងហើយក្នុងហង្សទាំងឡាយជាច្រើន ព្រោះមិនបានឃើញទូលព្រះបង្គំទាំង ២ ។ បទថា **បស្សេមុរិន្ទម** បានដល់ បពិត្រព្រះអង្គ ទ្រង់ជាអ្នកបង្ក្រាបសត្រូវឲ្យរាបទាប ទូលព្រះបង្គំទាំង ២ គប្បីបានឃើញ ។ បទថា **ភវន្តំ** បានដល់ ព្រោះទូលព្រះបង្គំបានមកគាល់ទ្រង់ដ៏ចម្រើន ។ បទថា **ឯសោ វាបិ មហាអត្ថោ** សេចក្ដីថា ការស្និទ្ធស្នាលជាមួយពួកញាតិ ពោលគឺការសង្គ្រោះញាតិនេះជាបំណាច់យ៉ាងធំរបស់ទូលព្រះបង្គំដោយពិត ។

កាលព្រះមហាសត្វទូលយ៉ាងនេះហើយ ព្រះរាជាក៏ទ្រង់បានអនុញ្ញាត ឲ្យហង្សទាំង ២ នោះត្រឡប់ទៅ សូម្បីព្រះមហាសត្វ ក៏ទូលសម្ដែងទោសក្នុងការប្រព្រឹត្តខុសក្នុងសីល ៥ និងសម្ដែងអានិសង្សក្នុងសីល ដល់ព្រះរាជាហើយថ្វាយឱវាទថា សូមទ្រង់រក្សាសីលនេះ សូមសោយរាជសម្បត្តិដោយធម៌ សូមសង្គ្រោះមហាជនដោយសង្គហវត្ថុ ៤ ប្រការ ហើយទូលលាទៅ

កាន់ភ្នំចិត្តកូដ ។ ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

លុះរាជហង្សឈ្មោះ ធតរដ្ឋៈ ( និងហង្សឈ្មោះសុមុខៈ )
បានពោលពាក្យនេះ ចំពោះព្រះរាជាជាធំលើជនរួចហើយ
ក៏ហើរសំដៅទៅរកពួកញាតិ អាស្រ័យនូវសមុទ្រដ៏ឧត្តម ។
សត្វហង្សទាំងឡាយ បានឃើញនូវហង្សដ៏ឧត្តមទាំង ២ នោះ
មិនមានរោគ មកដល់ហើយ ក៏បានធ្វើនូវសំឡេងថា កេកាៗ
សូរសំឡេងយ៉ាងខ្លាំង ក៏កើតមានឡើង ។ បក្សីទាំងនោះ
មានសេចក្តីត្រេកអរ ព្រោះម្ចាស់រួចហើយ ជាសត្វគោរព
ចំពោះម្ចាស់ ជាសត្វបានទនូវទីពឹង ហើយហើរក្រឡឹងជុំវិញ
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧចាគមុំ** សេចក្តីថា ស្តេចហង្សធតរដ្ឋនិងសុមុខហង្សជាសេនាបតីទាំង ២ នោះ កាលអរុណរះហើយ ក៏បរិភោគលាជលាយដោយទឹកឃ្មុំទឹកអំពៅជាដើម ដែលព្រះរាជានិងព្រះទេវីទ្រង់លើកឡើងដោយស្លឹកត្នោតមាស ២ សន្លឹកហើយ ធ្វើសក្ការៈដោយគ្រឿងក្រអូប និងកម្រងផ្កាជាដើម ហើយចុះចាកស្លឹកត្នោតមាសនោះ ធ្វើប្រទក្សិណព្រះរាជាហើរឡើងទៅកាន់អាកាស កាលព្រះរាជាទ្រង់ផ្គងអញ្ជលីត្រាស់ថា សម្លាញ់ទាំង ២ ចូរអ្នកនាំគ្នាទៅល្អចុះ ទើបចេញតាមសីហបញ្ជរ ហើរទៅកាន់ហ្វូងនៃញាតិរបស់ខ្លួន ដោយសមុទ្រដ៏ឧត្តម ។ បទថា **បរមេ** បានដល់ ឧត្តម ។ បទថា **កេកា** សេចក្តីថា បានបន្លឺសំឡេងស្រែកថា កេកា ដោយសំឡេង

យំ តាមសភាវៈរបស់ខ្លួន ។ បទថា **ភត្តុនោ ភត្តុគារវា** បានដល់ មានសេចក្ដីគោរពម្ចាស់ ។ បទថា **បរិកិរឹសុ** សេចក្ដីថា ហង្សទាំងឡាយនាំគ្នាត្រេកអរ ព្រោះម្ចាស់ផុតភ័យត្រឡប់មក នាំគ្នាចោមរោមដោយជុំវិញ ។ បទថា **លទ្ធបច្ចយា** បានដល់ ជាអ្នកបានទូវទីពឹងពំនាក់ហើយ ។

កាលហង្សទាំងនោះ ចូលចោមរោមហង្សទាំង ២ យ៉ាងនោះហើយ ទើបទូលសួរស្ដេចហង្សថា បពិត្រមហារាជ ទ្រង់រួចផុតមកបានដូចម្ដេច ព្រះមហាសត្វក៏និទានរឿងដែលខ្លួនរួចផុតមកបាន ព្រោះអាស្រ័យសុមុខហង្សនិងកិច្ចការដែលព្រះបាទសាគលរាជ និងនេសាទបុត្តធ្វើ ។ ពួកហង្សទាំងឡាយបានឮដូច្នោះ ក៏នាំគ្នាត្រេកអរ សរសើរ ឲ្យពរថា សូមឲ្យសុមុខហង្សជាសេនាបតី នេសាទបុត្ត ព្រមទាំងព្រះរាជាមានសេចក្ដីសុខ ប្រាសចាកទោស សូមមានអាយុអស់កាលយូរ ។

ព្រះសាស្ដា កាលទ្រង់ប្រកាសសេចក្ដីនោះ ទើបត្រាស់ថា

> ប្រយោជន៍ទាំងអស់របស់ពួកជនអ្នកមានមិត្ត រមែងសម្រេច
> សេចក្ដីសុខយ៉ាងនេះ ដូចជាហង្សឈ្មោះធតរដ្ឋៈ និងហង្ស
> ឈ្មោះសុមុខៈ បានហើរចូលទៅរកពួកញាតិដូច្នោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មិត្តវតំ** បានដល់ ដល់ព្រមហើយដោយកល្យាណមិត្ត ។ បទថា **បទក្ខិណា** បានដល់ សម្រេចសេចក្ដីសុខ ប្រកបដោយការចម្រើន ។ បទថា **ធតរដ្ឋា** សេចក្ដីថា ដូចហង្សធតរដ្ឋៈ គឺស្ដេចហង្សនិងសុមុខហង្សទាំង ២ នោះ ដល់ព្រមដោយកល្យាណមិត្តទាំង ២

គឺព្រះរាជានិងបុត្តនាយព្រាន ។ បទថា **ញាតិសង្ឃមុបាគមុំ** សេចក្តីថា ប្រយោជន៍ ពោលគឺ ការចូលដល់ពួកញាតិនៃពួកហង្សធតរដ្ឋៈនោះ ជាសេចក្តីសុខហើយ យ៉ាងណា ប្រយោជន៍ទាំងអស់របស់ជនដទៃ ដែលដល់ព្រមដោយកល្យាណមិត្ត រមែងសម្រេចផលជាសុខដូចគ្នានោះឯង ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន អានន្ទក៏បានលះជីវិត ដើម្បីប្រយោជន៍ដល់តថាគតហើយដូចគ្នា ហើយទ្រង់សមោធានជាតកថា នាយព្រានក្នុងកាលនោះ បានមកជាឆន្នភិក្ខុក្នុងកាលឥឡូវនេះ ព្រះរាជាសាគល ក្នុងកាលនោះ បានមកជាសារីបុត្ត សុមុខហង្សសេនាបតី ក្នុងកាលនោះ បានមកជាអានន្ទ ពួកហង្ស ៩៦០០០ ក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ក្នុងកាលឥឡូវនេះ ស្តេចហង្សធតរដ្ឋៈក្នុងកាលនោះ គឺតថាគតដ៏ជាលោកនាថ អ្នកទាំងឡាយចូរចាំទុកនូវជាតកនេះទុក ដោយប្រការដូច្នេះឯង ។

## អដ្ឋកថា ចុល្លហំសជាតក ចប់

# មហាហំសជាតក

[ ១៩៩ ] ( រាជហង្សពោលថា ) ហង្សទាំងឡាយនេះ ត្រូវភ័យគំរាមហើយ នាំគ្នាហើរទៅ ម្នាលសុមុខៈ អ្នកមានស្បែកដូចមាស មានសម្បុរដូចមាស អ្នកចូរហើរទៅតាមប្រាថ្នាចុះ ។ ពួកបក្សីជាញាតិ បានលះបោលនូវយើង ដែលលុះអំណាចនៃអន្ទាក់តែម្នាក់ឯង មិនអាល័យហើរទៅ អ្នកក្រាញនៅតែម្នាក់ឯងដូចម្ដេច ។ ម្នាលអ្នកដ៏ប្រសើរជាងពួកបក្សី អ្នកចូរហើរទៅចុះ ព្រោះថា ភាពជាសម្លាញ់នឹងយើងដែលជាប់ចំណង មិនមានទេ អ្នកកុំធ្វើខ្លួនឲ្យសាបសូន្យចាកសេចក្ដីសុខឡើយ ម្នាលសុមុខៈ អ្នកចូរហើរទៅតាមប្រាថ្នាចុះ ។

[ ២០០ ] ( ហង្សសេនាបតីឈ្មោះសុមុខៈពោលថា ) បពិត្រព្រះបាទធតរដ្ឋៈ ទូលព្រះបង្គំជាខ្ញុំ សូម្បីសេចក្ដីទុក្ខគ្របសង្កត់ហើយ ក៏មិនគប្បីលះបោលព្រះអង្គ ជីវិតឬសេចក្ដីស្លាប់របស់ទូលព្រះបង្គំជាខ្ញុំនឹងមានជាមួយព្រះអង្គ ។ បពិត្រព្រះបាទធតរដ្ឋៈ ទូលព្រះបង្គំជាខ្ញុំ សូម្បីសេចក្ដីទុក្ខគ្របសង្កត់ហើយ ក៏មិនគប្បីលះបោលព្រះអង្គ ទាំងព្រះអង្គក៏មិនគួរប្រកបទូលព្រះបង្គំជាខ្ញុំ ក្នុងអំពើមិនប្រសើរទេ ។ ទូលព្រះបង្គំជាខ្ញុំ ជាកុមារមានវ័យស្មើគ្នា ជាសម្លាញ់នឹងព្រះអង្គ ឋិតនៅក្នុងអំណាចចិត្តរបស់ព្រះអង្គ ដែលជាចិត្តប្រព្រឹត្តទៅដោយប្រពៃ បពិត្រព្រះអង្គដ៏ប្រសើរខ្ពង់ខ្ពស់ជាងពួកនៃហង្ស ទូលព្រះបង្គំជាខ្ញុំ ប្រាកដជាសេនាបតីរបស់ព្រះអង្គ លុះទូលព្រះបង្គំជាខ្ញុំហើរទៅអំពីទីនេះ នឹងថ្លែងសេចក្ដីក្នុងកណ្ដាលញាតិ ដោយប្រការដូចម្ដេច បពិត្រព្រះអង្គដ៏ប្រសើរជាងពួកបក្សី ទូលព្រះបង្គំ លះបោលព្រះអង្គហើយ

ទៅអំពីទីនេះ នឹងប្រាប់ ( ដំណឹង ) របស់ព្រះអង្គដូចម្ដេច ទូលព្រះបង្គំនឹងលះបង់ជីវិតក្នុងទីនេះ មិនអាចនឹងធ្វើអំពើមិនប្រសើរទេ ។

[ ២០១ ] ( រាជហង្ស... ) ម្នាលសុមុខៈ នុ៎ះជាធម៌ ( របស់បោរាណកបណ្ឌិតទាំងឡាយ ) ព្រោះថា អ្នកឋិតនៅក្នុងគន្លងរបស់ជនដ៏ប្រសើរ មិនអាចលះបង់នូវយើង ដែលជាម្ចាស់ផង ជាសម្លាញ់ផង ។ ដ្បិតថា កាលយើងសម្លឹងមើលអ្នក សេចក្ដីភ័យក៏មិនកើតសោះទេ អ្នកបានញុំាងយើងដែលមានសភាពយ៉ាងនេះ ឲ្យបាននូវជីវិត ។

[ ២០២ ] ( អភិសម្ពុទ្ធគាថា ) កាលដែលហង្សដ៏ប្រសើរ ( ពីរ ) មានការប្រព្រឹត្តដ៏ប្រសើរ កំពុងប្រឹក្សាគ្នាយ៉ាងនេះ ដូច្នេះ នាយនេសាទកាន់ដំបងប្រញាប់មកដល់ភ្លាម ។ ហង្សឈ្មោះសុមុខៈ លុះបានឃើញនាយនេសាទនោះមកដល់ ក៏ឋិតនៅខាងមុខរាជហង្ស ហើយលួងលោមរាជហង្សដែលកំពុងភ័យ រួចបានស្រែកថា បពិត្រព្រះអង្គដ៏ប្រសើរជាងសត្វស្លាប ព្រះអង្គកុំភ័យឡើយ ព្រោះថា បក្សីទាំងឡាយប្រហែលព្រះអង្គ រមែងមិនភ័យទេ ទូលព្រះបង្គំជាខ្ញុំ នឹងប្រកបសេចក្ដីព្យាយាមដ៏សមគួរ ដែលអាស្រ័យនូវធម៌ ព្រះអង្គនឹងរួចចាកអន្ទាក់ជាឆាប់ ដោយសេចក្ដីព្យាយាមនោះមិនខាន ។

[ ២០៣ ] នាយនេសាទ បានឮសុភាសិតរបស់ហង្ស ឈ្មោះសុមុខៈនោះហើយ ក៏ព្រឺរោម បង្អោននូវអញ្ជលី ចំពោះហង្សឈ្មោះសុមុខនោះថា អ្នកជាបក្សីពោលនូវភាសារបស់មនុស្ស ពោលពាក្យដ៏ប្រសើរ បញ្ចេញនូវវាចាជារបស់មនុស្ស ដែលអញមិនធ្លាប់ឮ មិនធ្លាប់ឃើញ ។ បក្សីនេះត្រូវ

ជាអ្វីទីងអ្នក អ្នកជាសត្វរួចហើយ ចូលមករកសត្វជាប់ ពួកបក្សីហើរចោល អស់ទៅហើយ ម្ដេចក៏អ្នកក្រាញនៅតែម្នាក់ឯង ។

[ ២០៤ ] ( ហង្សសេនាបតី ... ) ឱព្រានព្រៃជាសត្រូវនឹងបក្សី ឯរាជហង្សនោះ ជាព្រះរាជារបស់ខ្ញុំ ខ្ញុំជាសេនាបតីរបស់រាជហង្សនោះ ខ្ញុំមិនអាចលះចោលស្ដេចបក្សីនោះ ក្នុងកាលមានសេចក្ដីអន្តរាយទេ ។ ព្រះរាជារបស់ខ្ញុំនេះ ជាម្ចាស់នៃពួកហង្សដ៏ច្រើន កុំដល់នូវសេចក្ដីវិនាសតែម្នាក់ឯងឡើយ បពិត្រនាយនេសាទជាសម្លាញ់ ព្រោះថា រាជហង្សនេះជាម្ចាស់ ខ្ញុំតែងត្រេកអរក្រែកវាយ ( ក្នុងសំណាក់រាជហង្សនោះ ) ។

[ ២០៥ ] ( ព្រានព្រៃ... ) ម្នាលសត្វហង្ស អ្នកណាបានគោរព ដុំអាហារ ( ដែលបានអំពីម្ចាស់ ) អ្នកនោះឈ្មោះថា ប្រព្រឹត្តធម៌ដ៏ប្រសើរ យើងនឹងលែងនូវម្ចាស់របស់អ្នកនោះ អ្នកទាំង ២ ចូរទៅតាមស្រួលចុះ ។

[ ២០៦ ] ( ហង្សសេនាបតី... ) នែសម្លាញ់ បើលោកដាក់អន្ទាក់ពួកហង្សនិងបក្សីដ៏សេស ដោយសេចក្ដីព្យាយាមរបស់ខ្លួន យើងខ្ញុំនឹងទទួលនូវអភយទាននេះរបស់លោក បើលោកមិនដាក់អន្ទាក់ពួកហង្សនិងបក្សីដ៏សេស ដោយសេចក្ដីព្យាយាមរបស់ខ្លួនទេ បពិត្រនាយនេសាទ លោកមិនមែនជាធំ កាលលែងនូវយើងខ្ញុំ ឈ្មោះថាធ្វើនូវការលួច ។

[ ២០៧ ] លោកជាបុគ្គលស៊ីឈ្នួល របស់ព្រះរាជាណា លោកចូរនាំយើងខ្ញុំឲ្យដល់ទៅព្រះរាជានោះ តាមប្រាថ្នាចុះ ព្រះរាជាព្រះនាមសំយមៈនឹងធ្វើតាមគាប់ព្រះទ័យ ក្នុងព្រះរាជនិវេសន៍នោះ ។

[ ២០៨ ] ( អភិសម្ពុទ្ធគាថា ) លុះហង្សឈ្មោះសុមុខៈ និយាយយ៉ាងនេះហើយ នាយនេសាទ ក៏យកដៃស្ទួយនូវហង្សទាំង ២ ដែលមានសម្បុរនិងស្បែកដូចមាស ហើយដាក់ទៅក្នុងទ្រុង ។ ព្រានព្រៃបាននាំយកបក្សី ឈ្មោះសុមុខៈ ១ ឈ្មោះធតរដ្ឋៈ ១ ទាំង ២ មានសម្បុរដ៏ភ្លឺផ្លេកទាំនៅក្នុងទ្រុងនោះហើយចៀសចេញទៅ ។

[ ២០៩ ] រាជហង្សឈ្មោះធតរដ្ឋៈ ដែលព្រានព្រៃកំពុងនាំទៅ បានពោលពាក្យនេះនឹងហង្សឈ្មោះសុមុខៈថា ម្នាលសុមុខៈ ខ្ញុំខ្លាច ( សេចក្តីស្លាប់ ) នៃនាងបក្សីឈ្មោះសុហេមា ដែលមានសម្បុរដូចមាស មានភ្លៅប្រកបដោយលក្ខណៈខ្លាំងណាស់ តែនាងសុហេមាបានដឹងថា គេសម្លាប់នូវយើងទាំង ២ ហើយ មុខជានឹងសម្លាប់នូវខ្លួនដែរ ។ ម្នាលសុមុខៈ នាងបក្សី ឈ្មោះសុហេមាជាធីតានៃបាកហង្ស ដែលមានស្បែកល្អដូចមាស ជាសត្វកំព្រាទួញយំដោយពិត ដូចជាក្រៀលញី ទួញយំប្រែបឆ្នេរសមុទ្ទ ដូច្នោះ ។

[ ២១០ ] ( ហង្សសេនាបតី... ) ព្រះអង្គជាធំជាងហង្ស មានគុណប្រមាណមិនបាន ជាម្ចាស់នៃហ្វូងហង្សជាច្រើនយ៉ាងនេះ ហើយសោកស្តាយនូវមេហង្ស ១ ការយំនេះ ហាក់ដូចជាមិនសមគួរដល់ព្រះអង្គ ដែលមានប្រាជ្ញាឡើយ ។ ព្រះអង្គសោកស្តាយ ព្រោះតែស្ត្រីទាំងឡាយ ធម្មតាស្ត្រីទាំងឡាយដូចជាខ្យល់គួចយកនូវក្លិនទាំងល្អទាំងអាក្រក់ទាំង ២ ឬដូចជាក្មេងល្ងង់ចាប់យកផ្លៃឈើទាំងខ្ចីទាំងទុំ ពុំនោះសោត ដូចមនុស្សខ្វាក់ ជាអ្នកស្រេកឃ្លានកាន់យកអាមិសៈ ( ទាំងល្អទាំងអាក្រក់ ) ។ ព្រះអង្គមិនដឹងនូវការវិនិច្ឆ័យ

ក្នុងប្រយោជន៍ទាំងឡាយ ដូចជាមនុស្សល្ងង់ប្រាកដដល់ទូលព្រះបង្គំ លុះដល់កាលជាទីស្លាប់ នៅតែមិនដឹងអំពើដែលគួរធ្វើនិងមិនគួរធ្វើឡើយ ។ ព្រះអង្គជាបុគ្គលច្ចូតពាក់កណ្តាល និយាយផ្តេសផ្តាស ព្រោះថា ព្រះអង្គសម្គាល់នូវស្ត្រីទាំងឡាយថា ប្រសើរបំផុត ព្រោះថា ស្ត្រីទាំងនេះ ជាសាធារណៈដល់ជនច្រើន ដូចជាពេងសុរាជាសាធារណៈដល់ពួកអ្នកលេង ។ មួយទៀត ស្ត្រីទាំងនេះ មានមាយាដូចជាថ្ងៃបណ្តើរកូន ជាទីសោយសោក ជាទីកើតនៃរោគ ជាទីឧបទ្រព ស្ត្រីទាំងនេះមានអធ្យាស្រ័យដ៏រឹងរូស ជាចំណងសម្រាប់ចង ជាអន្ទាក់នៃសេចក្តីស្លាប់ ជាគុហាសម្រាប់នៅ ( របស់មច្ចុរាជ ) បុរសណាទុកចិត្តក្នុងស្ត្រីទាំងនោះ បណ្តាបុរសទាំងឡាយ បុរសនោះឈ្មោះថា បុរសថោកទាប ។

[ ២១១ ] ( រាជហង្ស... ) ( វត្ថុគឺស្ត្រី ) ណា ដែលពួកជនអ្នកចម្រើនដោយប្រាជ្ញាបញ្ញត្តហើយ បុគ្គលណា គួរតិះដៀលនូវស្ត្រីនោះបានធម្មតាស្ត្រីទាំងឡាយ មានគុណច្រើន ហើយកើតឡើងក្នុងលោក ( មុនគេ ) ។ ល្បែងគេតាំងទុកក្នុងស្ត្រីទាំងនោះ សេចក្តីត្រេកអរ ក៏តាំងនៅក្នុងស្ត្រីទាំងនោះដែរ ពូជទាំងឡាយ រមែងលូតលាស់ឡើងក្នុងស្ត្រីទាំងនោះ គឺពួកសត្វទាំងអស់ តែងកើត ( ត្រូវអាស្រ័យស្ត្រីទាំងនោះ ) បុរស ដូចម្តេច ប្តូរជីវិតដោយជីវិតហើយ គប្បីនឿយណាយក្នុងស្ត្រីទាំងនោះ ។ ម្នាលសុមុខៈ អ្នកឯងហ្នឹងហើយ មិនមែនជាអ្នកដទៃ រមែងប្រកបក្នុងប្រយោជន៍ ចំពោះពួកស្ត្រី ភ័យកើតឡើងដល់អ្នកក្នុងថ្ងៃនេះ គំនិតរបស់អ្នកក៏កើតឡើង ដោយ

សេចក្ដីភ័យ ។ ជនទាំងអស់ ដល់នូវសេចក្ដីសង្ស័យក្នុងជីវិត ហើយជាអ្នក វន្ធត់ ប្រឹងអត់ទ្រាំនូវសេចក្ដីខ្លាច ចំណែកពួកបណ្ឌិត ជាអ្នកឋិតនៅក្នុងទី ដ៏ប្រសើរ តែងប្រកបក្នុងប្រយោជន៍ ដែលគេប្រកបបានដោយក្រ ។ ព្រះរាជា ទាំងឡាយ តែងប្រាថ្នានូវមន្ត្រីដែលមានសេចក្ដីក្លៀវក្លា ដើម្បីប្រយោជន៍ការ ពារនូវអន្តរាយនេះ ព្រោះមន្ត្រីដែលក្លៀវក្លា រមែងឃាត់នូវសេចក្ដីអន្តរាយ នឹងការពារនូវខ្លួនបាន ។ ពួកពិសេសរបស់ព្រះរាជា កុំវះនូវយើង ក្នុងវេង គ្រួក្នុងថ្ងៃនេះ យ៉ាងណា ( អ្នកចូរធ្វើ ) យ៉ាងនោះចុះ ដ្បិតសម្បុរស្លាប សម្រាប់អ្នក ( និង ) យើង ដូចផ្លែឫស្សីសម្រាប់នូវដើមឫស្សី ។ អ្នករួច ( ជាមួយនឹងយើង ) ហើយ មិនចង់ហើរទៅ ចូលមករកចំណងដោយខ្លួន ឯងវិញ ថ្ងៃនេះ អ្នកនោះដល់នូវសេចក្ដីសង្ស័យ ( ក្នុងជីវិត ) អ្នកចូរកាន់ យកនូវប្រយោជន៍ចុះ កុំបានតែមាត់ឡើយ ។

[ ២១២ ] អ្នកនោះ ចូរប្រកបព្យាយាមដ៏សមគួរ ប្រកបដោយធម៌ ប្រព្រឹត្តនូវការស្វែងរកនូវជីវិត ឲ្យដល់យើងដោយព្យាយាមរបស់អ្នកចុះ ។

[ ២១៣ ] ( ហង្សសេនាបតី... ) បពិត្រព្រះអង្គដ៏ប្រសើរជាងសត្វ ស្លាប ព្រះអង្គកុំខ្លាចឡើយ ដ្បិតសត្វទាំងឡាយប្រហែលព្រះអង្គ រមែងមិន ខ្លាច ទូលព្រះបង្គំជាខ្ញុំ នឹងប្រកបនូវព្យាយាមដ៏សមគួរប្រកបដោយធម៌ ព្រះអង្គ នឹងរួចចាកអន្ទាក់យ៉ាងឆាប់ ដោយព្យាយាមរបស់ទូលព្រះបង្គំជាខ្ញុំ ។

[ ២១៤ ] ( អភិសម្ពុទ្ធគាថា ) ព្រានព្រៃនោះ បានចូលទៅកាន់ទ្វារ ព្រះរាជវាំងទាំងអម្រែក ហង្ស ( ពោលថា ) អ្នកទាំងឡាយ ចូរក្រាបទូល

ព្រះរាជាថា ខ្ញុំជារាជហង្សឈ្មោះ ធតរដ្ឋ: នេះមកហើយ ។

[ ២១៥ ] ព្រះរាជាព្រះនាមសំយមៈ ទតឃើញហង្សទាំង ២ នោះ ប្រាកដស្មើដោយបុណ្យ ដែលសន្មតថា មានលក្ខណៈល្អ ទ្រង់ត្រាស់ទៅនឹងពួកអាមាត្យថា អ្នកទាំងឡាយ ចូរឲ្យសំពត់ បាយ ទឹក និងភោជន ដល់នាយព្រាន ចូរបំពេញសេចក្ដីប្រាថ្នាដោយប្រាក់ដែលព្រាននេះប្រាថ្នាចុះ ។

[ ២១៦ ] ព្រះរាជាក្នុងដែនកាសី ទ្រង់បានទតឃើញព្រានព្រៃមានចិត្តរីករាយទ្រង់ត្រាស់យ៉ាងនេះថា ម្នាលខេមកៈជាសម្លាញ់ បើស្រះបោក្ខរណីពេញពាសដោយពួកហង្ស ។ អ្នកមានដៃកាន់អន្ទាក់ ចូលទៅរកហង្សដែលឋិតនៅក្នុងកណ្ដាលនៃពួកហង្សដ៏រុងរឿង ដោយប្រការដូចម្ដេច អ្នកចាប់ហង្សដ៏ឧត្ដមដែលនៅលាយឡំដោយពួកហង្សជាញាតិ ដោយប្រការដូចម្ដេច ។

[ ២១៧ ] ( ព្រានព្រៃ... ) កាលទូលព្រះបង្គំជាខ្ញុំ ចូលទៅកាន់ទីជាទីកាន់យកនូវចំណី ( របស់ហង្ស ) ថ្ងៃនេះ ជារាត្រីគម្រប់ ៧ ទូលព្រះបង្គំជាខ្ញុំ ស្វែងរកនូវស្នាមជើងនៃហង្សនោះ ឥតមានធ្វេសប្រហែស អាស្រ័យនៅតែក្នុងពាង ។ លុះទូលព្រះបង្គំជាខ្ញុំ បានឃើញស្នាមជើងនៃរាជហង្សនោះ ត្រាច់ស្វែងរកទីជាទីកាន់យកចំណីហើយ ទើបទូលព្រះបង្គំជាខ្ញុំ បានដាក់អន្ទាក់ក្នុងទីនោះ រួចចាប់យករាជហង្សនោះ ដោយឧបាយយ៉ាងនេះ ។

[ ២១៨ ] ( ព្រះរាជា... ) ម្នាលនាយព្រាន បក្សីនេះ ចុះហេតុអ្វីក៏បានជាអ្នកពោលថា បក្សី ១ ចិត្តរបស់អ្នកប្រែប្រួលឬ ឬមួយអ្នកប្រាថ្នាដូចម្ដេចវិញ ។

[ ២១៩ ] ( ព្រានព្រៃ... ) ធ្នូតក្រហមល្អ ភ្លឺរុងរឿងបិតនៅផ្ទាល់នឹងទ្រូងនៃហង្សណា ហង្សនោះ បានចូលមកជាប់អន្ទាក់របស់ទូលព្រះបង្គំជាខ្ញុំ ចំណែកបក្សីដែលភ្លឺផ្ទេកនេះ មិនបានជាប់អន្ទាក់ទេ ចម្រើននូវអរិយធម៌ បានឈរនិយាយវាចាជារបស់មនុស្សនឹងបក្សីដែលជាប់ចំណង កំពុងតែក្តៅក្រហាយ ( ដោយទុក្ខ ) ។

[ ២២០ ] ( ព្រះរាជា... ) ម្នាលសុមុខ: ឥឡូវនេះ អ្នកឈរទល់ចង្កា ( បិទមាត់ ) តើព្រោះហេតុអ្វី ឬក៏អ្នកមកកណ្តាលបរិស័ទរបស់យើង ហើយមានសេចក្តីភ័យខ្លាចទើប មិនពោល ។

[ ២២១ ] ( ហង្សសេនាបតី ...) បពិត្រព្រះអង្គជាធំក្នុងដែនកាសី ទូលព្រះបង្គំជាខ្ញុំ មិនមែនខ្លាច ព្រោះតែចូលមកកាន់បរិស័ទរបស់ព្រះអង្គទេ ទូលព្រះបង្គំជាខ្ញុំ មិនមែនជានឹងមិននិយាយព្រោះខ្លាចទេ កាលបើមានហេតុប្រាកដដូច្នោះហើយ ទូលព្រះបង្គំជាខ្ញុំមុខជានឹង ( បញ្ចេញ ) នូវវាចា ។

[ ២២២ ] ( ព្រះរាជា ... ) យើងមិនឃើញទាហាន មិនឃើញពលរថ មិនឃើញពលថ្មើរជើង មិនឃើញខែល មិនឃើញជនអ្នកកាន់អម្បែង មិនឃើញជនអ្នកពាក់អាវក្រោះ មិនឃើញអ្នកកាន់ធ្នូរបស់អ្នកឡើយ ។ ម្នាលសុមុខ: យើងមិនឃើញប្រាក់ ឬមាស ឬនគរ ដែលគេសាងល្អហើយ ជានគរមានគូដ៏ជេរជាស មិនងាយទៅមកបាន ជានគរមានប៉មនិងខ្លោងទ្វារដ៏មាំទេ ជាកន្លែងដែលអ្នកចូលទៅហើយ មិនខ្លាចនូវហេតុដែលគេគួរខ្លាច ។

[ ២២៣ ] ( ហង្សសេនាបតី... ) ទូលព្រះបង្គំជាខ្ញុំ មិនត្រូវការដោយ

ទាហាន ដោយនគរ ឬដោយទ្រព្យទេ ពួកទូលព្រះបង្គំជាខ្ញុំ តែងទៅកាន់ផ្លូវតាមផ្លូវ មិនមែនជាផ្លូវដែលព្រះអង្គទៅបានទេ ទូលព្រះបង្គំជាខ្ញុំ ត្រាច់ទៅឰដ៏អាកាស ។ ព្រះអង្គបានទ្រង់ឮហើយថា ពួកទូលព្រះបង្គំជាខ្ញុំ ជាបណ្ឌិតមានប្រាជ្ញាដ៏ល្អិត ជាអ្នកគិតនូវអាថ៌កំបាំង បើព្រះអង្គប្រតិស្ឋានក្នុងសច្ចៈ ពួកទូលព្រះបង្គំជាខ្ញុំ នឹងពោលនូវវាចាដែលមានប្រយោជន៍ ។ ឯវាចាជាសុភាសិត ដែលព្រះអង្គមិនមានសច្ចៈ ជាបុគ្គលមិនប្រសើរ បានពោលដល់ព្រានព្រៃ ជាអ្នកល្មោភ និយាយកុហកដែរ នឹងធ្វើដូចម្តេច ។

[ ២២៤ ] ព្រះអង្គបានឲ្យគេធ្វើស្រះបោក្ខរណីឈ្មោះខេមានោះ តាមសំដីនៃពួកព្រាហ្មណ៍ ម្យ៉ាងទៀត ព្រះអង្គឲ្យគេឃោសនានូវអភ័យ គ្រប់ទិសទាំង ១០ នេះ ។ ថាបើកឲ្យសត្វបក្សីចុះកាន់ស្រះបោក្ខរណី ដែលមានទឹកដ៏ថ្លាស្អាតបុះ ដ្បិតមានវត្ថុសម្រាប់ទំពាស៊ី ក្នុងស្រះនោះជាច្រើន ទាំងមិនមានការបៀតបៀននូវពួកសត្វបក្សីក្នុងស្រះនោះទេ ។ ពួកទូលព្រះបង្គំជាខ្ញុំបានឮនូវអភ័យនេះ ដែលព្រះអង្គឲ្យឃោសនាហើយ បានជាមកក្នុងសំណាក់នៃព្រះអង្គ ទូលព្រះបង្គំជាខ្ញុំទាំងនោះ ជាប់ដោយអន្ទាក់របស់ព្រះអង្គ នេះហើយជាសំដីកុហករបស់ព្រះអង្គ ។ បុគ្គលធ្វើនូវមុសាវាទផង នូវសេចក្តីលោភ គឺសេចក្តីប្រាថ្នាដ៏លាមកផង ឲ្យជាប្រធាន រមែងកន្លងនូវបដិសន្ធិក្នុងលោកទាំង ២ ហើយចូលទៅកាន់ទីមិនមានសេចក្តីត្រេកអរ ( នរក ) ។

[ ២២៥ ] ( ព្រះរាជា ... ) ម្នាលសុមុខៈ យើងមិនមែនប្រទូស្តអ្នកទេ យើងមិនមែនចាប់អ្នកព្រោះសេចក្តីលោភទេ យើងបានឮថា អ្នកទាំងឡាយ

ជាបណ្ឌិត មានប្រាជ្ញាដ៏ល្អិត ជាអ្នកគិតនូវអាថ៌កំបាំង ។ ធ្វើម្តេចហ្ន៎ ហង្សទាំងឡាយ បានមកក្នុងទីនេះ ពោលនូវវាចាមានប្រយោជន៍ ម្នាលសុមុខៈ ជាសម្លាញ់ ព្រោះហេតុនោះ បានជាយើងប្រាប់នាយនេសាទនេះ ឲ្យចាប់ ( អ្នក ) ។

[ ២២៦ ] ( ហង្សសេនាបតី... ) បពិត្រព្រះអង្គជាធំ ក្នុងដែនកាសី យើងទាំងឡាយជាសត្វ កាលបើជីវិតចូលទៅរក ( សេចក្តីស្លាប់ ) ហើយ ដល់នូវកាលកំណត់ដែលត្រូវស្លាប់ហើយ ពោលនូវពាក្យដែលមានប្រយោជន៍ មិនបានទេ ។ បុគ្គលណាសម្លាប់ម្រឹគដោយម្រឹគ ឬបក្សីដោយបក្សី ម្យ៉ាងទៀត បៀតបៀននូវបុគ្គលដែលមានឈ្មោះល្បី ដោយរបស់ដែលមានឈ្មោះល្បី អំពើអ្វីដែលអាក្រក់ជាងអំពើរបស់បុគ្គលនោះទៅទៀត ។ បុគ្គលណានិយាយសំដីដ៏ប្រសើរ ប៉ុន្តែជាបុគ្គលមិនប្រព្រឹត្តធម៌ដ៏ប្រសើរ បុគ្គលនោះរមែងឃ្លាតចាកលោកទាំង ២ គឺលោកនេះ និងលោកខាងមុខ ។ បុគ្គលដែលបាននូវយស មិនគួរស្រេវឹង ដល់នូវការសង្ស័យក្នុងជីវិត មិនគួរទុក្ខលំបាកឡើយ គួរព្យាយាមក្នុងកិច្ចទាំងឡាយផង គួរបិទនូវប្រហោងគឺ ( ទោស ) ទាំងឡាយផង ។ ពួកបុគ្គលណា ចម្រើនដោយគុណ ដល់កាលកំណត់ដែលត្រូវស្លាប់ មិនល្មើសធម៌ ទាំងបានប្រព្រឹត្តធម៌ក្នុងលោកនេះ ពួកបុគ្គលនោះ រមែងទៅកើតក្នុងត្រៃត្រិង្សយ៉ាងនេះ ។ បពិត្រព្រះអង្គជាធំ ក្នុងដែនកាសី ព្រះអង្គទ្រង់ព្រះសណ្តាប់នូវពាក្យនេះហើយ សូមរក្សានូវធម៌ក្នុងព្រះអង្គចុះ ម្យ៉ាងទៀត សូមព្រះអង្គទ្រង់ដោះលែងនូវរាជហង្សឈ្មោះ ធតរដ្ឋៈ ដ៏

ប្រសើរ លើសជាងពួកហង្ស ។

[ ២២៧ ] ( ព្រះរាជា... ) ពួកអ្នកបម្រើ ចូរនាំមកនូវទឹក ( សម្រាប់លាងជើង ) ផង នូវប្រេងសម្រាប់លាបជើងផង នូវអាសនៈដែលមានថ្លៃច្រើនផង យើងនឹងដោះនូវរាជហង្ស ឈ្មោះធតរដ្ឋៈដ៏មានយស ចេញអំពីទ្រុង ។ ម្យ៉ាងទៀត ហង្សណា កាលបើព្រះរាជាបានសេចក្ដីសុខ ខ្លួនក៏បានសេចក្ដីសុខដែរ ព្រះរាជាបានសេចក្ដីទុក្ខ ខ្លួនក៏បានសេចក្ដីទុក្ខដែរ យើងនឹងលែងនូវហង្សនោះ ជាសេនាបតី ជាអ្នកប្រាជ្ញ មានប្រាជ្ញាល្អិត អ្នកគិតនូវអាថ៌កំបាំង ។ បុគ្គលបែបនេះ ទើបគួរបរិភោគដុំបាយរបស់ម្ចាស់បាន ដូចជាហង្សសេនាបតីឈ្មោះ សុមុខៈ នេះជាសម្លាញ់មានជីវិតស្មើនឹងស្ដេច ។

[ ២២៨ ] ( អភិសម្ពុទ្ធគាថា ) រាជហង្សឈ្មោះធតរដ្ឋៈ បានចូលទៅទំលើតាំងជាវិការៈនៃមាសសុទ្ធ មានជើង ៥ ជាទីរីករាយនៃចិត្ត ជាតាំងដ៏រលីង ក្រាលដោយសំពត់អ្នកដែនកាសី ។ ចំណែកហង្សសេនាបតី ឈ្មោះសុមុខៈ បានចូលទៅទំលើកៅអី ជាវិការនៃមាសសុទ្ធ ដែលពាសដោយស្បែកខ្លា ក្នុងទីជាលំដាប់ នៃរាជហង្សឈ្មោះធតរដ្ឋៈ ។ ពួកអ្នកដែនកាសីជាច្រើន បាននាំយកនូវភោជនមានរសដ៏ប្រសើរ ដែលគេបញ្ជូនទៅថ្វាយព្រះរាជា ដោយភាជន៍ជាវិការៈនៃមាសទាំងឡាយ ហើយក៏បង្អោនទៅដល់ហង្សទាំងនោះ ។

[ ២២៩ ] រាជហង្សឈ្លាសវៃក្នុងបដិសណ្ឋារធម៌ លុះបានឃើញទឹក និងភោជនដ៏ប្រសើរ ដែលគេនាំមក ដែលព្រះរាជាក្នុងដែនកាសីទ្រង់បញ្ជូន

មកហើយ សួរក្នុងកាលជាលំដាប់នោះថា ព្រះអង្គទ្រង់បានសេចក្ដីសុខស្រួលដែរឬ ព្រះអង្គមិនមានជំងឺតម្កាត់អ្វីទេឬ ព្រះអង្គគ្រប់គ្រងដែនដីធំទូលាយនេះ ដោយធម៌ដែរឬ ។

[ ២៣០ ] ( ព្រះរាជា... ) ម្នាលហង្ស យើងមានសេចក្ដីសុខស្រួលដែរ ម្នាលហង្សយើងមិនមានជំងឺតម្កាត់អ្វីទេ យើងគ្រប់គ្រងដែនដីធំទូលាយនេះត្រឹមត្រូវដោយធម៌ហើយ ។

[ ២៣១ ] ( រាជហង្ស... ) ទោសតិចតួចរបស់ព្រះអង្គ មិនមានក្នុងពួកអាមាត្យទេឬ អាមាត្យទាំងនោះ មិនអាល័យក្នុងជីវិតចំពោះប្រយោជន៍ទាំងឡាយរបស់ព្រះអង្គទេឬ ។

[ ២៣២ ] ( ព្រះរាជា... ) ទោសតិចតួចរបស់យើង មិនមានក្នុងពួកអាមាត្យទេ អាមាត្យទាំងនោះ មិនអាល័យក្នុងជីវិត ចំពោះប្រយោជន៍ទាំងឡាយរបស់យើងទេ ។

[ ២៣៣ ] ( រាជហង្ស... ) អគ្គមហេសីដែលមានជាតិស្មើនឹងព្រះអង្គ ជាស្ត្រីស្តាប់បង្គាប់ ពោលនូវពាក្យជាទីស្រឡាញ់ ប្រកបដោយបុត្ត រូបនិងយស ជាស្ត្រីលុះអំណាចសេចក្ដីប្រាថ្នារបស់ព្រះអង្គទេឬ ។

[ ២៣៤ ] ( ព្រះរាជា... ) អគ្គមហេសី ដែលមានជាតិស្មើនឹងយើង ជាស្ត្រីស្តាប់បង្គាប់ ពោលនូវពាក្យជាទីស្រឡាញ់ បានប្រកបដោយបុត្ត រូបនិងយស ជាស្ត្រីលុះអំណាចសេចក្ដីប្រាថ្នារបស់យើង ។

[ ២៣៥ ] ( រាជហង្ស... ) ព្រះអង្គមិនបៀតបៀនអ្នកដែន ដែលមិន

មានឧបទ្រពអំពីណា គ្រប់គ្រងដោយអាការៈមិនរួសរាន់ តាមធម៌ដ៏ស្មើទេឬ ។

[ ២៣៦ ] ( ព្រះរាជា... ) យើងមិនបានបៀតបៀនអ្នកដែន ដែលមិនមានឧបទ្រពអំពីទីណា គ្រប់គ្រងដោយការមិនរួសរាន់ តាមធម៌ដ៏ស្មើ ។

[ ២៣៧ ] ( រាជហង្ស... ) ព្រះអង្គទ្រង់បានគោរពពួកសប្បុរស វៀរបង់ពួកអសប្បុរស មិនលះបង់នូវធម៌ ហើយប្រព្រឹត្តនូវអធម៌ទេឬ ។

[ ២៣៨ ] ( ព្រះរាជា... ) យើងបានគោរពនូវពួកសប្បុរស វៀរបង់នូវពួកអសប្បុរស យើងបានលះបង់នូវអធម៌ ហើយប្រព្រឹត្តតាមធម៌តែម្យ៉ាង ។

[ ២៣៩ ] ( រាជហង្ស... ) បពិត្រក្សត្រ ព្រះអង្គទ្រង់រំពឹង នូវកាលជាអនាគតដ៏វែងដែរឬ ព្រះអង្គស្រវឹងក្នុងអារម្មណ៍ ជាទីតាំងនៃសេចក្ដីស្រវឹងហើយ មិនតក់ស្លុតនឹងបរលោកទេឬ ។

[ ២៤០ ] ( ព្រះរាជា... ) ម្នាលបក្សី យើងតែងប្រមើលមើលនូវកាលអនាគតដ៏វែង យើងឋិតនៅក្នុងធម៌ ១០ ប្រការ មិនតក់ស្លុតនឹងបរលោកឡើយ ( ធម៌ ១០ ប្រការគឺ ) ទាន ១ សីល ១ បរិច្ចាគ ១ ភាពនៃចិត្តត្រង់ ១ ភាពនៃចិត្តទន់ ១ តបៈគឺឧបោសថសីល ១ ការមិនក្រោធ ១ ការមិនបៀតបៀន ១ ខន្តិ ១ កិរិយាមិនភ្លាត់ ១ ។ យើងឃើញនូវកុសលធម៌ទាំងនេះឋិតនៅក្នុងខ្លួន លំដាប់នោះ បីតិនិងសោមនស្សជាច្រើន កើតឡើងដល់យើងដោយប្រការដូច្នេះ ។ ឯបក្សី ឈ្មោះសុមុខៈ មិនបានគិត ហើយបញ្ចេញនូវវាចាដ៏ទ្រគោះ ព្រោះតែមិនបានដឹងច្បាស់ នូវការប្រទូស្តក្នុងចិត្តរបស់យើង ។ បក្សីនោះ លុះខឹងហើយ ក៏បញ្ចេញនូវវាចាដ៏ទ្រគោះ ដោយឥតគំនិត ( ពោល )

នូវទោសទាំងឡាយ ដែលមិនមានក្នុងពួកយើង ពាក្យនេះមិនមែនដូចពាក្យនៃបុគ្គលមានប្រាជ្ញា ( ពោលហើយ ) ទេ ។

[ ២៤១ ] ( ហង្សសេនាបតី... ) បពិត្រព្រះអង្គ ជាធំជាងពួកមនុស្ស ទូលព្រះបង្គំជាខ្ញុំ មានសេចក្ដីក្ដាំងក្ដាត់នោះ ព្រោះពោលពាក្យជោយរួសរាន់ពេក ដ្បិតកាលដែលរាជហង្សឈ្មោះ ធតរដ្ឋៈជាប់ចំណាង ទូលព្រះបង្គំជាខ្ញុំ មានសេចក្ដីទុក្ខដ៏ធំ ។ បពិត្រព្រះអង្គជារាជកុញ្ជរៈ ព្រះអង្គ ( ជាទីពឹង ) នៃពួកទូលព្រះបង្គំជាខ្ញុំ ដូចជាបិតា ( ជាទីពឹង ) នៃកូនឬដូចធរណី ( ជាទីពឹង ) នៃពួកកូត សូមព្រះអង្គអត់ទោស ដល់ទូលព្រះបង្គំជាខ្ញុំទាំងឡាយ ដែលត្រូវសេចក្ដីខុសគ្របសង្កត់ ។

[ ២៤២ ] ( ព្រះរាជា... ) យើងរីករាយចំពោះអ្នកយ៉ាងនេះ ព្រោះថាអ្នកមិនលាក់នូវភាវៈនៃចិត្តដ៏កំបាំងរបស់ខ្លួន ម្នាលបក្សី អ្នកបានទម្លាយចោលនូវចិត្តរឹងត្អឹង ម្នាលបក្សី អ្នកជាសត្វមានចិត្តត្រង់ ។

[ ២៤៣ ] រតនៈណាមួយ គឺប្រាក់ មាស កែវមុក្តា កែវពៃទូរ្យជាច្រើន មាននៅក្នុងព្រះរាជនិវេសន៍ ក្នុងដែនកាសី ។ មួយទៀត កែវមណី សង្ខ ( ជាទក្ខិណាវដ្ដ ) កែវមុក្តា ( មានសណ្ឋានមូលដូចផ្លែកន្ទួតព្រៃ ) សំពត់ខ្លឹមចន្ទន៍ក្រហម ស្បែកខ្លាឃ្មុំ កណ្ឌជាវិការៈនៃភ្លុក លោហៈក្រហម និងលោហៈខ្មៅដ៏ច្រើន យើងឲ្យនូវទ្រព្យទាំងនេះដល់អ្នក យើងនឹងលះបង់នូវភាវៈជាធំដល់អ្នក ។

[ ២៤៤ ] ( រាជហង្ស... ) បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ព្រះអង្គ

បានគោរព ធ្វើសក្ការៈ ( ដល់យើងទាំងឡាយ ) ដោយពិត សូមព្រះអង្គជាអាចារ្យរបស់យើង ដែលជាអ្នកប្រព្រឹត្តក្នុងធម៌ទាំងឡាយ ។ បពិត្រព្រះអង្គជាអាចារ្យ ព្រះអង្គបានអនុញ្ញាត បើកយើងទាំងឡាយ ឲ្យទៅដោយស្រួលហើយ បពិត្រព្រះអង្គជាអ្នកទូន្មានទូវសត្រូវយើងទាំងឡាយ សូមធ្វើប្រទក្សិណនូវព្រះអង្គ ហើយទៅជួបនឹងពួកញាតិ ។

[ ២៨៥ ] ( អភិសម្ពុទ្ធគាថា ) ព្រះរាជាក្នុងដែនកាសី ទ្រង់បានគិតបានប្រឹក្សា នូវហេតុដ៏គួរតាមពិត ពេញមួយរាត្រី ហើយទ្រង់អនុញ្ញាតឲ្យរាជហង្សដ៏ប្រសើរខ្ពង់ខ្ពស់ជាងពួកហង្ស ហើរទៅ ។

[ ២៨៦ ] លំដាប់នោះ កាលដែលរាត្រីនោះអស់ហើយ ព្រះអាទិត្យក៏រះឡើង កាលព្រះរាជាក្នុងដែនកាសី ទ្រង់កំពុងទតមើល សត្វហង្សទាំងពីរក៏ហើរចេញទៅអំពីទីនៅរបស់ព្រះរាជា ។

[ ២៨៧ ] ហង្សទាំងឡាយ លុះបានឃើញបក្សីហង្សដ៏ប្រសើរទាំង ២ នោះ មិនមានរោគ មកដល់ហើយក៏ធ្វើនូវសំឡេងថា កេកាៗ ដូច្នេះ សូរស័ព្ទរំពងក៏កើតឡើង ។ បក្សីហង្សជាអណ្ឌជាតិទាំងនោះ មានចិត្តរីករាយ ព្រោះម្ចាស់រួចហើយ ជាសត្វគោរពម្ចាស់ ជាសត្វបាននូវទីពឹង ក៏ចោមរោមម្ចាស់ដោយជុំវិញ ។

[ ២៨៨ ] ប្រយោជន៍គ្រប់យ៉ាង របស់ពួកជនអ្នកមានមិត្តល្អ រមែងជាប្រយោជន៍គួរចម្រើនដូចហង្សឈ្មោះធតរដ្ឋៈ និងហង្សឈ្មោះសុមុខៈ បានចូលទៅជួបនឹងពួកញាតិ ។

**ចប់ មហាហង្សជាតក ទី ២**

# អដ្ឋកថា

# មហាហំសជាតក

[ ១៩៩-២៤៨ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធការលះបង់ជីវិតរបស់ព្រះអានន្ទត្ថេរនោះឯង ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ឯតេ ហំសា បក្កមន្តិ** ដូច្នេះជាដើម ។

ចំណែករឿង ដូចគ្នានឹងរឿងដែលពោលមកហើយនោះឯង ។ ក្នុងថ្ងៃមួយ ពួកភិក្ខុសន្ទនាគ្នាក្នុងធម្មសភាថា នែអាវុសោទាំងឡាយ ព្រះអានន្ទដ៏មានអាយុ លះបង់ជីវិតដើម្បីជាប្រយោជន៍ដល់ព្រះតថាគត ធ្វើកិច្ចដែលអ្នកដទៃធ្វើបានដោយកំបាក លោកឃើញដំរីនាឡាគិរីហើយ សូម្បីត្រូវព្រះសាស្តាឃាត់អស់វារៈ ៣ ដង ក៏មិនព្រមត្រឡប់ឡើយ គួរសរសើរព្រះអានន្ទត្ថេរ លោកធ្វើកិច្ចដែលអ្នកដទៃធ្វើបានដោយក្រហ្ម ។ ព្រះសាស្តាទ្រង់ព្រះតម្រិះថា វាចាសរសើរគុណរបស់អានន្ទកំពុងប្រព្រឹត្តទៅ តថាគតគួរទៅក្នុងទីនោះ ទើបយាងចេញអំពីព្រះគន្ធកុដិមក ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីអម្បាញ់មិញនេះ កាលភិក្ខុទាំងនោះក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន អានន្ទកើតហើយ ក្នុងកំណើតសត្វតិរច្ឆាន ក៏សុខចិត្តលះបង់ជីវិតរបស់ខ្លួនដើម្បីជាប្រយោជន៍ដល់តថាគតហើយដូចគ្នាដូច្នេះ ហើយទើបតុណ្ហីភាព កាលភិក្ខុទាំងឡាយអារាធនា ទើបទ្រង់នាំអតីតនិទានមកត្រាស់ថា

ក្នុងអអតីតកាល ក្នុងនគរពារាណសី ព្រះបាទពារាណសីទ្រង់ព្រះនាមថា

សំយម: មានអគ្គមហេសីព្រះនាមថា ខេមា ។ ក្នុងកាលនោះ ព្រះពោធិសត្វមានពួកហង្ស ៩៦០០០ ចោមរោមជាបរិវារ អាស្រ័យនៅនាភ្នំចិត្តកូដ ។ ថ្ងៃមួយ ព្រះនាងខេមាទេវីទ្រង់ព្រះសុបិនទិមិត្ត ក្នុងពេលទៀបភ្លឺថា មានស្តេចហង្សមាស ២ មកទំត្រង់ព្រះរាជបល្ល័ង្ក ហើយសម្តែងធម្មកថា ដោយសំឡេងដ៏ពីរោះ កាលព្រះទេវីប្រទានសាធុការ ទ្រង់ស្តាប់ធម្មកថា មិនទាន់ឆ្អែតក្នុងការស្តាប់ធម៌ រាត្រីក៏អស់ហើយ ស្តេចហង្សទាំង ២ កាលសម្តែងធម៌ហើយ ក៏នាំគ្នាហើរចេញទៅតាមបង្អួច ព្រះនាងក៏បញ្ជាថា ពួកអ្នកទាំងឡាយ ចូរប្រញាប់ក្រោកឡើង ជួយនាំគ្នាចាប់ ជួយនាំគ្នាចាប់ ហង្សហើរទៅហើយ កំពុងលាព្រះហស្តនោះឯង ក៏តើនចាកព្រះបន្ទំ ស្រីស្នំបានឮព្រះរាជសវនីយ៍របស់ព្រះនាង ក៏នាំគ្នាសើចចំអក ពោលថា បពិត្រព្រះនាង ហង្សនៅឯណា ទើបព្រះនាងជ្រាបក្នុងខណៈនោះថា ជាសុបិនទិមិត្ត ទើបព្រះនាងទ្រង់ព្រះតម្រិះថា វត្ថុដែលមិនពិត អាត្មាអញមិនយល់សប្តិឃើញឡើយ ស្តេចហង្សដែលមានពណ៌ដូចមាស គង់មានក្នុងលោកនេះដោយពិត តែបើអញទូលព្រះរាជាថា ខ្ញុំម្ចាស់ប្រាថ្នានឹងស្តាប់ធម៌ របស់ស្តេចហង្សមាសទាំងឡាយ ព្រះរាជានឹងត្រាស់ថា ឈ្មោះថាហង្សមាសទាំងឡាយ យើងមិនធ្លាប់ឃើញឡើយ ធម្មតាហង្សទាំងឡាយនឹងពោលពាក្យបាន ក៏មិនធ្លាប់មានមកឡើយ ដូច្នេះ ទ្រង់នឹងមិនខ្វល់ខ្វាយ តែបើអញទូលថា អញមានគភ៌ មានអាការចាញ់គភ៌ហើយ ទ្រង់នឹងជួយខ្នះខ្នែងស្វែងរកដោយឧបាយណាមួយ សេចក្តីប្រាថ្នារបស់អញនឹងសម្រេចតាមមនោរថ ដោយប្រការដូច្នេះ ។ ទើប

ព្រះនាងក្លែងអាការធ្វើជាប្រឈួន ឲ្យសញ្ញាដល់ស្រីស្នំ ហើយព្រះនាងផ្ទំ ។ ព្រះរាជាប្រថាប់គង់ក្នុងព្រះរាជអាសនៈ មិនបានទតឃើញព្រះនាងក្នុងកាលដែលព្រះនាងធ្លាប់គាល់ហៅ ទើបត្រាស់សួរថា ព្រះនាងខេមាទៅណា ទ្រង់បានស្តាប់ថា ព្រះនាងប្រឈួន ទើបយាងទៅកាន់សម្នាក់របស់ព្រះនាង ប្រថាប់គង់ក្នុងចំណែកម្ខាង ក្បែរទីបន្ទំ ទ្រង់ស្ទាបព្រះបិដ្ឋិ ត្រាស់សួរថា នែនាង នាងមិនសប្បាយរឿងអ្វី ព្រះនាងទូលថា បពិត្រព្រះអង្គ ការមិនសប្បាយដទៃមិនមានឡើយ តែអាការចាញ់គភ៌កើតឡើងដល់ខ្ញុំម្ចាស់ ព្រះរាជាត្រាស់ថា នែនាង បើដូច្នោះ ចូរប្រាប់មកចុះ នាងប្រាថ្នាវត្ថុណា អញនឹងនាំវត្ថុនោះមកឲ្យនាង ដោយរហ័ស ។ ព្រះនាងទូលថា បពិត្រមហារាជ ខ្ញុំម្ចាស់ប្រាថ្នាធ្វើការបូជាដោយគ្រឿងក្រអូប និងកម្រងផ្កាជាដើម ដល់ស្តេចហង្សមាសមួយ ដែលទំត្រង់រាជបល្ល័ង្ក មានស្វេតច្ឆត្រលើកឡើង ហើយឲ្យសាធុការស្តាប់ធម្មកថារបស់ស្តេចហង្សនោះ បើខ្ញុំម្ចាស់បានយ៉ាងនេះ ការបាននោះជាការល្អ បើរកមិនបាន ជីវិតរបស់ខ្ញុំម្ចាស់នឹងមិនមាន ។ លំដាប់នោះ ព្រះរាជាក៏ទ្រង់លួងលោមយកចិត្តព្រះនាងថា បើសុវណ្ណហង្សមានក្នុងមនុស្សលោក សោត នាងគង់នឹងបានសមតាមបំណង នាងកុំទោមនស្សឡើយ ហើយទ្រង់ចេញអំពីបន្ទប់ដ៏មានសិរី ត្រាស់ប្រឹក្សានឹងពួកអាមាត្យថា នែអ្នកដ៏ចម្រើនទាំងឡាយ ព្រះនាងខេមាទេវីត្រាស់ជាមួយយើងថា ខ្ញុំម្ចាស់បានស្តាប់ធម្មកថារបស់ស្តេចហង្សមាស ទើបមានជីវិតបាន បើមិនបានហើយ ជីវិតរបស់នាងនឹងមិនមាន ហង្សមានពណ៌ដូចមាស តើមានដែរឬទេ អាមាត្យទាំងឡាយ

ក្រាបទូលថា ទូលបង្គំមិនធ្លាប់ឃើញផង មិនធ្លាប់ឮផង ព្រះរាជាត្រាស់សួរថា តើមាននរណាដឹងខ្លះ ពួកអាមាត្យក្រាបទូលថា បពិត្រព្រះអង្គ មានតែពួកព្រាហ្មណ៍ប៉ុណ្ណោះ ព្រះរាជាត្រាស់ឲ្យហៅព្រាហ្មណ៍ទាំងឡាយមក ទ្រង់ធ្វើសក្ការៈ ហើយត្រាស់សួរថា បពិត្រលោកអាចារ្យទាំងឡាយ ហង្សដែលមានពណ៌ដូចមាសមានដែរឬ ពួកព្រាហ្មណ៍ទូលថា បពិត្រមហារាជ សត្វតិរច្ឆាន ៦ ពួក គឺត្រី ក្តាម អណ្តើក ម្រឹគ ក្ងោក ហង្ស មានក្នុងមន្តរបស់ទូលព្រះបង្គំទាំងឡាយថា មានពណ៌ដូចមាស បណ្តាសត្វទាំង ៦ ពួកនេះ ឈ្មោះថាហង្សដែលកើតក្នុងត្រកូលធតរដ្ឋៈ ជាសត្វឈ្លាស ប្រកបដោយវិជ្ជា រាប់ទាំងពួកមនុស្សផង រមែងជាសត្វដែលមានពណ៌ដូចមាស រួមជា ៧ ពួក ដោយប្រការដូច្នេះ ។ ព្រះរាជា ត្រេកអរក្នុងព្រះហឫទ័យសួរថា ពួកហង្សដែលកើតក្នុងត្រកូលធតរដ្ឋៈនោះនៅឯណា ពួកព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះអង្គ ទូលព្រះបង្គំមិនដឹងឡើយ ព្រះរាជាត្រាស់សួរថា តើមាននរណាស្គាល់ពួកហង្សទាំងនោះដែរឬទេ កាលពួកព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះអង្គ មានតែពួកព្រានព្រៃប៉ុណ្ណោះទើបដឹង ទើបត្រាស់ឲ្យហៅពួកព្រានព្រៃក្នុងដែនរបស់ព្រះអង្គទាំងអស់មកប្រជុំគ្នា ហើយត្រាស់សួរថា នែបា ឈ្មោះថា ហង្សត្រកូលធតរដ្ឋៈ មានពណ៌ដូចមាស មានក្នុងទីណា ។ លំដាប់នោះនាយព្រានម្នាក់ក៏ក្រាបទូលថា បពិត្រព្រះអង្គ បានឮថា ត្រកូលនៃញាតិទាំងឡាយ តំណាលតៗគ្នាមកថា ហង្សទាំងនោះ នៅនាភ្នំចិត្តកូដ នាហិមវន្តប្បទេស ។ ព្រះរាជាត្រាស់សួរថា នែបា អ្នកដឹងឧបាយចាប់ហង្សទាំងនោះ

ដែរឬទេ ព្រានព្រៃក្រាបទូលថា បពិត្រព្រះអង្គ ទូលបង្គំមិនជ្រាបឡើយ ។ ព្រះរាជាត្រាស់សួរថា តើអ្នកណាដឹង ពួកនាយព្រានក្រាបទូលថា គឺពួកព្រាហ្មណ៍ទើបដឹង ព្រះរាជាត្រាស់ឲ្យហៅពួកព្រាហ្មណ៍ ដែលជាបណ្ឌិតមក ហើយត្រាស់ប្រាប់ភាពដែលពួកហង្ស មានពណ៌ដូចមាសមាន នាក្នុំចិត្តកូដ ហើយត្រាស់សួរថា អ្នកទាំងឡាយដឹងឧបាយចាប់ហង្សទាំងនោះដែរឬទេ ពួកព្រាហ្មណ៍ក្រាបទូលថា បពិត្រមហារាជ ប្រយោជន៍អ្វី ដែលត្រូវទៅចាប់ហង្សទាំងនោះឯក្នុំចិត្តកូដនោះ ទូលព្រះបង្គំ នឹងបញ្ឆោតហង្សទាំងនោះឲ្យមកកាន់ព្រះនគរ ហើយចាប់យកដោយឧបាយ ។ ព្រះរាជាត្រាស់សួរថា តើឧបាយដូចម្តេច ។ ពួកព្រាហ្មណ៍ក្រាបទូលថា បពិត្រមហារាជ សូមទ្រង់ត្រាស់ឲ្យជីកស្រះធំ ឈ្មោះថាខេមៈ ប្រមាណ ៣ គាវុត ខាងជើងអំពីព្រះនគរ ឲ្យពេញដោយទឹក ដាំធញ្ញជាតិផ្សេងៗ ធ្វើឲ្យដេរដាសទៅដោយផ្កាឈូក ៥ ពណ៌ ឲ្យនាយព្រានអ្នកឈ្លាសវៃម្នាក់នៅរក្សាជាប្រចាំ កុំឲ្យមនុស្សចូលទៅជិត ឲ្យមនុស្សនៅត្រង់ជ្រុងស្រះទាំង ៤ ចាំប្រកាសការផុតភ័យ សកុណជាតិផ្សេងៗ ក៏នឹងចុះចាកទិសទាំង ១០ ហង្សទាំងនោះបានឮថា ស្រះនោះជាទីក្សេមដោយល្បីតៗមក ក៏នាំគ្នាមក កាលបើដូច្នោះ ទ្រង់គប្បីឲ្យគេដាក់អន្ទាក់ធ្វើដោយរោមសត្វ ចាប់យកហង្សទាំងនោះចុះ ។

ព្រះរាជាទ្រង់ស្តាប់ពាក្យនោះ ទ្រង់ឲ្យធ្វើស្រះមានប្រការដូចពោលហើយក្នុងប្រទេសដែលពួកព្រាហ្មណ៍ទាំងនោះទូលថ្វាយ ហើយត្រាស់ឲ្យព្រានព្រៃអ្នកឈ្លាសវៃមក ទ្រង់លួងលោមព្រានព្រៃនោះថា ចាប់ពីពេលនេះទៅ ចូរ

អ្នកលើកលែងការងាររបស់ខ្លួនចុះ យើងនឹងចិញ្ចឹមកូន និងភរិយារបស់អ្នកឯង ចូរអ្នកកុំប្រមាទ គប្បីឃាមខេមស្រះ ឲ្យពួកមនុស្សថយទៅ ប្រកាសការផុតភ័យក្នុងជ្រុងស្រះទាំង ៤ គប្បីប្រាប់ដល់ហ្វូងបក្សីដែលមកហើយដល់យើង កាលសុវណ្ណហង្សទាំងឡាយមកហើយ អ្នកនឹងបានសក្ការៈធំ ហើយឲ្យរក្សាខេមស្រះ ។ ចាប់ពីពេលនោះមក ព្រាននោះក៏បដិបត្តិក្នុងទីនោះ ដោយន័យដែលព្រះរាជាត្រាស់នោះឯង ។ ព្រាននេសាទនោះ ក៏ប្រាកដឈ្មោះថា ខេមនេសាទ ដូច្នេះឯង ព្រោះជាអ្នករក្សាខេមស្រះ ។ ចាប់តាំងអំពីនោះមក សកុណជាតិទាំងឡាយ នាំគ្នាមកចុះក្នុងស្រះនោះ ពួកហង្សផ្សេងៗ នាំគ្នាមកដោយសំឡេងប្រកាសតៗគ្នាថា ខេមស្រះមិនមានភ័យ ។ ជាដំបូង ពួកតិណហង្សមកមុន បន្ទាប់មក ពួកបណ្ឌុហង្សក៏នាំគ្នាមក ដោយសំឡេងប្រកាសរបស់ពួកតិណហង្សនោះ ហើយពួកមនោសិលាវណ្ណហង្ស ក៏នាំគ្នាមកដោយសំឡេងប្រកាសរបស់ពួកបណ្ឌុហង្ស តមក សេតហង្ស នាំគ្នាមកដោយសំឡេងប្រកាសរបស់ពួកមនោសិលាវណ្ណហង្ស បន្ទាប់អំពីនោះ ពួកបាកហង្សក៏នាំគ្នាមកដោយសំឡេងប្រកាសនៃសេតហង្សទាំងនោះ កាលពួកហង្សទាំងនោះមកហើយ នាយខេមនេសាទក៏បានមកគាល់ ក្រាបទូលដល់ព្រះរាជាថា បពិត្រព្រះអង្គ ហង្សមកស៊ីចំណីក្នុងស្រះ ៥ ប្រភេទ ហើយពួកហង្សដែលមានពណ៌ដូចមាស គង់នឹងមកក្នុងពេល ២-៣ ថ្ងៃនេះ ដោយពិត ព្រោះពួកបាកហង្សមកហើយ សូមទ្រង់កុំព្រះវិតក្កឡើយ ។ ព្រះរាជាទ្រង់ស្ដាប់ពាក្យនោះ ទើបឲ្យរាជបុរសវាយស្គរប្រកាសពេញព្រះនគរថា

បុគ្គលដទៃមិនគប្បីចូលទៅក្នុងដែនរបស់ស្រះនោះ អ្នកណាចូលទៅ អ្នកនោះត្រូវកាត់ដៃនិងជើង រឹបអូសយកផ្ទះទៀតផង ។ តាំងអំពីកាលនោះមក បុគ្គលណាម្នាក់ ក៏មិនហ៊ានទៅត្រង់ស្រះនោះ ឯពួកបាកហង្សទាំងឡាយអាស្រ័យនៅក្នុងគុហាមាស ក្បែរភ្នំចិត្តកូដ សូម្បីបាកហង្សទាំងនោះ ជាសត្វមានកម្លាំងច្រើន ម្យ៉ាងទៀត ពណ៌សម្បុរនៃសរីរៈ របស់ពួកបាកហង្សទាំងនោះ ក៏មិនខុសប្លែកអំពីហង្សត្រកូលធតរដ្ឋៈ ឯបុត្រីរបស់ស្តេចហង្សបាករាជ មានពណ៌ដូចមាសស្តេចបាកហង្សនោះ ត្រិះរិះថា ធីតារបស់អញនេះ សមគួរដល់ព្រះបាទធតរដ្ឋរាជហង្ស ដែលជាសត្វមានយសធំ ទើបបញ្ជូននាងទៅឲ្យជាបាទបរិចារិកា របស់ស្តេចហង្សធតរដ្ឋៈនោះ នាងបានជាទីសព្វព្រះរាជហឫទ័យរបស់ស្តេចហង្សធតរដ្ឋៈនោះ ព្រោះហេតុនោះឯង ទើបត្រកូលហង្សទាំង ២ មានការរាប់អានគ្នាយ៉ាងជិតស្និទ្ធ ។

ថ្ងៃមួយ ពួកហង្សដែលជាបរិវាររបស់ព្រះពោធិសត្វ សួរពួកបាកហង្សថា សព្វថ្ងៃនេះ ពួកអ្នកទៅស្វែងរកអាហារក្នុងទីណា ហង្សទាំងនោះប្រាប់ថា ពួកយើងទៅរកអាហារក្នុងខេមស្រះ ជិតនគរពារាណសី ចុះពួកអ្នកវិញ ទៅរកស៊ីឯណា កាលពួកហង្សធតរដ្ឋៈប្រាប់ថា ពួកយើងទៅរកស៊ីក្នុងទីឈ្មោះនោះ ពួកបាកហង្សក៏ពណ៌នាគុណរបស់ខេមស្រះថា ហេតុអ្វីពួកអ្នកមិនទៅកាន់ខេមស្រះ ព្រោះថា ស្រះនោះជាទីត្រេកអរ កុះករទៅដោយសកុណជាតិផ្សេងៗ ច្រើនប្រភេទ ដេរដាសទៅដោយផ្កាឈូកមានពណ៌ ៥ សម្បុរទៅដោយធញ្ញាហារនិងផ្លែឈើផ្សេងៗ មានភមរជាតិច្រើនប្រភេទហើរក្រឡឹង

ត្រង់ជ្រុងស្រះទាំង ៤ មានសំឡេងប្រកាសការមិនមានភ័យ អស់កាលជានិច្ច មនុស្សណាមួយ មិនអាចចូលទៅជិតបានឡើយ នឹងពោលទៅថ្វីដល់ការធ្វើអន្តរាយដទៃនោះ ស្រះមានគុណបែបនេះឯង ។ ពួកហង្សធតរដ្ឋៈទាំងនោះ បានស្តាប់ពាក្យនៃបាកហង្សទាំងឡាយហើយ នាំគ្នាទៅប្រាប់ដល់សុមុខហង្សថា បានឮថា មានស្រះមួយឈ្មោះខេមៈ មានគុណបែបនេះ នៅជិតនគរពារាណសី ពួកបាកហង្សត្រាច់រកស៊ីក្នុងស្រះនោះ សូម្បីលោក ក៏ចូរប្រាប់ដល់ស្តេចហង្សធតរដ្ឋៈជាធំ បើទ្រង់អនុញ្ញាត ពួកយើងគប្បីទៅរកអាហារក្នុងទីនោះដែរ ។ សុមុខហង្សក៏ប្រាប់ដល់ស្តេចហង្ស សូម្បីស្តេចហង្សនោះ ក៏គិតថា ឈ្មោះថាមនុស្សទាំងឡាយ ជាអ្នកមានល្បិចច្រើន មានការគិតល្អិតល្អន់ ឈ្លាសក្នុងឧបាយ គួរមានហេតុក្នុងទីនោះ ឈ្មោះថាស្រះរមែងមិនមានក្នុងទីនោះអស់កាលមានប្រមាណប៉ុណ្ណេះ ឥឡូវនេះ ប្រហែលជាមានអ្នកណាមកជីកទុក ហើយនឹងជីកទុកចាំចាប់ពួកយើងពិត ទើបស្តេចហង្សពោលនឹងសុមុខហង្សថា អ្នកកុំពេញចិត្តទៅក្នុងទីនោះឡើយ ស្រះនោះ ពួកមនុស្សទាំងនោះ មិនបានជីកតាមធម្មតារបស់ខ្លួន គង់ជីកដើម្បីចាប់ពួកយើង ឈ្មោះថា មនុស្សទាំងឡាយ មានឧបាយច្រើន មានការគិតល្អិតល្អន់ ជាអ្នកឈ្លាសក្នុងឧបាយ អ្នកទាំងឡាយ ចូរត្រាច់ទៅក្នុងទីគោចររបស់ខ្លួនដូចមុនចុះ ។ ពួកហង្សមាសក៏បានប្រាប់ដល់សុមុខហង្សអស់វារៈ ២-៣ ដងថា ពួកយើងប្រាថ្នានឹងទៅកាន់ខេមស្រះ ដូច្នេះ ទើបសុមុខហង្ស ប្រាប់ភាពដែលពួកហង្សទាំងនោះប្រាថ្នានឹងទៅកាន់ស្រះនោះដល់ព្រះមហាសត្វ ។ សម័យនោះ ព្រះមហាសត្វក៏

ពោលថា ពួកញាតិទាំងឡាយរបស់យើង ចូរកុំលំបាកព្រោះអាស្រ័យយើងឡើយ បើដូច្នោះ យើងទាំងឡាយ នឹងទៅជាមួយគ្នា មានហង្ស ៩៦០០០ ចោមរោមជាបរិវារ នាំគ្នាទៅរកស៊ីក្នុងស្រះនោះ លេងនូវហង្សកីឡាហើយ ហើរត្រឡប់មកកាន់ភ្នំចិត្តកូដ ។ ឯព្រានខេមកៈក្នុងកាលដែលហង្សទាំងនោះមកហើយត្រឡប់ទៅវិញ ក៏ទៅក្រាបទូលដល់ព្រះរាជាថា ពួកហង្សមាសទាំងនោះនាំគ្នាមកហើយ ព្រះរាជាទ្រង់ត្រេកអរ ទ្រង់ត្រាស់ថា នែខេមកៈសម្លាញ់ ចូរអ្នកព្យាយាមចាប់ហង្សមាសនោះ ឲ្យបាន ១-២ យើងនឹងឲ្យយសធំដល់អ្នក ហើយក៏ប្រទានស្បៀង បញ្ជូនព្រានព្រៃនោះទៅ នាយខេមកនេសាទនោះ ទៅដល់ស្រះនោះហើយ ក៏អង្គុយស្ងៀម អង្គុយក្នុងផ្ទះដែលមានសណ្ឋានដូចពាង ពិចារណាទីរកស៊ីរបស់ពួកហង្ស ។ ធម្មតាព្រះពោធិសត្វទាំងឡាយ ជាអ្នកមានប្រក្រតី មិនប្រព្រឹត្តល្មោភ ព្រោះហេតុនោះ ទើបចឹកស៊ីស្រូវសាលីទៅតាមលំដាប់ ។ ឯហង្សក្រៅអំពីនោះ ស៊ីខាងនោះខ្លះខាងនេះខ្លះ លំដាប់នោះ នាយព្រានគិតថា ហង្សនេះមានប្រក្រតីប្រាថ្នាតិចអញគួរចាប់ហង្សនេះចុះ ក្នុងថ្ងៃរះឡើង កាលហង្សទាំងឡាយមិនទាន់ចុះមកកាន់ស្រះនោះឯង ក៏អង្គុយក្នុងផ្ទះ ដែលមានសណ្ឋានដូចពាងនោះ ហើយដើរលបៗ ទៅកាន់ទីនោះ ហើយពួនក្នុងគុម្ពស្មៅ ក្នុងទីមិនឆ្ងាយ សម្លឹងមើលតាមចន្លោះ ។

ក្នុងខណៈនោះ ព្រះមហាសត្វ មានហង្ស ៩៦០០០ ទៅខាងមុខ បន្ទាបខ្លួនចុះ ក្នុងទីដែលខ្លួនធ្លាប់ចុះ ក្នុងថ្ងៃម្សិលមិញនោះឯង ចឹកស៊ីស្រូវសាលី

បណ្ដើរៗទៅ ។ នាយនេសាទពិនិត្យមើលឃើញអត្តភាពរបស់ព្រះពោធិសត្វនោះ ដែលដល់ហើយនូវចំណែកដ៏ល្អនៃរាងកាយ ទើបគិតថា ហង្សនេះ មានរាងកាយធំប៉ុនដុំរទេះ មានពណ៌ដូចមាស មានផ្នូតកពណ៌ក្រហម ៣ ជាន់ មានធ្នូតចាប់អំពីកដល់ពោះ ៣ ធ្នូត និងមានធ្នូតបណ្ដោយទៅ ៣ ធ្នូត រហូតដល់កន្ទុយ រុងរឿងដូចធ្លោរនៃមាស ដែលបុគ្គលដាក់លើសំពត់កម្ពលក្រហម ហង្សនេះគង់ជាស្ដេចហង្សពិត អញនឹងចាប់ហង្សនេះឯង ។ ស្ដេចហង្សត្រាច់រកអាហារបានជាច្រើន លេងឧទកកីឡា មានហ្វូងហង្សចោមរោម ត្រឡប់ទៅកាន់ភ្នំចិត្តកូដនោះឯង ព្រះពោធិសត្វត្រាច់រកអាហារដោយទំនងនេះ អស់កាលប្រមាណ ៥-៦ ថ្ងៃ ក្នុងថ្ងៃទី ៧ នាយព្រានខេមកៈ ធ្វញខ្សែយ៉ាងធំដែលធ្វើដោយរោមកន្ទុយសេះពណ៌ខ្មៅយ៉ាងជាប់មាំទាំ ធ្វើជាអន្ទាក់មានដងបានដឹងដោយពិតថា ថ្ងៃនេះ ស្ដេចហង្សនឹងចុះក្នុងទីនេះ ទើបដាក់អន្ទាក់ក្នុងទឹក ។ ស្អែកឡើង ស្ដេចហង្សកាលបន្ទាបខ្លួនចុះមក ជើងក៏ជាន់ចំអន្ទាក់ ។ រំពេចនោះ អន្ទាក់របស់ព្រាននោះ ក៏រឹតជើង ដូចមាននរណាមកទាញ ដោយលួសដែក ស្ដេចហង្សនោះគិតថា អញនឹងទាញអន្ទាក់នេះឲ្យដាច់ ទើបប្រមូលកម្លាំង ហើយទាញមក ។ លើកទី ១ ស្បែកមានពណ៌ដូចមាសក៏ដាច់ទៅ លើកទី ២ សាច់ដែលមានពណ៌ដូចសំពត់កម្ពលក៏ដាច់ទៅ លើកទី ៣ សរសៃក៏បានដាច់ទៅ រហូតដល់ឆ្អឹង ។ ព្រះពោធិសត្វត្រិះរិះថា លើកទី ៤ ជើងរបស់អញនឹងដាច់ពិត ធម្មតាព្រះរាជា ដែលមានអវយវៈអាក្រក់ មិនសមគួរឡើយ ទើបមិនធ្វើសេចក្ដីព្យាយាមបន្តទៅទៀត ។ ទុក្ខវេទនាបាន

ផ្សាយទៅដ៏ខ្លាំងក្លា ព្រះពោធិសត្វក៏ត្រិះរិះថា បើអញស្រែក សម្ដែងអាការថា ជាប់អន្ទាក់ ពួកញាតិរបស់អញនឹងភិតភ័យ មិនបានបរិភោគអាហារ ហើរទៅទាំងស្រេកឃ្លាន ក៏នឹងធ្លាក់ក្នុងមហាសមុទ្រ ទើបមហាសត្វអត់ធន់ចំពោះទុក្ខវេទនា សូម្បីធ្លាក់ក្នុងអំណាចអន្ទាក់ ក៏ធ្វើដូចជាចឹកស៊ីនូវស្រូវសាលី ។ ក្នុងកាលដែលហង្សទាំងនោះ បរិភោគអាហារឆ្អែតស្កប់ស្កល់ហើយ លេងហង្សកីឡា ទើបស្រែកដោយសំឡេងខ្លាំងថា យើងជាប់អន្ទាក់ហើយ ហង្សទាំងឡាយបានឮសំឡេងនោះ មានការភ័យខ្លាចជាកម្លាំង ទើបបែរមុខទៅកាន់ភ្នំចិត្តកូដជាក្រុមៗ គេចទៅដោយន័យមុននោះឯង ។

សុមុខហង្សជាសេនាបតីគិតថា ភ័យនេះកើតឡើងដល់ព្រះរាជារបស់យើងដែរឬហ្ន៎ អញនឹងដឹងហេតុនេះ ទើបប្រញាប់ហើរទៅរកមើល ក្នុងរវាងពួកហង្ស ដែលហើរទៅមុន ដោយន័យដូចពោលអំពីខាងដើមនោះឯង មិនបានឃើញព្រះមហាសត្វក្នុងក្រុមទាំង ៣ គិតថា ភ័យនេះនឹងកើតឡើងដល់មហារាជរបស់អញដោយពិត ទើបវិលត្រឡប់មក ឃើញព្រះមហាសត្វជាប់អន្ទាក់ មានសរីរៈប្រឡាក់លោហិត ក្ដៅផ្សាដោយសេចក្ដីទុក្ខ ទំលើភក់ ទើបពោលថា បពិត្រមហារាជ ទ្រង់កុំខ្លាចឡើយ ខ្ញុំនឹងលះបង់ជីវិត ឲ្យនាយព្រានដោះលែងទ្រង់ ហើយបន្ទាបខ្លួនចុះ លួងលោមមហាសត្វ ហើយឈរក្នុងភក់ ។ លំដាប់នោះ ព្រះមហាសត្វត្រិះរិះថា កាលហង្ស ៩៦០០០ លះបង់អញគេចទៅ សុមុខហង្សនេះមកតែម្នាក់ឯង គេនឹងបោះបង់អញ ក្នុងពេលដែលនេសាទបុត្តមក ឬមិនលះបង់ហ្ន៎ ជាសត្វមានកាយប្រឡាក់ដោយ

ឈាម ឈរត្រង់ចុងអន្ទាក់នោះឯង បានពោល ៣ គាថា ដោយការដក ពិសោធចិត្តថា

*ហង្សទាំងឡាយនេះ ត្រូវភ័យគំរាមហើយ នាំគ្នាហើរទៅ ម្នាល សុមុខៈ អ្នកមានស្បែកដូចមាស មានសម្បុរដូចមាស អ្នក ចូរហើរទៅតាមប្រាថ្នាចុះ ។ ពួកបក្សីជាញាតិ បានលះចោល នូវយើង ដែលលុះអំណាចនៃអន្ទាក់តែម្នាក់ឯង មិនអាល័យ ហើរទៅ អ្នកក្រាញនៅតែម្នាក់ឯងដូចម្ដេច ។ ម្នាលអ្នកដ៏ ប្រសើរជាងពួកបក្សី អ្នកចូរហើរទៅចុះ ព្រោះថា ភាពជា សម្លាញ់ នឹងយើងដែលជាប់ចំណងមិនមានទេ អ្នកកុំធ្វើ ខ្លួនឲ្យសាបសូន្យចាកសេចក្ដីសុខឡើយ ម្នាលសុមុខៈ អ្នក ចូរហើរទៅតាមប្រាថ្នាចុះ ដូច្នេះ ។*

បណ្ដាបទទាំងនោះ បទថា **ភយមេរិតា** សេចក្ដីថា ត្រូវភ័យបៀតបៀន ត្រូវភ័យគំរាម គឺញាប់ញ័រដោយភ័យ ។ បទថា **ហរិ** និងបទថា **ហេម** ក្នុង បទទី ៣ ជាឈ្មោះនៃមាសដូចគ្នានោះឯង ។ ហង្សនោះមានពណ៌ដូចមាស ព្រោះមានស្បែកដូចមាស ព្រោះហេតុនោះ ទើបស្ដេចហង្សហៅសុមុខហង្ស យ៉ាងនេះ ។ ពាក្យថា **សុមុខ** គឺអ្នកមានមុខល្អ ។ បទថា **អនបេក្ខមានា** បានដល់ ពួកញាតិទាំងនោះ មិនបានសម្លឹងមើល អស់នូវអាល័យ ។ បទថា **បតេវ** បានដល់ ចូរឯងត្រឡប់ទៅចុះ ។ បទថា **អនីឃាយ** សេចក្ដីថា កុំ ប្រាសចាកសេចក្ដីព្យាយាម ព្រោះសេចក្ដីសុខ ដែលគប្បីដល់ដោយការទៅ

អំពីទីនេះ ។

សុមុខហង្សសេនាបតីស្តាប់ពាក្យនោះហើយ គិតថា ស្តេចហង្សនេះ មិនដឹងថា អញជាមិត្ត កំណត់អញថា ជាមិត្តដែលមិនមានសេចក្តីស្រឡាញ់ អញនឹងសម្តែងសេចក្តីស្រឡាញ់ដល់ស្តេចហង្សនេះ ដូច្នេះ បានពោលគាថា ៤ ថា

បពិត្រព្រះបាទធតរដ្ឋៈ ទូលព្រះបង្គំជាខ្ញុំ សូម្បីសេចក្តីទុក្ខគ្របសង្កត់ហើយ ក៏មិនគប្បីលះបោលព្រះអង្គ ជីវិតឬសេចក្តីស្លាប់របស់ទូលព្រះបង្គំជាខ្ញុំនឹងមានជាមួយព្រះអង្គ ។ បពិត្រព្រះបាទធតរដ្ឋៈ ទូលព្រះបង្គំជាខ្ញុំ សូម្បីសេចក្តីទុក្ខគ្របសង្កត់ហើយ ក៏មិនគប្បីលះបោលព្រះអង្គ ទាំងព្រះអង្គ ក៏មិនគួរប្រកបទូលព្រះបង្គំជាខ្ញុំក្នុងអំពើមិនប្រសើរទេ ។ ទូលព្រះបង្គំជាខ្ញុំ ជាកុមារមានវ័យស្មើគ្នា ជាសម្លាញ់នឹងព្រះអង្គ ឋិតនៅក្នុងអំណាចចិត្តរបស់ព្រះអង្គ ដែលជាចិត្តប្រព្រឹត្តទៅដោយប្រពៃ បពិត្រព្រះអង្គដ៏ប្រសើរខ្ពង់ខ្ពស់ជាងពួកនៃហង្ស ទូលព្រះបង្គំជាខ្ញុំ ប្រាកដជាសេនាបតីរបស់ព្រះអង្គ លុះទូលព្រះបង្គំជាខ្ញុំហើរទៅអំពីទីនេះ នឹងថ្លែងសេចក្តី ក្នុងកណ្តាលញាតិ ដោយប្រការដូចម្តេច បពិត្រព្រះអង្គ ដ៏ប្រសើរជាងពួកបក្សី ទូលព្រះបង្គំ លះបោលព្រះអង្គហើយ ទៅអំពីទីនេះ នឹងប្រាប់ ( ដំណឹង ) របស់ព្រះអង្គដូចម្តេច ទូលព្រះបង្គំ

នឹងលះបង់ជីវិតក្នុងទីនេះ មិនអាចនឹងធ្វើអំពើមិនប្រសើរទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធាហំ** សេចក្តីថា បពិត្រមហារាជ ខ្ញុំទោះ សេចក្តីទុក្ខផ្លូវកាយនិងសេចក្តីទុក្ខផ្លូវចិត្តពាល់ត្រូវហើយ ក៏មិនលះបង់ទ្រង់ ។ បទថា **អនរិយសំយុត្តេ** បានដល់ ប្រកបព្រមហើយ ដោយការមិនប្រសើរ ព្រោះកម្ម ដែលបុគ្គលទ្រុស្តមិត្តទាំងឡាយដែលមិនប្រសើរគប្បីធ្វើ ។ បទថា **កម្មេ** បានដល់ កម្មដែលត្រូវលះទ្រង់ជៀសចេញទៅ ។ បទថា **សកុមារោ** បានដល់ ជាកុមារស្មើគ្នា អធិប្បាយថា បដិសន្ធិក្នុងថ្ងៃតែមួយ ញាស់ក្នុងថ្ងៃតែមួយ ហើយធំធាត់ជាមួយគ្នា ។ បទថា **សខា ត្យស្មិ** បានដល់ ខ្ញុំជាសម្លាញ់ស្មើដោយកែវក្នែកស្តាំរបស់ព្រះអង្គ ។ បទថា **សចិត្តេ** បានដល់ ខ្ញុំតាំងនៅក្នុងចិត្តរបស់ព្រះអង្គ រមែងប្រព្រឹត្តទៅក្នុងអំណាចរបស់ព្រះអង្គ អធិប្បាយថា កាលព្រះអង្គនៅមានជីវិត ខ្ញុំក៏មានជីវិត បើព្រះអង្គអស់ជីវិត ខ្ញុំក៏អស់ជីវិតដូចគ្នា ។ បាលីថា **សំចិត្តេ** ដូច្នេះក៏មាន អធិប្បាយថា ខ្ញុំតាំងនៅល្អហើយក្នុងចិត្តរបស់ព្រះអង្គ ។ បទថា **ញាតោ** បានដល់ ស្គាល់ទូទៅប្រាកដក្នុងរវាងហង្សទាំងអស់ ។ បទថា **វិកត្ថិស្សំ** សេចក្តីថា ខ្ញុំត្រូវហង្សទាំងនោះសួរថា ស្តេចហង្សទៅណា នឹងប្រាប់ដូចម្តេច ។ បទថា **កិន្តេ វក្ខាមិ** សេចក្តីថា ខ្ញុំនឹងពោលជាមួយហង្សដែលសួរដំណឹងរបស់ព្រះអង្គដូចម្តេច ។

កាលសុមុខហង្សបន្លឺសីហនាទ ៤ គាថាយ៉ាងនេះហើយ ព្រះមហាសត្វកាលនឹងពោលគុណរបស់សុមុខហង្សនោះ ទើបពោលគាថានេះថា

ម្នាលសុមុខៈ នុ៎ះជាធម៌ ( របស់បោរាណកបណ្ឌិតទាំងឡាយ )
ព្រោះថា អ្នកឋិតនៅក្នុងគន្លងរបស់ជនដ៏ប្រសើរ មិនអាចលះ
បង់នូវយើង ដែលជាម្ចាស់ផង ជាសម្លាញ់ផង ។ ដ្បិតថា
កាលយើងសម្លឹងមើលអ្នក សេចក្តីភ័យ ក៏មិនកើតសោះទេ
អ្នកបានញុំាងយើង ដែលមានសភាពយ៉ាងនេះ ឲ្យបាននូវ
ជីវិត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឯសោ ធម្មោ** បានដល់ នេះជាសភាវៈនៃបណ្ឌិតទាំងឡាយក្នុងកាលមុន ។ បទថា **ភត្តារំ សខារំ មំ** បានដល់ អ្នកជាម្ចាស់ផង ជាសម្លាញ់ផង ។ បទថា **ភយំ** បានដល់ ភ័យ រមែងមិនកើតដល់ខ្ញុំ ដូចនៅក្នុងកណ្តាលពួកញាតិលើភ្នំចិត្តកូដ ដូច្នោះ ។ បទថា **មយ្ហំ** បានដល់ លោមនឹងឲ្យយើងរួចជីវិត ។

កាលហង្សទាំង ២ នោះ កំពុងពោលយ៉ាងនេះឯង លុទ្ទបុត្តឈរត្រង់មាត់ស្រះ ឃើញហង្សហើរទៅ ៣ ហ្វូងហើយ ទើបសម្លឹងមើលទីដែលខ្លួនដាក់អន្ទាក់ថា យ៉ាងម៉េចទៅហើយហ្ន៎ ឃើញព្រះពោធិសត្វសំយុងត្រង់ជងអន្ទាក់ មានសេចក្តីសោមនស្សកើតឡើង ចងក្បិនយ៉ាងតឹង កាន់ដំបង អើតក្បាលស្ទុះចូលទៅជិត ដូចភ្លើងប្រល័យកប្ប ។ ព្រះសាស្តា កាលទ្រង់ប្រកាសនូវសេចក្តីនោះ ទើបត្រាស់ថា

កាលដែលហង្សដ៏ប្រសើរ ( ពីរ ) មានការប្រព្រឹត្តដ៏ប្រសើរ
កំពុងប្រឹក្សាគ្នា យ៉ាងនេះ ដូច្នេះ នាយនេសាទកាន់ដំបង

ប្រញាប់មកដល់ភ្លាម ។ ហង្សឈ្មោះសុមុខៈ លុះបានឃើញនាយនេសាទនោះមកដល់ ក៏បិតនៅខាងមុខរាជហង្សហើយលួងលោមរាជហង្ស ដែលកំពុងភ័យ រួចបានស្រែកថា បពិត្រព្រះអង្គដ៏ប្រសើរជាងសត្វស្លាប ព្រះអង្គកុំភ័យឡើយ ព្រោះថាបក្សីទាំងឡាយប្រហែលព្រះអង្គ រមែងមិនភ័យទេ ទូលព្រះបង្គំជាខ្ញុំ នឹងប្រកបសេចក្តីព្យាយាមដ៏សមគួរ ដែលអាស្រ័យនូវធម៌ ព្រះអង្គនឹងរួចចាកអន្ទាក់ជាធាប់ ដោយសេចក្តីព្យាយាមនោះមិនខាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អរិយវុត្តិនំ** បានដល់ ប្រព្រឹត្តក្នុងគន្ធធម៌ដ៏ប្រសើរ ។ បទថា **កុសំ** បានដល់ មានកម្លាំងរឹងមាំ ។ បទថា **អតិព្រូហយិ** សេចក្តីថា សុមុខហង្សកាលពោលពាក្យថា ព្រះអង្គកុំខ្លាចឡើយដូច្នេះជាដើម ដែលមកហើយក្នុងគាថាដែលជាលំដាប់តទៅ បានហៅដោយសំឡេងខ្លាំង គឺបានបន្លឺសំឡេងខ្លាំង ។ បទថា **អជ្ឈាសិ** សេចក្តីថា សុមុខហង្សនោះ រមែងលះបង់ជីវិត ហើយឈរខាងមុខស្តេចហង្ស ដោយគិតថា បើនាយព្រានប្រហារស្តេចហង្ស អញនឹងទទួលការប្រហារនោះឯង ។ បទថា **វិស្សាសយំ** បានដល់ ឲ្យធូរស្បើយចិត្ត ។ បទថា **ព្យថំ** បានដល់ ស្តេចហង្សភ័យខ្លាចហើយ សុមុខហង្សបានលួងលោមស្តេចហង្សឲ្យស្រាកស្រាន្ត ដោយពាក្យថា **មាភាយិ** ដូច្នេះ ។ បទថា **តាទិសា** បានដល់ បុគ្គលដែលដល់ព្រមដោយវិជ្ជានិងសេចក្តីព្យាយាមដូចព្រះអង្គ ។ បទថា **យោគំ** បានដល់ ប្រកប

ដោយញាណវិរិយៈ ។ បទថា **យុត្តំ** បានដល់ សមគួរ ។ បទថា **ធម្មូប-សញ្ហិតំ** បានដល់ អាស្រ័យហេតុ ។ បទថា **តេន បរិយាបទាតេន** បានដល់ ដោយសេចក្តីព្យាយាម ដែលជាគ្រឿងប្រកបបរិសុទ្ធ ដូចខ្ញុំបានពោលហើយនោះ ។ បទថា **បមោក្ខសិ** បានដល់ ព្រះអង្គនឹងរួចផុត ។

សុមុខហង្សលួងលោមមហាសត្វឲ្យក្សេមក្សាន្តយ៉ាងនេះហើយ ទើបចូលទៅជិតនាយលុទ្ទបុត្ត បន្ទឺវាចាមនុស្សដ៏ពីរោះថា នែសម្លាញ់ លោកឈ្មោះអ្វីកាលព្រានឆ្លើយថា ម្នាលហង្សមានពណ៌ដូចមាស ខ្ញុំឈ្មោះខេមកៈ ទើបពោលថា នែខេមកៈសម្លាញ់ លោកកុំធ្វើនូវការសម្គាល់ថា ហង្សដែលជាប់ក្នុងអន្ទាក់នោះ ជាហង្សសាមញ្ញ ហង្សដែលជាប់អន្ទាក់នេះ គឺស្តេចហង្សធតរដ្ឋៈ ប្រសើរជាងហង្ស ៩៦០០០ ដល់ព្រមដោយញាណនិងសីលាចារវត្ត តាំងនៅក្នុងចំណែកនៃការសរសើរ ហង្សនេះ មិនគួរលោកសម្លាប់ឡើយ ខ្ញុំនឹងធ្វើកិច្ចដែលគួរធ្វើដោយសរីរៈនេះដល់លោក ស្តេចហង្សនោះមានពណ៌ដូចមាស ខ្ញុំក៏មានពណ៌ដូចមាសដូចគ្នា ខ្ញុំនឹងលះបង់ជីវិតរបស់ខ្លួន ដើម្បីជាប្រយោជន៍ដល់ស្តេចហង្សនេះ បើលោកបំណងយករោមស្លាបទាំងឡាយរបស់ហង្សនេះ ក៏សូមយករោមស្លាបរបស់ខ្ញុំចុះ បើបំណងយកស្បែក សរសៃ ឆ្អឹងណាមួយ ក៏សូមយកអំពីសរីរៈរបស់ខ្ញុំនេះឯង ឬបើលោកបំណងនឹងធ្វើស្តេចហង្សនេះឲ្យជាហង្សកីឡា គឺហង្សរបាំ ក៏សូមធ្វើខ្ញុំនេះឯង បើលោកបំណងឲ្យកើតទ្រព្យសូមយកស្តេចហង្សនោះលក់ទាំងរស់ ធ្វើទ្រព្យឲ្យកើតឡើង លោកកុំសម្លាប់ស្តេចហង្សដែលប្រកបដោយគុណ មានញាណជាដើមនេះឡើយ ព្រោះបើ

លោកសម្លាប់ស្តេចហង្សនេះ លោកមិនផុតចាកអបាយ មាននរកជាដើម ឡើយ ។ សុមុខហង្ស ពោលគំរាមនាយព្រាននោះ ដោយភ័យក្នុងអបាយ មាននរកជាដើម ឲ្យកាន់យកពាក្យដ៏ពីរោះរបស់ខ្លួន ហើយត្រឡប់ទៅកាន់សម្នាក់នៃព្រះពោធិសត្វវិញ លួងលោមឲ្យស្រាកស្រាន្តហើយឈរ ។ នាយនេសាទស្តាប់ពាក្យរបស់សុមុខហង្សនោះហើយ គិតថា ហង្សនេះជាសត្វតិរច្ឆាន គង់ធ្វើមិត្តធម៌បែបនេះ សូម្បីមនុស្សក៏មិនអាចធ្វើបានឡើយ ពិតហើយ សូម្បីពួកមនុស្សដូចគ្នា ក៏មិនអាចធ្វើមិត្តធម៌ បានយ៉ាងនេះ គួរអស្ចារ្យ ស្តេចហង្សនេះ ជាសត្វដល់ព្រមដោយបញ្ញា ពោលវាចាពីរោះ ឈ្មោះថាជាអ្នកសម្តែងធម៌ រមែងធ្វើសរីរៈទាំងមូលរបស់អញ ឲ្យពេញដោយបីតិនិងសោមនស្ស ព្រានមានលោមជាតិព្រឺហើយ បោះនូវដំបង ផ្គងអញ្ជលីលើក្បាល ដូចនមស្ការព្រះអាទិត្យ បានឈរពោលសរសើរគុណរបស់សុមុខហង្ស ។ ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

នាយនេសាទ បានឮសុភាសិតរបស់ហង្ស ឈ្មោះសុមុខៈ
នោះហើយក៏ព្រឺរោម បង្អោននូវអញ្ជលី ចំពោះហង្សឈ្មោះ
សុមុខនោះថា អ្នកជាបក្សី ពោលនូវភាសារបស់មនុស្ស
ពោលពាក្យដ៏ប្រសើរ បញ្ចេញនូវវាចា ជារបស់មនុស្ស
ដែលអញមិនធ្លាប់ឮ មិនធ្លាប់ឃើញ ។ បក្សីនេះត្រូវជាអ្វីនឹង
អ្នក អ្នកជាសត្វរួចហើយ ចូលមករកសត្វជាប់ ពួកបក្សី
ហើរចោលអស់ទៅហើយ ម្តេចក៏អ្នកក្រាញនៅតែម្នាក់ឯង

ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អញ្ជលិស្ស បណាមយិ** សេចក្ដីថា នាយព្រាន នោះផ្គងអញ្ជលីដល់សុមុខហង្សនោះ គឺធ្វើនូវការសរសើរសុមុខហង្សដោយ គាថាដែលជាលំដាប់តទៅ ។ បណ្ដាបទទាំងនោះ បទថា **មានុសឹ** បានដល់ ភាសាមនុស្ស ។ បទថា **អរិយំ** បានដល់ ល្អ មិនមានទោស ។ បទថា **ចជន្តោ** បានដល់ ពោល ។ មានពាក្យដែលលោកអធិប្បាយទុកថា នែសម្លាញ់អ្នក ជាបក្សី ក៏បានពោលភាសាមនុស្សជាមួយយើងក្នុងថ្ងៃនេះ ជាវាចាមិនមាន ទោស ជាភាសាមនុស្ស យើងឃើញហើយដោយប្រចក្ស ព្រោះថា វត្ថុដ៏ អស្ចារ្យនេះ យើងមិនធ្លាប់បានឮមក មិនធ្លាប់បានឃើញមក ក្នុងកាលមុនទេ ។ បទថា **កិន្នុ តាយំ** សេចក្ដីថា អ្នកចូលទៅជិតបក្សីណា បក្សីនោះជាអ្វីនឹង អ្នក ។ សុមុខហង្ស ត្រូវនាយព្រានមានចិត្តត្រេកអរសោកសួរ ដោយពាក្យ យ៉ាងនោះហើយ ទើបត្រិះរិះថា ព្រាននេះ ជាអ្នកមានចិត្តទន់ភ្លន់ កើតហើយ ឥឡូវនេះ អញនឹងសម្ដែងគុណរបស់អញ ដើម្បីឲ្យព្រាននេះ មានចិត្តទន់ ក្រៃលែងទៀត ទើបពោលថា

ឱព្រានព្រៃ ជាសត្រូវនឹងបក្សី ឯរាជហង្សនោះ ជាព្រះរាជា
របស់ខ្ញុំ ខ្ញុំជាសេនាបតីរបស់រាជហង្សនោះ ខ្ញុំមិនអាចលះ
បោលស្ដេចបក្សីនោះ ក្នុងកាលមានសេចក្ដីអន្តរាយទេ ។
ព្រះរាជារបស់ខ្ញុំនេះ ជាម្ចាស់នៃពួកហង្សដ៏ច្រើន កុំដល់នូវ
សេចក្ដីវិនាស តែម្នាក់ឯងឡើយ បពិត្រនាយនេសាទជា

សម្លាញ់ ព្រោះថា រាជហង្សនេះ ជាម្ចាស់ ខ្ញុំតែងត្រេកអរ
រីករាយ ( ក្នុងសំណាក់រាជហង្សនោះ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆុស្សហោ** បានដល់ ជាអ្នកមិនអាច ។ បទថា **មហាគណាយំ** បានដល់ របស់មហាគណៈហង្ស ។ បទថា **មា ឯកោ** សេចក្តីថា កាលអាមាត្យរាជសេវកៈដូចខ្ញុំនៅមាន សូមស្តេចហង្ស កុំវិនាសតែឯងឡើយ ។ បទថា **យថា តំ** បានដល់ ខ្ញុំពោលយ៉ាងណា ក៏យ៉ាងនោះឯង ។ បទថា **សខ្ម** បានដល់ មិត្តជាទីស្រឡាញ់ ។ បទថា **ភត្តាយំ អភិរតោ រមេ** សេចក្តីថា ស្តេចហង្សនេះជាម្ចាស់ទើបខ្ញុំត្រេកអរដល់ព្រះអង្គ ត្រេកអរក្នុងទីជិត មិននៀយណាយ ។

នាយនេសាទស្តាប់ពាក្យដ៏ពីរោះ ដែលអាស្រ័យធម៌ របស់សុមុខហង្ស នោះ ហើយកើតនូវសោមនស្ស ត្រេកអរ ព្រឺរោម ព្រឺស្បែក គិតថា បើអញសម្លាប់ស្តេចហង្សដែលប្រកបដោយគុណ មានសីលជាដើម យ៉ាងនេះ គង់មិនផុតចាកអបាយទាំង ៤ ទៅបានឡើយ ព្រះរាជាទ្រង់បំណងនឹងធ្វើអញយ៉ាងណា ក៏ចូរធ្វើអញយ៉ាងនោះចុះ អញនឹងធ្វើស្តេចហង្សនេះ ឲ្យជារង្វាន់ដល់សុមុខហង្ស ហើយលែងទៅ ទើបពោលគាថានេះថា

ម្នាលសត្វហង្ស អ្នកណាបានគោរពដុំអាហារ ( ដែលបាន
អំពីម្ចាស់ ) អ្នកនោះឈ្មោះថា ប្រព្រឹត្តធម៌ដ៏ប្រសើរ យើង
នឹងលែងនូវម្ចាស់របស់អ្នកនោះ អ្នកទាំង ២ ចូរទៅតាម
ស្រួលចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អរិយវុត្តិ** បានដល់ ជាអ្នកប្រកបហើយដោយវត្តរបស់បុគ្គលប្រសើរ ដោយអាចារទាំងឡាយ ពោលគឺការរក្សាមិត្តធម៌ ។ បទថា **យោ បិណ្ឌមបចាយសិ** សេចក្តីថា បុគ្គលណាបូជានូវដុំបាយ ដែលបានហើយអំពីសម្នាក់របស់ម្ចាស់ ។ បទថា **គច្ឆថូភោ** សេចក្តីថា អ្នកទាំង ២ ចូរញ៉ាំងពួកញាតិដែលមានមុខជោកដោយទឹកភ្នែក ឲ្យត្រេកអរ ហើយទៅតាមសប្បាយចុះ ។

នាយនេសាទកាលពោលយ៉ាងនេះហើយ ក៏ចូលទៅជិតមហាសត្វដោយចិត្តទន់ភ្លន់ ហើយបង្អោនដងអន្ទាក់មក ឲ្យឈរក្នុងកក់ ស្រាយមហាសត្វចេញអំពីដងអន្ទាក់ នាំចេញអំពីស្រះ ឲ្យទំលើស្បូវភ្លាំងខ្ចី ស្រាយអន្ទាក់ដែលរឹតត្រង់ជើងទាំង ២ ចេញ កើតនូវការស្រឡាញ់ក្នុងមហាសត្វយ៉ាងខ្លាំងក្លា ជងទឹកមកលាងឈាម ដែលប្រឡាក់ដោយមេត្តាចិត្ត ។ ខណៈនោះ ដោយអានុភាពនៃមេត្តារបស់នាយនេសាទនោះ សរសៃនិងសរសៃ សាច់និងសាច់ ស្បែកនិងស្បែក ក៏ជាប់គ្នា ជើងក៏ទៅជាប្រក្រតី មិនមានចំណែកខុសប្លែកជាមួយអវយវៈដទៃឡើយ ។ ព្រះពោធិសត្វដល់នូវសេចក្តីសុខហើយ ទំដោយភាពជាប្រក្រតីនោះឯង សុមុខហង្សឃើញស្តេចហង្ស បានទទួលសេចក្តីសុខ ព្រោះអាស្រ័យខ្លួន កើតនូវសោមនស្សគិតថា នាយនេសាទបានធ្វើឧបការៈដល់អញជាច្រើន ចំណែកអញ មិនទាន់មានឧបការៈដល់គេឡើយ បើនាយនេសាទនេះចាប់យកអញទៅ ដើម្បីជាប្រយោជន៍ដល់ព្រះរាជានិងអាមាត្យនៃព្រះរាជាជាដើម នាំទៅកាន់សម្នាក់របស់ឥស្សរជនទាំងនោះក៏

នឹងបានទ្រព្យច្រើន បើគេចាប់យកទៅដើម្បីជាប្រយោជន៍ដល់ខ្លួន គេលក់អញហើយ នឹងបានទ្រព្យដូចគ្នា អញនឹងសួរគេមើលសិន លំដាប់នោះ សុមុខហង្សកាលនឹងសួរនាយនេសាទនោះ ព្រោះភាពដែលខ្លួនប្រាថ្នានឹងធ្វើឧបការៈ ទើបពោលគាថានេះថា

នែសម្លាញ់ បើលោកដាក់អន្ទាក់ ពួកហង្សនឹងបក្សីដ៏សេស ដោយសេចក្ដីព្យាយាមរបស់ខ្លួន យើងខ្ញុំនឹងទទួលនូវអភយទាននេះរបស់លោក បើលោកមិនដាក់អន្ទាក់ពួកហង្ស និងបក្សីដ៏សេស ដោយសេចក្ដីព្យាយាមរបស់ខ្លួនទេ បពិត្រនាយនេសាទ លោកមិនមែនជាធំ កាលលែងនូវយើងខ្ញុំ ឈ្មោះថា ធ្វើនូវការលួច ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សចេ** សេចក្ដីថា នែអ្នកនេសាទសម្លាញ់ បើលោកដាក់អន្ទាក់ហង្ស និងបក្សីទាំងឡាយដោយប្រយោជន៍ខ្លួន គឺដើម្បីប្រយោជន៍ដល់ខ្លួន ។ បទថា **អនិស្សរោ** សេចក្ដីថា លោកមិនមានឥស្សរៈដែលនឹងលែងខ្ញុំឡើយ កាលលែងខ្ញុំ ទៅកាន់សម្នាក់របស់ជនដែលបញ្ជូលោកនោះ ក៏គប្បីធ្វើនូវការលួច អ្នកកុំធ្វើនូវបំណុលឡើយ នាយនេសាទស្ដាប់ពាក្យនោះ ទើបពោលថា ខ្ញុំមិនបានចាប់អ្នកទាំងឡាយ ដើម្បីប្រយោជន៍ដល់ខ្លួនឡើយ តែព្រះបាទពារាណសីព្រះនាមថា សំយមៈ មានព្រះតម្រាស់ឲ្យខ្ញុំចាប់ ហើយតំណាលរឿងទាំងអស់ ចាប់តាំងពីកាលដែលព្រះទេវីទ្រង់សុបិននិមិត្ត រហូតដល់ព្រះរាជាទ្រង់ជ្រាបភាព ដែលហង្សមាសទាំងនោះមក

ហើយ ទើបត្រាស់ថា នែខេមកៈសម្លាញ់ អ្នកចូរព្យាយាមចាប់ហង្ស ១-២ ឲ្យបាន យើងនឹងឲ្យយសធំដល់អ្នក ហើយប្រទានស្បៀងបញ្ជូនមក សុមុខហង្សស្តាប់រឿងនោះហើយ ក៏ត្រិះរិះថា នាយនេសាទនេះ មិនឃើញដល់ជីវិតខ្លួន លែងយើងទៅហើយ ឈ្មោះថា ធ្វើកិច្ចដែលអ្នកដទៃធ្វើបានដោយកម្រ បើអញទៅកាន់ក្ដិចិត្តកូដ អំពីទីនេះ អានុភាពនៃបុណ្យបារមីរបស់ស្ដេចហង្សធតរដ្ឋៈនិងមិត្តធម៌របស់អញក៏មិនប្រាកដ លុទ្ទបុត្តក៏មិនបានយសធំ ព្រះរាជាក៏មិនបានតាំងនៅក្នុងសីល ៥ សេចក្តីប្រាថ្នារបស់ព្រះទេវី ក៏មិនដល់ទីបំផុត ទើបពោលថា នែសម្លាញ់ បើដូច្នេះ លោកលែងខ្ញុំទៅមិនបាន លោកត្រូវបង្ហាញខ្ញុំដល់ព្រះរាជា ព្រះរាជាទ្រង់នឹងធ្វើខ្ញុំតាមព្រះហឫទ័យ ។

ព្រះសាស្ដា កាលទ្រង់ប្រកាសសេចក្ដីនោះ ទើបត្រាស់ថា

លោកជាបុគ្គលស៊ីឈ្នួល របស់ព្រះរាជាណា លោកចូរនាំ
យើងខ្ញុំឲ្យដល់ទៅព្រះរាជានោះ តាមប្រាថ្នាចុះ ព្រះរាជា
ព្រះនាមសំយមៈនិងធ្វើ តាមគាប់ព្រះទ័យ ក្នុងព្រះរាជ
និវេសន៍នោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តស្សេវ** សេចក្តីថា សូមលោកនាំខ្ញុំទៅកាន់សម្នាក់របស់ព្រះបាទសំយមរាជនោះចុះ ។ បទថា **តត្ថ** បានដល់ ក្នុងព្រះរាជនិវេសន៍នោះ ។ បទថា **យថាភិញ្ញាំ** សេចក្ដីថា ទ្រង់នឹងធ្វើតាមព្រះរាជបំណង គឺតាមគាប់ព្រះហឫទ័យ ។

នាយព្រានស្តាប់ពាក្យនោះ ទើបពោលថា អ្នកដ៏ចម្រើន អ្នកកុំគាប់ចិត្ត

ឲ្យព្រះរាជាទតឡើយ ឈ្មោះថា ព្រះរាជាទាំងឡាយ គួរខ្ចាប់ក្រលែងគប្បីធ្វើអ្នកឲ្យជាហង្សប្រចាំ ឬគប្បីសម្លាប់អ្នកចោល ។ លំដាប់នោះ សុមុខហង្ស ក៏ពោលនឹងនាយនេសាទនោះថា បពិត្រលោកនេសាទ លោកឲ្យនូវជីវិត លោកកុំគិតពីខ្ញុំឡើយ ខ្ញុំបានធ្វើមនុស្សគ្រោតគ្រាតអម្បាលលោកឲ្យទោរទន់ដោយធម្មកថា ចំណង់បើព្រះរាជា តើមិនទោរទន់ឯណាបាន ព្រោះថា ព្រះរាជាទាំងឡាយជាអ្នកឈ្លាស ដឹងនូវវាចាជាសុភាសិត ឬជាទុព្ភាសិត លោកនាំយើងទាំង ២ ទៅកាន់សម្នាក់របស់ព្រះរាជា ដោយរហ័សចុះ តែកាលនាំទៅ កុំនាំទៅដោយការចង សូមញុំាងខ្ញុំឲ្យទំក្នុងទ្រុងផ្កា ហើយនាំទៅម្យ៉ាងទៀត បើលោកធ្វើទ្រុងផ្កា សូមធ្វើទ្រុងស្តេចហង្សធតរដ្ឋៈឲ្យធំ រចនាដោយផ្កាឈូកពណ៌ស ឯខ្ញុំធ្វើឲ្យតូច រចនាដោយឈូកពណ៌ក្រហម ហើយរែកស្តេចហង្សធតរដ្ឋៈដាក់ខាងមុខ ឯខ្ញុំដាក់ខាងក្រោយ ធ្វើខ្ញុំឲ្យទាបបន្តិច ហើយសូមនាំទៅបង្ហាញដល់ព្រះរាជាដោយរួសរាន់ចុះ ។ នាយព្រាននោះស្តាប់ពាក្យរបស់សុមុខហង្សនោះហើយទើបគិតថា សុមុខហង្សប្រាថ្នាគាល់ព្រះរាជា ឲ្យប្រទានយសធំដល់អញ កើតសោមនស្សត្រេកអរ យកវល្លិទន់ៗមកធ្វើជាទ្រុងលម្អដោយផ្កាឈូកហើយ នាំទៅដោយន័យដូចពោលហើយនោះឯង ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

លុះហង្សឈ្មោះសុមុខៈ និយាយយ៉ាងនេះហើយ នាយនេសាទ

ក៏យកដៃស្ទួយនូវហង្សទាំង ២ ដែលមានសម្បុរនិងស្បែក

ដូចមាស ហើយដាក់ទៅក្នុងទ្រុង ។ ព្រានព្រៃបាននាំយក បក្សី ឈ្មោះសុមុខៈ ១ ឈ្មោះធតរដ្ឋៈ ១ ទាំង ២ មាន សម្បុរដ៏ភ្លឺផ្លេក ទំនៅក្នុងទ្រុងនោះ ហើយចៀសចេញទៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អជ្ឈាបេន្ទហិ** បានដល់ ដាក់ចុះហើយ គឺ តម្កល់ទុកហើយ ។ បទថា **ភស្សរវណ្ណិនេ** បានដល់ មានពណ៌សម្បុរដល់ ព្រមដោយរស្មី ។

ក្នុងកាលដែលនាយលុទ្ទបុត្តនាំហង្សទាំង ២ ទៅដោយអាការយ៉ាងនេះ ស្តេចហង្សធតរដ្ឋៈរឭកដល់ព្រះរាជធីតា របស់ស្តេចបាកហង្សដែលជាករិយា របស់ខ្លួន ទើបហៅសុមុខហង្ស ហើយកន្ទក់កន្ទេញដោយអំណាចកិលេស ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

រាជហង្សឈ្មោះធតរដ្ឋៈ ដែលព្រានព្រៃកំពុងនាំទៅ បាន ពោលពាក្យនេះនឹងហង្សឈ្មោះសុមុខៈថា ម្នាលសុមុខៈ ខ្ញុំ ខ្លាច ( សេចក្តីស្លាប់ ) នៃនាងបក្សីឈ្មោះសុហេមា ដែល មានសម្បុរដូចមាស មានភ្លៅប្រកបដោយលក្ខណៈខ្លាំង ណាស់ តែនាងសុហេមាបានដឹងថា គេសម្លាប់នូវយើងទាំង ២ ហើយ មុខជានឹងសម្លាប់នូវខ្លួនដែរ ។ ម្នាលសុមុខៈ នាងបក្សី ឈ្មោះសុហេមាជាធីតានៃបាកហង្ស ដែលមាន ស្បែកល្អដូចមាស ជាសត្វកំព្រាទួញយំដោយពិត ដូចជា

ក្រៀលញី ទួញយំប្របនេ្ទរសមុទ្ទដូច្នោះ ។

បណ្ដាបទទាំងនោះ បទថា **ភាយាមិ** សេចក្ដីថា ខ្ញុំខ្លាចចំពោះមរណ-ភ័យ ។ បទថា **សាមាយ** បានដល់ ព្រោះនាងមានពណ៌សម្បុរដូចមាស ។ បទថា **លក្ខណូរុយា** បានដល់ មានភ្លៅដល់ព្រមដោយលក្ខណៈ ។ បទថា **វធមញ្ញាយ** សេចក្ដីថា កាលនាងដឹងថា យើងត្រូវសម្លាប់ គឺជាអ្នកមានសេចក្ដីសម្គាល់ថា ប្ដីជាទីស្រឡាញ់របស់យើងត្រូវគេសម្លាប់ហើយ ។ បទថា **វធិស្សតិ** សេចក្ដីថា នឹងសម្លាប់ខ្លួនដោយគិតថា កាលប្ដីជាទីស្រឡាញ់របស់អញស្លាប់ហើយ ប្រយោជន៍អ្វីដោយអញនៅមានជីវិត ។ បទថា **ធាតរដ្ឋា** បានដល់ ជាបុត្រីរបស់ស្ដេចបាកហង្ស ។ បទថា **សុហេមា** បានដល់ រាជធីតាមានឈ្មោះយ៉ាងនេះ ។ បទថា **ហេមសុត្តចា** បានដល់ មានពណ៌ស្បែកល្អដូចមាស ។ បទថា **កោញ្ចី** សេចក្ដីថា នាងគង់យំសោកដោយពិត ដូចក្រៀលញី កាលប្ដីលិចក្នុងទឹកសមុទ្ទ ពោលគឺ ទឹកប្រៃស្លាប់ហើយ ក៏រមែងយំសោកដូច្នោះឯង ។

សុមុខហង្សបានស្ដាប់ពាក្យនោះហើយ ទើបគិតថា ស្ដេចហង្សនេះ ជាអ្នកសមគួរទូន្មានអ្នកដទៃ មកកន្ទក់កន្ទេញដោយអំណាចកិលេស ព្រោះអាស្រ័យមាតុគ្រាម ហាក់បីដូចពេលដែលទឹកមានអាការក្ដៅ និងដូចពេលដែលស្រែមិនមានរបង ត្រូវសត្វចូលស៊ី បើដូច្នេះ អញនឹងប្រកាសទោសមាតុគ្រាម ដោយកម្លាំងញាណរបស់ខ្លួន គប្បីញ៉ាំងស្ដេចហង្សនេះឲ្យដឹង ទើបពោលគាថានេះថា

ព្រះអង្គជាធំជាងហង្ស មានគុណប្រមាណមិនបាន ជាម្ចាស់នៃហ្វូងហង្សជាច្រើន យ៉ាងនេះ ហើយសោកស្តាយនូវមេហង្ស ១ ការយំនេះ ហាក់ដូចជាមិនសមគួរដល់ព្រះអង្គ ដែលមានប្រាជ្ញាឡើយ ។ ព្រះអង្គសោកស្តាយ ព្រោះតែស្ត្រីទាំងឡាយ ធម្មតាស្ត្រីទាំងឡាយ ដូចជាខ្យល់គួចយកនូវក្លិនទាំងល្អទាំងអាក្រក់ទាំង ២ ឬដូចជាក្មេងល្ងង់ ចាប់យកផ្លែឈើទាំងខ្ចីទាំងទុំ ពុំនោះសោតដូចមនុស្សខ្វាក់ ជាអ្នកស្រេកឃ្លានកាន់យកអាមិសៈ ( ទាំងល្អទាំងអាក្រក់ ) ។ ព្រះអង្គមិនដឹងនូវការវិនិច្ឆ័យ ក្នុងប្រយោជន៍ទាំងឡាយ ដូចជាមនុស្សល្ងង់ប្រាកដដល់ទូលព្រះបង្គំ លុះដល់កាលជាទីស្លាប់ នៅតែមិនដឹងអំពើដែលគួរធ្វើនិងមិនគួរធ្វើឡើយ ។ ព្រះអង្គជាបុគ្គលធ្លាក់កណ្តាល និយាយផ្តេសផ្តាស ព្រោះថា ព្រះអង្គសម្គាល់នូវស្ត្រីទាំងឡាយថា ប្រសើរបំផុត ព្រោះថា ស្ត្រីទាំងនេះ ជាសាធារណៈដល់ជនច្រើន ដូចជារោងសុរាជាសាធារណៈដល់ពួកអ្នកលេង ។ មួយទៀត ស្ត្រីទាំងនេះមានមាយាដូចជាថ្លៃបណ្តើរកូន ជាទីសោយសោក ជាទីកើតនៃរោគ ជាទីឧបទ្រព ស្ត្រីទាំងនេះមានអធ្យាស្រ័យដ៏រឹងរូសជាចំណងសម្រាប់ចង ជាអន្ទាក់នៃសេចក្តីស្លាប់ ជាគុហាសម្រាប់នៅ ( របស់មច្ចុរាជ ) បុរសណា ទុកចិត្តក្នុងស្ត្រី

ទាំងនោះ បណ្តាបុរសទាំងឡាយ បុរសនោះឈ្មោះថា បុរស ថោកទាប ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មហាឆ្គោ** បានដល់ ជាអ្នកធំក្រៃលែង ។ បទថា **លោកស្ស** បានដល់ នៃលោករបស់ពួកហង្ស ។ បទថា **អប្បមេយ្យោ** បានដល់ បុគ្គលណាមួយ មិនអាចប្រមាណគុណទាំងឡាយបាន ។ បទថា **មហាគណី** បានដល់ ជាគ្រូរបស់គណៈ ដែលជាមហាគណៈ ។ បទថា **ឯកិត្ថី** សេចក្តីថា សុមុខហង្សពោលដោយបំណងថា ទ្រង់ចម្រើនបែបនេះ តែនៅសោយសោកដល់ស្រីម្នាក់ ការសោយសោកនោះ មិនមែនរបស់អ្នកមានបញ្ញាឡើយ ព្រោះដូច្នោះ ទើបខ្ញុំមានសេចក្តីសម្គាល់ទ្រង់ថា ជាសត្វល្ងង់ខ្លៅក្នុងថ្ងៃនេះឯង ។ បទថា **អាទេតិ** បានដល់ រមែងកាន់យក ។ បទថា **ធេកចាបកំ** បានដល់ ទាំងល្អទាំងអាក្រក់ ។ បទថា **អាមកបក្កំ** បានដល់ ខ្ចីផង ទុំផង ។ បទថា **លោលោ** បានដល់ ល្មោភក្នុងរស ។ មានពាក្យអធិប្បាយទុកថា បពិត្រមហារាជ ចម្មតាខ្យល់ រមែងបក់ស្រះផ្កាឈូកជាដើម ដែលមានក្លិនក្រអូប និងបក់ទីដែលពេញដោយគំនរសំរាមជាដើម ដែលមានក្លិនស្អុយ តែងបក់យកក្លិនទាំង ២ យ៉ាង ដោយប្រការនេះ យ៉ាងណា ម្យ៉ាងទៀត កុមារតូចៗ អង្គុយក្រោមដើមស្វាយ និងដើមព្រីងទាំងឡាយ លាដៃចាប់ផ្លែឈើ ទាំងខ្ចីទាំងទុំដែលជ្រុះមក ហើយទំពាស៊ី យ៉ាងណា ម្យ៉ាងទៀត មនុស្សខ្វាក់ ដែលល្មោភក្នុងរសអាហារ កាលគេយកកត្តមកឲ្យ រមែងកាន់យកអាហារ ទាំងមានសត្វល្អិត និងមិនមានសត្វល្អិតគ្រប់យ៉ាង យ៉ាងណា

ឈ្មោះថា ស្រីទាំងឡាយ រមែងកាន់យក គឺរមែងគប់រកសូម្បីមនុស្សខ្វាក់ មនុស្សក្រីក្រ មនុស្សមានត្រកូលខ្ពស់ មនុស្សមានត្រកូលទាប មនុស្សរូបស្អាត មនុស្សរូបអាក្រក់ទាំងអស់ ដោយអំណាចកិលេសដូច្នោះដូចគ្នា បពិត្រមហារាជ ព្រះអង្គមកយំសោក ព្រោះហេតុនៃស្រីទាំងឡាយ ជាអ្នកមានធម៌ដ៏លាមក ដូចគ្នានឹងខ្យល់ ក្មេងតូចៗ និងមនុស្សក្អែកខ្វាក់ ។ បទថា **អត្ថេសុ** បានដល់ ទាំងហេតុនិងមិនមែនហេតុ ។ បទថា **មន្ទោ** បានដល់ អន្ធពាល ។ បទថា **បដិភាសិ មំ** បានដល់ រមែងតាំងឡើងដល់ខ្ញុំ ។ បទថា **កាល-បរិយាយំ** សេចក្តីថា ទ្រង់ដល់ពេលជិតមរណៈបែបនេះហើយ នៅមិនដឹងទៀតថា ក្នុងកាលនេះ របស់នេះគួរធ្វើ របស់នេះមិនគួរធ្វើ របស់នេះគួរពោល របស់នេះមិនគួរពោល ។ បទថា **អឌ្ឍម្មត្តោ** បានដល់ ប្រហែលជាឆ្កួតពាក់កណ្តាល ។ បទថា **ឧធីរេសិ** សេចក្តីថា ព្រះអង្គរវើរវាយ ដូចបុរសដែលផឹកស្រាហើយ តែមិនស្រវឹងពេក រវើរវាយដល់របស់នោះខ្លះ ដល់របស់នេះខ្លះ មានប្រការផ្សេងៗ ។ បទថា **សេយ្យា** បានដល់ ប្រសើរ គឺឧត្តម ។ បណ្តាបទទាំងឡាយ បទថា **មាយា ច** ជាដើម សេចក្តីថា ឈ្មោះថា ស្រីទាំងឡាយ ជាអ្នកមានមាយា ដោយអត្ថថា បោកបញ្ឆោត ប្រៀបដូចថ្ងៃបណ្តើរកូន ដោយអត្ថថា ជាវត្ថុដែលបុគ្គលណាមួយ ចូលទៅចាប់មិនបាន ជាអ្នកមានសេចក្តីសោក ព្រោះជាបច្ច័យនៃសេចក្តីសោកជាដើម ជាអ្នកមានរោគ និងមានអន្តរាយជាអនេក ទាំងឈ្មោះថា ជាមនុស្សគ្រោតគ្រាត ព្រោះរឹងត្អឹងដោយអំណាចនៃកិលេស មានសេចក្តីក្រោធជាដើម មួយវិញទៀត ឈ្មោះ

ថា ស្រីទាំងនេះ ជាគ្រឿងចង ព្រោះបុគ្គលដែលត្រូវចងដោយចំណង មានខ្នោះជាដើម ក៏ព្រោះអាស្រ័យស្រីទាំងនោះ ម្យ៉ាងទៀត ស្រីទាំងនោះ ឈ្មោះថាជាស្តេចមច្ចុរាជ ដែលស្ថិតនៅក្នុងគុហា គឺសរីរៈ ព្រោះហេតុនោះ គប្បីសម្តែងសេចក្តីថា ព្រះរាជាចាប់ចោរទាំងឡាយបានហើយ ក៏កាត់ក្បាលដោយពូថៅដ៏មុត ហើយដោតត្រង់ចុងលំពែង ក៏ព្រោះចោរទាំងនោះ អាស្រ័យកាមជាហេតុ មានកាមជាមូល មានកាមជាកិច្ចដែលគួរធ្វើនោះឯង ។

លំដាប់នោះ ស្តេចហង្សធតរដ្ឋៈព្រោះខ្លួនជាអ្នកមានចិត្តវង្វេងក្នុងមាតុគ្រាម កាលនឹងសម្តែងថា ឯងមិនទាន់ដឹងគុណរបស់មាតុគ្រាម ពួកបណ្ឌិតប៉ុណ្ណោះទើបដឹង បុគ្គលណាក៏ដោយមិនគួរតិះដៀលស្រីទាំងនោះឡើយ ទើបពោលគាថាទាំងនេះថា

( វត្ថុគឺស្ត្រី ) ណា ដែលពួកជន អ្នកចម្រើនដោយប្រាជ្ញាបញ្ញាត្តហើយ បុគ្គលណា គួរតិះដៀលនូវស្ត្រីនោះបាន ធម្មតាស្ត្រីទាំងឡាយ មានគុណច្រើន ហើយកើតឡើងក្នុងលោក ( មុនគេ ) ។ ល្បែងគេតាំងទុកក្នុងស្ត្រីទាំងនោះ សេចក្តីត្រេកអរក៏តាំងនៅក្នុងស្ត្រីទាំងនោះដែរ ពូជទាំងឡាយរមែងលូតលាស់ឡើងក្នុងស្ត្រីទាំងនោះ គឺពួកសត្វទាំងអស់ តែងកើត ( ត្រូវអាស្រ័យស្ត្រីទាំងនោះ ) បុរសដូចម្តេច ប្តូរជីវិតដោយជីវិតហើយ គប្បីនឿយណាយក្នុងស្ត្រីទាំងនោះ ។ ម្នាលសុមុខៈ អ្នកឯងហ្នឹងហើយ មិនមែនជាអ្នកដទៃ រមែង

ប្រកបក្នុងប្រយោជន៍ ចំពោះពួកស្ត្រី ភ័យកើតឡើងដល់អ្នក ក្នុងថ្ងៃនេះ គំនិតរបស់អ្នកក៏កើតឡើងដោយសេចក្តីភ័យ ។ ជនទាំងអស់ ដល់នូវសេចក្តីសង្ស័យ ក្នុងជីវិតហើយ ជាអ្នករន្ធត់ ប្រឹងអត់ទ្រាំនូវសេចក្តីខ្លាច ចំណែកពួកបណ្ឌិត ជាអ្នកឋិតនៅ ក្នុងទីដ៏ប្រសើរ តែងប្រកបក្នុងប្រយោជន៍ ដែលគេប្រកបបានដោយក្រ ។ ព្រះរាជាទាំងឡាយ តែងប្រាថ្នានូវមន្ត្រីដែលមានសេចក្តីក្លៀវក្លា ដើម្បីប្រយោជន៍ ការពារនូវអន្តរាយនេះ ព្រោះមន្ត្រីដែលក្លៀវក្លា រមែងឃាត់នូវសេចក្តីអន្តរាយ និងការពារនូវខ្លួនបាន ។ ពួកពិសេសរបស់ព្រះរាជាកុំរំខានូវយើងក្នុងរោងគ្រួក្នុងថ្ងៃនេះ យ៉ាងណា ( អ្នកចូរធ្វើ ) យ៉ាងនោះចុះ ដ្បិតសម្បុរស្លាបសម្លាប់អ្នក ( និង ) យើងដូចផ្លៃឫស្សី សម្លាប់នូវដើមឫស្សី ។ អ្នករួច ( ជាមួយនឹងយើង ) ហើយ មិនចង់ហើរទៅ ចូលមករកចំណាំងដោយខ្លួនឯងវិញ ថ្ងៃនេះ អ្នកនោះដល់នូវសេចក្តីសង្ស័យ ( ក្នុងជីវិត ) អ្នកចូរកាន់យកនូវប្រយោជន៍ចុះ កុំបានតែមាត់ឡើយដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យំ** សេចក្តីថា វត្ថុ ពោលគឺមាតុគ្រាមណា ដែលលោកអ្នកចម្រើនដោយបញ្ញាទាំងឡាយបញ្ញត្តហើយ គឺប្រាកដដល់លោកទាំងនោះឯង មិនបានប្រាកដដល់ពួកជនពាល ។ បទថា **មហាភូតា**

បានដល់ មានគុណច្រើន គឺមានអានិសង្សច្រើន ។ បទថា **ឧបបជ្ជិសុំ** សេចក្តីថា កើតមុន ព្រោះភេទស្រីប្រាកដមុនក្នុងបឋមកប្ប ។ បទថា **តាសុ** សេចក្តីថា នែបាសុមុខៈ ការផ្គងកាយនិងផ្គងវាចា ដែលបុគ្គលតាំងមាំ គឺកប់ទុកក្នុងស្រីទាំងនោះ ការត្រេកអរក្នុងកាមគុណក៏តាំងនៅក្នុងស្រីទាំងនោះដែរ ។ បទថា **វីជានិ** សេចក្តីថា ពូជ មានព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះអរិយសាវកនិងស្តេចចក្រពត្តិក៏រមែងកើតឡើងក្នុងស្រីទាំងនោះ ។ បទថា **យទិទំ** បានដល់ សត្វទាំងអស់នេះ ។ បទថា **បជាយរេ** សេចក្តីថា ស្តេចហង្ស រមែងសម្តែងថា សត្វទាំងអស់ រមែងចម្រើនព្រមហើយ ក្នុងផ្ទៃរបស់ស្រីទាំងនោះឯង ។ បទថា **និព្វិជេ** បានដល់ អស់នូវការអាល័យ ។ បទថា **ចាណាមាសជ្ជចាណភិតិ** សេចក្តីថា បុគ្គលណាដែលយកជីវិតរបស់ខ្លួន ប្រឡូកប្រឡំជាមួយជីវិតរបស់ស្រីទាំងនោះ ដល់នូវការលះបង់ជីវិតរបស់ខ្លួន ទើបបានស្រីនោះមក ហើយគប្បីនឿយណាយបាននោះ ។ បទថា **ឆាញ្ញោ** សេចក្តីថា នែបាសុមុខៈ អ្នកមិនត្រូវពោលដល់ស្រីដទៃ កាលយើងនៅក្នុងកណ្តាលពួកហង្សត្រង់ភ្នំចិត្តកូដ មិនឃើញឯង ទើបសួរថា ហង្សឈ្មោះសុមុខៈទៅណា ហង្សទាំងឡាយឆ្លើយថា សុមុខហង្សនាំមាតុគ្រាមទៅដោយសេចក្តីត្រេកអរក្នុងគុហាមាស បានោះឯង រមែងប្រកបក្នុងប្រយោជន៍របស់ស្រីទាំងឡាយយ៉ាងនេះ គឺជាអ្នកប្រកបហើយ ប្រកបទូទៅហើយនោះឯង មិនចាំបាច់ពោលដល់អ្នកដទៃ ។ បទថា **តស្ស ត្យជ្ជ** សេចក្តីថា ស្តេចហង្សនោះពោលដូច្នេះដោយសំដៅថា កាលសេចក្តីខ្លាចស្លាប់កើតឡើងដល់ឯងក្នុងថ្ងៃនេះ ប្រហែល

ជាឯង ខ្លាចមរណភ័យនេះ ទើបកើតការគិតល្អិតល្អន់ ហើយសម្តែងដល់ទោសរបស់មាតុគ្រាមនេះឡើង ។ បទថា **សព្វោ ហិ** បានដល់ បុគ្គលណាមួយ ។ បទថា **សំសយំ បត្តោ** បានដល់ ជាអ្នកដល់នូវសេចក្តីសង្ស័យក្នុងជីវិត ។ បទថា **ភីរុ** បានដល់ ជាអ្នកមានសេចក្តីតក់ស្លុត រម្ងាប់នូវការខ្លាចបាន ។ បទថា **មហន្តានោ** សេចក្តីថា ឯជនណាជាបណ្ឌិតផង តាំងនៅក្នុងឋានៈធំផង ព្រោះដូច្នោះ ទើបឈ្មោះថា **មហន្តានោ** ។ បទថា **អត្ថេ យុញ្ជន្តិ ទុយ្យុជេ** សេចក្តីថា ជនទាំងនោះរមែងប្រកប គឺបន្តព្យាយាមក្នុងប្រយោជន៍ដែលប្រកបបាន ព្រោះហេតុនោះ ស្តេចធតរដ្ឋៈកាលឲ្យកើតនូវឧស្សាហៈ ទើបពោលយ៉ាងនេះថា នែបា កុំខ្លាចឡើយ ចូរបាជាអ្នកប្រាជ្ញចុះ ។ បទថា **អាបទំ** សេចក្តីថា អ្នកក្លាហាន រមែងការពារបាននូវអន្តរាយ ដែលមកដល់ម្ចាស់ ព្រោះដូច្នោះ ទើបព្រះរាជាទាំងឡាយទ្រង់ប្រាថ្នាបុគ្គលដែលក្លាហាន ដើម្បីប្រយោជន៍យ៉ាងនេះឯង ។ បទថា **អត្ថបរិយាយំ** អធិប្បាយថា ម្យ៉ាងទៀត អ្នកក្លាហាននោះ រមែងធ្វើការរក្សាខ្លួនឯងបានផង ។ បទថា **វិក្កន្តិសុ** បានដល់ វះហើយ ។ មានពាក្យដែលលោកអធិប្បាយទុកថា នែសុមុខៈសម្លាញ់ យើងតែងតាំងឯងទុកក្នុងតំណែងបន្ទាប់ពីយើង ព្រោះដូច្នោះចុងភៅរបស់ព្រះរាជា កុំធូតសាច់យើងទាំង ២ ដើម្បីសាច់ក្នុងថ្ងៃនេះ ដោយប្រការណា ចូរអ្នកធ្វើដោយប្រការនោះចុះ ព្រោះថា ពណ៌នៃរោមស្លាបរបស់យើងទាំងឡាយ នឹងសម្លាប់អ្នកបាន ។ បទថា **តំ វធិ** សេចក្តីថា ស្តេចហង្សពោលដោយបំណងថា ពណ៌សម្បុរយ៉ាងនេះ នឹងសម្លាប់អ្នកដូច

ផ្លែឫស្សីដែលអាស្រ័យដើមឫស្សីកើតឡើង ក៏រមែងសម្លាប់ឫស្សី ដូច្នោះ គឺពណ៌សម្បុរយ៉ាងនេះ កុំសម្លាប់អ្នកនិងយើងឡើយ ។ បទថា **មុត្តោបិ** សេចក្តីថា អ្នកជាបុគ្គលដែលលុទ្ទបុត្តដោះលែងហើយ គឺលះបង់ហើយ ជាមួយយើងដោយពាក្យយ៉ាងនេះថា ចូរអ្នកត្រឡប់ទៅ កាន់ក្នុំចិត្តកូដតាមសប្បាយចុះ ដូច្នេះហើយ កុំប្រាថ្នាជាប់អន្ទាក់ទៀតឡើយ ។ បទថា **សយំ** អធិប្បាយថា បាប្រាថ្នាគាល់ព្រះរាជា ឈ្មោះថា ចូលដល់ការសម្លាប់ខ្លួនឯងនោះឯង ភ័យរបស់យើងទាំងនេះមកហើយ ព្រោះអាស្រ័យបាយ៉ាងនេះ ។ បទថា **សោសជ្ជ** សេចក្តីថា ក្នុងថ្ងៃនេះ បាដល់នូវសេចក្តីសង្ស័យក្នុងជីវិតហើយ ។ បទថា **អត្ថំ គណ្ហាហិ មា មុធំ** សេចក្តីថា ចូរបាកាន់យកហេតុដែលឲ្យលែងពួកយើង ក្នុងឥឡូវនេះចុះ គឺយើងទាំង ២ នឹងរួចផុតបានដោយប្រការណា ចូរព្យាយាមដោយប្រការនោះចុះ ឯងពោលពាក្យជាដើមថា ខ្យល់រមែងផាត់ក្លិនក្រអូបនិងក្លិនស្អុយ យ៉ាងណា ដូច្នេះ ចូរឯងកុំបានតែមាត់ខាងតិះដៀលស្រីឡើយ ។

មហាសត្វ កាលសរសើរមាតុគ្រាមយ៉ាងនេះហើយ បានធ្វើឲ្យសុមុខហង្សអស់ពាក្យពោលឆ្លើយបាន ដឹងថា សុមុខហង្សនោះមានការអាក់អន់ចិត្តកាលពោលសរសើរសុមុខហង្សក្នុងកាលនោះ ទើបពោលគាថាបន្តថា

> អ្នកនោះ ចូរប្រកបព្យាយាមដ៏សមគួរ ប្រកបដោយធម៌
> ប្រព្រឹត្តនូវការស្វែងរកនូវជីវិត ឲ្យដល់យើងដោយព្យាយាម
> របស់អ្នកចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សោ** សេចក្តីថា ម្នាលសុមុខសម្លាញ់បា នោះឯង ។ បទថា **យោគំ** សេចក្តីថា ឥឡូវនេះ ចូរបាប្រកបព្យាយាម ដែលអ្នកធ្លាប់ពោលទុកក្នុងកាលមុនហើយថា ខ្ញុំនឹងប្រកបសេចក្តីព្យាយាម ដែលសមគួរដែលប្រកបដោយធម៌ ។ បទថា **តវ បរិយាបទានេន** គឺដោយ សេចក្តីព្យាយាមជាគ្រឿងប្រកបដ៏បរិសុទ្ធិរបស់បានោះ ។ បាលីថា **បរិយោ–ទានេន** ដូច្នេះក៏មាន ។ អធិប្បាយថា ដោយការការពារ អធិប្បាយថា អ្នក ចូរប្រព្រឹត្តរកឱកាសឲ្យយើងរួចជីវិត ដោយការការពារ ដែលជារបស់អ្នក ព្រោះអ្នកធ្វើឯង ។

សុមុខហង្សបានស្តាប់ពាក្យនោះ ទើបគិតថា ស្តេចហង្សខ្លាចចំពោះ មរណភ័យពេកណាស់ មិនដឹងកម្លាំងរបស់អញ អញនឹងគាល់ព្រះរាជា បាន សន្ទនាតិចតួចហើយនឹងដឹង អញនឹងឲ្យស្តេចហង្សនេះធូរស្បើយជាមុន ទើប ពោលគាថានេះថា

> បពិត្រព្រះអង្គដ៏ប្រសើរជាងសត្វស្លាប ព្រះអង្គកុំខ្លាចឡើយ
> ដ្បិតសត្វទាំងឡាយ ប្រហែលព្រះអង្គ រមែងមិនខ្លាចទូល
> ព្រះបង្គំជាខ្ញុំ នឹងប្រកបនូវព្យាយាមដ៏សមគួរ ប្រកបដោយ
> ធម៌ ព្រះអង្គនឹងរួចចាកអន្ទាក់យ៉ាងឆាប់ ដោយព្យាយាម
> របស់ទូលព្រះបង្គំជាខ្ញុំ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចាសា** បានដល់ អន្ទាក់ គឺសេចក្តីទុក្ខ ។ កាលស្តេចហង្សទាំង ២ នោះ សន្ទនាគ្នាដោយភាសារបស់បក្សីដូច្នេះ លុទ្ទ–

បុត្តមិនបានដឹងរឿងអ្វីឡើយ បានតែនាំស្តេចហង្សទាំង ២ នោះទៅដោយជន វែក ក៏ចូលទៅកាន់នគរពារាណសីតែម្យ៉ាង នាយព្រាននោះ ត្រូវមហាជនទះដៃអស្ចារ្យដែលមិនធ្លាប់មាន ក៏ទៅដល់ទ្វារព្រះរាជវាំង ក្រាបទូលភាពដែលខ្លួនមកដល់ហើយដល់ព្រះរាជា ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

ព្រានព្រៃនោះ បានចូលទៅកាន់ទ្វារ ព្រះរាជវាំងទាំងអម្រែក

ហង្ស ( ពោលថា ) អ្នកទាំងឡាយ ចូរក្រាបទូលព្រះរាជា

ថា ខ្ញុំជារាជហង្សឈ្មោះធតរដ្ឋៈ នេះមកហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បដិវេទេថ មំ** សេចក្តីថា ព្រានចូលទៅប្រាប់ព្រះរាជាថា អ្នកទាំង ២ ចូរក្រាបទូលដល់ព្រះរាជាយ៉ាងនេះថា នាយព្រានខេមកៈមកហើយ ។ បទថា **ធតរដ្ឋាយំ** សេចក្តីថា ចូរក្រាបទូលឲ្យទ្រង់ជ្រាបថា ស្តេចហង្សធតរដ្ឋៈ ក៏មកដល់ហើយដែរ ។

នាយទ្វារប្រញាប់ទៅក្រាបទូលតាមពាក្យនោះ ព្រះរាជាទ្រង់ត្រេកអរត្រាស់ថា ចូរមកឲ្យឆាប់ចុះ ហើយទ្រង់ចោមរោមដោយពួកអាមាត្យ ប្រថាប់គង់លើរាជបល្ល័ង្ក ដែលមានស្វេតច្ឆត្រលើកទុកហើយ ទតឃើញនាយព្រានខេមកៈនាំយកស្តេចហង្ស កាត់តាមលានព្រះរាជវាំង ទ្រង់ទតមើលស្តេចហង្សទាំង ២ ដែលមានពណ៌ដូចមាស ទើបទ្រង់ព្រះតម្រិះថា សេចក្តីប្រាថ្នារបស់យើងសម្រេចហើយ ទើបទ្រង់បង្គាប់អាមាត្យទាំងឡាយ ដល់កិច្ចដែលគួរធ្វើដល់ព្រាននោះ ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

ព្រះរាជាព្រះនាមសំយមៈ ទតឃើញហង្សទាំង ២ នោះ ប្រាកដស្មើដោយបុណ្យ ដែលសន្មតថា មានលក្ខណៈល្អ ទ្រង់ត្រាស់ទៅនឹងពួកអាមាត្យថា អ្នកទាំងឡាយ ចូរឲ្យសំពត់ បាយ ទឹក និងភោជន ដល់នាយព្រាន ចូរបំពេញសេចក្តីប្រាថ្នាដោយប្រាក់ ដែលព្រាននេះប្រាថ្នាចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បុញ្ញសង្កាសេ** បានដល់ មានបុណ្យដូចគ្នានឹងខ្លួន ។ បទថា **លក្ខណាសម្មតេ** បានដល់ សន្មតថា ប្រសើរដោយទូទៅហើយ ។ បទថា **ខលុ** ជានិបាត ភ្ជាប់សេចក្តីដោយបទខាងដើមថា បានឮថា ព្រះរាជាទ្រង់ទតហង្សទាំង ២ នោះ ដូច្នេះ ។ ព្រះរាជាកាលទ្រង់ធ្វើអាការ គឺការជ្រះថ្លាឲ្យប្រាកដ ទើបត្រាស់ពាក្យជាដើមថា **ទេថ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **កាមង្គរោ ហិរញ្ញស្ស** សេចក្តីថា ប្រាក់មាសរមែងជាវត្ថុដែលឲ្យនូវការពេញចិត្តដល់ព្រាន ។ បទថា **យាវន្តំ** សេចក្តីថា នាយព្រាននេះបំណងទ្រព្យប៉ុនណាៗ អ្នកទាំងឡាយចូរឲ្យប្រាក់មានប្រមាណប៉ុណ្ណោះដល់គេចុះ ។

ព្រះរាជាត្រាស់ឲ្យធ្វើអាការ គឺការជ្រះថ្លាយ៉ាងនេះ ទ្រង់ត្រេកអរដោយបីតិនិងសោមនស្ស ត្រាស់នឹងពួកអាមាត្យថា អ្នកទាំងឡាយចូរទៅចុះ ចូរទៅប្រដាប់តាក់តែងនាយព្រាន ហើយនាំត្រឡប់មក ។ លំដាប់នោះ ពួកអាមាត្យក៏នាំបុរសនោះ ចុះចាកព្រះរាជនិវេសន៍ ឲ្យជាងកោរកាត់ជម្រះនូវ

សក់និងពុកមាត់ ឲ្យងូតទឹក ឲ្យលាប ប្រដាប់ដោយគ្រឿងអលង្ការ ស្រេចហើយ ទើបនាំមកគាល់ព្រះរាជា ។ លំដាប់នោះ ព្រះរាជាក៏ត្រាស់ថា អ្នកទាំងឡាយ ចូរឲ្យស្រុក ១២ ដែលស្រុកនីមួយៗ មានសួយមួយសែនកហាបណៈក្នុងមួយឆ្នាំ រថដែលទឹមដោយសេះអាជានេយ្យ និងផ្ទះធំមួយខ្នងដែលតាក់តែងទុកហើយ បានប្រទានយសធំដល់នាយព្រានខេមកៈនោះ ។ នាយព្រាននោះ បានយសធំហើយ ប្រារព្ធនឹងប្រកាសការងាររបស់ខ្លួន ទើបក្រាបទូលថា បពិត្រព្រះអង្គ ហង្ស ២ ដែលទូលព្រះបង្គំនាំមកថ្វាយនេះ មិនមែនហង្សធម្មតាឡើយ ដ្បិតថា ហង្សមានឈ្មោះថា ធតរដ្ឋៈ ជាស្តេចនៃពួកហង្ស ៩៦០០០ ហង្សនេះឈ្មោះថា សុមុខៈ ជាសេនាបតី ។ លំដាប់នោះ ព្រះរាជាក៏ត្រាស់សួរនាយព្រាននោះថា នែសម្លាញ់ ហង្សទាំង ២ នេះ អ្នកចាប់បានមកដូចម្តេច ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

ព្រះរាជាក្នុងដែនកាសី ទ្រង់បានទតឃើញព្រានព្រៃមានចិត្តរីករាយ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលខេមកៈ ជាសម្លាញ់ បើស្រះបោក្ខរណី ពេញពាសដោយពួកហង្ស ។ អ្នកមានដៃកាន់អន្ទាក់ ចូលទៅរកហង្ស ដែលឋិតនៅក្នុងកណ្តាលនៃពួកហង្សដ៏រុងរឿង ដោយប្រការដូចម្តេច អ្នកចាប់ហង្សដ៏ឧត្តមដែលនៅលាយឡំដោយពួកហង្សជាញាតិ ដោយប្រការដូចម្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បសន្នត្តំ** បានដល់ ជាអ្នកមានភាវៈផូរផង់ គឺមានសោមនស្សត្រេកអរហើយ ។ បទថា **យធាយំ** សេចក្តីថា ម្នាលខេមកៈ សម្លាញ់ បើស្រះបោក្ខរណី របស់យើងនេះ ពេញទៅដោយហ្វូងហង្សទាំង ៩៦០០០ សោត ។ បទថា **កថំ រុចិមជ្ឈគតំ** សេចក្តីថា កាលបើដូច្នេះ អ្នកកាន់យកអន្ទាក់ដើរចូលទៅជិតស្តេចហង្សនោះ ដែលនៅក្នុងកណ្តាល ហ្វូងហង្សដែលគួរពេញចិត្ត គួរស្រឡាញ់ទាំងនោះ គឺ ដេរដាសទៅដោយ ហ្វូងហង្សដែលជាញាតិនឹងគ្នា ។ បទថា **ឆិម្មជ្ឈិមំ** សេចក្តីថា អ្នកកាន់យក អន្ទាក់ដើរចូលទៅជិតស្តេចហង្សដ៏ឧត្តម ដែលមិនមែនហង្សថ្នាក់កណ្តាលនិង មិនមែនហង្សថ្នាក់តូច បានដូចម្តេច គឺអ្នកចាប់យកមកបានដូចម្តេច ។

នាយខេមកៈស្តាប់ពាក្យរបស់ព្រះរាជាហើយ ក៏ក្រាបទូលថា

កាលទូលព្រះបង្គំជាខ្ញុំ ចូលទៅកាន់ទីជាទីកាន់យកនូវចំណី
( របស់ហង្ស ) ថ្ងៃនេះ ជារាត្រីគម្រប់ ៧ ទូលព្រះបង្គំជា
ខ្ញុំស្វែងរកនូវស្នាមជើងនៃហង្សនោះ ឥតមានធ្វេសប្រហែស
អាស្រ័យនៅតែក្នុងពាង ។ លុះទូលព្រះបង្គំជាខ្ញុំ បានឃើញ
ស្នាមជើងនៃរាជហង្សនោះ ត្រាច់ស្វែងរកទីជាទីកាន់យក
ចំណីហើយ ទើបទូលព្រះបង្គំជាខ្ញុំ បានដាក់អន្ទាក់ក្នុងទីនោះ
រួចចាប់យករាជហង្សនោះ ដោយឧបាយយ៉ាងនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាធាធានិ** សេចក្តីថា ទីសម្រាប់កាន់យក ជាទីរកស៊ី ។ ម្យ៉ាងទៀត បាលីក៏យ៉ាងនេះដូចគ្នា ។ បទថា **ឧចាសតោ** បាន

ដល់ ចូលទៅក្បែរ ។ បទថា **បទំ** បានដល់ ស្នាមជើងដែលស្តេចហង្ស ជាន់លើផែនដីសម្រាប់រកស៊ី ។ បទថា **ឃដស្សិតោ** បានដល់ អាស្រ័យនៅក្នុងទ្រុងដែលធ្វើដូចគ្នានឹងពាង ។ បទថា **អជស្ស** សេចក្តីថា លំដាប់នោះលុះដល់ថ្ងៃទី ៦ ទូលព្រះបង្គំបានឃើញស្នាមជើងស្តេចហង្សនេះ ក្នុងទីស្វែងរកអាហារ ។ បទថា **ឯវន្តំ** អធិប្បាយថា នាយព្រាននោះ ក្រាបទូលឧបាយទាំងអស់ ដែលខ្លួនចាប់ស្តេចហង្ស ដោយពាក្យថា ទូលព្រះបង្គំចាប់ស្តេចបក្សីនោះមកដោយវិធីយ៉ាងនេះឯង ។

ព្រះរាជាស្តាប់ពាក្យនោះហើយ ទ្រង់ព្រះតម្រិះថា ព្រាននេះ ឈរក្រាបទូលត្រង់ទ្វារព្រះរាជវាំង ក៏ក្រាបទូលដល់ការមករបស់ស្តេចហង្ស ឈ្មោះធតរដ្ឋៈតែមួយ សូម្បីក្នុងឥឡូវនេះក៏ក្រាបទូលទៀតថា សូមទ្រង់ទទួលស្តេចហង្សធតរដ្ឋៈនេះតែមួយចុះ ក្នុងរឿងនេះ មានហេតុអ្វីហ្ន៎ ទើបត្រាស់គាថានេះថា

> ម្នាលនាយព្រាន បក្សីនេះ ចុះហេតុអ្វីក៏បានជាអ្នកពោលថា
> បក្សី ១ ចិត្តរបស់អ្នកប្រែប្រួលឬ ឬមួយអ្នកប្រាថ្នាដូចម្តេច
> វិញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិបរិយត្តំ** បានដល់ ការប្រែប្រួល ។ បទថា **អាទុ កិន្នុ ជិគីសសិ** សេចក្តីថា ព្រះរាជាត្រាស់សួរថា អ្នកគិតឃើញដូចម្តេចហ្ន៎ គឺអ្នកប្រាថ្នានឹងកាន់យកស្តេចហង្សមួយទៀតទៅឲ្យអ្នកដទៃឬ ។

លំដាប់នោះ នាយនេសាទក៏ក្រាបទូលថា បពិត្រព្រះអង្គ ចិត្តរបស់ខ្ញុំមិនវិបរិតឡើយ ខ្ញុំមិនប្រាថ្នាឲ្យហង្សមួយនេះដល់អ្នកដទៃ ព្រោះថា កាល

ខ្ញុំជាក់អន្ទាក់ ហង្សមួយនេះប៉ុណ្ណោះជាប់អន្ទាក់ កាលធ្វើសេចក្តីនោះឲ្យប្រាកដ ទើបទូលថា

ធ្មួតក្រហមល្អក្លីរុងរឿង បិតនៅផ្គាល់នឹងទ្រូងនៃហង្សណា ហង្សនោះ បានចូលមកជាប់អន្ទាក់របស់ទូលព្រះបង្គំជាខ្ញុំ ចំណែកបក្សីដែលភ្លឺផ្ទេកនេះ មិនបានជាប់អន្ទាក់ទេ ចម្រើននូវអរិយធម៌ បានឈរនិយាយវាចាជារបស់មនុស្សនឹងបក្សីដែលជាប់ចំណងកំពុងតែក្តៅក្រហាយ (ដោយទុក្ខ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **លោហិតកា តាលា** សេចក្តីថា មានពណ៌ក្រហម មានធ្មួត ៣ ។ បទថា **ឧរំ សំហច្ច** បានដល់ រហូតដល់ទ្រូង មានពាក្យដែលលោកពោលអធិប្បាយទុកថា បពិត្រមហារាជ ស្តេចហង្សដែលមានធ្មួតក្រហម ៣ មានរស្មីដូចមាសទឹក ១០ នេះ មានធ្មួតជុំវិញក រហូតដល់ទ្រូង តែមួយប៉ុណ្ណោះ ចូលទៅជាប់អន្ទាក់របស់ខ្ញុំ ។ បទថា **ភស្សរោ** បានដល់ បរិសុទ្ធិ ដល់ព្រមដោយរស្មី ។ បទថា **អាតុរំ** បានដល់ មានជំងឺកំពុងបាននូវទុក្ខ ។ បទថា **អជ្ឈាសិ** សេចក្តីថា ចំណែកហង្សនេះ កាលជ្រាបថា ស្តេចហង្សធតរដ្ឋៈជាប់អន្ទាក់ ទើបហើរត្រឡប់មកលួងលោមស្តេចហង្សធតរដ្ឋៈនេះ ធ្វើនូវការទទួលក្នុងកាលដែលខ្ញុំទៅដល់ ធ្វើបដិសណ្ឋារៈដោយពាក្យដ៏ពីរោះជាមួយខ្ញុំ ក្នុងកណ្តាលអាកាសនោះឯង ពោលសរសើរគុណរបស់ស្តេចហង្សឈ្មោះ ធតរដ្ឋៈ ដោយពាក្យជាភាសានៃមនុស្ស ជាច្រើន ធ្វើចិត្តរបស់ខ្ញុំឲ្យទន់ ហើយបានឈរខាងមុខស្តេចហង្សនោះឯង បពិត្រ

ព្រះអង្គដ៏ចម្រើន លំដាប់នោះ ខ្ញុំបានស្តាប់ពាក្យដែលជាសុភាសិតរបស់សុមុខហង្ស ជាអ្នកមានចិត្តជ្រះថ្លា ទើបបានលែងស្តេចហង្សធតរដ្ឋៈទៅ ស្តេចហង្សធតរដ្ឋៈផុតចាកអន្ទាក់ ដោយប្រការដូច្នេះ ការដែលខ្ញុំនាំយកហង្សទាំង ២ មកក្នុងទីនេះ សុមុខហង្សជាអ្នកផ្តួចផ្តើមឡើង ។

ខេមកនេសាទនោះ ក្រាបទូលសរសើរគុណរបស់សុមុខហង្សយ៉ាងនេះ ព្រះរាជាទ្រង់ស្តាប់ពាក្យនោះ ក៏មានបំណងនឹងស្តាប់ធម្មកថារបស់សុមុខហង្ស កាលទ្រង់ធ្វើសក្ការៈដល់លុទ្ទបុត្តនោះឯង ព្រះអាទិត្យក៏អស្តង្គត ពន្លឺប្រទីបក៏ភ្លឺទូទៅ ។ ឥស្សរជន មានក្សត្រជាដើមមកប្រជុំគ្នាជាច្រើន សូម្បីព្រះនាងខេមាទេវីក៏ចោមរោមដោយអ្នករបាំផ្សេងៗ ប្រថាប់គង់ខាងស្តាំរបស់ព្រះរាជា ។ ខណៈនោះ ព្រះរាជាបំណងឲ្យសុមុខហង្សសម្តែងធម្មកថា ទើបត្រាស់គាថានេះថា

> ម្នាលសុមុខៈ ឥឡូវនេះ អ្នកឈរទល់ចង្កា ( បិទមាត់ )
> តើព្រោះហេតុអ្វី ឬក៏អ្នកមកកណ្តាលបរិស័ទរបស់យើង
> ហើយមានសេចក្តីភ័យខ្លាចទើបមិនពោល ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ហនុំ សំហច្ច** សេចក្តីថា បានឮថា លោកអ្នកមានសម្តីពីរោះ បើដូច្នោះ ហេតុអ្វីទើបឈរបិទមាត់ក្នុងកាលនេះ ។ បទថា **អាទុ** បានដល់ ឬ ។ បទថា **ភយា ភីតោ** បានដល់ ឬអ្នកខ្លាចភ័យដែលកើតអំពីអំណាចរាជសក្តិក្នុងបរិស័ទ ។ សុមុខហង្ស បានស្តាប់ពាក្យនោះហើយ កាលនឹងប្រកាសភាពដែលខ្លួនមិនបានខ្លាចក្រែងភ័យ ទើបពោលគាថានេះថា

បពិត្រព្រះអង្គជាធំក្នុងដែនកាសី ទូលព្រះបង្គំជាខ្ញុំ មិនមែនខ្លាច ព្រោះតែចូលមកកាន់បរិស័ទរបស់ព្រះអង្គទេ ទូលព្រះបង្គំជាខ្ញុំ មិនមែនជានឹងមិននិយាយព្រោះខ្លាចទេ កាលបើមានហេតុប្រាកដដូច្នោះហើយ ទូលព្រះបង្គំជាខ្ញុំ មុខជានឹង ( បញ្ចេញ ) នូវវាចា ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តាធិសេ** សេចក្ដីថា តែទូលព្រះបង្គំអង្គុយរង់ចាំឱកាសដែលនឹងពោល ដោយគិតថា បើប្រយោជន៍បែបនោះកើតឡើង អញនឹងពោល ។

ព្រះរាជាស្ដាប់ពាក្យនោះហើយ កាលទ្រង់ធ្វើនូវការបំអក ព្រោះទ្រង់បំណងឲ្យសុមុខហង្សនោះពោលពាក្យបន្ថែមទៀត ទើបត្រាស់ថា

យើងមិនឃើញទាហាន មិនឃើញពលរថ មិនឃើញពលថ្មើរជើង មិនឃើញខែល មិនឃើញជនអ្នកកាន់អម្បែង មិនឃើញជនអ្នកពាក់អាវក្រោះ មិនឃើញអ្នកកាន់ធ្នូរបស់អ្នកឡើយ ។ ម្នាលសុមុខៈ យើងមិនឃើញប្រាក់ឬមាស ឬនគរដែលគេសាងល្អហើយ ជានគរមានគូដ៏ជ្រៅជាស មិនងាយទៅមកបាន ជានគរមានប៉មនិងខ្លោងទ្វារដ៏មាំទេ ជាកន្លែងដែលអ្នកចូលទៅហើយ មិនខ្លាចនូវហេតុ ដែលគេគួរខ្លាច ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អភិស្សរំ** សេចក្ដីថា យើងមិនឃើញបុគ្គល

ដែលកាន់អាវុធឈរបោមរោម ដើម្បីរក្សាក្នុងទីបំផុតបរិស័ទរបស់អ្នកឡើយ ។ បទថា **អស្សុ** ក្នុងបទថា **ឆាស្សុ** នោះ ត្រឹមតែជានិបាត ។ បទថា **ចម្មំ** បាន ដល់ គ្រោះស្បែកសម្រាប់ការពារខ្លួន ។ បទថា **កីដំ** បានដល់ បន្ទះលោហៈ ជូនកាលលោកពោលថា ជាបន្ទះអំបែងក៏មាន ព្រះរាជាសម្តែងថា សូម្បីអ្នក កាន់អំបែង ក៏មិនមានក្នុងសម្នាក់របស់អ្នកឡើយ ។ បទថា **វម្មិនេ** បានដល់ បុគ្គលដែលពាក់ហើយដោយគ្រោះ ។ បទថា **ន ហិរញ្ញំ** សេចក្តីថា អ្នក អាស្រ័យវត្ថុណា ទើបមិនខ្លាចភ័យ យើងមើលមិនឃើញវត្ថុនោះ សូម្បីត្រឹម តែប្រាក់ក្នុងសម្នាក់របស់អ្នកឡើយ ។

សុមុខហង្ស កាលត្រូវព្រះរាជាត្រាស់សួរយ៉ាងនេះថា អ្វីជាហេតុដែល អ្នកមិនខ្លាច កាលប្រាប់ដល់ហេតុនោះ ទើបពាលថា

> ទូលព្រះបង្គំជាខ្ញុំ មិនត្រូវការដោយទាហាន ដោយនគរ ឬ ដោយទ្រព្យទេ ពួកទូលព្រះបង្គំជាខ្ញុំ តែងទៅកាន់ផ្លូវតាម ផ្លូវ មិនមែនជាផ្លូវដែលព្រះអង្គទៅបានទេ ទូលព្រះបង្គំជា ខ្ញុំត្រាច់ទៅឰដ៏អាកាស ។ ព្រះអង្គបានទ្រង់ឮហើយថា ពួក ទូលព្រះបង្គំជាខ្ញុំជាបណ្ឌិត មានប្រាជ្ញាដ៏ល្អិត ជាអ្នកគិតនូវ អាបិកំបាំង បើព្រះអង្គប្រតិស្ឋានក្នុងសច្ចៈ ពួកទូលព្រះបង្គំ ជាខ្ញុំ នឹងពោលនូវវាចាដែលមានប្រយោជន៍ ។ ឯវាចាជា សុភាសិត ដែលព្រះអង្គមិនមានសច្ចៈ ជាបុគ្គលមិនប្រសើរ បានពោលដល់ព្រានព្រៃ ជាអ្នកល្មោភ និយាយកុហកដែរ

នឹងធ្វើដូចម្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អភិស្សរេន** បានដល បរិវារអ្នករក្សា ។ បទថា **អត្ថោ** សេចក្តីថា ទូលព្រះបង្គំមិនមានកិច្ចដោយការរក្សានេះ ព្រោះហេតុអ្វី ព្រោះទូលព្រះបង្គំ សាំងផ្លូវទៅដោយទីដែលមិនមែនផ្លូវ គឺដែលមិនមែនផ្លូវ របស់បុគ្គល ដែលដូចគ្នានឹងព្រះអង្គ ព្រោះថា ខ្ញុំត្រាច់ទៅក្នុងអាកាស ។ បទថា **បណ្ឌិតា ត្យម្ហា** សេចក្តីថា បានឮថា ទ្រង់ឮថា ខ្ញុំជាបណ្ឌិត ព្រះអង្គមានប្រាថ្នានឹងស្តាប់ធម៌អំពីសម្នាក់របស់ខ្ញុំ ទើបឲ្យចាប់ខ្ញុំទាំង ២ មក ដោយហេតុនោះឯង ។ បទថា **សច្ចេ ចស្ស** សេចក្តីថា បើព្រះអង្គជាអ្នកតាំងនៅក្នុងភាពសច្ចៈសោត ទូលព្រះបង្គំគប្បីពោលវាចាដែលអាស្រ័យហេតុ ។ បទថា **អសច្ចស្ស** សេចក្តីថា ពាក្យដែលខ្ញុំពោល ទោះជាសុភាសិត ក៏នឹងធ្វើអ្វីដល់ព្រះអង្គ ដែលវៀរចាកវចីសច្ចៈបាន ដូចម្ជុលដែលធ្វើដោយក្អករមែងមិនមានប្រយោជន៍ដល់សមណៈ ។

ព្រះរាជាស្តាប់ពាក្យនោះហើយ ទើបត្រាស់ថា ព្រោះហេតុអ្វី ទើបអ្នកពោលនឹងយើងថា យើងជាអ្នកពោលកុហក មិនមែនបុគ្គលប្រសើរ យើងបានធ្វើអ្វី ។ លំដាប់នោះ ទើបសុមុខហង្សក្រាបទូលនឹងព្រះរាជាថា បពិត្រមហារាជ បើដូច្នោះ ទ្រង់ស្តាប់ចុះ ហើយក្រាបទូលថា

ព្រះអង្គបានឲ្យគេធ្វើស្រះបោក្ខរណីឈ្មោះ ខេមានោះ តាមសំដី
នៃពួកព្រាហ្មណ៍ ម្យ៉ាងទៀត ព្រះអង្គឲ្យគេឃោសនានូវអភ័យ
គ្រប់ទិសទាំង ១០ នេះ ។ ថាបើកឲ្យសត្វបក្សីចុះកាន់ស្រះ

បោក្ខរណី ដែលមានទឹកដ៏ថ្លាស្អាតចុះ ជ្រិតមានវត្ថុសម្រាប់ទំពាស៊ីក្នុងស្រះនោះជាច្រើន ទាំងមិនមានការបៀតបៀននូវពួកសត្វបក្សីក្នុងស្រះនោះទេ ។ ពួកទូលព្រះបង្គំជាខ្ញុំបានឮនូវអភ័យនេះ ដែលព្រះអង្គឲ្យឃោសនាហើយ បានជាមកក្នុងសំណាក់នៃព្រះអង្គ ទូលព្រះបង្គំជាខ្ញុំទាំងនោះ ជាប់ដោយអន្ទាក់របស់ព្រះអង្គ នេះហើយជាសំដីកុហករបស់ព្រះអង្គ ។ បុគ្គលធ្វើនូវមុសាវាទផង នូវសេចក្តីលោភ គឺសេចក្តីប្រាថ្នាដ៏លាមកផង ឲ្យជាប្រធាន រមែងកន្លងនូវបដិសន្ធិក្នុងលោកទាំង ២ ហើយចូលទៅកាន់ទីមិនមានសេចក្តីត្រេកអរ ( នរក ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តំ** បានដល់ **ត្វំ** ប្រែថា ខ្លួនព្រះអង្គឯង ។ បទថា **ឯមំ** បានដល់ ស្រះបោក្ខរណីដែលមានឈ្មោះយ៉ាងនេះ ។ បទថា **ឃុដ្ឋំ** បានដល់ ទ្រង់បញ្ជាឲ្យមនុស្សឈរប្រកាសត្រង់ជ្រុងស្រះទាំង ៤ ។ បទថា **ទសធា** បានដល់ ទ្រង់ប្រកាសអភ័យក្នុងទិសទាំង ១០ នេះ ។ បទថា **ឱគ្គយ្ហ** បានដល់ ចាកសម្នាក់របស់ហង្សដែលហើរចុះ ហើយត្រឡប់មក ។ បទថា **បហូតំ ខាទនំ** បានដល់ មានអាហារសម្រាប់បរិភោគជាដើមថា ផ្កាឈូកផ្កាឧប្បលនិងស្រូវសាលីគ្រប់គ្រាន់ ។ បទថា **ឥធំ សុត្វាន** សេចក្តីថា បានឮអភ័យនេះ អំពីសម្នាក់របស់ហង្សទាំងនោះ ដែលហើរចុះកាន់ស្រះបោក្ខរណីរបស់ព្រះអង្គ ហើយទើបត្រឡប់មក ។ បទថា **តវន្តិកេ** សេចក្តីថា

ទូលព្រះបង្គំ ក៏នាំគ្នាមកកាន់ស្រះបោក្ខរណី ដែលព្រះអង្គជីកឡើង ក្នុងសម្នាក់របស់ព្រះអង្គ ។ បទថា **តេ តេ** បានដល់ ពួកទូលព្រះបង្គំនោះក៏បាននាំគ្នាជាប់អន្ទាក់របស់ព្រះអង្គ ។ បទថា **បុរេក្ខត្វា** បានដល់ ធ្វើទុកខាងមុខ ។ បទថា **ឥដ្ឋាលោភំ** បានដល់ សេចក្តីលោភដ៏លាមក ពោលគឺការចង់បាន ។ បទថា **ឧភោសន្ធឹ** បានដល់ បដិសន្ធិក្នុងលោកទាំងពីរ គឺ ក្នុងទេវលោកនិងមនុស្សលោក គឺបុគ្គលដែលប្រព្រឹត្តធម៌ដ៏លាមកបែបនេះ ធ្វើទុកខាងមុខ ឈ្មោះថា ឈានកន្លងបដិសន្ធិដែលជាសុគតិ ។ បទថា **អសាតំ** បានដល់ រមែងចូលដល់នរក ។

សុមុខហង្ស ធ្វើព្រះរាជាឲ្យខ្មាសកណ្តាលបរិស័ទយ៉ាងនេះឯង ។ គ្រានោះព្រះរាជាក៏ត្រាស់សួរសុមុខហង្សថា នៃសុមុខៈ យើងមានបំណងនឹងចាប់អ្នកមកសម្លាប់ស៊ីសាច់ក៏មិនមែន តែយើងបានឮមកថា អ្នកជាបណ្ឌិត បំណងនឹងស្តាប់ពាក្យដែលជាសុភាសិត ទើបឲ្យចាប់អ្នកមក កាលទ្រង់ប្រកាសនូវសេចក្តីនោះទើបត្រាស់ថា

ម្នាលសុមុខៈ យើងមិនមែនប្រទូស្តអ្នកទេ យើងមិនមែនចាប់
អ្នក ព្រោះសេចក្តីលោភទេ យើងបានឮថា អ្នកទាំងឡាយ
ជាបណ្ឌិតមានប្រាជ្ញាដ៏ល្អិត ជាអ្នកគិតនូវអាថ៌កំបាំង ។ ធ្វើ
ម្តេចហ្ន៎ ហង្សទាំងឡាយបានមកក្នុងទីនេះ ពោលនូវវាចា
មានប្រយោជន៍ ម្នាលសុមុខៈជាសម្លាញ់ ព្រោះហេតុនោះ
បានជាយើងប្រាប់នាយនេសាទនេះ ឲ្យចាប់ (អ្នក) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឆាបរជ្ឈាម** សេចក្ដីថា យើងសម្លាប់អ្នកទើបឈ្មោះថា ប្រព្រឹត្តខុស តែយើងមិនបានសម្លាប់អ្នកឡើយ ។ បទថា **លោភាវ មគ្គហឹ** សេចក្ដីថា យើងបំណងនឹងស៊ីសាច់អ្នកទើបចាប់មកដោយសេចក្ដីលោភក៏មិនមែន ។ បទថា **បណ្ឌិតាត្យត្ត** សេចក្ដីថា តែយើងបានឮថា អ្នកជាបណ្ឌិត ។ បទថា **អត្ថចិន្តកា** បានដល់ គិតនូវអាថ៌កំបាំងបាន ។ បទថា **អត្ថវតី** បានដល់ ពាក្យដែលអាស្រ័យហេតុ ។ បទថា **តថា** បានដល់ ដោយហេតុនោះ ។ បទថា **វុត្តោ** បានដល់ ជាបុគ្គលដែលយើងពោលហើយ ។ បទថា **សុមុខ មគ្គហិ** បានដល់ ព្រះរាជាហៅថា នែសុមុខៈ ។ **ម** អក្ខរៈ គ្រាន់តែជាសន្ធិ ។ បទថា **អគ្គហិ** សេចក្ដីថា យើងចាប់មកដើម្បីឲ្យសម្ដែងធម៌ទេតើ ។

សុមុខហង្សបានស្ដាប់ពាក្យនោះហើយ ក៏ក្រាបទូលថា បពិត្រមហារាជ ព្រះអង្គមានបំណងនឹងស្ដាប់ពាក្យដែលជាសុភាសិត ទ្រង់ធ្វើកិច្ចមិនសមគួរឡើយ ហើយក្រាបទូលថា

បពិត្រព្រះអង្គជាធំ ក្នុងដែនកាសី យើងទាំងឡាយជាសត្វ
កាលបើជីវិតចូលទៅរក ( សេចក្ដីស្លាប់ ) ហើយ ដល់នូវ
កាលកំណត់ដែលត្រូវស្លាប់ហើយ ពោលនូវពាក្យដែលមាន
ប្រយោជន៍មិនបានទេ ។ បុគ្គលណាសម្លាប់ម្រឹគដោយម្រឹគ
ឬបក្សីដោយបក្សី ម្យ៉ាងទៀត បៀតបៀននូវបុគ្គលដែលមាន
ឈ្មោះល្បី ដោយរបស់ដែលមានឈ្មោះល្បី អំពើអ្វីដែល

អាក្រក់ជាងអំពើរបស់បុគ្គលនោះទៅទៀត ។ បុគ្គលណា និយាយសំដីដ៏ប្រសើរ ប៉ុន្តែជាបុគ្គលមិនប្រព្រឹត្តធម៌ដ៏ប្រសើរ បុគ្គលនោះ រមែងឃ្លាតចាកលោកទាំង ២ គឺលោកនេះ និងលោកខាងមុខ ។ បុគ្គលដែលបាននូវយស មិនគួរស្រវឹងដល់នូវការសង្ស័យក្នុងជីវិត មិនគួរទុក្ខលំបាកឡើយ គួរព្យាយាមក្នុងកិច្ចទាំងឡាយផង គួរបិទនូវប្រហោងគឺ (ទោស) ទាំងឡាយផង ។ ពួកបុគ្គលណា ចម្រើនដោយគុណ ដល់កាលកំណត់ដែលត្រូវស្លាប់ មិនល្មើសធម៌ ទាំងបានប្រព្រឹត្តធម៌ក្នុងលោកនេះ ពួកបុគ្គលនោះ រមែងទៅកើតក្នុងត្រៃត្រិង្ស យ៉ាងនេះ ។ បពិត្រព្រះអង្គជាធំក្នុងដែនកាសី ព្រះអង្គទ្រង់ព្រះសណ្តាប់នូវពាក្យនេះហើយ សូមរក្សានូវធម៌ ក្នុងព្រះអង្គចុះ ម្យ៉ាងទៀត សូមព្រះអង្គទ្រង់ដោះលែងនូវរាជហង្ស ឈ្មោះធតរដ្ឋៈដ៏ប្រសើរលើសជាងពួកហង្ស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧបនីតស្មិំ** បានដល់ រមែងចូលទៅក្បែរសេចក្តីស្លាប់ ។ បទថា **កាលបរិយាយំ** សេចក្តីថា ព្រះអង្គដល់វារៈជិតមរណកាលហើយ នឹងមិនពោលអ្វីឡើយ ដ្បិតថា ព្រះអង្គជាអ្នកចងបុគ្គលដែលសម្តែងធម្មកថាហើយ គំរាមឲ្យខ្លាចដោយមរណភ័យ គិតថា អញនឹងស្តាប់ធម៌ដូច្នេះ ឈ្មោះថា ធ្វើកម្មមិនសមគួរឡើយ ។ បទថា **មិគេន** បានដល់ ម្រឹគដែលបានទទួលការហ្វឹកហាត់យ៉ាងល្អហើយ ។ បទថា **ហន្តិ** គឺ **ហនតិ**

ជាឯកវចនៈ ប្រែថា រមែងសម្លាប់ ។ បទថា **បក្ខិណា** បានដល់ បក្សីដែលនាំមកបញ្ឆោត គឺបក្សីឈ្មោលនោះឯង ។ បទថា **សុខេន វា** បានដល់ ដោយស្រះផ្កាឈូក ដូចគ្នានឹងម្រឹគនិងបក្សីឈ្មោលដែលប្រាកដល្បីថា ខេមស្រះ មិនមានភ័យ ។ បទថា **សុតំ** បានដល់ អ្នកសម្ដែងធម៌ ដែលល្បីយ៉ាងនេះថា ជាបណ្ឌិតមានប្រក្រតីពោលពាក្យដ៏វិចិត្រ ។ បទថា **កឹលេ្យ** សេចក្ដីថា បុគ្គលណាចាប់អ្នកល្បី គឺគប្បីបៀតបៀនធ្វើឲ្យក្ដៅក្រហាយដោយចំណង គឺអន្ទាក់ដោយគិតថា អញនឹងស្ដាប់ធម៌ ។ បទថា **តតោ** សេចក្ដីថា តើវត្ថុឯណាដទៃដែលអាក្រក់ជាងជនទាំងនោះទៀតនោះ គឺដែលធ្វើនូវការអាក្រក់ក្រៃលែងជាងនូវមានទៀតនោះ ។ បទថា **អរិយរុធំ** សេចក្ដីថា បុគ្គលណាពោលពាក្យដ៏ប្រសើរ គឺពាក្យដែលពីរោះ ។ បទថា **ធម្មនិស្សិតោ** បានដល់ អាស្រ័យធម៌ដែលអាក្រក់នោះដោយការធ្វើ ។ បទថា **ឧភោ** បានដល់ ចាកលោកទាំង ២ គឺទេវលោក និងមនុស្សលោក ។ បទថា **ឥធ ចេវ** សេចក្ដីថា បុគ្គលនេះសូម្បីកើតក្នុងលោកនេះ ឬក្នុងលោកខាងមុខ ឈ្មោះថា កម្ចាត់នូវលោកនៃសុគតិទាំង ២ ចោលហើយ រមែងចូលដល់នរកតែម្យ៉ាង ។ បទថា **បត្តសំសយំ** បានដល់ បុគ្គលដល់នូវសេចក្ដីទុក្ខ សូម្បីដល់នូវការសង្ស័យក្នុងជីវិតក៏មិនគប្បីលំបាក ។ បទថា **សំវរេ វិវរានិ ច** សេចក្ដីថា គប្បីបិទ គប្បីរាំងនូវឱកាសដែលធ្លុះធ្លាយរបស់ខ្លួន ។ បទថា **វុឌ្ឍា** បានដល់ ជាបណ្ឌិតដែលចម្រើនដោយគុណ ។ បទថា **សម្បត្តា កាលបរិយាយំ** បានដល់ ជាអ្នកដល់ហើយនូវពេលជិតមរណកាល មិនគប្បីកន្ទងផុតទៅបានឡើយ ។ បទថា

**ឯវេតេ** កាត់បទជា **ឯវំ ឯតេ** ប្រែថា ជនទាំងនោះ ។ បទថា **ឥធំ** បានដល់ពាក្យដែលអាស្រ័យហេតុដែលខ្ញុំក្រាបទូលទុកហើយនេះ ។ បទថា **ធម្មំ** បានដល់ ទាំងធម៌ដែលជាបវេណី ទាំងធម៌ដែលជាសុចរិត ។

ព្រះរាជាទ្រង់ស្តាប់ពាក្យនោះហើយទើបត្រាស់ថា

ពួកអ្នកបម្រើ ចូរនាំមកនូវទឹក ( សម្រាប់លាងជើង ) ផង នូវប្រេងសម្រាប់លាបជើងផង នូវអាសនៈដែលមានថ្លៃច្រើនផង យើងនឹងដោះនូវរាជហង្ស ឈ្មោះធតរដ្ឋៈដ៏មានយសចេញអំពីទ្រុង ។ ម្យ៉ាងទៀត ហង្សណា កាលបើព្រះរាជាបានសេចក្តីសុខ ខ្ជួនក៏បានសេចក្តីសុខដែរ ព្រះរាជាបានសេចក្តីទុក្ខ ខ្ជួនក៏បានសេចក្តីទុក្ខដែរ យើងនឹងលែងនូវហង្សនោះ ជាសេនាបតី ជាអ្នកប្រាជ្ញ មានប្រាជ្ញាល្អិត អ្នកគិតនូវអាថ៌កំបាំង ។ បុគ្គលបែបនេះ ទើបគួរបរិភោគដុំបាយរបស់ម្ចាស់បាន ដូចជាហង្សសេនាបតីឈ្មោះ សុមុខៈ នេះជាសម្លាញ់មានជីវិតស្មើនឹងស្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧទកំ** បានដល់ ទឹកសម្រាប់លាងជើង ។ បទថា **បជ្ជំ** បានដល់ ប្រេងសម្រាប់លាបជើង ។ បទថា **សុខេ** បានដល់ កាលទ្រង់បានសុខ ។

ពួកក្មាក់ងារ មានអាមាត្យជាដើម បានស្តាប់ព្រះតម្រាស់របស់ព្រះរាជាហើយ ទើបនាំអាសនៈមក ដើម្បីស្តេចហង្សទាំង ២ នោះ ហើយទើបលាង

ជើងរបស់ស្តេចហង្សទាំង ២ នោះដែលទំលើអាសនៈដោយទឹកក្រអូបលាប ដោយប្រេងដែលចម្រាញ់មួយរយដង ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

រាជហង្សឈ្មោះធតរដ្ឋៈ បានចូលទៅទំលើតាំងជាវិការៈនៃមាស សុទ្ធ មានជើង ៥ ជាទីរីករាយនៃចិត្ត ជាតាំងដ៏រលីង ក្រាល ដោយសំពត់អ្នកដែនកាសី ។ ចំណែកហង្សសេនាបតីឈ្មោះ សុមុខៈ បានចូលទៅទំលើកៅអី ជាវិការនៃមាសសុទ្ធ ដែល ពាសដោយស្បែកខ្លា ក្នុងទីជាលំដាប់នៃរាជហង្សឈ្មោះ ធត រដ្ឋៈ ។ ពួកអ្នកដែនកាសីជាច្រើន បាននាំយកនូវភោជនមាន រសដ៏ប្រសើរដែលគេបញ្ជូនទៅថ្វាយព្រះរាជាដោយភាជន៍ជា វិការៈនៃមាសទាំងឡាយ ហើយក៏បង្អោនទៅដល់ហង្សទាំង នោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មជ្ឈំ** បានដល់ ជាតាំងសម្រេចបរិបូណ៌ ហើយ ។ បទថា **កាសិកវត្ថិនំ** បានដល់ ជាតាំងដែលក្រាលដោយសំពត់ ដែលមកអំពីដែនកាសី ។ បទថា **កោច្ឆំ** បានដល់ តាំងដែលគេត្បាញទុក ត្រង់កណ្តាល ។ បទថា **វេយ្យគ្ឃបរិសិព្វិតំ** បានដល់ តាំងសម្រាប់ជាទី ប្រថាប់គង់របស់អគ្គមហេសី ក្នុងថ្ងៃមង្គលដែលស្រោបដោយស្បែកខ្លាធំ ។ បទថា **កាញ្ចនបត្តេហិ** បានដល់ ភាជនៈមាស ។ បទថា **បុថូ** បានដល់ ជាចំនួនច្រើន ។ បទថា **កាសិយោ** បានដល់ ជនដែលនៅក្នុងដែនកាសី ។

បទថា **អភិហារេសុំ** បានដល់ បង្អោនចូលទៅ ។ បទថា **អគ្គំ រញ្ញោ បវាសិតំ** សេចក្តីថា ភោជនមានរសដ៏ប្រសើរផ្សេងៗ ដែលពួកជនទាំងនោះដាក់ក្នុងថាសមាសទម្ងន់ ១០៨ បលៈ សម្រាប់បញ្ជូនទៅថ្វាយព្រះរាជា ដើម្បីប្រយោជន៍ជាបណ្ណាការដល់ស្តេចហង្ស ។

កាលអាមាត្យនាំភោជនចូលទៅយ៉ាងនេះហើយ ព្រះបាទកាសិករាជ ទ្រង់ទទួលភាជនៈមាសអំពីដៃរបស់ពួកអាមាត្យទាំងនោះ ដោយព្រះហស្តហើយ ទើបទ្រង់បង្អោននាំចូលទៅដោយព្រះហស្តឯង ដើម្បីទ្រង់លើកតម្កើង ។ ហង្សទាំង ២ នោះ ក៏ចឹកលាជដែលលាយដោយទឹកឃ្មុំអំពីភាជនៈនោះ ហើយផឹកនូវទឹកដែលមានរសផ្អែម លំដាប់នោះ មហាសត្វឃើញការបូជា និងការជ្រះថ្លារបស់ព្រះរាជាហើយ ទើបបានធ្វើនូវបដិសណ្ឋារៈ ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

> រាជហង្សឈ្មោះសុវៃ ក្នុងបដិសណ្ឋារធម៌ លុះបានឃើញទឹក
> និងភោជនដ៏ប្រសើរ ដែលគេនាំមក ដែលព្រះរាជាក្នុងដែន
> កាសី ទ្រង់បញ្ជូនមកហើយ សួរក្នុងកាលជាលំដាប់នោះ ថា
> ព្រះអង្គទ្រង់បានសេចក្តីសុខស្រួលដែរឬ ព្រះអង្គមិនមាន
> ជំងឺតម្កាត់អ្វីទេឬ ព្រះអង្គគ្រប់គ្រងដែនដ៏ធំទូលាយនេះ ដោយ
> ធម៌ដែរឬ ដូច្នេះ ។

ព្រះរាជាត្រាស់ថា

> ម្នាលហង្ស យើងមានសេចក្តីសុខស្រួលដែរ ម្នាលហង្ស

យើងមិនមានជំងឺតម្កាត់អ្វីទេ យើងគ្រប់គ្រងដែនដ៏ធំទូលាយនេះត្រឹមត្រូវដោយធម៌ហើយ ដូច្នេះ ។

ព្រះមហាសត្វក្រាបទូលសួរថា

ទោសតិចតួចរបស់ព្រះអង្គ មិនមានក្នុងពួកអាមាត្យទេ ឬអាមាត្យទាំងនោះ មិនអាល័យក្នុងជីវិត ចំពោះប្រយោជន៍ទាំងឡាយរបស់ព្រះអង្គទេឬ ដូច្នេះ ។

ព្រះរាជាត្រាស់តបថា

ទោសតិចតួចរបស់យើង មិនមានក្នុងពួកអាមាត្យទេ អាមាត្យទាំងនោះ មិនអាល័យក្នុងជីវិត ចំពោះប្រយោជន៍ទាំងឡាយរបស់យើងទេ ដូច្នេះ ។

ព្រះមហាសត្វក្រាបទូលសួរថា

អគ្គមហេសីដែលមានជាតិស្មើនឹងព្រះអង្គ ជាស្ត្រីស្តាប់បង្គាប់ពោលនូវពាក្យជាទីស្រឡាញ់ ប្រកបដោយបុត្ត រូបនិងយសជាស្ត្រីលុះអំណាចសេចក្តីប្រាថ្នារបស់ព្រះអង្គទេឬ ដូច្នេះ ។

ព្រះរាជាត្រាស់តបថា

អគ្គមហេសីដែលមានជាតិ ស្មើនឹងយើង ជាស្ត្រីស្តាប់បង្គាប់ពោលនូវពាក្យជាទីស្រឡាញ់ បានប្រកបដោយបុត្ត រូបនិងយស ជាស្ត្រីលុះអំណាចសេចក្តីប្រាថ្នារបស់យើង ដូច្នេះ ។

ព្រះមហាសត្វទូលសួរថា

ព្រះអង្គមិនបៀតបៀនអ្នកដែន ដែលមិនមានឧបទ្រពអំពី
ណា គ្រប់គ្រងដោយអាការៈមិនរួសរាន់ តាមធម៌ដ៏ស្មើទេឬ
ដូច្នេះ ។

ព្រះរាជាត្រាស់តបថា

យើងមិនបានបៀតបៀនអ្នកដែន ដែលមិនមានឧបទ្រពអំពីទី
ណា គ្រប់គ្រងដោយការមិនរួសរាន់ តាមធម៌ដ៏ស្មើ ដូច្នេះ ។

ព្រះមហាសត្វក្រាបទូលសួរថា

ព្រះអង្គទ្រង់បានគោរពពួកសប្បុរស វៀរបង់ពួកអសប្បុរស
មិនលះបង់នូវធម៌ ហើយប្រព្រឹត្តនូវអធម៌ទេឬ ដូច្នេះ ។

ព្រះរាជាត្រាស់តបថា

យើងបានគោរពនូវពួកសប្បុរស វៀរបង់នូវពួកអសប្បុរស
យើងបានលះបង់នូវអធម៌ ហើយប្រព្រឹត្តតាមធម៌ តែម្យ៉ាង
ដូច្នេះ ។

ព្រះមហាសត្វក្រាបទូលសួរថា

បពិត្រក្សត្រ ព្រះអង្គទ្រង់រំពឹងនូវកាលជាអនាគតដ៏វែងដែរ
ឬ ព្រះអង្គស្រវឹងក្នុងអារម្មណ៍ ជាទីតាំងនៃសេចក្តីស្រវឹង
ហើយមិនតក់ស្លុតនឹងបរលោកទេឬ ដូច្នេះ ។

ព្រះរាជាត្រាស់តបថា

ម្នាលបក្សី យើងតែងប្រមើលមើល នូវកាលអនាគតដ៏វែង

យើងឋិតនៅក្នុងធម៌ ១០ ប្រការ មិនតក់ស្លុតនឹងបរលោកឡើយ ( ធម៌ ១០ ប្រការគឺ ) ទាន ១ សីល ១ បរិច្ចាគ ១ ភាពនៃចិត្តត្រង់ ១ ភាពនៃចិត្តទន់ ១ តបៈ គឺឧបោសថសីល ១ ការមិនក្រោធ ១ ការមិនបៀតបៀន ១ ខន្តិ ១ កិរិយាមិនភ្ញាត់ ១ ។ យើងឃើញនូវកុសលធម៌ទាំងនេះ ឋិតនៅក្នុងខ្លួន លំដាប់នោះ បីតិនឹងសោមនស្សជាច្រើន កើតឡើងដល់យើង ដោយប្រការ ដូច្នេះ ។ ឯបក្សីឈ្មោះសុមុខៈមិនបានគិត ហើយបញ្ចេញនូវវាចាដ៏ទ្រគោះ ព្រោះតែមិនបានដឹងច្បាស់នូវការប្រទូស្តក្នុងចិត្តរបស់យើង ។ បក្សីនោះលុះខឹងហើយ ក៏បញ្ចេញនូវវាចាដ៏ទ្រគោះ ដោយឥតគំនិត ( ពោល ) នូវទោសទាំងឡាយ ដែលមិនមានក្នុងពួកយើង ពាក្យនេះមិនមែនដូចពាក្យនៃបុគ្គលមានប្រាជ្ញា ( ពោលហើយ ) ទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥស្សា** បានដល់ មើលឃើញនូវគ្រឿងផឹកនិងគ្រឿងបរិភោគដ៏ប្រសើរជាច្រើននោះ ។ បទថា **បេសិតំ** បានដល់ ដែលព្រះរាជាឲ្យនាំមកហើយ ទ្រង់បង្អោនចូលទៅឲ្យ ។ បទថា **១ត្តធម្មានំ** បានដល់ ធម៌សម្រាប់ធ្វើបដិសណ្ឋារៈក្នុងបុគ្គលដែលធ្វើដំបូង ។ បទថា **តតោ បុច្ឆិ អនន្តរា** បានដល់ ក្នុងកាលនោះ ។ បទថា **កច្ចិ នុ ភោតោ** សេចក្តីថា គាថា ៦ ដែលស្តេចហង្សធតរដ្ឋៈ ទូលសួរតាមលំដាប់ មានន័យដូចពោល

ទុកហើយខាងដើមនោះឯង ។ បទថា **អនុប្បីឡំ** បានដល់ ស្តេចហង្សធតរដ្ឋៈ ទូលសួរថា ទ្រង់មិនបានរឹបជាន់អ្នកនគរ ដូចបុគ្គលគាបអំពៅ ដោយគ្រឿងយន្តទេឬ ។ បទថា **អកុតោចិឧបទ្ទវំ** បានដល់ មិនមានអន្តរាយណាឡើយ ។ បទថា **សមេន អនុសាសសិ** បានដល់ ទ្រង់គ្រប់គ្រងដែននេះដោយធម៌ដ៏ស្មើឬ ។ បទថា **សន្តោ** បានដល់ ទ្រង់ជាសប្បុរសដែលប្រកបដោយគុណមានសីលជាដើម ។ បទថា **និរង្កត្វា** បានដល់ មិនលះបង់ធម៌ ។ បទថា **អនាគតំ ទីឃំ** បានដល់ ជីវិតរបស់ព្រះអង្គដែលជាអនាគតដែលប្រព្រឹត្តទៅ នៅវែងឆ្ងាយឬ ។ បទថា **សមវេក្ខសិ** សេចក្តីថា ស្តេចហង្សធតរដ្ឋៈ ទូលសួរថា ទ្រង់ជ្រាបថា អាយុសង្ខារជារបស់តិចឬ ។ បទថា **មទនីយេ** បានដល់ ក្នុងអារម្មណ៍មានរូបជាដើមដែលនាំសេចក្តីស្រវឹងមក ។ បទថា **ន សន្តសិ** បានដល់ ទ្រង់មិនតក់ស្លុត ។ មានពាក្យអធិប្បាយទុកថា ទ្រង់ជាអ្នកមិនប្រមាទ ហើយក្នុងកាមគុណទាំងឡាយ មានរូបជាដើម ទ្រង់មិនបានតក់ស្លុតចំពោះបរលោក ព្រោះទ្រង់ធ្វើកុសល មានទានជាដើម ឬ ។ បទថា **ទសស្ម** សេចក្តីថា រាជធម៌ ១០ ប្រការ ។ ចេតនាដែលប្រព្រឹត្តទៅក្នុងទានជាដើម ឈ្មោះថា ទាន សីល ៥ និងសីល ១០ ជាដើម ឈ្មោះថា សីល ការលះនូវទេយ្យធម៌ ឈ្មោះថា បរិច្ចាគ ។ ភាពជាអ្នកស្មោះត្រង់ ឈ្មោះថា អាជ្ជវៈ ភាពជាអ្នកទន់ភ្លន់ ឈ្មោះថា មទ្ទវៈ កម្មគឺការរក្សាឧបោសថ ឈ្មោះថា តបៈ ចំណែកខាងដើមនៃមេត្តា ឈ្មោះថា អក្កោធៈ ចំណែកខាងដើមនៃករុណា ឈ្មោះថា អវិហឹសៈ ការអត់ធន់ ឈ្មោះ

ជា ខន្តិ ការមិនអាក់អន់ ឈ្មោះថា អវិរោធនៈ ។ បទថា **អចិន្តេត្វា** បាន ដល់ មិនទាន់គិតដល់គុណសម្បត្តិនេះរបស់យើង ។ បទថា **ភាវទោសំ** បាន ដល់ ទោសដែលកើតដល់ចិត្ត ។ បទថា **អនញ្ញាយ** បានដល់ មិនដឹង ។ បទថា **អស្មាកំ** សេចក្តីថា ឈ្មោះថា ទោសដែលកើតឡើងដល់ចិត្តរបស់ យើង រមែងមិនមាន ហង្សសុមុខៈមិនដឹងដល់វត្ថុដែលខ្លួនគួរដឹងនោះ ទើប បានជាពោលវាចាគ្រោតគ្រាតចេញមក ។ បទថា **អយោនិសោ** បានដល់ ដោយមិនមែនឧបាយ ។ បទថា **យានស្មាសុ** សេចក្តីថា ហង្សឈ្មោះសុមុខៈ នេះ រមែងពោលដល់ទោសដែលមានក្នុងយើង ។ បទថា **ឆយិធំ** កាត់បទ ជា **ឆ ឥធំ** អធិប្បាយថា ព្រោះដូច្នោះ ទើបពាក្យរបស់សុមុខហង្សនេះមិន ដូចជាពាក្យរបស់បុគ្គលដែលមានបញ្ញា គឺដោយហេតុនេះឯង សុមុខហង្ស ទើបប្រាកដដល់យើងដូចមិនមែនបណ្ឌិត ។

សុមុខហង្សបានស្តាប់ពាក្យនោះហើយ ទើបគិតថា ព្រះរាជាទ្រង់ប្រកប ទៅដោយគុណដ៏ធំ ត្រូវអញរុករាន នឹងអាក់អន់ក្នុងព្រះអង្គ អញនឹងសូម ខមាទោសព្រះរាជាចុះ ទើបក្រាបទូលថា

បពិត្រព្រះអង្គជាធំជាង ពួកមនុស្សទូលព្រះបង្គំជាខ្ញុំ មាន
សេចក្តីក្តាំងក្តាត់នោះ ព្រោះពោលពាក្យដោយរួសរាន់ពេក
ដ្បិតកាលដែលរាជហង្សឈ្មោះ ធតរដ្ឋៈ ជាប់ចំណាង ទូល
ព្រះបង្គំជាខ្ញុំ មានសេចក្តីទុក្ខដ៏ធំ ។ បពិត្រព្រះអង្គជារាជ
កុញ្ជរៈ ព្រះអង្គ ( ជាទីពឹង ) នៃពួកទូលព្រះបង្គំជាខ្ញុំ ដូច

ជាបិតា ( ជាទីពឹង ) នៃកូនឬដូចធរណី ( ជាទីពឹង ) នៃពួកកូត សូមព្រះអង្គអត់ទោស ដល់ទូលព្រះបង្គំជាខ្ញុំទាំងឡាយ ដែលត្រូវសេចក្តីខុសគ្របសង្កត់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អតិសារំ** បានដល់ ការភ្លាំងភ្លាត់គ្រប់យ៉ាង ។ បទថា **វេគេន** បានដល់ ខ្ញុំព្រះអង្គ កាលក្រាបទូលសេចក្តីនេះ បានក្រាបទូលដោយរួសរាន់ គឺដោយឆាប់រហ័សពេក ។ បទថា **ទុក្ខំ** បានដល់ សេចក្តីទុក្ខដែលប្រព្រឹត្តទៅផ្លូវចិត្ត មានដល់ទូលបង្គំជាច្រើន ព្រោះដូច្នោះ ទើបទូលព្រះបង្គំបានក្រាបទូលពាក្យនោះដោយអំណាចសេចក្តីក្រោធ បពិត្រមហារាជ សូមទ្រង់អត់ទោសនោះដល់ខ្ញុំចុះ ។ បទថា **បុត្តានំ** បានដល់ ទ្រង់ប្រៀបដូចជាបិតារបស់បុត្តទាំងឡាយ ។ បទថា **ធរណីរិវ** បានដល់ ម្យ៉ាងទៀត សូមទ្រង់ជាទីពឹងរបស់ខ្ញុំ ដូចជាផែនដីជាទីពឹងពំនាក់អាស្រ័យនៃពួកកូត គឺសត្វដូច្នោះ ។ បទថា **អធិបន្នានំ** បានដល់ ខ្ញុំកំពុងត្រូវទោស គឺកំហុសគ្របសង្កត់ហើយ ។ បទថា **ខមស្សុ** សេចក្តីថា សុមុខហង្សនោះ ចុះចាកអាសនៈផ្គងនូវអញ្ជលីដោយស្លាបទាំង ២ ហើយ ទើបក្រាបទូលពាក្យនេះ ។

លំដាប់នោះ ព្រះរាជាក៏ឱបសុមុខហង្សនោះ នាំទៅឲ្យទំលើតាំងមាស កាលទ្រង់ទទួលការសម្តែងទោស ទើបត្រាស់ថា

យើងរីករាយចំពោះអ្នកយ៉ាងនេះ ព្រោះថា អ្នកមិនលាក់នូវការៈនៃចិត្តដ៏កំបាំងរបស់ខ្លួន ម្នាលបក្សី អ្នកបានទម្លាយចោលនូវចិត្តរឹងត្អឹង ម្នាលបក្សី អ្នកជាសត្វមានចិត្តត្រង់ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អនុមោទាម** សេចក្ដីថា យើងអត់ទោសនោះដល់អ្នក ។ បទថា **យំ** សេចក្ដីថា ព្រោះអ្នកមិនបានលាក់កំបាំងនូវវត្ថុដែលគួរបិទបាំងក្នុងចិត្តរបស់ខ្លួន ។ បទថា **ខិលំ** បានដល់ សសរខឿននៃចិត្ត គឺជង្គត់នៃចិត្ត ។

ព្រះរាជាត្រាស់យ៉ាងនេះហើយ ទ្រង់ជ្រះថ្លាក្នុងធម្មកថា របស់ព្រះមហាសត្វ និងសេចក្ដីស្មោះត្រង់របស់សុមុខហង្ស ទើបទ្រង់ព្រះតម្រិះថា ធម្មតាបុគ្គលមានសេចក្ដីជ្រះថ្លា ដោយការធ្វើអាការសម្ដែងនូវសេចក្ដីជ្រះថ្លា កាលទ្រង់ប្រគល់សិរីរាជសម្បត្តិ របស់ព្រះអង្គដល់ស្ដេចហង្សទាំង ២ នោះ ទើបត្រាស់គាថានេះថា

*រតនៈណាមួយ គឺប្រាក់ មាស កែវមុក្ដា កែវពៃទូរ្យជាច្រើន មានទៅក្នុងព្រះរាជនិវេសន៍ ក្នុងដែនកាសី ។ មួយទៀត កែវមណី ស័ង្ខ ( ជាទក្ខិណាវដ្ដ ) កែវមុក្ដា ( មានសណ្ឋានមូល ដូចផ្លែកន្ទួតព្រៃ ) សំពត់ ខ្លឹមចន្ទន៍ក្រហម ស្បែកខ្លាឃ្មុំ កណ្ឌជាវិការៈនៃភ្លុក លោហៈក្រហមនិងលោហៈខ្មៅដ៏ច្រើន យើងឲ្យនូវទ្រព្យទាំងនេះ ដល់អ្នក យើងនឹងលះបង់នូវការៈជាធំដល់អ្នក ដូច្នេះ ។*

បណ្ដាបទទាំងនោះ បទថា **អត្ថិ** បានដល់ ដែលរក្សាទុក ។ បទថា **មុត្តា** បានដល់ កែវមុក្ដាដែលច្នៃហើយនិងមិនទាន់ច្នៃ ។ បទថា **មណយោ** បានដល់ គ្រឿងប្រើប្រាស់ដែលធ្វើដោយកែវមណីទាំងឡាយ ។ បទថា **សង្ខ-**

**មុត្តញ្ច** បានដល់ រតនៈគឺសង្ខទក្ខិណាវដ្ដ និងរតនៈគឺគជ់មូលដូចផ្លែកន្ទួតព្រៃ ។ បទថា **វត្ថិកំ** បានដល់ សំពត់សាច់ម៉ដ្ឋដែលនាំមកអំពីដែនកាសី ។ បទថា **អជិនំ** បានដល់ ស្បែកខ្លាដំបង ។ បទថា **លោហំ កាឡាយសំ** បានដល់ លោហៈដែលមានពណ៌ក្រហម និងលោហៈដែលមានពណ៌ខ្មៅ ។ បទថា **ឥស្សរំ** សេចក្ដីថា យើងសូមលះរាជសម្បត្តិ ក្នុងនគរពារាណសី ដែលមានអាណាខេត្ត ១២ យោជន៍និងស្វេតច្ឆត្រ ដែលប្រដាប់ដោយកម្រងមាសដល់អ្នក ។

ព្រះរាជា កាលទ្រង់ត្រាស់យ៉ាងនេះហើយ ទើបទ្រង់បូជាហង្សទាំង ២ នោះដោយស្វេតច្ឆត្រ ប្រគល់រាជសម្បត្តិឲ្យ ។ លំដាប់នោះ ព្រះមហាសត្វកាលសន្ទនាជាមួយព្រះរាជា ទើបក្រាបទូលថា

បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ព្រះអង្គបានគោរព ធ្វើសក្ការៈ ( ដល់យើងទាំងឡាយ ) ដោយពិត សូមព្រះអង្គជាអាចារ្យរបស់យើង ដែលជាអ្នកប្រព្រឹត្តក្នុងធម៌ទាំងឡាយ ។ បពិត្រព្រះអង្គជាអាចារ្យ ព្រះអង្គបានអនុញ្ញាត បើកយើងទាំងឡាយឲ្យទៅដោយស្រួលហើយ បពិត្រព្រះអង្គ ជាអ្នកទូន្មាននូវសត្រូវយើងទាំងឡាយ សូមធ្វើប្រទក្សិណនូវព្រះអង្គហើយទៅជួបនឹងពួកញាតិ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ធម្មេសុ** បានដល់ ធម៌ គឺកុសលកម្មបថ ១០ ប្រការ ។ បទថា **អាចរិយោ** សេចក្ដីថា ព្រះអង្គជាអ្នកឈ្លាសជាងទូលព្រះ

បង្គំទាំង ២ ព្រោះហេតុនោះ សូមទ្រង់ជាអាចារ្យរបស់ទូលព្រះបង្គំចុះ ម្យ៉ាងទៀត ព្រះមហាសត្វទូលថា សូមទ្រង់ជាអាចារ្យរបស់ខ្ញុំទាំង ២ ចុះ ព្រោះព្រះអង្គត្រាស់រាជធម៌ ១០ ប្រការ និងព្រោះព្រះអង្គបង្ហាញទោសដល់សុមុខហង្ស ហើយទ្រង់ធ្វើនូវការអត់ទោស ព្រោះហេតុនោះ សូមទ្រង់ជាអាចារ្យរបស់ខ្ញុំទាំង ២ ដោយហេតុដែលឲ្យសិក្សាមារយាទក្នុងថ្ងៃនេះចុះ ។ បទថា **បស្សេមុរិន្ទម** សេចក្តីថា បពិត្រព្រះអង្គដ៏ចម្រើន ទ្រង់ញ៉ាំញីនូវសត្រូវ ខ្ញុំនឹងឃើញ ( ពួកញាតិទាំងឡាយ ) ។

ព្រះរាជាអនុញ្ញាតឲ្យហង្សទាំង ២ នោះត្រឡប់ទៅ កាលព្រះពោធិសត្វសម្តែងធម៌នោះឯង អរុណក៏រះឡើង ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

ព្រះរាជាក្នុងដែនកាសី ទ្រង់បានគិត បានប្រឹក្សានូវហេតុដ៏គួរ
តាមពិត ពេញមួយរាត្រី ហើយទ្រង់អនុញ្ញាតឲ្យរាជហង្សដ៏
ប្រសើរខ្ពង់ខ្ពស់ជាងពួកហង្សហើរទៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យថាកថំ** សេចក្តីថា ព្រះបាទកាសិករាជទ្រង់ត្រិះរិះនិងសិក្សាដល់អត្ថគ្រប់យ៉ាងដែលទ្រង់គួរត្រិះរិះ និងប្រឹក្សាជាមួយនឹងស្តេចហង្សទាំង ២ នោះ ។ បទថា **អនុញ្ញាសិ** បានដល់ ទ្រង់អនុញ្ញាតថា អ្នកទាំង ២ ចូរនាំគ្នាត្រឡប់ទៅចុះ ។

ព្រះពោធិសត្វ កាលព្រះរាជាទ្រង់អនុញ្ញាតយ៉ាងនេះហើយ ទើបថ្វាយឱវាទព្រះរាជាថា សូមទ្រង់កុំប្រមាទ សូមសោយរាជសម្បត្តិដោយធម៌ចុះ

ហើយឲ្យព្រះរាជាប្រតិស្ឋានក្នុងសីល ៥ ព្រះរាជាបង្អោនលាជលាយដោយទឹកឃ្មុំនិងទឹកផ្អែមឲ្យដល់ស្តេចហង្សទាំង ២ នោះ ដោយភាជនៈមាស ក្នុងកាលស្រេចអាហារកិច្ចហើយ ទើបទ្រង់បូជាដោយគ្រឿងក្រអូប និងកម្រងផ្កាជាដើម យកប្រអប់មាសទ្រព្រះពោធិសត្វ លើកឡើងដោយព្រះអង្គឯង ឯព្រះនាងខេមាទេវីលើកសុមុខហង្សឡើង ។ លំដាប់នោះ ព្រះរាជាក៏ឲ្យបើកសីហបញ្ជរ ហើយត្រាស់ថា អ្នកទាំង ២ ចូរត្រឡប់ទៅក្នុងកាលអរុណរះចុះ ហើយទ្រង់លែងហង្សទាំងនោះ ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

លំដាប់នោះ កាលដែលរាត្រីនោះអស់ហើយ ព្រះអាទិត្យក៏រះឡើង កាលព្រះរាជាក្នុងដែនកាសីទ្រង់កំពុងទតមើល សត្វហង្សទាំងពីរ ក៏ហើរចេញទៅអំពីទីនៅរបស់ព្រះរាជា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិគាហិសុំ** បានដល់ ហើរឡើងលើអាកាស ។

ព្រះមហាសត្វហើរឡើងអំពីប្រអប់មាស ហើយលួងលោមព្រះរាជាថា សូមទ្រង់កុំទោមនស្សឡើយ ព្រះអង្គគប្បីជាបុគ្គលមិនប្រមាទ ទ្រង់ប្រព្រឹត្តក្នុងឱវាទរបស់ខ្ញុំចុះ ដូច្នេះហើយ ទើបនាំសុមុខហង្សហើរទៅកាន់ភ្នំចិត្តកូដនោះឯង ។ ឯហង្ស ៩៦០០០ នោះឯង នាំគ្នាហើរចេញអំពីគុហារមាស ទំលើកំពូលភ្នំ ឃើញស្តេចហង្សត្រឡប់មក ទើបហើរទៅទទួលចោមរោមហើយ ហង្សទាំង ២ នោះ ចោមរោមដោយពួកញាតិ ចូលទៅកាន់ភ្នំចិត្តកូដ ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

ហង្សទាំងឡាយ លុះបានឃើញបក្សីហង្សដ៏ប្រសើរទាំង ២ នោះ មិនមានរោគ មកដល់ហើយក៏ធ្វើនូវសំឡេងថា កេកាៗ ដូច្នេះ សូរស័ព្ទរំពងក៏កើតឡើង ។ បក្សីហង្សជាអណ្ឌជាតិទាំងនោះ មានចិត្តរីករាយ ព្រោះម្ចាស់រួចហើយ ជាសត្វគោរពម្ចាស់ ជាសត្វបាននូវទីពឹង ក៏ចោមរោមម្ចាស់ ដោយជុំវិញដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អក្ករុំ** បានដល់ បន្លឺសំឡេងទ្រហឹងអឺងកង ។ បទថា **បរមេ** បានដល់ ឧត្តម ។ បទថា **កេកា** សេចក្តីថា ពួកហង្សទាំងនោះ បានបន្លឺសំឡេងថា កេកា តាមភាសារបស់ខ្លួន ។ បទថា **ភត្តុគារវា** បានដល់ ពេញទៅដោយសេចក្តីគោរពដល់ស្តេចហង្សដែលជាម្ចាស់ ។ បទថា **បរិកិរឹសុ** សេចក្តីថា ហង្សទាំងនោះមានសេចក្តីត្រេកអរ ដោយហេតុដែលផុតចាកភ័យមកបាន ទើបនាំគ្នាចូលទៅចោមរោមម្ចាស់ដោយជុំវិញ ។ បទថា **លទ្ធបច្ចយា** បានដល់ បាននូវទីពឹងពំនាក់ហើយ ។

ពួកហង្សទាំងនោះ កាលចោមរោមយ៉ាងនេះហើយ ក៏នាំគ្នាសាកសួរថា បពិត្រមហារាជ ទ្រង់ផុតមកបានដូចម្តេច ។ ព្រះមហាសត្វ ក៏និទានដល់ការដែលខ្លួនផុតមកបាន ព្រោះអាស្រ័យសុមុខហង្សនិងរៀបរាប់ដល់កម្ម ដែលរាជត្រកូលធ្វើនិងកម្មដែលលុទ្ទបុត្តធ្វើ ឲ្យពួកហង្សទាំងនោះស្តាប់ ពួកហង្សបានស្តាប់រឿងនោះហើយ ទើបឲ្យពរថា សុមុខហង្សសេនាបតី និងនាយព្រានចូរជាអ្នកមានសេចក្តីសុខ ប្រាសចាកទុក្ខ មានអាយុយឺនយូរចុះ ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់អភិសម្ពុទ្ធគាថានេះថា

ប្រយោជន៍គ្រប់យ៉ាង របស់ពួកជនអ្នកមានមិត្តល្អ រមែងជា
ប្រយោជន៍គួរចម្រើន ដូចហង្សឈ្មោះធតរដ្ឋៈនិងហង្សឈ្មោះ
សុមុខៈ បានចូលទៅជួបនឹងពួកញាតិ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មិត្តវតំ** បានដល់ ដល់ព្រមដោយកល្យាណមិត្ត ។ បទថា **បទក្ខិណា** បានដល់ រមែងសម្រេចសេចក្តីសុខប្រកបទៅដោយសេចក្តីចម្រើន ។ បទថា **ធតរដ្ឋា** សេចក្តីថា ប្រៀបដូចស្តេចហង្សធតរដ្ឋៈ គឺស្តេចហង្ស និងសុមុខហង្សសេនាបតីដល់ព្រមដោយកល្យាណមិត្តទាំង ២ គឺព្រះរាជានិងនាយលុទ្ទបុត្ត ។ បទថា **ញាតិសង្ឃមុបាគមុំ** សេចក្តីថា ប្រយោជន៍របស់ហង្សទាំង ២ នោះ ពោលគឺការបានត្រឡប់មកដល់ពួកញាតិជាសេចក្តីសុខហើយ យ៉ាងណា ប្រយោជន៍ទាំងឡាយរបស់បុគ្គលដែលដល់ព្រមដោយកល្យាណមិត្ត ក៏រមែងប្រកបទៅដោយសេចក្តីសុខ សេចក្តីចម្រើន យ៉ាងនោះដូចគ្នា ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះ មកសម្តែងហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អានន្ទ មិនមែនលះបង់ជីវិតដើម្បីតថាគតក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន អានន្ទ ក៏បានលះបង់ជីវិតដើម្បីតថាគតមកហើយដូចគ្នា ហើយទើបទ្រង់ប្រជុំជាតកថា នាយព្រានក្នុងកាលនោះ បានមកជាភិក្ខុឈ្មោះឆន្នៈ ក្នុងកាលឥឡូវនេះ ព្រះនាងខេមាទេវីក្នុង

កាលនោះ បានមកជាភិក្ខុនីឈ្មោះខេមា ព្រះរាជាក្នុងកាលនោះ បានមកជាសារីបុត្ត សុមុខហង្សសេនាបតីក្នុងកាលនោះ បានមកជាភិក្ខុឈ្មោះអានន្ទ បរិស័ទក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ក្នុងកាលឥឡូវនេះ ឯស្តេចហង្សឈ្មោះធតរដ្ឋៈក្នុងកាលនោះ គឺតថាគតដ៏ជាសម្មាសម្ពុទ្ធនេះឯង ។

## អដ្ឋកថា មហាហំសជាតក ចប់

## សុធាភោជនជាតក

[ ២៤៩ ] ( កោសិយសេដ្ឋីពោលថា ) ខ្ញុំមិនមែនទិញ មិនមែនលក់ទេ មួយទៀត ការសន្សំទុករបស់ខ្ញុំ ក៏មិនមានក្នុងទីនេះដែរ របស់នេះមានប្រមាណតិច មានសភាពដ៏ក្រណាស់ បាយចំនួនអឌ្ឍនាឡិនេះ មិនល្មមដល់ជនពីរនាក់ទេ ។

[ ២៥០ ] ( សក្កៈទេវរាជពោលថា ) បុគ្គលគប្បីឲ្យវត្ថុតិច អំពីវត្ថុតិច គួរឲ្យវត្ថុពាក់កណ្តាល អំពីវត្ថុពាក់កណ្តាល គួរឲ្យវត្ថុច្រើន អំពីវត្ថុច្រើន ការមិនឲ្យ មិនកើតទេ ។ ម្នាលកោសិយៈ ព្រោះហេតុនោះ យើងនិយាយនឹងអ្នក ចូរអ្នកឲ្យនូវទានផង ចូរបរិភោគផង អ្នកចូរឡើងកាន់អរិយមគ្គ ព្រោះថា បុគ្គលអ្នកបរិភោគម្នាក់ឯង មិនបានសេចក្តីសុខទេ ។

[ ២៥១ ] ( ចន្ទទេវបុត្ត... ) បុគ្គលណា កាលបើភ្ញៀវអង្គុយហើយ បរិភោគនូវភោជនម្នាក់ឯង ការបូជារបស់បុគ្គលនោះ ជាការឥតអំពើ ទាំងការព្យាយាមជាហេតុឲ្យកើតទ្រព្យ ( របស់បុគ្គលនោះ ) ក៏ឥតអំពើដែរ ។ ម្នាលកោសិយៈ ព្រោះហេតុនោះ យើងនិយាយនឹងអ្នក ចូរអ្នកឲ្យទានផង ចូរបរិ-ភោគផង ចូរឡើងកាន់អរិយមគ្គ ព្រោះថា បុគ្គលអ្នកបរិភោគម្នាក់ឯង មិនបានសេចក្តីសុខទេ ។

[ ២៥២ ] ( សុរិយទេវបុត្ត... ) បុគ្គលណា កាលបើភ្ញៀវអង្គុយហើយ មិនបរិភោគនូវភោជនម្នាក់ឯង ការបូជារបស់បុគ្គលនោះ ជាការបូជាពិតមែន ទាំងការព្យាយាមជាហេតុឲ្យកើតទ្រព្យ ( របស់បុគ្គលនោះ ) ក៏ជាការព្យាយាមពិតមែន ។ ម្នាលកោសិយៈ ព្រោះហេតុនោះ យើងនិយាយនឹងអ្នក

ចូរអ្នកឲ្យទានផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គ ព្រោះថា បុគ្គលអ្នកបរិភោគម្នាក់ឯង មិនបានសេចក្ដីសុខទេ ។

[ ២៥៣ ] ( មាតលិទេវបុត្ត... ) បុរសបូជាស្រះក្ដី ទន្លេឈ្មោះពហុកា ឬស្រះបោក្ខរណីឈ្មោះគយាក្ដី កំពង់ឈ្មោះទោណៈ ឬកំពង់ឈ្មោះតិម្ពរុក្ខ ទន្លេដ៏ធំមានខ្សែទឹកដ៏រហ័សក្ដី ។ ការបូជារបស់បុរសនោះក្នុងទីនោះ រមែងមាន ( ផល ) ទាំងការព្យាយាមជាហេតុឲ្យកើតទ្រព្យរបស់បុរសនោះ ក្នុងទីទាំងនោះ ក៏មានផលដែរ ព្រោះថា បុរសនោះ កាលបើភ្ញៀវអង្គុយនៅហើយ មិនគួរបរិភោគភោជនម្នាក់ឯងទេ ។ ម្នាលកោសិយៈ ព្រោះហេតុនោះ យើងនិយាយនឹងអ្នក ចូរអ្នកឲ្យទានផង បរិភោគផង ចូរឡើងកាន់អរិយមគ្គ ព្រោះថា បុគ្គលអ្នកបរិភោគភោជនម្នាក់ឯង មិនបានសេចក្ដីសុខទេ ។

[ ២៥៤ ] ( បញ្ចសិខទេវបុត្ត... ) បុគ្គលណា កាលបើភ្ញៀវអង្គុយនៅហើយ បរិភោគភោជនម្នាក់ឯង បុគ្គលនោះ ឈ្មោះថា លេបសន្ទូចដែលមានខ្សែដ៏វែង ព្រមទាំងចំណង ។ ម្នាលកោសិយៈ ព្រោះហេតុនោះ យើងនិយាយនឹងអ្នក ចូរអ្នកឲ្យទានផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គ ព្រោះថា បុគ្គលអ្នកបរិភោគម្នាក់ឯងមិនបានសុខទេ ។

[ ២៥៥ ] ( កោសិយសេដ្ឋី... ) អើហ្ន៎ ព្រាហ្មណ៍ទាំងនេះ ពេញជាមានសម្បុរល្អលើសលុប ចុះឆ្កែនេះ របស់ពួកអ្នក ក្លែងខ្លួនឲ្យមានពណ៌ផ្សេងៗ រុងរឿងប្លែកៗ ព្រោះហេតុអ្វី ម្នាលព្រាហ្មណ៍ទាំងឡាយ អ្នកទាំងឡាយ ចូរប្រាប់យើង អ្នកទាំងឡាយជាអ្វី ។

[ ២៥៦ ] ( ព្រះឥន្ទ្រ.... ) ព្រាហ្មណ៍ទាំងពីរនាក់ ដែលមកក្នុងទីនេះ គឺចន្ទទេវបុត្ត និងសុរិយទេវបុត្ត ចំណែកព្រាហ្មណ៍នេះ គឺមាតលិទេវបុត្ត ដែលជាទេវសារថី ឯយើងជាសក្កៈ ជាធំជាងពួកទេវតាក្នុងជាន់តាវត្តិង្ស ឯព្រាហ្មណ៍នេះ គេហៅថា បញ្ចសិខៈ ។

[ ២៥៧ ] ល្បែងទះដៃក្តី ស្គរសម្ភោរក្តី ស្គរតូចនិងស្គរធំក្តី តែងញុំាងបញ្ចសិខទេវបុត្តនេះ ដែលដេកលក់ឲ្យភ្ញាក់ឡើងបាន លុះបញ្ចសិខទេវបុត្តនោះភ្ញាក់ឡើងហើយ រមែងរីករាយ ។

[ ២៥៨ ] ពួកជនណានីមួយ មានសេចក្តីកំណាញ់ស្វិតស្វាញ ជាអ្នកប្រទេចផ្តាសាទូវសមណព្រាហ្មណ៍ ពួកជននោះ ដាក់ចុះនូវរាងកាយ គឺសរីរៈ ក្នុងលោកនេះ លុះបែកធ្លាយរាងកាយហើយ រមែងទៅកើតក្នុងនរក ។ ពួកជនណានីមួយ កាលប្រាថ្នានូវសុគតិឋិតនៅក្នុងធម៌ គឺការសង្រួមនិងការបែករំលែកនូវទាន ពួកជននោះ ដាក់ចុះនូវរាងកាយគឺសរីរៈក្នុងលោកនេះ លុះបែកធ្លាយរាងកាយ រមែងទៅកាន់សុគតិ ។

[ ២៥៩ ] អ្នកជាញាតិរបស់យើង ក្នុងជាតិមុន អ្នកនោះ ឈ្មោះកោសិយៈ ជាបុគ្គលកំណាញ់ មានធម៌ដ៏លាមក យើងមកក្នុងទីនេះ ដើម្បីប្រយោជន៍ដល់អ្នកតែម្យ៉ាងថា ញាតិរបស់យើងដែលមានធម៌ដ៏លាមក កុំទៅកាន់នរកឡើយ ។

[ ២៦០ ] ( កោសិយសេដ្ឋី... ) អ្នកទាំងឡាយនោះ ជាអ្នកប្រាថ្នានូវប្រយោជន៍ដល់ខ្ញុំដោយពិត ព្រោះថា អ្នកទាំងឡាយបានប្រៀនប្រដៅខ្ញុំ

ដោយល្អ ខ្ញុំនោះនឹងធ្វើតាមពាក្យទាំងអស់ ដែលអ្នកទាំងឡាយជាអ្នកស្វែងរកប្រយោជន៍ បានពោល ហើយដូច្នោះ ។ ខ្ញុំនោះវៀរចាកសេចក្តីកំណាញ់ក្នុងថ្ងៃនេះឯង ខ្ញុំមិនធ្វើអំពើអាក្រក់តិចតួច ខ្ញុំមិនមែនជាមិនឲ្យវត្ថុតិចតួចទេ បើខ្ញុំមិនទាន់បានឲ្យទានទឹក មិនផឹកនូវទឹកទេ ។ បពិត្រព្រះវាសវៈ កាលខ្ញុំឲ្យទានសព្វកាលយ៉ាងនេះ ភោគៈទាំងឡាយរបស់ខ្ញុំមុខជានឹងអស់ទៅ បពិត្រសក្កៈ តអំពីនេះទៅ ខ្ញុំនឹងលះនូវកាមទាំងឡាយតាមចំណែកហើយបួស ។

[ ២៦១ ] ( អភិសម្ពុទ្ធគាថា ) ពួកទេវធីតានោះ ដែលទេវរាជរក្សាហើយក៏រីករាយ លើភ្នំគន្ធមាទន៍ដ៏ប្រសើរ ដែលជាភ្នំខ្ពង់ខ្ពស់ គ្រានោះ ឥសីដ៏ប្រសើរ ជាអ្នកអាចទៅកាន់លោកទាំងអស់ បានកាន់យកនូវផ្កាទុមវសាខា ដែលរីកស្គុសស្គាយនិមន្តមក ។ ផ្កានោះជាផ្កាស្អាតមានក្លិនក្រអូប ដែលពួកទេវតាក្នុងជាន់ត្រៃត្រិង្ស ធ្វើសក្ការៈហើយ ជាផ្កាដ៏ឧត្តម ដែលពួកទេវតាដ៏ប្រសើរសេពហើយ ពួកមនុស្សដទៃក្តី ពួកអសុរក្តី វៀរលែងតែពួកទេវតាមិនដែលបានឡើយ ព្រោះថា ផ្កានោះ ជាប្រយោជន៍ដ៏សមគួរដល់ ( ពួកទេវតាទាំងនោះ ) ។ លំដាប់នោះ នារីទាំង ៤ ដែលជាធំលើសអស់ពួកស្រី មានស្បែកភ្លឺដូចមាស ឈ្មោះអាសា ១ សទ្ធា ១ សិរី ១ ហិរី ១ បានក្រោកឡើងហើយទូលសួរនារទតាបសជាអ្នកប្រាជ្ញ ទាំងជាព្រាហ្មណ៍ដ៏ប្រសើរដូច្នេះថា បពិត្រមហាមុនីដ៏ប្រសើរ បើផ្កាបារិច្ឆត្តព្រឹក្សនេះ លោកមិនឧទ្ទិស ( អ្នកណាទេ ) សូមលោកឲ្យដល់ពួកយើង គតិ ( នៃចិត្ត ) ទាំងពួង សូមសម្រេចដល់លោក ទោះបីលោកក៏សូម ( ឲ្យមានមេត្តា ) ចំពោះពួកយើង

ដូចជាព្រះវស្សាៈដែរ ។ នារទតាបស បានឃើញពួកនារីមកសូមនូវផ្កានោះ ក៏ពោលថា នាងនិយាយនូវពាក្យនាំឲ្យបង្កជម្លោះ ប្រយោជន៍តិចតួចដោយផ្កាឈើទាំងនេះ មិនមានដល់យើងទេ នាងណា ដែលចម្បងជាងនាងទាំងឡាយ នាងនោះ ចូរប្រដាប់ផ្កានេះចុះ ។

[ ២៦២ ] ( ពួកទេវធីតា... ) បពិត្រនារទតាបសដ៏ឧត្តម សូមលោករមិលមើលនូវពួកយើងចុះ បើលោកប្រាថ្នានឹងឲ្យដល់នាងណា សូមលោកបោះផ្កានោះ សំដៅទៅនាងនោះ បពិត្រនារទតាបស ព្រោះថា បណ្តាពួកយើងបើលោកឲ្យដល់នាងណា នាងនោះឯង យើងសន្មតថា ប្រសើរបំផុតជាងគេ ។

[ ២៦៣ ] ( នារទតាបស... ) នែនាងមានខ្លួនដ៏ល្អ សំដីនេះមិនគួរទេបុគ្គលដូចម្តេច ដែលហៅថាព្រាហ្មណ៍ បុគ្គលដូចម្តេច គួរពោលពាក្យដែលនាំបង្កជម្លោះ បើនាងទាំងឡាយ ដែលមិនដឹងធម៌ដ៏ខ្ពង់ខ្ពស់ក្នុងលោកនេះទេ ចូរទៅសួរព្រះឥន្ទ្រ ដែលជាធំជាងពួកទេវតាចុះ ។

[ ២៦៤ ] ពួកទេវធីតាទាំងនោះ ដែលនារទតាបស បានពោលយ៉ាងនេះហើយ ក៏មានចិត្តក្រេវក្រោធយ៉ាងក្រៃលែង ជាស្ត្រីស្រវឹងដោយសេចក្តីស្រវឹងនឹងសម្បុរ ហើយបានទៅកាន់សំណាក់ព្រះឥន្ទ្រ ជាសហស្សចក្ខុ រួចសួរនូវព្រះឥន្ទ្រ ដែលជាធំជាងពួកទេវតាថា ( បណ្តាពួកយើង ) នាងណាប្រសើរជាងគេ ។

[ ២៦៥ ] ព្រះឥន្ទ្រដ៏ប្រសើរជាងពួកទេវតា ដែលពួកទេវតា តែង

ប្រណម្យអញ្ជលី លុះបានឃើញនូវពួកទេវធីតាទាំងនោះ មានចិត្តខ្វល់ខ្វាយ ក៏បានពោលតបដូច្នេះថា នែនាងមានជោគល្អ នាងទាំងអស់ប្រហែលៗគ្នាទេ ម្នាលនាងដ៏ចម្រើន ចុះបុគ្គលណាហ្ន៎ បានពោលពាក្យដែលនាំបន្ទជម្លោះ ។

[ ២៦៦ ] ( ពួកទេវធីតា... ) នារទតាបសណា ជាមហាមុនី អាចត្រាច់ទៅក្នុងលោកទាំងអស់បាន ឋិតនៅក្នុងធម៌ មានព្យាយាមដ៏ទៀងទាត់ នារទតាបសនោះ បានពោលនឹងពួកយើងលើភ្នំដ៏ប្រសើរ ឈ្មោះគន្ធមាទន៍ថា បើនាងទាំងឡាយ មិនដឹងនូវធម៌ដ៏ឧត្តមក្នុងលោកនេះទេ ចូរទៅសួរព្រះឥន្ទ្រ ដែលជាធំជាងពួកទេវតាចុះ ។

[ ២៦៧ ] ( ព្រះឥន្ទ្រ... ) ម្នាលនាងមានខ្លួនដ៏ប្រសើរ តាបសឯណោះ ជាមហាមុនី ជាអ្នកត្រាច់ទៅក្នុងព្រៃធំ បើមិនទាន់ឲ្យទាន មិនបរិភោគនូវភត្តទេ កោសិយតាបសនោះ ពិចារណាហើយ ទើបឲ្យនូវទានទាំងឡាយ ព្រោះថា តាបសនោះ នឹងឲ្យផ្កាដល់នាងណា នាងនោះឯង ពេញជាប្រសើរជាងគេ ។

[ ២៦៨ ] តាបសឯណោះនោះ គង់នៅក្នុងទិសខាងត្បូង នៃភ្នំហិមវន្ត ប្របច្នេរទន្លេគង្គា កោសិយតាបសនោះ បានទឹកនឹងភោជនដោយកម្រ ម្នាលមាតលិទេវបុត្តជាទេវសារថី អ្នកចូរញុំាងសុធាភោជន ឲ្យសម្រេចដល់កោសិយតាបសចុះ ។

[ ២៦៩ ] មាតលិទេវបុត្តនោះ លុះព្រះឥន្ទ្រប្រសើរជាងទេវតាប្រើហើយ ក៏ឡើងជិះទេវរថដែលទឹមដោយសេះ ១០០០ ហើយចូលទៅកាន់

អាស្រមយ៉ាងរហ័ស មិនបង្ហាញកាយឲ្យឃើញ ស្រាប់តែប្រគេននូវសុធាភោជន ដល់តាបសជាអ្នកប្រាជ្ញ ។

[ ២៧០ ] ( កោសិយតាបស... ) កាលដែលអាត្មាអញ បម្រើនូវការបូជាភ្លើងនិងព្រះអាទិត្យដ៏ឧត្តម ដែលបន្ទោបង់នូវងងឹតក្នុងលោក អ្នកណាហ្ន៎ ដូចព្រះវាសវៈ កន្លងនូវពួកទេវតាទាំងអស់ ដាក់សុធាភោជនលើដៃទាំងពីររបស់អញឬ ។ សុធាភោជននោះដ៏សដូចជាស័ង្ខ គួររមិលមើលរកអ្វីប្រៀបគ្មាន ជាភោជនស្អាត មានក្លិនក្រអូប មានសភាពគួរពេញចិត្តយ៉ាងចំឡែក ភ្នែករបស់អញតាំងអំពីកើតមក មិនដែលឃើញសោះឡើយ ទេវតាណាហ្ន៎ ដាក់នូវសុធាភោជន លើដៃទាំងពីររបស់អញឬ ។

[ ២៧១ ] ( មាតលិទេវបុត្ត... ) បពិត្រលោកជាមហាមុនី អ្នកស្វែងរកនូវគុណដ៏ធំ ខ្ញុំដែលព្រះឥន្ទ្រជាធំបានប្រើមក ខ្ញុំក៏បាននាំសុធាភោជនយ៉ាងរួសរាន់ លោកបានស្គាល់នូវខ្ញុំថា ឈ្មោះមាតលិទេវបុត្ត ជាទេវសារថី សូមលោកឆាន់នូវភត្តដ៏ឧត្តមចុះ លោកកុំប្រកែកករាំងឡើយ ។ ឯសុធាភោជននោះ លុះលោកបរិភោគហើយ រមែងកម្ចាត់បង់បាបធម៌ ១២ យ៉ាងបានគឺ សេចក្តីឃ្លាន ១ ការស្រេក ១ សេចក្តីអផ្សុក ១ ក្រវល់ក្រវាយកាយ ១ លំបាកកាយ ១ ក្រោធ ១ ចងសេចក្តីក្រោធក្នុងចិត្ត ១ ឈ្លោះប្រកែក ១ ញុះញង់ ១ ត្រជាក់ ១ ក្តៅ ១ ខ្ជិល ១ ដ្បិតភោជននេះមានរសដ៏ឧត្តម ។

[ ២៧២ ] ( កោសិយៈ... ) ម្នាលទេវបុត្តឈ្មោះមាតលិ ការដែលអាត្មាមិនបានឲ្យទានជាមុនសិនហើយបរិភោគមិនគួរទេ ព្រោះវត្តនេះជាវត្ត

ឧត្តមរបស់អាត្មា ឯការបរិភោគតែម្នាក់ឯង ជាអំពើដែលព្រះអរិយៈមិនបូជាឡើយ មួយទៀត បុគ្គលអ្នកមិនបានចែករំលែក រមែងមិនបាននូវសេចក្តីសុខទេ ។

[ ២៧៣ ] ពួកជនណាមួយ ជាអ្នកសម្លាប់ស្ត្រី ជាអ្នកប្រព្រឹត្តបរទារិកកម្ម ឬក៏ពួកជនណា ជាអ្នកប្រទូស្តមិត្ត ជេរប្រទេចពួកបុគ្គលអ្នកមានវត្តល្អ ជនទាំងអស់នោះ សុទ្ធតែមានសេចក្តីកំណាញ់ដ៏ថោកទាបជាគម្រប់ ៥ ព្រោះហេតុនោះ អាត្មាបើមិនបានឲ្យស្អូម្បីនូវទឹក ក៏មិនបរិភោគទេ ។ មួយទៀត អាត្មានោះ ត្រូវតែឲ្យទានដែលអ្នកប្រាជ្ញសរសើរហើយ ដល់ស្ត្រី ឬបុរស ដ្បិតបុគ្គលអ្នកមានសទ្ធា អ្នកដឹងនូវពាក្យស្អូម ប្រាសចាកសេចក្តីកំណាញ់ទាំងនុ៎ះ លោកសន្មតថា ជាអ្នកមានសច្ចដ៏ស្អាត ក្នុងលោកនេះ ។

[ ២៧៤ ] ( អភិសម្ពុទ្ធគាថា ) លំដាប់នោះ នាងកញ្ញាទាំង ៤ នាក់ ដែលមានស្បែកដូចជាមាស ឈ្មោះអាសា ១ សទ្ធា ១ សិរី ១ ហិរី ១ ដែលព្រះឥន្ទ្រប្រសើរជាងទេវតា បានយល់ព្រម ប្រើទៅហើយ នាងក៏មកកាន់អាស្រមជាទីនៅនៃកោសិយតាបសនោះ ។ កោសិយតាបស បានឃើញនាងកញ្ញាទាំង ៤ នោះ ដែលមានចិត្តត្រេកអរយ៉ាងលើសលុបទាំងអស់គ្នា មានវណ្ណៈដ៏ល្អដូចអណ្តាតភ្លើង ឋិតនៅក្នុងទិសទាំង ៤ ហើយ បានពោលដូច្នេះក្នុងទីចំពោះមុខនៃមាតលិទេវបុត្តថា ម្នាលទេវតា នាងជាអ្វី មានកាយប្រដាប់ហើយ បានញុំាងទិសខាងកើតឲ្យភ្លឺ ដូចជាផ្កាយព្រឹកដ៏ប្រសើរ ម្នាលនាងមានរាងកាយដូចជារូបប្រៀប ជាវិការៈនៃមាស អាត្មាសូមសួរនាង ចូរ

នាងប្រាប់អាត្មា នាងជាទេវតាឈ្មោះអ្វី ។

[ ២៧៥ ] ( នាងសិរី... ) ខ្ញុំជាទេវធីតាឈ្មោះសិរី ដែលគេបូជាក្នុងពួកមនុស្ស មិនចូលទៅគប់រកនូវសត្រូវលាមកគ្រប់កាល មកកាន់សំណាក់លោក ព្រោះទាស់ទែងគ្នាអំពីសុធាភោជន បពិត្រលោកមានប្រាជ្ញាដ៏ប្រសើរ ព្រោះហេតុនោះ សូមលោកចែកនូវសុធាភោជនដល់ខ្ញុំ ។ បពិត្រលោកជាមហាមុនី ខ្ញុំប្រាថ្នាសុធាភោជនរបស់ជនណា ជននោះឯងរមែងរីករាយដោយកាមគ្រប់យ៉ាង បពិត្រលោកដ៏ខ្ពង់ខ្ពស់ជាងពួកជនអ្នកបូជាភ្លើង សូមលោកដឹងនូវខ្ញុំថា ជាទេវធីតាឈ្មោះសិរី បពិត្រលោកអ្នកមានប្រាជ្ញាដ៏ប្រសើរ ព្រោះហេតុនោះ សូមលោកចែកនូវសុធាភោជនដល់ខ្ញុំ ។

[ ២៧៦ ] ( កោសិយ... ) ពួកជនដែលប្រកបដោយសិល្បវិជ្ជា ចរណៈនិងប្រាជ្ញា ជាអ្នកស្ទាត់ជំនាញដោយអំពើរបស់ខ្លួន ត្រឡប់ជាថោកទាបជាងនាងវិញ មិនបានយស ឬសេចក្តីសុខនោះតិចតួចសោះឡើយ អំពើណាដែលនាងបានធ្វើហើយ អំពើនោះ មិនប្រពៃទេ ។ អាត្មាបានឃើញនូវជនខ្ជិលច្រអូស បរិភោគច្រើន ទាំងមានត្រកូលថោកទាប មានរូបអាក្រក់បុរសនោះ ដែលនាងបានរក្សាហើយ ក៏ប្រែទៅជាអ្នកមានសិរី អាចប្រើនូវជនដែលមានជាតិខ្ពស់ ដូចជនអ្នកមានភោគៈ មានសេចក្តីសុខ ប្រើនូវខ្ញុំកំដរ ។ ព្រោះហេតុនោះ យើងដឹងនូវនាង ជាស្រីមិនមានសច្ចៈ គប់រកឥតរើសមុខ ជាស្រីល្ងង់បៀតបៀនអ្នកប្រាជ្ញ ស្រីប្រហែលដូចនាង មិនគួរទទួលអាសនៈនិងទឹកទេ សុធាភោជននឹងមានពីណា នាងចូរទៅចុះ អាត្មាមិនពេញចិត្តនឹងនាងទេ ។

[ ២៧៧ ] នាងជាអ្វី មានចង្កូមស ពាក់កុណ្ឌល មានគ្រឿងប្រដាប់ដើមដៃដ៏វិចិត្រ ទ្រទ្រង់គ្រឿងប្រដាប់មាស ដ៏រលីងស្អាត ស្លៀកដណ្តប់សំពត់មានពណ៌ដូចទនៃទឹកដែលគេស្រោចចុះ សៀតត្រួយឈើមានពណ៌ក្រហមដូចភ្លើងឆេះស្បូវ ល្អរុងរឿង ។ នាងដូចមេម្រឹគដែលព្រានព្រៃបាញ់ខុសហើយ ក៏ភ្ញាក់ផ្អើលក្រឡេកមើលភ្លៀកៗ ដូច្នោះ ម្នាលនាងមានភ្នែកស្រទន់ បុគ្គលណា ជាគម្រប់ពីរនឹងនាងក្នុងទីនេះ នាងតែម្នាក់ឯង នៅក្នុងព្រៃធំ មិនខ្លាចទេឬ ។

[ ២៧៨ ] ( នាងអាសា... ) បពិត្រកោសិយតាបស ក្នុងទីនេះ មិនមានបុគ្គលជាគម្រប់ពីរនឹងខ្ញុំទេ ខ្ញុំជាទេវតាឈ្មោះអាសា កើតក្នុងភពតាវត្តិង្ស មកកាន់សំណាក់លោកដោយ ( សេចក្តីប៉ុនប៉ង ) នូវសុធាភោជន បពិត្រលោកអ្នកមានប្រាជ្ញាដ៏ប្រសើរ ព្រោះហេតុនោះ សូមលោកចែកនូវសុធាភោជនដល់ខ្ញុំ ។

[ ២៧៩ ] ( កោសិយៈ... ) ពួកពាណិជ អ្នកស្វែងរកទ្រព្យ ឡើងសំពៅទៅក្នុងសមុទ្ទ ព្រោះសេចក្តីប្រាថ្នា ពាណិជទាំងនោះ ជួនកាលលិចចុះក្នុងសមុទ្ទនោះ ជួនកាលសាបសូន្យចាកទ្រព្យ បាត់ទាំងដើមទុន ។ ពួកកសិករបានកសិស្រែទាំងឡាយ ព្រោះនូវពូជទាំងឡាយ ធ្វើ ( កិច្ចនោះ ៗ ) ដោយឧបាយ ក៏មិនបាននូវផលិតផលបន្តិចបន្តួចអំពីសទ្ទនោះ ដោយសេចក្តីអន្តរាយឬគ្មានភ្លៀង ព្រោះតែសេចក្តីប្រាថ្នា ។ ពួកជនអ្នកស្វែងរកសេចក្តីសុខ បានធ្វើនូវសេចក្តីប្រាថ្នាជាប្រធាន ទើបធ្វើនូវសេចក្តីព្យាយាមក្នុងទីយុទ្ធភូមិ ដើម្បី

ម្ចាស់ ជនទាំងនោះធ្វើនូវប្រយោជន៍ដល់ម្ចាស់ ត្រូវពួកបច្ចាមិត្តបៀតបៀន យ៉ាងខ្លាំងមិនបាននូវឥស្សរិយយសនោះតិចតួច ក៏រត់ទៅកាន់ទិសទាំងឡាយ។ ពួកជនអ្នកចង់ទៅកាន់ឋានសួគ៌ ស្វែងរកសេចក្តីសុខ ក៏លះបង់នូវស្រូវ ទ្រព្យ និងពួកញាតិ ហើយដុតកម្តៅនូវតបៈដ៏សៅហ្មង អស់កាលយូរអង្វែង តែបែរជាឡើងកាន់ផ្លូវខុស ត្រឡប់ទៅកាន់ទុគ្គតិ ព្រោះតែសេចក្តីប្រាថ្នា ។ នែនាងអាសា នាងឯងដែលឈ្មោះថា អាសា គេសន្មតថា ជាស្រីបោកប្រាស់នូវជនទាំងនេះ ( ហេតុនោះ ) នាងចូរបន្ទោបង់នូវសុធាភោជនចំពោះខ្លួនឯងចុះ ស្រីប្រហែលនាង មិនគួរទទួលអាសនៈនិងទឹកទេ សុធាភោជននឹងមានអំពីណា នាងចូរទៅចុះ អាត្មាមិនពេញចិត្តនឹងនាងទេ ។

[ ២៨០ ] នាងជាស្រីមានយស រុងរឿងដោយយស ជាធំក្នុងទិស គេហៅដោយឈ្មោះថោកទាប ម្នាលនាងមានរាងកាយដូចរូបប្រៀប ជាវិការនៃមាស អាត្មាសួរនាង នាងចូរប្រាប់ដល់អាត្មា នាងជាទេវតាឈ្មោះអ្វី ។

[ ២៨១ ] ( នាងសទ្ធា... ) ខ្ញុំជានាងទេវីឈ្មោះសទ្ធា ដែលគេបូជាក្នុងពួកមនុស្សមិនសេពគប់នូវសត្វដ៏លាមកសព្វកាល មកកាន់សំណាក់លោកដោយការឈ្លោះក្រកែក ព្រោះសុធាភោជន បពិត្រលោកអ្នកមានប្រាជ្ញាដ៏ប្រសើរ ព្រោះហេតុនោះ សូមលោកចែករំលែកនូវសុធាភោជនដល់ខ្ញុំ ។

[ ២៨២ ] ( កោសិយៈ... ) ជួនកាល មនុស្សទាំងឡាយពឹងផ្អែកលើសទ្ធា ទើបធ្វើនូវទាន នូវការទូន្មានឥន្ទ្រិយ នូវការបរិច្ចាគនិងការសង្រួម ក៏មាន មនុស្សពួកខ្លះ ដែលឃ្លាតអំពីនាង ( សទ្ធា ) វិញ ក៏ធ្វើនូវការលួច

កុហក បន្ទំនិងញុះញង់ក៏មាន ។ បុរសអ្នកប្រាថ្នាក្នុងកិរិយាទាំងឡាយ ដែលមានគុណសម្បត្តិស្មើគ្នា ជាស្រីបរិបូណ៌ដោយសីល មានវត្តចំពោះប្តី តែលះបង់នូវសេចក្តីប្រាថ្នាក្នុងពួកស្រីដែលមានត្រកូលល្អ ហើយធ្វើនូវការជឿចំពោះកុម្ភទាសីវិញក៏មាន ។ ម្នាលនាងសុទ្ធា នាងឯងគប់រកនូវប្រពន្ធរបស់ជនដទៃ ហើយ ធ្វើនូវអំពើដ៏លាមក លះចោលនូវកុសល ស្រីប្រហែលនាងមិនគួរទទួលនូវអាសនៈនិងទឹកទេ សុជាភោជននឹងមានអំពីណា នាងចូរទៅចុះ អាត្មាមិនពេញចិត្តនឹងនាងទេ ។

[ ២៨៣ ] ទិសខាងកើតឯណា មានសម្បុររូបដ៏ឧត្តម ប្រាកដច្បាស់ក្នុងវេលាអរុណរះឡើង ក្នុងទីបំផុតនៃរាត្រី ម្នាលនាងទេវធីតា នាងប្រាកដច្បាស់ដល់អាត្មា ដូចជាទិសខាងកើតនោះដែរ នាងចូរប្រាប់អាត្មា នាងជាស្រីអប្សរអ្វី ។ នាងឈ្មោះអ្វី ដូចជាវល្លិ៍ប្រេងដែលត្រូវខ្យល់ មានរបៀបនៃស្លឹកដ៏ក្រហមក្នុងនិទាឃរដូវ ឬដូចជាអណ្តាតភ្លើង ពុំនោះសោត ដូចម្រឹគស្មាវកាលក្រឡេកមើលនាងហាក់ដូចជាមានប្រាថ្នានឹងនិយាយ តែមិនបញ្ចេញនូវវាចាទៅវិញ ។

[ ២៨៤ ] ( នាងហិរី... ) ខ្ញុំជានាងទេវីឈ្មោះហិរី ដែលគេបូជាក្នុងពួកមនុស្ស ជាស្រីមិនសេពគប់នូវសត្វដ៏លាមកសព្វៗកាល មកកាន់សំណាក់លោកដោយការឈ្លោះប្រកែក ព្រោះសុជាភោជន តែខ្ញុំនោះមិនអាចនឹងសូមនូវសុជាភោជនទេ ធម្មតាការសូមគេនៃស្រី ដូចជាការបើកបង្ហាញកេរ្តិ៍ខ្មាស ។

[ ២៨៥ ] ( កោសិយៈ... ) ម្នាលនាងមានរាងកាយល្អ នាងនឹងបាន

( នូវសុធាភោជន ) តាមសភាពតាមហេតុ នេះពិតជាធម៌ហើយ ដ្បិតថា សុធាភោជន គេមិនបានព្រោះការសូមទេ ព្រោះហេតុនោះ អាត្មានឹងអញ្ជើញនាងដែលមិនសូម នាងប្រាថ្នានូវសុធាភោជនណាៗ អាត្មានឹងឲ្យនូវសុធា-ភោជននោះៗ ដល់នាង ។ ម្នាលនាងមានរាងកាយដូចរូបប្រៀប ជាវិការៈនៃមាស នាងនោះអាត្មានឹងអញ្ជើញទៅក្នុងអាស្រមរបស់អាត្មា ក្នុងថ្ងៃនេះ នាងជាស្រីគួរអាត្មាបូជា ដោយវត្ថុមានរសគ្រប់យ៉ាង អាត្មាលុះបូជានាងហើយ ទើបនឹងបរិភោគនូវសុធាភោជនដែរ ។

[ ២៨៦ ] ( អភិសម្ពុទ្ធគាថា ) នាងហិរីនោះ ជាស្រីមិនសេពគប់នូវសត្វលាមកសព្វៗកាល ដែលកោសិយតាបស មានអានុភាពដ៏រុងរឿងអនុញ្ញាតហើយ ក៏ចូលទៅកាន់អាស្រមជាទីរីករាយ ជាអាស្រមមានទឹក មានផ្លែឈើ ដែលពួកអរិយជនបូជាហើយ ។ ជិតអាស្រមនោះ មានព្រៃឈើស៊ុមទ្រុមដ៏ច្រើន មានផ្ការីកហើយ ដើមស្វាយ ដើមទ្រយឹង ដើមខ្នុរ ដើមចារ ដើមម្រុម ដើមលោទ ដើមក្លោកឆ្កែប ដើមលំពែក ដើមចន្ទន៍ ដើមត្រមូចមានផ្ការីកហើយ ។ ជិតអាស្រមនោះ មានដើមឈើច្រើន គឺដើមរាំង ដើមថ្វាន់ ដើមព្រីង ដើមពោធិ៍បាយ ដើមជ្រៃ ដើមស្រគំ មានមែកទោរទន់ចុះ និងដើមរាជព្រឹក្ស ដើមប្រទៀង ដើមជ្រៃពួរ ដើមរាំងអន្ទក់ និងដើមរំពេក មានក្លិនផ្សព្វផ្សាយគួរគាប់ចិត្ត ។ ជិតអាស្រមនោះ មានអបរណ្ណជាតិ អំពៅខ្មៅ សណ្តែកព្រៃ ដើមទន្ទាប់ ស្រងែ និងគែលលក សណ្តែករាជមាស ចេកមានគ្រាប់ និងស្រូវស ស្រូវក្រហមជាច្រើន ផ្លែចេញជាអន្តរគួរបរិភោគបាន ។

នៅខាងជើងនៃទីអាស្រមនោះ មានជាតិស្រះបោក្ខរណីដ៏ក្សេម មិនមានវត្ថុអាក្រក់ មានកំពង់មិនចោទ ជាស្រះដ៏ស្អាត ប្រកបដោយទឹកមានក្លិន មិនគួរខ្ពើម ។ ក្នុងស្រះនោះ មានពួកត្រីត្រេកត្រអាល ជាសត្វមានសេចក្តីក្សេម មានគ្រឿងបរិភោគដ៏ច្រើន គឺត្រីផ្ទក់ ត្រីខ្ជឹង ត្រីក្រាយ បង្កង ត្រីឆ្តិន ត្រីស្លាតនិងត្រីក្អែក ក៏ហែបហែលទៅមកដេរដាស ។ ក្នុងស្រះនោះ មានពួកសត្វស្លាបត្រេកត្រអាល ជាសត្វមានសេចក្តីក្សេម មានគ្រឿងបរិភោគដ៏ច្រើន គឺហង្សក្រៀល ក្ងោក ចាកក្រពាក អក តាវៅ ក្ងោកមាស ទោម ព្រហិត ដ៏ច្រើន ។ មានពួកសត្វ គឺហ្វូងនៃម្រឹគផ្សេងៗជាច្រើន គឺសីហៈ ខ្លាធំ ខ្លាឃ្មុំ ឆ្កែព្រៃ ខ្លារខិន រមាស គោព្រៃ ក្របី រមាំង ប្រើស ទ្រាយ ជ្រូកព្រៃ ក្តាន់ និងជ្រូកស្រុក មកប្រជុំគ្នាក្បែរស្រះនោះ ។ មានឈ្លូស ត្នោ ទន្សាយ និងខ្ទឹងជាច្រើន ផែនដីនឹងក្នុំពេញពាសដោយផ្កាដ៏វិចិត្រ កងរំពងដោយសំឡេងនៃសត្វបក្សី មានហ្វូងបក្សី គប់រកជានិច្ចក្បែរស្រះនោះ ។

[ ២៨៧ ] នាងហិរីនោះ មានស្បែកដ៏ល្អ គោងដើមឈើមានពណ៌ដ៏ខៀវ បានចូលទៅ ( កាន់អាស្រម ) ហាក់ដូចជាផ្លេកបន្ទោររបស់មហាមេឃ កោសិយតាបសបានរៀបចំកៅអី ដែលមានបណ្តាញប្រទាក់គ្នាដ៏ល្អ ជាវិការនៃស្បូវភ្លាំងដ៏ស្អាត មានក្លិនដ៏ល្អ ពាសដោយស្បែកខ្លាឃ្មុំ បម្រុងនាងហិរីនោះ បានពោលពាក្យនេះនឹងនាងហិរីថា ម្នាលនាងមានលម្អ នាងចូរអង្គុយឲ្យស្រួលចុះ នេះអាសនៈ ។ កាលដែលនាងហិរីនោះ បិតនៅលើកៅអី ប្រាថ្នានូវសុធាភោជនណា គ្រានោះ កោសិយតាបស អ្នកទ្រទ្រង់នូវផ្នួងសក់ដ៏រុងរឿង ជា

មហាមុនី ប្រញាប់ប្រញាល់ បាននាំមកនូវសុធាភោជនទោះ ព្រមទាំងទឹកដោយស៊ីកឈូកថ្មីៗ ដោយខ្លួនឯង ។ នាងហិរីនោះ មានចិត្តត្រេកអរ បានទទួលនូវសុធាភោជនទោះ ដោយដៃទាំងពីរ ហើយពោលនឹងកោសិយតាបសអ្នកទ្រទ្រង់នូវផ្នួងសក់ដូច្នេះថា បពិត្រព្រហ្ម ឥឡូវនេះ ខ្ញុំដែលលោកបូជាហើយ ជាបុគ្គលមានជ័យជម្នះ សូមទៅកាន់កពត្រៃត្រិង្សវិញ ។ នាងហិរីនោះ ដែលកោសិយតាបសមានអានុភាពដ៏រុងរឿង បានអនុញ្ញាតហើយ ជាស្រីស្រើងដោយការស្រើងនឹងវណ្ណៈ ក៏ទៅក្នុងសំណាក់ព្រះឥន្ទ្រជាសហស្សចក្ខុ រួចក្រាបទូលថា បពិត្រព្រះវាសវៈ នេះជាសុធាភោជន សូមព្រះអង្គទ្រង់ប្រទាននូវជ័យជម្នះដល់ខ្ញុំ ។ នាងហិរីនោះដែលពួកទេវតានិងមនុស្សផ្គងអញ្ជលី បូជាហើយ ក៏ចូលទៅអង្គុយលើកៅអី ដ៏ថ្មីក្នុងកាលណា ព្រះឥន្ទ្រព្រមទាំងពួកទេវតា ក៏បូជានាងហិរីនោះ ជាទេវធីតាដ៏ឧត្តមក្នុងកាលនោះ ។

[ ២៨៨ ] សហស្សនេត្ត ជាធំជាងពួកទេវតាជាន់ត្រៃត្រិង្ស ទ្រង់បានត្រាស់នឹងមាតលិទេវបុត្តនោះម្តងទៀតថា អ្នកចូរទៅសួរ កោសិយតាបសតាមពាក្យរបស់យើងថា បពិត្រកោសិយៈ នាងហិរីដទៃអំពីនាងអាសា នាងសទ្ធា នាងសិរី បាននូវសុធាភោជន ដោយហេតុអ្វី ។

[ ២៨៩ ] មាតលិទេវបុត្ត បានឡើងជិះរថនោះ អណ្តែតទៅដោយស្រួល ដ៏រុងរឿងប្រហែលនឹងគ្រឿងឧបករណ៍ មានចន្ទោលជាវិការៈនៃមាសជម្ពូនទ ភ្លឺដូចជាអណ្តាតភ្លើង ដែលបុញ្ញឫទ្ធិប្រដាប់ស្រស់ល្អ ប្រកបដោយកម្រោលជាវិការៈនៃមាស វិចិត្រដោយកែវ ៧ ប្រការ ។ ក្នុងរថនុ៎ះ មាន

រូបព្រះចន្ទជាវិការៈនៃមាស រូបដំរី គោ សេះ កិន្នរ ខ្លាធំ ខ្លាដំបង ទ្រាយ ជាច្រើនក្នុងរថនោះ មានរូបបក្សីជាវិការៈនៃកែវផ្សេងៗក្នុងរថនោះ មានទាំងរូបម្រឹគប្រកបដោយហ្វូងជាវិការៈនៃកែវពៃទូរ្យក្នុងរថនោះ ។ ពួកទេវតាបានទឹមនូវស្តេចសេះ មានសម្បុរលឿង ១០០០ ក្នុងរថនោះ ជាសេះមានសម្បុរដូចមាស ប្រហែលនឹងដំរីស្មាវ ប្រដាប់ដោយគ្រឿងអលង្ការ មានគ្រឿងប្រដាប់ទ្រូងជាវិការៈនៃបណ្តាញមាស មានគ្រឿងប្រដាប់ពាក់ត្រចៀក ស្ទុះទៅដោយគ្រាន់តែឮសំឡេង ជាសេះមានសន្ទុះដ៏លឿន ។ មាតលិទេវបុត្ត បានឡើងជិះរថនោះ ជាយានដ៏ប្រសើរ ហើយញុំាងទិសទាំង ១០ នេះ ឲ្យគឹកកងរំពងទាំងញុំាងអាកាស ភ្នំ ឈើម្ចាស់ព្រៃ សាគរនិងផែនដីឲ្យរំភើបញាប់ញ័រ ។ មាតលិទេវបុត្តនោះ ចូលទៅកាន់អាស្រមជាចាប់ ពាក់សំពត់ទិព្វជាស្រេច រួចផ្គងអញ្ជលីពោលទៅនឹងកោសិយតាបស ជាទេវព្រាហ្មណ៍ ដែលជាពហុស្សូត ជាអ្នកចម្រើនដោយគុណ មានអាចរិយវត្តទូន្មានហើយ ដូច្នេះថា បពិត្រកោសិយៈ សូមលោកស្តាប់ពាក្យព្រះឥន្ទ ខ្ញុំឯងជាទូតព្រះឥន្ទ សូមសួរលោកថា បពិត្រកោសិយៈ ចុះនាងហិរីដទៃអំពីនាងអាសា នាងសទ្ធានិងនាងសិរី តើបាននូវសុធាភោជនដោយហេតុអ្វី ។

[ ២៩០ ] ( កោសិយៈ... ) ម្នាលមាតលិ ជាទេវសារថី នាងសិរីប្រាកដដល់អាត្មាថា ជាស្ត្រីស្អកស្អុកស្រោប់ហើយ ចំណែកនាងសទ្ធា ប្រាកដដល់អាត្មា ថាជាស្ត្រីមិនទៀង នាងអាសា ក៏ប្រាកដដល់អាត្មា ថាជាស្ត្រីដែលគេសន្មតថាជាស្រីបោកប្រាស់ នាងហិរីតាំងនៅស៊ប់ក្នុងគុណដ៏ប្រសើរ ។

[ ២៩១ ] ពួកនាងកុមារីណា ដែលត្រកូលរក្សាហើយក្តី ពួកស្រ្តីចាស់ៗ ( ស្រ្តីមេម៉ាយ ) ណាក្តី ពួកស្រ្តីណា ដែលមានប្តីក្តី ស្រ្តីទាំងនោះ ( ដឹងច្បាស់ ) នូវធនូរាគដែលកើតឡើងក្នុងពួកបុរសហើយ រារាំងនូវចិត្តរបស់ខ្លួនដោយហិរិ ។ កាលជនទាំងឡាយបរាជ័យក្នុងប្រធាននៃសង្រ្គាម ដែលប្រកបដោយព្រួញនិងលំពែងស្ទុះរត់ទៅ ជនទាំងនោះ បានលះបង់នូវជីវិត ក៏ត្រឡប់វិលវិញដោយហិរិ មានចិត្តប្រកបដោយហិរិ ទទួលយក ( ម្ចាស់ ) វិញ ។ ច្រាំងជាគ្រឿងរារាំងនូវកម្លាំងនៃរលកទឹកក្នុងសមុទ្ទ យ៉ាងណា ហិរិនេះ ក៏ឃាត់នូវជនចាកបាប យ៉ាងនោះដែរ ម្នាលទេវសារថី ព្រោះហេតុនោះ អ្នកចូរក្រាបទូលព្រះឥន្ទថា ហិរិនោះ ត្រូវអរិយជនបូជាហើយ ក្នុងលោកទាំងពួង ។

[ ២៩២ ] ( មាតលិទេវបុត្ត... ) បពិត្រកោសិយៈ បុគ្គលណាជាព្រហ្ម ឬព្រះឥន្ទ្រ ឬបជាបតិ ប្រកាន់តាមសេចក្តីយល់របស់លោកនេះថា ធីតារបស់ព្រះឥន្ទ្រ ជាស្រ្តីស្វែងរកនូវគុណដ៏ប្រសើរ ដែលគេសន្មតថា ជាស្រ្តីប្រសើរបំផុតក្នុងពួកទេវតា ព្រោះតែហិរិ ។

[ ២៩៣ ] បើដូចនោះ ឥឡូវនេះ សូមលោកមក សូមលោកទៅកាន់ឋានត្រៃត្រិង្ស សូមលោកឡើងជិះរថ ដែលជាទីគាប់ចិត្តនេះ បពិត្រលោកអ្នកមានគោត្តស្មើដោយព្រះឥន្ទ ព្រះឥន្ទទទឹងលោក សូមលោកទៅនៅរួមជាមួយនឹងព្រះឥន្ទ្រ ក្នុងថ្ងៃនេះ ។

[ ២៩៤ ] ( អភិសម្ពុទ្ធគាថា ) ពួកសត្វអ្នកមិនធ្វើនូវអំពើបាប រមែង

បរិសុទ្ធិយ៉ាងនេះ មួយទៀត ផលនៃកុសល ដែលបុគ្គលបានសន្សំល្អហើយ រមែងមិនសាបសូន្យទេ ពួកសត្វណាមួយ បានឃើញនូវសុធាភោជន ( ក្នុងកាលនោះ ) សត្វទាំងអស់នោះឯង រមែងដល់នូវការនៅរួមជាមួយនឹងព្រះឥន្ទ្រ ។

[ ២៩៥ ] នាងហិរីទេវធីតា គឺនាងឧប្បលវណ្ណាភិក្ខុនី កោសិយតាបស គឺភិក្ខុជាម្ចាស់ទាន បញ្ចសិខទេវបុត្ត គឺអនុរុទ្ធភិក្ខុ មាតលិទេវបុត្ត គឺអានន្ទ សុរិយទេវបុត្ត គឺកស្សបភិក្ខុ ចន្ទទេវបុត្ត គឺមោគ្គល្លាន នារទតាបស គឺសារីបុត្ត ឯព្រះវាសវៈ គឺតថាគតជាព្រះសម្ពុទ្ធ ។

**ចប់ សុធាភោជនជាតកទី ៣**

## អដ្ឋកថា

## សុធាភោជន ជាតក

[ ២៤៩-២៩៥ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមានអធ្យាស្រ័យបំពេញទានមួយរូប ទើបត្រាស់ធម្មទេសនានេះ មានពាក្យផ្តើមថា **នេវ កិណាមិន វិក្កិណាមិ** ដូច្នេះជាដើម ។

បានឮថា ភិក្ខុរូបនោះ ជាកុលបុត្តម្នាក់ក្នុងនគរសាវត្ថី បានស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា មានចិត្តជ្រះថ្លាហើយ ទើបចេញបួស ធ្វើសីល

ឲ្យបរិបូណ៌ ប្រកបដោយធុតង្គគុណ មានមេត្តាចិត្តផ្សាយទៅក្នុងសព្រហ្មចារី ទាំងឡាយ ជាអ្នកមិនប្រមាទក្នុងការបម្រើព្រះពុទ្ធព្រះធម៌និងព្រះសង្ឃ មួយថ្ងៃ ៣ ដង ដល់ព្រមដោយមារយាទ មានអធ្យាស្រ័យក្នុងការឲ្យទាន បានបំពេញសារាណីយធម៌គ្រប់បរិបូណ៌ហើយ ភិក្ខុរូបនោះ កាលបដិគ្គាហកៈទាំងឡាយនៅមាន ក៏ឲ្យវត្ថុដែលខ្លួនបានហើយរហូតអស់ ទោះបីខ្លួនឯងត្រូវអត់អាហារក៏ដោយ ព្រោះហេតុនោះទើបលោកប្រាកដក្នុងពួកភិក្ខុថា ជាអ្នកមានអធ្យាស្រ័យក្នុងការឲ្យទាន ត្រេកអរក្រៃលែងក្នុងទាន ។ ថ្ងៃមួយ ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា នែអាវុសោទាំងឡាយ ភិក្ខុឈ្មោះនោះ ជាអ្នកមានអធ្យាស្រ័យក្នុងការឲ្យទាន ត្រេកអរក្រៃលែងហើយក្នុងទាន កាត់នូវសេចក្តីលោភចេញបាន មានទឹកប្រមាណត្រឹមមួយទូកដៃ ដែលខ្លួនបានមកក៏ប្រគេនដល់សព្រហ្មចារីទាំងឡាយរហូតអស់ មានអធ្យាស្រ័យដូចព្រះពោធិសត្វ ព្រះសាស្តាទ្រង់បានឮពាក្យនោះ ដោយព្រះសោតធាតុទិព្វ ទើបយាងចេញពីព្រះគន្ធកុដិ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងនោះក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ ក្នុងកាលមុន ជាអ្នកមិនឲ្យទានជាប្រចាំ ជាអ្នកកំណាញ់មិនឲ្យរបស់ណាមួយដល់អ្នកដទៃ សូម្បីតំណក់ប្រេងដែលជ្រលក់ដោយចុងស្បូវ ក្នុងកាលជាក្រោយ តថាគតបានទូន្មាន ធ្វើឲ្យអស់ព្យសន៍ ពណ៌នាផលនៃទាន ឲ្យតាំងនៅក្នុងទានហើយ បានទទួលពរនៅក្នុងសម្នាក់របស់តថាគត

ថា បើខ្ញុំបានទឹកមកត្រឹមតែបន្តិចបន្តួច ត្រឹមមួយទូកដៃ បើមិនទាន់បានឲ្យទាន ក៏មិនផឹកទឹកនោះ ដោយផលនៃការដែលបានទទួលពរ ក្នុងសម្នាក់របស់តថាគតនេះ ទើបលោកជាអ្នកមានអធ្យាស្រ័យក្នុងការឲ្យទាន ជាអ្នកមានចិត្តត្រេកអរក្រៃលែងហើយក្នុងទាន កាលត្រាស់ដូច្នេះហើយ ទ្រង់ក៏នៅស្ងៀម កាលពួកភិក្ខុដែលឈ្មោសដោយអនុសន្ធិក្នុងរឿងទេសនាទាំងនោះ ក្រាបទូលអារាធនា ទើបទ្រង់នាំយកអតីតនិទានមកត្រាស់ដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតជាគហបតីម្នាក់ ជាអ្នកស្តុកស្តម្ភដោយទ្រព្យ និងភោគសម្បត្តិប្រមាណ ៨០ កោដិ ក្រោយមក ព្រះរាជាបានព្រះរាជទានតំណែងជាសេដ្ឋីដល់ព្រះពោធិសត្វ សេដ្ឋីនោះបានជាបុគ្គលដែលព្រះរាជាទ្រង់បូជាហើយ និងដែលអ្នកនគរ អ្នកជនបទរាប់អានបូជាហើយ ។ ថ្ងៃមួយ គហបតីក្រឡេកមើលសម្បត្តិរបស់ខ្លួនហើយ គិតថា យសនេះ អញមិនបានដេកលក់ បានហើយ ឬថាធ្វើកាយទុច្ចរិតជាដើមទុកក្នុងអតីតភពហើយបានមក ក៏មិនមែន អញបំពេញកាយសុចរិតជាដើមឲ្យបរិបូណ៌ហើយទើបបានមក សូម្បីក្នុងកាលអនាគតសោត អញក៏គួរធ្វើទីពឹងរបស់អញ ទើបទៅកាន់សម្នាក់របស់ព្រះរាជាក្រាបទូលថា បពិត្រព្រះអង្គ ទ្រព្យក្នុងផ្ទះរបស់ទូលព្រះបង្គំមាន ៨០ កោដិ សូមទ្រង់ទទួលទ្រព្យនោះចុះ កាលព្រះរាជាត្រាស់ថា យើងមិនត្រូវការទ្រព្យរបស់អ្នកទេ ទ្រព្យរបស់យើងមានច្រើនស្រាប់ហើយ តាំងអំពីនេះទៅអ្នកប្រាថ្នាវត្ថុណា ក៏ចូរកាន់យកវត្ថុនោះចុះ ទើបក្រាបទូលថា បពិត្រ

ព្រះអង្គ ទូលព្រះបង្គំនឹងឲ្យទ្រព្យរបស់ទូលព្រះបង្គំបានដែរឬទេ លំដាប់នោះ ព្រះរាជា ក៏ត្រាស់ថា ចូរអ្នកធ្វើតាមគាប់ចិត្តចុះ ដូច្នេះ ទើបឲ្យសាងសាលាទាន ៦ កន្លែង គឺត្រង់ទ្វារនគរ ៤ កន្លែង ត្រង់កណ្តាលនគរ ១ កន្លែង និងត្រង់ទ្វារផ្ទះរបស់ខ្លួន ១ កន្លែង ធ្វើការបរិច្ចាគទ្រព្យមួយថ្ងៃ ៦ សែន បំពេញមហាទានរាល់ៗថ្ងៃ លោកឲ្យទានយ៉ាងនេះដរាបដល់អស់ជីវិត ហើយទូន្មានកូនថា ឯងកុំកាត់នូវទានវង្សនេះរបស់យើងឡើយ កាលអស់ជីវិតហើយ បានទៅកើតជាសក្កទេវរាជ សូម្បីកូនរបស់សេដ្ឋីនោះ ក៏ឲ្យទានដូចបិតាដូច្នោះ កាលទម្លាយខន្ធ ក៏ទៅកើតជាចន្ទទេវបុត្ត កូនរបស់ចន្ទទេវបុត្ត ក៏បំពេញទានដូចបិតា បានទៅកើតជាសុរិយទេវបុត្ត ។ បុត្តនៃសុរិយទេវបុត្តនោះ បំពេញទានដូចបិតា ក៏កើតជាមាតលីទេវបុត្ត បុត្តនៃមាតលី ក៏បំពេញទានដូចបិតា កើតជាបញ្ចសិខទេវបុត្ត ។

ឯបុត្តទី ៦ នៃបញ្ចសិខទេវបុត្តនោះ បានជាសេដ្ឋី មានឈ្មោះថា មច្ឆរិ-យកោសិយ មានទ្រព្យសម្បត្តិ ៨០ កោដិដូចគ្នា សេដ្ឋីនោះ ជាបុគ្គលកំណាញ់ ស្វិតស្វាញ គិតថា បិតានិងជីតារបស់អញជាបុគ្គលពាល បំផ្លាញទ្រព្យដែលស្វែងរកមកដោយលំបាក អញនឹងរក្សាទ្រព្យទុក នឹងមិនឲ្យដល់បុគ្គលណាមួយឡើយ ទើបឲ្យរើរោងទានទាំង ៦ កន្លែងនោះ យកភ្លើងដុតចោល ។ លំដាប់នោះ ពួកយាចកមកប្រជុំគ្នាត្រង់ទ្វារផ្ទះរបស់សេដ្ឋីនោះ លើកដើមដៃទាំង ២ ឡើង ស្រែកដោយសំឡេងខ្លាំងថា បពិត្រមហាសេដ្ឋី សូមលោកកុំធ្វើទានវង្សនៃបិតា និងជីតារបស់ខ្លួនឲ្យវិនាសឡើយ សូមលោកឲ្យទានចុះ

មហាជនបានឮ នាំគ្នាតិះដៀលសេដ្ឋីនោះថា មច្ឆរិយកោសិយសេដ្ឋី កាត់នូវវង្ស របស់ខ្លួនចោលហើយ សេដ្ឋីនោះ ក៏មាននូវការខ្មាស បានតាំងមនុស្សរក្សា ទុកដើម្បីចាំឃាត់យាចកដែលមកកាន់ទ្វារផ្ទះ ។ ពួកយាចកទាំងនោះអស់ទីពឹង មិនបានសម្លឹងទ្វារផ្ទះរបស់សេដ្ឋីនោះទៀតឡើយ ចាប់តាំងពីនោះមក គាត់ក៏ ប្រមូលទ្រព្យឯង មិនបរិភោគដោយខ្លួនឯង ទាំងមិនឲ្យបុត្តនិងភរិយាជាដើម បរិភោគទៀតផង ខ្លួនឯងបរិភោគបាយចុងអង្ករ មានទឹកជ្រក់ជាគម្រប់ ២ ស្លៀកសំពត់សាច់គ្រោតគ្រាត ដែលជាងត្បាញអំពីឫសឈើ ឬផ្លៃឈើ បាំងនូវឆត្រស្លឹកត្នោត ប្រើរទេះចាស់ ទឹមដោយគោចាស់ជាពាហនៈ ទ្រព្យ របស់សេដ្ឋីអសប្បុរសនោះ ដូចជាសុនខបាននូវផ្លែដូង ដោយប្រការដូច្នេះ ។

ថ្ងៃមួយ មច្ឆរិយកោសិយសេដ្ឋីនោះ កាលនឹងទៅកាន់ទីគាល់ព្រះរាជា គិត ថា អញនឹងទៅបបួលអនុសេដ្ឋីទៅដែរ ទើបបានទៅកាន់ផ្ទះអនុសេដ្ឋីនោះ ក្នុង ខណៈនោះ សេដ្ឋីចោមរោមដោយបុត្តធីតាកំពុងបរិភោគបាយាស ដែលផ្សំ ដោយសប្បិ ទឹកឃ្មុំនិងស្ករក្រាម អនុសេដ្ឋីនោះ កាលឃើញមច្ឆរិយកោសិយ សេដ្ឋីនោះមកដល់ ក៏ក្រោកចាកអាសនៈ ពោលថា សូមលោកមហាសេដ្ឋី អង្គុយលើបល្ល័ង្កនេះ អញ្ជើញបរិភោគបាយាសជាមួយគ្នា ។ មហាសេដ្ឋី គ្រាន់ តែឃើញបាយាស ក៏ស្រក់ទឹកមាត់ ចង់បរិភោគដែរ តែគិតយ៉ាងនេះថា បើ អញបរិភោគ អញក៏ត្រូវធ្វើសក្ការៈ តបស្នង ក្នុងកាលដែលអនុសេដ្ឋីទៅ កាន់ផ្ទះរបស់អញ កាលបើដូច្នេះ ទ្រព្យរបស់អញនឹងវិនាស អញនឹងមិន បរិភោគ ។ លំដាប់នោះ មហាសេដ្ឋីត្រូវអនុសេដ្ឋីអង្វររឿយៗ ទើបពោល

នឹងអនុសេដ្ឋីថា ខ្ញុំទើបតែបរិភោគមកអម្បាញ់មិញនេះឯង ខ្ញុំនៅឆ្អែតនៅឡើយ ហើយមិនបានប្រាថ្នានឹងបរិភោគ តែកាលអនុសេដ្ឋីបរិភោគ មហាសេដ្ឋីអង្គុយមើល មានទឹកមាត់ហូរចេញអំពីមាត់ កាលស្រេចកត្តកិច្ចរបស់អនុសេដ្ឋី ទើបទៅកាន់រាជនិវេសន៍ជាមួយគ្នា ត្រឡប់មកអំពីព្រះរាជនិវេសន៍ មកដល់ផ្ទះរបស់ខ្លួន ត្រូវចំណង់ក្នុងរសនៃបាយាសគ្របសង្កត់ គិតថា បើអញពោលថា ខ្ញុំចង់បរិភោគបាយាស មហាជនក៏ចង់បរិភោគជាមួយអញដែរ ទ្រព្យជាច្រើន មានអង្ករជាដើម ក៏នឹងអស់ទៅ អញនឹងមិនប្រាប់ដល់បុគ្គលណាមួយ មហាសេដ្ឋីនោះ គិតដល់បាយាសតែម្យ៉ាង ធ្វើយប់និងថ្ងៃឲ្យកន្លងទៅ មិនបានប្រាប់ដល់អ្នកណាមួយ ព្រោះខ្លាចអស់ទ្រព្យ អត់ធន់នូវចំណង់ ឲ្យពេលវេលាកន្លងទៅដោយលំដាប់ កាលមិនអាចអត់ធន់បាន ក៏ជាអ្នកមានរោគស្គមលឿងកើតឡើង កាលបើដូច្នេះ មហាសេដ្ឋី ក៏មិនប្រាប់ដល់បុគ្គលណា ព្រោះខ្លាចទ្រព្យអស់ទៅ ក្នុងកាលតមក ក៏ជាអ្នកអស់កម្លាំង ទើបចូលទៅកាន់ទីដេក ហើយក៏ដេកសម្ងំ ។

លំដាប់នោះ ភរិយាក៏ចូលទៅរកមហាសេដ្ឋីនោះ ហើយយកដៃស្ទាបខ្នងសួរថា បពិត្រលោកម្ចាស់ លោកម្ចាស់មិនសប្បាយរឿងអ្វីឬ សេដ្ឋីពោលថា នែនាង យើងមិនកើតអ្វីឡើយ ភរិយាសួរថា ការមិនសប្បាយក្នុងរាងកាយរបស់លោកមានឬ សេដ្ឋីពោលថា ការមិនសប្បាយក្នុងរាងកាយរបស់យើង ក៏មិនមាន ។ ភរិយាពោលថា បពិត្រលោកម្ចាស់ លោកជាអ្នកមានរោគស្គមលឿងកើតឡើងហើយ លោកគិតក្នុងរឿងអ្វីឬ ឬមួយព្រះរាជាទ្រង់

ព្រះពិរោធជាមួយលោក ឬពួកកូនៗធ្វើនូវការមើលងាយ ឬចំណង់ណាមួយកើតឡើងដល់លោក ។ សេដ្ឋីពោលថា អើ ចំណង់កើតឡើងហើយ ដល់យើង ។ ភរិយាពោលថា កាលបើដូច្នោះ សូមលោកប្រាប់មកចុះ ។ សេដ្ឋីពោលថា នាងអាចរក្សាពាក្យសម្ងាត់របស់យើងបានឬ ។ ភរិយាពោលថា បើវាជាដែលខ្ញុំគួររក្សា ខ្ញុំក៏នឹងរក្សាបាន ។ កាលភរិយាពោលទទួលយ៉ាងនេះ មហាសេដ្ឋីក៏មិនអាចប្រាប់បាន ព្រោះខ្លាចវិនាសទ្រព្យ កាលត្រូវភរិយាដេញសួររឿយៗ ទើបប្រាប់ថា នៃនាងដ៏ចម្រើន ថ្ងៃមួយ អញឃើញអនុសេដ្ឋីបរិភោគបាយាសដែលចម្អិនដោយសប្បិ ទឹកឃ្មុំ និងស្ករក្រាម ចាប់តាំងពីនោះមក ក៏កើតចំណង់ ចង់បរិភោគបាយាសយ៉ាងនោះដែរ ។ ភរិយាពោលថា បពិត្រ អសប្បុរស លោកក្រីក្រណាស់ឬ ខ្ញុំនឹងចម្អិនបាយាសឲ្យគ្រប់គ្រាន់ដល់អ្នកនគរទាំងមូល ។ គ្រានោះ មហាសេដ្ឋីហាក់ដូចវាយសីសៈដោយដំបង ក្រោធនឹងភរិយាពោលថា ខ្ញុំដឹងថា នាងមានទ្រព្យច្រើន បើទ្រព្យដែលនាំមកអំពីត្រកូលរបស់នាងមាន ចូរនាងចម្អិនបាយាសចែកដល់អ្នកនគរទាំងឡាយចុះ ។ ភរិយាពោលថា បើដូច្នោះ ខ្ញុំនឹងចម្អិនឲ្យពួកអ្នកស្រុកដែលនៅក្នុងវិថីមួយ ។ សេដ្ឋីពោលថា ប្រយោជន៍អ្វីដោយជនទាំងនោះដល់នាង ពួកគេចូរបរិភោគទ្រព្យរបស់ពួកគេចុះ ។ ភរិយាពោលថា បើយ៉ាងនោះ ខ្ញុំនឹងចម្អិនឲ្យគ្រប់គ្រាន់ ឲ្យដល់ពួកជនដែលនៅក្នុងផ្ទះខាង ៧ ផ្ទះនៃផ្ទះនេះ ។ សេដ្ឋីពោលថា ប្រយោជន៍អ្វីដោយជនទាំងនោះដល់នាង ។ ភរិយាពោលថា កាលបើដូច្នោះ ខ្ញុំនឹងចម្អិនឲ្យគ្រប់គ្រាន់ដល់បរិវារ ក្នុងផ្ទះ

នេះ ។ សេដ្ឋីពោលថា ប្រយោជន៍អ្វីដោយជនទាំងនោះដល់នាង កិរិយាពោលថា បើយ៉ាងនោះ ខ្ញុំនិងចម្អិនឲ្យគ្រប់គ្រាន់ចំពោះអ្នកនិងខ្ញុំត្រឹមតែ ២ នាក់ប៉ុណ្ណោះ សេដ្ឋីពោលថា នាងជាអ្វី បាយាសនេះ មិនសមគួរដល់នាងទេ ។ កាលកិរិយាពោលថា កាលបើយ៉ាងនោះ ខ្ញុំនឹងចម្អិនឲ្យគ្រប់គ្រាន់ដល់លោកម្ចាស់តែម្នាក់ប៉ុណ្ណោះ ។

មហាសេដ្ឋីក៏ពោលថា បើនាងចម្អិនចំពោះយើងម្នាក់ហើយ កុំចម្អិនក្នុងផ្ទះនេះឡើយ ព្រោះថា បើនាងចម្អិនក្នុងផ្ទះនេះ មហាជនក៏ចង់បរិភោគ ចូរនាងយកម្សៅស្រូវសាលីរបស់យើងចែកជា ៤ ចំណែក ស្ករក្រាមចាប់យកដោយដៃមួយ ទឹកដោះនិងទឹកឃ្មុំមួយមុខមួយដប និងភាជនៈសម្រាប់ចម្អិន ១ ឲ្យដល់យើង យើងនឹងទៅកាន់ព្រៃ ចម្អិនក្នុងទីនោះ ហើយបរិភោគ ។ កិរិយាបានធ្វើតាមពាក្យប្រាប់គ្រប់ប្រការ ។ សេដ្ឋីឲ្យអ្នកបម្រើយកសំពត់ខ្ចប់របស់ទាំងអស់នោះ ឲ្យកាន់យកទៅ ហើយពោលថា ចូរអ្នកទៅឈរក្នុងទីឈ្មោះនោះ បញ្ជូនអ្នកបម្រើទៅមុន ដើរតែម្នាក់ឯង យកសំពត់ទទូរក្បាល ក្លែងខ្លួនមិនឲ្យអ្នកណាស្គាល់ ទៅដល់ព្រៃនោះ ឲ្យអ្នកបម្រើធ្វើជើងក្រាន ត្រង់គុម្ពឈើមួយកន្លែងក្បែរស្ទឹង ឲ្យរកឧសនិងទឹកមក ហើយប្រាប់ថា ចូរឯងទៅឈរត្រង់ផ្លូវមួយ បើឃើញអ្នកណាមក គប្បីឲ្យសញ្ញាដល់យើង ម្យ៉ាងទៀតកាលយើងហៅសឹមមក បញ្ជូនអ្នកបម្រើទៅហើយ ទើបបង្កាត់ភ្លើងចម្អិនបាយាស ។

ក្នុងខណៈនោះ សក្កទេវរាជទ្រង់ទតសិរីសម្បត្តិរបស់ទ្រង់យ៉ាងនេះ គឺ

ទេវនគរដែលប្រដាប់ហើយប្រមាណមួយម៉ឺនយោជន៍ វិថីដែលសម្រេចហើយដោយមាស ៦០ យោជន៍ វេជយន្តប្រាសាទកម្ពស់ ១០០០ យោជន៍ សុធម្មាសភា ៥០០ យោជន៍ ថ្មបណ្ឌុកម្ពលទន់ មានពណ៌លឿង ទំហំ ៦០ យោជន៍ ស្វេតច្ឆត្រមានកម្រងផ្កាជុំវិញ ៥០០ យោជន៍ ស្រីទេពអប្សរ ២ កោដិកន្លះ និងអត្តភាពដែលប្រដាប់តាក់តែងហើយ កាលទ្រង់ឃើញដូច្នេះ ទើបពិចារណាថា យសនេះ អញបានមកព្រោះធ្វើអ្វីហ្ន៎ ទើបទ្រង់ឃើញទានដែលទ្រង់បានបំពេញឲ្យប្រព្រឹត្តទៅ កាលជាសេដ្ឋីក្រុងពារាណសី ។ លំដាប់នោះ ទើបទ្រង់រំពឹងមើលថា ជនទាំងឡាយ មានកូនរបស់អញជាដើមកើតក្នុងទីណា បានទតឃើញទីកើតរបស់ជនទាំងពួង គឺកូនរបស់អញកើតជាចន្ទទេវបុត្ត កូនចន្ទទេវបុត្ត កើតជាសុរិយទេវបុត្ត កូនរបស់សុរិយទេវបុត្ត កើតជាមាតលីទេវបុត្ត កូនរបស់មាតលីទេវបុត្ត កើតជាបញ្ចសិខទេវបុត្ត ទើបរំពឹងមើលទៀតថា កូនរបស់បញ្ចសិខទេវបុត្តដូចម្តេច ក៏បានឃើញកូនរបស់បញ្ចសិខទេវបុត្តជាអ្នកកាត់នូវទានវង្សរបស់ព្រះអង្គចោល ។ លំដាប់នោះ ទ្រង់បរិវិតក្កថា បុគ្គលនេះជាអសប្បុរស ជាអ្នកកំណាញ់ មិនបានបរិភោគខ្លួនឯងផង មិនឲ្យដល់អ្នកដទៃផង គេកាត់នូវទានវង្សរបស់អញចោល ធ្វើកាលកិរិយាហើយនឹងទៅកើតក្នុងនរក អញនឹងឲ្យឱវាទដល់គេ នឹងឲ្យទានវង្សប្រតិស្ឋានតទៅ នឹងធ្វើហេតុឲ្យគេមកកើតក្នុងទេវនគរនេះ ទើបហៅចន្ទទេវបុត្តជាដើមមក ហើយមានបញ្ជាថា អ្នកទាំងឡាយចូរមក យើងនឹងទៅកាន់មនុស្សលោកជាមួយគ្នា មច្ឆរិយកោសិយសេដ្ឋីចូលទៅកាត់ទានវង្សរបស់ពួកយើង ហើយ

ឲ្យដុតរោងទានចោល ខ្លួនឯងក៏មិនបរិភោគ ពួកជនដទៃក៏មិនឲ្យបរិភោគ ឥឡូវនេះ គេជាអ្នកប្រាថ្នានឹងបរិភោគបាយាស គិតថា កាលចម្អិនបាយាសក្នុងផ្ទះក៏ត្រូវឲ្យដល់អ្នកដទៃដែរ ទើបចូលទៅកាន់ព្រៃចម្អិនបរិភោគតែម្នាក់ឯង យើងនឹងទូន្មានសេដ្ឋីនេះ ធ្វើឲ្យស្គាល់ផលនៃទាន ហើយសឹមត្រឡប់មក តែសេដ្ឋីនេះ បើពួកយើងទាំងអស់គ្នាទៅសូមព្រមគ្នា ក៏នឹងស្លាប់ក្នុងទីនោះឯង ក្នុងពេលដែលយើងទៅសូមបាយាស អន្តរាយហើយ ពួកអ្នកគប្បីការពារខ្លួនជាព្រាហ្មណ៍ ទៅសូមតាមលំដាប់ចុះ ។ កាលបញ្ជាហើយ សក្កៈក៏និម្មិតភេទជាព្រាហ្មណ៍ ចូលទៅរកមហាសេដ្ឋីនោះមុន ហើយសួរថា ផ្លូវណាទៅកាន់នគរពារាណសី ។

លំដាប់នោះ មច្ឆរិយកោសិយសេដ្ឋីក៏ពោលថា អ្នកជាមនុស្សឆ្កួតឬ ទើបមិនស្គាល់នគរពារាណសី មកធ្វើអ្វីផ្លូវនេះ ចូរទៅផ្លូវនោះចុះ សក្កទេវរាជស្តាប់ពាក្យរបស់សេដ្ឋីហើយ ធ្វើដូចជាមិនបានឮ ត្រាស់សួរថា លោកនិយាយថាម៉េច ហើយក៏ដើរចូលទៅជិតបន្ថែមទៀត ។ សេដ្ឋីក៏ស្រែកគំហកថា នែព្រាហ្មណ៍តម្រង់អាក្រក់ អ្នកមកធ្វើអ្វីតាមផ្លូវនេះ ចូរទៅផ្លូវនោះចុះ ។ គ្រានោះ សក្កទេវរាជក៏ពោលថា បពិត្រលោកម្ចាស់ លោកស្រែកធ្វើអ្វី ផ្សែងនិងភ្លើងកំពុងប្រាកដ លោកប្រហែលជាចម្អិនបាយាសឆ្អិនហើយ ប្រហែលជានិមន្តព្រាហ្មណ៍ទាំងឡាយមកឆាន់ក្នុងទីនេះ ក្នុងពេលដែលពួកព្រាហ្មណ៍ឆាន់ហើយ ខ្ញុំក៏នឹងបានបរិភោគបន្តិច លោកមិននិមន្តខ្ញុំខ្លះទេឬ សេដ្ឋីឆ្លើយថា ការនិមន្តពួកព្រាហ្មណ៍ក្នុងទីនេះមិនមានឡើយ សូមលោកអញ្ជើញទៅខាងមុខ

ចុះ សក្កទេវរាជក៏ពោលថា បើដូច្នោះ លោករីងនឹងខ្ញុំធ្វើអ្វី ក្នុងពេលដែលលោកបរិភោគហើយ ខ្ញុំគង់បានបរិភោគបន្តិចបន្តួច ។ លំដាប់នោះ សេដ្ឋីពោលនឹងសក្កទេវរាជនោះថា ខ្ញុំនឹងមិនឲ្យ សូម្បីត្រឹមតែមួយគ្រាប់ដល់អ្នក ភត្តនេះ មានតិចតួច ល្មមតែខ្ញុំបរិភោគម្នាក់ឯងប៉ុណ្ណោះ ម្យ៉ាងទៀត ភត្តនេះ យើងក៏ត្រូវសូមគេ ទើបបានមក ចូរអ្នកស្វែងរកអាហាររបស់អ្នក ក្នុងទីដទៃចុះ សេដ្ឋីសំដៅយកអាហារដែលខ្លួនសូមករិយាបានមក ទើបពោលគាថានេះថា

ខ្ញុំមិនមែនទិញ មិនមែនលក់ទេ មួយទៀត ការសន្សំទុករបស់
ខ្ញុំ ក៏មិនមានក្នុងទីនេះដែរ របស់នេះមានប្រមាណតិច មាន
សភាពដ៏ក្រណាស់ បាយចំនួនអឌ្ឍាឡូមួយនាឡិនេះ មិនល្មម
ដល់ជនពីរនាក់ទេ ដូច្នេះ ។

សក្កទេវរាជបានស្តាប់ពាក្យនោះ ទើបត្រាស់ថា ខ្ញុំនឹងពោលពាក្យស្លោកត្រឹមតែមួយបទ ដោយសំឡេងដ៏ពីរោះដល់លោក សូមលោកស្តាប់ពាក្យស្លោកនោះចុះ កាលសេដ្ឋីនោះកំពុងឃាត់ថា ខ្ញុំមិនត្រូវការដោយពាក្យស្លោករបស់លោកទេ សក្កៈក៏នៅតែពោល ២ គាថានេះថា

បុគ្គលគប្បីឲ្យវត្ថុតិច អំពីវត្ថុតិច គួរឲ្យវត្ថុពាក់កណ្តាល អំពី
វត្ថុពាក់កណ្តាល គួរឲ្យវត្ថុច្រើន អំពីវត្ថុច្រើន ការមិនឲ្យ មិន
កើតទេ ។ ម្នាលកោសិយៈ ព្រោះហេតុនោះ យើងនិយាយ
នឹងអ្នក ចូរអ្នកឲ្យនូវទានផង ចូរបរិភោគផង អ្នកចូរឡើង

កាន់អរិយមគ្គ ព្រោះថា បុគ្គលអ្នកបរិភោគម្នាក់ឯង មិនបាន
សេចក្ដីសុខទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អនុមជ្ឈតោ មជ្ឈកំ** សេចក្ដីថា សូម្បីវត្ថុមានប្រមាណតិច បុគ្គលគួរវិលែកពាក់កណ្ដាល ធ្វើឲ្យជា ២ ចំណែក ឲ្យទាន ១ ចំណែក សូម្បីចំណែកដែលសល់អំពីចំណែកដែលឲ្យទានទៅហើយនោះ គប្បីបែងជា ២ អំពីចំណែកពាក់កណ្ដាលនោះម្ដងទៀតហើយ គប្បីឲ្យចំណែក ១ ។ បទថា **អទានំ នុបបជ្ជតិ** សេចក្ដីថា វត្ថុដែលឲ្យទាននោះ ទោះតិចឬច្រើនក៏ដោយ ក៏ឈ្មោះថា បានឲ្យហើយ ឈ្មោះថា ការមិនឲ្យសោះ រមែងមិនគួរ ទាននោះរមែងមានផលច្រើននោះឯង ។

មច្ឆរិយកោសិយសេដ្ឋី ស្ដាប់ពាក្យរបស់សក្កៈនោះហើយ ក៏ពោលថា អើព្រាហ្មណ៍ អ្នកពោលគួរពេញចិត្តយើងណាស់ កាលបាយាសឆ្អិនហើយ អ្នកនឹងបានបន្ដិច ចូរអ្នកអង្គុយសិនចុះ សក្កៈក៏អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ កាលសក្កៈអង្គុយហើយ ចន្ទទេវបុត្តក៏ចូលទៅជិតសេដ្ឋីដោយទំនងនោះឯង ញ៉ាំងពាក្យឲ្យប្រព្រឹត្តទៅយ៉ាងនោះ កាលសេដ្ឋីនោះហាមប្រាម បានពោលគាថា ២ ថា

បុគ្គលណា កាលបើភ្ញៀវអង្គុយហើយ បរិភោគនូវភោជន
ម្នាក់ឯង ការបូជារបស់បុគ្គលនោះ ជាការឥតអំពើ ទាំងការ
ព្យាយាមជាហេតុឲ្យកើតទ្រព្យ ( របស់បុគ្គលនោះ ) ក៏ឥត
អំពើដែរ ។ ម្នាលកោសិយៈ ព្រោះហេតុនោះ យើងនិយាយ

នឹងអ្នក ចូរអ្នកឲ្យទានផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គ ព្រោះថា បុគ្គលអ្នកបរិភោគម្នាក់ឯង មិនបានសេចក្ដីសុខទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សមីហិតំ** សំដៅយក សេចក្ដីព្យាយាមដែលឲ្យកើតទ្រព្យ ។

សេដ្ឋីស្ដាប់ពាក្យចន្ទទេវបុត្តនោះហើយ ក៏បានពោលពាក្យយ៉ាងនោះ ដូចគ្នា ហើយពោលដោយសេចក្ដីលំបាក ដោយទើសទាល់ថា បើដូច្នោះ សូមលោកអង្គុយសិនចុះ លោកនឹងបានបន្តិច ចន្ទទេវបុត្តអង្គុយក្នុងសម្នាក់របស់សក្កៈ ។ លំដាប់នោះ សុរិយទេវបុត្រក៏ចូលទៅរកសេដ្ឋីនោះ ដោយទំនងនេះដូចគ្នា ហើយពោលយ៉ាងនោះ កាលសេដ្ឋីនោះកំពុងជំទាស់ ឃាត់នោះឯងបានពោលគាថា ២ ថា

បុគ្គលណា កាលបើភ្ញៀវអង្គុយហើយ មិនបរិភោគនូវភោជនម្នាក់ឯង ការបូជារបស់បុគ្គលនោះ ជាការបូជាពិតមែន ទាំងការព្យាយាមជាហេតុឲ្យកើតទ្រព្យ ( របស់បុគ្គលនោះ ) ក៏ជាការព្យាយាមពិតមែន ។ ម្នាលកោសិយៈ ព្រោះហេតុនោះ យើងនិយាយនឹងអ្នក ចូរអ្នកឲ្យទានផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គ ព្រោះថា បុគ្គលអ្នកបរិភោគម្នាក់ឯង មិនបានសេចក្ដីសុខទេ ដូច្នេះ ។

សេដ្ឋី បានស្ដាប់ពាក្យរបស់សុរិយទេវបុត្តនោះហើយ ទើបពោលដោយ

ទើសទាល់ថា បើដូច្នោះ ចូរអ្នកអង្គុយសិនចុះ អ្នកនឹងបានបន្តិច សុរិយទេវបុត្ត ក៏បានអង្គុយក្នុងសម្នាក់ចន្ទទេវបុត្ត ។ លំដាប់នោះ មាតលីទេវបុត្ត ក៏ចូលទៅរកសេដ្ឋីនោះដោយឧបាយដូចគ្នា ហើយពោលពាក្យយ៉ាងនោះ កាលសេដ្ឋីនោះកំពុងឃាត់នោះឯង បានពោលគាថាទាំងនេះថា

បុរសបូជាស្រះក្តី ទន្លេឈ្មោះពហុកា ឬស្រះបោក្ខរណី ឈ្មោះគយាក្តី កំពង់ឈ្មោះទោណៈ ឬកំពង់ឈ្មោះ តិម្ពរុក្តី ទន្លេដ៏ធំ មានខ្សែទឹកដ៏រហ័សក្តី ។ ការបូជារបស់បុរសនោះក្នុងទីនោះ រមែងមាន ( ផល ) ទាំងការព្យាយាមជាហេតុ ឲ្យកើតទ្រព្យរបស់បុរសនោះ ក្នុងទីទាំងនោះ ក៏មានផលដែរ ព្រោះថា បុរសនោះ កាលបើក្បៀវអង្គុយនៅហើយ មិនគួរបរិភោគភោជនម្នាក់ឯងទេ ។ ម្នាលកោសិយៈ ព្រោះហេតុនោះ យើងនិយាយនឹងអ្នក ចូរអ្នកឲ្យទានផង បរិភោគផង ចូរឡើងកាន់អរិយមគ្គ ព្រោះថា បុគ្គលអ្នកបរិភោគភោជនម្នាក់ឯង មិនបានសេចក្តីសុខទេ ដូច្នេះ ។

អត្ថនៃគាថាទាំងនោះ ដូច្នេះថា បុរសណាគិតថា យើងនឹងធ្វើពលីកម្មដល់នាគ និងយក្ខជាដើម ទើបចូលទៅកាន់ស្រះឯណានីមួយ បណ្តាសមុទ្រជ្រោះនិងស្រះបោក្ខរណីជាដើម ហើយបូជា ធ្វើពលីកម្មក្នុងទីនោះៗ ។ ម្យ៉ាងទៀត បុគ្គលបូជាត្រង់ស្ទឹងឈ្មោះពហុកា ត្រង់ស្រះបោក្ខរណីឈ្មោះគយា ត្រង់កំពង់ឈ្មោះទោណៈក្តី ត្រង់កំពង់ឈ្មោះតិម្ពរុក្តី ឬត្រង់អន្លង់ទឹកដែលមាន

ក្រសែខ្វួលខ្វាញ់ក្តី ។ បទថា **អត្រ ចស្ស** សេចក្តីថា បើការបូជានិងការព្យាយាមស្វែងរកទ្រព្យរបស់បុរសនោះក្នុងទីនោះ គឺត្រង់ស្រះជាដើមនោះ រមែងបានផលកម្រ គឺមានផល ។ ក្នុងពាក្យថា កាលបើភ្ញៀវអង្គុយនៅហើយ មិនគួរបរិភោគភោជនម្នាក់ឯងទេ ពាក្យដែលគប្បីពោល មិនមានឡើយ ។ ព្រោះហេតុនោះ ខ្ញុំសូមប្រាប់អ្នកថា នៃកោសិយសេដ្ឋី សូមលោកឲ្យទានផង បរិភោគឯងផង ចូរឡើងកាន់ផ្លូវរបស់ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើម ដែលជាអ្នកត្រេកអរក្រៃលែងហើយក្នុងទាន ព្រោះថា បុគ្គលបរិភោគតែឯង គឺបរិភោគត្រឹមតែម្នាក់ឯង មិនបានទទួលសេចក្តីសុខឡើយ ។

សេដ្ឋីស្តាប់ពាក្យមាតលីទេវបុត្តនោះហើយ ដូចត្រូវកំពូលភ្នំបាក់សង្កត់ ទើបនិយាយដោយទើសទាល់ថា បើដូច្នោះ សូមលោកអង្គុយចុះ លោកនឹងបានបន្តិច មាតលីទេវបុត្តក៏ចូលទៅអង្គុយជាមួយសុរិយទេវបុត្ត ។ លំដាប់នោះ បញ្ចសិខទេវបុត្តក៏ចូលទៅរកមហាសេដ្ឋីដោយធ្វើទំនងនោះទៀត ហើយពោលពាក្យដូចគ្នាយ៉ាងនោះ កាលសេដ្ឋីកំពុងពោលទាស់នោះឯង ទើបពោលគាថា ២ ថា

> បុគ្គលណា កាលបើភ្ញៀវអង្គុយនៅហើយ បរិភោគភោជន
> ម្នាក់ឯង បុគ្គលនោះ ឈ្មោះថា លេបសន្ទូចដែលមានខ្សែ
> ដ៏វែង ព្រមទាំងចំណង ។ ម្នាលកោសិយៈ ព្រោះហេតុនោះ
> យើងនិយាយនឹងអ្នក ចូរអ្នកឲ្យទានផង ចូរបរិភោគផង ចូរ
> ឡើងកាន់អរិយមគ្គ ព្រោះថា បុគ្គលអ្នកបរិភោគម្នាក់ឯង មិន

បានសុខទេ ដូច្នេះ ។

មច្ឆរិយកោសិយសេដ្ឋី បានស្តាប់ពាក្យនោះ អត់ធន់ដោយកម្លាំងនៃសេចក្តីទុក្ខនោះឯង ពោលថា បើដូច្នោះ សូមលោកអង្គុយចុះ លោកនឹងបានបន្តិច បញ្ចសិខទេវបុត្ត ក៏ចូលទៅអង្គុយជិតមាតលីទេវបុត្ត ។ កាលព្រាហ្មណ៍ទាំង ៥ នាក់នោះ អង្គុយព្រមគ្នាប៉ុណ្ណោះ បាយាសក៏ឆ្អិនល្មមដោយប្រការដូច្នេះ លំដាប់នោះទើបកោសិយសេដ្ឋីលើកបាយាសនោះចុះអំពីជើងក្រាន ហើយពោលថា អ្នកទាំងឡាយចូរនាំស្លឹកឈើមកឲ្យយើងចុះ ព្រាហ្មណ៍ទាំងនោះ មិនបានក្រោកឡើង អង្គុយក្នុងទីដដែលនោះឯង លាដៃទៅបេះស្លឹកឈើទាល មកអំពីព្រៃហិមពាន្ត ។ កោសិយសេដ្ឋីឃើញស្លឹកទាំងនោះ ទើបពោលថា បាយាសដែលគួរឲ្យដល់អ្នក ក្នុងស្លឹកឈើទាំងនេះមិនមាន ចូរនាំស្លឹកគគីរជាដើមមក ព្រាហ្មណ៍ទាំងនោះ ក៏នាំយកស្លឹកឈើទាំងឡាយមកហើយ តែស្លឹកឈើនីមួយៗ ដែលនាំមកនោះ ធំប្រមាណប៉ុនខែលរបស់ទាហាន កោសិយសេដ្ឋីនោះ ក៏យកវែកដួសបាយាស ឲ្យដល់ព្រាហ្មណ៍ទាំងនោះ ម្នាក់មួយវែក ក្នុងកាលដែលឲ្យដល់ព្រាហ្មណ៍បញ្ចសិខៈដែលជាព្រាហ្មណ៍ចុងក្រោយ បាយាសនោះ ក៏មិនប្រាកដថាអស់ឡើយ ។

សេដ្ឋីកាលឲ្យដល់ព្រាហ្មណ៍ទាំង ៥ ហើយ ឯខ្លួនឯងក៏អង្គុយចាប់ឆ្នាំងទុក ។ ក្នុងខណៈនោះ បញ្ចសិខទេវបុត្តក៏ក្រោកឡើង កាឡាខ្លួនជាឆ្កែ ចូលទៅឈរខាងមុខព្រាហ្មណ៍ទាំងនោះ បន្ទោបង់បស្សាវៈ ហើយក៏ទៅ ។ ពួកព្រាហ្មណ៍យកដៃបិទបាយាសរបស់ខ្លួន តំណក់ទឹកបស្សាវៈក៏ខ្ទាតត្រូវស្បែកដៃ

កោសិយសេដ្ឋី ពួកព្រាហ្មណ៍ក៏យកឃោកទៅដងទឹកមកលាងបាយាស ធ្វើដូចជាបរិភោគ កោសិយសេដ្ឋីក៏ពោលថា អ្នកទាំងឡាយ ចូរឲ្យទឹកដល់ខ្ញុំខ្លះ ខ្ញុំលាងដៃហើយនឹងបរិភោគ ។ ព្រាហ្មណ៍ទាំងនោះពោលថា សូមលោកទៅដងខ្លួនឯងមកលាងដៃ ហើយបរិភោគចុះ ។ កោសិយសេដ្ឋីពោលថា ខ្ញុំឲ្យបាយាសដល់ពួកលោកហើយ សូមលោកឲ្យទឹកដល់ខ្ញុំបន្តិចចុះ ។ ពួកព្រាហ្មណ៍ពោលថា ពួកយើងឈ្មោះថា រមែងមិនធ្វើកម្ម គឺការឲ្យបាយតបជុំបាយ ។ សេដ្ឋីពោលថា កាលបើយ៉ាងនោះ អ្នកទាំងឡាយ ជួយមើលថ្នាំងបាយនេះ ខ្ញុំលាងដៃហើយនឹងត្រឡប់មក ហើយទើបចុះទៅកាន់ស្ទឹង ក្នុងខណៈនោះ ឆ្កែក៏បន្ទោបង់បស្សាវៈដាក់ទាល់តែពេញថ្នាំង សេដ្ឋីត្រឡប់មកឃើញឆ្កែកំពុងបន្ទោបង់បស្សាវៈ ទើបកាន់យកដំបងធំសម្កុតឆ្កែនោះ ឆ្កែក៏មានខ្លួនធំឡើងៗ ប្រមាណប៉ុនសេះអាជានេយ្យដេញតាមសេដ្ឋីនោះ ហើយកាឡាខ្លួនជាសត្វមានពណ៌ផ្សេងៗ ជាពណ៌ខ្មៅខ្លះ សខ្លះ ពណ៌ដូចមាសខ្លះ ពពាលខ្លះ ទាបខ្លះ ខ្ពស់ខ្លះ ជាសត្វមានពណ៌ផ្សេងៗយ៉ាងនេះ ដេញតាមមច្ឆរិយកោសិយសេដ្ឋីទៅ សេដ្ឋីមានសេចក្តីខ្លាចចំពោះមរណភ័យ ទើបចូលទៅរកពួកព្រាហ្មណ៍ ពួកព្រាហ្មណ៍ទាំងនោះ ក៏នាំគ្នាហោះឡើងទៅឈរលើអាកាស សេដ្ឋីឃើញឥទ្ធិឫទ្ធិរបស់ពួកព្រាហ្មណ៍ទាំងនោះ ក៏ពោលគាថានេះថា

អើហ្ន៎ ព្រាហ្មណ៍ទាំងនេះ ពេញជាមានសម្បុរល្អលើសលុប
ចុះឆ្កែនេះរបស់ពួកអ្នក ក្លែងខ្លួនឲ្យមានពណ៌រុងរឿងប្លែកៗ
ព្រោះហេតុអ្វី ម្នាលព្រាហ្មណ៍ទាំងឡាយ អ្នកទាំងឡាយចូរ

ប្រាប់យើង អ្នកទាំងឡាយជាអ្វី ដូច្នេះ ។

សក្កទេវរាជទ្រង់ស្តាប់ពាក្យនោះ ទើបត្រាស់គាថានេះថា

ព្រាហ្មណ៍ទាំងពីរនាក់ ដែលមកក្នុងទីនេះ គឺចន្ទទេវបុត្តនិង
សុរិយទេវបុត្ត ចំណែកព្រាហ្មណ៍នេះ គឺមាតលិទេវបុត្ត ដែល
ជាទេវសារថី ឯយើងជាសក្កៈ ជាធំជាងពួកទេវតាក្នុងជាន់
តាវត្តិង្ស ឯព្រាហ្មណ៍នេះ គេហៅថា បញ្ចសិខៈ ដូច្នេះ ។

សក្កទេវរាជកាលត្រាស់គាថានេះហើយ កាលទ្រង់សរសើរនូវយសនៃបញ្ចសិខទេវបុត្ត ទើបត្រាស់គាថានេះថា

ល្បែងទះដៃក្តី ស្គរសម្ភោរក្តី ស្គរតូចនិងស្គរធំក្តី តែងញ៉ាំង
បញ្ចសិខទេវបុត្តនេះ ដែលដេកលក់ឲ្យភ្ញាក់ឡើងបាន លុះ
បញ្ចសិខទេវបុត្តនោះ ភ្ញាក់ឡើងហើយរមែងរីករាយ ដូច្នេះ ។

សេដ្ឋីបានស្តាប់ពាក្យរបស់សក្កៈនោះ ទើបសួរថា បពិត្រសក្កៈ បញ្ច-សិខទេវបុត្តបានទិព្វសម្បត្តិបែបនេះ ព្រោះធ្វើកម្មអ្វីទុក កាលសក្កៈសម្តែងថា បុគ្គលមិនឲ្យទានជាប្រក្រតី មានអំពើលាមក មានសេចក្តីកំណាញ់នឹងទៅទេវលោកមិនបាន រមែងទៅកើតក្នុងនរក ទើបត្រាស់គាថានេះថា

ពួកជនណានីមួយ មានសេចក្តីកំណាញ់ស្វិតស្វាញ ជាអ្នក
ប្រទេចផ្តាសានូវសមណព្រាហ្មណ៍ ពួកជននោះ ដាក់ចុះនូវ
រាងកាយគឺសរីរៈ ក្នុងលោកនេះ លុះបែកធ្លាយរាងកាយ
ហើយ រមែងទៅកើតក្នុងនរក ដូច្នេះ ។

សក្កទេវរាជ កាលត្រាស់គាថានេះហើយ បំណងនឹងសម្ដែងការបាន ចំពោះនូវទេវលោករបស់បុគ្គលទាំងឡាយ ដែលតាំងនៅក្នុងធម៌ ទើបត្រាស់ គាថានេះថា

ពួកជនណានីមួយ កាលប្រាថ្នានូវសុគតិ ឋិតនៅក្នុងធម៌ គឺ ការសង្រួមនិងការចែករំលែកនូវទាន ពួកជននោះ ដាក់ចុះនូវ រាងកាយគឺសរីរៈក្នុងលោកនេះ លុះបែកធ្លាយរាងកាយ រមែង ទៅកាន់សុគតិ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អាសីសមានា** សេចក្ដីថា ជនពួកណា កាល សង្ឃឹម រមែងសង្ឃឹមសុគតិ ជនទាំងអស់នោះតាំងនៅហើយក្នុងធម៌ គឺសីល ១០ ប្រការ ដែលរាប់ថា ជាការសង្រួមនោះក្នុងធម៌ គឺការឲ្យនូវទាន ដែល មានតែការចែករំលែកតែម្យ៉ាង លះបង់រាងកាយ ពោលគឺសរីរៈ ទុកក្នុង លោកនេះឯង ព្រោះការបែកធ្លាយនៃកាយ ជនទាំងនោះរមែងចូលដល់សុគតិ ។

សក្កទេវរាជកាលត្រាស់យ៉ាងនេះហើយ បំណងនឹងប្រកាសដល់សេដ្ឋី នោះថា នៃកោសិយសេដ្ឋី ពួកយើងមកកាន់សម្នាក់អ្នក មិនមែនត្រូវការ បាយាសទេ តែពួកយើងអាណិតអ្នកទើបនាំគ្នាមកដោយសេចក្ដីករុណា ហើយ ត្រាស់គាថានេះថា

អ្នកជាញាតិរបស់យើងក្នុងជាតិមុន អ្នកនោះឈ្មោះ កោសិយៈ ជាបុគ្គលកំណាញ់ មានធម៌ដ៏លាមក យើងមកក្នុងទីនេះ ដើម្បីប្រយោជន៍ដល់អ្នកតែម្យ៉ាងថា ញាតិរបស់យើង ដែល

មានធម៌ដ៏លាមក កុំទៅកាន់នរកឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សោ** សេចក្តីថា អ្នកនោះ ។ បទថា **មា ចាបធម្មោ** សេចក្តីថា ពួកយើងនាំគ្នាមក ដោយគិតយ៉ាងនេះថា សេដ្ឋីជាញាតិរបស់យើង កុំជាអ្នកមានធម៌ដ៏លាមកទៅកាន់នរកឡើយ ។

កោសិយសេដ្ឋីកាលស្តាប់ពាក្យនោះ មានចិត្តត្រេកអរថា បានឮថា ទេវបុត្តទាំងនោះ ប្រាថ្នាប្រយោជន៍ដល់អញ ប្រាថ្នាលើកអញឡើងអំពីនរក ឲ្យប្រតិស្ឋានក្នុងស្ថានសួគ៌ ទើបពោលគាថាទាំងឡាយថា

អ្នកទាំងឡាយនោះ ជាអ្នកប្រាថ្នានូវប្រយោជន៍ដល់ខ្ញុំដោយពិត ព្រោះថា អ្នកទាំងឡាយបានប្រៀនប្រដៅខ្ញុំដោយល្អ ខ្ញុំនោះនឹងធ្វើតាមពាក្យទាំងអស់ ដែលអ្នកទាំងឡាយ ជាអ្នកស្វែងរកប្រយោជន៍ បានពោលហើយដូច្នោះ ។ ខ្ញុំនោះ វៀរចាកសេចក្តីកំណាញ់ក្នុងថ្ងៃនេះឯង ខ្ញុំមិនធ្វើអំពើអាក្រក់តិចតួច ខ្ញុំមិនមែនជាមិនឲ្យវត្ថុតិចតួចទេ បើខ្ញុំមិនទាន់បានឲ្យទានទឹក មិនផឹកនូវទឹកទេ ។ បពិត្រព្រះវាសវៈ កាលខ្ញុំឲ្យទានសព្វកាលយ៉ាងនេះ ភោគៈទាំងឡាយរបស់ខ្ញុំមុខជានឹងអស់ទៅ បពិត្រសក្កៈ តអំពីនេះទៅ ខ្ញុំនឹងលះនូវកាមទាំងឡាយតាមចំណែក ហើយបួស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មេ** សេចក្តីថា ដល់ខ្ញុំ ។ បទថា **តេ** បានដល់ អ្នកទាំងឡាយ ។ បទថា **យំ មំ** អធិប្បាយថា អ្នកទាំងឡាយ តាម

មកទូន្មានខ្ញុំដោយហេតុណា អ្នកទាំងឡាយជាអ្នកប្រាថ្នាប្រយោជន៍ដល់ខ្ញុំ ដោយហេតុនោះ ។ ពាក្យថា **តថា** អធិប្បាយថា លោកពោលយ៉ាងណា ខ្ញុំនឹងធ្វើយ៉ាងនោះឯង ។ បទថា **ឧបរមាមិ** បានដល់ ខ្ញុំវៀរចាកភាពជាមនុស្សកំណាញ់ ។ បទថា **អនេយ្យមត្ថិ** បានដល់ ម្យ៉ាងទៀត ចាប់តាំងអំពីនេះទៅឈ្មោះថា ការមិនឲ្យសូម្បីប្រមាណពាក់កណ្ដាលនៃដុំបាយរបស់ខ្ញុំ នឹងមិនមានតទៅឡើយ ។ បទថា **ន ចាបិទត្វា** សេចក្ដីថា ម្យ៉ាងទៀត ខ្ញុំបានទឹកមកសូម្បីត្រឹមមួយទូកដៃ បើមិនឲ្យទានជាមុនហើយនឹងមិនផឹកទឹកនោះឡើយ ។ បទថា **ទីយិស្សន្តិ** បានដល់ អស់ទៅ ។ បទថា **យថោធិកានិ** បានដល់ ខ្ញុំនឹងលះកាមដែលជាចំណែកនៅសល់ ដោយអំណាចវត្ថុកាម និងកិលេសកាមនោះឯង ។

សក្កទេវរាជទ្រង់ទូន្មានមច្ឆរិយកោសិយសេដ្ឋី ធ្វើឲ្យអស់ព្យសន៍ ឲ្យដឹងផលនៃទាន ឲ្យតាំងនៅក្នុងសីល ៥ ដោយធម្មទេសនាហើយ ទើបនាំគ្នាយាងត្រឡប់មកទេវនគររបស់ទ្រង់ មួយអន្លើដោយទេវបុត្តទាំងនោះ ឯមច្ឆរិយកោសិយសេដ្ឋី ចូលទៅកាន់ព្រះនគរ សូមព្រះបរមរាជានុញ្ញាតហើយ ឲ្យទ្រព្យដល់យាចកទាំងឡាយ ដោយពាក្យថា អ្នកទាំងឡាយចូរកាន់យកទ្រព្យពេញភាជនៈ ដែលខ្លួនកាន់យកមកហើយនោះចុះ ហើយចេញអំពីផ្ទះទៅក្នុងខណៈនោះ ទៅសាងបណ្ណសាលាក្នុងរវាងស្ទឹងគង្គា និងជាតស្រះមួយកន្លែងត្រង់ទិសទក្សិណ អំពីហិមវន្តប្បទេស ហើយទើបបព្វជ្ជា មានឫសឈើ និងផ្លែឈើក្នុងព្រៃជាអាហារ បាននៅក្នុងទីនោះ អស់កាលដល់ជរា ។

ក្នុងកាលនោះ ធីតារបស់សក្កៈ មាន ៤ នាក់ គឺនាងអាសា នាងសទ្ធា នាងសិរី នាងហិរី ស្រីទាំង ៤ នោះ កាន់យកគ្រឿងក្រអូប និងកម្រងផ្កា ដែលជាទិព្វជាច្រើន ទៅកាន់អនោតត្តស្រះ បំណងនឹងលេងទឹក កាលលេងទឹកក្នុងស្រះនោះហើយ ក៏នាំគ្នាអង្គុយលើផ្ទាំងមនោសិលា ក្នុងខណៈនោះ ព្រាហ្មណតាបសឈ្មោះនារទៈ ទៅកាន់តាវត្តិង្សព្រឹកព ដើម្បីសម្រាកក្នុងពេលថ្ងៃ ទើបធ្វើលំនៅក្នុងចំណែកនៃនន្ទនវនឧទ្យាននិងចិត្តលតាវនឧទ្យាន ហើយយកផ្កាបារិច្ឆត្តកៈធ្វើជាម្ហូបដូចជាឆត្ត ទៅកាន់កញ្ចនគុហាដែលជាលំនៅរបស់ខ្លួន ក្នុងទីបំផុតនៃមនោសិលា ។ លំដាប់នោះ ពួកទេពធីតាទាំង ៤ ឃើញផ្កាក្នុងដៃរបស់តាបស ទើបនាំគ្នាសូម ព្រះសាស្តាកាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់គាថានេះថា

> ពួកទេវធីតានោះ ដែលទេវរាជរក្សាហើយក៏រីករាយលើភ្នំគន្ធ-
> មាទន៍ដ៏ប្រសើរ ដែលជាភ្នំខ្ពង់ខ្ពស់ គ្រានោះ ឥសីដ៏ប្រសើរ ជា
> អ្នកអាចទៅកាន់លោកទាំងអស់ បានកាន់យកនូវផ្កា ទុមវរ
> សាខា ដែលរីកស្គុសស្គាយ និមន្តមក ។ ផ្កានោះជាផ្កាស្អាត
> មានក្លិនក្រអូប ដែលពួកទេវតាក្នុងជាន់ត្រៃត្រិង្ស ធ្វើសក្ការៈ
> ហើយ ជាផ្កាដ៏ឧត្តម ដែលពួកទេវតាដ៏ប្រសើរសេពហើយ
> ពួកមនុស្សដទៃក្តី ពួកអសុរក្តី វៀរលែងតែពួកទេវតា មិន
> ដែលបានឡើយ ព្រោះថា ផ្កានោះ ជាប្រយោជន៍ដ៏សមគួរ
> ដល់ ( ពួកទេវតាទាំងនោះ ) ។ លំដាប់នោះ នារីទាំងបួន

ដែលជាធំលើសអស់ពួកស្រី មានស្បែកភ្លឺដូចមាស ឈ្មោះ អាសា ១ សទ្ធា ១ សិរី ១ ហិរី ១ បានក្រោកឡើង ហើយ ទូលសួរនារទតាបសជាអ្នកប្រាជ្ញ ទាំងជាព្រាហ្មណ៍ដ៏ប្រសើរ ដូច្នេះថា បពិត្រមហាមុនីដ៏ប្រសើរ បើផ្កាបារិច្ឆត្តព្រឹក្សនេះ លោកមិនឧទ្ទិស ( អ្នកណាទេ ) សូមលោកឲ្យដល់ពួកយើង គតិ ( នៃចិត្ត ) ទាំងពួង សូមសម្រេចដល់លោក ទោះបី លោកក៏សូម ( ឲ្យមានមេត្តា ) ចំពោះពួកយើង ដូចជា ព្រះវាសវៈដែរ ។ នារទតាបស បានឃើញពួកនារីមកសូម នូវផ្កានោះ ក៏ពោលថា នាងនិយាយនូវពាក្យនាំឲ្យបង្កជម្លោះ ប្រយោជន៍តិចតួចដោយផ្កាឈើទាំងនេះ មិនមានដល់យើងទេ នាងណា ដែលចម្បងជាងនាងទាំងឡាយ នាងនោះ ចូរ ប្រដាប់ផ្កានេះចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **គិរិវរេ** នេះ ជាវេវចនៈនៃពាក្យដំបូង គឺជា ភ្នំដ៏ឧត្តម ។ បទថា **ទេវវរាភិបាលិតា** បានដល់ ( ទេពធីតាទាំង ៤ ) ជា បុគ្គលដែលសក្កទេវរាជ ទ្រង់រក្សាហើយ ។ បទថា **សព្វលោកគូ** បានដល់ ជាអ្នកអាចទៅបានក្នុងលោកទាំងពួង គឺទាំងក្នុងទេវលោក ទាំងក្នុងមនុស្ស លោក ។ បទថា **ឧមាវរសាខមាភិយ** បានដល់ កាន់យកមែកឈើដែលបាន ហើយថា **ឧមាវរសាខ** ព្រោះផ្កានេះកើតអំពីមែក ។ បទថា **សក្កតំ** បានដល់ មានសក្ការៈដែលធ្វើហើយ ។ បទថា **អមរវរេភិ** នេះ ព្រះសាស្តាត្រាស់សំដៅ

យកសក្កទេវរាជ ។ បទថា **អញ្ញត្រ ទេវេហិ** បានដល់ ក្រៅពីពួកទេវតា និង ពួកអ្នកមានឫទ្ធិហើយ ពួកមនុស្ស ឬពួកអមនុស្សមានយក្ខជាដើម ទៅមិន បានទេ ។ បទថា **តទារហំ ហិតំ** បានដល់ ជាប្រយោជន៍ គឺសមគួរដល់ ពួកទេវតាទាំងនោះឯង ។ បទថា **កញ្ចនត្ថម្ភូបមា** បានដល់ មានពណ៌សម្បុរ ដូចមាស ។ បទថា **ឧដ្ឋាយ** បានដល់ ទេវនារីទាំងនោះប្រឹក្សាគ្នាថា លោក ម្ចាស់ ជាអ្នកផ្តាច់បង់ហើយចាកកម្រងផ្កា និងគ្រឿងក្រអូប និងគ្រឿងលាប ជាដើម គង់មិនប្រដាប់ផ្កា នឹងចោលក្នុងទីណាមួយ យើងសូមលោកហើយ នឹងប្រដាប់ផ្កា កាលលាដៃសូម ទើបក្រោកឡើងព្រមគ្នានោះឯង ។ បទថា **បមុទាធិបា** បានដល់ ជាអ្នកឧត្តមជាងស្រីអ្នកត្រេកអរទាំងឡាយ ។ បទថា **មុនី** សំដៅយកឥសី ។ បទថា **អនុទ្ទិដ្ឋំ** បានដល់ មិនឧទ្ទិសចំពោះថា យើង នឹងឲ្យផ្កានេះដល់ជនឈ្មោះនោះ ។ បទថា **សច្ចា គតិ តេ ឥជ្ឈតុ** បានដល់ ទេពធីតាទាំងនោះ ពោលពាក្យដែលជាមង្គលដល់នារទមុនីនោះថា សូមគតិ នៃចិត្តរបស់លោកម្ចាស់ទាំងអស់សម្រេចចុះ សូមលោកម្ចាស់ ជាអ្នកបាននូវ វត្ថុដែលខ្លួនប្រាថ្នាហើយចុះ ។ បទថា **យថេវ វាសវោ** បានដល់ ស្តេចវាសវៈ ជាបិតារបស់យើងទាំងឡាយ ប្រទានវត្ថុដែលខ្ញុំប្រាថ្នាហើយ ចង់បានហើយ យ៉ាងណា សូមឱ្យលោកម្ចាស់ ក៏សូមឲ្យដល់ពួកខ្ញុំ យ៉ាងនោះចុះ ។ បទថា **តំ** សំដៅយកផ្កានោះ ។ បទថា **អភិសមេក្ខ** បានដល់ សម្លឹងឃើញ ។ បទថា **សង្គលហំ** បានដល់ នាំពោលពាក្យសម្តីមានការកាន់យកផ្សេងៗ នាំឲ្យកើតវិវាទ ។ បទថា **ឥមេហិ** បានដល់ យើងមិនត្រូវការដោយផ្កាទាំង

នេះ ។ នារទមុនីសម្ដែងថា យើងជាអ្នកវៀរជាច់ស្រឡះហើយចាកការទ្រទ្រង់គ្រឿងប្រដាប់ គឺផ្កា ។ បទថា **យាយេវ ហោ សេយ្យសិ** បានដល់ ស្រីណាដែលប្រសើរបំផុតក្នុងរវាងនាងទាំងឡាយ ។ បទថា **សា បិលន្ធតុ** បានដល់នាងនោះ ចូរប្រដាប់ផ្កានេះ ។

ទេពធីតាទាំង ៤ អង្គ កាលបានស្ដាប់ពាក្យរបស់តាបស ទើបពោលគាថានេះថា

បពិត្រនារទតាបសដ៏ឧត្ដម សូមលោករមិលមើលនូវពួកយើងចុះ បើលោកប្រាថ្នានឹងឲ្យដល់នាងណា សូមលោកបោះផ្កានោះ សំដៅទៅនាងនោះ បពិត្រនារទតាបស ព្រោះថាបណ្ដាពួកយើង បើលោកឲ្យដល់នាងណា នាងនោះឯងយើងសន្មតថា ប្រសើរបំផុតជាងគេ ដូច្នេះ ។

ក្នុងគាថានោះ បទថា **ត្វំ នោត្តមេវ** បានដល់ បពិត្រមហាមុនីដ៏ឧត្ដមលោកម្ចាស់នោះឯង សូមពិចារណាមើលពួកខ្ញុំ ។ នារទតាបសស្ដាប់ពាក្យរបស់ស្រីទាំង ៤ នោះ កាលនឹងចរចា ទើបពោលគាថានេះថា

នៃនាងមានខ្លួនដ៏ល្អ សំដីនេះមិនគួរទេ បុគ្គលដូចម្ដេច ដែលហៅថាព្រាហ្មណ៍ បុគ្គលដូចម្ដេច គួរពោលពាក្យដែលនាំបន្ដជម្លោះ បើនាងទាំងឡាយ ដែលមិនដឹងធម៌ដ៏ខ្ពង់ខ្ពស់ ក្នុងលោកនេះទេ ចូរទៅសួរព្រះឥន្ទ្រដែលជាធំជាងពួកទេវតាចុះ ដូច្នេះ ។

សេចក្តីអធិប្បាយក្នុងគាថានោះថា ម្នាលនាងមានកាយល្អ ពាក្យដែលពួកនាងពោលហើយនេះ មិនសមគួរដល់យើង ព្រោះថា កាលបើដូច្នេះ គ្រាយើងធ្វើនាងម្នាក់ បណ្តាពួកនាងឲ្យជាបុគ្គលប្រសើរ ទេពធីតាដ៏សេសឲ្យជាបុគ្គលមិនប្រសើរហើយ ជម្លោះគប្បីកើតឡើង នរណានឹងជាព្រាហ្មណ៍បន្សាត់បាប អ្នកណាគប្បីពោលការឈ្លោះ គឺគប្បីធ្វើជម្លោះឲ្យចម្រើន ដ្បិតថា ការធ្វើជម្លោះឲ្យកើតឡើង រមែងមិនសមគួរដល់យើង ដែលមានសភាពបែបនេះ ព្រោះហេតុនោះ បើនាងមិនដឹងថា បុគ្គលប្រសើរ ឬធម៌ប្រសើរ នាងទាំងឡាយចូរទៅអំពីទីនេះ ហើយចូរសួរសក្កៈ ដែលជាធំជាងភូតទាំងឡាយ ដែលជាបិតារបស់ពួកនាងចុះ ។

ព្រះសាស្តា កាលទ្រង់ត្រាស់ដឹងហើយ ទ្រង់ត្រាស់អភិសម្ពុទ្ធគាថាដូច្នេះថា

ពួកទេវធីតាទាំងនោះ ដែលនារទតាបស បានពោលយ៉ាងនេះ
ហើយ ក៏មានចិត្តក្រេវក្រោធយ៉ាងក្រៃលែង ជាស្រ្តីស្រវឹង
ដោយសេចក្តីស្រវឹងនឹងសម្បុរ ហើយបានទៅកាន់សំណាក់
ព្រះឥន្ទជាសហស្សចក្ខុ រួចសួរនូវព្រះឥន្ទ ដែលជាធំជាងពួក
ទេវតាថា (បណ្តាពួកយើង) នាងណាប្រសើរជាងគេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បរមប្បកោបិតា** បានដល់ កាលនារទតាបសមិនឲ្យផ្កា ក៏ជាអ្នកមានសេចក្តីក្រោធក្រៃពេក ។ បទថា **ឧទីរិតា** បានដល់ កាលនារទតាបសពោលថា ពួកនាងចូរទៅសួរសក្កទេវរាជដែលជាស្តេចនៃទេវតាឯងចុះ ។ បទថា **សហស្សចក្ខុនោ** បានដល់ ទៅកាន់សម្នាក់របស់

សក្កៈ ។ បទថា **កា នុ** បានដល់ ទេពធីតាទាំង ៤ ទូលសួរថា ក្នុងរវាង ខ្ញុំទាំងឡាយ អ្នកណាប្រសើរជាងគេ ។ ទេពធីតាទាំង ៤ រូប បានឈរទូលសួរដូច្នេះហើយ ។

ព្រះសាស្តា កាលទ្រង់ត្រាស់ដឹងហើយ ទើបបន្ទឹអភិសម្ពុទ្ធគាថានេះថា

ព្រះឥន្ទដ៏ប្រសើរជាងពួកទេវតា ដែលពួកទេវតាតែងប្រណម្យ
អញ្ជលី លុះបានឃើញនូវពួកទេវធីតាទាំងនោះ មានចិត្តខ្វល់
ខ្វាយ ក៏បានពោលតបដូច្នេះថា នែនាង មានជោគល្អ នាង
ទាំងអស់ប្រហែលៗ គ្នាទេ ម្នាលនាងដ៏ចម្រើន ចុះបុគ្គលណា
ហ្ន៎ បានពោលពាក្យដែលនាំបង្កជម្លោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តា ទិស្វា** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ សក្កទេវរាជឃើញទេពធីតាទាំង ៤ ដែលមកកាន់សម្នាក់របស់ខ្លួន ។ បទថា **អាយត្តមនា** សេចក្តីថា មិនឲ្យចិត្តវង្វេងរាយមាយ ។ បទថា **កតញ្ជលី** សេចក្តីថា ដែលទេវតាទាំងឡាយធ្វើអញ្ជលីហើយ ។ បទថា **សាទិសី** សេចក្តីថា ពួកនាងទាំងអស់ជាបុគ្គលដូចគ្នា ។ បទថា **កោនេវ** សេចក្តីថា បុគ្គលណាហ្ន៎ក្នុងទីនេះ ។ បទថា **កលហំ ឧទីរយិ** សេចក្តីថា ពោលការឈ្លោះវិវាទនេះឡើង គឺធ្វើនូវការឈ្លោះឲ្យកើតឡើង ។

លំដាប់នោះ ទេពនារីទាំង ៤ កាលក្រាបទូលដល់សក្កៈនោះ បានពោលគាថាដូច្នេះថា

នារទតាបសណា ជាមហាមុនី អាចត្រាច់ទៅក្នុងលោកទាំង

អស់បាន ឋិតនៅក្នុងធម៌ មានព្យាយាមដ៏ទៀងទាត់ នារទតាបស
នោះ បានពោលនឹងពួកយើងលើភ្នំដ៏ប្រសើរឈ្មោះ គន្ធមាទន៍
ថា បើនាងទាំងឡាយ មិនដឹងនូវធម៌ដ៏ឧត្តមក្នុងលោកនេះទេ
ចូរទៅសួរព្រះឥន្ទដែលជាធំជាងពួកទេវតាចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សច្ចនិក្កមោ** ក្នុងគាថានោះ សំដៅយក មាន
សេចក្ដីព្យាយាមជាគ្រឿងឈានទៅខាងមុខយ៉ាងពិត ។

សក្កទេវរាជទ្រង់ស្ដាប់ដូច្នោះ ទ្រង់ព្រះតម្រិះថា ស្រីទាំង ៤ នេះ សុទ្ធ
តែជាធីតារបស់យើងទាំងអស់ បើយើងនឹងពោលស្រីម្នាក់បណ្ដាស្រីទាំងនេះ
ថា ជាអ្នកដល់ព្រមដោយគុណ ជាបុគ្គលឧត្តមហើយសោត ស្រីដ៏សេស
នឹងក្រោធ អញមិនអាចកាត់សេចក្ដីក្នុងរឿងនេះបាន អញនឹងបញ្ជូនធីតាទាំង
៤ នេះ ទៅកាន់សម្នាក់កោសិយតាបសក្នុងហិមវន្តប្បទេស លោកនឹងវិនិច្ឆ័យ
រឿងនេះដល់ស្រីទាំងនេះឯង ទើបត្រាស់ប្រាប់ថា បិតាកាត់ក្ដីឲ្យនាងទាំងឡាយ
មិនបាន ក្នុងហិមវន្តប្បទេស មានតាបសមួយរូបឈ្មោះ កោសិយៈ បិតានឹង
បង្អោនសុធាភោជនទៅប្រគេនលោក លោកមិនទាន់ឲ្យដល់អ្នកដទៃក៏មិន
បរិភោគ កាលនឹងឲ្យលោកពិចារណាមុនហើយទើបឲ្យដល់បុគ្គលដែលមាន
គុណ បណ្ដានាងទាំងឡាយ នាងណាបានភត្តអំពីដៃរបស់លោក នាងនោះ
នឹងជាអ្នកប្រសើរ ទើបត្រាស់គាថានេះថា

ម្នាលនាងមានខ្លួនដ៏ប្រសើរ តាបសឯណោះ ជាមហាមុនី ជា
អ្នកត្រាច់ទៅក្នុងព្រៃធំ បើមិនទាន់ឲ្យទាន មិនបរិភោគនូវភត្ត

ទេ កោសិយតាបសនោះ ពិចារណាហើយ ទើបឲ្យនូវទាន
ទាំងឡាយ ព្រោះថា តាបសនោះ នឹងឲ្យផ្កា[១]ដល់នាងណា
នាងនោះឯង ពេញជាប្រសើរជាងគេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ព្រហារញ្ញចរោ** ក្នុងគាថានោះ សំដៅយក បុគ្គលអ្នកមានប្រក្រតីនៅក្នុងព្រៃធំ ។

សក្កៈបញ្ជូនស្រីទាំង ៤ ទៅកាន់សម្នាក់តាបស ដោយប្រការដូច្នេះហើយ ឲ្យហៅមាតលីទេវបុត្តមក ដើម្បីនឹងបញ្ជូនទៅកាន់សម្នាក់របស់តាបសនោះ ទើបត្រាស់គាថាជាប់តគ្នាថា

តាបសឯណោះនោះ គង់នៅក្នុងទិសខាងត្បូង នៃភ្នំហិមវន្ត
ប្របច្នេរទន្លេគង្គា កោសិយតាបសនោះ បានទឹកនឹងភោជន
ដោយកម្រ ម្នាលមាតលិទេវបុត្ត ជាទេវសារថី អ្នកចូរញ៉ាំង
សុធាភោជនឲ្យសម្រេចដល់កោសិយតាបសចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សម្មតិ** បានដល់ អាស្រ័យនៅ ។ បទថា **ទក្ខិណំ** បានដល់ ទិសទក្សិណនៃភ្នំហិមពាន្ត ។ បទថា **បស្សិធិ** បានដល់ ក្បែរភ្នំហិមពាន្ត ។ ព្រះសាស្ដា កាលទ្រង់បានត្រាស់ហើយ ទ្រង់ត្រាស់ អភិ-សម្ពុទ្ធគាថាដូច្នេះថា

មាតលិទេវបុត្តនោះ លុះព្រះឥន្ទប្រសើរជាងទេវតាប្រើហើយ
ក៏ឡើងជិះទេវរថដែលទឹមដោយសេះ ១០០០ ហើយ ចូល

---

១-គួរប្រែបញ្ចូលថា នឹងឲ្យភោជនដល់នាងណា ទើបត្រូវតាមន័យរបស់អដ្ឋកថា ។

ទៅកាន់អាស្រមយ៉ាងរហ័ស មិនបង្ហាញកាយឲ្យឃើញស្រាប់

តែប្រគេននូវសុធាភោជនដល់តាបសជាអ្នកប្រាជ្ញ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អធិស្សមានោ** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ មាតលីនោះទទួលព្រះតម្រាស់របស់សក្កទេវរាជហើយ ក៏ទៅកាន់អាស្រមបទនោះ មានកាយមិនប្រាកដឲ្យឃើញ បានប្រគេនសុធាភោជនដល់តាបសនោះ កាលប្រគេន បានដាក់ថាសសុធាភោជន ក្នុងដៃរបស់តាបស ដែលប្រកបសេចក្ដីព្យាយាមអស់រាត្រី បម្រើភ្លើងក្នុងកាលទៀបភ្លឺ កាលរាត្រីអស់ហើយ ទើបឈរនមស្ការព្រះអាទិត្យដែលកំពុងរះក្នុងលម្ហ ។

កោសិយតាបសទទួលភោជននោះហើយ ឈរពោលគាថា ២ ថា

កាលដែលអាត្មាអញ បម្រើនូវការបូជាភ្លើង និងព្រះអាទិត្យ

ដ៏ឧត្ដម ដែលបន្ទោបង់នូវងងឹតក្នុងលោក អ្នកណាហ្ន៎ ដូច

ព្រះវាសវៈ កន្លងនូវពួកទេវតាទាំងអស់ ដាក់សុធាភោជន

លើដៃទាំងពីរ របស់អញឬ ។ សុធាភោជននោះដ៏សដូចជា

ស័ង្ខ គួររមិលមើល រកអ្វីប្រៀបគ្មាន ជាភោជនស្អាត មាន

ក្លិនក្រអូប មានសភាពគួរពេញចិត្តយ៉ាងចំឡែក ភ្នែករបស់

អញតាំងអំពីកើតមក មិនដែលឃើញសោះឡើយ ទេវតា

ណាហ្ន៎ដាក់នូវសុធាភោជនលើដៃទាំងពីររបស់អញឬ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧទគ្គិហុត្តំ** សេចក្ដីថា កាលយើងបម្រើភ្លើង ដែលយើងបូជាហើយចេញអំពីរោងភ្លើង ឈរត្រង់ទ្វារបណ្ណសាលា ឈរមើល

ព្រះអាទិត្យ ដែលមានពន្លឺភ្លឺស្វាង បន្ទោបង់នូវងងឹតក្នុងលោកដ៏ឧត្តមចេញបាន ស្តេចវាសវៈដែលគ្របសង្កត់ ឈានកន្លងនូវភូតទាំងអស់ ប្រព្រឹត្តទៅឬមិនមែនហ្ន៎ មកដាក់ភត្តដ៏សស្អាតលើដៃរបស់អញ យ៉ាងនេះ កោសិយតាបសនោះ ជាអ្នកឈរនោះឯង បានពោលសរសើរសុធាភោជនដ៏វិសេសដោយពាក្យជាដើមថា ដ៏សដូចជាស័ង្ខ ដូច្នេះ ។

គ្រានោះ មាតលីទេវសារថីក៏ឆ្លើយថា

បពិត្រលោកជាមហាមុនី អ្នកស្វែងរកនូវគុណដ៏ធំ ខ្ញុំដែលព្រះឥន្ទជាធំបានប្រើមក ខ្ញុំក៏បាននាំសុធាភោជនយ៉ាងរួសរាន់លោកបាន ស្គាល់នូវខ្ញុំថាឈ្មោះមាតលិទេវបុត្ត ជាទេវសារថីសូមលោក ឆាន់នូវភត្តដ៏ឧត្តមចុះ លោកកុំប្រកែកពារាំងឡើយ ។ ឯសុធាភោជនទោះ លុះលោកបរិភោគហើយរមែងកម្ចាត់បង់បាបធម៌ ១២ យ៉ាងបានគឺ សេចក្តីឃ្លាន ១ ការស្រេក ១ សេចក្តីអផ្សុក ១ ក្រវល់ក្រវាយកាយ ១ លំបាកកាយ ១ ក្រោធ ១ ចងសេចក្តីក្រោធក្នុងចិត្ត ១ ឈ្លោះប្រកែក ១ ញុះញង់ ១ ត្រជាក់ ១ ក្តៅ ១ ខ្ជិល ១ ដ្បិតភោជននេះ មានរសដ៏ឧត្តម ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុធាភិហាសឹ** សេចក្តីថា ខ្ញុំនាំសុធាភោជនមកចំពោះលោកម្ចាស់ ។ បទថា **ជានាសិ មំ** សេចក្តីថា សូមលោកម្ចាស់ស្គាល់ខ្ញុំថា បុគ្គលនេះ គឺទេវសារថី មានឈ្មោះថាមាតលី ។ បទថា **មាភិ–**

**វារយិ** សេចក្តីថា សូមលោកម្ចាស់កុំឃាត់ឡើយថា យើងមិនបរិភោគកត្តនេះទេ សូមលោកម្ចាស់ធាន់ចុះ កុំធ្វើនូវការឃើតយូរឡើយ ។ បទថា **ធាបកោ** សេចក្តីថា ព្រោះថា សុធាភោជនដែលបុគ្គលបរិភោគហើយនេះ រមែងកម្ចាត់បង់នូវធម៌ដ៏លាមក ១២ ប្រការ ។ បទថា **ខុទ្ទំ** បានដល់ រមែងកម្ចាត់សេចក្តីឃ្លានជាទី ១ កម្ចាត់ការស្រេកទឹកជាទី ២ កម្ចាត់ការអផ្សុកជាទី ៣ កម្ចាត់ការក្រវល់ក្រវាយកាយជាទី ៤ កម្ចាត់ការហត់នឿយជាទី ៥ កម្ចាត់សេចក្តីក្រោធជាទី ៦ កម្ចាត់ឧបនាហៈជាទី ៧ កម្ចាត់នូវវិវាទជាទី ៨ កម្ចាត់នូវការញុះញង់ជាទី ៩ កម្ចាត់នូវរងាជាទី ១០ កម្ចាត់នូវក្តៅជាទី ១១ កម្ចាត់នូវសេចក្តីខ្ជិលច្រអូសជាទី ១២ សុធាភោជនមានរសដ៏ឧត្តម គឺមានរសដ៏ប្រសើរនេះ រមែងកម្ចាត់បាបធម៌ ១២ ប្រការ នេះចេញបាន ។

កោសិយតាបសស្តាប់ពាក្យនោះហើយ កាលធ្វើឲ្យជាក់ច្បាស់នូវការសមាទានវត្តរបស់ខ្លួន បានពោលគាថានេះថា

ម្នាលទេវបុត្តឈ្មោះមាតលិ ការដែលអាត្មាមិនបានឲ្យទានជាមុនសិនហើយបរិភោគមិនគួរទេ ព្រោះវត្តនេះជាវត្តឧត្តមរបស់អាត្មា ឯការបរិភោគតែម្នាក់ឯង ជាអំពើដែលព្រះអរិយៈមិនបូជាឡើយ មួយទៀត បុគ្គលអ្នកមិនបានចែករំលែក រមែងមិនបាននូវសេចក្តីសុខទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បុព្វេ** បានដល់ មិនឲ្យមុនហើយ ។ម្យ៉ាងទៀត កោសិយតាបសសម្តែងថា វត្តនេះជាវត្តដ៏ឧត្តមរបស់ពួកយើង មកអំពី

មុន គឺយើងសមាទានវត្តនេះ មកអំពីមុនដោយប្រការដូច្នេះឯង ។ បទថា **ឃាសមេសំ** បានដល់ ការបរិភោគរបស់បុគ្គលម្នាក់ឯង ដែលព្រះអរិយទាំងឡាយ មានព្រះពុទ្ធជាដើម មិនបូជាហើយ ។ បទថា **សុខំ** បានដល់ រមែងមិនបានទទួលសេចក្ដីសុខទាំងជារបស់ទិព្វនិងជារបស់មនុស្ស ។

កោសិយតាបស កាលពោលគាថាហើយ ដែលមានមាតលិទេវបុត្តសួរថា បពិត្រលោកម្ចាស់ លោកម្ចាស់ឃើញទោសអ្វីក្នុងការមិនឲ្យដល់អ្នកដទៃជាមុនហើយបរិភោគ ទើបសមាទានវត្តនេះ ក៏ឆ្លើយថា

ពួកជនណាមួយ ជាអ្នកសម្លាប់ស្ត្រី ជាអ្នកប្រព្រឹត្តបរទារិកកម្ម ឬក៏ពួកជនណា ជាអ្នកប្រទូស្តមិត្ត ជេរប្រទេចពួកបុគ្គលអ្នកមានវត្តល្អ ជនទាំងអស់នោះ សុទ្ធតែមានសេចក្ដីកំណាញ់ដ៏ថោកទាបជាគម្រប់ ៥ ព្រោះហេតុនោះ អាត្មាបើមិនបានឲ្យ សូម្បីនូវទឹក ក៏មិនបរិភោគទេ ។ មួយទៀត អាត្មានោះត្រូវតែឲ្យទានដែលអ្នកប្រាជ្ញសរសើរហើយ ដល់ស្ត្រីឬបុរសដ្បិត បុគ្គលអ្នកមានសទ្ធា អ្នកដឹងនូវពាក្យស្អូម ប្រាសចាកសេចក្ដីកំណាញ់ទាំងនុ៎ះ លោកសន្មតថា ជាអ្នកមានសច្ចៈដ៏ស្អាត ក្នុងលោកនេះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឥត្ថីឃាតកា** បានដល់ ជាអ្នកសម្លាប់ស្ត្រី ។ បទថា **យេ កេចិមេ** បានដល់ បុគ្គលទាំងនេះ ពួកណាមួយ ។ បទថា **សបន្តិ** បានដល់ រមែងជេរប្រទេច ។ បទថា **សុព្វតេ** សំដៅយកសមណព្រាហ្មណ៍

ដែលប្រកបដោយធម៌ ។ បទថា **មច្ឆរិបញ្ហា** មានវិគ្គហៈថា សេចក្តីកំណាញ់ ជាគម្រប់ ៥ របស់ជនទាំងនេះ ហេតុនោះ ទើបជនទាំងនេះ ឈ្មោះថា មានសេចក្តីកំណាញ់ជាគម្រប់ ៥ ។ បទថា **អធមា** បានដល់ ធម៌ទាំង ៥ ប្រការនេះ ឈ្មោះថាអធម៌ ។ បទថា **តស្មា** សេចក្តីថា ព្រោះហេតុនោះ ទើបយើងសមាទានវត្តនេះថា បើមិនទាន់បានឲ្យមុនហើយ នឹងមិនផឹក គឺមិនបរិភោគសូម្បីទឹក ដូច្នេះ ព្រោះខ្លាចភាពជាអធម៌គម្រប់ ៥ ។ បទថា **សោហិត្តិយាវា** បានដល់ ខ្ញុំនឹងឲ្យទានដល់ស្រីឬ ។ បទថា **វិទុសម្បវណ្ណិតំ** សំដៅយកបុគ្គលដែលជាអ្នកប្រាជ្ញ បានដល់ បណ្ឌិត មានព្រះពុទ្ធជាដើម សរសើរហើយ ។ បទថា **សុចិសច្ចសម្មតា** អធិប្បាយថា បុរសទាំងឡាយនេះ ជាអ្នកប្រកបទៅដោយសទ្ធាចុះស៊ប់ ជាអ្នកដឹងពាក្យរបស់អ្នកសូម ប្រាសចាកសេចក្តីកំណាញ់ រមែងឈ្មោះថា ជាអ្នកស្អាតនិងសន្មតថា ឧត្តម ។

មាតលីស្តាប់ពាក្យនោះ ទើបឈរបង្ហាញកាយឲ្យប្រាកដ ។ ក្នុងខណៈនោះ ទេវកញ្ញាទាំង ៤ នោះ បានមកឈរក្នុងទិសទាំង ៤ គឺនាងសិរីឈរក្នុងទិសខាងកើត នាងអាសាឈរក្នុងទិសទក្សិណ នាងសទ្ធាឈរក្នុងទិសបស្ចិម នាងហិរីឈរក្នុងទិសឧត្តរ ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់គាថានេះថា

លំដាប់នោះ នាងកញ្ញាទាំង ៤ នាក់ ដែលមានស្បែកដូចជា
មាស ឈ្មោះអាសា ១ សទ្ធា ១ សិរី ១ ហិរី ១ ដែលព្រះឥន្ទ
ប្រសើរជាងទេវតា បានយល់ព្រមប្រើទៅហើយ នាងក៏មក

កាន់អាស្រមជាទីនៅនៃកោសិយតាបសនោះ ។ កោសិយតាបស បានឃើញនាងកញ្ញាទាំង ៤ នោះ ដែលមានចិត្តត្រេកអរយ៉ាងលើសលុបទាំងអស់គ្នា មានវណ្ណៈដ៏ល្អដូចអណ្តាតភ្លើង ឋិតនៅក្នុងទិសទាំង ៤ ហើយបានពោល ដូច្នេះក្នុងទីចំពោះមុខនៃមាតលិទេវបុត្តថា ម្នាលទេវតា នាងជាអ្វីមានកាយប្រដាប់ហើយ បានញុំាងទិសខាងកើតឲ្យភ្លឺ ដូចជាផ្កាយព្រឹកដ៏ប្រសើរ ម្នាលនាងមានរាងកាយដូចជារូបប្រៀបជាវិការៈនៃមាស អាត្មាសូមសួរនាង ចូរនាងប្រាប់អាត្មា នាងជាទេវតាឈ្មោះអ្វី ដូច្នេះ ។

នាងសិរីបានស្តាប់ដូច្នោះហើយ កាលនឹងធ្វើខ្លួនឲ្យប្រាកដ ទើបពោលគាថានេះថា

ខ្ញុំជាទេវធីតាឈ្មោះសិរី ដែលគេបូជាក្នុងពួកមនុស្ស មិនចូលទៅគប់រកនូវសត្វលាមកគ្រប់កាល មកកាន់សំណាក់លោកព្រោះទាស់ទែងគ្នាអំពីសុធាភោជន បពិត្រលោកមានប្រាជ្ញាដ៏ប្រសើរ ព្រោះហេតុនោះ សូមលោកចែកនូវសុធាភោជនដល់ខ្ញុំ ។ បពិត្រលោកជាមហាមុនី ខ្ញុំប្រាថ្នាសុធាភោជនរបស់ជនណា ជននោះឯង រមែងរីករាយដោយកាមគ្រប់យ៉ាងបពិត្រលោកដ៏ខ្ពង់ខ្ពស់ជាងពួកជនអ្នកបូជាភ្លើង សូមលោកដឹងនូវខ្ញុំថាជា ទេវធីតាឈ្មោះសិរី បពិត្រលោកអ្នកមានប្រាជ្ញា

ដ៏ប្រសើរ ព្រោះហេតុនោះ សូមលោកចែកនូវសុធាភោជន ដល់ខ្ញុំ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អតោ** បានដល់ ក្នុងកាលនោះ ។ បទថា **មតា** បានដល់ ទទួលដឹងហើយ អធិប្បាយថា ជាបុគ្គលដែលសក្កទេវរាជប្រសើរជាងទេវតាទាំងឡាយ អនុមតិហើយផង បញ្ជូនទៅហើយផង ក្នុងកាលនោះ ។ បទថា **សព្វា បរមប្បមោធិតា** បានដល់ ទេវកញ្ញាទាំងនោះ មិនមានសេសសល់ឡើយ ជាអ្នកត្រេកអរក្រៃកែង ។ ព្រះបាលីខ្លះថា **សាមំ** ប្រែថា ឯង អធិប្បាយថា កោសិយតាបសនោះ ឃើញទេវកញ្ញាទាំងនោះឯង ។ បទថា **ចតុរោ** កែជា **ចុរា** ។ម្យ៉ាងទៀត ព្រះបាលីជា **ចតុរា** ដូច្នេះក៏មាន អធិប្បាយថា ប្រកបព្រមដោយអាការៈគួរស្រឡាញ់ ។ បទថា **តារវរា** បានដល់ ប្រសើរជាងផ្កាយទាំងអស់ ។ បទថា **កញ្ចនវេល្លិវិគ្គហេ** បានដល់ មានសរីរៈដូចគ្នានឹងបដិមាមាស ។ បទថា **សិរាហា** បានដល់ ខ្ញុំឈ្មោះថា សិរី ។ បទថា **តវន្តិមាគតា** បានដល់ មកកាន់សម្នាក់របស់លោកម្ចាស់ ។ បទថា **ភាជយ** បានដល់ ចែករំលែក ឲ្យខ្ញុំបានដោយប្រការណា សូមលោកម្ចាស់ ធ្វើដោយប្រការនោះចុះ អធិប្បាយថា ចូរឲ្យសុធាភោជនដល់ខ្ញុំខ្លះ ។ បទថា **ជានាហិ** បានដល់ ចូរជ្រាបចុះ ។ បទថា **ជុហតុត្តម** បានដល់ជាបុគ្គលដ៏ឧត្តមជាងអ្នកបូជានូវភ្លើង ។

លំដាប់នោះ កោសិយតាបស ស្តាប់ពាក្យនោះហើយ ទើបពោលគាថានេះថា

ពួកជនដែលប្រកបដោយសិល្បវិជ្ជាចរណៈនិងប្រាជ្ញា ជាអ្នក
ស្ទាត់ជំនាញ ដោយអំពើរបស់ខ្លួន ត្រឡប់ជាថោកទាបជាង
នាងវិញ មិនបានយសឬសេចក្តីសុខនោះ តិចតួចសោះឡើយ
អំពើណាដែលនាងបានធ្វើហើយ អំពើនោះ មិនប្រពៃទេ ។
អាត្មាបានឃើញនូវជនខ្វិលច្រអូស បរិភោគច្រើន ទាំងមាន
ត្រកូលថោកទាប មានរូបអាក្រក់ បុរសនោះ ដែលនាងបាន
រក្សាហើយ ក៏បែរទៅជាអ្នកមានសិរី អាចប្រើនូវជនដែល
មានជាតិខ្ពស់ ដូចជនអ្នកមានភោគៈ មានសេចក្តីសុខ ប្រើនូវ
ខ្ញុំកំដរ ។ ព្រោះហេតុនោះ យើងដឹងនូវនាងជាស្រីមិនមាន
សច្ចៈ គប់រកឥតរើសមុខ ជាស្រីល្ងង់ បៀតបៀនអ្នកប្រាជ្ញ
ស្រីប្រហែលដូចនាង មិនគួរទទួលអាសនៈនឹងទឹកទេ សុជា
កោជននឹងមានពីណា នាងចូរទៅចុះ អាត្មាមិនពេញចិត្តនឹង
នាងទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សិប្បេន** បានដល់ ប្រកបដោយសិប្បៈ មាន
សិប្បៈដែលទាក់ទងដោយដំរី សេះ រថ និងធ្នូជាដើម ។ បទថា **វិជ្ជាចរ-
ណេន** បានដល់ វិជ្ជាគឺវេទទាំង ៣ និងសីល ។ បទថា **បគុណា សកម្មុនា**
បានដល់ ជាអ្នកប្រកបដោយព្យាយាមនៃបុរសរបស់ខ្លួន ។ បទថា **កិញ្ចិ ធំ**
បានដល់ មិនបានយស ឬសេចក្តីសុខសូម្បីមានប្រមាណតិចតួច ។ បទថា
**តយិធំ** បានដល់ កំហុសឯណា ដែលនាងធ្វើហើយ ដល់បុគ្គលដែលរៀន

សិប្បៈទាំងឡាយ ហើយត្រាច់ទៅដើម្បីត្រូវការភាពជាធំ កិច្ចនោះ មិនមាន ទេ ។ បទថា **អរូបិមំ** បានដល់ មានរូបខុសប្រក្រតី ។ បទថា **តយា-ន្នុគុត្តោ** បានដល់ ដែលនាងតាមរក្សាទុកហើយ ។ បទថា **ជាតិមាមបិ** បានដល់ ដល់ព្រមហើយដោយជាតិខ្លះ ដល់ព្រមហើយដោយសិប្បវិជ្ជា ការប្រព្រឹត្តនិងការងារដែលប្រកបដោយបញ្ញាខ្លះ ។ បទថា **បេសេតិ** បានដល់ រមែងធ្វើនូវការប្រើប្រាស់ ។ បទថា **តន្តំ** បានដល់ ព្រោះហេតុនោះ យើងស្គាល់នាង ។ បទថា **អសច្ចំ** បានដល់ នាងមិនមានសច្ចៈ ព្រោះមិនប្រព្រឹត្តក្នុងសច្ចៈដែលរាប់ថា ជាសភាវៈ គឺវៀរចាកភាពជាបុគ្គលឧត្តម ។ បទថា **អវិភជ្ជ សេវិនី** បានដល់ មិនចែករំលែក មិនដឹងវត្ថុដែលគួរនិងមិនគួរសេពនូវនរជន ក្រៅអំពីនេះ សូម្បីដល់ព្រមដោយសិប្បៈជាដើម ។ បទថា **វិធុរា-ន្នុចាតិនី** បានដល់ ធ្វើបណ្ឌិតឲ្យធ្លាក់ទៅតាម គឺធ្វើបណ្ឌិតឲ្យធ្លាក់ទៅ ហើយបៀតបៀន ។ បទថា **កុតោ សុជា** អធិប្បាយថា សុជាកោជនរបស់នាងបុគ្គលមានគុណជាបកថយបែបនេះនឹងមានអំពីណា នាងមិនគាប់ចិត្តយើង ចូរនាង ត្រឡប់ទៅចុះ កុំនៅទីនេះឡើយ ។

សិរីទេពធីតានោះ កាលត្រូវកោសិយៈឃាត់ហើយ ក៏អន្តរធានទៅក្នុងទីនោះឯង លំដាប់នោះ កោសិយតាបសនោះ កាលសន្ទនាជាមួយនាងអាសាទេវធីតា ទើបពោលគាថាបន្តថា

នាងជាអ្វី មានចង្កូមស ពាក់កុណ្ឌល មានគ្រឿងប្រដាប់ដើម
ដៃដ៏វិចិត្រ ទ្រទ្រង់គ្រឿងប្រដាប់មាសដ៏រលើងស្អាត ស្លៀក

ដណ្តប់សំពត់ មានពណ៌ដូចទន្ទេទឹកដែលគេស្រោចចុះ សៀត
ត្រួយឈើមានពណ៌ក្រហម ដូចភ្លើងឆេះស្បូវ ល្អរុងរឿង ។
នាងដូចមេម្រឹគដែលព្រានព្រៃបាញ់ខុសហើយ ក៏ភ្ញាក់ផ្អើល
ក្រឡេកមើលភ្លៀកៗ ដូច្នោះ ម្នាលនាងមានភ្នែកស្រទន់
បុគ្គលណាជាគម្រប់ពីរ នឹងនាងក្នុងទីនេះ នាងតែម្នាក់ឯងនៅ
ក្នុងព្រៃធំមិនខ្លាចទេឬ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចិត្តង្គទា** បានដល់ ប្រកបដោយអវយវៈដ៏វិចិត្រ ។ បទថា **កម្ពុវិមដ្ឋធារិនី** បានដល់ ទ្រទ្រង់នូវគ្រឿងអលង្ការមាសដ៏រលោងដែលធ្វើសម្រេចបរិបូរណ៍ ។ បទថា **ឱសិត្តវណ្ណំ** បានដល់ ស្លៀកដណ្តប់ទុកូលពស្ត្រដែលជាទិព្វ មានពណ៌ដូចផ្ការទឹកដែលហូរចុះ ។ បទថា **បរិធយ្ហ** បានដល់ ស្លៀកហើយផង ដណ្តប់ហើយផង ។ បទថា **កុសគ្គិរត្តំ** បានដល់ មានពណ៌ក្រហមដូចអណ្តាតភ្លើងដែលកំពុងឆេះស្បូវភ្លាំង ។ បទថា **អបិឡយ្ហ មញ្ជរី** អធិប្បាយថា ប្រដាប់ដោយសំណុំផ្កា ដូចជាផ្កាអសោកជាដើម ត្រង់ត្រចៀកទាំងសងខាង ។ បទថា **សរចាបធារិនា** បានដល់ នាយព្រាន ។ បទថា **វិរាធិតា** បានដល់ បាញ់ខុស ។ បទថា **មន្ទមិវ** បានដល់ ម្រឹគនោះផ្អើលហើយ ទើបឈរក្នុងចន្លោះព្រៃ សម្លឹងមើលព្រានភ្លៀកៗ យ៉ាងណា នាងក៏សម្លឹងមើលអាត្មាយ៉ាងនោះដូចគ្នា ។

ក្នុងលំដាប់នោះ ទើបនាងអាសាឆ្លើយថា

បពិត្រកោសិយតាបស ក្នុងទីនេះ មិនមានបុគ្គលជាគម្រប់ពីរ

នឹងខ្ញុំទេ ខ្ញុំជាទេវតាឈ្មោះអាសា កើតក្នុងភពតាវត្តិង្ស មក
កាន់សំណាក់លោកដោយ ( សេចក្តីប៉ុនប៉ង ) នូវសុធាភោជន
បពិត្រលោកអ្នកមានប្រាជ្ញាដ៏ប្រសើរ ព្រោះហេតុនោះ សូម
លោកចែកនូវសុធាភោជនដល់ខ្ញុំ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មសក្កសារប្បភវម្ហិ** សេចក្តីថា ជាអ្នកកើតព្រមហើយក្នុងតាវត្តិង្សពិភព ។

កោសិយតាបសស្តាប់ពាក្យនោះ កាលនឹងសម្តែងថា នាងឲ្យនូវការសង្ឃឹម ដោយការសម្រេចផលនៃការសង្ឃឹម ដល់បុគ្គលដែលនាងគាប់ចិត្ត មិនឲ្យដល់បុគ្គលដែលនាងមិនគាប់ចិត្តឡើយ សេចក្តីវិនាសនៃការប្រាថ្នា មិនមានដល់នាងជានិច្ច ហើយបានពោលគាថានេះថា

ពួកពាណិជ អ្នកស្វែងរកទ្រព្យ ឡើងសំពៅទៅក្នុងសមុទ្រ
ព្រោះសេចក្តីប្រាថ្នា ពាណិជទាំងនោះ ជួនកាលលិចចុះក្នុង
សមុទ្រនោះ ជួនកាលសាបសូន្យចាកទ្រព្យបាត់ទាំងដើមទុន ។
ពួកកសិករបានកសិស្រែទាំងឡាយ ព្រោះនូវពូជទាំងឡាយ ធ្វើ
( កិច្ចនោះៗ ) ដោយឧបាយ ក៏មិនបាននូវផលិតផលបន្តិច
បន្តួច អំពីសន្ទូងនោះ ដោយសេចក្តីអន្តរាយ ឬគ្មានភ្លៀង
ព្រោះតែសេចក្តីប្រាថ្នា ។ ពួកជនអ្នកស្វែងរកសេចក្តីសុខ បាន
ធ្វើនូវសេចក្តីប្រាថ្នាជាប្រធាន ទើបធ្វើនូវសេចក្តីព្យាយាមក្នុង
ទីយុទ្ធភូមិដើម្បីម្ចាស់ ជនទាំងនោះធ្វើនូវប្រយោជន៍ដល់ម្ចាស់

ត្រូវពួកបច្ចាមិត្ត បៀតបៀនយ៉ាងខ្លាំង មិនបានទូវឥស្សរិយ យសនោះតិចតួច ក៏រត់ទៅកាន់ទិសទាំងឡាយ ។ ពួកជនអ្នកចង់ទៅកាន់ឋានសួគ៌ ស្វែងរកសេចក្តីសុខ ក៏លះបង់នូវស្រូវទ្រព្យនិងពួកញាតិ ហើយដុតកម្តៅនូវតបៈដ៏សៅហ្មងអស់កាលយូរអង្វែង តែបែរជាឡើងកាន់ផ្លូវខុស ត្រឡប់ទៅកាន់ទុគ្គតិព្រោះតែសេចក្តីប្រាថ្នា ។ នៃនាងអាសា នាងឯងដែលឈ្មោះថា អាសា គេសន្មតថា ជាស្រីបោកប្រាស់នូវជនទាំងនេះ ( ហេតុនោះ ) នាងចូរបន្ទោបង់នូវសុធាភោជន ចំពោះខ្លួនឯងចុះ ស្រីប្រហែលនាង មិនគួរទទួលអាសនៈនិងទឹកទេ សុធាភោជននឹងមានអំពីណា នាងចូរទៅចុះ អាត្មាមិនពេញចិត្តនឹងនាងទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បរេន្តិ** បានដល់ ចេញសំពៅទៅ ។ បទថា **ឯនាធនា** បានដល់ ទ្រព្យសូន្យទៅហើយ កោសិយតាបស ពោលថា ជនពួកមួយរមែងឆ្អែតដោយអំណាចរបស់នាង និងជនមួយពួកទៀត ក៏នឹងវិនាសដោយអំណាចរបស់នាង ដោយប្រការដូច្នេះ ព្រោះហេតុនោះ បុគ្គលមានធម៌ដ៏លាមកដូចនាងមិនមានឡើយ ។ បទថា **ករោន្តុបាយសោ** បានដល់ រមែងធ្វើកិច្ចនោះៗ ដោយឧបាយ ។ បទថា **ឡ្ហតីនិចានេន** បានដល់ ព្រោះអន្តរាយដែលកើតអំពីសមុទ្ទទាំងឡាយ មានធាតុមិនស្មើគ្នា ដូចជាសត្វទាំងឡាយ មានពួកកណ្តុរ កណ្តូប ជ្រូក និងសត្វល្អិតផ្សេងៗ រោគក្រាសជាដើម ឯណានី

មួយ ។ បទថា **តតោ** កោសិយតាបសពោលថា អ្នកស្រែទាំងនោះ រមែងមិនជួបនូវផលណាមួយអំពីសម្លូងនោះ នាងម្នាក់ឯង រមែងធ្វើកម្ម គឺកាត់នូវសេចក្តីសង្ឃឹមរបស់អ្នកស្រែទាំងនោះ ។ បទថា **អជត្តកាភានិ** បានដល់ ធ្វើនូវសេចក្តីព្យាយាម របស់បុរសក្នុងយុទ្ធភូមិទាំងឡាយ ។ បទថា **អាសំ បុរក្ខត្វា** បានដល់ ធ្វើនូវការសង្ឃឹមដែលជាធំខាងមុខ ។ បទថា **ភត្តុរត្ថា** បានដល់ ដើម្បីសេចក្តីត្រូវការរបស់ចៅហ្វាយ ។ បទថា **អតិតាធ្មិតា** បានដល់ ត្រូវសត្រូវទាំងឡាយបៀតបៀនហើយ មានសម្បត្តិត្រូវដណ្តើមហើយ មានសេនានិងពាហនៈត្រូវកម្ចាត់ហើយ ។ បទថា **បឩស្សន្តិ** បានដល់ រមែងគេចទៅ ។ បទថា **អលទ្ធ កិញ្ចា ធំ** បានដល់ មិនបាននូវភាពជាធំ កោសិយតាបសពោលថា នាងម្នាក់ឯង រមែងធ្វើឲ្យជនទាំងនេះ មិនបាននូវភាពជាធំដោយប្រការដូច្នេះ ។ បទថា **សគ្គាធិមនា** បានដល់ ជាបុគ្គលប្រាថ្នាទៅកាន់ស្ថានសួគ៌ ។ បទថា **ល្វំ** សំដៅយកសេចក្តីលំបាកកាយ មានសេចក្តីព្យាយាម ៥ យ៉ាងដែលមិននាំប្រយោជន៍មកឲ្យ ។ បទថា **ចិរត្តាំ** បានដល់ អស់កាលយូរក្រៃលែង ។ បទថា **អាសា វិសំវាទិកសម្មតា ឥមេ** អធិប្បាយថា សត្វទាំងនោះ រមែងទៅកាន់ទុគ្គតិ ដោយអាការៈយ៉ាងនេះ ព្រោះហេតុនោះ នាងមានឈ្មោះថា អាសា ជាអ្នកដែលគេសន្មតហើយថា ជាអ្នកពោលឲ្យឃ្លៀងឃ្លាតចាកការពិត គឺដល់នូវការរាប់ថា ជាអ្នកពោលឲ្យឃ្លៀងឃ្លាតចាកការពិត កោសិយតាបស រមែងហៅទេពធីតានោះថា នៃនាងអាសា ដូច្នេះ ។

នាងអាសានោះ កាលកោសិយតាបសឃាត់ហើយ ក៏អន្តរធានទៅ ។

លំដាប់នោះ កោសិយតាបស កាលនឹងចរចាជាមួយនាងសទ្ធា ទើបពោលគាថានេះថា

នាងជាស្រីមានយស រុងរឿងដោយយស ជាធំក្នុងទិស គេ
ហៅដោយឈ្មោះថោកទាប ម្នាលនាងមានរាងកាយដូចរូប
ប្រៀប ជាវិការនៃមាស អាត្មាសួរនាង នាងចូរប្រាប់ដល់
អាត្មា នាងជាទេវតាឈ្មោះអ្វី ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧឡារវណ្ណា** បានដល់ រុងរឿង ។ បទថា **និយញ្ញនាមទ្ធយនំ** អធិប្បាយថា ត្រូវហៅដោយឈ្មោះដែលគួរខ្ពើមគឺលាមកយ៉ាងនេះថា ទិសដទៃៗ ( មិនមានសេចក្ដីសំខាន់ ) ខ្វះ ទិសក្រោយខ្វះ ។ បទថា **ទិសំបតិ** បានដល់ នាងឈររុងរឿង ។

លំដាប់នោះ នាងសទ្ធាក៏ពោលគាថានេះថា

ខ្ញុំជានាងទេវីឈ្មោះសទ្ធា ដែលគេបូជាក្នុងពួកមនុស្ស មិន
សេពគប់នូវសត្វដ៏លាមក សព្វកាល មកកាន់សំណាក់លោក
ដោយការឈ្លោះក្រកែក ព្រោះសុធាភោជន បពិត្រលោក
អ្នកមានប្រាជ្ញាដ៏ប្រសើរ ព្រោះហេតុនោះ សូមលោកចែក
រំលែកនូវសុធាភោជនដល់ខ្ញុំ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សទ្ធា** បានដល់ ការជឿតាមពាក្យរបស់បុគ្គលណាមួយ មានទោសក៏មាន មិនមានទោសក៏មាន ។ បទថា **បូជិតា** បានដល់ បូជាហើយ ដោយអំណាចនៃចំណែកដែលមិនមានទោស ។ បទថា **អចាប–**

**សទ្ធបណិសេវិណីសធា** អធិប្បាយថា ជាអ្នកមានសទ្ធាមិនមានទោស ពិតហើយ ពាក្យថា **សទ្ធា** នេះ ជាឈ្មោះរបស់ទេវតាដែលអាចតាក់តែងចាត់ចែងក្នុងបុគ្គលដទៃមានការចាត់ចែងដោយចំណែកមួយជាសភាវៈ ។

លំដាប់នោះ កោសិយតាបសក៏ពោលនឹងនាងសទ្ធានោះថា

ជួនកាល មនុស្សទាំងឡាយ ពឹងផ្អែកលើសទ្ធា ទើបធ្វើនូវទាន នូវការទូន្មានឥន្ទ្រិយ នូវការបរិច្ចាគ និងការសង្រួមក៏មាន មនុស្សពួកខ្លះ ដែលឃ្លាតអំពីនាង ( សទ្ធា ) វិញ ក៏ធ្វើនូវការលួច កុហក បន្លំ និងញុះញង់ក៏មាន ។ បុរសអ្នកប្រាជ្ញក្នុងកិរិយាទាំងឡាយ ដែលមានគុណសម្បត្តិស្មើគ្នា ជាស្រីបរិបូណ៌ដោយសីល មានវត្តចំពោះប្តី តែលះបង់នូវសេចក្តីប្រាថ្នាក្នុងពួកស្រីដែលមានត្រកូលល្អ ហើយធ្វើនូវការជឿចំពោះកុម្ភទាសីវិញក៏មាន ។ ម្នាលនាងសទ្ធា នាងឯងគប់រកនូវប្រពន្ធរបស់ជនដទៃហើយ ធ្វើនូវអំពើដ៏លាមក លះបោលនូវកុសល ស្រីប្រហែលនាង មិនគួរទទួលនូវអាសនៈនិងទឹកទេ សុធាភោជនទឹងមានអំពីណា នាងចូរទៅចុះ អាត្មាមិនពេញចិត្តនឹងនាងទេ ដូច្នេះ ។

តាបសនោះ ពោលនឹងទេពធីតាឈ្មោះសទ្ធានោះថា សត្វទាំងនេះជឿនូវពាក្យរបស់អ្នកណាមួយហើយ រមែងធ្វើកម្មនោះៗ ជនទាំងនោះរមែងធ្វើកម្មដែលមិនសមគួរ និងធ្វើច្រើនជាងកម្មដែលគួរធ្វើនោះទៅទៀត កម្មទាំងអស់

រមែងឈ្មោះថា ជាកម្មដែលនាងប្រើឲ្យគេធ្វើគ្រប់យ៉ាង ដូច្នេះហើយ ពោលទុកដោយបំណងយ៉ាងនេះ ។

បណ្ដាបទទាំងនោះ បទថា **ទានំ** បានដល់ ការឲ្យដែលប្រកបដោយចេតនាមានវត្ថុ ១០ ប្រការ ។ បទថា **ទមំ** បានដល់ ការទូន្មានឥន្ទ្រិយ ។ បទថា **ចាគំ** បានដល់ ការបរិច្ចាគទេយ្យធម៌ ។ បទថា **សំយមំ** បានដល់ សីល ។ បទថា **អាទាយ សទ្ទាយ** អធិប្បាយថា កាន់យកហើយ ក៏រមែងធ្វើតាមពាក្យរបស់បុគ្គលដែលពោលថា ការឲ្យទានជាដើមនេះ មានអានិសង្សច្រើន នាងគប្បីធ្វើចុះ ដូច្នេះ ព្រោះការជឿ ។ បទថា **ក្រូដំ** សេចក្ដីថា មនុស្សទាំងឡាយ រមែងធ្វើនូវកម្ម មានការបន្ទំដោយជញ្ជីងជាដើម ឬកម្ម មានការបោកប្រាស់អ្នកស្រុកជាដើម ។ បទថា **ករោន្តិ ហេកេ** អធិប្បាយថា ឯមនុស្សមួយពួកជឿពាក្យរបស់ជនពួកខ្លះថា នាងគប្បីធ្វើចោរកម្មជាដើម ដើម្បីប្រយោជន៍ដល់មនុស្សទាំងនោះផង ទាំងនេះផង ក្នុងកាលទាំងឡាយបែបនេះ ដូច្នេះហើយ ធ្វើនូវកម្មទាំងនេះ ។ បទថា **បុន វិចុតា តយា** អធិប្បាយថា ជនដទៃត្រូវនាងពន្រ៉ាត់ចេញហើយចាកសទ្ធាដើម មិនជឿពាក្យរបស់បុគ្គលដែលពោលថា កម្មទាំងនេះពេញទៅដោយទោស មានទុក្ខជាផល នាងមិនគួរធ្វើ ដូច្នេះ ក៏នៅតែចចេសធ្វើកម្មនោះ ព្រោះហេតុនោះ កម្មដែលបុគ្គលធ្វើដោយអំណាចរបស់នាងនោះ មានទោសក៏មាន មិនមានទោសក៏មាន ។ បទថា **សទិសីសុ** បានដល់ ជាអ្នកស្មើគ្នាដោយជាតិ គោត្តនិងសីលជាដើម ។ បទថា **បេក្ខវា** អធិប្បាយថា តណ្ហា លោកហៅថា **បេក្ខវា** ជាអ្នកមានការសម្លឹង

គឺនៅមានតណ្ហា ។ បទថា **ឆន្ទំ** បានដល់ ធ្វើនូវតម្រេកដោយអំណាចនៃការពេញចិត្ត គឺជាអ្នកមានចិត្តស្រឡាញ់ហើយ ។ បទថា **ករោតិ សទ្ធំ** បានដល់ រមែងធ្វើនូវការជឿស្តាប់តាមពាក្យរបស់កុម្ភទាសី ពិតហើយ កាលកុម្ភទាសីនោះពោលថា ខ្ញុំនឹងធ្វើឧបការៈឈ្មោះនេះដល់លោក ដូច្នេះ បុរសនោះជឿហើយ ក៏លះបង់ស្រីដែលមានត្រកូល ( ភរិយា ) ត្រឡប់មករួមបរិភោគជាមួយទាសីនោះឯង ម្យ៉ាងទៀត បុរសធ្វើនូវការជឿតាមពាក្យរបស់នាងកុម្ភទាសីថា ស្រីមានឈ្មោះនោះ មានចិត្តស្រឡាញ់ចំពោះលោក ដូច្នេះហើយ រមែងសេពកិរិយារបស់អ្នកដទៃ ។ បទថា **តុមេវ សទ្ធេ បរធារសេវិនិ** អធិប្បាយថា ព្រោះជនទាំងឡាយជឿពាក្យនោះៗ ទើបសេពប្រពន្ធអ្នកដទៃ ធ្វើនូវបាបកម្ម លះបង់នូវកុសលចោល ព្រោះអំណាចរបស់នាង ព្រោះដូច្នោះ ខ្ញុំនូននាងនោះឯងឈ្មោះថា ជាអ្នកសេពនូវកិរិយារបស់អ្នកដទៃ នាងរមែងធ្វើបាបកម្មទាំងឡាយ រមែងលះបង់នូវកុសល បុគ្គលដែលមានធម៌ដ៏លាមក ជាអ្នកធ្វើលោកឲ្យវិនាសដូចនាងមិនមានឡើយ ចូរនាងទៅចុះ នាងមិនគាប់ចិត្តយើងឡើយ ។ នាងសទ្ធានោះ ក៏បានអន្តរធានទៅក្នុងទីនោះឯង ឯកោសិយតាបសកាលចរចាជាមួយនាងហិរី ដែលឈរក្នុងទិសខាងជើង ទើបពោលគាថា ២ ថា

ទិសខាងកើតឯណា មានសម្បុររូបដ៏ឧត្តម ប្រាកដច្បាស់ក្នុង
វេលាអរុណរះឡើង ក្នុងទីបំផុតនៃរាត្រី ម្នាលនាងទេវធីតា
នាងប្រាកដច្បាស់ដល់អាត្មា ដូចជាទិសខាងកើតនោះដែរ នាង

ចូរប្រាប់អាត្មា នាងជាស្រីអប្សរអ្វី ។ នាងឈ្មោះអ្វី ដូចជា
វល្លិ៍ប្រេងដែលត្រូវខ្យល់ មានរបៀបនៃស្លឹកដ៏ក្រហមក្នុង
និទាឃរដូវ ឬដូចជាអណ្តាតភ្លើង ពុំនោះសោត ដូចម្រឹគស្មាវ
កាលក្រឡេកមើលនាង ហាក់ដូចជាមានប្រាថ្នានឹងនិយាយតែ
មិនបញ្ចេញនូវវាចាទៅវិញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆិយញ្ញារត្តិ** បានដល់ ទីបំផុតនៃរាត្រី អធិប្បាយថា កាលជាទីបំផុតនៃរាត្រី ។ បទថា "**ហរេ** បានដល់ កាលអរុណរះឡើងហើយ ។ បទថា **យា** អធិប្បាយថា ទេពធីតាណា ជាអ្នកទ្រទ្រង់ទុកនូវរូបដ៏ស្អាត ព្រោះមានពណ៌ដូចមាសប្រាកដនៅទិសបូព៌កណ្តាលរាត្រី ។ បទថា **កាឡា និទាឃេវិវ** បានដល់ ហាក់បីដូចវល្លិប្រេង ក្នុងសម័យនៃរដូវក្តៅដូច្នោះ ។ បទថា **អគ្គិជាវិវ** បានដល់ ដូចអណ្តាតភ្លើង សូម្បីទេពធីតានោះឈរដូចវល្លិប្រេងដែលដុះឡើងថ្មីៗ មានពណ៌ក្រហមល្អ ក្នុងស្រែដែលភ្លើងឆេះហើយថ្មី ៗ ។ បទថា **លោហិតបត្តមាលិនី** បានដល់ មានស្លឹកឈើផ្សេងៗ ដែលមានពណ៌ក្រហមចោមរោម ។ បទថា **កា តិដ្ឋសិ** អធិប្បាយថា វល្លិប្រេងខ្ចីនោះ ត្រូវខ្យល់បក់ហើយ រេរាំទៅមក តាំងនៅដោយល្អដោយប្រការណា នាងមានឈ្មោះដូចម្តេច ទើបមកឈរដោយប្រការនោះ ។ បទថា **ភាសេសមានាវ** បានដល់ នាងហាក់ដូចជាប្រាថ្នានិយាយនឹងយើង តែនិយាយមិនចេញ ។

លំដាប់នោះ នាងហិរីទេពធីតាក៏ពោលគាថាដូច្នេះថា

ខ្ញុំជានាងទេវីឈ្មោះហិរី ដែលគេបូជាក្នុងពួកមនុស្ស ជាស្រី
មិនសេពគប់នូវសត្វដ៏លាមកសព្វៗកាល មកកាន់សំណាក់
លោក ដោយការឈ្មោះប្រកែកព្រោះសុធាភោជន តែខ្ញុំនោះ
មិនអាចនឹងសូមនូវសុធាភោជនទេ ធម្មតាការសូមគេនៃស្រី
ដូចជាការបើកបង្ហាញកេរ្តិ៍ខ្មាស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ហិរាហ** បានដល់ ខ្ញុំឈ្មោះហិរី ។ បទថា **សុធំបិ** សេចក្តីថា ខ្ញុំមិនអាចសូមសុធាភោជនជាមួយលោក ។ ព្រោះហេតុអ្វី អធិប្បាយថា ព្រោះការសូមរបស់ពួកស្រីជារបស់គួរខ្មាស ដូចគ្នានិងការបើកបង្ហាញកេរ្តិ៍ខ្មាស និងជាការប្រាសចាកហិរិ ។ កោសិយតាបស បានស្តាប់ពាក្យនោះ ទើបបានពោលគាថា ២ ថា

ម្នាលនាងមានរាងកាយល្អ នាងនឹងបាន ( នូវសុធាភោជន )
តាមសភាពតាមហេតុ នេះពិតជាធម៌ហើយ ដ្បិតថា សុធា
ភោជន គេមិនបានព្រោះការសូមទេ ព្រោះហេតុនោះ អាត្មា
នឹងអញ្ជើញនាងដែលមិនសូម នាងប្រាថ្នានូវសុធាភោជន
ណាៗ អាត្មានឹងឲ្យនូវសុធាភោជននោះៗ ដល់នាង ។ ម្នាល
នាងមានរាងកាយដូចរូបប្រៀបជាវិការៈនៃមាស នាងនោះ
អាត្មានឹងអញ្ជើញទៅក្នុងអាស្រមរបស់អាត្មា ក្នុងថ្ងៃនេះ នាង
ជាស្រីគួរអាត្មាបូជា ដោយវត្ថុមានរសគ្រប់យ៉ាង អាត្មាលុះ
បូជានាងហើយ ទើបនឹងបរិភោគនូវសុធាភោជនដែរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឆម្ទេន** បានដល់ តាមសភាវៈ ។ បទថា **ញាយេន** បានដល់ តាមហេតុ ។ បទថា **ន ហិ យាចនា សុធា** អធិប្បាយថា សុធាភោជននេះ នាងមិនបានព្រោះការសូមឡើយ ទេពធីតាទាំង ៣ ក្រៅអំពីនេះ មិនបានហើយ ព្រោះហេតុនោះឯង ។ បទថា **តំ តំ** បានដល់ ព្រោះហេតុនោះ យើងគប្បីអញ្ជើញនាង ។ បទថា **យញ្ចិច្ឆសិ** បានដល់ យើងមិនបានអញ្ជើញនាងតែម្យ៉ាងប៉ុណ្ណោះទេ នាងប្រាថ្នាសុធាភោជនណា យើងនឹងឲ្យសុធាភោជននោះដល់នាង ។ បទថា **កញ្ចនវេល្លិវិគ្គហោ** បានដល់ នាងមានសរីរៈពេញដោយសិរីដូចគំនរនៃមាស ។ បទថា **បូជិតា** បានដល់ យើងមិនបានបូជានាង ដោយសុធាភោជនតែម្យ៉ាងប៉ុណ្ណោះទេ នាងជាបុគ្គលសមគួរ ដែលយើងគួរបូជាដោយសេសពូយ៉ាងដទៃទៀតផង ។ បទថា **អស្មិយេ** បានដល់ បូជានាងហើយ ចំណែកដ៏សេសនៃសុធាភោជននឹងមាន យើងនឹងបរិភោគចំណែកដែលសល់នោះ ។

ព្រះសាស្ដា កាលប្រកាសសេចក្ដីនោះ ទើបត្រាស់ថា

នាងហិរីនោះ ជាស្រីមិនសេពគប់នូវសត្វលាមកសព្វៗ កាល
ដែលកោសិយតាបសមានអានុភាពដ៏រុងរឿង អនុញ្ញាតហើយ
ក៏ចូលទៅកាន់អាស្រមជាទីរីករាយ ជាអាស្រមមានទឹក មាន
ផ្លែឈើ ដែលពួកអរិយជនបូជាហើយ ។ ជិតអាស្រមនោះ
មានព្រៃឈើ ស៊ុមទ្រុមដ៏ច្រើន មានផ្កាវីកហើយ ដើមស្វាយ
ដើមទ្រយឹង ដើមខ្នុរ ដើមចារ ដើមម្រុម ដើមលោទ ដើមក្ងោ

កន្ទ្រែប ដើមលំពេក ដើមចន្ទន៍ ដើមត្រមូច មានផ្ការីកហើយ ។ ជិតអាស្រមនោះ មានដើមឈើច្រើន គឺដើមរាំង ដើមថ្វាន់ ដើមព្រីង ដើមពោធិ៍ប្បាយ ដើមជ្រៃ ដើមស្រគំ មានមែកទោរទន់ចុះ និងដើមរាជព្រឹក្ស ដើមប្រទៀង ដើមជ្រៃពួរ ដើមរាំងអន្ទក់និងដើមរំពេក មានក្លិនផ្សព្វផ្សាយគួរគាប់ចិត្ត ។ ជិតអាស្រមនោះ មានអបរណ្ណជាតិ អំពៅខ្មៅ សណ្តែកព្រៃដើមទន្ទាប់ ស្រងែ និងគែលលក សណ្តែករាជមាស ពេកមានគ្រាប់នឹងស្រូវស ស្រូវក្រហមជាច្រើន ផ្លែចេញជាអង្ករគួរបរិភោគបាន ។ នៅខាងជើងនៃទីអាស្រមនោះ មានជាតិស្រះបោក្ខរណីដ៏ក្សេម មិនមានវត្ថុអាក្រក់ មានកំពង់មិនចោទ ជាស្រះដ៏ស្អាត ប្រកបដោយទឹក មានក្លិនមិនគួរខ្ពើម ។ ក្នុងស្រះនោះ មានពួកត្រីត្រេកត្រអាល ជាសត្វមានសេចក្តីក្សេម មានគ្រឿងបរិភោគដ៏ច្រើន គឺត្រីផ្ទក់ ត្រីខ្ទីង ត្រីក្រាយ បន្តង ត្រីឆ្ពិន ត្រីស្លាត និងត្រីអ្កែក ក៏ហែបហែលទៅមកដេរដាស ។ ក្នុងស្រះនោះ មានពួកសត្វស្លាបត្រេកត្រអាល ជាសត្វមានសេចក្តីក្សេម មានគ្រឿងបរិភោគដ៏ច្រើន គឺហង្ស ក្រៀល ក្ងោក ចាកក្រពាក អក តាវៅ ក្ងោកមាស ទោម ព្រហីតដ៏ច្រើន ។ មានពួកសត្វ គឺហ្វូងនៃម្រឹគផ្សេងៗ ជាច្រើន គឺសីហៈ ខ្លាធំ ខ្លាឃ្មុំ ឆ្កែព្រៃ ខ្លារខិន រមាស គោព្រៃ

ក្របី រមាំង ប្រើស ទ្រាយ ជ្រូកព្រៃ ក្តាន់ និងជ្រូកស្រុក មកប្រជុំគ្នាក្បែរស្រះនោះ ។ មានឈូស ធ្លា ទន្សាយ និងទីងជាច្រើន ផែនដីនិងភ្នំ ពេញពាសដោយផ្កាដ៏វិចិត្រ កងរំពងដោយសំឡេងនៃសត្វបក្សី មានហ្វូងបក្សី គប់រកជានិច្ចក្បែរស្រះនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ជុតិមតា** បានដល់ ជាអ្នកដល់ព្រមហើយដោយអានុភាព ។ បទថា **ចារិសិយស្សមំ** បានដល់ អញ្ជើញឲ្យចូលទៅកាន់អាស្រមបទ ។ **យ** អក្ខរៈ ជាព្យញ្ជនៈសន្ធិ ។ បទថា **ឧទកវន្តំ** បានដល់ សម្បូរដោយទឹកក្នុងទីនោះៗ ។ បទថា **ផលំ** បានដល់ សម្បូរដោយផ្លែឈើជាច្រើន ។ បទថា **អរិយបូជិតំ** បានដល់ ដែលព្រះអរិយៈទាំងឡាយ ជាអ្នកមានប្រក្រតីបានឈាន ជាអ្នកវៀរចាកទោស គឺនីវរណៈ បូជាហើយ គឺសរសើរហើយ ។ បទថា **រុក្ខគ្គហាណា** បានដល់ ពួកឈើដែលកំពុងចេញនូវផ្កាផ្លែ ។ បទថា **សោភញ្ជនា** បានដល់ ដើមម្រុម ។ បទថា **លោទ្ទមថោបិបទ្មកា** បានដល់ ដើមលោទផង ដើមក្លោកក្អែបផង ។ បទថា **កេតកា ច ភង្គា** បានដល់ ដើមឈើដែលមានឈ្មោះយ៉ាងនោះឯង ។ បទថា **ករេរី** បានដល់ ដើមថ្ងាន់នោះឯង ។ បទថា **ឧទ្ទាលកា** បានដល់ ដើមរាជព្រឹក្ស ។ បទថា **មុចលិន្ទកេតកា** បានដល់ ដើមរាំងអន្ទក់និងដើមរំចេក ៥ ប្រភេទ ។ បទថា **ហរេណុកា** បានដល់ អបរណ្ណជាតិមួយប្រភេទ ។ បទថា **វេលុកា** បានដល់ អំពៅខ្មៅ ។ បទថា **វេណុ** បានដល់ សណ្តែករាជមាសព្រៃ ។ បទ

ថា **តិណ្ឌុកា** បានដល់ ដើមទន្លាប់ ។ បទថា **ចីរកា** បានដល់ សណ្តែករាជមាសតូច ។ ចំណែកចេកគ្រាប់លោកហៅថា **មោចា** ។ បទថា **សាលិយោ** បានដល់ ស្រូវសាលីច្រើនប្រភេទ ដែលអាស្រ័យជាតស្រះកើតហើយ មានប្រការផ្សេងៗ ។ បទថា **បរីហាយោ** បានដល់ ស្រូវខ្សាយច្រើនប្រភេទ ។ បទថា **អាភុជិនោ** បានដល់ ដើមសម៉ ។ បទថា **តណ្ឌុលា** សំដៅដល់ ក្តួរអង្ករ ដែលកើតឯង មិនមានកន្ទក់និងអង្កាម ។ បទថា **តស្ស ច** បានដល់ ម្នាលភិក្ខុទាំងឡាយ ក្នុងចំណែកនៃទិសឧត្តរនៃអាស្រមនោះ ។ បទថា **ពោក្ខ-រណី** បានដល់ ស្រះបោក្ខរណីដែលកើតឯង ដេរដាសទៅដោយផ្កាឈូក ៥ ប្រភេទ ។ បទថា **អកក្កសា** បានដល់ រៀវចាករបស់ស្មោកគ្រោក មានប្រមាត់ត្រីនិងសារាយជាដើម ។ បទថា **អបត្ថារា** បានដល់ មានកំពង់រាបស្មើ មានច្រាំងមិនចោទ ។ បទថា **អប្បដិគន្ធិកា** បានដល់ ប្រកបដោយទឹកមានក្លិនដែលមិនគួរខ្ពើម គឺមានក្លិនក្រអូប ។ បទថា **តត្ថ** បានដល់ ក្នុងស្រះបោក្ខរណីនោះ ។ បទថា **ខេមិនោ** បានដល់ មិនមានភ័យ ។ បទថា **សិង្គុ** នេះ ជាឈ្មោះរបស់ត្រីប្រភេទនោះ ( ត្រីផ្ទក់ ) ។ បទថា **កុណា-លកា** បានដល់ ពួកសត្វតាវៅ ។ បទថា **ចិត្រា** បានដល់ មានរោមស្វាងដ៏ស្អាត ។ បទថា **សិខណ្ឌី** បានដល់ ក្ងោកដែលមានសិរតាំងឡើង ឬបក្សីដទៃដែលមានសិរដុះលើក្បាល ។ បទថា **ចាណា សមាយន្តិ** បានដល់ ពួកសត្វដែលមានជីវិតទាំងឡាយនាំគ្នាមក ។ បទថា **បលសទា** បានដល់ ពួករមាសផ្សេងៗ ។ បទថា **គវជា** បានដល់ ពួកគោព្រៃទាំងឡាយ ។ បទថា

**គណភិនោ** បានដល់ រមាស ។ បទថា **កណ្ណិកា** បានដល់ ម្រឹគដែលមានស្នែងស្រួច គឺសត្វខ្ទីង ។ បទថា **ជមាតីរ** បានដល់ ឈើផ្ការំងថ្មដែលមានផ្ការបស្មើដេរជាសជោយផ្កាដ៏វិចិត្រ ។ បទថា **ធិជាភិឃុដ្ឋា** បានដល់ ទឹកដីនិងភ្នំក្នុងទីនោះ មានសភាពបែបនេះ ដែលពួកបក្សីទាំងឡាយ យំអឺងកងហើយ ។

ព្រះសាស្តា ទ្រង់បានពណ៌នាអាស្រមរបស់កោសិយតាបសយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់បំណាងនឹងសម្តែងអាការៈដែលនាងហិរីចូលទៅក្នុងអាស្រមនោះ ទើបត្រាស់ថា

នាងហិរីនោះ មានស្បែកដ៏ល្អ គោងដើមឈើមានពណ៌ដ៏ខៀវ បានចូលទៅ ( កាន់អាស្រម ) ហាក់ដូចជាផ្ទេកបន្ទោររបស់មហាមេឃ កោសិយតាបសបានរៀបចំកៅអី ដែលមានបណ្តាញប្រទាក់គ្នាដ៏ល្អ ជាវិការនៃស្បូវក្លាំងដ៏ស្អាត មានក្លិនដ៏ល្អ ពាសដោយស្បែកខ្លាឃ្មុំ បម្រុងនាងហិរីនោះ បានពោលពាក្យនេះនឹងនាងហិរីថា ម្នាលនាងមានលម្អ នាងចូរអង្គុយឲ្យស្រួលចុះ នេះអាសនៈ ។ កាលដែលនាងហិរីនោះ ឋិតនៅលើកៅអី ប្រាថ្នានូវសុធាភោជនណា គ្រានោះ កោសិយតាបស អ្នកទ្រទ្រង់នូវផ្នួងសក់ដ៏រុងរឿង ជាមហាមុនី ប្រញាប់ប្រញាល់ បាននាំមកនូវសុធាភោជនោះ ព្រមទាំងទឹកដោយស្លឹកឈូកថ្មីៗ ដោយខ្លួនឯង ។ នាងហិរីនោះ មានចិត្តត្រេក

អរ បានទទួលនូវសុធាភោជននោះ ដោយដៃទាំងពីរ ហើយ ពោលនឹងកោសិយតាបស អ្នកទ្រទ្រង់នូវផ្នួងសក់ ដូច្នេះថា បពិត្រព្រហ្ម ឥឡូវនេះ ខ្ញុំដែលលោកបូជាហើយ ជាបុគ្គល មានជ័យជម្នះ សូមទៅកាន់ភពត្រៃត្រិង្សវិញ ។ នាងហិរីនោះ ដែលកោសិយតាបសមានអានុភាពដ៏រុងរឿង បានអនុញ្ញាត ហើយជាស្រីស្រវឹង ដោយការស្រវឹងនឹងវណ្ណៈ ក៏ទៅក្នុង សំណាក់ព្រះឥន្ទ្រ ជាសហស្សចក្ខុ រួចក្រាបទូលថា បពិត្រ ព្រះវាសវៈ នេះជាសុធាភោជន សូមព្រះអង្គទ្រង់ប្រទាននូវ ជ័យជម្នះដល់ខ្ញុំ ។ នាងហិរីនោះ ដែលពួកទេវតានិងមនុស្ស ផ្គងអញ្ជលីបូជាហើយ ក៏ចូលទៅអង្គុយលើកៅអីដ៏ថ្មីក្នុង កាលណា ព្រះឥន្ទ្រព្រមទាំងពួកទេវតា ក៏បូជានាងហិរីនោះ ជាទេវធីតាដ៏ឧត្តមក្នុងកាលនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុត្តចា** បានដល់ មានពណ៌សម្បុរល្អ ។ បទថា **នីលទុមាភិលម្ពិតា** បានដល់ គោងនូវដើមឈើពណ៌ខៀវ ស្ទាប អង្អែលនូវមែកឈើពណ៌ខៀវនោះៗ ។ បទថា **មហាមេឃវិវា** បានដល់ នាងហិរីទេពធីតានោះ ដែលកោសិយតាបសនោះអញ្ជើញហើយ ទើបដើរចូល ទៅកាន់អាស្រមរបស់លោក ដូចផ្លេកបន្ទោរក្នុងរវាងមហាមេឃ ដូច្នោះ ។ បទថា **តស្សា** បានដល់ របស់នាងហិរីទេពធីតានោះ ។ បទថា **សុសម្ពន្ធសិរំ** បានដល់ មានក្បាលចងទុកល្អហើយ ។ បទថា **កុសាមយំ** បានដល់ សម្រេច

ដោយស្បូវភ្លាំងលាយដោយឫសស្បូវភ្លាំងជាដើម ។ បទថា **សុគន្ធំ** បានដល់ មានក្លិនក្រអូប ព្រោះលាយដោយឫសស្បូវភ្លាំងនិងស្មៅដែលមានក្លិនក្រអូបដទៃ ។ បទថា **អជិនូបសេវិតំ** បានដល់ ប្រើស្បែកខ្លាឃ្មុំក្រាលខាងលើ ។ បទថា **អត្រិច្ឆកោច្ឆំ** បានដល់ ក្រាលកៅអីបែបនោះត្រង់ទ្វារបណ្ណសាលា ។ បទថា **សុខយិធមាសនំ** បានដល់ សូមនាងអង្គុយលើអាសនៈនេះ តាមសប្បាយចុះ ។ បទថា **យទិច្ឆមានាយ** បានដល់ ដល់នាងដែលប្រាថ្នានូវសុធាភោជនល្អមដែលត្រូវការ ។ បទថា **ឆវេហិ បត្តេហិ** បានដល់ ដោយស្លឹកឈូកដែលស្រស់ ដែលនាំមកអំពីស្រះបោក្ខរណី ក្នុងខណៈនោះឯង ។ បទថា **សយំ** បានដល់ ដោយដៃរបស់ខ្លួនឯង ។ បទថា **សហូធកំ** បានដល់ ប្រកបដោយទក្ខិណោទក ។ បទថា **សុធាភិហាសី** បានដល់ នាំសុធាភោជនមកចំពោះហើយ ។ បទថា **តុរិតោ** បានដល់ ប្រញាប់នាំមកដោយកម្លាំងសោមនស្ស ។ បទថា **ហន្ទ** នេះ ជានិបាត ប្រើក្នុងអត្ថជាឧបសគ្គ ។ បទថា **ជិតាវិនី** បានដល់ ជាអ្នកដល់ហើយនូវជ័យជម្នះ ។ បទថា **អនុមតា** បានដល់ អនុញ្ញាតហើយថា ចូរនាងទៅតាមគាប់ចិត្តក្នុងឥឡូវនេះចុះ ។ បទថា **ឧទីរិតា** សេចក្ដីថា នាងហិរីនោះ ត្រឡប់ទៅកាន់ត្រៃត្រិង្សបុរី ហើយពោលក្នុងសម្នាក់របស់សក្កៈថា នេះសុធាភោជន ។ បទថា **សុរកញ្ញំ** បានដល់ នាងទេពធីតា ។ បទថា **ឧត្តមំ** បានដល់ ប្រសើរឧត្តម ។ បទថា **សា បញ្ជលី ទេវមនុស្សបូជិតា** បានដល់ ជាបុគ្គលដែលទេវតាទាំងឡាយផង មនុស្សទាំងឡាយផងបូជាហើយ ដោយលើកដៃប្រណម្យ ។ បទថា **យធា** បានដល់

នាងចូលទៅកាន់កៅអី ពោលគឺតាំងមាសថ្មីដែលសក្កៈប្រទានហើយ ដើម្បីប្រយោជន៍ដល់ការអង្គុយ ក្នុងកាលណា ក្នុងកាលនោះ សក្កទេវរាជនិងទេវតាដ៏សេសក៏នាំគ្នាបូជានាង ដែលអង្គុយលើតាំងនោះដោយផ្កាបារិច្ឆត្តកៈ ជាដើម ។

សក្កទេវរាជ កាលបូជាយ៉ាងនោះហើយ ទើបទ្រង់ព្រះតម្រិះថា ព្រោះហេតុអ្វីហ្ន៎ ទើបកោសិយៈមិនឲ្យដល់ទេពធីតាដ៏សេស បានឲ្យសុធាភោជនដល់នាងហិរីតែម្នាក់ ទើបលោកបញ្ជូនមាតលីទេវសារថីទៅម្តងទៀត ដើម្បីដឹងដល់ហេតុនោះ ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

សហស្សនេត្ត ជាធំជាងពួកទេវតាជាន់ត្រៃត្រិង្ស ទ្រង់បានត្រាស់នឹងមាតលិទេវបុត្តនោះម្តងទៀតថា អ្នកចូរទៅសួរកោសិយតាបស តាមពាក្យរបស់យើងថា បពិត្រកោសិយៈ នាងហិរីដទៃអំពីនាងអាសា នាងសទ្ធា នាងសិរី បានទទួលសុធាភោជនដោយហេតុអ្វី ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អសំសិ** បានដល់ បានត្រាស់ទុកហើយ ។ បទថា **វាក្យំ មម** បានដល់ អ្នកចូរពោលនូវពាក្យរបស់យើងនឹងកោសិយតាបសនោះ ។ បទថា **អាសាយ សទ្ធាយ សិរិយា ច** សេចក្តីថា វៀរចាកនាងអាសា នាងសទ្ធា នាងសិរីហើយ នាងហិរីតែម្នាក់ប៉ុណ្ណោះ បានទទួលសុធាភោជនហើយ ព្រោះហេតុអ្វី ។

មាតលិទេវសារថីនោះ ទទួលពាក្យរបស់សក្កៈនោះហើយ ក៏បានឡើងវេជយន្តរថចេញទៅ ។ ព្រះសាស្តាកាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

មាតលិទេវបុត្ត បានឡើងជិះរថនោះ អណ្តែតទៅដោយស្រួល ដ៏រុងរឿងប្រហែលនឹងគ្រឿងឧបករណ៍ មានចន្ទោលជាវិការៈនៃមាសជម្ពូនទ ភ្លឺដូចជាអណ្តាតភ្លើង ដែលបុញ្ញឫទ្ធិប្រដាប់ស្រស់ល្អ ប្រកបដោយកម្រាលជាវិការៈនៃមាស វិចិត្រដោយកែវ ៧ ប្រការ ។ ក្នុងរថនុ៎ះមានរូបព្រះចន្ទជាវិការៈនៃមាស រូបដំរី គោ សេះ កិន្នរ ខ្លាធំ ខ្លាដំបង ទ្រាយ ជាច្រើនក្នុងរថនោះ មានរូបបក្សីជាវិការៈនៃកែវផ្សេងៗ ក្នុងរថនោះ មានទាំងរូបម្រឹគប្រកបដោយហ្វូង ជាវិការៈនៃកែវពៃទូរ្យក្នុងរថនោះ ។ ពួកទេវតាបានទឹមនូវស្តេចសេះ មានសម្បុរលឿង ១០០០ ក្នុងរថនោះ ជាសេះមានសម្បុរដូចមាសប្រហែលនឹងដំរីស្ទាវ ប្រដាប់ដោយគ្រឿងអលង្ការ មានគ្រឿងប្រដាប់ទ្រូងជាវិការៈនៃបណ្តាញមាស មានគ្រឿងប្រដាប់ពាក់ត្រចៀកស្ទុះទៅដោយគ្រាន់តែឮសំឡេង ជាសេះមានសន្ទុះដ៏លឿន ។ មាតលិទេវបុត្ត បានឡើងជិះរថនោះ ជាយានដ៏ប្រសើរ ហើយញុំាងទិសទាំង ១០ នេះ ឲ្យគឹកកងរំពង ទាំងញុំាងអាកាស ភ្នំ ឈើម្ចាស់ព្រៃ សាគរនិងផែនដីឲ្យរំភើបញាប់ញ័រ ។ មាត

លិទេវបុត្តនោះ ចូលទៅកាន់អាស្រមជាធាប់ ពានាសំពត់ទិព្វជាស្រេច រួចផ្គងអញ្ជលី ពោលទៅនឹងកោសិយតាបស ជាទេវព្រាហ្មណ៍ ដែលជាពហុស្សូត ជាអ្នកចម្រើនដោយគុណ មានអាចរិយវត្តទូន្មានហើយ ដូច្នេះថា បពិត្រកោសិយៈ សូមលោកស្ដាប់ពាក្យព្រះឥន្ទ ខ្ញុំឯងជាទូតព្រះឥន្ទ សូមសួរលោកថា បពិត្រកោសិយៈ ចុះនាងហិរីដទៃអំពីនាងអាសា នាងសទ្ធានិងនាងសិរី តើបាននូវសុធាភោជនដោយហេតុអ្វី ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តំ សុប្បវត្តំ** សេចក្ដីថា មាតលិឡើងរថយន្តរថនោះ បរចេញទៅតាមសប្បាយ ។ បទថា **ឧទតារយី** បានដល់ ឡើងកាន់រថនោះ ធ្វើនូវការត្រៀមនឹងហោះទៅ ។ បទថា **ឧបក្រិយសាធិសំ** បានដល់ ដូចគ្នានឹងកណ្ឌៈគ្រឿងឧបករណ៍ទាំងឡាយ អធិប្បាយថា រថនេះរុងរឿងដូចគ្រឿងឧបករណ៍ដែលមានពណ៌ស្មើដោយអណ្ដាតភ្លើង របស់មាតលិនោះរុងរឿងប្រាកដដូច្នោះ ។ បទថា **ជម្ពោនធីសំ** បានដល់ មានចន្ទោលរថសម្រេចដោយមាស មានពណ៌ក្រហម ពោលគឺមាសជម្ពូនទៈ ។ បទថា **កញ្ចន–ចិត្តសន្និភំ** បានដល់ ប្រកបដោយកម្រាលដែលជាមង្គលវិចិត្រដោយរតនៈ ៧ ប្រការ សម្រេចដោយមាស ។ បទថា **សុវណ្ណា ចន្ទេត្ថ** បានដល់ រូបព្រះចន្ទដែលសម្រេចដោយមាសមាននៅក្នុងរថនោះ ។ បទថា **ហត្ថី** បានដល់ រូបដំរីដែលសម្រេចដោយមាស សម្រេចដោយប្រាក់និងសម្រេចដោយ

កែវមណី សូម្បីក្នុងពាក្យថា **គវ** ( គោ ) ជាដើម ក៏មានន័យនេះដូចគ្នា ។ បទថា **លង្ឃមយេត្ត បក្ខិណោ** បានដល់ សូម្បីហ្វូងបក្សីដែលសម្រេចដោយរតនៈផ្សេងៗ ហាក់ដូចកំពុងលោតលេងក្នុងរថនោះតាមលំដាប់នោះឯង ។ បទថា **យុថាយុតា** បានដល់ ប្រកបហើយជាហ្វូងរបស់ខ្លួន បង្ហាញខ្លួនទុកហើយ ។ បទថា **អស្សរាជហរិយោ** បានដល់ ស្តេចសេះអស្សរាជមនោមយដែលមានពណ៌ដូចមាស ។ បទថា **សុសុនាគសាទិសេ** បានដល់ ដូចគ្នានឹងដំរីជំទង់ដែលដល់ព្រមដោយកម្លាំង ។ បទថា **កញ្ចនជាលុរច្ឆទេ** បានដល់ ប្រកបដោយគ្រឿងអលង្ការត្រង់ទ្រូង ដែលធ្វើដោយបណ្តាញមាស ។ បទថា **អាវេឡិនេ** បានដល់ ប្រកបដោយគ្រឿងប្រដាប់ត្រចៀក ពោលគឺកម្រងកុណ្ឌល ។ បទថា **សទ្ទគមេ** បានដល់ មានការរត់ទៅជាប្រក្រតីដោយអាការត្រឹមតែសំឡេងប៉ុណ្ណោះ ប្រាសចាកការប្រហារដោយជន្ទួញ ។ បទថា **អសង្គិតេ** បានដល់ ពួកទេវបុត្តទឹមសេះអស្សតរបែបនេះ ទើបមិនមានការរារាំង ស្ទុះទៅដោយសម្ទុះដ៏រហ័សក្នុងរថនោះហើយ ។ បទថា **អភិធានយិត្ត** បានដល់ មាតលិបានធ្វើនូវការបន្ទឺដែលដូចគ្នានឹងសំឡេងយាន ។ បទថា **វនប្បតិ-ធិញ្ញ** បានដល់ ជាម្ចាស់នៃព្រៃ ។ បទថា **បព្យតយិត្ត** បានដល់ ឲ្យនូវការញាប់ញ័រទូទៅ បណ្ឌិតគប្បីជ្រាបការញាប់ញ័រ ដោយការញាប់ញ័រនៃវិមានដែលតាំងនៅក្នុងអាកាសនាកពតាវត្តិង្សនោះ ។ បទថា **ធាវារមេកំសកតោ** បានដល់ ធ្វើនូវសំពត់បាវាទិព្វឆៀងស្មាម្ខាង ។ បទថា **វុឌ្ឍំ** បានដល់ ចម្រើនដោយគុណ ។ បទថា **វិធីតវត្តំ** បានដល់ ប្រកបដោយវត្ត គឺមារយាទដែល

អប់រំទុកល្អហើយ ។ បទថា **ឥច្ចព្រវី** សេចក្តីថា មាតលិបញ្ឈប់រថនោះ ក្នុងអាកាស ហើយទើបចុះទៅពោលយ៉ាងនេះ ។ បទថា **ទេវព្រាហ្មណំ** បានដល់ជាព្រាហ្មណ៍ប្រសើរជាងទេវតាទាំងឡាយ ។

កោសិយតាបស បានស្តាប់ពាក្យមាតលិនោះហើយ ក៏បានពោលគាថានេះថា

ម្នាលមាតលិ ជាទេវសារថី នាងសិរី ប្រាកដដល់អាត្មាថា
ជាស្ត្រីស្តុកស្តម្ភស្រាប់ហើយ ចំណែកនាងសទ្ធាប្រាកដដល់
អាត្មាថាជាស្ត្រីមិនទៀង នាងអាសា ក៏ប្រាកដដល់អាត្មា
ថាជាស្ត្រីដែលគេសន្មតថា ជាស្រីបោកប្រាស់ នាងហិរីតាំង
នៅស៊ប់ក្នុងគុណដ៏ប្រសើរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អទ្ធា** មានពាក្យអធិប្បាយថា នាងសិរីធ្លើយនឹងយើងថា នៃ ( អទ្ធា ) ព្រោះគប់រកជនដែលដល់ព្រមហើយដោយសិល្បសាស្ត្រជាដើមខ្លះ ជនដែលប្រាសចាកគុណបែបនោះខ្លះ ។ បទថា **សទ្ធា អនិច្ចា** បានដល់ ចំណែកនាងសទ្ធាធ្លើយនឹងយើងថា មិនទៀង ដោយអាការៈដែលមានហើយ ត្រឡប់ជាមិនមាន ព្រោះបុគ្គលលះបង់វត្ថុនោះៗហើយទើបទៅកើតឡើងក្នុងទីដទៃ ។ បទថា **អាសា វិសំវាទិកសម្មតា** បានដល់ ចំណែកនាងអាសាពោលនឹងយើងថា ពួកជនដែលមានសេចក្តីត្រូវការដោយទ្រព្យ ចេញសំពៅទៅកាន់មហាសមុទ្ទ លុះខាតដើមអស់ហើយ ក៏ត្រឡប់ ព្រោះហេតុនោះ ទើបឈ្មោះថា ជាអ្នកពោលឲ្យខុស ។ បទថា **អរិយម្ហិ គុណោ**

ចំណែកនាងហិរី ជាអ្នកតាំងនៅក្នុងគុណដ៏បរិសុទ្ធនិងក្នុងគុណដ៏ប្រសើរ ពោលគឺជាបុគ្គលដែលមានហិរិនិងឱត្តប្បៈជាប្រក្រតី ។

កោសិយតាបស ពណ៌នាគុណរបស់នាងហិរីនោះ ក្នុងកាលឥឡូវនេះ ទើបពោលគាថាដូច្នេះថា

ពួកនាងកុមារីណា ដែលត្រកូលរក្សាហើយក្តី ពួកស្ត្រីចាស់ៗ ( ស្ត្រីមេម៉ាយ ) ណាក្តី ពួកស្ត្រីណាដែលមានប្តីក្តី ស្ត្រីទាំងនោះ ( ដឹងច្បាស់ ) នូវឆន្ទរាគដែលកើតឡើងក្នុងពួកបុរស ហើយរារាំងនូវចិត្តរបស់ខ្លួនដោយហិរិ ។ កាលជនទាំងឡាយបរាជ័យក្នុងប្រធាននៃសង្គ្រាម ដែលប្រកបដោយព្រួញ និងលំពែងសុះរត់ទៅ ជនទាំងនោះបានលះបង់នូវជីវិត ក៏ត្រឡប់វិលវិញដោយហិរិ មានចិត្តប្រកបដោយហិរិ ទទួលយក ( ម្ចាស់ ) វិញ ។ ច្រាំងជាគ្រឿងរារាំងនូវកម្លាំងនៃរលកទឹកក្នុងសមុទ្រយ៉ាងណា ហិរិនេះ ក៏ឃាត់នូវជនចាកបាប យ៉ាងនោះដែរ ម្នាលទេវសារថី ព្រោះហេតុនោះ អ្នកចូរក្រាបទូលព្រះឥន្ទថា ហិរិនោះ ត្រូវអរិយជនបូជាហើយក្នុងលោកទាំងពួង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ជិណ្ណា** សំដៅដល់ ស្រីមេម៉ាយ ។ បទថា **សភត្តុ** សំដៅដល់ ស្រីក្មេងដែលមានប្តី ។ បទថា **អត្តនោ** បានដល់ ស្រីទាំងអស់នោះ ដឹងនូវតម្រេកដោយអំណាចនៃការពេញចិត្តរបស់ខ្លួនកើតឡើង

ហើយក្នុងបុរេសដទៃ ក៏ឃាត់នូវចិត្តរបស់ខ្លួនបាន គឺមិនធ្វើកម្មដ៏លាមក ព្រោះខ្មាសថា កម្មនេះមិនសមគួរដល់អញ ។ បទថា **បតតំ បលាយិនំ** បានដល់ក្នុងរវាងនៃបុគ្គលដែលជួលចុះផង គេចទៅផង ។ បទថា **ជហិត្វ ជីវិតំ** បានដល់ អ្នកចម្បាំងពួកណា រមែងជាអ្នកមានចិត្តខ្មាស រមែងលះបង់ជីវិតរបស់ខ្លួន ហើយត្រឡប់មកដោយការខ្មាស កាលត្រឡប់មកហើយយ៉ាងនេះ អ្នកចម្បាំងទាំងនោះ ទើបជាអ្នកមានចិត្តខ្មាស រមែងទទួលចៅហ្វាយរបស់ខ្លួនទៀត គឺជួយចៅហ្វាយនាយឲ្យផុតអំពីកណ្ដាប់ដៃរបស់សត្រូវ ហើយទទួលយកទៅ ។ បទថា **ចាបជនំ និវារណី** បានដល់ នាងហិរីនោះ ជាអ្នកមានប្រក្រតីហាមជនចេញអំពីបាប ម្យ៉ាងទៀត ព្រះបាលីក៏យ៉ាងនោះឯង ។ បទថា **តំ** សំដៅដល់ នាងហិរីនោះ ។ បទថា **អរិយបូជិតំ** បានដល់ ដែលលោកអ្នកដ៏ប្រសើរទាំងឡាយ មានព្រះពុទ្ធជាដើមបូជាហើយ ។ បទថា **ឥន្ទស្ស តំ វេទយ** បានដល់ ព្រោះនាងហិរីមានគុណច្រើន មានភេទដែលលោកអ្នកដ៏ប្រសើរបូជាហើយយ៉ាងនេះ ព្រោះហេតុនោះ ចូរអ្នកទៅប្រាប់ដល់ព្រះឥន្ទថា នាងហិរីនោះ មានភេទដ៏ប្រសើរយ៉ាងនេះ ។

មាតលិស្ដាប់ពាក្យនោះ ទើបពោលគាថានេះថា

បពិត្រកោសិយៈ បុគ្គលណាជាព្រហ្ម ឬព្រះឥន្ទ ឬបជាបតិ ប្រកាន់តាមសេចក្ដីយល់របស់លោកនេះថា ធីតារបស់ព្រះឥន្ទ ជាស្ត្រីស្វែងរកនូវគុណដ៏ប្រសើរ ដែលគេសន្មតថា ជាស្ត្រីប្រសើរបំផុតក្នុងពួកទេវតា ព្រោះតែហិរិ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ធិដ្ឋិ** បានដល់ នរណាហ្ន៎ យល់នូវទិដ្ឋិថា ឈ្មោះថា នាងហិរីនេះ ជាអ្នកមានគុណច្រើន ដែលលោកអ្នកប្រសើរ បូជាហើយ ។ បទថា **ឱធហិ** បានដល់ ឲ្យចូលទៅក្នុងហទយៈ ។ បទថា **សេដ្ឋ-សម្មតា** បានដល់ នាងហិរីនោះ ចាប់តាំងពីបានសុធាភោជន ក្នុងសម្នាក់របស់លោកហើយ ក៏បាននូវសេនាសនៈមាសក្នុងសម្នាក់ព្រះឥន្ទទៀត ជាបុគ្គលដែលទេវតាទាំងពួងបូជា រមែងបានទទួលសន្មតិថា ជាបុគ្គលដ៏ឧត្ដម ។

កាលមាតលិកំពុងពោលយ៉ាងនេះ ធម៌គឺការវិនាស ( សេចក្ដីស្លាប់ ) បានកើតឡើងហើយដល់កោសិយតាបសក្នុងខណៈនោះឯង ។ លំដាប់នោះ មាតលិក៏ពោលថា បពិត្រកោសិយៈ លោកដាក់អាយុសង្ខារបានហើយ ធម៌គឺចុតិក៏ដល់ព្រមដល់លោកហើយ លោកមានប្រយោជន៍អ្វីដោយមនុស្សលោក យើងនឹងទៅទេវលោកជាមួយគ្នាចុះ ជាអ្នកប្រាថ្នានាំកោសិយតាបសនោះ ទៅកាន់ទេវលោកនោះ ទើបពោលគាថាដូច្នេះថា

> បើដូចនោះ ឥឡូវនេះ សូមលោកមក សូមលោកទៅកាន់
> ឋានត្រៃត្រិង្ស សូមលោកឡើងជិះរថ ដែលជាទីគាប់ចិត្តនេះ
> បពិត្រលោកអ្នកមានគោត្ត ស្មើដោយព្រះឥន្ទ ព្រះឥន្ទទន្ទឹង
> លោក សូមលោកទៅនៅរួមជាមួយនឹងព្រះឥន្ទ ក្នុងថ្ងៃនេះ
> ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មមាយិតំ** បានដល់ ជាវត្ថុដែលគួរស្រឡាញ់ពេញចិត្ត ។ បទថា **ឥន្ទសគោត្ត** បានដល់ ជាអ្នកមានគោត្តស្មើជាមួយ

ព្រះឥន្ទក្នុងភពមុន ។ បទថា **កដ្ឋំតិ** បានដល់ ទាំងព្រះឥន្ទ ក៏ទ្រង់ប្រាថ្នាឲ្យលោកមក ។

កាលមាតលិនោះ កំពុងនិយាយជាមួយកោសិយតាបស ដោយប្រការដូច្នេះនោះឯង កោសិយតាបសក៏ចុតិចាកអត្តភាពនោះ កើតឡើងជាឧបបត្តិកទេវបុត្តលើទិព្វរថ លំដាប់នោះ មាតលិក៏នាំកោសិយទេវបុត្តទៅកាន់សម្នាក់សក្កទេវរាជ សក្កទេវរាជឃើញកោសិយទេវបុត្តមានព្រះហឫទ័យត្រេកអរបានព្រះទាននាងហិរីទេវី ដែលជាធីតារបស់ព្រះអង្គ ឲ្យជាអគ្គមហេសី ។ កោសិយទេវបុត្តនោះ មានឥស្សរិយយសច្រើនប្រមាណមិនបាន ។

ព្រះសាស្តាទ្រង់ជ្រាបសេចក្តីនោះ ទើបត្រាស់ថា ឈ្មោះថា កម្មរបស់សត្វដែលមានគុណមិនថោកថយ រមែងបរិសុទ្ធិបានដូច្នេះ ហើយទើបត្រាស់អវសានគាថាដូច្នេះថា

ពួកសត្វអ្នកមិនធ្វើនូវអំពើបាប រមែងបរិសុទ្ធិយ៉ាងនេះ មួយទៀត ផលនៃកុសលដែលបុគ្គលបានសន្សំល្អហើយ រមែងមិនសាបសូន្យទេ ពួកសត្វណាមួយ បានឃើញនូវសុធាភោជន ( ក្នុងកាលនោះ ) សត្វទាំងអស់នោះឯង រមែងដល់នូវការនៅរួមជាមួយនឹងព្រះឥន្ទ ។

ក្នុងគាថានោះ បទថា **អចាបកម្មិនោ** បានដល់ សត្វទាំងឡាយ ដែលមិនបានធ្វើកម្មលាមក រមែងបរិសុទ្ធិយ៉ាងនេះ ។ បទថា **យេកេចិ អទ្ទក្ខុំ** បានដល់ សត្វទាំងឡាយឯណាមួយ បានឃើញសុធាភោជន ដែលកោសិយតាបស

ឲ្យដល់នាងហិរីទេវធីតា ក្នុងហិមវន្តប្បទេស ក្នុងកាលនោះ ។ បទថា **សព្វេ តេ** សេចក្តីថា សត្វទាំងអស់នោះអនុមោទនាទាននោះហើយ ធ្វើនូវសេចក្តីជ្រះថ្លាក្នុងទាននោះហើយ ដល់នូវភាពជាសម្លាញ់របស់ព្រះឥន្ទ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន តថាគតក៏បានទូន្មានភិក្ខុដែលមិនត្រេកអរក្នុងការឲ្យទាន ជាអ្នកមានសេចក្តីកំណាញ់ហើយនេះដូចគ្នា ហើយទ្រង់ប្រជុំជាតកថា

នាងហិរីទេវធីតា គឺនាងឧប្បលវណ្ណាភិក្ខុនី កោសិយតាបស គឺភិក្ខុជាម្ចាស់ទាន បញ្ចសិខទេវបុត្ត គឺអនុរុទ្ធភិក្ខុ មាតលិទេវបុត្ត គឺអានន្ទ សុរិយទេវបុត្ត គឺកស្សបភិក្ខុ ចន្ទទេវបុត្ត គឺមោគ្គល្លាន នារទតាបស គឺសារីបុត្ត ឯព្រះវាសវៈ គឺតថាគតជាព្រះសម្ពុទ្ធ ។

## អដ្ឋកថាសុធាភោជនជាតក ចប់

# កុណាលជាតក

[ ២៩៦ ] ហេមវន្តប្រទេស ដែលគេតែងពោលយ៉ាងនេះ តែងឮយ៉ាងនេះ មានសេចក្តីដំណាលថា បក្សីកុណាល ( តាវៅ ) មានសម្បុរដ៏វិចិត្រក្រៃលែង មានស្លាបជាគ្រឿងបិទបាំងដ៏វិចិត្រក្រៃលែង តែងនៅអាស្រ័យក្នុងដងព្រៃជាទីរីករាយ មានសភាពយ៉ាងនេះ ជាប្រទេសទ្រទ្រង់នូវធរណីប្រកបដោយឱសថគ្រប់យ៉ាង រយោងរយានដោយចង្កោមផ្កាជាច្រើន ជាប្រទេស ជាទីចរទៅមករឿយៗនៃដំរី គោ ក្របី ប្រើសមាស ចាមរី ក្តាន់ រមាស ខ្ទីង សីហៈ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ឆ្កែព្រៃ ខ្លារខិន កេ ឈ្លូស ខ្លាត្រី ទន្សាយ រមាំង ជាទីអាស្រ័យនៅនៃហ្វូងដំរីតូចៗ និងដំរីធំ និងមេដំរី ក្នុងនាគត្រកូល ដ៏ដេរដាសជាទីអាស្រ័យនៅនៃខ្លាឃ្មុំ ស្វាសរភៈ ម្រឹគទ្រាយ ក្តាន់បុរិសាលុ ( យក្ខិនីមានមុខដូចសេះ ) កិន្នរ យក្ខ អារក្សទឹក ជាព្រៃដ៏ដេរដាសដោយពួកឈើជាច្រើនយ៉ាង គឺឈើមានផ្កាក្រពុំ ឈើមានត្រួយលាស់រហង់ សឹងដ៏ខ្ញៀវខ្ញារដោយហ្វូងបក្សីជាច្រើន គឺសត្វអក លលកទ្រាំង ហត្ថិលិង្គៈ ក្ងោក ទីទុយ ប៉ោលតោក ចាប កុកក្រក សម្បកត្រពាំង ករវិក ជាប្រទេសដ៏ប្រដាប់ដោយវត្ថុជាទីត្រេកអរច្រើនយ៉ាង គឺថ្មនោសិលាមានពណ៌ខៀវ ដូចផ្កាអញ្ជ័ន ជាតិហិង្គុល មាស ប្រាក់ មាសស្រួយ និងលោហធាតុជាច្រើនយ៉ាង ។ បក្សីតាវៅនោះឯង មានបក្សីញីចំនួន ៣៥០០ សុទ្ធតែបក្សីជំទង់ចាំបម្រើ ។ មានសេចក្តីដំណាលថា គ្រានោះ បក្សីញីជំទង់ពីរ ពាំមែកឈើដោយចំពុះ ឲ្យបក្សីតាវៅឈ្មោលនោះទំត្រង់កណ្តាលមែកឈើ ហើរឡើងទៅ ដោយគិតថា សូមកុំឲ្យមានសេចក្តីលំបាកក្នុងផ្លូវឆ្ងាយ បៀតបៀនបក្សីតាវៅឈ្មោលនោះ

ឡើយ ។ ពួកបក្សីបញ្ញាចំនួន ៥០០ ក៏ហើរពីខាងក្រោមៗ ដោយគិតថា បើបក្សីតាវ៉ៅនេះធ្លាក់ពីបន្គង យើងនឹងទទួលបក្សីតាវ៉ៅនោះដោយស្លាបទាំងឡាយ ។ ពួកបក្សីកញ្ញាចំនួន ៥០០ ហើរអំពីខាងលើៗ ដោយគិតថា សូមកុំឲ្យកម្ដៅក្ដៅដល់បក្សីតាវ៉ៅឈ្មោលនោះឡើយ ។ ពួកបក្សីកញ្ញាចំនួន ៥០០ ម្ខាងៗ ហើរអមអំពីខាងទាំងពីរ ដោយគិតថា សូមកុំឲ្យត្រជាក់ ក្ដៅ ស្មៅធូលីខ្យល់ ឬទឹកសន្សើមប៉ះពាល់ត្រូវបក្សីតាវ៉ៅឈ្មោលនោះឡើយ ។ ពួកបក្សីកញ្ញាចំនួន ៥០០ ហើរទៅអំពីខាងមុខៗ ដោយគិតថា សូមកុំឲ្យគង្វៀលគោ គង្វៀលសត្វចិញ្ចឹម អ្នកនាំស្មៅ អ្នកនាំឧស អ្នកធ្វើការងារក្នុងព្រៃប្រហារនូវបក្សីតាវ៉ៅឈ្មោលនោះដោយកំណាត់ឈើ ដោយអំបែង ដោយដៃ ( ដោយដុំថ្ម ) ដោយដុំដី ដោយដំបង ដោយសស្ត្រាវុធ ឬដោយដុំក្រួសទាំងឡាយឡើយ សូមកុំឲ្យបក្សីតាវ៉ៅនោះ ប៉ះទង្គិចនឹងគុម្ពឈើ វល្លិ៍ ដើមឈើ មែកឈើ សសរ ថ្មភ្នំ ឬពួកបក្សីមានកម្លាំងឡើយ ។ ពួកបក្សីកញ្ញាចំនួន ៥០០ ហើរអមអំពីខាងក្រោយៗ និយាយឆ្លើយឆ្លងគ្នា ដោយពាក្យស្រទន់ផ្អែផង់ពីរោះផ្អែមល្ហែម ដោយគិតថា សូមកុំឲ្យបក្សីតាវ៉ៅនេះ អផ្សុកនៅលើទ្រនំឡើយ ។ ពួកបក្សីកញ្ញាចំនួន ៥០០ ហើរទៅគ្រប់ទិស នាំយកផ្លែឈើផ្សេងៗ ចំឡែកជាច្រើន ដោយគិតថា សូមកុំឲ្យបក្សីតាវ៉ៅនេះ លំបាកដោយការស្រេកឃ្លានឡើយ ។ គ្រានោះ ពួកហ្វូងបក្សីកញ្ញាទាំងនោះ ហើរនាំបក្សីតាវ៉ៅនោះអំពីសួនច្បារទៅកាន់សួនច្បារ អំពីឧទ្យានទៅកាន់ឧទ្យាន អំពីកំពង់ស្ទឹងទៅកាន់កំពង់ស្ទឹង អំពីកំពូលភ្នំទៅកាន់កំពូលភ្នំ អំពីព្រៃស្វាយទៅកាន់ព្រៃស្វាយ

អំពីព្រៃព្រីងទៅកាន់ព្រៃព្រីង អំពីព្រៃខ្នុរសម្ងទៅកាន់ព្រៃខ្នុរសម្ង អំពីព្រៃដូងទៅកាន់ព្រៃដូង ដើម្បីសេចក្តីសប្បាយរីករាយ ដោយឆាប់រហ័ស ។ គ្រានោះឯង បក្សីតាវៅនោះ ដែលពួកបក្សីកញ្ញាទាំងនោះចោមរោមហើយ ពេញមួយថ្ងៃ ក៏បណ្តេញយ៉ាងនេះថា នែមេចង្រៃ ហងឯងទាំងឡាយ ចូរចៀសចេញទៅ នែមេចង្រៃ ជាចោរ ជាស្រីអ្នកលេង ហិនហោច មានចិត្តស្រាលមិនធ្វើតបចំពោះឧបការគុណដែលគេធ្វើហើយ ជាអ្នករហើរហោចក្នុងកាម ដូចជាខ្យល់ ហងឯងទាំងឡាយ ចូរវិនាសទៅ ។

[ ២៩៧ ] មានសេចក្តីដំណាលថា ក្នុងកាគទិសខាងកើតនៃស្តេចភ្នំហិមវន្តនោះឯង មានស្ទឹងហូរនាំយកនូវស្មៅខៀវខ្ចី អំពីភ្នំដែលមានទឹកដ៏ល្អសុខុមថាឈ្មោង ។ មានសេចក្តីដំណាលថា តាវៅសឈ្មោះបុណ្ណមុខៈ មានសំឡេងដ៏ពីរោះគ្រលួច មានភ្នែកក្រឡែត ដូចភ្នែកអ្នកស្រវឹង តែងអាស្រ័យនៅក្នុងដងព្រៃ ជាទីសប្បាយរីករាយ មានសភាពយ៉ាងនេះ គឺប្រទេសជាទីពេញចិត្តរីករាយដោយផ្កាឧប្បល ឈូកក្រហម កុមុទ ឈូកស ឈូកមានស្រទាប់ជាច្រើន ចន្លោះណីមានក្លិនក្រអូបឈ្ងុយឈ្ងប់ ទើបនឹងដុះឡើងថ្មីៗ ជាព្រៃដេរដាសដោយកុរវកព្រឹក្ស រាំងអន្ទក់ កេតកព្រឹក្ស វេទិសព្រឹក្ស ដើមជ្រៃ ដើមបុន្នាគ ពកុល ទ្រមួច ទ្រមូង ខ្ទម្ព ធ្នង់ រាំងភ្នំ ស្រឡៅ ចំបក់ អាសោកព្រឹក្ស ខ្នុង ស្មាច់ លោទ្ទ និងចន្ទន៍ក្រហម ជាព្រៃញាតស្បាតដោយដើមឈើខ្មៅ បិយង្គុ មានពណ៌ក្រហម ទេពទារូ ចេកមានគ្រាប់ជាព្រៃទ្រទ្រង់នូវដើមថ្ងាន់ ខ្ទឹងគង់ ព្រូស ម៉ែសាក់ កណិការ ដើមច្បារ ដើមប្រមោយ

ដរី ដើមរលួសផ្អុង ដើមចារ ដើមយុក្កា និងចង្កោមផ្កាម្ទិះព្រៃ ក្តាំងឆា ចម្បា ចំប៉ី នួនស្រី ជាព្រៃដ៏ដេរដាសដោយម្ទិះរួត ចេកទេស ប្រទៀង ដើមទ្រាំង ក្រស្នា ស្បូវក្លាំង និងគុម្ពឈើជាពួកៗ ជាប្រទេសដ៏ប្រដាប់ដោយឈើ ដ៏ដេរដាស គឺដើមរំដួល និងវល្លិ៍មានផ្កាដ៏ល្អ ជាព្រៃឮសូរសំរែមកនៃសត្វហង្ស ទុង ប្រវឹក ក្អែកទឹក ជាទីដែលពួកវិទ្យាធរសមណៈ និងតាបសឥសីស័ក្តិសិទ្ធនៅអាស្រ័យ ជាប្រទេសដែលនរជន ទេវតា យក្ខ អារក្សទឹក អសុរ គន្ធព្វ និងកិន្នរអាស្រ័យនៅជាច្រើន ។ មានសេចក្តីដំណាលថា សត្វតាវៅសឈ្មោះ បុណ្ណមុខៈនោះឯង មានបក្សីកញ្ញាចំនួន ៣៥០ ជាអ្នកបម្រើ ។ មានសេចក្តីដំណាលថា គ្រានោះឯង មានបក្សីកញ្ញាពីរ ពាំមែកឈើដោយមាត់ ហើយឲ្យសត្វតាវៅស ឈ្មោះបុណ្ណមុខៈនោះ ទំត្រង់កណ្តាល ហើរទៅដោយគិតថា កុំឲ្យមានសេចក្តីលំបាកក្នុងផ្លូវឆ្ងាយប៉ះពាល់តាវៅសឈ្មោះ បុណ្ណមុខៈនោះឡើយ ។ ពួកបក្សីកញ្ញាចំនួន ៥០ ក៏ហើរពីខាងក្រោមៗ ដោយគិតថា បើតាវៅសឈ្មោះបុណ្ណមុខៈនេះនឹងធ្លាក់អំពីបង្គង ពួកយើងនឹងទទួលតាវៅស នោះដោយស្លាបទាំងឡាយ ។ ពួកបក្សីកញ្ញាចំនួន ៥០ ក៏ហើរអំពីខាងលើ ៗ ដោយគិតថា សូមកុំឲ្យកម្តៅក្តៅដល់តាវៅសឈ្មោះបុណ្ណមុខៈនោះឡើយ ។ ពួកបក្សីកញ្ញាចំនួន ៥០ ( ម្ខាង ) ក៏ហើរអមអំពីខាងទាំងពីរ ដោយគិតថា សូមកុំឲ្យត្រជាក់ក្តៅស្មៅធូលីខ្យល់ ឬទឹកសន្សើម ប៉ះពាល់ត្រូវតាវៅស ឈ្មោះបុណ្ណមុខៈនោះឡើយ ។ ពួកបក្សីកញ្ញាចំនួន ៥០ ហើរទៅអំពីខាងមុខៗ ដោយគិតថា សូមកុំឲ្យគង្វៀលគោ គង្វៀលសត្វចិញ្ចឹម អ្នកនាំស្មៅ

អ្នកនាំឧស អ្នកធ្វើការងារក្នុងព្រៃ ប្រហារស្តេចសត្វតាវៅសឈ្មោះបុណ្ណមុខៈ នោះ ដោយកំណាត់ឈើ ដោយអំបែង ដោយដៃ ( ដោយដុំថ្ម ) ដោយដុំដី ដោយដំបង ដោយសស្ត្រាវុធ ដោយដុំក្រួសទាំងឡាយ សូមកុំឲ្យតាវៅសឈ្មោះបុណ្ណមុខៈនេះ ប៉ះទង្គិចនឹងគុម្ពឈើ វល្លិ ដើមឈើ មែកឈើ សសរ ដុំថ្មភ្នំ ឬក៏ពួកបក្សីមានកម្លាំងឡើយ ។ ពួកបក្សីកញ្ញាចំនួន ៥០ ហើរអំពីខាងក្រោយៗ និយាយឆ្លើយឆ្លងគ្នា ដោយពាក្យដ៏ស្រទន់ ផូរផង់ ពីរោះផ្អែមល្ហែម ដោយគិតថា សូមកុំឲ្យតាវៅសឈ្មោះ បុណ្ណមុខៈ អផ្សុកលើទ្រនំឡើយ ។ ពួកបក្សីកញ្ញាចំនួន ៥០ ហើរទៅគ្រប់ទិស នាំយកផ្លែឈើផ្សេងៗ ចំឡែកជាច្រើនយ៉ាង ដោយគិតថា សូមកុំឲ្យតាវៅសឈ្មោះបុណ្ណមុខៈនេះ លំបាកដោយការស្រេកឃ្លានឡើយ ។ គ្រានោះ ពួកហ្វូងបក្សីកញ្ញាទាំងនោះ ហើរនាំតាវៅសឈ្មោះបុណ្ណមុខៈអំពីសួនច្បារ ទៅកាន់សួនច្បារ អំពីឧទ្យាន ទៅកាន់ឧទ្យាន អំពីកំពង់ស្ទឹងទៅកាន់កំពុងស្ទឹង អំពីកំពូលភ្នំទៅកាន់កំពូលភ្នំ អំពីព្រៃស្វាយទៅកាន់ព្រៃស្វាយ អំពីព្រៃព្រីងទៅកាន់ព្រៃព្រីង អំពីព្រៃខ្នុរសម្លទៅកាន់ព្រៃខ្នុរសម្ល អំពីព្រៃដូងទៅកាន់ព្រៃដូង ដើម្បីសេចក្តីសប្បាយរីករាយដោយឆាប់រហ័ស ។ គ្រានោះឯង តាវៅសឈ្មោះបុណ្ណមុខៈដែលពួកបក្សីកញ្ញាទាំងនោះ បម្រើធូធរអស់ថ្ងៃមួយ សរសើរយ៉ាងនេះថា ម្នាលនាងទាំងឡាយប្រពៃណាស់ ៗ នាងទាំងឡាយបម្រើប្តីដោយហេតុណា ម្នាលនាងទាំងឡាយ ហេតុនោះឯង ជាកិច្ចដ៏សមគួរដល់នាងទាំងឡាយ ជាធីតាក្នុងត្រកូលហើយ ។

[ ២៩៨ ] គ្រានោះឯង តាវៅសឈ្មោះបុណ្ណមុខៈ ចូលទៅរកកុណាលសកុណៈ ( តាវៅខ្មៅ ) ។ បក្សីកញ្ញាជាអ្នកបម្រើកុណាលសកុណៈបានឃើញតាវៅសឈ្មោះបុណ្ណមុខៈនោះមកពីចម្ងាយ លុះឃើញហើយនាំគ្នាចូលទៅរកតាវៅសឈ្មោះ បុណ្ណមុខៈ លុះចូលទៅដល់ហើយ និយាយពាក្យនេះនឹងតាវៅសឈ្មោះ បុណ្ណមុខៈ នោះថា បពិត្របុណ្ណមុខៈសម្លាញ់ កុណាលសកុណៈនេះអាក្រក់ក្រៃលែង មានសំដីអាក្រក់ក្រៃលែង ពួកយើងសូមពឹងផ្អែកនូវលោក ក្រែងបានវាចាជាទីស្រឡាញ់ ( អំពីកុណាលៈ ) ។ តាវៅសឆ្លើយតបថា ឱប្អូនស្រីទាំងឡាយ យ៉ាងនោះឬ ហើយក៏ចូលទៅរកកុណាលសកុណៈ លុះចូលទៅដល់ហើយ ក៏និយាយសំណេះសំណាលជាមួយនឹងកុណាលសកុណៈ ហើយទំក្នុងទីដ៏សមគួរ ។ លុះតាវៅសឈ្មោះបុណ្ណមុខៈទំក្នុងទីដ៏សមគួរហើយ និយាយពាក្យនេះនឹងកុណាលសកុណៈនោះថា នែកុណាលសម្លាញ់ ហេតុអ្វី អ្នកប្រតិបត្តិខុសចំពោះតាវៅញី ដែលមានជាតិល្អ ជាធីតាក្នុងត្រកូល ជាអ្នកប្រតិបត្តិល្អ នែកុណាលៈសម្លាញ់ឮថាអ្នកគួរនិយាយសំដីជាទីពេញចិត្ត ទៅរកពួកតាវៅញី សូម្បីនិយាយសំដីមិនជាទីគាប់ចិត្ត នឹងបាច់និយាយថ្វីដល់ពួកតាវៅញី ជាសត្វនិយាយសំដីជាទីពេញចិត្ត ។ កាលបើតាវៅសនិយាយយ៉ាងនេះហើយ កុណាលសកុណៈក៏បណ្តេញតាវៅសឈ្មោះ បុណ្ណមុខៈ នោះថា នែសម្លាញ់ ជាសត្វអាក្រក់ចង្រៃ អ្នកចូរចៀសចេញ នែសម្លាញ់ជាសត្វអាក្រក់ចង្រៃ អ្នកចូរវិនាសទៅនរណាឡើយជាអ្នកឈ្លាសវៃជាងអ្នក ជាអ្នកចាញ់ស្រី ។ ចំណែកខាងតាវៅ

សេះឈ្មោះបុណ្ណមុខៈ ត្រូវកុណាលសកុណៈបណ្តេញយ៉ាងនេះហើយក៏ត្រឡប់មកពីទីនោះវិញ ។

[ ២៩៩ ] គ្រានោះឯង លុះសម័យខាងក្រោយមក កន្លងទៅមិនយូរប៉ុន្មាន តាវ៉ៅសេះឈ្មោះបុណ្ណមុខៈ មានជំងឺជាទម្ងន់ ។ មានវេទនាយ៉ាងខ្លាំង គឺរោគធ្លាក់ឈាម រៀបដល់នូវមរណៈ គ្រានោះ ពួកបក្សីកញ្ញា ជាអ្នកបម្រើតាវ៉ៅសេះឈ្មោះបុណ្ណមុខៈ មានសេចក្តីត្រិះរិះយ៉ាងនេះថា តាវ៉ៅសេះឈ្មោះបុណ្ណមុខៈនេះ មានជំងឺជាខ្លាំង ធ្វើដូចម្តេច លោកនឹងបានសះស្បើយចាកជំងឺនេះ ។ ពួកបក្សីកញ្ញាបោះបង់តាវ៉ៅសេះនោះ ឲ្យនៅតែម្នាក់ឯង មិនឲ្យមានគ្នា ជាគម្រប់ពីរ ហើយនាំគ្នាចូលទៅរកកុណាលសកុណៈ កុណាលសកុណៈនោះបានឃើញពួកបក្សីកញ្ញាទាំងនោះ កំពុងមកពីចម្ងាយ លុះឃើញហើយ និយាយពាក្យនេះនឹងពួកបក្សីកញ្ញានោះថា នែមេចង្រៃរាល់គ្នា ចុះប្តីរបស់ហាងឯងទៅក្នុងទីណា ។ ពួកបក្សីកញ្ញាទាំងនោះតបថា បពិត្រកុណាលៈជាម្ចាស់តាវ៉ៅសេះឈ្មោះបុណ្ណមុខៈ មានជំងឺជាខ្លាំង ធ្វើដូចម្តេច លោកនឹងបានសះស្បើយចាកជំងឺនោះ ។ កាលបើពួកបក្សីកញ្ញាឆ្លើយតបយ៉ាងនេះហើយ កុណាលសកុណៈ ក៏បណ្តេញពួកបក្សីកញ្ញាទាំងនោះយ៉ាងនេះថា នែពួកមេចង្រៃ ហាងឯងចូរចៀសចេញទៅ នែមេចង្រៃជាចោរ ជាស្រីអ្នកលេង ហិនហោច មានចិត្តស្រាល មិនធ្វើតបចំពោះឧបការគុណដែលគេធ្វើហើយ ជាអ្នករហើររហាចក្នុងកាម ដូចជាខ្យល់ ហាងឯងទាំងឡាយចូរវិនាសទៅ លុះពោលដូច្នេះហើយ ក៏ចូលទៅរកតាវ៉ៅសេះឈ្មោះបុណ្ណមុខៈ លុះចូលទៅដល់ហើយ ទើបនិយាយ

ពាក្យនេះនឹងតាវៅសឈ្មោះបុណ្ណមុខៈនោះថា នែបុណ្ណមុខៈសម្លាញ់ ម្តេចទៅហ៏ ។ តាវៅសឆ្លើយថា ឱ កុណាលៈសម្លាញ់ ។ គ្រានោះ កុណាលសកុណៈជួយគ្រាហ៍តាវៅស ឈ្មោះបុណ្ណមុខៈនោះ ដោយស្លាបទាំងឡាយផង ដោយចំពុះផង ហើយក្រោកឡើង ទើបឲ្យផឹកថ្នាំផ្សេងៗ ។ គ្រានោះ ជំងឺរបស់តាវៅសឈ្មោះបុណ្ណមុខៈនោះ ក៏ជាសះស្បើយ ។

[ ៣០០ ] គ្រានោះ កុណាលសកុណៈ បាននិយាយពាក្យនេះនឹងតាវៅសឈ្មោះបុណ្ណមុខៈដែលសះស្បើយចាកជំងឺ ដែលស្រាកស្រាន្តចាកភាពនៃខ្លួនជាអ្នកឈឺមិនយូរប៉ុន្មានថា នែបុណ្ណមុខៈសម្លាញ់ កុមារីឈ្មោះនាងកណ្ហាមានបិតាពីរ មានប្តី ៥ នាក់ ជាប់ជំពាក់ចិត្តក្នុងបុរសទី ៦ គឺក្នុងបុរសខ្វិនគម ( ដូចខ្មោចកំបុតក ) ក៏ខ្ញុំបានឃើញហើយ ។ ពាក្យក្នុងរឿងនោះមានដូចតទៅនេះ

ស្ត្រីប្រព្រឹត្តកន្លងប្តីទាំង ៥ នាក់នុ៎ះគឺ អជ្ជុនរាជកុមារ ១ នកុលរាជកុមារ ១ ភីមសេនរាជកុមារ ១ យុធិដ្ឋិលរាជកុមារ ១ សហទេវរាជកុមារ ១ ធ្វើនូវអំពើដ៏លាមក គឺសេពមេថុនធម្មជាមួយបុរសគមទាបតឿ ។

នែបុណ្ណមុខៈសម្លាញ់ នាងសមណីឈ្មោះបញ្ចបាវី កាលនៅកណ្តាលព្រៃស្មសាន រំលងចោលនូវបាយ ៤ ដង បានធ្វើនូវអំពើដ៏លាមក ជាមួយនឹងអ្នកលេងសុរា ខ្ញុំបានឃើញហើយ ។ នែបុណ្ណមុខៈសម្លាញ់ នាងទេវីឈ្មោះកាកវតី កាលនៅកណ្តាលសមុទ្ទ ជាភរិយារបស់វេនតេយ្យ បានធ្វើនូវអំពើដ៏លាមក ជាមួយនឹងបុរសឈ្មោះ នដកុវេរៈ ខ្ញុំក៏បានឃើញហើយ ។

នែបុណ្ណមុខៈសម្លាញ់ ព្រះអគ្គមហេសីមានព្រះលោមាល្អ ព្រះនាមកុរុង្គទេវី កាលចង់បានឯឡកកុមារ ធ្វើនូវអំពើដ៏លាមកជាមួយនឹងបុរសអ្នកនៅដោយទ្រព្យ ( បុរសខ្ញុំគេ ) ឈ្មោះធឡន្តកុមារ ខ្ញុំក៏បានឃើញហើយ ។ សេចក្តីពិត រឿងដូចគ្នានេះ ខ្ញុំដឹងហើយយ៉ាងនេះថា ព្រះវរមាតារបស់ព្រះបាទព្រហ្មទត្ត លះបង់ព្រះបាទកោសល ទៅធ្វើអំពើដ៏លាមកជាមួយនឹងព្រាហ្មណកុមារឈ្មោះបញ្ចាលចណ្ឌៈ ។

ពួកស្ត្រីទាំងនុ៎ះក្តី ពួកស្ត្រីឯទៀតក្តី បានធ្វើនូវអំពើដ៏លាមក ព្រោះហេតុនោះ ទើបខ្ញុំមិនទុកចិត្ត មិនសរសើរស្ត្រីទាំងឡាយទេ ពួកស្ត្រីដូចផែនដី ជាទីដើរទៅ ជាទីទ្រទ្រង់ មានសេចក្តីត្រេកអរស្មើជាទីតម្កល់ទុកនៃវត្ថុគ្រប់យ៉ាង អត់ធន់ចំពោះអារម្មណ៍ទាំងពួង មិនញាប់ញ័រ មិនកម្រើក នរជនមិនគប្បីទុកចិត្តស្ត្រីទាំងនោះទេ សីហៈជាម្រឹគសាហាវ ជាសត្វស៊ីឈាមនិងសាច់ មានអាវុធ ៥ សាហាវក្រៃលែង ត្រេកអរក្នុងការបៀតបៀនសត្វដទៃ កំហែង ខាំស៊ីយ៉ាងណាមិញ ពួកស្ត្រីទាំងនោះក៏ដូច្នោះដែរ នរជនមិនត្រូវទុកចិត្តឡើយ ។

នែបុណ្ណមុខៈសម្លាញ់ ស្រីទាំងឡាយមិនមែនឈ្មោះថាពេស្យា ថានារីថាជាទីគប់រកទេ ស្រីទាំងនុ៎ះ មិនមែនគ្រាន់តែឈ្មោះថា អ្នកកោងកាច អ្នកចងទុក ( នូវបុរស ) ទេ ស្រីទាំងនុ៎ះ គឺស្រីពេស្យា នារីជាទីគប់រក ឈ្មោះថា ស្រីសម្លាប់ ( ប្តី ) ។ ពួកស្រីស្អិតស្អាងផ្នួងសក់ ដូចចោរ ដូចគ្រឿងស្រវឹងដែលលាយដោយថ្នាំពិស បិទបាំងដោយវាចា ដូចពាណិជមានអាការៈប្រែប្រួល ដូចកុយរមាស មានអណ្តាតពីរ ដូចពស់ បិទបាំង ( នូវកាយ )

ដូចជាគេបិទបាំងរណ្ដៅ បំពេញបានដោយក្រដូចសមុទ្ទ ត្រេកអរបានដោយក្រដូចអារក្សទឹក នាំទៅដោយដាច់ខាតដូចយមបាល ស៊ីនូវវត្ថុគ្រប់ មុខដូចភ្លើង នាំយកនូវវត្ថុគ្រប់យ៉ាងដូចស្ទឹង ប្រព្រឹត្តរហើរហាចដូចខ្យល់ ធ្វើនូវវត្ថុមិនឲ្យប្លែកគ្នាដូចភ្នំនេរុ ផ្លែជានិច្ចដូចឈើមានពិសពុល ។ ពាក្យក្នុងរឿងនេះ មានតទៅទៀតថា

ពួកស្រីមានកលមាយាដូចចោរ មានពិសខ្លាំងដូចសុរា ដែលលាយថ្នាំពិស និយាយបិទបាំងទោសដូចពាណិជ្ជ មានអាការប្រែប្រួលដូចកុយរមាស មានអណ្ដាតពីរដូចពស់ ។ ពួកស្រីបិទបាំង ( នូវកាយ ) ដូចជាគេបិទបាំងរណ្ដៅ បំពេញបានដោយក្រដូចសមុទ្ទ ត្រេកអរបានដោយក្រដូចអារក្សទឹក នាំយកទៅដោយដាច់ខាតដូចយមបាល ។ ពួកស្រីដូចភ្លើង នាំយកនូវវត្ថុគ្រប់យ៉ាងដូចស្ទឹង មានអាការៈរហើរហាចក្នុងកាមដូចខ្យល់ មិនឲ្យមានប្លែកដូចភ្នំនេរុ មានផ្លែជានិច្ចដូចឈើមានពិសពុល ពួកស្រីតែងញុំាងភោគៈក្នុងផ្ទះឲ្យវិនាស ធ្វើសេចក្ដីអន្តរាយនូវរតនៈវត្ថុទាំងឡាយ ។

[ ៣០១ ] នៃបុណ្ណមុខៈសម្លាញ់ ទ្រព្យណា ដែលបុគ្គលមិនត្រូវឲ្យនៅក្នុងត្រកូលនៃជនដទៃ ទ្រព្យទាំងនេះមាន ៤ យ៉ាងគឺ គោឈ្មោល ១ មេគោ ១ យាន ១ ភរិយា ១ បណ្ឌិតមិនត្រូវញុំាងទ្រព្យទាំង ៤ យ៉ាងនេះឲ្យនៅប្រាសចាកផ្ទះឡើយ ។

បុគ្គលមិនគប្បីញុំាងគោឈ្មោល ១ គោញី ១ យាន ១ ភរិយា ១ ឲ្យនៅក្នុងត្រកូលញាតិទេ ( ព្រោះថា ) ពួកបុគ្គលមិនមានរទេះ រមែងប្រើ

ប្រាស់រទេះ បៀតបៀនទូវគោឈ្មោល ដោយការដឹកនាំហួសកម្លាំង បៀតបៀនមេគោដោយការរូតទឹកដោះ កិរិយារមែងប្រព្រឹត្តខូច ( ក្បត់ចិត្តប្តី ) ក្នុងត្រកូលនៃញាតិ ។

[ ៣០២ ] នែបុណ្ណមុខៈសម្លាញ់ វត្ថុ ៦ យ៉ាងនេះ រមែងមិនបានជាប្រយោជន៍ចំពោះកិច្ចការដែលកើតឡើងទេ ( វត្ថុ ៦ យ៉ាង ) គឺធ្នូគ្មានបន្ទោះ ១ កិរិយា ( ដែលនៅ ) ក្នុងត្រកូលញាតិ ១ ទូកនៅឯត្រើយម្ខាង ១ រទេះបាក់ភ្លៅ ១ មិត្តនៅក្នុងទីឆ្ងាយ ១ សម្លាញ់ដ៏លាមក ១ ( ទាំងនេះ ) រមែងមិនបានជាប្រយោជន៍ចំពោះកិច្ចការដែលកើតឡើងទេ ។

[ ៣០៣ ] នែបុណ្ណមុខៈសម្លាញ់ ស្រីរមែងមើលងាយប្តីដោយហេតុ ៨ យ៉ាងគឺ សេចក្តីទ័លក្រ ១ សេចក្តីឈឺចាប់ជានិច្ច ១ សេចក្តីចាស់គ្រាំគ្រា ១ ភាពជាអ្នកលេងផឹកស្រា ១ ភាពល្ងង់ខ្លៅ ១ សេចក្តីធ្វេសប្រហែស ១ ការមិនប្រព្រឹត្តធ្វើរឿយៗ ក្នុងកិច្ចការទាំងពួង ១ ការមិនញុំាំងទ្រព្យសម្បត្តិគ្រប់យ៉ាងឲ្យកើតមាន ១ នែបុណ្ណមុខៈសម្លាញ់ ស្រីរមែងមើលងាយប្តីដោយហេតុ ៨ យ៉ាងនេះឯង ។ ពាក្យក្នុងរឿងនេះ មានតទៅទៀត

ស្រីមើលងាយប្តី ( ដោយហេតុ ៨ យ៉ាង ) គឺប្តីទ័លក្រ ១ ប្តីឈឺជានិច្ច ១ ប្តីចាស់គ្រាំគ្រា ១ ប្តីជាអ្នកលេងផឹកស្រា ១ ប្តីធ្វេសប្រហែស ១ ប្តីដល់នូវភាពល្ងង់ខ្លៅ ១ ប្តីខ្ជិលច្រអូសក្នុងកិច្ចការ ១ ប្តីញុំាំងសេចក្តីប្រាថ្នាក្នុងវត្ថុដែលគួរប្រាថ្នាគ្រប់យ៉ាងឲ្យវិនាស ១ ។

[ ៣០៤ ] នែបុណ្ណមុខៈសម្លាញ់ ស្រីរមែងនាំមកនូវការប្រព្រឹត្តខូចដោយ

ហេតុ ៩ យ៉ាង គឺស្រីទៅកាន់សួនច្បាររឿយៗ ១ ទៅកាន់ឧទ្យានរឿយៗ ១ ទៅកាន់កំពង់ស្ទឹងរឿយៗ ១ ទៅកាន់ត្រកូលញាតិរឿយៗ ១ ទៅកាន់ត្រកូលដទៃរឿយៗ ១ ប្រកបរឿយៗ ក្នុងការលៃលកតែខាងកញ្ចក់ និងសំពត់ និងគ្រឿងស្អិតស្អាងជាប្រក្រតី ១ ផឹកនូវទឹកស្រវឹងជាប្រក្រតី ១ មានការលបមើលបុរសមិនដាច់ជាប្រក្រតី ១ ឈរបង្ហាញខ្លួនទៀបមាត់ទ្វារជាប្រក្រតី ១ នែបុណ្ណមុខៈសម្លាញ់ ស្រីរមែងនាំមកនូវការខូចកាចដោយហេតុ ៩ យ៉ាងនេះឯង ។ ពាក្យក្នុងរឿងនេះ មានតទៅទៀត

ពួកស្រី តែងនាំមកនូវការខូចដោយហេតុ ៩ យ៉ាងគឺ ជាអ្នកទៅកាន់សួនច្បាររឿយៗ ១ ទៅកាន់ឧទ្យាន ១ ទៅកាន់ស្ទឹង ១ ទៅកាន់ត្រកូលញាតិ ១ ទៅកាន់ត្រកូលដទៃ ១ ប្រកបរឿយៗតែខាងសំពត់និងគ្រឿងស្អិតស្អាង ១ ជាស្រីផឹកទឹកស្រវឹងជាប្រក្រតី ១ មានការលបមើលបុរសមិនដាច់ជាប្រក្រតី ១ ឈរបង្ហាញខ្លួនទៀបមាត់ទ្វារជាប្រក្រតី ១ ។

[ ៣០៥ ] នែបុណ្ណមុខៈសម្លាញ់ ស្រីរមែងចៃចង់បុរសដោយហេតុ ៤០ យ៉ាង គឺកាច់រាង ១ បន្ទន់ខ្លួន ១ កែក្រាយ ១ ក្រអឺមក្រអៀម ១ យកក្រចកផ្ទាត់ក្រចក ១ យកជើងជាន់ជើង ១ យកកំណាត់ឈើគូសផែនដី ១ លើកកូនក្មេងដោយខ្លួនឯង ១ ឲ្យកូនក្មេងលើកខ្លួនវិញ ១ លេងកូនក្មេងដោយខ្លួនឯង ១ ញុំាងកូនក្មេងឲ្យលេង ១ ថើបកូនក្មេងដោយខ្លួនឯង ១ ញុំាងកូនក្មេងឲ្យថើបវិញ ១ ស៊ីខ្លួនឯង ១ ញុំាងកូនក្មេងឲ្យស៊ី ១ ឲ្យវត្ថុទៅកូនក្មេង ១ សុំល្បួងលោមយកមកវិញ ១ ធ្វើត្រាប់តាម ( ក្មេង ) ដែលវា

ធ្វើ ១ និយាយខ្លាំង ១ និយាយតិច ១ និយាយបើកចំហមាត់ ១ និយាយលាក់លៀម ១ ( ធ្វើនូវនិមិត្ត ) ដោយអាការរាំច្រៀងប្រគំ យំរាប់រៀបម៉្រិកម៉្រក់ ស្អិតស្អាង ១ សើចក្អាកក្អាយ ១ សម្លឹងសំឡក់ ១ ញាក់ចង្កេះ ១ ញាំងទ្រព្យកំបាំងឲ្យកម្រើក ១ បើកបង្ហាញភ្លៅ ១ បិទភ្លៅទៅវិញ ១ បង្ហាញដោះ ១ បង្ហាញក្លៀក ១ បង្ហាញផ្ចិត ១ មិចភ្នែក ១ ញាក់ចិញ្ចើម ១ ខាំបបូរមាត់ ១ លៀនអណ្ដាត ១ ច្បូតសំពត់ ១ ស្លៀកសំពត់វិញ ១ រំសាយសក់ ១ បួងសក់វិញ ១ នែបុណ្ណមុខៈសម្លាញ់ ស្រីរមែងបែចង់បុរសដោយហេតុ ៤០ យ៉ាងនេះឯង ។

[ ៣០៦ ] នែបុណ្ណមុខៈសម្លាញ់ ស្រីដែលខូច បណ្ឌិតគប្បីដឹងដោយហេតុ ២៥ យ៉ាង គឺស្រីសរសើរការនៅឃ្លាតអំពីប្ដី ១ មិនរឭកប្ដីដែលនៅឃ្លាតគ្នា ១ មិនត្រេកអរនឹងប្ដីដែលទើបមកដល់ ១ ពោលទោសប្ដីនោះ ១ មិននិយាយសរសើរគុណប្ដីនោះ ១ ប្រព្រឹត្តនូវសេចក្ដីវិនាសដល់ប្ដីនោះ ១ មិនប្រព្រឹត្តសេចក្ដីចម្រើនដល់ប្ដីនោះ ១ ធ្វើតែអំពើដែលមិនគួរធ្វើដល់ប្ដីនោះ ១ មិនធ្វើអំពើដែលគួរធ្វើដល់ប្ដីនោះ ១ ស្លៀកជាប់មាំមួនដេក ១ លបដេកកំបាំងមុខ ១ ដេកបម្រះនទៀល ១ បន្ថជម្លោះ ១ ដកដង្ហើមចេញវែង ( ដូចជា ) រងទុក្ខ ១ ទៅកាន់ទីឧច្ចារៈបស្សាវៈរឿយៗ ១ ប្រព្រឹត្តទទឹងទាស់ ១ ឮសំឡេងប្រុសឯទៀតខំផ្ទៀងត្រចៀកស្ដាប់ ១ ជាស្រីបំផ្លាញទ្រព្យ ១ ធ្វើនូវសន្ថវកិច្ចនឹងប្រុសទាំងឡាយដែលស្និទ្ធស្នាល ១ បានតែខាងជើងចេញដើរ ១ ជាស្រីប្រព្រឹត្តដើរលេងរឿយៗក្នុងវេលាយប់ ប្រព្រឹត្តកន្លងចិត្ត

ប្តី ១ មិនគោរពប្តី ១ មានចិត្តគំនិតខូចកាច ១ ឈរទៀបមាត់ទ្វារញយៗ ១ បង្ហាញក្លៀក រាងកាយ ដោះ ដើរទៅកាន់ទិសទាំងពួងហើយក្រឡេកមើល ១ នៃបុណ្ណមុខៈសម្លាញ់ ស្រីដែលខូចបណ្ឌិតគប្បីដឹងដោយហេតុ ២៥ យ៉ាងនេះឯង ។ ពាក្យក្នុងរឿងនុ៎ះ ដូចមានតទៅទៀត

ស្រីសរសើរការនៅឃ្លាតអំពីប្តីនោះ ១ មិននឹកស្រណោះរកប្តីដែលទៅហើយ ១ ឃើញប្តីមកដល់មិនត្រេកអរ ១ មិនពោលសរសើរគុណប្តីក្នុងកាលណាម្តង ១ ទាំងនេះជាលក្ខណៈរបស់ស្រីខូច ។ ស្រីជាអ្នកមិនសង្រួម ប្រព្រឹត្តនូវសេចក្តីវិនាសដល់ប្តីនោះ ១ ញុំាងប្រយោជន៍ឲ្យវិនាស ១ ជាអ្នកធ្វើនូវកិច្ចដែលមិនគួរធ្វើ ១ ស្លៀកជាប់មាំមួនដេក ១ ដេកក្នុងទីកំបាំងមុខ[១] ១ ទាំងនេះជាលក្ខណៈរបស់ស្រីខូច ។ ស្រីដេកបម្រះនទៀល ១ បង្កជម្លោះ ១ ដកដង្ហើមវែង ( ហាក់ដូជា ) រងទុក្ខវេទនា ១ ទៅកាន់ទីឧច្ចារៈបស្សាវៈរឿយៗ ១ ទាំងនេះជាលក្ខណៈរបស់ស្រីខូច ។ ស្រីជាអ្នកមិនធ្វើការងារ តែងប្រព្រឹត្តទទឹងទាស់ ១ ផ្ទៀងស្តាប់សំឡេងរបស់បុរសដទៃនិយាយ ១ បំផ្លាញទ្រព្យ ១ ធ្វើសន្ថវកិច្ច ( នឹងបុរសដទៃ ) ១ ទាំងនេះជាលក្ខណៈរបស់ស្រីខូច ។ បំផ្លាញទ្រព្យសម្បត្តិដែលប្តីបានមកដោយក្រ នាំមកដោយលំបាក បានមកដោយទុក្ខ ១ ធ្វើសន្ថវកិច្ចនឹងពួកបុរសអ្នកស្និទ្ធស្នាល ១ ទាំងនេះជាលក្ខណៈរបស់ស្រីខូច ។ ស្រីបានតែខាងដើងចេញដើរ ១ ដើរលេងរឿយៗ ក្នុងវេលាយប់ ១ មានចិត្តប្រទូស្តចំពោះប្តីជានិច្ច ១ ប្រព្រឹត្តកន្លងចិត្តប្តី ១ ប្រាសចាក

---

១-ដេកបែរខ្នង ។

សេចក្តីគោរព ១ ទាំងនេះជាលក្ខណៈរបស់ស្រីខូច ។ ស្រីឈរទៀបមាត់ទ្វារ ញយៗ ១ បង្ហាញដោះនឹងក្លៀក ១ មានចិត្តភ្ញាក់ផ្អើលក្រឡេកមើលទិសទាំងពួង ១ ទាំងនេះជាលក្ខណៈរបស់ស្រីខូច ។ ស្ទឹងទាំងអស់ មានដំណើរវៀច ព្រៃទាំងអស់សម្រេចអំពីឈើ ( យ៉ាងណាមិញ ) ពួកស្រីទាំងអស់ ( វៀរលែងតែស្រីដែលមានកិលេសស្តើង ) កាលបើមានបុគ្គលអ្នកខ្សឹបខ្សៀវ ក៏តែងធ្វើនូវអំពើលាមកបាន ( យ៉ាងនោះដែរ ) ។ ពួកស្រីបាននូវឱកាស ឬទីកំបាំង ឬក៏បាននូវបុគ្គលខ្សឹបខ្សៀវប្រាកដដូច្នោះ ពួកស្រីទាំងអស់មិនបាននូវបុរសដទៃ ក៏គប្បីធ្វើនូវអំពើលាមកជាមួយបុរសខ្វិនបាន ។ ពួកបុរសទោះបីធ្វើនូវអំណរចំពោះនារីទាំងឡាយ ជាអ្នកធ្វើនូវសេចក្តីត្រេកអរដល់ពួកបុរស ជាស្រីមានចិត្តច្រើន ដែលគេផ្ចញ់ផ្ចាល់មិនបាន ដោយប្រការទាំងពួង បុគ្គលមិនត្រូវស្និទ្ធស្នាលទេ ព្រោះថា ស្ត្រីទាំងឡាយស្មើដោយកំពង់ទឹក ។

[ ៣០៧ ] បុគ្គលឃើញ ( នូវហេតុនៃសេចក្តីនឿយណាយ ) របស់ព្រះរាជា ព្រះនាមកិន្នរនិងព្រះនាងកិន្នរី ( គប្បីដឹងចុះ ) ពួកស្រីទាំងអស់រមែងមិនត្រេកអរក្នុងផ្ទះ ( របស់ស្វាមីទេ ) ដូចជាកិរិយា ( របស់ព្រះរាជាកិន្នរៈ ) លះបង់នូវសត្វតី ( ស្វាមី ) បែបនោះ ព្រោះឃើញនូវបុរសផ្តេសផ្តាសដទៃជាបុរសខ្វិន ។

[ ៣០៨ ] កិរិយារបស់ព្រះបាទពកៈ និងព្រះបាទពាវរិយៈ ជាព្រះរាជាល្មោភកាមដ៏ក្រៃលែង បានប្រព្រឹត្តក្បត់ចំពោះបុរសអ្នកលុះក្នុងអំណាចដែលខ្លួនប្រាថ្នា ស្រីមិនប្រព្រឹត្តកន្ទងស្វាមីទីងបុរសដទៃនោះ ឯណាកើត ។

[ ៣០៩ ] នាងបិង្គិយានី ជាភរិយា ជាទីស្រឡាញ់នៃព្រះបាទព្រហ្មទត្ត ព្រះអង្គជាធំក្នុងលោកទាំងមូល បានប្រព្រឹត្តក្បត់ចំពោះបុរស អ្នកលុះក្នុងអំណាចដែលខ្លួនប្រាថ្នា នាងបិង្គិយានី ជាអ្នកល្មោភក្នុងកាមនោះ មិនបានទូវបុរសគង្វៀលសេះនោះផង ( នូវទីអគ្គមហេសីផង ) ។

[ ៣១០ ] បុរសដែលមិនមែនខ្វាចចូល មិនគួរជឿពួកស្រីដែលអាក្រក់មានចិត្តរហ័ស ជាស្រីមិនដឹងគុណដែលគេធ្វើដល់ខ្លួន ជាស្រីប្រទូស្ត ( ប្តី ) ទេ ។ ពួកស្រីទាំងនោះ មិនដឹងនូវឧបការៈដែលគេធ្វើហើយ ( ដល់ខ្លួន ) មិនដឹងនូវកិច្ចការដែលគួរធ្វើ មិនស្គាល់ម្តាយ មិនស្គាល់ឪពុក មិនស្គាល់បងប្អូន មិនមានអរិយធម៌ មានការប្រព្រឹត្តកន្លងជាធម្មតា តែងលុះអំណាចចិត្តរបស់ខ្លួន ។ ពួកស្រីតែងលះបង់ប្តីជាទីស្រឡាញ់ ជាទីពេញចិត្ត ជាអ្នកអនុគ្រោះស្មើដោយជីវិត ដែលកប់ប្រសព្វអស់កាលដ៏យូរ ឬលះបង់នូវប្តីក្នុងកិច្ចមានអន្តរាយ ព្រោះហេតុនោះ ខ្ញុំមិនទុកចិត្តចំពោះស្រីទាំងឡាយទេ ។ ព្រោះថា ចិត្តរបស់ស្រីដូចគ្នានឹងចិត្តពានរ ហឫទ័យរបស់ពួកស្រីចុះឡើងញាប់ញ័រ ដូចជាម្លប់ឈើ តែងវិលទៅ ដូចកង់រទេះ ។ ពួកស្រីទាំងនោះកាលក្រឡេកមើលឃើញទ្រព្យរបស់ប្រុស ដែលគួរកាន់យក ក្នុងកាលណា ក៏កៀរគរប្រុសនោះ ដោយសំដីដ៏ផ្អែមល្ហែម ក្នុងកាលណោះ ដូចពួកជនអ្នកកម្ពោជ បញ្ឆោតចាប់សេះដោយសារាយ ។ ពួកស្រីកាលបើក្រឡេកមើលមិនឃើញទ្រព្យរបស់ប្រុសដែលគួរកាន់យក ក្នុងកាលណា ក៏វៀរប្រុសនោះដោយជុំវិញ ក្នុងកាលណោះ ដូចគេឆ្លងទៅដល់ត្រើយស្ទឹងហើយ លះបង់នូវ

ក្បួន ។ ពួកស្រីឧបមាដូចជ័រ ( ជាទីជាប់ស្អិតនៃចិត្តបុរស ) ដូចភ្លើង ស៊ីនូវវត្ថុគ្រប់យ៉ាង មានមាយាដ៏រហ័ស ដូចស្ទឹងមានខ្សែទឹកដ៏រហ័ស ពួកស្រីទាំងនេះ តែងសេពគប់បុរសទាំងជាទីស្រឡាញ់ ទាំងមិនជាទីស្រឡាញ់ ដូចទូកតែងជួបប្រទះទាំងច្រាំងខាងអាយនិងច្រាំងខាងនាយ ។ ពួកស្រីទាំងនោះ មិនមែនជារបស់ប្រុសម្នាក់ឬពីរនាក់ទេ ដូចជាពនផ្សារដែលបើកហើយ បុគ្គលណាសំគាល់នូវពួកស្រីទាំងនោះថា ជារបស់អញ បុគ្គលនោះ ដូចគេយកសំណាញ់ខ្ទប់ខ្យល់ ។ ស្ទឹង ផ្លូវ រោងសុរា រោងជាទីប្រជុំ និងអណ្តូងទឹកយ៉ាងណា ធម្មតា ពួកស្រីក្នុងលោក ក៏យ៉ាងនោះដែរ វេលា ( នៃសេចក្តីស្រើបក្នុងកាម ) របស់ពួកស្រីទាំងនោះ មិនមានឈប់ឈរទេ ។ ពួកស្រីទាំងនេះ ស្មើដោយអណ្តាតភ្លើង មានឧបមាដូចក្បាលពស់វែក ដូចពួកគោស៊ីនូវស្មៅដ៏ល្អៗ ខាងក្រៅ ។ នរៈគប្បីគប់រកដោយការប្រយ័ត្ននូវវត្ថុទាំងនេះ គឺ ភ្លើង ១ ដីរ ១ ពស់វែក ១ ព្រះរាជាដែលគេអភិសេកហើយ ១ ពួកស្រីទាំងអស់ ១ ព្រោះភាពទៀងទាត់នៃវត្ថុទាំងនោះ ដឹងបានដោយក្រណាស់ ។ ពួកស្រីមានពណ៌សម្បុរដ៏ល្អលើសលុបពេក បុគ្គលមិនត្រូវសេពគប់ ១ ស្រីជាទីស្រឡាញ់ពេញចិត្តរបស់ពួកជនច្រើន បុគ្គលមិនត្រូវសេពគប់ ១ ស្រីឆ្មៀវឆ្លាស ក្នុងការរាំនិងច្រៀង បុគ្គលមិនត្រូវសេពគប់ ១ ប្រពន្ធអ្នកដទៃ បុគ្គលមិនត្រូវសេពគប់ ១ ស្រី ( សេពគប់ ) ព្រោះហេតុនៃទ្រព្យបុគ្គលក៏មិនត្រូវសេពគប់ ១ ស្រី ៥ ពួកនេះ បុគ្គលមិនត្រូវសេពគប់ទេ ។

[ ៣១១ ] ដំណាលថា គ្រានោះ ស្តេចត្មាតឈ្មោះអានន្ទ បានដឹងនូវ

គាថាជាខាងដើម កណ្ដាលនិងខាងចុងរបស់កុណាលសកុណៈ ហើយបាន ពោលគាថានេះ ក្នុងវេលានោះថា

បុរសទោះបីឲ្យនូវផែនដី ដែលពេញដោយទ្រព្យដល់ស្ត្រី ដែលសន្មត ហើយ ស្រីនោះលុះបានឱកាស រមែងមើលងាយបុរសនោះវិញ ( ព្រោះ ហេតុនោះ ) បុរសមិនត្រូវលុះអំណាចនៃស្រីទាំងនោះឡើយ ។ ពួកស្រីរមែង លះបង់នូវប្ដីក្មេង ដែលជាអ្នកមានព្យាយាមក្រោកឡើង មានការប្រព្រឹត្តមិន រួញរា គួរជាទីស្រឡាញ់ពេញចិត្តផង លះបង់នូវប្ដីនោះ ព្រោះកិច្ចដែលមាន អន្តរាយផង ព្រោះហេតុនោះ ខ្ញុំមិនទុកចិត្តចំពោះស្រីទាំងឡាយទេ ។ បុរស មិនត្រូវទុកចិត្តស្រី ដោយគិតថា ស្រីនោះចង់បានអញ មិនត្រូវទុកចិត្តស្រី ដោយគិតថា ស្រីនោះយំរំជែចំពោះអញ ( ដូច្នេះទេ ) ព្រោះថា ស្រីទាំងនោះ រមែងគប់រកនូវបុរស ទាំងជាទីស្រឡាញ់ ទាំងមិនជាទីស្រឡាញ់ ដូចទូកជួប ប្រទះទាំងច្រាំងខាងអាយនឹងច្រាំងខាងនាយ ។ បុគ្គលមិនត្រូវទុកចិត្តមែក ឈើចាស់ដែលគេក្រាលទុកទេ មិនត្រូវទុកចិត្តចោរជើងចាស់ជាមិត្ត[១]ទេ មិន ត្រូវទុកចិត្តថា ព្រះរាជាជាសម្លាញ់របស់អញដូច្នេះទេ មិនត្រូវទុកចិត្តស្រីជា មាតារបស់បុត្ត ១០ នាក់ ( យាយចាស់ ) ទេ បុគ្គលមិនត្រូវទុកចិត្តចំពោះ ពួកនារីអ្នកធ្វើនូវសេចក្ដីត្រេកអរ អ្នកកន្លងសីលធម៌ មិនសង្រួមទេ មិនត្រូវ ទុកចិត្តកិរិយាដែលមានសេចក្ដីស្រឡាញ់ក្រៃពេក ព្រោះថា នារីទាំងឡាយ ទុកស្មើកំពង់ទឹក ។ ពួកស្រីរមែងសម្លាប់ ( បុរស ) ខ្វះ កាត់ ( កបុរស )

---

១-មិត្តចាស់ដែលជាចោរ ។

ខ្លួនឯងខ្លះ ប្រើគេឲ្យកាត់ខ្លះ កាត់កហើយផឹកឈាមខ្លះ បុគ្គលកុំធ្វើសេចក្តីស្នេហាចំពោះពួកស្រីដែលមានសេចក្តីប្រាថ្នាថោកទាប ជាអ្នកមិនសង្រួម មានចិត្តដូចកំពង់ទឹក ។ ពាក្យកុហករបស់ពួកស្រីទាំងនោះ ក៏ដូចជាពាក្យពិត ឯពាក្យពិតរបស់ពួកស្រីទាំងនោះ ក៏ដូចជាពាក្យកុហក ( ពួកស្រី ) ដូចគោស៊ីច្បិចតែស្មៅល្អៗ ខាងក្រៅ ។ ពួកស្រីទាំងនោះ តែងប្រលោម ( ប្រុស ) ដោយដំណើរផង ដោយអាការដែលក្រឡេកមើលផង ដោយសំណើចផង ឬដោយសំពត់ដែលស្លៀកអាក្រក់ផង ដោយពាក្យពីរោះផង ។ ពិតណាស់ស្រីទាំងនេះដូចចោរ មានចិត្តរឹងត្អឹង ខូចកាច តែមានសំដីផ្អែមដូចស្ករ ការបញ្ឆោតណាក្នុងពួកមនុស្ស ពួកស្រីទាំងនោះ មិនមែនជាមិនដឹងការបញ្ឆោតណាមួយ ( នោះ ) ទេ ។ ធម្មតាពួកស្រីក្នុងលោក ( ច្រើនតែ ) លាមកវេលារបស់ពួកស្រីទាំងនោះ មិនមានទេ ពួកស្រីជាអ្នកស្រើបស្រាលផង ឃ្នើសឃ្នងផង ដូចភ្លើងស៊ីវត្ថុគ្រប់យ៉ាង ។ ប្រុសឈ្មោះថា ជាទីស្រឡាញ់របស់ពួកស្រីមិនមាន ទាំងមិនជាទីស្រឡាញ់ក៏មិនមាន ព្រោះថា ពួកស្រីទាំងនេះ តែងគប់រកបុរសជាទីស្រឡាញ់ទាំងមិនស្រឡាញ់ ដូចទូកតែងជួបប្រទះទាំងច្រាំងខាងអាយនិងច្រាំងខាងនាយ ។ ប្រុសឈ្មោះថា ជាទីស្រឡាញ់របស់ពួកស្រីមិនមាន ទាំងមិនជាទីស្រឡាញ់ក៏មិនមាន ពួកស្រីតែងរួបរឹត ( ប្រុស ) ដើម្បីទ្រព្យសម្បត្តិ ដូចវល្លិ៍តោងដើមឈើ ។ ស្រីទាំងឡាយតែងរត់តាមប្រុសឃ្វាលដំរី ឃ្វាលសេះ ឃ្វាលគោ ប្រុសចណ្ឌាល អ្នកដុតខ្មោចនិងអ្នកចោលសំរាមដែលមានទ្រព្យ ។ ស្រីទាំងឡាយតែងលះបង់នូវកូន

អ្នកមានត្រកូលដែលមិនមានទ្រព្យតិចតួច ទុកស្មើសាកសព នារីទាំងឡាយ ( ច្រើនតែ ) គប់រកប្រុស ព្រោះហេតុតែទ្រព្យ ។

[ ៣១២ ] សេចក្តីដំណាលថា គ្រានោះ ទេវព្រាហ្មណ៍ ឈ្មោះនារទៈ បានដឹងនូវគាថាជាខាងដើម កណ្តាលនឹងទីបំផុតរបស់ស្តេចត្មាតឈ្មោះអានន្ទ ហើយ ក៏ពោលគាថាទាំងឡាយនេះក្នុងវេលានោះថា

បពិត្រលោកជាម្ចាស់នៃបក្សី សូមលោកស្តាប់ពាក្យដែលខ្ញុំនឹងនិយាយ ដូចតទៅនេះ ជន ៤ ពួកនេះគឺ សមុទ្ទ ១ ព្រាហ្មណ៍ ១ ព្រះរាជា ១ ស្រី ១ រមែងមិនពេញ ។ ស្ទឹងណាមួយដែលអាស្រ័យនៅប្រឹថពី ដែលហូរទៅកាន់សាគរ ស្ទឹងទាំងនោះ ក៏ញុំាងសមុទ្ទឲ្យពេញមិនបាន ព្រោះថា សមុទ្ទរមែងមិនពេញ ចេះតែនៅខ្វះខាត ។ ព្រាហ្មណ៍រៀននូវវេទមានគម្ពីរឈ្មោះឥតិហាសៈជាគម្រប់ ៥ ហើយ តែងប្រាថ្នានូវការចេះដឹងឲ្យក្រៃលែង ព្រោះថា ព្រាហ្មណ៍នោះ រមែងមិនពេញចេះតែខ្វះខាត ។ ចំណែកព្រះរាជាឈ្នះគ្រប់គ្រងផែនដីទាំងអស់ ព្រមទាំងសមុទ្ទនិងភ្នំហើយ តែងប្រាថ្នារកច្រាំងសមុទ្ទនិងផ្ទៃសមុទ្ទ ដែលសម្បូណ៌ដោយរតនៈ មិនមានទីបំផុត ព្រោះថា ព្រះរាជានោះ រមែងមិនគ្រប់គ្រាន់ ចេះតែខ្វះខាត ។ ស្រីម្នាក់ៗ មានប្តី ៨ ៗ ហើយប្តីនោះ ជាអ្នកក្លៀវក្លាផង មានកម្លាំងផង នាំមកនូវរសនៃសេចក្តីប្រាថ្នាគ្រប់យ៉ាង ក៏គង់ធ្វើនូវសេចក្តីប្រាថ្នាក្នុងប្តីទី ៩ ទៀត ព្រោះថា ស្រីនោះ រមែងមិនគ្រប់គ្រាន់ ចេះតែខ្វះខាត ។ ពួកស្រីទាំងអស់ ដូចភ្លើងស៊ីនូវវត្ថុគ្រប់យ៉ាង ពួកស្រីទាំងអស់ ដូចស្ទឹងនាំទៅនូវវត្ថុគ្រប់យ៉ាង ពួកស្រីទាំងអស់ ដូចមែកឈើមាន

បន្ទា ពួកស្រីទាំងអស់ គប់រក ( ប្តី ) ព្រោះហេតុតែទ្រព្យ ។ នរជនណា ផ្តុកផ្តាក់នូវភាព គឺការផ្សារទាំងពួងលើពួកស្រី នរជននោះ ទុកដូចគេយក បណ្តាញចាប់ខ្យល់ ឬដូចជាគេបាចទឹកសមុទ្រដោយដៃម្ខាង ពុំនោះ ដូចគេ យកដៃ ១ ទះឲ្យឮស្នូរគឹកកង ។ ពួកស្រីដែលដូចជាចោរ មានពុតត្បុតច្រើន មានពាក្យសច្ចៈគេរកបានដោយកម្រណាស់ ភាពនៃស្រីទាំងឡាយ គេដឹង បានដោយក្រ ដូចដំណើរនៃត្រីក្នុងទឹក ។ ពួកស្រីទាំងនោះ មានមារយាទ របិញរបុញ មានសំដីទន់ ទុកស្មើដោយស្អឹង បំពេញបានដោយក្រ តែងលិច ចុះ ( ក្នុងអបាយព្រោះហេតុតែកាម ) បុគ្គលដឹងច្បាស់នូវដំណើរនោះហើយ គប្បីវៀរឲ្យឆ្ងាយចេញ ។ ពួកស្រី ជាអ្នកញុំាងចិត្តប្រុសឲ្យត្រឡប់ត្រឡិន មានមាយាច្រើន ញុំាងព្រហ្មចរិយធម៌ឲ្យកម្រើក តែងលិចចុះ ( ក្នុងអបាយ ) បុគ្គលដឹងច្បាស់នូវដំណើរនោះហើយ គប្បីចៀសឲ្យឆ្ងាយចេញ ។ ពួកស្រី ទាំងនោះ ចូលទៅគប់រកប្រុសណាដោយសេចក្តីប្រាថ្នា ឬដោយទ្រព្យសម្បត្តិ រមែងដុតកម្តៅប្រុសនោះដោយឆាប់រហ័ស ដូចភ្លើងឆេះនូវទីរបស់ខ្លួន ។

[ ៣១៣ ] សេចក្តីដំណាលថា គ្រានោះ កុណាលសកុណៈ ដឹងនូវ គាថាជាខាងដើម កណ្តាលនឹងទីបំផុតនៃទេវព្រាហ្មណ៍ឈ្មោះនារទហើយ ក៏ ពោលគាថានេះក្នុងវេលានោះថា

បណ្ឌិតគួរចរចា ( ជាមួយ ) នឹងបុគ្គលមានដៃកាន់ដាវសំលៀងហើយ ( ជាមួយ ) នឹងបុគ្គលប្រទុស្តដូចជាបិសាច ឬក៏ចូលទៅរកពស់ដែលមាន ពិសដ៏ពន្លឹក ( ប្រសើរជាង ) ប្រុសម្នាក់ឯង មិនគួរនិយាយចរចាចំពោះស្រី

ម្នាក់ឯងទេ ។ ព្រោះថា នារីទាំងឡាយ ជាអ្នកញ៉ាំញីនូវចិត្តនៃមនុស្សលោក ជាអ្នកមានការរាំច្រៀង និយាយ សើច ញញឹម ជាអាវុធ តែងបៀតបៀននូវប្រុសដែលមិនបានតម្កល់ស្មារតី ដូចពួកស្រីអារក្សទឹកក្នុងកោះ បៀតបៀនពួកពាណិជ ។ ពួកស្រីទាំងនោះ មិនមានវិន័យ មិនមានសំវរៈ ពួកស្រីទាំងនោះ ជាអ្នកល្មោភទឹកស្រវឹងនិងសាច់ ជាអ្នកមិនសង្រួម តែងលេបទ្រព្យសម្បត្តិរបស់បុរស ដូចត្រីធំឈ្មោះតិមិង្គលៈលេបនូវមករក្នុងសាគរ ។ ពួកស្រីមានសេចក្តីត្រេកអរក្នុងបញ្ចកាមគុណជាអារម្មណ៍ មានអាការឆ្មើងឆ្មៃ មិនទៀង មិនសង្រួម យ៉ាំរកតែបុរសអ្នកប្រមាទ ដូចទឹកស្ទឹងតែងហូរចុះទៅរកទីមានទឹកប្រៃ ( សមុទ្ទ ) ។ នារីទាំងឡាយ រមែងនិយាយស្រស់ស្រាយរកជនណា ដោយសេចក្តីស្រឡាញ់ ឬដោយតម្រេក ឬក៏ដោយទ្រព្យជាស្រីសម្លាប់ប្រុស ដោយរាគៈនិងទោសៈ រមែងដុតពោលនរជននោះ សូម្បីប្រុសរុងរឿងដូចភ្លើងជាអ្នកទីងនួន ។ ពួកស្រីដឹងថាបុរសអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន រមែងក្រវែលរកប្រុសដែលមានទ្រព្យដោយខ្លួនឯង រួបរុំបុរសដែលមានចិត្តត្រេកអរ ដូចពួរជ្រែក្នុងព្រៃរួបព័ទ្ធដើមរាំង ។ នារីទាំងឡាយនោះមានខ្លួននិងមុខដ៏វិចិត្រតាក់តែងហើយ ផ្គាប់ផ្គុន ( បុរស ) ដោយសេចក្តីប្រាថ្នាផ្សេងៗ ជាអ្នកយល់កលមាយាទាំងរយ រមែងសើច រមែងញញឹម តែហាក់ដូចជាសង្រួម ។ នារីទាំងឡាយ ស្អិតស្អាងខ្លួនដោយមាស កែវមណីនិងកែវមុក្តា ដែលគេធ្វើសក្ការៈ ក្នុងត្រកូលរបស់ប្តីដែលគេរក្សាហើយ ក៏នៅតែប្រព្រឹត្តក្បត់ស្វាមីបាន ដូចជាប្រពន្ធ ដែលអាស្រ័យនៅក្នុងចន្លោះហឫទ័យ

ប្រព្រឹត្តក្បត់អសុរវិញបាន ។ នរជន សូម្បីមានតេជៈ មានប្រាជ្ញាវាងវៃដែលអ្នកផងច្រើនគ្នា ធ្វើសក្ការបូជា លុះក្នុងអំណាចនៃស្រីទាំងឡាយហើយ រមែងមិនរុងរឿង ដូចព្រះចន្ទដែលត្រូវរាហូចាប់ ។ ចោរអ្នកក្រោធ មានចិត្តអាក្រក់ ( ឃើញ ) ចោរជាសត្រូវ ( នឹងខ្លួន ) មកប្រទះគ្នាហើយ ធ្វើនូវសេចក្តីវិនាសណា បុគ្គលអ្នកមានតណ្ហា លុះក្នុងអំណាចនៃស្រីទាំងឡាយ រមែងដល់នូវសេចក្តីវិនាសក្រៃលែង ជាងសេចក្តីវិនាសនោះទៅទៀត ។ នារីទាំងឡាយ ដែលមានសក់របោច មានស្នាមដាច់ដោយក្រចក ដែលត្រូវគេវាយគេធាក់ដោយជើងដៃនិងដំបង ក៏នៅតែចូលទៅកាន់អាការថោកទាបវិញ នៅតែត្រេកអរ ( ក្នុងកាមទៀត ) ដូចរុយត្រេកអរនឹងសាកសព ។ បុរសអ្នកមានបញ្ញាចក្ខុ ត្រូវការដោយសេចក្តីសុខ គប្បីវៀរស្រីទាំងឡាយនោះ ( ដែលនៅ ) ក្នុងត្រកូលទាំងឡាយក្តី ក្នុងចន្លោះប្រកក្តី ក្នុងរាជធានីក្តី ក្នុងនិគមក្តី ឬក៏វៀរនូវអារម្មណ៍ ដូចជាអន្ទាក់និងបង្កាត់របស់មារ ដែលកិលេសមារដាក់ហើយក្តី ។ បគ្គលណា លះបង់នូវតបោគុណ ( គុណគឺសេចក្តីព្យាយាម ) ជាកុសលហើយ ប្រព្រឹត្តនូវចរិតមិនប្រសើរ បុគ្គលនោះ ( លុះច្យុត ) ចាកទេវតាហើយ នឹងមកកាន់នរកវិញ ដូចពាណិជ្ជ ( មានទ្រព្យច្រើនដូរយក ) ក្អមកំបែក ។ បុរស ( ដែលលុះក្នុងអំណាចស្រី ) នោះ ត្រូវគេតិះដៀលក្នុងលោកនេះផង ក្នុងលោកខាងមុខផង ជាមនុស្សមានគំនិតអាក្រក់ ត្រូវកម្មរបស់ខ្លួនបៀតបៀន ជាបុគ្គលមិនទៀង តែងធ្លាក់ទៅកាន់អបាយភូមិ ដូចរថដែលទឹមលាកាច ដើរទៅក្នុងទីខុសផ្លូវ ។ បុរសនោះ រមែងចូលទៅកាន់

នរក ជាទីញុំាំងសត្វឲ្យក្តៅ នៅអាស្រ័យនឹងព្រៃរកា មានបន្ទាដូចលំពែងធ្វើអំពីដែកផង កំណើតតិរច្ឆានផង វិស័យនៃប្រេតនិងអសុរកាយផង រមែងមិនអាចរួចបានទេ ។ ស្រីទាំងឡាយរមែងញុំាំងល្បែងជាទិព្វ ឬញុំាំងតម្រេកក្នុងទីជាទីរីករាយ ឬញុំាំងសម្បត្តិចក្រពត្តិ ក្នុងទីជារបស់មនុស្សនៃបុគ្គលអ្នកប្រមាទឲ្យវិនាស ពួកស្រីរមែងញុំាំងប្រុសនោះ ឲ្យដល់នូវទុគ្គតិ ។ ល្បែងជាតម្រេកទិព្វ សម្បត្តិស្តេចចក្រពត្តិក្នុងទីជារបស់មនុស្ស និងពួកស្រីអប្សរមានពិមានមាសជាលំនៅ ជាសម្បត្តិដែលបុគ្គលមិនត្រូវការដោយពួកស្ត្រីហើយប្រព្រឹត្ត ( ព្រហ្មចរិយធម៌ ) មិនមែនបានដោយក្រទេ ។ គតិជាទីកន្លងផុតចាកកាមធាតុ គឺការកើតក្នុងរូបធាតុ និងការកើតក្នុងសុទ្ធាវាស ជាវិស័យរបស់អ្នកប្រាសចាករាគៈ ជាសម្បត្តិដែលបុគ្គលមិនត្រូវការដោយពួកស្ត្រីហើយប្រព្រឹត្ត ( ព្រហ្មចរិយធម៌ ) មិនមែនបានដោយក្រទេ ។ គុណជាតដ៏ក្សេមក្សាន្ត គឺព្រះនិព្វាន ជាទីកន្លងផុតចាកទុក្ខទាំងពួង ជាអច្ចន្តសុខ មិនកម្រើក មិនមានបច្ច័យតាក់តែង បុគ្គលមិនត្រូវការដោយស្រី ហើយប្រព្រឹត្ត ( ព្រហ្មចរិយធម៌ ) ជាអ្នកស្អាត មានកិលេសរលត់ មិនមែនបានដោយក្រទេ ។

[ ៣១៤ ] ( ព្រះសាស្តាទ្រង់ប្រជុំជាតកនេះថា ) ក្នុងកាលណោះ កុណាលបក្សី បានមកជាតថាគត បុស្សកោកិលបក្សី បានមកជាឧទាយិភិក្ខុ ស្តេចត្មាតបានមកជាអានន្ទ នារទព្រាហ្មណ៍បានមកជាសារីបុត្ត ពួកបរិស័ទបានមកជាពុទ្ធបរិស័ទ អ្នកទាំងឡាយចូរចាំទុកជាតកយ៉ាងនេះ ។

**ចប់ កុណាលជាតកទី ៤**

## អដ្ឋកថា

## កុណាល ជាតក

[ ២៩៦-៣១៤ ] ព្រះសាស្តា កាលគង់នៅត្រង់មាត់ស្រះឈ្មោះ កុណាល ទ្រង់ប្រារព្ធភិក្ខុ ៥០០ រូប ដែលត្រូវសេចក្តីអផ្សុកបៀតបៀនចង់សឹក ហើយត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឯវមក្ខាយតិ** ដូច្នេះជាដើម ។

លំដាប់រឿងក្នុងកុណាលជាតកនោះ មានសេចក្តីដូច្នេះថា បានឮមកថា ក្នុងចន្លោះនគរកបិលពស្តុនិងនគរកោលិយៈទាំង ២ នោះ មានស្ទឹងមួយខ្សែឈ្មោះរោហិណី ហូរកាត់មក អ្នកសាកិយៈនិងអ្នកកោលិយៈ ក៏ធ្វើទំនប់ទប់ទឹកនោះរួមគ្នា ហើយសាបព្រោះ ។ សម័យមួយ ក្នុងដើមខែជេស្ឋ សន្ទូងទាំងឡាយក៏ស្វិតស្រពោន ពួកកម្មកររបស់ពួកអ្នកនគរទាំង ២ ក៏ប្រជុំគ្នា បណ្តាកម្មករទាំង ២ នគរនោះ ពួកកម្មករអ្នកកោលិយៈពោលឡើងថា ទឹកដែលទប់នេះ បើបង្ហូរចូលស្រែទាំងសងខាង ក៏មិនគ្រប់គ្រាន់សម្រាប់សន្ទូងរបស់ពួកយើងនិងពួកលោក សន្ទូងរបស់ពួកយើង នឹងសម្រេចព្រោះទឹកតែម្តងប៉ុណ្ណោះ សូមពួកលោកឲ្យទឹកនេះដល់ពួកយើងចុះ សូម្បីពួកកម្មករអ្នកនគរលេបិលពស្តុក៏ពោលថា កាលពួកលោកបានស្រូវដាក់ពេញជង្រុក ហើយពួកយើងមិនអាចកាន់យកមាស ប្រាក់ និល មណី សំរឹទ្ធ កែវល្អ បាវជាដើម ដើរទៅសុំទិញតាមទ្វារផ្ទះរបស់លោកបានទេ ឯសន្ទូងរបស់ពួកយើងក៏សម្រេចព្រោះទឹកតែម្តងប៉ុណ្ណោះដូចគ្នា សូមពួកលោកឲ្យទឹកនេះដល់ពួកយើងចុះ ។ ជនទាំង ២ ពួក ក៏ជំទាស់ឡើងសំឡេងដាក់គ្នាថា ពួកយើងនឹងមិនឲ្យ ពួកយើងនឹងមិនឲ្យ ដូច្នេះ កាលនិយាយគ្នាច្រើនឡើងៗយ៉ាងនេះ កម្មករ

ម្នាក់ក្រោកឡើង វាយកម្មករម្នាក់ កម្មករដែលត្រូវវាយនោះ ក៏វាយអ្នកដទៃបន្តៗ ឯអ្នកដែលវាយតប់គ្នាយ៉ាងនេះ ក៏កើតជម្លោះទាស់ទែងគ្នានៃជាតិក្នុងរាជត្រកូល ពួកកម្មករអ្នកកោលិយៈពោលថា ពួកអា ចូរនាំក្មេងៗសាកិយៈដែលនៅក្នុងនគរកបិលពស្តុទៅចុះ ពួកអារួមសំវាសជាមួយប្អូនស្រីខ្លួនឯងដូចសត្វតិរច្ឆាន មានឆ្កែស្រុកនិងឆ្កែព្រៃជាដើម ទោះបីមានកម្លាំងដូចជាដំរី សេះ ខែលនិងអាវុធ ក៏នឹងធ្វើអ្វីដល់ពួកអញបាន ។ ពួកកម្មករអ្នកសាកិយៈក៏ពោលឆ្លើយថា ពួកអា ក៏ចូរនាំក្មេងឋោកទាបទាំងនេះទៅក្នុងឥឡូវនេះ ពួកអាជាមនុស្សអនាថាមិនមានទីពឹង ត្រាច់អាស្រ័យនៅត្រង់រូងក្រពៅ ដូចសត្វតិរច្ឆាន ទោះបីមានយោធាដ៏អង់អាច មានដំរី សេះ ខែលនិងអាវុធ ក៏នឹងធ្វើអ្វីដល់ពួកអញបាន ជនទាំងនោះ នាំគ្នាទៅប្រាប់អាមាត្យដែលជាម្ចាស់រឿងៗខ្លួន ពួកអាមាត្យក៏ក្រាបទូលរឿងនោះ ដល់រាជត្រកូលតទៅ ។ ក្នុងលំដាប់នោះ ពួកស្តេចសាកិយៈទាំងឡាយត្រាស់ថា ពួកយើងនឹងបង្ហាញកម្លាំងរបស់អ្នកដែលរួមសង្វាសជាមួយប្អូនស្រីឯងឲ្យមើល ហើយលើកទ័ពចេញទៅ សូម្បីពួកស្តេចកោលិយៈ ក៏ត្រាស់ថា ពួកយើងនឹងសម្តែងឲ្យឃើញកម្លាំងរបស់អ្នកដែលនៅអាស្រ័យក្នុងព្រង់ក្រពៅ ហើយលើកទ័ពចេញទៅដូចគ្នា ។

រឿងដែលវិវាទគ្នានេះ អាចារ្យពួកខ្លះពោលថា ពួកទាសីរបស់អ្នកសាកិយៈនិងអ្នកកោលិយៈ ទៅកាន់ស្ទឹងដើម្បីដងទឹក ដោះក្បាំងមុខដាក់ត្រង់ផែនដីហើយអង្គុយសម្រាកនិយាយគ្នាយ៉ាងសប្បាយ ទាសីម្នាក់កាន់យកក្បាំងមុខ

របស់ទាសីនោះទៅ ដោយសា្គាល់ថាជារបស់ខ្លួន អាស្រ័យក្បាំងមុខនោះជាហេតុ ទើបកើតជម្លោះឡើងថា ក្បាំងមុខរបស់អញ ក្បាំងមុខរបស់ឯង ដូច្នេះហើយ ជនអ្នកនគរទាំង ២ តាំងពីកម្មករជាលំដាប់ រហូតដល់សេវកៈ មេស្រុក អាមាត្យ ឧបរាជ និងព្រះរាជាទាំងអស់ក៏នាំគ្នាត្រៀមចេញទៅធ្វើសង្គ្រាមជាមួយគ្នា ដោយន័យទី ១ មានមកក្នុងអដ្ឋកថាច្រើនកន្លែងដូចគ្នា ហើយដើមរឿង ក៏មានទំនងសមហេតុសមផល ព្រោះដូច្នោះ ទើបបណ្ឌិតគួរកាន់យករឿងការទាស់គ្នាព្រោះដណ្ដើមទឹកនោះឯង ។ ក្សត្រសាកិយៈ កោលិយៈទាំង ២ ចំណែកនោះ បានត្រៀមទ័ពចេញមកក្នុងវេលាល្ងាចដោយប្រការដូច្នេះ ។

ក្នុងសម័យនោះ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងនគរសាវត្ថី ទ្រង់ទតមើលសត្វលោកក្នុងពេលទៀបភ្លឺ បានឃើញក្សត្រទាំង ២ នគរនេះ មានការត្រៀមច្បាំង ហើយលើកកងទ័ពចេញទៅយ៉ាងនេះ កាលឃើញហើយ ពិចារណាថា កាលតថាគតទៅឃាត់ ការឈ្លោះគ្នានេះនឹងស្ងប់រម្ងាប់ឬហ្ន៎ ទ្រង់ឃើញថា បើតថាគតទៅក្នុងទីនោះ នឹងបានសម្ដែងជាតក ៣ រឿង ដើម្បីរម្ងាប់នូវវិវាទ ការឈ្លោះប្រកែកនឹងរម្ងាប់ក្នុងខណៈនោះ ហើយទ្រង់នឹងសម្ដែងនូវជាតក ២ រឿងទៀត ដើម្បីឲ្យនូវការសាមគ្គីនោះ ហើយនឹងសម្ដែងអត្តទណ្ឌសូត្រតទៅ ក្សត្រដែលនៅក្នុងនគរទាំង ២ កាលបានស្ដាប់ធម្មទេសនារបស់តថាគតហើយ ក៏នឹងឲ្យព្រះរាជកុមារម្ខាង ២៥០ អង្គ តថាគតនឹងឲ្យព្រះរាជកុមារទាំងនេះបព្វជ្ជា សមាគមធំនឹងមានដោយប្រការដូច្នេះ ។ កាលសម្រេច

ព្រះហឫទ័យ ដូច្នេះហើយ ព្រឹកឡើង ទ្រង់ធ្វើនូវការជម្រះព្រះសរីរៈ ត្រាច់ទៅបិណ្ឌបាតក្នុងនគរសាវត្ថី ដល់វេលាល្ងាច ក៏ចេញអំពីព្រះគន្ធកុដិ មិនបានប្រាប់ដល់អ្នកណាមួយឡើយ ទ្រង់កាន់យកបាត្រនិងចីវរដោយព្រះអង្គឯង ទ្រង់គង់ពត់ភ្នែនក្នុងអាកាស ចន្លោះកងទ័ពទាំង ២ ចំណែក ទ្រង់បញ្ចេញព្រះរស្មីអំពីព្រះកេស ធ្វើឲ្យងងឹតទាំងថ្ងៃ ដើម្បីឲ្យកើតការរួញរាចិត្តដល់អ្នកចម្បាំងទាំងនោះ លំដាប់នោះ កាលពួកអ្នកចម្បាំងទាំងនោះកើតនូវការរារែកចិត្តហើយ ទ្រង់ក៏បង្ហាញរាងកាយឲ្យប្រាកដ ទ្រង់បញ្ចេញព្រះពុទ្ធរស្មី មានពណ៌ ៦ ប្រការ ពួកស្តេចសាកិយៈ អ្នកនគរកបិលពស្តុ កាលឃើញព្រះសាស្តា ទើបត្រិះរិះថា ញាតិដ៏ប្រសើររបស់ពួកយើង យាងមកហើយ ប្រហែលជាទ្រង់ជ្រាបថា ពួកយើងទាស់ទែងគ្នា ទើបនាំគ្នាដាក់អាវុធចុះ ដោយសម្រេចចិត្តថា កាលព្រះសាស្តាយាងមកហើយ ពួកយើងមិនអាចឲ្យអាវុធប៉ះរាងកាយរបស់អ្នកដទៃបានទេ ពួកអ្នកនគរកោលិយៈនឹងសម្លាប់ពួកយើងក៏ដោយចុះ ឯពួកអ្នកកោលិយៈក៏គិតដូច្នោះដូចគ្នា ។ លំដាប់នោះ ទើបព្រះមានព្រះភាគ យាងមកគង់ក្នុងពុទ្ធាសនៈដ៏ប្រសើរ ដែលពួកក្សត្ររៀបចំថ្វាយលើផ្នូកខ្សាច់ គួរជាទីរីករាយមួយកន្លែង ទ្រង់រុងរឿងដោយព្រះសិរីគ្មានអ្វីប្រៀប សូម្បីព្រះរាជាទាំង ២ ចំណែកនោះ ក៏នាំគ្នាថ្វាយបង្គំព្រះមានព្រះភាគហើយប្រថាប់គង់ ។

លំដាប់នោះ ព្រះសាស្តាទ្រង់ជ្រាបរឿងនេះ ក៏បានត្រាស់សួរពួកក្សត្រទាំងនោះថា បពិត្រមហារាជទាំងឡាយ ពួកទ្រង់មកទីនេះធ្វើអ្វីក្សត្រទាំង

នោះទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយមកក្នុងទីនេះ ដើម្បីមើលស៊ីងក៏មិនមែន មកដើម្បីកម្សាន្តក៏មិនមែន មកដើម្បីមើលទិដ្ឋភាពដែលគួរត្រេកអរក្នុងព្រៃព្រឹក្សាក៏មិនមែន តែមកក្នុងទីនេះ ព្រោះសង្គ្រាមកើតឡើង ព្រះសាស្តាត្រាស់ថា បពិត្រមហារាជ ពួកទ្រង់ទាស់ទែងគ្នាដោយរឿងអ្វី ក្សត្រទាំងនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រោះរឿងទឹក ព្រះសាស្តាត្រាស់ថា បពិត្រមហារាជ ទឹកមានតម្លៃប៉ុន្មាន ស្តេចទាំងនោះតបថា បពិត្រព្រះអង្គដ៏ចម្រើន មានតម្លៃតិចតួច ព្រះសាស្តាត្រាស់ថា បពិត្រមហារាជ ផែនដីមានតម្លៃប៉ុន្មាន ស្តេចទាំងនោះតបថា បពិត្រព្រះអង្គដ៏ចម្រើន មានតម្លៃកាត់ថ្លៃមិនបាន ព្រះសាស្តាត្រាស់ថា បពិត្រមហារាជ ចុះក្សត្រមានតម្លៃប៉ុន្មាន ស្តេចទាំងនោះឆ្លើយថា ក្សត្រមានតម្លៃប្រមាណមិនបានដូចគ្នា ។ ព្រះសាស្តាត្រាស់ថា បពិត្រមហារាជទាំងឡាយ ហេតុអ្វី ពួកទ្រង់ក៏ញុំាងក្សត្រទាំងឡាយដែលមានតម្លៃកាត់ថ្លៃមិនបាន ឲ្យវិនាសទៅព្រោះអាស្រ័យទឹកដែលមានតម្លៃបន្តិចបន្តួច កាលទ្រង់ត្រាស់ដូច្នេះហើយ ទើបត្រាស់ផន្ទួនជាតកថា បពិត្រមហារាជទាំងឡាយ ឈ្មោះថា វត្ថុដែលគួរពេញចិត្តក្នុងការទាស់ទែងគ្នា មិនមានឡើយ រុក្ខទេវតានិងខ្លាឃ្មុំ ចងអាឃាតគ្នា ព្រោះទាស់ទែងគ្នា ពៀរនោះក៏ជាប់តាមមកអស់កប្ប បន្ទាប់អំពីនោះ ទ្រង់ក៏ត្រាស់ទុទ្ទុភាយជាតកថា មហាបពិត្រទាំងឡាយ កើតមកជាមនុស្ស មិនគួរបែរទៅតាមហេតុដែលដល់របស់បុគ្គលដទៃ គឺមិនគួររើសយករឿងរបស់អ្នកដទៃមកគិត និងពោលឲ្យស្តាប់ ពួកសត្វចតុបាទក្នុងហិមវន្តប្បទេស ដែលមានទំហំ ៣០០០ យោជន៍

កាន់យករឿងរបស់អ្នកដទៃ នាំគ្នារត់ទៅកាន់សមុទ្ទ ព្រោះស្ដាប់ពាក្យរបស់ទន្សាយមួយ ព្រោះដូច្នោះ បុគ្គលមិនគួរកាន់យករឿងរបស់អ្នកដទៃ ។ បន្ទាប់ពីនោះ ទ្រង់លើកយកលដុកិកជាតកដោយសេចក្ដីថា បពិត្រមហារាជទាំងឡាយ ជួនកាលអ្នកដែលមានកម្លាំងតិច ក៏រកឱកាសកម្ចាត់អ្នកមានកម្លាំងច្រើនបាន ជួនកាលអ្នកមានកម្លាំងច្រើន ក៏បានឱកាសធ្វើដល់អ្នកមានកម្លាំងតិច សូម្បីចាបចៀបកប្បាសក៏គង់សម្លាប់ដំរីបាន ។ ព្រះបរមសាស្ដាត្រាស់ជាតក ៣ ដើម្បីរម្ងាប់ការទាស់ទែងគ្នាដូច្នេះហើយ ទើបត្រាស់ជាតក ២ ទៀតដើម្បីសម្ដែងសាមគ្គីធម៌ដូច្នោះទៀត ទើបទ្រង់ត្រាស់រុក្ខធម្មជាតកថា មហារាជទាំងឡាយ កាលបុគ្គលព្រមព្រៀងគ្នា បុគ្គលណា ក៏មិនអាចរកឱកាសប្រទូស្តបាន ហើយត្រាស់វដ្តកជាតកថា មហារាជទាំងឡាយ កាលហ្វូងចាបព្រមព្រៀងគ្នា នាយព្រាន ក៏មិនអាចធ្វើអន្តរាយបាន លុះហ្វូងចាបកើតជម្លោះនឹងគ្នាឡើង កាលនោះ នាយព្រានម្នាក់ក៏ទម្លាយជីវិត ចាប់ចាបទាំងនោះទៅអស់ឈ្មោះថា ការសុខសាន្តក្នុងជម្លោះមិនមានឡើយ ព្រះសាស្ដាត្រាស់ជាតក ៥ រឿងយ៉ាងនេះហើយក្នុងទីបំផុត ទើបត្រាស់អត្តទណ្ឌសូត្រ ។

ព្រះរាជាទាំងអស់ ស្ដាប់ព្រះធម្មទេសនានោះហើយ ក៏ទ្រង់ជ្រះថ្លាប្រឹក្សាគ្នាថា បើព្រះសាស្ដាមិនយាងមក ពួកយើងនឹងត្រូវសម្លាប់គ្នានឹងគ្នា រហូតឈាមហូរជាស្ទឹង ពួកយើងបានជីវិត ព្រោះអាស្រ័យព្រះសាស្ដា បើព្រះសាស្ដាទ្រង់គ្រប់គ្រងឃរាវាស រាជសម្បត្តិក្នុងមហាទ្វីបទាំង ៤ មានទ្វីបតូច ២០០០ ជាបរិវារក៏នឹងធ្លាក់ក្នុងកណ្ដាប់ដៃរបស់ទ្រង់ ទ្រង់នឹងមានព្រះរាជឱរស

ជាង ១០០០ បន្ទាប់អំពីនោះ នឹងមានក្សត្រជាបរិវារត្រាច់ទៅ តែទ្រង់លះរាជសម្បត្តិបែបនេះ ហើយយាងបព្វជ្ជា រហូតសម្រេចសម្មាសម្ពោធិញ្ញាណ តែទោះជាយ៉ាងនោះ ឥឡូវនេះ ព្រះអង្គក៏គួរមានក្សត្រជាបរិវារត្រាច់ទៅ កាលប្រឹក្សាគ្នាដូច្នេះហើយ ក្សត្រទាំង ២ នគរនោះ ក៏ថ្វាយព្រះរាជកុមារម្ខាង ២៥០ អង្គ ។ ព្រះសាស្តា ទ្រង់ឲ្យព្រះរាជកុមារទាំងនោះបព្វជ្ជា ហើយទ្រង់យាងទៅកាន់មហាវ័ន ។ ចាប់ពីស្អែកជាដើមឡើងទៅ ព្រះសាស្តាមានព្រះរាជកុមារទាំងនោះចោមរោមជាបរិវារ ទ្រង់យាងបិណ្ឌបាតក្នុងនគរទាំង ២ គឺជួនកាលក្នុងនគរកបិលពស្តុ ជួនកាលក្នុងនគរកោលិយៈ សូម្បីអ្នកនគរទាំង ២ ក៏ធ្វើសក្ការៈធំដល់ទ្រង់ ឯពួកភិក្ខុរាជកុមារទាំងនោះ បួសដោយការគោរពក្នុងព្រះបរមគ្រូមិនមែនបួសដោយពេញចិត្តរបស់ខ្លួនឡើយ ទើបកើតនូវការអផ្សុកចង់សឹក មិនតែប៉ុណ្ណោះ បុរាណទុតិយិការបស់ភិក្ខុទាំងនោះ ក៏ពោលផ្តេះផ្តង និងបញ្ជូនលិខិតទៅដឹកនាំឲ្យលោកអផ្សុកទៀត ភិក្ខុរាជកុមារទាំងនោះ រឹងរឹតតែអផ្សុកក្រៃលែងឡើង ព្រះមានព្រះភាគ ទ្រង់ពិចារណាមើល ក៏ជ្រាបថា ភិក្ខុទាំងនោះ កើតនូវការនឿយណាយឡើងហើយ ទើបទ្រង់ពិចារណាថា ភិក្ខុទាំងនេះ នៅរួមជាមួយព្រះពុទ្ធដូចតថាគត ក៏នៅតែអផ្សុក ធម្មកថាដូចម្តេចហ្ន៎ ទើបជាទីសប្បាយនៃភិក្ខុទាំងនេះ ទ្រង់ឃើញថា កុណាលធម្មទេសនាជាទីសប្បាយ លំដាប់នោះទើបទ្រង់ព្រះតម្រិះថា តថាគតនឹងនាំភិក្ខុទាំងនោះទៅកាន់ហិមវន្តប្បទេស ប្រកាសទោសនៃមាតុគ្រាមតាមពាក្យសម្តីរបស់សត្វតាវ៉ៅឈ្មោះកុណាលឲ្យភិក្ខុទាំងនោះបានស្តាប់ កម្ចាត់នូវការអផ្សុក

ចេញ និងឲ្យសោតាបត្តិមគ្គដល់ភិក្ខុទាំងនេះ ។ លុះព្រឹកឡើង ទ្រង់ស្លៀកដណ្តប់កាន់បាត្រនិងចីវរ ចូលទៅបិណ្ឌបាតក្នុងនគរកបិលពស្តុ លុះពេលបច្ឆាភត្ត ក៏យាងត្រឡប់អំពីបិណ្ឌបាត ត្រាស់ឲ្យហៅភិក្ខុទាំង ៥០០ រូបនោះមកក្នុងកាលស្រេចភត្តកិច្ចហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកធ្លាប់ឃើញហិមវន្តប្បទេសដែលជាទីស្ថានគួរជាទីត្រេកអរដែរឬ ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន មិនធ្លាប់ឃើញឡើយ ទើបត្រាស់សួរថា ពួកអ្នកត្រាច់ទៅកាន់ហិមវន្តប្បទេសដែរឬទេ កាលភិក្ខុទាំងនោះក្រាបទូលថា ខ្ញុំព្រះអង្គទាំងឡាយ មិនមានឫទ្ធិ នឹងទៅបានដូចម្តេច ព្រះសាស្តាត្រាស់ថា បើមានអ្នកណាមួយនាំពួកអ្នកទាំងឡាយទៅ តើទៅដែរឬទេ ភិក្ខុទាំងនោះក្រាបទូលថា ខ្ញុំព្រះអង្គនឹងទៅ ។

ព្រះបរមសាស្តា កាលទ្រង់នាំភិក្ខុទាំងនោះទៅដោយឫទ្ធិរបស់ទ្រង់ ទ្រង់ក៏នាំភិក្ខុទាំងនោះហោះតាមអាកាស ទៅកាន់ព្រៃហិមពាន្ត ប្រថាប់ឈរលើលម្ហ ទ្រង់ចង្អុលឲ្យមើលភ្នំ ៧ គឺភ្នំមាស ភ្នំប្រាក់ ភ្នំកែវមណី ភ្នំហរតាល ភ្នំអញ្ជន ភ្នំត្រងិល ភ្នំកែវផលិក ហើយទ្រង់ចង្អុលឲ្យមើលស្ទឹងទាំង ៥ ខ្សែ គឺគង្គា យមុនា អចិរវតី សរភូ មហី ហើយទ្រង់ចង្អុលឲ្យមើលស្រះទាំង ៧ គឺស្រះឈ្មោះកណ្ណមុណ្ឌៈ រថការ មន្ទាកិណី សីហបបាត ឆទ្ទន្ត អនោតត្តៈ កុណាល ក្នុងហិមវន្តប្បទេសដ៏គួររីករាយ ។ ភ្នំដែលបានឈ្មោះថា ហិមពាន្តមានកម្ពស់ ៥០០ យោជន៍ ទំហំ ៣០០០ យោជន៍ ព្រះសាស្តាទ្រង់ចង្អុលទីស្ថានដែលគួរត្រេកអរនេះ ត្រឹមតែជាចំណែកខ្លះនៃភ្នំហិមពាន្តនោះ ដោយ

អានុភាពរបស់ព្រះអង្គ ហើយទ្រង់បង្ហាញដល់សត្វចតុបាទជាដើមថា រាជសីហ៍ ខ្លាធំ ត្រកូលដំរីនិងសត្វជើង ២ មានតាវៅជាដើម ដែលអាស្រ័យនៅត្រង់ភ្នំហិមពាន្តនោះ ។ តែចំណែកខ្លះទៀត ទ្រង់បង្ហាញព្រៃដែលជាទីត្រេកអរ ហាក់បីដូចប្រដាប់តាក់តែងទុក មានទាំងផ្កា ផ្លែឈើ មានពណ៌ចម្រុះ ដេរដាស ដោយពួកបក្សីច្រើនប្រភេទ ទាំងផ្កាឈើក្នុងទឹក ផ្កាឈើលើគោក ក្នុងទិសខាងកើតនៃភ្នំហិមពាន្តនោះមានបទុមមាស ក្នុងទិសខាងលិចមានដុំហរតាល ។ ចាប់តាំងអំពីកាលដែលភិក្ខុទាំងនោះ ឃើញទីកន្លែងនិងវត្ថុដែលគួរត្រេកអរទាំងនេះហើយ ការត្រេកអរក្នុងជាយាក៏ស្ងប់ទៅ ។ លំដាប់នោះ ព្រះសាស្តាទ្រង់ក៏នាំភិក្ខុទាំងនោះចុះអំពីអាកាស ដែលភិក្ខុទាំងនោះចោមរោមហើយ ទ្រង់គង់លើអាសនៈមនោសិលា ដែលមានបរិមណ្ឌល ៣ យោជន៍ ក្រោមដើមរាំង ដែលមានអាយុតាំងនៅអស់កប្ប មានបរិមណ្ឌល ៧ យោជន៍ ដុះឡើងទៅលើ ៦០ យោជន៍ នៅផ្នែកខាងលិចនៃភ្នំហិមពាន្ត ទើបទ្រង់បញ្ចេញរស្មីទាំង ៦ ពណ៌ ដូចព្រះសុរិយាចាំងលើផ្ទៃមហាសមុទ្ទ ដែលរលកកំពុងឡើងចុះដូច្នោះ ហើយទ្រង់បញ្ចេញព្រះសូរសៀងដ៏ពីរោះ ត្រាស់ហៅភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ វត្ថុណាដែលពួកអ្នកមិនធ្លាប់ឃើញក្នុងភ្នំហិមពាន្តនេះ ចូរសួរតថាគតចុះ ។ ក្នុងខណៈនោះ តាវៅញី ២ ដ៏ស្រស់ស្អាត ពាំកំណាត់ឈើត្រង់ចុងទាំងសងខាង ឲ្យតាវៅឈ្មោល ដែលជាប្តីរបស់ខ្លួនទុំត្រង់កណ្តាល ហើយមានតាវៅញី ហើរខាងមុខ ៨ ខាងក្រោយ ៨ ខាងឆ្វេង ៨ ខាងស្តាំ ៨ ខាងក្រោម ៨ ខាងលើបាំងជាម្លប់ ៨ ។ ពួកតាវៅញីទាំងនោះ

ហើរហោមរោមតាវ៉ៅនោះ ទៅក្នុងអាកាស ដោយអាការយ៉ាងនេះ ភិក្ខុទាំងនោះ ឃើញហ្វូងបក្សីទាំងអស់ ទើបទូលសួរព្រះសាស្ដាថា បពិត្រព្រះអង្គដ៏ចម្រើន សត្វទាំងនេះឈ្មោះសត្វអ្វី ព្រះសាស្ដាត្រាស់តបថា ម្នាលភិក្ខុទាំងឡាយ នេះជាបុរាណវង្សរបស់តថាគត តថាគតបានរៀបចំប្រពៃណីនេះទុកក្នុងកាលមុន សត្វតាវ៉ៅទាំងឡាយ ក៏បានបម្រើតថាគតយ៉ាងនេះមកហើយដូចគ្នា តែក្នុងកាលនោះ បក្សីទាំងនេះ ជាហ្វូងបក្សីធំ គឺមានបក្សីហើរហោមរោមតថាគតដល់ទៅ ៣៥០០ ។ តែក្នុងកាលជាខាងក្រោយមក ក៏រៀវរោយចុះតាមលំដាប់ រហូតនៅសល់ត្រឹមតែដែលបានឃើញនេះ ។ ពួកភិក្ខុទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន បក្សីទាំងនេះធ្លាប់បម្រើព្រះអង្គក្នុងព្រៃបែបនេះដូចម្ដេច ។ គ្រានោះ ព្រះសាស្ដាក៏ត្រាស់ដាស់ស្មារតីពួកភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ កាលបើដូច្នោះ ពួកអ្នកទាំងឡាយ ចូរតាំងចិត្តស្ដាប់ពាក្យរបស់តថាគតចុះ ហើយទ្រង់នាំអតីតនិទានមកសម្ដែង ទើបមានព្រះពុទ្ធដីកាថា

ហេមវន្តប្រទេស ដែលគេតែងពោលយ៉ាងនេះ តែងឮយ៉ាងនេះ មានសេចក្ដីដំណាលថា បក្សីកុណាល ( តាវ៉ៅ ) មានសម្បុរដ៏វិចិត្រក្រៃលែង មានស្លាបជាគ្រឿងបិទបាំងដ៏វិចិត្រក្រៃលែង តែងនៅអាស្រ័យក្នុងដងព្រៃជាទីរីករាយ មានសភាពយ៉ាងនេះ ជាប្រទេសទ្រទ្រង់នូវធរណី ប្រកបដោយឱសថគ្រប់យ៉ាង រយោងរយានដោយចង្កោមផ្កាជាច្រើន ជាប្រទេសជាទីចរទៅមករឿយៗនៃដំរី គោ ក្របី ប្រើសមាស

ចាមរី ក្ដាន់ រមាស ខ្ទីង សីហៈ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ឆ្កែព្រៃ ខ្លារខិន គេ ឈ្លូស ខ្លាត្រី ទន្សាយ រមាំង ជាទីអាស្រ័យនៅនៃហ្វូងដំរីតូចៗ និងដំរីធំនិងមេដំរីក្នុងនាគត្រកូល ដ៏ដេរដាសជាទីអាស្រ័យនៅនៃខ្លាឃ្មុំ ស្វាសរកៈ ម្រឹគទ្រាយ ក្ដាន់ បុរិសាលុ ( យក្ខិនីមានមុខដូចសេះ ) កិន្នរ យក្ខ អារក្សទឹក ជាព្រៃ ដ៏ដេរដាសដោយពួកឈើជាច្រើនយ៉ាង គឺឈើមានផ្កាក្រពុំ ឈើមានត្រួយលាស់រហង់ សឹងដ៏ខ្មៀវខ្មារដោយហ្វូងបក្សីជាច្រើន គឺសត្វអក លលកទ្រាំង ហត្ថិលិង្គៈ ក្ងោក ទីទុយ ប៉ោលតោក ចាប កុកក្រក សម្បុកត្រពាំង ករវិក ជាប្រទេសដ៏ប្រដាប់ដោយវត្ថុជាទីត្រេកអរច្រើនយ៉ាង គឺ ថ្មនោសិលាមានពណ៌ខៀវ ដូចផ្កាអញ្ចន់ ជាតិហិង្គុល មាស ប្រាក់ មាសស្រួយ និងលោហធាតុជាច្រើនយ៉ាង ។ បក្សីតាវ៉ៅនោះឯង មានបក្សីញីចំនួន ៣៥០០ សុទ្ធតែបក្សីជំទង់ចាំបម្រើ ។ មានសេចក្ដីដំណាលថា គ្រានោះ បក្សីញីជំទង់ពីរ ពាំមែកឈើដោយចំពុះ ឲ្យបក្សីតាវ៉ៅឈ្មោលនោះទំត្រង់កណ្ដាលមែកឈើ ហើរឡើងទៅ ដោយគិតថា សូមកុំឲ្យមានសេចក្ដីលំបាកក្នុងផ្លូវឆ្ងាយ បៀតបៀនបក្សីតាវ៉ៅឈ្មោលនោះឡើយ ។ ពួកបក្សីបញ្ញាចំនួន ៥០០ ក៏ហើរពីខាងក្រោមៗ ដោយគិតថា បើបក្សីតាវ៉ៅនេះធ្លាក់ពីបង្គង យើងនឹងទទួល

បក្សីតាវ៉ៅនោះដោយស្លាបទាំងឡាយ ។ ពួកបក្សីកញ្ញាចំនួន ៥០០ ហើរអំពីខាងលើៗ ដោយគិតថា សូមកុំឲ្យកម្តៅក្តៅដល់បក្សីតាវ៉ៅឈ្មោលនោះឡើយ ។ ពួកបក្សីកញ្ញាចំនួន ៥០០ ម្ខាងៗ ហើរអមអំពីខាងទាំងពីរ ដោយគិតថា សូមកុំឲ្យត្រជាក់ ក្តៅ ស្មៅ ធូលី ខ្យល់ ឬទឹកសន្សើមប៉ះពាល់ត្រូវបក្សីតាវ៉ៅឈ្មោលនោះឡើយ ។ ពួកបក្សីកញ្ញាចំនួន ៥០០ ហើរទៅអំពីខាងមុខៗ ដោយគិតថា សូមកុំឲ្យគង្វៀលគោ គង្វៀលសត្វចិញ្ចឹម អ្នកនាំស្មៅ អ្នកនាំឧស អ្នកធ្វើការងារក្នុងព្រៃ ប្រហារនូវបក្សីតាវ៉ៅឈ្មោលនោះ ដោយកំណាត់ឈើ ដោយអំបែង ដោយដៃ ( ដោយដុំថ្ម ) ដោយដុំដី ដោយដំបង ដោយសស្ត្រាវុធ ឬដោយដុំក្រួសទាំងឡាយឡើយ សូមកុំឲ្យបក្សីតាវ៉ៅនោះ ប៉ះទង្គិចនឹងគុម្ពឈើ វល្លិ៍ ដើមឈើ មែកឈើ សសរ ថ្មក្ដុំឬពួកបក្សីមានកម្លាំងឡើយ ។ ពួកបក្សីកញ្ញាចំនួន ៥០០ ហើរអមអំពីខាងក្រោយៗនិយាយឆ្លើយឆ្លងគ្នា ដោយពាក្យស្រទន់ ផូរផង់ ពិរោះ ផ្អែមល្ហែម ដោយគិតថា សូមកុំឲ្យបក្សីតាវ៉ៅនេះ អផ្សុកនៅលើទ្រនំឡើយ ។ ពួកបក្សីកញ្ញាចំនួន ៥០០ ហើរទៅគ្រប់ទិស នាំយកផ្លែឈើផ្សេងៗ ចំឡែកជាច្រើន ដោយគិតថា សូមកុំឲ្យបក្សីតាវ៉ៅនេះ លំបាកដោយការស្រេកឃ្លានឡើយ ។ គ្រា

នោះ ពួកហ្វូងបក្សីកញ្ញាទាំងនោះ ហើរនាំបក្សីតាវៅនោះអំពីសួនច្បារទៅកាន់សួនច្បារ អំពីឧទ្យានទៅកាន់ឧទ្យាន អំពីកំពង់ស្ទឹងទៅកាន់កំពង់ស្ទឹង អំពីកំពូលភ្នំទៅកាន់កំពូលភ្នំ អំពីព្រៃស្វាយទៅកាន់ព្រៃស្វាយ អំពីព្រៃព្រីងទៅកាន់ព្រៃព្រីង អំពីព្រៃខ្នុរសម្ងទៅកាន់ព្រៃខ្នុរសម្ង អំពីព្រៃដូងទៅកាន់ព្រៃដូង ដើម្បីសេចក្តីសប្បាយរីករាយ ដោយឆាប់រហ័ស ។ គ្រានោះឯង បក្សីតាវៅនោះ ដែលពួកបក្សីកញ្ញាទាំងនោះ បោមរោមហើយ ពេញមួយថ្ងៃ ក៏បណ្តើញយ៉ាងនេះថា នៃមេចង្រៃ ហាងឯងទាំងឡាយ ចូរចៀសចេញទៅ នៃមេចង្រៃជាចោរ ជាស្រីអ្នកលេង ហិនហោច មានចិត្តស្រោល មិនធ្វើតបចំពោះឧបការគុណដែលគេធ្វើហើយ ជាអ្នករហើរហោចក្នុងកាមដូចជាខ្យល់ ហាងឯងទាំងឡាយចូរវិនាសទៅ ដូច្នេះ ។

ក្នុងគាថានោះ មានអធិប្បាយដូចតទៅនេះថា ម្នាលភិក្ខុទាំងឡាយ បានឮមកយ៉ាងនេះ បានស្តាប់មកយ៉ាងនេះថា ព្រៃនោះ ជាទីពេញទៅដោយឱសថគ្រប់ប្រភេទ មានសេចក្តីពិស្តារថា បទថា **សព្វោសធធរណីធរេ** មានអធិប្បាយថា ប្រកបដោយផែនដីដែលទ្រទ្រង់នូវឱសថទាំងឡាយ មានឫសឈើ សម្បកឈើ ស្លឹកឈើ និងផ្កាឈើជាដើម ម្យ៉ាងទៀត ជាបទេសដែលទ្រទ្រង់នូវផែនដីដែលប្រកបដោយឱសថទាំងអស់ ព្រោះថា បទេសនោះ ជាបទេសដែលទ្រទ្រង់ទុកនូវផែនដីដែលប្រកបដោយឱសថទាំងអស់ ព្រោះដូច្នោះ

ទើបពោលមកយ៉ាងនេះ និងបានឮមកយ៉ាងនេះ មានពាក្យអធិប្បាយថា ក្នុងព្រៃនោះ មានផែនដីដែលជាថ្នាំទាំងអស់ សូម្បីក្នុងការប្រកបពាក្យដ៏សេសក៏មានន័យនេះដូចគ្នា ។ បទថា **នេកបុប្ផមាល្យវិតតេ** អធិប្បាយថា ដេរដាសហើយដោយផ្កាដែលកើតឡើង ដើម្បីជាផ្លែនិងផ្កាកម្រង សម្រាប់ជាគ្រឿងប្រដាប់មិនមែនតិច ។ បទថា **រុរូ** សំដៅដល់ ពួកម្រឹគដែលមានពណ៌ដូចមាស គឺប្រើសមាស ។ បទថា **ឧទ្ធារ** សំដៅដល់ ពួកគោ ។ បទថា **វិឡារ** សំដៅយកខ្លាធំៗ ។ បទថា **នេលមណ្ឌល** បានដល់ មណ្ឌលនៃដីរំជំទង់និងកូនដីរ ។ បទថា **មហាវរាហា** សំដៅដល់ជីរំធំ អធិប្បាយថា មានត្រកូលជីរដ៏ប្រសើរ ១០ ត្រកូលជាជីរធំ មានមណ្ឌលរាបស្មើនិងហ្វូងជីរជំទង់នៅអាស្រ័យ ។ បទថា **ឥស្សមិគ** សំដៅដល់ រាជសីហ៍ខ្មៅ ។ បទថា **វាតមិគ** សំដៅដល់ ម្រឹគស្មាន់ដែលមានរាងកាយធំៗ ។ បទថា **បសទមិគ** សំដៅដល់ ម្រឹគដែលស្អាត ។ បទថា **បុរិសាលុ** សំដៅដល់ យក្ខិនីដែលមានមុខដូចសេះ ។ បទថា **កឹបុរិស** បានដល់ ពួកកិន្នរច្រើនប្រភេទ មានទេវកិន្នរ ចន្ទកិន្នរ ទុមកិន្នរ គឺកិន្នរលើដើមឈើ ទណ្ឌមាណវកកិន្នរ ( កិន្នរដែលមានមុខដូចមាណព ) កោន្តិសកុណកិន្នរ ( កិន្នរដែលមានសំឡេងដូចសត្វក្រៀល ) និងកិន្នរមានសំពត់សំយុងត្រង់ត្រចៀកជាដើម ។ បទថា **អមជ្ឈរ-មញ្ញរធរបហដ្ឋបុប្ផផុសិតគ្គានេកទានបគណាវិតតេ** អធិប្បាយថា ដេរដាសដោយពួកឈើជាច្រើន សុទ្ធតែទ្រទ្រង់ទុកនូវផ្កាក្រពុំនិងត្រួយ មានផ្ការីកល្អហើយ រហូតដល់ចុង ។ បក្សីហត្ថីលិង្គៈ ឈ្មោះថា វារណៈ បក្សីទាំងនេះ

ជួនកាល ហៅថា ចេលាវក: ក៏មាន ។ បទថា **ហេមកណក** សំដៅដល់ មាស ពីរយ៉ាង អធិប្បាយថា ជាបទេសដែលប្រដាប់ដោយធាតុច្រើនយ៉ាងប្រភេទ មានអញ្ជ័នជាដើម និងគំនរនៃធាតុមានពណ៌ជាច្រើន ។ បទថា **ភោ** នេះ ជាពាក្យរាក់ទាក់ដោយធម៌ ។ បទថា **ចិត្តោ** បានដល់ ស្អាតតាំងពីចំពុះ រហូតដល់ខាងក្រោមនៃពោះ ។ បទថា **អឌ្ឍុឌ្ឍានិ** បានដល់ ៤ ពាន់ខ្វះ ៥ រយ ដោយអត្ថថា ៣៥០០ នោះឯង ។ បទថា **អទ្ធានបរិយាយបថេ** បានដល់ ផ្លូវទៅជាផ្លូវឆ្ងាយ ។ បទថា **ឧព្វាហេថ** បានដល់ បៀតបៀន ឬសង្កត់សង្កិន ។ បទថា **ឧបប្ផុសិ** អធិប្បាយថា រងាជាដើមកុំចូលទៅប៉ះខ្លួនឡើយ ។ បទថា **បហារំ អទំសុ** នេះ បណ្ឌិតគប្បីជ្រាបអត្ថថា ក្មេងឃ្វាលគោជាដើម កុំបីគប់ស្តេចបក្សីនោះឡើយ ។ បទថា **សង្ឃាមេសិ** បានដល់ ស្តេចបក្សីនោះ កុំពាល់ត្រូវគុម្ពឈើជាដើមឡើយ ។ បទថា **សណ្ហាហិ** បានដល់ ស្រទន់ ។ បទថា **សខិលាហិ** បានដល់ គួរស្រឡាញ់ ។ បទថា **មញ្ជូហិ** បានដល់ មិនគ្រោតគ្រាត ។ បទថា **មធុរាហិ** សំដៅដល់ វាចាដែលបន្លឺដោយសំឡេងដ៏ពីរោះ ។ បទថា **សមុទាចរន្តិយោ** បានដល់ បម្រើដោយអំណាចការច្រៀងរាំជាដើម ។ បទថា **អនេករុក្ខវិវិធវិកតិផលំ** សំដៅដល់ ផ្លែឈើមានរសផ្សេងៗ ច្រើនប្រភេទ ។ បទថា **អាភាមេនេវ អារាមំ** អធិប្បាយថា បណ្តាព្រៃផ្កាជាដើម បក្សីញីទាំងនោះ បាននាំស្តេចបក្សីចូលទៅកាន់ព្រៃនេះ អំពីព្រៃឯណាទីមួយ សូម្បីក្នុងបទថា **ឧយ្យានំ** ជាដើម ក៏មានន័យដូចគ្នា ។ បទថា **នាឡិកេរសញ្ញារិយេនេវ** សំដៅដល់ ចម្ការដូងដទៃអំពីចម្ការដូងនោះ ។

បទថា **អភិសម្ភោន្តិ** សេចក្ដីថា បក្សីទាំងនោះ នាំស្ដេចបក្សីចូលទៅយ៉ាងនេះ គឺចូលដល់ទីនោះដោយរួសរាន់ ដើម្បីឲ្យត្រេកអរដោយឆាប់រហ័ស ។ បទថា **ទិវសំ បរិព្យូឡ្ហា** អធិប្បាយថា បម្រើទាំងថ្ងៃទាំងយប់ ។ បទថា **អបសាទេតិ** អធិប្បាយថា បានឮថា បក្សីទាំងនោះ បម្រើស្ដេចបក្សីនោះអស់ថ្ងៃយ៉ាងនេះ ឲ្យចុះអំពីដើមឈើដែលជាលំនៅ ទំត្រង់មែកឈើជាដើម ប្រាថ្នាថា ធ្វើម្ដេចហ្ន៎ អញគប្បីស្ដាប់ពាក្យពីរោះខ្លះ ទំដោយគិតថា ក្នុងពេលដែលស្ដេចឲ្យត្រឡប់ ពួកយើងនឹងទៅកាន់លំនៅរបស់ខ្លួន ហើយស្នាក់នៅឯស្ដេចតាវ៉ៅ កាលបញ្ជូនបក្សីញីទាំងនោះត្រឡប់ទៅ បានពោលពាក្យអាក្រក់ ដោយពាក្យថា មេវិនាសជាដើម ។ បទថា **ឧស្សជ** សេចក្ដីថា ចូរហែងត្រឡប់ទៅ ។ បទថា **វិឧស្សជ** សេចក្ដីថា ពួកហែងចូរត្រឡប់ទៅដោយប្រការទាំងពួង ។ អធិប្បាយថា ស្ដេចបក្សីពោលថា **ចោរិយោ** ព្រោះធ្វើទ្រព្យនិងស្រូវជាដើមក្នុងផ្ទះឲ្យវិនាស ហៅថា **ធុត្តិយោ** ព្រោះមានមាយាច្រើន ហៅថា **អសតិយោ** ព្រោះមិនមានស្មារតី ហៅថា **លហុចិត្តាយោ** ព្រោះមានចិត្តឡេះឡោះ ហៅថា **កតស្ស អប្បដិការិកាយោ** ព្រោះទម្លាយមិត្តដោយការធ្វើសេចក្ដីវិនាសឲ្យ ។

ព្រះមានព្រះភាគ កាលត្រាស់យ៉ាងនេះហើយ ទើបត្រាស់បន្តថា ម្នាលភិក្ខុទាំងឡាយ អម្បាលតថាគតជាសត្វតិរច្ឆាន ក៏គង់ដឹងថា ស្រីទាំងឡាយជាអកតញ្ញូ ជាអ្នកមានមាយាច្រើន ជាអ្នកប្រព្រឹត្តអនាចារ ជាអ្នកទ្រុស្តសីល ដោយប្រការដូច្នេះ ក្នុងកាលនោះ តថាគតមិនបាននៅក្នុងអំណាចរបស់ស្រី

ទាំងនោះ ឲ្យស្រីទាំងនោះនៅក្នុងអំណាចរបស់ខ្លួន ទ្រង់នាំនូវការអផ្សុករបស់ភិក្ខុទាំងនោះចេញទៅ ដោយធម្មកថាយ៉ាងនេះហើយ ទ្រង់ក៏នៅស្ងៀម ក្នុងខណៈនោះ មានតាវៅញី ២ ឲ្យបក្សីជាប្ដីទំលើកំណាត់ឈើត្រង់កណ្ដាល ហើយពាំកំណាត់ឈើសងខាងហើរមក ក្នុងចំណែកខាងក្រោមជាដើម ក៏មានបក្សីប្រចាំបួនៗ បានមកដល់បទេសនោះ ភិក្ខុទាំងនោះ ឃើញបក្សីទាំងនោះ បានទូលសួរព្រះសាស្ដា ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលមុន មានតាវៅសមួយ ឈ្មោះបុណ្ណមុខៈ ជាសម្លាញ់របស់យើង នេះជាវង្សរបស់តាវៅបុណ្ណមុខៈនោះ កាលភិក្ខុទាំងនោះទូលសួរដោយន័យមុននោះឯង ទើបត្រាស់ថា

> មានសេចក្ដីជំណាលថា ក្នុងភាគទិសខាងកើតនៃស្ដេចភ្នំហិម
> វន្តនោះឯង មានស៊ីងហូរនាំយកនូវស្មៅខៀវខ្ចី អំពីភ្នំដែល
> មានទឹកដ៏ល្អសុខុមថ្លាឈ្វេង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សុសុខុមា** អធិប្បាយថា ញកភ្នំដែលល្អិតសុខុមល្អព្រោះមានទឹកថ្លាស្អាតល្អ ជាប្រកតនៃស៊ីងទាំងនេះ ព្រោះហេតុនោះ ទើបស៊ីងទាំងនោះ បានឈ្មោះថា **សុសុខុមសុនិបុណា** ។ ស៊ីងដែលហូរចេញភ្នំហិមពាន្តនោះ មានពណ៌ខៀវ ព្រោះមានជំនន់ទឹកលាយដោយស្មៅពណ៌ខៀវ ហូរចេញមកតាមស្រះឈ្មោះកុណាល ទើបស៊ីងទាំងឡាយមានញកភ្នំដ៏ល្អិតសុខុមជាដែនកើត មានពណ៌ខៀវហូរចេញទៅបែបនេះ រមែងហូរទៅក្នុងទីណា ។ ឥឡូវនេះ ព្រះសាស្ដាកាលទ្រង់ពណ៌នានូវផ្កាទាំងឡាយ ក្នុងស្រះ

ឈ្មោះកុណាលដែលស៊ីងទាំងនោះហូរមក ទើបត្រាស់ថា

មានសេចក្ដីដំណាលថា តាវៅស**ឈ្មោះបុណ្ណមុខៈមានសំឡេង ដ៏ពីរោះគ្រលួច មានភ្នែកក្រឡែត ដូចភ្នែកអ្នកស្រវឹង តែង អាស្រ័យនៅ ក្នុងដងព្រៃជាទីសប្បាយរីករាយ មានសភាព យ៉ាងនេះ គឺប្រទេសជាទីពេញចិត្តរីករាយ ដោយផ្កាឧប្បល ឈូកក្រហម កុមុទ ឈូកស ឈូកមានស្រទាប់ជាច្រើន ចន្ទុលណី មានក្លិនក្រអូបឈ្ងុយឈ្ងប់ ទើបនឹងដុះឡើងថ្មីៗ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧប្បលំ** សំដៅដល់ ផ្កាឧប្បលខៀវ ។ បទ ថា **ធេឡិនំ** សំដៅដល់ ឈូកស ។ បទថា **សតបត្តំ** បានដល់ មានស្រទាប់ ១០០ បរិបូណ៌ ។ បទថា **សម្បតិ** បានដល់ ផ្កាទាំងនេះ ដុះឡើងក្នុងឥឡូវ នេះ គឺកើតឡើងថ្មីៗ ។ ភ្នំហិមពាន្តនោះ ប្រកបដោយបទេសដែលមានក្លិន ក្រអូបនិងក្លិនជាទីត្រេកអរនៃចិត្តនិងជាទីរីករាយ ព្រោះអាចចងចិត្តទុកបាន ។

ឥឡូវនេះ ព្រះសាស្ដា កាលទ្រង់ពណ៌នាដល់ដើមឈើជាដើមក្នុងស្រះ នោះ ទើបត្រាស់គាថាដូចតទៅនេះថា

ជាព្រៃដេរដាសដោយកុរវកព្រឹក្ស រាំងអន្ទក់ កេតកព្រឹក្ស វេទិសព្រឹក្ស ដើមព្រៃ ដើមបុន្នាគ ពកុល ទ្រមួច ទ្រមូង ខ្ទម្ពា ធ្នង់ រាំងភ្នំ ស្រឡៅ ចំបក់ អាសោកព្រឹក្ស ខ្ទឹង ស្មាច់ លោទ្ធ និងចន្ទន៍ក្រហម ជាព្រៃញាតិស្បាត ដោយដើមឈើ

ខ្មៅ បិយង្គុ មានពណ៌ក្រហម ទេពទារុ ចេកមានគ្រាប់ ជាព្រៃទ្រទ្រង់នូវដើមថ្នាន់ ខ្ទឹងគង់ ព្រួស ម៉ៃសាក់ កណិការ ដើមច្បារ ដើមប្រមោយដំរី ដើមល្ហុសផ្អុង ដើមចារ ដើមយុថ្កា និងចង្កោមផ្កាម្លិះព្រៃ ក្តាំងនា ចម្បា ចំប៉ី នួនស្រី ជាព្រៃ ដ៏ដេរដាសដោយម្លិះរួត ចេកទេស ប្រទៀង ដើមទ្រាំង ក្រស្នា ស្បូវភ្លាំង និងគុម្ពឈើជាពួកៗ ជាប្រទេសដ៏ប្រដាប់ដោយឈើដ៏ដេរដាស គឺដើមរំដួល និងវល្លិ៍មានផ្កាដ៏ល្អ ជាព្រៃឮសូរសំរែកនៃសត្វ ហង្ស ទុង ប្រវឹក ក្អែកទឹក ជាទីដែលពួកវិទ្យាធរសមណៈ និងតាបសឥសីស័ក្តិសិទ្ធនៅអាស្រ័យ ជាប្រទេសដែលនរជន ទេវតា យក្ខ អារក្សទឹក អសុរ គន្ធព្វ និងកិន្នរអាស្រ័យនៅជាច្រើន ។ មានសេចក្តីដំណាលថា សត្វតាវ៉ៅស ឈ្មោះបុណ្ណមុខៈនោះឯង មានបក្សីកញ្ញាចំនួន ៣៥០ ជាអ្នកបម្រើ ។ មានសេចក្តីដំណាលថា គ្រានោះឯង មានបក្សីកញ្ញាពីរ ពាំមែកឈើដោយមាត់ហើយឲ្យសត្វតាវ៉ៅស ឈ្មោះបុណ្ណមុខៈនោះ ទំត្រង់កណ្តាលហើរទៅដោយគិតថា កុំឲ្យមានសេចក្តីលំបាកក្នុងផ្លូវឆ្ងាយ ប៉ះពាល់តាវ៉ៅស ឈ្មោះបុណ្ណមុខៈនោះឡើយ ។ ពួកបក្សីកញ្ញាចំនួន ៥០ ក៏ហើរពីខាងក្រោម ៗ ដោយគិតថា បើតាវ៉ៅសឈ្មោះបុណ្ណមុខៈនេះ នឹងធ្លាក់អំពីបង្គង ពួកយើងនឹង

ទទួលតាពៅសនោះ ដោយស្លាបទាំងឡាយ ។ ពួកបក្សីកញ្ញា ចំនួន ៥០ ក៏ហើរអំពីខាងលើ ៗ ដោយគិតថា សូមកុំឲ្យកម្តៅក្តៅដល់តាពៅសឈ្មោះ បុណ្ណមុខៈ នោះឡើយ ។ ពួកបក្សីកញ្ញាចំនួន ៥០ ( ម្ខាង ) ក៏ហើរអមអំពីខាងទាំងពីរ ដោយគិតថា សូមកុំឲ្យត្រជាក់ ក្តៅ ស្មៅ ធូលី ខ្យល់ឬទឹកសន្សើម ប៉ះពាល់ត្រូវតាពៅសឈ្មោះបុណ្ណមុខៈនោះឡើយ ។ ពួកបក្សីកញ្ញាចំនួន ៥០ ហើរទៅអំពីខាងមុខៗ ដោយគិតថា សូមកុំឲ្យគង្វៀលគោ គង្វៀលសត្វចិញ្ចឹម អ្នកនាំស្មៅ អ្នកនាំឧស អ្នកធ្វើការងារក្នុងព្រៃ ប្រហារស្តេចសត្វតាពៅសឈ្មោះបុណ្ណមុខៈនោះ ដោយកំណាត់ឈើ ដោយអំបែង ដោយដៃ ( ដោយដុំថ្ម ) ដោយដុំដី ដោយដំបង ដោយសស្ត្រាវុធ ដោយដុំក្រួសទាំងឡាយ សូមកុំឲ្យតាពៅស ឈ្មោះបុណ្ណមុខៈនេះ ប៉ះទង្គិចនឹងគុម្ពឈើ វល្លិ ដើមឈើ មែកឈើ សសរ ដុំថ្មភ្នំ ឬក៏ពួកបក្សីមានកម្លាំងឡើយ ។ ពួកបក្សីកញ្ញាចំនួន ៥០ ហើរអំពីខាងក្រោយៗ និយាយឆ្លើយឆ្លងគ្នា ដោយពាក្យដ៏ស្រទន់ ផូរផង់ ពិរោះ ផ្អែមល្ហែម ដោយគិតថា សូមកុំឲ្យតាពៅសឈ្មោះបុណ្ណមុខៈ អផ្សុកលើទ្រនំឡើយ ។ ពួកបក្សីកញ្ញាចំនួន ៥០ ហើរទៅគ្រប់ទិស នាំយកផ្លែឈើផ្សេងៗ ចំឡែកជាច្រើនយ៉ាង ដោយគិតថា សូមកុំឲ្យតាពៅសឈ្មោះ

បុណ្ណមុខៈនេះ លំបាកដោយការស្រេកឃ្លានឡើយ ។ គ្រានោះ ពួកហ្វូងបក្សីកញ្ញាទាំងនោះ ហើរនាំតាវៅសឈ្មោះបុណ្ណមុខៈ អំពីសួនច្បារទៅកាន់សួនច្បារ អំពីឧទ្យានទៅកាន់ឧទ្យាន អំពីកំពង់ស្ទឹងទៅកាន់កំពុងស្ទឹង អំពីកំពូលភ្នំទៅកាន់កំពូលភ្នំ អំពីព្រៃស្វាយទៅកាន់ព្រៃស្វាយ អំពីព្រៃព្រីងទៅកាន់ព្រៃព្រីង អំពីព្រៃខ្នុរសម្ល ទៅកាន់ព្រៃខ្នុរសម្ល អំពីព្រៃដូងទៅកាន់ព្រៃដូង ដើម្បីសេចក្តីសប្បាយរីករាយដោយឆាប់រហ័ស ។ គ្រានោះឯង តាវៅសឈ្មោះបុណ្ណមុខៈ ដែលពួកបក្សីកញ្ញាទាំងនោះបម្រើធូរអស់ថ្ងៃមួយ សរសើរយ៉ាងនេះថា ម្នាលនាងទាំងឡាយប្រពៃណាស់ ៗ នាងទាំងឡាយបម្រើប្តីដោយហេតុណា ម្នាលនាងទាំងឡាយ ហេតុនោះឯងជាកិច្ចដ៏សមគួរ ដល់នាងទាំងឡាយ ជាធីតាក្នុងត្រកូលហើយ ។

គ្រានោះឯង តាវៅសឈ្មោះ បុណ្ណមុខៈ ចូលទៅរកកុណាលសកុណៈ ( តាវៅខ្មៅ ) ។ បក្សីកញ្ញាជាអ្នកបម្រើកុណាលសកុណៈ បានឃើញតាវៅសឈ្មោះបុណ្ណមុខៈនោះមកពីចម្ងាយ លុះឃើញហើយ នាំគ្នាចូលទៅរកតាវៅសឈ្មោះបុណ្ណមុខៈ លុះចូលទៅដល់ហើយ និយាយពាក្យនេះនឹងតាវៅសឈ្មោះបុណ្ណមុខៈនោះថា បពិត្របុណ្ណមុខៈសម្លាញ់

កុណាលសកុណៈនេះ អាក្រក់ក្រៃលែង មានសំដីអាក្រក់ក្រៃលែង ពួកយើងសូមពឹងផ្អែកនូវលោក ក្រែងបានវាចាជាទីស្រឡាញ់ ( អំពីកុណាលៈ ) ។ តាវៅសឆ្លើយតបថា ឱប្អូនស្រីទាំងឡាយ យ៉ាងនោះឬ ហើយក៏ចូលទៅរកកុណាលសុកណៈ លុះចូលទៅដល់ហើយ ក៏និយាយសំណេះសំណាលជាមួយនឹងកុណាលសកុណៈ ហើយទំក្នុងទីដ៏សមគួរ ។ លុះតាវៅសឈ្មោះបុណ្ណមុខៈ ទំក្នុងទីដ៏សមគួរ ហើយនិយាយពាក្យនេះនឹងកុណាលសកុណៈនោះថា នែកុណាលសម្លាញ់ ហេតុអ្វី អ្នកប្រតិបត្តិខុសចំពោះតាវៅញី ដែលមានជាតិល្អ ជាធីតាក្នុងត្រកូល ជាអ្នកប្រតិបត្តិល្អ នែកុណាលៈសម្លាញ់ ឮថា អ្នកគួរនិយាយសំដីជាទីពេញចិត្តទៅរកពួកតាវៅញី សូម្បីនិយាយសំដីមិនជាទីគាប់ចិត្ត នឹងបាច់និយាយថ្វីដល់ពួកតាវៅញី ជាសត្វនិយាយសំដីជាទីពេញចិត្ត ។ កាលបើតាវៅសនិយាយ យ៉ាងនេះហើយ កុណាលសកុណៈ ក៏បណ្តេញតាវៅសឈ្មោះ បុណ្ណមុខៈ នោះថា នែសម្លាញ់ជាសត្វអាក្រក់ចង្រៃ អ្នកចូរចៀសចេញ នែសម្លាញ់ជាសត្វអាក្រក់ចង្រៃ អ្នកចូរវិនាសទៅ នរណាឡើយជាអ្នកឈ្លាសវៃជាងអ្នកជាអ្នកចាញ់ស្រី ។ ចំណែកខាងតាវៅស ឈ្មោះបុណ្ណមុខៈ ត្រូវកុណាលសកុណៈ បណ្តេញយ៉ាងនេះហើយ

ក៏ត្រឡប់មកពីទីនោះវិញ ។

គ្រានោះឯង លុះសម័យខាងក្រោយមក កន្លងទៅមិនយូរប៉ុន្មាន តាវៀសឈ្មោះបុណ្ណមុខៈ មានជំងឺជាទម្ងន់ ។ មានវេទនាយ៉ាងខ្លាំង គឺរោគធ្លាក់ឈាម រៀបដល់នូវមរណៈ គ្រានោះ ពួកបក្សីកញ្ញា ជាអ្នកបម្រើតាវៀសឈ្មោះ បុណ្ណមុខៈ មានសេចក្តីត្រិះរិះយ៉ាងនេះថា តាវៀសឈ្មោះ បុណ្ណមុខៈនេះ មានជំងឺជាខ្លាំង ធ្វើដូចម្តេច លោកនឹងបានសះស្បើយ ចាកជំងឺនេះ ។ ពួកបក្សីកញ្ញាបោះបង់តាវៀសនោះ ឲ្យនៅតែម្នាក់ឯង មិនឲ្យមានគ្នាជាគម្រប់ពីរ ហើយនាំគ្នាចូលទៅរកកុណាលសកុណៈ កុណាលសកុណៈនោះ បានឃើញពួកបក្សីកញ្ញាទាំងនោះ កំពុងមកពីចម្ងាយ លុះឃើញហើយ និយាយពាក្យនេះនឹងពួកបក្សីកញ្ញានោះថា នែ មេចង្រៃរាល់គ្នា ចុះប្តីរបស់ហាងឯងទៅក្នុងទីណា ។ ពួកបក្សីកញ្ញាទាំងនោះតបថា បពិត្រកុណាលៈជាម្ចាស់ តាវៀសឈ្មោះបុណ្ណមុខៈ មានជំងឺជាខ្លាំង ធ្វើដូចម្តេចលោកនឹងបានសះស្បើយ ចាកជំងឺនោះ ។ កាលបើពួកបក្សីកញ្ញាឆ្លើយតបយ៉ាងនេះហើយ កុណាលសកុណៈ ក៏បណ្តេញពួកបក្សីកញ្ញាទាំងនោះយ៉ាងនេះថា នែពួកមេចង្រៃ ហាងឯងចូរចៀសចេញទៅ នែមេចង្រៃ ជាចោរ ជាស្រីអ្នកលេង ហិនហោច មានចិត្តស្រាល

មិនធ្វើតបចំពោះឧបការគុណដែលគេធ្វើហើយ ជាអ្នករហើរហោចក្នុងកាម ដូចជាខ្យល់ ហនឯងទាំងឡាយ ចូរវិនាសទៅ លុះពោលដូច្នេះហើយ ក៏ចូលទៅរកតាវៅសឈ្មោះបុណ្ណមុខៈ លុះចូលទៅដល់ហើយ ទើបនិយាយពាក្យនេះនឹងតាវៅសឈ្មោះបុណ្ណមុខៈនោះថា នែបុណ្ណមុខៈសម្លាញ់ ម្តេចទៅហ៎ ។ តាវៅសឆ្លើយថា ឱកុណាលៈសម្លាញ់ ។ គ្រានោះ កុណាលសកុណៈ ជួយគ្រាហ៍តាវៅសឈ្មោះបុណ្ណមុខៈនោះ ដោយស្លាបទាំងឡាយផង ដោយចំពុះផង ហើយក្រោកឡើង ទើបឲ្យផឹកថ្នាំផ្សេងៗ ។ គ្រានោះ ជំងឺរបស់តាវៅសឈ្មោះបុណ្ណមុខៈនោះ ក៏ជាសះស្បើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បិយក** បានដល់ ផ្កាឈើដែលមានពណ៌ស ។ **ហ** អក្ខរៈ ក្នុងពាក្យថា **ហាសន** នោះ ជាបទសន្ធិ ។ សេចក្តីពិតជា **អសន** នោះឯង ។ បទថា **តិរិដិ** សំដៅដល់ រុក្ខជាតិមួយប្រភេទ ។ បទថា **ចន្ទន** សំដៅដល់ ដើមចន្ទន៍ក្រហម ។ បទថា **ឱយវនេ** បានដល់ ក្នុងព្រៃដែលប្រកបដោយជួររបស់ដើមឈើទាំងនេះ ។ បទថា **ទេវទារុកចោចគហនេ** សំដៅដល់ ព្រៃដែលមានដើមទេពទារូ និងដើមចេកទាំងឡាយ ។ បទថា **កច្ចិការ** បានដល់ រុក្ខជាតិម្យ៉ាង គឺដើមម៉ៃសាក់ ។ បទថា **កណិការ** សំដៅដល់ ដើមកណិការដែលជាឈើមានផ្កាធំ ។ បទថា **កណ្ណវេរ** សំដៅដល់ ដើមកណិការមានផ្កាល្អិតៗ ។ បទថា **កឹសុក** បានដល់ ដើមចារ ឬ

ដើមរាជព្រឹក្សក៏បាន ។ បទថា **យោធិក** បានដល់ ដើមយុថ្កាក៏បាន ។ បទថា **មល្លិកមនង្គណាមនវដ្ឋកណ្ហិស្សុរចិរកគិនិមាលមាល្យធរេ** អធិប្បាយថា ទ្រទ្រង់ទុកនូវផ្កាទាំងឡាយ មានផ្កាម្លិះព្រៃ ផ្កាកែវ ដើមឈើដែលមិនមានទោស ដើមប្រេស ដើមឈើដែលល្អ ដើមក្ដៅនាង សឹងក្រងជាមាល័យបាន ។ បទថា **ធនុតក្ការិ** សំដៅដល់ ដើមប្រទៀងក៏បាន ។ បទថា **តាលិស** សំដៅដល់ ទាំងដើមទាំងស្លឹករបស់ដើមទ្រាំង ។ បទថា **គច្ឆវិតតេ** សំដៅដល់ គុម្ពឈើដែលកើតក្នុងទឹក និងគុម្ពឈើដែលកើតលើភ្នំ ដេរដាសទៅដោយផ្កាម្លិះជាដើម ។ បទថា **សំកុសុមិតលតា** សំដៅដល់ ប្រទេសដែលដេរដាស និងប្រដាប់ដោយពណ៌នៃផ្កាច្រើនប្រភេទ មានឈើផ្កាជាដើមនិងវល្លិផ្សេងៗ ដែលដុះឡើងជាគុម្ពយ៉ាងល្អក្នុងទីនោះៗ ។ បទថា **គណាធិវុត្ថេ** អធិប្បាយថា មានពួកវិជ្ជាធរជាដើមស្ថិតនៅក្នុងទីនោះ ។ បទថា **បុណ្ណមុខោ** បានដល់ សត្វដែលបានឈ្មោះថាបុណ្ណមុខៈ ព្រោះមានមុខពេញ និងបានឈ្មោះថា **បុស្សកោកិលោ** ព្រោះបក្សដែទៃប៉ះពាល់បាន ។ បទថា **វិលាសិតនយនោ** បានដល់ មានភ្នែកវេទៅវេមក ។ បទថា **មត្តក្ខោ** អធិប្បាយថា មានភ្នែកក្រហម ដូចភ្នែកនៃមនុស្សស្រវឹង ឬមានភ្នែកធំ ។

បទថា **ភគិនិយោ** បានដល់ ប្អូនស្រីទាំងឡាយ ជាពាក្យហៅដោយវោហារដ៏ប្រសើរ ។ បទថា **បរិចរេយ្យាថ** បានដល់ គប្បីទទួលបម្រើអស់ថ្ងៃនិងយប់ បក្សីបុណ្ណមុខៈពោលដោយពាក្យជាទីស្រឡាញ់ ហើយក៏បញ្ជូនបក្សីញីទាំងអស់ទៅ ដោយប្រការដូច្នេះ ក្នុងកាលខ្លះ បក្សីកុណាលមួយអន្ទើ

ដោយបរិវារ បានមករកបក្សីបុណ្ណមុខៈ ជួនកាលបក្សីបុណ្ណមុខៈ ក៏ទៅឲ្យរកបក្សីកុណាល ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **អថ ១លុភោ...** ដូច្នេះជាដើម ។ បទថា **សម្ម** សំដៅយក សម្លាញ់ដែលស្រឡាញ់គ្នា ។ បទថា **អាគម្ម** បានដល់ អាស្រ័យ ចូលទៅអាស្រ័យ ប្រាថ្នានូវប្រយោជន៍ ។ បទថា **លភេយ្យាម** អធិប្បាយថា ពួកយើងគប្បីបានដោយពាក្យដែលជាទីស្រឡាញ់អំពីសម្នាក់បក្សីកុណាល ។ បទថា **អបេ្យវ ឆាម** អធិប្បាយថា គប្បីបានខ្លះពិត អញនឹងសាកល្បងនិយាយនឹងបក្សីកុណាលសាកមើល ។ បទថា **សុជាតានំ** បានដល់ មានជាតិរួមគ្នា ។

បទថា **ឆស្សុ** បានដល់ ចូរប្រាសទៅ ។ បទថា **ជម្ម** បានដល់ អាក្រក់ ។ បទថា **វិយត្តោ** បានដល់ អ្នកដទៃណាដែលឈ្លាសដូចឯងនឹងមាននោះ ។ បទថា **ជាយាជិនេន** សេចក្តីថា ឈ្នះហើយនូវប្រពន្ធ ម្យ៉ាងទៀត បាលីជា **ជាយាជិតេន** ដូច្នេះក៏មាន អធិប្បាយថា បក្សីកុណាលបានបៀតបៀនបក្សីបុណ្ណមុខៈដោយសម្តីថា ឈ្មោះថា នរណាឡើយ ជាអ្នកឈ្លាសវៃជាងឯងដែលជាអ្នកចាញ់ស្រី ដូច្នេះ ដើម្បីកុំឲ្យពោលពាក្យនោះតទៅទៀត ។ បទថា **តតោយេវ** អធិប្បាយថា បក្សីបុណ្ណមុខគិតថា បក្សីកុណាលខឹងនឹងអញហើយ ទើបត្រឡប់ទៅអំពីទីនោះ មួយអន្លើដោយបរិវារ ទៅកាន់លំនៅរបស់ខ្លួននោះឯង ។ បទថា **អបេ្យវ ឆាម** នេះ ជាពាក្យសម្តែងដល់ការត្រិះរិះដោយការសង្ស័យ ពួកបក្សីញីទាំងនោះគិតគ្នាយ៉ាងនេះថា បក្សីបុណ្ណមុខៈនេះគប្បីជាអំពីជំងឺ ឬមិនជាក៏មិនដឹង ដូច្នេះ ទើបនាំគ្នាលះបក្សីបុណ្ណមុខៈនោះ

ហើយចៀសចេញទៅ ។ បទថា **តុម្ហំ** បានដល់ ប្តីរបស់ពួកនាងទាំងឡាយ ។ បទថា **អបេវ្ស ឆាម** អធិប្បាយថា ពួកបក្សីញីទាំងនោះ ពោលថា ស្តេចបក្សីបុណ្ណមុខៈនេះ ប្រាសចាកជំងឺ ឬមិនជាទេក៏មិនដឹង ក្នុងកាលដែលពួកខ្ញុំទៅហើយ គេនឹងស្លាប់ពិត ដ្បិតថា ពួកខ្ញុំដឹងថា បក្សីបុណ្ណមុខៈនេះនឹងស្លាប់ក្នុងឥឡូវនេះ ទើបនាំគ្នាមក ដើម្បីជាបាទបរិចារិការបស់លោក ។ បទថា **តេនុបសង្កមិ** អធិប្បាយថា ស្តេចបក្សីកុណាលគិតថា ពួកបក្សីញីទាំងនេះគិតថា ពួកយើងនឹងនាំគ្នាមកក្នុងកាលដែលប្តីស្លាប់ហើយ ក៏គួរឲ្យស្អប់ ទើបនាំគ្នាលះបង់ស្តេចបក្សីបុណ្ណមុខៈនោះ ហើយនាំគ្នាមក ឯអញនឹងទៅរៀបចំថ្នាំផ្សេងៗ មានផ្កានិងផ្លែឈើជាដើម ធ្វើសម្លាញ់របស់អញឲ្យជារោគ កាលគិតដូច្នេះហើយ មហាសត្វដែលមានកម្លាំងដូចដំរីសា ក៏ហើរទៅក្នុងអាកាស ចូលទៅរកបក្សីបុណ្ណមុខៈត្រង់ចំណែកដែលបក្សីនោះនៅ ។ បទថា **ហំ** ជានិបាត បក្សីកុណាល កាលនឹងសួរថា ឯងនៅមានជីវិតឬសម្លាញ់ ទើបបានពោលយ៉ាងនេះ សូម្បីបក្សីបុណ្ណមុខៈក៏ពោលនឹងបក្សីកុណាលថា អើ អញនៅមានជីវិតនៅឡើយទេ ។ បទថា **ចាយាបេសិ** បានដល់ ឲ្យផឹកថ្នាំច្រើនមុខ ។ បទថា **បដិប្បស្សម្ភិ** បានដល់ រោគារបស់បក្សីបុណ្ណមុខៈ ក៏ជាសះស្បើយក្នុងខណៈនោះ ។

តាវៅញីទាំងឡាយនោះ លុះស្តេចបក្សីបុណ្ណមុខៈជាសះស្បើយហើយ ក៏នាំគ្នាមក ស្តេចកុណាលរកផ្លែឈើតូចធំមកឲ្យបុណ្ណមុខៈបរិភោគ ២-៣ ថ្ងៃ លុះបុណ្ណមុខៈមានកម្លាំងល្អហើយ ទើបពោលថា នែសម្លាញ់ ឥឡូវនេះ ឯង

ប្រាសចាករោគហើយ ចូរនៅជាមួយបរិចារិការបស់ឯងចុះ អញនឹងទៅលំនៅរបស់អញ ។ លំដាប់នោះ បុណ្ណមុខៈក៏ពោលថា បក្សីញីបរិចារិកាទាំងនេះនាំគ្នាបោះបង់អញកាលមានជំងឺធ្ងន់ គេចទៅហើយ អញមិនត្រូវការនៅជាមួយស្រីអ្នកលេងទាំងនេះ ។ ព្រះមហាសត្វបានស្តាប់ពាក្យនោះ ទើបពោលថា នែសម្លាញ់ បើយ៉ាងនោះ អញនឹងពោលកាពលាមករបស់ស្រីទាំងឡាយឲ្យឯងស្តាប់ ពោលហើយ ក៏នាំបុណ្ណមុខៈមកកាន់ផ្ទាំងមនោសិលា ក្បែរភ្នំហិមពាន្តសម្រាកត្រង់មនោសិលាត្រង់គល់រាំងដែលមានបរិមណ្ឌល ៧ យោជន៍ ។ បុណ្ណមុខៈ និងបរិវារក៏នាំគ្នានៅក្នុងចំណែកម្ខាង ។ ឯទេវតាក៏ត្រាច់ប្រកាសពេញព្រៃហិមពាន្តថា ថ្ងៃនេះ ស្តេចបក្សីកុណាល នឹងសម្តែងធម៌ដោយពុទ្ធលីលា លើផ្ទាំងមនោសិលា អញ្ជើញអ្នកទាំងឡាយមកស្តាប់ ទេវតាក្នុងកាមាវចរ ៦ ក៏បានដឹង ព្រោះការប្រកាសតៗទៅ ក៏នាំគ្នាប្រជុំក្នុងទីនោះ ជាច្រើន មិនតែប៉ុណ្ណោះ ពួកនាគ យក្ខ អារក្ខទឹក គ្រុឌ វិជ្ជាធរ ត្មាតនិងទេវតាដែលអាស្រ័យក្នុងព្រៃ ក៏ឃោសនាសេចក្តីនោះតៗទៅ ។ កាលនោះ ស្តេចត្មាតឈ្មោះអានន្ទ មានត្មាតបរិវារមួយម៉ឺន នៅអាស្រ័យត្រង់ភ្នំគិជ្ឈកូដ បានឮនូវសំឡេងប្រកាសជាកោលាហល ក៏នាំបរិវារមក ចុះត្រង់ចំណែកម្ខាងដោយបំណងនឹងស្តាប់ធម៌ នារទតាបសជាអ្នកមានអភិញ្ញា ៥ មានតាបសមួយម៉ឺន នៅក្នុងហិមវន្តប្បទេស បានឮសំឡេងប្រកាសថា បានឮថា ស្តេចបក្សីកុណាល សម្លាញ់របស់យើងឃើញទោសរបស់ស្រីទាំងឡាយ នឹងមានសមាគមធំ អញគួរទៅស្តាប់ទេសនារបស់ស្តេចកុណាល គិតហើយ ក៏នាំ

តាបសមួយម៉ឺនមកដោយឫទ្ធិ ហើយស្ថិតក្នុងទីសមគួរនាចំណែកម្ខាង ។ សមាគមធំក៏កើតមាន ដូចគ្នានឹងការប្រជុំនៃទេសនារបស់ព្រះសម្ពុទ្ធ ។ លំដាប់នោះ មហាសត្វអាងនូវស្តេចបុណ្ណមុខៈជាបន្ទាល់ហើយ ក៏សម្តែងហេតុដែលខ្លួនបានឃើញមកហើយ ក្នុងអតីតភព ដែលប្រកបដោយទោសនៃស្រីដោយជាតិស្សរញ្ញាណ គឺញាណដែលរឭកជាតិបាន ។

កាលព្រះសាស្តា ទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

គ្រានោះ កុណាលសកុណៈ បាននិយាយពាក្យនេះនឹងតាវៅស ឈ្មោះបុណ្ណមុខៈ ដែលសះស្បើយចាកជំងឺ ដែលស្រាកស្រាន្តចាកភាពនៃខ្លួនជាអ្នកឈឺ មិនយូរប៉ុន្មានថា នៃបុណ្ណមុខៈសម្លាញ់ កុមារីឈ្មោះនាងកណ្ហា មានបិតាពីរ មានប្តី ៥ នាក់ ជាប់ជំពាក់ចិត្តក្នុងបុរសទី ៦ គឺក្នុងបុរសខ្វិនគម ( ដូចខ្មោចកំបុតក ) ក៏ខ្ញុំបានឃើញហើយ ។ ពាក្យក្នុងរឿងនោះមាន ដូចតទៅនេះ

ស្ត្រីប្រព្រឹត្តកន្លងប្តីទាំង ៥ នាក់នុ៎ះ គឺ អជ្ជុនរាជកុមារ ១ នកុលរាជកុមារ ១ ភីមសេនរាជកុមារ ១ យុធិដ្ឋិលរាជកុមារ ១ សហទេវរាជកុមារ ១ ធ្វើនូវអំពើដ៏លាមកគឺសេពមេថុនធម្មជាមួយបុរសគមទាបតឿ ។

នៃបុណ្ណមុខៈសម្លាញ់ នាងសមណីឈ្មោះបញ្ចតបាវី កាលនៅកណ្តាលព្រៃស្មសាន រំលងចោលនូវបាយ ៤ ដង បាន

ធ្វើនូវអំពើដ៏លាមកជាមួយនឹងអ្នកលេងស្គរ ខ្ញុំបានឃើញហើយ ។ នៃបុណ្ណមុខៈសម្លាញ់ នាងទេវី ឈ្មោះកាកវតី កាលនៅកណ្ដាលសមុទ្ទ ជាកិរិយារបស់វេនតេយ្យ បានធ្វើនូវអំពើដ៏លាមកជាមួយនឹងបុរសឈ្មោះ នដកុវេរៈ ខ្ញុំក៏បានឃើញហើយ ។ នៃបុណ្ណមុខៈសម្លាញ់ ព្រះអគ្គមហេសី មានព្រះលោមាល្អ ព្រះនាមកុរុង្គទេវីកាលចង់បានឯឡកកុមារ ធ្វើនូវអំពើដ៏លាមក ជាមួយនឹងបុរសអ្នកនៅដោយទ្រព្យ ( បុរសខ្ញុំគេ ) ឈ្មោះធឡង្គកុមារ ខ្ញុំក៏បានឃើញហើយ ។ សេចក្ដីពិត រឿងដូចគ្នានេះ ខ្ញុំដឹងហើយយ៉ាងនេះថា ព្រះវរមាតារបស់ព្រះបាទព្រហ្មទត្ត លះបង់ព្រះបាទកោសល ទៅធ្វើអំពើដ៏លាមក ជាមួយនឹងព្រាហ្មណកុមារឈ្មោះ បញ្ចាលចណ្ឌៈ ។

ពួកស្ត្រីទាំងនុ៎ះក្ដី ពួកស្ត្រីឯទៀតក្ដី បានធ្វើនូវអំពើដ៏លាមក ព្រោះហេតុនោះ ទើបខ្ញុំមិនទុកចិត្ត មិនសរសើរស្ត្រីទាំងឡាយទេ ពួកស្ត្រីដូចផែនដី ជាទីដើរទៅ ជាទីទ្រទ្រង់ មានសេចក្ដីត្រេកអរស្មើ ជាទីតម្កល់ទុកនៃវត្ថុគ្រប់យ៉ាង អត់ធន់ចំពោះអារម្មណ៍ទាំងពួង មិនញាប់ញ័រ មិនកម្រើក នរជនមិនគប្បីទុកចិត្តស្ត្រីទាំងនោះទេ សីហៈជាម្រឹគសាហាវ ជាសត្វស៊ីឈាមនឹងសាច់ មានអាវុធ ៥ សាហាវក្រៃលែង ត្រេកអរ

ក្នុងការបៀតបៀនសត្វដទៃ កំហែងខាំស៊ីយ៉ាងណាមិញ ពួកស្ត្រីទាំងនោះក៏ដូច្នោះដែរ នរជនមិនត្រូវទុកចិត្តឡើយ ។

នៃបុណ្ណមុខៈសម្លាញ់ ស្រីទាំងឡាយមិនមែនឈ្មោះថាពេស្យា ថានារី ថាជាទីគប់រកទេ ស្រីទាំងនុ៎ះមិនមែនគ្រាន់តែឈ្មោះថា អ្នកកោងកាច អ្នកចងទុក ( នូវបុរស ) ទេ ស្រីទាំងនុ៎ះ គឺស្រីពេស្យា នារីជាទីគប់រក ឈ្មោះថា ស្រីសម្លាប់ ( ប្តី ) ។ ពួកស្រីស្អិតស្អាងផ្គងសក់ ដូចចោរ ដូចគ្រឿងស្រវឹងដែលលាយដោយថ្នាំពិស បិទបាំងដោយវាចា ដូចពាណិជ មានអាការៈវែបប្រួលដូចកុយរមាស មានអណ្តាតពីរដូចពស់ បិទបាំង ( នូវកាយ ) ដូចជាគេបិទបាំងរណ្តៅបំពេញបានដោយក្រដូចសមុទ្ទ ត្រេកអរបានដោយក្រដូចអារក្សទឹក នាំទៅដោយដាច់ខាតដូចយមបាល ស៊ីនូវវត្ថុគ្រប់មុខដូចភ្លើង នាំយកនូវវត្ថុគ្រប់យ៉ាងដូចស្ទឹង ប្រព្រឹត្តរហើរហាចដូចខ្យល់ ធ្វើនូវវត្ថុមិនឲ្យប្លែកគ្នាដូចភ្នំនេរុ ផ្លែជានិច្ចដូចឈើមានពិសពុល ។ ពាក្យក្នុងរឿងនេះ មានតទៅទៀតថា

ពួកស្រីមានកលមាយាដូចចោរ មានពិសខ្លាំងដូចសុរាដែលលាយថ្នាំពិស និយាយបិទបាំងទោសដូចពាណិជ មានអាការប្រែប្រួលដូចកុយរមាស មានអណ្តាតពីរដូចពស់ ។ ពួកស្រីបិទបាំង ( នូវកាយ ) ដូចជាគេបិទបាំងរណ្តៅ បំពេញ

បានដោយក្រដូចសមុទ្ទ ត្រេកអរបានដោយក្រដូចអារក្សទឹក នាំយកទៅដោយដាច់ខាតដូចយមបាល ។ ពួកស្រីដូចភ្លើងនាំយកនូវវត្ថុគ្រប់យ៉ាងដូចស្ទឹង មានអាការៈរហើរហាចក្នុងកាមដូចខ្យល់ មិនឲ្យមានប្លែកដូចភ្នំនេរុ មានផ្លែជានិច្ចដូចឈើមានពិសពុល ពួកស្រីតែងញុំាងកោគៈក្នុងផ្ទះឲ្យវិនាស ធ្វើសេចក្ដីអន្តរាយនូវរតនៈវត្ថុទាំងឡាយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **គិលានា វុដ្ឋិតំ** បានដល់ មានជំងឺមកអំពីមុន ទើបជាសះស្បើយក្នុងកាលជាក្រោយ ។ បទថា **ធិដ្ឋា មយា** សេចក្ដីថា បានឮថា ក្នុងកាលកន្លងមកហើយ ព្រះបាទព្រហ្មទត្ត ជាព្រះរាជាក្នុងដែនកាសី ទ្រង់យាងទៅវាយដណ្ដើមបានរាជសម្បត្តិក្នុងដែនកោសល ព្រោះទ្រង់មានពលពាហនៈច្រើន សម្លាប់ព្រះបាទកោសលហើយ នាំអគ្គមហេសីរបស់ព្រះបាទកោសលរាជ ដែលកំពុងមានគភ៌នៅខ្ទិមកផង យាងមកកាន់នគរពារា-ណសី ទ្រង់តែងតាំងឲ្យជាអគ្គមហេសីរបស់ព្រះអង្គ មិនយូរប៉ុន្មាននាង ក៏ប្រសូតព្រះរាជធីតា ។ ជាប្រក្រតី ព្រះបាទព្រហ្មទត្តមិនមានព្រះរាជឱរស ឬព្រះរាជធីតាឡើយ ទ្រង់ត្រេកអរហួតដល់មានព្រះបន្ទូលចេញមកថា នែនាងដ៏ចម្រើន យើងឲ្យពរ ។ អគ្គមហេសីព្រះនាងក៏សម្គាល់ពាក្យនោះទុក ។ ពួកព្រះញាតិទាំងឡាយ ថ្វាយព្រះនាមរាជកុមារីនោះថា កណ្ហា ។ កាលព្រះនាងចម្រើនវ័យហើយ ព្រះមាតាក៏ប្រាប់ថា បិតារបស់នាងព្រះរាជទានពរទុក មាតាក៏កាន់យកពាក្យនោះជាសញ្ញាទុកហើយ ចូរកូនកាន់យកនូវពរនោះ

តាមគាប់ចិត្តចុះ ។ ព្រះនាងកណ្ហាទូលថា ទ្រព្យសម្បត្តិណាមួយរបស់ខ្ញុំម្ចាស់ មិនខ្វះឡើយ ខ្ញុំម្ចាស់សូមតែរើសប្តីបានតាមគាប់ចិត្ត ការដែលនាងមិនមាន ខ្មាស ហ៊ានទូលព្រះរាជមាតាយ៉ាងនោះ ក៏ព្រោះកិលេសខ្លាំងក្លា ព្រះមាតាក៏ នាំសេចក្តីនោះទៅក្រាបទូលដល់ព្រះបាទព្រហ្មទត្ត ព្រះបាទព្រហ្មទត្តត្រាស់ថា សាធុ ចូរនាងជ្រើសរើសប្តីតាមគាប់ចិត្តចុះ ទើបប្រកាសឲ្យបុរសមកហើយ ឲ្យបុត្រីរើសតាមគាប់ចិត្ត ពួកបុរសទាំងឡាយ ក៏នាំគ្នាប្រដាប់ដោយគ្រឿង អលង្ការ មកប្រជុំព្រមគ្នាត្រង់លានព្រះរាជវាំង ។ នាងកណ្ហាកាន់យកប្រអប់ កម្រងផ្កា ឈរត្រង់មាត់បង្អួច សម្លឹងមើលប្រុសទាំងនោះ ក៏មិនបានគាប់ចិត្ត ត្រឹមតែម្នាក់ ។

គ្រានោះ មានព្រះរាជកុមារ ៥ អង្គ ជាព្រះរាជបុត្តរបស់ព្រះបាទបណ្ឌុ រាជ ព្រះរាជបុត្តមួយអង្គព្រះនាមអជ្ជុនៈ មួយអង្គព្រះនាមថានកុល មួយអង្គ ព្រះនាមថាភីមសេន មួយអង្គព្រះនាមថាយុធិដ្ឋិល មួយអង្គព្រះនាមថា សហ ទេព នាំគ្នាទៅរៀនសិល្បសាស្ត្រក្នុងសម្នាក់អាចារ្យទិសាបាមោក្ខឯនគរតក្ក សិលា ចប់ស្រេចបាច់ហើយ ចង់ដឹងនូវការប្រព្រឹត្តក្នុងប្រទេសផ្សេងៗ នាំគ្នា មកដល់នគរពារាណសី បានឮកោលាហលក្នុងនគរ ទើបចូលទៅសួរ កាលដឹង សេចក្តីហើយ ក៏ប្រឹក្សាគ្នាថា យើងនឹងទៅមើលនឹងគេដែរ ។ កុមារទាំង ៥ មានរូបល្អដូច ៗ គ្នា នាំគ្នាទៅឈរមើលត ៗ គ្នា ។ ឯព្រះនាងកណ្ហានោះ ឃើញព្រះរាជកុមារទាំង ៥ ក៏មានសេចក្តីស្នេហាគ្រប់ ៗ អង្គ ក៏បោះកម្រងផ្កា ឲ្យព្រះរាជបុត្តទាំង ៥ ហើយក្រាបទូលព្រះរាជមាតាថា ខ្ញុំម្ចាស់នឹងជ្រើស

រើសយកបុរសទាំង ៥ នេះ ព្រះមាតា ក៏ក្រាបទូលដល់ព្រះបាទព្រហ្មទត្ត ព្រះបាទព្រហ្មទត្តមិនពេញព្រះហឫទ័យ តែមិនអាចត្រាស់ថា មិនបាន ព្រោះបានព្រះរាជទានពរទុកហើយ ទើបសួរដល់ជាតិត្រកូល និងឈ្មោះរបស់មាតាបិតា កាលទ្រង់ជ្រាបថា ជារាជកុមាររបស់ព្រះបាទបណ្ឌុរាជ ក៏ព្រះរាជទានសក្ការៈហើយលើកនាងកណ្ហាឲ្យជាបរិចារិកាដល់ព្រះរាជកុមារទាំង ៥ អង្គ ៗ នាងកណ្ហាបម្រើព្រះរាជកុមារទាំង ៥ ដោយអំណាចកិលេស លើប្រាសាទ ៧ ជាន់ ៗ

ព្រះនាងកណ្ហាមានបុរសគមម្នាក់ជាអ្នកបម្រើ កាលនាងតណ្ហាបម្រើរាជកុមារទី ៥ ដោយកិលេសហើយ លុះរាជកុមារនោះចេញទៅខាងក្រៅ នាងមានពេលទំនេរ កាលកិលេសរោលរាលឡើង ក៏ធ្វើអំពើអាក្រក់ជាមួយបុរសគម កាលនាងចរចាជាមួយបុរសគមនោះ បានពោលថា អ្នកដទៃ ដែលជាទីស្រឡាញ់របស់យើងក្រៃលែងជាងអ្នកមិនមាន យើងនឹងសម្លាប់ព្រះរាជកុមារទាំង ៥ យកឈាមបំពង់កមកលាងជើងអ្នក ដូច្នេះ ៗ សូម្បីព្រះរាជកុមារទាំង ៥ នាងក៏ពោលយ៉ាងនេះ គឺក្នុងពេលដែលកៀកកើយព្រះរាជកុមារដែលជាច្បង នាងក៏ពោលថា ខ្ញុំម្ចាស់ស្រឡាញ់ព្រះអង្គក្រៃលែងជាងព្រះរាជកុមារ ៤ អង្គ ជីវិតខ្ញុំម្ចាស់ផ្ញើលើព្រះអង្គហើយ អំណឹះឥតពីបិតា ខ្ញុំម្ចាស់ទៅ ខ្ញុំម្ចាស់នឹងថ្វាយរាជសម្បត្តិដល់ទ្រង់ ដូច្នេះ ពេលនាងកៀកកើយជាមួយព្រះរាជកុមារអង្គដទៃទៀត នាងក៏ពោលយ៉ាងនេះទាំង ៤ អង្គ ៗ ព្រះកុមារទាំង ៥ អង្គ ទ្រង់ត្រេកអរក្រៃលែងជាមួយនាងកណ្ហា ដោយ

សម្គាល់ថា នាងកណ្ហាស្រឡាញ់ខ្លួន ហើយឥស្សរិយយសនឹងកើតឡើងដល់ខ្លួន ព្រោះអាស្រ័យនាងកណ្ហា ។ សម័យមួយ ព្រះនាងកណ្ហាក៏ប្រឈួន ព្រះរាជកុមារទាំង ៥ ក៏ទៅអង្គុយចោមរោម មួយអង្គប្របាច់ត្រង់សីសៈ ៤ អង្គទៀត ប្របាច់ដៃនិងជើង បុរសគមអង្គុយត្រង់ចុងជើង ។ ឯនាងកណ្ហា ក៏ឲ្យសញ្ញាដល់អជ្ជុនកុមារ ដែលជាច្បងដោយសីសៈ បញ្ជាក់ថា អ្នកដទៃជាទីស្រឡាញ់របស់ខ្ញុំម្ចាស់ក្រៅលែងជាងព្រះអង្គមិនមាន កាលខ្ញុំម្ចាស់មានជីវិតក៏មានជីវិតសម្រាប់ព្រះអង្គ បើព្រះបិតាសោយទិវង្គតទៅ នឹងថ្វាយរាជសម្បត្តិដល់ព្រះអង្គ ។ ឯរាជកុមារ ៤ ព្រះអង្គទៀត នាងក៏ឲ្យសញ្ញាដោយដៃនិងជើងតាមទិសដែលអង្គុយ សម្តែងន័យតែមួយដូចគ្នា មិនតែប៉ុណ្ណោះ ក៏ធ្វើអណ្តាតឲ្យជាសញ្ញាដល់បុរសគម ដោយន័យថា អ្នកប៉ុណ្ណោះជាទីស្រឡាញ់របស់ខ្ញុំ ជីវិតខ្ញុំសម្រាប់តែអ្នក ។ ជនទាំងអស់ឃើញនូវសញ្ញាហើយ ក៏ដឹងសេចក្តី ព្រោះព្រះនាងធ្លាប់និយាយមករឿយៗ ។ អជ្ជុនរាជកុមារសង្កេតឃើញអាការកម្រើកដៃជើងនិងអណ្តាត របស់នាងក៏ត្រិះរិះថា នាងកណ្ហាឲ្យសញ្ញាដល់អញ យ៉ាងណា ប្រហែលឲ្យដល់អ្នកដទៃយ៉ាងនោះ ប្រហែលជាធ្វើសេចក្តីស្រឡាញ់ជាមួយបុរសគម ដោយឥតសង្ស័យ ត្រិះរិះហើយ ទើបនាំប្អូនប្រុសចេញទៅខាងក្រៅ ហើយសាកសួរថា នាងប្តី ៥ សម្តែងអាកប្បកិរិយាដោយក្បាលឲ្យយើង តើឯងឃើញដែរឬទេ ព្រះរាជកុមារទាំង ៤ ក៏ទទួលថាឃើញ អជ្ជុនរាជកុមារ ក៏សួរថា តើឯងដឹងទាន់ដែរឬទេ ព្រះរាជកុមារទាំង ៤ ឆ្លើយថា មិនដឹង ទើបអជ្ជុនកុមារសួរថា នាងឲ្យសញ្ញាដល់

អ្នកទាំង ៤ ដោយដៃនិងជើង ឯងដឹងដែរឬទេ ព្រះរាជកុមារទាំង ៤ ឆ្លើយថា ដឹង ។ អជ្ជុនកុមារ ក៏ត្រាស់ថា នាងឲ្យសញ្ញាដល់ពួកឯង ដោយរឿងតែមួយនោះឯង ហើយសួរបន្តថា នាងសម្តែងកិរិយាដោយអណ្តាតដល់បុរសគមនោះ តើឯងដឹងដែរឬទេ ព្រះរាជកុមារទាំង ៤ ក៏ឆ្លើយថា មិនដឹង លំដាប់នោះ អជ្ជុនកុមារ ក៏ប្រាប់ដល់ប្អូនប្រុសថា ប្រហែលជានាងបានប្រព្រឹត្តអាក្រក់ជាមួយបុរសគមម្នាក់ទៀតដោយពិត កាលឃើញថា ប្អូនប្រុសទាំង ៤ មិនជឿ ទើបឲ្យហៅបុរសគមមកសួរ បុរសគមក៏ព្រមសារភាពទាំងអស់ ។ ព្រះរាជកុមារទាំង ៥ បានស្តាប់ហើយ ក៏អស់សេចក្តីត្រេកអរ តិះដៀលនូវមាតុគ្រាម ដោយអនេកបរិយាយថា គួរសង្វេគហ្ន៎ ឈ្មោះថា មាតុគ្រាមទ្រុស្តសីល លាមក លះបង់បុគ្គលដែលបរិបូណ៌ដោយជាតិនិងសម្រស់ដូចពួកយើង ហើយទៅប្រព្រឹត្តជាមួយមនុស្សគ្រមគួរខ្ពើម គួរបដិកូលបាន បុគ្គលជាអ្នកប្រាជ្ញ គប្បីត្រេកអរជាមួយស្រីទាំងឡាយដែលមិនមានខ្មាសនោះ មានតែធម៌លាមក កាលតិះដៀលហើយ ព្រះរាជកុមារទាំង ៥ ក៏សម្រេចចិត្តថា មិនត្រូវនៅជាយរាវាស ទើបនាំគ្នាទៅកាន់ព្រៃហិមពាន្ត កាន់យកបព្វជ្ជាភេទធ្វើកសិណបរិកម្ម អស់ជីវិតហើយទៅតាមយថាកម្ម ។

កាលនោះ ស្តេចបក្សីកុណាលកើតជាអជ្ជុនកុមារ ដូច្នោះ កាលសម្តែងហេតុដែលខ្លួនបានឃើញ ទើបពោលថា ក៏ខ្ញុំបានឃើញហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទេ្វបិតិកា** ក្នុងព្រះពុទ្ធវចនៈនោះ ព្រះមានព្រះភាគត្រាស់សំដៅ ព្រះបាទកោសល ១ ព្រះបាទកាសិករាជ ១ ។ បទ

ថា **បញ្ចបតិកាយ** បានដល់ ប្ដីរបស់នាងមានដល់ទៅ ៥ នាក់ ។ **យ** អក្ខរៈ ត្រឹមតែជានិបាត ។ បទថា **បដិពន្ធចិត្តិយា** បានដល់ នៅមានចិត្តជាប់ជំពាក់ ។ បទថា **កពន្ធេ** អធិប្បាយថា បានឮថា បុរសគមនោះ មានមុខកោងដល់ពោះ ព្រោះហេតុនោះ ទើបប្រាកដដូចជាមិនមានក្បាល ។ បទថា **បតី បញ្ចមតិច្ច** អធិប្បាយថា នាងប្រព្រឹត្តក្បត់ប្ដីទាំង ៥ នាក់នោះហើយ ។ បទថា **ខុជ្ជវាមនកេន** បានដល់ នាងធ្វើកម្មអាក្រក់ជាមួយបុរសគមទាបតឿ ។

ស្ដេចបក្សីកុណាល កាលពោលរឿងនេះចប់ហើយ កាលសំដែងរឿងដែលខ្លួនធ្លាប់ឃើញមក ដទៃទៀត ទើបពោលបន្តថា **ទិដ្ឋា** ដូច្នេះជាដើម បណ្ដារឿងទាំងនោះ រឿងទីមួយនេះ មានការពង្រីកសេចក្ដីដូចតទៅនេះថា បានឮមកថា ក្នុងអតីតកាល មានសមណីស្លៀកសមួយរូបឈ្មោះបញ្ចតបាវី អាស្រ័យក្នុងនគរពារាណសី ធ្វើបណ្ណសាលាអាស្រ័យនៅក្នុងព្រៃស្មសាន ប្រព្រឹត្តវត្តអត់អាហារ ៤ ថ្ងៃ ទើបបរិភោគម្ដង កិត្តិគុណរបស់នាងប្រាកដដូចព្រះចន្ទ និងព្រះអាទិត្យ ក្នុងនគរទាំងមូល ។ ពួកអ្នកនគរពារាណសីកណ្ដាស់ក្ដី រអិលដួលក្ដី ក៏ភ្ញាត់មាត់ថា **នមោ បញ្ចតបាវី** ខ្ញុំសូមនមស្ការនាងបញ្ចតបាវី ។ ក្នុងកាលក្រោយមក ជាសម័យនក្ខត្តឫក្ស ថ្ងៃដំបូង ពួកជាងមាសក៏បបួលគ្នាធ្វើបារំមួយខ្នង ហើយស្វែងរករបស់ផ្សេងៗ មានត្រីសាច់ ស្រា គ្រឿងក្រអូប អង្គុយព័ទ្ធវង់ផឹកស្រា ពេលនោះ ជាងមាសម្នាក់ធ្វើកំពប់ស្រា ក៏ភ្ញាត់មាត់ថា **នមោ បញ្ចតបាវី** ក្នុងពេលនោះ មានបុរសឈ្លាសវៃម្នាក់ពោលឡើងថា លោកល្ងង់ខ្លៅពេកណាស់ ហេតុអ្វី ក៏នមស្ការ

មនុស្សស្រីដែលមានចិត្តមិនទៀងទាត់ ជាងមាសក៏ឆ្លើយថា អើសម្លាញ់ ឯង កុំពោលយ៉ាងនេះ កុំធ្វើកម្មដែលនាំទៅនរកឡើយវ៉ើយ បុរសឈ្មោសវៃ ក៏ពោលថា លោកវង្វេងគ្មានប្រាជ្ញា ឥឡូវនេះ ក្អាល់ជាក់ម្នាក់ ១០០០ ឬ ៧ ថ្ងៃទៀត ខ្ញុំនឹងនាំនាងបញ្ចុតបាវីមក ឲ្យតែងខ្លួនឲ្យស្អាត ហើយមកអង្គុយ ទីនេះចាក់ស្រា ឲ្យយើងផឹកទៀតផង ឈ្មោះថា មាតុគ្រាម ជាអ្នកមានសីល ស្ថិតស្ថេរមិនមានឡើយ ជាងមាសនោះក៏ឆ្លើយថា មិនមែនជាឋានៈ ទើប ក្អាល់ជាមួយបុរសដែលជាបណ្ឌិត ១០០០ កហាបណៈ ។

បុរសបណ្ឌិតនោះប្រាប់រឿងការក្អាល់ ឲ្យជាងមាសដទៃៗ ស្តាប់ហើយ ស្អែកឡើងក្នុងពេលព្រឹក ក៏ចូលទៅក្នុងព្រៃស្មសាន អង្គុយនមស្ការព្រះ-អាទិត្យ ក្បែរលំនៅរបស់នាងបញ្ចុតបាវី កាលនាងបញ្ចុតបាវីចូលទៅកិច្ចាចារ ក្នុងនគរ ត្រឡប់មកឃើញបុរសនោះហើយ គិតថា តាបសរូបនេះប្រហែល ជាមានឫទ្ធិច្រើន អញនៅត្រង់ជាយព្រៃស្មសាន តែគាត់មកនៅត្រង់កណ្តាល ប្រហែលជាមានសប្បុរសធម៌នៅខាងក្នុង អញនឹងចូលទៅធ្វើសេចក្តីគោរព គិតហើយ នាងក៏ចូលទៅថ្វាយបង្គំ តាបសក្លែងក្លាយក៏នៅស្ងៀម មិនបាន សម្លឹងមើលនិងមិនរាក់ទាក់ ថ្ងៃទី ២ ក៏ធ្វើយ៉ាងនោះទៀត លុះដល់ថ្ងៃទី ៣ កាលនាងបញ្ចុតបាវីថ្វាយបង្គំហើយ តាបសក្លែងក្លាយឈ្ងោកមុខ ពោលថា ទៅចុះ ថ្ងៃទី ៤ ទើបប្រាស្រ័យថា នាងមិនលំបាកដោយកិច្ចាហារទេឬ នាង បញ្ចុតបាវីត្រេកអរដែលបានទទួលបដិសណ្ឋារៈ ក្នុងថ្ងៃទី ៥ នាងក៏បាន ទទួលបដិសណ្ឋារៈច្រើនជាងនេះបន្តិចទៀត ទើបត្រូវអង្គុយក្នុងទីនោះបន្តិច

ហើយក្រោកទៅ ក្នុងថ្ងៃទី ៦ កាលនាងមកថ្វាយបង្គំ តាបសក្មែងក្លាយ ក៏សួរថា ម្នាលប្អូនស្រី ថ្ងៃនេះ សំឡេងប្រគំគគ្រឹកគគ្រេង ក្នុងនគរពារាណសី គេធ្វើអ្វីហ្ន៎ នាងបញ្ចុតបារិតបថា បពិត្រលោកម្ចាស់ លោកម្ចាស់មិនដឹងទេឬ គេលេងមហោស្រពក្នុងព្រះនគរ ន៎ុះជាសំឡេងអ្នកលេងមហោស្រព តាបសក្មែងក្លាយ ធ្វើជាមិនដឹងថា ជាសំឡេងអ្វី ក្មែងសួររឿងដទៃបន្តថា នាងប្រព្រឹត្តវត្តនេះ វៀរចាកអាហារដូចម្តេច នាងឆ្លើយថា វៀរ ៤ ថ្ងៃ ហើយក៏សួរត្រឡប់ថា ចុះលោកម្ចាស់វៀរប៉ុន្មានដែរ តាបសឆ្លើយថា វៀរ ៧ ថ្ងៃ ដែលពិតយ៉ាងនោះ ព្រោះវៀរតែពេលថ្ងៃ ពេលយប់បរិភោគ ហើយតាបសក៏សួរបន្តថា ម្នាលប្អូនស្រី នាងបួសប៉ុន្មានឆ្នាំហើយ នាងប្រាប់ថា ១២ ឆ្នាំ ហើយសាកសួរថា ចុះលោកម្ចាស់បួសប៉ុន្មានឆ្នាំហើយ ទើបឆ្លើយថា ៦ ឆ្នាំហើយ រួចសួរបន្តថា នាងបានសម្រេចធម៌ជាគ្រឿងស្ងប់រម្ងាប់ឬ កាលនាងបដិសេធថា មិនបានសម្រេចទេ ក៏សួរត្រឡប់ទៅកាន់តាបសនោះវិញ តាបសពោលថា មិនបានសម្រេចដូចគ្នា បន្ទាប់អំពីនោះ ក៏និយាយរៀបរាប់បបែរបបួលឲ្យកើតសេចក្តីត្រូវការដូច្នេះថា ម្នាលប្អូនស្រី យើងទាំង ២ មិនបានទទួលសេចក្តីសុខទាំង ២ យ៉ាង ទាំងកាមភោគី សម្រាប់អ្នកគ្រប់គ្រងផ្ទះដែលជាសុខដោយទ្រព្យសម្បត្តិក៏មិនបាន នេក្ខម្មសុខ ជាគ្រឿងស្ងប់រម្ងាប់ផ្លូវចិត្តក៏មិនកើតឡើង ភ្លើងនរក ក្តៅសម្រាប់តែយើងទាំង ២ ប៉ុណ្ណោះឬ យើងទាំងពីរនឹងធ្វើការប្រព្រឹត្តដូចមហាជន យើងនឹងត្រូវសឹកជាគ្រហស្ថ ទ្រព្យសម្បត្តិរបស់មាតាក៏នៅមាន ខ្ញុំមិនអាចអត់ធន់នូវទុក្ខតទៅទៀតបានទេ ។

នាងបញ្ចតបាវីបានស្តាប់ដូច្នោះ ក៏កើតតម្រេកក្នុងតាបសក្លែងក្លាយនោះ ព្រោះខ្លួនមានចិត្តប្រែប្រួលទើបពោលថា បពិត្រលោកម្ចាស់ រឿងនេះ ខ្ញុំក៏គិតដូចគ្នា តែមិនដឹងជាបែរមុខទៅរកអ្នកណា បើលោកម្ចាស់មិនបោះបង់ខ្ញុំសោត ខ្ញុំនឹងជាប្អូនស្រីរបស់លោក តាបសក្លែងក្លាយតបថា បើនាងដាក់ចិត្តដូច្នោះសោត មកយើងមិនបោះបង់នាងនឹងចិញ្ចឹមនាងជាភរិយា ពោលហើយ ក៏នាំគ្នាទៅកាន់នគរ រួមរស់ដូចស្វាមីភរិយាទាំងឡាយ ហើយក៏ឲ្យនាងកាន់កំសៀវស្រា នាំគ្នាទៅកាន់បារំសុរា ក្នុងស្រុកអន្តរយផឹក ឯជាងមាសក៏ចាញ់ទ្រព្យ ១០០០ នាងបញ្ចតបាវី កើតបានកូនប្រុសស្រីជាមួយអ្នកលេងសុរានោះច្រើននាក់ ។ ក្នុងកាលនោះ ស្តេចបក្សីកុណាល កើតជាអ្នកលេងសុរា កាលនាំហេតុនោះមកសម្តែង ទើបពោលថា ខ្ញុំបានឃើញហើយ ដូច្នេះ ។

អតីតនិទានក្នុងរឿងទី ២ មានពណ៌នាទុកក្នុងអដ្ឋកថានៃ កាកាតិជាតក ក្នុងចតុក្កនិបាត ក្នុងកាលនោះ ស្តេចបក្សីកុណាលកើតជាស្តេចគ្រុឌ ព្រោះដូច្នោះ កាលនឹងប្រកាសហេតុដែលខ្លួនជួបមក ទើបពោលថា ខ្ញុំបានឃើញហើយ ដូច្នេះ ។

ក្នុងរឿងទី ៣ នេះ មានសេចក្តីពិស្តារថា ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តផ្តាច់ព្រះជន្មព្រះបាទកោសលរាជ ទ្រង់ដណ្តើមយករាជសម្បត្តិហើយ នាំអគ្គមហេសីរបស់ព្រះបាទកោសលដែលកំពុងមានគភ៌ ទៅកាន់នគរពារាណសី សូម្បីទ្រង់ជ្រាបថា ព្រះនាងមានគភ៌ ក៏ទ្រង់តែងតាំងនាងទុកក្នុងតំណែងអគ្គមហេសី កាលនាងមានគភ៌គ្រប់ខែហើយ ក៏ប្រសូតព្រះរាជបុត្ត មានរូប

ល្អដូចមាស ។ នាងត្រិះរិះថា កាលកុមារនេះធំ ព្រះបាទពារាណសី ក៏នឹង ឲ្យសម្លាប់ចោល ព្រោះជាកូនរបស់សត្រូវ មិនមានបំណងនឹងចិញ្ចឹម កុំឲ្យ កូនរបស់អញស្លាប់ក្នុងដៃរបស់អ្នកដទៃឡើយ ទើបនាងបញ្ជាស្រីស្នំថា ចូរ នាងយកកន្ទបរុំទារកនេះ ហើយយកទៅចោលត្រង់ព្រៃខ្មោច ហើយសឹម ត្រឡប់មក ស្នំក៏ធ្វើតាមពាក្យបញ្ជា ងូតទឹកជម្រះហើយ ទើបត្រឡប់មក ។

ឯព្រះបាទកោសលទ្រង់សោយទិវង្គតហើយ កើតជារុក្ខទេវតា ទើប បណ្ដាលអានុភាពរបស់ខ្លួន ឲ្យអ្នកចិញ្ចឹមពពែ កៀងពពែទៅកាន់ទីនោះ ពពែ ញីមួយ ឃើញទារកនោះ កើតសេចក្ដីស្រឡាញ់ ទើបឲ្យទារកនោះបៅដោះ ខ្លួន ហើយក៏ត្រាច់ទៅ ហើយត្រឡប់មកឲ្យបៅទៀត ៣-៤ ដង ។ អ្នក ចិញ្ចឹមពពែ ឃើញកិរិយារបស់ពពែញីនោះ ទើបចូលទៅមើល ឃើញទារក នោះហើយ ក៏កើតសេចក្ដីស្រឡាញ់ដូចបុត្ត ទើបបីមកឲ្យភរិយារបស់ខ្លួន ។ ភរិយារបស់គាត់មិនមានបុត្ត ទើបមិនមានទឹកដោះឲ្យបៅ ក៏ឲ្យទារកនោះបៅ ដោះពពែនោះ ។ តាំងអំពីនោះមក មេពពែក៏ស្លាប់មួយថ្ងៃ ២-៣ រាល់ៗ ថ្ងៃ អ្នកចិញ្ចឹមពពែគិតថា បើអញនៅចិញ្ចឹមកុមារនេះ ពពែញីនឹងស្លាប់អស់ពិត អញចិញ្ចឹមធ្វើអ្វី ទើបយកទារកនោះដាក់ក្នុងភាជនៈដីមួយ យកភាជនៈមួយ ទៀតគ្រប យកម្សៅសណ្ដែកមកបិទធ្វើឲ្យមានប្រហោង ហើយបណ្ដែតទឹក ទៅ ។ មានបុរសចណ្ឌាលប្ដីប្រពន្ធ ២ នាក់ បោកគក់របស់ចាស់ៗ ក្នុង ព្រះរាជនិវេសន៍ ចុះទៅកាន់កំពង់ទឹក ឃើញភាជនៈអណ្ដែតមក ក៏ហែល ទៅចាប់នាំឡើងមកលើគោក លុះបើកឡើងក៏បានឃើញទារករូបល្អ ។ ភរិយា

របស់បុរសចណ្ឌាលមិនមានកូន ក៏មានសេចក្ដីស្រឡាញ់ដូចបុត្ត ទើបនាំទៅចិញ្ចឹមក្នុងផ្ទះរបស់ខ្លួន លុះទារកនោះចម្រើនវ័យបាន ៧-៨ ឆ្នាំ កាលមាតាបិតាទៅកាន់រាជត្រកូល ក៏នាំទៅដែរ ។ លុះទារកចម្រើនវ័យបាន ១៦ ឆ្នាំ ក៏បានទៅជួយធ្វើការជួសជុលរបស់ចាស់ក្នុងរាជត្រកូល អគ្គមហេសីរបស់ព្រះបាទព្រហ្មទត្តនោះ មានរាជធីតាមួយអង្គ ព្រះនាមថា កុរុង្គទេវី មានរូបស្រស់ត្រកាល តាំងពីនាងកុរុង្គទេវីបានឃើញកុមារនោះ ក៏មានចិត្តប្រាថ្នាមិនត្រេកអរក្នុងអ្នកដទៃ នាងយាងទៅកាន់ទីធ្វើការ របស់កុមារនោះរឿយៗ កាលជួបគ្នារឿយៗ ជនទាំង ២ ក៏មានចិត្តប្រតិព័ទ្ធគ្នាទៅវិញទៅមក លបលួចប្រព្រឹត្តសង្វាសក្នុងទីកំបាំង ក្នុងរាជត្រកូលនោះឯងអស់កាលយូរ ពួកបរិចារិកាដឹងរឿងនោះ ទើបនាំសេចក្ដីទៅនេះ ក្រាបទូលដល់ព្រះបាទព្រហ្មទត្ត ព្រះបាទព្រហ្មទត្តទ្រង់ព្រះពិរោធ ទើបឲ្យប្រជុំអាមាត្យទាំងឡាយ ត្រាស់ប្រឹក្សាទោសថា កូនអ្នកចណ្ឌាលធ្វើយ៉ាងនេះ អ្នកទាំងឡាយ ចូរដាក់ទោសតាមគួរដល់ទោស ។ អាមាត្យទាំងឡាយក្រាបទូលថា ទោសធំបែបនេះ គួរធ្វើទារុណកម្មជាមុន ហើយសឹមសម្លាប់ឯក្រោយ ។

ក្នុងខណៈនោះ អារក្ខទេវតាដែលជាបិតារបស់កុមារនោះ ក៏បានចូលមកសណ្ឋិតក្នុងអគ្គមហេសីដែលជាមាតារបស់កុមារនោះ នាងក៏ចូលទៅគាល់ព្រះបាទព្រហ្មទត្តដោយអានុភាពនៃទេវតា ហើយទូលថា បពិត្រមហារាជកុមារនេះមិនមែនកូនចណ្ឌាល កុមារនេះកើតក្នុងផ្ទៃរបស់ខ្ញុំម្ចាស់ ជាបុត្តរបស់ព្រះបាទកោសល ខ្ញុំម្ចាស់បានទូលមុសាវាទដល់ព្រះអង្គថា ព្រះឱរសស្លាប់

ហើយ ដោយគិតថា ជាបុត្ររបស់ព្រះរាជាដែលជាសត្រូវរបស់ព្រះអង្គ ទើបឲ្យទាសីយកទៅចោលក្នុងព្រៃខ្មោច អ្នកចិញ្ចឹមពពែម្នាក់ រើសយកទៅចិញ្ចឹម កាលមេពពែស្លាប់ច្រើន អ្នកចិញ្ចឹមពពែ ក៏យកទៅបណ្តែតទឹក ។ មនុស្សចណ្ឌាលដែលបោកគក់របស់ចាស់ក្នុងរាជត្រកូលរបស់ព្រះអង្គ ឃើញកុមារនេះអណ្តែតទឹកមក ទើបរើសយកទៅចិញ្ចឹម បើទ្រង់មិនជឿ ចូរហៅជនទាំងនោះមកត្រាស់សួរចុះ ។ ព្រះបាទព្រហ្មទត្ត ត្រាស់ឲ្យហៅជនទាំងនោះ តាំងពីទាសីឡើងទៅ ហើយមកត្រាស់សួរ ជនទាំងនោះក៏ទូលតាំងពី ដើមដល់ចប់ ។ ព្រះបាទព្រហ្មទត្តក៏ទ្រង់ត្រេកអរ ត្រាស់ថា កុមារប្រកបដោយជាតិ ក៏ឲ្យស្រពស្រង់តាក់តែងគ្រឿងអលង្ការ ហើយព្រះរាជទានធីតាឲ្យ មនុស្សទាំងឡាយក៏ថ្វាយព្រះនាមកុមារនោះថា ឯឡកកុមារ ដ្បិតសំដៅយកហេតុដែលពពែស្លាប់ ។ តមក ព្រះបាទព្រហ្មទត្ត ក៏ព្រះរាជទានសេនាពាហនៈដល់ឯឡកកុមារ រួចបញ្ជូនទៅគ្រប់គ្រងរាជសម្បត្តិរបស់បិតា ។ ឯលកកុមារនាំនាងកុរុង្គទេវីទៅគ្រប់គ្រងរាជសម្បត្តិ ។ ក្រោយមក ព្រះបាទព្រហ្មទត្តទ្រង់ត្រិះរិះថា ឯឡកកុមារ មិនបានសិក្សាសិល្បសាស្ត្រ ក៏បានតែងតាំងឆឡង្គកុមារឲ្យជាអាចារ្យ បង្រៀនសិល្បសាស្ត្រ ។ ឯឡកកុមារទ្រង់តែងតាំងឆឡង្គកុមារឲ្យជាសេនាបតីដោយយល់ឃើញថា ជាអាចារ្យរបស់ព្រះអង្គ ។

ក្នុងកាលជាខាងក្រោយ នាងកុរុង្គទេវីក៏លបលួចប្រព្រឹត្តធ្វើអចារជាមួយឆឡង្គកុមារ ។ ឆឡង្គកុមារមានអ្នកបម្រើម្នាក់ ឈ្មោះធនន្តេវាសី ឆឡង្គកុមារធ្លាប់ប្រើឲ្យនាំរបស់របរ មានសំពត់និងគ្រឿងប្រដាប់ជាដើម ទៅឲ្យនាង

កុរុង្គទេវី នាងកុរុង្គទេវីក៏ប្រព្រឹត្តលាមកជាមួយអ្នកបម្រើនោះទៀត ។ កាល បក្សីកុណាលនាំយកហេតុនេះមកសម្តែង ទើបពោលថា ខ្ញុំឃើញហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **លោមសុទ្ធរី** បានដល់ លោកពោលសំដៅ ដល់ព្រះនាង ដែលមានពោះប្រដាប់ដោយរោមជាជួរៗ ។ បទថា **ធឡន្ត-កុមារធនន្តេវាសិនា** អធិប្បាយថា សូម្បីនាងប្រាថ្នារស់នៅជាមួយឯឡក កុមារ ក៏បានធ្វើកម្មអាក្រក់ជាមួយធឡង្គកុមារសេនាបតី និងធនន្តេវាសីអ្នក បម្រើរបស់សេនាបតីនោះទៀត ។ បក្សីកុណាលពោលថា ស្រីទាំងឡាយ មានការប្រព្រឹត្តថោកទាបយ៉ាងនេះ ជាស្រីទ្រុស្តសីល មានធម៌លាមក ដោយ ហេតុនេះ ទើបយើងមិនសរសើរស្រីទាំងនោះឡើយ ព្រះមហាសត្វនាំអតីត និទានមកមកសម្តែងហើយ ក្នុងកាលនោះស្តេចបក្សីបានជាធឡង្គកុមារ ព្រោះ ហេតុនោះ ទើបនាំហេតុដែលខ្លួនឃើញមកនិទានឲ្យស្តាប់ ។

ក្នុងរឿងទី ៤ មានសេចក្តីពិស្តារថា ក្នុងកាលកន្លងមកហើយ ព្រះបាទ កោសលរាជដណ្តើមយកសម្បត្តិក្នុងនគរពារាណសីបាន ទើបទ្រង់តាំងអគ្គ មហេសីរបស់ព្រះបាទពារាណសី ដែលទ្រទ្រង់គភ៌ស្រាប់ហើយ ឲ្យជាអគ្គ មហេសីរបស់ព្រះអង្គ ហើយយាងមកនគររបស់ព្រះអង្គ មិនយូរប៉ុន្មាន អគ្គ មហេសីក៏ប្រសូតព្រះរាជឱរស ទ្រង់ចិញ្ចឹមដោយសេចក្តីស្រឡាញ់ ដូចជា ព្រះរាជបុត្តបង្កើត ព្រោះទ្រង់មិនមានព្រះឱរស កាលព្រះរាជកុមារនោះចម្រើន វ័យ ក៏ឲ្យសិក្សាសិល្បសាស្ត្រ បញ្ជូនឲ្យទៅគ្រប់គ្រងនគរព្រះជនក ។ ព្រះ

រាជកុមារ ក៏ទៅសោយរាជសម្បត្តិក្នុងនគរពារាណសី ។

ចំណេរកាលតមក ព្រះមាតារបស់ព្រះបាទពារាណសីចូលទៅបង្គំទូលលាព្រះបាទកោសលថា នឹងទៅសួរសុខទុក្ខព្រះរាជបុត្ត ហើយនាងក៏នាំនូវបរិវារជាច្រើនទៅកាន់នគរពារាណសី ឈប់សម្រាកក្នុងនិគមមួយ ក្នុងរវាងដែនទាំង ២ មានព្រាហ្មណកុមារម្នាក់ឈ្មោះបញ្ចាលចណ្ឌៈ មានរូបស្អាតនៅក្នុងនិគមនោះ បាននាំបណ្ណាការមកថ្វាយព្រះនាង ព្រះនាងគ្រាន់តែឃើញ ក៏មានចិត្តប្រតិព័ទ្ធ លបលួចធ្វើអាក្រក់ជាមួយព្រាហ្មណ៍នោះ សម្រាក ២-៣ ថ្ងៃក្នុងទីនោះហើយ ក៏ទៅកាន់នគរពារាណសី ជួបព្រះរាជបុត្តហើយ ក៏ប្រញាប់ត្រឡប់មកសម្រាកត្រង់និគមនោះវិញ លបលួចប្រព្រឹត្តអនាចារជាមួយនឹងព្រាហ្មណ៍នោះទៀត បាន ២-៣ ថ្ងៃហើយក៏ទៅកាន់នគរកោសល ។ តាំងអំពីនោះមក មិនយូរប៉ុន្មាននាងក៏ទៅទូលលាព្រះបាទកោសល អាងហេតុនោះៗថា ទៅសួរសុខទុក្ខព្រះរាជឱរស កាលទៅនិងកាលត្រឡប់ ក៏ទៅសម្រាកប្រព្រឹត្តអនាចារជាមួយព្រាហ្មណ៍ត្រង់និគមនោះអស់កន្លះខែ ។

នៃបុណ្ណមុខៈសម្លាញ់ ឈ្មោះថា ស្រីទាំងនេះ ជាអ្នកទ្រុស្តសីល មានប្រក្រតីប្រព្រឹត្តកុហក ។ ព្រះមហាសត្វសម្តែងអតីតនិទាននេះ ទើបពោលពាក្យថា **ឯវញ្ហេតំ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ព្រហ្មទត្តស្ស មាតុកា** បានដល់ ព្រះជននីរបស់ព្រហ្មទត្តកុមារ ដែលសោយរាជសម្បត្តិក្នុងនគរពារាណសី បានឮថា ក្នុងកាលនោះ បក្សីកុណាលកើតជាព្រាហ្មណ៍ឈ្មោះបញ្ចាលចណ្ឌៈ ព្រោះ

ហេតុនោះ កាលសម្តែងហេតុដែលខ្លួនបានដឹងនោះ ទើបពោលយ៉ាងនេះ ។

បទថា **ឯតា ៩** សេចក្តីថា នៃបុណ្ណមុខៈសម្លាញ់ ស្រីទាំង ៥ នាក់នេះ បានធ្វើកម្មលាមកហើយ ឯងកុំសម្គាល់ថា ស្រីដទៃមិនធ្វើ ស្រីទាំងនេះក្តី ស្រីដទៃជាច្រើនក្តី បានធ្វើកម្មលាមកសព្វកាល ខ្ញុំតាំងនៅក្នុងឋានៈ គប្បីពោលដល់រឿងរបស់ស្រីដែលប្រព្រឹត្តក្រៅចិត្តប្តីក្នុងលោក ។ បទថា **ជគតិ** បានដល់ ផែនដី មេទនី វសុន្ធរា បឋវី ពោលគឺ លោក តែងទទួលទ្រទ្រង់ទុកនូវវត្ថុទាំងល្អទាំងអាក្រក់ យ៉ាងណា ។ បទថា **សមានរត្តា** បានដល់ ឈ្មោះថា ត្រេកអរស្មើគ្នាក្នុងវត្ថុទាំងអស់ ដោយភាវៈដែលទទួលទ្រទ្រង់ ព្រោះថា ផែនដីនោះ ជាទីទទួលរាប់រងវត្ថុសព្វយ៉ាង ទាំងរបស់ខ្ពង់ខ្ពស់និងរបស់ថោកទាប ឯស្រីទាំងឡាយក៏ដូចគ្នា ជាទីទទួលនូវវត្ថុទាំងខ្ពង់ខ្ពស់និងថោកទាប ដោយអំណាចកិលេស ។ ពិតហើយ ស្រីទាំងឡាយកាលបានឱកាស ឈ្មោះថា មិនធ្វើកម្មលាមកជាមួយបុរសណាម្នាក់មិនមានទេ ។ បទថា **សព្វសហា** អធិប្បាយថា ធម្មតាផែនដីរមែងអត់ធន់បានទាំងអស់នោះឯង គឺមិនញាប់ញ័រ មិនឃ្លេងឃ្លោង មិនកម្រើក យ៉ាងណា ស្រីទាំងឡាយក៏ដូចគ្នា រមែងទ្រាំទ្របានក្នុងបុរសទាំងអស់ ដោយអំណាចសេចក្តីត្រេកអរក្នុងលោក បើបុរសណា ជាទីពេញចិត្តរបស់នាង ដើម្បីរក្សាបុរសនោះ នាងមិនរើបម្រះ មិនធ្វើកោលាហល ម្យ៉ាងទៀត ផែនដី រមែងមិនញាប់ញ័រ មិនកម្រើក យ៉ាងណា សូម្បីស្រីទាំងឡាយក៏យ៉ាងនោះ រមែងមិនកម្រើក មិនញាប់ញ័រដោយមេថុនធម្ម គឺមិនអាចឲ្យពេញដោយមេថុនធម្មនោះបានឡើយ ។

បទថា **វាឡមិគោ** បានដល់ សត្វសាហាវ ។ បទថា **បញ្ចាវុធោ** លោកពោលសំដៅដល់អាវុធ ៥ គឺមាត់និងជើងទាំង ៤ ។ បទថា **សុរុទ្ធោ** បានដល់ គ្រោតគ្រាត កាចឃោរឃៅ ។ បទថា **តថិត្ថិយោ** បានដល់ រាជសីហ៍ មានអាវុធ ៥ យ៉ាង គឺមាត់ ១ និងជើង ៤ យ៉ាងណា ស្រីទាំងឡាយក៏ដូចគ្នា មានអាវុធ ៥ យ៉ាង គឺរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ។ រាជសីហ៍នោះ កាលចាប់ចំណីរបស់ខ្លួន រមែងចាប់ដោយអាវុធ ៥ យ៉ាងនោះ យ៉ាងណា សូម្បីពួកស្រីទាំងនោះក៏ដូចគ្នា កាលកាន់យកអាហារ គឺកិលេស រមែងប្រហារដោយអាវុធ មានរូបជាដើម ហើយទើបកាន់យក រាជសីហ៍នោះកាច ញាំញីសត្វ ចាប់ស៊ីជាអាហារ យ៉ាងណា សូម្បីស្រីទាំងនេះក៏ដូចគ្នា គ្រោតគ្រាត ញាំញី ចាប់បរិភោគក៏យ៉ាងនោះ ស្រីទាំងឡាយរមែងធ្វើអាការៈ គឺញាំញីក្នុងបុរស ទោះបីមានសីលដ៏មធ្យ័ត ដោយកម្លាំងរបស់ខ្លួន ឲ្យដល់នូវសីលវិបត្តិបាន ។ រាជសីហ៍រមែងត្រេកអរក្នុងការបៀតបៀបសត្វដទៃ យ៉ាងណា សូម្បីស្រីទាំងនោះ ក៏ដូចគ្នា ត្រេកអរក្នុងការបៀតបៀនអ្នកដទៃដោយអំណាចកិលេស ។ បទថា **នាយោ** បានដល់ នរជន មិនគួរស្និទ្ធស្នាលនឹងស្រី ដែលប្រកបដោយវត្ថុមិនជាគុណ យ៉ាងនេះឡើយ ។ បទថា **គមណិយោ** សំដៅដល់ ស្រីគណិកា អធិប្បាយថា នៃបុណ្ណមុខៈសម្លាញ់ ឈ្មោះរបស់ស្រីទាំងឡាយ គឺពេស្យា មិនជាឈ្មោះរបស់ពួកនាង ស្រីទាំងនោះ មិនឈ្មោះ **វេសិយា នារី គមនីយៈ ពន្ធកិយៈ** តែស្រីទាំងនោះ ដោយឈ្មោះដើមហៅថា **វធិកាយោ** ( អ្នកសម្លាប់ ) ។

ស្រីទាំងនោះ ហៅដោយពាក្យផ្សេងៗថា **វេសិយា ធារី គមនិយ** ។ បទថា **វធិកាយោ** សេចក្តីថា សម្លាប់ប្តី សេចក្តីនេះបណ្ឌិតគប្បីសម្តែងរឿង មហាហំសជាតក ពិតហើយ លោកពោលទុកក្នុងជាតកនោះថា

មួយទៀត ស្ត្រីទាំងនេះ មានមាយាដូចជាថ្ងៃបណ្តើរកូន ជាទីសោយសោក ជាទីកើតនៃរោគ ជាទីឧបទ្រព ស្ត្រីទាំងនេះ មានអធ្យាស្រ័យដ៏រឹងរូស ជាចំណងសម្រាប់ចង ជាអន្ទាក់នៃសេចក្តីស្លាប់ ជាគុហាសម្រាប់នៅ ( របស់មច្ចុរាជ ) បុរសណា ទុកចិត្តក្នុងស្ត្រីទាំងនោះ បណ្តាបុរសទាំងឡាយ បុរសនោះ ឈ្មោះថា បុរសថោកទាប ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វេណិកតា** បានដល់ មានផ្នួងសក់ចងទុកហើយ ពិតហើយ ពួកចោរដែលនៅក្នុងព្រៃ រមែងចងផ្នួងសក់ ហើយទើបដណ្តើមយកទ្រព្យ យ៉ាងណា សូម្បីពួកស្រីទាំងនេះក៏យ៉ាងនោះដូចគ្នា នាំយកពួកបុរសទៅកាន់អំណាចកិលេស ហើយប្លន់ទ្រព្យ ។ បទថា **មធិរា វិយ វិសទុដ្ឋា** បានដល់ ដូចស្រាដែលលាយដោយថ្នាំពិស ដូច្នោះ អធិប្បាយថា ស្រាដែលលាយថ្នាំពិស សម្តែងអាការប្លែកៗ យ៉ាងណា សូម្បីស្រីទាំងនេះក៏ដូចគ្នា ជាអ្នកមានតម្រេកក្នុងបុរសដទៃទាំងឡាយ ជាអ្នកស៊ីមិនរើសតូចធំកាលធ្វើកិច្ចក្នុងបុរសដទៃហើយ នឹងធ្វើក្នុងបុរសដទៃបន្តទៀត ឈ្មោះថា តែងសម្តែងអាការប្លែកៗ ។ បទថា **វាចាសន្ថុតិយោ** អធិប្បាយថា ពាណិជរមែងពោលអួតគុណភាពនៃទំនិញរបស់ខ្លួន យ៉ាងណា សូម្បីស្រីទាំងនោះ ក៏

ដូចគ្នា បិទបាំងទោសមិនមែនគុណរបស់ខ្លួន ប្រកាសគុណតែម្យ៉ាង ។ បទថា **វិបរិវត្តាយោ** អធិប្បាយថា ស្នែងរបស់ម្រឹគត្រវីទៅត្រវីមក យ៉ាងណា ពួកស្រីទាំងនេះ ក៏ប្រែប្រួល រលាស់ទៅរលាស់មក ព្រោះខ្លួនមានចិត្តស្រាល យ៉ាងនោះដូចគ្នា ។ បទថា **ឱរគមិវ** អធិប្បាយថា ស្រីទាំងឡាយ ឈ្មោះថា មានអណ្តាតពីរដូចពស់ ព្រោះជាអ្នកច្រើនដោយពាក្យកុហកជានិច្ច ។ បទថា **សោព្ភមិវ** អធិប្បាយថា រណ្តៅលាមក រមែងបិទបាំងដោយបន្ទះក្តារយ៉ាងណា សូម្បីស្រីទាំងឡាយក៏បិទបាំងរាងកាយដោយសំពត់និងគ្រឿងអាភរណៈ គ្រាប់ទៅយ៉ាងនោះដូចគ្នា ម្យ៉ាងទៀត រណ្តៅដែលបិទបាំងដោយសំរាម ជាដើម កាលជាន់ចំ ក៏រមែងឲ្យកើតនូវការមុតដល់ជើង យ៉ាងណា សូម្បីស្រីទាំងនោះក៏ដូចគ្នា កាលបុគ្គលចូលទៅស្និទ្ធស្នាល ក៏ឲ្យកើតទុក្ខដល់បុគ្គលនោះ ។ បទថា **ចាតាលមិវ** អធិប្បាយថា អន្លង់ទឹកក្នុងមហាសមុទ្ររមែងធ្វើឲ្យពេញបានលំបាក យ៉ាងណា សូម្បីស្រីទាំងនេះ ក៏ដូចគ្នា រមែងធ្វើឲ្យពេញបានលំបាកដោយហេតុ ៣ ប្រការ គឺដោយមេថុន ១ ដោយការប្រសូត ១ ដោយការតែងខ្លួន ១ ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ស្រីមិនឆ្អែតដោយធម៌ ៣ ប្រការ គឺដោយមេថុន ១ ដោយការប្រសូតបុត្ត ១ ដោយការតែងខ្លួន ១ រមែង ធ្វើកាលកិរិយាដូច្នេះជាដើម ។

បទថា **រក្ខសី វិយ** អធិប្បាយថា ធម្មតាអារក្ខ បុគ្គលណាមួយ មិនអាចឲ្យត្រេកអរដោយទ្រព្យបាន ព្រោះខ្លួនស៊ីសាច់តែម្យ៉ាង អារក្ខនោះរមែងឃាត់

នូវទ្រព្យជាច្រើន ប្រាថ្នានូវសាច់តែម្យ៉ាង យ៉ាងណា ស្រីទាំងនេះក៏ដូចគ្នា រមែងមិនត្រេកអរដោយទ្រព្យច្រើន ព្រោះខ្លួនប្រាថ្នាមេថុន ស្រីទាំងនោះរមែងមិនទទួលទ្រព្យ ប្រាថ្នាមេថុនតែម្យ៉ាង ។ បទថា **យមោវ** អធិប្បាយថា ស្តេចយមមានតែនាំទៅដោយចំណែកមួយ មិនមានវៀរបុគ្គលណាឡើយ យ៉ាងណា សូម្បីស្រីទាំងនេះក៏ដូចគ្នា រមែងមិនលើកលែងអ្នកណាឡើយ បណ្តាបុគ្គលដែលសម្បូរដោយជាតិជាដើម រមែងឲ្យដល់នូវការវិនាសនៃសីលដោយអំណាចកិលេស ក្នុងវារៈនៃចិត្តទី ២ ក៏រមែងនាំទៅកាន់នរក ។ បទថា **សិខីរ** អធិប្បាយថា ធម្មតាអណ្តាតភ្លើង រមែងលេបត្របាក់ ទាំងអស់ទោះបីរបស់ស្អាត ឬមិនស្អាត យ៉ាងណា សូម្បីស្រីទាំងនោះ ក៏ដូចគ្នា រមែងសេពវត្ថុទាំងអស់ តាំងពីអាក្រក់រហូតដល់ល្អ ។ សូម្បីក្នុងការប្រៀបដោយស្ទឹង ក៏មានន័យដូចគ្នា ។ បទថា **យេនកាមំចរា** ជាតតិយាវិភត្តិ ប្រើក្នុងអត្ថនៃសត្តមីវិភត្តិ ។ អធិប្បាយថា ស្រីទាំងនេះ រមែងមានសេចក្តីប្រាថ្នាក្នុងទីណា ក៏រមែងស្ទុះទៅក្នុងទីនោះ ។ បទថា **នេរុ** អធិប្បាយថា ក្នុងព្រៃហិមពាន្ត មានភ្នំមាសមួយ សូម្បីក្អែកដែលមានពណ៌ខ្មៅ លុះចូលទៅជិតភ្នំនោះ ក៏ក្លាយជាពណ៌មាស ភ្នំនោះមានឧបមាយ៉ាងណា ស្រីទាំងនោះ ក៏ដូចគ្នា មិនបានធ្វើវត្ថុណាឲ្យវិសេសឡើយ រមែងមើលឃើញបុរសដែលចូលទៅជិតខ្លួនជាមនុស្សតែមួយទាំងអស់ ។

បទថា **វិសរុក្ខោ** អធិប្បាយថា ដើមឈើឈ្មោះកិម្បក្កៈមានផ្លែទុំ ដូចគ្នានឹងផ្លែស្វាយនោះ រមែងមានផ្លែជានិច្ច រមែងជាផ្លែដែលសម្បូរដោយពណ៌

ជាដើម ដោយហេតុនោះ បុគ្គលមិនមានសេចក្ដីសង្ស័យ បរិភោគផ្លែឈើនោះ រមែងស្លាប់ យ៉ាងណា សូម្បីស្រីទាំងនោះ ក៏ដូចគ្នា រមែងប្រាកដដូចជាទីត្រេកអរ ព្រោះមានផ្លែជានិច្ចដោយអំណាចនៃរូបជាដើម ។ កាលបុគ្គលណាសេព រមែងនាំបុគ្គលនោះឲ្យកើតនូវការប្រមាទ ប្រាទទម្លាក់ឲ្យធ្លាក់ក្នុងអបាយ ព្រោះហេតុនោះ ទើបលោកពោលទុក ( ក្នុងកិម្បក្កជាតក ) ថា

> បុគ្គលណា មិនយល់ទោសក្នុងអនាគត ហើយសេពកាម
> ទាំងឡាយ ( កាមទាំងនោះ ) តែងសម្លាប់បុគ្គលនោះ ក្នុង
> ទីបំផុតនៃផល ដូចបុគ្គលស៊ីផ្លែឈើកិម្បក្កៈ ( ឈើពុល )
> ដូច្នេះ ។

ម្យ៉ាងទៀត ដើមឈើពុលរមែងនាំសេចក្ដីវិនាសមកឲ្យសព្វកាល ព្រោះមានផ្លែជានិច្ច យ៉ាងណា សូម្បីស្រីទាំងនោះក៏ដូចគ្នា រមែងធ្វើសេចក្ដីវិនាសមកឲ្យសព្វកាលដោយអំណាចសេចក្ដីវិនាសនៃគុណ មានសីលជាដើម ម្យ៉ាងទៀត ឫស សម្បក ស្លឹក ផ្កា ផ្លែរបស់ដើមឈើពុលនោះរមែងពុល ព្រោះហេតុនោះ ទើបឈ្មោះថា មានផ្លែជានិច្ច យ៉ាងណា សូម្បីរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ទាំង ៥ យ៉ាងរបស់ស្រីទាំងនោះ ក៏មានពិសដូចគ្នាយ៉ាងនោះ ព្រោះហេតុនោះ ទើបស្រីទាំងនោះឈ្មោះថា មានផ្លែជានិច្ច ដូចដើមឈើពុល ដូច្នោះ ។ បទថា **បន្ថុត្តរេត្ថ** បានដល់ បក្សីកុណាលពោលយ៉ាងនេះ ដើម្បីធ្វើអត្ថនោះឲ្យប្រាកដក្រៃលែងឡើង ដោយពាក្យដែលចងជាគាថា ។ បទថា **រតនានត្ថកាវិត្តិយោ** បានដល់ ស្រីទាំងឡាយជាអ្នកធ្វើអន្តរាយដល់រតនៈ

ទាំងឡាយដែលប្ដីរកមកបាន ដោយសេចក្ដីនឿយហត់ នាំយករតនៈទាំងនោះទៅឲ្យបុរសដទៃ រមែងប្រព្រឹត្តអនាចារ ។

ខាងមុខអំពីនេះទៅ បក្សីកុណាលកាលសម្ដែងគាថាដ៏ក្បោះក្បាយរបស់ខ្លួន ដោយប្រការផ្សេងៗ ទើបពោលថា

នែបុណ្ណមុខៈសម្លាញ់ ទ្រព្យណា ដែលបុគ្គលមិនត្រូវឲ្យនៅក្នុងត្រកូលនៃជនដទៃ ទ្រព្យទាំងនេះ មាន ៤ យ៉ាងគឺ គោឈ្មោល ១ មេគោ ១ យាន ១ ភរិយា ១ បណ្ឌិតមិនត្រូវញុំាងទ្រព្យទាំង ៤ យ៉ាងនេះ ឲ្យនៅប្រាសចាកផ្ទះឡើយ ។

បុគ្គលមិនគប្បីញុំាងគោឈ្មោល ១ គោញី ១ យាន ១ ភរិយា ១ ឲ្យនៅក្នុងត្រកូលញាតិទេ ( ព្រោះថា ) ពួកបុគ្គល មិនមានរទេះ រមែងប្រើប្រាស់រទេះ បៀតបៀនទូវគោឈ្មោល ដោយការដឹកនាំហួសកម្លាំង បៀតបៀនមេគោ ដោយការរូតទឹកដោះ ភរិយារមែងប្រព្រឹត្តខូច ( ក្បត់ចិត្តប្ដី ) ក្នុងត្រកូលនៃញាតិ ។

នែបុណ្ណមុខៈសម្លាញ់ វត្ថុ ៦ យ៉ាងនេះ រមែងមិនបានជាប្រយោជន៍ចំពោះកិច្ចការ ដែលកើតឡើងទេ ( វត្ថុ ៦ យ៉ាង ) គឺធ្នូគ្មានបន្ទោះ ១ ភរិយា ( ដែលនៅ ) ក្នុងត្រកូលញាតិ ១ ទូកនៅឯត្រើយម្ខាង ១ រទេះបាក់ភ្លៅ ១ មិត្តនៅក្នុងទីឆ្ងាយ ១ សម្លាញ់ដ៏លាមក ១ ( ទាំងនេះ ) រមែង

មិនបានជាប្រយោជន៍ចំពោះកិច្ចការដែលកើតឡើងទេ ។

នែបុណ្ណមុខៈសម្លាញ់ ស្រីរមែងមើលងាយប្តីដោយហេតុ ៨ យ៉ាងគឺ សេចក្តីទ័លក្រ ១ សេចក្តីឈឺចាប់ជានិច្ច ១ សេចក្តីចាស់គ្រាំគ្រា ១ ភាពជាអ្នកលេងផឹកសុរា ១ ភាពល្ងង់ខ្លៅ ១ សេចក្តីធ្វេសប្រហែស ១ ការមិនប្រព្រឹត្តធ្វើរឿយៗ ក្នុងកិច្ចការទាំងពួង ១ ការមិនញុំាងទ្រព្យសម្បត្តិគ្រប់យ៉ាងឲ្យកើតមាន ១ នែបុណ្ណមុខៈសម្លាញ់ ស្រីរមែងមើលងាយប្តីដោយហេតុ ៨ យ៉ាងនេះឯង ។ ពាក្យក្នុងរឿងនេះ មានតទៅទៀត

ស្រីមើលងាយប្តី ( ដោយហេតុ ៨ យ៉ាង ) គឺ ប្តីទ័លក្រ ១ ប្តីឈឺជានិច្ច ១ ប្តីចាស់គ្រាំគ្រា ១ ប្តីជាអ្នកលេងផឹកសុរា ១ ប្តីធ្វេសប្រហែស ១ ប្តីដល់នូវភាពល្ងង់ខ្លៅ ១ ប្តីខ្ជិលច្រអូសក្នុងកិច្ចការ ១ ប្តីញុំាងសេចក្តីប្រាថ្នាក្នុងវត្ថុដែលគួរប្រាថ្នាគ្រប់យ៉ាងឲ្យវិនាស ១ ។

នែបុណ្ណមុខៈសម្លាញ់ ស្រីរមែងនាំមកនូវការប្រព្រឹត្តខូចដោយហេតុ ៩ យ៉ាងគឺ ស្រីទៅកាន់សួនច្បាររឿយៗ ១ ទៅកាន់ឧទ្យានរឿយៗ ១ ទៅកាន់កំពង់ស្ទឹងរឿយៗ ១ ទៅកាន់ត្រកូលញាតិរឿយៗ ១ ទៅកាន់ត្រកូលដទៃរឿយៗ ១ ប្រកបរឿយៗក្នុងការលៃលកតែខាងកញ្ចក់ និងសំពត់ និងគ្រឿង

ស្អិតស្អាងជាប្រក្រតី ១ ផឹកនូវទឹកស្រវឹងជាប្រក្រតី ១ មានការលបមើលបុរសមិនដាច់ជាប្រក្រតី ១ ឈរបង្ហាញខ្លួនទៀបមាត់ទ្វារជាប្រក្រតី ១ នែបុណ្ណមុខៈសម្លាញ់ ស្រីរមែងនាំមកនូវការខូចកាចដោយហេតុ ៩ យ៉ាងនេះឯង ។

ពាក្យក្នុងរឿងនេះ មានតទៅទៀត

ពួកស្រី តែងនាំមកនូវការខូច ដោយហេតុ ៩ យ៉ាងគឺ ជាអ្នកទៅកាន់សួនច្បាររឿយៗ ១ ទៅកាន់ឧទ្យាន ១ ទៅកាន់ស្ទឹង ១ ទៅកាន់ត្រកូលញាតិ ១ ទៅកាន់ត្រកូលដទៃ ១ ប្រកបរឿយតែខាងសំពត់និងគ្រឿងស្អិតស្អាង ១ ជាស្រីផឹកទឹកស្រវឹងជាប្រក្រតី ១ មានការលបមើលបុរសមិនដាច់ជាប្រក្រតី ១ ឈរបង្ហាញខ្លួនទៀបមាត់ទ្វារជាប្រក្រតី ១ ។

នែបុណ្ណមុខៈសម្លាញ់ ស្រីរមែងបៃចង់បុរស ដោយហេតុ ៤០ យ៉ាងគឺ កាច់រាង ១ បន្ទន់ខ្លួន ១ កែក្រាយ ១ ក្រអឺមក្រអៀម ១ យកក្រចកផ្ទាត់ក្រចក ១ យកជើងជាន់ជើង ១ យកកំណាត់ឈើគូសផែនដី ១ លើកកូនក្មេងដោយខ្លួនឯង ១ ឲ្យកូនក្មេងលើកខ្លួនវិញ ១ លេងកូនក្មេងដោយខ្លួនឯង ១ ញុំាងកូនក្មេងឲ្យលេង ១ ថើបកូនក្មេងដោយខ្លួនឯង ១ ញុំាងកូនក្មេងឲ្យថើបវិញ ១ ស៊ីខ្លួនឯង ១ ញុំាងកូនក្មេងឲ្យស៊ី ១ ឲ្យវត្ថុទៅកូនក្មេង ១ សុំលួងលោមយកមកវិញ ១

ធ្វើត្រាប់តាម ( ក្មេង ) ដែលវាធ្វើ ១ និយាយខ្លាំង ១ និយាយតិច ១ និយាយបើកចំហមាត់ ១ និយាយលាក់លៀម ១ ( ធ្វើនូវនិមិត្ត ) ដោយអាការរាំច្រៀង ប្រគំ យំ រាប់រៀបម៉ិកម៉ក់ស្អិតស្អាង ១ សើចក្អាកក្អាយ ១ សម្លឹងសំឡក់ ១ ញាក់ចង្កេះ ១ ញ៉ាំងទ្រព្យកំបាំងឲ្យកម្រើក ១ បើកបង្ហាញភ្លៅ ១ បិទភ្លៅទៅវិញ ១ បង្ហាញដោះ ១ បង្ហាញក្លៀក ១ បង្ហាញផ្ចិត ១ មិចភ្នែក ១ ញាក់ចិញ្ចើម ១ ខាំបបូរមាត់ ១ លៀនអណ្តាត ១ ច្បូតសំពត់ ១ ស្លៀកសំពត់វិញ ១ រំសាយសក់ ១ បួងសក់វិញ ១ នៃបុណ្ណមុខៈសម្លាញ់ ស្រីរមែងចែចង់បុរសដោយហេតុ ៤០ យ៉ាងនេះឯង ។

នៃបុណ្ណមុខៈសម្លាញ់ ស្រីដែលខូច បណ្ឌិតគប្បីដឹងដោយហេតុ ២៥ យ៉ាង គឺស្រីសរសើរការនៅឃ្លាតអំពីប្តី ១ មិនរឭកប្តីដែលនៅឃ្លាតគ្នា ១ មិនត្រេកអរនឹងប្តី ដែលទើបមកដល់ ១ ពោលទោសប្តីនោះ ១ មិននិយាយសរសើរគុណប្តីនោះ ១ ប្រព្រឹត្តនូវសេចក្តីវិនាសដល់ប្តីនោះ ១ មិនប្រព្រឹត្តសេចក្តីចម្រើនដល់ប្តីនោះ ១ ធ្វើតែអំពើដែលមិនគួរធ្វើដល់ប្តីនោះ ១ មិនធ្វើអំពើដែលគួរធ្វើដល់ប្តីនោះ ១ ស្លៀកជាប់មាំមួនដេក ១ លបដេកកំបាំងមុខ ១ ដេកបម្រះ

នទៀល ១ បន្ទជម្លោះ ១ ដកដង្ហើមចេញវែង ( ដូចជា ) វេទនុក្ខ ១ ទៅកាន់ទីឧច្ចារៈ បស្សាវៈរឿយៗ ១ ប្រព្រឹត្ត ទទឹងទាស់ ១ ឮសំឡេងប្រុសឯទៀត ខំផ្ទៀងត្រចៀកស្តាប់ ១ ជាស្រីបំផ្លាញទ្រព្យ ១ ធ្វើនូវសន្ថវកិច្ចនឹងប្រុសទាំងឡាយ ដែលស្និទ្ធស្នាល ១ បានតែខាងជើងចេញដើរ ១ ជាស្រី ប្រព្រឹត្តដើរលេងរឿយៗក្នុងវេលាយប់ ប្រព្រឹត្តកន្លងចិត្តប្តី ១ មិនគោរពប្តី ១ មានចិត្តគំនិតខូចកាច ១ ឈរទៀបមាត់ទ្វារ ញយៗ ១ បង្ហាញក្លៀក រាងកាយ ដោះ ដើរទៅកាន់ទិស ទាំងពួងហើយក្រឡេកមើល ១ នែបុណ្ណមុខៈសម្លាញ់ ស្រី ដែលខូច បណ្ឌិតគប្បីដឹងដោយហេតុ ២៥ យ៉ាងនេះឯង ។ ពាក្យក្នុងរឿងនុ៎ះដូចមានតទៅទៀត

ស្រីសរសើរការនៅឃ្លាតអំពីប្តីនោះ ១ មិននឹកស្រណោះ រកប្តីដែលទៅហើយ ១ ឃើញប្តីមកដល់មិនត្រេកអរ ១ មិនពោលសរសើរគុណប្តីក្នុងកាលណាម្តង ១ ទាំងនេះជា លក្ខណៈរបស់ស្រីខូច ។ ស្រីជាអ្នកមិនសង្រួម ប្រព្រឹត្តនូវ សេចក្តីវិនាសដល់ប្តីនោះ ១ ញុំាងប្រយោជន៍ឲ្យវិនាស ១ ជាអ្នកធ្វើនូវកិច្ចដែលមិនគួរធ្វើ ១ ស្លៀកជាប់មាំមួនដេក ១ ដេកក្នុងទីកំបាំងមុខ ១ ទាំងនេះ ជាលក្ខណៈរបស់ស្រីខូច ។ ស្រីដេកបម្រះនទៀល ១ បន្ទជម្លោះ ១ ដកដង្ហើមវែង

( ហាក់ដូជា ) វេទនា ១ ទៅកាន់ទីឧច្ចារៈបស្សាវៈរឿយៗ ១ ទាំងនេះជាលក្ខណៈរបស់ស្រីខូច ។ ស្រីជាអ្នកមិនធ្វើការងារ តែងប្រព្រឹត្តទទឹងទាស់ ១ ផ្ទៀងស្តាប់សំឡេងរបស់បុរសដទៃនិយាយ ១ បំផ្លាញទ្រព្យ ១ ធ្វើសន្ថវកិច្ច ( នឹងបុរសដទៃ ) ១ ទាំងនេះជាលក្ខណៈរបស់ស្រីខូច ។ បំផ្លាញទ្រព្យសម្បត្តិដែលប្តីបានមកដោយក្រ នាំមកដោយលំបាក បានមកដោយទុក្ខ ១ ធ្វើសន្ថវកិច្ចនឹងពួកបុរសអ្នកស្និទ្ធស្នាល ១ ទាំងនេះជាលក្ខណៈរបស់ស្រីខូច ។ ស្រីបានតែខាងជើងចេញដើរ ១ ដើរលេងរឿយៗ ក្នុងវេលាយប់ ១ មានចិត្តប្រទូស្តចំពោះប្តីជានិច្ច ១ ប្រព្រឹត្តកន្លងចិត្តប្តី ១ ប្រាសចាកសេចក្តីគោរព ១ ទាំងនេះជាលក្ខណៈរបស់ស្រីខូច ។ ស្រីឈរទៀបមាត់ទ្វារញយៗ ១ បង្ហាញដោះនិងក្លៀក ១ មានចិត្តភ្ញាក់ផ្អើលក្រឡេកមើលទិសទាំងពួង ១ ទាំងនេះជាលក្ខណៈរបស់ស្រីខូច ។ ស្ទឹងទាំងអស់មានដំណើរវៀច ព្រៃទាំងអស់សម្រេចអំពីឈើ ( យ៉ាងណាមិញ ) ពួកស្រីទាំងអស់ ( វៀរលែងតែស្រីដែលមានកិលេសស្តើង ) កាលបើមានបុគ្គលអ្នកខ្សឹបខ្សៀវ ក៏តែងធ្វើនូវអំពើលាមកបាន ( យ៉ាងនោះដែរ ) ។ ពួកស្រីបាននូវឱកាស ឬទីកំបាំង ឬក៏បាននូវបុគ្គលខ្សឹបខ្សៀវ ប្រាកដ

ដូច្នោះ ពួកស្រីទាំងអស់ មិនបានទូវបុរសដទៃ ក៏គប្បីធ្វើនូវអំពើលាមកជាមួយបុរសខ្វិនបាន ។ ពួកបុរស ទោះបីធ្វើនូវអំណរចំពោះនារីទាំងឡាយ ជាអ្នកធ្វើនូវសេចក្តីត្រេកអរដល់ពួកបុរស ជាស្រីមានចិត្តច្រើន ដែលគេផ្គញ់ផ្គាល់មិនបាន ដោយប្រការទាំងពួង បុគ្គលមិនត្រូវស្និទ្ធស្នាលទេ ព្រោះថា ស្ត្រីទាំងឡាយស្មើដោយកំពង់ទឹក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **គោណាំ ធេនុ** លោកពោលទុកដោយអំណាចលិង្គវិបល្លាស ។ បទថា **ញាតិកុលេ បធុស្សតិ** សេចក្តីថា ក្នុងត្រកូលញាតិនោះ នាងមិនមានការខ្លាច រមែងប្រព្រឹត្តអនាចារ សូម្បីនឹងពួកទាសៈជាដើមដែលស្និទ្ធស្នាលគ្នា ចាប់តាំងអំពីកាលខ្លួនជាកុមារនោះឯង ទោះបីពួកញាតិដឹង ក៏មិនបានធ្វើការតិះដៀល បិទបាំងនូវទោសដែលមិនមែនជាកិត្តិយសរបស់ខ្លួន រមែងធ្វើដូចមិនដឹង ។ បទថា **អនត្ថចរាណិ** បានដល់សន្សឹមនូវប្រយោជន៍មិនបាន មិនគប្បីបាននូវប្រយោជន៍ឡើយ គឺធ្វើនូវកិច្ចមិនបាន ។ បទថា **អគុណាំ** បានដល់ ធ្នូដែលមិនមានខ្សែ ។ បទថា **ទាប-សហាយកោ** បានដល់ មិត្តអាក្រក់ ។ បទថា **ទលិទ្ទតា** បានដល់ ព្រោះភាពក្រីក្រ សូម្បីក្នុងពាក្យដ៏សេស ក៏មានន័យនេះដូចគ្នា អធិប្បាយក្នុងគាថានោះថា ប្តីដែលក្រីក្រ មិនអាចសង្គ្រោះខ្លួនបានដោយកិលេស ព្រោះមិនមានគ្រឿងប្រដាប់ជាដើម ព្រោះហេតុនោះ ទើបភរិយាមើលងាយប្តី ដោយប្រការដូច្នេះ សូម្បីប្តីជាអ្នកមានជំងឺ ក៏មិនអាចជួយសង្គ្រោះអ្វីបាន ដោយវត្ថុកាម

និងកិលេសកាម ប្តីដែលចាស់ជរា ក៏មិនអាចនឹងថ្នាក់ថ្នម ឬធ្វើនូវការត្រេកអរឲ្យកើតឡើងបាន ទាំងផ្លូវកាយនិងផ្លូវចិត្ត ។ ប្តីដែលជាអ្នកលេងសុរា ក៏តែងនាំយកគ្រឿងប្រដាប់មានខ្សែក ឬខ្សែដៃរបស់ភរិយាជាដើម ចូលទៅកាន់រោងសុរា ។ បទថា **មុទុ** បានដល់ ប្តីដែលជាអន្ធពាល រមែងមិនឈ្លាសក្នុងការថ្នាក់ថ្នម ។ បទថា **បមត្តំ** បានដល់ ប្តីដែលជាអ្នកលេង រមែងអភិរម្យជាមួយពួកទាសីក្នុងផ្ទះរបស់ខ្លួន និងរមែងជេរបរិភាសភរិយា ទើបភរិយាមើលងាយប្តីដោយហេតុនោះឯង ។ ភរិយា រមែងជេរប្តីដែលមិនធ្វើតាម ក្នុងកិច្ចការទាំងពួងថា ប្តីរបស់អញនេះអស់នូវតេជះហើយទើបប្រព្រឹត្តតាមអញរហូត ។ ឯប្តីណា មិនធ្វើទ្រព្យទាំងពួងឲ្យកើតឡើង ប្រគល់ទ្រព្យទាំងអស់ឲ្យគ្រប់គ្រង ភរិយាក៏រមែងកាន់យកទ្រព្យធនដែលជាសារសម្បត្តិទាំងអស់ទុកក្នុងកណ្តាប់ដៃ មើលងាយប្តីដូចជាទាសៈ កាលប្រាថ្នា ក៏អូសស្វាមីចេញទៅខាងក្រៅផ្ទះ ដោយពាក្យថា ប្រយោជន៍អ្វី ដោយខ្លួនលោក ។ បទថា **មុទុបត្តំ** បានដល់ ដល់នូវភាពជាអ្នកល្ងង់ខ្លៅ ។ បទថា **ឧត្តំ** បានដល់ ជាអ្នកប្រហែសធ្វេស ។

បទថា **បនោសមាហរតិ** បានដល់ ភរិយារមែងនាំការប្រទូសរ៉ាយមកឲ្យប្តី អធិប្បាយថា រមែងប្រទូស្តគឺធ្វើកម្មដ៏លាមកដល់ប្តី ។ បទថា **អារាម-គមនសីលា** អធិប្បាយថា ភរិយាលាប្តីខ្លះ មិនប្រាប់ខ្លះ ត្រាច់ទៅកាន់សួនច្បារជាដើមណាមួយរឿយៗ ប្រព្រឹត្តអនាចារក្នុងព្រៃនោះ ហើយបោកបញ្ឆោតប្តីដែលល្ងង់ខ្លៅ ឲ្យជឿថា ថ្ងៃនេះ ខ្ញុំទៅធ្វើពលីកម្មឲ្យដល់រុក្ខទេវតាក្នុងព្រៃ

ដូច្នេះជាដើម ។ ឯប្តីដែលជាអ្នកឈ្លាសរមែងដឹងទាន់ថា ស្រីនេះ គង់នឹងទៅធ្វើនូវអនាចារក្នុងទីនោះដោយពិត មិនឲ្យនាងទៅទៀត ក្នុងបទទាំងអស់ បណ្ឌិតគប្បីជ្រាបសេចក្តីយ៉ាងនេះដូចគ្នា ។

បទថា **បរកុលំ** បានដល់ ផ្ទះរបស់អ្នកដែលធ្លាប់ឃើញគ្នា និងធ្លាប់ជួបគ្នាជាដើម នាងពោលនឹងប្តីជាដើមថា ផលចំណេញដែលយើងប្រកបឡើងទុកក្នុងត្រកូលនោះមាន ទ្រព្យដែលឲ្យជារបស់ខ្ចីក្នុងត្រកូលនោះមាន ខ្ញុំនឹងទៅចាត់ចែងរឿងនោះឲ្យស្រេច ដូច្នេះហើយក៏ទៅ ។ បទថា **និល្លោកនសីលា** បានដល់ ចូលចិត្តសម្លឹងមើលតាមប្រហោងមានប្រហោងបង្អួចជាដើម ។ បទថា **បទ្វារដ្ឋាយិនី** បានដល់ ឈរត្រង់ទ្វារបង្ហាញរូបរាងទ្រង់ទ្រាយរបស់ខ្លួន ។ បទថា **អច្ចាវទតិ** បានដល់ ពោលកន្លងស្វាមី អធិប្បាយថា ស្រីដែលនៅក្នុងសម្នាក់របស់ប្តីហើយ សម្តែងនិមិត្តដល់ប្រុសដទៃ ។

បទថា **វិជម្ភតិ** បានដល់ ស្រីធ្វើនូវការសង្កេតឬមិនបានធ្វើនូវសង្កេតទុកមុនថា លោកគប្បីដឹងថា ឱកាសមានឬមិនមាន ឈរនៅក្រោយប្តីនោះឯងរមែងពត់កាយ គឺសម្តែងអាការមឹតពត់កាយ ដោយគិតថា បុរសនេះនឹងស្រមៃដល់អញយ៉ាងនេះ ។ បទថា **វិឆមតិ** បានដល់ ធ្វើជាជ្រុះវត្ថុណាមួយលើផែនដី ធ្វើជាឱនរើសវត្ថុនោះ បង្ហាញនូវសាច់ខ្នង ។ បទថា **វិលាសតិ** បានដល់ សម្តែងអាការកែក្រាយ ដោយឥរិយាបថទាំងឡាយ មានការដើរជាដើម ឬដោយគ្រឿងប្រដាប់ ។ បទថា **វិលជ្ជតិ** បានដល់ ធ្វើជាអៀនហើយបិទសរីរៈដោយសំពត់ ឬលួចមើលតាមសន្ទុះទ្វារ ឬជញ្ជាំង ។ បទថា

**ឆេទន** បានដល់ យកក្រចកជើងនិងក្រចកជើង យកក្រចកដៃនិងក្រចកដៃ ថ្កឹះគ្នា ។ បទថា **កាដ្ឋេន** សំដៅដល់ កំណាត់ឈើ ។ បទថា **ធារកំ** បានដល់ ចាប់កូនរបស់ខ្លួនឯងខ្លះ កូនរបស់អ្នកដទៃខ្លះ ហើយលើកឡើងឯងខ្លះ ឲ្យអ្នកដទៃលើកខ្លះ ។ បទថា **កីឡតិ** បានដល់ លេងឯងខ្លះ ឲ្យក្មេងលេងខ្លះ សូម្បីក្នុងការថើបជាដើម ក៏មានន័យដូចគ្នា ។ បទថា **ទទាតិ** បានដល់ ឲ្យនូវផ្លែឈើខ្លះ ស្លឹកឈើខ្លះ ផ្កាខ្លះ ណាមួយដល់ក្មេងនោះ ។ បទថា **យាចតិ** បានដល់ សុំវត្ថុទាំងនោះ ។ បទថា **អនុករោតិ** បានដល់ ធ្វើត្រាប់កូនក្មេង ។ បទថា **ឧច្ចំ** បានដល់ ទីខ្ពស់ ដោយអំណាចធ្វើសំឡេងខ្លាំង ឬសរសើរ ។ បទថា **នីចំ** បានដល់ សំឡេងទាបដោយអំណាចធ្វើសំឡេងតិច ដោយអំណាចការពោលពាក្យដែលមិនពេញចិត្ត ឬដោយអំណាចការពោលពាក្យមើលងាយ ឬប្រមាថ ។ បទថា **អាវិច្ចំ** បានដល់ ពោលមិនបិទបាំងក្នុងកណ្តាលពួកជនច្រើន ។ បទថា **វិវិច្ចំ** បានដល់ និយាយបិទបាំង ( ខ្សឹប ) ក្នុងទីកំបាំង ។ បទថា **នច្ចេន** បានដល់ ការធ្វើនិមិត្តដោយការរាំជាដើម ។ បទថា **រោទិតេន** បានដល់ ធ្វើនិមិត្តដោយហេតុនៃការយំ ។ បណ្ឌិតគប្បីពោលដល់រឿងព្រាហ្មណីរបស់បុរោហិត ដែលសេដ្ឋីបុត្ត បីបុះតាមបង្អួចក្នុងយប់ដែលមានភ្លៀងធ្លាក់ នាំមកហើយជាឧបមា ។ បទថា **ជគ្ឃតិ** បានដល់ សើចដោយសំឡេងខ្លាំង ស្រីរមែងធ្វើនិមិត្តដោយអាការយ៉ាងនេះ ។ បទថា **កច្ឆំ** បានដល់ ក្លៀក ។ បទថា **ឱដ្ឋំ** បានដល់ បបូរមាត់ខាងលើ ។ បទថា **បលិក្ខតិ** បានដល់ យកធ្មេញខាំ ។ បទថា **សិរសំ** បានដល់ ផ្គងសក់

អធិប្បាយថា ស្រីរមែងធ្វើនិមិត្តដល់បុរសដទៃ ដោយការរំសាយសក់ និងក្ដួចផ្នួងសក់យ៉ាងនេះ ម្យ៉ាងទៀត នាងធ្វើដោយគិតថា បុគ្គលណាមួយ ទោះកំណត់ ឬមិនកំណត់នឹងមានការត្រេកអរ ។

បទថា **បត្ថទ្ធា ផេនិតញ្ញា ភវតិ** បានដល់ បណ្ឌិតគប្បីជ្រាបចុះថា ស្រីនេះប្រទូស្តក្នុងអញ គឺក្រោធនឹងអញ កាលក្រោធហើយ នឹងធ្វើអនាចារ ។ បទថា **បវាសំ** បានដល់ ស្រីពោលពាក្យជាដើមថា ទ្រព្យដែលយើងប្រកបឡើងទុកក្នុងស្រុកនោះនឹងវិនាស សូមអ្នកទៅ ចូរចាត់ចែងទ្រព្យនោះឲ្យសម្រេច ចូរធ្វើនូវការចរចា កាលប្ដីទៅហើយ ប្រាថ្នានឹងធ្វើអនាចារ ទើបពណ៌នាការទៅខាងរនោជ ។ បទថា **អនត្ថំ** បានដល់ វត្ថុដែលមិនជាប្រយោជន៍ គឺមិនមែនសេចក្ដីចម្រើន ។ បទថា **អកិច្ចំ** បានដល់ មិនមែនកិច្ចដែលគួរធ្វើ ។ បទថា **បរិធហិត្វា** បានដល់ ស្លៀកដណ្ដប់យ៉ាងខ្ជាប់ខ្ជួន ។ បទថា **បរិវត្តកជាតា** បានដល់ បម្រះទៅខាងនោះទៅខាងនេះ ។ បទថា **កុញ្ចមិយជាតា** បានដល់ ធ្វើឲ្យកើតកោលាហល ធ្វើជាជាស់អ្នកបម្រើដែលដេកក្បែរជើងឲ្យដុតភ្លើង ធ្វើនូវការភ្ញាក់ផ្អើល មានប្រការផ្សេងៗ រមែងញុំាងនូវការត្រេកអរផ្លូវកិលេសរបស់ប្ដីឲ្យជាប់ទៅ ។ បទថា **ធុក្ខំ វេទយតិ** បានដល់ នាងពោលពាក្យជាដើមថា ខ្ញុំឈឺក្បាលណាស់ជាដើម ។ បទថា **វិ-លោមមាចរតិ** បានដល់ រមែងជាអ្នកមានប្រក្រតីប្រព្រឹត្តជាសត្រូវ ដោយអំណាចនៃអាការផ្សេងៗ ជាដើមថា បើប្ដីចូលចិត្តអាហារត្រជាក់ ក៏ឲ្យអាហារក្ដៅដូច្នេះ ។ បទថា **ឆីហាតភោគា** បានដល់ នាំភោគសម្បត្តិ ដែលប្ដីរក

បានដោយការនៀយហត់ឲ្យវិនាសទៅ ដោយភាពជាអ្នកឡេះឡោះព្រោះសុរាជាដើម ។ បទថា **សន្ថវំ** បានដល់ ធ្វើនូវសេចក្តីស្និទ្ធស្នាលដោយអំណាចកិលេស ។ បទថា **និក្ខន្តទាឋា** បានដល់ ចេញក្រៅផ្ទះដើម្បីស្វែងរកសហាយ ។ បទថា **សាមិកេ** បានដល់ រមែងជាអ្នកប្រព្រឹត្តក្រៅចិត្ត ដោយការមិនគោរពក្នុងស្វាមី និងជាអ្នកមានចិត្តប្រទូស្ត ។ បទថា **សត្តិត្តិយោ** បានដល់ វៀរចាកស្រីដែលធ្វើកិលេសឲ្យស្រោលស្តើង ដោយវិបស្សនាហើយ ស្រីដ៏សេសទាំងអស់រមែងប្រព្រឹត្តលាមក ។ បទថា **លភមានេ** បានដល់ កាលមានឱកាស ។ បទថា **និវាតកេ** បានដល់ កាលបានទីកន្លែងប្រឹក្សា ឬធ្វើនូវការញុះញង់យ៉ាងកំបាំង ។ បទថា **១ណំ វា រហោ វា** បានដល់ គប្បីធ្វើឱកាស ឬទីកំបាំងដើម្បីប្រព្រឹត្តអាក្រក់ ។ បទថា **ន** ត្រឹមតែជានិបាត ។ បទថា **អលត្ថា** បានដល់ មិនបានហើយ ។ម្យ៉ាងទៀត បាលីជា **អលទ្ធា** ដូច្នេះក៏មាន អធិប្បាយថា កាលមិនបានបុរសដទៃដែលបរិបូរណ៍ ( ដោយអវយវៈជាដើម ) ក៏គប្បីធ្វើកម្មអាក្រក់ សូម្បីជាមួយបុរសខ្វិន ឬជាមួយបុរសដែលមានរូបគួរខ្ពើមជាងនោះ ។ បទថា **អាវាមកភាសុ** បានដល់ ធ្វើឲ្យកើតបីតិ គឺធ្វើឲ្យកើតសេចក្តីត្រេកអរ ។ បទថា **អនិគ្គហាសុ** បានដល់ មិនអាចណែនាំដោយការសង្កត់សង្កិនបាន ។ បទថា **តិត្ថសមា** បានដល់ កំពង់ទឹកមិនឃាត់បុគ្គលណាមួយ បណ្តាអ្នកដែលខ្ពង់ខ្ពស់ និងមនុស្សដែលថោកទាប ដែលទៅចុះងូតទឹក យ៉ាងណា សូម្បីស្រីទាំងនេះ កាលមានឱកាស ឬទីកំបាំង រមែងមិនឃាត់បុរសណាមួយដូចគ្នា ដូច្នេះ ។

តទៅនេះ ព្រះអដ្ឋកថាចារ្យនាំរឿងផ្សេងៗ មកសាធកៈទុកថា នៅក្នុងអតីតកាល មានព្រះរាជាមួយអង្គ ព្រះនាមថា កិន្នរ សោយរាជ្យក្នុងនគរពារាណសី មានព្រះរូបឆោមល្អក្រៃលែង អាមាត្យ ១០០០ នាក់ រមែងនាំប្រអប់ដែលជាគ្រឿងក្រអូប ១០០០ មកថ្វាយរាល់ៗ ថ្ងៃ អាមាត្យទាំងនោះកាលប្រោះព្រំនូវគ្រឿងក្រអូបក្នុងរាជនិវេសន៍ទូទៅហើយ ក៏ពុះប្រអប់ធ្វើជាឧសក្រអូបចម្អិនព្រះក្រយាហារថ្វាយ ។ មហេសីរបស់ព្រះបាទកិន្នរនោះ មានរូបល្អក្រៃលែង ព្រះនាមថាកិន្នរី ព្រះបាទកិន្នរ មានបុរោហិតម្នាក់ មានបញ្ញាមុតស្រួច ឈ្មោះបញ្ចាលចណ្ឌៈ មានអាយុដំណាលគ្នានឹងព្រះអង្គ ។ ជាប់គ្នានឹងប្រាសាទរបស់ព្រះបាទកិន្នរនោះ មានដើមព្រីងមួយដុះនៅក្នុងកំពែង មែកព្រីងក៏លូតឆ្លងកំពែងចេញទៅ មានបុរសខ្វិនម្នាក់ មានរូបអាក្រក់គួរខ្ពើមអាស្រ័យនៅត្រង់ម្លប់ព្រីងនោះ ។ ថ្ងៃមួយ ព្រះនាងកិន្នរីទេវីទតទៅតាមបង្អួចឃើញបុរសខ្វិននោះហើយ ក៏មានចិត្តប្រតិព័ទ្ធ ក្នុងពេលរាត្រី ញុំាងព្រះបាទកិន្នរឲ្យត្រេកអរ ដោយកិលេសហើយ ឲ្យផ្ទំលក់ទៅ ទើបនាងក្រោកឡើងសន្សឹមៗ រៀបចំនូវអាហារដ៏ប្រណីត មានរសឆ្ងាញ់ដាក់ក្នុងផ្តិលមាស ទុកក្នុងថ្នក់ ហើយគោងខ្សែដែលតជាយសំពត់ ចុះតាមបង្អួចឡើងដើមព្រីង ស្ទួចុះតាមមែក អញ្ជើញបុរសខ្វិនឲ្យបរិភោគអាហារ ហើយធ្វើអំពើលាមកជាមួយបុរសខ្វិនស្រេចបាច់ហើយ ក៏ឡើងកាន់ប្រាសាទវិញតាមផ្លូវដែលចុះមកនោះឯង ប្រោះព្រំសរីរកាយដោយគ្រឿងក្រអូបហើយ ចូលទៅផ្ទំជាមួយព្រះបាទកិន្នរ ព្រះនាងប្រព្រឹត្តលាមកយ៉ាងនេះជានិច្ចមក ព្រះបាទកិន្នរ ក៏ទ្រង់

មិនជ្រាប ។ ថ្ងៃមួយ ទ្រង់ប្រទក្សិណព្រះនគរ ពេលទ្រង់ត្រឡប់ចូលព្រះរាជនិវេសន៍ បានទតឃើញបុរសខ្វិន មានអាការគួរករុណាក្រៃលែងត្រង់ម្លប់ព្រីង ទើបត្រាស់សួរបុរោហិតថា អ្នកឃើញមនុស្សប្រេតនោះដែរឬទេ កាលបុរោ- ហិតទូលព្រះរាជឱង្ការថា ឃើញ ទើបត្រាស់សួរបន្តថា បុរសមានរូបគួរខ្ពើមបែបនោះ មានស្រីគប់រកដោយអំណាចតន្ហារាគៈខ្លះដែរឬហ្ន៎ បុរសខ្វិនបានស្តាប់ព្រះតម្រាស់នោះ ក៏កើតមានះឡើង គិតថា ស្តេចផែនដីនិយាយអ្វីដូច្នេះ ប្រហែលជាមិនដឹងថា ព្រះទេវីរបស់ខ្លួនមករកអញ គិតហើយ ក៏ប្រណម្យដៃ ថ្វាយបង្គំដើមព្រីង ពោលវាចារឿយៗថា អញ្ជើញទេវតាដែលអាស្រ័យនៅត្រង់ដើមព្រីងស្តាប់ខ្ញុំចុះ អ្នកដទៃៗក្រៅអំពីលោកហើយ ក៏មិនមានអ្នកណាដឹងឡើយ ។

បុរោហិតឃើញកិរិយារបស់បុរសខ្វិន ក៏គិតថា អគ្គមហេសីរបស់ព្រះរាជា ពិតជាចុះតាមដើមព្រីងមកប្រព្រឹត្តអាក្រក់ជាមួយបុរសខ្វិននេះដោយពិត គិតហើយ ទើបទូលសួរព្រះរាជាថា បពិត្រព្រះអង្គ ក្នុងកាលរាត្រី ទ្រង់ប៉ះសរីរកាយរបស់ព្រះទេវី មានអាការដូចម្តេច ព្រះបាទកិន្នរត្រាស់ឆ្លើយថា វត្ថុដទៃក៏មិនធ្លាប់ឃើញ តែកណ្តាលយប់ សរីរកាយរបស់ព្រះនាងត្រជាក់ បុរោហិតទូលថា បើដូច្នោះ អ្នកដទៃចូរលើកទុកចុះ ព្រះនាងកិន្នរីអគ្គមហេសីរបស់ព្រះអង្គ បានប្រព្រឹត្តកម្មដ៏លាមកជាមួយនឹងបុរសខ្វិននេះ ព្រះបាទកិន្នរត្រាស់ឆ្លើយថា សម្លាញ់និយាយអ្វី នាងកិន្នរីសម្បូរដោយរូបដ៏ឧត្តមបែបនោះមករួមអភិរម្យជាមួយបុរសខ្វិនដែលគួរខ្ពើមបែបនេះបានដូចម្តេច បុរោហិត

ទូលថា បើដូច្នោះ សូមទ្រង់ឃ្លាំចាំមើលចុះ ។ ព្រះបាទកិន្នរទ្រង់ព្រមទទួលថា សាធុ កាលសោយព្រះក្រយាហារល្ងាចហើយ ក៏ចូលព្រះបន្ទំជាមួយនាងកិន្នរី តាំងចិត្តចាំសង្កេត លុះដល់វេលាផ្ទំតាមប្រក្រតី ទ្រង់ក៏ក្លែងធ្វើជាផ្ទំលក់ទៅ ។ ឯនាងកិន្នរីក្រោកឡើង តាមទម្លាប់ ព្រះបាទកិន្នរ ក៏ឃ្លាំចាំមើល ទៅឈរត្រង់ស្រមោលដើមព្រីង ។ ថ្ងៃនោះ បុរសខ្វិនក្រោធ គំហកថា ហេតុអ្វីទើបមកយឺត ហើយយកដៃទះកំភ្លៀង ព្រះទេវីនាងក៏សូមទោសថា អ្នកកុំអាលខឹងឡើយ ខ្ញុំរង់ចាំឲ្យព្រះរាជាផ្ទំលក់ ទើបមកបាន ពោលហើយប្រព្រឹត្តប្រតិបត្តិបុរសនោះ ដូចស្រីបម្រើក្នុងផ្ទះ កាលបុរសខ្វិនទះកំភ្លៀងនាងកិន្នរីនោះ កុណ្ឌលមុខរាជសីហ៍ ក៏ជ្រុះអំពីត្រចៀក ខ្ទាតទៅជិតព្រះបាទារបស់ព្រះបាទកិន្នរ ព្រះបាទកិន្នរឃើញសមគួរ ទើបរើសយកទុកជាកស្តុតាង ឯនាងកិន្នរីប្រព្រឹត្តអនាចារជាមួយបុរសខ្វិននោះហើយ ក៏ត្រឡប់ទៅដោយន័យដើម ហើយផ្ទើមផ្ទំជាមួយព្រះរាជស្វាមី ឯព្រះបាទកិន្នរទ្រង់ឃាត់ ស្អែកឡើង ទើបត្រាស់ឲ្យមនុស្សទៅប្រាប់ថា សូមព្រះនាងកិន្នរីទេវីប្រដាប់នូវគ្រឿងអលង្ការដែលយើងប្រទានទាំងអស់ ហើយមកគាល់ ។ នាងកិន្នរ ក៏ឲ្យក្រាបទូលថា កុណ្ឌលមុខរាជសីហ៍បានបញ្ជូនទៅទុកឯផ្ទះជាងមាសហើយ នាងក៏មិនបានមកគាល់ កាលព្រះបាទកិន្នរត្រាស់ឲ្យហៅទៀត នាងក៏ប្រដាប់កុណ្ឌលតែម្ខាង ចូលទៅគាល់ ព្រះបាទកិន្នរត្រាស់សួរថា កុណ្ឌលទៅណា នាងក៏ទូលថា បញ្ជូនទៅផ្ទះជាងមាស ។ ព្រះបាទកិន្នរ ក៏ត្រាស់ឲ្យហៅជាងមាសមក ហើយត្រាស់សួរថា ហេតុអ្វីទើបអ្នកមិនឲ្យកុណ្ឌលដល់នាងកិន្នរី ជាង

មាសទូលថា ទូលព្រះបង្គំមិនបានទទួលឡើយ ។ ព្រះបាទកិន្នរ ក៏ទ្រង់ព្រះពិរោធត្រាស់ថា នៃស្រីចណ្ឌាល មនុស្សដូចយើងនេះឯងជាជាងមាសរបស់នាង ត្រាស់ហើយ ក៏លូកយកកុណ្ឌលដាក់ត្រង់មុខនាងកិន្នរីហើយ បែរមកត្រាស់ជាមួយបុរោហិតថា សម្លាញ់ពោលពិតនោះឯង ហើយត្រាស់ឲ្យកាត់ក្បាលនាងចោល បុរោហិត ក៏នាំនាងកិន្នរីទៅលាក់ក្នុងទីមួយខាងក្នុងព្រះរាជវាំងនោះ ហើយត្រឡប់ទៅគាល់ក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់កុំខ្ញាល់នឹងនាងកិន្នរីឡើយ ស្រីទាំងពួងរមែងដូចគ្នាយ៉ាងនេះទាំងអស់ បើទ្រង់មិនជឿបំណងនឹងជ្រាបរឿងទុស្តសីលរបស់ស្រីទាំងឡាយ
ទូលព្រះបង្គំនឹងបង្ហាញឲ្យមើលនូវកាពលាមក និងមាយារបស់ស្រីទាំងឡាយ សូមទ្រង់ក្លែងព្រះកាយ យាងទៅក្នុងជនបទជាមួយទូលព្រះបង្គំ ព្រះបាទកិន្នរទ្រង់ទទួលថា សាធុ ទ្រង់ប្រគល់រាជសម្បត្តិឲ្យដល់មាតា ហើយទ្រង់ក៏យាងទៅជាមួយបុរោហិត ។

កាលព្រះបាទកិន្នរ និងបុរោហិតទៅបានប្រមាណមួយយោជន៍ហើយ គង់សម្រាកក្បែរផ្លូវធំ ។ មានកុដុម្ពិកៈម្នាក់ ធ្វើវិវាហមង្គលដើម្បីបុត្ត ឲ្យនាងកុមារីម្នាក់អង្គុយក្នុងយានដែលបិទបាំង ហើយនាំមកដោយបរិវារជាច្រើន បុរោហិតបានឃើញហើយ ទើបទូលថា បពិត្រមហារាជ បើទ្រង់ប្រាថ្នា ទូលព្រះបង្គំអាចឲ្យកុមារីធ្វើកម្មអាក្រក់ជាមួយព្រះអង្គបាន ព្រះបាទកិន្នរត្រាស់ថា នៃសម្លាញ់ ឯងនិយាយអ្វី គេមកជាមួយបរិវារច្រើន ឯងមិនអាចធ្វើបានទេ បុរោហិតក៏ទូលថា បពិត្រព្រះអង្គ បើដូច្នោះ សូមទ្រង់ចាំទតចុះ ទូលហើយ

ក៏យកវាំងននមកបាំងជុំវិញ ឲ្យព្រះបាទកិន្នរប្រថាប់ក្នុងវាំងនន ហើយខ្លួនក៏ទៅអង្គុយយំក្បែរផ្លូវ កុដ្ដម្ពិកៈនោះឃើញក៏សួរថា អ្នកអង្គុយយំធ្វើអ្វី បុរោហិតក៏ឆ្លើយថា ឱ លោកអើយ ភរិយារបស់ខ្ញុំគ្រប់ខែ ខ្ញុំនាំធ្វើដំណើរមកបំណងនឹងទៅកាន់ត្រកូល លុះមកដល់កណ្ដាលផ្លូវក៏ឈឺពោះ លំបាកនៅក្នុងវាំងនន មិត្តស្រីត្រឹមម្នាក់ ក៏មិនមាន ខ្លួនខ្ញុំក៏មិនហ៊ានចូលទៅ មិនដឹងថាដូចម្ដេចទៅហើយ បើបានស្រីម្នាក់ជួយមើលប្រហែលជាគួរ កុដុម្ពិកៈ ក៏ឆ្លើយថា បើដូច្នោះ កុំយំឡើយ ស្រីរបស់ពួកយើងមានច្រើន ល្មមជួយបានត្រឹមតែម្នាក់ បុរោហិតក៏ពោលថា បើដូច្នោះ សូមឲ្យកុមារីនេះឯងទៅនឹងបានជាសុវត្ថិមង្គលដល់នាង ។ កុដុម្ពិកៈនោះគិតថា បុរសនេះនិយាយត្រូវសុវត្ថិមង្គលនឹងមានដល់កូនប្រសាស្រីរបស់អញពិត ដោយនិមិត្តនេះ កូនប្រសាស្រីរបស់អញនឹងចម្រើនដោយបុត្តធីតា គិតហើយ ទើបបញ្ជូនកុមារីនោះទៅ កុមារីនោះក៏ចូលទៅក្នុងវាំងនន លុះឃើញព្រះបាទកិន្នរក៏កើតសេចក្ដីស្រឡាញ់ បានប្រព្រឹត្តលាមកជាមួយព្រះរាជាហើយ ព្រះរាជាទ្រង់ដោះព្រះទម្រង់ព្រះរាជទាន លុះសម្រេចកិច្ច កុមារីនោះត្រឡប់មក ជនទាំងឡាយក៏សួរថា គេប្រសូតកូនប្រុសឬកូនស្រី នាងក៏ឆ្លើយថា កូនប្រុស ស្អាតដូចមាស ។ កុដុម្ពិកៈក៏នាំកុមារីទៅ ឯបុរោហិត ក៏ត្រឡប់មកគាល់ព្រះបាទកិន្នរ ហើយទូលថា បពិត្រព្រះអង្គ ទ្រង់ទតឃើញហើយឬ កុមារីនោះលាមកដល់ម៉្លេះ នឹងពោលថ្វីដល់ស្រីដទៃ ទ្រង់មានប្រទានអ្វីដល់នាងខ្លះដែរឬទេ ព្រះបាទកិន្នរត្រាស់ថា យើងឲ្យចិញ្ចៀនដែលពាក់មកដល់នាង បុរោហិតក៏ទូលថា

ព្រះអង្គប្រទានដល់នាងធ្វើអ្វី ពោលហើយ ក៏រត់ទៅទាញយានទុក កាលមនុស្សទាំងឡាយសួរថា មានរឿងអ្វី ក៏ឆ្លើយថា កុមារីនេះ យកចិញ្ចៀនដែលទុកក្បែរក្បាលរបស់ព្រាហ្មណីរបស់ខ្ញុំមក សូមឲ្យចិញ្ចៀនមកខ្ញុំវិញ កុមារីខ្លាចដៃបុរោហិតខណៈដែលឲ្យហើយ គំហកថា តាចោរយករបស់ឯងទៅវិញចុះ ហើយដោះចិញ្ចៀនឲ្យ ។ បុរោហិតបង្ហាញស្រីដែលប្រព្រឹត្តក្រៅចិត្តប្តីច្រើននាក់ ថ្វាយព្រះបាទកិន្នរដោយឧបាយផ្សេងៗ ហើយទូលថា បពិត្រព្រះអង្គ ប៉ុណ្ណេះក៏ល្មមហើយ សូមទ្រង់យាងទៅទីដទៃចុះ ព្រះបាទកិន្នរត្រាស់ថា ទោះបីត្រាច់ទៅឲ្យពេញជម្ពូទ្វីប ស្រីទាំងពួងក៏ដូចគ្នាទាំងអស់ យើងនឹងត្រូវពោលអ្វីទៀត ត្រឡប់ចុះ ត្រាស់ហើយ ក៏ទ្រង់យាងត្រឡប់ទៅកាន់នគរពារាណសី ។ បុរោហិត ក៏ទូលសូមព្រះរាជទានទោសឲ្យព្រះនាងកិន្នរីថា បពិត្រព្រះអង្គ ឈ្មោះថាស្រីទាំងឡាយរមែងលាមកយ៉ាងនេះ ប្រក្រតីរបស់ស្រីទាំងឡាយយ៉ាងនេះឯង សូមទ្រង់ព្រះរាជទានទោសដល់ព្រះនាងកិន្នរីចុះ ព្រះបាទកិន្នរក៏ទ្រង់ព្រះរាជទានទោសហើយឲ្យបំបរបង់ព្រះនាងចេញអំពីព្រះរាជនិវេសន៍ កាលទ្រង់បណ្តេញអំពីតំណែងហើយ ក៏ទ្រង់តាំងស្រីដទៃជាអគ្គមហេសី ហើយត្រាស់ឲ្យបណ្តេញបុរសខ្វិនចេញអំពីទីនោះ ហើយឲ្យកាប់មែកព្រីងចោល ។ ក្នុងកាលនោះ បក្សីកុណាល កើតជាបញ្ចាលចណ្ឌបុរោហិត កាលនាំហេតុដែលខ្លួនបានឃើញមកសម្តែង ទើបពោលថា

បុគ្គលឃើញ ( នូវហេតុនៃសេចក្តីនឿយណាយ ) របស់
ព្រះរាជា ព្រះនាមកិន្នរ និងព្រះនាងកិន្នរី ( គប្បីដឹងចុះ )

ពួកស្រីទាំងអស់ រមែងមិនត្រេកអរក្នុងផ្ទះ ( របស់ស្វាមីទេ )
ដូចជាកិរិយា ( របស់ព្រះរាជាកិន្នរៈ ) លះបង់នូវសត្វ គឺ
( ស្វាមី ) បែបនោះ ព្រោះឃើញនូវបុរសផ្តេសផ្តាសដទៃ
ជាបុរសទ្វិន ដូច្នេះ ។

គាថានោះ មានអធិប្បាយថា បណ្ឌិតឃើញហេតុនៃការនៀយណាយរបស់ព្រះបាទកិន្នរ និងនាងកិន្នរីទាំងនេះ ។ ស្រីទាំងពួងរមែងមិនត្រេកអរក្នុងផ្ទះនៃស្វាមីរបស់ខ្លួន ។ ពិតហើយ កិរិយាឃើញបុរសទ្វិនដទៃ រមែងលះបង់ព្រះរាជាអង្គនោះ ដែលជាអ្នកមានការឈ្លាសវៃក្នុងការអភិរម្យ បែបនោះ ធ្វើនូវកម្មលាមកជាមួយមនុស្សប្រេតនោះបាន ។

រឿងដទៃនៅមានបន្តទៀត ក្នុងអតីតកាល ព្រះបាទពារាណសីព្រះនាមជាពកៈ ទ្រង់គ្រងរាជ្យដោយធម៌ ។ មានស្រីឈ្មោះបញ្ចបាបី ជាកូនស្រីរបស់អ្នកក្រីក្រម្នាក់ ដែលនៅក្បែរទិសខាងកើតនៃក្រុងពារាណសី ។ បានឮមកថា កាលពីជាតិមុន នាងកើតជាកូនស្រីអ្នកក្រីក្រម្នាក់ អង្គុយប្រចាប់ដីបូកជញ្ជាំងផ្ទះ ពេលនោះ មានព្រះបច្ចេកពុទ្ធមួយអង្គពិចារណាថា នឹងរកដីឥដ្ឋក្នុងទីណាហ្ន៎ មកបូកលាបជញ្ជាំងទីនៅអាស្រ័យ កាលសម្រេចចិត្តថា អាចរកបានក្នុងនគរពារាណសី ដូច្នេះហើយ ទើបស្លៀកដណ្តប់កាន់បាត្រចូលទៅក្នុងនគរ ហើយនិមន្តទៅឈរក្បែរស្រីនោះ នាងឃើញព្រះបច្ចេកពុទ្ធហើយក៏ក្រោធ ទើបពោលដោយចិត្តប្រទូស្តថា គ្រាន់តែដុំដីក៏សូម ។ ព្រះបច្ចេកពុទ្ធ ក៏នៅស្ងៀម មិនបានញាប់ញ័រ នាងឃើញព្រះបច្ចេកពុទ្ធមិនកម្រើក ក៏

មានចិត្តជ្រះថ្លា ពោលថា បពិត្រសមណៈ លោកម្ចាស់ត្រូវការដីឥដ្ឋឬ ពោលហើយ ក៏លើកដីឥដ្ឋមួយដុំធំដាក់ក្នុងបាត្រ ។ ព្រះបច្ចេកពុទ្ធ ក៏យកទៅបូកលាបជញ្ជាំង ជាទីនៅអាស្រ័យ មិនយូរប៉ុន្មាន ស្រីនោះ ក៏ចុតិចាកអត្តភាពនោះ ទៅបដិសន្ធិក្នុងផ្ទៃស្រីទុគ៌ត ក្បែរទ្វារខាងក្រៅនគរនោះ លុះគ្រប់ខែហើយ នាងក៏ប្រសូត ដោយផលដែលបានប្រគេនដីនោះឯង ទើបរាងកាយរបស់នាងប្រកបដោយសម្បុរល្អក្រៃលែង តែព្រោះវិបាកដែលនាងសម្លឹងមើលព្រះបច្ចេកពុទ្ធដោយសេចក្ដីក្រោធ ដៃ ជើង មាត់ ភ្នែក ច្រមុះ ទាំង ៥ នេះ ក៏វិកលវិបរិតទៅ ដូច្នោះ ទើបគេដាក់ឈ្មោះឲ្យថា បញ្ចបាបី ។

ថ្ងៃមួយ ព្រះបាទពារាណសីទ្រង់ក្លែងព្រះអង្គ ត្រាច់មើលព្រះនគរដល់កន្លែងនោះ ។ នាងបញ្ចបាបីលេងជាមួយទារិកាអ្នកស្រុក មិនស្គាល់ព្រះបាទពារាណសី ក៏យកដៃចាប់ព្រះហស្ត ព្រះបាទពារាណសីត្រូវសម្ផស្សដៃរបស់នាង ក៏តម្កល់ព្រះហឫទ័យមិនបាន ដូចត្រូវសម្ផស្សទិព្វ ទ្រង់ក៏មានតម្រេកក្នុងសម្ផស្សដ៏ក្រៃលែង ទើបយកព្រះហស្តចាប់នាងបញ្ចបាបីដែលមានរូបអាក្រក់បែបនោះ ត្រាស់សួរថា នាងជាកូនស្រីរបស់អ្នកណា កាលនាងឆ្លើយថា ជាកូនស្រីអ្នកស្រុកជិតទ្វារព្រះនគរ ទ្រង់ក៏សាកសួរ បានដឹងថាមិនទាន់មានប្ដី ក៏ត្រាស់ថា យើងនេះឯងជាប្ដីរបស់នាង ចូរនាងទៅសូមអនុញ្ញាតអំពីមាតាបិតា ។ នាងបញ្ចបាបីក៏ចូលទៅរកមាតាបិតា ហើយប្រាប់ថា បុរសម្នាក់គេត្រូវការខ្ញុំ មាតាបិតាគិតឃើញថា បុរសនោះប្រហែលជាមិនមែនបុរសទុគ៌ត ទើបពោលថា បើគេចង់បានមនុស្សដូចឯង ជាការល្អ

ហើយ ។ ទើបនាងត្រឡប់មកប្រាប់ថា ឪពុកម្ដាយរបស់ខ្ញុំអនុញ្ញាតហើយ ព្រះបាទពារាណសី ក៏នៅជាមួយនាងបញ្ចបាបីក្នុងផ្ទះនោះ រហូតភ្លឺឡើង ក៏ត្រឡប់ទៅកាន់ព្រះរាជនិវេសន៍ ។ តាំងអំពីនោះមក ព្រះបាទពារាណសីទ្រង់ក៏ក្លែងព្រះកាយទៅរកនាងបញ្ចបាបីជានិច្ច ទ្រង់មិនសម្លឹងមើលស្រីដទៃឡើយ ។

ថ្ងៃមួយ បិតារបស់នាងបញ្ចបាបីកើតរោគចុះឈាម ថ្នាំដែលព្យាបាលរោគនោះ ត្រូវនឹងបាយាសដែលផ្សំដោយទឹកដោះស្រស់ សប្បិ ទឹកឃ្មុំ ស្ករក្រាមជាដើម តែគ្រួសាររបស់នាងក្រីក្រ មិនអាចរកមកបាន ។ គ្រានោះ មាតារបស់នាងបញ្ចបាបី ក៏និយាយនឹងកូនស្រីថា ប្ដីរបស់នាងអាចរកបា-យាសបានដែរឬទេ ។ នាងបញ្ចបាបីក៏ឆ្លើយថា ប្ដីរបស់ខ្ញុំប្រហែលជាក្រជាងគ្រួសារយើង តែណ្ហើយចុះ ខ្ញុំនឹងសាកសួរគាត់មើល សូមម៉ែកុំក្រវល់ក្រវាយឡើយ ។ ពោលដូច្នេះហើយ នាងបញ្ចបាបី ក៏ធ្វើអាកប្បកិរិយាជាទុក្ខអង្គុយរង់ចាំមើលព្រះបាទពារាណសីមក ។ លុះព្រះបាទពារាណសីយាងមកហើយ ត្រាស់សួរថា នែនាង នាងទុក្ខព្រួយរឿងអ្វី កាលទ្រង់ស្ដាប់សេចក្ដីនោះ ទើបត្រាស់ថា ម្នាលប្អូនស្រីថ្នាំបែបនេះ ជាថ្នាំសម្រាប់អ្នកធំ បងនឹងបានមកអំពីណា ត្រាស់ដូច្នេះហើយ ទ្រង់គិតបន្តទៀត អញមិនអាចត្រាច់ទៅមកយ៉ាងនេះបាន ក្រែងជួបអន្តរាយតាមផ្លូវ តែបើនាំនាងបញ្ចបាបីចូលទៅខាងក្នុងវាំង ជនទាំងឡាយមិនដឹងថា នាងមានសម្បត្តិ គឺសម្ផស្សល្អ ក៏នឹងនាំគ្នាសើចចំអកអញថា ស្ដេចផែនដីរបស់យើង នាំយកយក្ខិនីមកអំពី

ណា អញទើងធ្វើអ្នកនគរឲ្យដឹងសម្ផស្សរបស់នាងជាមុន ទើបអាចដោះពាក្យនិន្ទាបាន ។

លំដាប់នោះ ព្រះរាជាត្រាស់ថា នាងកុំកង្វល់ឡើយ ខ្ញុំនឹងនាំបាយាសមកឲ្យឪពុករបស់នាង កាលទ្រង់អភិរម្យជាមួយនាងហើយ ក៏យាងត្រឡប់ទៅកាន់ព្រះរាជនិវេសន៍ ។ ស្អែកឡើង ត្រាស់ឲ្យចម្អិនបាយាស ឲ្យយកស្លឹកឈើមកធ្វើជាកញ្ចប់ ២ កញ្ចប់ ដាក់បាយាស ហើយក៏ដាក់ព្រះចូឡាមណីក្នុងកញ្ចប់មួយ ចងទុកឲ្យល្អ ។ លុះដល់ពេលរាត្រី ក៏ទ្រង់បញ្ជូនបញ្ចប់បាយទៅឲ្យ ហើយបញ្ជាក់ថា ខ្ញុំជាមនុស្សក្រីក្រដល់ម៉្លេះ រកបានមកដោយលំបាក ចូរនាងប្រាប់ដល់ឪពុកថា ថ្ងៃនេះ ពិសាកញ្ចប់មួយនេះ ស្អែកនេះ សឹមពិសាមួយកញ្ចប់ទៀត នាងបញ្ចបាបីក៏ធ្វើតាមពាក្យប្រាប់ លុះឪពុករបស់នាងបញ្ចបាបីបរិភោគចូលទៅបានបន្តិច ក៏ឆ្អែតស្កប់ស្កល់ មានសេចក្ដីសប្បាយព្រោះបាយាសនោះ មានឱជារសក្រៃលែង ។ នាងបញ្ចបាបី ក៏នាំយកបាយាសដ៏សេសទៅឲ្យម្ដាយ ហើយបរិភោគឯង ក្នុងកាលជាក្រោយបាយាសក៏ល្មមឆ្អែតទាំង ៣ នាក់ ។ ចំណែកកញ្ចប់បាយដែលមានកន្ទប់ព្រះចូឡាមណី ក៏រក្សាទុកដើម្បីថ្ងៃស្អែក ។

កាលព្រះបាទពារាណសីត្រឡប់ទៅព្រះរាជនិវេសន៍ ទ្រង់ស្រងព្រះភក្ត្រស្រេចហើយ ទើបត្រាស់ឲ្យភ្នាក់ងារនាំព្រះចូឡាមណីមកថ្វាយ កាលភ្នាក់ងារទូលថា មិនឃើញទេព្រះអង្គ ក៏ត្រាស់ថា ចូររកឲ្យពេញព្រះនគរ ។ លុះរកពេញនគរមិនឃើញ ទើបត្រាស់ថា ចូរឲ្យមនុស្សរកខាងក្រៅព្រះនគរ

ដោយហោចសូម្បីក្នុងផ្ទះមនុស្សក្រីក្រទុគ៌តក៏កុំវៀរ ។ រាជបុរសទាំងឡាយក៏នាំគ្នាផែកឆេរ ទើបឃើញព្រះចូឡាមណីក្នុងផ្ទះរបស់នាងបញ្ចបាបី ក៏នាំគ្នាចងឪពុកម្តាយរបស់នាងចោទថាជាចោរ ជនទាំង ២ ក៏យំថា ខ្ញុំមិនមែនចោរទេ អ្នកដទៃនាំមកឲ្យ កាលគេសួរថា អ្នកណា ក៏ប្រាប់ថា កូនប្រសាប្រុស កាលគេសួររកថា កូនប្រសានៅឯណា ក៏ប្រាប់ថា កូនស្រីរបស់ខ្ញុំទើបដឹង កាលបិតាបែរមកពោលជាមួយកូនស្រីថា នាងស្គាល់ប្តីរបស់នាងឬ នាងក៏ឆ្លើយថា មិនស្គាល់ បិតាពោលថា បើដូច្នោះ ជីវិតរបស់យើងមិនមាន នាងបញ្ចបាបីក៏ពោលថា ប្តីរបស់ខ្ញុំ មកក្នុងពេលយប់ ត្រឡប់ទៅក៏ក្នុងពេលយប់ ទើបខ្ញុំមិនស្គាល់រូបរាងរបស់គេដូចម្តេច តែបើបានស្ទាបដៃហើយក៏នឹងដឹងបាន ហើយនាងក៏ប្រាប់ដល់រាជបុរសទាំងឡាយបែបនោះ ។ ពួករាជបុរសទាំងឡាយ ក៏នាំសេចក្តី មកក្រាបទូលដល់ព្រះបាទពារាណសី ព្រះបាទពារាណសីធ្វើជាមិនដឹងមិនឮ ទើបត្រាស់ថា បើដូច្នោះ ចូរឲ្យស្រីនោះអង្គុយក្នុងរាំងននត្រង់លានព្រះរាជវាំង ហើយចោះរាំងនន ល្មមលូកដៃចូលបាន ត្រាស់ឲ្យអ្នកនគរមកប្រជុំ ឲ្យស្រីនោះចាប់ចោរឲ្យបាន ដោយសម្ទស្សដៃ ។ រាជបុរសទាំងឡាយក៏ធ្វើតាមរាជតម្រាស់ នាំគ្នាទៅកាន់សម្នាក់របស់នាងបញ្ចបាបី សម្ទឹងមើលរូបហើយ ក៏កើតនូវការក្តៅក្រហាយ ស្អប់ខ្ពើមថា ថ្វីយៗ ស្រីបិសាច មិនអាចពាល់ត្រូវបាន កាលពួករាជបុរស នាំនាងមកហើយឲ្យអង្គុយក្នុងរាំងនន ត្រង់មុខលានព្រះរាជវាំង រៀបចំឲ្យអ្នកនគរទាំងអស់មកប្រជុំព្រមគ្នា នាងបញ្ចបាបីក៏ចាប់ដៃបុរសដែលមកហើយ

ក្នុងប្រហោងវាំងនន ប្រាប់រឿយៗ ថា នេះមិនមែនប្តី បុរសទាំងឡាយបាន ប៉ះសម្ផស្ស ក៏ជាប់ជំពាក់ក្នុងសម្ផស្សរបស់នាង ដូចសម្ផស្សទិព្វ មិនអាច ជៀសចេញទៅបាន ក៏នាំគ្នាគិតក្នុងចិត្តថា បើស្រីនេះគួរដល់បំណុល អញ នឹងរកទ្រព្យមកលោះ ទោះធ្វើជាទាសកម្មករក៏ដោយ អញនឹងនាំទៅទុកក្នុង ផ្ទះ រហូតដល់រាជបុរសវាយដោយរំពាត់ ទើបគេចទៅ មនុស្សទាំងពួង តាំង ពីឧបរាជឡើងទៅ ក៏មានអាការដូចមនុស្សឆ្កួត លុះអស់មនុស្សហើយ ព្រះ បាទពារាណសីត្រាស់ថា ប្រហែលជាយើងទេដឹង ទើបលូកព្រះហស្តចូលទៅ នាងក៏ចាប់ព្រះហស្តជាប់ ក៏ស្រែកខ្លាំងថា ចាប់ចោរបានហើយ ។ ព្រះបាទ ពារាណសីត្រាស់សួររាជបុរសទាំងឡាយថា កាលនាងចាប់ដៃរបស់ពួកឯង តើពួកឯងគិតដូចម្តេច រាជបុរសទាំងឡាយក៏ក្រាបទូលតាមសេចក្តីពិត ។ លំ-ដាប់នោះ ព្រះបាទពារាណសីក៏ត្រាស់ថា ដែលយើងឲ្យធ្វើយ៉ាងនេះ ដើម្បី នាំស្រីនេះមកទុកក្នុងវាំង តែគិតឃើញថា បើអ្នកទាំងឡាយមិនដឹងសម្ផស្ស របស់ស្រីនេះ ក៏នឹងមើលងាយប្រមាទយើងបាន ព្រោះហេតុនោះ ទើបឲ្យអ្នក ទាំងឡាយដឹង ចូរពោលទៅមើល ស្រីនេះ សមគួរនៅក្នុងផ្ទះអ្នកណា រាជ បុរសទាំងឡាយក៏ក្រាបទូលថា សមគួរនៅក្នុងវាំងរបស់ព្រះអង្គនោះឯង ។ ព្រះបាទពារាណសីក៏ឲ្យអភិសេកតែងតាំងជាអគ្គមហេសី និងព្រះរាជទាន ឥស្សរិយយសដល់ឪពុកម្តាយរបស់នាង ។ តាំងពីនោះមក ព្រះបាទពារា-ណសីទ្រង់វង្វេងក្នុងព្រះនាងបញ្ចបាបី រហូតលែងខ្វល់ក្នុងការកាត់ក្តី និងគិត គូរឿងពន្ធដារអាករ ទ្រង់មិនសម្លឹងមើលស្រីដទៃ ពួកស្រីស្នំទាំងឡាយ ក៏

ចាំចាប់កំហុស ។

សម័យមួយ នាងបញ្ចបាបីយល់ព្រះសុបិននិមិត្ត ដែលខ្លួនត្រូវបានជាអគ្គមហេសីរបស់ស្តេចផែនដី ២ អង្គ ទើបនាងក្រាបទូលឲ្យទ្រង់ជ្រាប ព្រះបាទពារាណសី ក៏ត្រាស់ឲ្យហៅហោរាមកគាល់ ត្រាស់សួរថា យល់សប្តិបែបនេះ មានផលដូចម្តេច ពួកអ្នកទាយយល់សប្តិ បានសំណូកពីស្នំដទៃៗ ក៏ទាយថា បពិត្រព្រះអង្គ ការដែលព្រះរាជទេវីទ្រង់សុបិន បានអង្គុយលើកដីរសេសុទ្ធនោះ ជាបុព្វនិមិត្តនាំនូវមរណៈមកកាន់ព្រះអង្គ ដែលព្រះនាងទ្រង់សុបិនថា អង្គុយលើកដីរ ហើយស្ទាបព្រះចន្ទលេងនោះ ជាបុព្វនិមិត្តដែលនាំព្រះរាជាជាសត្រូវមកឲ្យដល់ព្រះអង្គ ។ កាលព្រះបាទពារាណសីបញ្ជាក់ថា បើដូច្នោះ គួរធ្វើដូចម្តេច ទើបក្រាបទូលថា បពិត្រព្រះអង្គ មិនគួរឲ្យសម្រេចទោសព្រះនាងឡើយ គួរដាក់ទូកបណ្តែតនាងទៅតាមស្ទឹង ។ ទើបព្រះបាទពារាណសីឲ្យនាងបញ្ចបាបីចូលទៅកាន់ទូក មួយអន្ទើដោយអាហារនិងគ្រឿងអលង្ការ លុះពេលរាត្រី ក៏បន្សាត់ទូកទៅក្នុងស្ទឹង ទូកនាងបញ្ចបាបី អណ្តែតទៅតាមខ្សែទឹក រហូតដល់មុខព្រះនគររបស់ព្រះបាទពាវរីដែលទ្រង់ចុះទូកនៅខាងក្រោមខ្សែទឹក សេនាបតីរបស់ព្រះបាទពាវរីឃើញទូកនោះ ក៏ស្រែកថា ទូកនោះជារបស់ខ្ញុំ ព្រះបាទពាវរីត្រាស់ថា របស់ក្នុងទូកជារបស់យើង លុះទូកមកដល់ ក៏ទតឃើញនាងបញ្ចបាបី ក៏ត្រាស់សួរថា ស្រីនេះជាអ្វី រូបដូចបិសាច ។ នាងបញ្ចបាបីញញឹម ហើយទូលថាខ្ញុំម្ចាស់ជាអគ្គមហេសីរបស់ព្រះបាទពកៈ ហើយទូលហេតុទាំងពួងឲ្យទ្រង់

ជ្រាប ឯនាងបញ្ចបាបីនោះ មានឈ្មោះបោះសំឡេងប្រាកដពេញជម្ពូទ្វីប ព្រះបាទពាវរី ទ្រង់ក៏ចាប់ដៃទាញចេញអំពីទូក គ្រាន់តែចាប់ប៉ុណ្ណោះ ទ្រង់ក៏ត្រេកអរក្នុងសម្ផស្ស រហូតមិនដឹងថា ស្រីដទៃមាន ទើបទ្រង់តែងតាំង នាងបញ្ចបាបីទុកក្នុងតំណែងអគ្គមហេសី នាងក៏ជាទីស្រឡាញ់ស្មើជីវិត ។ ព្រះបាទពកៈបានដំណឹងនោះ ក៏ត្រិះរិះថា អញមិនព្រមឲ្យព្រះបាទពាវរីតែងតាំងនាងបញ្ចបាបីជាអគ្គមហេសី ទើបរួបរួមពលសេនា លើកជាក្បួនទ័ពទៅ បោះជំរំត្រង់កំពង់ទឹក ហើយបានបញ្ជូនសាសន៍ទៅថា សូមព្រះបាទពាវរីឲ្យកិរិយាក្នុងទូកមកវិញ ឬក៏ច្បាំងគ្នា ព្រះបាទពាវរីក៏តបទៅថា យើងនឹងច្បាំង មិនឲ្យនូវអគ្គមហេសីរបស់យើងទេ ហើយទ្រង់ក៏លើកទ័ពមក ។ ពួកអាមាត្យទាំង ២ ពួកក៏ប្រឹក្សាគ្នាថា ពួកយើងនាំគ្នាមកស្លាប់ព្រោះហេតុតែស្រី មិនសមគួរឡើយ នាងបញ្ចបាបីគួរបានទៅព្រះបាទពកៈ ព្រោះធ្លាប់ជាស្វាមីអំពីមុន តែក៏គួរបានដល់ព្រះបាទពាវរី ព្រោះទ្រង់រើសបានក្នុងទូក ព្រោះហេតុនោះ ព្រះនាងបញ្ចបាបីគួរនៅក្នុងព្រះរាជតំណាក់របស់ព្រះរាជា មួយអង្គ ៧ ថ្ងៃ ទើបក្រាបទូលឲ្យព្រះរាជាទាំងពីរអង្គយល់ព្រម ។

ព្រះរាជាទាំងពីរព្រះអង្គ ក៏ពេញព្រះហឫទ័យ ឲ្យសាងព្រះនគរត្រង់ត្រើយស្ទឹងទាំងសងខាងហើយប្រថាប់គង់ ។ នាងបញ្ចបាបីធ្វើនាទីជាអគ្គមហេសីរបស់ព្រះរាជាទាំង ២ អង្គ ព្រះរាជាទាំងពីរអង្គក៏វង្វេងក្នុងសម្ផស្សរបស់នាង ។ ចំណែកនាងបញ្ចបាបី កាលគង់នៅក្នុងដំណាក់របស់ព្រះរាជាមួយអង្គ គ្រប់ ៧ ថ្ងៃហើយ ក៏ចុះទូកទៅកាន់ព្រះរាជដំណាក់ព្រះរាជាមួយ

អន្តទៀត បានធ្វើអនាចារក្នុងសុបិនជាមួយអ្នកប្រមង់ខ្ទងគម ចាស់ជរា ដែលជាអ្នកអុំទូកនាំព្រះនាងទៅ ។

កាលនោះ បក្សីកុណាលកើតជាព្រះបាទពកៈ ព្រោះហេតុនោះ កាលនាំរឿងដែលខ្លួនបានដឹងហើយមកសម្តែង ទើបពោលថា

កិរិយារបស់ព្រះបាទពកៈ និងព្រះបាទពាវរិយៈ ជាព្រះរាជាល្មោភកាមដ៏ក្រៃលែង បានប្រព្រឹត្តក្បត់ចំពោះបុរសអ្នកលុះក្នុងអំណាចដែលខ្លួនប្រាថ្នា ស្រីមិនប្រព្រឹត្តកន្លងស្វាមីនឹងបុរសដទៃនោះ ឯណាកើត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អច្ចន្តកាមានុគតស្ស** បានដល់ ងប់ជ្រប់ក្នុងកាមពន់ប្រមាណ ។ បទថា **អចារី** បានដល់ ប្រព្រឹត្តអនាចារ ។ បទថា **បដ្ឋវសានុគស្ស** បានដល់ ប្រព្រឹត្តកន្លងក្នុងសម្នាក់នៃបុរស ដែលធ្វើការបម្រើខ្លួនជាអ្នកជិតស្និទ្ធ និងប្រព្រឹត្តក្នុងអំណាចរបស់ខ្លួន ។ ពាក្យនេះជាឆដ្ឋីវិភត្តិប្រើក្នុងអត្តតតិយាវិភត្តិ មានពាក្យអធិប្បាយថា បានធ្វើកម្មអាក្រក់ជាមួយអ្នកបម្រើនោះ ។ បទថា **តមញ្ញំ** អធិប្បាយថា ប្តីក៏ស្រី មិនប្រព្រឹត្តកន្លងជាមួយបុរសដទៃនោះទៀត ។

មានរឿងដទៃទៀត ក្នុងអតីតកាល អគ្គមហេសីព្រះបាទព្រហ្មទត្ត ព្រះនាមថា បិង្គិយានី បើកបង្អួចសម្លឹងមើលនាយអាយ ឃើញអ្នកថែសេះមង្គលមានចិត្តប្រតិព័ទ្ធ កាលព្រះបាទព្រហ្មទត្តផ្ទំលក់ ក៏ចុះតាមបង្អួចប្រព្រឹត្តកន្លងជាមួយអ្នកចិញ្ចឹមសេះ ហើយឡើងលើប្រាសាទវិញ ព្រោះព្រំសរីរៈដោយ

គ្រឿងប្រអប់ហើយ ក៏ចូលទៅផ្ទំជាមួយព្រះបាទព្រហ្មទត្ត តមក ព្រះបាទព្រហ្មទត្តត្រិះរិះថា ព្រោះហេតុអ្វីហ្ន៎ ក្នុងពាលរាត្រី ព្រះសរីរៈរបស់ព្រះទេវីត្រជាក់ ប្រហែលជាត្រូវសង្កេតមើល ។ ថ្ងៃមួយ ទ្រង់ក្លែងធ្វើអាការ ដូចជាដេកលក់ លុះនាងក្រោកទៅ ទ្រង់ក៏យាងទៅតាមក្រោយ រហូតឃើញនាងប្រព្រឹត្តកន្លងជាមួយអ្នកចិញ្ចឹមសេះ ហើយក៏យាងត្រឡប់ទៅកាន់ទីបន្ទំ ឯព្រះនាងបិង្គិយានី ប្រព្រឹត្តកន្លងហើយ ក៏ត្រឡប់មកផ្ទំត្រង់ទីបន្ទំតូច ។

ព្រឹកឡើងព្រះបាទព្រហ្មទត្តហៅនាងបិង្គិយានីមកហើយ ក្នុងកណ្តាលពួកអាមាត្យ ទ្រង់បានចង្អុលទោសឲ្យឃើញច្បាស់ ហើយត្រាស់ថា ស្រីទាំងពួង រមែងមានកាពលាមកជាធម្មតា ដូច្នេះហើយ ទ្រង់ក៏វៀរទោសសម្លាប់ចាប់ចង មានកាត់អវយវៈជាដើម គ្រាន់តែដកនូវតំណែង ហើយតាំងស្រីដទៃជាអគ្គមហេសីតទៅ ។

កាលនោះ បក្សីកុណាលបានកើតជាព្រះបាទព្រហ្មទត្ត ព្រោះហេតុនោះ កាលសម្តែងដល់ហេតុដែលខ្លួនឃើញឯង ទើបពោលថា

> នាងបិង្គិយានី ជាភរិយា ជាទីស្រឡាញ់នៃព្រះបាទព្រហ្មទត្ត
> ព្រះអង្គជាធំក្នុងលោកទាំងមូល បានប្រព្រឹត្តក្បត់ ចំពោះ
> បុរសអ្នកលុះក្នុងអំណាចដែលខ្លួនប្រាថ្នា នាងបិង្គិយានីជាអ្នក
> ល្មោភក្នុងកាមនោះ មិនបាននូវបុរសគង្វៀលសេះនោះផង
> ( នូវទីអគ្គមហេសីផង ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តំ វាបិ** សេចក្តីថា នាងប្រព្រឹត្តក្រៅចិត្ត

យ៉ាងនេះ ក៏មិនបានជួបនូវរបស់ទាំង ២ គឺអ្នកចិញ្ចឹមសេះនោះ និងតំណែងអគ្គមហេសី គឺប្រាសចាកហើយទាំង ២ យ៉ាង ។ បទថា **កាមកាមិនី** សេចក្ដីថា ជាអ្នកប្រាថ្នាកាម ។

បក្សីកុណាលពោលទោសស្រីទាំងឡាយថា ស្រីទាំងឡាយមានធម៌ដ៏លាមកយ៉ាងនេះ ដូចរឿងអតីតដែលបានពណ៌នាមកហើយ កាលនឹងពោលទោសនៃស្រីទាំងឡាយដោយបរិយាយដទៃទៀត ទើបពោលថា

បុរសដែលមិនមែនខ្មោចចូល មិនគួរជឿពួកស្រីដែលអាក្រក់ មានចិត្តរហ័ស ជាស្រីមិនដឹងគុណ ដែលគេធ្វើដល់ខ្លួន ជាស្រីប្រទូស្ត ( ប្ដី ) ទេ ។ ពួកស្រីទាំងនោះ មិនដឹងនូវឧបការៈដែលគេធ្វើហើយ ( ដល់ខ្លួន ) មិនដឹងនូវកិច្ចការដែលគួរធ្វើ មិនស្គាល់ម្ដាយ មិនស្គាល់ឪពុក មិនស្គាល់បងប្អូន មិនមានអរិយធម៌ មានការប្រព្រឹត្តកន្លងជាធម្មតា តែងលុះអំណាចចិត្តរបស់ខ្លួន ។ ពួកស្រីតែងលះបង់ប្ដីជាទីស្រឡាញ់ ជាទីពេញចិត្ត ជាអ្នកអនុគ្រោះស្មើដោយជីវិត ដែលកប់ប្រសព្វអស់កាលដ៏យូរ ឬលះបង់នូវប្ដីក្នុងកិច្ចមានអន្តរាយ ព្រោះហេតុនោះ ខ្ញុំមិនទុកចិត្តចំពោះស្រីទាំងឡាយទេ ។ ព្រោះថា ចិត្តរបស់ស្រីដូចគ្នានឹងចិត្តពានរ ហឫទ័យរបស់ពួកស្រីចុះឡើងញាប់ញ័រដូចជាម្លប់ឈើ តែងវិលទៅដូចកង់រទេះ ។ ពួកស្រីទាំងនោះកាលក្រឡេកមើលឃើញទ្រព្យ របស់ប្រុស

ដែលគួរកាន់យក ក្នុងកាលណា ក៏កៀគរប្រុសនោះដោយសំដីដ៏ផ្អែមល្ហែម ក្នុងកាលណោះ ដូចពួកជនអ្នកកម្មោជបញ្ឆោតចាប់សេះដោយសារាយ ។ ពួកស្រីកាល បើក្រឡេកមើលមិនឃើញទ្រព្យ របស់ប្រុសដែលគួរកាន់យក ក្នុងកាលណា ក៏វៀរប្រុសនោះដោយជុំវិញ ក្នុងកាលណោះ ដូចគេឆ្លងទៅដល់ត្រើយស្ទឹងហើយ លះបង់នូវក្បូន ។ ពួកស្រីឧបមាដូចជ័រ ( ជាទីជាប់ស្អិតនៃចិត្តបុរស ) ដូចភ្លើងស៊ីនូវវត្ថុគ្រប់យ៉ាង មានមាយាដ៏រហ័ស ដូចស្ទឹងមានខ្សែទឹកដ៏រហ័ស ពួកស្រីទាំងនេះតែងសេពគប់បុរសទាំងជាទីស្រឡាញ់ទាំងមិនជាទីស្រឡាញ់ ដូចទូកតែងជួបប្រទះ ទាំងប្រាំងខាងអាយនិងប្រាំងខាងនាយ ។ ពួកស្រីទាំងនោះ មិនមែនជារបស់ប្រុសម្នាក់ឬពីរនាក់ទេ ដូចជារានផ្សារដែលបើកហើយ បុគ្គលណាសំគាល់នូវពួកស្រីទាំងនោះ ថាជារបស់អញបុគ្គលនោះ ដូចគេយកសំណាញ់ខ្ទប់ខ្យល់ ។ ស្ទឹង ផ្លូវ រោងសុរា រោងជាទីប្រជុំ និងអណ្តូងទឹក យ៉ាងណា ធម្មតា ពួកស្រីក្នុងលោក ក៏យ៉ាងនោះដែរ វេលា ( នៃសេចក្តីស្រើបក្នុងកាម ) របស់ពួកស្រីទាំងនោះ មិនមានឈប់ឈរទេ ។ ពួកស្រីទាំងនេះស្មើដោយអណ្តាតភ្លើង មានឧបមាដូចក្បាលពស់វែក ដូចពួកគោស៊ីនូវស្មៅដ៏ល្អៗខាងក្រៅ ។ នរៈគប្បីគប់រកដោយការ

ប្រយ័ត្ននូវវត្ថុទាំងនេះ គឺភ្លើង ១ ដីរ ១ ពស់វែក ១ ព្រះរាជាដែលគេអភិសេកហើយ ១ ពួកស្រីទាំងអស់ ១ ព្រោះភាពទៀងទាត់នៃវត្ថុទាំងនោះ ដឹងបានដោយក្រណាស់ ។ ពួកស្រីមានពណ៌សម្បុរដ៏ល្អលើសលុបពេក បុគ្គលមិនត្រូវសេពគប់ ១ ស្រីជាទីស្រឡាញ់ពេញចិត្តរបស់ពួកជនច្រើន បុគ្គលមិនត្រូវសេពគប់ ១ ស្រីឆ្លៀវឆ្លាសក្នុងការរាំនិងច្រៀង បុគ្គលមិនត្រូវសេពគប់ ១ ប្រពន្ធអ្នកដទៃ បុគ្គលមិនត្រូវសេពគប់ ១ ស្រី ( សេពគប់ ) ព្រោះហេតុនៃទ្រព្យ បុគ្គលក៏មិនត្រូវសេពគប់ ១ ស្រី ៥ ពួកនេះ បុគ្គលមិនត្រូវសេពគប់ទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ខុជ្ជានំ** បានដល់ គ្រោតគ្រាត ។ បទថា **ខុជ្ជានំ** នេះ លោកពោលសំដៅដល់ស្រីដែលមានតម្រេកស្នេហ៍ក្នុងចោរដែលត្រូវនាំទៅសម្លាប់ ដូចក្នុងរឿងកណវេរជាតកនោះ ។ បទថា **លហុចិត្តានំ** បានដល់ ត្រឹមតែមួយរំពេចប៉ុណ្ណោះ ក៏មានចិត្តប្រែប្រួលទៅមក ស្រីចិត្តស្រាលនេះ បណ្ឌិតគប្បីសម្ដែងដោយរឿងចុល្លធនុគ្គហជាតក ។ ឯ បទថា **អកតញ្ញូន** របស់ពួកស្រីទាំងនេះ បណ្ឌិតគប្បីសម្ដែងដោយរឿង តក្កជាតកក្នុងឯកនិបាត ។ បទថា **ឆាទេវសន្តោ** បានដល់ បុរសដែលមិនត្រូវទេវតាចូលសណ្ឋិត ឬមិនត្រូវយក្ខចូលសណ្ឋិត ឬមិនត្រូវភូតបិសាចចូលសណ្ឋិត មិនគួរជឿស្រីដែលមានវាទៈថា ខ្លួនជាអ្នកមានសីលវត្ត ។ ឯបុរសដែលត្រូវ

ពួកកូតបូលសណ្ឋិត ទើបគួរជឿ ។ បទថា **កតំ** បានដល់ ឧបការគុណដែលអ្នកដទៃធ្វើហើយដល់ខ្លួន ។ បទថា **កិច្ចំ** បានដល់ កិច្ចដែលគួរធ្វើ ។ បទថា **ន មាតរំ** អធិប្បាយថា ស្រីទាំងនេះ លះញាតិទាំងអស់ ឈ្មោះថាមិនស្គាល់សូម្បីមាតាជាដើម ព្រោះជាប់តាមបុរសដែលខ្លួនមានចិត្តប្រាថ្នាតែម្នាក់ប៉ុណ្ណោះ ដូចមាតារបស់មហាបទុមកុមារ ដូច្នោះ ។ បទថា **អនរិយា** បានដល់ មិនមានខ្មាស ។ បទថា **សមេស្សរ** បានដល់ ចិត្តរបស់ខ្លួនឯង ។ បទថា **អាវាសុ** បានដល់ អន្តរាយគ្រប់ប្រភេទ ។ បទថា **កិច្ចេសុ** បានដល់ កិច្ចដែលគួរធ្វើនោះៗ ។ បទថា **កន្ទប្បកន្ទំ** បានដល់ ខ្ពស់ទាបៗ ដូចម្លប់ឈើក្នុងប្រទេសដែលមិនរាបស្មើ រមែងទាបចុះខ្លះ ខ្ពស់ឡើងខ្លះ យ៉ាងណា សូម្បីចិត្តរបស់ស្រីទាំងនោះក៏ដូចគ្នា រមែងមិនជ្រើសរើសថា អ្នកណាជាអ្នកណាឧត្តម ឬថោកថយ ។ បទថា **ចលាចលំ** បានដល់ មិនតាំងនៅក្នុងទីមួយកន្លែង ។ បទថា **នេមិ** បានដល់ ចិត្តរបស់ស្រី រមែងវិលទៅដូចកង់រថដែលវិលទៅតាមរទេះ ដូច្នោះ ។ បទថា **អាទេយ្យរូបំ** បានដល់ ទ្រព្យដែលជាវត្ថុល្អមខ្លួនកាន់យកបាន ។ បទថា **វិត្តំ** បានដល់ ទ្រព្យគ្រប់ប្រភេទ ។ បទថា **នយន្តិ** បានដល់ នាំទៅកាន់អំណាចរបស់ខ្លួន ។

បទថា **ជលជេនេវ** បានដល់ សារាយដែលកើតក្នុងទឹក បានឮថា អ្នកកម្លោជៈទាំងឡាយ ប្រាថ្នានឹងចាប់សេះអំពីព្រៃ ទើបនាំគ្នាធ្វើក្រោលក្នុងទីមួយកន្លែង រៀបចំទ្វារហើយ យកទឹកឃ្មុំលាបសារាយ ដែលអណ្តែតលើទឹក កាលពួកសេះព្រៃទំពាស៊ីហើយ លាបស្មៅដោយទឹកឃ្មុំលើប្រាំងបន្តអំពី

*សារាយរហូតដល់ទ្វារក្រោល ពួកសេះព្រៃចុះផឹកទឹកហើយស៊ីស្មៅដែលលាប ដោយទឹកឃ្មុំ ដោយជាប់ក្នុងរស ក៏ចូលទៅក្នុងទីនោះដោយលំដាប់ ។ ពួកអ្នកកម្មោជៈទាំងនោះ ក៏បញ្ឆោតសេះដោយសារាយនាំទៅកាន់អំណាចបាន យ៉ាងណា សូម្បីស្រីទាំងនេះ ឃើញទ្រព្យហើយរមែងនាំបុរសទៅកាន់អំណាច ដោយពាក្យផ្អែមពីរោះ ព្រោះត្រូវការយកទ្រព្យនោះ ដោយប្រការដូច្នេះ ។ បទថា* **កុលុំ** *បានដល់ វត្ថុដែលចងរួមគ្នាណាមួយ ដើម្បីឆ្លងត្រើយ ។ បទថា* **សិលេសូបមា** *បានដល់ ដូចគ្នានឹងគ្រឿងចងរឹត ព្រោះចងចិត្តបុរសទាំងឡាយទុក ។ បទថា* **តិក្ខមាយា** *បានដល់ មានមាយាធ្មើម មានមាយារហ័ស ។ បទថា* **នទីរិវ** *អធិប្បាយថា ស្រីទាំងឡាយមាន មាយារហ័ស ដូចទឹកស្ទឹងដែលមានទឹកធ្លាក់មកអំពីលើភ្នំ រមែងមានខ្សែខ្នុលខ្ទាញ់ដូច្នោះឯង ។ បទថា* **អាបណោវ** *បានដល់ រានផ្សារដែលគេដាក់លក់ដូររមែងមានឧបការ ដល់ទ្រព្យដែលមានតម្លៃទាំងនោះ យ៉ាងណា សូម្បីពួកស្រីទាំងនោះក៏ដូចគ្នា ។ បទថា* **យោ តា** *បានដល់ បុរសណាសម្គាល់ថា ស្រីទាំងនោះជារបស់ខ្លួន ។ បទថា* **ពន្ធយេ** *អធិប្បាយថា បុរសនោះដូចបង់ខ្យល់ដោយសំណាញ់ ។ បទថា* **វេលា តាសំ ន វិជ្ជតិ** *អធិប្បាយថា ទីមានស្ទឹងជាដើមនោះ រមែងមិនមានវេលាថា គប្បីទៅបានក្នុងទីនេះ ក្នុងពេលនោះប៉ុណ្ណោះ បុគ្គលគប្បីចូលទៅបានក្នុងខណៈដែលខ្លួនប្រាថ្នាហើយ ទាំងពេលយប់ទាំងពេលថ្ងៃ មិនមានកំណត់ថា បុគ្គលឈ្មោះនោះប៉ុណ្ណោះ ទើបចូលបាន អ្នកមានបំណងគប្បីចូលទៅបាន យ៉ាងណា សូម្បីពួកស្រីទាំងនោះ ក៏មិនមាន ( ពេលវេលា )*

យ៉ាងនោះ ដូចគ្នា ។

បទថា **យថាសនសមា** អធិប្បាយថា ភ្លើងរមែងមិនឆ្អែតដោយឧស យ៉ាងណា សូម្បីស្រីទាំងនេះ ក៏រមែងមិនឆ្អែតដោយការត្រេកអរក្នុងកិលេស យ៉ាងនោះដូចគ្នា ។ បទថា **កណ្ហាសប្បសិរូបមា** អធិប្បាយថា ស្រីទាំងឡាយដូចគ្នានឹងក្បាលពស់វែក ព្រោះហេតុ ៥ ប្រការ គឺជាអ្នកច្រើនដោយសេចក្តីក្រោធ ១ មានពិសពន្លឺក ១ ចងក្រោធទុក ១ មានអណ្តាតអាក្រក់ ១ ច្រើនដោយការទ្រុស្តមិត្ត ១ បណ្តាហេតុទាំង ៥ នោះ បណ្ឌិតគប្បីជ្រាបថា មានពិសកាច ព្រោះមានតម្រេកច្រើន មានអណ្តាតអាក្រក់ ព្រោះពោលពាក្យញុះញង់ ទ្រុស្តមិត្ត និងព្រោះច្រើនដោយការប្រព្រឹត្តក្រៅចិត្តប្តី ។ បទថា **គាវោ ពហិ តិណស្សេវ** អធិប្បាយថា គោទាំងឡាយ លះបង់នូវទីដែលខ្លួនធ្លាប់រកស៊ី ហើយជ្រើសរើសតែស្មៅឆ្ងាញ់ៗ ដែលខ្លួនគាប់ចិត្ត ខាងក្រៅយ៉ាងណា សូម្បីស្រីទាំងនោះ ក៏ដូចគ្នា រមែងលះនូវបុរសដែលអស់ទ្រព្យសម្បត្តិ ហើយគប់រកបុរសដែលមានទ្រព្យដទៃបន្តទៅទៀត ។ បទថា **មុទ្ធាភិសិត្តំ** បានដល់ ស្តេចផែនដី ។ បទថា **បមុទា ច សព្វា** បានដល់ ស្រីទាំងអស់ ។ បទថា **ឯតេ** បានដល់ ជនទាំង ៥ ពួកនេះ ។ បទថា **និច្ចយតោ** អធិប្បាយថា នរជនគប្បីជាបុគ្គលតម្កល់សតិទុក សង្រួមជានិច្ច គឺជាអ្នកមិនប្រមាទ ។ បទថា **ទុព្វិទុ** បានដល់ ដឹងបានដោយលំបាក ។ បទថា **សច្ចភាវោ** បានដល់ អជ្ឈាស្រ័យ អធិប្បាយថា ពិតហើយ ភ្លើង ទោះបីបម្រើយូរបើប្រហែសក៏ឆេះ ដីរដែលស្និទ្ធស្នាលមកយូរ ក៏គង់សម្លាប់ហ្នបាន

ពស់វែកសូម្បីចិញ្ចឹមរហូតស្និទ្ធស្នាល បើប្រមាទក៏ចឹកអ្នកចិញ្ចឹមបាន ព្រះរាជាសូម្បីទ្រង់សព្វព្រះហឫទ័យ បើក្លេចខ្លួន គង់ធ្វើវត្តុមិនជាប្រយោជន៍បាន ស្រីទាំងឡាយក៏ដូចគ្នា ទោះបីប្រតិបត្តិមកអស់កាលយូរប៉ុនណា បើកើតការមិនពេញចិត្តក៏អាចធ្វើវត្តុមិនសមគួរបាន ។ បទថា **នាច្ចន្តវណ្ណា** បានដល់ ស្រីដែលស្អាតពេក បុរសមិនគួរគប់រកឡើយ ។ បទថា **ន ពហូន កន្តា** បានដល់ ស្រីដែលជាទីស្រឡាញ់ ជាទីពេញចិត្តនៃប្រុសច្រើនគ្នា ប្រៀបដូចស្រីនគរសោភិនី ដែលមនុស្សពេញចិត្តពាក់កណ្តាលដែនកាសី ( នាងអឌ្ឍកាសី ) បុរសមិនគួរគប់រក ។ បទថា **ន ទក្ខិណា** បានដល់ ស្រីដែលពូកែក្នុងការរាំនិងការច្រៀង ពិតហើយ ស្រីបែបនោះ រមែងមានមនុស្សប្រាថ្នាច្រើន មានសម្លាញ់ច្រើន ព្រោះហេតុនោះ ទើបបុរសមិនគួរគប់រក ។ បទថា **ន ធនស្ស ហេតុ** បានដល់ ស្រីណាគប់រកបុរស ព្រោះឃើញតែទ្រព្យ ស្រីនោះ សូម្បីមិនមានអ្នកណាហួងហែង បុរសក៏មិនគួរគប់រក ព្រោះថា ស្រីប្រភេទនោះ កាលមិនបានទ្រព្យ ក៏ខឹងសម្បារ ។

កាលបក្សីកុណាលពោលយ៉ាងនេះហើយ មហាជនបានស្តាប់ធម្មកថាដ៏ពីរោះរបស់មហាសត្វ ក៏ឲ្យសាធុការថា អស្ចារ្យហ្ន៎ លោកពោលល្អពិតៗ សូម្បីស្តេចបក្សីកុណាលនោះ ក៏បានពោលទោសរបស់ស្រីទាំងឡាយ ដោយហេតុមានប្រមាណប៉ុណ្ណេះហើយ ក៏នៅស្ងៀម ស្តេចត្មាតឈ្មោះថាអានន្ទ បានស្តាប់ពាក្យនោះហើយ ទើបពោលថា បពិត្រស្តេចកុណាលសម្លាញ់ ខ្ញុំសូមពោលទោសរបស់ពួកស្រីតាមចំណេះដឹងរបស់ខ្ញុំបន្តិច ហើយក៏ប្រារព្ធសម្តែង

ទោសតទៅ ។

ព្រះសាស្តា កាលទ្រង់សម្តែងរឿងដែលស្តេចត្មាតប្រាប់ពួកថាសម្តែងទោសរបស់ស្រីនោះ ទើបត្រាស់ថា

ជំណាលថា គ្រានោះ ស្តេចត្មាតឈ្មោះអានន្ទ បានដឹងនូវគាថា ជាខាងដើម កណ្តាល និងខាងចុងរបស់កុណាលសកុណៈ ហើយ បានពោលគាថានេះក្នុងវេលានោះថា

បុរសទោះបីឲ្យនូវផែនដី ដែលពេញដោយទ្រព្យដល់ស្ត្រី ដែលសន្មតហើយ ស្រីនោះលុះបានឱកាស រមែងមើលងាយប្រុសនោះវិញ ( ព្រោះហេតុនោះ ) បុរសមិនត្រូវលុះអំណាចនៃស្រីទាំងនោះឡើយ ។ ពួកស្រីរមែងលះបង់នូវប្តីក្មេងដែលជាអ្នកមានព្យាយាមក្រោកឡើង មានការប្រព្រឹត្តមិនរួញរា គួរជាទីស្រឡាញ់ពេញចិត្តផង លះបង់នូវប្តីនោះ ព្រោះកិច្ចដែលមានអន្តរាយផង ព្រោះហេតុនោះ ខ្ញុំមិនទុកចិត្តចំពោះស្រីទាំងឡាយទេ ។ បុរសមិនត្រូវទុកចិត្តស្រីដោយគិតថា ស្រីនោះចង់បានអញ មិនត្រូវទុកចិត្តស្រីដោយគិតថា ស្រីនោះយំរំជែចំពោះអញ ( ដូច្នេះទេ ) ព្រោះថា ស្រីទាំងនោះរមែងគប់រកនូវបុរស ទាំងជាទីស្រឡាញ់ ទាំងមិនជាទីស្រឡាញ់ ដូចទូកជួបប្រទះទាំងច្រាំងខាងអាយ និងច្រាំងខាងនាយ ។ បុគ្គលមិនត្រូវទុកចិត្តមែកឈើចាស់ ដែលគេ

ក្រោលទុកទេ មិនត្រូវទុកចិត្តចោរជើងចាស់ជាមិត្តទេ មិនត្រូវទុកចិត្តថា ព្រះរាជាជាសម្លាញ់របស់អញដូច្នេះទេ មិនត្រូវទុកចិត្តស្រីជាមាតារបស់បុត្ត ១០ នាក់ ( យាយចាស់ ) ទេ បុគ្គលមិនត្រូវទុកចិត្ត ចំពោះពួកនារីអ្នកធ្វើនូវសេចក្តីត្រេកអរ អ្នកកន្លងសីលធម៌ មិនសង្រួមទេ មិនត្រូវទុកចិត្តកិរិយាដែលមានសេចក្តីស្រឡាញ់ក្រៃពេក ព្រោះថា នារីទាំងឡាយទុកស្មើកំពង់ទឹក ។ ពួកស្រីរមែងសម្លាប់ ( ប្រុស ) ខ្លះកាត់ ( កប្រុស ) ខ្លួនឯងខ្លះ ប្រើគេឲ្យកាត់ខ្លះ កាត់កហើយផឹកឈាមខ្លះ បុគ្គលកុំធ្វើសេចក្តីស្នេហាចំពោះពួកស្រី ដែលមានសេចក្តីប្រាថ្នាថោកទាប ជាអ្នកមិនសង្រួម មានចិត្តដូចកំពង់ទឹក ។ ពាក្យកុហករបស់ពួកស្រីទាំងនោះ ក៏ដូចជាពាក្យពិត ឯពាក្យពិតរបស់ពួកស្រីទាំងនោះ ក៏ដូចជាពាក្យកុហក ( ពួកស្រី ) ដូចគោ ស៊ីច្បិចតែស្មៅល្អៗ ខាងក្រៅ ។ ពួកស្រីទាំងនោះ តែងប្រឡោម ( ប្រុស ) ដោយដំណើរផង ដោយអាការដែលក្រឡេកមើលផង ដោយសំណើចផង ឬដោយសំពត់ដែលស្លៀកអាក្រក់ផង ដោយពាក្យពីរោះផង ។ ពិតណាស់ ស្រីទាំងនេះដូចចោរ មានចិត្តរឹងត្អឹង ខូចកាច តែមានសំដីផ្អែមដូចស្ករ ការបញ្ឆោតណា ក្នុងពួកមនុស្ស ពួកស្រីទាំងនោះ មិនមែនជាមិនដឹងការបញ្ឆោត

ណាមួយ ( នោះ ) ទេ ។ ធម្មតាពួកស្រីក្នុងលោក ( ច្រើនតែ ) លាមក វេលារបស់ពួកស្រីទាំងនោះមិនមានទេ ពួកស្រីជាអ្នកស្រើបស្រាលផង ឃ្នើសឃ្នងផង ដូចភ្លើងស៊ីវត្ថុគ្រប់យ៉ាង ។ បុរសឈ្មោះថា ជាទីស្រឡាញ់របស់ពួកស្រីមិនមាន ទាំងមិនជាទីស្រឡាញ់ក៏មិនមាន ព្រោះថា ពួកស្រីទាំងនេះ តែងគប់រកបុរសជាទីស្រឡាញ់ ទាំងមិនស្រឡាញ់ ដូចទូកតែងជួបប្រទះទាំងច្រាំងខាងអាយ និងច្រាំងខាងនាយ ។ បុរសឈ្មោះថា ជាទីស្រឡាញ់របស់ពួកស្រីមិនមាន ទាំងមិនជាទីស្រឡាញ់ក៏មិនមាន ពួកស្រីតែងរួបរួមព័ទ្ធ ( បុរស ) ដើម្បីទ្រព្យសម្បត្តិ ដូចវល្លិ៍តោងដើមឈើ ។ ស្រីទាំងឡាយតែងរត់តាមបុរសឃ្វាលដំរី ឃ្វាលសេះ ឃ្វាលគោ បុរសចណ្ឌាល អ្នកដុតខ្មោច និងអ្នកចោលសំរាម ដែលមានទ្រព្យ ។ ស្រីទាំងឡាយ តែងលះបង់នូវកូនអ្នកមានត្រកូល ដែលមិនមានទ្រព្យតិចតួច ទុកស្មើសាកសព នារីទាំងឡាយ ( ច្រើនតែ ) គប់រកបុរស ព្រោះហេតុតែទ្រព្យ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អាធិមជ្ឈគាថាបរិយោសានំ** បានដល់ ស្ដេចត្រាតដីងច្បាស់នូវបទខាងដើម កណ្ដាលនិងខាងចុងនៃគាថា ។ បទថា **លទ្ធា ខណំ** បានដល់ បានឱកាស ។ បទថា **ឥច្ចតិ មំ** បានដល់ បុរសមិនគប្បីស្និទ្ធស្នាលជាមួយស្រីទាំងឡាយ ដោយគិតថា ស្រីនេះប្រាថ្នាក្នុងអញ ។ បទ

ថា **សាខបុរាណសន្ថតំ** បានដល់ បុរសមិនគប្បីស្និទ្ធស្នាល គឺទុកចិត្ត កម្រាលស្លឹកឈើ ដែលគេក្រាលទុកហើយ កាលពីម្សិលមិញ ឬក្នុងថ្ងៃមុនៗ កាលមិនបានពិនិត្យមើល ឬមិនបានពិចារណាហើយ មិនគប្បីប្រើប្រាស់ ព្រោះថា សត្វលូនវារគប្បីចូលទៅអាស្រ័យ ឬថា សត្រូវគប្បីបង្កប់សស្ត្រា ទុកក្នុងកម្រាលនោះ ។ បទថា **មិត្តចោរាណចោរំ** បានដល់ ចោរដែលស្កាត់ ក្នុងទីចាំប្រទូស្តអ្នកដំណើរ បុគ្គលមិនគួរទុកចិត្តថា ជាមិត្តចាស់របស់អញ ព្រោះធម្មតា ចោរទាំងឡាយ រមែងសម្លាប់បំបិទមាត់បុគ្គលដែលស្គាល់ខ្លួន ចោល ។ បទថា **សខា មមំ** បានដល់ ដ្បិតថា ព្រះរាជាទាំងឡាយ តែង ខឹងក្រោធបានដោយរហ័ស ព្រោះហេតុនោះ បុគ្គលមិនគួរស្និទ្ធស្នាលនឹងព្រះ រាជាថា ជាសម្លាញ់របស់យើងឡើយ ។ បទថា **ឧសន្ធ មាតរំ** បានដល់ បុរស មិនគប្បីទុកចិត្ត ដោយគិតថា ស្រីនេះចាស់ហើយ ឥឡូវនេះ គង់នឹង មិនប្រព្រឹត្តក្រៅចិត្ត នឹងរក្សាខ្លួន ដូច្នេះ ។ បទថា **រាមករាសុ** បានដល់ ធ្វើនូវការត្រេកអរដល់ពួកជនពាល ។ បទថា **អច្ចន្តសីលាសុ** បានដល់ ជា អ្នកឈានកន្លងនូវសីលហើយ ។ បទថា **អច្ចន្តបេមានុគតស្ស** បានដល់ ទោះបីស្រីមានសេចក្តីស្រឡាញ់បំផុត ហេតុនោះ បុគ្គលមិនគប្បីស្និទ្ធស្នាល ជាមួយស្រីនោះ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះស្រីទាំងឡាយ ស្មើ ដោយស្ទឹង អធិប្បាយថា ធម្មតាស្រី រមែងជារបស់ទូទៅដល់ប្រុសទាំងអស់ ប្រៀបដូចកំពង់ទឹក ។

បទថា **ហនេយ្យុំ** បានដល់ ស្រីទាំងឡាយដែលក្រោធនឹងប្តី ឬប្រាថ្នា

ក្នុងបុរសដទៃ គប្បីធ្វើនូវការសម្លាប់ជាដើមទាំងអស់ ។ បទថា **មា ធីឯកា-មាសុ** បានដល់ មានអធ្យាស្រ័យអាក្រក់ ។ បទថា **ភាវំ** បានដល់ កុំធ្វើនូវសេចក្តីស្នេហាក្នុងពួកស្រីបែបនេះ ។ បទថា **គង្គតិត្ថូបមាសុ** បានដល់ ដូចគ្នានឹងកំពង់ទឹក ដោយអត្ថថា ទូទៅដល់ពួកជន ។ បទថា **មុសា** បានដល់ ពាក្យមុសាវាទរបស់ស្រីទាំងនោះ ដូចគ្នានឹងពាក្យពិតនោះឯង ។ បទថា **គតេធ** បានដល់ បណ្ឌិតគប្បីសម្តែងឧម្មាទន្តីជាតក ដោយការសម្លឹងមើលនិងដោយការលួងលោម គប្បីសម្តែងរឿងនិឡិកាជាតក ដោយការស្លៀកសំពត់មិនជិត គប្បីសម្តែងរឿងរបស់ព្រះនន្ទត្ថេរ មានពាក្យជាដើមថា បពិត្រអយ្យបុត្ត សូមទ្រង់ប្រញាប់មកឆាប់ៗ ដូច្នេះ ដោយពាក្យលួងលោមដ៏ពីរោះ ។ បទថា **ចោរិយោ** បានដល់ ស្រីទាំងឡាយជាចោរ ដោយធ្វើទ្រព្យដែលប្តីរកមកបានឲ្យវិនាស ។ បទថា **កឋិនា** បានដល់ មានហទយៈរឹងត្អឹង ។ បទថា **វាឡា** បានដល់ មានចិត្តប្រទូស្ត អធិប្បាយថា ក្រោធដោយហេតុបន្តិចបន្តួចប៉ុណ្ណោះ ។ បទថា **លបសក្ខរា** បានដល់ ជាបុគ្គលនិយាយផ្អែមដូចស្ករ ដោយការបរបាតែពាក្យឥតប្រយោជន៍ ។ បទថា **អសា** បានដល់ ជាអ្នកស្វែងរកនូវការត្រេកអរមិនបាន ជាបុគ្គលលាមក ។ បទថា **សារត្តា** បានដល់ ជាអ្នកមានតម្រេកសព្វកាល ។ បទថា **បគព្ភា** បានដល់ ជាអ្នកក្តាំក្តួង ដោយការក្តាំក្តួងកាយជាដើម ។ បទថា **យថា** បានដល់ អណ្តាតភ្លើង រមែងឆេះទាំងអស់ មិនលើកលែង យ៉ាងណា សូម្បីស្រីទាំងនោះក៏ដូចគ្នា រមែងស៊ីគ្រប់យ៉ាងមិនលើកលែងយ៉ាងនោះ ។ បទថា **បដិ-**

**វេល្លន្តិ** បានដល់ ការប្រឡូកប្រឡាំជំពាក់ជំពិន ។ បទថា **លតាវ** អធិប្បាយថា វល្លិរមែងរុំដើមឈើ យ៉ាងណា ស្រីទាំងនោះ ទោះបីគោងបុរស ឈ្មោះថាសេពគប់ ព្រោះទ្រព្យ ។ បទថា **ហត្ថិពន្ធំ** បានដល់ បណ្ដាអ្នកចិញ្ចឹមដំរីជាដើម អ្នកចិញ្ចឹមគោហៅថា គោបុរស ។ បទថា **ធវធាហកំ** បានដល់ អ្នកពុកអ្នកកុយ អធិប្បាយថា អ្នកដុតខ្មោច ។ បទថា **បុប្ផឆឌ្ឌកំ** បានដល់ បុគ្គលដែលសម្អាតក្នុងទីស្មោកគ្រោក ។ បទថា **សធនំ** បានដល់ បណ្ដាបុគ្គលទាំងអស់នេះ ស្រីរមែងជាប់តាមបុរសដែលមានទ្រព្យ ។ បទថា **អ-កិញ្ចនំ** បានដល់ មិនមានទ្រព្យ ។ បទថា **ធវកសមំ សធិសំ** បានដល់ដូចគ្នានឹងមនុស្សចណ្ឌាលដែលស៊ីសាច់ឆ្កែ ស្រីទាំងឡាយរមែងដល់ គឺរមែងគប់រក បុរសដែលមិនមានគុណវិសេសដោយទ្រព្យនោះ ព្រោះហេតុនោះ ទើបស្រីទាំងឡាយ ជាប់តាមបុរស ព្រោះហេតុនៃទ្រព្យ ។

ស្ដេចត្មាតឈ្មោះអានន្ទ តាំងនៅក្នុងចំណោះដឹងរបស់ខ្លួន ពោលទោសនៃស្រីទាំងឡាយដូច្នេះហើយ ក៏នៅស្ងៀម នារទឥសីបានស្ដាប់ពាក្យរបស់ស្ដេចត្មាតអានន្ទនោះហើយ ក៏តាំងនៅក្នុងញាណរបស់ខ្លួន ពោលទោសនៃស្រីទាំងនោះដែរ ។

ព្រះសាស្ដា កាលទ្រង់សម្ដែងដល់រឿងនារទឥសីពោលទោសនៃស្រីទើបត្រាស់ថា

សេចក្ដីដំណាលថា គ្រានោះ ទេវព្រាហ្មណ៍ ឈ្មោះនារទៈ
បានដឹងនូវគាថាជាខាងដើម កណ្ដាលនិងទីបំផុតរបស់ស្ដេច

ត្ថាគឈ្មោះអានន្ទហើយ ក៏ពោលគាថាទាំងឡាយនេះ ក្នុងវេលានោះថា

បពិត្រលោកជាម្ចាស់នៃបក្សី សូមលោកស្តាប់ពាក្យដែលខ្ញុំនឹងនិយាយដូចតទៅនេះ ជន ៤ ពួកនេះគឺ សមុទ្ទ ១ ព្រាហ្មណ៍ ១ ព្រះរាជា ១ ស្រី ១ រមែងមិនពេញ ។ ស្ទឹងណាមួយ ដែលអាស្រ័យនៅប្រឹថពី ដែលហូរទៅកាន់សាគរ ស្ទឹងទាំងនោះ ក៏ញុំាងសមុទ្ទឲ្យពេញមិនបាន ព្រោះថា សមុទ្ទរមែងមិនពេញបេះតែនៅខ្វះខាត ។ ព្រាហ្មណ៍រៀននូវវេទ មានគម្ពីរឈ្មោះឥតិហាសៈជាគម្រប់ ៥ ហើយ តែងប្រាថ្នានូវការបេះដឹងឲ្យក្រៃលែង ព្រោះថា ព្រាហ្មណ៍នោះ រមែងមិនពេញបេះតែខ្វះខាត ។ ចំណែកព្រះរាជាឈ្នះគ្រប់គ្រងផែនដីទាំងអស់ ព្រមទាំងសមុទ្ទនិងភ្នំហើយ តែងប្រាថ្នារកច្រាំងសមុទ្ទ និងផ្ទៃសមុទ្ទ ដែលសម្បូណ៌ដោយរតនៈមិនមានទីបំផុត ព្រោះថា ព្រះរាជានោះ រមែងមិនគ្រប់គ្រាន់ បេះតែខ្វះខាត ។ ស្រីម្នាក់ៗ មានប្តី ៨ ៗ ហើយប្តីនោះ ជាអ្នកក្លៀវក្លាផង មានកម្លាំងផង នាំមកនូវរសនៃសេចក្តីប្រាថ្នាគ្រប់យ៉ាង ក៏គង់ធ្វើនូវសេចក្តីប្រាថ្នាក្នុងប្តីទី ៩ ទៀត ព្រោះថា ស្រីនោះ រមែងមិនគ្រប់គ្រាន់ បេះតែខ្វះខាត ។ ពួកស្រីទាំងអស់ ដូចភ្លើងស៊ីនូវវត្ថុគ្រប់យ៉ាង ពួកស្រីទាំងអស់ ដូច

ស៊ីងនាំទៅនូវវត្ថុគ្រប់យ៉ាង ពួកស្រីទាំងអស់ ដូចមែកឈើមានបន្ទា ពួកស្រីទាំងអស់ គប់រក ( ប្តី ) ព្រោះហេតុតែទ្រព្យ ។ នរជនណា ផ្តុកផ្តាក់នូវភាព គឺការងារទាំងពួង លើពួកស្រី នរជននោះ ទុកដូចគេយកបណ្តាញចាប់ខ្យល់ ឬដូចជាគេបាចទឹកសមុទ្រដោយដៃម្ខាង ពុំនោះ ដូចគេយកដៃ ១ ទះឲ្យឮសូរគឹកកង ។ ពួកស្រីដែលដូចជាចោរ មានពុតត្បុតច្រើន មានពាក្យសច្ចៈគេរកបានដោយកម្រណាស់ ភាពនៃស្រីទាំងឡាយ គេដឹងបានដោយក្រ ដូចដំណើរនៃត្រីក្នុងទឹក ។ ពួកស្រីទាំងនោះ មានមារយាទរបិញរបុញ មានសំដីទន់ទុកស្មើដោយស៊ីង បំពេញបានដោយក្រ តែងលិចចុះ ( ក្នុងអបាយព្រោះហេតុតែកាម ) បុគ្គលដឹងច្បាស់នូវដំណើរនោះ ហើយគប្បីវៀរឲ្យឆ្ងាយចេញ ។ ពួកស្រីជាអ្នកញុំាងចិត្តប្រុសឲ្យត្រឡប់ត្រឡិន មានមាយាច្រើន ញុំាងព្រហ្មចរិយធម៌ឲ្យកម្រើក តែងលិចចុះ ( ក្នុងអបាយ ) បុគ្គលដឹងច្បាស់នូវដំណើរនោះហើយ គប្បីចៀសឲ្យឆ្ងាយចេញ ។ ពួកស្រីទាំងនោះ ចូលទៅគប់រកប្រុសណា ដោយសេចក្តីប្រាថ្នា ឬដោយទ្រព្យសម្បត្តិ រមែងដុតកម្តៅប្រុសនោះដោយឆាប់រហ័ស ដូចភ្លើងឆេះនូវទីរបស់ខ្លួន ដូច្នេះ ។

ក្នុងគាថានោះ នារទឥសីហៅបក្សីកុណាលដ៏ប្រសើរជាងពួកបក្សីថា

**ធិជម្បតិ** ។ បទថា **សរិតា** លោកពោលទុកហើយដើម្បីចែកមាតិកាដែល តាំងទុកហើយ ។ បទថា **ខិនត្តា** បានដល់ នៅខ្វះខាតនោះឯង ព្រោះ សមុទ្រនោះជាទីទទួលនូវទឹកច្រើន ។ បទថា **អធិយាន** បានដល់ ទន្ទេញនូវ វេទហើយ ។ បទថា **វេទមក្ខានបញ្ចមំ** បានដល់ វេទទាំង ៤ ពួក មាន ឥតិហាសៈជាគម្រប់ ៥ ។ បទថា **ខិនត្តា** បានដល់ ពិតហើយ ព្រាហ្មណ៍ នោះ ឈ្មោះថា មិនឆ្អែតដោយវេទដែលខ្លួនគប្បីសិក្សា ព្រោះខ្លួន មានអធ្យា ស្រ័យធំធេង ។ បទថា **អនន្តរតនោចិតំ** បានដល់ ប្រកបបរិបូណ៌ដោយ រតនៈផ្សេងៗ ។ បទថា **ខិនត្តា** បានដល់ ឯព្រះរាជានោះ រមែងមិនពេញ ព្រោះខ្លួនមានចំណង់ច្រើន ។ បទថា **សិយា** កែជា **សិយុំ** ម្យ៉ាងទៀត បាលី ជា **សិយុំ** ដូច្នេះក៏មាន ។ បទថា **សព្វកាមរសាហរា** បានដល់ នាំរសនៃ ការមកសព្វបែបយ៉ាង ។ បទថា **ឆរមេ** នេះ លោកពោលទុកដើម្បីសម្តែង ភាវៈដែលកន្លងមកហើយដល់ទៅ ៨ នាក់ ស្រីនោះ ក៏រមែងធ្វើសេចក្តីពេញ ចិត្តក្នុងបុរសទី ១០ ទី ២០ ឬដែលក្រៃលែងជាងនោះបាន ។ បទថា **ខិនត្តា** បានដល់ ស្រីទាំងនោះរមែងមិនពេញ ព្រោះមានកាមតណ្ហាច្រើន ។ បទថា **កណ្ដកានំវ សាខា** បានដល់ ដូចគ្នានឹងមែកឈើដែលមានបន្លាក្នុងផ្លូវដែល ចង្អៀត ។ ពិតហើយ បន្លានោះរមែងទាក់បាន យ៉ាងណា ស្រីនេះ ក៏រមែង ផ្តក់យកបុរសនោះមក ដោយរូបជាដើម យ៉ាងនោះ ម្យ៉ាងទៀត មែកឈើជន់ នូវអវយវៈ មានដៃជាដើម តែងនាំឲ្យកើតទុក្ខ យ៉ាងណា សូម្បីស្រីទាំងនេះ ក៏យ៉ាងនោះដូចគ្នា គ្រាន់តែប៉ះពាល់ប៉ុណ្ណោះ ក៏ផ្តក់យកសម្មស្សនៃសរីរៈ

រមែងឲ្យដល់នូវសេចក្តីវិនាសធំកន្លង ។ បទថា **វជន្តិ** បានដល់ ទៅតាម គឺជាប់តាមបុរសដទៃ ។ បទថា **បរាមសេ** បានដល់ ចាប់ ។ បទថា **ឧសិញ្ចយេ** បានដល់ បុគ្គលចុះកាន់សមុទ្រដើម្បីផឹកទឹក ហើយដងទឹកក្នុងសមុទ្រដោយដៃម្ខាង ហើយបាចទៅ គឺបាចសមុទ្រទាំងមូលដោយដៃម្ខាង ។ បទថា **សកោន** បានដល់ បុគ្គលយកដៃម្ខាងរបស់ខ្លួនវាយ ( ក្នុងទីទទេ ) នោះឯង ធ្វើឲ្យកើតសំឡេង ( ទះដៃម្ខាង ) ។ បទថា **សព្ភាវំ** អធិប្បាយថា បុរសណាកាលស្រីប្រាប់ថា លោកតែម្នាក់ជាទីប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត ដូច្នោះ ជឿស៊ប់ថា ពាក្យនេះជាពាក្យពិត យ៉ាងនេះហើយ គប្បីដាក់អធ្យាស្រ័យរបស់ខ្លួនទាំងអស់ទុកក្នុងស្រីទាំងឡាយ បុរសនោះ ឈ្មោះថា ធ្វើការបង់ខ្យល់ដោយសំណាញ់ជាដើម ។ បទថា **គតំ** បានដល់ ការហែលទៅរបស់ពួកត្រី ។ បទថា **អនលា** បានដល់ វៀរចាកពាក្យថាគ្រប់គ្រាន់ ដោយរឿងរបស់គ្រហស្ថ ។ បទថា **ឧប្បុរា តា** បានដល់ សមុទ្រពេញបានក្រ យ៉ាងណា សូម្បីស្រីក៏បំពេញបានដោយក្រ ដោយការត្រេកអរក្នុងកិលេស យ៉ាងនោះ ដូចគ្នា ។ បទថា **ធំ** ក្នុងបទថា **សីធន្តិ ធំ វិធិត្វាន** នេះ ត្រឹមតែជានិបាត អធិប្បាយថា បុគ្គលដឹងហើយថា ស្រីទាំងឡាយ រមែងធ្វើឲ្យលិចចុះក្នុងអបាយទាំង ៤ ដោយការជាប់ជំពាក់ ។ បទថា **អាវដ្តនី** បានដល់ អន្ទង់ទឹកក្តី មាយាក្តី រមែងធ្វើចិត្តរបស់នរជនឲ្យវង្វេង ឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួនបាន យ៉ាងណា សូម្បីស្រីទាំងនោះ ក៏យ៉ាងនោះដូចគ្នា ។ បទថា **វិកោបនា** បានដល់ ធ្វើនូវព្រហ្មចរិយៈឲ្យកម្រើក ដោយអត្ថថា ឲ្យ

វិនាស និងដោយអត្ថថា ព្រៃស្ងួក ។ បទថា **ឆន្ទសា វា** បានដល់ ដោយការនៅរួមគ្នា ដោយការពេញចិត្ត ។ បទថា **ធនេន វា** បានដល់ ឬព្រោះទ្រព្យជាហេតុ ។ បទថា **សណ្ឋានំ** បានដល់ ភ្លើងព្រៃឆេះក្នុងបទេសណា ក៏ដុតបទេសនោះៗដែលជាទីកើតរបស់ខ្លួន យ៉ាងណា ស្ត្រីប្រសើរទាំងនោះក៏យ៉ាងនោះ គប់រកជាមួយបុរសណាមួយដោយអំណាចកិលេស ក៏តាមដុតបុរសនោះៗ ឲ្យដល់នូវសេចក្តីវិនាសយ៉ាងធំ ។

កាលនារទឥសីប្រកាសទោសរបស់ស្រីទាំងឡាយ យ៉ាងនេះហើយ មហាសត្វក៏ប្រកាសទោសរបស់ស្រីទាំងនោះឲ្យវិសេសឡើងបន្តទៀត ។

ព្រះសាស្តា កាលទ្រង់សម្តែងការដែលបក្សីកុណាលប្រកាសទោសនៃស្រីដោយវិសេសឡើងនោះ ទើបត្រាស់ថា

សេចក្តីដំណាលថា គ្រានោះ កុណាលសកុណៈ ដឹងនូវគាថាជាខាងដើម កណ្តាល និងទីបំផុតនៃទេវព្រាហ្មណ៍[១]ឈ្មោះនារទ ហើយក៏ពោលគាថានេះក្នុងវេលានោះថា

បណ្ឌិតគួរចរចា ( ជាមួយ ) នឹងបុគ្គលមានដៃកាន់ដាវសំលៀងហើយ ( ជាមួយ ) នឹងបុគ្គលប្រទូស្តដូចជាបិសាច ឬក៏ចូលទៅរកពស់ដែលមានពិសដ៏ពន្លឹក ( ប្រសើរជាង ) ប្រុសម្នាក់ឯង មិនគួរនិយាយចរចាចំពោះស្រីម្នាក់ឯងទេ ។

ព្រោះថា នារីទាំងឡាយ ជាអ្នកញាំញីនូវចិត្តនៃមនុស្សលោក

---

១-ពាក្យថាទេវព្រាហ្មណ៍ គឺព្រាហ្មណ៍ដ៏ប្រសើរ មិនមែនព្រាហ្មណ៍ឈ្មោះទេវៈ ។

ជាអ្នកមានការរាំច្រៀង និយាយ សើច ញញឹមជាអាវុធ តែង បៀតបៀនទូវប្រុសដែលមិនបានតម្កល់ស្មារតី ដូចពួកស្រី អារក្សទឹកក្នុងកោះបៀតបៀនពួកពាណិជ្ជ ។ ពួកស្រីទាំងនោះ មិនមានវិន័យ មិនមានសំវរៈ ពួកស្រីទាំងនោះ ជាអ្នកល្មោភ ទឹកស្រវឹងនិងសាច់ ជាអ្នកមិនសង្រួម តែងលេបទ្រព្យសម្បត្តិ របស់បុរស ដូចត្រីធំឈ្មោះតិមិង្គលៈលេបទូវមករក្នុងសាគរ ។ ពួកស្រី មានសេចក្តីត្រេកអរក្នុងបញ្ចកាមគុណជាអារម្មណ៍ មានអាការឆ្មើងឆ្មៃ មិនទៀង មិនសង្រួម ឃ្លាំរកតែបុរសអ្នក ប្រមាទដូចទឹកស្ទឹងតែងហូរចុះទៅរកទីមានទឹកប្រៃ ( សមុទ្ទ ) ។ នារីទាំងឡាយ រមែងនិយាយស្រស់ស្រាយ រកជនណា ដោយសេចក្តីស្រឡាញ់ ឬដោយតម្រេក ឬក៏ដោយទ្រព្យ ជា ស្រីសម្លាប់ប្រុសដោយរាគៈ និងទោសៈ រមែងដុតរោលនរ ជននោះ សូម្បីបុរសរុងរឿងដូចភ្លើង ជាអ្នកទីងទួន ។ ពួក ស្រីដឹងថា បុរសអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន រមែងក្រវែល រកប្រុស ដែលមានទ្រព្យដោយខ្លួនឯង រួបរុំបុរសដែលមាន ចិត្តត្រេកអរ ដូចពួរជ្រែក្នុងព្រៃរួបព័ទ្ធដើមរាំង ។ នារីទាំង ឡាយនោះ មានខ្លួននិងមុខដ៏វិចិត្រតាក់តែងហើយ ផ្គាប់ផ្គុន ( បុរស ) ដោយសេចក្តីប្រាថ្នាផ្សេងៗ ជាអ្នកយល់កល មាយាទាំងរយ រមែងសើច រមែងញញឹម តែហាក់ដូចជា

សង្គ្រាម ។ នារីទាំងឡាយ ស្អិតស្អាងខ្លួនដោយមាស កែវមណី និងកែវមុក្តា ដែលគេធ្វើសក្ការៈ ក្នុងត្រកូលរបស់ប្តី ដែលគេរក្សាហើយ ក៏នៅតែប្រព្រឹត្តក្បត់ស្វាមីបាន ដូចជាប្រពន្ធ ដែលអាស្រ័យនៅក្នុងចន្លោះហឫទ័យ ប្រព្រឹត្តក្បត់អសុរវិញបាន ។ នរជនសូម្បីមានតេជៈ មានប្រាជ្ញាវាងវៃ ដែលអ្នកផងច្រើនគ្នាធ្វើសក្ការបូជា លុះក្នុងអំណាចនៃស្រីទាំងឡាយហើយ រមែងមិនរុងរឿង ដូចព្រះចន្ទដែលត្រូវរាហូចាប់ ។ ចោរអ្នកក្រោធ មានចិត្តអាក្រក់ ( ឃើញ ) ចោរជាសត្រូវ ( នឹងខ្លួន ) មកប្រទះគ្នាហើយ ធ្វើនូវសេចក្តីវិនាសណា បុគ្គលអ្នកមានតណ្ហា លុះក្នុងអំណាចនៃស្រីទាំងឡាយ រមែងដល់នូវសេចក្តីវិនាសក្រៃលែងជាងសេចក្តីវិនាសនោះទៅទៀត ។ នារីទាំងឡាយ ដែលមានសក់របោច មានស្នាមដាច់ដោយក្រចក ដែលត្រូវគេវាយ គេជាក់ដោយជើងដៃនិងដំបង ក៏នៅតែចូលទៅកាន់អាការថោកទាបវិញ នៅតែត្រេកអរ ( ក្នុងកាមទៀត ) ដូចរុយត្រេកអរនឹងសាកសព ។ បុរសអ្នកមានបញ្ញាចក្ខុ ត្រូវការដោយសេចក្តីសុខគប្បីវៀរស្រីទាំងឡាយនោះ ( ដែលនៅ ) ក្នុងត្រកូលទាំងឡាយក្តី ក្នុងចន្លោះប្រកក្តី ក្នុងរាជធានីក្តី ក្នុងនិគមក្តី ឬក៏វៀរនូវអារម្មណ៍ ដូចជាអន្ទាក់និងបង្កាត់របស់មារ ដែលកិលេស

មារដាក់ហើយក្តី ។ បគ្គលណា លះបង់នូវតបោគុណ ( គុណ គឺសេចក្តីព្យាយាម ) ជាកុសលហើយ ប្រព្រឹត្តនូវចរិតមិន ប្រសើរ បុគ្គលនោះ ( លុះច្យុត ) ចាកទេវតាហើយ នឹង មកកាន់នរកវិញ ដូចពាណិជ ( មានទ្រព្យច្រើនដូរយក ) ក្អមកំបែក ។ ប្រុស ( ដែលលុះក្នុងអំណាចស្រី ) នោះ ត្រូវគេតិះដៀលក្នុងលោកនេះផង ក្នុងលោកខាងមុខផង ជា មនុស្សមានគំនិតអាក្រក់ ត្រូវកម្មរបស់ខ្លួនបៀតបៀន ជា បុគ្គលមិនទៀង តែងធ្លាក់ទៅកាន់អបាយភូមិ ដូចរថដែលទឹម លាកាច ដើរទៅក្នុងទីខុសផ្លូវ ។ ប្រុសនោះ រមែងចូលទៅ កាន់នរក ជាទីញុំាងសត្វឲ្យក្តៅ នៅអាស្រ័យនឹងព្រៃរកា មាន បន្ទាដូចលំពែងធ្វើអំពីដែកផង កំណើតតិរច្ឆានផង វិស័យនៃ ប្រេតនិងអសុរកាយផង រមែងមិនអាចរួចបានទេ ។ ស្រីទាំង ឡាយ រមែងញុំាងល្បែងជាទិព្វ ឬញុំាងតម្រេកក្នុងទីជាទីរីក រាយ ឬញុំាងសម្បត្តិចក្រពត្តិ ក្នុងទីជារបស់មនុស្សនៃបុគ្គល អ្នកប្រមាទឲ្យវិនាស ពួកស្រីរមែងញុំាងប្រុសនោះ ឲ្យដល់ នូវទុគ្គតិ ។ ល្បែងជាតម្រេកទិព្វ សម្បត្តិស្តេចចក្រពត្តិ ក្នុង ទីជារបស់មនុស្ស និងពួកស្រីអប្សរមានពិមានមាសជាលំ នៅ ជាសម្បត្តិដែលបុគ្គលមិនត្រូវការដោយពួកស្ត្រី ហើយ ប្រព្រឹត្ត ( ព្រហ្មចរិយធម៌ ) មិនមែនបានដោយក្រទេ ។ គតិ

ជាទីកន្លងផុតចាកកាមធាតុ គឺការកើតក្នុងរូបធាតុនិងការកើត ក្នុងសុទ្ធាវាស ជាវិស័យរបស់អ្នកប្រាសចាករាគៈ ជាសម្បត្តិ ដែលបុគ្គលមិនត្រូវការដោយពួកស្ត្រី ហើយប្រព្រឹត្ត ( ព្រហ្ម- ចរិយធម៌ ) មិនមែនបានដោយក្រទេ ។ គុណជាតដ៏ក្សេម ក្សាន្តគឺព្រះនិព្វាន ជាទីកន្លងផុតចាកទុក្ខទាំងពួង ជាអច្ចន្តសុខ មិនកម្រើក មិនមានបច្ច័យតាក់តែង បុគ្គលមិនត្រូវការដោយ ស្រី ហើយប្រព្រឹត្ត ( ព្រហ្មចរិយធម៌ ) ជាអ្នកស្អាត មាន កិលេសរលត់ មិនមែនបានដោយក្រទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សល្លបេ** បានដល់ បណ្ឌិតគប្បីចរចាជាមួយ បុរសដែលឈរកាន់ដាវ ពោលថា បើអ្នកចរចាជាមួយយើង យើងនឹងកាត់ ក្បាលអ្នក គប្បីចរចាជាមួយបិសាចដែលកំពុងក្រោធ ឈរពោលថា យើង នឹងស៊ីអ្នក ក្នុងខណៈដែលអ្នកនិយាយនេះឯង នឹងធ្វើឲ្យអ្នកដល់នូវសេចក្តី វិនាសនៃជីវិត ។ ម្យ៉ាងទៀត បណ្ឌិតគប្បីចូលទៅអង្គុយជិតពស់ ដែលមាន តេជៈដ៏ពន្លឹក ដែលអើតក្បាលពោលថា ខ្ញុំនឹងចឹកអ្នក ដែលចូលមកជិតហើយ ធ្វើឲ្យវិនាស ។ តែបណ្ឌិតកាលនៅតែឯងហើយ កុំចរចាជាមួយស្រីក្នុងទីកំបាំង តែ ២ នាក់ ។ បទថា **លោកចិត្តមថនា** បានដល់ ស្រីទាំងឡាយជាអ្នក ញាំញីចិត្តរបស់សត្វលោក គឺគ្របសង្កត់ចិត្តរបស់សត្វលោក ។ បទថា **ឱបេ រក្ខសិគណោ** បានដល់ ពួកអារក្ខស្រី ( យក្ខិនី ) អាស្រ័យត្រង់កោះ កណ្តាលសមុទ្រ កាឡាខនជាស្រីមនុស្សមកបញ្ឆោតពួកឈ្មួញ នាំទៅទុកក្នុង

អំណាចរបស់ខ្លួន ហើយទំពាស៊ី យ៉ាងណា សូម្បីស្រីទាំងនោះ ក៏យ៉ាងនោះ ធ្វើសត្វលោកទុកក្នុងអំណាចរបស់ខ្លួន ដោយកាមគុណទាំង ៥ មានរូបជាដើម ហើយឲ្យដល់នូវសេចក្ដីវិនាសយ៉ាងធំ ។ បទថា **វិធយោ** បានដល់ ការប្រព្រឹត្ត ។ បទថា **សំវរោ** បានដល់ មារយាទ ។ បទថា **បុរិសស្ស ចាភតំ** បានដល់ ស្រីទាំងឡាយរមែងលេប គឺធ្វើទ្រព្យប្ដីដែលរកបានមក ដោយការនឿយហត់ ឲ្យវិនាសទៅ ។ បទថា **អធិយតា** បានដល់ មានចិត្តមិនពិតប្រាកដ ។ បទថា **លោណតោយវតិយំ** បានដល់ ហូរទៅកាន់ទឹកប្រៃ គឺសមុទ្រនោះឯង ។ បទថា **អាបគា** បានដល់ ស្ទឹងទាំងឡាយ ។ ម្យ៉ាងទៀតបាលីជា **នធិយោ** ដូច្នេះក៏មាន អធិប្បាយថា ស្ទឹងទាំងឡាយ រមែងហូរចូលទៅកាន់សមុទ្រ យ៉ាងណា ស្រីទាំងឡាយ រមែងនាំយកបុរសដែលប្រមាទដោយការប្រហែលធ្វេសនោះ ដូចគ្នា ។ បទថា **ឆន្ទសា** បានដល់ ព្រោះសេចក្ដីស្រឡាញ់ ។ បទថា **រតិយា** បានដល់ ព្រោះការត្រេកអរក្នុងកាមគុណទាំង ៥ ។ បទថា **ធនេន វា** បានដល់ ឬព្រោះហេតុនៃទ្រព្យ ។ បទថា **ជាតវេទសធិសំ** បានដល់ ដូចភ្លើងដែលឆេះសន្ធោសន្ធៅហើយ ព្រោះដល់ព្រមដោយទោស ។ បទថា **រាគទោសវធិយោ** បានដល់ ជាអ្នកសម្លាប់ដោយកាមរាគៈនិងទោសៈ ម្យ៉ាងទៀត បាលីជា **រាគទោសគតិយោ** ( ជាអ្នកមានរាគៈទោសៈជាទីទៅ ) ដូច្នេះក៏មាន ។ បទថា **ឱរសន្តិ** បានដល់ ចូលទៅចងបុរសនោះដោយពាក្យផ្អែមល្ហែម ។ បទថា **សធនំ** បានដល់ ស្រីមានប្រាក់ មានមាសច្រើន បាលីជា **សធនា** ដូច្នេះក៏មាន អធិប្បាយថា

សូម្បីឲ្យទ្រព្យរបស់ខ្លួនណាមួយហើយ ក៏គង់ផ្សាយទៅដើម្បីត្រូវការសំពត់និងគ្រឿងប្រដាប់ជាដើម ។ បទថា **សហត្ថា** បានដល់ ដូចជាលះបង់ខ្លួនរបស់ខ្លួនឯងដល់បុរសនោះឯង ។ បទថា **អតិវេលយន្តិ** បានដល់ ជាប់ស្អិតក្រៃលែង ព្រោះត្រូវការទ្រព្យ ។ បទថា **វិវិធេន ឆន្ទសា** បានដល់ ដោយអាការច្រើនយ៉ាង ។ បទថា **ចិត្រពិម្ពមុខិយោ** បានដល់ មានរាងកាយល្អ មានមុខស្អាត ដោយអំណាចនៃគ្រឿងប្រដាប់ ។

បទថា **ឱហាសន្តិ** បានដល់ សើចដោយសំឡេងខ្លាំង ។ បទថា **បហាសន្តិ** បានដល់ សើចដោយសំឡេងថ្នមៗ ។ បទថា **សំវរោ** បានដល់ ដូចបុរសដែលធ្វើការបោកបញ្ឆោតនិងដូចស្តេចអសុរ ។ បទថា **ទានវំ ហានយន្ត វធិស្សិតា** បានដល់ មហាសត្វសម្តែងថា មានរឿងពោលទុកថា ទានវៈម្នាក់ឲ្យកិរិយាអន្ទយក្នុងស្មុគ ហើយលេបទុកក្នុងពោះ ថ្ងៃមួយ ខ្ចាក់ស្មុគចេញមក ត្រេកអរនឹងគ្នាហើយ ចុះងូតទឹកក្នុងស្រះ វិទ្យាធរម្នាក់ ហោះមកឃើញកិរិយារបស់ទានវៈ ក៏ចុះមកធ្វើនូវសហាយស្មន់ លុះទានវៈឡើងអំពីទឹក នាងក៏យកវិទ្យាធរលាក់ទុកក្នុងស្មុគ ទានវៈក៏យកកិរិយានិងវិទ្យាធរ ដែលនៅក្នុងស្មុគលេបទៅក្នុងពោះទៀត ។ ស្រីសូម្បីលេបទុកក្នុងពោះ អាស្រ័យនៅត្រង់ចន្លោះហទយៈក៏គង់លះបង់ទានវៈបាន ប្រព្រឹត្តកន្លងជាមួយវិទ្យាធរផ្សេងទៅវិញ ដូចក្នុងរឿងសមុគ្គជាតក មានពាក្យផ្តើមថា នៃអ្នកដ៏ចម្រើន ចុះអ្នកទាំង ៣ នាក់ មកអំពីទីណា ដូច្នេះ ។ ស្រីទាំងឡាយរមែងប្រព្រឹត្តក្រៅចិត្តយ៉ាងនេះ នឹងពោលថ្វីដល់ស្រីទាំងនេះ ដែលមិនមានអ្នកហួងហែងថែរក្សា

នោះ ។ បទថា **ន ភាសតិ** បានដល់ រមែងមិនរុងរឿង ដូចព្រះបាទហារិតៈ ព្រះបាទលោមសកស្សបៈនិងព្រះបាទកុសរាជ ដូច្នោះ ។ បទថា **តេន** បានដល់ រមែងដល់នូវសេចក្តីវិនាសធំជាងសេចក្តីវិនាសដែលសត្រូវធ្វើនោះទៅទៀត ។ បទថា **អបេក្ខវា** បានដល់ នៅមានការចង់បាន ។ បទថា **កេស-លូនខច្ឆិន្នតជ្ជិតា** បានដល់ មានពោចសក់ មានខ្វាចនឹងក្រចក ត្រូវគំរាមហើយ ។ បទថា **តាឡិតា** បានដល់ ត្រូវវាយដោយអវយវៈ មានទាត់ជាដើម បុរសណា រមែងធ្វើអាការប្លែកៗ ទាំងនេះ ដោយអំណាចទោសៈ ស្រីទាំងឡាយរមែងចូលទៅរកបុរសដែលអាក្រក់បែបនោះ ហើយអភិរម ។ សួរថា ស្រីទាំងឡាយមិនបានទទួលការធ្វើអាការប្លែកៗយ៉ាងនេះ មិនត្រេកអរនឹងបុរសដែលប្រព្រឹត្តរាបសារ ព្រោះហេតុអ្វី ឆ្លើយថា ព្រោះពួករុយ រមែងត្រេកអរត្រង់សាកសព ។ បទថា **កុណបេវ មក្ខិកា** បានដល់ ស្រីទាំងនោះរមែងត្រេកអរក្នុងបុរសអាក្រក់ ដូចរុយគាប់ចិត្តក្នុងសាកសពដ៏វីជាដើមដែលគួរខ្ពើមដូច្នោះ ។

បទថា **ឱឌ្ឌិតំ** បានដល់ ស្រីទាំងនោះមិនឈ្មោះថាស្រីដោយពិត បុរសដែលមានបញ្ញាចក្ខុ ជាអ្នកត្រូវការដោយសុខដែលជាទិព្វ និងសុខដែលជារបស់មនុស្ស សម្គាល់នូវស្រីនោះក្នុងទីទាំងនេះ ហាក់បីដូចជាអន្ទាក់ និងសំណាញ់របស់មារ គឺកិលេសមារ គប្បីវៀរចេញ ដូចម្រឹគនិងបក្សី វៀរនូវអន្ទាក់និងជង់ ដែលពួកព្រានដាក់ដើម្បីចាប់ខ្លួន ដូច្នោះ ។ បទថា **ឱស្សជិត្វា** បានដល់ លះបង់នូវគុណ មានតបៈជាដើម ដែលអាចឲ្យនូវសម្បត្តិដ៏ធំ ក្នុង

ស្ថានសួគ៌និងស្ថានមនុស្ស ។ បទថា **យោ** បានដល់ បុរសណា អាចប្រព្រឹត្ត នូវចរិត ពោល គឺសេចក្ដីត្រេកអរក្នុងបញ្ចកាមគុណ ដែលមិនប្រសើរ មិន បរិសុទ្ធិ ។ បទថា **ទេវតាហិ និរយំ និមិស្សតិ** បានដល់ បុរសនោះនឹង ត្រឡប់ចាកទេវលោក ហើយមកបដិសន្ធិក្នុងនរក ។ បទថា **ជេនគាមិ-មណិយំវ វាណិជោ** បានដល់ ឈ្មួញលួងឲ្យទ្រព្យដែលមានតម្លៃច្រើន ដូរ យក ឆ្នាំងកំបែក យ៉ាងណា បុរសនេះក៏យ៉ាងនេះឯង ។ បទថា **សោ** បាន ដល់ បុរសដែលធ្លាក់នៅក្នុងអំណាចរបស់ស្រីទាំងឡាយ ។ បទថា **អនិយ-តោ** បានដល់ មិនពិតប្រាកដថា នឹងឆេះក្នុងអបាយទាំងឡាយអស់កាលមាន ប្រមាណប៉ុណ្ណេះ ។ បទថា **គលាគលំ** បានដល់ ក្លាត់ចាកទេវលោក ឬ មនុស្សលោកហើយ រមែងធ្លាក់ក្នុងអបាយតែម្យ៉ាង សួរថា ប្រៀបដូចអ្វី ឆ្លើយ ថា ប្រៀបដូចរថដែលទឹមដោយលាកាច ដូច្នោះ អធិប្បាយថា ដូចរថដែល ទឹមដោយលាកាច រមែងគេចចេញអំពីផ្លូវទៅខាងក្រៅផ្លូវ ។ បទថា **សត្តិ-សិម្ពលិវនញ្ច** បានដល់ នរកនោះ មានព្រៃរកាជាដែក ប្រកបដោយបន្លាដូច លំពែង ។ បទថា **បេតរាជវិសយំ** បានដល់ បិត្តិវិស័យ និងកាឡកញ្ជិកាសុរ វិស័យ ។

បទថា **បមាទិនំ** បានដល់ ប្រហែសធ្វេស ។ ពិតហើយ បុរសទាំង នោះ ជាអ្នកប្រមាទហើយក្នុងស្រីទាំងឡាយ រមែងមិនធ្វើគុណដែលជាមូល នៃសម្បត្តិទាំងនោះ ស្រីទាំងនោះ ឈ្មោះថា រមែងធ្វើសម្បត្តិរបស់បុរសដែល ប្រមាទហើយទាំងនោះឲ្យវិនាសទៅដោយប្រការដូច្នេះ ។ បទថា **បដិបាទ-**

**យន្តិ** បានដល់ ស្រីទាំងនោះ រមែងញ៉ាំងបុរសបែបនោះ ឲ្យធ្វើតែអកុសលកម្មដោយអំណាចនៃការប្រមាទ ឈ្មោះថា ធ្វើបុរសនោះឲ្យធ្លាក់ទៅកាន់ទុគ្គតិ ។ បទថា **សោវណ្ណព្យម្ហនិលយា** បានដល់ ជាអ្នកមានប្រក្រតីនៅក្នុងវិមានដែលសម្រេចដោយមាស ។ បទថា **បមុទាហានត្ថិកា** បានដល់ បុរសពួកណាជាអ្នកមិនមានសេចក្ដីត្រូវការដោយស្រីទាំងឡាយហើយ រមែងប្រព្រឹត្តព្រហ្មចរិយៈ ។ បទថា **កាមធាតុសមតិក្កមា** បានដល់ ផ្លូវដើរព្រោះកន្លងកាមធាតុបាន ។ បទថា **រូបធាតុសម្ភវា** បានដល់ ការកើតក្នុងរូបធាតុ ពោលគឺផ្លូវដើរដែលឈានកន្លងកាមធាតុ រមែងជារបស់រកបានមិនលំបាក ដល់ជនទាំងនោះឡើយ ។ បទថា **វីតរាគវិសយូបបត្តិ យា** បានដល់ ការកើតក្នុងទេវលោកជាន់សុទ្ធាវាស ដែលជាវិស័យនៃបុគ្គលដែលប្រាសចាករាគៈនោះ ដែលជនទាំងនោះ បានមិនលំបាក ។ បទថា **អចុន្តំ** បានដល់ មិនប្រព្រឹត្តកន្លង គឺមិនដល់នូវសេចក្ដីវិនាសជាធម្មតា ។ បទថា **អចលិតំ** បានដល់ មិនកម្រើកដោយកិលេសទាំងឡាយ ។ បទថា **និព្វុតេហិ** បានដល់ មានកិលេសរលត់ហើយ ។ បទថា **សុចីហិ** បានដល់ ព្រះនិព្វានបែបនេះ ដែលលោកអ្នកបរិសុទ្ធ គឺអ្នកស្អាតទាំងឡាយ គប្បីបានដោយមិនលំបាកឡើយ ។ ព្រះមហាសត្វ ញ៉ាំងនូវទេសនាឲ្យចប់ដល់អមតមហានិព្វានយ៉ាងនេះហើយ សត្វទាំងឡាយមានកិន្នរនិងស្ដេចនាគក្នុងហិមពាន្ត និងទេវតានៅក្នុងអាកាសក៏នាំគ្នាឲ្យសាធុការថា គួរអស្ចារ្យហ្ន៎ ស្ដេចបក្សីកុណាល ពោលដូចលីលារបស់ព្រះពុទ្ធ ។

ស្តេចត្មាតឈ្មោះអានន្ទ ព្រាហ្មណឥសីឈ្មោះនារទៈនិងស្តេចបក្សីបុណ្ណមុខ តាវេស ក៏នាំបរិវាររបស់ខ្លួនទៅកាន់លំនៅ ព្រះមហាសត្វក៏ត្រឡប់ទៅកាន់លំនៅរបស់ខ្លួនដូចគ្នា ចំណែកជនដែលពោលមកហើយ ក្រៅអំពីនេះ រមែងទៅមករកគ្នាជានិច្ច និងតាំងនៅក្នុងឱវាទរបស់ព្រះមហាសត្វ ក៏មានស្ថានសួគ៌ជាទីទៅខាងមុខ ។

ព្រះសាស្តាទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ កាលទ្រង់ប្រជុំជាតក ទើបត្រាស់អវសានគាថាថា

ក្នុងកាលណោះ កុណាលបក្សី បានមកជាតថាគត បុស្សកោកិលបក្សី បានមកជាឧទាយិភិក្ខុ ស្តេចត្មាត បានមកជាអានន្ទ នារទព្រាហ្មណ៍ បានមកជាសារីបុត្ត ពួកបរិស័ទបានមកជាពុទ្ធបរិស័ទ អ្នកទាំងឡាយចូរចាំទុកជាតកយ៉ាងនេះដូច្នេះ ។

ចំណែកភិក្ខុរាជកុមារទាំងឡាយ កាលទៅ ទៅដោយអានុភាពរបស់ព្រះសាស្តា តែកាលមក មកដោយអានុភាពរបស់ខ្លួន គឺព្រះសាស្តាទ្រង់សម្តែងកម្មដ្ឋានឲ្យភិក្ខុទាំងនោះ ក្នុងព្រៃមហាវ័ន ភិក្ខុទាំងនោះ បានសម្រេចអរហត្តក្នុងថ្ងៃនោះឯង និងមានទេវតាសមាគមធំ លំដាប់នោះ ព្រះមានព្រះភាគទ្រង់សម្តែងមហាសមយសូត្រ កាលចប់ ទេវតាទាំងឡាយបានសម្រេចមគ្គផលមានសោតាបន្នជាដើម ។

**អដ្ឋកថា កុណាលជាតក ចប់**

# មហាសុតសោម ជាតក

[ ៣១៥ ] ( សេនាបតីសួរថា ) ម្នាលសេកៈ ( នាយពិសេស ) ព្រោះហេតុអ្វី អ្នកធ្វើនូវអំពើដ៏លាមកក្រៃលែង ប្រាកដដូច្នេះ អ្នកជាបុគ្គលវង្វេង សម្លាប់ពួកស្រីនិងប្រុស ព្រោះហេតុសាច់ ឬព្រោះហេតុទ្រព្យ ។

[ ៣១៦ ] ( នាយពិសេសជម្រាបថា ) ខ្ញុំសម្លាប់ មិនមែនព្រោះហេតុខ្លួនឯង មិនមែនព្រោះហេតុទ្រព្យ មិនមែនព្រោះហេតុកូនប្រពន្ធ ឬសម្លាញ់និងញាតិទេ បពិត្រលោកដ៏ចម្រើន ព្រោះថា ព្រះភូមិបាលអ្នកមានបុណ្យជាម្ចាស់នៃខ្ញុំ ទ្រង់សោយនូវសាច់ប្រាកដ ដូច្នេះ ។

[ ៣១៧ ] ( សេនាបតី... ) បើអ្នកឯងខ្វល់ខ្វាយ ក្នុងកិច្ចរបស់ព្រះរាជាជាម្ចាស់ ហើយធ្វើនូវអំពើដ៏លាមកក្រៃលែង អ្នកឯងលុះព្រឹកឡើង ចូលទៅខាងក្នុងព្រះរាជវាំងហើយ គប្បីនិយាយនូវដំណើរនោះប្រាប់ខ្ញុំក្នុងទីចំពោះព្រះភក្ត្រនៃព្រះរាជា ។

[ ៣១៨ ] ( នាយពិសេស... ) បពិត្រសេនាបតីឈ្មោះ កាឡហត្ថីដ៏ចម្រើន លោកនិយាយយ៉ាងណា ខ្ញុំនឹងធ្វើយ៉ាងនោះ ព្រឹកឡើងខ្ញុំនឹងចូលទៅខាងក្នុងព្រះរាជវាំង ហើយថ្លែងសេចក្តីនោះ ជម្រាបលោកក្នុងទីចំពោះព្រះភក្ត្រនៃព្រះរាជា ។

[ ៣១៩ ] ( អភិសម្ពុទ្ធគាថា ) គ្រានោះ កាលដែលវេលារាត្រីភ្លឺច្បាស់ ព្រះអាទិត្យរះឡើងប្រាកដ សេនាបតីឈ្មោះកាឡហត្ថី បាននាំសេកៈចូលទៅគាល់ព្រះរាជា លុះចូលទៅដល់ហើយ ក៏ក្រាបទូលពាក្យនេះ ចំពោះព្រះរាជាថា បពិត្រមហារាជ បានឮថា ព្រះអង្គប្រើសេកៈឲ្យទៅសម្លាប់ស្រី

ប្រុស ព្រះអង្គទ្រង់សោយសាច់មែនឬ ។

[ ៣២០ ] ( ព្រះរាជា... ) ម្នាលកាឡហត្ថិ ខ្ញុំបានប្រើសេកៈដូច្នោះមែន ហេតុអ្វីអ្នកជេរប្រទេចសេកៈបុរស ដែលធ្វើប្រយោជន៍ឲ្យខ្ញុំនុ៎ះ ។

[ ៣២១ ] ( កាឡហត្ថិ... ) ត្រីឈ្មោះអានន្ទ ជាប់ចិត្តនឹងរស ស៊ីនូវពួកត្រីទាំងពួង កាលបើត្រីជាបរិវារអស់ហើយក៏ខាំស៊ីកន្ទុយខ្លួនឯងស្លាប់ទៅ ។ ព្រះអង្គជាអ្នកប្រមាទ ត្រេកអរក្នុងរសដែលគួរគោរព បើព្រះអង្គនៅជាបុគ្គលពាល មិនយល់ហេតុអ្វីតទៅយ៉ាងនេះទេ ព្រះអង្គនឹងឃ្លាត បោះបង់នូវបុត្តទាំងឡាយផង នូវពួកញាតិផង ដូចត្រីឈ្មោះអានន្ទត្រឡប់ស៊ីខ្លួនឯង ។ បពិត្រព្រះរាជា សូមសេចក្តីប្រាថ្នារបស់ព្រះអង្គប្រាសចេញទៅ ព្រោះបានទ្រង់ព្រះសណ្តាប់នូវពាក្យនេះ សូមព្រះអង្គកុំសោយសាច់មនុស្ស បពិត្រព្រះអង្គជាធំជាងសត្វជើងពីរ សូមព្រះអង្គកុំធ្វើដែននេះឲ្យសោះសូន្យ ដូចត្រីឈ្មោះអានន្ទ ធ្វើមហាសមុទ្ទទាំងមូលនេះឲ្យសូន្យ ( ចាកត្រី ) ។

[ ៣២២ ] ( ព្រះរាជា... ) កូនបង្កើតរបស់សុជាតកុដុម្ពិក៍នោះ ឈ្មោះសុជាតដោយឈ្មោះ មិនបានសាច់ព្រីងហើយស្លាប់ទៅ ព្រោះអស់សាច់ព្រីងនោះ ( យ៉ាងណា ) ម្នាលកាឡហត្ថិ ខ្ញុំបរិភោគនូវអាហារមានរសដ៏ឧត្តម បើមិនបានសាច់មនុស្សទេ ប្រហែលជានឹងលះបង់នូវជីវិត ក៏យ៉ាងនោះដែរ ។

[ ៣២៣ ] ( កាឡហត្ថិនាំរឿងព្រាហ្មណ៍ថា ) ម្នាលមាណពកូន អ្នកមានរូបស្រស់បស់ កើតក្នុងត្រកូលសោត្ថិយៈ ម្នាលកូន អ្នកមិនគួរស៊ីនូវអាហារដែលមិនគួរស៊ីទេ ។

[ ៣២៤ ] ( មាណព... ) បណ្តារសទាំងឡាយ ទឹកសុរានេះ រាប់ថាជាទឹកមានរសមួយដែរ ព្រោះហេតុអ្វី ទើបលោកឪពុកឃាត់ខ្ញុំ ខ្ញុំបាននូវទឹកសុរានេះក្នុងទីណា ខ្ញុំនឹងទៅក្នុងទីនោះ ។ បពិត្រព្រាហ្មណ៍ឪពុក បើលោកឪពុកមិនត្រេកអរនឹងការឃើញខ្ញុំណា ខ្ញុំនោះនឹងគេចចេញ ( អំពីស្រុក ) ខ្ញុំមិននៅក្នុងសំណាក់លោកឪពុកទេ ។

[ ៣២៥ ] ( ព្រាហ្មណ៍... ) នែមាណពកូន យើងនឹងបាននូវកូនទាំងឡាយឯទៀត ទទួលមត៌កដោយពិត នែកូនជួជាតិ ឯងចូរវិនាសចុះ លំនៅដែលកូនទៅដល់ក្នុងទីណា សូមកុំឲ្យអញឮនូវទីនោះ ។

[ ៣២៦ ] ( កាឡហត្ថី... ) បពិត្រព្រះមហាក្សត្រជាធំជាងសត្វជើងពីរ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ខ្ញុំ ពួកប្រជាជននឹងបណ្តេញព្រះអង្គ ចាកដែន ដូចមាណពអ្នកលេងស៊ីផឹកដូច្នោះ ។

[ ៣២៧ ] ( ព្រះរាជា... ) សាវ័ករបស់ពួកឥសីអ្នកមានខ្លួនអប់រំហើយ ជាសាវ័កឈ្មោះសុជាត ប្រាថ្នានូវស្រីអប្សរ ទើបសាវ័កនោះមិនស៊ី មិនផឹកទេ។

បុគ្គលយកទឹកដោយចុងស្មៅមកប្រៀបផ្ទឹមនឹងទឹកក្នុងសមុទ្រ យ៉ាងណា កាមទាំងឡាយជារបស់មនុស្ស ( ប្រៀបផ្ទឹម ) ក្នុងសំណាក់នៃកាមជាទិព្វ ក៏យ៉ាងនោះដែរ ។ ម្នាលកាឡហត្ថី ខ្ញុំបរិភោគនូវអាហារមានរសដ៏ឧត្តម បើមិនបានសាច់មនុស្សទេ ប្រហែលជាលះបង់ជីវិត យ៉ាងនោះឯង ។

[ ៣២៨ ] ( កាឡហត្ថី... ) ដូចយ៉ាងពួកបក្សីហង្ស ឈ្មោះធតរដ្ឋទាំងនោះ ជាសត្វហើរឰដ៏អាកាស ដល់នូវសេចក្តីវិនាសទាំងអស់គ្នា ព្រោះ

ស៊ីនូវចំណីមិនគួរ ។ បពិត្រព្រះរាជា ជាធំជាងសត្វជើងពីរ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ខ្ញុំ បពិត្រព្រះរាជា ព្រះអង្គកុំសោយអាហារ ដែលមិនគួរសោយ ក៏យ៉ាងនោះឯង ពួកប្រជាជននឹងបណ្តេញព្រះអង្គ ( ចាកដែន ) ក៏យ៉ាងនោះដែរ ។

[ ៣២៩ ] ( ព្រះរាជា... ) អ្នកកាលដែលខ្ញុំនិយាយថា អ្នកឈប់សិន ហើយចេះតែដើរទៅមុខ ម្នាលអ្នកជាព្រហ្មចារិនី អ្នកមិនឈប់តែនិយាយថា ខ្ញុំឈប់ហើយ ពាក្យនេះមិនគួរដល់អ្នកជាសមណៈទេ អ្នកសម្គាល់នូវដាវរបស់ខ្ញុំ គួរដល់សេចក្តីសង្ស័យដែរឬ ។

[ ៣៣០ ] ( ទេវតា... ) បពិត្រព្រះរាជា អាត្មាជាអ្នកឈប់ ក្នុងព្រះសទ្ធម្មទាំងឡាយ មិនត្រឡប់ប្រែនាមនិងគោត្តទេ អ្នកប្រាជ្ញទាំងឡាយតែងពោលនូវចោរថា មិនឈប់ក្នុងលោកដែលច្យុតអំពីលោកនេះទៅ ជាអ្នកទៅកាន់អបាយ កាន់នរក ។ បពិត្រព្រះរាជា បើព្រះអង្គជឿ ចូរព្រះអង្គចាប់សុតសោមៈជាក្សត្រមកបូជាយញ្ញ ព្រះអង្គនឹងទៅកាន់ឋានសួគ៌ដោយការបូជានោះ ។

[ ៣៣១ ] ( ព្រះរាជាសុតសោម... ) ជាតិភូមិរបស់អ្នក ក្នុងដែនណាមួយទៀត អ្នកមកដល់ក្នុងទីនេះដោយប្រយោជន៍ដូចម្តេច ម្នាលព្រាហ្មណ៍ អ្នកចូរប្រាប់សេចក្តីនុ៎ះដល់ខ្ញុំ អ្នកប្រាថ្នារបស់អ្វី ខ្ញុំនឹងឲ្យនូវរបស់នោះ តាមដែលអ្នកប្រាថ្នាក្នុងថ្ងៃនេះ ។

[ ៣៣២ ] ( នន្ទព្រាហ្មណ៍... ) បពិត្រព្រះអង្គជាមហិស្សរៈលើដែនដី

គាថាទាំងឡាយ ៤ បទ មានអត្ថដ៏ជ្រៅប្រសើរក្រៃលែង ប្រៀបដូចជាសាគរ ខ្ញុំមកក្នុងទីនេះ ដើម្បីប្រយោជន៍ដល់ព្រះអង្គតែម្យ៉ាង សូមព្រះអង្គទ្រង់ព្រះសណ្ដាប់នូវគាថា ដែលប្រកបដោយប្រយោជន៍ដ៏ប្រសើរ ។

[ ៣៣៣ ] ( ព្រះបាទបោរិសាទ... ) បណ្ឌិតទាំងឡាយណា ជាអ្នកមានយោបល់ ប្រកបដោយបញ្ញា ជាពហុស្សូត គិតនូវហេតុបានច្រើនយ៉ាង រមែងមិនយំទេ បណ្ឌិតទាំងឡាយនោះ ជាអ្នកបន្ទោបង់នូវសេចក្ដីសោកដោយហេតុណាពិត ហេតុនោះជាទីពឹងដ៏ក្រៃលែងរបស់ជនទាំងឡាយ ។ បពិត្រព្រះបាទសុតសោម ព្រះអង្គសោកស្ដាយចំពោះខ្លួន ញាតិ ឬកូនប្រពន្ធ ស្រូវ ទ្រព្យ ប្រាក់ មាស ឬអ្វី បពិត្រព្រះបាទកោរព្យៈដ៏ប្រសើរ យើងនឹងស្ដាប់ពាក្យរបស់លោក ។

[ ៣៣៤ ] ( ព្រះបាទសុតសោម... ) ខ្ញុំមិនសោកស្ដាយចំពោះខ្លួន មិនសោកស្ដាយចំពោះកូនប្រពន្ធ មិនសោកស្ដាយចំពោះទ្រព្យ មិនសោកស្ដាយចំពោះដែនទេ ( មាន ) បុរាណធម៌ ជាចរិតរបស់សប្បុរសទាំងឡាយ ខ្ញុំសោកស្ដាយនឹងការបេ្ដជ្ញានោះ ចំពោះព្រាហ្មណ៍ ។ ការបេ្ដជ្ញានឹងព្រាហ្មណ៍ ដែលខ្ញុំបិតនៅក្នុងឥស្សរភាពក្នុងដែនរបស់ខ្លួន បានធ្វើហើយ ខ្ញុំជាអ្នករក្សាខ្ជាប់នូវសច្ចៈ នឹងដោះនូវការបេ្ដជ្ញានោះរបស់ព្រាហ្មណ៍ ហើយនឹងត្រឡប់មកវិញ ។

[ ៣៣៥ ] ( ព្រះបាទបោរិសាទ... ) ខ្ញុំមិនជឿនូវពាក្យនុ៎ះថា ជនមានសេចក្ដីសុខ បានរួចអំពីមាត់នៃមច្ចុហើយ ត្រឡប់មករកដៃនៃសត្រូវវិញ

ដូច្នេះទេ បពិត្រព្រះបាទកោរព្យៈដ៏ប្រសើរ ទ្រង់នឹងមិនមករកខ្ញុំ ។ បពិត្រព្រះរាជា ទ្រង់បានរួចអំពីដៃនៃព្រះបាទបោរិសាទហើយ មានប្រាថ្នាទៅកាន់មន្ទីររបស់ខ្លួនហើយបាននូវជីវិត ជាទីស្រឡាញ់ពេញចិត្តកាលណា ទ្រង់នឹងមកកាន់សំណាក់របស់ខ្ញុំវិញ ។

[ ៣៣៦ ] ( ព្រះបាទសុតសោម... ) បុគ្គលអ្នកមានសីលបរិសុទ្ធរមែងប្រាថ្នានូវសេចក្ដីស្លាប់ ឯបុគ្គលអ្នកមានធម៌ដ៏លាមក ដែលគួរអ្នកផងតិះដៀល មិនគួរបង់រស់ឡើយ បុគ្គលទ្រុស្តសីល ពោលនូវពាក្យមិនពិតព្រោះហេតុខ្លួនណា ខ្លួននោះ រមែងមិនរក្សានូវជននោះចាកទុគ្គតិបានឡើយ ។ បើទុកជាខ្យល់បក់កើចភ្នំបានក្ដី ព្រះចន្ទ និងព្រះអាទិត្យធ្លាក់មកលើផែនដីក្ដី ទឹកស្ទឹងទាំងអស់ ហូរច្រាសខ្សែទឹកក្ដី បពិត្រព្រះរាជា ខ្ញុំក៏មិនពោលពាក្យកុហកទេ ។

[ ៣៣៧ ] មេឃបែកធ្លាយ ទឹកសមុទ្ររីងស្ងួត ឬផែនដីជាទីទ្រទ្រង់នូវសត្វប្រែត្រឡប់ ឬក៏ភ្នំឈ្មោះមេរុរលើងទាំងឫស ខ្ញុំក៏មិនពោលពាក្យកុហកទេ ។

[ ៣៣៨ ] ខ្ញុំចាប់ដាវនិងលំពែង បពិត្រទ្រង់ជាសម្លាញ់ ខ្ញុំនឹងធ្វើនូវសម្បថចំពោះទ្រង់ ខ្ញុំរួចចេញអំពីទ្រង់ ជាអ្នកមិនមានបំណុលរក្សានូវសច្ចៈនឹងត្រឡប់មកវិញ ។

[ ៣៣៩ ] ( ព្រះបាទបោរិសាទ... ) ការបេ្តជ្ញាណា ជាមួយនឹងព្រាហ្មណ៍ដែលព្រះអង្គឋិតនៅក្នុងឥស្សរភាព ក្នុងដែនរបស់ខ្លួនបានធ្វើហើយ សូមព្រះអង្គជាអ្នករក្សានូវសច្ចៈ ដោះនូវការបេ្តជ្ញានោះនឹងព្រាហ្មណ៍ ហើយ

ចូរត្រឡប់មកវិញ ។

[ ៣៤០ ] ( ព្រះបាទសុតសោមៈ... ) ការបេ្តជ្ញាណា ជាមួយនឹងព្រាហ្មណ៍ ដែលខ្ញុំឋិតនៅក្នុងឥស្សរភាព ក្នុងដែនរបស់ខ្លួនបានធ្វើហើយ ខ្ញុំជាអ្នករក្សានូវសច្ចៈ នឹងដោះនូវការបេ្តជ្ញានោះនឹងព្រាហ្មណ៍ហើយ នឹងត្រឡប់មកវិញ ។

[ ៣៤១ ] ( អភិសម្ពុទ្ធគាថា ) ព្រះបាទសុតសោមនោះ រួចពីព្រះហស្តនៃព្រះបាទបោរិសាទ ហើយទៅបានពោលពាក្យនេះនឹងព្រាហ្មណ៍នោះថាម្នាលព្រាហ្ម ខ្ញុំសូមស្តាប់នូវគាថាទាំងឡាយ ដែលគួរដល់ថ្លៃ ១០០ កហាបណៈជាគាថាដែលខ្ញុំស្តាប់ហើយមានប្រយោជន៍ ។

[ ៣៤២ ] ( ព្រាហ្មណ៍... ) បពិត្រព្រះបាទសុតសោម ការជួបប្រទះដោយសប្បុរសទាំងឡាយអស់វារៈតែម្តង ការជួបប្រទះនោះ រមែងរក្សានូវបុគ្គលនោះបាន ឯការជួបជុំដោយពួកអសប្បុរសជាច្រើនដង រមែងមិនរក្សានូវបុគ្គលនោះបានទេ ។ បុគ្គលគប្បីគប់រកនឹងពួកសប្បុរស គប្បីធ្វើនូវការស្និទ្ធស្នាលនឹងពួកសប្បុរស គុណធម៌ដ៏ប្រសើររមែងកើតមាន ព្រោះដឹងនូវព្រះសទ្ធម្មរបស់ពួកសប្បុរស មិនមែនជាទោសដ៏លាមកឡើយ ។ រាជរថទាំងឡាយ ដែលគេរចនាល្អហើយ រមែងគ្រាំគ្រាទៅវិញ សូម្បីសរីរៈ ( នៃពួកសត្វ ) ក៏រមែងដល់នូវសេចក្តីគ្រាំគ្រាដោយពិត ឯធម៌របស់សប្បុរសទាំងឡាយ រមែងមិនដល់នូវសេចក្តីគ្រាំគ្រាទេ ពួកសប្បុរស រមែងចរចាដោយពួកសប្បុរស ។ អាកាសនិងដីឋិតនៅក្នុងទីឆ្ងាយពីគ្នា អ្នកប្រាជ្ញទាំង

ឡាយ បានពោលនូវប្រាំងសមុទ្ទថាឆ្ងាយ បពិត្រព្រះរាជា អ្នកប្រាជ្ញទាំងឡាយបានពោលនូវធម៌របស់ពួកសប្បុរស និងពួកអសប្បុរសថា ឆ្ងាយជាងនោះទៅទៀត ។

[ ៣៨៣ ] ( ព្រះបាទសុតសោម... ) គាថាទាំងនេះ គួរដល់ថ្លៃ ១ ពាន់កហាបណៈ គាថាទាំងនេះ មិនគួរដល់ថ្លៃត្រឹម ១០០ កហាបណៈទេ ម្នាលព្រាហ្មណ៍ លោកចូរទទួលយកកហាបណៈ ៤ ពាន់ ជាប្រញាប់ចុះ ។

[ ៣៨៤ ] ( ព្រះវរបិតា... ) គាថាមានថ្លៃ ៨០ កហាបណៈ ៩០ កហាបណៈ និងគាថាគួរដល់ថ្លៃ ១០០ កហាបណៈ ម្នាលសុតសោម អ្នកចូរដឹងដោយខ្លួនឯងចុះ គាថាដូចម្តេច ដែលឈ្មោះថា គួរដល់ថ្លៃ ១ ពាន់កហាបណៈ ។

[ ៣៨៥ ] ( ព្រះបាទសុតសោម... ) ខ្ញុំព្រះអង្គប្រាថ្នានូវសេចក្តីចម្រើនដោយសុតៈ គឺការចេះដឹងដើម្បីខ្លួន សប្បុរសទាំងឡាយអ្នកមានចិត្តស្ងប់គប្បីគប់រកនូវខ្ញុំព្រះអង្គ បពិត្រព្រះបិតា ខ្ញុំព្រះអង្គមិនឆ្អែតដោយសុភាសិតដូចជាមហាសមុទ្ទ មិនឆ្អែតដោយទឹកស្ទឹងដែលហូរចូលទៅ ។ ភ្លើងកាលឆេះស្មៅនិងឈើ រមែងមិនឆ្អែត សាគររមែងមិនឆ្អែតដោយទឹកស្ទឹងយ៉ាងណា បពិត្រព្រះរាជាដ៏ប្រសើរ បណ្ឌិតទាំងឡាយនោះ បានស្តាប់ហើយ ក៏មិនឆ្អែតដោយសុភាសិតក៏យ៉ាងនោះដែរ ។

បពិត្រព្រះអង្គជាធំជាងជន ខ្ញុំព្រះអង្គស្តាប់នូវគាថាដែលមានប្រយោជន៍របស់ទាសៈនៃខ្លួន ក្នុងកាលណា ក្នុងកាលណោះ ខ្ញុំព្រះអង្គតែងផ្ទៀងស្តាប់

នូវគាថានោះឯងដោយគោរព បពិត្រព្រះបិតា ខ្ញុំព្រះអង្គមិនមានសេចក្ដីឆ្អែតក្នុងធម៌ទាំងឡាយទេ ។

[ ៣៨៦ ] ដែនរបស់ព្រះអង្គនេះ ព្រមទាំងទ្រព្យ ព្រមទាំងយាន ព្រមទាំងគ្រឿងប្រដាប់កាយ បរិបូណ៌ដោយវត្ថុគួរប្រាថ្នាគ្រប់យ៉ាង ព្រះអង្គជេរប្រទេចខ្ញុំព្រះអង្គ ព្រោះហេតុនៃសេចក្ដីប្រាថ្នាដូចម្ដេច ខ្ញុំព្រះអង្គនឹងទៅកាន់សំណាក់នៃព្រះបាទបោរិសាទ ។

[ ៣៨៧ ] ( ព្រះបិតា... ) ដ្បិតពួកពលទាំងនុ៎ះ គឺពលដំរី ពលរថពលថ្មើរជើង ពលសេះ និងខ្មាន់ធ្នូ ក៏មានសម្រាប់រក្សាខ្លួន យើងនឹងលើកពលសេនាទៅសម្លាប់សត្រូវ ។

[៣៨៨] ( ព្រះបាទសុតសោម... ) ព្រះបាទបោរិសាទ បានធ្វើនូវអំពើដ៏កម្រក្រៃលែង ចាប់ខ្ញុំព្រះអង្គទាំងរស់ ហើយលែងវិញ បពិត្រព្រះអង្គជាធំជាងជន ខ្ញុំព្រះអង្គរឭកឃើញនូវឧបការគុណក្នុងកាលមុន ប្រាកដដូច្នោះខ្ញុំនឹងប្រទូស្ដចំពោះស្ដេចបោរិសាទនោះដូចម្ដេចកើត ។

[ ៣៨៩ ] ( អភិសម្ពុទ្ធគាថា ) ព្រះបាទសុតសោម ក្រាបថ្វាយបង្គំលាព្រះបិតាមាតា ប្រៀនប្រដៅអ្នកនិគមនិងពលសេនា ព្រះអង្គពោលនូវពាក្យសច្ចៈ រក្សានូវពាក្យសច្ចៈ ហើយក៏ទៅកាន់សំណាក់នៃព្រះបាទបោរិសាទ ។

[ ៣៥០ ] ( ព្រះបាទសុតសោម... ) ការបេ្ដជ្ញានឹងព្រាហ្មណ៍ ដែលខ្ញុំឋិតនៅក្នុងឥស្សរភាពក្នុងដែនរបស់ខ្លួនបានធ្វើហើយ ខ្ញុំជាអ្នករក្សានូវសច្ចៈដោះបេ្ដជ្ញានឹងព្រាហ្មណ៍ហើយត្រឡប់មកវិញ បពិត្រព្រះបាទបោរិសាទ ចូរ

ព្រះអង្គបូជាយញ្ញ សូមព្រះអង្គសោយនូវខ្ញុំចុះ ។

[ ៣៥១ ] ( ព្រះបាទបោរិសាទ... ) ទ្រង់មិនបាត់ទេ ចាំខ្ញុំស៊ីជាខាងក្រោយចុះ ព្រោះជើងថ្ករនេះ ប្រកបដោយផ្សែងនៅឡើយ សាច់ដែលចម្អិនលើភ្លើងឥតផ្សែងជាសាច់ឆ្អិនល្អ យើងនឹងស្តាប់នូវគាថារបស់ទ្រង់ ដែលគួរដល់ថ្លៃ ១០០ កហាបណសិន ។

[ ៣៥២ ] ( ព្រះបាទសុតសោម... ) ព្រះអង្គជាអធម្មិករាជ ជាអ្នកស៊ីនូវបុរស ខ្ចាត់ខ្ចាត់អំពីដែន ព្រោះហេតុតែពោះ គាថាទាំងឡាយនេះ រមែងប្រកាសសុចរិតធម៌ ចំណែកធម៌នឹងអធម៌ស្របគ្នាក្នុងទីណាកើត ។

ព្រះអង្គជាអធម្មិករាជ ព្រះហស្តប្រឡាក់ឈាមជានិច្ច មិនមានសច្ចៈធម៌នឹងមានមកអំពីណា ព្រះអង្គនឹងធ្វើអ្វីដោយការស្តាប់ ។

[ ៣៥៣ ] ( ព្រះបាទបោរិសាទ... ) បុគ្គលណា ត្រាច់ទៅកាន់ទីសម្លាប់ម្រឹគ ព្រោះហេតុតែសាច់ ឬសម្លាប់បុរស ព្រោះហេតុតែខ្លួន បុគ្គលទាំងពីរនោះ ស្មើគ្នាក្នុងលោកខាងមុខ ហេតុអ្វីព្រះអង្គហៅខ្ញុំថាជាអធម្មិករាជ ។

[ ៣៥៤ ] ( ព្រះបាទសុតសោម... ) ក្សត្រិយ៍ជាអ្នកចេះដឹង មិនគួរសោយនូវពួកសត្វ ៥ និង ៥[1]ទេ បពិត្រព្រះរាជា ព្រះអង្គសោយនូវសាច់ ដែលមិនគួរសោយ ព្រោះហេតុនោះ ទើបព្រះអង្គឈ្មោះថា ជាអធម្មិករាជ ។

[៣៥៥] ( ព្រះបាទបោរិសាទ... ) លោកបានរួចអំពីដៃបោរិសាទ

---

១-សាច់ ១០ យ៉ាងដែលសមណមិនគួរបរិភោគ ។

ហើយទៅកាន់មន្ទីររបស់ខ្លួនតាមសេចក្ដីប្រាថ្នា ហើយត្រឡប់មករកដៃរបស់សត្រូវវិញ បពិត្រព្រះរាជា ព្រះអង្គជាបុគ្គលមិនឈ្លាសក្នុងខត្តិយធម៌ទេ ។

[ ៣៥៦ ] ( ព្រះបាទសុតសោម... ) ពួកបុគ្គលណា ជាអ្នកឈ្លាសក្នុងខត្តិយធម៌ ពួកបុគ្គលនោះ ច្រើនតែធ្លាក់ទៅក្នុងនរក ព្រោះហេតុនោះ បានជាខ្ញុំលះបង់នូវខត្តិយធម៌ ជាអ្នករក្សានូវសច្ចៈ ត្រឡប់មកវិញ បពិត្រព្រះបាទបោរិសាទ សូមព្រះអង្គបូជាយញ្ញ សូមព្រះអង្គសោយនូវខ្ញុំចុះ ។

[ ៣៥៧ ] ( ព្រះបាទបោរិសាទ... ) ប្រាសាទជាទីនៅលើផែនដី គោនិងសេះ ពួកស្រីដែលគួរប្រាថ្នា និងខ្លឹមចន្ទន៍ក្នុងដែនកាសី ទ្រង់បាននូវវត្ថុទាំងអស់ ក្នុងទីនោះ ដោយភាពជាម្ចាស់ ចុះទ្រង់ឃើញនូវអានិសង្សនៃពាក្យសច្ចៈ ដូចម្ដេច ។

[ ៣៥៨ ] ( ព្រះបាទសុតសោម... ) រសឯណាទីមួយ មាននៅលើផែនដី សច្ចៈជារសល្អក្រៃលែងជាងរសទាំងឡាយនោះ ពួកសមណៈនិងព្រាហ្មណ៍ដែលតាំងនៅក្នុងសច្ចៈ រមែងឆ្លងទៅកាន់ត្រើយនៃជាតិនិងមរណៈបាន ។

[ ៣៥៩ ] ( ព្រះបាទបោរិសាទ... ) ទ្រង់បានរួចអំពីដៃបោរិសាទហើយ បានទៅកាន់មន្ទីររបស់ខ្លួនវិញ តាមសេចក្ដីប្រាថ្នា ត្រឡប់មករកដៃសត្រូវវិញ បពិត្រទ្រង់ជាធំជាងជន ភ័យអំពីសេចក្ដីស្លាប់ មិនមានដល់ទ្រង់ដោយពិត ទ្រង់ជាអ្នកពោលនូវពាក្យសច្ចៈ ទាំងមានចិត្តក៏មិនរួញរា ។

[ ៣៦០ ] ( ព្រះបាទសុតសោម... ) យញ្ញ ( ការបូជា ) មានច្រើន

ប្រការ ជាកល្យាណធម៌ ដែលខ្ញុំបានធ្វើហើយ បូជាហើយ ជាបូជាដ៏ធំទូលាយ ដែលអ្នកប្រាជ្ញតែងសរសើរ ផ្លូវសម្រាប់បរលោកខ្ញុំក៏បានជម្រះហើយ អ្នកណាឋិតនៅក្នុងធម៌ហើយនឹងខ្លាចសេចក្តីស្លាប់ ។ យញ្ញមានច្រើនប្រការ ជាកល្យាណធម៌ ដែលខ្ញុំបានធ្វើហើយ បូជាហើយ ជាបូជាដ៏ធំទូលាយដែលអ្នកប្រាជ្ញតែងសរសើរ ខ្ញុំមិនក្តៅក្រហាយនឹងទៅកាន់បរលោកទេ បពិត្រព្រះបាទបោរិសាទ សូមព្រះអង្គបូជាយញ្ញ សូមព្រះអង្គសោយខ្ញុំចុះ ។ មាតានិងបិតា ខ្ញុំបានបម្រើហើយ ឥស្សរភាព ខ្ញុំគ្រប់គ្រងហើយតាមធម៌ ផ្លូវសម្រាប់បរលោក ខ្ញុំក៏បានជម្រះហើយ អ្នកណាឋិតនៅក្នុងធម៌ហើយនឹងខ្លាចសេចក្តីស្លាប់ ។ បិតានិងមាតា ខ្ញុំក៏បានបម្រើហើយ ឥស្សរភាពខ្ញុំគ្រប់គ្រងហើយតាមធម៌ ខ្ញុំមិនក្តៅក្រហាយនឹងទៅបរលោកទេ បពិត្រព្រះបាទបោរិ-សាទ សូមព្រះអង្គបូជាយញ្ញ សូមព្រះអង្គសោយខ្ញុំចុះ ។ ខ្ញុំបានធ្វើឧបការ-កិច្ចចំពោះពួកញាតិនិងមិត្តហើយ ឥស្សរភាព ខ្ញុំគ្រប់គ្រងហើយតាមធម៌ ផ្លូវសម្រាប់បរលោកខ្ញុំក៏បានជម្រះហើយ អ្នកណាឋិតនៅក្នុងធម៌ហើយនឹងខ្លាចសេចក្តីស្លាប់ ។ ខ្ញុំបានធ្វើឧបការកិច្ចចំពោះពួកញាតិនិងមិត្តហើយ ឥស្សរ-ភាពខ្ញុំគ្រប់គ្រងហើយតាមធម៌ ខ្ញុំមិនក្តៅក្រហាយ នឹងទៅកាន់បរលោកទេ បពិត្រព្រះបាទបោរិសាទ សូមព្រះអង្គបូជាយញ្ញ សូមព្រះអង្គសោយខ្ញុំចុះ ។ ការឲ្យទានដល់ពួកជនជាច្រើន ដោយអាការច្រើនយ៉ាង ខ្ញុំក៏បានឲ្យហើយ ទាំងពួកសមណព្រាហ្មណ៍ ខ្ញុំក៏បានផ្គត់ផ្គង់ហើយ ផ្លូវសម្រាប់បរលោកខ្ញុំក៏បានជម្រះហើយ អ្នកណាឋិតនៅក្នុងធម៌ហើយ នឹងខ្លាចសេចក្តីស្លាប់ ។ ការ

ឲ្យទានដល់ពួកជនជាច្រើន ដោយអាការច្រើនយ៉ាង ខ្ញុំក៏បានឲ្យហើយ ទាំងសមណព្រាហ្មណ៍ខ្ញុំក៏បានផ្គត់ផ្គង់ហើយខ្ញុំមិនក្តៅក្រហាយនឹងទៅកាន់បរលោកទេ បពិត្រព្រះបាទបោរិសាទ សូមទ្រង់បូជាយញ្ញ សូមទ្រង់សោយខ្ញុំចុះ ។

[ ៣៦១ ] ( ព្រះបាទបោរិសាទ... ) បុគ្គលណា ស៊ីនូវជនអ្នកពោលពាក្យសច្ចៈប្រាកដដូច្នោះ ក្បាលរបស់បុគ្គលនោះនឹងបែកជា ៧ ភាគ ដូចបុរសស្គាល់នូវថ្នាំពិសហើយ ស៊ីនូវថ្នាំពិស ( ឬដូចគេចាប់ ) ពស់អាសិរពិសដែលមានពិសកាច មានតេជៈខ្លាំង ។

[៣៦២] ជនទាំងឡាយ បានស្តាប់ធម៌ហើយ រមែងដឹងច្បាស់នូវបុណ្យនិងបាប ប៉ុនអម្បាលចិត្តរបស់ខ្ញុំ គង់ត្រេកអរក្នុងធម៌ ព្រោះបានស្តាប់នូវគាថាទាំងឡាយ ។

[ ៣៦៣ ] ( ព្រះបាទសុតសោម... ) បពិត្រមហារាជ ការជួបប្រទះដោយសប្បុរសទាំងឡាយអស់វារៈតែម្តង ការជួបប្រទះនោះ រមែងរក្សានូវបុគ្គលនោះបាន ការជួបជុំដោយពួកអសប្បុរសច្រើនដង រមែងមិនរក្សាបុគ្គលបានទេ ។ បុគ្គលគប្បីគប់រកនឹងពួកសប្បុរស គប្បីធ្វើនូវការស្និទ្ធស្នាលនឹងពួកសប្បុរស គុណធម៌ដ៏ប្រសើររមែងកើតមាន ព្រោះដឹងនូវព្រះសទ្ធម្មរបស់ពួកសប្បុរស មិនមែនជាទោសដ៏លាមកទេ ។ រាជរថទាំងឡាយដែលគេរចនាល្អហើយ រមែងគ្រាំគ្រា សូម្បីសរីរៈ ( របស់ពួកសត្វ ) ក៏រមែងដល់នូវសេចក្តីគ្រាំគ្រា ដោយពិត ឯធម៌របស់សប្បុរស មិនដល់នូវសេចក្តីគ្រាំគ្រាទេ សប្បុរសទាំងឡាយ រមែងចរចានូវពួកសប្បុរសបាន ។ អាកាសនិងដី

*ឋិតនៅក្នុងទីឆ្ងាយពីគ្នា អ្នកប្រាជ្ញទាំងឡាយ បានពោលនូវប្រាំងសមុទ្រនោះថាឆ្ងាយ បពិត្រព្រះរាជា បណ្ឌិតទាំងឡាយរមែងពោលថា ធម៌របស់ពួកសប្បុរសនិងពួកអសប្បុរស ឆ្ងាយជាងនេះទៅទៀត ។*

*[ ៣៦៤ ] ( ព្រះបាទបោរិសាទ... ) បពិត្រទ្រង់ជាធំជាងជន គាថាទាំងឡាយនេះ មានអត្ថមានព្យញ្ជនៈដ៏ល្អ ទ្រង់សម្តែងពីរោះណាស់ ខ្ញុំបានស្តាប់ហើយ ក៏ត្រេកអររីករាយ មានចិត្តល្អជ្រះថ្លា បពិត្រទ្រង់ជាសម្លាញ់ ខ្ញុំសូមថ្វាយពរ ៤ ប្រការដល់ទ្រង់ ។*

*[ ៣៦៥ ] ( ព្រះបាទសុតសោម... ) ទ្រង់មិនដឹងនូវសេចក្តីស្លាប់របស់ខ្លួនទាំងអំពើមានប្រយោជន៍និងឥតប្រយោជន៍ ទាំងនរកនិងឋានសួគ៌ទេ បពិត្រព្រះអង្គមានធម៌ដ៏លាមក ព្រះអង្គជាប់ជំពាក់ក្នុងរស ( នៃសាច់មនុស្ស ) តាំងនៅស៊ប់ក្នុងទុច្ចរិតធម៌ ធ្វើម្តេចនឹងឲ្យពរកើត ។ បើខ្ញុំពោលថា សូមព្រះអង្គប្រទានពរនោះ ព្រះអង្គប្រទានហើយ ត្រឡប់ជាមិនប្រទានវិញ តើបណ្ឌិតណាកាលដឹងនឹងហ៊ានចូលទៅរកជម្លោះនិងវិវាទដ៏ជាក់ស្តែងនេះ ។*

*[ ៣៦៦ ] ( ព្រះបាទបោរិសាទ... ) ជនឲ្យនូវពរណា ហើយត្រឡប់ជាមិនឲ្យវិញ មិនគួរឲ្យពរនោះទេ បពិត្រទ្រង់ជាសម្លាញ់ សូមទ្រង់កុំញាប់ញ័រ សូមទទួល ( ពរ ) ចុះ ខ្ញុំសូម្បីលះបង់ជីវិតក៏នៅតែថ្វាយទ្រង់ ។*

*[ ៣៦៧ ] ( ព្រះបាទសុតសោម... ) ធម៌ជាបន្ទាល់សាក្សីរបស់អរិយៈ រមែងស្របគ្នានឹងអរិយៈ របស់បុគ្គលមានប្រាជ្ញា រមែងស្របគ្នានឹងបុគ្គលមានប្រាជ្ញា ខ្ញុំសូមឃើញព្រះអង្គមានជន្មាយុ ១០០ ឆ្នាំ ឥតមានរោគ បណ្តា*

ពរទាំងឡាយ ខ្ញុំប្រាថ្នានូវពរទី ១ នុ៎ះ ។

[ ៣៦៨ ] ( ព្រះបាទបោរិសាទ... ) ធម៌ជាបន្ទាល់សាក្សីរបស់អរិយៈ រមែងស្របគ្នានឹងអរិយៈ របស់បុគ្គលមានប្រាជ្ញា រមែងស្របគ្នានឹងបុគ្គលមានប្រាជ្ញា ទ្រង់សូមឃើញនូវខ្ញុំមានអាយុ ១០០ ឆ្នាំ ឥតមានរោគ បណ្ដាពរទាំងឡាយ ខ្ញុំនឹងថ្វាយពរទី ១ នេះ ។

[ ៣៦៩ ] ( ព្រះបាទសុតសោម... ) ពួកក្សត្រណា រក្សាផែនដីក្នុងទ្វីបនេះ បានមុទ្ធាភិសេកហើយ មានព្រះនាមសម្រេចហើយ ព្រះអង្គជាម្ចាស់ផែនដី កុំសោយនូវពួកក្សត្រទាំងនោះឡើយ បណ្ដាពរទាំងឡាយ ខ្ញុំប្រាថ្នានូវពរទី ២ នេះ ។

[ ៣៧០ ] ( ព្រះបាទបោរិសាទ... ) ពួកក្សត្រណា រក្សាផែនដីក្នុងទ្វីបនេះ បានមុទ្ធាភិសេកហើយ មានព្រះនាមសម្រេចហើយ ខ្ញុំជាម្ចាស់ផែនដីក៏លែងស៊ីនូវពួកក្សត្រទាំងនោះដែរ បណ្ដាពរទាំងឡាយ ខ្ញុំនឹងថ្វាយនូវពរទី ២ នេះ ។

[ ៣៧១ ] ( ព្រះបាទសុតសោម... ) ពួកក្សត្រជាង ១០០ នាក់ ដែលព្រះអង្គចាប់ដោតបាតដៃ មានមុខជោកដោយទឹកភ្នែក កំពុងទួញយំ សូមព្រះអង្គឲ្យក្សត្រទាំងនោះត្រឡប់ទៅ ក្នុងដែនរបស់ខ្លួនវិញ បណ្ដាពរទាំងឡាយ ខ្ញុំប្រាថ្នាពរទី ៣ នេះ ។

[ ៣៧២ ] ( ព្រះបាទបោរិសាទ... ) ពួកក្សត្រជាងរយនាក់ ដែលខ្ញុំចាប់ដោតបាតដៃ មានមុខជោកដោយទឹកភ្នែក កំពុងទួញយំ ខ្ញុំនឹងឲ្យពួក

ក្សត្រទាំងនោះ ត្រឡប់ទៅក្នុងដែនរបស់ខ្លួនវិញ បណ្ដាពរទាំងឡាយ ខ្ញុំនឹងថ្វាយពរទី ៣ នេះ ។

[ ៣៧៣ ] ( ព្រះបាទសុតសោម... ) ដែនរបស់ព្រះអង្គ ជាដែនប្រហោង ( មិនសូវមានប្រជាជន ) ព្រោះពួកប្រជាជនជាច្រើនញាប់ញ័រហើយ ព្រោះភ័យគ្របសង្កត់ ហើយរត់ចូលទៅកាន់ទីពឹងពួន បពិត្រព្រះរាជាសូមព្រះអង្គវៀរសាច់មនុស្សទៅ បណ្ដាពរទាំងឡាយ ខ្ញុំប្រាថ្នាពរទី ៤ នេះ ។

[ ៣៧៤ ] ( ព្រះបាទបោរិសាទ... ) អាហារនោះ ជាទីពេញចិត្តរបស់ខ្ញុំដោយពិត ខ្ញុំចូលព្រៃព្រោះហេតុតែសាច់មនុស្សនោះឯង នឹងវៀរចាកសាច់មនុស្សនោះដូចម្ដេចបាន បណ្ដាពរទាំងឡាយ សូមទ្រង់ប្រាថ្នានូវពរទី ៤ ដទៃវិញ ។

[ ៣៧៥ ] ( ព្រះបាទសុតសោម... ) បពិត្រព្រះអង្គ ជាធំជាងជនបុគ្គលប្រហែលដូចព្រះអង្គ លះបង់នូវខ្លួនចោល ដោយគិតថា នេះជាទីស្រឡាញ់របស់អញដូច្នេះ រមែងមិនបានគប់រកនូវវត្ថុជាទីស្រឡាញ់ទេ ខ្លួនហ្នឹងហើយជាសភាវៈប្រសើរ ឈ្មោះថា ប្រសើរក្រៃលែង បុគ្គលអ្នកមានចិត្តសន្សំហើយ គប្បីបាននូវគុណជាទីស្រឡាញ់ ក្នុងកាលជាខាងក្រោយ ។

[ ៣៧៦ ] ( ព្រះបាទបោរិសាទ... ) បពិត្រព្រះបាទសុតសោម សូមទ្រង់ជ្រាបនូវសាច់មនុស្សថា ជាទីស្រឡាញ់របស់ខ្ញុំ ទ្រង់មិនអាចឃាត់ខ្ញុំបានទេ បពិត្រទ្រង់ជាសម្លាញ់ សូមទ្រង់ប្រាថ្នាពរឯទៀតវិញ ។

[ ៣៧៧ ] ( ព្រះបាទសុតសោម... ) បុគ្គលណា ជាអ្នករក្សានូវវត្ថុជា

ទីស្រឡាញ់ ដោយគិតថា វត្ថុនេះជាទីស្រឡាញ់របស់អញដូច្នេះ លះបង់ខ្លួន ហើយនៅសេពគប់វត្ថុជាទីស្រឡាញ់ បុគ្គលនោះ រមែងជាទុក្ខក្នុងកាលខាងមុខ ព្រោះអំពើនោះឯង ដូចជាអ្នកលេងសុរា ផឹកទឹកសុរាដែលលាយដោយថ្នាំពិស ។ ចំណែកខាងបុគ្គលណាក្នុងលោកនេះ បានពិចារណា លះបង់នូវវត្ថុជាទីស្រឡាញ់ ហើយបែរមកគប់រកនូវអរិយធម៌ សូម្បីដោយលំបាក បុគ្គលនោះ រមែងបានសុខក្នុងកាលខាងមុខ ព្រោះអំពើនោះឯង ដូចបុគ្គលដល់នូវសេចក្តីទុក្ខ ព្រោះផឹកនូវឱសថ ។

[ ៣៧៨ ] ( ព្រះបាទបោរិសាទ... ) ខ្ញុំលះបង់បិតាមាតានិងបញ្ចកាមគុណជាទីពេញចិត្ត ហើយចូលព្រៃ ព្រោះហេតុតែសាច់មនុស្សនោះ ខ្ញុំនឹងថ្វាយនូវពរនោះដល់ទ្រង់ដូចម្តេចបាន ។

[ ៣៧៩ ] ( ព្រះបាទសុតសោម... ) បណ្ឌិតទាំងឡាយ ជាសប្បុរសជាអ្នកប្តេជ្ញាដោយពាក្យសច្ចៈ មិនពោលនូវពាក្យពីរជាន់ទេ ព្រះអង្គបានពោលនឹងខ្ញុំថា បពិត្រទ្រង់ជាសម្លាញ់ សូមទ្រង់ទទួលពរចុះ ព្រះអង្គបានពោលដូច្នេះហើយ ( តែពាក្យនោះ ) របស់ព្រះអង្គមិនស្របគ្នាទេ ។

[ ៣៨០ ] ( ព្រះបាទបោរិសាទ... ) ខ្ញុំដល់នូវភាពជាអ្នកមិនមានបុណ្យ មិនមានយស មិនមានកេរ្តិ៍ឈ្មោះ មានបាប មានទុច្ចរិតស្មោកគ្រោកជាច្រើន ក៏ព្រោះហេតុតែសាច់មនុស្ស ខ្ញុំនឹងថ្វាយនូវពរនោះដល់ទ្រង់ ដូចម្តេចកើត ។

[ ៣៨១ ] ( ព្រះបាទសុតសោម... ) ( ទ្រង់មានបន្ទូលហើយថា ) ជនឲ្យនូវពរណា ហើយត្រឡប់ជាមិនឲ្យវិញ មិនគួរឲ្យពរនោះទេ បពិត្រ

ទ្រង់ជាសម្លាញ់ សូមទ្រង់កុំញាប់ញ័រ សូមទទួលយក ( ពរ ) ចុះ ខ្ញុំសូម្បី លះបង់ជីវិត ក៏នៅតែថ្វាយទ្រង់ដែរ ។

[ ៣៨២ ] នុ៎ះជាធម៌របស់ពួកសប្បុរស ធម្មតាពួកសប្បុរស ជាអ្នកប្តេជ្ញាដោយពាក្យសច្ចៈ តែងលះបង់នូវជីវិត ព្រះអង្គឲ្យពរហើយ ចូរឲ្យរហ័ស បពិត្រព្រះរាជាដ៏ប្រសើរ សូមព្រះអង្គសម្រេចដោយធម៌ និងពាក្យសច្ចៈនុ៎ះចុះ ។ ជនគប្បីលះបង់នូវទ្រព្យព្រោះហេតុនៃអវយវៈដ៏ប្រសើរ កាលបើរក្សានូវជីវិត ក៏គប្បីលះបង់នូវអវយវៈ កាលបើរឭកឃើញនូវធម៌ គប្បីលះបង់ទាំងអវយវៈ ទ្រព្យនិងជីវិតទាំងអស់ ។

[៣៨៣] បុរសចេះដឹងនូវធម៌អំពីបុគ្គលណា ឬក៏ពួកសប្បុរសណា បន្ទោបង់នូវសេចក្តីសង្ស័យរបស់បុគ្គលនោះបាន ដំណើរនោះ ឈ្មោះថា ជាទីពឹងជាទីពំនាក់របស់បុគ្គលនោះ បុគ្គលអ្នកមានប្រាជ្ញា មិនត្រូវបំបាត់មេត្រីចិត្តអំពីបុគ្គលនោះទេ ។

[ ៣៨៤ ] ( ព្រះបាទបោរិសាទ... ) អាហារនោះ ជាទីគាប់ចិត្តរបស់ខ្ញុំដោយពិត ខ្ញុំចូលព្រៃ ព្រោះហេតុតែសាច់មនុស្សនុ៎ះ បើទ្រង់ទទួចសូមសេចក្តីនុ៎ះនឹងខ្ញុំ បពិត្រទ្រង់ជាសម្លាញ់ ខ្ញុំក៏ឲ្យពរនោះដល់ទ្រង់ ។

[ ៣៨៥ ] ព្រះអង្គជាសាស្តារបស់ខ្ញុំផង ជាសម្លាញ់របស់ខ្ញុំផង បពិត្រព្រះអង្គជាសម្លាញ់ ខ្ញុំនឹងធ្វើតាមព្រះឱង្ការរបស់ព្រះអង្គ ព្រះអង្គក៏ចូរធ្វើតាមពាក្យរបស់ខ្ញុំដែរ យើងទាំងពីរនាក់ ទៅដោះលែង ( ពួកក្សត្រទាំងនោះជាមួយគ្នា ) ។

[ ៣៨៦ ] ( ព្រះបាទសុតសោម... ) ខ្ញុំជាសាស្តារបស់ព្រះអង្គផង ជាសម្លាញ់របស់ព្រះអង្គផង បពិត្រព្រះអង្គជាសម្លាញ់ បើព្រះអង្គធ្វើតាមពាក្យខ្ញុំ ទាំងខ្ញុំក៏ធ្វើតាមពាក្យព្រះអង្គដែរ យើងទាំងពីរនាក់ទៅដោះលែង ( ពួកក្សត្រទាំងនោះជាមួយគ្នា ) ។

[ ៣៨៧ ] ពួកយើងដែលត្រូវព្រះរាជាជើងពពាលបៀតបៀនដោតបាតដៃ មានមុខជោកដោយទឹកភ្នែកស្រែកយំ ( ឥឡូវនេះ ) អ្នកទាំងឡាយលែងប្រទូស្តនឹងព្រះរាជានេះចុះ អ្នកទាំងឡាយ ចូរទទួលស្តាប់ពាក្យប្តេជ្ញាដ៏ទៀងទាត់របស់ខ្ញុំចុះ ។

[ ៣៨៨ ] ( ពួកក្សត្រ... ) ពួកយើងដែលត្រូវព្រះរាជាជើងពពាលបៀតបៀនដោយបាតដៃ មានមុខជោកដោយទឹកភ្នែក ស្រែកយំ ( ឥឡូវនេះ ) ពួកយើងមិនប្រទូស្តចំពោះព្រះរាជានេះទេ ពួកយើងនឹងទទួលស្តាប់ពាក្យប្តេជ្ញាដ៏ទៀងទាត់របស់ព្រះអង្គ ។

[ ៣៨៩ ] ( ព្រះបាទសុតសោម... ) បិតាឬមាតា ជាអ្នកអនុគ្រោះប្រាថ្នានូវសេចក្តីចម្រើនដល់បុត្តទាំងឡាយ យ៉ាងណាមិញ ចំណែកព្រះរាជានេះ ចូរមានដល់លោកទាំងឡាយ ក៏យ៉ាងនោះដែរ ទាំងលោកទាំងឡាយក៏សូមដូចជាបុត្ត ។

[ ៣៩០ ] ( ពួកក្សត្រ... ) បិតាឬមាតា ជាអ្នកអនុគ្រោះ ប្រាថ្នានូវសេចក្តីចម្រើនដល់បុត្តទាំងឡាយ យ៉ាងណាមិញ ចំណែកខាងព្រះរាជានេះ ចូរមានដល់យើងទាំងឡាយ យ៉ាងនោះដែរ ទាំងពួកយើងក៏ដូចបុត្តដែរ ។

[ ៣៩១ ] ( ព្រះបាទសុតសោម... ) ព្រះអង្គធ្លាប់សោយនូវសាច់នៃសត្វជើង ៤ ឬសត្វបក្សីដែលពួកនាយពិសេសចាត់ចែងល្អ សម្រេចដោយល្អ ជាទីត្រេកអរដូចព្រះឥន្ទ្រសោយនូវសុធាភោជន ព្រះអង្គលះបង់ចោលហើយត្រេកអរក្នុងព្រៃតែម្នាក់ឯង ដូចម្ដេចកើត ។ ពួកនាងខត្តិយានីនោះ មានគ្រឿងប្រដាប់ក្លីផ្ចេកនឹងចង្កេះដ៏វៀវ តាក់តែងខ្លួនគាល់ត្រៀបត្រា ញុំាងព្រះអង្គឲ្យរីករាយ ដូចជាស្រីអប្សរ បម្រើព្រះឥន្ទ្រក្នុងទេវលោក ព្រះអង្គលះបង់ចោលហើយត្រេកអរក្នុងព្រៃម្នាក់ឯង ដូចម្ដេចកើត ។ ព្រះអង្គផ្ទំលើព្រះបន្ទំ មានខ្នើយពណ៌ក្រហម មានព្រំមានរោមច្រើន តាក់តែងក្នុងទីព្រះបន្ទំទាំងអស់ដ៏ល្អ ជាសុខសប្បាយក្នុងទីពាក់កណ្ដាលនៃព្រះបន្ទំ ហើយលះបង់ចោល ត្រេកអរក្នុងព្រៃម្នាក់ឯង ដូចម្ដេចកើត ។ ក្នុងវេលារាត្រី មានសូរសំឡេងគងនិងស្គរទាំងតូរ្យតន្ត្រី ឥតមានបុរសនៅលាយ មានទាំងចម្រៀងដ៏ពីរោះ និងប្រគុំក៏ពីរោះជាច្រើនយ៉ាង ព្រះអង្គលះបង់ចោល ហើយត្រេកអរក្នុងព្រៃម្នាក់ឯង ដូចម្ដេចកើត ។ ឧទ្យាន ( ឈ្មោះមិគាជិន ) ក៏មានផ្កាច្រើនបរិបូណ៌ បុរីប្រកបដោយឈ្មោះតាមឧទ្យានមិគាជិន ជាបុរីគួរជាទីសប្បាយក្រៃពេក សម្បូរដោយពាហនៈ សេះ ដំរី រថ ព្រះអង្គលះបង់ចោល ហើយត្រេកអរក្នុងព្រៃតែម្នាក់ឯង ដូចម្ដេចកើត ។

[ ៣៩២ ] ( ព្រះបាទបោរិសាទ... ) ព្រះចន្ទក្នុងកាឡបក្ខ ( រនោច ) រមែងអស់ទៅរាល់ៗថ្ងៃ យ៉ាងណាមិញ បពិត្រព្រះរាជា ការសមាគមនឹងពួកអសប្បុរស ឧបមាដូចព្រះចន្ទក្នុងកាឡបក្ខ ។ ដូចយ៉ាងខ្ញុំ អាស្រ័យរសកៈ

អ្នកស្ទួជណ្តាំ ជាបុរសអាក្រក់លាមក ហើយបានធ្វើនូវកម្មអាក្រក់ ជាហេតុទៅកាន់ទុគ្គតិ ។ ព្រះចន្ទក្នុងសុក្កបក្ខ រមែងចម្រើនឡើងរាល់ៗ ថ្ងៃ យ៉ាងណាមិញ បពិត្រព្រះរាជា ការជួបប្រទះនឹងពួកសប្បុរស ឧបមាដូចជាព្រះចន្ទក្នុងសុក្កបក្ខ ។ បពិត្រព្រះបាទសុតសោម សូមព្រះអង្គជ្រាបចុះ ដូចយ៉ាងខ្ញុំអាស្រ័យព្រះអង្គ ហើយធ្វើការកុសលជាហេតុទៅកាន់សុគតិ ។

បពិត្រព្រះអង្គជាធំជាងជន ទឹកដែលបង្អុរចុះលើទីទួលមិនជក់នៅមិនឋិតនៅអស់កាលយូរ យ៉ាងណាមិញ ការសមាគមនឹងពួកអសប្បុរសរបស់ខ្ញុំ មិនតាំងនៅអស់កាលយូរ ដូចទឹកលើទីទួលយ៉ាងនោះដែរ ។ បពិត្រព្រះអង្គជាធំជាងជន មានព្យាយាមដ៏ប្រសើរជាងជន ទឹកដែលបង្អុរចុះក្នុងស្រះឋិតនៅអស់កាលយូរ យ៉ាងណាមិញ ការសមាគមនឹងពួកសប្បុរសរបស់ខ្ញុំ ឋិតនៅអស់កាលយូរ ដូចទឹកក្នុងស្រះ យ៉ាងនោះដែរ ។ សមាគមនឹងពួកសប្បុរស រមែងមិនឃ្លាតចេញទេ គប្បីឋិតនៅដរាបអស់ជីវិត ការសមាគមនឹងពួកអសប្បុរសរមែងវិនាសទៅឆាប់ ដោយប្រការដូច្នេះឯង ព្រោះហេតុនោះ ធម៌របស់ពួកសប្បុរស រមែងឆ្ងាយអំពីពួកអសប្បុរស ។

[ ៣៩៣ ] ( ព្រះបាទសុតសោម... ) ព្រះរាជាណាផ្ចាញ់នូវបុគ្គលមិនគួរផ្ចាញ់ ( មាតាបិតា ) ព្រះរាជានោះ មិនមែនជាព្រះរាជាទេ សម្លាញ់ណាផ្ចាញ់នូវសម្លាញ់ សម្លាញ់នោះ មិនមែនជាសម្លាញ់ទេ ភរិយាណា មិនខ្លាចប្តីភរិយានោះ មិនមែនជាភរិយាទេ ពួកបុត្តណា មិនចិញ្ចឹមមាតាបិតា ជាបុគ្គលចាស់ទុំ ពួកបុត្តនោះ មិនមែនជាកូនទេ ។ ពួកសប្បុរសមិនមានក្នុងទីប្រជុំ

ណា ទីនោះ មិនមែនទីប្រជុំទេ ពួកជនណា មិនពោលនូវធម៌ ពួកជននោះ មិនមែនជាសប្បុរសទេ លុះតែពួកជនលះបង់នូវរាគៈ ទោសៈនិងមោហៈហើយ ពោលនូវធម៌ ទើបឈ្មោះថា សប្បុរស ។

បណ្ឌិតកាលបើមិនពោល ( នូវធម៌ ) ជាអ្នកច្រឡូកច្រឡំដោយពួកជនពាល ពួកអ្នកផងរមែងស្គាល់មិនបាន លុះតែពោលសម្តែងនូវអមតបទ ទើបពួកអ្នកផងស្គាល់បាន ។ បណ្ឌិតគប្បីពោលបំភ្លឺនូវធម៌ ផ្គងឡើងនូវធម៌ ជាទង់ជ័យនៃពួកឥសី ពួកឥសីមានសុភាសិតជាទង់ជ័យ ព្រោះជាធម៌ទុកដូចជាទង់ជ័យនៃពួកឥសី ។

## ចប់ សុតសោមជាតក ទី ៥ ។

## ឧទ្ទាននៃជាតកនោះគឺ

ចុល្លហង្សឈ្មោះសុមុខៈ ១ មហាហង្សដ៏ប្រសើរ ១ តាបសឲ្យនូវសុធាភោជនដ៏ប្រសើរជាទេ ១ ស្តេចបក្សីឈ្មោះកុណាលៈ ១ ព្រះរាជាដ៏ប្រសើរព្រះនាមសុតសោម ១ ។

## ចប់ អសីតិនិបាត ។

# អដ្ឋកថា

## មហាសុតសោម ជាតក

[ ៣១៥-៣៩៣ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអង្គុលិមាលត្ថេរ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កស្មា តុវំ រសក ឯទិសានិ** ដូច្នេះជាដើម ។

ការកើតនិងការចេញបួសរបស់អង្គុលិមាលត្ថេរនោះ បណ្ឌិតគប្បីជ្រាបពិស្តារតាមន័យ ដែលព្រះអដ្ឋកថាចារ្យពោលទុកហើយ ក្នុងអដ្ឋកថាអង្គុលិមាលសូត្រ រឿងនេះបានពោលតាំងអំពីអង្គុលិមាលត្ថេរនោះ បានធ្វើនូវសួស្តីដល់ស្រីដែលមានគភ៌ ដោយសច្ចវាចា ចាប់តាំងពីនោះមក ក៏បានអាហារដោយស្រួល ចម្រើននូវវិវេក ក្នុងកាលតមក បានសម្រេចអរហត្តជាព្រះអរហន្ត មានឈ្មោះប្រាកដ ដែលរាប់បញ្ចូលក្នុងអសីតិមហាសាវ័ក ។ ក្នុងកាលនោះ ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា នែអាវុសោទាំងឡាយ គួរអស្ចារ្យពិតហ្ន៎ ព្រះសាស្តាទ្រង់ទូន្មានអង្គុលិមាលដែលជាមហាចោរ មានបាតដៃប្រឡាក់ដោយឈាម សាហាវបែបនោះ ដោយមិនចាំបាច់ប្រើដំបង ឬសស្ត្រាធ្វើឲ្យអស់ព្យសន៍បាន ទ្រង់ធ្វើកិច្ចដែលធ្វើបានដោយក្រ ធម្មតាព្រះពុទ្ធទាំងឡាយ រមែងជាអ្នកធ្វើកិច្ចដែលធ្វើបានលំបាកក្រៃលែង ព្រះសាស្តាគង់នៅក្នុងព្រះគន្ធកុដិ ទ្រង់បានស្តាប់ពាក្យរបស់ភិក្ខុទាំងនោះ ដោយទិព្វសោត ក៏ទ្រង់ជ្រាបថា បើតថាគតទៅក្នុងកាលឥឡូវនេះ នឹងមានឧបការៈច្រើន ធម្មទេសនានឹងប្រព្រឹត្តទៅយ៉ាងធំ ដូច្នេះ ទើបទ្រង់យាងចេញអំពីព្រះគន្ធកុដិទៅកាន់ធម្មសភាដោយពុទ្ធលីលា មិនមានអ្វីប្រៀប គង់លើអាសនៈដ៏ប្រសើរ

ដែលពួកភិក្ខុរៀបចំថ្វាយ ហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកសន្ទនាគ្នាដោយរឿងអ្វី កាលពួកភិក្ខុក្រាបទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតបានសម្រេចអភិសម្ពោធិញ្ញាណ ទូន្មានអង្គុលិមាលបានក្នុងកាលឥឡូវនេះ មិនជាអស្ចារ្យឡើយ កាលតថាគតនៅបំពេញបុព្វចរិយា តាំងនៅក្នុងបទេសញ្ញាណ ក៏ទូន្មានអង្គុលិមាលនេះបាន ត្រាស់ដូច្នេះហើយ ទ្រង់ក៏តុណ្ហីភាព កាលភិក្ខុទាំងនោះទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល ព្រះរាជាព្រះនាមកោរព្យៈ សោយរាជសម្បត្តិដោយធម៌ក្នុងនគរឥន្ទបត្ត ដែនកុរុ ។ ក្នុងកាលនោះ ព្រះពោធិសត្វនៃយើងកើតក្នុងព្រះឧទររបស់អគ្គមហេសីនៃព្រះបាទកោរព្យៈនោះ ក៏ព្រោះព្រះរាជកុមារនោះមាននិស្ស័យពេញចិត្តក្នុងការសិក្សា ជនទាំងឡាយក៏នាំគ្នាហៅថា សុតសោម ព្រះរាជា ទ្រង់ឃើញព្រះរាជកុមារនោះចម្រើនវ័យហើយ ទើបព្រះរាជទានដុំមាស ១០០០ ដុំ បញ្ជូនទៅកាន់នគរតក្កសិលា ដើម្បីឲ្យសិក្សាសិប្បសាស្ត្រក្នុងសម្នាក់អាចារ្យទិសាបាមោក្ខ ។ សុតសោម ទទួលទ្រព្យដែលជាទ្រនឹបអាចារ្យ ហើយចេញដំណើរទៅ ឯព្រហ្មទត្តកុមារ ជាព្រះរាជបុត្ររបស់ព្រះបាទកាសិករាជក្នុងនគរពារាណសី ព្រះបិតាក៏ត្រាស់យ៉ាងនោះដូចគ្នា ហើយបញ្ជូនទៅ ធ្វើដំណើរតាមផ្លូវនោះ ។ លំដាប់នោះ សុតសោមកុមារធ្វើដំណើរទៅដល់ហើយ ក៏អង្គុយសម្រាកលើបន្ទះក្តារ ក្នុងសាលាក្បែរទ្វារនគរ សូម្បី

ព្រហ្មទត្តកុមារទៅដល់ហើយ ក៏អង្គុយលើបន្ទះក្ដារជាមួយគ្នានឹងសុត សោមកុមារនោះ លំដាប់នោះ សុតសោម ក៏ធ្វើបដិសណ្ឋារៈ ហើយសួរព្រហ្មទត្តកុមារនោះថា នែសម្លាញ់ អ្នកធ្វើដំណើរមកហត់នឿយ អ្នកមកអំពីណា ព្រហ្មទត្តកុមារឆ្លើយថា ខ្ញុំមកពីនគរពារាណសី សុតសោមសួរថា ឯងជាកូនអ្នកណា ព្រហ្មទត្តកុមារឆ្លើយថា ខ្ញុំជាឱរសរបស់ព្រះបាទកាសី សុតសោមសួរថា ឯងឈ្មោះអ្វី ព្រះរាជកុមារឆ្លើយថា ខ្ញុំឈ្មោះព្រហ្មទត្តកុមារ សុតសោមសួរថា ឯងមកទីនេះដោយហេតុអ្វី ក៏ឆ្លើយថា ខ្ញុំមករៀនសិល្បសាស្ត្រ ហើយសួរសុតសោមកុមារ ដោយន័យដូចគ្នាថា សូម្បីខ្លួនឯង ក៏ធ្វើដំណើរហត់នឿយមក ឯងមកពីណា សុតសោមប្រាប់ដល់ព្រហ្មទត្តកុមារសព្វគ្រប់ប្រការ ព្រះរាជកុមារទាំងនោះ ក៏ពោលថា យើងទាំង ២ ជាក្សត្រ ចូលទៅសិក្សាសិល្បសាស្ត្រក្នុងសម្នាក់អាចារ្យជាមួយគ្នាចុះ យើងធ្វើជាមិត្តសម្លាញ់នឹងគ្នា ទើបចូលទៅកាន់នគរ ទៅរកត្រកូលអាចារ្យ ថ្វាយបង្គំអាចារ្យ ហើយ ប្រាប់ជាតិរបស់ខ្លួន ប្រាប់កាលដែលខ្លួនទាំង ២ មកដើម្បីសិក្សាសិប្បៈ អាចារ្យក៏ទទួលថា សាធុ រាជកុមារទាំង ២ ក៏ឲ្យទ្រព្យថ្លៃការសិក្សាដល់អាចារ្យ ហើយរៀនសិប្បៈ ។

ក្នុងកាលនោះ មិនមែនតែព្រះរាជកុមារទាំង ២ ប៉ុណ្ណោះទេ សូម្បីព្រះរាជបុត្តដទៃៗ ក្នុងជម្ពូទ្វីបប្រមាណ ១០១ អង្គ ក៏រៀនសិប្បៈក្នុងសម្នាក់នៃអាចារ្យនោះ សុតសោមកុមារបានជាអន្តេវាសិកដែលឈ្លាសជាងគេបំផុតក្នុងរាជបុត្តទាំងនោះ រៀនសិល្បសាស្ត្រដោយការប្រឹងប្រែង មិនយូរប៉ុន្មានក៏ដល់

នូវការសម្រេច ។ សុតសោមកុមារមិនបានទៅកាន់សម្នាក់របស់ព្រះរាជកុមារដទៃ ទៅរកតែព្រហ្មទត្តកុមារតែមួយអង្គប៉ុណ្ណោះ ដោយគិតថា កុមារនេះជាសម្លាញ់របស់អញ ធ្វើជាគ្រូដោយប្រយោល ជួយណែនាំបន្ថែមដល់ព្រហ្មទត្តកុមារនោះ បង្រៀនឲ្យសម្រេចក្នុងការសិក្សាដោយរហ័ស សិប្បៈរបស់រាជកុមារក្រៅពីនេះក៏សម្រេច តាមលំដាប់គ្នា ពួករាជកុមារទាំងនោះ ឲ្យទ្រនិបដល់អាចារ្យ ថ្វាយបង្គំហើយ ចោមរោមសុតសោមកុមារធ្វើដំណើរមក ។ សម័យនោះ សុតសោមក៏ឈរក្នុងវាងផ្លូវបំបែក កាលបញ្ជូនរាជបុត្តទាំងនោះទៅ ទើបពោលថា សម្លាញ់ទាំងឡាយសម្តែងសិល្បសាស្ត្រដល់ព្រះរាជមាតាបិតារបស់ខ្លួនហើយ នឹងតាំងនៅក្នុងរាជសម្បត្តិ កាលតាំងនៅក្នុងរាជសម្បត្តិហើយ គប្បីធ្វើតាមឱវាទរបស់យើង ព្រះរាជកុមារទាំងនោះ សួរថា ធ្វើដូចម្តេចលោកអាចារ្យ សុតសោមប្រាប់ថា អ្នកទាំងឡាយ ចូររក្សាឧបោសថរៀងរាល់កន្លះខែម្តង កុំធ្វើនូវការសម្លាប់សត្វ រាជបុត្តទាំងនោះទទួលថា សាធុ ។ ព្រះពោធិសត្វទ្រង់ក៏ជ្រាបជាមុនថា ភ័យធំ នឹងកើតឡើងក្នុងនគរពារាណសី ព្រោះអាស្រ័យព្រហ្មទត្តកុមារនេះ ព្រោះប្រាកដក្នុងអង្គវិជ្ជា ( វិជ្ជាមើលអវយវៈ ) ទើបឲ្យឱវាទដល់ពួករាជកុមារទាំងនោះ ហើយបញ្ជូនទៅ ។

រាជបុត្តទាំងនោះគ្រប់អង្គ ទៅដល់នគររបស់ខ្លួនហើយ សម្តែងនូវសិប្បៈដល់ព្រះមាតាបិតា ហើយតាំងនៅក្នុងរាជសម្បត្តិ ហើយទ្រង់បញ្ជូននូវរាជសាសន៍ មួយអន្លើដោយរាជបណ្ណាការ ដើម្បីឲ្យជ្រាបភាពដែលខ្លួនតាំងនៅក្នុងរាជសម្បត្តិ ហើយប្រព្រឹត្តនៅក្នុងឱវាទផងដែរ ព្រះពោធិសត្វទ្រង់ជ្រាប

ដំណើងនោះហើយ ទ្រង់ក៏បញ្ជូនរាជសាសន៍ទៅថា អ្នកទាំងឡាយចូរកុំប្រមាទ ក្នុងបណ្តាព្រះរាជាទាំងនោះ ព្រះបាទពារាណសីទ្រាំអត់អាហារមិនបាន សូម្បី ក្នុងថ្ងៃឧបោសថ ក៏ពួកអ្នកវិសេសត្រូវរក្សាសាច់ទុកថ្វាយទ្រង់ដែរ ។ ថ្ងៃមួយ សាច់ដែលរក្សាទុកនោះត្រូវពួកកោលេយ្យសុនខក្នុងព្រះរាជវាំងស៊ីអស់ព្រោះ ការប្រហែសធ្វេសរបស់អ្នកពិសេស ។ អ្នកពិសេសមិនឃើញសាច់ ក៏កាន់ យកកហាបណៈមួយក្តាប់ត្រាច់ទៅ ក៏មិនអាចរកសាច់បាន ទើបត្រិះរិះថា បើ ព្រះស្ងោយមិនមានមំសៈ អញនឹងមិនមានជីវិត ធ្វើដូចម្តេចហ្ន៎ កាលនឹកឃើញ ឧបាយ ក្នុងពេលព្រលប់ក៏បានទៅកាន់ព្រៃខ្មោចស្រស់ រះយកសាច់ភ្លៅរបស់ បុរសដែលស្លាប់ថ្មីៗ នាំមកចម្អិនឲ្យឆ្អិនល្អ ចាត់ចែងជាព្រះស្ងោយមួយអន្ទើ ដោយមំសៈ ។ ព្រះរាជាគ្រាន់តែដាក់សាច់ដល់ចុងអណ្តាត ជុំសាច់នោះក៏ បានផ្សាយទៅកាន់សរសៃប្រសាទ ដែលសម្រាប់ទទួលរសទាំង ៧០០០ ជ្រួត ជ្រាបពេញសរីរៈ ។ មានពាក្យជ្រៀតសួរចូលមកថា តើព្រោះហេតុអ្វី ឆ្លើយ ថា ព្រោះធ្លាប់សោយពីមុនមក ។

បានឮថា ក្នុងអត្តភាពមុន ព្រះរាជាកើតជាយក្ខ បរិភោគសាច់មនុស្ស ជាច្រើន ព្រោះហេតុនោះ ទើបសាច់មនុស្សជាទីសព្វព្រះហឫទ័យរបស់ព្រះ អង្គ ព្រះរាជាទ្រង់ត្រិះរិះថា បើអញនៅស្ងៀម ហើយបរិភោគ អ្នកពិសេស នេះ ក៏មិនប្រាប់សាច់នេះដល់អញ ទើបក្អែងធ្វើជាស្តោះចោលទៅលើដី មួយ អន្ទើដោយព្រះខេឡៈ កាលអ្នកពិសេសក្រាបទូលថា បពិត្រព្រះអង្គ សាច់ មិនមានទោសឡើយ សូមទ្រង់សោយចុះ ទើបទ្រង់ត្រាស់ឲ្យរាជសេវកៈចេញ

ទៅ ហើយត្រាស់សួរអ្នកពិសេសថា យើងក៏ដឹងថា សាច់នេះមិនមានទោស តែសាច់នេះជាសាច់អ្វី ។ អ្នកពិសេសក្រាបទូលថា សាច់ដែលទ្រង់សោយក្នុងថ្ងៃមុនៗ និងសាច់នេះមានរសដូចគ្នាមិនមែនឬ ព្រះរាជាត្រាស់ថា គប្បីធ្វើបានល្អក្នុងថ្ងៃនេះឯង សូម្បីថ្ងៃមុន ឯងក៏ធ្វើយ៉ាងនេះ មិនមែនឬ លំដាប់នោះព្រះរាជាទ្រង់ជ្រាបថា អ្នកពិសេសនោះនៅស្ងៀម ទើបត្រាស់បន្តថា ចូរប្រាប់តាមសេចក្តីពិតចុះ បើមិនប្រាប់ឯងនឹងមិនមានជីវិត អ្នកពិសេសក៏ក្រាបទូលសូមព្រះរាជទានអភ័យ ហើយក្រាបទូលតាមសេចក្តីពិត ព្រះរាជាត្រាស់ថា ឯងកុំខ្លាចឡើយ ចូរឯងបរិភោគសាច់តាមធម្មតា ហើយចូរចម្អិនសាច់មនុស្សឲ្យដល់យើងតែម្យ៉ាង អ្នកពិសេសក្រាបទូលថា បពិត្រព្រះអង្គ សាច់នេះរកបានដោយកម្រមិនមែនឬ ព្រះរាជាត្រាស់ថា កុំខ្លាចឡើយ មិនមែនរបស់ក្រឡើយ អ្នកពិសេសទូលសួរថា បពិត្រព្រះអង្គ ទូលព្រះបង្គំនឹងបានមកអំពីណា ព្រះរាជាត្រាស់ថា មនុស្សក្នុងគុកមានច្រើន មិនមែនឬ ។

ចាប់តាំងពីកាលនោះ អ្នកពិសេសបានធ្វើតាមព្រះរាជបញ្ជាគ្រប់ប្រការ ក្នុងកាលជាខាងក្រោយមក អ្នកទោសក្នុងគុកក៏អស់ អ្នកពិសេសក៏ក្រាបទូលថា បពិត្រព្រះអង្គ ឥឡូវនេះ ទូលព្រះបង្គំនឹងធ្វើដូចម្តេច ព្រះរាជាត្រាស់ថា ចូរឯងទម្លាក់ថង់ទ្រព្យ ១០០០ ត្រង់ផ្លូវដើរ អ្នកណារើសយកថង់ទ្រព្យនោះ ចូរចាប់អ្នកនោះ ដោយចោទថាជាចោរ ហើយសម្លាប់ចោល អ្នកពិសេសបានធ្វើតាមព្រះរាជបញ្ជានោះហើយ ក្នុងកាលតមក ថង់ទ្រព្យ ១០០០ នោះមិនមានសូម្បីអ្នកក្រឡេកមើល ព្រោះការភ័យខ្លាច ទើបទូលសួរព្រះរាជថា

បពិត្រព្រះអង្គ ឥឡូវនេះ នឹងធ្វើដូចម្តេច ព្រះរាជាត្រាស់ថា ក្នុងពេលវាយស្គរកណ្តាលយប់ ព្រះនគរនឹងកើតការប្របូកប្របល់ ពេលនោះ ចូរឯងឈរស្ទាក់ត្រង់ប្រកផ្ទះឬប្រកផ្លូវដែលបែកជា ៤ ចូរសម្លាប់មនុស្សយកសាច់មក ។ ចាប់តាំងពីនោះ បុរសនោះបានធ្វើយ៉ាងនោះ ហើយយកសាច់ដែលល្អៗ មកសាកសពក៏ប្រាកដនៅក្នុងទីនោះៗ ព្រះនគរ ក៏ស្មោកគ្រោកដោយសាកសពឮតែសំឡេងមហាជនយំសោកថា ម្តាយរបស់ខ្ញុំបាត់ទៅ ឪពុករបស់ខ្ញុំបាត់ទៅ បងប្រុស ប្អូនប្រុសរបស់ខ្ញុំបាត់ទៅ បងស្រី ប្អូនស្រីរបស់ខ្ញុំបាត់ទៅ ។

អ្នកនគរខ្លាចផង តក់ស្លុតផង ប្រឹក្សាគ្នាថា មនុស្សទាំងនេះ ត្រូវរាជសីហ៍ស៊ី ឬត្រូវខ្លាស៊ី ឬក៏ត្រូវយក្ខស៊ីហ្ន៎ ការពិនិត្យមើលសាកសព ឃើញមុខរបួសដែលត្រូវប្រហារ ទើបសន្និដ្ឋានថា ជាចោរមនុស្ស ស៊ីមនុស្សទាំងនេះដោយពិត ទើបមហាជនប្រជុំគ្នាស្រែកតវ៉ាត្រង់លានព្រះលានរាជវាំង ព្រះរាជាត្រាស់សួរថា នែអ្នកទាំងឡាយ តើមានរឿងអ្វី អ្នកនគរឆ្លើយថា ក្នុងនគរនេះកើតចោរស៊ីមនុស្សឡើងហើយ សូមទ្រង់ចាប់ចោរស៊ីសាច់មនុស្សនោះចុះ ព្រះរាជាត្រាស់ថា យើងនឹងដឹងបានដូចម្តេច យើងជាអ្នករក្សាព្រះនគរត្រាច់ទៅពិនិត្យមើលឬ ។ មហាជនប្រឹក្សាគ្នាថា ព្រះរាជាទ្រង់មិនយកចិត្តទុកដាក់ក្នុងព្រះនគរ ពួកយើងនឹងនាំគ្នាទៅប្រាប់ដល់កាឡហត្ថិសេនាបតីចុះ ទើបនាំគ្នាប្រាប់សេចក្តីនោះ ដល់លោកសេនាបតី ជម្រាបថា គួរស៊ើបចាប់ខ្លួនមនុស្សអាក្រក់នោះឲ្យបាន សេនាបតីប្រាប់ថា ពួកអ្នកចូរបង្អង់ ៧ ថ្ងៃសិន យើងនឹងចាប់ខ្លួនមនុស្សអាក្រក់មកឲ្យពួកអ្នកឲ្យបាន ហើយបញ្ជូន

មហាជនត្រឡប់ទៅ ។

សេនាបតីប្រាប់រាជបុរសថា នែបាទាំងឡាយ ល្បីថា ចោរស៊ីសាច់មនុស្ស មានក្នុងព្រះនគរ ពួកអ្នកចូរពួនក្នុងទីនោះៗ ចាប់វាឲ្យបាន ពួករាជបុរសទទួលបញ្ជាហើយ ចាប់ពីនោះមក ក៏ឃ្លាំចាំមើលក្នុងព្រះនគរជានិច្ច ។ អ្នកពិសេសពួនត្រង់ប្រកផ្ទះមួយ សម្លាប់ស្រីម្នាក់បានហើយ គិតនឹងអារយកសាច់ដែលល្អដាក់ក្នុងល្អី រំពេចនោះ ពួករាជបុរសក៏ចាប់អ្នកពិសេសវាយហើយចងក្រពាត់ដៃទៅក្រោយ ប្រកាសខ្លាំងៗ ថា ពួកយើងចាប់ចោរស៊ីសាច់មនុស្សបានហើយ មហាជននាំគ្នាចោមរោមអ្នកពិសេសនោះ ខណៈនោះ បុរសទាំងឡាយចងជាប់មាំទាំហើយ ចងល្អីសាច់ត្រង់ក នាំខ្លួនទៅបង្ហាញដល់សេនាបតីលំដាប់នោះ សេនាបតីកាលបានឃើញអ្នកពិសេសនោះ ក៏ត្រិះរិះថា បុរសនេះស៊ីឯង ឬយកទៅលក់ដូរ ឬសម្លាប់តាមព្រះរាជបញ្ជា កាលនឹងសួរសេចក្តីនោះ ទើបពោលគាថាទី ១ ថា

> ម្នាលរសកៈ ( នាយពិសេស ) ព្រោះហេតុអ្វី អ្នកធ្វើនូវ
> អំពើដ៏លាមកក្រៃលែង ប្រាកដដូច្នេះ អ្នកជាបុគ្គលវង្វេង
> សម្លាប់ពួកស្រីនិងប្រុស ព្រោះហេតុសាច់ ឬព្រោះហេតុទ្រព្យ
> ដូច្នេះ ។

ក្នុងគាថានោះ សេនាបតីហៅចុងភៅនោះថា រសកៈ បន្ទាប់អំពីនេះទៅ បណ្ឌិតគប្បីជ្រាបសេចក្តីដែលទាក់ទងគ្នាងាយៗ ដោយអំណាចបាលីដែលជាពាក្យសាកសួរនិងពាក្យឆ្លើយ ។

លំដាប់នោះ អ្នកពិសេសក៏ពោលនឹងសេនាបតីនោះថា

ខ្ញុំសម្លាប់ មិនមែនព្រោះហេតុខ្លួនឯង មិនមែនព្រោះហេតុទ្រព្យ មិនមែនព្រោះហេតុកូនប្រពន្ធ ឬសម្លាញ់និងញាតិទេ បពិត្រលោកដ៏ចម្រើន ព្រោះថា ព្រះភូមិបាលអ្នកមានបុណ្យជាម្ចាស់នៃខ្ញុំ ទ្រង់សោយនូវសាច់ប្រាកដ ដូច្នេះ ។

លំដាប់នោះ សេនាបតីក៏ពោលនឹងអ្នកពិសេសនោះថា

បើអ្នកឯងខ្វល់ខ្វាយ ក្នុងកិច្ចរបស់ព្រះរាជាជាម្ចាស់ ហើយធ្វើនូវអំពើដ៏លាមកក្រៃលែង អ្នកឯង លុះព្រឹកឡើងចូលទៅខាងក្នុងព្រះរាជវាំងហើយ គប្បីនិយាយនូវដំណើរនោះប្រាប់ខ្ញុំ ក្នុងទីចំពោះព្រះភក្ត្រនៃព្រះរាជា ដូច្នេះ ។

លំដាប់នោះ អ្នកពិសេសក៏ពោលនឹងសេនាបតីនោះថា

បពិត្រសេនាបតី ឈ្មោះកាឡហត្ថីដ៏ចម្រើន លោកនិយាយយ៉ាងណា ខ្ញុំនឹងធ្វើយ៉ាងនោះ ព្រឹកឡើងខ្ញុំនឹងចូលទៅខាងក្នុងព្រះរាជវាំង ហើយថ្លែងសេចក្តីនោះ ជម្រាបលោកក្នុងទីចំពោះព្រះភក្ត្រនៃព្រះរាជា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភទ្ទេ** ក្នុងគាថានោះ ជាពាក្យសម្តែងសេចក្តីគោរព ។ បទថា **សចេ ត្វំ** អធិប្បាយថា សេនាបតីកាលសាកល្បងមើលថា អ្នកពិសេសនេះពោលពិត ឬពោលកុហកព្រោះខ្លាចស្លាប់ ទើបបានជាពោលយ៉ាងនេះ ។ បទថា **សុទារុណានិ** សំដៅដល់ កម្ម គឺការសម្លាប់

មនុស្ស ។ បទថា **សម្មុខេ ឋាំ** សេចក្ដីថា ចូរអ្នកទៅឈរក្នុងទីចំពោះព្រះភក្ត្រ ហើយគប្បីពោលពាក្យយ៉ាងនេះ ។ អ្នកពិសេសនោះ កាលទទួលពាក្យទើបពោលគាថាដោយប្រការដូច្នោះឯង ។

លំដាប់នោះ សេនាបតីបញ្ជាឲ្យចងអ្នកពិសេសនោះឲ្យមាំទាំ កាលរាត្រីអស់ហើយ ទើបប្រឹក្សានឹងពួកអាមាត្យនិងអ្នកនគរ កាលរួមចន្ទះគ្នាទាំងអស់ហើយ ដាក់នូវការរក្សាគ្រប់កន្លែង ធ្វើនគរឲ្យនៅក្នុងកណ្ដាប់ដៃ ចងល្អីនេះត្រង់កអ្នកពិសេស នាំខ្លួនចូលទៅកាន់រាជនិវេសន៍ សំឡេងភ្ញាក់ផ្អើលបានកើតពេញនគរហើយ ។ ម្សិលមិញនេះ ព្រះរាជាសោយព្រះក្រយាហារព្រឹកហើយមិនបានសាច់ក្នុងពេលល្ងាច ទើបប្រថាប់គង់រង់ចាំ គិតក្នុងព្រះហឫទ័យថា អ្នកពិសេសនឹងមកក្នុងកាលឥឡូវនេះ នឹងមកឥឡូវនេះ ប្រថាប់រង់ចាំរហូតដល់ភ្លឺ ទ្រង់ព្រះតម្រិះថា សូម្បីថ្ងៃនេះ អ្នកពិសេសគង់មិនមក អ្នកនគរក៏បន្លឺសំឡេង តើមានរឿងអ្វីហ្ន៎ ទើបទ្រង់ទតតាមបង្អួច ទ្រង់ឃើញអ្នកពិសេសត្រូវគេនាំមកដោយអាការយ៉ាងនោះ ទ្រង់ព្រះតម្រិះថា ហេតុនេះប្រាកដឡើងហើយ ទ្រង់តាំងព្រះសតិយ៉ាងមាំប្រថាប់គង់លើបល្ល័ង្ក កាឡហត្ថិសេនាបតីក៏ចូលទៅគាល់ទូលសួរជេញដោល ទើបទ្រង់ថ្លែងដល់សេនាបតីនោះ ។

ព្រះសាស្ដា កាលទ្រង់ប្រកាសសេចក្ដីនោះ ទើបត្រាស់ថា

គ្រានោះ កាលដែលវេលារាត្រីភ្លឺច្បាស់ ព្រះអាទិត្យរះឡើង
ប្រាកដ សេនាបតី ឈ្មោះកាឡហត្ថិ បាននាំសេកៈ ចូលទៅ
គាល់ព្រះរាជា លុះចូលទៅដល់ហើយ ក៏ក្រាបទូលពាក្យនេះ

ចំពោះព្រះរាជាថា បពិត្រមហារាជ បានឮថា ព្រះអង្គប្រើសេវកៈ ឲ្យទៅសម្លាប់ស្រី ប្រុស ព្រះអង្គទ្រង់សោយសាច់ មែនឬ ដូច្នេះ ។

លំដាប់នោះ ព្រះរាជាត្រាស់តបថា

ម្នាលកាឡហត្ថិ ខ្ញុំបានប្រើសេវកៈដូច្នោះមែន ហេតុអ្វីអ្នកជេរប្រទេចសេវកៈបុរស ដែលធ្វើប្រយោជន៍ឲ្យខ្ញុំនុ៎ះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កាឡ** ក្នុងគាថានោះ សំដៅដល់ កាឡហត្ថិសេនាបតី ។ បទថា **ឯវមេវ** បានដល់ ព្រះរាជាត្រូវសេនាបតី ដែលមានតេជះដេញដោល មិនអាចពោលកុហកបាន ទើបត្រាស់យ៉ាងនេះ ។ បទថា **តថា** នេះ ជាពាក្យដូចពាក្យខាងមុខ ។ បទថា **មម អត្ថំ** បានដល់ ដើម្បីសេចក្តីចម្រើនរបស់យើង ។ បទថា **ករោន្តស្ស** បានដល់ ធ្វើ ។ បទថា **កិមេតំ** អធិប្បាយថា លោកជេរបរិភាសអ្នកពិសេសនេះ ព្រោះហេតុអ្វី ។

លំដាប់នោះ ព្រះរាជាត្រាស់ថា អ្នកធ្វើកិច្ចដែលអ្នកដទៃលំបាកនឹងធ្វើបាន គួរសរសើរពិតហ្ន៎ ហើយត្រាស់សម្លុតសេនាបតីឲ្យខ្លាចថា នែកាឡហត្ថិ ចោរដទៃម្តេចក៏លោកមិនចាប់ មកចាប់អ្នកបម្រើរបស់យើង សេនាបតីស្តាប់ពាក្យនោះ ត្រិះរិះថា ព្រះរាជាទ្រង់ទទួលសារភាព ដោយព្រះឱស្ឋរបស់ព្រះអង្គឯងទ្រង់ឃោរឃៅគួរភ័យខ្លាច ទ្រង់ស៊ីសាច់មនុស្សអស់កាលមានប្រមាណប៉ុណ្ណេះ អញនឹងទូលឃាត់ទ្រង់សាកមើល ដូច្នេះហើយ ក្រាបទូលថា បពិត្រមហារាជ សូមទ្រង់កុំធ្វើយ៉ាងនេះទៀតឡើយ កុំសោយសាច់មនុស្សឡើយ

ព្រះរាជាត្រាស់ថា នែកាឡហត្ថិ លោកនិយាយអ្វី យើងមិនអាចអត់សាច់មនុស្សបានឡើយ ។ សេនាបតីទូលថា បពិត្រព្រះអង្គ បើទ្រង់អត់ធន់មិនបានទេ ទ្រង់ឯងនឹងធ្វើព្រះអង្គឯងនិងនគរឲ្យវិនាស ព្រះរាជាត្រាស់ថា ទោះបីយើងត្រូវវិនាសដោយអាការយ៉ាងនេះ យើងក៏មិនអាចអត់សាច់មនុស្សនោះបាន ។ លំដាប់នោះ សេនាបតីបំណាងឲ្យទ្រង់ដឹងខ្លួន ទើបនាំយករឿងមកនិទានដូចតទៅនេះថា ក្នុងអតីតកាល ក្នុងមហាសមុទ្ទ មានត្រីធំ ៦ គឺត្រីឈ្មោះអានន្ទ ១ ត្រីឈ្មោះឧបនន្ទ ១ ត្រីឈ្មោះអជ្ឈោហារ ១ ត្រីធំទាំង ៣ នេះមានប្រវែងដល់ទៅ ៥០០ យោជន៍ ត្រីឈ្មោះតិមិង្គលៈ ១ ត្រីឈ្មោះតិមិរមិង្គលៈ ១ ត្រីឈ្មោះមហាតិមិរមិង្គលៈ ១ ត្រីធំទាំង ៣ នេះ មានប្រវែង ១០០០ យោជន៍ ត្រីធំទាំង ៦ នោះ មានជុំថ្មនិងសារាយជាកិច្ចាហារ បណ្តាត្រីទាំង ៦ នោះ ត្រីឈ្មោះអានន្ទនៅក្នុងចំណែកមួយនៃមហាសមុទ្ទ ហ្វូងត្រីជាច្រើន នាំគ្នាចូលទៅរកត្រីឈ្មោះអានន្ទនោះ ថ្ងៃមួយ ត្រីទាំងនោះគិតគ្នាថា ព្រះរាជារបស់សត្វជើង ២ និងសត្វជើង ៤ រមែងប្រាកដ តែព្រះរាជារបស់ពួកយើងមិនទាន់មាន ពួកយើងនឹងធ្វើត្រីមួយឲ្យជាស្តេច ត្រីទាំងអស់បានរួមគ្នាជាឯកច្ឆ័ន្ទ លើកត្រីឈ្មោះអានន្ទជាព្រះរាជា ចាប់តាំងពីពេលនោះមក ត្រីទាំងនោះ ក៏ទៅបម្រើត្រីអានន្ទនោះ រាល់ល្ងាចព្រឹក ។

ថ្ងៃមួយ ត្រីអានន្ទស៊ីជុំថ្ម និងសារាយក្នុងភ្នំមួយកន្លែង ក៏បរិភោគត្រីមួយដោយមិនដឹងថាជាត្រី ស្មានថាជាសារាយ សាច់ត្រីនោះជ្រួតជ្រាបពេញសរីរៈរបស់ត្រីឈ្មោះអានន្ទ ត្រីឈ្មោះអានន្ទគិតថា សាច់នេះជាសាច់អ្វីហ្ន៎ អីក៏

ឆ្ងាញ់ពន់ពេក ខ្លាក់មកមើល ឃើញថាជាសាច់ត្រី គិតថា អញមិនចេះបរិ-
ភោគមកយូរដល់ម្ល៉េះ ហើយក៏គិតបន្តថា ពួកត្រីមកកាន់ទីបម្រើរបស់អញ
ទាំងពេលព្រឹកនិងពេលល្ងាច ពេលត្រឡប់ទៅ អញនឹងស៊ីវាមួយពីរ ។ តែ
បើស៊ីវាដោយចំហ សូម្បីតែត្រីមួយក៏មិនចូលមកក្បែរអញ នឹងនាំគ្នាគេចទៅ
អស់ អញនឹងធ្វើរឿងនេះដោយសម្ងាត់ អញនឹងស៊ីត្រីណាដែលចេញទៅ
ក្រោយគេ ដូច្នេះហើយ បានធ្វើតាមការត្រិះរិះសព្វប្រការ ពួកត្រីទាំងនោះ
ក៏អស់ទៅដោយលំដាប់ ទើបគិតគ្នាថា ភ័យកើតឡើងដល់ពួករបស់យើង
អំពីទីណាហ្ន៎ ។ សម័យនោះ ត្រីឈ្លាសវៃមួយគិតថា កិរិយារបស់ ត្រី
អានន្ទ មិនគាប់ចិត្តអញសោះ អញនឹងឃ្លាំចាំមើលអាកប្បកិរិយារបស់គេ
កាលហ្វូងត្រីទៅកាន់ទីបម្រើ បានលួចចូលទៅពួនក្នុងត្រចៀករបស់ត្រីអានន្ទ
ត្រីអានន្ទបញ្ជូនហ្វូងត្រីទៅហើយ ស៊ីត្រីដែលទៅក្រោយគេ ត្រីនោះ ឃើញការ
ធ្វើរបស់ត្រីអានន្ទនោះ ក៏ទៅប្រាប់ដល់គ្នីគ្នារបស់ខ្លួន ត្រីទាំងនោះ កិតភ័យ
នាំគ្នាគេចទៅអស់ ចាប់ពីនោះមក អានន្ទមច្ឆា មិនបានបរិភោគអាហារដទៃ
ឡើយ ព្រោះជាប់ក្នុងរស គឺសាច់ត្រី ។ ត្រីឈ្មោះអានន្ទត្រូវ សេចក្ដីឃ្លាន
គ្របសង្កត់ខ្លាំងឡើងៗ ដល់នូវសេចក្ដីលំបាកគិតថា ត្រីទាំងនេះ នាំគ្នាទៅពួន
ឯណាហ្ន៎ កាលស្វែងរកត្រីទាំងនោះ ឃើញភ្នំមួយគិតថា ប្រហែលជាពួកវា
អាស្រ័យភ្នំនេះ ព្រោះខ្លាចអញ ព្រោះហេតុនោះ អញនឹងហែលសសៀរ
ជុំវិញភ្នំនេះរកមើល ទើបយកកន្ទុយនិងក្បាលព័ទ្ធភ្នំនោះដោយជុំវិញ ។ លំ-
ដាប់នោះ ត្រីអានន្ទត្រិះរិះថា ត្រីនឹងនៅក្នុងទីនេះទាំងអស់ នឹងគេចទៅណា

មិនបាន ហើយព័ទ្ធភ្នំ ឃើញកន្ទុយរបស់ខ្លួនឯង ក៏ក្រោធ សម្គាល់ថា ត្រីនេះ បោកបញ្ឆោតអញ អាស្រ័យភ្នំពួនសម្ងំ ទើបត្របាក់កន្ទុយខ្លួនឯង អស់ប្រមាណ ៥០ យោជន៍ ដោយសម្គាល់ថា ជាត្រីដទៃ ហើយទំពាស៊ីយ៉ាងឆ្ងាញ់ លុះដល់ កើតទុក្ខវេទនា ។ ពួកត្រីមកប្រជុំគ្នា ព្រោះក្លិននៃឈាម ក៏នាំគ្នាចឹកស៊ី រហូតដល់ក្បាល ត្រីអានន្ទមិនអាចត្រឡប់ខ្លួនបាន ព្រោះខ្លួនធំ ដល់នូវការ អស់ជីវិតក្នុងទីនោះឯង គំនរឆ្អឹងដូចភ្នំដ៏ធំមួយ តាបសទិព្វចក្ខុដែលត្រាច់ តាមអាកាស បានមកតំណាលឲ្យពួកមនុស្សស្តាប់ ទើបពួកមនុស្សក្នុងជម្ពូ ទ្វីបដឹងគ្រប់គ្នាទាំងអស់ ។ កាលកាឡសេនាបតីនាំរឿងនេះមកសម្តែង បាន ពោលគាថានេះថា

ត្រីឈ្មោះអានន្ទ ជាប់ចិត្តនឹងរស ស៊ីនូវពួកត្រីទាំងពួង កាល
បើត្រីជាបរិវារអស់ហើយ ក៏ខាំស៊ីកន្ទុយខ្លួនឯងស្លាប់ទៅ ។
ព្រះអង្គជាអ្នកប្រមាទ ត្រេកអរក្នុងរសដែលគួរគោរព បើ
ព្រះអង្គនៅជាបុគ្គលពាល មិនយល់ហេតុអ្វីតទៅយ៉ាងនេះទេ
ព្រះអង្គនឹងឃ្លាត បោះបង់នូវបុត្តទាំងឡាយផង នូវពួក
ញាតិផង ដូចត្រីឈ្មោះអានន្ទត្រឡប់ស៊ីខ្លួនឯង ។ បពិត្រ
ព្រះរាជា សូមសេចក្តីប្រាថ្នារបស់ព្រះអង្គប្រាសចេញទៅព្រោះ
បានទ្រង់ព្រះសណ្តាប់នូវពាក្យនេះ សូមព្រះអង្គកុំសោយសាច់
មនុស្ស បពិត្រព្រះអង្គជាធំជាងសត្វជើងពីរ សូមព្រះអង្គកុំ
ធ្វើដែននេះឲ្យសោះសូន្យ ដូចត្រីឈ្មោះអានន្ទ ធ្វើមហាសមុទ្រ

ទាំងមូលនេះឲ្យសូន្យ ( ចាកត្រី ) ដូច្នេះ ។

ក្នុងសេចក្ដីនោះ មានអធិប្បាយថា បពិត្រមហារាជ ក្នុងកាលកន្លងមក ហើយ មហាសមុទ្ទ មានត្រីមួយឈ្មោះអានន្ទ មានបណ្ដោយ ៥០០ យោជន៍ ជាស្ដេចនៃពួកត្រី អាស្រ័យនៅមួយចំណែកនៃមហាសមុទ្ទ ។ បទថា **ខាទិត្វា** បានដល់ ត្រីអានន្ទនោះជាសត្វជាប់ក្នុងរសរបស់ត្រី ដែលជាជាតិដូចគ្នានឹង ខ្លួន ទើបស៊ីត្រីទាំងឡាយ ។ បទថា **បរិក្ខីណាយ** បានដល់ កាលបរិស័ទ គឺត្រីដល់នូវការអស់ទៅហើយ ។ បទថា **អត្តានំ** បានដល់ មិនបរិភោគ អាហារដទៃ ព័ទ្ធភ្នំមួយទុកខាំស៊ីកន្ទុយរបស់ខ្លួនឯងអស់ ៥០ យោជន៍ដោយ សម្គាល់ថាជាត្រី ហើយដល់នូវការស្លាប់ ឥឡូវនេះ គំនរឆ្អឹងប្រមាណប៉ុនភ្នំ មាននៅក្នុងមហាសមុទ្ទ ។ បទថា **ឯវំ បមត្តោ** បានដល់ ទ្រង់ជាបុគ្គល ជាប់ក្នុងតណ្ហាយ៉ាងនោះ ទ្រង់ប្រមាទហើយ គឺដល់នូវភាពជាអ្នកប្រមាទដូច ត្រីធំឈ្មោះអានន្ទ ។ បទថា **រសគារវេ រត្តោ** សេចក្ដីថា ត្រេកអរហើយ គឺមានព្រះហឫទ័យត្រេកអរក្រៃលែង ក្នុងការសេពរសរបស់សាច់មនុស្ស ។ បទថា **ពាលោ** សេចក្ដីថា បើទ្រង់នៅជាបុគ្គលពាល មានបញ្ញាថោកថយ មិនបានដឹង គឺទ្រង់មិនជ្រាបសេចក្ដីទុក្ខ ដែលកើតឡើងក្នុងអនាគតតទៅ ។ បទថា **វិធម្មំ បុត្តេ ច** បានដល់ ព្រះរាជឱរស ព្រះជាយា និងពួកញាតិ សម្លាញ់ ។ បទថា **វិធម្មំ** បានដល់ កម្ចាត់ គឺការមិនបានអាហារដទៃ ត្រូវ សេចក្ដីស្រេកឃ្លានបៀតបៀន កាលមិនបាននូវសាច់មនុស្ស ក៏នឹងបរិភោគ នូវសាច់ខ្លួនឯង ឈ្មោះថា រមែងស៊ីខ្លួនឯង ដូចត្រីធំឈ្មោះអានន្ទ ដូច្នោះ ។

បទថា **ឥទំ តេ សុត្វាន** សេចក្តីថា បពិត្រមហារាជ ព្រះអង្គទ្រង់ស្តាប់ឧទាហរណ៍ ដែលខ្ញុំនាំមកនិទានដូច្នេះហើយ ។ បទថា **វិគេតុ ឆន្ទោ** សេចក្តីថា សូមការពេញព្រះហឫទ័យរបស់ព្រះអង្គប្រាសទៅ ។ បទថា **មា ភក្ខយិ** បានដល់ បពិត្រព្រះរាជា ទ្រង់កុំសោយ គឺកុំទំពាសាច់មនុស្សទៀតឡើយ ។ បទថា **មា ត្វំ ឥមំ កេវលំ** បានដល់ ដូចត្រីឈ្មោះអានន្ទធ្វើមហាសមុទ្រឲ្យទទេ ។ បទថា **ទ្វិបទាធិប** បានដល់ បពិត្រមហារាជជាធំជាងសត្វជើង ២ សូមទ្រង់កុំធ្វើនគរ គឺដែនកាសីរបស់ព្រះអង្គឲ្យសាបសូន្យ ។

ព្រះរាជាទ្រង់ស្តាប់ពាក្យនោះហើយ ទើបត្រាស់ថា នែកាឡហត្ថីដ៏ចម្រើន លោកចេះរឿងប្រៀបធៀបតែម្នាក់ឯងឬ សូម្បីយើងមិនចេះខ្វះទេឬ ដោយទ្រង់ជាប់ក្នុងសាច់មនុស្ស ទើបនាំរឿងអំពីបុរាណមកសម្តែងជាគាថា ដូច្នេះថា

> កូនបង្កើតរបស់សុជាតកុដុម្ពីក៏នោះ ឈ្មោះសុជាតដោយ
> ឈ្មោះ មិនបានសាច់ព្រីងហើយស្លាប់ទៅ ព្រោះអស់សាច់
> ព្រីងនោះ ( យ៉ាងណា ) ម្នាលកាឡហត្ថី ខ្ញុំបរិភោគនូវ
> អាហារមានរសដ៏ឧត្តម បើមិនបានសាច់មនុស្សទេ ប្រហែល
> ជានឹងលះបង់នូវជីវិត ក៏យ៉ាងនោះដែរ ដូច្នេះ ។

បទថា **តស្ស** បានដល់ របស់កុដុម្ពិកៈឈ្មោះសុជាត ។

មានរឿងតំណាលថា ក្នុងអតីតកាលកុដុម្ពិកៈឈ្មោះថា សុជាត ក្នុងនគរពារាណសី ឃើញឥសី ៥០០ មកអំពីព្រៃហិមពាន្ត ដើម្បីសេពរសជូរប្រៃ និមន្តឥសីទាំងនោះ ឲ្យនៅក្នុងចម្ការរបស់ខ្លួន ហើយទំនុកបម្រុងយ៉ាងល្អ ។ ក្នុង

ផ្ទះកុដុម្ពិកៈនោះ បានរៀបចំភិក្ខា ៥០០ ជានិច្ច តែតាបសនោះ ជួនកាល ក៏ត្រាច់ភិក្ខាក្នុងជនបទ នាំយកសាច់ផ្លែព្រីងធំមកឆាន់ឯងខ្លះ ពេលតាបសទាំង នោះ នាំនូវសាច់ព្រីងមកឆាន់ សុជាតគិតថា លោកម្ចាស់ទាំងឡាយខានមក ៣-៤ ថ្ងៃ ពួកលោកទៅណាហ្ន៎ ទើបឲ្យកូនប្រុសចាប់ម្រាមដៃរបស់ខ្លួន នាំ ទៅកាន់សម្នាក់នៃតាបសទាំងនោះ ក្នុងពេលដែលលោកកំពុងឆាន់ ។ ពេល នោះ តាបសដែលបួសថ្មីជាងគេ ប្រគេនទឹកខ្ពុរមាត់ដល់តាបសដែលជាធំ រួច ឆាន់ចំណិតព្រីង សុជាតថ្វាយបង្គំពួកតាបសហើយអង្គុយ សួរថា លោក ម្ចាស់ឆាន់អ្វី ពួកតាបសឆ្លើយថា អាវុសោ ពួកយើងឆាន់ចំណិតព្រីងធំ កុមារ បានឮដូច្នោះ ក៏កើតចំណង់ឡើង ។ គ្រានោះ តាបស ដែលជាមេគណៈ ក៏ឲ្យកុមារនោះបន្តិច កុមារបរិភោគចំណិតព្រីងនោះហើយ ជាប់ចិត្តក្នុងរស រំអុករឿយៗថា សូមពុកឲ្យចំណិតព្រីងដល់ខ្ញុំ សូមពុកឲ្យចំណិតព្រីងដល់ខ្ញុំ ដូច្នេះ កុដុម្ពិកៈកំពុងស្តាប់ធម៌ បញ្ឆោតកូនថា កុំយំឡើយ ឯងត្រឡប់ទៅ ផ្ទះហើយនឹងបានបរិភោគ គាត់ត្រិះរិះថា លោកម្ចាស់ទាំងឡាយ នឹងរំខាន ព្រោះអាស្រ័យកូនរបស់អញនេះ លួងកូនមិនបាត់ ក៏លាពួកឥសី ទៅផ្ទះ តាំងអំពីទៅដល់ផ្ទះហើយ បុត្តរបស់គាត់ ក៏ទាររឿយៗថា សូមពុកឲ្យចំណិត ព្រីងដល់ខ្ញុំ ។ ពួកឥសីពោលថា យើងនៅក្នុងទីនេះយូរហើយ ទើបនាំគ្នា ត្រឡប់ទៅព្រៃហិមពាន្ត កុដុម្ពិកៈមិនជួបឥសីក្នុងចម្ការ បានឲ្យចំណិតផ្លែឈើ មានស្វាយ ព្រីង ខ្នុរ និងចេកជាដើមដែលជ្រលក់ដោយទឹកឃ្មុំ ស្ករ ដល់កូន តែចំណិតផ្លែឈើទាំងនោះ គ្រាន់តែពាល់ត្រូវចុងអណ្តាត ក៏ប្រែកជហាក់ដូច

ថ្នាំពិសដ៏ខ្លាំងក្លា កុមារមិនបរិភោគអាហារអស់ ៧ ថ្ងៃ ក៏ដល់នូវការអស់ជីវិត ព្រះរាជាកាលនាំហេតុនេះមកសម្តែង ទើបពោលពាក្យយ៉ាងនេះ ។ បទ **តស្ស សង្ខយេ** អធិប្បាយថា កូនរបស់សុជាត មិនបរិភោគអាហារដទៃស្លាប់ហើយព្រោះអស់ទៅនៃចំណិតព្រីងនោះ ។ បទថា **ភក្ខំ** បានដល់ របស់ទំពា ។ បទថា **រសុត្តមំ** បានដល់ មានរសដ៏ឧត្តម ។ បទថា **ហោស្សាមិ** បានដល់ នឹងលះជីវិត ព្រះបាលីជា **ហិស្សាមិ** ដូច្នេះ ក៏មាន ។

លំដាប់នោះ កាឡហត្ថីសេនាបតីគិតថា ព្រះរាជានេះជាប់ក្នុងរសពន់ពេក អញនឹងនាំឧទាហរណ៍ដទៃៗមកសម្តែងដល់ទ្រង់ទៀត ហើយទូលថា បពិត្រមហារាជ សូមទ្រង់វៀរចោលចុះ ព្រះរាជាត្រាស់ថា យើងមិនអាចវៀរសាច់មនុស្សបានទេ កាឡហត្ថីសេនាបតីក្រាបទូលថា បើទ្រង់មិនវៀរ ទ្រង់នឹងវិនាសចាកព្រះញាតិវង្ស និងសិរីរាជសម្បត្តិ ហើយនិទានរឿងថ្វាយដូចតទៅនេះថា

បពិត្រមហារាជ ក្នុងអតីតកាល ក្នុងនគរពារាណសីនេះ មានត្រកូលសេដ្ឋីអ្នករក្សាសីល ៥ មួយត្រកូល ត្រកូលនោះមានកូនប្រុសម្នាក់ ជាទីស្រឡាញ់ ពេញចិត្តរបស់មាតាបិតា ជាអ្នករៀនចប់នូវត្រៃវេទ មាណពនោះបានទៅសេពគប់ជាមួយមិត្តកក្រកំលោះៗ ដែលមានវ័យស្រករគ្នា មិត្តទាំងនោះបរិភោគត្រីនិងសាច់ជាដើម ហើយផឹកសុរា តែមាណពមិនបរិភោគសាច់ មិនផឹកសុរា ពួកមិត្តទាំងនោះក៏គិតថា មាណពនេះមិនផឹកសុរា នឹងមិនចេញថ្លៃសុរាឲ្យដល់ពួកយើង ពួកយើងនឹងរកឧបាយឲ្យគេផឹកសុរាឲ្យបាន ពួក

មិត្តកក្រទាំងនោះ ក៏ប្រជុំគ្នាពោលថា នែសម្លាញ់ ពួកយើងនឹងលេងមហោស្រពក្នុងឧទ្យាន កុមារពោលថា នែសម្លាញ់ ពួកឯងផឹកស្រា ខ្ញុំមិនផឹក ពួកឯងចូរនាំគ្នាទៅចុះ សម្លាញ់ទាំងនោះពោលថា យើងនឹងឲ្យទឹកដោះដល់ឯងផឹក ។ មាណពនោះ ក៏ទទួលថា សាធុ ។ ពួកអ្នកលេងទៅដល់ឧទ្យានហើយក៏ខ្ចប់សុរាជាច្រើនកញ្ចប់ទុកក្នុងស្លឹកឈូក ។ លំដាប់នោះ ដល់កាលដែលពួកគេផឹកសុរា ទើបគេបញ្ជូនទឹកដោះឲ្យមាណពអ្នកលេងម្នាក់ពោលឡើងថា នែសម្លាញ់ ចូរអ្នកយកទឹកឃ្មុំក្នុងស្លឹកឈូកមកឲ្យយើង ឲ្យពួកសម្លាញ់នាំកញ្ចប់សុរានោះមកហើយ ចាប់កញ្ចប់ស្លឹកឈូកបោះឲ្យជាប្រហោងខាងក្រោមយកដៃបិទប្រហោង ហើយលើកមកផឹក សូម្បីសម្លាញ់ទាំងនោះ ក៏នាំមកយ៉ាងនោះ មាណពសួរថា កញ្ចប់នោះជាអ្វី មិត្តកក្រទាំងនោះក៏ប្រាប់ថា នេះជាបោក្ខរមធុ គឺទឹកឃ្មុំក្នុងស្លឹកឈូក មាណពសួរថា ឲ្យខ្ញុំសុំភ្លក្សបន្តិចចុះ ពួកអ្នកលេងទាំងនោះនិយាយថា ឲ្យគេភ្លក្សមើលបន្តិច ហើយហុចទៅឲ្យមាណពនោះផឹកស្រា ដោយសម្គាល់ថា បោក្ខរមធុ ។ គ្រានោះ ពួកមិត្តកក្របានឲ្យសាច់អាំងដល់គេ មាណពបានបរិភោគសាច់អាំងនោះហើយ កាលមាណពនោះផឹកយ៉ាងនេះរឿយៗ ក៏ស្រវឹង ក្នុងវេលាដែលគេស្រវឹងហើយពួកសម្លាញ់ទាំងនោះ ក៏ប្រាប់ថា នុ៎ះមិនមែនបោក្ខរមធុ នុ៎ះឯងជាសុរា ។ មាណពនោះពោលថា យើងមិនដឹងថាឆ្ងាញ់យ៉ាងនេះមកអស់កាលមានប្រមាណប៉ុណ្ណោះ អ្នកដ៏ចម្រើនទាំងឡាយ ចូរនាំសុរាមកទៀត ។ ពួកអ្នកលេងទាំងនោះ ក៏បានឲ្យសុរាទៀត មាណពនោះបានជាអ្នកចង់ផឹកយ៉ាងខ្លាំង កាល

សូមគេរឿយ ៗ សម្លាញ់ទាំងនោះក៏ប្រាប់ថា អស់ហើយ មាណពក៏ដោះចិញ្ចៀនឲ្យ ពោលថា ចូរទៅយកសុរាមកចុះសម្លាញ់ គេផឹកជាមួយពួកសម្លាញ់មួយថ្ងៃទល់យប់ ស្រវឹងរហូតភ្នែកក្រហម មានខ្លួនញ័រ និយាយផ្ដេសផ្ដាស ទៅដល់ផ្ទះហើយក៏ដេក ។ សម័យនោះ បិតារបស់គេដឹងថាកូនប្រុសផឹកសុរា កាលកូនស្វាងហើយ ក៏ពោលថា នែកូន ឯងកើតមកក្នុងត្រកូលសេដ្ឋី ធ្វើនូវការផឹកសុរាមិនសមគួរឡើយ កុំប្រព្រឹត្តយ៉ាងនេះទៀតឡើយ បុរសនោះឆ្លើយថា បពិត្រលោកឪពុក ខ្ញុំមានកំហុសអ្វី ឪពុកឆ្លើយថា ឯងមានកំហុសព្រោះផឹកសុរា កូននោះពោលថា លោកឪពុកនិយាយអ្វីសេចក្ដីបែបនេះ ខ្ញុំមិនធ្លាប់បរិភោគ អស់កាលយូរ មានប្រមាណប៉ុណ្ណោះ ព្រាហ្មណ៍ជាបិតា ក៏សំណូមពររឿយៗ សូម្បីមាណពនោះ ក៏នៅតែពោលពាក្យដដែលថា ខ្ញុំមិនអាចវៀរការផឹកនេះបានទេ ។ លំដាប់នោះ ព្រាហ្មណ៍គិតថា កាលបើដូច្នេះ វង្សត្រកូលរបស់អញគង់នឹងដាច់សូន្យពិត ទាំងទ្រព្យក៏នឹងវិនាស ហើយពោលគាថានេះថា

ម្នាលមាណពកូន អ្នកមានរូបស្រស់បស់ កើតក្នុងត្រកូល
សោត្ថិយៈ ម្នាលកូន អ្នកមិនគួរស៊ីនូវអាហារដែលមិនគួរស៊ី
ទេ ដូច្នេះ ។

បទថា **អភក្ខំ ភក្ខយេតវេ** ក្នុងគាថានោះ សំដៅដល់ មិនសមគួរបរិ-ភោគនូវរបស់មិនសមគួរឡើយ ។

កាលពោលយ៉ាងនេះហើយ បិតាក៏ពោលបន្តថា ចូរបារៀរចុះ បើបាមិន

វៀរ បានឹងត្រូវឃ្លាតចាកសម្បត្តិក្នុងផ្ទះនេះ យើងនឹងនិទេសចេញអំពីដែន មាណពពោលថា ទោះបីលោកឪពុកធ្វើយ៉ាងនេះ ខ្ញុំក៏នឹងចេញទៅ ខ្ញុំមិនអាចលះសុរាបាន ដូច្នេះហើយ ពោលគាថា ២ ថា

បណ្តារសទាំងឡាយ ទឹកសុរានេះ រាប់ថាជាទឹកមានរសមួយដែរ ព្រោះហេតុអ្វីទើបលោកឪពុកឃាត់ខ្ញុំ ខ្ញុំបាននូវទឹកសុរានេះក្នុងទីណា ខ្ញុំនឹងទៅក្នុងទីនោះ ។ បពិត្រព្រាហ្មណ៍ឪពុក បើលោកឪពុកមិនត្រេកអរនឹងការឃើញខ្ញុំណា ខ្ញុំនោះ នឹងគេចចេញ ( អំពីស្រុក ) ខ្ញុំមិននៅក្នុងសំណាក់លោកឪពុកទេដូច្នេះ ។

បទថា **រសានំ** ក្នុងគាថានោះ អធិប្បាយថា រសទាំង ៧ យ៉ាង គឺរសប្រៃ រសជូរ រសល្វីង រសហឹរ រសហាង រសផ្អែម និងរសចត់ ឈ្មោះថាទឹកស្រវឹងនេះ ចាត់ជារសដ៏ប្រសើរមួយបែប ។ បទថា **សោវាហាំ** សំដៅដល់ ខ្លួនខ្ញុំម្នាក់ប៉ុណ្ណោះ ។ បទថា **និប្បតិស្សាមិ** បានដល់ នឹងចេញអំពីផ្ទះ ។

មាណពកាលពោលយ៉ាងនេះហើយ ក៏ពោលបន្តថា ខ្ញុំនឹងមិនឈប់ផឹកសុរា សូមលោកឪពុកធ្វើតាមគាប់ចិត្តចុះ ។ ព្រាហ្មណ៍ពោលថា បើឯងលះបង់អញបាន អញក៏លះបង់ឯងបានដូចគ្នា ហើយពោលគាថានេះថា

នែមាណពកូន យើងនឹងបាននូវកូនទាំងឡាយឯទៀតទទួលមត៌កដោយពិត នែកូនជួជាតិ ឯងចូរវិនាសចុះ លំនៅដែល

កូនទៅដល់ក្នុងទីណា សូមកុំឲ្យអញឮនូវទីនោះ ដូច្នេះ ។

បទថា **យត្ថ បត្តំ** ក្នុងគាថានោះ អធិប្បាយថា ឯងទៅក្នុងទីណា យើងមិនបានឮថា ឯងនៅក្នុងទីនោះ ចូរឯងទៅក្នុងទីនោះចុះ ។

លំដាប់នោះ ព្រាហ្មណ៍ជាបិតា នាំខ្លួនមាណពនោះទៅកាន់សាលា ធ្វើមិនឲ្យជាកូន បណ្តេញចេញអំពីផ្ទះ ។ មាណពនោះ ក្នុងកាលជាខាងក្រោយមកក្លាយខ្លួនជាមនុស្សកំព្រា មិនមានទីពឹង ស្លៀកសំពត់ចាស់ៗ កាន់អំបែងដើរសូមទាន អាស្រ័យសំយាបផ្ទះអ្នកដទៃណាមួយអស់ជីវិតហើយ កាលហត្ថីសេនាបតី នាំហេតុនេះមកសម្តែងដល់ព្រះរាជា ហើយក្រាបទូលថា បពិត្រមហារាជ បើទ្រង់មិនធ្វើតាមពាក្យរបស់ទូលព្រះបង្គំ ពួកអ្នកនគរនឹងធ្វើការនិទ្ទេសព្រះអង្គចោលពិត ហើយពោលបន្តថា

បពិត្រព្រះមហាក្សត្រ ជាធំជាងសត្វជើងពីរ សូមព្រះអង្គ
ទ្រង់ព្រះសណ្តាប់ខ្ញុំ ពួកប្រជាជន នឹងបណ្តេញព្រះអង្គចាក
ដែន ដូចមាណពអ្នកលេងស៊ីផឹកដូច្នោះ ។

កាឡហត្ថីសេនាបតីបាននាំរឿងឧបមាផ្សេង ៗ មកនិទានថ្វាយយ៉ាងនេះ ព្រះរាជាក៏មិនអាចអត់សាច់នោះបាន ត្រាស់ឧបមាប្រៀបធៀបផ្សេងៗ ដោយគាថានេះថា

សាវករបស់ពួកឥសីអ្នកមានខ្លួនអប់រំហើយ ជាសាវកឈ្មោះ
សុជាត ប្រាថ្នានូវស្រីអប្សរ ទើបសាវកនោះមិនស៊ី មិនផឹក
ទេ ។

បុគ្គលយកទឹកដោយចុងស្មៅមកប្រៀបផ្ទឹមនឹងទឹកក្នុងសមុទ្រ
យ៉ាងណា កាមទាំងឡាយជារបស់មនុស្ស ( ប្រៀបផ្ទឹម )
ក្នុងសំណាក់នៃកាមជាទិព្វ ក៏យ៉ាងនោះដែរ ។ ម្នាលកាឡ
ហត្ថិ ខ្ញុំបរិភោគនូវអាហារមានរសដ៏ឧត្ដម បើមិនបានសាច់
មនុស្សទេ ប្រហែលជាលះបង់ជីវិត យ៉ាងនោះឯង ដូច្នេះ ។

រឿងដូចរឿងដែលពោលទុកខាងដើមនោះឯង បទថា **ភាវិតត្ដាន** សំដៅ សំដៅ ដល់ឥសីទាំង ៥០០ រូបដែលបានអប់រំខ្លួនមកហើយ ។ បទថា **អដ្ឋរំ កាមយន្ដោវ** អធិប្បាយថា បានឮថា ក្នុងកាលពួកឥសីទាំងនោះ ធាន់ចំណិតព្រៃធំ ( ព្រៃប្រចាំទ្វីប ) សុជាតជ្រាបថា ឥសីខានមកយូរពិត ទើបគិតថា លោកមិនមកដោយហេតុណាហ្ន៎ លោកទៅណាហ្ន៎ អញនឹងជ្រាប បើលោកមិនបានទៅ អញនឹងបានស្ដាប់ធម៌ក្នុងសម្នាក់របស់លោក ហើយទៅកាន់ចម្ការ ថ្វាយបង្គំបាតជើងរបស់ឥសីទាំងឡាយ អង្គុយស្ដាប់ធម៌ ក្នុងសម្នាក់របស់មេគណៈ កាលព្រះអាទិត្យអស្ដង្គតហើយ ម្ចាស់គណៈប្រាប់ ឲ្យត្រឡប់ ទើបពោលថា ថ្ងៃនេះ ខ្ញុំស្នាក់នៅចម្ការនេះ ថ្វាយបង្គំពួកឥសី ហើយចូលទៅកាន់បណ្ណសាលា រួចក៏ដេក លុះដល់កណ្ដាលយប់ សក្កទេវរាជមានពួកអប្សរចោមរោមហើយ មកថ្វាយបង្គំពួកឥសី មួយអន្លើដោយបរិចារិការបស់ខ្លួន ចម្ការទាំងមូលមានពន្លឺតែមួយ សុជាតគិតថា នុ៎ះអ្វីហ្ន៎ ទើបក្រោកឡើង សម្លឹងមើលតាមប្រហោងបណ្ណសាលា ឃើញសក្កទេវរាជ មកថ្វាយបង្គំពួកឥសី មានស្រីទេពអប្សរចោមរោម ក៏មានតម្រេកកើតឡើង

ដោយអំណាចរាគៈ ព្រមជាមួយនឹងការបានឃើញពួកស្រីអប្សរ សក្កទេវរាជ ប្រថាប់គន់ស្តាប់ធម្មកថាហើយ យាងត្រឡប់ទៅកាន់តាវត្តិង្សពិភពរបស់ព្រះអង្គ ។ ឯកុដុម្ពិកៈ លុះដល់ថ្ងៃរះឡើង បានថ្វាយបង្គំពួកឥសី ហើយសួរថា អ្នកណាមកថ្វាយបង្គំលោកម្ចាស់ទាំងឡាយកាលពីយប់មិញនេះពួកឥសីឆ្លើយថា នែអាវុសោ នុ៎ះគឺព្រះឥន្ទ សុជាតសួរបន្តថា អ្នកដែលអង្គុយចោមរោមព្រះឥន្ទនោះជានរណា ពួកឥសីឆ្លើយថា នុ៎ះជាទេពអប្សរ ។ សុជាតថ្វាយបង្គំហើយត្រឡប់ទៅផ្ទះ តាំងពីកាលដែលគេទៅដល់ផ្ទះហើយ ក៏ពោលរវើរវាយថា សូមលោកឲ្យទេពអប្សរដល់ខ្ញុំ សូមលោកឲ្យទេពអប្សរដល់ខ្ញុំចុះ ។ លំដាប់នោះ ពួកញាតិក៏ចោមរោមសម្គាល់ថា សុជាតត្រូវខ្មោចចូល ទើបផ្ទាត់ម្រាមដៃ កុដុម្ពិកៈនោះពោលថា ខ្ញុំមិនបានពោលដល់អប្សរនេះ តែខ្ញុំពោលដល់ទេពអប្សរ ។ ពួកញាតិទាំងនោះ ក៏បានតែងខ្លួនកិរិយា និងស្រីពេស្យា នាំមកបង្ហាញថា នេះទេពអប្សរ សុជាតមើលហើយ ក៏ពោលថា នេះមិនមែនទេពអប្សរ នេះជាយក្ខិនី ហើយរវើរវាយបន្តថា ចូរឲ្យទេពអប្សរដល់ខ្ញុំ មិនបរិភោគអាហារ ដល់នូវការអស់ជីវិតក្នុងផ្ទះរបស់ខ្លួននោះឯង ព្រោះហេតុនោះ ទើបព្រះរាជាត្រាស់ថា

សាវករបស់ពួកឥសីអ្នកមានខ្លួនអប់រំហើយ ជាសាវក ឈ្មោះ
សុជាត ។បេ។ កាមទាំងឡាយជារបស់មនុស្ស ( ប្រៀប
ផ្ទឹម ) ក្នុងសំណាក់នៃកាមជាទិព្វ ក៏យ៉ាងនោះដែរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សមុទ្ទេ ឧទកំ មិនេ** សេចក្តីថា នៃកាឡ-

ហត្ថីសម្លាញ់ បុគ្គលណាកាន់យកទឹកដោយចុងស្បូវ នាំមកហើយប្រៀបធៀប នឹងទឹកក្នុងមហាសមុទ្ទថា ទឹកក្នុងមហាសមុទ្ទមានប្រមាណប៉ុណ្ណេះ ដូច្នេះ បុគ្គលនោះគប្បីប្រៀបធៀបបានដូចម្តេច ព្រោះថា ទឹកក្នុងចុងស្បូវភ្លាំង មាន ប្រមាណតិចតួច បើប្រៀបធៀបក្នុងកាមរបស់មនុស្សក្នុងសម្នាក់នៃកាមជា ទិព្វ ក៏ដូចគ្នាដូច្នោះ ព្រោះហេតុនោះ ទើបសុជាតមិនសម្ញឹងមើលស្រីដទៃ ប្រាថ្នា ទេពអប្សរតែម្យ៉ាង ក៏ដល់នូវសេចក្តីស្លាប់ ។ បទថា **ឯវមេវ** បានដល់ ព្រះ រាជាត្រាស់ថា សុជាតនោះ កាលមិនបានកាមដែលជាទិព្វ ក៏លះបង់ជីវិតទៅ ហើយ យ៉ាងណា សូម្បីខ្លួនយើង ក៏យ៉ាងនោះ បើមិនបានសាច់មនុស្សដែល មានរសជាតិដ៏ឧត្តម ក៏នឹងលះបង់នូវជីវិតយ៉ាងនោះ ។

កាឡហត្ថិបានស្តាប់ដូច្នោះ ទើបគិតថា ព្រះរាជាអង្គនេះទ្រង់ជាប់ក្នុងរស ពន់ពេក នឹងទូលតឿនឲ្យទ្រង់ដឹងខ្លួន ទើបសម្តែងរឿងប្រៀបធៀបថា សុវណ្ណ ហង្សមួយ ហើរទៅក្នុងអាកាស ស៊ីសាច់សត្វដែលមានជាតិដូចគ្នា ក៏វិនាស មកហើយ ទើបពោលគាថា ២ ថា

> ដូចយ៉ាងពួកបក្សីហង្សឈ្មោះ ធតរដ្ឋ ទាំងនោះ ជាសត្វហើរ
> ក្នុងអាកាស ដល់នូវសេចក្តីវិនាសទាំងអស់គ្នា ព្រោះស៊ីនូវ
> ចំណីមិនគួរ ។ បពិត្រព្រះរាជា ជាធំជាងសត្វជើងពីរ សូម
> ព្រះអង្គទ្រង់ព្រះសណ្តាប់ខ្ញុំ បពិត្រព្រះរាជា ព្រះអង្គកុំសោយ
> អាហារដែលមិនគួរសោយ ក៏យ៉ាងនោះឯង ពួកប្រជាជននឹង
> បណ្តេញព្រះអង្គ ( ចាកដែន ) ក៏យ៉ាងនោះដែរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អយុត្តបរិភោគេន** បានដល់ ព្រោះបរិភោគអាហារដែលមិនមែនជាការចិញ្ចឹមជីវិតរបស់ខ្លួន ។ បទថា **អត្តត្ថំ គតា** បានដល់ ដល់នូវការស្លាប់ទាំងអស់ ។

បានឮថា ក្នុងអតីតកាល ហង្ស ៩ ម៉ឺន ស៊ីស្រូវសាលីនៅក្នុងសុវណ្ណគុហា ត្រង់ភ្នំចិត្តកូដ ហង្សទាំងនោះ មិនព្រមចេញពីគុហាអស់ ៤ ខែ បើចេញទៅស្លាបនឹងសើម មិនអាចហើរបាន នឹងធ្លាក់នៅក្នុងមហាសមុទ្រ ព្រោះហេតុនោះ ទើបមិនព្រមចេញក្រៅគុហា កាលដល់រដូវភ្លៀង ក៏នាំស្រូវសាលីដែលកើតឯងតាមធម្មជាតិ មកអំពីជាតស្រះ ដាក់ពេញគុហា ស៊ីស្រូវសាលីនោះជាមួយគ្នា ក្នុងកាលដែលហង្សទាំងនោះចូលទៅកាន់គុហាហើយ ពីងពាងមួយមានខ្លួនប៉ុនកង់រទេះ សន្ទឹងសំណាញ់ត្រង់ទ្វារគុហាម្ដងមួយសរសៃៗ សរសៃរបស់ពីងពាងនេះប៉ុនខ្សែសម្រាប់ចងគោ ពួកហង្សគិតនឹងទម្លាយសំណាញ់ពីងពាងនោះ ឲ្យអាហារដល់ហង្សជំទង់មួយដោយចំណែក ២ ដងហង្សជំទង់នោះ កាលរដូវភ្លៀងអស់ហើយ ទើបបើកផ្លូវមុនគេ ទម្លាយសំណាញ់ពីងពាងនោះចេញទៅ ហង្សក្រៅពីនោះ ក៏ចេញទៅតាមផ្លូវនោះ ។ សម័យមួយ ភ្លៀងធ្លាក់រហូតដល់ ៥ ខែ ហង្សទាំងនោះក៏អស់ស្បៀង ប្រឹក្សាគ្នាថា នឹងធ្វើដូចម្ដេចហ្ន៎ ក៏សម្រេចគ្នាថា បើយើងទាំងឡាយនៅមានជីវិតនឹងបានពងទៀត ទើបស៊ីពងជាមុន បន្ទាប់មក ក៏ស៊ីកូនហង្ស បន្ទាប់មក ក៏ស៊ីហង្សចាស់ៗ កាលរដូវភ្លៀងពន្យាដល់ ៥ ខែ ពីងពាងក៏សន្ទឹង សរសៃបាន ៥ សរសៃ ពួកហង្សស៊ីសាច់គ្នាឯង ជាសត្វមានកម្លាំងតិច ហង្សជំទង់បាន

អាហារ ២ ចំណែក ទាញជាប់តែ ៤ សរសៃ ទាញសរសៃ ទី ៥ មិនជាប់ ជាប់នៅត្រង់នោះឯង ត្រូវពីងពាងចោះត្រង់ក្បាល បឺតឈាម សូម្បីហង្សដទៃមកក៏ជាប់ត្រង់សរសៃនោះទៀត ដោយទំនងនេះ ត្រូវពីងពាងបឺតឈាមទាល់តែអស់ បានឮថា ត្រកូលធតរដ្ឋហង្សបានសាបសូន្យក្នុងកាលនោះ ព្រោះហេតុនោះ ទើបកាឡហត្ថិសេនាបតីពោលថា **សព្វេ អត្តត្ថតំ គតា** ដូច្នេះ ។

ក្នុងគាថាទី ២ មានអធិប្បាយថា ហង្សទាំងនោះ ស៊ីសាច់របស់សត្វដែលមានជាតិដូចគ្នា ដែលមិនគួរនឹងបរិភោគ យ៉ាងណា សូម្បីព្រះអង្គ ក៏បរិភោគសាច់ដែលមិនសមគួរបរិភោគ យ៉ាងនោះដូចគ្នា ខណៈនេះ ព្រះនគរទាំងមូល កើតភ័យឡើងហើយ ។ បទថា **តស្មា បព្វាជិស្សន្តិ តំ** សេចក្តីថា បពិត្រមហារាជ សូមទ្រង់វៀរចុះ ព្រោះហេតុដែលព្រះអង្គសោយសាច់មនុស្សដែលមានជាតិស្មើគ្នា មិនមែនជាអាហារដែលគួរបរិភោគ ព្រោះហេតុនោះ អ្នកនគរទាំងនេះ នឹងនាំគ្នាបណ្តេញព្រះអង្គចេញអំពីដែន ។

ព្រះរាជាទ្រង់ក៏មានបំណង នាំរឿងដទៃមកប្រៀបធៀបទៀត តែអ្នកនគរក្រោកឡើងស្រែកថា លោកសេនាបតីធ្វើអ្វី យកចោរស៊ីសាច់មនុស្សទុកធ្វើអ្វី សូមនិរទេសទ្រង់អំពីដែន កុំឲ្យទ្រង់ត្រាស់តទៅទៀត ព្រះរាជាបានស្តាប់ពាក្យរបស់មហាជន ភិតភ័យ មិនអាចត្រាស់បន្តទៅទៀតបាន សេនាបតីក្រាបទូលបន្តថា បពិត្រមហារាជ ទ្រង់អាចវៀរបានដែរឬទេ កាលព្រះរាជាត្រាស់ថា មិនអាច ទើបរៀបចំស្រីស្នំដែលទ្រង់សព្វព្រះហឫទ័យ មួយអន្លើដោយព្រះរាជឱរសនិងព្រះរាជធីតា ដែលប្រដាប់ដោយគ្រឿងអលង្ការ ឲ្យ

ចូលមកគាល់ព្រះរាជា ក្រាបទូលថា បពិត្រមហារាជ សូមទ្រង់ទតព្រះញាតិវង្សានុវង្សនិងពួកអាមាត្យនិងសិរីរាជសម្បត្តិនេះ ទ្រង់កុំវិនាស ព្រាត់ប្រាសចាកវត្ថុទាំងនេះឡើយ សូមទ្រង់វៀរចាកការសោយសាច់មនុស្សចុះ ព្រះរាជាត្រាស់ថា មនុស្សនិងសម្បត្តិទាំងនេះមិនជាទីស្រឡាញ់របស់យើង ជាងសាច់មនុស្សឡើយ កាលសេនាបតីក្រាបទូលថា បើដូច្នោះ សូមទ្រង់យាងចេញអំពីនគរនិងដែននេះ ទើបត្រាស់ថា នែកាឡហត្ថិសេនាបតី យើងមិនត្រូវការរាជសម្បត្តិ យើងព្រមចេញអំពីព្រះនគរ យើងសុំតែដាវ ១ អ្នកពិសេសម្នាក់ និងឆ្នាំងមួយប៉ុណ្ណោះ កាលនោះ អ្នកនគរក៏ឲ្យដាវ ១ ឆ្នាំង សម្រាប់ចម្អិនសាច់មនុស្ស ១ ល្អីនិងចុងភៅម្នាក់ ថ្វាយព្រះរាជានោះហើយ និរទេសចេញពីដែន ព្រះរាជាកាន់ដាវនាំចុងភៅចេញពីព្រះនគរចូលព្រៃ បោះជម្រកក្រោមដើមជ្រៃមួយកន្លែងក្នុងទីនោះ ចាំស្ទាក់ត្រង់កណ្តាលព្រៃ សម្លាប់មនុស្សដែលទៅមក ហើយនាំមកឲ្យអ្នកពិសេសចម្អិន ។ អ្នកពិសេសចម្អិនឆ្អិនហើយថ្វាយព្រះរាជា ជនទាំងពីររស់នៅយ៉ាងនេះ ។ កាលព្រះរាជាស្រែកថា យើងជាចោរឈ្មោះបោរិសាទហើយរត់ទៅ មិនមានអ្នកណាម្នាក់អាចតាំងនៅដោយសភាពរបស់ខ្លួនបាន ដួលចុះក្នុងផែនដីទាំងអស់ ក្នុងមនុស្សទាំងនោះ ព្រះរាជាប្រាថ្នាអ្នកណា ក៏ធ្វើអ្នកនោះឲ្យមានជើងឡើងលើ ឲ្យមានក្បាលចុះក្រោម នាំមកឲ្យចុងភៅ ថ្ងៃមួយ មិនបានសាច់មនុស្សក្នុងព្រៃ ត្រឡប់មក កាលអ្នកពិសេសទូលថា បពិត្រព្រះអង្គ យើងនឹងធ្វើដូចម្តេច ព្រះរាជាក៏ត្រាស់ថា លើកឆ្នាំងដាក់លើជើងប្រានចុះ អ្នកពិសេសសួរថា សាច់នៅឯណា

ក៏ត្រាស់ថា យើងនឹងបានសាច់ ។ អ្នកពិសេសមានខ្លួនញ័រចំប្រប់ គិតថា ជីវិតរបស់អញគង់មិនរួចផុតពិត ថ្វាយបង្គំព្រះរាជាហើយ យំបណ្ដើរបង្កាត់ភ្លើងបណ្ដើរ លើកឆ្នាំងដាក់លើជើងក្រាន ។ កាលនោះ ព្រះបាទបោរិសាទក៏កាប់អ្នកពិសេសនោះដោយដាវ ហើយធ្វើសាច់ឲ្យឆ្អិនល្អ ដោយព្រះអង្គឯងស្រេចហើយក៏សោយ តាំងអំពីនោះមក ក៏រស់នៅឯកអង្គ បានមនុស្សមកត្រូវធ្វើបរិភោគខ្លួនឯង ។ រឿងស្ដេចបោរិសាទស្កាត់ផ្លូវមនុស្ស បានល្បីរន្ទឺពេញជម្ពូទ្វីបហើយ ។

## បញ្ចជនីយកណ្ឌ ចប់

កាលនោះ ព្រាហ្មណ៍ម្នាក់ មានសម្បត្តិបរិបូណ៌ ប្រកបពាណិជ្ជកម្ម ដោយរទេះ ៥០០ ធ្វើដំណើរឆ្លងព្រៃ គិតថា បានឮថា ចោរបោរិសាទសម្លាប់អ្នកដំណើរជាច្រើន អញនឹងជួលមនុស្សឲ្យជូនអញឆ្លងព្រៃនេះ ហើយឲ្យទ្រព្យ ១០០០ ដល់អ្នករក្សាព្រៃ ពោលថា ចូរអ្នកជួយនាំយើងឲ្យឆ្លងផុតព្រៃផងចុះ រួចធ្វើដំណើរទៅជាមួយមនុស្សទាំងនោះ កាលទៅ ក៏ឲ្យពួករទេះទាំងអស់ទៅមុន ចំណែកខ្លួនឯងងូតទឹកលាបស្រឡាបយ៉ាងល្អ រួចប្រដាប់ដោយគ្រឿងអលង្ការទាំងពួង អង្គុយលើយានតូចដែលជាទីសប្បាយ ទឹមដោយគោស មានអ្នកនាំផ្លូវចោមរោមទៅខាងក្រោយគេបង្អស់ ខណៈនោះ ចោរបោរិសាទឡើងដើមឈើសម្លឹងមើល មិនពេញចិត្តមនុស្សដទៃៗ ដោយគិតថា អញនឹងស៊ីជនទាំងនោះធ្វើអ្វី លុះឃើញព្រាហ្មណ៍ ក៏ចង់ស៊ីរហូតដល់ស្រក់ទឹកមាត់ កាលព្រាហ្មណ៍នោះចូលមកក្បែរ ទើបចុះអំពីដើមឈើប្រកាស

ឈ្មោះថា រ៉ិយ អញនេះ គឺចោរបោរិសាទ ៣ ដងហើយ រត់ត្រវីដាវ ហាក់ឲ្យដូចជាធ្វើកែវភ្នែករបស់មនុស្សទាំងនោះ ពេញដោយខ្សាច់ មិនមាននរណាម្នាក់ដែលអាចតម្កល់ខ្លួនបាន ក្រាបរាបដល់ដីទាំងអស់ ស្ដេចបោរិសាទចាប់ព្រាហ្មណ៍ដែលអង្គុយត្រង់យានតូចដែលជាទីសប្បាយនោះ ត្រង់ជើងពំនាក់លើខ្នង ឲ្យមានក្បាលចុះក្រោម ទង្គិចក្បាលដោយកែងជើង ហើយពុនទៅ ។

ពួកអ្នកស៊ីឈ្នួលជូនដំណើរ ក្រោកឡើងបាន ទើបពោលថា រ៉ិយ ពួកយើងទទួលកហាបណៈ ១០០០ ពីដៃរបស់ព្រាហ្មណ៍ ការធ្វើកិច្ចការរបស់កូនប្រុសនៃពួកយើងអាច ឬមិនអាច ទោះជាយ៉ាងណា សាកល្បងជួយគ្នាដេញតាមសាកមើលបន្តិចចុះ ពោលហើយ ក៏នាំគ្នាដេញតាមទៅ ។ ឯស្ដេចបោរិសាទ កាលត្រឡប់ក្រោយ មិនឃើញនរណាមួយ ក៏ដើរសន្សឹមៗទៅ ខណៈនោះ បុរសក្លាហានសម្បូរដោយកម្លាំងម្នាក់ រត់តាមទៅដោយរហ័សទាន់ស្ដេចបោរិសាទ ស្ដេចបោរិសាទឃើញមនុស្សទាំងនោះ ទើបលោតឆ្លងរបងមួយកន្លែង បែជន់ក៏ធ្លាក់មកជង់ជន្ទត់គគីរមុតធ្លុះដល់ខ្នងជើង ឈាមហូរខ្លាំង ក៏ដើរខ្វិកៗ ទៅ ។ បុរសនោះឃើញអាការដូច្នោះ ទើបស្រែកថា ចោរត្រូវយើងចាក់ហើយរ៉ិយ ពួកយើងចូរមកឲ្យរហ័ស ចាប់វាឲ្យបាន មនុស្សទាំងនោះ ដឹងថា ស្ដេចបោរិសាទមានរបួស ទើបដេញតាមទៅព្រមគ្នា ស្ដេចបោរិសាទដឹងថា ជនទាំងនោះកំពុងតាមមក ទើបលែងព្រាហ្មណ៍ ហើយរត់យកតែរួចខ្លួនទៅ ពួកមនុស្សអ្នកនាំផ្លូវ កាលបានព្រាហ្មណ៍មកហើយ ក៏ពោលថា ប្រយោជន៍អ្វីរបស់ពួកយើង ដោយការចាប់ចោរ ទើបនាំគ្នាត្រឡប់ត្រឹមទីនោះឯង ។

ឯចោរបោរិសាទ ទៅដល់គល់ជ្រៃរបស់ខ្លួនហើយ ចូលដេកក្រោមឫសជ្រៃ ធ្វើពិធីបួងសួងថា បពិត្ររុក្ខទេវតា បើលោកអាចធ្វើឫសរបស់ខ្ញុំឲ្យជាក្នុង ៧ ថ្ងៃ ខ្ញុំនឹងលាងដើមជ្រៃរបស់លោកដោយឈាមបំពង់ករបស់ក្សត្រ ១០១ អង្គ ក្នុងជម្ពូទ្វីប នឹងព័ទ្ធដោយពោះវៀនរបស់ស្តេចទាំងនោះ នឹងធ្វើពលីកម្មដោយសាច់ដែលមានរស ៥ ដូច្នេះ ។ កាលចោរបោរិសាទមិនបានសាច់ បាយនិងទឹក រាងកាយក៏ស្គាំងស្គម មុខដំបៅក៏ជាសះស្បើយក្នុង ៧ ថ្ងៃនោះឯង ទើបសម្គាល់ថា ជាដោយអានុភាពរបស់ទេវតា កាលបានស៊ីសាច់មនុស្ស ២-៣ ថ្ងៃ មានកម្លាំងល្អហើយ ទើបគិតយ៉ាងនេះថា ទេវតាមានឧបការៈដល់អញច្រើន អញនឹងលាបំណន់ដល់ទេវតា កាន់យកដាវចេញអំពីគល់ឈើ ដោយបំណងថា នឹងនាំព្រះរាជាមកឲ្យបាន ។

សម័យនោះ យក្ខដែលជាសម្លាញ់ស៊ីសាច់មនុស្សជាមួយគ្នា ដែលស្តេចបោរិសាទធ្លាប់ជាយក្ខក្នុងជាតិមុន ត្រាច់តាមទឹកដីនោះ ឃើញស្តេចបោរិសាទចាំបានថា នេះជាសម្លាញ់របស់អញក្នុងអតីត ទើបសួរថា ឯងចាំយើងបានទេសម្លាញ់ ស្តេចបោរិសាទប្រាប់ថា យើងចាំមិនបានឡើយ ។ ទើបយក្ខតំណាលហេតុការណ៍ដែលធ្លាប់ធ្វើរួមគ្នាមក កាលស្តេចបោរិសាទនៅជាយក្ខក្នុងភពមុន ឲ្យស្តេចបោរិសាទស្តាប់ ស្តេចបោរិសាទចាំយក្ខនោះបាន ក៏ធ្វើនូវការទទួល ។ យក្ខសួរថា ឯងកើតនៅឯណា ស្តេចបោរិសាទបានប្រាប់ទីដែលខ្លួនកើតហើយ និងហេតុការណ៍ដែលត្រូវនិរទេសចាកដែននិងទីលំនៅក្នុងឥឡូវនេះ និងហេតុដែលជង្គត់ឈើមុតហើយ ហេតុដែលទៅលាបំណន់

ដល់ទេវតាឲ្យជ្រាបគ្រប់ប្រការ ហើយពោលថា កិច្ចរបស់យើង ចូរឯងជួយផង យើងទាំង ២ ទៅជាមួយគ្នាចុះសម្លាញ់ ។ យក្ខឆ្លើយថា នែសម្លាញ់ អញទៅជាមួយមិនបាន ព្រោះកិច្ចមួយរបស់អញនៅមាន តែអញចេះមន្ត ឈ្មោះ បទលក្ខណៈ មានតម្លៃកាត់ថ្លៃមិនបាន មន្តនោះ នឹងធ្វើឲ្យមានកម្លាំង រត់បានលឿននិងមានតេជះខ្ពស់ ចូរឯងរៀនមន្តនេះចុះ កាលស្តេចបោរិសាទ ទទួលពាក្យថា សាធុ យក្ខបានឲ្យមន្តនោះដល់ស្តេចបោរិសាទ ហើយចៀសចេញទៅ ។ ស្តេចបោរិសាទតាំងពីបានមន្តហើយ រត់បានរហ័សដូចខ្យល់ ក្លាហានខ្លាំង មានកម្លាំងនិងសេចក្តីព្យាយាមច្រើន ខាងក្នុង ៧ ថ្ងៃនោះឯង បានជួបព្រះរាជា ១០១ អង្គកំពុងប្រពាត ព្រះរាជឧទ្យានជាដើម រត់ទៅដោយកម្លាំងដូចខ្យល់ ប្រកាសឈ្មោះហើយ គំរាមដោយសំឡេងដ៏ខ្លាំង ឲ្យស្តេចទាំងនោះតក់ស្លុត ហើយចាប់ជើងឲ្យមានក្បាលចុះក្រោម ប្រហារក្បាលដោយកែងជើង នាំទៅដោយកម្លាំងដូចខ្យល់ ចោះត្រង់បាតដៃរបស់ស្តេចទាំងនោះ ហើយដោតដោយខ្សែ ចងព្យួរទុកត្រង់ដើមជ្រៃ ។ ពេលនោះ ព្រះរាជាទាំងអស់នោះ មានចុងជើងដល់ផែនដី កាលខ្យល់បក់មក ក៏រេទៅមកដូចផ្កាសិរមាន់ដែលស្វិតស្រពោន ដូច្នោះ ។ ស្តេចបោរិសាទមិនបានទៅចាប់ព្រះបាទសុតសោម ព្រោះយល់ឃើញថា ជាអាចារ្យពីមុនរបស់ខ្លួន នឹងខ្លាចក្រែងបើចាប់ទៅ ជម្ពូទ្វីបក៏នឹងទទេចាកក្សត្រ ហើយចាប់ផ្តើមធ្វើពលីកម្ម បន្លាត់ភ្លើងហើយអង្គុយសំលៀងលំពែង ។ រុក្ខទេវតាឃើញការធ្វើរបស់ស្តេចបោរិសាទគិតថា ស្តេចបោរិសាទ នឹងធ្វើពលីកម្មដល់អញ សេចក្តីសុខតិចតួចក្នុងរបួសរបស់

គេ អញមិនបានធ្វើឲ្យ ឥឡូវនេះ ជាសុករបស់គេនោះ នឹងធ្វើសេចក្ដីវិនាស ធំ ដល់ព្រះរាជាទាំងនេះ អញនឹងធ្វើដូចម្ដេចហ្ន៎ កាលឃើញថា ខ្លួនមិនអាច ឃាត់បាន ទើបទៅកាន់សម្នាក់មហារាជទាំង ៤ ហើយប្រាប់សេចក្ដីនោះឲ្យ ស្ដាប់ ហើយពោលថា សូមលោកទាំងឡាយជួយឃាត់គេផង មហារាជឆ្លើយ ថា សូម្បីពួកយើងក៏មិនអាចឃាត់គេបាន ទើបចូលទៅគាល់សក្កទេវរាជ ក្រាប ទូលសេចក្ដីនោះ ឲ្យទ្រង់ជ្រាបថា សូមឲ្យទ្រង់ឃាត់ស្ដេចបោរិសាទផងចុះ សូម្បីសក្កទេវរាជក៏ត្រាស់ថា យើងមិនអាចឃាត់គេបាន តែយើងនឹងប្រាប់ ឧបាយមួយ កាលរុក្ខទេវតាទូលសួរថា ឧបាយនោះដូចម្ដេច សក្កទេវរាជ ត្រាស់ថា អ្នកដទៃក្នុងលោក ទាំងទេវតា ដែលស្មើដូចព្រះរាជឱរសរបស់ ព្រះបាទកោរព្យរាជ ក្នុងនគរឥន្ទបត្ត ដែនកុរុ ព្រះនាមថា សុតសោម មិន មាន ព្រះបាទសុតសោមនឹងទូន្មានស្ដេចបោរិសាទនោះឲ្យអស់ព្យសន៍បាន នឹង ព្រះរាជទានជីវិតដល់ព្រះរាជាទាំងឡាយផងដែរ នឹងឲ្យស្ដេចបោរិសាទនោះ វៀរចាកការស៊ីសាច់មនុស្សបានទៀតផង ទ្រង់នឹងស្រោចស្រង់ជម្ពូទ្វីបទាំង មូលដោយទឹកអមតៈ បើអ្នកប្រាថ្នានឹងឲ្យជីវិតដល់ព្រះរាជាទាំងឡាយ ចូរ ពោលនឹងស្ដេចបោរិសាទនោះថា ការធ្វើពលីកម្មនោះ ត្រូវនាំព្រះបាទសុត សោមមកផង រុក្ខទេវតាទទួលទេវបញ្ជាហើយ ទើបប្រញាប់មក កាឡាខ្លួនជា បព្វជិត ស្ថិតក្នុងទីជិតស្ដេចបោរិសាទ ឯស្ដេចបោរិសាទ បានឮសំឡេងជើង សម្គាល់ថា ព្រះរាជាណាមួយរត់ទៅ កាលបានឃើញរុក្ខទេវតានោះ ក៏គិតថា ធម្មតាបព្វជិត រមែងជាក្សត្រទាំងអស់ អញនឹងចាប់បព្វជិតនេះ ធ្វើពលីកម្ម

ឲ្យគ្រប់ចំនួន ១០១ ដូច្នេះហើយ ទើបក្រោកឡើងកាន់ដាវដេញតាមទៅ សូម្បីដេញ តាមដល់ទៅ ៣ យោជន៍ ក៏មិនអាចទាន់ ញើសហូរជោកខ្លួន ទើបស្តេចបោរិសាទគិតថា ក្នុងកាលមុន ដំរីក្តី សេះក្តី រថក្តី កំពុងស្ទុះទៅ អញរត់ដេញតាម ចាប់មកបានទាំងអស់ ថ្ងៃនេះ សូម្បីអញរត់ពេញកម្លាំង ក៏គង់មិនអាចចាប់បព្វជិតដែលដើរទៅដោយប្រក្រតីរបស់ខ្លួនបាន មានហេតុអ្វីហ្ន៎ ទើបត្រិះរិះបន្តថា ឈ្មោះថា បព្វជិតជាអ្នកធ្វើតាមពាក្យ អញនឹងបង្គាប់ឲ្យលោកឈប់ លោកឈប់ហើយ សឹមចាប់ ដូច្នេះ ទើបពោលថា ឈប់សមណៈ រុក្ខទេវតាឆ្លើយថា យើងឈប់ស្រាប់ហើយ អ្នកនោះឯងចូរព្យាយាមឈប់ដែរចុះ ។ លំដាប់នោះ ស្តេចបោរិសាទក៏ពោលនឹងរុក្ខទេវតានោះថា បពិត្រលោកម្ចាស់ ធម្មតាបព្វជិត តែងមិនពោលកុហក សូម្បីព្រោះហេតុនៃជីវិត ឯលោកពោលកុហក ដូច្នេះហើយ ពោលគាថានេះថា

អ្នកកាលដែលខ្ញុំនិយាយថា អ្នកឈប់សិន ហើយចេះតែដើរ
ទៅមុខ ម្នាលអ្នកជាព្រហ្មចារិនី អ្នកមិនឈប់តែនិយាយថា
ខ្ញុំឈប់ហើយ ពាក្យនេះមិនគួរដល់អ្នកជាសមណៈទេ អ្នក
សម្គាល់នូវដាវរបស់ខ្ញុំគួរដល់សេចក្តីសង្ស័យដែរឬ[១]ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឋិដ្ឋាហិ** សេចក្តីថា នៃសមណៈ លោកកាលយើងពោលពាក្យថា ចូរឈប់ ដូច្នេះ ក៏ដើរទៅមិនងាកក្រោយ នៃព្រហ្មចារី

---

១-បាលីអដ្ឋកថាជា កន្កបត្តំ ទើបលោកប្រែថា អ្នកសម្គាល់នូវដាវរបស់ខ្ញុំថាជាស្លាបខ្វែងឬ ( កន្ក- បត្តំ ប្រែថាស្លាបត្រដក់ក៏បាន ) ។

លោកមិនបានឈប់ តែពោលថា ឈប់ហើយ លោកសម្គាល់ថា ជាវរបស់ខ្ញុំជារោមត្រដក់ឬ ។ បទថា **បម្មុខោ** បានដល់ ដើរត្រង់ទៅមុខ ។

ក្នុងលំដាប់នោះ ទេវតាក៏ពោលគាថា ២ ថា

បពិត្រព្រះរាជា អាត្មាជាអ្នកឈប់ ក្នុងព្រះសទ្ធម្មទាំងឡាយ
មិនត្រឡប់ប្រែនាមនឹងគោត្តទេ អ្នកប្រាជ្ញទាំងឡាយតែងពោល
នូវចោរថា មិនឈប់ក្នុងលោក ដែលច្យុតអំពីលោកនេះទៅ
ជាអ្នកទៅកាន់អបាយកាន់នរក ។ បពិត្រព្រះរាជា បើព្រះអង្គ
ជឿ ចូរព្រះអង្គចាប់សុតសោមៈជាក្សត្រមកបូជាយញ្ញ ព្រះ
អង្គនឹងទៅកាន់ឋានសួគ៌ដោយការបូជានោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សទ្ធម្មេសុ** សេចក្តីថា បពិត្រមហារាជ អាត្មាជាអ្នកឈប់ហើយ ក្នុងកម្មរបស់ខ្លួន ពោលគឺកុសលកម្មបថ ១០ ប្រការ ។ បទថា **ន នាមគោត្តំ** បានដល់ កាលមុន ទ្រង់ជាព្រះរាជាព្រះនាមថា ព្រហ្មទត្ត លះនាមនោះ ប្តូរមកជាឈ្មោះបោរិសាទ ឥឡូវនេះ មានឈ្មោះថា កម្មាសបាទ គឺចោរជើងពពាល សូម្បីកើតក្នុងខត្តិយត្រកូល ក៏នៅតែស៊ីសាច់មនុស្ស ដែលជារបស់មិនសមគួរស៊ី ទ្រង់ផ្លាស់នាមនិងគោត្ត យ៉ាងណា អាត្មាមិនបានផ្លាស់នាមនិងគោត្តយ៉ាងនោះឡើយ ឯចោរ អ្នកប្រាជ្ញទាំងឡាយពោលថា មិនឈប់ ព្រោះមិនតាំងនៅក្នុងកុសលកម្មបថ ១០ ប្រការ ។ បទថា **ឥតោ ចុតំ** បានដល់ ឃ្លាតចាកលោកនេះហើយ ត្រូវទៅកើតក្នុងអបាយ ឬនរក កាលចោរនោះធ្លាក់នរកហើយ រមែងមិនបាននូវទីពឹងពំនាក់របស់ខ្លួន

ដូច្នេះឯង ។ បទថា **សុតំ** ក្នុងគាថានោះ សំដៅដល់ព្រះបាទសុតសោម អធិប្បាយថា បពិត្រស្តេចបោរិសាទដ៏ចម្រើន ទ្រង់នោះឯងពោលមុសាវាទ ព្រោះទ្រង់ប្តេជ្ញាដល់យើងថា នឹងនាំព្រះរាជាក្នុងជម្ពូទ្វីបទាំងអស់មកធ្វើពលីកម្ម ឥឡូវនេះ ទ្រង់នាំព្រះរាជាសាមញ្ញធម្មតា ដែលមានកម្លាំងទុព្វលមក ដូច្នោះ ឯព្រះបាទសុតសោមមហារាជជាធំក្នុងជម្ពូទ្វីប ទ្រង់មិនបាននាំមក ពាក្យរបស់ទ្រង់ ឈ្មោះថា ជាពាក្យកុហក ព្រោះហេតុនោះ ចូរទៅចាប់ព្រះបាទសុតសោមមក ។

ទេវតាពោលយ៉ាងនេះហើយ ក៏បណ្តាលឲ្យគេទបព្វជិតវិនាសទៅ ក្លាយជារាងកាយរបស់ខ្លួន ឈរុងរឿងដូចព្រះអាទិត្យក្នុងអាកាស ស្តេចបោរិសាទបានស្តាប់ពាក្យនិងឃើញរូបទេវតានោះហើយ សួរថា អ្នកជានរណា ទេវតាឆ្លើយថា ខ្ញុំជាទេវតានៅត្រង់ដើមឈើនេះឯង ស្តេចបោរិសាទត្រេកអរថា អញបានឃើញទេវតាដោយខ្លួនឯង ក៏ពោលថា សូមទេវរាជជាធំ កុំវិតក្កៈ ព្រោះហេតុព្រះបាទសុតសោមឡើយ អញ្ជើញត្រឡប់ទៅដើមជ្រៃរបស់អ្នកចុះ ទេវតាក៏ចូលទៅកាន់ដើមជ្រៃ ក្នុងខណៈដែលស្តេចបោរិសាទកំពុងសម្លឹងមើល ខណៈនោះ ព្រះអាទិត្យក៏អស្តង្គត ព្រះចន្ទរះឡើងប្រាកដហើយ ស្តេចបោរិសាទ ជាអ្នកប្រាជ្ញខាងវេទង្គសាស្ត្រ ស្គាល់នក្ខត្តឫក្ស សម្លឹងមើលផ្ទៃមេឃត្រិះរិះថា ស្អែកនេះ ជាផុស្សនក្ខត្តឫក្ស ស្តេចសុតសោមនឹងយាងស្រង់ក្នុងព្រះឧទ្យាន អញនឹងចាប់ទ្រង់ក្នុងទីនោះ តែការរក្សារបស់ព្រះអង្គម៉ឺងម៉ាត់ខ្លាំងណាស់ អ្នកនគរទាំងមូលតាមរក្សា ៣ យោជន៍ដោយជុំវិញ កាលការរក្សា

*មិនទាន់ចាត់ចែង អញនឹងទៅកាន់មិគាចិរវនរាជឧទ្យាន ចុះកាន់ស្រះមង្គលបោក្ខរណី លាក់ខ្លួនអំពីបឋមយាម ហើយបានទៅកាន់ព្រះរាជឧទ្យាននោះ ចុះកាន់ស្រះបោក្ខរណី ឈរបិទក្បាលដោយស្លឹកឈូក ។ ដោយតេជះរបស់ស្តេចបោរិសាទនោះ សត្វមានត្រីនិងអណ្តើកជាដើម ក៏បានចេញទៅហែលជុំវិញដោយហ្វូង មានពាក្យសួរជ្រៀតចូលមកថា តេជះនេះ ស្តេចបោរិសាទបានព្រោះអ្វី មានពាក្យឆ្លើយថា បានដោយអំណាចបុណ្យក្នុងជាតិមុន ពិតហើយក្នុងសាសនកាលរបស់ព្រះទសពលព្រះនាមថា កស្សបៈ ព្រះរាជានេះបានផ្តើមសលាកភត្តដោយទឹកដោះស្រស់ ទើបទ្រង់មានកម្លាំងច្រើន ដោយហេតុនោះ បានសាងរោងភ្លើង ហើយប្រគេនភ្លើង ឧស កាំបិតពុះឧសនិងពូថៅដើម្បីបន្ទោបង់រងាដល់ភិក្ខុសង្ឃ ទើបទ្រង់មានតេជានុភាព ដោយហេតុនោះ កាលស្តេចបោរិសាទទៅខាងក្នុងរាជឧទ្យានយ៉ាងនេះហើយ ភ្នាក់ងារបានរៀបចំការរក្សាក្នុងទីប្រមាណ ៣ យោជន៍ដោយជុំវិញតាំងអំពីអរុណរះ ។ ចំណែកព្រះបាទសុតសោម សោយអាហារពីព្រលឹមនោះឯង យាងឡើងមង្គលហត្ថីដែលគេប្រដាប់តាក់តែងយ៉ាងល្អ ហែហមទៅដោយចតុរង្គសេនា យាងចេញអំពីព្រះនគរ ។*

*កាលនោះ ព្រាហ្មណ៍ឈ្មោះថា នន្ទៈ នាំយកគាថាឈ្មោះសតារហាចំនួន ៤ គាថា ដោយធ្វើដំណើរអស់ ១២០ យោជន៍ មកអំពីនគរតក្កសិលា ដល់ព្រះនគរនោះ ហើយស្នាក់នៅត្រង់ស្រុកក្បែរទ្វារនគរ កាលព្រះអាទិត្យរះ ក៏ចូលទៅកាន់ព្រះនគរ ឃើញព្រះរាជាយាងចេញតាមទ្វារព្រះនគរទិសខាងកើត*

ក៏លាដៃថ្វាយជ័យមង្គល ព្រះរាជាទតទិស បានឃើញដៃដែលលាចេញរបស់ព្រាហ្មណ៍ ដែលឈរក្នុងប្រទេសខ្ពស់ ទ្រង់បរដំរីចូលទៅជិតព្រាហ្មណ៍ កាលត្រាស់សួរ បានត្រាស់គាថានេះថា

ជាតិភូមិរបស់អ្នក ក្នុងដែនណា មួយទៀត អ្នកមកដល់ក្នុង
ទីនេះដោយប្រយោជន៍ដូចម្តេច ម្នាលព្រាហ្មណ៍ អ្នកចូរប្រាប់
សេចក្តីនុ៎ះ ដល់ខ្ញុំ អ្នកប្រាថ្នារបស់អ្វី ខ្ញុំនឹងឲ្យនូវរបស់នោះ
តាមដែលអ្នកប្រាថ្នា ក្នុងថ្ងៃនេះ ដូច្នេះ ។

លំដាប់នោះ ព្រាហ្មណ៍ក៏ក្រាបទូលព្រះរាជាដោយគាថានេះថា

បពិត្រព្រះអង្គជាមហិស្សរៈលើដែនដី គាថាទាំងឡាយ ៤ បទ
មានអត្ថដ៏ជ្រៅប្រសើរក្រៃលែង ប្រៀបដូចជាសាគរ ខ្ញុំមក
ក្នុងទីនេះ ដើម្បីប្រយោជន៍ដល់ព្រះអង្គតែម្យ៉ាង សូមព្រះអង្គ
ទ្រង់ព្រះសណ្តាប់នូវគាថា ដែលប្រកបដោយប្រយោជន៍ដ៏
ប្រសើរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធរណីមហិស្សរ** បានដល់ បពិត្រព្រះអង្គជាធំក្នុងដែន គ្រប់គ្រងផែនដី ព្រះគាថា ៤ គាថាកើតឡើងហើយដូចម្តេច មានអត្ថជ្រាលជ្រៅប្រសើរក្រៃលែង ប្រៀបដូចសាគរ ទូលព្រះបង្គំមកកាន់ទីនេះ ដើម្បីប្រយោជន៍របស់ទ្រង់ សូមទ្រង់ស្តាប់គាថា ដែលគួរដល់តម្លៃមួយរយ ដែលប្រកបដោយប្រយោជន៍ក្រៃលែង ដែលព្រះកស្សបទសពលទ្រង់សម្តែងទុកហើយនេះចុះ ។

ព្រាហ្មណ៍ទូលដូច្នេះហើយ ក៏ទូលបន្តថា បពិត្រមហារាជ គាថាឈ្មោះ សតារហា ៤ ព្រះគាថានេះ ព្រះកស្សបទសពលទ្រង់សម្តែងទុកហើយ ខ្ញុំបានស្តាប់ថា ទ្រង់សព្វព្រះហឫទ័យក្នុងការសិក្សា ទើបមកសម្តែងដល់ទ្រង់ ព្រះរាជា មានព្រះហឫទ័យសោមនស្ស ត្រាស់ថា លោកអាចារ្យ លោកមកល្អហើយ តែខ្ញុំមិនអាចត្រឡប់ពីទីនេះបាន ថ្ងៃនេះ ខ្ញុំស្រពស្រង់ដោយគន្ធនៃផុស្សទន្តក្តឫក្ស ព្រោះហេតុនោះ ខ្ញុំនឹងមកស្តាប់ក្នុងថ្ងៃស្អែក សូមអ្នកកុំរសាយចិត្តឡើយ ហើយត្រាស់នឹងអាមាត្យទាំងឡាយថា អ្នកទាំងឡាយចូរទៅចាត់ចែងទីដេកដល់ព្រាហ្មណ៍ត្រង់ផ្ទះនោះ ចូរចាត់ចែងអាហារនិងសំពត់ស្លៀកផង ហើយទ្រង់ព្រះរាជដំណើរចូលទៅកាន់ព្រះរាជឧទ្យាន ។ ព្រះរាជឧទ្យាននោះ ព័ទ្ធដោយកំពែង ១៨ ហត្ថ ដ៏រឈរតម្រៀបតៗគ្នាជារង្វង់ បន្ទាប់អំពីនោះទៅ ជាក្បួនសេះ បន្ទាប់អំពីនោះទៅ ក៏ជាក្បួនរថ បន្ទាប់អំពីនោះទៅជាក្បួននាយខ្មាន់ធ្នូ បន្ទាប់អំពីនោះទៅ ជាក្បួនថ្មើរជើង ព័ទ្ធជារង្វង់ដោយលំដាប់ ដូច្នេះឯង ពលនិកាយកុះករ ដូចមហាសមុទ្រដែលរញ្ជួយដោយមហារលកដូច្នោះ ។ ព្រះរាជាទ្រង់ដោះគ្រឿងរាជឥស្សរិយាភរណៈឲ្យធ្វើមស្សុកម្ម ( កោរពុកមាត់ ) មានព្រះសរីរៈលាបហើយដោយលម្អិតសម្រាប់ស្រង់ទ្រង់ចុះខាងក្នុងមង្គលបោក្ខរណីតាមព្រះរាជបវេណី រួចទ្រង់ឡើង ទ្រទ្រង់នូវព្រះភូសា ហើយប្រថាប់ឈរ ។ លំដាប់នោះ ភ្នាក់ងារថ្វាយព្រះភូសាគ្រឿងប្រអប់ កម្រងផ្កានិងគ្រឿងអលង្ការ ។ ខណៈនោះ ស្តេចបោរិសាទគិតថា ព្រះរាជានេះ កាលតែងខ្លួនហើយនឹងធូន់ អញចាប់ពេលនេះ ទើបស្រោល

ដូច្នេះហើយ ដាក់ម្រាមដៃត្រង់ថ្ងាស ផុសឡើងអំពីទឹក ក្រវីដាវលើក្បាល ដូចស្តេចមច្ចុរាជ បន្លឺសំឡេងប្រកាសថា វ៉ឺយ អញនេះឯង ឈ្មោះចោរបោរិសាទ ពួករាជបរិវារបានឮសំឡេងនោះហើយ អ្នកដែលឡើងជិះដំរី ក៏ធ្លាក់ពីលើដំរី អ្នកឡើងជិះសេះក៏ធ្លាក់ពីលើសេះ អ្នកឡើងលើរថ ក៏ធ្លាក់ពីលើរថ ពលនិកាយបោះអាវុធ ផ្កាប់មុខលើផែនដី ស្តេចបោរិសាទចាប់ព្រះបាទសុតសោម លើកឡើង កាលចាប់ព្រះរាជាដទៃៗ យកជើងឡើងលើ យកក្បាលចុះក្រោម ហើយទន្លិលក្បាលដោយកែងជើង ។ ឯព្រះពោធិសត្វ លើកឡើងដាក់ឲ្យអន្ទុយលើកគិតថា បើអញទៅតាមទ្វារនាំឲ្យយឺតយូរ កាលមិនឃើញផ្លូវដែលគួរទៅ ក៏លោតរំលងកំពែង ១៨ ហត្ថនោះឯង ហើយជាន់លើក្បាលដំរីចុះប្រេង ជាន់លើខ្នងសេះដោយកម្លាំងដ៏រហ័សដូចខ្យល់ ហាក់ដូចលោតជាន់កំពូលភ្នំដែលតម្រៀបគ្នាដូច្នោះ និងជាន់ត្រង់នឹមត្រង់ចន្ទោលរបស់រថ ហើយរត់ទៅដោយរហ័សអស់ចម្ងាយផ្លូវ ៣ យោជន៍ ដូចបន្ទិលនូវក្តារយន្តរបស់ជាងក្រឡឹង និងជាន់ស្លឹកជ្រៃដែលដល់ព្រមដោយផ្លែពណ៌ខៀវដូច្នោះ ក្រឡេកមើលគិតថា មានអ្នកណាតាមជួយស្តេចសុតសោមដែរឬទេ មិនឃើញបុគ្គលណាមួយ ទើបដើរសន្សឹមៗ ទៅឃើញតំណក់ទឹកស្រក់អំពីចុងសក់របស់ព្រះបាទសុតសោមចំត្រង់ដើមទ្រូងរបស់ខ្លួន គិតថា ឈ្មោះថាសត្វដែលមិនខ្លាចស្លាប់មិនមាន ស្តេចសុតសោមប្រហែលជាយំ ព្រោះខ្លាចសេចក្តីស្លាប់ ហើយបានពោលគាថានេះថា

បណ្ឌិតទាំងឡាយណា ជាអ្នកមានយោបល់ ប្រកបដោយ

បញ្ញាជាពហុស្សូត គិតនូវហេតុបានច្រើនយ៉ាង រមែងមិនយំទេ បណ្ឌិតទាំងឡាយនោះ ជាអ្នកបន្ទោបង់នូវសេចក្ដីសោកដោយហេតុណាពិត ហេតុនោះ ជាទីពឹងដ៏ក្រៃលែងរបស់ជនទាំងឡាយ ។ បពិត្រព្រះបាទសុតសោម ព្រះអង្គសោកស្ដាយចំពោះខ្លួន ញាតិឬកូនប្រពន្ធ ស្រូវ ទ្រព្យ ប្រាក់ មាស ឬអ្វី បពិត្រព្រះបាទកោរព្យៈដ៏ប្រសើរ យើងនឹងស្ដាប់ពាក្យរបស់លោក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យំ បណ្ឌិតា** សេចក្ដីថា បណ្ឌិតទាំងឡាយដូចទ្រង់ ជាអ្នកបន្ទោបង់នូវសេចក្ដីសោករបស់អ្នកដទៃបាន ការបន្ទោបង់សេចក្ដីសោកនេះឯង រមែងជាទីពឹងដ៏ប្រសើររបស់អ្នកដទៃ ប្រៀបដូចកោះជាទីពឹងរបស់បុគ្គលដែលលិចសំពៅក្នុងមហាសមុទ្រដូច្នោះ ព្រោះហេតុនោះលោកអ្នកមានប្រាជ្ញាដូចទ្រង់ រមែងមិនយំ ។ បទថា **កិមេវ ត្វំ** សេចក្ដីថា នៃសុតសោមសម្លាញ់ កាលមនុស្សដូចទ្រង់យំ ព្រោះខ្លាចស្លាប់ បុគ្គលល្ងង់ខ្លៅដទៃនឹងធ្វើដូចម្ដេច ខ្ញុំសូមសួរទ្រង់ នៃសុតសោម ក្នុងបិយជន មានខ្លួនឯងជាដើមនេះ ទ្រង់សោយសោកដល់អ្វី ទ្រង់គិតដល់អ្វី ។

ព្រះបាទសុតសោមត្រាស់ថា

ខ្ញុំមិនសោកស្ដាយចំពោះខ្លួន មិនសោកស្ដាយចំពោះកូនប្រពន្ធ មិនសោកស្ដាយចំពោះទ្រព្យ មិនសោកស្ដាយចំពោះដែនទេ ( មាន ) បុរាណធម៌ ជាចរិតរបស់សប្បុរសទាំង

ឡាយ ខ្ញុំសោកស្តាយនឹងការបេ្តជ្ញានោះ ចំពោះព្រាហ្មណ៍ ។ ការបេ្តជ្ញានឹងព្រាហ្មណ៍ដែលខ្ញុំឋិតនៅក្នុងឥស្សរភាព ក្នុងដែនរបស់ខ្លួន បានធ្វើហើយ ខ្ញុំជាអ្នករក្សាខ្ជាប់នូវសច្ចៈ នឹងដោះនូវការបេ្តជ្ញានោះរបស់ព្រាហ្មណ៍ ហើយនឹងត្រឡប់មកវិញដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនុត្ថុនាមិ** សេចក្តីថា ព្រះបាទសុតសោមត្រាស់ថា ខ្ញុំមិនបានយំ មិនបានសោយសោកឡើយ មិនបានគិតដល់ មិនបានសោក ដើម្បីប្រយោជន៍ដល់ខ្លួនឯងជាដើមទាំងនេះឡើយ តែធម៌របស់សប្បុរសដែលជាបណ្ឌិត ដែលលោកប្រព្រឹត្តមកហើយពីបុរាណមានឈ្មោះថាសច្ចៈ ព្រោះធ្វើការសន្យាណាទុក ខ្ញុំសោកដល់ការសន្យានឹងព្រាហ្មណ៍នោះ ។ បទថា **សច្ចានុរក្ខី** ក្នុងគាថានោះ សេចក្តីថា ខ្ញុំជាអ្នករក្សាពាក្យសច្ចៈ ព្រោះថា ព្រាហ្មណ៍នោះ នាំយកគាថា ៤ ដែលព្រះកស្សបពលទល ទ្រង់សម្តែងហើយ មកពីនគរតក្កសិលា ខ្ញុំបានឲ្យធ្វើអាគន្តុកវត្តដល់ព្រាហ្មណ៍នោះហើយ ធ្វើនូវសន្យាទុកថា ខ្ញុំត្រឡប់អំពីងូតទឹកហើយ នឹងស្តាប់គាថានោះ សូមអ្នករង់ចាំទម្រាំខ្ញុំត្រឡប់មក ដូច្នេះហើយ ទើបមក តែទ្រង់មិនបានឲ្យខ្ញុំស្តាប់គាថានោះ ចាប់ខ្ញុំមកមុន បើទ្រង់ដោះលែងខ្ញុំទៅ ខ្ញុំនឹងស្តាប់ធម៌ នឹងជាអ្នករក្សាសច្ចៈត្រឡប់មក ។

កាលនោះ ស្តេចបោរិសាទទូលព្រះបាទសុតសោមថា

ខ្ញុំមិនជឿនូវពាក្យនុ៎ះ ថាជនមានសេចក្តីសុខ បានរួចអំពីមាត់

នៃមច្ចុហើយត្រឡប់មករកដៃនៃសត្រូវវិញដូច្នេះទេ បពិត្រព្រះបាទកោរព្យៈដ៏ប្រសើរ ទ្រង់នឹងមិនមករកខ្ញុំ ។ បពិត្រព្រះរាជា ទ្រង់បានរួចអំពីដៃនៃព្រះបាទបោរិសាទហើយ មានប្រាថ្នាទៅកាន់មន្ទីរបស់ខ្លួនហើយ បាននូវជីវិតជាទីស្រឡាញ់ពេញចិត្ត កាលណាទ្រង់នឹងមកកាន់សំណាក់របស់ខ្ញុំវិញដូច្នេះ ។

ក្នុងគាថានោះ បទថា **សុខី** សេចក្ដីថា បុគ្គលដែលដល់នូវសេចក្ដីសុខហើយ ។ បទថា **មច្ចុមុខា បមុត្តោ** សេចក្ដីថា រួចផុតចាកមាត់របស់សេចក្ដីស្លាប់ ព្រោះផុតចាកកណ្ដាប់ដៃរបស់ចោរដូចខ្ញុំហើយ នឹងគប្បីត្រឡប់មកទៀត ពាក្យនេះ ខ្ញុំមិនជឿឡើយ បពិត្រកោរព្យៈដ៏ប្រសើរ ទ្រង់មិនមកកាន់សម្នាក់របស់ខ្ញុំទៀតទេដឹង នៃសុតសោម ទ្រង់ផុតចាកដៃរបស់បោរិសាទខ្ញុំហើយ នឹងទៅកាន់ព្រះរាជដំណាក់ ។ បទថា **សកំ មន្ទិរំ** បានដល់ រាជវាំងក្នុងរាជធានី ។ បទថា **កាមកាមី** សេចក្ដីថា ព្រះអង្គទ្រង់ត្រេកអរដោយកាមគុណ នឹងត្រឡប់មកកាន់សម្នាក់របស់ខ្ញុំបានដូចម្ដេច ។

ព្រះមហាសត្វបានស្ដាប់ដូច្នោះ ទ្រង់មិនញាប់ញ័រ ដូចស្ដេចកេសរសីហៈត្រាស់តបថា

បុគ្គលអ្នកមានសីលបរិសុទ្ធ រមែងប្រាថ្នានូវសេចក្ដីស្លាប់ ឯបុគ្គលអ្នកមានធម៌ដ៏លាមក ដែលគួរអ្នកផងតិះដៀល មិនគួរចង់រស់ឡើយ បុគ្គលទ្រុស្តសីល ពោលនូវពាក្យមិនពិត

ព្រោះហេតុខ្លួនណា ខ្លួននោះ រមែងមិនរក្សានូវជននោះចាក ទុគ្គតិបានឡើយ ។ បើទុកជាខ្យល់បក់កើចភ្នំបានក្តី ព្រះចន្ទ និងព្រះអាទិត្យធ្លាក់មកលើផែនដីក្តី ទឹកស្ទឹងទាំងអស់ ហូរប្រាសខ្សែទឹកក្តី បពិត្រព្រះរាជា ខ្ញុំក៏មិនពោលពាក្យកុហកទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មតំ វាហេយ្យ** សេចក្តីថា នៃបោរិសាទ នរជនណាមានសីលបរិសុទ្ធ គប្បីប្រាថ្នា គឺត្រូវការ ចូរប្រាថ្នាសេចក្តីស្លាប់ ។ បទថា **ន ជីវិតំ** សេចក្តីថា ឯបុគ្គលដែលមានធម៌ដ៏លាមក ដែលអ្នកប្រាជ្ញតិះដៀល មិនគប្បីប្រាថ្នា គឺមិនត្រូវការជីវិត ព្រោះជីវិតរបស់បុគ្គលនោះ ជាជីវិតអាក្រក់ ព្រោះមិនធ្វើសេចក្តីចម្រើនតទៅ ។ បទថា **យស្ស** បានដល់ អ្នកទ្រុស្តសីល គប្បីពោលពាក្យកុហក ដើម្បីជាប្រយោជន៍ដល់ខ្លួនណា វត្ថុមានខ្លួនឯងជាដើមនោះ រមែងមិនការពារ មិនរក្សាបុរសនោះ ចាកទុគ្គតិបានឡើយ ។

បទថា **គិរិមាវហេយ្យ** សេចក្តីថា នៃបោរិសាទសម្លាញ់ ឯងជាសម្លាញ់ស្និទ្ធស្នាល ធ្លាប់រៀនក្នុងសម្នាក់អាចារ្យជាមួយខ្ញុំ ខ្ញុំមិនពោលពាក្យកុហក ព្រោះហេតុនៃជីវិតឡើយ សូម្បីខ្យល់ច្រើនប្រភេទ មានខ្យល់ទិសខាងកើតជាដើម គប្បីបក់ភ្នំធំ ហើរមកតាមអាកាស ដូចប៉ុយគបាន សូម្បីហេតុនោះ ក៏គប្បីជឿបាន តែអ្នកគប្បីជឿពាក្យនេះថា ខ្ញុំមិនពោលពាក្យកុហកក្រៃលែងជាងនោះ ព្រះចន្ទនិងព្រះអាទិត្យគប្បីធ្លាក់លើផែនដី មួយអន្លើដោយវិមានរបស់ខ្លួន

ស៊ីនគ្រប់ខែ្ស ទោះបីហូរប្រាសបាន នៃបោរិសាទ ពាក្យយ៉ាងនេះ បើមានអ្នកណាពោលឡើង ក៏គប្បីជឿបាន ឯពាក្យថា ខ្ញុំពោលកុហកនេះ បើជនទាំងឡាយពោលដល់អ្នកហើយ ពាក្យនោះ អ្នកមិនគប្បីជឿឡើយ ហើយព្រះមហាសត្វក៏ពោលថា

មេឃបែកធ្លាយ ទឹកសមុទ្ររីងស្ងួត ឬផែនដីជាទីទ្រទ្រង់នូវ
សត្វប្រែត្រឡប់ ឬក៏ភ្នំឈ្មោះមេរុ រលើងទាំងឫស ខ្ញុំក៏មិន
ពោលពាក្យកុហកទេ ដូច្នេះ ។

សូម្បីព្រះពោធិសត្វត្រាស់យ៉ាងនេះហើយ ស្តេចបោរិសាទ ក៏នៅតែមិនជឿ ។ លំដាប់នោះ ទើបព្រះពោធិសត្វទ្រង់ត្រិះរិះថា ស្តេចបោរិសាទនេះមិនជឿអញ អញនឹងឲ្យគេជឿដោយពាក្យស្បថ ហើយត្រាស់ថា បោរិសាទសម្លាញ់ ចូរអ្នកឲ្យខ្ញុំចុះអំពីកសិន ខ្ញុំនឹងធ្វើការស្បថដល់ទ្រង់ កាលស្តេចបោរិសាទដាក់ចុះខាងមុខដល់ផែនដីហើយ កាលទ្រង់ធ្វើការស្បថ បានត្រាស់គាថានេះថា

ខ្ញុំចាប់ដាវនិងលំពែង បពិត្រទ្រង់ជាសម្លាញ់ ខ្ញុំនឹងធ្វើនូវ
សម្បថចំពោះទ្រង់ ខ្ញុំរួចចេញអំពីទ្រង់ ជាអ្នកមិនមានបំណុល
រក្សានូវសច្ចៈនឹងត្រឡប់មកវិញ ដូច្នេះ ។

សេចក្តីនៃគាថានោះ មានពាក្យអធិប្បាយថា នៃបោរិសាទសម្លាញ់ បើទ្រង់ប្រាថ្នា ខ្ញុំនឹងចាប់ដាវនិងលំពែងស្បថថា សូមកុំឲ្យខ្ញុំកើតក្នុងត្រកូលក្សត្រដែលមានការរក្សាយ៉ាងល្អ ដោយអាវុធបែបនេះ នៃសម្លាញ់ បើអ្នកប្រាថ្នា

ពាក្យសម្បថដទៃទៀត ខ្ញុំក៏នឹងធ្វើការស្បថឲ្យដល់ទ្រង់ទៀតក៏បាន ខ្ញុំផុតចាកទ្រង់ហើយ ក៏នឹងទៅរកព្រាហ្មណ៍ ធ្វើខ្លួនមិនឲ្យមានបំណុលដល់ព្រាហ្មណ៍ហើយ នឹងជាអ្នករក្សាសច្ចៈត្រឡប់មក ។

លំដាប់នោះ ស្តេចបោរិសាទគិតថា ស្តេចសុតសោមនេះ ធ្វើនូវការស្បថដែលពួកក្សត្រមិនគួរធ្វើ ពាក្យសម្បថនេះ មានប្រយោជន៍អ្វីដល់អញ ទោះគេត្រឡប់មក ឬមិនត្រឡប់មក សូម្បីខ្លួនអញក៏ជាខត្តិយរាជ អញនឹងយកឈាមក្នុងដើមដៃរបស់អញធ្វើពលីកម្មដល់ទេវតា នេះរមែងលំបាកក្រៃពេក ហើយពោលគាថានេះថា

ការបេ្តជ្ញាណា ជាមួយនឹងព្រាហ្មណ៍ដែលព្រះអង្គឋិតនៅក្នុង
ឥស្សរភាព ក្នុងដែនរបស់ខ្លួនបានធ្វើហើយ សូមព្រះអង្គជា
អ្នករក្សានូវសច្ចៈ ដោះនូវការបេ្តជ្ញានោះនឹងព្រាហ្មណ៍ហើយ
ចូរត្រឡប់មកវិញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បុនរាវជស្សុ** សេចក្តីថា ទ្រង់គប្បីយាងមកទៀត ។

លំដាប់នោះ ព្រះមហាសត្វត្រាស់ថា បោរិសាទសម្លាញ់ អ្នកកុំវិតក្កឡើយ ខ្ញុំបានស្តាប់សតារហគាថា ៤ ហើយ ឲ្យគ្រឿងបូជាដល់ធម្មកថិកហើយ នឹងត្រឡប់មកអំពីព្រឹកនោះឯង ហើយត្រាស់គាថានេះថា

ការបេ្តជ្ញាណា ជាមួយនឹងព្រាហ្មណ៍ ដែលខ្ញុំឋិតនៅក្នុងឥស្សរ
ភាព ក្នុងដែនរបស់ខ្លួនបានធ្វើហើយ ខ្ញុំជាអ្នករក្សានូវសច្ចៈ

នឹងដោះនូវការបេ្ដជ្ញានោះនឹងព្រាហ្មណ៍ហើយ នឹងត្រឡប់មកវិញ ដូច្នេះ ។

បទថា **បុនរាវជិស្សំ** បានដល់ ខ្ញុំនឹងត្រឡប់មកវិញ ។

លំដាប់នោះ ទើបព្រះបាទបោរិសាទ ទូលព្រះបាទសុតសោមថា បពិត្រមហារាជ ព្រះអង្គទ្រង់ធ្វើនូវការស្បថ ដែលពួកក្សត្រមិនគួរធ្វើ សូមទ្រង់រឭកដល់ព្រះតម្រាស់ដែលទ្រង់បេ្ដជ្ញា កាលព្រះមហាសត្វត្រាស់ឲ្យជឿ ដោយព្រះតម្រាស់ថា នែសម្លាញ់បោរិសាទ អ្នកស្គាល់ខ្ញុំតាំងពីនៅក្មេង ពាក្យកុហកខ្ញុំមិនធ្លាប់ពោលឡើយ សូម្បីត្រឹមតែការលេងសើច ខ្ញុំនឹងពោលកុហកបានឬ ឥឡូវនេះ ខ្ញុំតាំងនៅក្នុងរាជសម្បត្តិហើយ ស្គាល់ត្រូវនិងខុស នឹងពោលកុហកបានឬ សូមទ្រង់ជឿខ្ញុំចុះ ខ្ញុំនឹងត្រឡប់មកឲ្យទាន់ពលិកម្មរបស់ទ្រង់ ក្នុងថ្ងៃស្អែកនេះ ស្ដេចបោរិសាទក៏ពោលថា បពិត្រមហារាជ បើដូច្នោះ សូមទ្រង់យាងចុះ បើទ្រង់មិនយាងមក ពលិកម្មមិនមាន ព្រោះទេវតាវៀរទ្រង់មិនទទួល សូមទ្រង់កុំធ្វើអន្តរាយដល់ពលិកម្មរបស់ខ្ញុំ ហើយបញ្ជូនមហាសត្វទៅ ។ ព្រះមហាសត្វដូចព្រះចន្ទផុតហើយចាកមាត់រាហូ ព្រះអង្គមានកម្លាំងដូចដំរី សម្បូរដោយថាមពល យាងដល់ព្រះនគរដោយឆាប់រហ័ស ។

សម័យនោះ សេនារបស់ព្រះបាទសុតសោមនោះ ក៏បោះជំរុំនៅខាងក្រៅព្រះនគរ ព្រោះត្រិះរិះថា ព្រះបាទសុតសោមមហារាជ ទ្រង់ជាបណ្ឌិត ទ្រង់សម្ដែងធម៌ពីរោះ កាលបានត្រាស់គាថាមួយឬគាថាពីរ នឹងទូន្មានស្ដេចបោរិសាទបាន ហើយត្រឡប់មក ដូចដំរីចុះប្រេងដ៏ប្រសើរផុតហើយចាកមាត់សីហៈ

ដូច្នោះ និងខ្លាចអ្នកនគរតិះដៀលថា ពួកសេនាបតីទាំងនេះ ឲ្យព្រះរាជាដល់ស្តេចបោរិសាទ ហើយនាំគ្នាមក កាលឃើញព្រះពោធិសត្វយាងមកអំពីចម្ងាយ បាននាំគ្នាក្រោកឡើងទទួល ធ្វើបដិសណ្ឋារៈហើយ ទូលថា បពិត្រមហារាជ ទ្រង់ត្រូវស្តេចបោរិសាទធ្វើឲ្យលំបាកដូចម្តេចខ្លះ កាលត្រាស់តបថា ស្តេចបោរិសាទ បានធ្វើកិច្ចដែលមាតាបិតាធ្វើបានដោយកំបាកដល់យើង គេឃោរឃៅយ៉ាងនោះ បានស្តាប់ធម្មកថារបស់យើងហើយ ក៏ដោះលែងយើង ទើបតាក់តែងព្រះបាទសុតសោម យាងឡើងលើកដំរីព្រះទីន័ង ចោមរោមចូលកាន់ព្រះនគរ អ្នកនគរបានឃើញដូច្នោះ ក៏ត្រេកអរគ្រប់គ្នា ។ ព្រះពោធិសត្វមិនទាន់បានចូលគាល់ព្រះរាជមាតាបិតា ព្រោះមានសេចក្តីគោរពក្នុងធម៌ ជាអ្នកធ្ងន់ក្នុងធម៌ តាំងព្រះហឫទ័យថា នឹងគាល់ឯក្រោយ ទើបយាងចូលព្រះរាជនិវេសន៍ ប្រថាប់គង់នាព្រះរាជាសនៈ ត្រាស់ឲ្យហៅព្រាហ្មណ៍មក និងត្រាស់ឲ្យធ្វើឧបដ្ឋានកិច្ច មានការកោរពុកមាត់ជាដើមដល់ព្រាហ្មណ៍នោះ ពេល ដែលភ្នាក់ងារកោរពុកមាត់ព្រាហ្មណ៍ហើយ ឲ្យងូតទឹក លាបដោយគ្រឿងក្រអូបប្រដាប់ដោយសំពត់និងគ្រឿងអលង្ការ ហើយនាំចូលទៅគាល់ ព្រះអង្គទ្រង់ស្រង់ជាក្រោយ ទ្រង់ព្រះរាជទានភោជនរបស់ព្រះអង្គដល់ព្រាហ្មណ៍នោះ កាលព្រាហ្មណ៍បរិភោគហើយ ព្រះអង្គសោយហើយ អញ្ជើញព្រាហ្មណ៍ឲ្យអង្គុយលើបល្ល័ង្កដែលគួរបូជា ធ្វើនូវការបូជាព្រាហ្មណ៍ដោយសក្ការៈ មានផ្កាកម្រងនិងគ្រឿងក្រអូបជាដើម ព្រោះទ្រង់គោរពក្នុងធម៌ ប្រថាប់គង់ត្រង់អាសនៈទាបអារាធនាថា លោកអាចារ្យ ខ្ញុំសូមស្តាប់គាថាឈ្មោះសតារហា ដែលលោក

នាំមកដើម្បីខ្ញុំ ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ បានត្រាស់គាថានេះថា

ព្រះបាទសុតសោមនោះ រួចពីព្រះហស្តនៃព្រះបាទបោរិសាទ
ហើយទៅ បានពោលពាក្យនេះនឹងព្រាហ្មណ៍នោះថា ម្នាល
ព្រាហ្មណ៍ ខ្ញុំសូមស្តាប់នូវគាថាទាំងឡាយដែលគួរដល់ថ្លៃ ១០០
កហាបណៈ ជាគាថាដែលខ្ញុំស្តាប់ហើយ មានប្រយោជន៍ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឯតទវោច** កាត់បទជា **ឯតំ អវោច** ។ លំដាប់នោះ ក្នុងកាលដែលព្រះមហាសត្វអាពាធនាហើយ ព្រាហ្មណ៍ក៏លាបដៃទាំង ២ ដោយគ្រឿងក្រអូប នាំយកគម្ពីរដែលជាទីគួរត្រេកអរមកអំពីថង់យាម ចាប់ដោយដៃទាំង ២ ហើយទូលថា ឥឡូវនេះ សូមមហាបពិត្រ ទ្រង់ស្តាប់នូវគាថា ឈ្មោះថា សតារហា ៤ គាថា ដែលព្រះកស្សបទសពល ទ្រង់សម្តែងទុក ដែលនឹងដកនូវសេចក្តីស្រើប មានការស្រើបដោយរាគៈជាដើម ឲ្យសម្រេចអមតមហានិព្វាន ហើយអានគម្ពីរពោលគាថានេះថា

បពិត្រព្រះបាទសុតសោម ការជួបប្រទះដោយសប្បុរសទាំង
ឡាយអស់វារៈតែម្តង ការជួបប្រទះនោះ រមែងរក្សានូវបុគ្គល
នោះបាន ឯការជួបជុំដោយពួកអសប្បុរសជាច្រើនដង រមែង
មិនរក្សានូវបុគ្គលនោះបានទេ ។ បុគ្គលគប្បីគប់រកនឹងពួក
សប្បុរស គប្បីធ្វើនូវការស្និទ្ធស្នាលនឹងពួកសប្បុរស គុណ
ធម៌ដ៏ប្រសើរ រមែងកើតមាន ព្រោះដឹងនូវព្រះសទ្ធម្មរបស់

ពួកសប្បុរស មិនមែនជាទោសដ៏លាមកឡើយ ។ រាជរថទាំងឡាយ ដែលគេរចនាល្អហើយ រមែងគ្រាំគ្រាទៅវិញ សូម្បីសរីរៈ (នៃពួកសត្វ) ក៏រមែងដល់នូវសេចក្ដីគ្រាំគ្រាដោយពិត ឯធម៌របស់សប្បុរសទាំងឡាយ រមែងមិនដល់នូវសេចក្ដីគ្រាំគ្រាទេ ពួកសប្បុរសរមែងចរចា ដោយពួកសប្បុរស ។ អាកាសនិងដីឋិតនៅក្នុងទីឆ្ងាយពីគ្នា អ្នកប្រាជ្ញទាំងឡាយបានពោលនូវច្រាំងសមុទ្ទថា ឆ្ងាយ បពិត្រព្រះរាជា អ្នកប្រាជ្ញទាំងឡាយបានពោលនូវធម៌របស់ពួកសប្បុរស និងពួកអសប្បុរសថា ឆ្ងាយជាងនោះទៅទៀត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សកិទេវ** បានដល់ អស់វារៈម្ដងប៉ុណ្ណោះ ។ បទថា **សព្ភិ** បានដល់ សប្បុរស ។ បទថា **សា នំ** បានដល់ ការជួប គឺការសេពគប់ជាមួយពួកសប្បុរសនោះ សូម្បីប្រព្រឹត្តទៅត្រឹមតែម្ដង ក៏រមែងអភិបាលគ្រប់គ្រងបុគ្គលនោះបាន ។ បទថា **នាសព្ភិ** អធិប្បាយថា ឯការសេពគប់ជាមួយអសប្បុរស សូម្បីបុគ្គលធ្វើទុកហើយច្រើន គឺធ្វើទុកអស់កាលយូរការនៅក្នុងទីជាមួយគ្នា ក៏រក្សាមិនបាន គឺរមែងនាំសេចក្ដីវិនាសមកឲ្យ ។ បទថា **សមាសេថ** បានដល់ គប្បីអង្គុយជិត អធិប្បាយថា គប្បីប្រឡូកប្រឡំ ជាមួយបណ្ឌិតទាំងនោះ គ្រប់ឥរិយាបថ ។ បទថា **សន្ថវំ** បានដល់ ការស្និទ្ធស្នាលដោយមេត្រី ។ បទថា **សតំ សទ្ធម្មំ** បានដល់ ព្រះសទ្ធម្ម គឺពោធិបក្ខិយធម៌ ៣៧ ប្រការ របស់បណ្ឌិតទាំងឡាយ មានព្រះពុទ្ធជាដើម ។ បទ

ថា **សេយ្យោ** អធិប្បាយថា កាលដឹងនូវធម៌នេះហើយ មានតែសេចក្តីចម្រើន តែម្យ៉ាង ឈ្មោះថា ការវិនាសរមែងមិនមានឡើយ ។ បទថា **រាជរថា** បានដល់ រាជរថរបស់ព្រះរាជាទាំងឡាយ ។ បទថា **សុចិត្តា** សេចក្តីថា ដែលគេធ្វើបរិកម្មយ៉ាងល្អ ។ បទថា **សតំ បវេទយន្តិ** បានដល់ សប្បុរសទាំងឡាយមានព្រះពុទ្ធជាដើម រមែងប្រាប់ព្រះនិព្វានដ៏ឧត្តម ដល់នូវការរាប់ថា **សតំ** ធម៌របស់សប្បុរសទាំងឡាយ ពោលគឺព្រះនិព្វាននោះ រមែងមិនចូលដល់ជរា គឺរមែងមិនចាស់ ។ បទថា **នភំ** សេចក្តីថា បានដល់ អាកាស ។ បទថា **ទូរេ** បានដល់ ផែនដីតាំងនៅមាំទាំ អាកាសមិនបានធ្លាក់ចុះមក មិនតាំងនៅមាំទាំរបស់ទាំង ២ យ៉ាងនេះ សូម្បីទាក់ទងជាមួយគ្នា តែឈ្មោះថា នៅឆ្ងាយគ្នាព្រោះអត្ថថា មិនបានទាក់ទងគ្នា និងព្រោះអត្ថថា មិនជាប់តគ្នា ។ បទថា **ចារំ** បានដល់ អំពីត្រើយអាយទៅកាន់ត្រើយនាយ ។ បទថា **តទាហុ** កាត់បទជា **តំ អាហុ** ។

ព្រាហ្មណ៍ពោលគាថាឈ្មោះថា សតារហៈ ៤ គាថា តាមដែលព្រះកស្សបទសពលសម្តែងទុកយ៉ាងនេះហើយ បានអង្គុយស្ងៀម ព្រះមហាសត្វទ្រង់បានស្តាប់ដូច្នោះ មានព្រះហឫទ័យសោមនស្សថា ការមករបស់យើងមានផលហ្ន៎ ទ្រង់ព្រះតម្រិះថា គាថាទាំងនេះ មិនមែនភាសិតរបស់សាវក មិនមែនភាសិតរបស់ឥសី មិនមែនភាសិតរបស់កវី តែជាភាសិតរបស់ព្រះសព្វញ្ញូនិងគួរដល់តម្លៃប៉ុនណាហ្ន៎ ទ្រង់ព្រះតម្រិះតទៅថា សូម្បីយើងឲ្យចក្កវាឡទាំងមូលធ្វើឲ្យពេញដោយរតនៈ ៧ ប្រការ កម្ពស់ដល់ព្រហ្មលោក ក៏មិនអាចធ្វើឲ្យ

សមគួរដល់គាថានេះ ឯយើងទោះបីឲ្យរាជសម្បត្តិក្នុងនគរឥន្ទបត្ត ប្រមាណ ៧ យោជន៍ក្នុងកុរុរដ្ឋប្រមាណ ៣០០ យោជន៍ដល់ព្រាហ្មណ៍នេះ ជោគគឺវាសនាដែលត្រូវបានរាជសម្បត្តិរបស់ព្រាហ្មណ៍នេះ មានឬហ្ន៎ ទ្រង់ប្រមើលមើលដោយអានុភាពនៃអង្គវិជ្ជា មិនឃើញមាន លំដាប់នោះ ទ្រង់ពិនិត្យមើលដល់ឋានន្តរ មានតំណែងជាសេនាបតីជាដើម ក៏មិនឃើញជោគឋានន្តរ សូម្បីត្រឹមតែជាមេស្រុក កាលទ្រង់ពិនិត្យមើលដល់ជោគលាភ ទ្រង់គិតនឹងតម្កល់ទ្រព្យមួយកោដិ ទ្រង់ឃើញជោគលាភត្រឹមតែ ៤០០០ កហាបណៈ ក៏ដាក់ព្រះហឫទ័យថា នឹងបូជាព្រាហ្មណ៍នោះ ដោយទ្រព្យប៉ុណ្ណោះ ត្រាស់ឲ្យព្រះរាជទានថង់ទ្រព្យ មួយថង់ ១០០០ កហាបណៈចំនួន ៤ ថង់ ត្រាស់សួរថា លោកអាចារ្យសម្តែងគាថានេះដល់ពួកក្សត្រដទៃៗ បានទ្រព្យប៉ុន្មាន ព្រាហ្មណ៍ក្រាបទូលថា បពិត្រមហារាជបានមួយគាថា ១០០ កហាបណៈ ព្រោះហេតុនោះទើបគាថានេះបានឈ្មោះថា សតារហា ។ លំដាប់នោះ ព្រះមហាសត្វត្រាស់នឹងព្រាហ្មណ៍នោះថា លោកអាចារ្យមិនដឹងតម្លៃកណ្ឌៈ ដែលខ្លួនកាន់ត្រាច់ទៅដូច្នេះ តែគាថាទាំងនេះ ចូរឈ្មោះថា សហស្សារហា ដូច្នេះ ហើយត្រាស់ព្រះគាថាដូច្នេះថា

> គាថាទាំងនេះ គួរដល់ថ្លៃ ១ ពាន់កហាបណៈ គាថាទាំងនេះ
> មិនគួរដល់ថ្លៃត្រឹម ១០០ កហាបណៈទេ ម្នាលព្រាហ្មណ៍
> លោកចូរទទួលយកកហាបណៈ ៤ ពាន់ ជាប្រញាប់ចុះ
> ដូច្នេះ ។

កាលព្រះមហាសត្វ ព្រះរាជទានយានតូចដែលជាសុខមួយគ្រឿងដល់ព្រាហ្មណ៍ ត្រាស់នឹងរាជបុរសថា ចូរបញ្ជូនព្រាហ្មណ៍ឲ្យដល់ស្រុកដោយសួស្តី ហើយទ្រង់ក៏បញ្ជូនព្រាហ្មណ៍នោះទៅ ខណៈនោះ ក៏កើតសំឡេងសាធុការធំថា សាធុ សាធុ គាថាឈ្មោះថា សតារហា ព្រះបាទសុតសោម ទ្រង់ប្តូរមកជា សហស្សារហា ទ្រង់បូជាហើយ ។ ព្រះរាជមាតាបិតារបស់ព្រះមហាសត្វបានស្តាប់សំឡេងនោះ ត្រាស់សួរថា នុ៎ះជាសំឡេងអ្វី ទ្រង់បានជ្រាបតាមសេចក្តីពិត ទ្រង់ព្រះពិរោធព្រះមហាសត្វ ព្រោះស្តាយទ្រព្យ ឯព្រះមហាសត្វទ្រង់បញ្ជូនព្រាហ្មណ៍ហើយ យាងទៅគាល់ព្រះរាជមាតាបិតា ថ្វាយបង្គំ ប្រថាប់ឈរ កាលនោះ ព្រះរាជបិតា ទ្រង់មិនធ្វើសូម្បីត្រឹមតែបដិសណ្ឋារៈថា កូនផុតចាកកណ្តាប់ដៃ ចោរដែលកាចបែបនោះបានមក ដូចម្តេច ព្រោះទ្រង់ស្តាយទ្រព្យ ទើបត្រាស់សួរថា បានឮថា ឯងស្តាប់គាថា ៤ ឲ្យទ្រព្យ ៤ ពាន់ពិតឬ កាលព្រះមហាសត្វក្រាបទូលថា ពិត ទើបត្រាស់គាថានេះថា

គាថាមានថ្លៃ ៨០ កហាបណៈ ៩០ កហាបណៈ និងគាថា
គួរដល់ថ្លៃ ១០០ កហាបណៈ ម្នាលសុតសោម អ្នកចូរដឹង
ដោយខ្លួនឯងចុះ គាថាដូចម្តេច ដែលឈ្មោះថា គួរដល់ថ្លៃ ១
ពាន់កហាបណៈ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អត្តនាវ** បានដល់ ចូរឯងដឹងខ្លួន ដោយខ្លួនឯង ។ បទថា **កតា អត្ថិ** បានដល់ គាថាដែលគួរដល់តម្លៃ ១០០០ នោះមានក្នុងទីណា ។

លំដាប់នោះ ព្រះមហាសត្វកាលក្រាបទូលព្រះរាជបិតានោះ ឲ្យទ្រង់ជ្រាបថា ទូលព្រះបង្គំមិនប្រាថ្នានូវការចម្រើនដោយទ្រព្យប៉ុណ្ណោះ រមែងប្រាថ្នាសេចក្តីចម្រើនដោយការសិក្សា ហើយត្រាស់គាថាបន្តថា

ខ្ញុំព្រះអង្គប្រាថ្នានូវសេចក្តីចម្រើនដោយសុតៈ គឺការចេះដឹង ដើម្បីខ្លួន សប្បុរសទាំងឡាយ អ្នកមានចិត្តស្ងប់ គប្បីគប់រកនូវខ្ញុំព្រះអង្គ បពិត្រព្រះបិតា ខ្ញុំព្រះអង្គ មិនឆ្អែតដោយសុភាសិត ដូចជាមហាសមុទ្ទមិនឆ្អែតដោយទឹកស្ទឹងដែលហូរចូលទៅ ។ ភ្លើងកាលឆេះស្មៅនិងឈើ រមែងមិនឆ្អែត សាគររមែងមិនឆ្អែតដោយទឹកស្ទឹង យ៉ាងណា បពិត្រព្រះរាជាដ៏ប្រសើរ បណ្ឌិតទាំងឡាយនោះបានស្តាប់ហើយ ក៏មិនឆ្អែតដោយសុភាសិត ក៏យ៉ាងនោះដែរ ។

បពិត្រព្រះអង្គជាធំជាងជន ខ្ញុំព្រះអង្គស្តាប់នូវគាថាដែលមានប្រយោជន៍របស់ទាសៈនៃខ្លួន ក្នុងកាលណា ក្នុងកាលណោះ ខ្ញុំព្រះអង្គតែងផ្ទៀងស្តាប់នូវគាថានោះឯងដោយគោរព បពិត្រព្រះបិតា ខ្ញុំព្រះអង្គមិនមានសេចក្តីឆ្អែត ក្នុងធម៌ទាំងឡាយទេដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វេ** ក្នុងគាថានោះ ត្រឹមតែជានិបាត ។ បទថា **សន្តោ** អធិប្បាយថា ទូលព្រះបង្គំប្រាថ្នាថា ពួកសប្បុរសទាំងនេះឯង គប្បីគប់រកទូលព្រះបង្គំ ។ បទថា **សវន្តីហិ** សំដៅដល់ ស្ទឹងគ្រប់ខ្សែ ។ បទថា

**សកស្ស** បានដល់ នន្ទព្រាហ្មណ៍ចូរលើកទុកចុះ ពេលណាទូលព្រះបង្គំនឹងត្រូវស្តាប់ធម្មកថាអំពីទោសៈរបស់ខ្លួនឯង ។

កាលត្រាស់យ៉ាងនេះហើយ ព្រះបាទសុតសោមក៏ទូលបន្តថា បពិត្រព្រះអង្គ ទ្រង់កុំបរិភាសទូលព្រះបង្គំព្រោះទ្រព្យ ទូលព្រះបង្គំបានឲ្យបដិជ្ញាចំពោះស្តេចបោរិសាទថា ស្តាប់ធម៌ហើយនឹងត្រឡប់ ឥឡូវនេះ ទូលព្រះបង្គំនឹងទៅកាន់សម្នាក់របស់បោរិសាទ សូមទ្រង់ទទួលរាជសម្បត្តិនេះចុះ កាលក្រាបទូលប្រគល់រាជសម្បត្តិ បានត្រាស់គាថានេះថា

ដែនរបស់ព្រះអង្គនេះ ព្រមទាំងទ្រព្យ ព្រមទាំងយាន ព្រមទាំងគ្រឿងប្រដាប់កាយ បរិបូណ៌ដោយវត្ថុគួរប្រាថ្នាគ្រប់យ៉ាង ព្រះអង្គជេរប្រទេចខ្ញុំព្រះអង្គ ព្រោះហេតុនៃសេចក្តីប្រាថ្នាដូចម្តេច ខ្ញុំព្រះអង្គនឹងទៅកាន់សំណាក់នៃព្រះបាទបោរិសាទ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ញាន្តេ** បានដល់ លំនៅរបស់ស្តេចបោរិសាទ ក្នុងសម័យនោះ ព្រះហឫទ័យរបស់ព្រះរាជបិតា ក៏ក្តៅឡើងមួយរំពេច ព្រះរាជាត្រាស់ថា នៃបាសុតសោម ហេតុអ្វី ទើបពោលយ៉ាងនេះ បិតានឹងចាប់ចោរដោយចតុរង្គសេនា ហើយត្រាស់គាថានេះថា

ដ្បិតពួកពលទាំងនុ៎ះ គឺពលដំរី ពលរថ ពលថ្មើរជើង ពលសេះនិងខ្មាន់ធ្នូ ក៏មានសម្រាប់រក្សាខ្លួន យើងនឹងលើកពលសេនាទៅសម្លាប់សត្រូវ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ហាឆាម** បានដល់ បើសេនាដែលយើងត្រៀមទុកយ៉ាងនេះ អាចចាប់ចោរនោះបាន លំដាប់នោះ យើងនឹងនាំជនអ្នកដែនទាំងអស់ទៅចាប់ចោរនោះ ហើយសម្លាប់ចោល គឺសម្លាប់សត្រូវដែលជាបច្ចាមិត្តរបស់ពួកយើងនោះ ។

លំដាប់នោះ ព្រះរាជមាតាបិតា មានព្រះភក្ត្រជោកដោយអស្សុជល ទ្រង់ព្រះកន្សែងរៀបរាប់ថា កុំទៅឡើយបា បាទៅមិនបានឡើយ ទាំងស្រីស្នំ ១៦០០០ ទាំងរាជបរិវារក្រៅអំពីនេះ ក៏បរិទេវនាថា បពិត្រព្រះសម្មតិទេព ទ្រង់នឹងយាងទៅណា ចោលពួកខ្ញុំឲ្យអនាថា សូម្បីបុគ្គលណាមួយ ក្នុងព្រះនគរទាំងមូល ក៏មិនអាចតាំងនៅក្នុងភាវៈរបស់ខ្លួនបាន បានកើតកោលាហលដូចគ្នា ពេញព្រះនគរថា បានឮថា ព្រះរាជាទ្រង់ទទួលបេ្តជ្ញាស្ដេចបោរិសាទមក ឥឡូវនេះទ្រង់ស្ដាប់សតារហា ៤ គាថា ទ្រង់ធ្វើសក្ការៈដល់ព្រាហ្មណ៍ធម្មកថិក ថ្វាយបង្គំលាព្រះរាជមាតាបិតា ហើយនឹងយាងទៅកាន់សម្នាក់ចោរវិញ ដូច្នេះ ។ ចំណែកព្រះមហាសត្វបានស្ដាប់ព្រះតម្រាស់ព្រះរាជមាតាបិតាហើយ ត្រាស់ព្រះគាថានេះថា

> ព្រះបាទបោរិសាទ បានធ្វើនូវអំពើដ៏កម្រក្រៃលែង ចាប់ខ្ញុំព្រះ
> អង្គទាំងរស់ ហើយលែងវិញ បពិត្រព្រះអង្គជាធំជាងជន ខ្ញុំ
> ព្រះអង្គ រឭកឃើញនូវឧបការគុណក្នុងកាលមុនប្រាកដដូច្នោះ
> ខ្ញុំនឹងប្រទូស្តចំពោះស្ដេចបោរិសាទនោះ ដូចម្ដេចកើត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ជីវំ គហេត្វាន** បានដល់ ចាប់បានទាំងមាន

ជីវិត ។ បទថា **តំ តាធិសំ** បានដល់ បុព្វកិច្ចបែបនោះដែលស្តេចបោរិសាទធ្វើទុកហើយ ។ បទថា **បុព្វកិច្ចំ** បានដល់ ឧបការៈដែលមានមកហើយក្នុងកាលមុន ព្រះបាទសុតសោមទ្រង់ហៅព្រះបិតាថា **ជនិន្ទ** ។

ព្រះបាទសុតសោមទូលអនុសាសន៍ព្រះរាជមាតាបិតាហើយ ក្រាបទូលបន្តថា សូមព្រះរាជមាតាបិតាកុំវិតក្កដល់ទូលព្រះបង្គំឡើយ ទូលព្រះបង្គំមាននូវកល្យាណធម៌បានធ្វើទុកហើយ ភាពជាឥស្សរៈក្នុងឆកាមាវចរបស់ទូលព្រះបង្គំមិនបានដោយលំបាកឡើយ ហើយថ្វាយបង្គំព្រះរាជមាតាបិតា ទូលលាហើយត្រាស់ទូន្មានជនដទៃៗ ហើយយាងទៅ ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ថា

> ព្រះបាទសុតសោម ក្រាបថ្វាយបង្គំលាព្រះបិតាមាតា ប្រៀនប្រដៅអ្នកនិគមនិងពលសេនា ព្រះអង្គពោលនូវពាក្យសច្ចៈ រក្សានូវពាក្យសច្ចៈ ហើយក៏ទៅកាន់សំណាក់នៃព្រះបាទបោរិសាទ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សច្ចានុរក្ខមានោ** បានដល់ ព្រះពោធិសត្វទ្រង់រក្សាពាក្យសច្ចៈយ៉ាងមាំទាំ បានយាងទៅហើយ ។

ក្នុងយប់នោះ ព្រះពោធិសត្វប្រថាប់នៅក្នុងព្រះរាជនិវេសន៍ ។ លុះអរុណរះឡើង ក៏ថ្វាយបង្គំលាព្រះរាជមាតាបិតា ត្រាស់ទូន្មានពលនិករទូទៅហើយ ដែលពួកមហាជន មានស្រីស្នំជាដើម មានមុខជោកដោយទឹកភ្នែក កន្ទក់កន្ទេញ នាំគ្នាជូនដំណើរព្រះរាជាចេញអំពីព្រះនគរ កាលមិនអាចឲ្យមិត្តជនទាំងនោះ

ត្រឡប់បាន ទើបធ្វើស្នាមគំនូសដោយកំណាត់ឈើក្នុងផ្លូវធំ ត្រាស់ថា បើមានសេចក្តីស្រឡាញ់ក្នុងយើង ចូរកុំកន្លងស្នាមគំនូសនេះមកឡើយ មហាជនមិនអាចកន្លងព្រះរាជអាជ្ញារបស់ព្រះពោធិសត្វដែលជាអ្នកមានសីល មានតេជះ យំកន្ទក់កន្ទេញដោយសំឡេងខ្លាំង សម្លឹងមើលព្រះពោធិសត្វដែលមានអាការអង់អាចដូចរាជសីហ៍យាងទៅ កាលព្រះមហាសត្វ ផុតកន្ទុយភ្នែកហើយក៏ស្រែកយំព្រមគ្នាត្រឡប់ចូលនគរហើយ ឯព្រះពោធិសត្វ យាងទៅកាន់សម្នាក់របស់ស្តេចបោរិសាទដោយផ្លូវដែលទ្រង់មក ព្រោះហេតុនោះទើបព្រះសាស្តាត្រាស់ថា ហើយក៏ទៅកាន់សំណាក់នៃព្រះបាទបោរិសាទ ដូច្នេះ ។

## ធម្មស្សវនកណ្ឌ ចប់

តាំងអំពីព្រះពោធិសត្វយាងទៅ ស្តេចបោរិសាទគិតថា បើស្តេចសុតសោមសម្លាញ់របស់អញ ត្រូវការមក ក៏ចូរមក បើមិនមក ក៏កុំបីមក រុក្ខទេវតា ចូរដាក់ទោសដល់អញតាមសេចក្តីប្រាថ្នា អញនឹងសម្លាប់ព្រះរាជាទាំងនោះ ហើយនឹងធ្វើពលិកម្ម ដោយសាច់ដែលមានរស ៥ កាលដែលព្រះបាទបោរិសាទធ្វើជើងថ្ករ បង្កាត់ភ្លើងឆេះទ្រលោម អង្គុយសម្រួចឈើអណ្តោតរង់ចាំឲ្យមានរងើកសិន ព្រះពោធិសត្វក៏យាងទៅដល់ ស្តេចបោរិសាទ កាលបានឃើញព្រះពោធិសត្វ ក៏មានចិត្តសោមនស្សទូលសួរថា អើ សម្លាញ់ ទ្រង់យាងទៅធ្វើកិច្ចដែលគួរធ្វើស្រេចហើយឬ ព្រះមហាសត្វឆ្លើយថា ពិតហើយមហារាជ គាថាដែលព្រះកស្សបទសពលទ្រង់សម្តែងទុក យើងបានស្តាប់ហើយ ការធ្វើសក្ការៈសម្រាប់ព្រាហ្មណ៍ធម្មកថិក ខ្ញុំបានធ្វើស្រេចហើយ ព្រោះ

ហេតុនោះឈ្មោះថាខ្ញុំបានធ្វើកិច្ចដែលគួរធ្វើស្រេចហើយ កាលសម្តែងសេចក្តីនេះ ទើបត្រាស់គាថានេះថា

ការប្តេជ្ញានឹងព្រាហ្មណ៍ដែលខ្ញុំឋិតនៅក្នុងឥស្សរភាព ក្នុងដែន
របស់ខ្លួនបានធ្វើហើយ ខ្ញុំជាអ្នករក្សានូវសច្ចៈ ដោះប្តេជ្ញានឹង
ព្រាហ្មណ៍ហើយ ត្រឡប់មកវិញ បពិត្រព្រះបាទបោរិសាទ ចូរ
ព្រះអង្គបូជាយញ្ញ សូមព្រះអង្គសោយនូវខ្ញុំចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យជស្សុ** បានដល់ អញ្ជើញទ្រង់សម្លាប់ខ្ញុំហើយបូជាយញ្ញដល់ទេវតា ឬចូរទំពាស៊ីសាច់របស់ខ្ញុំក៏បាន ។

ព្រះបាទបោរិសាទបានស្តាប់ដូច្នោះ គិតថា ព្រះរាជានេះមិនខ្លាច ជាអ្នកអង់អាច មិនញាប់ញ័រចំពោះមរណភ័យ បានត្រាស់ដូច្នេះ នេះដោយអានុភាពអ្វីហ្ន៎ ទើបសន្និដ្ឋានថា វត្ថុដទៃមិនមាន ព្រះបាទសុតសោមត្រាស់ថា យើងបានស្តាប់គាថាដែលព្រះកស្សបទសពលទ្រង់សម្តែងហើយ នោះគប្បីជាអានុភាពរបស់គាថានោះ អញនឹងឲ្យទ្រង់ត្រាស់គាថានោះ ដែលជាគាថា មិនមានការតក់ស្លុតយ៉ាងនេះ ហើយពោលគាថានេះថា

ទ្រង់មិនបាត់ទេ ចាំខ្ញុំស៊ីជាខាងក្រោយចុះ ព្រោះជើងថ្ករនេះ
ប្រកបដោយផ្សែងនៅឡើយ សាច់ដែលចម្អិនលើភ្លើងឥត
ផ្សែង ជាសាច់ឆ្អិនល្អ យើងនឹងស្តាប់នូវគាថារបស់ទ្រង់ ដែល
គួរដល់ថ្លៃ ១០០ កហាបណាសិន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ខាទិតុំ** បានដល់ ការទំពាស៊ី អធិប្បាយថា

ការបរិភោគខ្លួនទ្រង់នោះ សម្រាប់ខ្ញុំនឹងស៊ីមុន ឬក្រោយក៏បាន មិនបាត់ទៅណាទេ តែខ្ញុំគប្បីស៊ីទ្រង់ក្នុងកាលជាក្រោយ ។ បទថា **បចិតំ** បានដល់ សាច់ដែលឲ្យឆ្អិនក្នុងភ្លើងដែលមិនមានផ្សែង គឺមិនមានអណ្តាត ឈ្មោះថា ឆ្អិនល្អ ។

ព្រះមហាសត្វទ្រង់ស្តាប់ដូច្នោះ ទើបព្រះតម្រិះថា បោរិសាទនេះ ជាមនុស្សមានធម៌អាក្រក់ អញសម្មតទ្រង់បន្តិចដើម្បីឲ្យកើតហិរិ ហើយសឹមសម្តែងធម៌ឲ្យស្តាប់ ហើយត្រាស់គាថានេះថា

ព្រះអង្គជាអធម្មិករាជ ជាអ្នកស៊ីនូវបុរស ខ្ចាត់ខ្ចាត់អំពីដែន
ព្រោះហេតុតែពោះ គាថាទាំងឡាយនេះរមែងប្រកាសសុចរិត
ធម៌ ចំណែកធម៌និងអធម៌ ស្របគ្នាក្នុងទីណាកើត ។

ព្រះអង្គជាអធម្មិករាជ ព្រះហស្តប្រឡាក់ឈាមជានិច្ច មិន
មានសច្ចៈ ធម៌នឹងមានមកអំពីណា ព្រះអង្គនឹងធ្វើអ្វីដោយ
ការស្តាប់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធម្មញ្ញិមា** បានដល់ គាថាទាំងនេះ ពោលសរសើរលោកុត្តរធម៌ ៩ ប្រការ ។ បទថា **កុហឹ សមេតិ** អធិប្បាយថា នឹងរួមគ្នាបានដូចម្តេច ព្រោះថា ធម៌ ញុំាងសត្វឲ្យដល់សុគតិ ឬព្រះនិព្វាន ឯអធម៌ ញុំាងសត្វឲ្យដល់ទុគ្គតិ ។ បទថា **សច្ចំ** បានដល់ ត្រឹមតែពាក្យពិតមិនមានផង ធម៌នឹងមានអំពីណា ។ បទថា **កឹ សុតេន** អធិប្បាយថា ទ្រង់នឹងធ្វើអ្វីដោយការស្តាប់ ព្រោះទ្រង់មិនមែនជាភាជនៈរបស់ធម៌ ដូចភាជនៈដីមិនមែនជាភាជនៈសម្រាប់ដាក់ខ្លាញ់រាជសីហ៍ ដូច្នោះ ។

កាលព្រះពោធិសត្វត្រាស់យ៉ាងនេះហើយ ស្តេចបោរិសាទក៏មិនខឹង ព្រោះហេតុអ្វី ព្រោះព្រះមហាសត្វជាបុគ្គលប្រសើរ ដោយមេត្តាភាវនា ។ លំដាប់នោះ ស្តេចបោរិសាទក៏ទូលថា សុតសោមសម្លាញ់ ខ្ញុំជាអ្នកប្រព្រឹត្តអធម៌ម្នាក់ឯងឬ ហើយពោលគាថានេះថា

បុគ្គលណា ត្រាច់ទៅកាន់ទីសម្លាប់ម្រឹគ ព្រោះហេតុតែសាច់
ឬសម្លាប់បុរស ព្រោះហេតុតែខ្លួន បុគ្គលទាំងពីរនោះស្មើគ្នា
ក្នុងលោកខាងមុខ ហេតុអ្វីព្រះអង្គហៅខ្ញុំថា ជាអធម្មិករាជ
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កស្មា នោ** សេចក្តីថា ស្តេចបោរិសាទទូលថា ពួកព្រះរាជាក្នុងជម្ពូទ្វីបតែងខ្លួនហើយ មានពលនិករជាបរិវារធំ ទ្រទ្រង់នូវរថយ៉ាងល្អ ត្រាច់ប្រពាតព្រៃ ដែលជាទីសម្រាប់សម្លាប់ម្រឹគ បាញ់ម្រឹគដោយព្រួញដ៏មុត សម្លាប់ឲ្យស្លាប់ ហេតុអ្វី ទើបទ្រង់មិនត្រាស់ដល់ព្រះរាជាទាំងនោះផង មកស្តីថាដល់ខ្ញុំដែលប្រព្រឹត្តអធម៌តែម្នាក់ឯង បើគេមិនមានទោស ខ្ញុំក៏មិនមានទោសដូចគ្នា ។

ព្រះមហាសត្វទ្រង់ស្តាប់ដូច្នោះ កាលទ្រង់កែនូវទិដ្ឋិរបស់ស្តេចបោរិសាទនោះ ទើបត្រាស់ថា

ក្សត្រិយ៍ជាអ្នកចេះដឹង មិនគួរសោយនូវពួកសត្វ ៥ នឹង ៥
ទេ បពិត្រព្រះរាជា ព្រះអង្គសោយនូវសាច់ ដែលមិនគួរ
សោយ ព្រោះហេតុនោះ ទើបព្រះអង្គឈ្មោះថាជាអធម្មិករាជ

ដូច្នេះ ។

គាថានោះ មានអធិប្បាយថា នែបោរិសាទសម្លាញ់ ធម្មតាក្សត្រដែលដឹងធម៌របស់ក្សត្រ មិនគួរបរិភោគសាច់សត្វ មានដំរីជាដើម ៥ ប្រភេទ ២ ដងរួមជា ១០ ប្រភេទ ដែលជាមំសៈមិនគួរបរិភោគ ។ បទថា **ន ខោ** ក្នុងគាថានោះបាលីច្បាប់ខ្លះដាក់ថា **នខោ** ដូច្នេះក៏មាន ន័យម្យ៉ាងទៀត មានអធិប្បាយថា ក្សត្រដែលស្គាល់ខត្តិយធម៌ គួរបរិភោគសាច់សត្វ ៥ ប្រភេទ គឺទន្សាយ ប្រមាទន្សង ជ្រូក អណ្តើក បណ្តាសត្វដែលមានក្រចក ៥ នោះជាកិច្ចាហារ តែមិនគួរបរិភោគសាច់ដទៃ ឯទ្រង់បរិភោគសាច់មនុស្ស ដែលជាសាច់មិនគួរបរិភោគឡើយ ព្រោះដូច្នោះ ទើបទ្រង់ជាអ្នកមិនតាំងនៅក្នុងធម៌ ។

ស្តេចបោរិសាទត្រូវព្រះមហាសត្វសង្កត់សង្កិនយ៉ាងនេះ មើលមិនឃើញឧបាយ ដែលនឹងត្រូវឆ្លើយដទៃបាន កាលនឹងឲ្យព្រះមហាសត្វទទួលបាបខ្លះ ទើបពោលគាថានេះថា

លោកបានរួចអំពីដៃបោរិសាទហើយ ទៅកាន់មន្ទីររបស់ខ្លួន
តាមសេចក្តីប្រាថ្នា ហើយត្រឡប់មករកដៃរបស់សត្រូវវិញ
បពិត្រព្រះរាជា ព្រះអង្គជាបុគ្គលមិនឈ្លាសក្នុងខត្តិយធម៌ទេ
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ន ខត្តធម្មេ** សេចក្តីថា ស្តេចបោរិសាទពោលថា ទ្រង់មិនឈ្លាសគម្ពីរក្នុងនីតិសាស្ត្រ ដែលជាខត្តិយធម៌ ទ្រង់មិនស្គាល់សេចក្តីចម្រើននិងសេចក្តីវិនាសរបស់ខ្លួន កិត្តិយសរបស់ព្រះអង្គ ល្បីខ្ទរខ្ទើទៅ

ក្នុងលោកថា ជាបណ្ឌិត ដោយមិនមានហេតុ ឯខ្ញុំមិនឃើញឡើយថា ទ្រង់ជាបណ្ឌិត ទ្រង់ជាបុគ្គលល្ងង់ខ្លៅបំផុត ។ ព្រះមហាសត្វទ្រង់បានស្តាប់ដូច្នោះ ត្រាស់ថា នែសម្លាញ់ បុគ្គលដែលឈ្លាសក្នុងខត្តិយធម៌ ជាបុគ្គលដូចខ្ញុំនេះឯង ព្រោះខ្ញុំស្គាល់ខត្តិយធម៌ តែមិនបដិបត្តិដូចដែលទ្រង់ ពោលហើយត្រាស់គាថានេះថា

ពួកបុគ្គលណា ជាអ្នកឈ្លាសក្នុងខត្តិយធម៌ ពួកបុគ្គលនោះ
ច្រើនតែធ្លាក់ទៅក្នុងនរក ព្រោះហេតុនោះ បានជាខ្ញុំលះបង់
នូវខត្តិយធម៌ ជាអ្នករក្សានូវសច្ចៈ ត្រឡប់មកវិញ បពិត្រ
ព្រះបាទបោរិសាទ សូមព្រះអង្គបូជាយញ្ញ សូមព្រះអង្គសោយ
នូវខ្ញុំចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កុសលា** បានដល់ ឈ្លាសក្នុងការបដិបត្តិដើម្បីភាពយ៉ាងនោះ ។ បទថា **ចាយេន** បានដល់ ជនទាំងនោះដោយច្រើនត្រូវធ្លាក់នរក ឯជនពួកណា មិនកើតក្នុងនរកនោះ ជនទាំងនោះ ក៏រមែងកើតក្នុងអបាយដ៏សេស ។

ស្តេចបោរិសាទពោលថា

ប្រាសាទជាទីនៅលើផែនដីគោនិងសេះ ពួកស្រីដែលគួរប្រាថ្នា
នឹងខ្លឹមចន្ទន៍ក្នុងដែនកាសី ទ្រង់បាននូវវត្ថុទាំងអស់ ក្នុងទីនោះ
ដោយភាពជាម្ចាស់ ចុះទ្រង់ឃើញនូវអានិសង្សនៃពាក្យសច្ចៈ
ដូចម្តេច ដូច្នេះ ។

*បណ្ដាបទទាំងនោះ បទថា* **ចាសាទវាសា** *សេចក្ដីថា នៃសុតសោម សម្លាញ់ ប្រាសាទដែលជាទីប្រថាប់គន់បីខួន សាងឡើងដូចទិព្វវិមាន សមគួរដល់រដូវទាំង ៣ របស់ទ្រង់ ។ បទថា* **បថវីគវស្សា** *បានដល់ ផែនដីគោនិងសេះ ។ បទថា* **កាមិត្ថិយោ** *បានដល់ ស្ត្រីដែលជាវត្ថុនៃកាមារម្មណ៍ ។ បទថា* **កាសិកចន្ទនញ្ច** *បានដល់ សំពត់កាសិកពស្រ្តនិងខ្លឹមចន្ទន៍ក្រហម ។ បទថា* **សព្វំ តហឹ** *សេចក្ដីថា វត្ថុទាំងនេះ និងគ្រឿងឧបភោគដទៃ ទ្រង់រមែងបានក្នុងព្រះនគររបស់ទ្រង់គ្រប់យ៉ាង ព្រោះទ្រង់ជាម្ចាស់ កាលទ្រង់ជាម្ចាស់ហើយ ក៏បានបរិភោគតាមប្រាថ្នា ទ្រង់លះបង់នូវវត្ថុទាំងអស់នោះ រក្សានូវសច្ចៈ យាងមកក្នុងទីនេះ ទ្រង់ឃើញអានិសង្សដូចម្ដេចដោយសច្ចៈ ។*

*លំដាប់នោះ ព្រះមហាសត្វត្រាស់គាថានេះថា*

*រសឯណាទីមួយ មាននៅលើផែនដី សច្ចៈជារសល្អក្រៃលែង*
*ជាងរសទាំងឡាយនោះ ពួកសមណៈនិងព្រាហ្មណ៍ដែលតាំង*
*នៅក្នុងសច្ចៈ រមែងឆ្លងទៅកាន់ត្រើយនៃជាតិនិងមរណៈបាន*
*ដូច្នេះ ។*

*បណ្ដាបទទាំងនោះ បទថា* **សាធុតរំ** *អធិប្បាយថា ព្រោះហេតុដែលរសទាំងអស់ រមែងជារបស់ប្រណីតដល់សត្វទាំងឡាយ សព្វកាលនោះឯង ព្រោះហេតុនោះ ទើបសច្ចៈល្អជាងរសទាំងនោះ ម្យ៉ាងទៀត ព្រោះហេតុដែលបុគ្គលតាំងនៅក្នុងវិរតិសច្ចៈនិងវចីសច្ចៈហើយ រមែងឆ្លងត្រើយនៃតេភូមិកវដ្ដ គឺជាតិនិងមរណៈបាន គឺដល់នូវអមតមហានិព្វានបាន ព្រោះហេតុនោះ ទើប*

សច្ចៈប្រសើរ ជាងរសទាំងនោះ ។

ព្រះមហាសត្វត្រាស់អានិសង្សក្នុងពាក្យសច្ចៈ ដល់ស្តេចបោរិសាទ ដោយប្រការដូច្នេះហើយ លំដាប់នោះ ស្តេចបោរិសាទសម្លឹងមើលព្រះភក្ត្ររបស់ព្រះមហាសត្វដែលដូចគ្នានឹងផ្កាឈូករីកនិងព្រះចន្ទពេញវង់ ទ្រង់ត្រិះរិះថា សុតសោមនេះ សូម្បីឃើញគំនររងើកភ្លើងនិងឃើញអញចាំងឈើអណ្តែត អាការរបស់ទ្រង់ត្រឹមតែតក់ស្លុតមិនមាន នេះជាអានុភាពនៃសតារហគាថា ឬនៃសច្ចៈ ឬរបស់ដទៃណាមួយហ្ន៎ អញនឹងសួរទ្រង់មើល កាលនឹងសួរ ទើបពោលគាថានេះថា

ទ្រង់បានរួចអំពីដៃ បោរិសាទហើយ បានទៅកាន់មន្ទីររបស់
ខ្លួនវិញ តាមសេចក្តីប្រាថ្នា ត្រឡប់មករកដៃសត្រូវវិញ បពិត្រ
ទ្រង់ជាធំជាងជន ភ័យអំពីសេចក្តីស្លាប់មិនមានដល់ទ្រង់
ដោយពិត ទ្រង់ជាអ្នកពោលនូវពាក្យសច្ចៈ ទាំងមានចិត្តក៏
មិនរួញរា ដូច្នេះ ។

លំដាប់នោះ ព្រះមហាសត្វ កាលត្រាស់ដល់ស្តេចបោរិសាទនោះ បានពោលគាថាដូច្នេះថា

យញ្ញ ( ការបូជា ) មានច្រើនប្រការ ជាកល្យាណធម៌
ដែលខ្ញុំបានធ្វើហើយ បូជាហើយ ជាបូជាដ៏ធំទូលាយ ដែល
អ្នកប្រាជ្ញតែងសរសើរ ផ្លូវសម្រាប់បរលោក ខ្ញុំក៏បានជម្រះ
ហើយ អ្នកណាឋិតនៅក្នុងធម៌ហើយនឹងខ្លាចសេចក្តីស្លាប់ ។

យញ្ញមានច្រើនប្រការ ជាកល្យាណធម៌ដែលខ្ញុំបានធ្វើហើយ បូជាហើយ ជាបូជាដ៏ធំទូលាយ ដែលអ្នកប្រាជ្ញតែងសរសើរ ខ្ញុំមិនក្តៅក្រហាយនឹងទៅកាន់បរលោកទេ បពិត្រព្រះបាទបោរិសាទ សូមព្រះអង្គបូជាយញ្ញ សូមព្រះអង្គសោយខ្ញុំចុះ ។ មាតានិងបិតា ខ្ញុំបានបម្រើហើយ ឥស្សរភាពខ្ញុំគ្រប់គ្រងហើយតាមធម៌ ផ្លូវសម្រាប់បរលោកខ្ញុំក៏បានជម្រះហើយ អ្នកណាឋិតនៅក្នុងធម៌ហើយនឹងខ្លាចសេចក្តីស្លាប់ ។ បិតានិងមាតា ខ្ញុំក៏បានបម្រើហើយ ឥស្សរភាពខ្ញុំគ្រប់គ្រងហើយតាមធម៌ ខ្ញុំមិនក្តៅក្រហាយនឹងទៅបរលោកទេ បពិត្រព្រះបាទបោរិសាទសូមព្រះអង្គបូជាយញ្ញ សូមព្រះអង្គសោយខ្ញុំចុះ ។ ខ្ញុំបានធ្វើឧបការកិច្ចចំពោះពួកញាតិនិងមិត្តហើយ ឥស្សរភាព ខ្ញុំគ្រប់គ្រងហើយតាមធម៌ ផ្លូវសម្រាប់បរលោក ខ្ញុំក៏បានជម្រះហើយ អ្នកណាឋិតនៅក្នុងធម៌ហើយនឹងខ្លាចសេចក្តីស្លាប់ ។ ខ្ញុំបានធ្វើឧបការកិច្ចចំពោះពួកញាតិនិងមិត្តហើយ ឥស្សរភាពខ្ញុំគ្រប់គ្រងហើយតាមធម៌ ខ្ញុំមិនក្តៅក្រហាយនឹងទៅកាន់បរលោកទេ បពិត្រព្រះបាទបោរិសាទ សូមព្រះអង្គបូជាយញ្ញ សូមព្រះអង្គសោយខ្ញុំចុះ ។ ការឲ្យទានដល់ពួកជនជាច្រើនដោយអាការច្រើនយ៉ាងខ្ញុំក៏បានឲ្យហើយ ទាំងពួកសមណព្រាហ្មណ៍ខ្ញុំក៏បានផ្គត់ផ្គង់ហើយ ផ្លូវសម្រាប់បរលោក ខ្ញុំក៏បានជម្រះ

ហើយ អ្នកណាឋិតនៅក្នុងធម៌ហើយនឹងខ្លាចសេចក្ដីស្លាប់ ។
ការឲ្យទានដល់ពួកជនជាច្រើន ដោយអាការច្រើនយ៉ាង ខ្ញុំក៏
បានឲ្យហើយ ទាំងសមណព្រាហ្មណ៍ ខ្ញុំក៏បានផ្គត់ផ្គង់ហើយ
ខ្ញុំមិនក្ដៅក្រហាយនឹងទៅកាន់បរលោកទេ បពិត្រព្រះបាទបោរិ
សាទ សូមទ្រង់បូជាយញ្ញ សូមទ្រង់សោយខ្ញុំចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កល្យាណា** បានដល់ កល្យាណកម្ម ។ បទថា **អនេករូបា** បានដល់ ការឲ្យទានជាច្រើន ( មានបាយជាដើម ) ។ បទថា **យញ្ញា** អធិប្បាយថា ម្យ៉ាងទៀត យញ្ញដែលបរិបូណ៌ក្រៃលែង ដែលពួកបណ្ឌិតសរសើរហើយ យើងក៏បានបូជាហើយ គឺឲ្យប្រព្រឹត្តទៅហើយដោយអំណាចនៃការបរិច្ចាគវត្ថុ ១០ យ៉ាង ។ បទថា **ធម្មេ ឋិតោ** អធិប្បាយថា បុគ្គលដែលស្ថិតនៅក្នុងធម៌ដូចខ្ញុំ រៀងអ្វីដែលខ្លាចចំពោះសេចក្ដីស្លាប់ ។ បទថា **អនានុតប្បំ** បានដល់ មិនមានសេចក្ដីក្ដៅក្រហាយឡើយ ។ បទថា **ធម្មេន មេ ឥស្សរិយំ បសត្ថំ** បានដល់ រាជសម្បត្តិ ខ្ញុំក៏បានគ្រប់គ្រងហើយដោយធម៌នោះឯង ព្រោះខ្ញុំមិនបានញុំាងទសពិធរាជធម៌ឲ្យកម្រើក ។ បទថា **កតា** បានដល់ កិច្ចសម្រាប់ញាតិ ខ្ញុំក៏បានធ្វើហើយក្នុងញាតិទាំងឡាយនិងកិច្ចរបស់មិត្ត ខ្ញុំក៏បានធ្វើហើយក្នុងមិត្តទាំងឡាយ ។ បទថា **ទានំ** បានដល់ ចេតនាមួយអន្លើដោយវត្ថុ ។ បទថា **ពហុធា** បានដល់ ដោយអាការច្រើន ។ បទថា **ពហូនំ** បានដល់ ខ្ញុំឲ្យទានដល់មនុស្ស ៥ ឬ ១០ នាក់ ប៉ុណ្ណោះក៏មិនមែន ខ្ញុំបានឲ្យហើយដល់មនុស្សទាំងរយទាំងពាន់នោះឯង ។ បទថា

**សន្តប្បិតា** បានដល់ ខ្ញុំធ្វើភោជនសម្រាប់ដាក់ឲ្យពេញហើយ ទើបឲ្យឆ្អែតស្កប់ស្កល់ យ៉ាងល្អ ។

ស្តេចបោរិសាទបានស្តាប់ដូច្នោះ តក់ស្លុត គិតថា សុតសោមមហារាជនេះ ជាសប្បុរស ដល់ព្រមដោយញាណ សម្តែងធម៌ដ៏ពីរោះ បើអញស៊ីទ្រង់ក្បាលរបស់អញនឹងបែកជា ៧ ភាគ ឬផែនដីគប្បីបើកឱកាសដល់អញ ក៏បានទូលថា សុតសោមសម្លាញ់ ទ្រង់ជាសប្បុរស ខ្ញុំមិនគួរស៊ី ហើយពោលគាថានេះថា

*បុគ្គលណា ស៊ីនូវជនអ្នកពោលពាក្យសច្ចៈប្រាកដដូច្នោះក្បាលរបស់បុគ្គលនោះ នឹងបែកជា ៧ ភាគ ដូចបុរសស្គាល់នូវថ្នាំពិសហើយ ស៊ីនូវថ្នាំពិស ( ឬដូចគេចាប់ ) ពស់អាសិរពិសដែលមានពិសកាច មានតេជះខ្លាំង ដូច្នេះ ។*

បទថា **វិសំ** បានដល់ ថ្នាំពិសដែលមានជាតិពុលដ៏ពន្លឹក អាចធ្វើអ្នកស៊ីឲ្យស្លាប់ក្នុងទីនោះឯងមួយរំពេច ។ បទថា **ជលិតំ** អធិប្បាយថា បុរសនោះគប្បីចាប់អាសិរពិសត្រង់ក ដែលរុងរឿងដោយពិសរបស់ខ្លួន មានតេជះខ្លាំងក្លា ដោយតេជះនៃពិសនោះឯង ដែលត្រាច់ទៅដូចគំនរភ្លើង ដូច្នោះ ។

ស្តេចបោរិសាទទូលព្រះមហាសត្វថា នែសម្លាញ់ ទ្រង់ដូចថ្នាំពិសដ៏ពន្លឹក អ្នកណាបរិភោគទ្រង់បាន ដោយប្រការដូច្នេះនោះ ហើយប្រាថ្នានឹងស្តាប់គាថា ទើបទូលព្រះមហាសត្វ ត្រូវព្រះមហាសត្វត្រាស់ឃាត់ ដើម្បីឲ្យកើតសេចក្តីគោរពក្នុងធម៌ថា ទ្រង់មិនមែនភាជនៈសម្រាប់ដាក់គាថាដែលមិនមានទោស

មានសភាពបែបនេះ ។ ស្តេចបោរិសាទត្រិះរិះថា បុគ្គលក្នុងជម្ពូទ្វីបទាំងមូល ឈ្មោះថាជាបណ្ឌិតដូចគ្នានឹងសុតសោមនេះមិនមាន ទ្រង់ផុតចាកដៃរបស់អញទៅហើយ បានស្តាប់គាថាទាំងនោះ ធ្វើសក្ការៈដល់ធម្មកថិកហើយ គង់មកយកមច្ចុជាក់ត្រង់ថ្វាស រួចត្រឡប់មកទៀត ព្រះគាថានឹងសម្រេចប្រយោជន៍យ៉ាងសក្តិសិទ្ធិ ទើបកើតសេចក្តីគោរពក្នុងធម៌ក្រៃលែងឡើង កាលទូលអារាធនាព្រះមហាសត្វ ទើបពោលគាថានេះថា

ជនទាំងឡាយ បានស្តាប់ធម៌ហើយ រមែងដឹងច្បាស់នូវបុណ្យ
និងបាប ប៉ុនអម្បាលចិត្តរបស់ខ្ញុំគង់ត្រេកអរក្នុងធម៌ ព្រោះ
បានស្តាប់នូវគាថាទាំងឡាយ ដូច្នេះ ។

គាថានោះមានអធិប្បាយថា បពិត្រសម្លាញ់សុតសោម ធម្មតាជនទាំងឡាយ បានស្តាប់ធម៌ហើយ រមែងស្គាល់បុណ្យខ្លះ បាបខ្លះ សូម្បីចិត្តរបស់ខ្ញុំបានស្តាប់គាថានោះហើយ គប្បីត្រេកអរក្នុងធម៌ គឺកុសលកម្មបថ ១០ ប្រការបានខ្លះដោយពិត ។

លំដាប់នោះ ព្រះមហាសត្វទ្រង់ព្រះតម្រិះថា ឥឡូវនេះ ស្តេចបោរិសាទត្រូវការស្តាប់ធម៌ អញនឹងសម្តែង ដូច្នេះហើយ ត្រាស់ថា នែសម្លាញ់ បើដូច្នោះ ចូរតាំងចិត្តស្តាប់ឲ្យល្អ កាលជាស់តឿនស្តេចបោរិសាទ ឲ្យផ្ទៀងនូវសោតៈស្តាប់ហើយ ត្រាស់សរសើរព្រះគាថាតែម្យ៉ាង ដូចននូព្រាហ្មណ៍ពោលហើយ កាលពួកទេវតាក្នុងជាន់កាមាវចរទាំង ៦ ឲ្យសាធុការ សំឡេងកោលាហលក៏ឮដូចគ្នាតែមួយ ទ្រង់សម្តែងធម៌ដល់ស្តេចបោរិសាទ ត្រាស់គាថានេះថា

បពិត្រមហារាជ ការជួបប្រទះដោយសប្បុរសទាំងឡាយអស់វារៈតែម្តង ការជួបប្រទះនោះ រមែងរក្សានូវបុគ្គលនោះបាន ការជួបជុំដោយពួកអសប្បុរសច្រើនដង រមែងមិនរក្សាបុគ្គលបានទេ ។ បុគ្គលគប្បីគប់រកនឹងពួកសប្បុរស គប្បីធ្វើនូវការស្និទ្ធស្នាលនឹងពួកសប្បុរស គុណធម៌ដ៏ប្រសើររមែងកើតមានព្រោះដឹងនូវព្រះសទ្ធម្មរបស់ពួកសប្បុរស មិនមែនជាទោសដ៏លាមកទេ ។ រាជរថទាំងឡាយដែលគេរចនាល្អហើយរមែងគ្រាំគ្រា សូម្បីសរីរៈ ( របស់ពួកសត្វ ) ក៏រមែងដល់នូវសេចក្តីគ្រាំគ្រាដោយពិត ឯធម៌របស់សប្បុរស មិនដល់នូវសេចក្តីគ្រាំគ្រាទេ សប្បុរសទាំងឡាយ រមែងចរចានូវពួកសប្បុរសបាន ។ អាកាសនិងដីឋិតនៅក្នុងទីឆ្ងាយពីគ្នា អ្នកប្រាជ្ញទាំងឡាយបាន ពោលនូវច្រាំងសមុទ្រនោះថាឆ្ងាយ បពិត្រព្រះរាជា បណ្ឌិតទាំងឡាយរមែងពោលថា ធម៌របស់ពួកសប្បុរសនិងពួកអសប្បុរស ឆ្ងាយជាងនេះទៅទៀត ដូច្នេះ ។

កាលស្តេចបោរិសាទគិតថា គាថាដែលព្រះពោធិសត្វត្រាស់នោះ ដូចព្រះសព្វញ្ញុពុទ្ធត្រាស់ហើយ ព្រោះត្រាស់ទុកពីរោះ ទាំងទ្រង់ជាបណ្ឌិតផង សរីរៈទាំងមូលពេញដោយបីតិ ៥ ប្រការ ទ្រង់មានចិត្តទន់ក្នុងព្រះពោធិសត្វ សម្គាល់ព្រះពោធិសត្វដូចព្រះជនក ដែលប្រទានស្វេតច្ឆត្រ ព្រោះហេតុនោះ ទ្រង់ត្រិះរិះថា អញមិនឃើញប្រាក់មាសណាមួយ ដែលគប្បីថ្វាយព្រះបាទសុតសោម

បាន តែអញនឹងថ្វាយជាគាថាថ្វាយព្រះពរ ទើបពោលគាថាដូច្នេះថា

បពិត្រទ្រង់ជាធំជាងជន គាថាទាំងឡាយនេះ មានអត្ថ មាន ព្យញ្ជនៈដ៏ល្អ ទ្រង់សម្តែងពីរោះណាស់ ខ្ញុំបានស្តាប់ហើយ ក៏ ត្រេកអររីករាយ មានចិត្តល្អជ្រះថ្លា បពិត្រទ្រង់ជាសម្លាញ់ ខ្ញុំសូមថ្វាយពរ ៤ ប្រការដល់ទ្រង់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អានន្ទិ** បានដល់ កើតនូវការត្រេកអរឡើង ហើយ ។ បទថា **វិត្តោ សុមនោ បតីតោ** ក្រៅអំពីនោះ ជាពាក្យអធិប្បាយ ពង្រីកសេចក្តីនៃពាក្យថា **អានន្ទិ** នោះឯង ។ ពិតហើយ គាថាទាំង ៤ នេះ ក៏គឺពាក្យដែលសម្តែងដល់អាការត្រេកអរនោះឯង ។

លំដាប់នោះ ព្រះមហាសត្វកាលបៀតបៀនស្តេចបោរិសាទថា ទ្រង់នឹង ឲ្យពរអ្វីបាន ទើបត្រាស់គាថានេះថា

ទ្រង់មិនដឹងនូវសេចក្តីស្លាប់របស់ខ្លួន ទាំងអំពើមានប្រយោជន៍ និងឥតប្រយោជន៍ ទាំងនរកនិងឋានសួគ៌ទេ បពិត្រព្រះអង្គ មានធម៌ដ៏លាមកព្រះអង្គជាប់ជំពាក់ក្នុងរស ( នៃសាច់មនុស្ស ) តាំងនៅស៊ប់ក្នុងទុច្ចរិតធម៌ ធ្វើម្តេចនឹងឲ្យពរកើត ។ បើខ្ញុំ ពោលថា សូមព្រះអង្គប្រទានពរនោះ ព្រះអង្គប្រទានហើយ ត្រឡប់ជាមិនប្រទានវិញ តើបណ្ឌិតណា កាលដឹងនឹងហ៊ាន ចូលទៅរកជម្លោះនឹងវិវាទដ៏ជាក់ស្តែងនេះ[១]ដូច្នេះ ។

---

១-សេចក្តីថា បណ្ឌិតណានឹងមកវិនិច្ឆ័យនូវជម្លោះនេះបាន ។

បណ្ដាបទទាំងនោះ បទថា **យោ** អធិប្បាយថា ទ្រង់មិនដឹង គឺមិនដឹងទាំងការស្លាប់របស់ព្រះអង្គឯងថា ខ្លួនខ្ញុំនេះក៏មានការស្លាប់ជាធម្មតា ទើបបានប្រកបកម្មដ៏លាមកតែម្យ៉ាង ។ បទថា **ហិតាហិតំ** សេចក្ដីថា ទ្រង់មិនស្គាល់ថា កម្មនេះជាប្រយោជន៍ដល់អញ កម្មនេះមិនមានប្រយោជន៍ កម្មនេះនឹងនាំទៅនរក កម្មនេះនឹងនាំទៅស្ថានសួគ៌ ។ បទថា **រសេ** បានដល់ ក្នុងរសនៃសាច់មនុស្ស ។ បទថា **វឌ្ឍំ** បានដល់ គប្បីពោល ។ បទថា **ឧ អវាក-រេយ្យ** សេចក្ដីថា ទ្រង់ឲ្យពរដោយវាចា សូម្បីខ្ញុំពោលថា ទ្រង់ចូរឲ្យពរឈ្មោះនោះដល់ខ្ញុំ នឹងត្រឡប់មិនឲ្យក៏បាន ។ បទថា **ឧបញ្ញជេយ្យ** សេចក្ដីថា អ្នកណានឹងមកជាបណ្ឌិតវិនិច្ឆ័យនូវជម្លោះនេះបាន ។

លំដាប់នោះ ស្ដេចបោរិសាទត្រិះរិះថា សុតសោមនេះមិនជឿអញ អញនឹងឲ្យទ្រង់ជឿឲ្យបាន ហើយពោលគាថានេះថា

ជនឲ្យនូវពរណា ហើយត្រឡប់ជាមិនឲ្យវិញ មិនគួរឲ្យពរ
នោះទេ បពិត្រទ្រង់ជាសម្លាញ់ សូមទ្រង់កុំញាប់ញ័រ សូម
ទទួល ( ពរ ) ចុះ ខ្ញុំសូម្បីលះបង់ជីវិតក៏នៅតែថ្វាយទ្រង់
ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អវិកម្បមានោ** ក្នុងគាថានោះ សេចក្ដីថា សូមទ្រង់មានព្រះហឫទ័យជឿជាក់ចុះ ។

គ្រានោះ ព្រះមហាសត្វទ្រង់ត្រិះរិះថា ស្ដេចបោរិសាទហ៊ាននិយាយយ៉ាងហ្នឹងម៉ាត់ ទ្រង់នឹងធ្វើតាមពាក្យរបស់អញ អញនឹងទទួលពរ អញនឹងសូម

ពរថា ជាដំបូងសូមទ្រង់កុំបរិភោគសាច់មនុស្ស ទ្រង់នឹងលំបាកពេក ណ្ហើយ ចុះ អញនឹងសូមពរ ៣ ជាទៃមុន ហើយសឹមសូមពរនេះជាក្រោយ ហើយ ត្រាស់គាថានេះថា

ធម៌ជាបន្ទាល់សាក្សីរបស់អរិយៈ រមែងស្របគ្នានឹងអរិយៈ
របស់បុគ្គលមានប្រាជ្ញា រមែងស្របគ្នានឹងបុគ្គលមានប្រាជ្ញា ខ្ញុំ
សូមឃើញព្រះអង្គមានជន្មាយុ ១០០ ឆ្នាំ ឥតមានរោគ បណ្ដា
ពរទាំងឡាយ ខ្ញុំប្រាថ្នានូវពរទី ១ នុ៎ះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អរិយស្ស** បានដល់ ភាពប្រសើរ ដោយមារ យាទ ។ បទថា **សត្ភិ** បានដល់ បុណ្យសក្តិនិងសិរី គឺមិត្តធម៌ ។ បទថា **បញ្ញាណវតា** បានដល់ បុគ្គលដែលដល់ព្រមដោយការដឹង ។ បទថា **សមេតិ** បានដល់ រមែងប្រៀបធៀបគ្នាបាន ដូចប្រៀបធៀបទឹកក្នុងស្ទឹងគង្គានិងទឹកក្នុងស្ទឹងយមុនាដូច្នោះ ពិតហើយ សត្វទាំងឡាយរមែងប្រៀបធៀបគ្នាបាន ដោយធាតុ ។ បទថា **បស្សេយ្យ តំ** អធិប្បាយថា ព្រះបាទសុតសោម ទ្រង់ធ្វើដូចជាប្រាថ្នាឲ្យស្ដេចបោរិសាទមានជីវិតយឺនយូរ ទើបសូមពរ គឺជីវិតមុន ពិតហើយ ធម្មតាអ្នកប្រាជ្ញ មិនគួរពោលថា អ្នកចូរឲ្យជីវិតដល់ខ្ញុំ ម្យ៉ាងទៀត ព្រះបាទសុតសោមគិតថា ស្ដេចបោរិសាទ ស្ដាប់ពាក្យនោះហើយរមែងប្រាថ្នាការមិនមានរោគដល់អញនោះឯង ទើបពោលយ៉ាងនេះ ។

ឯស្ដេចបោរិសាទស្ដាប់ពាក្យនោះ មានចិត្តត្រេកអរថា ស្ដេចសុតសោម នេះ គង់ប្រាថ្នាការរស់នៅរបស់អញដែលជាមហាចោរ កម្ចាត់ខ្លួនចេញចាក

ឥស្សរភាព ប្រាថ្នានឹងស៊ីសាច់ក្នុងឥឡូវនេះ ដែលធ្វើនូវសេចក្តីវិនាសធំយ៉ាងនេះ ទ្រង់ប្រាថ្នាប្រយោជន៍ដល់អញ គួរសរសើរហ្ន៎ កាលនឹងថ្វាយព្រះពរ រមែងស្របតាមព្រះមហាសត្វដែលត្រាស់បញ្ជោតហើយទទួលពរនោះ ទើបពោលគាថានេះថា

ធម៌ជាបន្ទាល់សាក្សីរបស់អរិយៈ រមែងស្របគ្នានឹងអរិយៈ
របស់បុគ្គលមានប្រាជ្ញា រមែងស្របគ្នានឹងបុគ្គលមានប្រាជ្ញា
ទ្រង់សូមឃើញនូវខ្ញុំមានអាយុ ១០០ ឆ្នាំ ឥតមានរោគ
បណ្តាពរទាំងឡាយ ខ្ញុំនឹងថ្វាយពរទី ១ នេះ ដូច្នេះ ។

បទថា **វរាណំ** ក្នុងគាថានោះ សំដៅដល់ពរទី ១ បណ្តាពរ ៤ ប្រការ ។ លំដាប់នោះ ព្រះពោធិសត្វក៏ត្រាស់បន្តថា

ពួកក្សត្រណា រក្សាផែនដីក្នុងទ្វីបនេះ បានមុទ្ធាភិសេកហើយ
មានព្រះនាមសម្រេចហើយ ព្រះអង្គជាម្ចាស់ផែនដីកុំសោយ
នូវពួកក្សត្រទាំងនោះឡើយ បណ្តាពរទាំងឡាយ ខ្ញុំប្រាថ្នានូវ
ពរទី ២ នេះ ដូច្នេះ ។

បទថា **កតនាមធេយ្យា** បានដល់ បុគ្គលមានឈ្មោះបញ្ញត្តិធ្វើហើយថា **មុទ្ធាភិសិត** ព្រោះទ្រង់បានអភិសេកលើព្រះសិរសា ។ បទថា **ឧ តាទិសេ** បានដល់ ទ្រង់កុំបរិភោគស្តេចដែលបានទទួលមុទ្ធាភិសេកទាំងនោះឡើយ ។

ព្រះមហាសត្វកាលទ្រង់ទទួលពរទី ២ បានទទួលពរ គឺជីវិតរបស់ពួកក្សត្រ ១០១ អង្គ ដោយប្រការដូច្នេះ សូម្បីស្តេចបោរិសាទ កាលថ្វាយព្រះ

ពរដល់ព្រះពោធិសត្វនោះ ទើបពោលគាថានេះថា

ពួកក្សត្រណា រក្សាផែនដីក្នុងទ្វីបនេះ បានមុទ្ធាភិសេកហើយ
មានព្រះនាមសម្រេចហើយ ខ្ញុំជាម្ចាស់ផែនដី ក៏លែងស៊ីនូវ
ពួកក្សត្រទាំងនោះដែរ បណ្ដាពរទាំងឡាយ ខ្ញុំនឹងថ្វាយនូវ
ពរទី ២ នេះ ដូច្នេះ ។

មានពាក្យសួរជ្រៀតចូលមកថា ក្សត្រទាំងនោះ បានឮសំឡេងរបស់ក្សត្រទាំង ២ នោះដែរឬទេ ឆ្លើយថា មិនបានឮទាំងអស់ឡើយ ព្រោះស្ដេចបោរិសាទបង្កាត់ភ្លើងឆ្ងាយពេក ព្រោះខ្លាចអណ្ដាតភ្លើងធ្វើអន្តរាយដល់ដើមឈើ ព្រះមហាសត្វប្រថាប់គង់ ត្រាស់នឹងស្ដេចបោរិសាទត្រង់ចន្លោះគំនរភ្លើងនិងដើមឈើ ព្រោះហេតុនោះ ទើបក្សត្រទាំងនោះមិនបានឮទាំងអស់ បានឮត្រឹមពាក់កណ្ដាលប៉ុណ្ណោះ ស្ដេចទាំងនោះត្រាស់លួងលោមគ្នាថា ព្រះបាទសុតសោម ទ្រង់នឹងទូន្មានស្ដេចបោរិសាទក្នុងកាលឥឡូវនេះ កុំខ្លាចឡើយ ។ ក្នុងខណៈនោះ ព្រះមហាសត្វត្រាស់គាថាដូច្នេះថា

ពួកក្សត្រជាង ១០០ នាក់ ដែលព្រះអង្គចាប់ដោតបាតដៃ មាន
មុខជោកដោយទឹកភ្នែក កំពុងទ្រហោយំ សូមព្រះអង្គឲ្យក្សត្រ
ទាំងនោះត្រឡប់ទៅក្នុងដែនរបស់ខ្លួនវិញ បណ្ដាពរទាំងឡាយ
ខ្ញុំប្រាថ្នាពរទី ៣ នេះ ដូច្នេះ ។

បទថា **បរោសតំ** បានដល់ ចំនួនជាង ១០០ ។ បទថា **តេ គហិតា** បានដល់ ដែលទ្រង់បានចាប់ទុកហើយ ។ បទថា **តលាវុតា** បានដល់ ចាប់

ដោតត្រង់បាតដៃ ។

កាលព្រះមហាសត្វទ្រង់ទទួលពរទី ៣ ទ្រង់បានទទួលពរ គឺសូមឲ្យប្រគល់ដែនរៀងៗខ្លួនដល់ក្សត្រទាំងនោះ ដោយប្រការដូច្នេះ ។ មានពាក្យជ្រៀតសួរចូលមកថា ទ្រង់ទទួលពរនេះព្រោះហេតុអ្វី ឆ្លើយថា ស្តេចបោរិសាទទោះបីមិនបរិភោគ តែក៏អាចឲ្យក្សត្រទាំងអស់នៅជាទាសៈក្នុងព្រៃនោះក៏ថាបាន ឬអាចសម្លាប់ចោលក៏បាន ឬអាចនាំទៅលក់ក្នុងជនបទក៏បាន ព្រោះការខ្លាចចំពោះការចងពៀរ ព្រោះហេតុនោះ ទើបព្រះមហាសត្វទទួលពរ គឺសូមឲ្យប្រគល់ដែនរៀងៗខ្លួនដល់ក្សត្រទាំងនោះ ឯព្រះបាទបោរិសាទ កាលថ្វាយពរដល់មហាសត្វ ក៏ពោលគាថានេះថា

ពួកក្សត្រជាងរយនាក់ ដែលខ្ញុំចាប់ដោតបាតដៃ មានមុខជោកដោយទឹកភ្នែក កំពុងទួញយំ ខ្ញុំនឹងឲ្យពួកក្សត្រទាំងនោះ ត្រឡប់ទៅក្នុងដែនរបស់ខ្លួនវិញ បណ្តាពរទាំងឡាយ ខ្ញុំនឹងថ្វាយពរទី ៣ នេះ ដូច្នេះ ។

កាលព្រះមហាសត្វទទួលពរទី ៤ បានត្រាស់គាថានេះថា

ដែនរបស់ព្រះអង្គ ជាដែនប្រហោង ( មិនសូវមានប្រជាជន ) ព្រោះពួកប្រជាជនជាច្រើនញាប់ញ័រហើយ ព្រោះភ័យគ្របសង្កត់ ហើយរត់ចូលទៅកាន់ទីពឹងពួន បពិត្រព្រះរាជា សូមព្រះអង្គវៀរសាច់មនុស្សទៅ បណ្តាពរទាំងឡាយ ខ្ញុំប្រាថ្នាពរទី ៤ នេះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ជិន្នំ** សេចក្ដីថា ដែនរបស់ទ្រង់ជាដែនប្រហោង ព្រោះអ្នកស្រុកជាដើមដែលតាំងនៅក្នុងទីនោះៗ ត្រូវកាសខ្ទួនទៅ ។ បទថា **ព្យថិតា ភយា ហិ** សេចក្ដីថា នរជនទាំងឡាយតក់ស្លុត ព្រោះខ្លាចទ្រង់ថា ស្ដេចបោរិសាទនឹងមកក្នុងកាលឥឡូវនេះ ។ បទថា **លេណាមនុប្បវិដ្ឋា** សេចក្ដីថា នាំគ្នាបីកូនពរចៅគេចទៅពួនតាមទីដែលមានស្មៅក្រាស់ជាដើម ។ បទថា **មនុស្សមំសំ** សេចក្ដីថា សូមទ្រង់វៀរសាច់មនុស្សដែលជារបស់គួរខ្ពើម មានក្លិនស្អុយចុះ ។ ពាក្យនេះជាទុតិយាវិភត្តិប្រើក្នុងអត្ថបញ្ចមីវិភត្តិ ក៏បានសេចក្ដីថា ចូរវៀរបង់នូវសាច់មនុស្សចុះ ។

កាលព្រះពោធិសត្វត្រាស់យ៉ាងនេះហើយ ស្ដេចបោរិសាទទះដៃសើចទូលថា សុតសោមសម្លាញ់ ឯងពោលដល់រឿងនេះឬ ព្រោះពរនេះ ស្មើនឹងជីវិតខ្ញុំនឹងឲ្យដល់ទ្រង់បានដូចម្ដេច បើទ្រង់ប្រាថ្នានឹងទទួល ចូរទទួលពរដទៃចុះ ហើយពោលថា

> អាហារនោះ ជាទីពេញចិត្តរបស់ខ្ញុំដោយពិត ខ្ញុំចូលព្រៃ ព្រោះ
> ហេតុតែសាច់មនុស្សនោះឯង នឹងវៀរចាកសាច់មនុស្សនោះ
> ដូចម្ដេចបាន បណ្ដាពរទាំងឡាយ សូមទ្រង់ប្រាថ្នានូវពរទី ៤
> ដទៃវិញ ដូច្នេះ ។

បទថា **វនំ** សេចក្ដីថា ខ្ញុំលះរាជសម្បត្តិហើយចូលកាន់ព្រៃនេះ ។

លំដាប់នោះ ព្រះមហាសត្វក៏ត្រាស់នឹងស្ដេចបោរិសាទថា ទ្រង់ពោលថា មិនអាចវៀរបាន ព្រោះសាច់មនុស្សជារបស់ស្រឡាញ់ក្រៃលែង បុគ្គលណា

ធ្វើបាប ព្រោះហេតុរបស់ស្រឡាញ់ បុគ្គលនោះ ជាអន្ធពាល ហើយត្រាស់គាថាដូច្នេះថា

បពិត្រព្រះអង្គជាធំជាងជន បុគ្គលប្រហែលដូចព្រះអង្គ លះបង់នូវខ្លួនចោល ដោយគិតថា នេះជាទីស្រឡាញ់របស់អញ ដូច្នេះ រមែងមិនបានគប់រកនូវវត្ថុជាទីស្រឡាញ់ទេ ខ្លួនហ្នឹងហើយ ជាសភាវៈប្រសើរ ឈ្មោះថាប្រសើរក្រៃលែង បុគ្គលអ្នកមានចិត្តសន្សំហើយ គប្បីបាននូវគុណជាទីស្រឡាញ់ក្នុងកាលជាខាងក្រោយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥានិសោ** សេចក្តីថា នៃព្រះអង្គជាចមនៃនរៈទ្រង់នៅក្មេង មានរូបស្អាត មានយសធំ ធ្វើខ្លួនឲ្យឆ្ងាយពីសេចក្តីល្អដោយសេចក្តីលោភក្នុងវត្ថុដែលជាទីស្រឡាញ់ថា ឈ្មោះថាវត្ថុនេះ រមែងជាទីស្រឡាញ់របស់យើង ឃ្លាតចាកសុគតិទាំងអស់ និងវិស័យនៃសេចក្តីសុខធ្លាក់ក្នុងនរកតែម្យ៉ាង ឈ្មោះថា មិនបានសេពនូវវត្ថុនោះ ៗ ដែលជាទីស្រឡាញ់ទាំងឡាយ ។ បទថា **បរមាវ សេយ្យោ** សេចក្តីថា ព្រោះថា ខ្លួនរបស់បុរសនោះឯងប្រសើរជាងវត្ថុដែលជាទីស្រឡាញ់ដទៃៗ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះបុគ្គលមានខ្លួនអប់រំហើយ គប្បីបាននូវវត្ថុដែលជាទីស្រឡាញ់ក្នុងកាលជាខាងក្រោយ ។ បទថា **លព្ភា បិយា** សេចក្តីថា ឈ្មោះថា **បិយា** ដែលបុគ្គលមានខ្លួនអប់រំហើយ និងមានខ្លួនដែលចម្រើនហើយដោយអំណាចនៃវិស័យ ដែលជាទីស្រឡាញ់និងបុណ្យ ធ្វើនូវសម្បត្តិក្នុង

ទេវតានិងមនុស្សហើយ ក៏អាចបានក្នុងទិដ្ឋធម៌ ឬក្នុងលោកខាងមុខ ។

កាលព្រះពោធិសត្វ ត្រាស់យ៉ាងនេះហើយ ស្តេចបោរិសាទញាប់ញ័រត្រិះរិះថា អញមិនអាចឲ្យសុតសោមលះបង់ពរនេះបានទេដឹង សូម្បីសាច់មនុស្សអញក៏មិនអាចអត់បាន នឹងធ្វើដូចម្តេចល្អហ្ន៎ បើទ្រង់ត្រាស់សូមពរទី ៤ ដទៃអញនឹងថ្វាយទ្រង់ក្លាម តើអញរស់នៅបានដូចម្តេច មានភ្នែកជោកដោយអស្សុជលពោលគាថានេះថា

បពិត្រព្រះបាទសុតសោម សូមទ្រង់ជ្រាបនូវសាច់មនុស្សថា ជាទីស្រឡាញ់របស់ខ្ញុំ ទ្រង់មិនអាចឃាត់ខ្ញុំបានទេ បពិត្រទ្រង់ជាសម្លាញ់ សូមទ្រង់ប្រាថ្នាពរឯទៀតវិញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិជានហិ** សេចក្តីថា សូមទ្រង់ចាំទុកចុះ ។ គ្រានោះ ព្រះមហាសត្វត្រាស់ថា

បុគ្គលណាជាអ្នករក្សានូវវត្ថុជាទីស្រឡាញ់ ដោយគិតថា វត្ថុនេះជាទីស្រឡាញ់របស់អញដូច្នេះ លះបង់ខ្លួនហើយនៅសេពគប់វត្ថុជាទីស្រឡាញ់ បុគ្គលនោះ រមែងជាទុក្ខក្នុងកាលខាងមុខ ព្រោះអំពើនោះឯង ដូចជាអ្នកលេងសុរា ផឹកទឹកសុរាដែលលាយដោយថ្នាំពិស ។ ចំណែកខាងបុគ្គលណា ក្នុងលោកនេះ បានពិចារណា លះបង់នូវវត្ថុទីស្រឡាញ់ហើយ បែរមកគប់រកនូវអរិយធម៌ សូម្បីដោយលំបាក បុគ្គលនោះ រមែងបានសុខ ក្នុងកាលខាងមុខ ព្រោះអំពើនោះឯង ដូច

បុគ្គលដល់នូវសេចក្តីទុក្ខ ព្រោះផឹកនូវឱសថ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យោ ច** អធិប្បាយថា បោរិសាទសម្លាញ់ បុរសណា ធ្វើខ្លួនឲ្យឆ្ងាយចាកសេចក្តីល្អ ដោយការធ្វើបាបថា វត្ថុនេះជាទីស្រឡាញ់ដល់យើង ហើយសេពនូវរបស់ជាទីស្រឡាញ់ បុរសនោះរមែងបានទទួលនូវសេចក្តីទុក្ខក្នុងអបាយមាននរកជាដើមក្នុងលោកខាងមុខ ព្រោះកម្មបែបនោះ ប្រៀបដូចអ្នកលេងសុរា ផឹកនូវសុរាដែលលាយថ្នាំពិស ព្រោះខ្លួនគាប់ចិត្តក្នុងសុរា ដូច្នោះ ។ បទថា **សង្ខាយ** សំដៅដល់ ដឹងខ្លួន ពិចារណាខ្លួនឯងបាន ។ បទថា **បិយានិ ហិត្វា** អធិប្បាយថា លះនូវរបស់ជាទីស្រឡាញ់ដែលប្រកបដោយរបស់ដែលមិនជាធម៌បាន ។

កាលព្រះពោធិសត្វ ត្រាស់យ៉ាងនេះហើយ ស្តេចបោរិសាទទ្រហោយំពោលគាថានេះថា

ខ្ញុំលះបង់បិតាមាតា និងបញ្ចកាមគុណជាទីពេញចិត្តហើយ
ចូលព្រៃ ព្រោះហេតុតែសាច់មនុស្សនោះ ខ្ញុំនឹងថ្វាយនូវពរ
នោះ ដល់ទ្រង់ដូចម្តេចបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឯតស្ស** នេះ ស្តេចបោរិសាទសម្តែងដល់សាច់មនុស្ស ។ បទថា **កិន្តិមហំ** អធិប្បាយថា ខ្ញុំនឹងធ្វើដូចម្តេច ទើបថ្វាយពរនេះដល់ទ្រង់បាន ។

លំដាប់នោះ ព្រះមហាសត្វក៏ត្រាស់គាថានេះថា

បណ្ឌិតទាំងឡាយជាសប្បុរស ជាអ្នកប្តេជ្ញាដោយពាក្យសច្ចៈ

មិនពោលនូវពាក្យពីរជាន់ទេ ព្រះអង្គបានពោលនឹងខ្ញុំថា បពិត្រ
ទ្រង់ជាសម្លាញ់ សូមទ្រង់ទទួលពរចុះ ព្រះអង្គបានពោល
ដូច្នេះហើយ ( តែពាក្យនោះ ) របស់ព្រះអង្គមិនស្រេបគ្នាទេ
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធិគុណំ** អធិប្បាយថា បោរិសាទសម្លាញ់
ធម្មតាបណ្ឌិតពោលពាក្យមួយហើយ មិនធ្វើពាក្យនោះឲ្យឃ្លៀងឃ្លាត រមែង
មិនពោលពាក្យបែកជា ២ ។ បទថា **ឥតិ មំ អវោច** សេចក្តីថា ទ្រង់បាន
ពោលទុកនឹងខ្ញុំហើយយ៉ាងនេះថា នែសុតសោមសម្លាញ់ សូមទ្រង់ទទួលពរ
ចុះ ។ បទថា **ឥច្ចព្រវី** សេចក្តីថា ព្រោះហេតុនោះ ពាក្យណា ទ្រង់ពោល
ទុកហើយដោយប្រការដូច្នេះ ពាក្យនោះរមែងមិនសមនឹងពាក្យរបស់ទ្រង់ក្នុង
កាលឥឡូវនេះឡើយ ។

ស្តេចបោរិសាទស្រែកយំទៀត ពោលគាថាយ៉ាងនេះថា

ខ្ញុំដល់នូវភាពជាអ្នកមិនមានបុណ្យ មិនមានយស មិនមាន
កេរ្តិ៍ឈ្មោះ មានបាប មានទុច្ចរិតស្មោហ្មងជាច្រើន ក៏ព្រោះ
ហេតុតែសាច់មនុស្ស ខ្ញុំនឹងថ្វាយនូវពរនោះដល់ទ្រង់ ដូចម្តេច
កើតដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធាបំ** បានដល់ មិនទាន់ដល់កម្មបថ ។ បទ
ថា **ទុច្ចរិតំ** បានដល់ ដល់កម្មបថហើយ ។ បទថា **កិលេសំ** បានដល់ សេចក្តី
លំបាក ។ បទថា **មនុស្សមំសស្ស ការេ** ព្រោះហេតុនៃសាច់មនុស្ស ។ បទ

ថា **ឧបាគា** បានដល់ ខ្ញុំជាអ្នកចូលដល់ហើយ ។ បទថា **តទេ្ហ** សេចក្តីថា ស្តេចបោរិសាទពោលថា ខ្ញុំថ្វាយព្រះពរនោះដល់ព្រះអង្គដូចម្តេចបាន ទ្រង់កុំឃាត់ខ្ញុំឡើយ សូមទ្រង់ធ្វើសេចក្តីអនុគ្រោះ សេចក្តីករុណាដល់ខ្ញុំចុះ សូមទ្រង់ទទួលពរដទៃចុះ ។

លំដាប់នោះ ព្រះមហាសត្វត្រាស់នឹងស្តេចបោរិសាទទៀតថា

( ទ្រង់មានបន្ទូលហើយថា ) ជនឲ្យនូវពរណា ហើយត្រឡប់
ជាមិនឲ្យវិញ មិនគួរឲ្យពរនោះទេ បពិត្រទ្រង់ជាសម្លាញ់ សូម
ទ្រង់កុំញាប់ញ័រ សូមទទួលយក ( ពរ ) ចុះ ខ្ញុំសូម្បីលះ
បង់ជីវិត ក៏នៅតែថ្វាយទ្រង់ដែរ ដូច្នេះ ។

កាលព្រះពោធិសត្វទ្រង់នាំគាថា ដែលស្តេចបោរិសាទនោះពោលអំពីមុនមកសម្តែងយ៉ាងនេះហើយ កាលទ្រង់ជម្រុញឲ្យស្តេចបោរិសាទអង់អាចក្នុងការឲ្យពរ ទើបត្រាស់ថា

នុ៎ះជាធម៌របស់ពួកសប្បុរស ធម្មតាពួកសប្បុរសជាអ្នកប្តេជ្ញា
ដោយពាក្យសច្ចៈ តែងលះបង់នូវជីវិត ព្រះអង្គឲ្យពរហើយ
ចូរឲ្យរហ័ស បពិត្រព្រះរាជាដ៏ប្រសើរ សូមព្រះអង្គសម្រេច
ដោយធម៌ និងពាក្យសច្ចៈនុ៎ះចុះ ។ ជនគប្បីលះបង់នូវទ្រព្យ
ព្រោះហេតុនៃអវយវៈដ៏ប្រសើរ កាលបើរក្សានូវជីវិតក៏គប្បី
លះបង់នូវអវយវៈ កាលបើរឭកឃើញនូវធម៌ គប្បីលះបង់
ទាំងអវយវៈ ទ្រព្យនិងជីវិតទាំងអស់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចាណំ** សំដៅដល់ លះបង់ជីវិតបាន អធិប្បាយថា ឈ្មោះថា សប្បុរសទាំងឡាយ រមែងលះជីវិតបាន ។ បទថា **ទិប្បមវា-ករោហិ** បានដល់ សូមទ្រង់ប្រទានពរដោយរួសរាន់ គឺចូរប្រទានដល់ខ្ញុំដោយរហ័សក្នុងទីនេះចុះ ។ បទថា **ឃរេន** បានដល់ ជាអ្នកបរិបូណ៌ ចូលដល់ហើយដោយធម៌និងពាក្យសត្យនេះ ។ ព្រះពោធិសត្វទ្រង់សរសើរស្តេចបោរិ-សាទនោះ ទើបទ្រង់ហៅដោយពាក្យថា **សុរាជសេដ្ឋ** ដូច្នេះ ។ បទថា **ចជេ ធនំ** អធិប្បាយថា នែបោរិសាទ បុរសដែលជាបណ្ឌិត កាលអវយវៈមានដៃនិងជើងជាដើមនៅមាន គប្បីលះនូវទ្រព្យច្រើន ដើម្បីរក្សាអវយវៈនោះ ។ បទថា **ធម្មមនុស្សរន្តោ** អធិប្បាយថា កាលរឭកដល់ធម៌យ៉ាងនេះថា សូម្បីអញត្រូវលះអវយវៈ ទ្រព្យនិងជីវិត ក៏មិនកន្លងនូវធម៌របស់សប្បុរស ។

ព្រះពោធិសត្វ ត្រាស់ជម្រុញឲ្យស្តេចបោរិសាទនោះតាំងនៅក្នុងភាពនៃសច្ចៈ ដោយហេតុផលទាំងនេះយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីសម្តែងថាព្រះអង្គជាបុគ្គលគួរគោរព ទើបត្រាស់គាថានេះថា

> បុរសចេះដឹងនូវធម៌អំពីបុគ្គលណា ឬក៏ពួកសប្បុរសណា
> បន្ទោបង់នូវសេចក្តីសង្ស័យរបស់បុគ្គលនោះបាន ដំណើរនោះ
> ឈ្មោះថា ជាទីពឹងជាទីពំនាក់របស់បុគ្គលនោះ បុគ្គលអ្នកមាន
> ប្រាជ្ញា មិនត្រូវបំបាត់មេត្រីចិត្តអំពីបុគ្គលនោះទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យស្មា** បានដល់ អំពីបុរសណា ។ បទថា **ធម្មំ** បានដល់ ហេតុដែលសម្តែងកុសលនិងអកុសលធម៌ ។ បទថា **វិជញ្ញា**

បានដល់ គប្បីដឹងច្បាស់ ។ បទថា **តញ្ហិស្ស** បានដល់ បុគ្គលដែលជាអាចារ្យនោះ ឈ្មោះថា **ទីបំ** ព្រោះអត្ថថា ជាទីពឹងរបស់បុគ្គលនោះ និងឈ្មោះថា **បរាយនំ** ព្រោះអត្ថថា ជាទីដែលបុគ្គលនោះគប្បីទៅក្នុងកាលមានភ័យកើតឡើង ។ បទថា **ន តេន មេត្តឹ** អធិប្បាយថា បុគ្គលជាបណ្ឌិត មិនគប្បីទម្លាយមេត្រី ដោយហេតុណាមួយនឹងបុគ្គលដែលជាអាចារ្យនោះ គឺមិនគប្បីធ្វើមេត្រីនោះឲ្យវិនាស ។

ព្រះពោធិសត្វត្រាស់យ៉ាងនេះហើយ ទើបត្រាស់បន្តថា នែបោរិសាទសម្លាញ់ ឈ្មោះថា ពាក្យរបស់អាចារ្យដែលមានគុណមិនគួរទម្លាយ យើងជាអាចារ្យដោយប្រយោលរបស់ទ្រង់ ឲ្យទ្រង់សិក្សាសិប្បៈជាច្រើន ក្នុងពេលដែលទ្រង់នៅកំលោះ ឥឡូវនេះ បានពោលសតារហគាថា ដោយពុទ្ធលីលាដល់ព្រះអង្គ ព្រោះហេតុនោះ ទ្រង់គួរធ្វើតាមពាក្យរបស់ខ្ញុំ ។

ស្តេចបោរិសាទបានស្តាប់ដូច្នោះ ទើបត្រិះរិះថា សុតសោមជាអាចារ្យរបស់អញ ហើយពរអញក៏បានថ្វាយដល់ព្រះអង្គ អញអាចធ្វើអ្វីបាន ធម្មតាការស្លាប់ក្នុងអត្តភាពមួយ រមែងជារបស់ទៀងទាត់ អញនឹងមិនស៊ីសាច់មនុស្ស អញនឹងថ្វាយព្រះពរ ដូច្នេះ មានមុខជោកដោយទឹកភ្នែកក្រោកឡើង ថ្វាយបង្គំព្រះបាទសុតសោម កាលថ្វាយព្រះពរនោះ ទើបពោលគាថានេះថា

អាហារនោះ ជាទីគាប់ចិត្តរបស់ខ្ញុំដោយពិត ខ្ញុំចូលព្រៃ ព្រោះ
ហេតុតែសាច់មនុស្សនុ៎ះ បើទ្រង់ទទូចសូមសេចក្តីនុ៎ះនឹងខ្ញុំ
បពិត្រទ្រង់ជាសម្លាញ់ ខ្ញុំក៏ឲ្យពរនោះដល់ទ្រង់ ដូច្នេះ ។

លំដាប់នោះ ព្រះមហាសត្វត្រាស់ថា នែសម្លាញ់ បុគ្គលដែលតាំងនៅក្នុងសីល ដល់នូវការស្លាប់ក៏ប្រសើរ ខ្ញុំសូមទទួលពរដែលទ្រង់ប្រទានហើយ ទ្រង់បានតាំងនៅក្នុងផ្លូវរបស់ព្រះអរិយៈ តាំងអំពីថ្ងៃនេះហើយ កាលបើយ៉ាងនោះ ខ្ញុំត្រូវទូលសូមទ្រង់ បើទ្រង់ស្រឡាញ់ខ្លួនរបស់ទ្រង់ សូមទ្រង់រក្សាសីល ៥ ចុះ ។ ស្តេចបោរិសាទទូលថា សាធុ សម្លាញ់ សូមទ្រង់ប្រទានសីល ៥ ដល់ខ្ញុំ ព្រះមហាសត្វត្រាស់ថា បពិត្រមហារាជ សូមទ្រង់ទទួលចុះ ។ ស្តេចបោរិសាទថ្វាយបង្គំព្រះមហាសត្វដោយបញ្ចង្គប្រតិស្ឋាន អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ ព្រះមហាសត្វ បានឲ្យស្តេចបោរិសាទតាំងនៅក្នុងសីល ៥ ហើយ ។ ខណៈនោះ ភុម្មទេវតាប្រជុំគ្នាក្នុងទីនោះ កើតនូវការត្រេកអរក្នុងព្រះមហាសត្វ បានធ្វើសាធុការ ញុំាងព្រៃធំឲ្យមាននូវសំឡេងកោលាហលថា តាំងពីអវីចិរហូតដល់ភវគ្គព្រហ្ម បុគ្គលឈ្មោះថា អាចឃាត់ស្តេចបោរិសាទចាកសាច់មនុស្សបានមិនមាន ព្រះបាទសុតសោម បានធ្វើកិច្ចដែលអ្នកដទៃធ្វើបានដោយក្រ គួរអស្ចារ្យហ្ន៎ ។ ទេវតាជាន់ចាតុម្មហារាជបានស្តាប់ពាក្យភុម្មទេវតាទាំងនោះ ក៏ធ្វើសាធុការបន្តទៅដូចគ្នាយ៉ាងនេះ កោលាហកក៏កើតដូចគ្នាតែមួយ រហូតដល់ព្រហ្មលោក សូម្បីព្រះរាជាដែលព្យួរដៃត្រង់ដើមឈើក៏បានឮនូវសំឡេងសាធុការរបស់ទេវតាទាំងនោះដែរ សូម្បីពួករុក្ខទេវតាដែលនៅក្នុងវិមាននោះៗ ក៏ឲ្យសាធុការ ការឲ្យសាធុការរបស់ទេវតាយ៉ាងនេះ បានឮតែសំឡេង មិនឃើញខ្លួនទេវតា ពួកព្រះរាជាបានស្តាប់សំឡេងសាធុការរបស់ពួកទេវតា ទើបត្រិះរិះថា ពួកយើងបានជីវិត ព្រោះអាស្រ័យព្រះបាទ

សុតសោម ព្រះបាទសុតសោមទ្រង់ទូន្មានស្តេចបោរិសាទបាន ឈ្មោះថា ធ្វើកិច្ចដែលអ្នកដទៃធ្វើបានដោយក្រ ហើយនាំគ្នាសរសើរព្រះពោធិសត្វ ។ ឯស្តេចបោរិសាទថ្វាយបង្គំ ព្រះយុគលបាទរបស់ព្រះមហាសត្វហើយឈរក្នុងចំណែកម្ខាង លំដាប់នោះ ព្រះពោធិសត្វត្រាស់នឹងព្រះបាទបោរិសាទថា នែសម្លាញ់ សូមទ្រង់ដោះលែងក្សត្រទាំងនេះចុះ ស្តេចបោរិសាទត្រិះរិះថា អញជាសត្រូវរបស់ស្តេចទាំងនេះ ស្តេចទាំងនេះកាលអញដោះលែងទៅហើយ នឹងនាំគ្នាចាប់អញថា ជាសត្រូវរបស់ខ្លួន ហើយនឹងបៀតបៀន សូម្បីអញត្រូវអស់ជីវិតក៏មិនអាចទម្លាយសីលដែលអញទទួលអំពីសម្នាក់ព្រះបាទសុតសោម អញនឹងទៅដោះលែងជាមួយព្រះបាទសុតសោមយ៉ាងនេះ ភ័យនឹងមិនមានដល់អញ ហើយថ្វាយបង្គំព្រះពោធិសត្វទូលថា សុតសោមសម្លាញ់ យើងទាំង ២ នឹងទៅដោះលែងក្សត្រទាំងឡាយជាមួយគ្នា ហើយពោលគាថានេះថា

ព្រះអង្គជាសាស្តារបស់ខ្ញុំផង ជាសម្លាញ់របស់ខ្ញុំផង បពិត្រ
ព្រះអង្គជាសម្លាញ់ ខ្ញុំនឹងធ្វើតាមព្រះឱង្ការរបស់ព្រះអង្គ ព្រះ
អង្គក៏ចូរធ្វើតាមពាក្យរបស់ខ្ញុំដែរ យើងទាំងពីរនាក់ ទៅដោះ
លែង ( ពួកក្សត្រទាំងនោះជាមួយគ្នា ) ដូច្នេះ ។

បទថា **សត្ថា** បានដល់ ជាសាស្តា ព្រោះបានសម្តែងស្ថានសួគ៌ និងជាសម្លាញ់តាំងពីនៅយុវវ័យ ។

លំដាប់នោះ ព្រះពោធិសត្វក៏ត្រាស់នឹងស្តេចបោរិសាទនោះថា

ខ្ញុំជាសាស្តារបស់ព្រះអង្គផង ជាសម្លាញ់របស់ព្រះអង្គផង

បពិត្រព្រះអង្គជាសម្លាញ់ បើព្រះអង្គធ្វើតាមពាក្យខ្ញុំ ទាំងខ្ញុំ
ក៏ធ្វើតាមពាក្យព្រះអង្គដែរ យើងទាំងពីរនាក់ទៅដោះលែង
( ពួកក្សត្រទាំងនោះជាមួយគ្នា ) ដូច្នេះ ។

កាលត្រាស់យ៉ាងនេះហើយ ព្រះមហាសត្វ ក៏យាងទៅរកក្សត្រទាំងនោះ ហើយត្រាស់គាថានេះថា

ពួកយើងដែលត្រូវព្រះរាជាជើងពពាលបៀតបៀន ដោតបាត
ដៃ មានមុខជោកដោយទឹកភ្នែកស្រែកយំ ( ឥឡូវនេះ )
អ្នកទាំងឡាយលែងប្រទូស្តនឹងព្រះរាជានេះចុះ អ្នកទាំងឡាយ
ចូរទទួលស្តាប់ពាក្យប្តេជ្ញាដ៏ទៀងទាត់របស់ខ្ញុំចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កម្មាសបាទេន** អធិប្បាយថា ព្រះមហាសត្វទ្រង់ទទួលពាក្យស្តេចបោរិសាទថា យើងទាំង ២ ចូរទៅដោះលែងពួកក្សត្រជាមួយគ្នា ដូច្នេះហើយ ទ្រង់ត្រិះរិះថា ធម្មតាក្សត្រជាអ្នករឹងត្អឹងដោយមានះ កាលរួចផុតអាចវាយតប់ ឬសម្លាប់ស្តេចបោរិសាទដោយ អាឃាតថា ពួកយើងត្រូវស្តេចបោរិសាទនេះបៀតបៀនហើយដូច្នេះក៏បាន តែស្តេចបោរិសាទមិនប្រទូស្តស្តេចទាំងនេះដោយពិត តែអញត្រូវទៅទទួលប្តេជ្ញាចំពោះក្សត្រទាំងនោះមុន ហើយយាងទៅកាន់សម្នាក់ស្តេចទាំងនោះ ទ្រង់ឃើញក្សត្រទាំងនោះត្រូវដោតបាតដៃ ព្យួរត្រង់មែកឈើ ចុងព្រះបាទដល់ផែនដី បម្រះនទៀលដូចកម្រងផ្កាសិរមាន់ដែលគេព្យួរទុកក្នុងពេលត្រូវខ្យល់ ។ សូម្បីក្សត្រទាំងនោះកាលឃើញព្រះពោធិសត្វហើយ ស្រែកឡើងព្រមគ្នាថា ពួកយើងនឹងផុត

ភ័យក្នុងកាលឥឡូវនេះហើយ ។ លំដាប់នោះ ព្រះមហាសត្វត្រាស់លួងលោម នូវក្សត្រទាំងនោះថា កុំខ្លាចឡើយ ហើយត្រាស់ថា ទ្រង់ទាំងឡាយបាន ទទួលអភ័យអំពីស្តេចបោរិសាទហើយ តែសូមទ្រង់ទាំងឡាយ ធ្វើតាមពាក្យ របស់ខ្ញុំ ហើយត្រាស់ព្រះគាថាដូចពោលមកហើយខាងដើម ។ បទថា **ឆ ជាតុ** ក្នុងគាថានោះ អធិប្បាយថា ទ្រង់ទាំងឡាយកុំប្រទូស្តដោយចំណែក មួយប៉ុណ្ណោះ ។

ស្តេចទាំងនោះ ត្រាស់តបដោយគាថានេះថា

ពួកយើង ដែលត្រូវព្រះរាជាជើងពពាលបៀតបៀន ដោយ ដោតបាតដៃ មានមុខជោកដោយទឹកភ្នែក ស្រែកយំ ( ឥឡូវ នេះ ) ពួកយើងមិនប្រទូស្តចំពោះព្រះរាជានេះទេ ពួកយើង នឹងទទួលស្តាប់ពាក្យប្តេជ្ញាដ៏ទៀងទាត់របស់ព្រះអង្គ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បដិសុណោម** សេចក្តីថា ក្សត្រទាំងនោះ ទូលព្រះមហាសត្វថា ខ្ញុំទទួលប្តេជ្ញាយ៉ាងនេះ តែពួកខ្ញុំកំពុងហេវហត់ មិនអាច រៀបពាក្យប្តេជ្ញាបានល្អ សូមទ្រង់ជាទីពឹងដល់សត្វទាំងពួងចុះ ទ្រង់រៀបពាក្យ ប្តេជ្ញាឲ្យផង ពួកខ្ញុំបានស្តាប់ប្តេជ្ញារបស់ទ្រង់ហើយ នឹងឲ្យពាក្យប្តេជ្ញា ។

លំដាប់នោះ ព្រះមហាសត្វក៏ត្រាស់នឹងពួកក្សត្រទាំងនោះថា បើដូច្នោះ សូម ទ្រង់ទាំងឡាយឲ្យប្តេជ្ញា ហើយត្រាស់គាថានេះថា

បិតាឬមាតា ជាអ្នកអនុគ្រោះ ប្រាថ្នានូវសេចក្តីចម្រើនដល់បុត្ត ទាំងឡាយ យ៉ាងណាមិញ ចំណែកព្រះរាជានេះ ចូរមានដល់

លោកទាំងឡាយ ក៏យ៉ាងនោះដែរ ទាំងលោកទាំងឡាយក៏សូមដូចជាបុត្ត ដូច្នេះ ។

សូម្បីក្សត្រទាំងនោះ ក៏ទទួលពាក្យប្តេជ្ញា បានពោលគាថានេះថា

បិតាឬមាតា ជាអ្នកអនុគ្រោះ ប្រាថ្នានូវសេចក្តីចម្រើនដល់បុត្តទាំងឡាយ យ៉ាងណាមិញ ចំណែកខាងព្រះរាជានេះ ចូរមានដល់យើងទាំងឡាយ យ៉ាងនោះដែរ ទាំងពួកយើងក៏ដូចបុត្តដែរ ដូច្នេះ ។

**ប៉ោ** អក្ខរៈ ក្នុងបទថា **តុម្ហេ ច ប៉ោ** ក្នុងគាថានោះ ត្រឹមតែជានិបាត ។ ព្រះមហាសត្វទ្រង់ទទួលប្តេជ្ញារបស់ក្សត្រទាំងនោះយ៉ាងនេះហើយ ទ្រង់ហៅស្តេចបោរិសាទត្រាស់ថា មកចុះសម្លាញ់ ចូរមកដោះលែងក្សត្រទាំងនេះចុះ ស្តេចបោរិសាទ ចាប់ដាវកាត់ខ្សែដែលចងព្រះរាជាមួយអង្គហើយ ព្រះរាជានោះ អត់អាហារ បានទទួលទុក្ខវេទនាមករហូត ៧ ថ្ងៃហើយ ធ្លាក់មកក៏សន្លប់ត្រង់ផែនដី ដំណាលគ្នានឹងការដាច់នៃខ្សែដែលចង ។ ព្រះមហាសត្វ ទតឃើញដូច្នោះ មានសេចក្តីករុណាត្រាស់ថា នែបោរិសាទសម្លាញ់ ទ្រង់កុំកាត់យ៉ាងនោះឡើយ ពេលនេះ យើងទាំងពីរនឹងចាប់ព្រះរាជាមួយអង្គឲ្យមាំ ធ្វើទ្រង់ទុកក្នុងទ្រូង រួចសឹមកាត់ចំណង កាលស្តេចបោរិសាទកាត់ខ្សែដោយព្រះខ័ន មហាសត្វទទួលព្រះរាជានោះដាក់ឲ្យផ្ទុំត្រង់ព្រះឧរៈ ព្រោះទ្រង់សម្បូរដោយកម្លាំង ផ្តងឲ្យផ្ទុំលើផែនដីដោយព្រះទ័យប្រកបដោយមេត្តា ដូចគ្នានឹងផ្តងបុត្តដែលកើតអំពីទ្រូងដូច្នោះ ព្រះមហាសត្វផ្តងព្រះរាជាទាំងនោះគ្រប់អង្គ

ដាក់ឲ្យផ្ងំលើផែនដីយ៉ាងនេះ ហើយទ្រង់ហូតខ្សែចេញសន្សឹមៗ ដូចទាញអំបោះចេញអំពីត្រចៀករបស់ក្មេងដូច្នោះ លាងខ្ទុះនិងឈាមហើយ ធ្វើមុខរបួសឲ្យស្អាតត្រាស់ថា បោរិសាទសម្លាញ់ សូមទ្រង់បុកសម្បកឈើនេះឲ្យល្អិតហើយនាំមក កាលឲ្យនាំមកហើយ ទើបទ្រង់តាំងសច្ចាធិដ្ឋាន លាបត្រង់បាតព្រះហស្តរបស់ក្សត្រទាំងនោះ មុខរបួសនោះ ក៏ជាសះស្បើយក្នុងខណៈនោះឯង ។ ស្តេចបោរិសាទយកអង្ករមកស្ងោរឲ្យរាវ សូម្បីក្សត្រទាំងពីរនេះបានឲ្យក្សត្រ ១០១ ព្រះអង្គបានសោយនូវទឹកបបរហើយ ។

កាលព្រះមហាសត្វឲ្យក្សត្រទាំងនោះស្កប់ស្កល់គ្រប់អង្គ ដូច្នេះហើយ ព្រះអាទិត្យក៏អស្តង្គត សូម្បីស្អែកឡើង ក៏ឲ្យសោយយ៉ាងនោះ ទាំងក្នុងពេលព្រឹក ពេលថ្ងៃត្រង់និងវេលាល្ងាច ថ្ងៃទី ៣ ឲ្យសោយនូវបបរខាប់យ៉ាងនេះ រហូតដល់ក្សត្រទាំងនោះប្រាសចាករោគ គ្រានោះ ព្រះមហាសត្វត្រាស់សួរក្សត្រទាំងនោះថា ពួកទ្រង់អាចត្រឡប់ទៅបានដែរឬទេ កាលក្សត្រទាំងនោះក្រាបទូលថា ទៅបាន ហើយត្រាស់ថា នែបោរិសាទសម្លាញ់ សូមទ្រង់យាងចុះ យើងទាំងឡាយនឹងត្រឡប់ទៅកាន់ដែនរបស់ខ្លួន ។ ស្តេចបោរិសាទបានស្តាប់ដូច្នោះ ក៏ស្រែកយំ ក្រាបទៀបបាទាទាំងទ្វេរបស់ព្រះមហាសត្វទូលថា សូមសម្លាញ់នាំព្រះរាជាទាំងឡាយទៅចុះ ខ្ញុំនឹងស៊ីឫសឈើ ផ្លែឈើក្នុងព្រៃនេះ ។ ព្រះមហាសត្វត្រាស់ថា នែសម្លាញ់នៅធ្វើអ្វីក្នុងព្រៃនេះ ដែនរបស់ទ្រង់គួរជាទីត្រេកអរ សូមទ្រង់យាងទៅសោយរាជសម្បត្តិក្នុងនគរពារាណសីនោះចុះ ។ ស្តេចបោរិសាទទូលថា សម្លាញ់ត្រាស់អ្វី ខ្ញុំមិនអាចទៅនគរពារាណសី

ព្រោះអ្នកនគរទាំងអស់ជាសត្រូវរបស់ខ្ញុំ នឹងជេរបរិភាសខ្ញុំថា អាចោរស៊ីម៉ែរបស់អញ ស៊ីឪរបស់អញដូច្នេះជាដើម ហើយនាំគ្នាចាប់ខ្ញុំដោយចោទថា ជាចោរ នឹងផ្តាច់ជីវិតដោយដំបង ដុំដី ញញួរ លំពែង ឬពូថៅ ឯខ្ញុំទទួលសីលក្នុងសម្នាក់របស់ទ្រង់ហើយ ខ្ញុំមិនអាចសម្លាប់គេ ព្រោះហេតុនៃជីវិត ព្រោះដូច្នោះ ខ្ញុំទៅមិនបានឡើយ កាលខ្ញុំវៀរចាកសាច់មនុស្សហើយ នឹងជាអ្នករស់នៅបានប៉ុនណា ការឃើញទ្រង់ទៀតរបស់ខ្ញុំមិនមានឡើយ ។ ស្តេចបោរិសាទ ពោលដូច្នេះហើយ ក៏ទ្រហោយំទូលថា សូមទ្រង់យាងចុះ ។ កាលនោះ មហាសត្វទ្រង់ស្ទាបខ្នងស្តេចបោរិសាទត្រាស់ថា បោរិសាទសម្លាញ់ ខ្ញុំឈ្មោះសុតសោម បុគ្គលឃោរឃៅដូចទ្រង់គង់ទូន្មានបាន អ្នកនគរពារាណសីតើនឹងមានបញ្ហាអ្វីទៅ ខ្ញុំនឹងឲ្យទ្រង់តាំងនៅក្នុងភាពជាព្រះរាជានៅក្នុងព្រះនគរពារាណសីនោះទៀត បើសិនមិនអាច ខ្ញុំនឹងចែករាជសម្បត្តិរបស់ខ្ញុំជា ២ ចំណែកថ្វាយដល់ទ្រង់មួយចំណែក កាលស្តេចបោរិសាទទូលថា សូម្បីក្នុងនគររបស់ទ្រង់ សត្រូវរបស់ខ្ញុំ ក៏មានដូចគ្នា ។ ព្រះពោធិសត្វត្រិះរិះថា ស្តេចបោរិសាទនេះធ្វើតាមពាក្យរបស់អញ ឈ្មោះថា ធ្វើកិច្ចដែលអ្នកដទៃធ្វើបានដោយក្រ អញនឹងឲ្យទ្រង់នៅក្នុងរាជឥស្សរិយយសដូចមុនដោយឧបាយណាមួយ កាលទ្រង់ពណ៌នាដល់សម្បត្តិរបស់ព្រះនគរ ដើម្បីលួងលោមស្តេចបោរិសាទ ឲ្យកើតសេចក្តីពេញចិត្ត ទើបត្រាស់ព្រះគាថានេះថា

ព្រះអង្គធ្លាប់សោយនូវសាច់នៃសត្វជើង ៤ ឬសត្វបក្សីដែល
ពួកនាយពិសេសចាត់ចែងល្អ សម្រេចដោយល្អ ជាទីត្រេកអរ

ដូចព្រះឥន្ទសោយនូវសុធាភោជន ព្រះអង្គលះបង់ចោល ហើយត្រេកអរក្នុងព្រៃតែម្នាក់ឯង ដូចម្តេចកើត ។ ពួកនាងខត្តិយានីនោះ មានគ្រឿងប្រដាប់ក្លីផ្ចេក និងចង្កេះដ៏វៀវ តាក់តែងខ្លួនគាល់ត្រៀបត្រា ញុំាំងព្រះអង្គឲ្យរីករាយ ដូចជាស្រីអប្សរបម្រើព្រះឥន្ទ ក្នុងទេវលោក ព្រះអង្គលះបង់ចោល ហើយត្រេកអរក្នុងព្រៃម្នាក់ឯងដូចម្តេចកើត ។ ព្រះអង្គផ្ទំលើព្រះបន្ទំមានខ្នើយពណ៌ក្រហម មានព្រំមានរោមច្រើន តាក់តែងក្នុងទីព្រះបន្ទំទាំងអស់ដ៏ល្អ ជាសុខសប្បាយ ក្នុងទីពាក់កណ្តាលនៃព្រះបន្ទំ ហើយលះបង់ចោល ត្រេកអរក្នុងព្រៃម្នាក់ឯងដូចម្តេចកើត ។ ក្នុងវេលារាត្រី មានស្គរសំឡេងគងនិងស្គរ ទាំងតូរ្យតន្ត្រីឥតមានបុរសនៅលាយ មានទាំងចម្រៀងដ៏ពីរោះ និងប្រគំក៏ពីរោះជាច្រើនយ៉ាង ព្រះអង្គលះបង់ចោល ហើយត្រេកអរក្នុងព្រៃម្នាក់ឯង ដូចម្តេចកើត ។ ឧទ្យាន ( ឈ្មោះមិគាជិន ) ក៏មានផ្កាច្រើនបរិបូណ៌ បុរីប្រកបដោយឈ្មោះតាមឧទ្យានមិគាជិន ជាបុរីគួរជាទីសប្បាយក្រៃពេក សម្បូរដោយពាហនៈ សេះ ដំរី រថ ព្រះអង្គលះបង់ចោលហើយត្រេកអរក្នុងព្រៃតែម្នាក់ឯង ដូចម្តេចកើតដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុកតំ** បានដល់ ធ្វើយ៉ាងល្អ ដោយប្រការផ្សេងៗ ។ បទថា **សុនិដ្ឋិតំ** សេចក្តីថា ធ្វើឲ្យសម្រេចដោយល្អ ដោយការ

ប្រកបគ្រឿងផ្សេងៗ ច្រើនប្រភេទ ។ បទថា **កាឋកោ រមសិ** អធិប្បាយថា ទ្រង់សោយឫសឈើនិងផ្លែឈើជាដើមនិងគាប់ចិត្តដូចម្តេច បពិត្រមហារាជ សូមទ្រង់យាងចុះ យើងទាំង ២ នឹងទៅជាមួយគ្នា ។ បទថា **វេល្លិវិលាក-មជ្ឈា** អធិប្បាយថា មានរស្មីដូចមាសដែលរំលាយល្អហើយ និងមានចង្កេះរៀវ ។ បទថា **ទេវេសុ** អធិប្បាយថា ក្នុងកាលមុន ពួកខត្តិយកញ្ញាចោមរោមធ្វើឲ្យត្រេកអរនៅក្នុងនគរពារាណសី ដែលជាស្ថានទីដែលគួរត្រេកអរ ដូចទេពអប្សរចោមរោមព្រះឥន្ទក្នុងទេវលោក ដូច្នោះ ហេតុអ្វីទើបទ្រង់លះពួកខត្តិយកញ្ញាទាំងនោះចោល ហើយទ្រង់នឹងធ្វើអ្វីក្នុងព្រៃនេះ នៃសម្លាញ់ សូមទ្រង់ត្រឡប់ចុះ យើងទាំង ២ នឹងទៅជាមួយគ្នា ។ បទថា **តម្ពូបធានេ** បានដល់ ព្រះខ្នើយ មានខ្នើយពណ៌ក្រហម ។ បទថា **សព្វសយនម្ហិ** បានដល់ព្រះទែនបន្ទំ ដែលក្រាលដោយកម្រាលទាំងអស់ ។ បទថា **អលង្កតេ** អធិប្បាយថា ទ្រង់ធ្លាប់ផ្ទំលើព្រះទែននោះ ដោយគ្រឿងអលង្ការដែលគួរត្រេកអរមានជាន់ជាច្រើន ។ បទថា **សុខំ** អធិប្បាយថា ទ្រង់ធ្លាប់ផ្ទំជាសុខត្រង់កណ្តាល ព្រះទែនបន្ទំបែបនោះ ឥឡូវនេះ ហេតុអ្វីទើបត្រេកអរក្នុងព្រៃ នៃសម្លាញ់ សូមទ្រង់យាងចុះ យើងទាំង ២ នឹងទៅជាមួយគ្នា ។ បទថា **និ-សីថេ** បានដល់ ក្នុងកាលដែលជាចំណែកនៃពេលយប់ ។ បទថា **ហិត្វា** បានដល់ លះបង់នូវសម្បត្តិបែបនេះ ។ បទថា **ឧយ្យាន សម្បន្នបហូតមាល្យំ** អធិប្បាយថា បពិត្រមហារាជ ព្រះរាជឧទ្យានរបស់ទ្រង់សម្បូរដោយផ្កាច្រើនប្រភេទ ។ បទថា **មិគាជិនូបេតបុរំ សុរម្មំ** អធិប្បាយថា ព្រះរាជឧទ្យាននេះ

មានឈ្មោះថា មិគាជិនវ័ន សួមវ្បីនគរដែលមានឧទ្យានបែបនោះ ក៏ជាស្ថានទីដែលគួរត្រេកអរដ៏ល្អដល់ព្រះអង្គ ។ បទថា **ហិត្វា** បានដល់ លះនគរដែលគួរត្រេកអរបែបនេះទៅបាន ។

មហាសត្វត្រាស់យ៉ាងនេះហើយ សង្ឃឹមក្នុងព្រះទ័យថា ស្តេចបោរិសាទនឹកដល់រស មានគ្រឿងឧបភោគបរិភោគដែលធ្លាប់សោយ គប្បីកើតនូវចំណង់ដែលចង់ត្រឡប់ទៅកាន់ព្រះនគរ ទើបត្រាស់លួងលោមដោយភោជនជាដើម ដោយអំណាចកិលេសជាគម្រប់ ២ ដោយទីបន្ទំជាគម្រប់ ៣ ដោយការច្រៀងរាំនិងការប្រគំជាគម្រប់ ៤ ដោយព្រះរាជឧទ្យាន និងព្រះនគរជាគម្រប់ ៥ ត្រាស់លួងលោមដូច្នេះហើយ ក៏ត្រាស់បន្តថា បពិត្រមហារាជ សូមទ្រង់យាងចុះ ខ្ញុំនឹងនាំទ្រង់ទៅតាំងរាជ្យក្នុងនគរពារាណសី ហើយនឹងត្រឡប់ទៅកាន់ដែនរបស់ខ្ញុំក្នុងកាលជាក្រោយ បើមិនបានរាជសម្បត្តិក្នុងនគរពារាណសី នឹងថ្វាយរាជសម្បត្តិរបស់ខ្ញុំដល់ទ្រង់ពាក្យកណ្តាល ប្រយោជន៍អ្វីរបស់ទ្រង់ដោយការនៅព្រៃ ចូរធ្វើតាមពាក្យរបស់ខ្ញុំចុះ ។ ស្តេចបោរិសាទបានស្តាប់ពាក្យរបស់ព្រះមហាសត្វ មានចំណង់ត្រឡប់ទៅកាន់ព្រះនគរត្រិះរិះថា សុតសោមសម្លាញ់ទ្រង់ប្រាថ្នាសេចក្តីចម្រើនដល់ខ្ញុំ តាំងខ្ញុំទុកក្នុងកល្យាណធម៌ហើយ ឥឡូវនេះនៅត្រាស់ថា នឹងស្ថាបនាក្នុងឥស្សរិយយសដូចមុន ទ្រង់អាចស្ថាបនាបាន អញគួរទៅជាមួយទ្រង់ ប្រយោជន៍អ្វីរបស់អញដោយការនៅក្នុងព្រៃ មានចិត្តត្រេកអរ បំណងនឹងពណ៌នាមិត្តធម៌ អាស្រ័យគុណរបស់ព្រះមហាសត្វ ទើបក្រាបទូលថា សុតសោមសម្លាញ់ អ្វីដែលត្រេកអរក្រៃលែងជាងការសេពគប់

កល្យាណមិត្តមិនមាន អ្វីដែលលាមកក្រៃលែងជាងការសេពគប់បាបមិត្តមិនមានឡើយ ហើយពោលគាថានេះថា

ព្រះចន្ទក្នុងកាឡបក្ខ ( រនោច ) រមែងអស់ទៅរាល់ៗថ្ងៃ យ៉ាងណាមិញ បពិត្រព្រះរាជា ការសមាគមនឹងពួកអសប្បុរស ឧបមាដូចព្រះចន្ទក្នុងកាឡបក្ខ ។ ដូចយ៉ាងខ្ញុំអាស្រ័យរសកៈ អ្នកស្លដណ្តាំ ជាបុរសអាក្រក់លាមក ហើយបានធ្វើនូវកម្មអាក្រក់ ជាហេតុទៅកាន់ទុគ្គតិ ។ ព្រះចន្ទក្នុងសុកបក្ខ រមែងចម្រើនឡើងរាល់ ៗ ថ្ងៃ យ៉ាងណាមិញ បពិត្រព្រះរាជា ការជួបប្រទះនឹងពួកសប្បុរស ឧបមាដូចជាព្រះចន្ទក្នុងសុកបក្ខ ។ បពិត្រព្រះបាទសុតសោម សូមព្រះអង្គជ្រាបចុះ ដូចយ៉ាងខ្ញុំអាស្រ័យព្រះអង្គ ហើយធ្វើការកុសល ជាហេតុទៅកាន់សុគតិ ។

បពិត្រព្រះអង្គជាធំជាងជន ទឹកដែលបង្អុរចុះលើទីទួល មិនដក់នៅ មិនឋិតនៅអស់កាលយូរ យ៉ាងណាមិញ ការសមាគមនឹងពួកអសប្បុរសរបស់ខ្ញុំ មិនតាំងនៅអស់កាលយូរ ដូចទឹកលើទីទួលយ៉ាងនោះដែរ ។ បពិត្រព្រះអង្គជាធំជាងជន មានព្យាយាមដ៏ប្រសើរជាងជន ទឹកដែលបង្អុរចុះក្នុងស្រះ ឋិតនៅអស់កាលយូរ យ៉ាងណាមិញ ការសមាគមនឹងពួកសប្បុរសរបស់ខ្ញុំ ឋិតនៅអស់កាលយូរ ដូចទឹកក្នុងស្រះយ៉ាងនោះដែរ ។

សមាគមនឹងពួកសប្បុរស រមែងមិនឃ្លាតចេញទេ គប្បីឋិត នៅដរាបអស់ជីវិត ការសមាគមនឹងពួកអសប្បុរស រមែងវិនាសទៅឆាប់ ដោយប្រការដូច្នេះឯង ព្រោះហេតុនោះ ធម៌របស់ពួកសប្បុរស រមែងឆ្ងាយអំពីពួកអសប្បុរស ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សុវេ សុវេ** បានដល់ ក្នុងថ្ងៃនីមួយៗ ។ បទថា **អនច្ចយំ** បានដល់ មិនគួរនៅបានយូរ ។ បទថា **សរេ** បានដល់ ក្នុងសមុទ្ទ ។ បទថា **នរវីរសេដ្ឋ** បានដល់ ជាអ្នកប្រសើរជាងនរជន ។ បទថា **ឧទកំ សរេវ** បានដល់ ដូចទឹកដែលធ្លាក់ចុះក្នុងសមុទ្ទ ។ បទថា **អព្យាយិកោ** បានដល់ មិនទ្រុឌទ្រោម ។ បទថា **យាវម្បិ តិដ្ឋេយ្យ** អធិប្បាយថា ជីវិតតាំងនៅអស់កាលត្រឹមណា ការសេពគប់សប្បុរស រមែងតាំងនៅអស់កាលត្រឹមនោះ ភាពជាមិត្តនឹងសប្បុរសមិនសាបសូន្យឡើយ ។

ស្ដេចបោរិសាទ ពណ៌នាដល់គុណរបស់ព្រះមហាសត្វ ៧ គាថា ដោយប្រការដូច្នេះ ។ មហាសត្វបាននាំស្ដេចបោរិសាទនិងព្រះរាជា ១០១ យាងទៅកាន់បច្ចន្តគ្រាម អ្នកស្រុកនោះឃើញមហាសត្វហើយ បានទៅប្រាប់សេចក្ដីនោះដល់អ្នកនគរ ពួកអាមាត្យបាននាំពួកពលនិកាយទៅគាល់ទទួលព្រះមហាសត្វបានទៅកាន់នគរពារាណសីដោយបរិវារនោះ ក្នុងរវាងផ្លូវ ពួកអ្នកជនបទថ្វាយគ្រឿងបណ្ណាការ ហើយដើរតាមព្រះរាជាទៅ ព្រះមហាសត្វមានបរិវារច្រើន យាងដល់នគរពារាណសីជាមួយបរិវារនោះ ពេលនោះព្រះឱរសរបស់ព្រះបាទបោរិសាទជាព្រះរាជា កាឡហត្ថិនៅជាសេនាបតីដដែល

អ្នកនគរក្រាបទូលព្រះរាជាថា បពិត្រព្រះអង្គ បានឮថា ព្រះបាទសុតសោម ទូន្មានព្រះបាទបោរិសាទបានហើយ កំពុងនាំមកក្នុងព្រះនគរនេះ ពួកទូលព្រះបង្គំមិនឲ្យចូលនគរ ដូច្នេះហើយ ប្រញាប់បិទទ្វារនគរ ចាប់នូវអាវុធព្រមគ្នា ។ ព្រះមហាសត្វទ្រង់ជ្រាបថា គេបិទទ្វារ ទើបបញ្ឈប់ស្តេចបោរិសាទ និងព្រះរាជាជាង ១០០ អង្គ ក្នុងទីមួយ យាងទៅក្បែរទ្វារជាមួយអាមាត្យ ២-៣ នាក់ ត្រាស់ថា យើងឈ្មោះសុតសោមមហារាជ ពួកអ្នកចូរបើកទ្វារ ពួករាជបុរសទៅក្រាបទូលព្រះរាជា ព្រះរាជាត្រាស់ថា ព្រះបាទសុតសោមមហារាជជាបណ្ឌិត ជាស្តេចទ្រទ្រង់ធម៌ តាំងនៅក្នុងសីល ភ័យមិនមានដល់ពួកយើងយ៉ាងពិតប្រាកដ ហើយត្រាស់ឲ្យបើកទ្វារព្រះនគរថា ពួកអ្នកចូរបើកទ្វារព្រះនគរ ។ មហាសត្វយាងចូលព្រះនគរ ព្រះរាជានិងកាឡហត្ថីសេនាបតីទៅទទួលព្រះមហាសត្វ នាំឡើងកាន់ប្រាសាទ ព្រះមហាសត្វប្រថាប់ក្នុងព្រះរាជអាសនៈ ហើយត្រាស់ឲ្យហៅអគ្គមហេសីនិងពួកអាមាត្យរបស់ស្តេចបោរិសាទមកហើយត្រាស់នឹងព្រះរាជាថា នែកាឡហត្ថី ហេតុអ្វីទើបមិនឲ្យព្រះរាជាចូលព្រះនគរ កាឡហត្ថីក្រាបទូលថា កាលព្រះរាជាគ្រងរាជ្យ បានសោយសាច់មនុស្សក្នុងនគរនេះអស់ច្រើននាក់ ទ្រង់ធ្វើកម្មដែលក្សត្រមិនគួរធ្វើឡើយ បានធ្វើនូវឱកាសឲ្យទទេក្នុងជម្ពូទ្វីបទាំងមូល ទ្រង់មានធម៌លាមកបែបនេះ ព្រោះហេតុនោះ ទើបមិនឲ្យទ្រង់ចូលព្រះនគរ ។ ព្រះមហាសត្វត្រាស់ថា ឥឡូវនេះអ្នកទាំងអស់គ្នាកុំរិតក្កឡើយថា ទ្រង់នឹងធ្វើបែបនោះទៀត យើងទូន្មានទ្រង់ឲ្យតាំងនៅក្នុងសីលហើយ ទ្រង់នឹងមិនបៀតបៀនបុគ្គលណាម្នាក់ ព្រោះហេតុ

នៃជីវិតឡើយ ភ័យអំពីទ្រង់មិនមានដល់អ្នកទាំងឡាយឡើយ អ្នកទាំងឡាយកុំធ្វើយ៉ាងនេះ ឈ្មោះថាបុត្តនិងធីតាត្រូវបដិបត្តិមាតាបិតា អ្នកដែលចិញ្ចឹមមាតាបិតានោះឯង នឹងទៅកាន់ស្ថានសួគ៌ អ្នកដែលមិនចិញ្ចឹមមាតាបិតា នឹងទៅកាន់នរក ។

ព្រះមហាសត្វ ប្រទានឱវាទដល់ព្រះរាជឱរស ដែលប្រថាប់គង់នៅក្នុងអាសនៈទាបយ៉ាងនេះហើយ ត្រាស់ទូន្មានសេនាបតីថា នៃកាឡហត្ថី អ្នកជាសម្លាញ់និងជាសេវកៈរបស់ព្រះរាជា សូម្បីព្រះរាជាក៏ទ្រង់ស្ថាបនាទុកក្នុងតំណែងដ៏ប្រសើរ អ្នកគួរប្រព្រឹត្តប្រយោជន៍ដល់ព្រះរាជា ហើយប្រទានឱវាទដល់ព្រះទេវីថា នែព្រះទេវី ព្រះនាងក៏មកអំពីត្រកូលអ្នកស្រុក បានទទួលតំណែងអគ្គមហេសីក្នុងសម្នាក់របស់ព្រះរាជា ដល់នូវសេចក្ដីចម្រើនក្នុងបុត្តនិងធីតា ព្រះនាងក៏គួរប្រព្រឹត្តវត្ថុជាប្រយោជន៍ដល់ព្រះរាជា កាលទ្រង់សម្ដែងធម៌ឲ្យសេចក្ដីនោះដល់ទីបំផុត ទើបត្រាស់ព្រះគាថានេះថា

ព្រះរាជាណាផ្ចាញ់នូវបុគ្គលមិនគួរផ្ចាញ់ ( មាតាបិតា ) ព្រះរាជានោះ មិនមែនជាព្រះរាជាទេ សម្លាញ់ណា ផ្ចាញ់នូវសម្លាញ់ សម្លាញ់នោះ មិនមែនជាសម្លាញ់ទេ ភរិយាណាមិនខ្លាចប្ដី ភរិយានោះ មិនមែនជាភរិយាទេ ពួកបុត្តណា មិនចិញ្ចឹមមាតាបិតាជាបុគ្គលចាស់ទុំ ពួកបុត្តនោះ មិនមែនជាកូនទេ ។ ពួកសប្បុរសមិនមានក្នុងទីប្រជុំណា ទីនោះមិនមែនទីប្រជុំទេ ពួកជនណា មិនពោលនូវធម៌ ពួកជននោះ មិន

មែនជាសប្បុរសទេ លុះតែពួកជនលះបង់នូវរាគៈ ទោសៈ និងមោហៈ ហើយពោលនូវធម៌ ទើបឈ្មោះថាសប្បុរស ។

បណ្ឌិតកាលបើមិនពោល ( នូវធម៌ ) ជាអ្នកច្រឡូកច្រឡំដោយពួកជនពាល ពួកអ្នកផងរមែងស្គាល់មិនបាន លុះតែពោលសម្តែងនូវអមតបទទើបពួកអ្នកផងស្គាល់បាន ។ បណ្ឌិតគប្បីពោលបំភ្លឺនូវធម៌ ផ្គងឡើងនូវធម៌ជាទង់ជ័យនៃពួកឥសី ពួកឥសីមានសុភាសិតជាទង់ជ័យ ព្រោះជាធម៌ទុកដូចជាទង់ជ័យនៃពួកឥសី ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អជេយ្យំ** អធិប្បាយថា មាតាបិតា ឈ្មោះថាបុត្តមិនគួរយកឈ្នះ ព្រះរាជាដែលយកឈ្នះមាតាបិតាទាំង ២ នោះ រមែងមិនឈ្មោះថា ជាព្រះរាជា បើទ្រង់បានរាជសម្បត្តិដែលទទួលបន្តអំពីបិតារបស់ព្រះអង្គមក ហើយជាសត្រូវរបស់បិតា ឈ្មោះថា ធ្វើកិច្ចដែលមិនគួរធ្វើ ។ បទថា **សខារំ ជាធាតិ** អធិប្បាយថា យកឈ្នះដោយក្ដីកោង នៃកាឡហត្ថិ បើអ្នកមិនបានបំពេញមិត្តធម៌ជាមួយព្រះរាជា ក៏បានឈ្មោះថា មិនជាបុគ្គលដែលតាំងនៅក្នុងធម៌នឹងកើតក្នុងនរក ។ បទថា **ន វិភេតិ** បានដល់ មិនខ្លាចក្រែង បើព្រះនាងមិនខ្លាចក្រែងព្រះរាជា ព្រះនាងមិនបានឈ្មោះថា ជាភរិយាដែលតាំងនៅក្នុងធម៌ ។ បទថា **ជិណ្ណំ** បានដល់ ចាស់ ពិតហើយ បុត្តដែលមិនចិញ្ចឹមមាតាបិតាក្នុងពេលបែបនោះរមែងមិនឈ្មោះថាជាបុត្ត ។ បទថា **សន្តោ** បានដល់ ពួកបណ្ឌិត ។ បទថា **ធម្មំ** អធិប្បាយថា បុគ្គលណា កាលត្រូវ

គេសួរហើយ មិនប្រាប់តាមសេចក្តីពិត បុគ្គលនោះ មិនឈ្មោះថាជាបណ្ឌិត ។ បទថា **ធម្មំ ភណាន្ត** អធិប្បាយថា បុគ្គលទាំងនេះ លះនូវភគៈបានហើយ ជាអ្នកអនុគ្រោះប្រយោជន៍ដល់បុគ្គលដទៃ ពោលតែសេចក្តីពិត រមែងឈ្មោះថាជាបណ្ឌិត ។ បទថា **ឆាភាសមានំ** បានដល់ មិននិយាយអ្វីចេញមក ក៏មិនដឹងថាជាបណ្ឌិត ។ បទថា **អមតំ បទំ** បានដល់ បុគ្គលរមែងដឹងនូវបុគ្គលដែលសម្តែងអមតមហានិព្វានថាជាបណ្ឌិត ព្រោះហេតុនោះឯង ស្តេចបោរិសាទបានស្តាប់ធម្មទេសនាហើយ ទើបមានចិត្តជ្រះថ្លាឲ្យនូវពរ ៤ ប្រការ ប្រតិស្ឋានក្នុងសីល ៥ ប្រការហើយ ។ បទថា **ភាសយេ** អធិប្បាយថា ព្រោះហេតុនោះ បុរសជាបណ្ឌិតគប្បីពោលធម៌ គឺគប្បីបំភ្លឺនូវធម៌ឲ្យភ្លឺស្វាង ពិតហើយ ឥសីទាំងឡាយ មានព្រះពុទ្ធជាដើម ព្រោះហេតុដែលធម៌ជាទង់ជ័យរបស់ឥសីទាំងនេះ ព្រោះហេតុនោះ ឥសីដែលមានសុភាសិតជាទង់ រមែងសរសើរសុភាសិត ឯបុគ្គលពាល ឈ្មោះថាលើកតម្កើងសុភាសិតមិនមានឡើយ ។

ព្រះរាជានិងសេនាបតីបានស្តាប់ធម្មកថារបស់ព្រះពោធិសត្វហើយ កើតនូវបីតិសោមនស្សប្រឹក្សាគ្នាថា ពួកយើងនឹងទៅយាងព្រះរាជា ទើបឲ្យមនុស្សវាយស្គរត្រាច់ទៅក្នុងព្រះនគរ ឲ្យអ្នកនគរប្រជុំគ្នាហើយ ប្រកាសឲ្យជ្រាបថា អ្នកទាំងឡាយកុំខ្លាចឡើយ បានឮថា ព្រះរាជាតាំងមាំនៅក្នុងធម៌ហើយ ចូរនាំគ្នាមកចុះ ពួកយើងនឹងទៅនាំព្រះរាជាមក ទើបនាំមហាជនទៅ ធ្វើព្រះមហាសត្វឲ្យជាប្រមុខ ទៅកាន់សម្នាក់របស់ព្រះរាជាថ្វាយបង្គំហើយ ឲ្យភ្នាក់ងារ

គោរកាត់សម្អាតព្រះកេសានិងព្រះមស្សុ ហើយស្រង់ព្រះកាយដោយគ្រឿងក្រអូប តែងព្រះកាយដោយកូសាភរណៈ តាមខត្តិយរាជបវេណី ហើយយាងឡើងលើគំនររតនៈ អភិសេកហើយយាងចូលព្រះនគរ ស្តេចបោរិសាទទ្រង់បានធ្វើសក្ការៈដល់ស្តេច ១០១ អង្គនិងព្រះមហាសត្វដោយសក្ការៈធំ កើតមហាកោលាហលពេញជម្ពូទ្វីបថា បានឮថា ស្តេចសុតសោម ទ្រង់ទូន្មានស្តេចបោរិសាទ បានឲ្យប្រតិស្ឋានក្នុងរាជសម្បត្តិហើយ ។ ពួកអ្នកនគរឥន្ទបត្ត ក៏បានបញ្ជូនទូតមកយាងព្រះមហាសត្វឲ្យត្រឡប់មកព្រះនគរ ព្រះមហាសត្វប្រថាប់នៅក្នុងនគរពារាណសីនោះ ប្រមាណកន្លះខែ ត្រាស់ទូន្មានស្តេចបោរិសាទថា នែសម្លាញ់ ខ្ញុំនឹងលាត្រឡប់ សូមទ្រង់កុំប្រមាទ ហើយឲ្យសាងរោងទាន ៥ កន្លែង គឺត្រង់ទ្វារនគរ ៤ កន្លែង ត្រង់ព្រះរាជវាំងមួយកន្លែង ទ្រង់បំពេញទាន ប្រព្រឹត្តរាជធម៌ ១០ ប្រការ កុំឲ្យកម្រើក សូមទ្រង់លះអគតិ ។ ពលនិកាយអំពីរាជធានី ១០១ បានមកប្រជុំគ្នាយ៉ាងកុះករ ព្រះមហាសត្វមានពលនិកាយទាំងនោះចោមរោម ហើយយាងចេញអំពីនគរពារាណសី សូម្បីស្តេចបោរិសាទ ក៏បានយាងចេញពីព្រះនគរ ជូនដំណើរដល់ពាក់កណ្តាលផ្លូវទើបទ្រង់ត្រឡប់ ។ ព្រះមហាសត្វប្រទានពាហនៈដល់ព្រះរាជាដែលមិនមានវាហនៈ ទ្រង់បញ្ជូនព្រះរាជាគ្រប់អង្គទាំងនោះទៅ ។ សូម្បីព្រះរាជាទាំងនោះក៏សម្តែងនូវការត្រេកអរជាមួយព្រះមហាសត្វ បានធ្វើកិច្ច មានការថ្វាយបង្គំនិងការបរបាជាដើមតាមសមគួរ ហើយបានយាងត្រឡប់ទៅកាន់ជនបទរៀងៗខ្លួន សូម្បីព្រះមហាសត្វក៏យាងចូលកាន់ព្រះនគរ ដែលពួកមហាជនអ្នកនគរ

ឥន្ទបត្តតាក់តែងទុកល្អហើយ ដូចទេវនគរ ថ្វាយបង្គំព្រះរាជមាតាបិតា ធ្វើបដិសណ្ឋារៈ ហើយយាងឡើងកាន់មហាប្រាសាទ ។

ឯស្តេចបោរិសាទ ទ្រង់គ្រងរាជ្យដោយធម៌ ទ្រង់ត្រិះរិះថា រុក្ខទេវតា មានឧបការៈដល់អញច្រើន អញនឹងធ្វើលាភ គឺពលិកម្មដល់ទេវតា ឲ្យសាងស្រះធំក្បែរដើមជ្រៃ ទ្រង់បញ្ជូនត្រកូលទៅជាច្រើន បង្កើតជាស្រុកឡើង ស្រុកនោះជាស្រុកធំ លម្អដោយផ្លូវនិងផ្សាររហូតដល់ ៨ ម៉ឺន ។ ព្រះបាទបោរិសាទឲ្យពង្រាបផ្ទៃដីត្រង់គល់ជ្រៃនោះឲ្យរាបស្មើ តាំងអំពី ( ស្រមោល ) ចុងមែកចូលមក ឲ្យសាងកំពែង មានទ្វេនបូជានិងរបងព័ទ្ធជុំវិញ ទេវតាត្រេកអរក្រៃលែង ។ ស្រុកនោះបានឈ្មោះថា កម្មាសបាទនិគម ព្រោះជាទីទូន្មានព្រះរាជាដើងពពាលផង ជាលំនៅនៃទ្រង់ផង ។ ព្រះរាជាទាំងអស់តាំងនៅក្នុងឱវាទរបស់ព្រះមហាសត្វ ទ្រង់បានធ្វើបុណ្យ មានទានជាដើម បំពេញផ្លូវទៅកាន់ស្ថានសួគ៌ឲ្យបរិបូណ៌ហើយ ។

ព្រះសាស្តា កាលទ្រង់យកនាំព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសអរិយសច្ចៈ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតទូន្មានអង្គុលិមាលក្នុងកាលឥឡូវនេះក៏មិនមែន សូម្បីក្នុងកាលមុន តថាគតក៏បានទូន្មានហើយដូចគ្នា ហើយទ្រង់ប្រជុំជាតកថា ស្តេចបោរិសាទក្នុងកាលនោះបានមកជាអង្គុលិមាលក្នុងកាលឥឡូវនេះ កាឡហត្ថីសេនាបតីក្នុងកាលនោះបានមកជាសារីបុត្ត នន្ទព្រាហ្មណ៍ក្នុងកាលនោះ បានមកជាអានន្ទ រុក្ខទេវតាក្នុងកាលនោះ បានមកជាកស្សបៈ សក្កៈក្នុងកាលនោះ បានមកជាអនុរុទ្ធ ព្រះ

រាជា ១០១ អង្គ ក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ព្រះរាជមាតាបិតាក្នុងកាលនោះ បានមកជាត្រកូលមហារាជ ឯព្រះបាទសុតសោម ក្នុងកាលនោះ គឺតថាគតអរហន្តសម្មាសម្ពុទ្ធនេះឯង ។

**អដ្ឋកថា មហាសុតសោមជាតក ចប់**

**អសីនិបាត ចប់**

# ក្បាលទី ៥០

# សុត្តន្តបិដក ចាលីប្រែ -៦០

## សន្ទឹកចង្អុលប្រាប់មាតិកា


| មាតិកា | ទំព័រ |
|---|---|
| តេសកុណជាតក | ២ |
| អដ្ឋកថា តេសកុណជាតក | ៩ |
| សរភង្គជាតក | ៥០ |
| អដ្ឋកថា សរភង្គជាតក | ៥៩ |
| អលម្ពុសាជាតក | ១១៣ |
| អដ្ឋកថា អលម្ពុសាជាតក | ១២០ |
| សង្ខបាលជាតក | ១៤២ |
| អដ្ឋកថា សង្ខបាលជាតក | ១៥១ |
| ចុល្លសុតសោមជាតក | ១៨១ |
| អដ្ឋកថា ចុល្លសុតសោមជាតក | ១៩០ |


# ចាលីប្រែ -៦១

# បញ្ញាសនិបាត


| | |
|---|---|
| នឡិនិកាជាតក | ២១៦ |
| អដ្ឋថា នឡិនិកាជាតក | ២២៦ |
| ឧម្មាទន្តីជាតក | ២៥៨ |
| អដ្ឋកថា ឧម្មាទន្តីជាតក | ២៧០ |
| មហាពោធិជាតក | ៣១១ |
| អដ្ឋកថា មហាពោធិជាតក | ៣២០ |

សោណកជាតក ......... ......... ......... ......... ......... ...... ៣៦១

## សដ្ឋិនិបាតជាតក

អដ្ឋកថា សោណកជាតក ......... ......... ......... ......... ......... ...... ៣៧០
សង្កិច្ចជាតក ......... ......... ......... ......... ......... ...... ៤០៥
អដ្ឋកថា សង្កិច្ចជាតក ......... ......... ......... ......... ......... ...... ៤១៣

## សត្តតិនិបាតជាតក

កុសជាតក ......... ......... ......... ......... ......... ...... ៤៥២
អដ្ឋកថា កុសជាតក ......... ......... ......... ......... ......... ...... ៤៦៦
សោណនន្ទជាតក ......... ......... ......... ......... ......... ...... ៥៤២
អដ្ឋកថា សោណនន្ទជាតក ......... ......... ......... ......... ......... ...... ៥៥៤

## អសីតិនិបាតជាតក

ចុល្លហំសជាតក ......... ......... ......... ......... ......... ...... ៥៩៩
អដ្ឋកថា ចុល្លហំសជាតក ......... ......... ......... ......... ......... ...... ៦១២
មហាហំសជាតក ......... ......... ......... ......... ......... ...... ៦៥៩
អដ្ឋកថា មហាហំសជាតក ......... ......... ......... ......... ......... ...... ៦៧៤
សុធាភោជនជាតក ......... ......... ......... ......... ......... ...... ៧៤០
អដ្ឋកថា សុធាភោជនជាតក ......... ......... ......... ......... ......... ...... ៧៥៧
កុណាលជាតក ......... ......... ......... ......... ......... ...... ៨២២
អដ្ឋកថា កុណាលជាតក ......... ......... ......... ......... ......... ...... ៨៤៦
មហាសុតសោមជាតក ......... ......... ......... ......... ......... ...... ៩៥៣
អដ្ឋកថា មហាសុតសោមជាតក ......... ......... ......... ......... ......... ...... ៩៧៥